ព្រះវិនយទណ្ឌនា

ជាធម្មបណ្ណាការ ឧទ្ទិសបំពោះ ព្រះពុទ្ធសាសនា

ភ្នំពេញ
ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ជាំ
សម្រាប់ចែកជាធម្មទាន

ព.ស. ២៥៦០ គ.ស. ២០១៦

ព្រះវិនយទណ្ឌនា

ព.ស. ២៥៦០

ព្រះវិនយវណ្ណនា

ជាធម្មបណ្ណាការ ឧទ្ទិសបំពោះ ព្រះពុទ្ធសាសនា

ភ្ជាំពេញ

ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ

សម្រាប់ចែកជាធម្មទាន

ព.ស. ២៥៦០ **គ.ស. ២០១៦**

ពាក្យជ្រោរពួ

វិនយវណ្ណនានេះ និពន្ធដោយចៅឃុន ព្រះអមរាភិរក្ខិត កើត ដែលសម្តេចព្រះសុគន្ធាសង្ឆរាជាធិបតី បញ្ញាសីលោ ច៉ាន បាននាំមកប្រែផ្សាយជាច្បាប់សម្រាប់ធម្មយុត្តិកវង្ស នៅប្រទេសកម្ពុជា ជាគោលការបដិបត្តិខាងព្រះពុទ្ធសាសនានោះ បានកើតជារូបរាងសៀវភៅពុម្ពឡើងគ្រាដំបូង គឺដោយសម្តេចក្រុមព្រះ ឌ្ឍេត្តម ភាណុវង្ស ទ្រង់បានចាត់ការបោះពុម្ពផ្សាយជាធម្មសម្បត្តិ សម្រាប់ព្រះពុទ្ធសាសនា (ធម្មយុត្តិកវង្ស) ហើយរក្សាសិទ្ធិតមក ។

ដល់មក ព.ស. ២៥០១ គ.ស. ១៩៥៨ លោក យ៉ិន-ស៉ាម៉ន បានចាត់ការបោះពុម្ពលើកទីពីរ តាមច្បាប់ដើម ។

នៅពេលដែលយើងខ្ញុំ បានចូលឧបសម្បទាជាភិក្ខុភាវ:ក្នុងព្រះពុទ្ធ-សាសនា ក្នុងឆ្នាំរកា នពស័ក ព.ស. ២៥០០ គ.ស. ១៩៥៧ ពេលនោះ សម្តេចព្រះសុធម្មាធិបតី ឥន្ទញ្ញាណោ ភុល-ធេស ឧបជ្ឈាយ៍យើងខ្ញុំ និងព្រះសទ្ធម្មប្រីជា ភេត-ធន អាចារ្យវត្តបទុម-វតីរាជវរាភមបានសុំឲ្យជួយឧបត្ថម្ភ ចាត់ការបោះពុម្ពសៀវភៅនេះទៀត យើងខ្ញុំក៏បានទទួលដោយសេចក្តីគោរព ។

តែមុននឹងបោះពុម្ព សម្តេចបានចាត់គណ:កម្មការសង្ឆមួយក្រុម ដូចមានរាយនាមខាងក្រោមនេះ ឲ្យរៀបចំពិនិត្យកែអក្ខរាវិរុទ្ធ ឃ្លាស្ទះ និងសម្រួលពាក្យពេចន៍ខ្លះ ឲ្យបានស្រួលទៅតាមសម័យនិយម ។

គណៈកម្មការសង្ឃពិនិត្យកែ

១- ព្រះមង្គលទេពាចារ្យ	កែវ អ៊ូច
២- ព្រះធម្មឧត្តម	ហ៊ី ជា
៣- ព្រះមហាវីរវង្សាចារ្យ	វ័ណ្ណ សាឌុំ
៤- ព្រះអរិយវង្ស	មាស សុវណ្ណ
៥- ព្រះញាណវង្សី	ប្រាក់ តោ
៦- ព្រះបទុមវង្សា	សុខ យឹន
៧- ព្រះធម្មវោត្តម	តុង ឈួន
៨- ព្រះទេពមោលី	នូ យ៉ន
៩- ព្រះធម្មត្រៃលោកាចារ្យ	ច័ន្ទ សាលី
១០- ព្រះគ្រូមហាឧត្តុល	ភោគ ផន
១១- ព្រះគ្រូសមាធិញាណ	មាស តន់
១២- ព្រះគ្រូវិសុទ្ធិវង្ស	ម៉ៅ ខាន់
១៣- ព្រះគ្រូញាណមុនី	ឡេង រៀម
១៤- ព្រះអាចារ្យ	រស់ សាវ៉ន

លុះគណៈកម្មការសង្ឃបានចាត់ការស្រេច និងបានទទួលសេចក្តីអនុញ្ញាតអំពីក្រុមគ្រួសារ សម្តេចក្រុមព្រះ ឧភោត្តម ភាណុវង្ស មានអ្នកម្នាង លួន ជាដើមហើយ ។

លុះដល់ឆ្នាំខាលចត្វាស័ក ព.ស. ២៥០៥ គ.ស. ១៩៦២ សម្តេចក៏បានប្រគល់សៀវភៅ វិនយវណ្ណនានេះ មកឲ្យយើងខ្ញុំ យើងខ្ញុំបានចាត់ការបោះពុម្ពចំនួន ១.០០០ ក្បាល ទុកជាគោលចារឹកពុទ្ធសាសនាតទៅ ។

សៀវភៅនេះ សម្រេចឡើងដោយអាស្រ័យកម្លាំងព្យាយាមរបស់ភិក្ខុ-សាមណេរជាច្រើនអង្គ ជួយសរសេរសំណៅពុម្ពផង ។

យើងខ្ញុំសូមឧទ្ទិសព្រះពជកុសលរាសីនេះថ្វាយចំពោះព្រះវិញ្ញាណ-ក្ខន្ធ សម្តេចព្រះសុគន្ធាសង្ឆរាជាធិបតី បញ្ញាសីលោ ច៉ាន, *សម្តេចព្រះវររាជនត្តី ព្រះនាម* ហ៊ីង ហៅយុន ច៉ាត់ *ជាជីដូន, ព្រះករុណាព្រះបាទសម្តេចព្រះ* ស៊ីសុវត្ថិ-មុនីវង្ស *ព្រះវររាជបិតា, សម្តេចព្រះអគ្គមហេសី* ការ៉ាញ្ញនវិមាន (*ហៅ* ការ៉ាន់វ៉ីម៉ាន) *ព្រះវររាជមាតា, និងព្រះករុណាគ្រប់ព្រះអង្គដែលទ្រង់សោយព្រះទិវង្គតទៅហើយ សូមព្រះអង្គទ្រង់បានប្រកបដោយព្រះបរមសុខសម្បត្តិគ្រប់ប្រការស្តាពរ សមតាមព្រះពជហឫទ័យប្រាថ្នា កុំបីខានឡើយ ។*

សម្តេចក្រុមព្រះ ស៊ីសុវត្ថិ-មុនីរ៉ែត
ប្រធានឧត្តមក្រុមប្រឹក្សា ព្រះពជបល្ល័ង្ក

m.sch_prv
សម្តេចព្រះសុគន្ធាសឡារាជាធិបតី
ឫទ្ធាសីសោ ព្រះនាម ជ្ជ សម្តេចព្រះសង្ឆរាជទី ១
នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
ព្រះជន្មាយុ ៦៧ ព្រះវស្សា

ធម្មសម្បត្តិ

រតនកថា និង សិក្ខាវណ្ណនា នៃចៅឃុនព្រះអមរាភិរក្ខិត (ភើត) ជាសិស្សនៃសម្តេចព្រះចមក្ខាវ ដែលសម្តេចព្រះសុគន្ធាសង្ឆរាជាធិបតី ទ្រង់បានប្រៃរៀបរៀង នាំមកផ្សាយប្រតិស្ឋានធម្មយុត្តិកវង្ស ក្នុងកម្ពុជរដ្ឋ ដូចមានសេចក្តីអធិប្បាយខាងក្រោយនេះ ។

ពាក្យបរិយាយផ្លូវប្រតិបត្តិ

ឯផ្លូវប្រតិបត្តិខាងសាសនា នៃសម្តេចព្រះបរមសម្មាសម្ពុទ្ធ ជាមកុដត្រៃលោក ទ្រង់ព្រះនាមព្រះសមណគោតមបរមសាស្តាចារ្យនោះ អ្នកប្រាជ្ញលោកសន្ទិដ្ឋានមានចិត្តខ្ជាប់ខ្ជួន ក្នុងគុណព្រះរតនត្រ័យក្រៃពេក គឺនឹកគិតខ្ជាប់ ត្រាតែយកមករៀបរៀងជាចិត្តភាវនា ជាបែបទុកសម្រាប់រលឹកនឹកទន្ទេញភាវនា ហៅថា ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឆានុស្សតិ ពណ៌នាសរសើរគុណព្រះរតនត្រ័យដោយអនេកន័យ តាមសេចក្តីនិយមនៃកាល:ទេស:នោះៗ ។ ហេតុដូច្នេះ ទើបមានតម្រាវចនារឿងនេះជាច្រើនច្បាប់ទាំងក្នុងជនជាតិមគធ: ទាំងជនជាតិដែលជាអ្នកកាន់ព្រះពុទ្ធ-សាសនាឯទៀតៗ ទាំងខេមរប្រទេសយើងនេះ ក៏កាន់តែមានអ្នកចេះដឹងចម្រើនឡើងៗ ដូចគ្នា ។

សេចក្ដីដែលយកចិត្តទុកដាក់ ក្នុងគុណព្រះរតនត្រ័យ តាមន័យលោកអ្នកប្រាជ្ញនោះ ប្រាកដជាត្រឹមត្រូវពេកណាស់ ជាហេតុនាំឲ្យបានរាប់អានខ្ជាប់មាំក្នុងព្រះពុទ្ធសាសនា ព្រះពុទ្ធសាសនាក៏នឹងបានស្ថិតស្ថេរស្ថាពរឃុំគ្រងជនានុជន ដែលរាប់អានកាន់សាសនាខ្ជាប់មាំប្រាកដនោះ ឲ្យរុងរឿងតទៅ ប្រៀបដូចជាបុរសស្រស់ល្អបរិសុទ្ធ ហើយមានពូជពង្សវង្សត្រកូលវិសូលវិសេស តែប្រហែលគំនិត គិតតែត្មះតិះដៀលធ្ដៀលនិន្ទាមើលងាយត្រកូលរបស់ខ្លួន ឈ្មោះថាមិនរក្សាធម៌ត្រកូល មិនគោរពចំពោះត្រកូល វង្សត្រកូលនោះក៏រមែងសាបសូន្យឬប្រែប្រួលខុសចាកការៈដើមនោះទៅ, ថាបើញាតិវង្ស រាប់អានត្រកូលនិងធម៌របស់ត្រកូលប្រាកដហើយ ក៏ឈ្មោះថារក្សាធម៌ត្រកូល គោរពវង្សត្រកូល ត្រកូលនោះក៏រមែងតាំងខ្ជាប់ឋិតវេរហាវៈយឺនយូរតទៅ ។ ហេតុនេះទើបលោកសម្ដែងថា ត្រកូលខ្សត់គុណសម្បត្ដិ គ្មានវង្សរបស់ខ្លួនរាប់អាន នឹងសាបសូន្យធាប់, ត្រកូលប្រកបដោយគុណសម្បត្ដិ មានធម៌សុចរិតល្អ ជាទីនាំឲ្យពូជពង្សរបស់ខ្លួននិយមតាម នឹងតាំងនៅបានយូរអង្វែង ត្រកូលនោះដូចម្ដេច ព្រះពុទ្ធសាសនាក៏ដូច្នោះដែរ ។ បើបរិស័ទពុំរាប់អានក្នុងសម្ដេចព្រះបរមសាស្ដាជាគ្រូដើម ក្នុងព្រះធម៌ជាបណ្ដូល និងក្នុងព្រះសង្ឆជាអ្នកនាំព្រះសាសនាតមកទេ ឈ្មោះថាគ្មានអ្នកប្រតិបត្ដិព្រះសាសនា ព្រះសាសនាក៏មិនរុងរឿង នឹងល្ហៀងទៅ

ខាងផ្លូវសាបសូន្យធាប់ ។ បើបរិស័ទរាប់អានព្រះបរមសាស្តាជាគ្រូដើម ព្រះធម៌ជាបណ្ណូល និងព្រះសង្ឆជាអ្នកនាំព្រះសាសនាឲ្យប្រព្រឹត្តតមក ហើយប្រតិបត្តិខ្ជាប់ខ្ជួនមាំមួនប្រាកដ ព្រះពុទ្ធសាសនា ក៏ជ្ជុំជ្ជើងរុងរឿង ហាវ:ឃុំគ្រងរក្សាបរិស័ទដែលប្រតិបត្តិមាំនោះ ឲ្យបានសេចក្ដីចម្រើនសុខ ស្ថាពរតទៅ បានជាលោកសន្ទតកិក្ខុដែលទ្រង់ចរិតកាន់ក្រឹត្យប្រព្រឹត្ត មាំនោះ ឲ្យឈ្មោះថាជាអ្នកគោរពព្រះរតនត្រ័យ ជាអ្នកនឹកដល់ព្រះ និព្វាន ។

ហេតុនោះ សាធុជនទាំងពួង ដែលទ្រង់នូវជ្ជិរប្ញញ្ញា ជ្រះថ្លាក្នុង ធម៌ក្នុងវិនិ័យ ត្រឹមត្រូវ តាមពុទ្ធានុញ្ញាត ក្នុងគណ:ធម្មយុត្តិក:នេះ គប្ជី នឹកដល់គុណសម្ប្ជត្តិលោកអ្នកប្រាជ្ញតួដើម ដែលផ្ដើមរកឃើញផ្លូវត្រឹម ត្រូវហើយ លោកបានប្រកាសព្រហ្មចរិយ:ឲ្យប្រព្រឹត្តរៀងមក និងលោក អ្នកប្រាជ្ញដែលបានរៀបរៀងរតនកថា និងរឿងបុព្ជសិក្ខាវណ្ណនា មក ប្រតិស្ថានទុកក្នុងកម្ពុជរដ្ឋ ផ្សាយសាសនាធម្មយុត្តិក: ឲ្យភ្ជ្ជ ច្ចាស់ត្រឹម ត្រូវនេះជាដើមវង្សត្រកូល ។

សាធុសប្ជុរស ជាបរិស័ទក្នុងធម្មយុត្តិកនិកាយ គប្ជីជ្រះថ្លាក្នុង ធម្មយុត្តិកវង្ស ជាវង្សត្រកូលរបស់ខ្ជួនឲ្យមាំមួនជាអចិន្ត្រៃយ៍ បើសង្ស័យ មិនភ្ជ្ជ ច្ចាស់ត្រូវសាកច្ជ្ជ ច្ចាត្រាតែឃើញជាក់ច្ជ្ជ ច្ចាស់ ដ្ជ ្ជ ្ជ

ធម្មយុត្តិក:ប្រព្រឹត្តទាំងប៉ុន្មាន សុទ្ធតែមានក្នុងព្រះគម្ពីរជាវិជ្ជីនៃព្រះអរិយ: ទាំងអស់ បើក្ងីចាស់ហើយគប្បីប្រតិបត្តិឲ្យខ្ជាប់ខ្ជួន ក្នុងសាសនវង្ស ធម្មយុត្តិក: សាសនវង្សធម្មយុត្តិក:ក៏នឹងបានចម្រើនហ្ការ:ដ្ឋាយ សាធុ សប្ប៉ុរសដែលប្រតិបត្តិមាំមួននោះ ក៏នឹងមានសេចក្ដីសុខចម្រើនតទៅ ។

ឯគុណសម្ផត្តិនៃលោកអ្នកប្រាជ្ញតួដើមនោះ គឺអង្គសម្ដេចព្រះចម-ក្ខ្លាវចៅហ្វាមកុដ សម្ដេចព្រះចមក្ខ្លាវចៅហ្វាមកុដនេះ ជាមហាខត្ដិយ-សុខុមាល័យថ្ងៃត្រកាល កាលមិនទាន់សោយរាជ្យ ក៏បានគ្រងព្រះរាជ-រ៉ាំងដើម ទ្រង់បរិបូណ៌ដោយស្ងួនស្ងើម្ការ បម្រើព្រះអង្គដោយកាមសុខ, លុះទ្រង់ព្រះផ្ទ្ធសក៏ទ្រង់បរិបូណ៌ដោយសង្ឆ្ងបរិស័ទជាបរមសុខ ដោយ តេជ:គុណានិសង្ឆ្ងជាប្រធាន ដូចមានសេចក្ដីក្នុងព្រះរាជប្រវត្ដិពិស្ដារថា:

អង្គសម្ដេចព្រះចមក្ខ្លាវនោះ ជាបរមក្សត្រមហាសម្ផ្ដិទេវ:ង្ឆ្ងទ្រង់ ន្ទូវគុណានុភាពអស្ចារ្ស ស្ដេចទ្រង់ប្រសូតនៅទីព្រះរាជរ៉ាំងដើមនាក្រុង ធនបុរី ក្នុងថ្ងៃព្រហស្ផ្ដ៍ ១៥កើត ខែអស្សុជ ឆ្នាំជូតឆស័ក ចុល្ងសក-រាជ ១១៦៦ ជាព្រះរាជសម្ភពមហាមង្គ្ល ព្រះអង្គជាឯកអគ្គបរមរាជឱ្ស-សាធិរាជទីពីរ នៃសម្ដេចព្រះពុទ្ធ្ធ្ឍ្ជ្ជ្ជ

ចៅហ្វា, លុះបានព្រះជន្ម ៥ ឆ្នាំ ព្រះបិតាព្រះរាជទានឲ្យមានកូនលៃឡុង-សុងថ្វាយព្រះនាមថា ចៅហ្វាមកុដរាជកុមារ ហើយទ្រង់សិក្សាវិជ្ជាការ សិល្ប:សាស្ត្រផ្សេងៗ រៀនអក្សរសៀម ក្នុងសំណាក់សម្តេចព្រះពុទ្ធ (ឃុន) វត្តមោលីលោកា្យរាម ។ លុះព្រះជន្មបាន ១៣ ឆ្នាំ ទ្រង់ធ្វើ ព្រះរាជពិធីសុកាន្ត លើកំ្ជកែលាសស្រង់ទឹកអនោតត្ត លុះព្រះជន្មបាន ១៤ ឆ្នាំ ទ្រង់ព្រះផ្នួសជាសាមណេរនៅវត្តសិរិរតនសាស្តារាម[1] រួចទៅ គង់នៅវត្តមហាធាតុបាន ៧ ខែ លាព្រះផ្នួសមក បានទទួលព្រះរាជទាន ជាអធិបតីបង្ហាប់បញ្ជាការមហាតលិកដាច់ខាត អាចដកហូតផ្ទាស់ប្តូរ ឬ តែងតាំងបាន ហើយទ្រង់ទៅគង់នៅព្រះរាជវាំងដើម ទ្រង់បរិបូណ៌ ដោយកស្តុស្រឹង្ការបរិវារ បម្រើដោយកាមសុខគ្រប់ទិវារាត្រី លុះមាន ព្រះទ័យរំពឹងឃើញអានិសង្ស ក្នុងអនាគារិយ: ប្រតិបត្តិ ប្រព្រឹត្តព្រហ្ម-ចរិយធម៌ ទើបទ្រង់បង្ហោនព្រះរាជអធ្យាស្ត្រ បែរទៅក្នុងបព្វជ្ជានិងឧប-សម្ប៉ៃទតាមដែលទ្រង់បានសិក្សាព្រះពុទ្ធវចន: បរិយត្តិធម៌ មកពីមុនពេល ទ្រង់ព្រះផ្នួសជាភិក្ខុនោះ ។

លុះថ្ងៃ ១២ ២ ១ ៨ ១ ២ ១ ២ ១ ២

និយមហើយ ស្តេចទៅគង់នៅវត្តសម៉ាយ លុះក្រោយមកបាននាមថ្មី ហៅវត្តរាជានិវាស លុះទ្រង់ព្រះផ្ទួសមិនយូរប៉ុន្មាន ទើបបានតែ ១៤ ថ្ងៃ ព្រះបាទសម្តេចព្រះពុទ្ធឡឺតឡាសុគតទៅ នៅថ្ងៃ ៤ ១១ ១ ៨ ឆ្នាំវកធស័ក ច.ស. ១១៨៦ នោះ បានរាជសម្បត្តិទៅព្រះណាំងក្វាវ សោយរាជ្យ តមក ។

ឯសម្តេចព្រះចមក្វាវទ្រង់គង់ចាំវស្សា នៅវត្តរាជានិយម លុះ ទ្រង់ជ្រាបដោយវជិរញ្ញាណថា លទ្ធិសមណនោះ ច្រើនតែរឹតវរទៅ ដោយសមណមោហវិហារ ដូចជាខ្ចីច្រមុះគេមកដកដង្ហើម នឹងនិយាយ អ្វី ក៏បានតែអាងគតិ ដូចជាអាចិណ្ណកប្បកថា ដែលលោកបុរាណធ្លាប់ ធ្វើមកយ៉ាងនេះជាដើម មិនចេះសម្តែងហេតុផល ចង្អុរឲ្យឃើញពិត សោះឡើយ ប្រកាន់លទ្ធិរឹងរូសប្រទូស្តព្រះពុទ្ធដីកា មិនដឹងខុសត្រូវ មិនជាទីតាំងនៃបញ្ញា ទ្រង់សង្វេគ នឿយណាយ ដោយហេតុនេះ ទើបទ្រង់ត្រឡប់ចុះមកគង់វត្តមហាធាតុ ដើម្បីរៀនព្រះត្រៃបិដកពុទ្ធ-វចនៈ លុះទ្រង់សិក្សាដល់សេចក្តីបដិបត្តិផ្សេងៗ ដែលមានមកក្នុង ព្រះគម្ពីរអំពីបូរាណ ក៏ទ្រង់អនុមានបានថា សាសនវង្ស វិនាស ដោយចលាចលមកអំពីក្រុងចាស់ ហើយថែមទាំងបានឃើញអរិយវិបត្តិ នៃសមណៈខ្ញុះនោះ មិននាំមកនូវសេចក្តីជ្រះថ្លា ទ្រង់ព្រះសង្វេគសុត ព្រះទ័យណាស់ នឹងការព្រះសាសនា គឺវង្សបព្វជ្ជាឧបសម្ព័ទ ឃើញពិត

ថាពួជ គឺឫសគល់នោះពុករលួយ មិនមានទ្លលជាទីតាំងនៃឧបសម្ព័ទ ក៏ស្ងុតព្រះទ័យក្នុងការដែលទ្រង់ភេទជាបព្វជិត ឃើញពិតពេញជាធ្វើ បញ្ជោតគេចិញ្ចឹមជីវិត ប្រព្រឹត្តខុសធម៌ខុសវិន័យក្រៃពេកណាស់ មិនគួរ នឹងប្រព្រឹត្តទុច្ចរិតតាមពួជនោះ តទៅទៀតឡើយ គួរតែសើរើស្វែងរក សេចក្ដីត្រឹមត្រង់តាមព្រះពុទ្ធដីកា រៀបរយ ឲ្យត្រឹមតាមទំនងព្រះអរិយ: ដែលលោកបានលើកព្រះពុទ្ធសាសនារៀងៗមកនោះឡើងវិញ ទើប ពេញជាបព្វជិតប្រព្រឹត្តតាមពុទ្ធានុញ្ញាត ឈ្មោះថាពាប់អានប្រតិបត្តិត្រឹម ត្រូវតាមព្រះពុទ្ធសាសនោវាទប្រាកដ ។

ដ្ឋិតព្រះសាសនានៃសម្ដេចព្រះសម្មាសម្ពុទ្ធជាមកុដលោកនេះ កាល សម្ដេចព្រះពុទ្ធអង្គទ្រង់នូវទសអរហាទិគុណមហាប្រសើរ ផ្ទុំលើមញ្ជា ពុទ្ធាសន:ជាអនុដ្ឋានសេយ្យាសន៍ចន្ទោះព្រឹក្សារ៉ាងទាំងគូ ក្នុងសាល-វនោទ្យានៃព្រះបាទសាមល្ងាជ ទៀបនគរកុសិនាពារជធានីនោះ មាន ព្រះពុទ្ធានុញ្ញាតដល់ភិក្ខុទាំងឡាយថា ព្រះធម៌វិន័យទាំង ៨.២០០០ ព្រះ ធម្មក្ខន្ធ ដែលតថាគតប្រដៅអ្នកទាំងឡាយ កាលបើតថាគតបរិនិព្វាន ហើយ ព្រះធម៌វិន័យប្រាំបីម៉ឺនបួនពាន់ធម្មក្ខន្ធនេះ នឹងជាគ្រូប្រដៅអ្នកនិង សត្វទាំងឡាយ តំណាងតថាគត ៨.២០០០ ព្រះអង្គ ព្រះអង្គត្រាស់ ប្រគល់ព្រះពុទ្ធសាសនានិងព្រះបរិយត្តិធម៌នេះទុកហើយ ក៏ទ្រង់បរិនិព្វាន ទៅ ។

ចាប់ដើមតាំងអំពីសម្តេចព្រះសព្វញ្ញូជាម្ចាស់បរិនិព្វាន ថ្ងៃយ-ព្រះ-ភ្ជើងហើយ កន្ទងទៅបាន ៣ ថ្ងៃ ព្រះមហាកស្សបត្ថេរ រលឹកដល់ពាក្ស-សុកទ្ធកិក្ខុបួសឯចាស់ ពោលតួះព្រះបរមគ្រូជាមូលហេតុ ក៏ប្រារព្ធការណ៍-សង្គាយនា រើសយកសុទ្ធតែព្រះអរហន្តទ្រង់បដិសម្ភិទាញាណ និងព្រះ-អានន្ទជាសេក្ខបុគ្គល ដែលបានសម្រេចព្រះអរហត្ត ក្នុងរាត្រីនោះមួយ-អង្គផង ជា ៥០០ ព្រះអង្គ លុះព្រឹកឡើងធ្វើសង្គាយនាទាំង ៥០០ ព្រះអង្គ មានព្រះបាទអជាតសត្រូវជាសាសនូបត្ថម្ភក៏ ។ សង្គាយនា-ព្រះត្រៃបិដកក្នុងមណ្ឌលទៀបសត្តបណ្ណគុហា នាវេការបព៌ត ទៀប-ក្រុងរាជគ្រឹះមហានគរ ៧ ខែ ទើបសម្រេចការបឋមសង្គាយនា ។

លុះព្រះពុទ្ធសាសនាកន្ទងទៅបាន ១០០ ឆ្នាំ ពួកភិក្ខុវជ្ជីគ្រាមជា-អលជ្ជី សម្តែងវត្ថុ ១០ ប្រការ ខុសអំពីព្រះវិនយបញ្ញត្តិ ទើបព្រះខីណា-ស្រព ៨ ព្រះអង្គ មានព្រះយសត្ថេរជាដើម មានព្រះរេវតត្ថេរជាបរិយោ-សាន ជម្រះទសវត្ថុអធិករណ៍ឲ្យរម្ងាប់ ញ្ចាំងព្រះពុទ្ធសាសនាឲ្យបរិសុទ្ធ-ហើយរើសព្រះអរហន្តដ៏ទ្រង់បដិសម្ភិទាញាណ បាន ៧០០ ព្រះអង្គ មាន-ព្រះសព្វកាមិមហាថេរជាប្រធាន ធ្វើសង្គាយនាព្រះត្រៃបិដក ក្នុងវាលុកា-រាម ទៀបនគរវេសាលី មានព្រះបាទកាលាសោករាជជាសាសនូបត្ថម្ភក៏ ៨ ខែ ទើបសម្រេចការទុតិយសង្គាយនា ។

លុះព្រះពុទ្ធសាសនាកន្ទ្ធ១ទៅបាន ២១៨ ឆ្នាំ ពួកតិរ្ថិយចូលបួសឫមក្នុងព្រះពុទ្ធសាសនា ទើបព្រះមោគ្គលីបុត្តតិស្សត្ថេរ ញ្ចុំងព្រះបាទធម្មាសោកពាជ ឲ្យរៀនចេះក្នុងពុទ្ធសម័យ ហើយជម្រះផ្សឹកតិរ្ថិយ ៦ ម៉ឺននាក់ ញ្ចុំងព្រះពុទ្ធសាសនាឲ្យបរិសុទ្ធ ទើបព្រះមោគ្គលីបុត្តតិស្សត្ថេរ ទ្រង់ជ្រើសរើសព្រះអរហន្តទ្រង់បដិសម្ភិទា បាន ១ ពាន់ព្រះអង្គ សង្គាយនាព្រះត្រៃបិដក ក្នុងអសោការាម ទៀបក្រុងបាតលីបុត្រ មានព្រះបាទធម្មាសោកពាជជាសាសនូបត្ថម្ភក៏ ៩ ខែ ទើបសម្រេចការតតិយ-សង្គាយនា ។

លុះព្រះពុទ្ធសាសនាកន្ទ្ធ១ទៅបាន ២៣៨ ឆ្នាំ ទើបព្រះមហិន្ទត្ថេរ បង្គាប់នាងសង្ឆមិត្តាថេរី ឲ្យនាំដើមព្រះពោធិព្រឹក្ស ដែលព្រះបាទធម្មាសោកទ្រង់សាកអំពីមហាពោធិ ផ្ញើទៅថ្វាយព្រះបាទទេវានម្ប្រិយតិស្ស ដាំក្នុងលង្ការ៉ូប ហើយបានបំបួសកុលបុត្រឲ្យរៀនព្រះបរិយត្តិធម៌ គឺញ្ចុំងឫសព្រះពុទ្ធសាសនាឲ្យចាក់ចុះក្នុងកោះលង្ការ៉ូហើយ ទើបព្រះខីណាស្រព ៦៨ ព្រះអង្គ មានព្រះមហិន្ទត្ថេរនិងព្រះអរិដ្ឋត្ថេរជាប្រធានប្រជុំព្រះសង្ឆទ្រង់ព្រះបរិយត្តិធម៌ ៥០០ អង្គ សង្គាយនាព្រះត្រៃបិដក ក្នុងមណ្ឌបថូបារាម ទៀបក្រុងអនុរាធបុរី មានព្រះបាទទេវានម្ប្រិយតិស្ស ជាសាសនូបត្ថម្ភក៏ ១០ ខែ ទើបសម្រេចការចតុត្ថសង្គាយនា ។

លុះព្រះពុទ្ធសាសនាកន្ទ្ធ១ទៅបាន ៤៣៣ ឆ្នាំ គ្រានោះព្រះអរហន្ត

ទាំងឡាយក្នុងលង្ការទ្វីប ពិចារណាយល់ថា ព្រះសង្ឆដែលទ្រង់ព្រះត្រៃ-
បិដកចាំមាត់នោះ កាន់តែថយតិចចុះទៅ ទើបជ្រើសរើសព្រះអរហន្តបដិ-
សម្ភិទាញាណ និងព្រះសង្ឆបុថុជ្ជន ដែលទ្រង់ព្រះបរិយត្តិច្រើនជាង
ពាន់អង្គ ប្រជុំក្នុងអភយគិរីបព៌ត ទៀបក្រុងអនុរាធបុរី មានព្រះបាទវដ្ត-
គាមិណីអភ័យជាសាសនូបត្ថម្ភក៍ ធ្វើមណ្ឌបថ្វាយ ដើម្បីធ្វើសង្គាយនា
ព្រះត្រៃបិដក ចារឹកចុះក្នុងស្លឹករឹតទាំងបាលី ទាំងអដ្ឋកថា ជាសីហឬ-
ភាសា ១ ឆ្នាំ ទើបសម្រេចការបញ្ចូមសង្គាយនា ។

លុះព្រះពុទ្ធសាសនាកន្ទងទៅបាន ៩៥៦ ឆ្នាំ ព្រះពុទ្ធឃោសាចារ្ય
ចេញអំពីជម្ពូទ្វីប ទៅប្រែព្រះត្រៃបិដកដែលជាសីហឬភាសានោះ ចារឹក
ក្នុងស្លឹករឹតជាថ្មី ប្រែជាមគធភាសា ធ្វើការក្នុងលោហប្រាសាទ ទៀប
ក្រុងអនុរាធបុរី មានព្រះមហានាមរាជជាសាសនូបត្ថម្ភក៍ ១ ឆ្នាំ ទើប
សម្រេចការធដ្ឋសង្គាយនា ។

លុះព្រះពុទ្ធសាសនាកន្ទងទៅបាន ១៥៨៧ ឆ្នាំ ទើបព្រះកស្សបត្ថេ-
រ និងព្រះសង្ឆបុថុជ្ជនច្រើនជាងពាន់អង្គ ប្រជុំជម្រះព្រះត្រៃបិដក ដែល
សល់នៅជាសីហឬភាសាខ្លះ លាយដោយមគធភាសាខ្លះនោះ ប្រែជា
មគធភាសាទាំងអស់ ចារឹកក្នុងស្លឹករឹតជាថ្មី មានព្រះបាទបរកមពាហុ-
រាជ ជាសាសនូបត្ថម្ភក៍ ១ ឆ្នាំ ទើបសម្រេចការសត្តមសង្គាយនា ។

ទើបព្រះបាទធម្មានុរុទ្ធ ព្រះចៅក្រុងអរិមទនបុរី គឺស្រុកភូកាម

ចេញទៅសុំចម្លងព្រះត្រៃបិដកចប់ហើយ សុំទាំងព្រះកែវមរកត ដាក់សំពៅនាំមកផ្សាយក្នុងជម្ពូទ្វីបនេះ ។

លុះព្រះពុទ្ធសាសនាកន្លងទៅបាន ២០២០ ឆ្នាំ ព្រះធម្មទិន្នត្ថេរ ឃើញថាព្រះត្រៃបិដកនេះពិរុទ្ធច្រើន ដោយចម្លងផ្ទាស់ប្ដូរតែងតួអក្សរតាមជាតិខ្លួនទីទៃៗ ទើបព្រះធម្មទិន្នត្ថេរជ្រើសរើសភិក្ខុ ដែលទ្រង់ព្រះបរិយត្តិបាន ១០០ អង្គ ជម្រះព្រះត្រៃបិដក នៅមណ្ឌលក្នុងមហាពោធ-ភម ទៀបក្រុងធ្ងៀងម៉ែ មានព្រះបាទសិរិធម្មក្រវតិលករាជ ជាសា-សនូបត្ថម្ភក៍ ១ ឆ្នាំ ទើបសម្រេចការអដ្ឋមសង្គាយនា ព្រះពុទ្ធសាសនាក៏រុងរឿងរៀងមក ។

*លុះថ្ងៃ ៣ ១ ២ ៥ ឆ្នាំកុរសប្ដស័ក ច.ស. ១១២៩ ទ័ពភូមាវាយបែកក្រុងទេព ដេញព្រះចៅសុរិយាមរិន្ទ្រ រត់ទៅសុគតដោយអត់អាហារ ហើយទ័ពភូមាដុតក្រុងទេពរលាយ គម្ពីរ វត្ថុអាវាស ផ្ទះសម្បែង សែងភ្ជើង ភ្ជួចពន្ធឹថ្ងៃ ជាចលាចលធំ គ្មានអ្នកណានឹងលត់ ព្រះសង្ឆទ្រង់សីលក៏រត់សូន្យអស់ពីទីក្រុង ស្ពាយបាត្រគាតចីពរចៀសចាកបច្ចាមិត្ត ទៅពួនព្រៃទីទៃៗ ប្រជាជនក៏ជំនុំគ្នាដោយពួកៗ លើកគ្នាទៅបូន់ដណ្ដើមអាហារ រក្សាគ្រប់គ្រងគ្រួសារតែសព្វអន្ទ្ធ ។ គ្រានោះផែនដីស្រុកសៀមបែកចេញជា ៦ ភាគ គឺ ព្រះ ណាយ**ក**ង និង **ម**ង**យ**ា មេទ័ពភូមាតាំងនៅបន្ទាយពោធ៍ ៣ ដើម យកអាចារ្យ **ឌ** វត្ដប្រគូជា*

ទីប្រឹក្សា ១ ចៅ **ណ្ហាន** បានអាចារ្យ **សី** ជាឧបទេស តាំងជាស្តេចនៅ ស្រុកណ្ហាន ១ ចៅ **តាក** ១ ចៅ **ភិម៉ាយ** ចៅពិស្ណុលោក **រ៉ៃ** ១ មហា **រ៉ៃ** ជាសង្ឆរាជធំ នៅស្រុកស្វាងបុរី តាំខ្ជួនជាស្តេច ហៅចៅ ព្រះ **ហ្ជាង** ១ ឯទ័ពព្រះហ្ជាង សុទ្ធតែកេទជាកិក្ខុទាំងអស់ មានតាំង មេកង ៥ ហៅព្រះគ្រូ **តិរិមានន្ទ** ១ ព្រះគ្រូ **ពេជ្រ** ១ អាចារ្យ **ចាន់** ១ **ថោង** ១ **ភ្ជើត** ១ សុទ្ធតែពួកអលជ្ជី មិនខ្ជាសបាប យកបាត្រ ច្រកថង់ បង្ក្ដប់អាវុធខ្ជីក្នុងបាត្រ ហើយគាតចីពរ ចងព័ទ្ធនូវត្ដពន្ធទ្រូង កាន់គ្រឿងសាស្ត្រាវុធ ដាវ កាំភ្ជើង ចេញច្បាំងឈ្នះចៅពិស្ណុលោក ហើយតាំងជាស្ដេចក្នុងស្រុកទាំងពីរនោះ ។ ក៏ក្នុងឆ្នាំកុរសប្ដស័ក នោះ ព្រះចៅ តាក ត្រឡប់ពីចន្ទបុរី មកវាយបែកទ័ពភូមា ហើយតាំងអាចារ្យ **ឌី** ជាសម្ដេចព្រះសង្ឆរាជ ហើយលើកទៅវាយចៅ **ណ្ហាន** បានអាចារ្យ **សី** មកដល់ក្នុងក្រុងនោះ សម្ដេចព្រះសង្ឆរាជ **ឌី** ត្រូវចោទថា ញុះទ័ព ភូមាឲ្យរិបយកទ្រព្យសម្បត្ដិអ្នកស្រុក ត្រូវផ្សឹកចេញហើយតាំងអាចារ្យ ជំនួស លុះបង្ក្រាបចៅ **ភិម៉ាយ** រាបហើយ លើកទៅបង្ក្រាបចៅព្រះ **ហ្ជាង**, ចៅព្រះ**ហ្ជាង** និងព្រះគ្រូ ពេជ្រ រត់គេចទៅបាត់ ចាប់បានតែ សង្ឆកងទ័ព កមឲ្យពិសោធមុជទឹក សង្ឆណាដែលចាញ់ពិសោធ ឲ្យ សម្ងាប់ សង្ឆណាស្មើពិសោធ ឲ្យសឹកបួសជាថ្មី សង្ឆណាដែលឈ្នះ ពិសោធ ទុកជាបរិស័ទ, ធ្វើខុសពីព្រះពុទ្ធប្ញញ្ញត្ដិ គឺជាពួកអលជ្ជី

នាំបង្ហើតចលាចលរាល់ស្រុក មិនតែប៉ុណ្ណោះ មហា **ជ** នៅវត្តព្រះពម ក្រុង ក៏តាំងខ្លួនជាស្តេច លើកទ័ពសង្ឆ្ចាំងទៀត លុះត្រូវចាប់បាន ក៏ឲ្យពិសោធមុជទឹកដូចមុន នេះពិតជាពូជអលជ្ជីសល់នៅជាច្រើន ។

លុះ ច.ស. ១១៤១ (ឆ្នាំកុរឯកស័ក) សម្តេចព្រះចៅពញ្ញាមហា-ក្សត្រសឹក បានព្រះកែវមរកតមកពីស្រុកលានជាងមកទុកក្នុងក្រុងទេព ហើយហួសមកស្រុកខ្មែរ ។ ពេលនោះព្រះចៅ **តាក** ឆ្ពួត ដោយរៀន កម្មដ្ឋានពីគ្រូមិនល្អ សន្ទតថាខ្លួនបានស្រោតាបត្ដិផល មានយសខ្ពស់ ជាងសង្ឆ ត្រូវសង្ឆសំពះគាល់ខ្លួនវិញ នោះពួកអលជ្ជី មានព្រះ ពោធិវ័ង្ស **ឈ្ម** ជាដើម ថាសំពះបាន ឯសម្តេចព្រះសង្ឆរាជជាដើម ថាសំពះមិនបាន ព្រះចៅ **តាក** ខ្ជាល់នឹងពួកសម្តេចព្រះសង្ឆរាជ ទាំង ៣ វត្ត ត្រូវជា ៥០០ អង្គ ឲ្យវាយតាំងពី ២០០ រំពាត់ ទៅដល់ ៣០០ រំពាត់ តាមសក្ដិធំ តូច ហើយហូតងារចេញ តាំងឲ្យពួកអលជ្ជី គឺព្រះ ពោធិវ័ង្ស ជាសម្តេចព្រះសង្ឆរាជ សម្តេចព្រះសង្ឆរាជក៏បញ្ញត្ដឲ្យមាន រ៉ាត់ប្រខុតជួសវត្ដពន្ធចូលគាល់ព្រះចៅ **តាក** ព្រះចៅ **តាក** ទៅរឹប រាតត្បាត បានទ្រព្យពីអ្នកស្រុក ក៏ប្រគល់ឲ្យមន្ត្រីសង្ឆទាំងអស់ត្រួត រក្សា កើតមហាភ័យដល់គ្រសហ្ជនិងបព្ជជិតខ្លាំងណាស់ បានជាជាប់ ទំនៀមសង្ឆ មានរ៉ាត់ប្រខុតរឹតទ្រូងរៀងមក ។ ឯព្រះចៅ តាក សោយរាជ្យដល់ព្រះជន្ម ៤៨ ឆ្នាំក៏សុគតទៅ ។

លុះ ច.ស. ១១៤៤ (ថ្ងៃ ១ ១/ ៦ ឆ្នាំខាលចត្វាស័ក) សម្តេចចៅ ពញ្ញាមហាក្សត្រសឹក បានសោយរាជ្យទ្រង់ព្រះនាម **ពុទ្ធយ៉ត**ហ្ការ រៀបរយរាជការរួច ទ្រង់ឲ្យដកសម្តេចចៅ ឈឹន ជាអលជ្ជីពីទីសម្តេចព្រះ សង្ឆរាជចេញ តែទ្រង់ស្តាយព្រោះចេះព្រះត្រៃបិដក ទ្រង់ឲ្យធ្វើជា ព្រះវនរ័ត ព្រះវនរ័តប្រព្រឹត្តខុសដោយផ្ទូរលក់ចេញទិញចូលទៀត ក៏ បន្ទយឲ្យធ្វើជាព្រះធម្មត្រៃលោក ឯសង្ឆដែលព្រះចៅ **តាក** ធ្វើ ទោសទាំងប៉ុន្មាន ។ នោះ ទ្រង់លើកទោស តាំងឡើងជាសម្តេច ព្រះសង្ឆរាជដូចដើមវិញទាំងអស់ ។

មួយទៀត ព្រះរាជាគណៈមុន ដែលចេះព្រះបរិយត្តិធម៌នោះ ទ្រង់តាំងជាព្រះសុមេធាចារ្យ នៅវត្តតង់បុះ ១ ព្រះត្រៃសរណធជ: នៅវត្តបាងហ្ជ ១ ព្រះសុមេធ **ត្ងូ** នៅវត្តបាងយីរៀក្នុង ១ វត្តទាំង នេះក្រុមព្រះរាជរ៉ាងសាងថ្វាយ ។

លុះ ព.ស. ២៣៣១ ក្នុងថ្ងៃ ១៥ កើតខែកត្តិ ឆ្នាំរកសំរឹទ្ធិ-ស័ក ច.ស. ១១៥០ នោះទ្រង់យល់ថា ព្រះត្រៃបិដក ឃ្យៀងឃ្លាតជា ច្រើន ពិរុទ្ធក៏ច្រើន ទើបទ្រង់ប្រជុំសង្ឆដែលទ្រង់បរិយត្តិបាន ២១៨ អង្គ ចាត់អាចារ្យដែលចេះព្រះបរិយត្តិ ៣២ រូប ព្រមឲ្យសម្តេចព្រះសង្ឆរាជ ជាប្រធាន ជម្រះព្រះសុត្តន្តបិដក ១ ព្រះវនរ័តជាប្រធាន ជម្រះព្រះវិនយ-បិដក ១ ព្រះវិមលធម្មជាប្រធាន ជម្រះព្រះសទ្ធាវិសេស ១ ព្រះធម្មត្រៃ-

លោក **ឈឹន** ដែលប្រព្រឹត្តអលជ្ជីពីរាជ្យមុន សុះចូលជាប្រធាន ជម្រះ ព្រះអភិធម្មបិដក ១ ជា ៤ ក្រុម ជំនុំផ្ទៀងព្រះត្រៃបិដកនៅវត្តព្រះរតន-សាស្តារាម ក្នុងក្រុងទេពមហានគរ មានព្រះបាទសម្តេចព្រះពុទ្ធយ៉ត-ហ្ការ-ចូទ្ធាលោកជាសាសនូបត្ថម្ភក៍ ៥ ខែ ទើបសម្រេចការនវមសង្គាយនា ។

លុះសម្តេចព្រះចមក្ការ បានទ្រង់បរិយត្តិ ជ្រាបប្រវត្តិហេតុគ្រប់ចំពូកហើយ ក៏រីងរឹតតែស្ងុតព្រះទ័យ ភ័យនឹងសាសនវង្សដែលចលាចល ខ្ជិចអំពីក្រុងចាស់កាលបះកូមា ហើយឃើញអាចារវិបត្តិ នៃពួកអលជ្ជី មិនជាទីនាំមកនូវសេចក្តីជ្រះថ្លា ខ្ញុះទេសនាមហាជាតក៏ស្ងួតជាបទណ្ឌាន មានពិផាតទទួល ខ្ញុះស៊ីឈ្ងួលសូត្រម៉ាឡៃ ចេញរ៉ាំប្រណាំងប្រជែងនឹងយីកេ អ៊ីប៉ ខ្ញុះជាជាងទង ជាងគំនូរ គូរប្រណាំងនឹងគ្រហស្ថ លក់យកចំណេញ ខ្ញុះជាអ្នកលេង ឫមបួសត្រឹកសឹកល្ងាច លេងស្រីធ្វើកសុវ ស៊ីបាយល្ងាច ជាច្រើនពួកណាស់ បានជាទ្រង់ស្ងុតព្រះទ័យអំពីការដែលទ្រង់ភេទបព្វជិត ឃើញពិតពេញលើវង្សបព្វជ្ជាឧបសម្ព័ទ្ធថាប្រាកដជាមានឫសគល់ពុកស្ងួយរលួយ ព្រួយព្រះទ័យណាស់ ក៏ស្តេចយាងទៅផ្ទុំក្នុងវេលាថ្ងៃ ក្នុងពោងឧបោសថវត្តមហាធាតុនោះ ហើយទ្រង់បូជាព្រះសាសនានឹងទេពរក្ស ដោយគ្រឿងសក្ការ:គ្រប់ៗ ទិស ហើយទ្រង់ធ្វើសច្ចកិរិយាធិដ្ឋានថា ទូលព្រះបង្គំនេះ ឧទ្ទិសចំពោះព្រះពុទ្ធជាអម្ចាស់ចេញបួសដោយសេចក្តីជឿសេចក្តីជ្រះថ្លា មិនមានសំឡឹងដល់

អាមិសឯណានីមួយ មានលាភ យស និងសេចក្ដីសរសើរជាដើមឡើយ បើវង្សបពូជ្ជាឧបសម្ប៉ៃ ដែលជាប់មកអំពីព្រះសុគតទសពល នៅមានសល់ក្នុងប្រទេសណា ទិសណា សូមឲ្យបានប្រសពូជ្ជ ឬបានឮដំណឹងក្នុងរវាង ៣ ថ្ងៃ ឬ ៧ ថ្ងៃនេះ បើមិនដូច្នោះទេ ទូលព្រះបង្គំនឹងសន្និដ្ឋានចូលចិត្តស្រេចថា សាសនវង្សនោះសាបសូន្យអស់ហើយ ក៏នឹងសឹកទៅជាគ្រឹហាវាស រក្សាសីល ៥ សីល ៨ តាមគួរ ។

លុះកន្ធងមកបាន ៣ ថ្ងៃ មិនទាន់អស់កំណត់ដែលទ្រង់អធិដ្ឋាន ក៏ស្រាប់តែមានព្រះថេរៈរាមញ្ញវង្សមួយអង្គ ព្រះនាមព្រះសុមេធាចារ្យ ធ្វាតក្នុងព្រះវិន័យ ចេះពុទ្ធវចនៈស្ទាត់ក្នុងអក្ខរុច្ចារណាវិធី មកសម្ដែងពុទ្ធ-សាសនវង្ស សម្ដែងចង្អុលឲ្យយល់ច្បាស់ មានសេចក្ដីជ្រះថ្លាថា នេះប្រាកដជាវង្សបពូជ្ជាឧបសម្ប៉ៃ មានពូជជាប់អំពីព្រះអនុរុទ្ធមហាថេរ មានព្រះវិហារសីមាព្រះអរិយៈតាំងខ្ជាប់ក្នុងស្រុកមន មិនដែលមានកម្រើករៀងមកដល់ព្រះឧបជ្ឈាយ៍ ព្រះសុមេធាចារ្យនេះ ៨៨ តំណហើយ ទើបទ្រង់ជ្រះថ្លាទទួលយកវិនយវង្សនោះ ទុកជាផ្លូវប្រតិបត្តិតមក ព្រះអង្គទ្រង់តាំងព្រះមហាវីរិយៈរៀនព្រះត្រៃបិដក បានទ្រង់ព្រះបរិយត្តិធម៌ដ៏ឧត្តម ។

លុះ ច.ស. ១១៨៨ ឆ្នាំចអដ្ឋស័ក ទ្រង់ចូលប្រៃព្រះបរិយត្តិ នៅទីជំនុំព្រះរាជគណៈ នៅព្រះទីនាំងអមរិន្ទ្រវិនិច្ឆ័យ ៣ ថ្ងៃជាបឋម ប្រៃធម្មបទ ថ្ងៃទី ២ ប្រៃមង្គលត្ថទីបនី ថ្ងៃទី ៣ ប្រៃសារត្ថសង្គហៈ គ្រប់ ៤

ប្រយោគ គ្រានោះសម្តេចព្រះវនរ័ត ថាប់ ព្រះញាណរក្ខិត **សុត** ព្រះសមុទ្ទមុនី **សាំ៩** ព្រះអមរាភិរក្ខិត **ភើត** សឹងចូលប្រៃព្រះបរិយត្តិជាមួយនឹងព្រះអង្គនោះបាន ៤ ប្រយោគ ហើយចូលប្រៃថែមក្រោយ បាន ៤-៥ ប្រយោគទៀត គឺទាំង ៥ ព្រះអង្គសឹងទ្រង់ព្រះបរិយត្តិ ៨-៩ ប្រយោគ សឹងទទួលយកវិនយវង្ស ក្នុងរាមញ្ញវង្ស ទុកជាផ្លូវប្រតិបត្តិ ហើយសង្វាតផ្ទៀងរៀបរៀងគ្រប់ៗ ព្រះគម្ពីរ តាមវិធីប្រតិបត្តិ កម្ចាត់នូវសេចក្តីមន្ទិលជាអចិន្ត្រៃយតតរង្គៀសឡើយ ហើយទ្រង់តាំងព្រះមហាវីរ:ប្រដៅព្រះវិនយវង្ស និងព្រះសុត្តន្តបិដក ដល់កុលបុត្រ ឲ្យប្រព្រឹត្តត្រូវតាមលំអានធម្មវិន័យ ជាសេចក្តីអស្ចារ្យ កុលបុត្រកាន់តែជ្រះថ្លាច្រើនឡើងៗ ។

លុះ ច.ស. ១១៩១ ឆ្នាំធ្លូវឯកស័ក ទ្រង់ព្រះតម្រិះយល់ថា វត្តមហាធាតុនេះ មិនជាទីសប្បាយ ទើបទ្រង់ត្រឡប់ឡើងទៅគង់វត្តសម៉-ង៉ាយ គឺវត្តរាជានិវាស ដើម្បីប្រកាសសាសនាព្រហ្មចរិយវង្ស និងបព្វជ្ជាឧបសម្ប៉ទ នៃកុលបុត្រដែលមានសទ្ធា អនុគ្រោះគ្រហស្ថដោយធម្មិកានុមានសាសនោវាទ ក្នុងធម្មស្សវនកាល ប្រតិស្ថានធម្មយុត្តិកនិកាយ ឲ្យផ្សាយរុងរឿងចេញទៅ ក៏កើតមានព្រះសង្ឆជ្រះថ្លាក្នុងវិនយវង្ស ក្នុងវស្សា ៣០ ឬ ៣១ ដោយសុខុម ។ ទើបទ្រង់ប្រារព្ធពីរឿងសីមា យល់ច្បាស់ថា ការធ្វើសីមាសព្វថ្ងៃនេះ ជាការមិនមួនមាំ មិនសម្រេចដោយអំណាចសង្ឆ ជាការជាប់ទៅដោយគ្រឹហាវាស ឱកាសនេះ មិនមាន

អ្នកស្គាល់លក្ខណៈសីមាដោយពិស្តារ ធ្វើតែតាមលទ្ធិអាចារ្យ ដែលខ្ជួនធ្លាប់ឃើញរៀងមក ។ ទ្រង់រង្គៀសដូច្នេះហើយ ទ្រង់ឲ្យជីកយកដុំនិមិត្តសីមា ក្នុងវត្តរាជានិវាសឡើង ទតព្រះនេត្រសង្កេតឃើញថាមិនឡើងជានិមិត្តបានឡើយ ។ ទើបទ្រង់ឲ្យស្វែងរកព្រះសង្ឆបរិសុទ្ធដែលឧបសម្ព័ទ្ធក្នុងបុរាណសីមា ដែលពិតជាព្រះអរហន្តចងទុកមកនោះ បានព្រះសង្ឆមន ១៨ អង្គ មានព្រះសុមេធាចារ្យមហាថេរជាដើម ទ្រង់ឲ្យធ្វើផែជាទីឧបោសថនៅមុខវត្តសម៉ាយ ហើយនិមន្តព្រះសុមេធាចារ្យជាព្រះឧបជ្ឈាយ៍ ព្រះត្រៃសរណធជត្ថេរ ជាឧបសម្ប្ទាចារ្យ ធ្វើញត្តិចតុត្ថកម្ម តាមវិនយវង្ស ទាំង ៥ ព្រះអង្គនេះជាដើមធម្មយុត្តិកៈ នោះព្រះ**ចមក្ការ** ទ្រង់មគធនាមថា "**ឋរមោ**" សម្តេចព្រះវនរ័ត **ថាប់** នាម "**ឋ្ឍ** គោ" ព្រះញាណរក្ខិត **សុត** នាម "**ញ្ញាណ**រ**ក្ខ**ិ**ត**ោ" ព្រះកទ្ទសមុទ្ទមុនី សាំង នាម "**ក**ទ្ទ**ិ**យ**ោ**" ព្រះអមរាភិរក្ខិត **ភ**ើ**ត** នាម "**អ**ម**ភ**ោ" តែព្រះអមរាភិរក្ខិត សុំយកសម្តេចព្រះចមក្ការ ជាឧបសម្ប្ទាចារ្យ ។

លុះដល់ថ្ងៃ ១៥ ១ ៨ ឆ្នាំធ្ងូវឯកស័ក មានព្រះសង្ឆលង្ការវង្ស ទ្រង់ប្រតិបត្តិត្រឹមត្រូវតាមវិន័យបញ្ញត្តិ ចំនួន ២៧ អង្គ មកកាន់វត្តសម៉ាយ នោះសម្តេចព្រះចមក្ការ បានសាកសួរផ្ទ្ធរបដិបត្តិទាំង ៥ ជំពូក ឃើញធ្ងើយត្រឹមត្រូវប្រាកដ ហើយថាចេញមកពីថ្ងបារាមជាសីមា ដែល

ព្រះមហិទ្ធត្ថេរចង់ទុក ក៏ទ្រង់មានព្រះសទ្ធាជ្រះថ្លា និមន្តព្រះសង្ឆ លង្ការទាំង ២៧ អង្គ ជាគណៈបកតត្តការកសង្ឆ ។ ទ្រង់ឧបសម្ព័ទ ទៀតជាពីរដង ក្នុងទីសីមាមុខវត្តរាជានិវេសនោះ ស្រេចហើយទើប បានទ្រង់ព្រះរាជឥស្សរិយយស ជាព្រះរាជាគណៈទ្រង់តាលបត្តសែកផ្ទៃ តាតបាក់លៀមជាគ្រឿងយស មានឋានានុក្រម ១០ អង្គជាបរិស័ទ ។

លុះ ច.ស. ១១៨៩ ឆ្នាំវកអដ្ឋស័ក សម្តេចព្រះណាំងក្ការសាង វត្តបវរនិវេសន៍និងវត្តបរមនិវាស រួចហើយ ទើបសម្តេចព្រះចមក្ការប្រជុំ សង្ឆបរិស័ទ ៥០ អង្គ ចងសីមាទាំងពីរវត្ត ជាសីមានិមិត្តទឹក តាម វិនយវង្សធម្មយុត្តិកៈ ទុកជាទីបព្វជ្ជាឧបសម្ព័ទកុលបុត្រ និងធ្វើសង្ឆ-កម្មទាំងពួង ហើយទ្រង់សង្កេតឃើញវិធីដែលធ្វើឧបោសថនោះ មិន ត្រឹមត្រង់តាមខ្នាតពេញវង់ ទើបទ្រង់តែងវិធីបក្ខគណនា តាមគម្ពីរមហា-វគ្គ និង តតិយសមន្តបាសាទិកា គម្ពីរហោរ ស្រេចស្តេចតែងរឿងសីមា វិធីបព្វជ្ជា វិធីកឋិន និងវិធីសង្ឆកម្មទាំងពួង ដែលសម្រេចជាត្រឹមត្រូវ ក្នុងវិន័យវង្សនេះទាំងប៉ុន្មាន សឹងបានទ្រង់ផ្ទៀងរៀបរយទាំងអស់ ហើយ ទៅគង់វត្តបវរនិវេសន៍ ប្រទានឲ្យព្រះញាណរក្ខិត ទៅគង់វត្តបរមនិវាស គ្រានោះ សម្តេចព្រះសុគន្ធាសង្ឆរាជាធិបតី ប៉ាន ទ្រង់ញត្តិនៅ វត្តបរមនិវាសនោះ ។

លុះ ច.ស. ១២១២ ឆ្នាំកុរនៅក្នុងទោស័ក ថ្ងៃ ៨ ១ ១ ៥ ព្រះណាំងក្ការ

សុគត, ថ្ងៃ ៦ ១ ១ ១

ផ្ទះផាង ខែត្រសមុទ្រសង្គ្រាមក្រុងទេព សម្ភពនៅថ្ងៃ ៥ ១/២ ៣ ឆ្នាំ ច ឆស័ក ច.ស. ១១៧៦ ព.ស. ២៣៥៧ នាមកំណើតឈ្មោះ **ភ្ជីត** ជាសិស្សច្បងនៃសម្តេចព្រះចមក្ខាវ បព្វជ្ជាជាសាមណេរ នៅវត្តពាជានិវាសជាដំបូង គ្រាក្រោយឧបសម្ប៉ីទ នៅវត្តបរមនិវាស ក្នុងថ្ងៃជាបឋមដែលព្រះសង្ឆធម្មយុត្តិក:លើកទៅតាំងនៅទីនោះ ដែលគ្រានោះនៅហៅថាវត្តបរមសុខ ជាឈ្មោះដទៃនៅឡើយ កាលឧបសម្ប៉ីទនោះ នៅឆ្នាំមមីឆស័ក ច.ស. ១១៩៦ ព.ស. ២៣៧៧ បាននាមក្នុងសាសនាថា អមរោ ព្រះថេរ:អង្គណាជាឧបជ្ឌាយ៍មិនច្បាស់ តែជាសង្ឆមន ឯឧបសម្ឆទាចារ្យគឺសម្តេចព្រះចមក្ខាវ បានរៀនសូត្របរិយត្តិធម៌ បានចូលប្រៃព្រះបរិយត្តិក្នុងវត្តព្រះកែវហ្ជ៉ង គ្រាដំបូងបាន៤ ប្រយោគ គ្រាទី ២ បាន ៤ ប្រយោគ ជា ៨ ប្រយោគ បានទទួលសមណស័ក្តិ ទីឋានានុក្រមទ្រង់គ្រឿងជាព្រះបាឡាត់នៃព្រះញាណរក្ខិត **សុ១** នៅវត្តបរមនិវាសនោះ កាលចុងឆ្នាំនោះ បានចេញទៅកោះលង្ការ ដោយកិច្ចព្រះសាសនាជាមួយនឹងព្រះសមុទ្ទមុនី ចៅវត្តបរមនិវាស ព្រះសង្ឆនិងគ្រហស្ថអ្នកលង្ការ សរសើររាល់គ្នាថា ជាពហូសូត ធ្ងាតក្នុងព្រះធម៌និងព្រះវិន័យ លុះព្រះញាណរក្ខិត លាសិក្ខាបទទៅធ្វើជាព្រះធម្មការបត្តិហើយ ទើបបានឡើង សមណស័ក្តិទីរាជគណ: មាននាមថា ព្រះ **អមរាភិរក្ខិត** ជាចៅវត្តបរមនិវាស ។

សេចក្ដីគម្រប់ពីរ កាលឆ្នាំខាល ឆស័ក ច.ស. ១២១៦ ព.ស. ២៣៩៧ ព្រះបាទសម្ដេចព្រះចមក្ខាវព្រះចៅក្រុងទេព បានអារាធនាព្រះមហា ប៉ាន ជាខេមរជាតិ មហា ៤ ប្រយោគ ឲ្យនាំព្រះត្រៃបិដក ៨០ គម្ពីរ ចេញមកតាំងធម្មយុត្ដិកវង្ស ផ្សាយព្រះពុទ្ធសាសនាក្នុងកម្ពុជរដ្ឋ តាមសេចក្ដីព្រះសុកអក្សរ នៃព្រះបាទសម្ដេចព្រះហរិរក្សរាមាតស្សរ-ធិបតី ព្រះចៅកម្ពុជរដ្ឋ ។

លុះ ច.ស. ១២១៨ ព.ស. ២៣៩៩ ព្រះមហា **ចាន** *បានចេញទៅដោយកិច្ចរាជការម្ដងទៀត គឺក្នុងគ្រាដែលទ្រង់ព្រះមេត្ដាប្រោសតាំងអង្គសម្ដេចព្រះនពោត្ដម ឲ្យចេញមកគ្រងខេមররដ្ឋរាជធានី ។ ឯព្រះអមរាភិរក្ខិតនោះ លោកប្រតិបត្ដិឧក្រិដ្ឋ ប្រព្រឹត្ដត្រឹមត្រូវ ជាអ្នកប្រាជ្ញ ប្រយោជន៍ដល់ពួកព្រហ្មចារីនិងកុលបុត្រទូទៅ តែជាអ្នកមានរោគច្រើន សូម្បីរាងកាយទុព្វលភាពដល់ម្ចឹង ក៏នៅតែខំប្រឹងព្យាយាម រចនាបករណៈទាំងឡាយទុក គឺបុព្វសិក្ខាសង្ខេប បុព្វសិក្ខាវណ្ណនា ជារឿងមួយចំនួន ១៥ ខ្សែ ចោះពុម្ពជាសៀវភៅចំនួន ៥៧៣ ក្បាល និងប្រតិលធម៌ ប្រថមកកា អក្សរនីតិ មានសិស្សខាងកិក្ខុសង្ឆ ដែលមានតំណអាចរិយវង្ស គឺព្រះមហា* **ចាន** *ដែលបានសមណស័ក្ដិ ជាសម្ដេចព្រះសុគន្ធាសង្ឆរាជាធិបតី គ្រប់គ្រងវត្ដបទុមវតី ជាស្ដេចសង្ឆ ហើយជាសង្ឆនាយកចៅគណៈធំ ខាងធម្មយុត្ដិកនិកាយ ហើយជាបឋម-*

គណាចារ្យនៃព្រះសង្ឆធម្មយុត្តិកៈក្នុងខេមររដ្ឋរាជធានី និងព្រះអរិយកវី **ថាប់** *៤ ប្រយោគ ចៅវត្តពីជ័យញ្ញាតិការាម ព្រះវិនយរក្ខិត* **ចាន់** *នៅវត្តបរមនិវាស ។*

តែក្នុងកាល ព.ស. ២៤៥៦ នេះ មានសិស្សនៅក្នុងសំណាក់តែ ចៅអធិការ **យ៉ា** *ចៅវត្តដូងខ១ ១ និងព្រះពិនិត្យវិន័យ* **ចេង** *ចៅវត្ត សម្ពន្ធវង្ស ១ ជាសិស្សផ្សេងវត្ត ។*

ឯគ្រហស្ថជាអ្នករាជការនោះ នៅតែពញ្ញាតសស្សរពន្ធសោកន **ម៉ម** *រាជវង្ស ១ និងឃុនមហាសិទ្ធិវោហារ* **ថាប់** *។*

លុះ ច.ស. ១២៣១ ព.ស. ២៦១២ ព្រះអមរាកិរក្ខិតប្រឈួន ដោយរោគម្រេញ ពេទ្យហ្ការ៉ែមិនស្រាក ក៏ទទួលអនិច្ចធម្មនៅថ្ងៃ ៣ ១០ ៨ ឆ្នាំម្សាញ់ឯកស័ក ព្រះជន្ម ៥៥ ឆ្នាំ បួសបាន ៣៥ វស្សា ។

ព្រះរាជប្រវត្តិនៃសម្តេចព្រះសុគន្ធាសង្ឆរាជាធិបតី

លំដាប់នេះនឹងពណ៌នាគុណសម្បត្តិ នៃសម្តេចព្រះសុគន្ធាសង្ឆ-រាជាធិបតី ព្រះនាមបញ្ញាសីលោ **ចាន** *ដែលទ្រង់បានទទួលច្បាប់រឿងនេះ មកប្រែរៀបរៀងជាខេមរភាសា ហើយផ្សាយវិនយវង្សធម្មយុត្តិកៈ ឲ្យថ្កើងរុងរឿងក្នុងកម្ពុជរដ្ឋតទៅ ។*

សម្តេចព្រះសុគន្ធាសង្ឆរាជាធិបតីអង្គនេះ ទ្រង់សម្ភពនៅថ្ងៃ

ថ្ងៃ ១ ១២ ឆ្នាំចអដ្ឋស័ក ច.ស. ១១៨៨ ព.ស. ២៣៦៩ វេលាទៀបព្រឹក ជាមហាឫក្សមង្គលពិសេស ស្រុកកំណើតនៅឃុំព្រៃកព្រះស្ពេច ខេត្ត បាត់ដំបង ឯស្រុកកំណើតមាតាបិតាលោក នៅភូមិស្នោង ស្រុកស្នោង ខេត្តកំពង់ធំ ឃ្លាតទៅនៅបាត់ដំបងដោយចលាចលតេជោទែន ។

លុះព្រះជន្ម ១២ ឆ្នាំ បានទ្រង់បព្វជ្ជាជាសាមណេរ នៅវត្តពោធិ៍ ឃុំសង្កែ ខេត្តបាត់ដំបង បាន ១ វស្សាក៏មានសតិនឹកឃ្នាសសេចក្តី ខ្ចៅលូង់ ហើយក៏ចូលទៅក្រុងទេព សំណាក់នៅវត្តស:កេត សង្វាត រៀនព្រះត្រៃបិដកតាំងពីព្រះជន្ម ១៣ លុះដល់ព្រះជន្ម ២១ ហើយទ្រង់ បួសតាមលទ្ធិមហានិកាយបាន ៤ វស្សា បានទ្រង់ព្រះបរិយត្តិ និងព្រះ កម្មដ្ឋាន ក៏បានចេះចប់ចំណេះអាចារ្យ បានរៀនខាងផ្លូវស្ងួតសូត្របទ ក៏ប្រាកដតាមបែបមហានិកាយគ្រប់យ៉ាង លុះឃើញអាចារវិបត្តិនៃសង្ឆ ក្នុងវត្តស:កេតនោះ មិនជាទីនាំមកនូវសេចក្តីជ្រះថ្លា ក៏ស្ងុតព្រះទ័យ ភ័យខ្ជាចចតុរាបាយ ទើបប្រឹក្សានឹងក្រុមមុឺន ភ្ជាងឱ្ងន ជាឧបដ្ឋាក គេក៏ យល់ព្រម ហើយបាននាំទៅថ្វាយសម្តេចព្រះចមក្ការ សម្តេចព្រះចមក្ការ ឲ្យទៅសិក្សាសិក្ខាវិន័យក្នុងសំណាក់ចៅឃុន ព្រះញាណរក្ខិត ចៅវត្ត បរមនិវាស ក៏បានឃើញច្បាស់ថា វិនយវង្សធម្មយុត្តិក:នេះ ប្រព្រឹត្ត បរិសុទ្ធ ត្រឹមត្រូវតាមផ្លូវធម្មវិន័យពិតមែន ។

លុះថ្ងៃ ១ ៨ ឆ្នាំរកាឯកស័ក ច.ស. ១២១១ ព.ស. ២៣៩២

ក៏បានចូលបព្វជ្ជាឧបសម្ប៉ាទក្នុងសំណាក់នៃសម្តេចព្រះចមក្ការ, សម្តេចព្រះចមក្ការ ជាព្រះឧបជ្ឌាយ៍ ចៅឃុនព្រះញាណរក្ខិត **សុត** និងព្រះអមរាភិរក្ខិត **ភើត** ជាឧបសម្ប្ទាចារ្ យ បានញត្តិចតុត្ថកម្ម ត្រឹមត្រូវតាមអក្ខរុច្ចារណាវិធី ជាធម្ម្យុត្តិក: បាននាមក្នុងសាសនាថា **បញ្ញាសីលោ** ហើយចេញទៅគង់វត្តបរមនិវាសវិញ បានសុំនិស្ស័យក្នុងសំណាក់ចៅឃុនព្រះញាណរក្ខិតជាអាចារ្ យ សិក្សាសិក្ខាវិន័យសេចក្តីប្រតិបត្តិ ចេះចាំតាមបែបបទស្ទាត់ប្រាកដហើយ ទ្រង់ព្រះមហាវីរ: ពិនិត្យផ្ទៀងផ្ទាត់ផ្លូវប្រតិបត្តិមិនឲ្យល្ម្ងៀងអំពីព្រះវិន័យទាំង ៥ គម្ពីរ និងព្រះសូត្រ ៥ គម្ពីរ ព្រះអភិធម្ម ៧ គម្ពីរ ញ្ចាំញ្ចីលទ្ធិខុសចេញអស់ ជាទីញ្ចាំងព្រហ្មចរិយធម៌ ឲ្យល្អបរិសុទ្ធឡើង លុះចេញព្រះវស្សា បានចូលទៅប្រៃប្រយោគ ក្នុងវត្តព្រះកែវហ្ជ ក្នុងក្រុងទេពបាន ៤ ប្រយោគ បានឡើងសមណាស័ក្តិ ជាមហាទ្រង់គ្រឿង មានបៀវត្ស ៤៨ បាទ ក្នុង ១ ឆ្នាំ ។

លុះ ច.ស. ១២១៦ ព.ស. ២៣៩៧ ឆ្នាំខាលឆស័ក មានព្រះសុកអក្សរព្រះបាទសម្តេចព្រះហរិក្សរាមាតស្សរាជិបតី ព្រះចៅប្រទេសកម្ពុជា ឲ្យទៅសុំវិនយវង្ស្ធម្ម្យុត្តិក: មកប្រដៅបរិស័ទក្នុងកម្ពុជរដ្ឋ ទើបសម្តេចព្រះចមក្ការ ថ្វាយគម្ពីរ ៨០ គម្ពីរ ហើយអាចធនាឲ្យចៅឃុនព្រះអមរាភិរក្ខិត ជូនព្រះមហា **ចាន** និងព្រះសង្ឆ ៦ អង្គ មកតាំង

វិនយវង្សធម្មយុត្តិក: ក្នុងក្រុងឧដុង្គមានជ័យនោះ សម្តេចព្រះសុគន្ធា-
សង្ឆរាជាធិបតី បានចម្ងងយកវតនកថានិងបុព្វសិក្ខាសង្ខេប បុព្ព-
សិក្ខាវណ្ណនា អក្សរនីតិ ជារបស់នៃចៅឃុន អមរាភិរក្ខិត ជាអក្សរ
ក្រសៀន រៀនទាំងអក្សរបុរាណ បានចេះស្ទាត់ទាំងគតិលោក គតិធម៌
ស្រេចហើយស្តេចចេញពីក្រុងបាងកកមកតាមផ្លូវកំពត ព្រមដោយសង្ឆ-
*បរិស័ទ ៦ អង្គ មានព្រះពោធិវង្ស **ចន្ធ** ជាដើម ឧបាសក ៤ នាក់ មាន*
*ព្រះទិព្វអក្សរ **ម:ផ្ទាប់** ជាដើម នោះព្រះបាទសម្តេច ព្រះហរិរក្សរាមា-*
ឥស្សរាធិបតី ទ្រង់ព្រះអំណរណាស់ ត្រាសឲ្យទៅគង់នៅវត្តសាលាគូ
ហើយថ្វាយចតុប្បច្ច័យ ឧបត្ថម្ភជានិច្ច គ្រានោះ សម្តេចព្រះសុគន្ធា-
សង្ឆរាជាធិបតី ព្រះអង្គទ្រង់ព្រះមហាវីរិយ: ប្រកាសព្រហ្មចរិយ:វិនយ-
វង្សធម្មយុត្តិក: ឲ្យបព្វជ្ជ-ឧបសម្ប៉ៃ ដល់កុលបុត្រដែលមានសទ្ធា
អនុគ្រោះគ្រឹហាវាសដោយធម្មស្សវនោកាស ហើយញ៉ាំងកុលបុត្រឲ្យទ្រ
ទ្រង់ព្រះបរិយត្តិជាច្រើន ដាស់តឿនឲ្យប្រព្រឹត្តឧក្រិដ្ឋក្នុងធម្មវិន័យជានិច្ច
ទើបវិនយវង្សធម្មយុត្តិក:ផ្សាយពេញក្នុងកម្ពុជរដ្ឋ ដោយគុណសម្បត្តិនៃ
សម្តេចដរាបរៀងមក ។

ឯចៅ ឃុន ព្រះអមរាភិរក្ខិត បានរៀបចំឃើញថាមាំមួនហើយ លុះដល់
ព្រះសិរីសម្មតិវង្ស ជេត កាលនៅជាបរិស័ទ លើកធុតង្គមកដល់ក្រោយ
គ្រប់ជាអដ្ឋកិក្ខុហើយ ក៏ថ្វាយព្រះពរត្រឡប់ទៅក្រុងបាងកកវិញ ។

កាលសម្តេចព្រះសុគន្ធាសង្ឆរាជាធិបតី ទ្រង់គង់ជាគណាចារ្យនៃធម្មយុត្តិកវង្ស ប្រដៅសាសនាដោយឧក្រិដ្ឋនោះ ក្នុងវស្សាជាបឋម បានឡើងសមណាស័ក្តិ ជាព្រះអរិយវង្ស គម្រប់ពីរជាព្រះវិមលធម្ម គម្រប់បីជាព្រះមហាវិមលធម្ម គម្រប់បួនបានអភិសេកជាស្តេចសង្ឆ ទ្រង់ព្រះនាមសម្តេចព្រះសុគន្ធាសង្ឆរាជាធិបតី ព្រះអង្គជាឧបជ្ឈាយ៍ដំបូងនៃវិនយវង្ស ធម្មយុត្តិក:ក្នុងប្រទេសកម្ពុជា ដោយអំណាចដែលទ្រង់មានព្រះចំណេះឈ្វាសវៃទាំងគតិលោក គតិធម៌ ចេះអក្សរភាសា សំស្ក្រឹត មគធ: សៀម លាវ ភូមា មន លង្ការ ខេមរបុរាណ ហើយបានរៀបរៀងប្រៃរឿង អភិធានប្បទីបិកា អក្ខរាភិធានស័ព្ទ អត្ថវិមុត្តិស័ព្ទ ព្រះរាជសព្ទ បុព្វសិក្ខា បុព្វសិក្ខាវណ្ណនា អាគារិយវិន័យ ជាប្រយោជន៍ដល់កុលបុត្រទាំងឡាយ បានសិក្សាជាផ្លូវប្រតិបត្តិមក ។

លុះ ច.ស. ១២២៧ ឆ្នាំធ្វូវសប្តស័ក ព្រះបាទសម្តេចព្រះនរោត្តមបរមទេវាវតារ ព្រះចៅកម្ពុជរដ្ឋ ស្តេចមកតាំងក្រុងនៅភ្នំពេញ ក៏ទ្រង់ស្តេចមកសាងវត្តបទុមវតីរាជវរារាម មានមហាសីមាទំហំទទឹង ៤ សិន (គឺ ១៦០ ម៉ែត្រ) បណ្តោយ ៥ សិន (គឺ ២០០ ម៉ែត្រ) ព្រះពោធិវ័ង្សគង់វត្តស្វាយពពែ ។ ឯបំណាច់ក្នុងកិច្ចរាជការនោះ ទ្រង់បានទៅក្រុងទេព ជាមួយនឹងឧកញ៉ាប្រសើរសូរ្យវង្ស កាលអញ្ជើញស្តេចព្រះអង្គ យ៉ៃ ព្រះអង្គ ណាយ មកក្រុងភ្នំពេញម្តង បានទ្រង់ពន្យល់អក្សរភាសាខេមរបុរាណ

ឲ្យលោកអេម៉ូនីញ៉ូ លោកអេម៉ូនីញ៉ូ បានកត់ត្រាចុះសៀវភៅ ទៅបោះ
ពុម្ពឯក្រុងបារីស នៅដល់សព្វថ្ងៃនេះផង ហើយទ្រង់បានសូមព្រះរាជ-
នុញ្ញាតឲ្យព្រះសិរិកជេនធម្ម **ចាប** និងព្រះសង្ឆ ៤ អង្គ នាំសក្ការ: ទៅ
ផ្ទៀងសាសនាឯលង្កាទ្វីប កាលនោះព្រះសុកូតិមហាថេររាមញ្ញវង្ស បាន
ឲ្យព្រះរតនសារត្ថេរសង្ឆលង្កា អញ្ជើញសក្ការ:តបវិញ គឺព្រះបរម-
សារីរិកធាតុ ១ ព្រះអង្គ ព្រះអរហន្តធាតុ ១ ព្រះអង្គ កូនព្រះពោធិព្រឹក្ষ
១ ដើម ទ្រង់បានឲ្យដាំទុកនៅមុខវត្តបទុមវតី នៅថ្ងៃ ៣ ១០ ៣ ឆ្នាំកុរ
នពស័ក ច.ស. ១២៤៩ ព.ស. ២៤៣០ គ.ស. ១៨៨៧ ជាចារឹក
ព្រះពុទ្ធសាសនាតមក ។ ឯព្រះបរមសារីរិកធាតុនោះ ទ្រង់កំពុងប្រារព្ធ
ឲ្យសាងព្រះចេតិយធំ ១ ស្រាប់តែទ្រង់ប្រឈួនចុកសៀតព្រះឧទរសោយ
ទិវង្គតទៅ នៅថ្ងៃ ៧ ២ ៣ ឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៣៦
ច.ស. ១២៥៥ គ.ស. ១៨៩៣ ក្នុងរវាងព្រះជន្ម ៦៨ ឆ្នាំ ទ្រង់ព្រះ
ផ្នួសបាន ៤៨ វស្សា ។

ឯព្រះចេតិយធំនោះ បានសម្តេចព្រះមង្គលទេពាចារ្យ អៀម ជា
សិស្សផ្ទាល់ ដែលបានឡើងឋានន្តរស័ក្តិជាសម្តេចព្រះសង្ឆនាយកទី ២
គ្រប់គ្រងវត្តបទុមវតីបានឃោសនាធ្វើការនោះហើយស្រេច បានសម្ពោធ
តម្កល់ព្រះបរមសារីរិកធាតុ ព្រះអរហន្តធាតុ និងព្រះធាតុសម្តេចព្រះ
សុគន្ធាសង្ឆរាជាធិបតី នៅថ្ងៃ ៤ ១ ៦ ឆ្នាំរកាឯកស័ក ព.ស. ២៤៥២

ត្រូវនឹងថ្ងៃ ៨ ខែ ម៉ែ (ឧសភា) ឆ្នាំ ១៩០៩ ជាចារឹកព្រះពុទ្ធសាសនា តមកទៀត ។

ហេតុនេះ ទើបលោកសម្តែងទុកថា ជីវិតនៃសត្វទាំងឡាយតែងតែ រលត់រលាយជាធម្មតា បើមិនបានធ្វើការអ្វីមួយ ជាប្រយោជន៍ ទុកឲ្យ ដល់អ្នកដទៃហើយ ជីវិតនោះក៏រកខ្វីមសារគ្មាន លុះតែបានធ្វើកិច្ចការជា ប្រយោជន៍ ប្រាកដដូច្នោះហើយ ទើបឈ្មោះថា បានធ្វើជីវិតឲ្យមាន សារៈ ដូចសម្តេចព្រះសុគន្ធាសង្ឆរាជាធិបតី **បញ្ញាសីលោ ចាន** ព្រះអង្គទ្រង់មានព្រះជន្មាយុតែត្រឹម ៦៨ ឆ្នាំប៉ុណ្ណោះ ក៏ឈ្មោះថារស់នៅ ដើម្បីជាប្រយោជន៍ដល់មហាជនជាច្រើន ទាំងបព្វជិត ទាំងគ្រហស្ថ គួរជាទិដ្ឋានុគតិ នៃសព្រហ្មចារីតទៅមុខ និងមានគុណូបការៈ ដល់ សិស្សានុសិស្ស សាធុសប្បុរសទាំងពួងជាអនេកប្បការ ។

ចប់

រឿងវិនយវង្សប្រវត្តិនេះ រៀបរៀងតាមព្រះរាជពង្សាវតារសៀម

ព្រះរាជប្រវត្តិមហាសាសនវង្ស និងដំណាង ។

ព្រះទិព្វអក្សរ **ម:ផ្ងាប់** ជាសិស្សដើម រៀបរៀងទុកជាទីសណ្ដាប់តទៅ ។

បុព្វសិក្ខាវណ្ណនា

លោកជេដ្ឋំ ច សម្ពុទ្ធំ ធម្មំ ពុទ្ធេន ឋបិតំ
គណំ អរិយសំឃស្ស នមាមិ រតនត្តយំ ។
បុព្វសិក្ខា ច យា បុព្វេ សំខេបេនេវ ឧស្សិតា
ខេមរាជុក្ត្រមេនេវ ឧរាជមជុសិក្ខិតុំ ។
ភិក្ខូនំ ញាតុកាមានំ ថោកំ ក្ខុច្ចិ វិត្ថារតោ
វណ្ណនំ ការិស្សំ ឥស្ស វិនយញ្ច ជិនេរិតំ ។
ឥស្មា ហិ សាធវោ ភិក្ខូ សុខកាមា ច សាសនេ
វិនយម្ហិ ច សិក្ខន្តុ អប្ប្ជមត្តា ច សាធុកំ ។

ខ្ញុំនមស្តារនូវព្រះរតនត្រ័យ គឺព្រះសម្ពុទ្ធជាធំក្នុងលោក ទាំងព្រះធម៌ដែលព្រះពុទ្ធបូជាហើយ និងពួកនៃព្រះអរិយសង្ឆ ។ បុព្វសិក្ខាណាដែលយើងសម្តែងពីមុនដោយសង្ខេប ដើម្បីញ៉ាំងពួកភិក្ខុដែលបួសថ្មីឲ្យសិក្សាតាមលំដាប់ជាខេមរភាសា ។

ខ្ញុំនឹងធ្វើនូវបុព្វសិក្ខាវណ្ណនានេះ ឲ្យពិស្តារបន្ថិច ជាងបុព្វសិក្ខាសង្ខេបនោះ សម្រាប់ភិក្ខុទាំងឡាយអ្នកប្រាថ្នាឲ្យចេះដឹង នូវព្រះវិន័យដែលព្រះជិនស្រីសម្តែងទុកហើយ ។ ហេតុដូច្នោះ ពួកភិក្ខុជាសប្បុរសអ្នកប្រាថ្នាសេចក្តីសុខ ចូរកុំប្រមាទឡើយ ហើយសិក្សានូវព្រះវិន័យក្នុងសាសនាដោយប្រពៃចុះ ។

ប្រការមួយទៀត ធម្មជាតិជាកុលបុត្រដែលមានសទ្ធា ជឿគុណ ព្រះរតនត្រ័យ មានចិត្តប្រាសចាកសេចក្តីសង្ស័យ គប្បីយកបញ្ញាយ៉ាង សុខុមល្អិតមកពិចារណា នូវរឿងបុព្វសិក្ខាវណ្ណនា ឲ្យត្រឹមត្រង់ហ្មត់ចត់ គ្រប់ៗ សិក្ខាបទកុំឲ្យណ្ដៀង ទើបនឹងស្គាល់ថា វិនយសាសនោវាទានុសា-សនី ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ ដែលឈ្មោះថា វិនយ-សាសន:នេះ ជាគម្ពីរភាពជ្រៅធ្វាយទូលាយ កម្រកុលបុត្រដឹងបាន ដោយងាយ ។ ការពិចារណាដឹងបានដូច្នេះ គង់កើតសេចក្តីសង្វេគ គិត ឃើញថា វិនយសាសន:នេះ ជាអាយុនៃព្រះពុទ្ធសាសនាប្រាកដ យល់ ច្បាស់ដោយបញ្ញាចក្ខុដូច្នេះហើយ គង់កើតសេចក្តីឧស្សាហ៍ ខំសូត្រ រៀនសិក្សានូវព្រះវិន័យ ឲ្យជាក់ច្បាស់ក្នុងចិត្តមិនឲ្យភ្លាត់បានក្នុងកាល ឯណាហើយ គង់បាននូវអានិសង្ស គឺការរក្សានូវសីលទាំង ៤ ប្រការ បានដោយងាយក្នុងកាលនោះប្រាកដ ទើបបានស្គាល់រសពុទ្ធវចន:ថា ជារបស់មានរសពិសា កម្របុគ្គលបានបរិភោគណាស់ ។

ហេតុដូច្នោះ កុលបុត្រគួរសិក្សា នូវវិនយវណ្ណនានេះដោយប្រពៃ តាមលំអានពាក្យដែលខ្ញុំពន្យល់នេះ ទើបមានផលានិសង្សច្រើន ។

បើមិនយល់ច្បាស់ក្នុងសិក្ខាបទណា ។ នៅជឿងធ្ងល់មិនយល់ ច្បាស់ដោយបញ្ញារបស់ខ្លួន គប្បីសាកសួរលោកអ្នកបរិយត្តិ វិន័យធរ

ពហុស្សូត បណ្ឌិត អ្នកប្រាជ្ញដែលជាអ្នកទ្រទ្រង់ព្រះវិន័យ ព្រោះលោករៀនព្រះវិនយសាសនោវាទ ទើបនឹងបានច្បាស់សេចក្ដីតទៅ ។

ពាក្យថា **បុព្វសិក្ខា** នេះ សង្គ្រោះជាឈ្មោះគម្ពីរ គឺក្បួនច្បាប់សម្រាប់កុលបុត្រសិក្សាជាដំបូង ទើបបានឈ្មោះថា **បុព្វសិក្ខា** ព្រោះហេតុនោះ ទើបបានពោលថា កុលបុត្រអ្នកជាឧបសម្បទាបេក្ខ: ឬ បានឧបសម្បទាហើយ គប្បីសិក្សាសេចក្ដីទាំង ៧ ប្រការនេះជាមុន ។

ឯសេចក្ដីទាំង ៧ ប្រការនោះគឺ ៖

រតនត្តយបទ: ពណ៌នាដោយគុណព្រះរតនត្រ័យ ១

អាបត្តិនាមាទិបទ: ពណ៌នាដោយឈ្មោះនៃអាបត្តិជាដើម ១

បដិបត្តិសិក្ខាបទ: ពណ៌នាដោយសិក្ខាបទជាប្រធាននៃផ្លូវបដិបត្តិដោយច្រើន ១

កាលិកបទ: ពណ៌នាដោយកាលិក ១

ពិន្ទូធិដ្ឋានាទិបទ: ពណ៌នាដោយពិធីមានពិន្ទុនិងអធិដ្ឋានជាដើម ១

វិនយានាទិបទ: ពណ៌នាដោយដាច់អធិដ្ឋានជាដើម ១

អាបត្តិទេសនាទិបទ: ពណ៌នាដោយសម្ដែងអាបត្តិជាដើម ១ ត្រូវជាសេចក្ដី ៧ ប្រការដូច្នេះ ។

រតនត្តយបព្វ:

ពាក្យថា រតនត្តយ: នោះ ប្រែថាប្រជុំបីនៃ រតន: គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឆ វត្ថុទាំង ៣ នេះឈ្មោះថា រតន: ព្រោះជារបស់ប្រសើរជាង **សវិញ្ញាណករតន:** និង **អវិញ្ញាណករតន:** ដែលមានក្នុងត្រៃភព ។

មួយទៀត ព្រោះជារបស់ធ្វើសេចក្ដីត្រេកអរឲ្យកើតឡើងដល់ត្រៃ-លោក ។

ពុទ្ធរតនកថា

បុច្ឆាសូរថា- ពុទ្ធ: នោះ អ្វីជាពុទ្ធ: ?

វិសជ្ជនាថា- ពុទ្ធ: បើពោលតាមបរមត្ថវោហារ បានដល់ វិសុទ្ធខន្ធសន្តាន គឺ កងរូប កងវេទនា កងសញ្ញា កងសង្ខារ កងវិញ្ញាណ ដែលជារបស់មានមកអំពីភពមុន ជារបស់បរិសុទ្ធចាកបាបធម៌ ឧបក្លិសេស គឺមិនមានអកុសលចេតសិក គ្រាន់តែជាអព្យាកតចេតសិក ដែលកើតអំពីកុសលចេតសិក នោះឯងជា ពុទ្ធ: បើពោលតាមលោក-វោហារ ថាជាសត្វវិសេសឯក មិនមែនព្រហ្ម មិនមែនមារ មិនមែនទេវតា មិនមែនអមនុស្ស គឺជាមនុស្សជាតិ តែជាមនុស្សអស្ចារ្យមាន

ប្រាជ្ញាឈ្វាស មានប្រាជ្ញាលើសជាង សមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម អាចធ្វើព្រះអង្គឯងឲ្យបរិសុទ្ធចាកបាបធម៌ឧបក្លិសបាន និង ទូន្មានសត្វដទៃឲ្យបានសេចក្តីបរិសុទ្ធបានផង នោះឯង ជាពុទ្ធ: ។

បុ. ពុទ្ធ: នោះ ប្រែថាដូចម្តេច?

វិ. ពុទ្ធ: នោះ ប្រែថាព្រះអង្គទ្រង់ជ្រាបច្បាស់នូវសង្ខារទាំងពួង ដោយព្រះអង្គឯង ហើយអាចឲ្យពួកសត្វដទៃដឹងច្បាស់នូវសង្ខារផង ព្រះអង្គរីកហើយពេញទី ។

បុថុជ្ជនដូចយើង ឈ្មោះថាមនុស្សខ្វៅមិនដឹងច្បាស់នូវសង្ខារ ទើបក្រៀមក្រំចិត្តក្នុងកាលដែលសង្ខារនោះវិបត្តិ ។

បុ. អ្វីជាសង្ខារ ?

វិ. វត្ថុទាំងពួងជារបស់ខាងក្នុង និងខាងក្រៅ ប្រកបដោយ វិញ្ញាណនិងមិនមានវិញ្ញាណ ដែលមានឡើងកើតឡើងដោយហេតុខាង ក្នុងមានកម្មជាដើម ដោយហេតុខាងក្រៅមានរដូវជាដើម នេះឯង ឈ្មោះថា សង្ខារ ។

បុ. ព្រះអង្គត្រាស់ដឹងនូវសង្ខារនោះដូចម្តេច ?

វិ. ព្រះអង្គទ្រង់ជ្រាបសេចក្តីកើតឯងរបស់សង្ខារ, ទ្រង់ជ្រាបហេតុ ដែលឲ្យកើតសង្ខារ, ទ្រង់ជ្រាបទីរលត់សង្ខារ, ទ្រង់ជ្រាបផ្លូវទៅកាន់ ទីរំលត់សង្ខារ, នេះឯងឈ្មោះថាព្រះអង្គទ្រង់ជ្រាបច្បាស់នូវសង្ខារ ។

ឬ. ព្រះអង្គទ្រង់ជ្រាប សេចក្តីកើតឯងនៃសង្ខារដូចម្តេច?

វិ. ព្រះអង្គទ្រង់ជ្រាបថា សង្ខារទាំងពួងមិនទៀងពិត រមែងប្រែប្រួលទៅផ្សេងៗ មានហើយមិនមានវិញ កើតហើយរលត់ទៅ ធម៌ទាំងពួងមិនមែនខ្លួនប្រាណ ព្រោះមិនបានប្រព្រឹត្តទៅក្នុងអំណាចបង្គាប់នៃអ្នកឯណា ព្រោះមិនទៀង ព្រោះមិនមែនខ្លួន គ្រាន់តែជាកងទុក្ខ ដូច្នេះជាសេចក្តីពិត ជាសេចក្តីកើតឯងនៃសង្ខារ ព្រះអង្គទ្រង់ជ្រាបច្បាស់ដូច្នេះ ដោយបរិញ្ញាភិសមយ យ៉ាងនេះឈ្មោះថា ព្រះអង្គជ្រាបច្បាស់នូវសេចក្តីកើតឯងនៃសង្ខារ ។

ឬ. ព្រះអង្គជ្រាបច្បាស់នូវហេតុដែលឲ្យកើតសង្ខារដូចម្តេច?

វិ. ព្រះអង្គជ្រាបច្បាស់ថា តណ្ហាគឺសេចក្តីអន្ទះអន្ទែងដោយការចង់បាន នេះឯង ជាអ្នកសាងសង្ខារខាងក្នុង ព្រោះតណ្ហាមានហើយជាហេតុឲ្យសត្វធ្វើកម្មជាកុសលនិងអកុសល ដែលនឹងតាក់តែងសង្ខារជាកងទុក្ខ ព្រះអង្គលះតណ្ហានោះបាន ដោយបហានាភិសមយ យ៉ាងនេះឈ្មោះថា ព្រះអង្គជ្រាបច្បាស់នូវហេតុដែលឲ្យកើតសង្ខារ ។

ឬ. ព្រះអង្គទ្រង់ជ្រាបច្បាស់នូវទីរលត់សង្ខារនោះដូចម្តេច?

វិ. ព្រះអង្គទ្រង់ជ្រាបច្បាស់ថា ព្រះនិព្វានជាទីរលត់តណ្ហា ដែលជាហេតុឲ្យកើតទុក្ខ ហើយធ្វើព្រះនិព្វានឲ្យជាក់ច្បាស់ក្នុងព្រះទ័យ ដោយ

សច្ចិកិរិយាកិសម័យ យ៉ាងនេះឈ្មោះថា ព្រះអង្គទ្រង់ជ្រាបច្បាស់នូវទីរំលត់នៃសង្ខារ ។

ឬ. ព្រះអង្គទ្រង់ជ្រាបច្បាស់នូវផ្លូវទៅកាន់ទីរំលត់នៃសង្ខារនោះដូចម្តេច?

វិ. ព្រះអង្គទ្រង់ជ្រាបច្បាស់ថា មគ្គប្រកបដោយអង្គ ៨ មានសម្មាទិដ្ឋិជាដើម ដែលកើតឡើងហើយ កំណត់ដឹងនូវសេចក្តីទុក្ខ លះតណ្ហា ឃើញព្រះនិព្វាន នេះឯងជាផ្លូវដល់នូវសេចក្តីរំលត់កងទុក្ខ ព្រះអង្គធ្វើមគ្គនោះឲ្យកើតឡើងក្នុងព្រះហឫទ័យ ដោយភាវនាកិសម័យ យ៉ាងនេះឈ្មោះថា ព្រះអង្គទ្រង់ជ្រាបច្បាស់នូវផ្លូវទៅកាន់ទីរំលត់នៃសង្ខារ ។

ព្រះអង្គទ្រង់ជ្រាបច្បាស់នូវហេតុទាំង ៤ ប្រការនេះហើយ ទើបមានសេចក្តីបរិសុទ្ធ ដរាបដល់មិនត្រេកអរ ប្រកាន់ថា យើងដឹង យើងឃើញ សូម្បីសង្ខារគឺរាងកាយរបស់ព្រះអង្គនិងវិបត្តិយ៉ាងណាៗ ក៏មិនទោមនស្សដូចបុថុជ្ជន យ៉ាងនេះឈ្មោះថា ព្រះអង្គជ្រាបច្បាស់នូវសង្ខារទាំងពួង ។

ឬ. បុគ្គលដែលលោកហៅថា **ពុទ្ធ:** *នោះមានប៉ុន្មានពួក?*

វិ. មាន ៤ ពួកគឺ:

១- ពហុស្សុត: លោកហៅថា **សុតពុទ្ធ** *ព្រោះជាអ្នកដឹងនូវសេចក្តីល្អអាក្រក់ជាដើម ដោយការបានស្តាប់និងបានរៀនបរិយត្តិធម៌ ។*

២- អរិយសាវក លោកហៅថា **សាវកពុទ្ធ** ព្រោះលោកបានស្តាប់ពាក្យប្រដៅ ពាក្យទូន្មានរបស់ព្រះពុទ្ធ ហើយជ្រាបច្បាស់នូវសង្ខារតាមដំណើរព្រះពុទ្ធ ។

៣- ព្រះសយម្ភូ លោកហៅថា **បចេ្ចកពុទ្ធ** អ្នកត្រាស់ដឹងឯងទូន្មានអ្នកដទៃមិនបាន ដូចមនុស្សគយល់សប្ត ព្រោះជ្រាបច្បាស់នូវសង្ខារបានចំពោះតែព្រះអង្គឯង ។

៤- ព្រះពុទ្ធ លោកហៅថា **សព្វញ្ញូពុទ្ធ** ព្រះអង្គត្រាស់ដឹងឯងហើយទូន្មានអ្នកដទៃ ឲ្យដឹងតាមបាន ព្រោះព្រះអង្គជ្រាបច្បាស់នូវសង្ខារនិងធម៌ទាំងពួង ។ ដែលពោលមកក្នុងបទ ពុទ្ធ: នេះ សង្គ្រោះយកតែសព្វញ្ញូពុទ្ធប៉ុណ្ណោះ ។

ឃ. ព្រះពុទ្ធជាអម្ចាស់នៃយើងនេះ (ក្នុងបច្ចិមជាតិ) ព្រះអង្គកើតឡើងក្នុងទីណា? ក្នុងមនុស្សជំពូកណា?

វិ. ព្រះអង្គកើតឡើងក្នុងមជ្ឈិមប្រទេស ក្នុងពួកមនុស្សអរិយក: ។ មជ្ឈិមប្រទេសនោះ ប្រែថាប្រទេសជាកណ្តាល ព្រោះជាទីកើតនៃព្រះពុទ្ធ ព្រះបចេ្ចកពុទ្ធ អគ្គសាវក ពុទ្ធុបដ្ឋាក ពុទ្ធបិតា ពុទ្ធមាតា ចក្រពត្រាធិរាជ និងតិត្ថករបពូជិត អ្នកមានទិដ្ឋិវាទផ្សេងៗ ដូចកណ្តាលនៃទីស្នាមជាទីប្រជុំជនទាំងពួង ។ មជ្ឈិមប្រទេសនោះ នៅក្នុងទិស

ឯលិចនៃប្រទេសកម្ពុជានេះ និងប្រទេសសៀម ប្រទេសមន ប្រទេសភូមា ប្រទេសលាវជាដើម ។ ឯប្រទេសទាំងអម្បាលនេះ ឈ្មោះថាបច្ចន្តប្រទេស ។ មនុស្សកើតក្នុងប្រទេសទាំងនេះ ឈ្មោះថាមិលក្ខ: ។ មនុស្សកើតក្នុងមជ្ឈិមប្រទេស ឈ្មោះថាអរិយក: ឥឡូវគេហៅប្រទេសនោះថា ឥណ្ឌា ។

ឃ. ព្រះអង្គកើតក្នុងមជ្ឈិមប្រទេស ក្នុងនគរណា ជាជាតិអ្វី ជាគោត្រអ្វី ព្រះនាមដើមជាអ្វី ជាបុត្របុគ្គលណា ព្រះអង្គមានបុត្រភរិយាឬទេ ព្រះអង្គបានត្រាស់ជាព្រះពុទ្ធក្នុងកាលណា?

ង. ព្រះអង្គជាអ្នកនគរកបិលពស្តុ ក្នុងដែនសក្ក: ព្រះអង្គជាជាតិក្សត្រពួកសក្យរាជ ជាគោតមគោត្រ ព្រះនាមដើមជា **សិទ្ធត្ថ:** ព្រះបិតាទ្រង់ព្រះនាម **សុទ្ធោទន** នៅក្នុងនគរកបិលពស្តុ ព្រះមាតាទ្រង់ព្រះនាម **សិរិមហាមាយា** ព្រះឱរសនៃព្រះអង្គព្រះនាម **រាហុល** ព្រះទេពីព្រះនាម **ពិម្ពាយសោធរា** កាលព្រះជន្មាយុបាន ២៩ វស្សា ព្រះអង្គលះគ្រឹហាវាសសម្បត្តិចេញបព្វជ្ជា បំពេញពិព្យាយាម ស្វែងរកមោក្ខធម៌ដ៏បរិសុទ្ធអស់ ៦ វស្សា ទើបបានត្រាស់ដឹងព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ "ដំណអំពីនោះទៅព្រះអង្គទ្រង់បំពេញពុទ្ធកិច្ច ទូន្មានវេនេយ្យនិករ ដរាបដល់ ៤៥ វស្សា ទើបទ្រង់រំលត់ខន្ធបរិនិព្វាន នានគរកុសិនារា" ។

បុ. ព្រះមាតា បិតា បុត្រ ភរិយា និងសុខសម្បត្តិដែលជាទីស្រឡាញ់ ហេតុអ្វីទើបព្រះអង្គលះបង់បាន?

*វិ. ព្រះអង្គលះបង់បានដោយហេតុដូច្នេះ គឺព្រះអង្គឃើញ ជរ សេចក្តីចាស់ **ព្យាធិ** សេចក្តីឈឺចាប់ **មរណៈ** សេចក្តីស្លាប់ជាកង់ទុក្ខធំ ដូចជាក្ងើងដុតសត្វដទៃ និងអត្តភាពព្រះអង្គ តែអ្នកដទៃនោះឃើញមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ ហើយខ្ពើមរអើម មិនដឹងថា របស់ ៣ យ៉ាងនេះជារបស់សម្រាប់ខ្លួន ចំណែកព្រះអង្គឃើញថា របស់ ៣ យ៉ាងនេះសម្រាប់សត្វដទៃ និងសម្រាប់អត្តភាពព្រះអង្គ នឹងខ្ពើមដូចមនុស្សដទៃគេខ្ពើមក៏មិនគួរ នឹងស្រឡាញ់ក៏មិនគួរ នឹងព្រងើយកន្តើយក៏មិនគួរ ព្រះអង្គឃើញថា **ជរ ព្យាធិ មរណៈ** នេះជាភ័យធំគួរខ្លាច តែនឹងគេចវេះទៅដោយផ្លូវណាក៏មិនរួច ដ្បិតជារបស់សម្រាប់អាស្រ័យនឹងរូបកាយ ព្រះអង្គទើបទ្រង់ព្រះចិន្តាថា ធម៌មិនមានចាស់ មិនមានឈឺ មិនមានស្លាប់ ជាទីគេចវេះ អំពីសេចក្តីចាស់ឈឺស្លាប់ គង់នឹងមានប្រាកដ ដូចក្ងើងជារបស់ក្តៅមានហើយក៏មានទឹកជារបស់ត្រជាក់កៃ មានងងឹតហើយ ក៏មានរស្មីភ្លឺកៃ ហើយព្រះអង្គពិចារណាថា សេចក្តីចាស់ឈឺស្លាប់ កើតមកអំពីអ្វី ទ្រង់ឃើញថា កើតមកអំពីជាតិ គឺសេចក្តីកើត ទ្រង់ពិចារណាតទៅថា ជាតិកើតមកអំពីអ្វី ក៏មិនឃើញដោយព្រះបញ្ញាសោះ ដូចជារបស់ ៣ យ៉ាងដែលកើតមក*

អំពីជាតិ ទើបព្រះអង្គក្តៅព្រះហឫទ័យ ការនៅក្នុងសុខសម្បត្តិនេះ នឹងរកធម៌ជាទីគេចវេះ អំពីសេចក្តីទុក្ខទាំងអម្បាលនេះ មិនបានប្រាកដ ព្រោះច្រឡំទៅដោយបុត្រភរិយាទ្រព្យសម្បត្តិដែលនាំឲ្យវង្វេង ឲ្យចម្រើនទុក្ខច្រើនឡើង សិរីសម្បត្តិនេះជាទីចង្អៀតចង្អល់ណាស់ ហើយទើបទ្រង់ឃើញថា បព្វជ្ជា ការទ្រង់ភេទជាបព្វជិតនៅតែម្នាក់ឯងនោះ មិនច្រឡំដោយហេតុដែលនាំឲ្យកើតសេចក្តីត្រេកអរទោមនស្ស ទើបព្រះអង្គលះសុខសម្បត្តិចេញ ទ្រង់ភេទជាបព្វជិត ស្វែងរកធម៌ដែលអស់ទុក្ខទាំងពួង ព្រោះហេតុដូច្នោះ ទើបលោកពោលថា ព្រះពុទ្ធអង្គកើត ២ ដង គឺកើតដោយរូបកាយម្តង កើតដោយនាមកាយម្តង គឺតាំងពីចុះកាន់ព្រះគភ៌ព្រះមាតា នៅក្នុងព្រះគភ៌ ១០ ខែ ហើយប្រសូតចាកព្រះគភ៌ ក្នុងព្រៃលុម្ពិនី ជាចន្ទោះទេវទហនគរ និងនគរកបិលពស្តុ មានព្រះកាយព្រមដោយទ្វត្តឹសមហាបុរិសលក្ខណៈ ដ៏គួរជាភាជនៈរងព្រះពុទ្ធគុណ ទ្រង់ព្រះនាមថា **សិទ្ធត្ថ**ៈ *នៅជារាជកុមារបាន ១៦ វស្សា ព្រះបិតាប្រគល់រាជ-សម្បត្តិឲ្យសោយនៅក្នុងប្រាសាទទាំង ៣ សមគួរដល់រដូវទាំង ៣ បាន ១៣ ឆ្នាំ ហើយទ្រង់លះឃរាវាសសម្បត្តិ ចេញទ្រង់ភេទជាបព្វជិត បំពេញសេចក្តីព្យាយាមស្វែងរកកឹកុសល[1] អស់ ៦ វស្សា ស្តេចយាងទៅគង់ក្រោមដើមអស្សត្ថព្រឹក្ស ដែលហៅថាដើមពោធិ៍ ប្រហនៃ្ទ*

1- កឹកុសល គឺសព្វញ្ញុតញ្ញាណ ។

នេរញ្ជរា ដរាបដល់សម្រេចវិជ្ជា ២ ខាងដើម និងវិបស្សនាញាណ រៀងរាបដរាបដល់គោត្រភូញាណ ទល់នឹងសោតាបត្តិមគ្គប៉ុណ្ណោះ ឈ្មោះថាកើតហើយដោយរូបកាយ តែហៅថាព្រះពុទ្ធមិនទាន់បាន ។ តាំងអំពីសោតាបត្តិមគ្គ សោតាបត្តិផល រហូតដល់អរហត្តមគ្គកើតឡើង ឈ្មោះថាកំពុងកើតដោយនាមកាយ តាំងអំពីអរហត្តផល គឺសេចក្តីជ្រាបច្បាស់នូវសង្ខារ កើតឡើងហើយ ឈ្មោះថាព្រះអង្គកើតហើយដោយនាមកាយ តែនៅមិនទាន់ឈ្មោះថា ព្រះអង្គរីកពេញទី ដ្ឋិតមិនទាន់បានបំពេញពុទ្ធកិច្ច តាំងអំពីព្រះអង្គទ្រង់សម្តែងព្រះធម្មចក្កប្បវត្តនសូត្រ ប្រោសបញ្ចវគ្គិយភិក្ខុ ដែលនៅក្នុងព្រៃឥសិបតនមិគទាយវ័ន ព្រះកោណ្ឌញ្ញត្ថេរបានសោតាបត្តិផល ដឹងច្បាស់នូវសង្ខារដោយឯកទេសតាមព្រះអង្គ ដរាបដល់ព្រះអង្គរំលត់ខន្ធ ដោយអនុបាទិសេសនិព្វានធាតុ ត្រង់ចន្លោះដើមរាំងទាំងគូក្នុងសាលវ័នឧទ្យានៃស្តេចមល្លៗជ ឈ្មោះថាព្រះអង្គរីកពេញទី ព្រោះបានបំពេញពុទ្ធកិច្ចជាស្រេចហើយ ។

បុ. អ្វីហៅថា **រូបកាយ** អ្វីហៅថា **នាមកាយ**?

វិ. មហាភូតរូប ៤ ឧបាទាយរូប ២៤ ឈ្មោះថា **រូបកាយ** ។ វេទនា សញ្ញា សង្ខារ វិញ្ញាណ ៤ នេះ ឈ្មោះថា **នាមកាយ** ។

បុ. នាមកាយមិនកើតព្រមគ្នានឹងរូបកាយទេ ឬ?

វិ. កើតព្រមគ្នា តែថានាមកាយ ដែលឲ្យកើតជាព្រះពុទ្ធ គឺ

អរហត្តមគ្គ អរហត្តផល ដែលជាសង្ខារក្ខន្ធ ដែលសម្ងាប់នាមកាយដ៏កាច មានលោភ:ជាដើម ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធនោះមិនទាន់កើត ទើបមិនហៅថា ជាព្រះពុទ្ធ ។ លុះតែអរហត្តមគ្គ អរហត្តផលកើតឡើងហើយ ទើបឈ្មោះថាព្រះពុទ្ធ ព្រោះហេតុនោះបានជាថាព្រះពុទ្ធកើតពីរដង ។

បុ. ព្រះអង្គស្វែងរកកុសលធម៌នោះ ដូចម្តេច?

*វិ. ព្រះអង្គស្វែងរកដោយឧបាយផ្សេងៗ ដរាបដល់អត់ដង្ហើមផ្តាច់បង់ទូវអាហារក៏មិនបានសម្រេចធម៌វិសេសណាមួយ លុះកាលជាឯក្រោយ ព្រះអង្គទើបទ្រង់នឹកឃើញដល់អានាបានស្សតិឈាន ដែលព្រះអង្គបានកាលនៅជាកុមារម្តង ជារបស់អស្ចារ្យចម្លែកណាស់ ឃើញថាជាផ្លូវនៃសេចក្តីត្រាស់ដឹងបាន ទើបព្រះអង្គត្រឡប់សោយអាហារវិញ ហើយស្តេចយាងទៅគង់ក្រោមដើមអស្សត្ថព្រឹក្ស ចម្រើនអានាបានស្សតិ គឺតាំងសតិធ្លោះដង្ហើមចេញចូលតែម្យ៉ាង មិនបានបញ្ជូនចិត្តទៅកាន់ទីដទៃ រំងាប់ **កាមឆន្ទ** សេចក្តីស្រឡាញ់ សេចក្តីគាប់ចិត្ត **ព្យាបាទ** បំណងញ៉ាំងសត្វឲ្យវិនាស **ថីនមិទ្ធ** សេចក្តីងុយដោកងក់ **ឧទ្ធច្ច-កុក្កុច្ច** សេចក្តីអណ្តែតអណ្តូងរាយមាយចិត្ត **វិចិកិច្ឆា** សេចក្តីសន្ទិះសង្ស័យ ទាំងអម្បាលនេះដែលជានីវរណ: គ្រឿងឃាត់សមាធិ គ្រឿងសៅហ្មងចិត្តជារបស់ធ្វើប្រាជ្ញាឲ្យវិនាសទៅ ទើបបានបឋមជ្ឈាន*

ជាឈានប្រកបដោយអង្គ ៥ គឺវិតក្ក: វិចារ: បីតិ សុខ: ឯកគ្គតា ចាស់ក្លាជាងចេតសិកធម៌ដទៃ ហើយព្រះអង្គធ្វើព្យាយាមចម្រើនៗ ឡើងទៅដោយលំដាប់ រំងាប់វិតក្ក: វិចារ: ជារបស់ជ្រោកជ្រាកចេញ សល់នៅតែ បីតិ សុខ: ឯកគ្គតា ជាទុតិយជ្ឈាន ហើយរំងាប់បីតិ ជារបស់ជ្រោកជ្រាកចេញ សល់នៅតែសុខ: និងឯកគ្គតា ជាតតិយជ្ឈាន ហើយលះសុខ: ជារបស់ជ្រោកជ្រាកចេញ សល់នៅតែឯកគ្គតា និងឧបេក្ខា ដែលខ្លាំងក្លាជាចតុត្ថជ្ឈាន ហើយព្រះអង្គធ្វើឈានទាំង ៤ នោះ ឲ្យស្ងាត់ជំនាញដោយការនឹកនិងការចូលជាដើម លុះចិត្តថ្លាបរិសុទ្ធ ល្អិតល្អដោយអំណាចចតុត្ថជ្ឈានហើយ ទើបព្រះអង្គបង្ហោនព្រះទ័យទៅដើម្បីបុព្វេនិវាសានុស្សតិញាណ គឺបញ្ញាដែលរឭកតាមលំដាប់ខន្ធនៃព្រះអង្គ និងសត្វដទៃដែលធ្លាប់នៅហើយក្នុងជាតិមុន ភពមុន គឺរឭកបាននូវអតីតជាតិ តាំងអំពីជាតិទី ១ លុះដល់អនេកសំវដ្ដវិវដ្ដកប្ប ។ សេចក្ដីសង្ស័យថា ភពមុន ជាតិមុន មានឬមិនមាននោះ ក៏អស់ទៅ ទ្រង់ឃើញច្បាស់ថា ជាតិមុន ភពមុន មានប្រាកដពិត តែទ្រង់ឃើញថា សង្សារវដ្ដមានខាងដើម សូម្បីបុគ្គលរឭកតាមទៅក៏មិនដឹង ដូច្នេះឈ្មោះ ថាវិជ្ជាជាបឋម ព្រះអង្គបានក្នុងបឋមយាម លុះមជ្ឈិមយាម ទ្រង់បង្ហោនព្រះទ័យទៅដើម្បីចុតូបបាតញ្ញាណ គឺប្រាជ្ញាដែលជ្រាប ដែលឃើញចុតិបដិសន្ធិនៃសត្វ ព្រះអង្គក៏បានឃើញសត្វទាំងឡាយ ដែល

ប្រព្រឹត្តទុច្ចរិតទាំង ៣ ប្រកបដោយមិច្ឆាទិដ្ឋិ លុះចុតិហើយទៅកើតក្នុងអបាយភូមិ ដោយអកុសលកម្មនោះ និងសត្វទាំងឡាយ ដែលប្រព្រឹត្តសុចរិតទាំង ៣ ប្រកបដោយសម្មាទិដ្ឋិ លុះចុតិហើយទៅកើតក្នុងសុគតិភូមិ ដោយកុសលកម្មនោះ ព្រះអង្គជ្រាបច្បាស់ដោយទិព្វចក្ខុ-ញាណដូច្នេះ ។

សេចក្តីសង្ស័យថា ធម្មជាតិអ្វីជារបស់តាក់តែងសត្វឲ្យបានល្អបានអាក្រក់ និងសេចក្តីសង្ស័យថា ជាតិមកអំពីណាក៏អស់ទៅ ដោយឃើញច្បាស់ថា កម្មគឺបុណ្យនិងបាប ជារបស់តាក់តែងសត្វឲ្យល្អអាក្រក់ ជាតិមកអំពីកម្មភព នេះជាវិជ្ជាគម្រប់ ២ ព្រះអង្គបានក្នុងមជ្ឈិម-យាម លុះវិជ្ជាទាំង ២ ជម្រះផ្លូវប្រាជ្ញាឲ្យបរិសុទ្ធហើយ ទើបព្រះអង្គបង្អោនព្រះទ័យទៅដើម្បីអាសវក្ខយញ្ញាណ ប្រាជ្ញាជ្រាបនូវធម៌ជាគ្រឿងធ្វើឲ្យក្សីយទៅនៃអាសវៈ បានដល់មគ្គផលនិព្វាន គឺព្រះអង្គប្រារព្ធនូវជរា ព្យាធិ មរណៈ ដែលជាទុក្ខ ដូចភ្ញើងដុតសត្វដែលបានឃើញអំពីមុននោះ ទើបពិចារណារកបច្ច័យនៃទុក្ខនោះ ក៏បានឃើញថា ជរា ព្យាធិ មរណៈ នោះកើតអំពីជាតិ ជាតិកើតអំពីកម្មភព គឺកុសល អកុសល ភពកើតអំពីឧបាទាន សេចក្តីប្រកាន់ខ្ជាប់ ៤ ប្រការ គឺ កាម ទិដ្ឋិ សីលព្វត អត្តវាទ ឧបាទាន ៤ នេះកើតអំពីតណ្ហា គឺសេចក្តីតក់ស្ទុត ដោយសេចក្តីប្រាថ្នា តណ្ហាកើតអំពីវេទនា គឺការទទួលរសអារម្មណ៍ជាសុខជាទុក្ខ និងឧបេក្ខា

វេទនាកើតអំពីផស្ស: គឺសេចក្ដីពាល់ត្រូវដោយទ្វារ មានចក្ខុទ្វារជាដើម និងញាណមានចក្ខុវិញ្ញាណជាដើម និងអារម្មណ៍មានរូបារម្មណ៍ជាដើម លុះកើតព្រមគ្នាដូច្នេះ ហៅថាផស្ស: ផស្ស:កើតអំពីអាយតន: ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត អាយតន: ៦ កើតអំពីនាមរូប (សភាវ:ដែលបង្ហោនទៅរកអារម្មណ៍បាន ឈ្មោះថានាម សភាវ:ដែលវិបត្តិទៅដោយរដូវមានក្ដៅណាស់ ត្រជាក់ណាស់ជាដើម ឈ្មោះថារូប) នាមរូបកើតអំពីវិញ្ញាណ គឺបដិសន្ធិចិត្ត វិញ្ញាណកើតអំពីសង្ខារ របស់តាក់តែងសត្វឲ្យល្អ អាក្រក់ គឺកុសលនិងអកុសល សង្ខារកើតអំពីអវិជ្ជា គឺសេចក្ដីមិនដឹងច្បាស់ថានេះទុក្ខ នេះហេតុឲ្យកើតទុក្ខ នេះទីរំលត់ទុក្ខ នេះផ្លូវឲ្យដល់នូវទីរំលត់ទុក្ខ ហើយព្រះអង្គឃើញថាអវិជ្ជា និងតណ្ហាទាំង ២ នេះ ជាឫសគល់នៃសង្សារវដ្ដ ហើយទើបខំចម្រើនវិបស្សនាឲ្យលើសលប់ឡើងទៅ ដើម្បីលះអវិជ្ជា តណ្ហានោះ ។

ឃ. ព្រះអង្គចម្រើនវិបស្សនានោះដូចម្ដេច?

វ. ព្រះអង្គទ្រង់ចាប់ អវិជ្ជា សង្ខារ វិញ្ញាណ នាមរូប អាយតន: ផស្ស: វេទនា តណ្ហា ឧបាទាន ភព ជាតិ ទាំងអស់នេះមួយៗ ឡើងពិចារណានឹកវិនិច្ឆ័យថា មិនមែនសត្ត្ব មិនមែនបុគ្គល មិនមែនខ្លួន មិនមែនប្រាណ មិនមែនគេ មិនមែនយើង ជាសភាវ:មួយៗ អាស្រ័យគ្នានិងគ្នា កើតឡើងហើយរលត់ទៅ រលត់ទៅហើយកើតឡើង កាល

អវិជ្ជាមាន ជាបច្ច័យឲ្យកើតសង្ខារ សង្ខារមាន ជាបច្ច័យឲ្យកើតវិញ្ញាណ វិញ្ញាណមាន ជាបច្ច័យឲ្យកើតនាមរូប នាមរូបមាន ជាបច្ច័យឲ្យកើត អាយតនៈ អាយតនៈមាន ជាបច្ច័យឲ្យកើតផស្សៈ ផស្សៈមាន ជាបច្ច័យឲ្យ កើតវេទនា វេទនាមាន ជាបច្ច័យឲ្យកើតតណ្ហា តណ្ហាមាន ជាបច្ច័យឲ្យ កើតឧបាទាន ឧបាទានមាន ជាបច្ច័យឲ្យកើតភព ភពមាន ជាបច្ច័យឲ្យ កើតជាតិ ជាតិមាន ជាបច្ច័យឲ្យកើតទុក្ខ គឺជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ ដូចជាកូនដុតឲ្យក្តៅគ្រប់ភពគ្រប់ជាតិ នេះជាធម៌អាស្រ័យគ្នានិងគ្នាកើតឡើងដូច្នេះ វិលវល់ក្នុងសង្សារវដ្ត នឹង ថារបស់អ្វីជាខាងដើម កណ្តាល ខាងចុង នោះមិនបាន ថាបានតែកងទុក្ខ ប៉ុណ្ណោះ កើតឡើងហើយរលត់ទៅ វិលវល់នៅក្នុងសង្សារវដ្ត នឹងថាសត្ត ថាបុគ្គលរងទុក្ខនោះមិនបាន ព្រោះថាសភាវៈមួយៗ អាស្រ័យគ្នានិងគ្នា កើតឡើងប៉ុណ្ណោះ ហើយព្រះអង្គឃើញថានេះជាទុក្ខ ទុក្ខនេះនឹងគប្បី កំណត់ដឹងបានពិត ហើយព្រះអង្គបានកំណត់ដឹងដោយបរិញ្ញាភិសម័យ ដូច្នេះ ហើយព្រះអង្គដឹងថា អវិជ្ជា តណ្ហា ពីរនេះឯងជាឫសគល់នៃ សង្សារវដ្ត ជាហេតុឲ្យកើតកងទុក្ខដូចពោលមកនេះ អវិជ្ជា តណ្ហានេះ គប្បីលះបានពិត ព្រះអង្គលះបង់បានដោយបហានាភិសម័យ ព្រះអង្គ ឃើញថារំលត់អវិជ្ជា តណ្ហា ២ នេះបានហើយ សង្ខារ វិញ្ញាណ នាមរូប ជាដើមដែលជាផលក៏រលត់អស់ ធម៌ជាទីរំលត់ទុក្ខនេះ នឹងគប្បីឃើញ

ច្បាស់ដោយពិត ព្រះអង្គឃើញច្បាស់នូវធម៌ដែលរំលត់ទុក្ខបានដោយ សច្ចិកិរិយាកិសម័យ ព្រះអង្គឃើញថាបញ្ញាការឃើញយ៉ាងនេះជាផ្លូវឲ្យ ដល់នូវទីរំលត់ទុក្ខ បញ្ញានេះជារបស់នឹងគប្បីឲ្យមានឲ្យចម្រើនឡើងបាន ពិត ហើយព្រះអង្គបានធ្វើឲ្យមានឲ្យចម្រើនឡើងដោយភាវនាកិសម័យ ។ ការកំណត់ដឹងទុក្ខ លះអវិជ្ជា តណ្ហា ឃើញព្រះនិព្វានច្បាស់ ដោយ ការកើតឡើងនៃមគ្គចិត្ត យ៉ាងនេះ កើតឡើងក្នុងខណៈចិត្តតែមួយ ឈ្មោះថាមគ្គកើតឡើង មគ្គនេះកើតឡើងក្នុងកាលណា កាលនោះ អាសវៈទាំង ៣ ជាគ្រឿងត្រាំក្នុងសន្ដានគឺ កាមាសវៈ ភវាសវៈ ជាតួ តណ្ហា មួយអន្ទើដោយអវិជ្ជាសវៈក៏អស់សូន្យទៅ ផលកើតឡើង រំងាប់ ថែមម្ដងទៀត មគ្គផលនេះឯងឈ្មោះថា អាសវក្ខយញ្ញាណ បញ្ញាដឹង សេចក្ដីអស់ទៅនៃអាសវៈគ្រឿងត្រាំក្នុងសន្ដាន អាសវក្ខយញ្ញាណនេះ ឈ្មោះថាវិជ្ជាគម្រប់ ៣ ព្រះអង្គបានក្នុងវេលាបច្ចូសសម័យនៃថ្ងៃវិសាខ បុណ្ណមី ។ ដូចពោលមកនេះ ឈ្មោះថាព្រះអង្គស្វែងរកធម៌ជាទី អស់ទៅនៃទុក្ខ ។

ឃ. អ្វីជាហេតុបណ្ដាលឲ្យព្រះអង្គឃើញ **ជរា ព្យាធិ មរណៈ** ជាទុក្ខ ដូចជាភ្លើងដុតព្រះអង្គនិងសត្វដទៃ ឲ្យក្ដៅព្រះហឫទ័យ លះសុខ-សម្ប្ដត្ដិចោលចេញ ស្វែងរកធម៌ដែលរំលត់ទុក្ខដូច្នេះ ជនដទៃហេតុអ្វី មិនឃើញដូចព្រះអង្គនោះ?

វិ. ព្រះអង្គធ្វាប់សង្កត់សង្កិនញ៉ាំញ៉ីសង្ខារ ឃើញសេចក្តីពិត ៣ ប្រការគឺ **អនិច្ចតា** សភាពជារបស់មិនទៀង **ទុក្ខតា** សភាពជាទុក្ខ **អនត្តតា** សភាពជារបស់មិនមែនខ្លួនប្រាណ ដោយប្រាជ្ញានិងធ្វាប់បំពេញកុសលដទៃ មាន ទាន សីល ជាដើម មកក្នុងភពមុនជាច្រើនអស់កាលយូរ ទើបទ្រង់បានឧបនិស្សយ ដែលបណ្តាលឲ្យព្រះអង្គឃើញដូច្នេះ ហើយស្វែងរកធម៌ដែលអស់ទុក្ខ ។ ឯជនដទៃមិនបានប្រតិបត្តិដូចព្រះអង្គ ទើបឃើញវត្ថុនៃសេចក្តីទុក្ខ ថាជាវត្ថុនៃសេចក្តីសុខ ហើយក៏រវៃងនៅក្នុងវត្ថុនោះ ។ ។

ឃ. ក្នុងបុព្វសិក្ខាថា ព្រះអង្គត្រាស់ដឹងសម្មាសម្ពោធិញ្ញាណដោយលះនីវរណៈ ៥ តាំងព្រះហឫទ័យស្ថិតនៅក្នុងសតិបដ្ឋាន ៤ ចម្រើនពោជ្ឌង្គ ៧ ទើបបានត្រាស់ជាព្រះពុទ្ធ ។ ក្នុងបទនេះថា ត្រាស់ដឹងបានដោយវិជ្ជា ៣ ទើបហៅថាព្រះពុទ្ធ ហេតុដូចម្តេចបានជាមិនដូចគ្នា?

វិ. គ្រាន់តែជាទេសនាមុខប៉ុណ្ណោះ ដោយអត្ថ ពាក្យទាំងពីរនោះ បញ្ជូលគ្នាក៏ដូចគ្នា នឹងពោលឲ្យច្បាស់ នីវរណៈ ៥ គឺ **កាមឆន្ទ** សេចក្តីស្រឡាញ់និងគាប់ចិត្តក្នុងកាមគុណ ១ **ព្យាបាទ** បំណងញ៉ាំងសត្វឲ្យវិនាស ១ **ថីនមិទ្ធ** សេចក្តីដោកងក់ងុយដេក ១ **ឧទ្ធច្ច-កុក្កុច្ច** សេចក្តីអណ្តែតអណ្តូងរាយមាយ ១ **វិចិកិច្ឆា** សេចក្តីសន្ទិះសង្សយ ១ ទាំង ៥ នេះ ហៅថានីវរណៈ ព្រោះជារបស់ឃាត់កុសលធម៌

មានសមាធិជាដើម មិនឲ្យកើតឡើងបាន ជារបស់ធ្វើចិត្តឲ្យសៅហ្មង ជារបស់ធ្វើប្រាជ្ញាឲ្យបង់កម្ទាំង ព្រះអង្គលះនីវរណៈ ទាំង ៥ នេះ ដោយ វិក្ខម្ភនបហានៈ គឺសង្កេតទុកដោយអានាបានស្សតិឈានជាមុន ហើយ កាលមគ្គកើតឡើងសម្ងាប់អវិជ្ជា តណ្ហា ដែលជាប្រធាននៃកិលេស ជា ឫសគល់នៃសង្ខារវដ្តស្ងាប់ហើយ នីវរណៈ ៥ ដែលជាកិលេស រាប់ចូល ក្នុង អវិជ្ជា តណ្ហានោះ ក៏ស្ងាប់បង់ដោយសមុច្ឆេទបហានៈដែរ ព្រោះ ហេតុនោះទើបឈ្មោះថាលះនីវរណៈ ៥ ។

សតិបដ្ឋាន ៤ គឺ **កាយានុបស្សនា** *ការឃើញរឿយៗ នូវកាយ ថាជារបស់អស់ទៅ និងសូន្យទៅ ១* **វេទនានុបស្សនា** *ការឃើញរឿយៗ នូវវេទនា ថាជារបស់អស់ទៅ និងសូន្យទៅ ១* **ចិត្តានុបស្សនា** *ការឃើញរឿយៗ នូវចិត្ត ថាជារបស់អស់ទៅនិង សូន្យទៅ ១* **ធម្មានុបស្សនា** *ការឃើញរឿយៗ នូវធម៌ ថាជា របស់អស់ទៅ និងសូន្យទៅ ១ ទាំង ៤ នេះឈ្មោះថាសតិបដ្ឋាន ។* **សតិបដ្ឋាន** *ប្រែថា ការតម្កល់ទុកនូវសតិ ឬថាសតិចូលទៅតាំង នៅក្នុងអារម្មណ៍ សតិ ប្រែថា សេចក្តីរឭក សតិនេះជាតួចេតសិក តែ ១ មិនមែន ២ ហេតុដូចម្តេចទើបឈ្មោះថាសតិបដ្ឋាន ៤ ដូច្នេះ ដែលពោលថាសតិបដ្ឋាន ៤ នោះ ដោយអំណាចអារម្មណ៍ជាទីចូលទៅ តាំងនៅនៃសតិ អារម្មណ៍នៃសតិនោះមាន ៤ គឺ កាយ ១ វេទនា ១*

ចិត្ត ១ ធម៌ ១ សតិប្រារព្ធយកឯកទេសនៃកាយ មានខ្យល់ដង្ហើមចេញចូលជាដើម ឬប្រារព្ធសកលកាយ មាន សក់ ពោម ក្រចក ធ្មេញជាដើម ជាអារម្មណ៍ និងឃើញការអស់ទៅសូន្យទៅ និងការកើតរលត់នៃកាយ ឬឃើញថា កាយជារបស់បដិកូល ឬឃើញថាគ្រាន់តែជាធាតុក្តី ឬឃើញថាគ្រាន់តែជាកាយក្តី ដូច្នេះឈ្មោះថាកាយានុបស្សនាសតិបដ្ឋាន ។ សតិប្រារព្ធយកវេទនា ៣ គឺ សុខ ទុក្ខ ឧបេក្ខា ណាមួយជាអារម្មណ៍ ហើយឃើញការអស់ទៅសូន្យទៅ និងការកើតរលត់នៃវេទនា ឬឃើញថាគ្រាន់តែជាវេទនាប៉ុណ្ណោះ ដូច្នេះឈ្មោះថា វេទនានុបស្សនាសតិ-បដ្ឋាន ។ សតិប្រារព្ធយកចិត្តប្រកបដោយរាគ:ត្រេកអរ ឬចិត្តប្រាសចាករាគ:ជាដើម ណាមួយជាអារម្មណ៍ ឬឃើញការអស់ទៅសូន្យទៅ និងការកើតរលត់នៃចិត្ត ឬឃើញថាគ្រាន់តែជាចិត្តប៉ុណ្ណោះ ដូច្នេះឈ្មោះថា ចិត្តានុបស្សនាសតិបដ្ឋាន ។ សតិប្រារព្ធយកធម៌គឺ ឧបាទាយរូប ឬសញ្ញា ឬសង្ខារក្ខន្ធដែលផុតចាក កាយ វេទនា ចិត្ត ណាមួយជាអារម្មណ៍ និងឃើញការអស់ទៅសូន្យទៅ និងការកើតរលត់នៃធម៌ ឬឃើញថាគ្រាន់តែជាធម៌ប៉ុណ្ណោះ ដូច្នេះឈ្មោះថា ធម្មានុបស្សនាសតិ-បដ្ឋាន ។

ក៏ក្នុងអង្គនៃបដិច្ចសមុប្បាទ ១២ មានអវិជ្ជាជាដើម មាន ជរ មរណ: ជាទីបំផុតនោះ អវិជ្ជា សង្ខារ អាយតន: ផស្ស: តណ្ហា ឧបាទាន

ភព ឧបាទាយរូបក្នុងរូប និងសញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយ៍ក្នុងនាម ឬក្នុងឧបបត្តិភព និងជាតិឈ្មោះថាជាធម៌ វិញ្ញាណនោះឈ្មោះថាជាចិត្ត វេទនាឈ្មោះថាជាវេទនា មហាភូតរូបក្នុងរូប ឬក្នុងឧបបត្តិភព និងជាតិ ឈ្មោះថាជាកាយ ព្រោះហេតុនោះព្រះដ៏មានព្រះភាគ កាលព្រះអង្គ លើកអង្គនៃបដិច្ចសមុប្បាទ មានអវិជ្ជាជាដើម មួយៗ ឡើងពិចារណា វិនិច្ឆ័យដូចពោលមកហើយក្នុងកាលមុន ឈ្មោះថាព្រះអង្គតាំងព្រះហ្ឫទ័យ ឆ្ពោះដោយប្រពៃក្នុងសតិបដ្ឋាន ៤ ។

ពោជ្ឈង្គ *ប្រែថា អង្គជាហេតុនៃសេចក្តីត្រាស់ដឹងច្បាស់នូវ សង្ខារ ពោជ្ឈង្គ ៧ នោះគឺ* **សតិ** *សេចក្តីរឭក បានដល់សតិបដ្ឋាន នោះឯង* **ធម្មវិចយ** *សេចក្តីជ្រើសរើសរកនូវធម៌ថា នេះជាកុសល នេះជាអកុសលជាដើម បានដល់ប្រាជ្ញាដែលប្រារព្ធនូវអង្គនៃបដិច្ច-សមុប្បាទ មានអវិជ្ជាជាដើម និងអារម្មណ៍នៃសតិបដ្ឋាន មានកាយជាដើម ជាអារម្មណ៍ និងឃើញការអស់ទៅសូន្យទៅនៃអារម្មណ៍នោះឯង* **វីរិយ** *សេចក្តីព្យាយាមដ៏ខ្លាំងក្លា បានដល់ការលះអកុសលមាននីវរណៈ ៥ ជា ដើម និងធ្វើកុសលមានសតិបញ្ញាជាដើមឲ្យកើតឡើង* **ปีติ** *សេចក្តីឆ្អែត ចិត្តក្នុងកុសលធម៌ ដែលបានដោយសតិ និងធម្មវិចយៈនោះ* **ปัสสัทธิ** *សេចក្តីស្ងប់កាយស្ងប់ចិត្ត បានដល់សេចក្តីមិនក្រវល់ក្រវាយចិត្តចេតសិក ក្នុងខណៈកុសលធម៌មានសតិ បញ្ញា និង សមាធិជាដើមកើតឡើង*

សមាធិ សេចក្តីតាំងចិត្តក្នុងអារម្មណ៍តែមួយ បានដល់ឯកគ្គតាអប្បនា-ឈាន ទាំង ៤ នោះ **ឧបេក្ខា** សេចក្តីសំឡឹងដោយឧប្បត្តិ បានដល់ការមិនខ្ជិលខ្ជាយក្នុងទីនិងតាំងចិត្តឲ្យជាសមាធិទៀត គ្រាន់តែសំឡឹងនូវចិត្តដែលស្ងប់ហើយប៉ុណ្ណោះ ធម៌ទាំង ៧ នេះឈ្មោះថាពោជ្ឌង្គ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ធ្វើដំណើរក្នុងវិជ្ជា ៣ ហើយដល់នូវសេចក្តីត្រាស់ដឹងជ្រាបច្បាស់នូវសង្ខារ ក៏ឈ្មោះថាព្រះអង្គចម្រើនពោជ្ឌង្គ-៧ ។ ឯពាក្យថា ចម្រើនពោជ្ឌង្គ ៧ នោះ ជាពាក្យពោលដោយនិរវសេសកំណត់តាមពោជ្ឌង្គនិយម តែថាក្នុងខណៈអរហត្តមគ្គ អរហត្តផលកើតឡើងដល់ព្រះមានព្រះភាគនោះ ព្រះអង្គដល់នូវសេចក្តីត្រាស់ដឹងច្បាស់នូវសង្ខារនោះ គឺឈ្មោះថាព្រះអង្គចម្រើនពោជ្ឌង្គបានតែ ៦ ព្រោះបីតិពោជ្ឌង្គព្រះអង្គបានលះបង់ហើយ ដោយតតិយជ្ឌាន ។

១ ទៀត កិច្ចក្នុងព្រហ្មចរិយៈពោលដោយសង្ខេបមាន ២ គឺបហានៈ និងភាវនា ពាក្យថាព្រះមានព្រះភាគ លះនីវរណៈ ៥ នោះ ជាពាក្យសម្តែងបហានកិច្ច ថាមិនលះតែនីវរណៈ ៥ ប៉ុណ្ណោះទេ បានលះទាំងអាសវៈ ៣ ដោយវិក្ខម្ភនបហានៈ សង្កត់ទុកដោយវិជ្ជា ២ ខាងដើម និងដោយសមុច្ឆេទបហានៈ លះដាច់ប្រាកដដោយវិជ្ជាទី ៣ ផង ពាក្យថាព្រះមានព្រះភាគចម្រើនពោជ្ឌង្គ ៧ នោះ ជាពាក្យសម្តែងភាវនាកិច្ច

ថាមិនមែនតែចម្រើនពោជ្ឌង្គ ៧ ប៉ុណ្ណោះទេ ព្រះអង្គធ្វើទាំងវិជ្ជា ៣ ឲ្យ
ចម្រើនឡើងផង ។

ពាក្យថា ព្រះមានព្រះភាគតាំងព្រះហឫទ័យក្នុងសតិបដ្ឋាន ៤ នោះ
ជាពាក្យសម្តែងបដិបទាផ្លូវបដិបត្តិ ដែលឲ្យកើតបហាន: និងភាវនា ។
ព្រះមានព្រះភាគទ្រង់សម្តែងសតិបដ្ឋាន ៤ មិនតឹងមិនធូរ តាមចរិតរបស់
បុគ្គលនោះៗ ។ ក៏ឯចរិតរបស់បុគ្គល ពោលដោយសង្ខេបមាន ២ ជំពូកគឺ
តណ្ហាចរិត ១ ទិដ្ឋិចរិត ១ ។ តណ្ហាចរិតមាន ២ គឺ ជ្រោកជ្រាក ១ ល្អិត ១ ។
ទិដ្ឋិចរិតក៏មាន ២ គឺ ជ្រោកជ្រាក ១ ល្អិត ១ ។ កាយានុបស្សនាសតិ-
បដ្ឋាន ជាទីសប្បាយរបស់បុគ្គលជាតណ្ហាចរិតជ្រោកជ្រាក វេទនានុ-
បស្សនាសតិបដ្ឋាន ជាទីសប្បាយរបស់បុគ្គលជាតណ្ហាចរិតល្អិត ចិត្តានុ-
បស្សនាសតិបដ្ឋាន ជាទីសប្បាយរបស់បុគ្គលជាទិដ្ឋិចរិត ជ្រោកជ្រាក
ធម្មានុបស្សនាសតិបដ្ឋាន ជាទីសប្បាយរបស់បុគ្គលជាទិដ្ឋិចរិតល្អិត ។
ឯពាក្យថា លះនីវរណៈ ៥ តាំងព្រះហឫទ័យក្នុងសតិបដ្ឋាន ៤ និងចម្រើន
ពោជ្ឌង្គ ៧ ធម៌ ៣ នេះ នីមួយៗ ក្នុងកាលជាបុព្វភាគ រមែងកើតមាន
ក្នុងខណៈចិត្តផ្សេងៗ គ្នាខ្លះ តែក្នុងកាលមគ្គកើតឡើង រមែងកើតមាន
ក្នុងខណៈចិត្តជាមួយគ្នា ដោយពាក្យថា ព្រះមានព្រះភាគលះនីវរណៈ ៥
តាំងព្រះហឫទ័យក្នុងសតិបដ្ឋាន ៤ ចម្រើនពោជ្ឌង្គ ៧ ហើយត្រាស់ដឹង
សម្មាសម្ពោធិដូច្នេះនោះ សម្តែងថាព្រះមានព្រះភាគ កាលនៅជាព្រះ

ពោធិសត្វនោះ ទ្រង់ប្រកបដោយទិដ្ឋិចរិតយ៉ាងល្អិត និងតាំងព្រះហឫទ័យ ក្នុងធម្មានុបស្សនាសតិបដ្ឋានដោយច្រើន ក្នុងកាលជាបុព្វភាគ ព្រោះ កុសលធម៌និងអកុសល ២ នេះ ពោលដោយសង្ខេប ឈ្មោះថាធម៌ជា អារម្មណ៍នៃធម្មានុបស្សនាសតិបដ្ឋាន ។

ឯអកុសលធម៌លើកនីវរណៈ ៥ ឡើងជាប្រធាន ខាងកុសលធម៌ លើកពោជ្ឈង្គ ៧ ឡើងជាប្រធាន ។ មួយទៀត បុគ្គលមានប្រាជ្ញាច្រើន រមែងប្រកបដោយទិដ្ឋិចរិតយ៉ាងល្អិត ដ្ឋិតក្នុងវិជ្ជាទី ៣ ពោលថា ព្រះ មានព្រះភាគធ្វើអង្គនៃបដិច្ចសមុប្បាទមានអវិជ្ជាជាដើម ឲ្យជាអារម្មណ៍នៃ វិបស្សនាញាណនោះ សម្តែងថាព្រះមានព្រះភាគ កាលនៅជាពោធិសត្ត នោះ ព្រះអង្គប្រកបដោយលោកិយបញ្ញាច្រើន ជាទិដ្ឋិចរិតដ៏ល្អិត និងតាំង ព្រះហឫទ័យក្នុងធម្មានុបស្សនាសតិបដ្ឋាន ដោយច្រើន ក្នុងកាលជាបុព្វភាគ ព្រោះអង្គបដិច្ចសមុប្បាទមានអវិជ្ជាជាដើម ឈ្មោះថាធម៌ជាអារម្មណ៍នៃ ធម្មានុបស្សនាសតិបដ្ឋានដោយច្រើន ដែលសម្តែងមកទាំងនេះ ដើម្បី នឹងឲ្យដឹងថា ពាក្យដែលសម្តែងថា ព្រះមានព្រះភាគបានលះនីវរណៈ ៥ តាំងព្រះហឫទ័យក្នុងសតិបដ្ឋាន ៤ ចម្រើនពោជ្ឈង្គ ៧ ទើបបានត្រាស់ ជាព្រះពុទ្ធ ប្រកបនឹងពាក្យថា ព្រះពុទ្ធទ្រង់ធ្វើដំណើរក្នុងវិជ្ជាទាំង ៣ ទើបបានត្រាស់ជាព្រះពុទ្ធ ពាក្យទាំង ២ នេះ ត្រូវគ្នាមិនខុសគ្នាឡើយ អ្នកប្រាជ្ញគប្បីដឹងថា ពាក្យដែលពណ៌នាអំពីការកើតនៃព្រះពុទ្ធរតនៈមក

ដូច្នេះ ដើម្បីនឹងឲ្យដឹងសេចក្ដីអធិប្បាយក្នុងបុព្វសិក្ខា ដែលសម្ដែងទុកដោយសង្ខេបថា ព្រះមានព្រះភាគនោះ ព្រះអង្គកើតហើយក្នុងពួកមនុស្សអរិយកៈ ក្នុងមជ្ឈិមប្រទេស ដោយព្រះជាតិជាក្សត្រិយ៍ ដោយគោត្រជាគោតមគោត្រ ជាបុត្រសក្យៈ ចេញចាកសក្យៈត្រកូលបួសហើយ ព្រះអង្គស្វែងរកកឹកុសលសន្ដិវរបទ ចំណែកធម៌រំងាប់ទុក្ខដ៏ប្រសើរ មិនមានធម៌ដទៃលើសលប់ជាង ព្រះអង្គបានលះនីវរណៈ ៥ ជាគ្រឿងសៅហ្នងចិត្ត ជារបស់ធ្វើប្រាជ្ញាឲ្យបង់កម្លាំង ព្រះអង្គមានព្រះហឫទ័យតាំងស៊ប់ក្នុងសតិបដ្ឋានទាំង ៤ ញ៉ាំងពោជ្ឈង្គទាំង ៧ ឲ្យកើត ឲ្យចម្រើនឡើងដោយជាក់ច្បាស់ ហើយសម្រេចសម្មាសម្ពោធិញ្ញាណ បញ្ញាជាគ្រឿងត្រាស់ដឹងឯងប្រពៃ ដ៏ប្រសើរមិនមាននរណាលើស ក្រោមដើមអស្សត្ថព្រឹក្សមហាពោធិដ្ឋាន ប្រហនេ្ទរស្ទឹងនេរញ្ជរា ដូច្នេះ ។

ឃ. ព្រះពុទ្ធមានគុណដូចម្ដេច?

វ. ព្រះពុទ្ធមានគុណច្រើនជាអនេកពុំអាចនឹងពណ៌នាបាន ធំក្រៃលែងធំ ដូចផែនដីនិងផ្ទៃអាកាស មនុស្សយើងនឹងពណ៌នាគុណព្រះពុទ្ធនោះ បីដូចជាសត្វស្វាបតូចហើរក្នុងអាកាស មិនអាចនឹងពណ៌នាឲ្យអស់ឲ្យផុតបាន សូម្បីបូរាណកាសិតលោកក៏បានពោលទុកថា សូម្បីព្រះពុទ្ធដូចគ្នា ពុំបានសម្ដែងរឿងដទៃឡើយ សម្ដែងតែគុណព្រះពុទ្ធផងគ្នាប៉ុណ្ណោះអស់មួយកប្ប កប្បនោះនឹងអស់ទៅទទេក្នុងចន្ទោះ គុណ

របស់ព្រះតថាគត ក្នុងចន្លោះកាលដ៏យូរប៉ុណ្ណោះមិនអស់ឡើយ ។ ព្រោះហេតុនោះឯងទើបថាគុណព្រះពុទ្ធច្រើនក្រៃលែងច្រើន មិនអាចនឹងពណ៌នាបាន បើកាត់ឲ្យខ្ជីមាន ៣ យ៉ាងគឺ ព្រះបញ្ញាគុណ ១ ព្រះវិសុទ្ធិគុណ ១ ព្រះករុណាគុណ ១ ប៉ុណ្ណោះឯងជាប្រធាននៃគុណទាំងពួង គុណទាំងពួងក៏ប្រជុំចុះក្នុងគុណទាំង ៣ នេះទាំងអស់ ។

ក៏ឯព្រះបញ្ញាគុណនោះ បានដល់សេចក្ដីដឹងច្បាស់នូវសង្ខារដូចពោលមកហើយ គឺ មគ្គញ្ញាណ ដែលជាទីតាំងនៃសព្វញ្ញុតញ្ញាណ មួយអន្ទើដោយញ្ញាណដ៏សេស មានចតុវេសារជ្ជញ្ញាណ ទសពលញ្ញាណ អនាវរណញ្ញាណជាដើម ដែលកើតអំពីមគ្គញ្ញាណ ឲ្យសម្រេចគុណដល់សត្វលោក គឺជ្រាបថា របស់នេះជាប្រយោជន៍ របស់នេះមិនជាប្រយោជន៍ដល់សត្ត។ របស់ដែលមិនជាប្រយោជន៍ ទ្រង់ណែនាំឲ្យសត្វលះបង់ ។ របស់ដែលជាប្រយោជន៍ ទ្រង់ណែនាំឲ្យសត្វធ្វើឲ្យចម្រើនឡើងដោយអនុសាសនី នេះឯងឈ្មោះថាព្រះបញ្ញាគុណ ។

ព្រះវិសុទ្ធិគុណនោះ គឺសេចក្ដីបរិសុទ្ធ បានដល់ការលះកិលេសគ្រឿងសៅហ្មងដាច់ស្រឡះព្រមទាំងវាសនា សូម្បីលោកធម៌ ៨ មកដល់ចំពោះព្រះកត្ត្រ្ដក៏មិនត្រេកអរមិនទោមនស្ស ព្រះហឫទ័យនៅតែថ្នាបរិសុទ្ធដដែល នេះឯងឈ្មោះថាព្រះវិសុទ្ធិគុណ ។

ព្រះករុណាគុណនោះ បានដល់សេចក្តីអាណិតប្រណីសត្ត្ব ដែលក្តៅដោយភ្លើងទុក្ខភ្លើងកិលេស ដែលនៅក្នុងសមុទ្រធំ ពោលគឺសង្សារ-វដ្ត និងឲ្យសត្ត្ববំលត់ភ្លើងទុក្ខភ្លើងកិលេសរួចចាកសង្សារវដ្ត ជាគុណមានដល់ព្រះអង្គ្ គ កាលនៅជាព្រះពោធិសត្ត្ব និងកាលត្រាស់ដឹងហើយ នេះឯងឈ្មោះថា ព្រះករុណាគុណ ។ ថាបើព្រះពុទ្ធមានតែព្រះបញ្ញា-គុណម្យ៉ាង ព្រះវិសុទ្ធិគុណនិងព្រះករុណាគុណមិនមាន ព្រះអង្គ្ គ ក៏នឹងមិនបានទូន្មានសត្ត្ববលោក ។ សត្ត្ববលោកក៏នឹងមិនដឹងកុសលអកុសល ផ្លូវសុគតិ ទុគ្គតិ និងសីល សមាធិ បញ្ញា ដែលជាផ្លូវព្រះនិព្វាន ឬមានតែព្រះបញ្ញាគុណនិងព្រះករុណាគុណប៉ុណ្ណោះ គង់នឹងទូន្មានសត្ត្ববដោយព្រះហឫទ័យបង្ហោនទៅតាមស្រឡាញ់តាមស្អប់ ។ ការទេសនាប្រដៅក៏នឹងមិនបរិសុទ្ធ ព្រោះមិនមានព្រះវិសុទ្ធិគុណឧបត្ថម្ភព្រះបញ្ញា-គុណ និងព្រះករុណាគុណ ។

មួយទៀត ថាបើមានតែព្រះវិសុទ្ធិគុណនិងព្រះករុណាគុណ ព្រះបញ្ញាគុណមិនមានសោត ក៏មិនអាចទូន្មានសត្ត្ববបាន ។ មួយទៀត បើមិនមានព្រះករុណាគុណ មានតែព្រះបញ្ញាគុណ និងព្រះវិសុទ្ធិគុណ ព្រះអង្គ្ គ ក៏មិនទ្រង់ទូន្មានសត្ត្ব និងសោយតែឯកីភាវសុខ នៅតែមួយព្រះអង្គ្ គ ឯង ឬវំលត់ខន្ធបរិនិព្វានធាប់រហ័ស សត្ត្ববទាំងឡាយក៏មិនដឹងកុសលាកុសល ផ្លូវសុគតិ ទុគ្គតិ និងសីល សមាធិ បញ្ញា ផ្លូវព្រះ

និព្វាន ។ ព្រះករុណាគុណរបស់ព្រះអង្គកាលនៅជាពោធិសត្វនៅឡើយ ដូច្នេះ ព្រះអង្គនៅជាពោធិសត្ត្ব មានឧបនិស្សយ័យគួរដល់អរហត្តផល សាវកបារមីញាណ ហើយបានជួបនឹងព្រះពុទ្ធទាំងឡាយ មានព្រះពុទ្ធ ព្រះនាម **ឌីបង្ករ** ជាដើម សូម្បីនឹងប្រាថ្នាឲ្យរួចចាកទុក្ខតែមួយព្រះអង្គ ហើយទទួលព្រះសទ្ធម្មទេសនា អំពីសំណាក់ព្រះពុទ្ធ ទ្រង់ព្រះនាម **ឌីបង្ករ** នោះ ក៏នឹងបានសម្រេចអរហត្តផលសាវកបារមីញាណ រួចអំពីសង្សារទុក្ខតែមួយព្រះអង្គឯងទៅហើយ តែព្រះអង្គឃើញសត្ត្ব ទាំងឡាយក្តៅក្រហាយ ដោយភ្លើងទុក្ខមានជាតិជាដើម ភ្លើងកិលេសមានរាគ:ជាដើម ហែលនៅក្នុងមហាសមុទ្រ ពោលគឺសង្សារវដ្ត ហើយព្រះអង្គមានព្រះហឫទ័យប្រណីប្រាថ្នារំលត់ភ្លើងទុក្ខ ភ្លើងកិលេសនៃសត្ត្ব ដទៃ នឹងជួយស្រង់អំពីមហាសមុទ្រ គឺសង្សារវដ្ត ទើបលះបង់ព្រះ-អរហត្តផល ដែលព្រះអង្គគួរបានក្នុងសំណាក់ព្រះពុទ្ធ **ឌីបង្ករ** នោះ ចេញ បង្ហោនព្រះហឫទ័យទៅដើម្បីសព្វញ្ញុតញ្ញាណ ហើយបំពេញ បារមីពុទ្ធការកធម៌គឺ ទាន សីល នេក្ខម្ម: បញ្ញា វិរិយ: ខន្តិ សច្ច: អធិដ្ឋាន មេត្តា ឧបេក្ខា នាំឲ្យទ្រង់សោយទុក្ខក្នុងសង្សារវដ្តជាអនេកទុក្ខ ក្នុងអនេកជាតិ ដូច្នេះឈ្មោះថា ព្រះករុណាគុណ ។ ព្រះករុណា-គុណជាហេតុឲ្យសម្រេចព្រះបញ្ញាគុណ ព្រះវិសុទ្ធិគុណ ដល់ព្រះអង្គ

នឹងអនុគ្រោះដល់សត្វដទៃផង ។ ព្រះករុណាគុណដែលមានអំពីកាលព្រះអង្គត្រាស់ដឹងហើយនោះ អនុគ្រោះដល់សត្វដទៃមួយជំពូក នឹងប្រកាសឲ្យសត្វដទៃដឹងគុណព្រះរតនត្រ័យ ព្រោះហេតុនោះ ទើបសំ-ដែងថា គុណ ៣ ប្រការនេះ ជាប្រធាននៃគុណទាំងពួង ។ គុណឯទៀតក៏ប្រជុំចុះក្នុងគុណទាំង ៣ នេះទាំងអស់ ។

មួយទៀត ព្រះពុទ្ធអង្គឧប្បត្តិឡើងក្នុងលោក ក៏ជាគុណដល់លោក ព្រោះហេតុព្រះអង្គបរិបូណ៌ព្រមដោយសម្បទា ៣ គឺ ហេតុសម្បទា ១ ផលសម្បទា ១ សត្ថុបការសម្បទា ១ ។

ហេតុសម្បទា មានប៉ុន្មាន? មាន ២ គឺ មហាករុណាសមា-យោគ: ១ ពោធិសម្ភារសម្ភរណ: ១ ។

មហាករុណាសមាយោគ: ដូចម្តេច? ការដែលព្រះអង្គប្រកបព្រមដោយករុណាប្រណីសត្វយ៉ាងធំ ដែលមានមកអំពីបាទមូលនៃព្រះពុទ្ធ ទ្រង់ព្រះនាម **ឌីបង្ករ** *នោះ ខ្ជាប់មាំមួនក្នុងសន្ធានមិនបានប្រែប្រួលគ្រប់ភពដរាបដល់បច្ចុប្បន្នជាតិនេះ ដូច្នេះឈ្មោះថា មហាករុណាសមាយោគ:។*

ពោធិសម្ភារសម្ភរណ: នោះដូចម្តេច? ការដែលព្រះអង្គសាងសន្សំបំពេញពោធិសម្ភារបារមីពុទ្ធការកធម៌គឺ ទាន សីល នេក្ខម្ម: បញ្ញា វីរិយ: ខន្តិ សច្ច: អធិដ្ឋាន មេត្តា ឧបេក្ខា ដែលសត្វដទៃកម្រនឹងធ្វើបានអស់កាលអង្វែងរាប់ដោយកោដិនៃកប្បជាច្រើននោះ ដូច្នេះឈ្មោះថា

ពោធិសម្ភារសម្ភរណៈ ។ សម្ប្ទា ២ នេះ ជាគុណគឺព្រះអង្គដល់ព្រម ជាហេតុខាងដើម អាចឲ្យសម្រេចផលសម្ប្ទា និងសត្ត្ឍបការសម្ប្ទា ខាងចុង ទើបឈ្មោះថា ហេតុសម្ប្ទា ។

ផលសម្ប្ទា មានប៉ុន្មាន? មាន ៤ គឺ ញាណសម្ប្ទា ១ បហានសម្ប្ទា ១ អានុភាវសម្ប្ទា ១ រូបកាយសម្ប្ទា ១ ។

ញាណសម្ប្ទា នោះដូចម្តេច? មគ្គញ្ញាណព្រះបញ្ញាជ្រាបសង្ខ្ការ ក្នុងមគ្គទាំង ៤ ដែលជាទីតាំងនៃសព្ញុតញ្ញាណនិងញាណដទៃ មាន ទសពលញ្ញាណ អនាវរណញ្ញាណ និងចតុវេសារជ្ជញ្ញាណជាដើម ដែលឲ្យសម្រេចតាមសេចក្តីប្រាថ្នា ក្នុងញ្ញេយ្យធម៌ទាំងពួងដោយស្រួល និងប្រកបដោយឧបាយទេសនាទូន្មានសត្ត្ឍមិនទើសទាល់ ព្រះញាណ អម្ប្ាលនេះ ឈ្មោះថាញ្ញាណសម្ប្ទា ។

បហានសម្ប្ទា នោះដូចម្តេច? ការដែលព្រះអង្គលះកិលេស ព្រមទាំងវាសនា ដាច់មិនមានសេសសល់ដល់តិចតួច មិនឲ្យកើតឡើង ទៀតជាធម្មតា នេះឯងឈ្មោះថា បហានសម្ប្ទា ។

អានុភាវសម្ប្ទា នោះដូចម្តេច? ការដែលព្រះអង្គជាអធិបតីក្នុង ហេតុ ដែលនឹងឲ្យសម្រេចតាមសេចក្តីប្រាថ្នា គឺព្រះអង្គមានឥស្សរភាព នឹងសម្តែងឫទ្ធិបាន តាមប្រាថ្នាគ្រប់ប្រការ ដូច្នេះឈ្មោះថា អានុភាវ-សម្ប្ទា ។

រូបកាយសម្បទា នោះដូចម្តេច? ការដែលព្រះអង្គបរិបូណ៌ដោយ ព្រះកាយ ដ៏ប្រដាប់ដោយទ្វត្ដឹសមហាបុរិសលក្ខណៈ និងអសីតានុព្យញ្ជនៈ ដ៏គួរជានយនាភិសេកស្រោចស្រង់ចក្ខុនៃសត្វលោកទាំងពួង ដូច្នេះឈ្មោះថា រូបកាយសម្បទា ។ សម្បទាទាំង ៤ នេះ ជាគុណគឺព្រះអង្គដល់ព្រម សម្រេចមកអំពីហេតុសម្បទា ទើបឈ្មោះថាផលសម្បទា ។

សត្ថុបការសម្បទា នោះមានប៉ុន្មាន? មាន ២ គឺ អាសយៈ ១ បយោគៈ ១ ។

អាសយៈ នោះដូចម្តេច? ការដែលព្រះអង្គមានព្រះរាជហឫទ័យត្រជាក់ដោយព្រះករុណា ប្រាថ្នាឲ្យសត្វទាំងឡាយបានប្រយោជន៍ជានិច្ច សូម្បីសត្វដែលធ្វើខុសដូចទេវទត្ដជាដើម ព្រះអង្គក៏ទ្រង់ព្រះករុណានេះ ១ មួយទៀត ការដែលព្រះអង្គឃើញសត្វដទៃ មានបញ្ញិន្ទ្រិយមិនទាន់ចាស់ក្លា ព្រះអង្គក៏ទ្រង់រង់ចាំ លុះតែសត្វមានបញ្ញិន្ទ្រិយចាស់ក្លា គួរនឹងត្រាស់ដឹងបាន ១ ពីរប្រការនេះឈ្មោះថា អាសយៈ ។

បយោគៈ នោះដូចម្តេច? ការដែលព្រះអង្គមានព្រះរាជហឫទ័យបរិសុទ្ធស្អាត មិនសំឡឹងឃើញតែអាមិស មានលាភនិងសក្ការៈជាដើម ទ្រង់សម្ដែងធម៌ដោយយានត្រៃមុខគឺ សីល សមាធិ បញ្ញា ដែលជាផ្លូវព្រះនិព្វាន ទ្រង់ចែកនូវធម៌នោះ ។ ឲ្យរាក់ឡើងដល់សត្វដទៃ ដែលមានឧបនិស្សយត្រាស់ដឹងតាម សម្រេចលោកុត្ដរផល នាំអត្ដភាពឲ្យផុតចាក

ទុក្ខទាំងពួងបាន ដូច្នេះឈ្មោះថា បយោគ: ។ អាសយ: និង បយោគ: ទាំងពីរនេះ ជាគុណសម្បត្តិរបស់ព្រះអង្គ ជាឧបការ:ដល់សត្វដទៃ ទើបឈ្មោះថាសត្ថុបការសម្បទា នេះហើយ ព្រះពុទ្ធកើតឡើងក្នុងលោក ជាគុណដល់លោក ព្រោះព្រះអង្គបរិបូណ៌ព្រមដោយសម្បទា ៣ ដូចសម្តែងមកនេះឯង ។

មួយទៀត អរហត្តាទិគុណនៃព្រះពុទ្ធ ដែលកើតឡើងហើយក្នុងលោក ក៏ជាកិត្តិគុណក្នុងលោក ប្រាកដដល់ទេវតានិងមនុស្សសត្វផងទាំងឡាយច្រើនជាងគុណទាំងពួង ព្រោះហេតុនោះ ក្នុងបុព្វសិក្ខា ទើបបានសម្តែងថា ឯកិត្តិសទ្ទដ៏ប្រពៃនៃព្រះមានព្រះភាគនោះ ខ្ជរខ្ជាយឡើងទៅ ដូច្នេះថា **ឥតិបិ សោ ភគវា អរហំ ។ ល ។ ភគវាតិ** ដូច្នេះ ។

គ្រានេះនឹងអធិប្បាយក្នុងបទថា **អរហំ** ជាដើម លោកប្រកបបទ ទុកក្នុងអនុស្សរណន័យ សម្រាប់រាប់ពន្យារគុណនៃព្រះពុទ្ធដូច្នេះថា **សោ ភគវា ឥតិបិ អរហំ ។ ល ។ សោ ភគវា ឥតិបិ ភគវា** ប្រែថា **សោ ភគវា** រីព្រះមានព្រះភាគនោះ **អរហំ** ទ្រង់ព្រះនាម **អរហំ ឥតិបិ** ពិតដូច្នេះ ប្រែយ៉ាងនេះគ្រប់ៗបទដរាបដល់បទថា **សោ ភគវា ឥតិបិ ភគវា** ។ អធិប្បាយថា **សោ ភគវា** រីព្រះមានព្រះភាគនោះ **អរហំ** ទ្រង់ព្រះនាម **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកកិលេសផង ព្រោះព្រះអង្គជាបុគ្គលដ៏គួរផង ដ្បិតព្រះមានព្រះភាគនោះ

ស្ថិតនៅហើយក្នុងទីឆ្ងាយក្រៃពេក ចាកកិលេសទាំងពួង ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **អរហំ** ។ កិលេសនោះ ប្រែថា គ្រឿងធ្វើចិត្តឲ្យសៅហ្មង បានដល់ លោភ: ទោស: មោហ: និងមាយា សាឋេយ្យ: គឺការបិទបាំងទោសនិងអួតអាងជាដើម ដែលកើតឡើងហើយធ្វើចិត្តឲ្យសៅហ្មងកករល្អក់ជាអកុសលចិត្ត ។ ដែលសម្តែងថា ព្រះអង្គឆ្ងាយចាកកិលេសនោះ មិនមែនកិលេសខ្ជាចព្រះអង្គរត់ទៅនៅទីណាមួយ ឬព្រះអង្គរត់ចោលកិលេសមកនោះទេ ព្រោះកិលេសជាអរូបធម៌ មិនមានរូបមិនមានខ្ជួន ដែលព្រះអង្គឆ្ងាយចាកកិលេសនោះ គឺព្រះអង្គមិនមានកិលេសគ្រឿងសៅហ្មងក្នុងព្រះសន្តាន ព្រោះសព្វកិលេសព្រមទាំងវាសនា ព្រះអង្គកម្ចាត់បង់បានអស់ហើយ ដោយមគ្គញ្ញាណនោះ។ ។

ឯវាសនានោះ ប្រែថា ប្រក្រតី ដែលកិលេសអប់រំ បានដល់អាការ: នៃកាយ វាចា របស់ព្រះខីណាស្រពលោកមិនមានកិលេស ដូចអាការ: នៃមនុស្សមានកិលេសដែរ ។ វាសនានេះ មានតែព្រះសព្វញ្ញូពុទ្ធប៉ុណ្ណោះ ទេ ដែលកម្ចាត់បង់បានដាច់ស្រឡះ ព្រមទាំងកិលេស ដោយអរហត្តមគ្គ ។ ព្រះបច្ចេកពុទ្ធនិងព្រះអរហន្ត ដែលជាសាវកនឹងលះវាសនាមិនបាន លះបានតែកិលេសប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះសារីបុត្តជាអគ្គសាវក កាលអំពីបុព្វជាតិលោកធ្លាប់កើតក្នុងកំណើតពានរ វាសនាអាការ:នៃពានរ ក៏ជាប់តាមមក សូម្បីជាព្រះអរហន្តហើយ

រៀបដើរទៅដល់ថ្ពុកអណ្ដូង លោកក៏លោតរំលងដូចពានរ ។

មួយទៀតព្រះបិលិន្ទវច្ឆត្ថេរ កាលលោកជាបុថុជ្ជននៅឡើយ រមែងពោលថា វសលិ១ ជាភាសាទាប តាមនិយមក្នុងមគធភាសា សូម្បីលោកជាព្រះអរហន្ដខីណាស្រពហើយ លោកក៏នៅពោលថា វសលិ១ ព្រោះវាសនា ព្រះអរហន្ដសាវកលោកលះមិនបាន ។ ព្រោះហេតុនោះ ការលះកិលេសនៃព្រះពុទ្ធ មិនសាធារណៈទូទៅ ដល់ព្រះបច្ចេកពុទ្ធ និងព្រះអរហន្ដសាវកឡើយ ។ ព្រះមានព្រះភាគ ហេតុតែព្រះអង្គ ធ្វាយចាកកិលេសដូច្នេះ ព្រះអង្គមានព្រះរាជហឫទ័យដ៏បរិសុទ្ធស្អាតមិនញាប់ញ័រដោយលោកធម៌ទាំង ៨ គឺ លាភ មិនមែនលាភ យស មិនមែនយស និន្ទា សរសើរ សុខ ទុក្ខ មកដល់ចំពោះព្រះអង្គ ព្រះអង្គក៏មិនមានអនុរោធ ពិរោធ រមែងព្រងើយប្រកបដោយឆន្ទគ្គុបេក្ខា សូម្បីរូប សំឡេង ក្លិន រស ផោដ្ឋព្វ: ធម្មារម្មណ៍ ល្អអាក្រក់ដូចម្ដេចៗ មកខ្ទប់ចក្ខុ សោត: ឃាន: ជិវ្ហា កាយ មនោទ្វារ ព្រះអង្គក៏មិនសោមនស្ស ទោមនស្ស រមែងសំឡឹងដោយឧប្បត្តិញ្ញាណុបេក្ខា ។

មួយទៀត ព្រះអង្គមានព្រះរាជហឫទ័យដូចផែនដី សូម្បីកាយព្រះអង្គម្ខាងលាបប្រឡាក់ដោយលម្អិតខ្ចីមចន្ទន៍សុគន្ធជាតជារបស់ក្រអូប ព្រះកាយម្ខាងលាបប្រឡាក់ដោយទុគ្គន្ធជាតជារបស់ស្អុយមិនស្អាត ព្រះអង្គក៏មិនសោមនស្ស ទោមនស្ស ក្នុងសុគន្ធជាត និងទុគ្គន្ធជាតនោះ មាន

ព្រះហឫទ័យដ៏ស្មើដូច្នេះ ព្រោះព្រះអង្គធ្វាយចាកកិលេស ។

មួយទៀត ព្រះមានព្រះភាគនោះ ទ្រង់ព្រះនាម **អរហំ** ព្រោះព្រះអង្គជាបុគ្គលគួរមែនពិត ដ្បិតព្រះមានព្រះភាគនោះ ព្រះអង្គគួរនឹងទ្រង់បញ្ញត្តនូវសិក្ខាបទដល់សាវក និងសម្តែងធម៌ដល់សត្វលោក ព្រោះព្រះអង្គធ្វាយចាកកិលេសហើយ មិនទ្រង់បញ្ញត្តសិក្ខាបទ និងសម្តែងធម៌តាមអំណាចកិលេស ព្រះអង្គប្រារព្ធយកធម៌និងវិន័យជាប្រធាន ហើយទ្រង់បញ្ញត្តនូវសិក្ខាបទនិងសម្តែងធម៌ ។

មួយទៀត ព្រះអង្គគួរក្នុង លាភ យស និងសេចក្តីសរសើរ សេចក្តីសុខ ព្រោះព្រះអង្គមិនមានសេចក្តីត្រេកអរ ។

មួយទៀត ព្រះអង្គគួរនឹងទទួលនូវចតុប្បច្ច័យទាំង ៤ មានចីវរជាដើម និងសក្ការបូជាយ៉ាងវិសេស ដែលទេវតានិងមនុស្សទាំងឡាយធ្វើ ព្រោះព្រះអង្គជាកំពូលទក្ខិណេយ្យបុគ្គល ធ្វើផលនៃទាននិងសក្ការបូជាឲ្យបរិបូណ៌ឧត្តមវិសេស ព្រោះហេតុព្រះអង្គជាបុគ្គលគួរដល់សក្ការបូជាវិសេសនោះ បានជាកាលព្រះអង្គឧប្បត្តិឡើងហើយក្នុងលោក ទេវតានិងមនុស្សទាំងឡាយ ដែលមានបញ្ញា បូជាព្រះអង្គដោយបច្ច័យ ៤ និងគ្រឿងសក្ការបូជាវិសេសផ្សេងៗ លុះព្រះអង្គរំលត់ខន្ធបរិនិព្វានហើយ សត្វលោកគឺ ទេវតានិងមនុស្សក៏នៅធ្វើសក្ការបូជាព្រះអង្គ ដរាបដល់សព្វថ្ងៃនេះ ព្រោះហេតុដូច្នេះទើបឈ្មោះថា ព្រះអង្គជាបុគ្គលគួរ ។

ក្នុងបុព្វសិក្ខា ប្រែបទ **អរហំ** ថាព្រះអង្គគួរ មុននោះ តាមសទ្ទរូប ហើយប្រែថា ធ្វាយចាកកិលេសទុកជាខាងក្រោយ ក្នុងរឿងនេះប្រែថា ធ្វាយចាកកិលេសមុនតាមន័យក្នុងបាលី ដើម្បីសម្តែងថា ព្រះអង្គគួរ នោះ ព្រោះធ្វាយចាកកិលេស ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** នោះ ព្រោះ ព្រះអង្គត្រាស់ដឹង គឺត្រាស់ដឹងដោយព្រះអង្គឯងនូវធម៌ទាំងពួង ដោយ ប្រពៃហើយ ។

អធិប្បាយសេចក្តីទាំងពួង អ្នកប្រាជ្ញគប្បីដឹងដូចបទថា **ពុទ្ធោ** ដែលសម្តែងខាងដើម ប្លែកតែក្នុងរឿងនេះ មានបទថា **សម្មាសំ** មួយអន្ទើដោយធម៌ទាំងពួង ជួសសង្ខារទាំងពួងប៉ុណ្ណោះ **សម្មា** ប្រែថា ប្រពៃ អធិប្បាយថា សេចក្តីត្រាស់ដឹងរបស់ព្រះអង្គប្រពៃពិត មិនបាន វិបរិត និងបន្ទោបង់កិលេសាសវៈចេញបាន ពាក្យថា **សំ** ប្រែថា ឯងនោះ អធិប្បាយថា ព្រះអង្គត្រាស់ដឹងដោយព្រះអង្គឯង មិនមាន អ្នកណាក្នុងត្រៃភពនេះជាគ្រូ ។

ឯធម៌ទាំងពួងដែលព្រះអង្គត្រាស់ដឹងនោះគឺ អាយតនៈ វិញ្ញាណ-កាយ ផស្សៈ វេទនា សញ្ញា ចេតនា តណ្ហាកាយ វិតក្កៈ វិចារៈ មួយបទ ៦ៗ ខន្ធ ៥ កសិណ ១០ អនុស្សតិ ១០ សញ្ញា ១០ អាការ មានសក់ ពោម ជាដើម អាយតនៈ ១២ ធាតុ ១៨ ភព ៩

ឈាន ៤ អប្បមញ្ញា ៤ អរូបសមាបត្តិ ៤ អង្គបដិច្ចសមុប្បាទ មាន អវិជ្ជាជាដើម មានជរាមរណៈជាទីបំផុត ដោយអនុលោម បដិលោម អម្បាលនេះឈ្មោះថា ធម៌ទាំងពួងជួសសង្ខារទាំងពួង ព្រះអង្គជ្រាបធម៌ ទាំងពួងនេះគឺ ជ្រាបថាជាអភិញ្ញេយ្យធម៌ គប្បីដឹងច្បាស់ដោយបញ្ញា ។ គប្បីដឹងច្បាស់ តើដូចម្តេច? ចំណែកធម៌ដែលជាបរិញ្ញេយ្យ គប្បីកំណត់ ដឹង គឺទុក្ខ ក៏កំណត់ដឹងថាជាទុក្ខ ចំណែកធម៌ដែលជាបហាតព្វៈ គប្បី លះបង់ គឺសមុទ័យ ក៏លះបាន ចំណែកធម៌ដែលជាសច្ឆិកាតព្វៈ គប្បី ធ្វើឲ្យច្បាស់ប្រាកដ គឺនិរោធ ក៏ធ្វើឲ្យជាក់ច្បាស់បាន ចំណែកធម៌ ដែលជាភាវេតព្វៈ គប្បីធ្វើឲ្យកើតឲ្យចម្រើនឡើង គឺមគ្គ ក៏ធ្វើឲ្យមានឲ្យ ចម្រើនឡើងបាន ដូច្នេះឈ្មោះថាជ្រាបប្រពៃ និងប្រកបក្នុងអាយតនៈ ១ គឺចក្ខុឈ្មមជានិទស្សនៈ (ឧទាហរណ៍) ចក្ខុនេះជារបស់គប្បីកំណត់ដឹង ថាជាទុក្ខ ព្រោះមិនទៀង មិនមែនខ្លួន ទើបជាទុក្ខ ។ តណ្ហាក្នុងកព មុនដែលឲ្យកើតចក្ខុមកនេះ ជាសមុទ័យ ហេតុឲ្យកើតទុក្ខ តណ្ហានេះ ជារបស់គប្បីលះ ។ សេចក្តីមិនបានប្រព្រឹត្តទៅនៃទុក្ខនិងសមុទ័យនោះ ឈ្មោះថានិរោធ និរោធនេះ ជារបស់គប្បីធ្វើឲ្យជាក់ច្បាស់ ។ សេចក្តី ដឹងច្បាស់នូវទុក្ខសមុទ័យនិរោធនោះ ឈ្មោះថាមគ្គ មគ្គនេះគប្បីធ្វើឲ្យមាន ឲ្យចម្រើនឡើង ។ ព្រះមានព្រះភាគត្រាស់ដឹងដូច្នេះ ឈ្មោះថាត្រាស់ ដឹងប្រពៃ មិនមានអ្នកណាជាគ្រូព្រះអង្គ ព្រះអង្គត្រាស់ដឹងឯង ព្រោះ

ហេតុនោះ ទើបទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ត្រាស់ដឹងនូវធម៌ទាំងពួងដ៏ប្រពៃដោយព្រះអង្គឯង ។ អ្នកប្រាជ្ញគប្បីប្រកបក្នុងអាយតនៈក្រៅនោះ និងធម៌ដ៏សេសសល់ដូច្នេះគ្រប់ៗ បទ ។ ក៏ឯបទថា **អរហំ** នោះ សម្រេចដោយបហានៈ ការលះកិលេស ។ បទថា **សម្មាសម្ពុទ្ធោ** នោះ សម្រេចដោយភាវនា ការធ្វើបញ្ញាឲ្យចម្រើនឡើង ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** នោះ ព្រោះព្រះអង្គបរិបូណ៌ហើយដោយវិជ្ជានិងចរណៈ វិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥ ។

វិជ្ជា ៣ នោះគឺ **បុព្វេនិវាសានុស្សតិញ្ញាណ** បញ្ញារឭកតាម នូវខន្ធដែលព្រះអង្គនិងសត្វដទៃនៅហើយក្នុងភពមុន ១ **ចុតូបបាតញ្ញាណ** បញ្ញាជ្រាបច្បាស់នូវចុតិនិងបដិសន្ធិនៃសត្វ ១ **អាសវក្ខយញ្ញាណ** បញ្ញាជ្រាបច្បាស់នូវធម៌ជាគ្រឿងអស់អាសវៈ ១ ។ ៣ នេះឈ្មោះថាវិជ្ជា ដ្បិតជាការដឹងច្បាស់ដោយវិសេស វិជ្ជា ៣ នេះ បានពោលពិស្តារហើយក្នុងខាងដើម ។

វិជ្ជា ៨ នោះគឺ **វិបស្សនាញ្ញាណ** បញ្ញាឃើញកាយនេះ ថាគ្រាន់តែជាធាតុ ៤ មានវិញ្ញាណអាស្រ័យនៅ មិនមែនសត្វ មិនមែនបុគ្គល ១ **មនោមយិទ្ធि** ឫទ្ធិសម្រេចដោយចិត្តគឺ និម្មិតនូវរូបដទៃចេញចាកកាយនេះ ដូចទាញបណ្ដូលស្មៅយ៉ាងនេះ ១ **ឥទ្ធិវិធि** ការ

ថ្ងៃឯ ឬទ្ធិសម្រេចដោយអធិដ្ឋាន គឺមនុស្សម្នាក់ អធិដ្ឋានឲ្យជាមនុស្សច្រើន មនុស្សច្រើន អធិដ្ឋានឲ្យជាមនុស្សម្នាក់ជាដើម ១ **ឥព្ធសោតធាតុ** ទិព្ធសោត ឮសំឡេងមនុស្សនិងសំលេងទិព្ធ ក្នុងទីឆ្ងាយ ឬ ទីជិត ១ **ចេតោបរិយញ្ញាណ** កំណត់ដឹងចិត្តនៃអ្នកដទៃថា ជាចិត្តប្រកបដោយរាគ: និងប្រាសចាករាគ: ជាដើម ១ មួយអន្ទើដោយវិជ្ជា ៣ ដូចសម្តែងហើយនោះទើបរួមជា ៨ ។ ទាំង ៨ នេះ ឈ្មោះថាវិជ្ជា ព្រោះជាការដឹងវិសេសដឹងផ្សេងៗ ត្រាស់ដឹងច្បាស់ ។ វិជ្ជា ៨ នេះ ពណ៌នាមកដោយសង្ខេប ។ វិជ្ជា ៣ ទុ:ះ ពណ៌នាមកដោយពិស្តារ ។

ចរណ:មាន ១៥ គឺ **សីលសំវរ:** សេចក្តីសង្រួមកាយវាចា ១ **ឥន្ទ្រិយសំវរ:** សេចក្តីសង្រួមឥន្ទ្រិយទាំង ៦ មានចក្ខុន្ទ្រិយ ជាដើម មិនឲ្យអកិជ្ឌាទោមនស្សបាបធម៌កើតឡើងបាន ១ **ភោជនេមត្តញ្ញុតា** សេចក្តីជាអ្នកដឹងប្រមាណក្នុងភោជន ១ **ជាគរិយានុយោគ:** សេចក្តីព្យាយាមជារបស់មនុស្សអ្នកភ្ញាក់ ១ មួយអន្ទើដោយសប្ប្ដិសធម៌ ៧ គឺ **សទ្ធា** សេចក្តីជឿចំពោះរបស់ដែលគួរជឿ ១ **ហិរិ** សេចក្តីខ្មាសចំពោះទុច្ចរិតបាបធម៌ ១ **ឱត្តប្ប:** សេចក្តីតក់ស្លុតចំពោះទុច្ចរិតបាបធម៌ ១ **ពាហុសច្ច:** សេចក្តីជាអ្នកចេះដឹងច្រើន ១ **វីរិយ:** សេចក្តីព្យាយាម ១ **សតិ** សេចក្តីរឭក ១ **បញ្ញា** សេចក្តីដឹងទូទៅ ១ មួយអន្ទើដោយឈាន ៤ គឺ បឋមជ្ឌាន ទុតិយជ្ឌាន តតិយជ្ឌាន

ចតុត្ថជ្ឌាន ធម៌មានប្រភេទ ១៥ នេះ ឈ្មោះថា ចរណៈ ព្រោះថា ធម៌សម្រាប់បុគ្គលសញ្ជ្ជរទៅកាន់ទិសដែលមិនធ្លាប់ទៅ គឺព្រះនិព្វាន ។ វិជ្ជា ៣ វិជ្ជា ៨ និងចរណៈ ១៥ នេះ រមែងមានបរិបូណ៌ មិនខ្វះក្នុងព្រះមានព្រះភាគ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **វិជ្ជា-ចរណសម្ប្ជ្ជ** *ព្រះអង្គបរិបូណ៌ហើយដោយវិជ្ជា និងចរណៈ ។* **វិជ្ជាសម្ប្ជ** *ការបរិបូណ៌ដោយវិជ្ជានៃព្រះមានព្រះភាគនោះ រមែងធ្វើនូវសព្វញ្ញុតា គឺភាពនៃព្រះអង្គជាសព្វញ្ញូឲ្យបរិបូណ៌ ។* **ចរណ-សម្ប្ជ** *ការបរិបូណ៌ដោយចរណៈ រមែងធ្វើនូវមហាការុណិកតាគឺភាពនៃព្រះអង្គដែលមានករុណាធំឲ្យបរិបូណ៌បាន ព្រះអង្គតែងជ្រាបនូវវត្ថុដែលជាប្រយោជន៍ និងមិនមែនប្រយោជន៍ នៃសព្វសត្ត្ব ដោយសព្វញ្ញុតា និងញ៉ាំសត្ត្ব ឲ្យវៀរចាកវត្ថុដែលមិនជាប្រយោជន៍ ហើយប្រកបសត្ត្ব ក្នុងវត្ថុដែលជាប្រយោជន៍ ដោយមហាការុណិកតា ទាំងនេះ ព្រោះព្រះអង្គបរិបូណ៌ហើយ ដោយវិជ្ជានិងចរណៈ ព្រោះហេតុនោះ សាវកនៃព្រះមានព្រះភាគ ទើបឈ្មោះថា* **សុប្ជដិបន្ធ** *លោកបដិបត្តិល្អហើយ មិនជា* **ទុប្ជដិបន្ធ** *លោកបដិបត្តិអាក្រក់ ដូចសាវកនៃគ្រូដែលវិបត្តិចាកវិជ្ជានិងចរណៈ ជា* **អត្តន្ត្ជ:** *អ្នកធ្វើខ្លួនឲ្យក្តៅក្រហាយទ្ធេជាដើម ។*

ព្រះមានព្រះភាគទ្រង់ព្រះនាមថា **សុគតោ** នោះ ព្រោះ ព្រះអង្គយាងទៅកាន់ទីដ៏ប្រពៃ គឺព្រះនិព្វានដ៏ជាអម្រឹតស្ថាន ។

មួយទៀត ព្រះអង្គទ្រង់ព្រះនាមថា **សុគតោ** ព្រោះព្រះអង្គ យាងទៅហើយដោយប្រពៃពិត ដ្បិតកិលេសណា ដែលព្រះអង្គលះ ហើយ ដោយសោតាបត្តិមគ្គ ព្រះអង្គមិនត្រឡប់មកកាន់កិលេសនោះ ទៀត កិលេសណាៗ ដែលព្រះអង្គលះហើយ ដោយសកទាគាមិមគ្គ អនាគាមិមគ្គ ឬអរហត្តមគ្គក្តី ព្រះអង្គ ក៏មិនត្រឡប់មកកាន់កិលេសនោះៗ ទៀត ព្រោះហេតុនោះ ព្រះអង្គទើបទ្រង់ព្រះនាមថា **សុគតោ** ព្រះ អង្គយាងទៅហើយដោយប្រពៃ ។

មួយទៀត **សុគតោ** ប្រែថា ព្រះអង្គយាងទៅហើយប្រពៃមែន ពិត ព្រោះព្រះអង្គទៅហើយចាកធម៌ណា ធម៌នោះមិនត្រឡប់មកកាន់ ព្រះអង្គបានទៀត កាលព្រះអង្គដល់ហើយនូវទីណា ទីនោះមិនកំរើក ធម៌ ដែលព្រះអង្គលះបង់ទៅហើយនោះគឺ កិលេសដែលព្រះអង្គលះហើយ ដោយមគ្គនោះៗ កិលេសនោះមិនត្រឡប់មកកើតក្នុងព្រះហឫទ័យបាន ទៀត ទីដែលព្រះអង្គដល់ហើយនោះ គឺព្រះនិព្វាន ព្រះនិព្វានជា អកុប្បធម៌ មិនកំរើកត្រឡប់ជាសរាគាទិធម៌ដែលប្រកបដោយរាគៈ និង ត្រឡប់ជាជាតិធម៌ ជរាធម៌ជាដើមឡើយ ព្រះអង្គទៅចាកកិលេស ដល់ ហើយនូវព្រះនិព្វាន ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគតោ**

ទ្រង់យាងទៅហើយដោយប្រពៃ ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា **លោកវិទូ** នោះ ព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់នូវលោកដោយប្រការទាំងពួង ។ ព្រោះថា ព្រះមានព្រះភាគនោះ ជ្រាបច្បាស់ហើយនូវខន្ធាទិលោក ដោយប្រការទាំងពួង គឺជ្រាបសភាវៈជារបស់នៃលោកគឺទុក្ខ សមុទ័យ ហេតុជាដែនកើតនៃលោក គឺតណ្ហា និរោធ ធម៌ជាទីរំលត់នៃលោកគឺព្រះនិព្វាន និងនិរោធុ-បាយ ធម៌ជាឧបាយរំលត់លោក គឺមគ្គ សមដោយព្រះពុទ្ធតម្រាស់ចំពោះ រោហិច្ចទេវបុត្រថា "ក្នុងទីបំផុតលោកណា ដែលសត្វមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនឧប្បត្តិទេ តថាគតមិនពោលនូវទីបំផុតលោកនោះ ថា ជាទីដែលបុគ្គលគប្បីដឹង គប្បីឃើញ គប្បីយល់ដោយដំណើរទៅជាប្រក្រតី មានទៅដោយបាទាជាដើមឡើយ ។ បើតថាគតមិនទាន់ដល់នូវទីបំផុតនៃលោកទេ រមែងមិនពោលនូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខឡើយ ។ មួយទៀត តថាគត រមែងបញ្ញត្តនូវលោក លោកសមុទ័យ ហេតុជាដែនកើតនៃលោក លោកនិរោធ ទីដែលជាទីរំលត់នៃលោក និងលោកនិរោធគামិនីបដិបទា ផ្លូវដំណើរទៅដល់ទីរំលត់លោក ទាំង ៤ នេះ នៅតែក្នុងកន្ទេរសរីរកាយប្រវែងមួយព្យាម ដែលប្រកបដោយសញ្ញានិងចិត្តនេះឯង មិនមែនបញ្ញត្តក្នុងទីដទៃទេ" ។ ព្រះពុទ្ធទ្រង់ជ្រាបលោក ដោយប្រការទាំងពួងដូច្នេះ ទើបទ្រង់ព្រះនាមថា **លោកវិទូ**

ព្រះអង្គជ្រាបច្បាស់នូវលោក នយ័ដូច្នេះ បានក្នុងសង្ខារលោក ។

មួយទៀត សូម្បីសត្វលោក ក៏ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ ។ ជ្រាបច្បាស់នោះដូចម្តេច? ព្រះអង្គជ្រាបច្បាស់ដូច្នេះថា សត្វលោកគឺ ទេវតា មនុស្ស ពួកនេះ មានអាសយៈ ធម៌ជាទីមកដេកត្រាំក្នុងចិត្ត ដូច្នេះ គឺពួកខ្លះជាសស្សតាសយៈ ពួកខ្លះជាឧច្ឆេទាសយៈ ពួកខ្លះជាអនុលោមិក-ខន្ត្យាសយៈ ពួកខ្លះជាយថាភូតញ្ញាណាសយៈ និងជ្រាបច្បាស់ថា សត្វ លោកជំពូកនេះ មានអនុស័យ គឺកិលេសដេកត្រាំក្នុងខន្ធសន្តាន មាន រាគានុស័យជាដើម ជ្រាបថា សត្វជំពូកនេះ ប្រកបដោយសុចរិត និងទុច្ចរិត ឬជ្រាបចរិតទាំង ៦ នៃសត្វក្តី ជ្រាបថា សត្វនេះមាន អធិ-មុត្តិ គឺអធ្យាស្រ័យទន់ទាប និងឧត្តមដូច្នេះក្តី និងជ្រាបថា សត្វនេះមាន ឥន្ទ្រិយ គឺសទ្ធាជាដើមដ៏ចាស់ក្លា សត្វពួកនេះមានឥន្ទ្រិយដ៏ទន់ខ្សោយ សត្វពួកនេះមានអាការៈដ៏ល្អ គឺជាវិដ្ឋាសយៈ សត្វពួកនេះមានអាការៈដ៏ អាក្រក់គឺជាវដ្ដាសយៈ សត្វពួកនេះគប្បីឲ្យដឹងបានដោយងាយ ព្រោះ មានសទ្ធានិងបញ្ញា សត្វពួកនេះគប្បីឲ្យដឹងបានដោយក្រ ព្រោះមិន មានសទ្ធានិងបញ្ញា សត្វពួកនេះជាភព្វសត្ត សត្វគួរនឹងត្រាស់ដឹង ព្រោះ ប្រាសចាកអាវរណធម៌ គ្រឿងឃាត់ គឺកម្ម កិលេសនិងវិបាក សត្វពួក នេះជាអភព្វសត្ត សត្វមិនគួរត្រាស់ដឹង ព្រោះប្រកបដោយអាវរណធម៌ មានកម្មជាដើម ព្រះអង្គជ្រាបច្បាស់នូវសត្វលោក ដូច្នេះឯង ទើបទ្រង់

ព្រះនាមថា **លោកវិទូ** ជ្រាបច្បាស់នូវលោក ។

មួយទៀត លោកដោយប្រភេទមាន ៣ គឺ សង្ខារលោក បានដល់នាមរូបជាដើម ១ សត្វលោក បានដល់ទេវតានិងមនុស្សជាដើម ១ ឱកាសលោក បានដល់ផែនដីនិងអាកាសជាដើម ១ ព្រះអង្គទ្រង់ជ្រាបនូវលោកទាំង ៣ នេះ ថាជាបលុជ្ជនធម៌ មានការធ្ទុះធ្ទាយបាក់បែក មិនបិតថេរជាធម្មតា ព្រោះហេតុនោះ ព្រះអង្គទើបទ្រង់ព្រះនាមថា **លោកវិទូ** ទ្រង់ជ្រាបច្បាស់នូវលោក ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា **អនុត្តរោ** នោះ ព្រោះមិនមានអ្នកណាក្នុងត្រៃភពប្រសើរជាងព្រះអង្គដោយគុណ ព្រោះថា ព្រះមានព្រះភាគនោះ គ្របសង្កត់នូវលោកទាំងពួងដោយគុណគឺ **សីល សមាធិ បញ្ញា វិមុត្តិ** និង **វិមុត្តិញ្ញាណទស្សនៈ** ។ ព្រះអង្គមិនមានបុគ្គលស្មើ រមែងស្មើដោយព្រះពុទ្ធដែលរកបុគ្គលស្មើគ្មាន ព្រះអង្គមិនមានបុគ្គលប្រៀបបាន មិនមានបុគ្គលប្រៀបដោយគុណ មានសីលជាដើម ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **អនុត្តរោ** ជាបុគ្គលមិនមានអ្នកណាប្រសើរជាង បណ្ឌិតគប្បីសម្រេចសេចក្តីដោយ អគ្គប្ប្ដាសាទ-សូត្រ ជាដើម ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា **បុរិសទ្ធសារថិ** នោះប្រែថា ព្រះអង្គជាអ្នកទូន្មាននូវបុរសដ៏គួរទូន្មាន ព្រោះថា ព្រះមានព្រះភាគនោះ

រមែងទ្ធានន្ទូវទេវតា មនុស្សនិងអមនុស្ស ដែលជាបុរសគួរទ្ធានានោះ ដោយវិនយន្ទូបាយដ៏វិចិត្រផ្សេងៗ ។ សត្ត្ববកណា គាប់ចិត្តធម៌ពីពោះ ព្រះអង្គក៏ទ្រង់ទ្ធានដោយធម៌ពីពោះ គឺសម្តែងសុចរិត ៣ មានកាយ-សុចរិតជាដើម និងសម្តែងផលនៃសុចរិត ឈ្មោះថាជាធម៌ពីពោះឲ្យសត្ত្ববនោះត្រេកអរប្រព្រឹត្ត ។ សត្ত្ববកណាគាប់ចិត្តធម៌ជ្រោកជ្រាក ព្រះអង្គក៏ទ្រង់ទ្ធានដោយធម៌ជ្រោកជ្រាក គឺប្រកាសទុច្ចរិត ៣ និងផលនៃទុច្ចរិតនោះឲ្យសត្ত្ববខ្ពើមខ្ជាចលះបង់ ។ សត្ত្ববកណា គាប់ចិត្តទាំងធម៌ពីពោះ ទាំងធម៌ជ្រោកជ្រាក ព្រះអង្គក៏ទ្រង់ទ្ធានដោយធម៌ទាំងពីពោះទាំងជ្រោកជ្រាក គឺទ្រង់សម្តែងន្ទូវសុចរិតនិងទុច្ចរិត ព្រមទាំងផលនៃសុចរិតនិងទុច្ចរិតនោះ ឲ្យសត្ত្ববលះបង់ន្ទូវពុតកំណាចគឺទុច្ចរិត ហើយបិតនៅក្នុងកុសល-សុចរិត ។ សត្ত្ববកណាមិនទទួលវិនយន្ទូបាយ វិធីទ្ធានដ៏វិចិត្ររបស់ព្រះអង្គដូច្នេះ សត្ত្ববកនោះ ឈ្មោះថា **អបុរិសធម្មោ** មិនមែនជាបុរសគួរទ្ធានា ។ បុរសមិនគួរទ្ធានា ព្រះអង្គក៏មិនទ្រង់ទ្ធានា បុរសពួកនោះឈ្មោះថា គឺព្រះមានព្រះភាគលះបង់ហើយ ដោយមិនទ្រង់ទ្ធានប្រដៅ បុរសពួកនោះ ឈ្មោះថា ស្ងាប់ចាកកុសលធម៌និងសេចក្ដីសុខក្នុងលោកទាំងពីរ ។ ព្រះអង្គឈ្ងាសក្នុងឧបាយទ្ធានសត្ত្ববលោក ដូចនាយហត្ថាចារ្ យ ឬអស្សាចារ្ យ ដែលជាអ្នកឈ្ងាសទ្ធានគជសា និងអស្សតរជាសត្ত្ববគួរទ្ធានា ឲ្យលះបង់ពុតកំណាចដូច្នេះ ទើបព្រះអង្គទ្រង់

ព្រះនាមថា **បុរិសឧម្មសារថិ** ជាអ្នកទូន្មានទូវបុរសដ៏គួរទូន្មាន ។

មួយទៀត **អនុត្តរោ បុរិសឧម្មសារថិ** ២ នេះ ជាព្រះនាមជាមួយគ្នា ប្រែថា ព្រះមានព្រះភាគទ្រង់ទូន្មានបុរសដ៏គួរទូន្មាន មិនមានអ្នកណាលើស ដូចជាគជសានិងអស្សតរ ដែលនាយហត្ថាចារ្យ និងអស្សាចារ្យ ដ៏ឈ្ងាស ក្នុងឧបាយទូន្មានដ៏ស្ទាត់ជំនាញដោយប្រពៃ នាយហត្ថាចារ្យ អស្សាចារ្យ ប្រាថ្នានឹងឲ្យស្ទុះទៅទិសណា ក៏ស្ទុះទៅទិសនោះបានតែក្នុងមួយវារៈ ។ ចំណែកខាងបុរសដែលព្រះអង្គទូន្មានហើយនោះ សូម្បីអង្គុយនៅដោយបល្ល័ង្ក តែមួយ ក៏រមែងស្ទុះទៅកាន់ទិសទាំង ៨ គឺ សមាបត្តិ ៨ បាន ព្រោះហេតុនោះ ទើបព្រះអង្គទ្រង់ព្រះនាមថា **អនុត្តរោ បុរិសឧម្មសារថិ** ។

មួយទៀត ព្រះអង្គទ្រង់ទូន្មានទេវតានិងមនុស្ស ជាបុរសដ៏គួរទូន្មានដោយអនុសាសនីបាដិហារ្យ ជាឧបាយទូន្មានមិនកំហែងដោយអាជ្ញាឲ្យសត្វសោយទុក្ខវេទនា ដូចនាយហត្ថាចារ្យ អស្សាចារ្យ និងមនុស្សជាឥស្សរាធិបតី ទូន្មានទូវគជសា អស្សតរ និងជននៅក្នុងអំណាចនៃខ្លួន ដោយពាក្យជេរនិងអាជ្ញា គឺចាប់ចងប្រហារដោយគ្រឿងប្រហារផ្សេងៗ ។ សូម្បីព្រះអង្គទូន្មានសត្វពួកខ្លះ ដោយឥទ្ធិបាដិហារ្យក្តី អាទេសនាបាដិហារ្យក្តី គឺជាឧបាយប្រាបប្រាមឲ្យអស់ពុតកំណាចមានះ រឹងរូសចេញ ហើយក៏ទ្រង់ទូន្មានដោយអនុសាសនីបាដិហារ្យ

គឺប្រទានទេសនាពាក្យប្រដៅឲ្យសត្វបដិបត្តិតាម លះពុតកំណាច គឺ ទុច្ចរិតសង្កិលេសធម៌ ដោយមគ្គភាវនានោះៗ ។ សត្វនោះមិនត្រឡប់វិល មកប្រកបដោយទុច្ចរិតសង្កិលេសធម៌ ដែលជាពុតកំណាចទៀតឡើយ ដូចគជសានិងអស្សតរ ដែលនាយទូន្មានហើយ ហើយត្រឡប់មាន ពុតកំណាចទៀតម្តងៗ ព្រោះហេតុនោះ ព្រះអង្គទើបទ្រង់ព្រះនាមថា **អនុត្តរោ បុរិសទ្ធសារថិ** *ព្រះអង្គទ្រង់ទូន្មានបុរសដ៏គួរទូន្មាន ពុំមានអ្នកណាលើស ។*

ព្រះមានព្រះភាគទ្រង់ព្រះនាមថា **សត្ថា ទេវមនុស្សានំ** *ប្រែ ថា ព្រះអង្គជាសាស្តានៃទេវតា និងមនុស្សសត្វទាំងឡាយ ។ មែនពិត ព្រះអង្គទ្រង់ប្រដៅដោយប្រយោជន៍ ៣ គឺ ទិដ្ឋធម្មិកត្ថ: ប្រយោជន៍ ក្នុង បច្ចុប្បន្ន សម្ប្រាយិកត្ថ: ប្រយោជន៍ក្នុងកពមុខ និងបរមត្ថ: ប្រយោជន៍ យ៉ាងក្រៃលែងគឺព្រះនិព្វាន តាមគួរដល់អធ្យាស្ស័យរបស់វេនេយ្ય-សត្ត ។ ព្រះអង្គទ្រង់ទូន្មានដោយទិដ្ឋធម្មិកត្ថ:នោះ ដូចជាព្រះអង្គទ្រង់ ប្រដៅ ទីឃជាណុកោឡិយបុត្រ និងឧជយព្រាហ្មណ៍ ដោយសម្ប្ទា ៤ គឺ* **ឧដ្ឋានសម្ប្ទា** *ការឧស្សាហ៍ប្រកបកិច្ចការដែលជានាទីដ៏គួរ ដែលខ្លួនត្រូវធ្វើនិងស្វែងរកទ្រព្យដោយឧបាយដ៏ប្រពៃ ។* **អារក្ខ-សម្ប្ទា** *ការឈ្វាសរក្សាកិច្ចការងារដែលខ្លួនប្រកបធ្វើ និងទ្រព្យដែល ស្វែងរកបានមកដោយសេចក្ដីឧស្សាហ៍នោះ មិនឲ្យវិនាសសាបសូន្យ ។*

សមជីវិតា *ការចិញ្ចឹមជីវិតតាមសមគួរដល់កម្ចាំងទ្រព្យដែលមានច្រើន និងតិច ។* **កល្យាណមិត្ততা** *ភាពជាអ្នកមានកល្យាណមិត្ត ដូច្នេះ ក៏មាន ។ ទ្រង់ចង្អុលឲ្យដឹងស្គាល់អបាយមុខ ឧបាយដែលឲ្យវិនាស សាបសូន្យ ៤ ប្រការ គឺជាអ្នកលេងស្រី ១ ជាអ្នកលេងសុរា ១ ជាអ្នក លេងល្បែងភ្នាល់ ១ ជាអ្នកគប់មិត្តអាក្រក់ ១ និងទ្រង់ចែកអបាយមុខ ៦ ទៀតគឺ ការសេពសុរា ១ ដើរលេងក្នុងវេលាយប់ ១ ដើរមើល មហោស្រព ១ លេងល្បែងភ្នាល់ ១ គប់មិត្តអាក្រក់ ១ ខ្ជិលច្រអូស ១ ឲ្យសិង្គាលមាណពគហបតិបុត្រដឹង ដើម្បីលះបង់ ដូច្នេះឈ្មោះថាទូន្មាន ដោយទិដ្ឋធម្មិកត្ថ: ។*

ឯព្រះអង្គទ្រង់ទូន្មានដោយសម្ជាយិកត្ថ:នោះ ដូចទូន្មានទីឃជា-ណុកោឡិយបុត្រជាដើម ដោយសម្ជទា ៤ គឺ សទ្ធា សីល: ចាគ: បញ្ញា ។

មួយទៀត ព្រះអង្គទ្រង់សម្តែង **មត្តេយ្យតា** *បដិបត្តិប្រពៃ ចំពោះមាតា* **បេត្តេយ្យតា** *បដិបត្តិប្រពៃចំពោះបិតា* **សាមញ្ញតា** *បដិបត្តិប្រពៃចំពោះសមណ: ដែលជាអ្នកបដិបត្តិរំងាប់ កាយ វាចា ចិត្ត ចាកបាប* **ព្រហ្មញ្ញតា** *បដិបត្តិប្រពៃចំពោះព្រហ្ម ដែលជាអ្នកបណ្តែត បង់នូវបាបក្នុងត្រៃទ្វារ ដែលបាននាមតាមអរិយវោហារថា ព្រាហ្មណ៍* **អបចាយន:** *ការប្រតិត្តឱនលំទោនដល់បុគ្គលគួរគោរព និងសម្តែង*

ញាតិសង្គ្រហៈ *សេចក្ដីសង្គ្រោះញាតិ* **បុត្តទារសង្គ្រហៈ** *សេចក្ដីសង្គ្រោះបុត្រភរិយា និងបុញ្ញកិរិយាវត្ថុទាំង ៣ គឺ* **ទាន** *ការឲ្យ ១* **សីល** *កិរិយាសង្រ្ដួម កាយ វាចា ឲ្យហ្មត់ចត់ ជ្រាសចាកទោស ១* **ភាវនា** *កិរិយាធ្វើកងការកុសលឲ្យកើតមានក្នុងចិត្ត ១ ។* **ឧច្ចរិត-ប្ផហានៈ** *កិរិយាលះសេចក្ដីប្រព្រឹត្តអាក្រក់* **សុចរិតសមាទានៈ** *ការសមាទានទ្រវសុចរិតជាដើម ដោយន័យដ៏វិចិត្រផ្សេងៗ ដែលមានមកក្នុងសុត្តន្តប្រទេសនោះ ។ ដូច្នេះឈ្មោះថា ទ្ធានដោយសម្ប្រាយិកត្ថ: ។*

ព្រះអង្គទ្រង់សម្ដែងត្រៃសិក្ខាគឺ សីល សមាធិ បញ្ញា និងសម្ដែងបដិបទាផ្សេងៗ ដែលជាឧបការ:ដល់ត្រៃសិក្ខា ជាផ្លូវដែលសត្វដំណើរទៅកាន់ព្រះនិព្វានជាទីក្សេមចាកទុក្ខ ដោយអនេកន័យដ៏វិចិត្រផ្សេងៗ ដែលមានមកក្នុងគម្ពីរបរិយត្តិធម៌នោះ។ ដូច្នេះឈ្មោះថា ទ្រង់ទ្ធានដោយបរមត្ថ: ។ ព្រោះតែព្រះអង្គប្រដៅសត្វដោយប្រយោជន៍ ៣ ដូច្នេះ ទើបទ្រង់ព្រះនាមថា **សត្ថា ទេវមនុស្សានំ** *។ ឯព្រះអង្គទ្ធានដោយទិដ្ឋធម្មិកត្ថ: និងសម្ប្រាយិកត្ថ:នោះ មិនជាអស្ចារ្យណាស់ទេ ព្រោះគ្រូដទៃគេអាចប្រដៅបានខ្ទះដោយឯកទេសដែរ ។ ដែលព្រះអង្គទ្រង់ទ្ធានដោយបរមត្ថ:នោះ ទើបជាមហាអស្ចារ្យ ដ្បិតគ្រូដទៃមិនអាចនឹងសម្ដែងបានដូចព្រះអង្គ សូម្បីតែដោយឯកទេសក៏គ្មាន ។*

មួយទៀត ព្រះមានព្រះភាគ ដូចជាអាចារ្យអ្នកប្រដៅអក្ខរសម័យ

ចំណែកខាងវេនេយ្យសត្វដែលនៅមិនធ្លាប់ស្តាប់ពុទ្ធភាសិត មិនដឹងនូវ ប្រយោជន៍ ២ ក្តី និងប្រភេទកុសលនិងអកុសល និងប្រភេទនៃសង្ខារ មានខន្ធជាដើម ប្រកបដោយវិបល្លាស សម្គាល់ថា សង្ខារជារបស់ទៀង ជាសុខ ជាខ្លួន ប្រាណ សត្ត បុគ្គល និងជារបស់ល្អ ដូចជាកុមារតូច ដែលនៅមិនទាន់សិក្សាក្នុងអក្ខរសម័យ សូម្បីឃើញអក្សរ ក៏សម្គាល់ថា ជាគំនូរក្បាច់ក្បូរដ៏វិចិត្រ លុះវេនេយ្យសត្វបានស្តាប់ពុទ្ធភាសិត ចំពោះ ព្រះភក្ត្រ ឬអាស្រ័យឧគ្គហបរិបុច្ឆា និងស្តាប់ទេសនាអំពីសំណាក់ពហូ-សូតដែលសម្តែងតៗមក ទើបដឹងប្រភេទនៃធម៌ជាកុសលនិងអកុសល និងប្រភេទនៃសង្ខារមាននាមរូបជាដើម ហើយញែកចែកកងសង្ខារ ជា នាមរូប ឬខន្ធ ៥ ពិចារណាដោយសម្មសនញ្ញាណ ឃើញសាមញ្ញ-លក្ខណៈ ក្នុងសង្ខារថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ឬឃើញថាជារបស់ បដិកូលគួរខ្ពើម លះវិបល្លាស ៣ បានដោយតទង្គប្ផហានៈតែ ១ ខណៈៗក្តី ឬដោយសមុច្ឆេទប្ផហានៈ លះដាច់ស្រឡះក្តី ដូចកុមារតូចបានសិក្សា អក្ខរសម័យក្នុងសំណាក់អាចារ្យ ហើយបានឃើញអក្សរក៏មើលស្គាល់ បានដឹងសេចក្តី លះបង់វិបល្លាស ដែលឃើញថាគំនូរក្បាច់ក្បូរដ៏វិចិត្ត នោះបាន ។ ព្រះមានព្រះភាគសូម្បីព្រះអង្គបរិនិព្វានកន្ទងទៅហើយ អនុសាសនៈដែលជាអនុសាសនីបាដិហារ្យ ក៏ប្រតិស្ឋាននៅ ជាគុណ ដល់ទេវតានិងមនុស្សក្នុងខាងក្រោយ ទ្រង់ក៏បាននាមថាជាសាស្តានៃ

ទេវតានិងមនុស្សក្នុងខាងក្រោយផង ព្រោះហេតុនោះ ព្រះមានព្រះភាគទើបទ្រង់ព្រះនាមថា **សត្ថា ទេវមនុស្សានំ** ។ ពាក្យថា **ទេវមនុស្សានំ** នោះ ជាពាក្យពោលដោយអំណាចកំណត់សត្វដ៏ឧក្រិដ្ឋ និងកំណត់សត្វដែលជាកព្វបុគ្គល គួរត្រាស់ដឹងចតុរារិយមគ្គារិយផល ហេតុដូច្នោះ ព្រះមានព្រះភាគទ្រង់ព្រះនាមថា ជាសាស្តានៃអមនុស្ស និងតិរច្ឆានពួកខ្លះផង ព្រោះព្រះអង្គប្រទានអនុសាសនី ទូន្មានដល់អមនុស្សនិងតិរច្ឆានអម្បាលនោះ ដូចអាឡវកយក្ស និងអបឡាលនាគរាជ ជាដើម ដែលបានទទួលអនុសាសនីនៃព្រះអង្គ មានបសាទសទ្ធាជឿស៊ប់ ក្នុងព្រះរតនត្រ័យ លះបង់នូវពុតកំណាច គឺទុច្ចរិតចេញបាន ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **ពុទ្ធោ** នោះ ប្រែថា ព្រះអង្គត្រាស់ដឹងច្បាស់ នូវញ្ញេយ្យធម៌ទាំងពួង ។

មួយទៀត ប្រែថា ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ទាំង ៤ ដោយព្រះអង្គឯង ហើយញ៉ាំងសត្វដទៃឲ្យត្រាស់ដឹងតាមផង ទើបទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រះអង្គមានព្រះគុណរីកពេញហើយ អធិប្បាយទាំងពួង អ្នកប្រាជ្ញគប្បីដឹងដូចន័យដែលសម្តែងហើយក្នុងខាងដើមនោះចុះ ក្នុងរឿងនេះ ម្ចែកតែពាក្យថាញ្ញេយ្យធម៌ជួសសង្ខ្យារប៉ុណ្ណោះ ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **ភគវា** នោះ ប្រែថា ព្រះមានព្រះភាគ **ភាគ:** នោះបានដល់កុសលធម៌ មានទានសីលជាដើម

ដែលជាធម៌ដល់នូវចំណែកដ៏ឧត្តមយ៉ាងឧក្រិដ្ឋ និងជាកុសលញ៉ាំងលោកិយសុខនិងលោកុត្តរសុខ ឲ្យកើតឡើង ភាគ:នោះរមែងមានដល់ព្រះអង្គ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ភគវា** ។

មួយទៀត **ភគវា** ប្រែថា ព្រះអង្គញែកចេញសម្តែងនូវធម៌ទាំងពួង ដោយប្រភេទថាជាកុសល អកុសល និងអព្យាកតធម៌ ធម៌មិនមែនជាកុសលនិងអកុសលជាដើម ហើយក៏ចែកនូវធម៌ទាំងអម្បាលនោះជា ចិត្ត ចេតសិក ហើយក៏បែងជាភូមិ ៤ ជាដើម ដើម្បីនឹងឲ្យកុលបុត្រដឹងច្បាស់ច្រាកដក្នុងធម៌មានកុសលជាដើមនោះ ហើយញែកចែកធម៌អម្បាលនោះជាខន្ធ អាយតន: ធាតុ ឥន្ទ្រិយ អរិយសច្ច បដិច្ចសមុប្បាទ ជាដើម ដើម្បីជាអារម្មណ៍នៃវិបស្សនាបញ្ញា និងចែកសាមញ្ញលក្ខណៈគ្រឿងសម្គាល់ជាសាមញ្ញ ដែលមានទូទៅក្នុងធម៌ទាំងពួងគឺ **អនិច្ចតា** សភាពមិនទៀង **ទុក្ខតា** សភាពជាទុក្ខ និង **អនត្តតា** សភាពមិនមែនខ្លួន ទាំង ៣ នេះជាលក្ខណៈគ្រឿងសម្គាល់នៃវិបស្សនាបញ្ញា កាលទ្រង់បញ្ជាក់សេចក្តីពិតក្នុងធម៌ទាំងនោះ ទើបទ្រង់ចែកសច្ច:របស់ពិតនៃព្រះអរិយ: ៤ គឺ ទុក្ខ សមុទ័យ និរោធ មគ្គ កាលទ្រង់ប្រាជ្ញានឹងឲ្យឃើញថា ជាទុក្ខដោយហេតុនេះ។ ទើបទ្រង់ចែកនូវអត្តនៃសច្ច: ៤ នោះថា ធម៌មានខន្ធជាដើមនោះ ជាទុក្ខដោយអត្តថា បៀតបៀនសត្ត ១ ដោយអត្តថា ធម៌គឺបច្ច័យទាំងឡាយមាន

តណ្ហាជាដើមប្រជុំព្រមគ្នា ធ្វើឲ្យកើតឡើង ១ ដោយអត្ថថា ញ៉ាំងសត្វ ឲ្យក្តៅក្រហាយ ១ ដោយអត្ថថា ជារបស់ប្រែប្រួល ១ ទើបជាទុក្ខ ។ តណ្ហាជាសមុទ័យ គឺហេតុជាដែនកើតនៃទុក្ខនោះ ដោយអត្ថថា ប្រមូលមកគឺញ៉ាំងទុក្ខឲ្យកើត ១ ដោយអត្ថថា ជាហេតុប្រគល់ឲ្យនូវទុក្ខជាផលរបស់ខ្លួន ១ ដោយអត្ថថា ប្រកបសត្វដោយទុក្ខ ១ ដោយអត្ថថា រារាំងសត្វមិនឲ្យបានមគ្គផល ១ ទើបជាសមុទ័យ ។ ព្រះនិព្វានជានិរោធ ទីរំលត់ទុក្ខនោះ ដោយអត្ថថា រលាស់ចោលនូវឧបធិ ធម៌ដែលត្រង់រងនូវទុក្ខទាំងពួង ១ ដោយអត្ថថា វិវេកស្ងាត់ចាកសង្ខារធម៌ទាំងពួង ១ ដោយអត្ថថា មិនមានធម៌ណាមួយជាបច្ច័យប្រជុំគ្នាធ្វើឲ្យកើតឡើង ១ ដោយអត្ថថា ជារបស់មិនស្ងាប់ ព្រោះជារបស់ទៀង ១ ទើបឈ្មោះថានិរោធ ។ **សម្មាបដិបទា** *ឈ្មោះថាមគ្គ ជាផ្លូវ ដោយអត្ថថា នាំសត្វចេញចាកវដ្តទុក្ខ ១ ដោយអត្ថថា ជាហេតុញ៉ាំងសត្វឲ្យដល់នូវព្រះនិព្វាន ១ ដោយអត្ថថា ជាគ្រឿងឃើញនូវព្រះនិព្វាន ជាធម៌ដ៏សុខុមក្រៃលែង ១ ដោយអត្ថថា ជាអធិបតីនៃសម្បយុត្តធម៌ក្នុងកិរិយាឃើញនូវព្រះនិព្វាន ១ ទើបឈ្មោះថាមគ្គ ។ ព្រះមានព្រះភាគទ្រង់ចែកនូវធម៌ទាំងឡាយដោយន័យដូច្នេះជាដើម ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា* **ភគវា** *។ ពាក្យថា* **ភគវា** *នេះជាព្រះនាមព្រះមានព្រះភាគ សម្រាប់ហៅដោយគោរព ចំពោះព្រះមានព្រះភាគ ដែលជាសាស្តាដ៏វិសេសនិងឧត្តមជាងសត្វទាំងឡាយ ។*

ព្រះនាមតាំងអំពី **អរហំ** ដរាបដល់ **ភគវា** នេះ មិនមែនព្រះពុទ្ធមាតា ព្រះពុទ្ធបិតា ព្រះញាតិទាំងពួងឬទេវតាវិសេសណាមួយថ្វាយព្រះអង្គទេ ព្រះនាមទាំងនេះ ជានេមិត្តកនាម មកអំពីនិមិត្ត គឺគុណកើតឡើងព្រមគ្នាជាមួយនាមកាយ ក្នុងអរិយជាតិ និងការសម្តែងធម្ម-ចក្កប្បវត្តនសូត្រនៃព្រះអង្គ ។ ព្រះនាមទាំងនេះ ព្រះនាមខ្លះដូចជាព្រះនាមព្រះខីណាស្រពដែលជាសាវកក៏មាន តែដំណើរសេចក្តីប្លែកគ្នាបន្តិច អ្នកប្រាជ្ញគប្បីដឹងដោយដំណើរសេចក្តីដែលសម្តែងមកហើយចុះ ។ គុណដែលបានក្នុងព្រះនាមទាំងនេះ សម្តែងដោយសង្ខេបមាន ២ គឺ **អត្ត-ហិតសម្បត្តិ** ការដល់ព្រមដោយធម៌ជាប្រយោជន៍ចំពោះព្រះអង្គ ១ **បរហិតបដិបត្តិ** ការបដិបត្តិជាអនុកូលដល់សត្វដទៃ ១ ។

បទថា **អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ** ទាំងនេះប្រកាសគុណ គឺ អត្តហិតសម្បត្តិ ព្រោះបទទាំងនេះសម្តែងញាណនិងបហាន: ដែលជាផលសម្បទា ។

បទថា **អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ** ទាំងនេះប្រកាសគុណគឺ បរហិតបដិបត្តិ ព្រោះបទទាំងនេះ សម្តែងសត្ត្ថុបការសម្បទា ។

ឯបទថា **ពុទ្ធោ ភគវា** នេះ ប្រកាសគុណទាំង ២ គឺ អត្តហិត-

សម្បត្តិ និងបរហិតបដិបត្តិ ព្រោះបទទាំងពីរនេះ សម្តែងពោធិសម្ភារ-សម្ភរណៈ និងញាណដែលជាហេតុសម្បទានិងផលសម្បទា និងសម្តែងសត្ថុបការសម្បទា ។ កាលបើមានដូច្នេះ បទទាំងឡាយអម្បាលនោះ បានឈ្មោះថា ប្រកាសមហាករុណាសមាយោគៈ និងអានុភាវសម្បត្តិ រូបកាយសម្បត្តិ ។ មួយទៀត បទថា **អរហំ** *សម្តែងបហានៈ កិរិយាលះបង់នូវកិលេស បទថា* **សម្មាសម្ពុទ្ធោ** *សម្តែងភាវនា ការធ្វើកុសលឲ្យកើតមានឡើង ព្រោះហេតុនោះ ទើបព្រះនាមទាំង ២ នេះជាព្រះនាមធំ ព្រះអង្គបានត្រាស់ដឹងដោយព្រះនាមនេះ មានក្នុងសុត្តន្តប្រទេសនោះៗ ដោយច្រើន ។ មួយទៀត បទទាំងអស់នេះជាហេតុតៗ គ្នាដូច្នេះ ព្រះអង្គឆ្ងាយចាកកិលេស ព្រោះទ្រង់ត្រាស់ដឹងប្រពៃដោយព្រះអង្គឯង ។ ទ្រង់ត្រាស់ដឹងប្រពៃដោយព្រះអង្គឯង ព្រោះព្រះអង្គដល់ព្រមហើយដោយវិជ្ជានិងចរណៈ ។ ព្រះអង្គដល់ព្រមហើយដោយវិជ្ជានិងចរណៈ ព្រោះព្រះអង្គយាងទៅប្រពៃហើយ ។ ព្រះអង្គយាងទៅប្រពៃហើយ ព្រោះព្រះអង្គជ្រាបច្បាស់នូវលោក ។ ដែលព្រះអង្គទូន្មាននូវបុរសដ៏គួរទូន្មានពុំមានអ្នកណាលើស ព្រោះព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រោះព្រះអង្គមានព្រះគុណរីកពេញហើយ ។ ព្រះអង្គមានព្រះគុណរីកពេញហើយ ព្រោះព្រះអង្គមានភាគគឺព្រះបារមីធម៌ហើយទ្រង់ចែកដល់សត្វទាំងឡាយ ។*

បើនឹងពិចារណា គឺចម្រើនពុទ្ធានុស្សតិ រឭកដល់គុណនៃព្រះពុទ្ធ គប្បីរឭកដូច្នេះថា **សោ ភគវា ឥតិបិ អរហំ** *ព្រះមានព្រះភាគ នោះ ទ្រង់ព្រះនាមថា* **អរហំ** *យ៉ាងដូច្នេះទៅគ្រប់ៗបទ លុះដល់* **សោ ភគវា ឥតិបិ ភគវា** *ព្រះមានព្រះភាគទ្រង់ព្រះនាមថា* **ភគវា** *ព្រោះហេតុនោះ ពាក្យសម្តែងនោះ សម្តែងយកពាក្យប្រែនិងអធិប្បាយ ដែលសម្តែងមកហើយមុននោះ ឲ្យកាន់យកអត្ថគឺលើកសេចក្តីឡើងរឭក រំពឹងឲ្យឃើញគុណព្រះពុទ្ធ តាមដំណើរសេចក្តីដែលបានពណ៌នាមក ហើយ កុំកាន់យកតែព្យញ្ជនៈឡើងទន្ទេញបរិកម្ម ធ្វើយ៉ាងដូច្នេះ នឹង មិនឃើញគុណព្រះពុទ្ធអង្គទេ នឹងរឭកគ្រប់ៗបទក៏បាន ឬរឭកបទ ណាមួយតាមចូលចិត្តក៏បាន ។*

ពុទ្ធរតនកថា ចប់ ។

ធម្មរតនកថា

ពណ៌នាអំពីធម្មរតនៈ

បុ. *ធម៌នោះ អ្វីជាធម៌ សភាវៈដែលល្អក៏ពោលថាធម៌ សភាវៈដែលអាក្រក់ក៏ពោលថាធម៌ សភាវៈដែលមិនល្អមិនអាក្រក់ក៏ពោលថាធម៌ ដូចបាលីថា* "**កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា**" *ដូច្នេះ សភាវៈដូចម្តេចឈ្មោះថាធម៌ក្នុងធម្មរតនៈនេះ?*

វិ. *សភាវៈដែលល្អហើយពិត ជាធម៌ក្នុងធម្មរតនៈនេះ សភាវៈដែលល្អតែមិនពិត មិនមែនជាធម៌ សភាវៈពិតតែមិនល្អ ក៏មិនមែនជាធម៌ សភាវៈមិនល្អហើយមិនពិត ក៏មិនមែនជាធម៌ ។ ការដែលឃើញថាផលបុណ្យ និងបាបមិនមាន ឥធលោកក៏មិនមាន ដូច្នេះជាដើម ឈ្មោះថាសភាវៈមិនល្អហើយមិនពិត ។ ការដែលឃើញថាព្រះអាទិត្យជាពន្លឺបំភ្លឺលោក ដី ទឹក ភ្លើង ខ្យល់ជាទីអាស្រ័យនៃសត្ត្ব ហើយក្រាបសំពះបូជារបស់ទាំងនោះ ដូច្នេះ ឈ្មោះថាសភាវៈពិតតែមិនល្អ ។ ការបដិបត្តិរបស់បុគ្គលពួកខ្ជះដូច្នេះ កាលបើរាគៈ ទោសៈ កើតឡើងក្នុងចិត្ត ក៏ឃើញថារាគៈ ទោសៈ ជារបស់មិនល្អ ហើយបែរមុខរកឧបាយគិតដូច្នេះថា ព្រះជាម្ចាស់ជាអ្នកសាងលោកនៅក្នុងទីទាំងពួង ដឹង ឃើញនូវការទាំងពួង ព្រះអង្គឃើញយើងលុះដោយអំណាចរាគៈ ទោសៈ មិនបានកម្ចាត់បង់ ព្រះអង្គនឹងកត់បញ្ជី*

ចុះឈ្មោះយើងទុកហើយនឹងពិន័យទោសជាខាងក្រោយ គិតដូច្នេះហើយ ក៏កម្ចាត់រាគ: ទោស: ចេញបាន ដូច្នេះ ឈ្មោះថាសេចក្តីល្អមែន តែមិនពិត ព្រោះបានបែរមុខតទល់កម្ចាត់រាគ: ទោស: ដែលជាកិលេស ឈ្មោះថា សេចក្តីល្អ តែព្រះជាម្ចាស់នឹងសាងលោកដូច្នោះក៏ទេ ។ ឯសេចក្តីមិន លោភ មិនក្រោធ មិនវង្វេងដែលបុគ្គលធ្វើឲ្យកើតឡើងដោយឧបាយដ៏ពិត ប្រាកដ មិនមែនសេចក្តីមិនលោភ មិនក្រោធមិនវង្វេង ដែលមានក្នុងវេលា ដេកលក់ជាដើមក្តី ឬការកើតឡើងឯង នៃសេចក្តីមិនលោភ មិនក្រោធ មិនវង្វេង ព្រោះមិនមានសង្ខារជាទីតាំងក្តី ឈ្មោះថាសេចក្តីល្អពិត ។

ឃ. សេចក្តីមិនលោភ មិនក្រោធ មិនវង្វេង ដែលបុគ្គលធ្វើឲ្យមាន ឲ្យកើតឡើងដោយឧបាយដែលពិតប្រាកដ ឈ្មោះថាសេចក្តីល្អពិតនោះ ដូចម្តេច?

ង. ដូចជាបុគ្គលដែលគិតឃើញថា រាងកាយដែលមានវិញ្ញាណគ្រប់ គ្រង នឹងដឹងនូវសេចក្តីសុខ ទុក្ខ ឈ្មោះថាសត្វនេះ ទោះបីជាមនុស្សក្តី តិរច្ឆានក្តី រមែងខ្ពើមទុក្ខ ស្រឡាញ់សុខទូទៅគ្រប់រូប កាលកំណត់ ឃើញដូច្នោះហើយ មិនបៀតបៀនសត្វដទៃឲ្យបានសេចក្តីទុក្ខ ដោយ កាយនិងវាចារបស់ខ្លួន ត្រិះរិះរកសេចក្តីសុខឲ្យដល់សត្វដទៃ សង្កត់ សង្កិនសេចក្តីលោភ ក្រោធ ចេញដោយឧបាយដូច្នេះ ដោយឃើញថា ការប្រព្រឹត្តដូច្នេះ ជាសេចក្តីល្អ នឹងឲ្យបានសេចក្តីសុខទៅខាងមុខ ឈ្មោះ

ថាសេចក្តីល្អហើយពិត ។ មួយទៀត ការដែលគិតរំពឹងដល់សេចក្តីស្ងាប់ មានសេចក្តីតក់ស្ទុតចិត្តក្តី ឬពិចារណាថា រូបកាយនេះពេញដោយគ្រឿងស្មោកគ្រោកមាន សក់ រោម ក្រចក ធ្មេញ ស្បែក ជាដើម មានបដិកូល-សញ្ញាកើតឡើង រំងាប់នូវតម្រេក ក្រោធ រវើរវាយ បានក្តី ឬឃើញស្អិតចុះទៅថាសព៌ាង្គកាយ មិនទៀង ជាទុក្ខ មិនមែនជារបស់ខ្លួន ដោយហេតុនោះ។ ហើយមិនមានសេចក្តីលោភ ក្រោធ រវើរវាយ ដោយឃើញថាបដិបត្តិយ៉ាងនេះ អាចនឹងនាំខ្លួនឲ្យបានសេចក្តីសុខខាងមុខ នឹងរួចចាកទុក្ខទាំងពួង ដូច្នេះក្តី ឈ្មោះថាសេចក្តី មិនលោភ មិនក្រោធ មិនវង្វេងកើតមានឡើងដោយឧបាយដ៏ពិតប្រាកដ ឈ្មោះថាសេចក្តីល្អហើយពិតដូចសម្តែងមកដូច្នេះ ។

ទាន គឺចាគចេតនាក្តី សីល គឺការវៀរចាកទុច្ចរិតក្តី ភាវនា គឺការញ៉ាំងកុសលឲ្យកើតឡើងដែលជាសេចក្តីល្អហើយពិតដូច្នេះក្តី ឬរបៀបពាក្យដែលប្រកាសសេចក្តីល្អហើយពិតនោះក្តី ឈ្មោះថាធម៌ ។

ឃ. ធម៌ ប្រែថាដូចម្តេច?

វ. ធម៌ ប្រែថា សភាវៈទ្រទ្រង់នូវសត្វ ដែលទ្រទ្រង់នូវខ្លួន ។ មួយទៀត ថាសភាវៈដែលបុគ្គលគប្បីទ្រទ្រង់ទុក ។ សេចក្តីមិនលោភ មិនក្រោធ មិនវង្វេង ដែលកើតឡើងដោយឧបាយពិតប្រាកដ ដូចសម្តែងមកហើយនោះ បើបុគ្គលណាធ្វើឲ្យកើតឡើងក្នុងសន្តានចិត្ត បុគ្គលនោះឈ្មោះថា

ធម្មចារី អ្នកទ្រទ្រង់នូវធម៌ ធម៌នេះឯងតែងទ្រទ្រង់អ្នកនោះ មិនឲ្យធ្លាក់ទៅក្នុងទីដែលប្រកបដោយសេចក្តីទុក្ខ មាននរកជាដើម ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ភាសិតទុកថា៖

"ធម្មោ ហវេ រក្ខតិ ធម្មចារឺ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
ឯសានិសំសោ ធម្មេ សុចិណ្ណេ
ន ទុគ្គតឹ គচ্ছតិ ធម្មចារី ។

"ធម៌ពិតជារក្សានូវបុគ្គល អ្នកប្រព្រឹត្តធម៌ ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ តែងនាំមកនូវសេចក្តីសុខ នេះជាអានិសង្សក្នុងធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ បុគ្គលអ្នកប្រព្រឹត្តនូវធម៌ រមែងមិនទៅកាន់ទុគ្គតិ" ។

ធម៌ដែលប្រែថា សការ:គឺបុគ្គលគប្បីទ្រទ្រង់នោះ បានដល់បរិយត្តិ-ធម៌ដែលប្រកាសសេចក្តីល្អហើយពិតនោះ ព្រោះបរិយត្តិធម៌ជារបៀបបទដែលបុគ្គលគប្បីរៀនសូត្រទ្រទ្រង់ចាំទុក ។

មួយទៀត បរិយត្តិធម៌ ប្រែថា ទ្រទ្រង់បុគ្គលអ្នកទ្រទ្រង់នូវខ្លួនផងក៏បាន ដ្បិតថា បរិយត្តិធម៌ បើបុគ្គលណា ទ្រទ្រង់ដោយប្រាជ្ញានឹងបដិបត្តិតាម ព្រះធម៌តែងទ្រទ្រង់នូវបុគ្គលនោះ ឲ្យបានចម្រើនដោយពាហុសច្ច:នឹងឲ្យរួចចាកទីប្រកបដោយទុក្ខមានអបាយទុក្ខជាដើម ។ សេចក្តីមិនលោភ មិនក្រោធ មិនវង្វេង ដែលជាសេចក្តីល្អហើយពិតនោះ ដែលបិតថេរក៏មាន មិនបិតថេរក៏មាន ។ ដែលមិនបិតថេរនោះ គឺកើតឡើង

ហើយរលត់ទៅ មានសេចក្ដីលោភ ក្រោធ វង្វេង កើតឡើងបានទៀត បានដល់លោកិយកុសលធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ គឺកាមាវចរភូមិ១ រូបាវចរភូមិ ១ អរូបាវចរភូមិ ១ ។ ដែលបិតថេរនោះ គឺកើតឡើងហើយ សូម្បីរលត់ទៅ សេចក្ដីលោភ ក្រោធ វង្វេង ក៏មិនត្រឡប់កើតឡើងវិញបានឡើយ បានដល់លោកុត្តរធម៌ដែលនឹងសម្ដែងទៅខាងមុខ ។

មួយទៀត ធម៌សម្ដែងដោយសង្ខេបមាន ៣ គឺ បរិយត្តិសទ្ធម្ម ១ បដិបត្តិសទ្ធម្ម ១ បដិវេធសទ្ធម្ម ១ ។

បរិយត្តិសទ្ធម្មកថា

របៀបពាក្យដែលប្រកាសបដិបត្តិសទ្ធម្ម និងបដិវេធសទ្ធម្ម ឈ្មោះថា បរិយត្តិសទ្ធម្ម ។ បរិយត្តិសទ្ធម្មនោះចាត់ដោយបុគ្គលអ្នកសម្ដែងមាន ៤ ពួកគឺ ពុទ្ធភាសិត ១ សាវកភាសិត ១ ឥសិភាសិត ១ ទេវតាភាសិត ១ ។

ធម៌ដែលព្រះពុទ្ធអង្គទ្រង់សម្ដែង ឈ្មោះថាពុទ្ធភាសិត បានដល់ព្រះវិន័យ ព្រះសូត្រ និងព្រះអភិធម្ម ។ ធម៌ដែលសាវកវាប់បញ្ចូលក្នុងបរិស័ទ ៤ សម្ដែង មានអនង្គណសូត្រ និងសម្មាទិដ្ឋិសូត្រជាដើម ឈ្មោះថាសាវកភាសិត ។ ធម៌ដែលឥសីបរិព្វាជកខាងក្រៅដែលដឹងភូមិធម៌សម្ដែង ដូចបរិព្វាជកវគ្គជាដើម ឈ្មោះថាឥសិភាសិត ។

ធម៌ដែល ទេវតា មារ ព្រហ្ម សម្តែង ឈ្មោះថាទេវតាភាសិត បានដល់របៀបពាក្យក្នុងទេវតាសំយុត្តជាដើម ដែលជាពាក្យគឺ ទេវតា ទេវបុត្ត និងមារ ព្រហ្ម សម្តែង ។

បរិយត្តិសទ្ធម្ម ដែលចាត់ដោយភាសិត ៤ នោះ មានអង្គ ៩ គឺ សុត្ត: ១ គេយ្យ: ១ វេយ្យាករណ: ១ គាថា ១ ឧទាន ១ ឥតិវុត្តក: ១ ជាតក: ១ អព្ភូតធម្ម: ១ វេទល្ល: ១ ។

របៀបពាក្យដែលសម្តែងសេចក្តីបានជារឿងមួយៗ គួរនឹងទាញមកជាគ្រឿងសាធក:[1] បាន អំពីបាលីប្រទេសនោះៗ ដូច្នេះឈ្មោះថាសុត្ត: ដូចព្រះបាលីជាឧទ្ទេសវារ:ថា:

"**បញ្ចិមានិ ភិក្ខវេ ពលានិ ១ កតមានិ ២ បញ្ច ៣ សទ្ធាពលំ ១ វីរិយពលំ ២ សតិពលំ ៣ សមាធិពលំ ៤ បញ្ញាពលំ ៥**" ដូច្នេះ ឈ្មោះថាសុត្ត: ។ ឬព្រះបាលីថា "**ឥធ ១ ភិក្ខវេ ២ អរិយ-សាវកោ ៣ សទ្ធো ៤ ហោតិ ៥ សទ្ធហតិ ៦ តថាគតស្ស ១ ពោធឿ ២ ឥតិបិ ៣ សោ ៤ ភគវា ៥ អរហំ ១ ។ ល ១ ។ ២ ភគវាតិ ៣**" ដូច្នេះជាដើម ក៏ឈ្មោះថាសុត្ត: ។ សូម្បីរបៀបពាក្យដែលសម្តែងសេចក្តីបានជារឿងមួយៗ ដូច្នេះ ទោះក្នុងវិនិ័យឬក្នុងអភិធម្ម ក៏ឈ្មោះថាសុត្ត:ក្នុងរឿងនេះដែរ ។

១- គ្រឿងអាង ។ -ដែលញ៉ាំងប្រយោជន៍ឲ្យសម្រេច ។

របៀបពាក្យដែលជាចុណ្ណិយបទខ្លះ គាថាខ្លះ លាយគ្នា ដូចជាសគាថកវគ្គ ក្នុងគម្ពីរសំយុត្តនិកាយ ឈ្មោះថា គេយ្យៈ ។

របៀបពាក្យដែលជាចុណ្ណិយបទសុទ្ធ មិនលាយដោយគាថា ដូចក្នុងធម្មចក្កប្បវត្តនសូត្រជាដើម ឈ្មោះថា វេយ្យាករណៈ ។

របៀបពាក្យដែលលោកនិពន្ធជាគាថាសុទ្ធ មិនលាយដោយចុណ្ណិ-យបទ ដូចកាមសូត្រ គុហដ្ឋកសូត្រជាដើម ឈ្មោះថា គាថា ។

របៀបពាក្យដែលព្រះមានព្រះភាគទ្រង់អាស្រ័យសោមនស្សញ្ញាណ បន្ទឺឡើង ឈ្មោះថា ឧទាន ដូចព្រះបាលីថា៖

"យតា ហវे ចាតុកវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ បជានាតិ សហេតុធម្មំ"

ជាដើម ឧទានេះជាគាថាក៏មាន ជាចុណ្ណិយបទក៏មាន ។

របៀបពាក្យដែលព្រះពុទ្ធទ្រង់សម្តែងជាឧទ្ទេសវារៈឡើងជាមុន សម្តែងឧទ្ទេសវារៈនោះហើយ ទើបសម្តែងនូវនិគមជាខាងក្រោយទៀត ឈ្មោះថាឥតិវុត្តកៈ ដូចព្រះបាលីថា៖

"ឥមា ឆ ជាតុយោតិ ភិក្ខវេ មយា ឆម្ហោ ឧេសិតោ អនិក្តហិតោ អសង្ខ្លិលិដ្ឋោ អនុបវជ្ជោ

អប្ឋដិកុដ្ឋោ វ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ឥតិ ខោ បនេតំ វុត្តំ, កិញ្ចេតំ បដិច្ច វុត្តំ, ឆយិមា ភិក្ខវេ ធាតុយោ បថវីធាតុ ។ ល ។ វិញ្ញូហីតិ ឥតិ យត្តំ វុត្តំ, ឥទមេតំ បដិច្ច វុត្តំ" ។

*របៀបពាក្យដែលព្រះពុទ្ធអង្គទ្រង់សម្តែងបុព្វចរិតដ៏ប្រកបដោយពាក្យ ថា "**ភូតបុព្វំ ភិក្ខវេ**" ដូច្នេះ ឈ្មោះថា ជាតក: ដូចទីឃាវុជាតក និងមឃទេវជាតកជាដើម ។*

*របៀបពាក្យប្រកបដោយអច្ឆរិយព្ភូតធម៌ ដូចព្រះបាលីថា "**ចត្តា-ភោមេ ភិក្ខវេ អច្ឆរិយា អព្ភូតធម្មា អានន្ទេ**" ជាដើម ឈ្មោះថា អព្ភូតធម៌ ។*

របៀបពាក្យដែលអ្នកសួរបានសេចក្តីដឹងច្បាស់ និងសេចក្តីត្រេកអរ សួរតៗឡើងទៅ ឈ្មោះថា វេទល្ល: ដូចជាចុល្លវេទល្លសូត្រ មហាវេទល្ល-សូត្រ សម្មាទិដ្ឋិសូត្រ សក្កប្ញញ្ហាសូត្រ ជាដើម ។

មួយទៀត គេយ្យ:និងវេយ្យាករណ:ជាដើម លោកក៏ហៅថា សុត្ត: ដែរ ។ ទាំង ៩ នេះ ឈ្មោះថា ជាអង្គនៃបរិយត្តិសទ្ធម្ម ។ បរិយត្តិ-សទ្ធម្មនេះ កាលព្រះធម្មសង្គីតិកាចារ្យមិនទាន់បានធ្វើសង្គាយនា និងធ្វើ សង្គាយនានោះ លោកហៅថា ធម្មវិនិ័យ ដូច្នេះ ។

របៀបពាក្យដែលប្រកាសនូវសេចក្តីបដិបត្តិដោយកាយ វាចា ដែលព្រះពុទ្ធអង្គទ្រង់តែងតាំងទុកជាពុទ្ធអាជ្ញា ជាអាណាទេសនា ឈ្មោះថា វិន័យ ។

របៀបពាក្យដែលព្រះពុទ្ធអង្គទ្រង់សម្តែងប្រកាសនូវសេចក្តីបដិបត្តិដែលប្រព្រឹត្តទៅក្នុងកាយ វាចា ចិត្ត មិនបានតែងតាំងជាអាជ្ញា គ្រាន់តែសម្តែងដោយវោហារទេសនាខ្លះ បរមត្តទេសនាខ្លះ ឈ្មោះថា ធម៌ ។

មួយទៀត កាលសម័យលោកធ្វើសង្គាយនានោះ ចំណែកវិន័យ លោកហៅថា ឧភតោវិន័យ ប្រែថា វិន័យមាន ២ យ៉ាងគឺ ភិក្ខុវិន័យ ១ ភិក្ខុនីវិន័យ ១ ។ ចំណែកធម៌ លោកហៅថា បញ្ចនិកាយ ប្រែថានិកាយ ៥ គឺ ទីឃនិកាយ ១ មជ្ឈិមនិកាយ ១ សំយុត្តនិកាយ ១ អង្គុត្តរនិកាយ ១ ខុទ្ទកនិកាយ ១ ។

មួយទៀត បរិយត្តិសទ្ធម្មនេះ តាំងពីធ្វើសង្គាយនាមកហើយ លោកហៅថា **តេបិដកំ ពុទ្ធវចនំ** *ជាវោហារប្រាកដនៅក្នុងគម្ពីរអដ្ឋកថា ។* **តេបិដកំ ពុទ្ធវចនំ** *ប្រែថា ពុទ្ធវចនៈ គឺប្រជុំបីនៃបិដក ។ លោកចាត់យកឧភតោវិន័យ ជាវិន័យបិដក ចាត់យកនិកាយ ៥ ជាបិដក ២ ។ ចំ-ណែករបៀបពាក្យដែលប្រកាសធម៌ល្អិតសុខុមខ្លះ មិនល្អិតសុខុមខ្លះដែលព្រះមានព្រះភាគទ្រង់សម្តែងថា គេយ្យៈខ្លះ វេយ្យាករណៈខ្លះ គាថាខ្លះ ឧទានខ្លះ ឥតិវុត្តកៈខ្លះ ជាតកៈខ្លះ អព្ភូតធម៌ខ្លះ វេទល្លៈខ្លះ និងដែលព្រះ*

សង្គីតិកាចារ្យលោកចាត់ទុកជារបៀបពាក្យ មាននិទានខ្លះ មិនមាននិទានខ្លះ ប្រជាប់ដោយអង្គគឺសុត្ត: ច្រើនខ្លះតិចខ្លះ ដូច្នេះឈ្មោះថាសុត្តន្តបិដក ។ លោកចាត់របៀបពាក្យដែលប្រកាសធម៌សុខុមល្អិតមិនមាននិទាន ប្រជាប់ដោយអង្គ ២ គឺ សុត្ត: និងវេយ្យាករណ: ដូច្នេះ ឈ្មោះថា អភិធម្មបិដក ។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យកាលចង្អុលបរិយត្តិសទ្ធម្ម ទើបពោលថា **"បិដកត្តយសង្ខ្យហិតំ សត្ថុ ពុទ្ធវចនំ បរិយត្តិសទ្ធម្មោ ជាម** *ប្រែថា ព្រះពុទ្ធវចន:ទាំងអស់ដែលលោកសង្គ្រោះដោយប្រជុំ ៣ នៃបិដក ឈ្មោះថា បរិយត្តិសទ្ធម្ម" ។ ឯពាក្យថា* **ពុទ្ធវចនំ** *ប្រែថា ព្រះពុទ្ធវចន:នោះ អ្នកប្រាជ្ញគប្បីដឹងថា ពាក្យដែលសាវក ឬឥសី ឬទេវតាសម្តែងហើយ តែព្រះពុទ្ធទ្រង់អនុមោទនាតាមក៏ឈ្មោះថា ពុទ្ធវចន: រាប់បញ្ចូលជាបរិយត្តិសទ្ធម្ម ។*

មួយទៀត បរិយត្តិសទ្ធម្មនេះ លោកសម្តែងថា ចាត់ដោយខន្ធ ជាពួកៗ មាន ៨៤.០០០ ខន្ធ ទើបបានសម្មតហៅថា ៨៤.០០០ ព្រះធម្មក្ខន្ធ ។ សព្វថ្ងៃនេះពុំមានអ្នកណាត្រួតត្រាពាក់មើលឲ្យដឹងថាលើសឬខ្វះបានឡើយ បរិយត្តិសទ្ធម្មនេះ អំពីដើមមក លោកទ្រទ្រង់ទុកដោយមុខចាប ១ កាលប្រតិស្ថានតាំងនៅក្នុងពួកព្រះអរិយ:ជាអ្នកមានសន្ធានដ៏បរិសុទ្ធ ព្រះបរិ-យត្តិសទ្ធម្មនេះក៏ជាធម៌បរិសុទ្ធស្អាត ប្រាសចាកសទ្ធម្មបដិរូប (ធម៌ក្លែម) ដូចមាសក្នុងព្រះឃ្នាំងហ្ជងដ៏បរិសុទ្ធប្រាសចាករបស់ក្លែម ។ លុះយូរមក

ព្រះពុទ្ធសាសនាកន្ធងទៅហើយបាន ៤០០ ឆ្នាំ ព្រះថេរៈទាំងឡាយ ក្នុងលង្កាទ្វីប ឃើញកុលបុត្រទាំងឡាយមានបញ្ញាតិច មិនអាចនឹងទ្រទ្រង់ទុកបានដោយមុខបាឬ ទើបចារឹកជាអក្សរទុកក្នុងស្លឹករឹត ។ លុះយូរមកកុលបុត្រមានបញ្ញាតិចចុះមកទៀត ទើបលោកតែងគម្ពីរអដ្ឋកថាអធិប្បាយបំភ្លឺព្រះបាលី តែងគម្ពីរដីកា អធិប្បាយបំភ្លឺអដ្ឋកថា ។ ព្រះបរិយត្តិសទ្ធម្មនេះ កាលប្រតិស្ឋានស្ថិតនៅក្នុងបុថុជ្ជន អ្នកមានសន្ដានមិនបរិសុទ្ធ ដូចព្រះអរិយៈ ប្រៀបបីដូចជាមាសប្រាក់នៅក្នុងដៃប្រជា-ជន ។ បុគ្គលជំពូកខ្លះជាកល្យាណបុថុជ្ជនមានសន្ដានដ៏ស្ងួតត្រង់ គោរពក្នុងព្រះបរិយត្តិសទ្ធម្មដ៏ច្រើន ។ បុគ្គលជំពូកខ្លះមានសន្ដានមិនបានស្ងួតត្រង់ គោរពក្នុងព្រះបរិយត្តិសទ្ធម្មដ៏តិច ។ ព្រោះហេតុនោះ សទ្ធម្មបដិរូប (ធម៌ឬម) ក៏ចូលឬមព្រះសទ្ធម្មផង ។ បុគ្គលជំពូកខ្លះតាក់តែងឡើងហើយអាងថាជាពុទ្ធវចនៈ ក៏មានដូចកុលម្ពសូត្រ ពជោវាទសូត្រ តិក្ខិន្ទ្រិយ-សូត្រជាដើម មានឈ្មោះប្រាកដនៅក្នុងអដ្ឋកថា សូត្រដូច្នោះ បុគ្គលជាអ្នកប្រាជ្ញរចនាទុកអាងថាពុទ្ធភាសិតខ្លះ សាវកភាសិតខ្លះ មាននៅជាច្រើន ដូចជា អគារវតារសូត្រ វិជ្ជានសូត្រ និងគម្ពីរដទៃៗ ។ ហេតុដូច្នោះ បើកុលបុត្រអ្នកមានប្រីជា កាលបើឃើញគម្ពីរនិងបាឬ: ដែលលោកអាងថាជាពុទ្ធភាសិត និងសាវកភាសិតឯណា ។ ក្ដី បើមាន

សេចក្តីសន្ទិះសង្ស័យ គួរគប្បីបដិបត្តិតាមមហាបទេស ៤ ដែលព្រះពុទ្ធអង្គទ្រង់សម្តែងទុក ជាគ្រឿងកាត់សេចក្តីធម្មវិន័យ ហើយត្រួតមើលព្យញ្ជនៈ និង អត្ថ បើវិបត្តិហើយ កុំគប្បីជឿ បើមិនវិបត្តិសោតក៏គួរជឿ ។ មួយទៀត ព្យញ្ជនៈបរិបូណ៌ព្រមហើយ តែអត្ថវិបត្តិ ក៏មិនគួរជឿ ។ របៀបពាក្យណាចង្អុលអត្ថ គឺសេចក្តីបដិបត្តិមិនប្រព្រឹត្តទៅដើម្បីវិន័យនាំចេញនូវអកុសល សង្កិលេសមានរាគៈជាដើម មិនបានរំងាប់នូវសេចក្តីលោភ សេចក្តីក្រោធ សេចក្តីវង្វេង ចេញបាន នឹងមិនប្រព្រឹត្តទៅដើម្បីអភិញ្ញាសេចក្តីដឹងក្រៃពេក ដឹងរបស់ពិត ៤ គឺអរិយសច្ច របៀបពាក្យនោះឈ្មោះថា វិបត្តិដោយអត្ថ មិនគួរជឿ ។ របៀបពាក្យណា សម្តែងអត្ថ គឺសេចក្តីបដិបត្តិប្រព្រឹត្តទៅដើម្បីវិន័យ នាំចេញបាននូវរាគៈ ទោសៈ មោហៈ ដ៏ជាអកុសលសង្កិលេស និងប្រព្រឹត្តទៅដើម្បីអភិញ្ញាសេចក្តីដឹងក្រៃពេក ដឹងនូវសេចក្តីពិតគឺសច្ចៈ ៤ របៀបពាក្យនោះ ឈ្មោះថាបរិបូណ៌ព្រមដោយអត្ថសម្បត្តិ ជារបស់គួរជឿ ។

មួយទៀត គប្បីកាត់សេចក្តីបរិយត្តិសទ្ធម្ម ដោយឱវាទដែលព្រះពុទ្ធអង្គទ្រង់សម្តែងដល់នាងមហាបជាបតី ដែលនឹងសម្តែងក្នុងបដិបត្តិសទ្ធម្មនោះផងចុះ ។ បរិយត្តិសទ្ធម្មនេះ ប្រែថាព្រះសទ្ធម្មគឺរបៀបពាក្យដែលបុគ្គលគប្បីដល់ដោយជុំវិញ គឺសិក្សាសូត្ររៀនឲ្យដឹងតាមអត្ថា-

ធិប្បាយក្នុងសំណាក់នៃអាចារ្យ ។ មួយទៀត បរិយត្តិសទ្ធម្មនេះ ជាធម៌អាស្រ័យហេតុខាងក្នុងពីរប្រការ គឺឧស្សាហ៌និងបញ្ញា អាស្រ័យ ហេតុខាងក្រៅ គឺកាលសម្បត្តិ ទើបប្រព្រឹត្តទៅដោយបរិសុទ្ធបរិបូណ៌ បាន ។

បរិយត្តិសទ្ធម្មកថា ចប់

បដិបត្តិសទ្ធម្មកថា

បុ. វត្ថុអ្វី ជាបដិបត្តិសទ្ធម្ម?

វិ. ត្រៃសិក្ខា គឺ សីល សមាធិ បញ្ញា, សិក្ខា ៣ នេះ ឈ្មោះថា បដិបត្តិសទ្ធម្ម ។

សីល គឺ សេចក្តីសង្រ្ទួម កាយ វាចា តាមសិក្ខាបទបញ្ញត្តិ បានដល់ បាតិមោក្ខសំវរសីល ដែលជាជេដ្ឋកសីល សម្រេចដោយអរិយសម្មតិ និងវិរតិ ការវៀរចាកវចីទុច្ចរិត ៤ កាយទុច្ចរិត ៣ មិច្ឆាជីវៈ ១ ដែលហៅថា អាជីវដ្ឋមកសីល សីលមានអាជីវៈជាគម្រប់ ៨ ដែលជាអាទិព្រហ្មចរិយ-កាសិក្ខា សម្រេចដោយសមាទានចេតនា ឈ្មោះថាសីលសិក្ខា ។

សមាធិ សេចក្តីតាំងចិត្តនៅក្នុងអារម្មណ៍តែមួយ គឺកុសលេកគ្គតា ភាពនៃចិត្តមានអារម្មណ៍តែមួយ ជាកុសលដែលកើតឡើងដោយសមថ-កម្មដ្ឋាន មានកសិណបរិកម្ម និងអសុភបរិកម្មជាដើម ដែលហៅថាអប្ប-នាសមាធិ ព្រោះជាសមាធិអែបជាប់ក្នុងអារម្មណ៍ ឬហៅថាអប្បនាឈាន ព្រោះថារបស់អែបជាប់សំឡឹងអារម្មណ៍មានកសិណជាដើមក្តី និងឧបចារ-សមាធិ ដែលជាសមាធិមិនទាន់ដល់នូវអប្បនាក្តី ឈ្មោះថាសមាធិសិក្ខា ។

បញ្ញា សេចក្តីដឹងច្បាស់នូវសង្ខារ គឺនាមរូប និងបញ្ចក្ខន្ធជាដើម

ថាជារបស់ មិនទៀង ជាទុក្ខ មិនមែនខ្លួន បានដល់វិបស្សនាបញ្ញា តាំងអំពីឧទយព្វយញ្ញាណដរាបដល់អនុលោមញ្ញាណ ដែលកើតឡើងដោយវិបស្សនាកម្មដ្ឋាននោះ ឈ្មោះថាបញ្ញាសិក្ខា ។

សីល សមាធិ បញ្ញា ទាំង ៣ នេះ ឈ្មោះថា សិក្ខា ព្រោះជាកិច្ចការក្នុងសាសនា ដែលបុគ្គលអ្នកប្រាថ្នានូវសេចក្តីអស់ទៅនៃទុក្ខ គប្បីសិក្សាឲ្យស្ទាត់ហើយបដិបត្តិតាម ។ សិក្ខាសព្វនេះ ប្រែថា ការសិក្សាក៏បាន ប្រែថា ធម្មជាតិដែលបុគ្គលគប្បីសិក្សាក៏បាន តែក្នុងបទនេះត្រូវប្រែថា ធម្មជាតិដែលបុគ្គលគប្បីសិក្សា ព្រោះសីល សមាធិ បញ្ញា ជាធម្មជាតិ ដែលបុគ្គលគប្បីសិក្សា ដ្បិតលោកពោលត្រៃសិក្ខានេះ ថាជាបដិបត្តិសទ្ធម្ម ។ សេចក្តីបដិបត្តិដ៏សេសដែលជាឧបការៈដល់ត្រៃសិក្ខាជាវត្តប្រវេណី ដែលព្រះពុទ្ធអង្គទ្រង់តែងតាំងទុកក្នុងវិនយខន្ធ មានបព្វជ្ជាខន្ធនិងឧបោសថខន្ធជាដើមក្តី និងសេចក្តីបដិបត្តិដែលព្រះពុទ្ធអង្គទ្រង់សម្តែងទុក ក្នុងព្រះសូត្រ មានអបណ្ណកបដិបទា ៣ គឺ ឥន្ទ្រិយ-សំវរៈ ភោជនេមត្តញ្ញុតា ជាគរិយានុយោគៈ និងអរិយវង្សបដិបទាជាដើមក្តី សេចក្តីបដិបត្តិទាំងអស់នេះ ក៏ពោលថាបដិបត្តិសទ្ធម្មដែរ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ កាលលោកចង្អុលបដិបត្តិសទ្ធម្ម ទើបលោកសម្តែងថា៖

"តេរសធុតង្គគុណា ចុទ្ទសខន្ធកវត្តានិ
ទ្វាសីតិមហាវត្តានិ សីលសមាធិវិបស្សនាតិ
បដិបត្តិសទ្ធម្មោ នាម

ប្រែថា ធុតង្គគុណទាំងឡាយ ១៣ វត្តទាំងឡាយដែលមកក្នុងខន្ធកវត្ត ១៤ មហាវត្តទាំងឡាយ ៨២ សីល សមាធិ វិបស្សនា ដូច្នេះទាំងអស់នេះ ឈ្មោះថា បដិបត្តិសទ្ធម្ម" ។

ធុតង្គគុណ ១៣ នោះគឺ បង្សុកូលិកង្គ: តេចីវរិកង្គ: បិណ្ឌបាតិកង្គ: សបទានចារិកង្គ: ឯកាសនិកង្គ: បត្តបិណ្ឌិកង្គ: ខលុបច្ឆាភត្តិកង្គ: សោសានិកង្គ: អរញ្ញិកង្គ: រុក្ខមូលិកង្គ: អព្ភោកាសិកង្គ: យថាសន្ថតិកង្គ: នេសជ្ជិកង្គ: ធុតង្គទាំង ១៣ នេះ កើតអំពីអរិយវង្សបដិបទា ។

ខន្ធកវត្ត ១៤ នោះគឺ អាគន្តុកវត្ត អាវាសិកវត្ត គមិកវត្ត អនុមោ-ទនវត្ត ភត្តគ្គវត្ត បិណ្ឌបាតចារិកវត្ត អរញ្ញិកវត្ត សេនាសនវត្ត ជន្ទាឃ-វត្ត វច្ចកុដិវត្ត ឧបជ្ឈាយវត្ត សទ្ធិវិហារិកវត្ត អាចរិយវត្ត អន្តេវាសិកវត្ត ។

មហាវត្ត ៨២ នោះ គឺ វត្តដែលព្រះអង្គទ្រង់បញ្ញត្តដល់ភិក្ខុបរិវាសិក: តាំងអំពីឃាត់មិនឲ្យឧបសម្ប័ទដល់កុលបុត្រ ដរាបដល់ឃាត់ថា កាលភិក្ខុជាបកតត្ត: ចង្ក្រមនៅលើផែនដី កុំចង្ក្រមលើទីចង្ក្រមណ៍ជាទីបំផុត រាប់បាន ៦៦ និងវត្តដែលព្រះអង្គទ្រង់ឃាត់ថា កុំនៅក្នុងអាវាសដែលប្រក់ចាំងក្នុងទីជាមួយគ្នាមួយអន្ទើដោយភិក្ខុបរិវាសិក:ចាស់ជាង និងដោយភិក្ខុអ្នក

ជាមូលាយបដិកស្សនារហ: និងកិក្ខុជាមានត្តារហ: កិក្ខុជាមានត្តចារី កិក្ខុជាអញ្ញានារហ: រាប់បាន ៥ ផ្សំនឹងវត្ត ៦៦ ត្រូវជា ៧១ មួយអន្ទើនឹងវត្តដែលព្រះពុទ្ធអង្គទ្រង់បញ្ញត្តដល់កិក្ខុ ដែលសង្ឆឡើងឧក្ខេបនីយកម្ម ឃាត់មិនឲ្យត្រេកអរសាមីចិកម្ម មានការក្រាបសំពះជាដើម នៃកិក្ខុជាបកតត្ត:រាប់ជា ១ មួយអន្ទើនឹងវត្តមានឃាត់មិនឲ្យចោទកិក្ខុជាបកតត្ត:ដោយសីលវិបត្តិជាដើម ១០ ទៀត រួមគ្នាជា ១១ ទើបគ្រប់ជាមហាវត្ត ៨២ ។ មហាវត្ត ៨២ នេះជាវត្តគប្បីប្រព្រឹត្តក្នុងកាលម្តងៗ មិនត្រូវប្រព្រឹត្តក្នុងកាលទាំងពួង ព្រោះហេតុនោះ ទើបមិនបានរាប់បញ្ចូលក្នុងខន្ធកវត្ត ១៤ ។ សីលសមាធិនោះ ដូចសម្តែងមកហើយ តែបញ្ញាក្នុងបទនេះហៅថាវិបស្សនា ព្រោះលោកបំណងឲ្យឃើញថា ត្រៃសិក្ខាដែលចាត់ជាបដិបត្តិសទ្ធម្មនេះ ជាលោកិយ-ធម៌ មិនមែនជាលោកុត្តរធម៌ ។ បដិបត្តិសទ្ធម្មនេះ កាលប្រតិស្ឋាននៅក្នុងព្រះអរិយ: លោកមានសន្ដានដ៏បរិសុទ្ធ និងកល្យាណបុថុជ្ជនលោកមានសន្ដានដ៏ស្ងួតត្រង់ប្រកបដោយប្រាជ្ញា និងអាស្រ័យកាលសម្ដ្ដិក៏បរិបូណ៌ បរិសុទ្ធប្រាសចាកទោសគឺសទ្ធម្មបដិរូប ដូចមាសដែលប្រតិស្ឋាននៅក្នុងដៃនៃមនុស្សស្ងួតត្រង់ឈ្វាសវៃមើលដឹងរបស់ពិតនិងរបស់ក្ងម ឬអាស្រ័យកាលសម្ដ្ដិផង ក៏បរិបូណ៌បរិសុទ្ធប្រាសចាកទោស គឺជាតរូបបដិរូបរបស់ធ្វើក្ងម ។ បដិបត្តិសទ្ធម្មនេះ កាលអាស្រ័យកាលវិបត្តិ ក៏មិនបរិបូណ៌ និងអាស្រ័យបុថុជ្ជនអ្នកមានសន្ដានមិនស្ងួតត្រង់ប្រកបដោយអគារវ:ច្រើន

ដោយសំឡឹងលោកាមិស ក៏ជាការមិនបានបរិបូណ៌បរិសុទ្ធប្រាសចាកទោស បដិបត្តិសទ្ធម្មបដិរូបក៏កើតឡើង ដូចពួកភិក្ខុវជ្ជីបុត្របញ្ញត្តនូវវត្ថុ ១០ ប្រការ ក្នុងកាលមុននោះ ព្រោះហេតុនោះបដិបត្តិសទ្ធម្ម ដែលនាំតៗ គ្នាមកអស់កាលយូរដរាបមកដល់កាលឥឡូវនេះ ម្តេចឡើយក៏មិនសាបសូន្យសោហ្ម៑ ។ សេចក្តីបដិបត្តិជាការមិនពិត និងសេចក្តីបដិបត្តិបូមដែលឈ្មោះថា សទ្ធម្មបដិរូប ក៏កើតឡើងផ្សេងៗ ដូចប្រកាន់ថាដើរចង្ក្រមអាបត្តិធ្លាក់អស់ យូរៗបរិវាស មានត្តចេញម្តង ជម្រះខ្លួនឲ្យបរិសុទ្ធ និងបដិបត្តិបែបដទៃទៀតក្នុងផ្លូវសីលក៏មានជាច្រើន និងប្រកាន់បរិកម្មថា អ.សំ.រ.សុ.លោ.បុ.ស.ពុ.ភ ឈ្មោះថាចម្រើនពុទ្ធគុណក្តី និងអញ្ជើញព្រះបីតិទាំង ៥ និងតាំងចិត្តទុកក្នុងទ្រូងជាដើម ហើយបរិកម្មថា **អរហំ** ។ មិនដឹងអធិប្បាយថាជាអ្វីឡើយ ហើយឃើញពណ៌ផ្សេងៗ សម្គាល់ថា ព្រះមកប្រាស ហើយក៏ប្រកាន់ថា សម្រេចក្នុងភូមិសមាធិប៉ុណ្ណោះ និងបដិបត្តិក្នុងសមាធិបញ្ញាដែលខុសទៅជាបែបដទៃ ។ ដែលជ្រោកជ្រាកនិងល្អិតជាងពោលមកនេះ ក៏មានច្រើន កាលបើដូច្នេះ អ្នកស្វែងរកបដិបត្តិសទ្ធម្មដែលពិតប្រាកដ គប្បីធ្វើខ្លួនឲ្យជាមនុស្សស្ងួតត្រង់ ។ ស្វែងរកនូវបរិយត្តិសទ្ធម្មដែលពិតប្រាកដនោះចុះ ក៏គង់នឹងបានដឹងបានឃើញ ។

មួយទៀត បើមានសេចក្តីសង្ស័យក្នុងផ្លូវបដិបត្តិនិងបរិយត្តិជំពូកខ្លះ

ហើយ គប្បីកាត់សេចក្តីសង្ស័យដោយឱវាទ ដែលព្រះពុទ្ធអង្គទ្រង់ប្រដៅនាងបជាបតិគោតមីដូច្នេះថា "ម្នាលនាងគោតមី បើនាងដឹងថា ធម៌ទាំងឡាយណា ប្រព្រឹត្តទៅដើម្បីសរាគៈ:ប្រកបដោយតម្រេកនៃចិត្ត មិនប្រព្រឹត្តទៅដើម្បីវិរាគៈ: សេចក្តីប្រាសចាកតម្រេកនៃចិត្ត ប្រព្រឹត្តទៅដើម្បីសំយោគៈ: សេចក្តីប្រកបព្រមដោយទុក្ខ មិនប្រព្រឹត្តទៅដើម្បីវិសំយោគៈ: សេចក្តីប្រាសចាកទុក្ខ ប្រព្រឹត្តទៅដើម្បីអាចយៈ:សេចក្តីសន្សំធ្វើឡើងនូវវដ្ត: មិនប្រព្រឹត្តទៅដើម្បីអបចយៈ:សេចក្តីមិនសន្សំធ្វើឡើងនូវវដ្ត: ប្រព្រឹត្តទៅដើម្បីមហិច្ឆតា ភាពជាអ្នកមានសេចក្តីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅដើម្បីអប្បិច្ឆតា ភាពជាអ្នកមានសេចក្តីប្រាថ្នាតិច ប្រព្រឹត្តទៅដើម្បីអសន្តុដ្ឋិ សេចក្តីមិនសន្ទោស ត្រេកអរដោយវត្ថុដែលខ្លួនមាន មិនប្រព្រឹត្តដើម្បីសន្តុដ្ឋិ សេចក្តីសន្ទោសត្រេកអរដោយវត្ថុដែលខ្លួនមាន ប្រព្រឹត្តទៅដើម្បីសង្គណិកា ភាពជាអ្នកច្រឡូកច្រឡំដោយពួក មិនប្រព្រឹត្តទៅដើម្បីបវិវេក សេចក្តីស្ងាត់ចាកពួក ប្រព្រឹត្តទៅដើម្បីកោសជ្ជ: សេចក្តីខ្ជិលច្រអូស មិនប្រព្រឹត្តទៅដើម្បីវិរិយារម្ភ: សេចក្តីប្រារព្ធនូវព្យាយាម ប្រព្រឹត្តទៅដើម្បីទុព្ភរតា ភាពជាអ្នកដែលគេចិញ្ចឹមបានដោយក្រ មិនប្រព្រឹត្តទៅដើម្បីសុភរតា ភាពជាអ្នកដែលគេចិញ្ចឹមបានដោយងាយ ។ ម្នាលនាងគោតមី នាងគប្បីចាំទុកដោយដាច់ខាតចុះថា

នុ៎ះមិនមែនជាធម៌ នុ៎ះមិនមែនជាវិន័យ នុ៎ះមិនមែនជាសត្ថុសាសន: ពាក្យប្រដៅរបស់ព្រះសាស្តាទេ ។ ម្នាលនាងគោតមី បើនាងដឹងថា ធម៌ទាំងឡាយណា ប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេកនៃចិត្ត មិនបាន ប្រព្រឹត្តទៅដើម្បីតម្រេកនៃចិត្ត ប្រព្រឹត្តទៅដើម្បីប្រាសចាកទុក្ខ មិន ប្រព្រឹត្តទៅដើម្បីប្រកបដោយទុក្ខ ប្រព្រឹត្តទៅដើម្បីមិនសន្សំធ្វើឲ្យច្រើន ឡើងនូវវដ្ត: មិនប្រព្រឹត្តទៅដើម្បីសន្សំធ្វើឲ្យច្រើនឡើងនូវវដ្ត: ប្រព្រឹត្ត ទៅដើម្បីជាអ្នកមានសេចក្តីប្រាថ្នាតិច មិនប្រព្រឹត្តទៅដើម្បីជាអ្នកមាន សេចក្តីប្រាថ្នាច្រើន ប្រព្រឹត្តទៅដើម្បីសន្តោសត្រេកអរ ដោយវត្ថុដែល ខ្លួនមាន មិនប្រព្រឹត្តទៅដើម្បីមិនសន្តោស ប្រព្រឹត្តទៅដើម្បីបវិវេក សេចក្តីស្ងាត់ចាកពួក មិនប្រព្រឹត្តទៅដើម្បីជាអ្នកច្រឡូកច្រឡំដោយពួក ប្រព្រឹត្តទៅ ដើម្បីប្រារព្ធ នូវសេចក្តីព្យាយាម មិនបានប្រព្រឹត្តទៅដើម្បី សេចក្តីខ្ជិលច្រអូស ប្រព្រឹត្តទៅ ដើម្បីភាពជាអ្នកដែលគេចិញ្ចឹមងាយ មិនប្រព្រឹត្តទៅដើម្បីភាពជាអ្នកដែលគេចិញ្ចឹមបានដោយក្រ ។ ម្នាលនាង គោតមី នាងគប្បីចាំទុកដោយដាច់ខាតចុះថា នុ៎ះជាធម៌ នុ៎ះជាវិន័យ នុ៎ះជាសត្ថុសាសន: ពាក្យប្រដៅរបស់ព្រះសាស្តា ។ សុគតោវាទនេះ ជាលក្ខណ:សម្រាប់កាត់សេចក្តីនៃព្រះសទ្ធម្មនិងសទ្ធម្មបដិរូប ។

ក៏ឯបដិបត្តិសទ្ធម្មនេះ ប្រែថា សទ្ធម្ម គឺសេចក្តីចរទៅ ដំណើរទៅ

ដ្ឋិតថា ត្រៃសិក្ខានេះ ជាផ្លូវនៃព្រះនិព្វាន កាលបើកុលបុត្រសិក្សា ហើយបដិបត្តិតាម ក៏ឈ្មោះថា ចរទៅ ដំណើរទៅ តាមផ្លូវព្រះនិព្វាន ។ បដិបត្តិសទ្ធម្មនេះ ជាធម៌អាស្រ័យហេតុខាងក្នុង គឺសទ្ធានិងបញ្ញា ទាំងពីរប្រការ ទើបកើតឡើងបរិបូណ៌បរិសុទ្ធបាន ។

បដិបត្តិសទ្ធម្មកថា ចប់

អធិគមសទ្ធម្មកថា

បុ. អធិគមសទ្ធម្ម នោះ ដូចម្តេច?

វិ. មគ្គ ៤ ផល ៤ និព្វាន ១ ឈ្មោះថាអធិគមសទ្ធម្ម ។

មគ្ត ប្រែថា ផ្លូវធម៌ ៨ ប្រការគឺ **សម្មាទិដ្ឋិ** ការឃើញប្រពៃ គឺឃើញសច្ច: ៤ **សម្មាសង្កប្ប** ការត្រិះរិះប្រពៃ គឺត្រិះរិះប្រកបដោយនេក្ខម្ម: អព្យាបាទ អវិហិង្សា **សម្មាវាចា** វាចាប្រពៃ គឺការវៀរចាកវចីទុច្ចរិត ៤ **សម្មាកម្មន្ត** ការងារប្រពៃ គឺការវៀរចាកកាយទុច្ចរិត ៣ **សម្មាអាជីវ** ការចិញ្ចឹមជីវិតប្រពៃ គឺការលះបង់នូវមិច្ឆាជីវ: ការចិញ្ចឹមជីវិតខុស **សម្មាវាយាមោ** ការព្យាយាមប្រពៃ គឺសម្មប្ផធាន ៤ **សម្មាសតិ** ការរឭកប្រពៃ គឺសតិបដ្ឋាន ៤ **សម្មា-សមាធិ** ការតាំងចិត្តទុកប្រពៃគឺឈាន ៤ ។ ចេតសិកធម៌ ៨ នេះ ឈ្មោះថាអង្គនៃមគ្គជាទីប្រជុំនៃធម៌ ៨ ដែលកើតឡើងព្រមគ្នាធ្វើកិច្ចរបស់ខ្លួនៗនោះ ឈ្មោះថាមគ្គព្រោះជាផ្លូវនៃព្រះនិព្វាន ដោយវោហារប្ញញ្ញត្តិនៃព្រះពុទ្ធអង្គ ព្រោះហេតុនោះ ព្រះពុទ្ធអង្គទើបទ្រង់សម្តែងថា មគ្គជារបស់ព្រះអរិយ: ប្រកបដោយអង្គ ៨ ។

ផល ប្រែថា ការបែកចេញ គឺសេចក្តីចាស់ក្ងាមកអំពីមគ្ត បាន

ដល់ការរំដាប់នៃប្រយោគ ក្នុងកិរិយាចេញចាកកិលេស នៃសម្មាទិដ្ឋិ ជាដើម នេះឈ្មោះថា ផល ។

ដែលឈ្មោះថា មគ្គ ៤ ផល ៤ នោះ គឺ សោតាបត្តិមគ្គ សោតា-បត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផល ។

ឯមគ្គ ៤ ផល ៤ នោះ តាមនិយមដែលលះកិលេសនោះៗ បាន និងគុណវិសេសដែលសម្រេចមកអំពីការលះកិលេស ។

នឹងសម្តែងអំពីកិលេសដែលមគ្គនោះៗត្រូវលះបង់សិន ។ សំយោជន: មាន ១០ គឺ **សក្កាយទិដ្ឋិ** ការឃើញខុសអាស្រ័យខន្ធ ឈ្មោះថា សក្កាយ: គឺការឃើញរូបថាជាខ្លួន ខ្លួនជារូប ដូចប្រទីបកំពុងឆេះ ឃើញ អណ្តាតជាពន្លឺ ពន្លឺជាអណ្តាត និងឃើញថាខ្លួនមានរូប ដូចដើមឈើ មានស្រមោល និងឃើញថារូបក្នុងខ្លួន ដូចជាក្ងិនក្នុងផ្ការ៉ាយ និងឃើញ ថាខ្លួនក្នុងរូប ដូចកែវមណីក្នុងប្រអប់ ឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន ខ្លួនជាវេទនា ជាសញ្ញា ជាសង្ខារ ជាវិញ្ញាណ ខ្លួនមាន វេទនា សញ្ញា សង្ខារ វិញ្ញាណ ដូច្នេះជាដើម ១ ។

វិចិកិច្ឆា ការសង្ស័យក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឆ និងក្នុង កាលទាំងបី ១ សីលព្វតបរាមាស: ការបបោសអង្ហែល គឺប្រកាន់ ថាបរិសុទ្ធដោយសីលវ័ត្តខាងក្រៅសាសនា គឺប្រក្រតី ទំនៀម ដូចវ័ត្តគោ

ជាដើម ១ កាមរាគ: ការត្រេកត្រអាលក្នុងកាមគុណមានអារម្មណ៍ដែលក្នុកឃើញជាដើម ១ បដិឃ: ការថ្នាំងថ្នាក់នៃចិត្ត ១ រូបរាគ: ការត្រេកអរក្នុងរូប គឺរូបាវចរឈាននិងរូបាវចរកុព ១ អរូបរាគ: ការត្រេកអរក្នុងអរូបធម៌ គឺអរូបាវចរឈាននិងអរូបាវចរកុព ១ មាន: ការសម្គាល់ឃើញថាយើងប្រសើរ យើងដូចគេ យើងទាបជាងគេ ជាដើម ១ ឧទ្ធច្ច: ការអណ្តែតអណ្តូងមិនស្ងប់ចិត្ត ១ អវិជ្ជា ការមិនដឹងច្បាស់នូវអរិយសច្ចជារបស់ពិត ៤ យ៉ាង ១ កិលេស ១០ នេះឈ្មោះថា សំយោជន: ព្រោះជាគ្រឿងប្រកប គ្រឿងតនូវខ្ទ ដោយខ្ទ និងតនូវកម្មដោយផល ។ មួយទៀត ព្រោះជាគ្រឿងប្រកបសត្វទុកដោយទុក្ខ ទើបបានឈ្មោះថា សំយោជន: ។

សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្ពតបរាមាស: កាមរាគ: បដិឃ: ទាំង ៥ នេះឈ្មោះថា ឱរម្ភាគិយសំយោជន: ប្រែថា សំយោជន: ចំណែកខាងក្រោមគឺ កាមកុព ព្រោះជាគ្រឿងធ្វើសត្វឲ្យកើតក្នុងកាមកុពដែលជាចំណែកខាងក្រោម ។

សំយោជន: ចំណែកខាងចុង ៥ គឺ រូបរាគ: អរូបរាគ: មាន: ឧទ្ធច្ច: អវិជ្ជា នេះឈ្មោះថា ឧទ្ធម្ភាគិយសំយោជន: ប្រែថា សំយោជន:ចំណែកខាងលើ ព្រោះជាកិលេសដ៏ល្អិតមានដល់សត្វដែលកើតក្នុងរូបកុពនិងអរូបកុព និងធ្វើសត្វឲ្យកើតក្នុងរូបកុពនិងអរូបកុព ។

សំយោជនៈ ៣ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្ពតបរាមាសៈ សោតា-
បត្តិមគ្គ លះដាច់ ព្រមទាំងលះកាមរាគៈ បដិឃៈ ដែលជាអបាយគামី
ជាកិលេសក្លា ញ៉ាំងសត្វឲ្យទៅកើត ក្នុងអបាយភូមិបាន ។ កាមរាគៈ
បដិឃៈ ទាំងពីរនេះជាចំណែកជ្រោកជ្រាក សកទាគামិមគ្គ លះដាច់
ព្រោះសកទាគামិមគ្គធ្វើ រាគៈ ទោសៈ មោហៈ ឲ្យស្រាលស្តើង ទើប
លះកិលេសដូច្នេះបាន ។ កាមរាគៈ បដិឃៈ សំយោជនៈពីរនេះ ដែលជា
កិលេសដ៏ល្អិតសល់នៅនោះ គឺអនាគামិមគ្គលះបាន ដោយដាច់ខាត ។
ឧទ្ធម្ភាគិយសំយោជនៈខាងចុង ៥ នោះ អរហត្តមគ្គ លះបង់បានដោយ
មិនមានសេសសល់ ដូច្នេះ ឈ្មោះថាមគ្គ ៤ ដោយនិយមនៃកិលេស-
ប្បហានៈ ការលះកិលេសនោះដូច្នេះឯង អ្នកប្រាជ្ញគប្បីដឹងចុះ ។
ចំណែកផលដែលសម្តែងមកថាមាន ៤ នោះ ក៏តាមនិយមនៃមគ្គ ព្រោះថា
សោតាបត្តិមគ្គកើតឡើង ក៏សម្រេចកិច្ចរបស់ខ្លួន គឺសម្លាប់សំយោជនៈ ៣
ដាច់ហើយរលត់ទៅ សោតាបត្តិផល ដែលជាគុណគឺការស្ងប់រំងាប់
នៃសេចក្តីខ្ជល់ខ្វាយក្នុងកិច្ចដែលនឹងសម្លាប់ នូវសំយោជនៈនោះទៀត ក៏
កើតឡើងក្នុងលំដាប់នៃសោតាបត្តិមគ្គនោះ ។ សូម្បីសកទាគামិផល
អនាគামិផល អរហត្តផល ទាំងអម្បាលនេះក៏ដូចគ្នា ព្រោះជាគុណ គឺ
ការស្ងប់ នៃប្រយោគក្នុងកិច្ចដែលនឹងចេញចាកកិលេស សម្លាប់កិលេស
នោះ។ កើតឡើងក្នុងលំដាប់នៃមគ្គនោះ ។ ដូច្នេះឯង ទើបបានឈ្មោះថា

ផល ៤ ដោយនិយមនៃប្រយោគឬស្សទ្ធិ ការស្ងប់នៃប្រយោគនោះដូច្នេះ ។

មួយទៀត មគ្គជាហេតុ គឺលោកុត្តរកុសល ផលជាសេចក្ដីចាស់ក្លា នៃមគ្គគឺលោកុត្តរវិបាក ផលកើតអំពីមគ្គ មគ្គកើតអំពីគោត្រភូ គោត្រភូ កើតអំពីអនុលោម អនុលោមកើតអំពីឧបចារៈ ឧបចារៈកើតអំពីសង្ខា-រូបេក្ខាញាណ គឺតួវិបស្សនាបញ្ញាដែលមានកម្លាំងក្លាជាងវិបស្សនាញាណ ទាំង ៧ មានឧទយព្វយានុបស្សនាញាណជាដើម ។ មគ្គនិងផលកើត ឡើងក្នុងវិថីចិត្តជាមួយគ្នា ។ ចិត្តជាកុសលក្ដី ជាអកុសលក្ដី កើតឡើង ក្នុងខណៈនៃជវន គឺការស្ទុះទៅនៃចិត្ត ។ ជវនចិត្តស្ទុះទៅ គឺកើតឡើង តាំងនៅរលត់ទៅ តែប្រាំពីរដងជាយ៉ាងក្រៃពេក ។ ព្រះយោគាវចរឃើញ ថាសង្ខារមិនទៀង ជាទុក្ខ មិនមែនរបស់ខ្លួន ដោយបញ្ញាដ៏ចាស់ក្លា ដរាប ដល់ព្រងើយកន្ដើយក្នុងសង្ខារទាំងពួង។ ការឃើញដូច្នេះ ឈ្មោះថាសង្ខា-រូបេក្ខាញាណ ។ សង្ខារូបេក្ខាញាណ កាលបើមានកម្លាំងខ្លាំងក្លាហើយ ក្នុងខណៈនៃមគ្គនឹងកើតឡើងនោះ ចិត្តដែលសម្បយុត្តដោយសង្ខារូបេក្ខា-ញាណចុះកាន់ភវង្គហើយ មនោទ្វារវជ្ជនចិត្ត ដែលជាកិរិយា ក៏កើតឡើង ជវនចិត្តប្រព្រឹត្តទៅប្រាំពីរដង ជវនចិត្តជាដំបូង ឈ្មោះថា បរិកម្ម ជវនចិត្ត ជាគម្រប់ពីរ ឈ្មោះថា ឧបចារៈ ជវនចិត្តជាគម្រប់បី ឈ្មោះថា អនុលោម ជវនចិត្តជាគម្រប់បួន ឈ្មោះថា គោត្រភូ ជវនចិត្តជាគម្រប់ប្រាំជាវារៈនៃមគ្គ ជវនចិត្តជាគម្រប់ប្រាំមួយ ប្រាំពីរ ឈ្មោះថាផល ។ បញ្ញាដែលមានក្នុង

ចិត្តក្ខណៈទាំង ៣ គឺបរិកម្ម ឧបចារៈ អនុលោម នោះរួមចូលគ្នា ឈ្មោះថា អនុលោមញ្ញាណ ព្រោះជារបស់អនុលោមដល់វិបស្សនាញាណទាំង ៨ មានឧទយព្វយានុបស្សនាញាណជាដើម ក្នុងខាងក្រោម និងជារបស់អនុលោមដល់ពោធិបក្ខិយធម៌ ៣៧ ក្នុងខាងលើ ។ បញ្ញាក្នុងខណៈចិត្ត ឈ្មោះថាគោត្រភូនោះ ហៅថាគោត្រភូញាណ ព្រោះជាបញ្ញាគ្របសង្កត់នូវគោត្រ គឺភូមិនៃបុថុជ្ជន និងចូលកាន់អរិយភូមិ ។ បញ្ញាក្នុងខណៈនៃមគ្គចិត្តនោះ ឈ្មោះថា មគ្គញ្ញាណ ព្រោះធ្វើនូវកិច្ច ៤ ប្រការគឺបរិញ្ញាកំណត់ដឹងនូវទុក្ខ ១ បហានៈលះកិលេស ១ សច្ឆិកិរិយា ឃើញព្រះនិព្វាន ១ ភាវនា ញុំងមគ្គឲ្យកើតឡើង ១ ។ បញ្ញាក្នុងខណៈផលចិត្តនោះ ឈ្មោះថា ផលញ្ញាណ ព្រោះជាការសូប់នៃប្រយោគក្នុងកិច្ចដែលនឹងលះនូវកិលេស ។ ឯអនុលោមញ្ញាណ ៣ នោះ ជាលោកិយកុសល លោកិយ-បញ្ញា ធ្វើនូវសង្ខារឲ្យជាអារម្មណ៍ ដោយសេចក្តីថាមិនទៀង ជាទុក្ខ មិនមែនជារបស់ខ្លួន និងជាញាណទីបំផុតនៃវុដ្ឋានគាមិនីវិបស្សនា ដែលមានសង្ខារជាអារម្មណ៍ សម្តែងដោយនិរវសេស គោត្រភូញាណជាទីបំផុតនៃវុដ្ឋានគាមិនីវិបស្សនា តែថាជាលោកិយបញ្ញាលះបង់នូវសង្ខារចេញ ទាញយកព្រះនិព្វានជាអារម្មណ៍ និងជាញាណតាំងនៅក្នុងកិច្ចជាអាវជ្ជនៈនៃមគ្គ ។ លោកិយបញ្ញាដែលឃើញព្រះនិព្វាន មានតែគោត្រភូញាណមួយប៉ុណ្ណោះ តែថាលះកិលេសមិនបាន ។ មគ្គញ្ញាណជាលោកុត្តរកុសល

លោកុត្តរប្ញញ្ញាធ្វើព្រះនិព្វានជាអារម្មណ៍សម្រាប់នូវកិលេសបាន ទើបចាត់ជាលោកុត្តរកុសល លោកុត្តរប្ញញ្ញា ។ ផលញ្ញាណក៏ជាលោកុត្តរប្ញញ្ញាធ្វើព្រះនិព្វានជាអារម្មណ៍ តែថាមិនសម្រាប់កិលេស គ្រាន់តែជាអានិ-សង្ស គឺការស្ងប់រំងាប់នៃសេចក្ដីខ្ជល់ខ្ជាយក្នុងកិច្ចដែលនឹងសម្រាប់កិលេសប៉ុណ្ណោះ ទើបចាត់ជាលោកុត្តរវិបាក ជាផលដ៏ចាស់ក្លាកើតមកអំពីមគ្គ ។

មួយទៀត ផលចិត្តក្នុងមគ្គវិថីនេះជា ៣ ក៏មាន ព្រោះអនុលោមចិត្តកើតតែពីរដង មិនបានកើតបីដងដូចវារៈមុន គោត្រភូចិត្តកើតក្នុងវារៈគម្រប់ ៣ មគ្គចិត្តកើតក្នុងវារៈជាគម្រប់ ៤ ផលចិត្តទើបជា ៣ ដូច្នេះ ក៏ឯផលចិត្តនោះចុះកាន់ភវង្គ:ហើយ មនោទ្វារវជ្ជនចិត្តកើតឡើងហើយ តទៅមគ្គប្ញច្ចវេក្ខណញ្ញាណ គឺបញ្ញាដែលពិចារណាមគ្គក៏កើតឡើងស្ទុះទៅ ៧ ដងដូចគ្នា សូម្បីផលប្ញច្ចវេក្ខណញ្ញាណ បញ្ញាដែលពិចារណាផលនិងបហីនកិលេសប្ញច្ចវេក្ខណញ្ញាណ បញ្ញាពិចារណាកិលេស ដែលមគ្គលះហើយក្ដី និងអវសិដ្ឋកិលេសប្ញច្ចវេក្ខណញ្ញាណ បញ្ញាពិចារណាកិលេសដែលសល់នៅក្ដី និងនិព្វានប្ញច្ចវេក្ខណញ្ញាណ បញ្ញាពិចារណានូវព្រះនិព្វានក្ដី ទាំងអស់នេះក៏កើតឡើងតាមលំដាប់ ដោយនិយមដូចសម្ដែងមកហើយក្នុងមគ្គប្ញច្ចវេក្ខណញ្ញាណនោះ បច្ចវេក្ខណញ្ញាណទាំង ៥ នេះ រមែងកើតមានដល់ព្រះអរិយ: ជាចំណែកខាងក្រោម ៣ ពួកគឺ ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី តែព្រះអរហន្តនោះ

មានតែ ៤ ព្រោះអវសិដ្ឋកិលេសប្ឋច្ចវេក្ខណញ្ញាណ មិនមាន ដែលសម្តែងមកនេះ មិនបាននិយម ថាមគ្គ ផលណាមួយឡើយ គ្រាន់តែសម្តែងដោយសាមញ្ញ ដើម្បីនឹងឲ្យដឹងលំដាប់វារៈ នៃមគ្គចិត្តនិងផលចិត្ត ប៉ុណ្ណោះ ។ ឯមគ្គទាំង ៤ មគ្គនីមួយៗ កើតក្នុងចិត្តវារៈមួយៗ គ្រប់ៗ មគ្គមិនកើតច្រើនដងដូចជាផល ចំណែកផលទាំង ៤ នោះ ផលនីមួយៗ ក្នុងមគ្គវិថីនីមួយៗ កើតឡើង ២ ដងខ្លះ ៣ ដងខ្លះ ដូចសម្តែងមកហើយ ក្នុងផលសមាបត្តិវិថី គឺការដែលព្រះអរិយៈនោះៗ នឹងចូលកាន់ផល-សមាបត្តិ រមែងប្រព្រឹត្តទៅតែតាមផលនិយមនៃខ្លួនៗ ។ ផលចិត្តនោះ កើត ៣ ដងខ្លះ ៤ ដងខ្លះ ព្រោះមគ្គចិត្តនោះមិនមានក្នុងវិថីនៃផលសមាបត្តិ ព្រោះថាកិច្ចដែលនឹងសម្ងាប់នូវកិលេសដែលមគ្គនោះៗ សម្ងាប់ហើយទៀត ក៏មិនមានដល់ព្រះអរិយៈដែលបានហើយនូវផលនោះ ។ មួយទៀតព្រះអរិយៈដែលបាននូវសោតាបត្តិផលហើយ ឈ្មោះថាព្រះសោតាបន្ន ព្រះសោតាបន្ននោះ អង្គខ្លះគង់លើអាសនៈដែលបានផលនោះឯង ចម្រើននូវវិបស្សនាតៗឡើងទៅបានសកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល និងអរហត្តមគ្គ អរហត្តផល ដោយលំដាប់ក៏មាន អង្គខ្លះក្រោកចាកអាសនៈនោះហើយ ក្នុងសម័យដទៃចម្រើននូវវិបស្សនាតៗឡើងទៅទើបបានសម្រេចនូវមគ្គនិងផលនោះៗដោយលំដាប់ក៏មាន ។ ឯសោតា-បត្តិមគ្គ សោតាបត្តិផល ប្រែថា មគ្គ ថា ផល នៃលោកអ្នកសម្រេចនូវធម៌

ជាដំបូងឈ្មោះថា សោត: គឺ មគ្គ ។ សោត: ស័ព្ទនេះប្រែថា "ក្រសៃនៃទឹក" តែក្នុងបទនេះ សោតស័ព្ទ ជាឈ្មោះនៃមគ្គ ព្រោះថាមគ្គ ដូចជាក្រសៃនៃទឹក ដែលនឹងនាំសត្វទៅកាន់ព្រះនិព្វាន ព្រោះហេតុនោះ ព្រះពុទ្ធអង្គ ទ្រង់ត្រាស់ថា ៖

"**និព្វានគាមិនី ភិក្ខវេ សម្មាទិដ្ឋិ និព្វានចោណា និព្វានបញ្ជ្ជា** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិ ការឃើញប្រពៃ ដែលជាប្រធាននៃអង្គមគ្គ រមែងជាធម៌ដ៏ទេរទៅកាន់ព្រះនិព្វាន ជាធម៌ទោរទៅកាន់ព្រះនិព្វាន ជាធម៌ទ្រិនទៅកាន់ព្រះនិព្វាន ដូចជាខ្សែនៃទឹកដែលហូរទៅកាន់មហាសមុទ្ទ" ដូច្នោះ ។ ព្រះអរិយ:ដែលសម្រេចនូវមគ្គផលខាងដើម ឈ្មោះថាជាបឋមបុគ្គលចុះកាន់ប្រឡាយព្រះនិព្វានគឺមគ្គ ព្រោះហេតុដូច្នោះ ទើបបានប្រែថាដូច្នេះ ។ សកទាគាមិមគ្គ សក-ទាគាមិផល ប្រែថា មគ្គ ថាផល នៃព្រះអរិយ:ដែលមកកាន់លោកនេះម្ដងទៀត ព្រោះថាព្រះអរិយ:ដែលសម្រេចនូវផលជាគម្រប់ពីរនេះ រមែងមកកើតក្នុងកាមភពនេះម្ដងទៀត ហើយទើបធ្វើនូវទីបំផុតនៃទុក្ខ គឺដល់នូវព្រះអរហត្ត ហើយរំលត់ខន្ធដោយអនុបាទិសេសនិព្វានធាតុ ។ អនា-គាមិមគ្គ អនាគាមិផល ប្រែថា មគ្គ ថាផល នៃព្រះអរិយ: ដែលមិនមកកាន់លោកនេះទៀត ព្រោះថាអរិយ:ដែលបាននូវផលជាគម្រប់បីនេះ រមែងទៅកើតក្នុងព្រហ្មលោក ឈ្មោះថាសុទ្ធាវាស ហើយបរិនិព្វានក្នុងព្រហ្ម-

លោកនោះ មិនបានត្រឡប់ចាកព្រហ្មលោកនោះ មកកើតក្នុងកាមភព នេះជាធម្មតា ។ អរហត្តមគ្គ ប្រែថា មគ្គជាទីមកនៃភាពជាព្រះអរហន្ត ។ អរហត្តផល ប្រែថា ផលគឺភាពជាព្រះអរហន្ត ។ ព្រះអរិយៈដែលបាន នូវផលជាគម្រប់បួននេះ ឈ្មោះថា ព្រះអរហន្ត ជាអ្នកឆ្ងាយចាកកិលេស រំលត់ខន្ធហើយមិនមានភពថ្មី ។ ឯមគ្គនោះ ជាអ្នករំងាប់នូវកិលេស ដូចព្រះមហាក្សត្រធ្វើសង្គ្រាមនឹងព្រះមហាក្សត្រ ដែលជាសត្រូវក្នុងរាជ-ធានីដទៃ ចាប់ក្សត្រដែលជាសត្រូវពិឃាតបង់ ។ ផលជាអានិសង្ស នៃមគ្គដែលព្រះអរិយៈ នឹងគប្បីបាន គប្បីសោយ ដូចរាជសម្បត្តិដែល ព្រះមហាក្សត្រនោះ ពិឃាតនូវក្សត្រជាសត្រូវ ហើយបានសោយ ប្រកបដោយសេចក្តីសុខសម្រាន្តដូច្នោះ ។

ឃ. មគ្គ នោះ លះនូវកិលេសណា? កិលេសនោះ ជាអតីត ឬអនា-គត ឬបច្ចុប្បន្ន?

វិ. កិលេសដែលជាអតីតក៏រលត់ពន្ធផុតទៅហើយ កិលេស ដែលជាអនាគតក៏មិនទាន់កើតឡើង កិលេសទាំងពីរចំណែកនេះ មិន មែនជាវិស័យដែលមគ្គត្រូវលះ កិលេសដែលជាបច្ចុប្បន្ន ក៏មិនមានក្នុង ខណៈនៃមគ្គ ព្រោះថាកិលេសនោះមិនមានតាំងពីក្នុងខណៈនៃលោកិយ-វិបស្សនាខាងដើម បើនឹងថាកិលេសមានក្នុងខណៈនៃមគ្គហើយសោត មគ្គភាវនាក៏នឹងជាសាសវៈប្រកបដោយអាសវៈគឺកិលេស ។ មួយទៀត

បើមិនដូច្នោះ កុសលនិងអកុសលទាំងពីរ ដែលជាសត្រូវនឹងគ្នាក៏គង់កើតព្រមគ្នាក្នុងខណៈចិត្តតែមួយបាន ។ ពាក្យដែលថាមគ្គលះកិលេសនោះ សំដៅយកកិលេសដែលអាចកើតក្នុងខន្ធទាំង ៥ មានរូបក្ខន្ធជាដើម ដែលជាភូមិនៃវិបស្សនា ដែលឈ្មោះថា ភូមិលទ្ធុប្បន្នកិលេស កិលេសបានភូមិគឺខន្ធ ៥ ហើយកើតឡើង ដូចរសនៃបឋវីធាតុនិងអាបោ-ធាតុដែលជ្រួតជ្រាបទៅក្នុងឫស ដើម មែក ស្លឹក ផ្កា ផ្លែ នៃឈើទាំងពួងដូច្នោះ ។ កាលមគ្គកើតឡើងក្នុងខន្ធសន្តានៃបុគ្គលណាហើយ ខន្ធ-សន្តានៃបុគ្គលនោះ ក៏បានពាល់ត្រូវសម្ផស្សនៃមគ្គដែលបានកើតឡើងនោះ ខន្ធសន្តានៃលោកនោះ ឈ្មោះថា ខន្ធសន្តានដែលស្ងាប់ ដោយស្ងាប់កិលេសហើយ មិនតពូជផល គឺកុសល អកុសល តទៅ បីដូចជាដើមឈើ មានផ្កានិងផ្លែជាពិស បុរសម្នាក់ចោះចាក់ ដោយក្រើសបបែលដែលលាបប្រឡាក់ដោយថ្នាំពិសក្នុងទិសទាំង ៤ ។ ដើមឈើនោះកាលបើត្រូវសម្ផស្សនៃថ្នាំពិសនោះហើយ ក៏ស្ងាប់ព្រោះរសនៃបឋវីធាតុ អា-បោធាតុ ដែលជ្រួតជ្រាបនោះស្ងួតទៅដោយសម្ផស្សនៃថ្នាំពិសនោះ ហើយជាដើមឈើមិនបានបញ្ចេញផ្កា ផ្លែតទៅទៀត ដូច្នោះឯង ។

មគ្គវិភាវនា ចប់

និញ្ជានវិភាវនា

បុច្ឆា **និញ្ជាន** ប្រែថា ដូចម្តេច?

វិសជ្ជនា **និញ្ជាន** ប្រែថា ធម៌ជាទីរលត់នៃកិលេសគ្គិ ភ្លើងគឺកិលេស និងទុក្ខគ្គិ ភ្លើងគឺទុក្ខ ។ រាគ: សេចក្តីតម្រេក ទោស: សេចក្តីប្រទូសរ៉ាយ មោហ: សេចក្តីវង្វេង ទាំងបីនេះ ឈ្មោះថាកិលេសគ្គិ ព្រោះកើតឡើងជាមួយនឹងចិត្ត ធ្វើចិត្តឲ្យសៅហ្មងកករល្អក់ផង និងឲ្យចិត្តក្តៅក្រហាយរសាប់រសល់ផង ទើបឈ្មោះថាកិលេសគ្គិ ។

ជាតិ សេចក្តីកើត ជរា សេចក្តីចាស់ មរណ: សេចក្តីស្លាប់ សោក: សេចក្តីក្រៀមក្រំនៃចិត្ត បរិទេវ: សេចក្តីខ្សឹកខ្សួល ទុក្ខ: សេចក្តីលំបាកកាយ ទោមនស្ស: សេចក្តីតូចចិត្តឈឺចិត្ត ឧបាយាស: សេចក្តីចង្អៀតចង្អល់ចិត្ត ទាំងអស់នេះឈ្មោះថាទុក្ខគ្គិ ព្រោះជាហេតុនៃសេចក្តីទុក្ខនិងជាតួទុក្ខ ធន់មិនបាន ដុតសត្វឲ្យក្តៅក្រហាយដូចគំនរភ្លើង ទើបឈ្មោះថាទុក្ខគ្គិ ។ កិលេសគ្គិនិងទុក្ខគ្គិ ទាំងអម្បាលនេះ កាលដល់ព្រះនិញ្ជាន អាស្រ័យព្រះនិញ្ជានហើយក៏រលត់ទៅ និងមិនមានក្នុងព្រះនិញ្ជាន ។ ព្រោះហេតុនោះ និញ្ជាននេះ ប្រែថាធម៌ជាទីរលត់នៃភ្លើងគឺកិលេសនិងភ្លើងគឺទុក្ខ ដ្ឋិតថាភ្លើងទុក្ខ គឺជាតិ ជរា មរណ: រលត់មិនមានក្នុងព្រះនិញ្ជាននោះ អ្នកប្រាជ្ញគប្បីដឹងចុះថា ខន្ធទាំង ៥ គឺ រូប វេទនា

សញ្ញា សង្ខារ វិញ្ញាណ មិនមានក្នុងព្រះនិព្វាន ដោយហេតុថា ជាតិសេចក្តីកើតនោះ គឺការមានឡើង កើតឡើងនៃបញ្ចក្ខន្ធ ឈ្មោះថា ជាតិ សេចក្តីចាស់ជុំវិញនៃបញ្ចក្ខន្ធ ឈ្មោះថា ជរា កាលបើជាតិនិងជរារលត់ ក៏បានឈ្មោះថាបញ្ចក្ខន្ធរលត់ មិនមានក្នុងព្រះនិព្វាន ដ្ឋិតព្រះនិព្វានជាវិសង្ខារ ប្រាសចាកសង្ខារគឺនាមរូប ឬ បញ្ចក្ខន្ធ ព្រោះហេតុនោះព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងថា **ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារ-សមថো សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយো និរោធো និព្វានំ** *ប្រែថា* **ឯតំ សន្តំ** *ធម្មជាតនេះ ជារបស់សូន្យ ជារបស់ល្អិត* **ឯតំ បណីតំ** *ធម្មជាតនេះ ជារបស់ប្រណីតឧត្តម* **យទិទំ** *គឺថា* **សព្វសង្ខារសមថো** *ធម៌ជាទីរំងាប់នូវសង្ខារទាំងពួង* **សព្វូ-បធិប្បដិនិស្សគ្គោ** *ធម៌ជាទីរលាស់បង់នូវឧបធិទាំងពួង* **តណ្ហាក្ខ-យো** *ធម៌ជាទីអស់ទៅនៃតណ្ហា* **និរោធো** *ធម៌ជាទីសូន្យស្ងាត់* **និព្វានំ** *ធម៌ជាទីរលត់ ពាក្យទាំងអម្បាលនេះជាឈ្មោះនៃព្រះនិព្វានទាំងអស់ ដោយពាក្យថា* **សព្វសង្ខារសមថো សព្វូបធិប្បដិ-និស្សគ្គោ** *នេះ សម្តែងថាសព្វវត្ថុទាំងពួង ដែលជាហេតុខាងក្នុងគឺ កុសល អកុសល និងកិលេសក្តី និងផលខាងក្នុងគឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលជាវិបាកខន្ធក្តី និងហេតុខាងក្រៅ មានរដូវជាដើមក្តី និងផលខាងក្រៅ មានដើមឈើ ផែនដី មេឃ អាកាស*

ព្រះអាទិត្យ ព្រះចន្ទជាដើមក្តី ក៏មិនមានក្នុងព្រះនិព្វាន ព្រោះថាសេចក្តីព្យាយាមឈ្មោះថាសង្ខារ កុសល អកុសល ក៏ឈ្មោះថាសង្ខារ វត្ថុទាំងពួងដែលកើតដោយហេតុខាងក្នុង គឺ កុសល អកុសល ដូចបញ្ចក្ខន្ធក្តី និងវត្ថុដែលកើតដោយហេតុខាងក្រៅ មានរដូវជាដើម ដូចដើមឈើ និងផែនដីជាដើមក្តី ក៏ឈ្មោះថា សង្ខារ សង្ខារទាំងអម្បាលនេះមិនមានក្នុងព្រះនិព្វាន ព្រះនិព្វានទើបឈ្មោះថា **សព្វសង្ខារសមថោ** ធម៌ជាទីរំងាប់នូវសង្ខារទាំងពួង កិលេសក៏ឈ្មោះថាឧបធិ កុសល អកុសល ក៏ឈ្មោះថាឧបធិ បញ្ចក្ខន្ធ ក៏ឈ្មោះថាឧបធិ កិលេសកាម និងវត្ថុកាមក៏ឈ្មោះថា ឧបធិ ឧបធិទាំងអម្បាលនេះមិនមានក្នុងព្រះនិព្វាន ព្រះនិព្វានទើបឈ្មោះថា **សព្វូបធិ**ប្ប**ដិនិ**ស្ស**ក្គោ** ធម៌ជាទីរលាស់បង់នូវឧបធិទាំងពួង ។ មួយទៀតពាក្យទាំងពីរនោះ ជាពាក្យសម្តែងថា ព្រះនិព្វានមិនមានពណ៌ខៀវលឿងជាដើម និងសណ្ឋានវែងខ្លីជាដើម ឯណានីមួយ និងមិនមានទីប្រតិស្ឋានក្នុងទិសណា តំបន់ណា មិនមានធម៌ណាមួយជាអារម្មណ៍ គ្រាន់តែជាអារម្មណ៍នៃអរិយមគ្គញ្ញាណ ព្រោះហេតុដូច្នោះ ព្រះពុទ្ធអង្គទើបទ្រង់បញ្ចេញនូវឧទានវាចាថា **អត្ថិ ភិក្ខវេ តទាយតនំ** ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះមាន **យត្ត** ក្នុងអាយតនៈឯណា **ណេ**ត **ឋ**ាវ **ី** ក៏មិនមែនជាដីមែនពិត **ន អាចោ** មិនមែនជាទឹក **ន តេជោ** មិនមែនជាភ្លើង **ន វាយោ** មិន

មែនជាខ្យល់ **ន អាកាសានញ្ចាយតនំ** *មិនមែនជាអាកាសានញ្ចាយតនៈ* **ន វិញ្ញាណញ្ចាយតនំ** *មិនមែនជាវិញ្ញាណ-ញ្ចាយតនៈ* **ន អាកិញ្ចញ្ញាយតនំ** *មិនមែនជាអាកិញ្ចញ្ញាយតនៈ* **ន នេវសញ្ញានាសញ្ញាយតនំ** *មិនមែនជានេវសញ្ញានាសញ្ញា-យតនៈ* **នាយំ លោកោ** *មិនមែនជាលោកនេះ* **ន បរោ លោកោ** *មិនមែនជាលោកខាងមុខ* **ន ឧភោ ចន្ទិមសុរិយា** *មិនមែនជាព្រះចន្ទនិងព្រះអាទិត្យទាំងពីរ* **តត្ថ ភិក្ខវេ នេវ អាគតិ ន គតិ** *ម្នាលភិក្ខុទាំងឡាយ តថាគតមិនសម្តែងនូវអា-យតនៈនោះ ថាមានកិរិយាមក ដូចមកអំពីភូមិនោះដល់ភូមិនេះ* **ន ឋិតិ** *តថាគតមិនបានសម្តែងថា មានកិរិយាទៅ ដូចទៅអំពីភូមិនេះដល់ភូមិដទៃ* **ន ចុតិ** *តថាគតមិនបានសម្តែងថា មានកិរិយាឈប់នៅ* **ន ឧបបត្តិ** *តថាគតមិនបានសម្តែងថា មានកិរិយាច្យុតឃ្លាតចេញ* **ន ឧបបត្តិ** *តថាគតមិនបានសម្តែងថា មានការចូលទៅដល់នូវទីណាមួយ* **អប្ប តិដ្ឋំ** *អាយតនៈនោះ ជាធម្មជាតមិនបានតាំងនៅក្នុងទីណា ឬមិនមានទីតាំងនៅក្នុងទិសណា តំបន់ណា* **អប្ប ្ បវត្តំ** *ជាធម្មជាតមិនមានបវត្តិការប្រព្រឹត្តទៅ* **អ ្ នារម្ម ្ ណ ្ ំ** *ជាធម្មជាតមិនមានអ្វីជាអារម្មណ៍* **ឯ ្ សេវ ្ ្ ្

ដី ទឹក ភ្លើង ខ្យល់ ក៏មិនមាន គឺមិនមានក្នុងព្រះនិព្វាន ព្រះនិព្វានជាអរូបធម៌ ដោយពាក្យថា **អាកាសានញ្ចាយតនៈ** ជាដើម ក៏មិនមាននោះ សម្តែងថានាមធម៌គឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ សូម្បីល្អិតសុខុមបីដូចជាមិនមាន ដូច នេវសញ្ញានាសញ្ញាយតនៈ ក៏មិនមានក្នុងព្រះនិព្វាន ។ ព្រះនិព្វានជាអនាមធម៌ មិនមែនជាអារម្មណិក-នាមធម៌ តួនាមប្រកបដោយអារម្មណ៍ជាគ្រឿងទាញ ។ ក៏ឯប្រភេទនៃធម៌សម្តែងនាមរូបជំពូកខ្ទះ លោកចាត់ព្រះនិព្វានចូលក្នុងប្រភេទនៃនាមធម៌នោះ សំដៅសេចក្តីថា ព្រះនិព្វានជាអារម្មណ៍នៃអរិយមគ្គប្ញញ្ញា គួរព្រះអរិយៈជាម្ចាស់លោកនឹងបង្អោនចូលមកដោយចិត្ត ដែលសម្បយុត្តដោយមគ្គនិងផលបានប៉ុណ្ណោះ មិនមែនសម្តែងថា ព្រះនិព្វានជាអារម្មណិកនាមធម៌គឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ វត្ថុណាមួយ ក៏មិនមាន ។ ដែលសម្តែងថា វេទនា សញ្ញា សង្ខារ វិញ្ញាណ វត្ថុណាមួយ មានក្នុងព្រះនិព្វានក៏មិនមាន ដ្ឋិតពាក្យថា លោកនេះក៏មិនមានជាដើមនោះ គឺសម្តែងថា ព្រះនិព្វាន មិនមានទីប្រតិស្ឋានតាំងនៅក្នុងទិសណា តំបន់ណា និងមិនបានប្រតិស្ឋានតម្កល់ទុកក្នុងទិសណា តំបន់ណាដោយពាក្យនេះ ឃាត់សេចក្តីឃើញខុសនៃមនុស្សពាលដែលពោលថាព្រះនិព្វានជានគរកែវដ៏វិសេសក្សេមក្សាន្តនិរាសភ័យ និងឃាត់សេចក្តី

ប្រកាន់ថាព្រះនិព្វានដូចជារូបត្រឡាច រូបព្រហ្ម មិនមានចិត្តសញ្ញាដេកស្ងៀម នៅក្នុងកាលទាំងពួងផង ។

ឃ. បើព្រះនិព្វានដូចពាក្យសម្តែងមកនេះ សេចក្តីសូន្យទទេ មិនកើត មិនមាន នៃសព្វវត្ថុទាំងពួង ជាព្រះនិព្វានឬ?

វិ. មិនដូច្នោះទេ បើថាសេចក្តីសូន្យដូច្នោះជាព្រះនិព្វាន ព្រះនិព្វានក៏ឈ្មោះថាមិនមាន ។ ពាក្យដែលព្រះពុទ្ធអង្គទ្រង់សម្តែងថា អាយតនៈគឺព្រះនិព្វាននោះរមែងមាន ពាក្យនោះក៏ខុស ។ ព្រះនិព្វានជារបស់មានពិត ទើបជាទុក្ខនិរោធអរិយសច្ច របស់ពិតនៃព្រះអរិយៈមួយចំណែក ជាអសាធារណធម៌ មិនទូទៅដល់បុថុជ្ជន បុថុជ្ជនមិនអាចឃើញបាន ព្រោះមិនមានបញ្ញាចក្ខុគឺអរិយមគ្គញ្ញាណ ។ ព្រះអរិយៈលោកធ្វើឲ្យច្បាស់ ឃើញច្បាស់ដោយអរិយមគ្គញ្ញាណ ដូចបុគ្គលដែលបានចេតោបរិយញ្ញាណដឹងវារៈចិត្តនៃអ្នកដទៃដូច្នោះ ។ ឯបុថុជ្ជនមិនឃើញធម៌ណាមួយ នឹងសម្តែងថាធម៌នោះមិនមានក៏មិនបាន ។ មួយទៀតបើសម្តែងថាព្រះនិព្វានមិនមានហើយ សម្មាបដិបទាគឺអរិយមគ្គប្រកបដោយអង្គ ៨ មានសម្មាទិដ្ឋិជាដើមដែលសង្គ្រោះដោយត្រៃសិក្ខានោះ ក៏ជាការឥតប្រយោជន៍មិនចេញផលគឺ ឲ្យដល់ព្រះនិព្វានបាន ។ មួយទៀតបើថា អរិយមគ្គមិនមែនជាការឥតប្រយោជន៍ ព្រោះឲ្យដល់នូវសេចក្តីមិនមាននៃបញ្ចក្ខន្ធ ដែលជាទីតាំងនៃសេចក្តីទុក្ខខាងមុខនោះក៏មិនត្រូវ ព្រោះថាការដែលសម្រេចនូវព្រះ

និព្វានក្នុងកិរិយាមិនកើតមិនមាននៃបញ្ចក្ខន្ធ ដែលជាអតីតនិងអនាគតមិនមាន ។ មួយទៀត នឹងសម្តែងយកសេចក្តីថា ការមិនកើតមិនមាននៃបញ្ចក្ខន្ធ ដែលជាបច្ចុប្បន្ន ជាព្រះនិព្វានក៏មិនត្រូវ ព្រោះខណៈនៃអរិយ-មគ្គប្បញ្ញាកើតឡើងឃើញព្រះនិព្វាននោះ បញ្ចក្ខន្ធក៏មានប្រាកដក្នុងទីចំពោះមុខមិនបានសូន្យទៅ ។ មួយទៀត ការសម្រេចនូវសឧបាទិសេស-និព្វានក៏កើតមានក្នុងខណៈនៃមគ្គ អាស្រ័យនូវបញ្ចក្ខន្ធដែលជាបច្ចុប្បន្ន ។ មួយទៀត នឹងសម្តែងសេចក្តីថា ការមិនមានមិនប្រព្រឹត្តទៅនៃកិលេសជាបច្ចុប្បន្ន ជាព្រះនិព្វាន អរិយមគ្គក៏ជារបស់មិនមានប្រយោជន៍ ព្រោះថាមុនដែលព្រះអរិយមគ្គកើតឡើង កិលេសក៏មិនមាន មិនប្រព្រឹត្តទៅដោយអំណាចលោកិយវិបស្សនាបញ្ញា ។ មួយទៀត បើនឹងសម្តែងសេចក្តីថាការមិនមានកិលេសជាព្រះនិព្វាន ការដេកលក់ស្និទ្ធក៏ហៅថាព្រះនិព្វានបានព្រោះកិលេសមិនមានក្នុងវេលាលក់ស្និទ្ធនោះ ។ មួយទៀត បើសំដៅថារាគក្ខយៈ ការអស់រាគៈ ទោសក្ខយៈ ការអស់ទោសៈ មោហក្ខយៈ ការអស់មោហៈ តាមជម្ពូខាទកសូត្រជាដើម ថាជាព្រះនិព្វាន ទោសក៏មានច្រើនគឺព្រះនិព្វានក៏នឹងជាឥត្តរកាល មានកាលមានវេលាមួយរំពេច មួយស្របក់តែត្រឹមអស់កិលេសប៉ុណ្ណោះ ។ មួយទៀត ក៏នឹងធ្លាក់ចុះក្នុងលក្ខណៈនៃសង្ខតធម៌ ។ មួយទៀត ក៏នឹងជាធម៌បានងាយមិនមានសម្ភារៈយាមៈក៏គង់សម្រេចបាន។ កាលបើធ្លាក់ចុះក្នុងលក្ខណៈនៃសង្ខតធម៌ ព្រោះមាន

មួយកាល មួយខណៈ ព្រះនិព្វានក៏នឹងរាប់ចូលក្នុងសង្ខតធម៌ ព្រោះជាប់ជំពាក់ក្នុងសង្ខតធម៌ ក៏នឹងជាធម្មជាតក្តៅដោយភ្លើងកិលេស ភ្លើងទុក្ខ ព្រោះជារបស់ក្តៅ ព្រះនិព្វានក៏នឹងជាទុក្ខ ។ មួយទៀត បើថារាគាទិក្ខយៈ ការអស់រាគៈជាដើម ជាព្រះនិព្វាន ព្រះនិព្វានក៏នឹងមានច្រើន ការអស់ រាគៈ ទោសៈ មោហៈ ក៏ហៅថាព្រះនិព្វានមួយៗ ។ មួយទៀត ព្រះនិព្វាន ក៏នឹងជាធម្មជាតជ្រៅជ្រាក សូម្បីមនុស្សពាលក៏ដឹងបានដោយងាយ ។ មួយទៀតព្រះនិព្វានក៏នឹងមិនជាអារម្មណ៍នៃគោត្រភូញាណនិងមគ្គបាន ។ មួយទៀតនឹងសំដៅថា តាំងអំពីការអស់កិលេសណា កិលេសនោះមិនកើតឡើងតទៅទៀត ការអស់កិលេសដូច្នោះជាព្រះនិព្វានហើយ ក៏មិនត្រូវ ព្រោះការអស់កិលេសដូច្នោះមិនកើតមិនមាន ។ ប្រសិនបើជាកើតជាមានក៏មិនរួចចាកទោសដូចសម្តែងមកនោះ ។ មួយទៀត អរិយមគ្គក៏នឹងជាព្រះនិព្វាន ព្រោះថាមគ្គនិងផលព្រះមានព្រះភាគទ្រង់សម្តែងដោយឈ្មោះថា **រាគក្ខយោ ទោសក្ខយោ មោហក្ខយោ** *ដូចឈ្មោះព្រះនិព្វានក៏មាន ។* **រាគក្ខយោ ទោសក្ខយោ មោហក្ខយោ** *ថាបើជាឈ្មោះនៃមគ្គ ត្រូវប្រែថា ធម៌ជាហេតុអស់ទៅនៃរាគៈ ទោសៈ មោហៈ ព្រោះការសម្ងាប់កិលេសជាកិច្ចនៃមគ្គ បើជាឈ្មោះនៃផលត្រូវប្រែថា ការអស់ រាគៈ ទោសៈ មោហៈ ព្រោះព្រះអរហត្តផល កើតក្នុងទីបំផុតនៃការអស់កិលេស បើជាឈ្មោះនៃព្រះនិព្វានត្រូវប្រែថា ធម៌*

ជាទីអស់ រាគ: ទោស: មោហ: ព្រោះថាកិលេសមកដល់ព្រះនិព្វានដែលជាអារម្មណ៍នៃមគ្គហើយអស់ទៅ តាំងអំពីអរិយមគ្គកើតឡើង កិលេសមិនកើតតទៅទៀតបាន អរិយមគ្គទើបជាអនុប្បត្តិនិរោធរលត់តែម្តងនៃកិលេសដែលមិនកើតបានទៀត ។ ចំណែកព្រះនិព្វានវិញមានជាឧបនិស្សយនៃអរិយមគ្គនោះ គឺថា ជាអារម្មណប្បច្ច័យដ៏មានកម្លាំងនៃអរិយមគ្គនោះដោយបរិយាយ ព្រះនិព្វាននោះព្រះមានព្រះភាគទ្រង់សម្តែងថា **រាគក្ខយោ ទោសក្ខយោ មោហក្ខយោ** ធម៌ជាទីអស់ រាគ: ទោស: មោហ: សម្តែងដូច្នេះដោយផលុបចារវោហារ គឺសម្តែងហេតុដោយផល ។ ក្នុងបទនេះសំដៅយកព្រះនិព្វានជាហេតុ មគ្គជាផល ដើម្បីនឹងអធិប្បាយបទថា **រាគក្ខយោ ទោសក្ខយោ មោហក្ខយោ** ប៉ុណ្ណោះ ។ បើនឹងសម្តែងដោយហេតុផលតាមអរិយសច្ចកថា មគ្គជាហេតុ ព្រះនិព្វានជាផល ។ មួយទៀតភាពចន្ទោះទទេនិងការមិនកើតមិនមាននៃបញ្ចក្ខន្ធជាដើម និងគ្រាន់តែការអស់ទៅនៃកិលេសជាព្រះនិព្វាន ចុះត្រង់បទដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ព្រះនិព្វានជារបស់ជ្រៅ និងត្រាស់ថាជាអសង្ខតធម៌តើដូចម្តេចទៅ? ដ្បិតព្រះពុទ្ធអង្គទ្រង់ត្រាស់ថា ព្រះនិព្វានជាធម៌ជ្រៅដូច្នេះ **តម្ហីកោ ចាយំ ធម្មោ** ធម៌គឺព្រះនិព្វានជាធម៌ជ្រៅ **ទុទ្ទសោ** ដែលបុគ្គលឃើញបានដោយក្រ **ទុរនុពោធោ** ដែលបុគ្គលត្រាស់ដឹងតាមដោយក្រ **សន្តោ** ជាធម៌សូប់រំងាប់ **បណីតោ**

ជាធម៌ហ្មត់ចត់ **អត្តការចរោ** មិនជាទីសង្ស័យប្រមើលដោយសេចក្តីត្រិះរិះ គឺថាបុថុជ្ជននឹងត្រិះរិះគិតគ្នេរយកឯងមិនបាន ** និបុណោ** ជារបស់ល្អិត **បណ្ឌិតវេទនីយោ** ជាធម៌ដែលបណ្ឌិតគឺព្រះអរិយៈគប្បីដឹងច្បាស់ បុថុជ្ជនមិនអាចដឹងច្បាស់ ។ ក៏ឯព្រះពុទ្ធអង្គទ្រង់សម្តែងថាជាអសង្ខតធម៌នោះ ដោយន័យច្រើនយ៉ាង អធិប្បាយដោយសេចក្តីសង្ខេបដូច្នេះថា ធម៌ទាំងពួងបើសម្តែងដោយខ្ជីមានពីរប្រភេទគឺ សង្ខតធម៌ ១ អសង្ខត-ធម៌ ១ ។ សង្ខតធម៌ប្រែថាធម៌ដែលបច្ច័យគឺ រដូវនិងកុសលនិងអកុសលជាដើម តាក់តែងឲ្យកើតឲ្យមានឡើង បានដល់សង្ខារទាំងពួង ដូចរូបកាយខាងក្រៅក្តី និងអារម្មណ៍ឈ្មោះ ដែលជាកុសលដរាបដល់មគ្គ ផលក្តី និងអកុសលទាំងពួងក្តី និងអព្យាកតធម៌ ដែលជាអារម្មណ៍ធម៌ក្តី ឈ្មោះថាសង្ខតធម៌ ព្រោះប្រកបដោយសង្ខតលក្ខណៈ ៣ ដូច្នេះ គឺការកើតឡើងរមែងប្រាកដមួយយ៉ាង ការរលត់ទៅរមែងប្រាកដមួយយ៉ាង ការតាំងនៅហើយប្រែទៅជាយ៉ាងដទៃ រមែងប្រាកដមួយយ៉ាង ព្រោះប្រកបដោយសង្ខតលក្ខណៈ ៣ ដូច្នេះ ទើបឈ្មោះថាសង្ខតធម៌ ។ អ-សង្ខតធម៌ ប្រែថាធម៌ដែលបច្ច័យណាមួយមិនបានតាក់តែងឲ្យកើតឲ្យមានឡើង បានដល់ព្រះនិព្វានតែមួយ ព្រោះព្រះនិព្វានប្រកបដោយអសង្ខត-លក្ខណៈ ៣ ដូច្នេះ គឺការកើតឡើងក៏មិនប្រាកដមួយយ៉ាង ការរលត់ទៅក៏មិនប្រាកដមួយយ៉ាង ការតាំងនៅហើយប្រែប្រួលទៅជាយ៉ាងដទៃក៏មិន

ប្រាកដមួយយ៉ាង ព្រោះព្រះនិព្វានប្រកបដោយអសង្ខតលក្ខណៈ ៣ ដូច្នេះ ទើបឈ្មោះថាអសង្ខតធម៌ ។ ការសូន្យទទេ ការមិនមានបញ្ចក្ខន្ធ និងការគ្រាន់តែអស់ទៅនៃកិលេសនោះ និងជារបស់ជ្រៅ របស់ឃើញក្រប៉ុន្មាន និងជាអសង្ខតធម៌ដូចម្តេចទៅបាន ។ ព្រោះហេតុនោះអ្នកប្រាជ្ញគប្បីដឹងចុះថា ព្រះនិព្វានជាធម្មជាតុមួយមាននៅប្រាកដ មិនមែនជាការសោះសូន្យទទេ មិនមែនជាមិនមានសង្ខារ មិនមែនគ្រាន់តែការមិនមានកិលេសជាព្រះនិព្វានទេ ។

បុ. ព្រះនិព្វានមានពិត ហេតុអ្វីទើបព្រះមានព្រះភាគមិនទ្រង់សម្តែងដោយរូប ចង្អុលអង្គព្រះនិព្វានឲ្យច្បាស់ដូចមគ្គនិងផល?

វិ. ព្រះនិព្វានសម្តែងឲ្យច្បាស់ដូច្នោះមិនបាន ព្រោះព្រះនិព្វានជាធម៌ល្អិតសុខុមណាស់ ។ ឯពាក្យដែលថា ព្រះនិព្វានជាធម៌ល្អិតសុខុមនោះរមែងប្រាកដមាននៅ នាំឲ្យព្រះមានព្រះភាគមានសេចក្តីខ្ជល់ខ្ជាយតិចក្នុងការសម្តែងធម៌ ក្នុងវេលាដែលព្រះអង្គទើបនឹងបានត្រាស់ដឹងជាដំបូងប្រាកដ ព្រោះព្រះនិព្វានជាធម៌ដែលព្រះអរិយៈគប្បីឃើញដោយបញ្ញាចក្ខុគឺអរិយមគ្គប្បញ្ញា ព្រោះហេតុនោះព្រះនិព្វានទើបជារបស់អ-សាធារណៈមិនទូទៅដល់បុថុជ្ជន ។ មួយទៀត ព្រះនិព្វានជាអប្បកវៈមិនមានដែនកើត គឺមិនមានទីបំផុតខាងដើមថា មានឡើងកាលព្រះពុទ្ធអង្គឯណោះ មុននោះមិនមាន ។ មួយទៀត នឹងថាព្រះនិព្វានជាបភវៈមានធម៌

ជាដែនកើត ព្រោះព្រះអរិយមគ្គឲ្យកើតឡើងក៏មិនត្រូវ ដ្បិតព្រះនិព្វាន នោះ ជាធម៌ដែលព្រះអរិយ:គប្បីដល់ គប្បីបានដោយអរិយមគ្គផ្សេងទេ មិនមែនជាធម៌ដែលអរិយមគ្គឲ្យមានឲ្យកើតឡើង ព្រោះហេតុនោះ ព្រះ និព្វានទើបជាអប្បភវ:មិនមានដែនកើត ។ ព្រោះព្រះនិព្វានមិនមានដែន កើត ទើបជាអជរាមរណ:មិនមានសេចក្តីចាស់ សេចក្តីស្លាប់ ។ ព្រោះមិន មានធម៌ជាដែនកើត និងមិនមានសេចក្តីចាស់ សេចក្តីស្លាប់ ព្រះនិព្វាន ទើបជាធម៌ដ៏ទៀង ។ ដោយហេតុដូចសម្តែងមកនេះ ព្រះនិព្វានជារបស់ មានពិតប្រាកដដោយបរមត្ថ ព្រោះជាធម៌ដែលបុគ្គលគប្បីបានដោយ ញាណដ៏វិសេសដែលសម្រេចដោយសេចក្តីព្យាយាម ដែលមិនបន្ធូ រ បន្ថយ ។ មួយទៀត ព្រោះមានព្រះពុទ្ធដីកាថា **អត្ថि ภิกฺขเว** ម្នាលភិក្ខុ ទាំងឡាយព្រះនិព្វានមានដោយពិត **อชาตํ** ឈ្មោះថា អជាត: ព្រោះ ជាធម្មជាតមិនកើតឡើងដោយប្រជុំព្រមនៃហេតុ និងបច្ច័យ **อภูตํ** ឈ្មោះថាអភូត: ព្រោះមិនមែនជាធម្មជាតប្រាសចាកហេតុហើយកើត ឡើងឯង **อกตํ** ឈ្មោះថា អកត: ព្រោះជាធម្មជាតដែលហេតុណា មួយមិនបានធ្វើ **อสํขตํ** ឈ្មោះថា អសង្ខត: ព្រោះជាធម្មជាត ដែលហេតុនិងបច្ច័យណាមួយ មិនបានតាក់តែងឡើង ។ ដោយពុទ្ធវចន: ដូច្នេះ អ្នកប្រាជ្ញគប្បីដឹងថាព្រះនិព្វានជាធម្មជាតមានមែនពិត ។ ឯពាក្ស ថា ព្រះនិព្វានជាធម៌ដែលបុគ្គលគប្បីបានដោយញាណដ៏វិសេសនោះ

សម្តែងថាព្រះនិព្វានជាបច្ចក្ខសិទ្ធិ សម្រេចដោយជាក់ច្បាស់ដល់ព្រះអរិយៈតែមួយជំពូក ដោយអាងសព្ទញ្ញូវចនៈនោះសម្តែងថា ព្រះនិព្វានជាអនុមានសិទ្ធិសម្រេចដល់បុថុជ្ជនដោយអនុមានគ្នាន់គ្នេរ ថាមានតាមពុទ្ធវចនៈ ។ លោកិយប្បញ្ញាដែលឃើញនូវព្រះនិព្វាន ក៏មានមកតាំងអំពីគោត្រភូញ្ញាណ ដែលកើតក្នុងជវនវារៈខាងដើមនៃមគ្គជវនវារៈដែលមិនបានត្រឡប់មកជាលោកិយប្បញ្ញាវិញទៀត ។ ក្រៅពីនោះលោកុត្តរ-ប្បញ្ញា គឺមគ្គញ្ញាណ ផលញ្ញាណមួយចំណែក ឃើញនូវព្រះនិព្វាន ។

និព្វានវិភាវនា ចប់ ។

ធម្មគុណកថា

បុ. ព្រះធម៌មានគុណដូចម្តេច?

វិ. គុណនៃព្រះធម៌មានច្រើនណាស់ ហួសវិស័យដែលបុថុជ្ជន នឹងពណ៌នាបាន តែបើកាត់ឲ្យខ្លី សភាពដែលល្អពិត ដូចសម្តែងមក ហើយនោះឯងជាគុណធំក្នុងព្រះធម៌ ។ មួយទៀតបើនឹងសម្តែងគុណ តាមប្រភេទនៃព្រះសទ្ធម្មទាំង ៣ បរិយត្តិសទ្ធម្មមានគុណយ៉ាងខ្ពស់ គឺ ប្រកាសបំភ្លឺសត្ត្ব ឲ្យសត្ត្ববស្គាល់បដិបត្តិសទ្ធម្ម ចំណែកបដិបត្តិសទ្ធម្មមាន គុណយ៉ាងខ្ពស់ឧត្តមក្រៃពេក គឺឲ្យសត្ត្ববដំណើរដល់អធិគមសទ្ធម្ម ។ ចំណែកអធិគមសទ្ធម្ម មានគុណយ៉ាងខ្ពស់ក្រៃពេក គឺសម្រាប់កិលេស នោះៗ ឲ្យសត្ត្ববបាននូវសេចក្តីសុខ ដល់នូវការអស់ទៅនៃទុក្ខ ។ មួយ ទៀត ស្វាក្ខាតតាទិគុណ ជាគុណនៃព្រះធម៌ដ៏គួរជាអនុស្សតិដ្ឋាន ទីតាំង នៃសេចក្តីរញ្ជក ។

គ្រានោះនឹងអធិប្បាយក្នុងបទទាំង ៦ មាន **ស្វាក្ខាតោ ភគវតា ធម្មោ** ជាដើម តាមលំដាប់ក្នុងបុព្វសិក្ខា ពាក្យក្នុងអដ្ឋកថាសម្តែង ទុកដូច្នេះថា សូម្បីព្រះបរិយត្តិសទ្ធម្ម រមែងដល់នូវសេចក្តីសង្គ្រោះក្នុង បទថា **ស្វាក្ខាតោ ភគវតា ធម្មោ** ផង លោកុត្តរធម៌តែមួយ យ៉ាងប៉ុណ្ណោះ រមែងដល់នូវសេចក្តីសង្គ្រោះក្នុងបទទាំង ៥ ក្រៅនោះ

តាំងអំពី **សន្ធិដ្ឋិកោ** *ដរាបដល់* **បច្ចត្តំ វេទិតព្ពោ វិញ្ញូហិ** *។ តាមពាក្យអដ្ឋកថានោះ បានន័ងបាលីថា* **ស្វាក្ខាតោ ។ ល ។ វិញ្ញូហិ** *នេះ ប្រកាសនូវគុណនៃព្រះបរិយត្តិសទ្ធម្ម និងអធិគមសទ្ធម្មពីរប្រការ ប៉ុណ្ណោះ មិនបានសំដៅយកបដិបត្តិសទ្ធម្មផងទេ សូម្បីដូច្នេះនឹងពណ៌-នាថា ប្រកាសនូវគុណនៃបដិបត្តិសទ្ធម្មផងក៏បាន ប្រែតាមអដ្ឋកថានោះ ថា* **ស្វាក្ខាតោ ភគវតា ធម្មោ** *រីបរិយត្តិសទ្ធម្ម ដែលព្រះមានព្រះ ភាគសម្តែងទុកប្រពៃហើយ ព្រោះជាធម៌ពីពោះក្នុងខាងដើម កណ្តាល និង ទីបំផុត ។ ម្យ៉ាងទៀត ព្រោះជាធម៌ប្រកាសនូវព្រហ្មចរិយ: មានអត្ថ និងព្យញ្ជន: ពេញបរិបូណ៌បរិសុទ្ធពុំមានសេសសល់ ទើបឈ្មោះថា ព្រះមានព្រះភាគសម្តែងប្រពៃហើយ ។ ព្រះបរិយត្តិសទ្ធម្ម សូម្បីជាគាថា ៤ បាទ ក៏ឈ្មោះថា ពីពោះខាងដើមដោយបាទជាបឋម ឈ្មោះថា ពីពោះ ក្នុងកណ្តាលដោយបាទជាគម្រប់ពីរ និងគម្រប់បី ឈ្មោះថាពីពោះក្នុងទីបំផុត ដោយបាទជាគម្រប់បួន ព្រោះថាក្នុងបាទនៃគាថាទាំងបួននោះ បាទណា មួយ ដែលសម្តែងនូវសេចក្តីវិបរិត និងសម្តែងនូវសេចក្តីមិនមែនជា ប្រយោជន៍ មិនមាន ។*

មួយទៀត បរិយត្តិសទ្ធម្ម ឈ្មោះថាពីពោះក្នុងខាងដើម ព្រោះសម្តែង សីលជាគុណខាងដើមនៃព្រហ្មចរិយ: ឈ្មោះថាពីពោះក្នុងកណ្តាល ព្រោះ សម្តែងសមាធិជាគុណត្រង់កណ្តាលនៃព្រហ្មចរិយ: ឈ្មោះថាពីពោះក្នុង

ទីបំផុត ព្រោះសម្តែងបញ្ញាជាគុណខាងចុងនៃព្រហ្មចរិយៈ ។ មួយទៀត បដិបត្តិសទ្ធម្មក៏ឈ្មោះថាល្អប្រពៃខាងដើមដោយសីល ព្រោះសីលជាគ្រឿងឃាត់បង់នូវកិលេសដ៏គ្រោតគ្រាតគឺ វីតិក្កមៈ សេចក្តីប្រព្រឹត្តកន្ទងបញ្ញត្តិ ដែលកើតដោយកាយនិងវាចា ឈ្មោះថាល្អប្រពៃត្រង់កណ្តាលដោយសមាធិ ព្រោះសមាធិជាគ្រឿងឃាត់កិលេសយ៉ាងកណ្តាល គឺ បរិយុដ្ឋានកិលេស ដ៏ផុសផុលឡើងតាំងនៅដោយជុំវិញនៃចិត្ត ឈ្មោះថាល្អប្រពៃក្នុងទីបំផុតដោយបញ្ញា ព្រោះបញ្ញាជាគ្រឿងឃាត់បង់នូវកិលេសយ៉ាងល្អិត គឺអនុសយកិលេសដែលដេកត្រាំក្នុងសន្តាន ។ មួយទៀត បរិយត្តិសទ្ធម្ម ឈ្មោះថាពីរោះខាងដើម ដោយកិរិយាស្តាប់ ព្រោះថាក្នុងខណៈដែលស្តាប់ដោយគោរព រមែងបាននូវសេចក្តីសង្វេគនិងសេចក្តីជ្រះថ្លា ក្នុងទីគួរសង្វេគនិងក្នុងទីគួរជ្រះថ្លា ហើយសង្កត់សង្កិនបាននូវនីវរណៈទាំង ៥ ឈ្មោះថាពីរោះត្រង់កណ្តាលដោយការបដិបត្តិ ព្រោះបុគ្គលអ្នកបដិបត្តិ កាលបដិបត្តិបានសេចក្តីសង្វេគ បានសេចក្តីជ្រះថ្លា រមែងសង្កត់សង្កិនកិលេសនោះៗ បាន និងឃើញគុណនៃព្រះធម៌ ឈ្មោះថាពីរោះក្នុងទីបំផុតដោយផលនៃការបដិបត្តិ គឺនាំមកនូវភាពជាមនុស្សឈ្មោះថា **តាទី** គឺមិនមានសោមនស្ស ទោមនស្ស ក្នុងអារម្មណ៍នោះៗ ជាគុណយ៉ាងខ្ពស់ក្រៃពេក ។ ព្រះធម៌ឈ្មោះថា ដែលព្រះមានព្រះភាគសម្តែងហើយដោយប្រពៃ ព្រោះថាជាគ្រឿងពីរោះក្នុងខាងដើម កណ្តាល និងទីបំផុត ដូច្នេះ ។

មួយទៀត វិធីដែលនឹងសម្តែងបរិយត្តិសទ្ធម្ម ឈ្មោះថាព្រះមានព្រះភាគសម្តែងហើយដោយប្រពៃ ព្រោះជាគ្រឿងប្រកាសនូវព្រហ្មចរិយៈដ៏ប្រកបដោយអត្ថនិងព្យញ្ជនៈបរិបូណ៌បរិសុទ្ធមិនសល់នោះ អធិប្បាយថា សាសនោវាទពាក្យទូន្មានមួយយ៉ាង មគ្គមួយយ៉ាង ឈ្មោះថាព្រហ្មចរិយៈ ក្នុងបទនេះ ។ សាសនព្រហ្មចរិយៈនិងមគ្គព្រហ្មចរិយៈណា ដែលព្រះមានព្រះភាគទ្រង់សម្តែងដោយន័យផ្សេងៗ ព្រហ្មចរិយៈពីរនោះឈ្មោះថា **សាត្ថំ** *ប្រកបដោយអត្ថ ព្រោះដល់ព្រមដោយសេចក្តី ដែលបុគ្គលអ្នកបដិបត្តិគប្បីដឹងឃើញ គប្បីបានដោយបញ្ញា ឈ្មោះថា* **សព្យញ្ជនំ** *ប្រកបដោយព្យញ្ជនៈ ព្រោះដល់ព្រមដោយព្យញ្ជនៈនិងអក្ខរៈ និងបទដែលចង់ជាបទបាលីប្រកាសសេចក្តីនោះ ។ ឯព្រហ្មចរិយៈឈ្មោះថា* **កេវលបរិបុណ្ណ** *បរិបូណ៌មិនសល់នោះ ព្រោះមិនមានវត្ថុដែលគួរបំពេញថែមទៀត ដូចសតិប្បដ្ឋាន ៤ ជាដើម ក៏គង់នៅជា ៤ មិនមានអ្នកប្រាជ្ញណា អាចពោលទោសថាខ្វះខាតហើយបំពេញឲ្យទៅជា ៥ ឡើងបាន ។ ក៏ឯព្រហ្មចរិយៈឈ្មោះថា* **បរិសុទ្ធំ** *ជារបស់បរិសុទ្ធនោះ ព្រោះជារបស់មិនមានទោសដែលគួរកាត់ចេញបាន ដូចអរិយមគ្គ ប្រកបដោយអង្គ ៨ ក៏គង់នៅជា ៨ ដដែល ។ ក្នុងអង្គមគ្គទាំង ៨ នោះ អង្គមគ្គណាមួយដែលអ្នកប្រាជ្ញអាចនឹងចំទាស់ថា លើស ហើយនឹងដកចេញឲ្យនៅតែ ៧ ឬ ៦ ក្តី ឬអ្នកប្រាជ្ញអាចនឹងអាងថាអង្គនៃមគ្គនេះមានទោស*

ដូច្នេះ។ មិនគួរជាអង្គ អវយវៈនៃមគ្គ ហើយផ្ទាស់យកធម៌ដទៃជាអង្គ អវយវៈមកជួសក្តីដូច្នេះ ក៏មិនបាន ។ ព្រោះហេតុនោះ ព្រហ្មចរិយៈ ទើបឈ្មោះថាបរិសុទ្ធពេញបរិបូណ៌មិនសល់ ។ វិធីដែលសម្តែងថាបរិយត្តិ-សទ្ធម្ម ឈ្មោះថា ដែលព្រះមានព្រះភាគ សម្តែងហើយដោយប្រពៃ ព្រោះប្រកាសនូវព្រហ្មចរិយៈ ព្រមដោយអត្ថ និងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌ប្រពៃពុំមានសេសសល់ ដូចសម្តែងមកនេះ ។

មួយទៀត បរិយត្តិសទ្ធម្មនោះឈ្មោះថាដែលព្រះពុទ្ធអង្គទ្រង់សម្តែងដោយប្រពៃ ព្រោះមិនមានអត្ថវិបល្លាសដូចធម៌នៃតិរ្ថិយ ។ ដ្បិតថាអត្ថនៃធម៌របស់តិរ្ថិយដែលជាគ្រូដទៃ រមែងដល់នូវវិបល្លាស គឺធម៌ដែលតិរ្ថិយពោលថាជាអន្តរាយិកធម៌ ជាធម៌ធ្វើឲ្យអន្តរាយដល់សុគតិជាដើម នឹងបានធ្វើឲ្យអន្តរាយដូចតិរ្ថិយពោលនោះមិនមាន ។ ឯធម៌ដែលតិរ្ថិយពោលថាជានិយ្យានិកធម៌ ដូចជាអត្តកិលមដ្ឋានុយោគបដិបទា បដិបត្តិទរមានខ្ជូនឲ្យលំបាក គឺផ្ទើរកម្ដៅកាយឲ្យស្ងួតកិលេស នេះឯងអាចនាំសត្វចេញចាកទុក្ខបាន សេចក្តីនេះនឹងថាជានិយ្យានិកៈនាំសត្វចេញចាកសង្សារទុក្ខបានពិតនោះ ក៏ទេ ។ ព្រោះហេតុនោះ ធម៌នៃតិរ្ថិយ ទើបឈ្មោះថា **ឧរ្ធ្ធ-ត្ថោ** គឺតិរ្ថិយពោលហើយដោយអាក្រក់ ពោលហើយមិនល្អ ។ ឯអត្ថនៃធម៌ដែលព្រះមានព្រះភាគសម្តែងនោះ នឹងបានដល់នូវវិបល្លាសក៏ទេ ។ ធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថាជាអន្តរាយិកធម៌ ជា

ធម៌ធ្វើឲ្យអន្តរាយដល់សួគ៌ជាដើម ដូចជាអន្តរាយិកធម៌ ៥ មានកម្មន្តរ-យិកធម៌ជាប្រធាន រមែងជាធម៌ធ្វើឲ្យអន្តរាយដល់សួគ៌និងមគ្គផលពិត ។ ក៏ឯសភាវធម៌ ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ថាជានិយ្យានិកធម៌ នាំសត្វចេញចាកសង្សារទុក្ខ ដូចជាអដ្ឋង្គិកមគ្គ ក៏រមែងនាំសត្វចេញចាកសង្សារ-ទុក្ខបានពិត ។ ព្រោះហេតុដូច្នោះ ធម៌នៃព្រះមានព្រះភាគ ទើបឈ្មោះ ថា **ស្វាក្ខាតោ** គឺព្រះមានព្រះភាគសម្តែងហើយដោយប្រពៃ ។

មួយទៀត លោកុត្តរធម៌ ក៏ឈ្មោះថា **ស្វាក្ខាតោ ភគវតា** គឺព្រះមានព្រះភាគ សម្តែងហើយដោយប្រពៃ ព្រោះបដិបទា សេចក្តីបដិបត្តិមានសភាពសមគួរដល់ព្រះនិព្វាន ព្រះនិព្វានក៏មានសភាពសមគួរដល់សេចក្តីបដិបត្តិ ដ្បិតព្រះនិព្វានជាស្ថានដែលគប្បីដល់ដោយបដិបត្តិ សោត ក៏ជាធម្មជាតបរិសុទ្ធមិនមានកិលេសគឺ រាគ: ទោស: មោហ: ។ បដិបទា ដែលជាផ្លូវដំណើរទៅកាន់ព្រះនិព្វាន គឺត្រៃសិក្ខា ចំណែកសីលក៏ឃាត់កិលេសគឺ រាគ: ទោស: មោហ: ដ៏ជ្រោកជ្រាកដែលជាវីតិក្កម: សេចក្តីកន្ទងសិក្ខាបទឬញ្ញត្តិ ដោយកាយនិងវាចា ។ ចំណែកសមាធិសោត ក៏ឃាត់កិលេស គឺ រាគ: ទោស: មោហ: យ៉ាងកណ្តាលដែលឈ្មោះថាបរិយុដ្ឋាន ផុសផុលឡើង តាំងនៅដោយជុំវិញនៃចិត្ត ។ ចំណែកបញ្ញាសោត ក៏ឃាត់កិលេសគឺ រាគ: ទោស: មោហ: យ៉ាងល្អិត ដែលឈ្មោះថាអនុស័យ បីដូចជាដេកត្រាំនៅក្នុងសន្ធាន ។

នេះឯង ជាផ្លូវបដិបត្តិដើម្បីដល់នូវព្រះនិព្វាន ដ៏សមគួរមិត្រមូលហូរមកចូលក្នុងទីជាមួយគ្នា មិនមែនទាស់ទែងប្លែកគ្នាដូច្នេះ ដូចជាទឹកក្នុងស្ទឹងគង្គាហូរចុះក្នុងទីជាមួយគ្នា និងទឹកក្នុងស្ទឹងយមុនា ស្មើដោយពណ៌និងរសដូចគ្នាដូច្នោះ ។ ព្រោះហេតុនោះ ព្រះធម៌ទើបឈ្មោះថាគឺព្រះមានព្រះភាគសម្តែងហើយដោយប្រពៃ បទថា **ឧម្មោ** ជាប្រធាននៃបទទាំងពួង តាំងអំពី **សន្ទិដ្ឋិកោ** ទៅ ។ **សន្ទិដ្ឋិកោ** ប្រែថាជាធម៌ដែលបុគ្គលគប្បីឃើញឯងច្បាស់ ។ អធិប្បាយថា លោកុត្តរធម៌ ៩ នោះ គឺព្រះអរិយៈអង្គណាៗ បានហើយ ដល់ហើយ ព្រះអរិយៈអង្គនោះៗ គប្បីឃើញឯង ដោយបច្ចវេក្ខណញ្ញាណ មិនបាច់ជឿអ្នកដទៃប្រាប់ លះបង់នូវភាពនៃធម៌ដែលខ្លួនគប្បីដល់ដោយការជឿអ្នកដទៃ ព្រោះហេតុនោះអធិគមសទ្ធម្មទាំងពួង ទើបឈ្មោះថា **សន្ទិដ្ឋិកោ** ជាធម៌ដែលបុគ្គលគប្បីឃើញឯង ។ **អកាលិកោ** ប្រែថាជាធម៌មិនមានកាល មិនមានវេលា អធិប្បាយថា ព្រះធម៌គឺព្រះអរិយមគ្គ កើតឡើងហើយក្នុងសន្ធានៃបុគ្គលណា នឹងបង្ហង់នៅអស់កាល ៥ ថ្ងៃ ៧ ថ្ងៃ ឬ ១ ថ្ងៃ កន្ទុះថ្ងៃ ហើយទើបឲ្យផលក៏ទេ រមែងឲ្យផលក្នុងលំដាប់ដែលខ្លួនប្រព្រឹត្តទៅនោះឯង គឺថាជវនវារៈនៃចិត្តដែលសម្បយុត្តដោយមគ្គ រលត់ហើយ ជវនវារៈនៃចិត្តដែលសម្បយុត្តដោយផល ក៏កើតឡើងក្នុងលំដាប់ មិនមានជវនវារៈនៃចិត្តដទៃខ័ណ្ឌក្នុងចន្លោះបាន ។ ព្រោះហេតុនោះ

មគ្គធម៌ទើបឈ្មោះថា **អកាលិកោ** ជាធម៌មិនមានកាល មិនមានវេលា ។ **ឯហិបស្សិកោ** ប្រែថា ជាធម៌គួរដល់ឯហិបស្សវិធី គឺបីដូចជានឹងហៅអ្នកដទៃថា អ្នកចូលមកមើលបាន អធិប្បាយថា អធិគមសទ្ធម្ម ទាំងពួង ជាធម៌មានពិត និងជាធម៌បរិសុទ្ធថ្លាស្អាតពិត ទើបគួរនឹងហៅឲ្យអ្នកដទៃមកមើលបាន ដូចជាបុគ្គលមានក្តាប់ដៃទេ មិនអាចនឹងហៅអ្នកដទៃថា ប្រាក់ មាស របស់យើងមាន ចូរអ្នកមកមើលចុះដូច្នេះបានទេ ព្រោះក្នុងក្តាប់ដៃមិនមានរបស់អ្វី ឬ ក្នុងក្តាប់ដៃនោះមានរបស់ដែរ តែជាមូត្រឬលាមក ក៏មិនអាចនឹងហៅថាអ្នកចូលមកមើលដូច្នេះ ដើម្បីញ៉ាំងចិត្តអ្នកដទៃឲ្យរីករាយដោយប្រកាសនូវរបស់គាប់ចិត្តបានឡើយ ។ មែនពិត មូត្រនិងលាមកនោះជារបស់ត្រូវបិទបាំង ដោយស្មៅនិងស្លឹកឈើ ព្រោះថាជារបស់មិនស្អាត ។ ចំណែកលោកុត្តរធម៌ទាំង ៩ នេះ ជាធម៌មានពិត ដោយសភាពរបស់ខ្លួន និងបរិសុទ្ធថ្លាស្អាត ដូចចន្ទ-មណ្ឌល ដ៏ពេញវង់ ឲ្យដ៏អាកាស ប្រាសចាកមេឃវលាហក ។ មួយទៀត បរិសុទ្ធ បីដូចកែវមណី ដែលបុគ្គលតម្កល់ទុកក្នុងសំពត់កម្ពល ។ ព្រោះហេតុនោះ អធិគមសទ្ធម្មទាំងពួង ទើបឈ្មោះថា **ឯហិបស្សិកោ** គួរនឹងហៅអ្នកដទៃ ឲ្យចូលមកមើលបាន ។ **ឱបនយិកោ** ប្រែថា ជាធម៌ដែលបុគ្គលគប្បីបង្អោនចូលមកបាន ។ អធិប្បាយថា ធម៌នេះ ដែលពួកព្រះអរិយៈ គួរបង្អោនចូលមកដាក់ក្នុងចិត្តខ្លួនៗ បាន ដោយ

អំណាចនៃភាវនា គឺប្រញាប់បំពេញនូវសេចក្ដីព្យាយាម បីដូចបុគ្គលប្រញាប់លត់ភ្លើងដែលឆេះសំពត់ និងឆេះក្បាល ហើយនិងធ្វើមគ្គផលឲ្យកើតមានឡើង ។ ព្រោះហេតុនោះ ព្រះធម៌ទើបឈ្មោះថា **ឱបនៈ-យិកោ** *ដែលបុគ្គលគប្បីបង្ហោនចូលមកបាន ។ អធិប្បាយដូច្នេះ បានក្នុងសង្ខ្ងតលោកុត្តរធម៌ គឺមគ្គផល ។ ចំណែកអសង្ខ្ងតលោកុត្តរធម៌ គឺព្រះនិព្វានដែលព្រះអរិយៈគួរបង្ហោនចូលមកដោយចិត្តនៃខ្លួនបាន គឺថាព្រះអរិយៈគប្បីធ្វើឲ្យជាក់ច្បាស់ ក្លួចយកជាអារម្មណ៍ ដោយអរិយមគ្គ-ចិត្ត ។ ព្រោះហេតុនោះ សូម្បីព្រះនិព្វាន ក៏ឈ្មោះថា* **ឱបនយិកោ** *ដែលបុគ្គលគួរបង្ហោនចូលមកបានដូចគ្នា ។* **បច្ចត្តំ វេទិតព្ពោ វិញ្ញូហិ** *ប្រែថាជាធម៌ ដែលអ្នកប្រាជ្ញវិសេសទាំងឡាយ គប្បីដឹងច្បាស់ ចំពោះខ្លួន ។ អធិប្បាយថា អធិគមសទ្ធម្មទាំងពួងនេះ ដែលអ្នកប្រាជ្ញ គឺព្រះអរិយៈជាឧគ្ឆដិតញ្ញូ វិបញ្ចិតញ្ញូ ឬ នេយ្យៈ ៣ ជំពូកនេះ នឹងគប្បីឃើញច្បាស់ ចំពោះខ្លួនៗ ថា មគ្គគឺយើងឲ្យកើតឲ្យមានហើយ ផលគឺយើងបានសម្រេចហើយ ព្រះនិព្វានជាទីរលត់ទុក្ខ គឺយើងធ្វើឲ្យជាក់ច្បាស់ហើយដូច្នេះ ។ មែនពិត មគ្គដែលឧបជ្ឌាយ៍ឲ្យកើតមានឡើងហើយ និងរំដោះនូវកិលេសនៃសទ្ធិវិហារិក ដែលជាសិស្សក៏មិនបាន ។ សទ្ធិវិហារិកនឹងនៅជាសុខសម្រាន្ត ដោយសារផលសមា-បត្តិនៃឧបជ្ឌាយ៍នោះផងក៏មិនបាន នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន*

ដែលឧបជ្ឈាយ៍នោះធ្វើឲ្យជាក់ច្បាស់ហើយផង៏ក៏មិនបាន ។ ព្រោះហេតុនោះលោកុត្តរធម៌នោះ ទើបជាធម៌ដែលអ្នកដទៃមិនគប្បីឃើញផង៏បាន ដូចអាករណៈគ្រឿងប្រដាប់សិរ្សនៃអ្នកដទៃ ជាធម៌មានចំពោះវិញ្ញូបុគ្គលដែលគប្បីឃើញ គប្បីសោយ ក្នុង៏ចិត្តរបស់ខ្លួនមួយចំណែក ដ្ឋិតថាលោកុត្តរធម៌ មិនមែនជាវិស័យនៃមនុស្សពាល ព្រោះហេតុដូច្នោះ លោកុត្តរធម៌ទើបជា **បច្ចត្តំ វេទិតព្ពោ វិញ្ញូហិ** ដែលអ្នកដឹង៏វិសេសទាំ៏ងឡាយ គប្បីដឹង៏ច្បាស់ចំពោះខ្លួន ។

មួយទៀត ធម៌ដែលឈ្មោះថា **ស្វាក្ខាតោ** គឺព្រះមានព្រះភាគសម្តែ៏ងទុកដោយប្រពៃហើយ ព្រោះជាធម៌ដែលបុគ្គលគប្បីឃើញ៏ឯ៏ង ។ ដែលឈ្មោះថា **សន្ទិដ្ឋិកោ** ជាធម៌ដែលបុគ្គលគប្បីឃើញ៏ឯ៏ង ព្រោះជាធម៌មិនមានកាល មិនមានវេលា ។ ដែលឈ្មោះថា **អកាលិកោ** មិនមានកាល មិនមានវេលា ព្រោះជារបស់គួរហៅអ្នកដទៃមកមើលបាន ។ ក៏ឯ៏ធម៌ណាឈ្មោះថា **ឯហិបស្សិកោ** ជាធម៌គួរនឹ៏ងហៅអ្នកដទៃឲ្យមកមើលបាន ធម៌នោះក៏រមែ៏ងជា **ឱបនយិកោ** ដែលបុគ្គលគប្បីបង្ហោនចូលមកជាក់ក្នុ៏ងចិត្តបាន ហើយនឹ៏ងគប្បីបង្ហោនចូលមកដោយចិត្តបាន ព្រោះជាធម៌ដែលអ្នកដឹ៏ងវិសេសទាំ៏ងឡាយ គប្បីដឹ៏ងច្បាស់ចំពោះខ្លួន ។ សម្តែ៏ងមកដូច្នេះ ជាពាក្យសម្តែ៏ងនូវបទខាង៏ក្រោយជាហេតុនៃបទ

មុនតៗគ្នា ។ ក៏ឯគុណនៃព្រះធម៌ដែលពណ៌នាសេចក្តីតាំងអំពីបទ **សន្ទិ-ដ្ឋិកោ** *មកនេះ សុទ្ធតែជាគុណនៃលោកុត្តរធម៌ ជាធម៌ខ្ពស់ ជាវិស័យនៃព្រះអរិយៈមួយជំពូក មិនមែនជាវិស័យនៃបុថុជ្ជន ។ កាលបើសម្តែងដល់បុថុជ្ជនក៏ងងឹតងងល់មិនប្រាកដដល់បុថុជ្ជន ដូចសម្តែងរូបដ៏វិសេសអស្ចារ្យក្នុងអាកាសដល់មនុស្សមានចក្ខុខ្វាក់អំពីកំណើត ។ ព្រោះហេតុនោះ កល្យាណបុថុជ្ជន អ្នកប្រាថ្នានឹងឃើញគុណនៃព្រះធម៌ តាមបទនៃព្រះបាលីនេះ ក៏គប្បីលើកយកគុណនៃបដិបត្តិសទ្ធម្មចំណែកជាលោកិយ ដែលជាវិស័យនៃខ្លួនចូលមកប្រៀបក្នុងបទថា* **សន្ទិដ្ឋិកោ** *ជាដើម ហើយរំពឹងមើលចុះ ក៏នឹងឃើញបាន ។ កាលបើឃើញគុណនៃបដិបត្តិសទ្ធម្ម ថាជា* **សន្ទិដ្ឋិកោ** *ហើយ ក៏នឹងអនុមានដឹងតាមក្នុងលោកុត្តរធម៌ថាជា* **សន្ទិដ្ឋិកោ** *បានខ្ទះដោយបរិយាយ បីដូចជាបុថុជ្ជនចម្រើនកាយគតា-សតិរំពឹងថាកាយនេះ ពេញដោយវត្ថុមិនស្អាតគ្រឿងស្មោកគ្រោកផ្សេងៗ គឺសក់ រោម ក្រចក ធ្មេញ ជាដើម ដរាបដល់មូត្រជាទីបំផុត ចំណែកអាការទាំង ៣១ នេះ សូម្បីតែចំណែកមួយៗ សុទ្ធសឹងជាគ្រឿងស្មោកគ្រោក ហើយនឹងបានសមាធិ ការតាំងចិត្តខ្ជាប់ យ៉ាងទាបជាខណិកៈ ឬឧបចារៈ ក្នុងចំណែកណាមួយក្តី ឬ បញ្ញាដែលឃើញទោសនៃកាយថាមិនល្អក្តី ។ ចំណែកសមាធិក៏ជាធម៌ថ្វាស្អាត ព្រោះគ្របសង្កត់កាមច្ឆន្ទៈ ដែលជាវាគៈ សេចក្តីត្រេកអរក្នុងកាយខ្លួននិងកាយអ្នកដទៃ*

សមាធិដ៏ថ្លាស្អាតកើតឡើងក្នុងចិត្ត ឃើញច្បាស់ដល់ខ្លួនឯង ។ ចំណែកបញ្ញាសោតកម្ចាត់ងងឹតគឺមោហៈ ដែលឃើញថាកាយល្អ ជាអសុកានុបស្សនា ដ៏ថ្លាស្អាតកើតឡើងជាមួយនឹងចិត្ត ឃើញច្បាស់ច្រាកដដល់ខ្លួន សមាធិនិងបញ្ញានេះ ឈ្មោះថាលោកិយបដិបត្តិសទ្ធម្ម ។ លោកិយបដិបត្តិសទ្ធម្មនេះ ក៏ជា **សន្ទិដ្ឋិកោ** ដែលបុគ្គលអ្នកបដិបត្តិគប្បីឃើញឯងដូច្នេះច្រាកដ ។ កាលបើឃើញថាលោកិយបដិបត្តិសទ្ធម្ម ជា **សន្ទិដ្ឋិកោ** ដូច្នេះហើយ ក៏គង់នឹងឃើញថាជា **អកាលិកោ** មិនមានកាល មិនមានវេលា ថាបដិបត្តិប្រពៃត្រូវល្អហើយថ្ងៃនេះ ព្រឹកនេះ សមាធិនិងបញ្ញា ទើបនឹងកើតឡើងដូច្នេះ ។ កាលឃើញថាជា **អកាលិកោ** ហើយ ក៏គង់នឹងឃើញថាជា **ឯហិបស្សិកោ** គួរនឹងហៅថា អ្នកចូលមកមើលបាន ព្រោះសមាធិនិងបញ្ញាជារបស់មាននៅច្រាកដ និងជារបស់បរិសុទ្ធ កាលបើឃើញថាជា **ឯហិបស្សិកោ** ហើយ ក៏គង់នឹងឃើញថាជា **ឱបនយិកោ** ដែលបុគ្គលគប្បីបង្អោនចូលមកក្នុងចិត្តបាន ព្រោះសមាធិនិងបញ្ញាកើតឡើងក្នុងចិត្តខ្លួន ។ កាលឃើញថាជា **ឱបនយិកោ** ហើយក៏គង់នឹងឃើញថាជា **បច្ចត្តំ វេទិតព្ពោ វិញ្ញូហិ** លោកអ្នកដឹងវិសេសទាំងឡាយនឹងគប្បីដឹងច្បាស់ចំពោះខ្លួន ព្រោះសមាធិនិងបញ្ញា ជារបស់កើតឡើងឃើញច្បាស់ដោយខ្លួនឯង អ្នកដទៃមិនបានឃើញផងដូច្នេះ ។ មួយទៀត

បើបុគ្គលដំណើរក្នុងវិបស្សនាបញ្ញាហើយសោត រមែងនឹងឃើញគុណនៃបដិបត្តិសទ្ធម្ម ដោយបទបាលីថា **ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ** *ទៅដោយងាយ តែថាបើវិបស្សនាបញ្ញាជារបស់ល្អិតសុខុម ខន្ធ អាយតនៈ ជាដើម ដែលជាអារម្មណ៍នៃវិបស្សនាបញ្ញានោះ កម្របុគ្គលនឹងគប្បីដឹង ព្រោះហេតុនោះ ទើបបានលើកនូវកាយគតាសតិ-ភាវនា មកពោលអាងលួមជាបដិបត្តិមុខ គឺជាប្រធាននៃបដិបត្តិ ។*

ធម្មគុណកថា ចប់

ធម្មរតនកថា ចប់

សង្ឆរតនកថា

ពណ៌នាព្រះសង្ឆរតន:

ឃ. អ្វីហៅថាសង្ឆ? សង្ឆនោះមានប៉ុន្មានយ៉ាង? សង្ឆនោះ ប្រែថាដូចម្តេច?

វ. ពួកបុគ្គលដែលបានស្តាប់នូវឱវាទានុសាសន: គឺពាក្យទូន្មាន ប្រដៅនៃព្រះពុទ្ធអង្គដោយគោរព ហើយត្រាស់ដឹងតាមព្រះមានបុណ្យ ទើបឈ្មោះថាសង្ឆក្នុងបទនេះ ។ ដែលហៅថាសង្ឆនោះមាន ២ យ៉ាង គឺ សម្មតិសង្ឆ ១ អរិយសង្ឆ ១ ។ ភិក្ខុតាំងពី ៤ អង្គឡើងទៅអង្គុយក្នុង សីមាមិនលះហត្ថបាសគ្នា មានអំណាចឲ្យសម្រេចសង្ឆកម្មនោះ។បាន មានឧបោសថកម្មជាដើម ឈ្មោះថាសម្មតិសង្ឆ ប្រែថាសង្ឆដោយ សម្មតិ ។ ពួកសាវកនៃព្រះមានបុណ្យ ដែលជាអរិយសាវក ឈ្មោះ ថាអរិយសង្ឆ ប្រែថាពួកនៃព្រះអរិយ: ។ នឹងសម្តែងអំពីសាវក នៃព្រះមានបុណ្យជាមុន សាវក ប្រែថា បុគ្គលអ្នកស្តាប់នូវពាក្យ ប្រដៅនៃព្រះមានបុណ្យ ក៏ឯបុគ្គលដែលឈ្មោះថាសាវកនោះមាន ២ ពួក គឺបុថុជ្ជនសាវក ១ អរិយសាវក ១ បុគ្គលជំពូកណាដែលបានស្តាប់ ឱវាទចំពោះ ព្រះកត្ត្រនៃព្រះមានបុណ្យ ឬស្តាប់អំពីសំណាក់សាវក នៃព្រះមានបុណ្យក្តី មិនបានត្រាស់ដឹងមគ្គផលវិសេសណានីមួយ

បានតែសទ្ធាសេចក្ដីជឿ ក្នុងគុណព្រះរតនត្រ័យ ស្ថិតនៅក្នុងសរណគមន៍ បុគ្គលជំពូកនោះ ឈ្មោះថាបុថុជ្ជនសាវក សាវកជាបុថុជ្ជន ។ បុគ្គលជំពូកណាបានស្ដាប់ធម្មានុសាសន:ដែលព្រះមានបុណ្យទ្រង់សម្ដែងដោយព្រះអង្គឯងក្ដី ឬសាវកនៃព្រះមានបុណ្យណាមួយក្នុងពុទ្ធកាល ឬខាងក្រោយពុទ្ធកាលសម្ដែងក្ដី អ្នកនោះរមែងបានលោកុត្តរកិសម័យមគ្គផល ក្នុងខណ:កាលស្ដាប់នោះក្ដី ឬបដិបត្តិតាមពាក្យប្រដៅហើយបានក្នុងខាងក្រោយក្ដី ទាំងអម្បាលនេះ ឈ្មោះថាអរិយសាវក ប្រែថា សាវកអ្នកឆ្ងាយចាកសត្រូវគឺ កិលេស ក្នុងបទនេះមិនសង្គ្រោះយកបុថុជ្ជនសាវកទេ សង្គ្រោះយកតែអរិយសាវក ១ ជំពូកប៉ុណ្ណោះ ។ ឯអរិយសាវកនោះ ចាត់ជាគូមាន ៤ គូ គឺ សោតាបត្តិមគ្គដ្ឋ: សោតាបត្តិផលដ្ឋ: គូ ១ សកទាគាមិមគ្គដ្ឋ: សកទាគាមិផលដ្ឋ: គូ ១ អនាគាមិមគ្គដ្ឋ: អនាគាមិផលដ្ឋ: គូ ១ អរហត្តមគ្គដ្ឋ: អរហត្តផលដ្ឋ: គូ ១ រាប់រៀងបុគ្គលបាន ៨ រីឯឈ្មោះព្រះអរិយ:មាន ៤ គឺ សោតាបន្ន ១ សកទាគាមី ១ អនាគាមី ១ អរហន្ត ១ ឈ្មោះ ៤ នេះ អាស្រ័យលោកដែលតាំងនៅហើយក្នុងផល ពោលដោយគុណគឺលះកិលេសនោះៗ ដោយមគ្គនោះៗ ហើយតាំងនៅក្នុងផល ព្រះសោតាបន្នលះសំយោជន: បាន ៣ គឺសក្កាយទិដ្ថិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាស: ១ ដូចសម្ដែងហើយក្នុងសោតាបត្តិមគ្គ ព្រមទាំងលះកាមរាគ ព្យាបាទ

ចំណែកដ៏ជ្រោកជ្រាកដែលនឹងឲ្យកើតទុច្ចរិត ៣ ជាអបាយគាមិអកុសល ឲ្យដល់អបាយ លោកជាបុគ្គលមានធម៌ជាគ្រឿងមិនឲ្យធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង ជាបុគ្គលគង់នឹងបានត្រាស់ដឹង នូវអរហត្តផលទៅខាងមុខ ជាព្រះអរិយៈដល់នូវព្រះនិព្វានជាដំបូង ខណៈកាលលោកដល់សោតាបត្តិមគ្គ ឈ្មោះថាសោតាបត្តិមគ្គដ្ឋ: ប្រែថាជាអ្នកតាំងនៅក្នុងសោតាបត្តិមគ្គ ខណៈកាលលោកដល់សោតាបត្តិផល ឈ្មោះថាសោតាបត្តិផលដ្ឋ: ប្រែថាលោកអ្នកស្ថិតនៅក្នុងសោតាបត្តិផល ។ មួយទៀតដែលឈ្មោះថាសោតាបន្ននោះ ប្រែថាលោកជាអ្នកដល់នូវប្រឡាយនៃព្រះនិព្វានគឺមគ្គ ព្រោះព្រះសោតាបន្នមាន ៣ ជំពូក គឺឯកពិជី មានពូជគឺកពតែ ១ ព្រោះត្រូវកើតក្នុងមនុស្សលោក ឬទេវលោកទៀតតែម្តង ហើយធ្វើឲ្យច្បាស់នូវព្រះអរហត្តផល អស់កពខាងមុខ ជំពូក ១ ឈ្មោះកោលំកោល: គឺត្រូវកើតពីរកព ឬ ៣ កពទៀត នឹងធ្វើឲ្យច្បាស់នូវព្រះអរហត្តផលជំពូក ១ ឈ្មោះថាសត្តក្ខត្តុំបរម: គឺនៅត្រាច់រង្គាត់ក្នុងមនុស្សលោកនិងទេវលោក ៧ ដងឬ៧ជាតិ ជាយ៉ាងច្រើនបំផុត មិនដល់ជាតិជាគម្រប់ ៨ នឹងធ្វើឲ្យច្បាស់នូវព្រះអរហត្តផលដោយខន្ធបរិនិព្វានក្នុងកពគម្រប់ ៧ ពិតប្រាកដជំពូក ១ ត្រូវជា ៣ ជំពូកដូច្នេះ ។ ព្រះសកទាគামី លោករមែងធ្វើ រាគ: ទោស: មោហ: ដែលជាអកុសលមូលឲ្យតិចឲ្យស្តើងឲ្យស្រាលទៅ ដូចដើមស្មៅដុះក្នុងម្ទ ប់ លោកមកកើតក្នុងកាមកព

នេះម្តងទៀត ហើយធ្វើឲ្យច្បាស់នូវអរហត្តផលជាទីបំផុតនៃទុក្ខ រំលត់ខន្ធ បរិនិព្វាន ក្នុងខណៈដែលលោកដល់សកទាគាមិមគ្គ ឈ្មោះថាសកទា-គាមិមគ្គដ្ឋ: ប្រែថាលោកអ្នកតាំងនៅក្នុងសកទាគាមិមគ្គ ក្នុងខណៈដែលលោកដល់សកទាគាមិផលហើយ ឈ្មោះថាសកទាគាមិផលដ្ឋ: ប្រែថាលោកអ្នកតាំងនៅក្នុងសកទាគាមិផល ឬមួយឈ្មោះថាសកទាគាមី ប្រែថាលោកអ្នកមកកាន់កាមភពម្តងទៀត ។ ព្រះអនាគាមី លោករមែងលះសំយោជនៈពីរ គឺកាមរាគ ព្យាបាទបាន រំលត់ខន្ធហើយ រមែងទៅកើតក្នុងសុទ្ធាវាសព្រហ្មលោកទាំង ៥ ណាមួយ ហើយរំលត់ខន្ធ បរិនិព្វានក្នុងសុទ្ធាវាសនោះ គឺមិនត្រឡប់ចាកព្រហ្មលោកនោះជាធម្មតា ក្នុងខណៈដែលលោកដល់អនាគាមិមគ្គ ឈ្មោះថាអនាគាមិមគ្គដ្ឋ: ប្រែថាលោកស្ថិតនៅក្នុងអនាគាមិមគ្គ ក្នុងខណៈដែលលោកដល់អនាគាមិផល ឈ្មោះថាអនាគាមិផលដ្ឋ: ប្រែថាលោកស្ថិតនៅក្នុងអនាគាមិផល ឬមួយឈ្មោះថាអនាគាមី ប្រែថា លោកមិនមកកាន់កាមភពនេះទៀត ព្រះអនាគាមីនោះមាន ៥ ជំពូកគឺ ឈ្មោះថា អន្តរាបរិនិព្វាយី លោករំលត់ក្នុងចន្ទោះ គឺថាកើតក្នុងសុទ្ធាវាសព្រហ្មលោកហើយ បិតនៅមិនទាន់ដល់ពាក់កណ្តាលអាយុ លោករមែងញ៉ាំងអរហត្តមគ្គឲ្យកើតឡើង ដើម្បីលះសំយោជនៈខាងលើបានជំពូក ១ ឈ្មោះថាឧបហច្ចបរិនិព្វាយី លោកអ្នកចូលទៅដល់ហើយរំលត់ គឺលោកមានអាយុជាង៨ពាក់កណ្តាលឡើង

ទៅ ដល់កាលទៀបនឹងអស់អាយុ ញ្ចុំងអរហត្តមគ្គឲ្យកើតឡើង ដើម្បីលះសំយោជនៈខាងលើទាំង ៥ បានជំពូក ១ ឈ្មោះថា អសំខារ-បរិនិព្វាយី លោករំលត់ដោយអសង្ខារ គឺថាលោកញ្ចុំងអរហត្តមគ្គឲ្យ កើតឡើង ដើម្បីលះសំយោជនៈ ៥ ខាងលើ បានដោយងាយ មិនបាច់ ប្រកបសេចក្ដីព្យាយាមជាយ៉ាងធំក្រៃពេក ជំពូក ១ ឈ្មោះថា សសំខារ-បរិនិព្វាយី លោកអ្នករំលត់ដោយសសង្ខារ គឺថា លោកញ្ចុំងអរហត្តមគ្គ ឲ្យកើតឡើងបានដោយក្រ គឺត្រូវប្រកបសេចក្ដីព្យាយាមយ៉ាងធំក្រៃពេក ជំពូក ១ ឈ្មោះថា ឧទ្ធំសោតោអកនិដ្ឋគামី លោកអ្នកមានក្រសៃឮដ៏ ខាងលើ ទៅកាន់ភពឈ្មោះអកនិដ្ឋៈ គឺចុតចាកអវិហាព្រហ្មលោក ហើយ ទៅកាន់អតប្ផាព្រហ្មលោក លុះចុតចាកអតប្ផាព្រហ្មលោក ហើយ ទៅកាន់សុទស្សាព្រហ្មលោក លុះចុតចាកសុទស្សាព្រហ្មលោក ហើយ ទៅកាន់សុទស្សីព្រហ្មលោក លុះចុតចាកសុទស្សីព្រហ្មលោក ហើយ ទៅកាន់អកនិដ្ឋព្រហ្មលោក ហើយញ្ចុំងអរហត្តមគ្គឲ្យកើតឡើង លះសំយោជនៈខាងលើ ក្នុងព្រហ្មលោកនោះជំពូក ១ ត្រូវជា ៥ ជំពូក ដូច្នេះ ។ ព្រះអរហន្តរមែងលះសំយោជនៈខាងលើបាន ៥ គឺរូបរាគ អរូបរាគ មានៈ ឧទ្ធច្ចៈ អវិជ្ជាដែលជាកិលេសយ៉ាងល្អិត អស់ភពក្នុង ខាងមុខ រំលត់ខន្ធហើយ បរិនិព្វាន ក៏ក្នុងខណៈកាលដែលលោកដល់ អរហត្តមគ្គ ឈ្មោះថា អរហត្តមគ្គដ្ឋៈ ប្រៃថាលោកស្ថិតនៅក្នុងអរហត្តមគ្គ

ក្នុងខណៈដែលលោកដល់អរហត្តផល ឈ្មោះថាអរហត្តផលដ្ឋ: ប្រែថា លោកស្ថិតនៅក្នុងអរហត្តផល ឬមួយ ឈ្មោះថាអរហន្ត ប្រែថា លោកជាអ្នកគួរ ជាអ្នកឆ្ងាយចាកកិលេស ព្រះអរហន្តនោះ ដោយគុណនាមដែលប្រាកដមាន ៤ ជំពូក គឺ សុក្ខវិបស្សកោ លោកមានវិបស្សនាដ៏រីងស្ងួត ព្រោះមិនមានជ័រ គឺ សមថភាវនា បានចម្រើនវិបស្សនា បានដល់នូវព្រះអរហត្ត មិនប្រកបដោយឫទ្ធិវិសេសណានីមួយជំពូក ១ ឈ្មោះ ថាតេវិជ្ជោ លោកប្រកបដោយវិជ្ជា ៣ ជំពូក ១ ឈ្មោះថាឆឡភិញ្ញោ លោកប្រកបដោយអភិញ្ញា ៦ ជំពូក ១ ឈ្មោះថាបដិសម្ភិទប្បត្តោ លោកដល់បដិសម្ភិទាទាំង ៤ ជំពូក ១ ជា ៤ ជំពូកដូច្នេះ ប្រភេទ ៤ នេះ រមែងបានក្នុងព្រះអរិយ:ឦដ៏ខាងក្រោម ដោយបរិយាយពួកនៃព្រះអរិយ: ដែលជាសាវកនៃព្រះមានបុណ្យ ដូចសម្តែងមកនេះ ឈ្មោះថាអរិយសង្ឆ ក្នុងបទនេះ ទើបបានសមដូចព្រះបាលីថា **ភតរតោ សាវកសង្ឆោ សង្ឆោ** នោះ ប្រែថា ពួក ថាជិតគ្នា គឺថាព្រះអរិយ:អម្បាលនេះ សូម្បីនៅឆ្ងាយអំពីគ្នា អង្គមួយ ប្រទេស ១ អង្គមួយ ពិភព ១ ផ្សេងគ្នា ដោយជាតិនិងភេទ ក៏ឈ្មោះថាជាពួកតែមួយ ឈ្មោះថាជិតគ្នា ដោយគុណគឺសីល និងទិដ្ឋិសេចក្តីឃើញស្មើគ្នា ដូចពាក្យថា **មិត្តសង្ឆោ** ប្រែថាពួកសត្វម្រឹគ **សកុណសង្ឆោ** ប្រែថា ពួកសត្វបក្សី ដោយលោកវោហារ ដែលថាដូច្នេះ អាស្រ័យជាតិនិងអវយវ:សណ្ឋានរាងកាយ

ដែលដូចគ្នា ប្រហែលគ្នា ជាពួកជាកងសញ្ជ្ញារទៅលើផែនដីក្តី លើអាកាសក្តី លោកវោហារហៅថា ពួកម្រឹគ ពួកបក្សី ព្រោះថាសត្វទាំងនោះដូចគ្នា ប្រហែលគ្នា ជិតគ្នា ក៏ឯព្រះអរិយៈនៅផ្សេងស្ថានគ្នាក្តី តែគុណគឺសីលនិងទិដ្ឋិនោះដូចគ្នា ប្រហែលគ្នា ជិតគ្នា ព្រោះហេតុនោះ ដោយអរិយវោហារ ទើបហៅថា **សង្ឆো** ថាពួក ថាជិតគ្នា ដោយគុណ ។

បុ. ព្រះសង្ឆមានគុណដូចម្តេច?

វិ. គុណនៃព្រះសង្ឆមានច្រើន តែនឹងបំប្លួញឲ្យខ្ចីចុះមក គុណដែលជាប្រធាននៃគុណទាំងពួងក៏មានតែមួយយ៉ាង គឺ **សុបដិបត្តិ** សេចក្តីបដិបត្តិប្រពៃ ។

លំដាប់នេះនឹងប្រែ អធិប្បាយក្នុងបាលីថា **សុបដិបន្ណো** ជាដើម ដើម្បីនឹងឲ្យសាធុជនដឹងគុណនៃព្រះសង្ឆ ដែលជាអនុស្សតិដ្ឋាន ។

ភគវតោ សាវកសង្ឆো ព្រះសង្ឆសាវកនៃព្រះមានបុណ្យ ឬប្រែថា ពួកសាវកនៃព្រះមានបុណ្យ **សុបដិបន្ណো** លោកបដិបត្តិប្រពៃហើយ គឺថាលោកដំណើរទៅកាន់ **សម្មាបដិបទា អនិវត្តិបដិបទា អនុលោមបដិបទា អប្ឍចូនិកបដិបទា** និង **ធម្មានុធម្មបដិបទា** ។ **មគ្គ** ប្រកបដោយអង្គ ៨ ដែលសង្គ្រោះដោយខន្ធ ៣ គឺ សីល សមាធិ បញ្ញា នេះឯង ឈ្មោះថា សម្មាបដិបទា ព្រោះជាការបដិបត្តិប្រពៃពិតមិនវិបល្ងាស ឈ្មោះថា អនិវត្តិបដិបទា

ការបដិបត្តិមិនត្រឡប់ ព្រោះអ្នកណាដំណើរដល់ហើយ អ្នកនោះ ឈ្មោះថា ព្រះអរិយៈមិនត្រឡប់មកជាបុថុជ្ជនទៀត ឈ្មោះថា អនុលោម-បដិបទា ការបដិបត្តិជាអនុលោមដល់ព្រះនិព្វាន ឈ្មោះថា អប្បច្ចនិក-បដិបទា ការបដិបត្តិមិនជាសត្រូវដល់ព្រះនិព្វាន ឈ្មោះថា ធម្មានុធម្ម-បដិបទា ការបដិបត្តិនូវធម៌តាមធម៌ គឺបដិបត្តិសមគួរដល់ព្រះនិព្វាន ។ ព្រះសង្ឆជាអ្នកដំណើរតាម សម្មាបដិបទា ដែលប្រកបដោយគុណ ដូចសម្តែងមកនេះឯង ទើបឈ្មោះថា **សុបដិបន្នោ** *លោកបដិបត្តិល្អ ហើយ ។*

ភគវតោ សាវកសង្ឆো *ព្រះសង្ឆសាវកនៃព្រះមានបុណ្យ* **ឧជុបដិបន្នោ** *លោកដំណើរទៅកាន់ផ្លូវបដិបត្តិត្រង់ សម្មាបដិបទា ដូចសម្តែងមកនេះឯង ឈ្មោះថា ឧជុបដិបទា ជាផ្លូវបដិបត្តិត្រង់មិនវៀច មិនកោង មិនរំពត់ជាផ្លូវត្រង់ទៅកាន់ព្រះនិព្វាន ព្រះសង្ឆដំណើរតាម សម្មាបដិបទានោះ ទើបឈ្មោះថា* **ឧជុបដិបន្នោ** *លោកដំណើរទៅ កាន់ផ្លូវបដិបត្តិត្រង់ ។*

ភគវតោ សាវកសង្ឆো *ព្រះសង្ឆសាវកនៃព្រះមានបុណ្យ* **ញាយបដិបន្នោ** *លោកដំណើរទៅកាន់ផ្លូវបដិបត្តិដើម្បីត្រាស់ដឹង សម្មាបដិបទា សេចក្តីបដិបត្តិប្រពៃនោះឯងឈ្មោះថា ញាយបដិបទា ព្រោះជាផ្លូវបដិបត្តិសម្រាប់ដឹងច្បាស់ ចាក់ធ្ងុនូវព្រះនិព្វាន ជារបស់ព្រះ*

អរិយ:ជាម្ចាស់ ព្រះសង្ឆដំណើរតាមផ្លូវបដិបត្តិនោះ ទើបឈ្មោះថា **ញ្ញាយបដិបន្នោ** *លោកដំណើរទៅហើយកាន់ផ្លូវបដិបត្តិដើម្បីត្រាស់ដឹង ។*

ភគវតោ សាវកសង្ឆោ *ព្រះសង្ឆសាវកនៃព្រះមានបុណ្យ* **សាមីចិបដិបន្នោ** *លោកដំណើរទៅកាន់ផ្លូវបដិបត្តិប្រពៃពិត សម្ម-បដិបទា ផ្លូវបដិបត្តិប្រពៃនោះឯង ឈ្មោះថា សាមីចិបដិបទា ព្រោះជាផ្លូវបដិបត្តិប្រពៃពិត សមគួរដល់ព្រះនិព្វាន ព្រះសង្ឆលោកដំណើរទៅតាមផ្លូវបដិបត្តិនោះ ទើបឈ្មោះថា* **សាមីចិបដិបន្នោ** *លោកដំណើរទៅកាន់ផ្លូវបដិបត្តិប្រពៃពិត ព្រះអរិយ:ជំពូកណាតាំងនៅក្នុងមគ្គ ព្រះអរិយ:ជំពូកនោះ បណ្ឌិតគប្បីដឹងថា* **សុបដិបន្នោ** *លោកបដិបត្តិល្អហើយ ព្រោះលោកដល់ព្រមដោយនូវសម្មាបដិបទា គឺមគ្គ ព្រះអរិយ:ទាំងឡាយណា ដែលតាំងនៅក្នុងផល ព្រះអរិយ:ទាំងឡាយនោះ បណ្ឌិតគប្បីដឹងថា* **សុបដិបន្នោ** *លោកបដិបត្តិល្អហើយ អាស្រ័យផ្លូវបដិបត្តិដែលជាអតីតកន្ទងទៅហើយ ព្រោះធម៌ដែលលោកគប្បីដល់គប្បីបានដោយសម្មាបដិបទានោះ លោកដល់ហើយលោកបានហើយ ។*

មួយទៀត ព្រះសង្ឆឈ្មោះថា **សុបដិបន្នោ** *លោកបដិបត្តិល្អ ព្រោះជាអ្នកបដិបត្តិតាមឱវាទដែលព្រះមានបុណ្យប្រដៅក្នុងធម្មវិន័យដែលព្រះអង្គសម្តែងល្អហើយ ។ មួយទៀតឈ្មោះថា* **សុបដិបន្នោ** *ព្រោះ*

លោកដំណើរទៅកាន់អបណ្ណកបដិបទា ដំណើរដោយផ្លូវបដិបត្តិមិនខុស ឈ្មោះថា **ឧជុបដិបន្ធោ** លោកបដិបត្តិត្រង់ហើយ ព្រោះលោកមិនចូលទៅជិតកាន់ផ្លូវលាមក ២ ប្រការ គឺ កាមសុខល្វិកានុយោគ និងអត្ត-កិលមថានុយោគ ដែលជាផ្លូវបដិបត្តិខុស លោកដំណើរតាមមជ្ឈិមាបដិ-បទាផ្លូវបដិបត្តិយ៉ាងកណ្តាល ។ មួយទៀតឈ្មោះថា **ឧជុបដិន្ធោ** ព្រោះលោកបដិបត្តិត្រង់ ដើម្បីលះបង់នូវទោស គឺសេចក្តីកោង កាយ-វាចាចិត្ត ព្រះសង្ឆឈ្មោះថា **ញាយបដិបន្ធោ** លោកបដិបត្តិ ដើម្បីធម៌ដែលបុគ្គលគប្បីដឹង ព្រោះលោកបដិបត្តិ ដើម្បីប្រយោជន៍ដល់ព្រះនិព្វាន ជាធម៌គឺព្រះអរិយបុគ្គលគប្បីដឹង ឈ្មោះថា **សាមីចិបដិបន្ធោ** លោកបដិបត្តិប្រពៃពិត ព្រោះថាបុគ្គលទាំងឡាយបដិបត្តិយ៉ាងដូចម្តេចទើបលោកថាអ្នកគួរ សាមីចិកម្មមានអភិវាទក្រាបសំពះជាដើម លោកក៏បដិបត្តិយ៉ាងនោះ ។

មួយទៀត ព្រះសង្ឆឈ្មោះថា **សុបដិបន្ធោ** លោកបដិបត្តិល្អនោះ គឺលោកធ្វើសីលប្រៀបបីដូចជារបងឬកំពែង ដែលការពារសឹកសត្រូវគឺទុច្ចរិតសង្កិលេស ដែលជាអកុសលដ៏គ្រោតគ្រាត កើតក្នុងកាយ-ទ្វារ វចីទ្វារ ហើយលោកធ្វើសមាធិ ប្រៀបដូចផែនសិលាធំ បិទបាំងទុកនូវសត្រូវក្នុងខាងក្នុង គឺបរិយុដ្ឋានសង្កិលេស ដែលជាអកុសលកើតឡើង គ្របសង្កត់ចិត្ត លោកធ្វើបញ្ញាជាដួងប្រទីបពន្លឺ ឲ្យភ្លឺក្នុងកងសង្ខារ

ទាំងពួងដោយចំណែកៗ មានខន្ធជាដើម ឃើញច្បាស់ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដោយហេតុនេះៗ ហើយ ទើបធ្វើបញ្ញាប្រៀប ដូចជាសស្ត្រា មានមុខមុតថ្នាពិឃាដសម្ងាប់អនុស័យសង្កិលេស ដែលជា ចំណែកល្អិត យ៉ាងទាបថាព្រះសោតាបន្នបុគ្គល អស់សក្កាយទិដ្ឋិដោយ ឃើញច្បាស់ថា បញ្ចក្ខន្ធមិនមែនខ្លួនប្រាណ អស់វិចិកិច្ឆា សេចក្តី សង្ស័យក្នុងកាលទាំង ៣ ក្នុងរតន:ទាំង ៣ ដោយឃើញគុណព្រះពុទ្ធ ច្បាស់ ទើបលោកុត្តរធម៌កើតឡើងប្រាកដក្នុងសន្តាន លុះលោកបាន សម្រេចជាព្រះអរិយសង្ឆ អស់សីលពូតបរាមាស ព្រោះឃើញច្បាស់ ថាខ្លួនបរិសុទ្ធដោយត្រៃសិក្ខា ដែលជាសម្មាបដិបទាផ្លូវបដិបត្តិប្រពៃ មិនបរិសុទ្ធដោយសីលពូតដែលជាផ្លូវបដិបត្តិយ៉ាងដទៃ ព្រះសង្ឆឈ្មោះ ថា **ឧជុបដិបន្ណោ** លោកបដិបត្តិត្រង់នោះ គឺលោកបដិបត្តិត្រង់ ព្រមទាំង កាយ វាចា ចិត្ត ព្រោះលះបាននូវការកោង ដោយកាយ វាចា ចិត្ត ឈ្មោះថា **ញាយបដិបន្ណោ** លោកបដិបត្តិដើម្បីចេញចាក សង្សារវដ្ត គឺលោកមិនបដិបត្តិដើម្បីលាភនិងយស សេចក្តីសរសើរ ក្នុងបច្ចុប្បន្ននិងសួគ៌សុគតិភព ដែលសោយសុខនោះៗ ក្នុងខាងមុខ លោកបដិបត្តិដើម្បីនឹងចេញចាកភពទាំងពួងនិងទុក្ខទាំងពួង មួយចំណែក ប៉ុណ្ណោះ ព្រះសង្ឆឈ្មោះថា **សាមីចិបដិបន្ណោ** លោកបដិបត្តិ ប្រពៃពិត គឺលោកបដិបត្តិពត់កាយ វាចា ចិត្ត ដោយត្រៃសិក្ខា គឺ

សីល សមាធិ បញ្ញា ដែលជាសម្មាបដិបទា សេចក្តីបដិបត្តិប្រពៃពិត គួរដល់លោកុត្តរធម៌ **យទិទំ** *ដូចម្តេចនេះ* **ចត្តារិ បុរិសយុគានិ** *គូនៃបុរសទាំងឡាយមាន ៤ គូ* **អដ្ឋ បុរិសបុគ្គលា** *បុរសបុគ្គលទាំងឡាយមាន ៨ គឺចាត់ជាគូមាន ៤ គូ បើរាប់រៀងខ្លួនបុគ្គលមាន ៨* **ឯស ភគវតោ សាវកសង្ឆោ** *នេះឯងឈ្មោះថាព្រះសង្ឆសាវកនៃព្រះមានបុណ្យ* **អាហុនេយ្យោ** *លោកគួរនូវអាហុនៈ អាហុនៈ នោះ ប្រែថារបស់ដែលបុគ្គលនាំមក សូម្បីអំពីទីឆ្ងាយហើយថ្វាយក្នុងបុគ្គលទាំងឡាយដែលជាអ្នកមានសីល គឺបច្ច័យទាំង ៤ នោះឯង ព្រះសង្ឆលោកគួរទទួលនូវអាហុនៈនោះ ព្រោះលោកជាអ្នកធ្វើនូវអាហុនៈនៃទាយកនោះ ឲ្យមានផលច្រើនក្រៃពេក បានដោយគុណនៃខ្លួន ព្រោះហេតុនោះ លោកទើបឈ្មោះថា* **អាហុនេយ្យោ** *លោកគួរទទួលនូវអាហុនៈ ។* **ចាហុនេយ្យោ** *លោកគួរនូវបាហុនៈ របស់សម្រាប់ទទួលភ្ញៀវ គឺអាគន្តុកទាន ដែលបុគ្គលតាក់តែងទុកព្រមដោយគ្រឿងសក្ការៈ ដើម្បីប្រយោជន៍និងទទួលញាតិមិត្ត ជាទីស្រឡាញ់គាប់ចិត្ត ដែលមកអំពីទិសានុទិស អាគន្តុកទានរបស់សម្រាប់ទទួលភ្ញៀវនោះ គួរនឹងលើកវៀរចេញ នូវញាតិមិត្តនិងមនុស្សដែលមកជាភ្ញៀវទាំងនោះ ហើយថ្វាយចំពោះព្រះសង្ឆ ព្រះសង្ឆនោះឯង គួរនឹងទទួលនូវរបស់សម្រាប់ទទួលភ្ញៀវនោះ ព្រោះមនុស្សដែលមកជាភ្ញៀវដទៃស្មើដោយ*

ព្រះសង្ឆនោះមិនមាន ដ្ឋិតថា ព្រះសង្ឆដែលមកជាក្ងៀវនោះ រមែងប្រាកដមានតែក្នុងពុទ្ធកាលប៉ុណ្ណោះ មិនមានក្នុងកាលទាំងពួង ហើយលោករមែងប្រកបដោយធម៌ ដែលធ្វើនូវភាពគួរស្រឡាញ់ គួរគាប់ចិត្ត មានសីលគុណជាដើម ដែលមិនសៅហ្មងដាច់ដាចធ្ងុះធ្ងាយ ព្រោះដូច្នេះ របស់សម្រាប់ទទួលក្ងៀវនោះ ទើបគួរថ្វាយដល់ព្រះសង្ឆ ព្រះសង្ឆនោះឯង គួរទទួលនូវរបស់សម្រាប់ទទួលក្ងៀវនោះ ព្រោះហេតុដូច្នេះ ព្រះសង្ឆទើបឈ្មោះថា **ចាហុនេយ្យោ** លោកគួរទទួលនូវរបស់សម្រាប់ទទួលក្ងៀវ ។ **ឧក្ខិណេយ្យោ** លោកគួរនូវទក្ខិណា-ទានជាគ្រឿងចម្រើនដោយសម្បត្តិ ទានគឺបុគ្គលជឿនូវបរលោក ហើយគប្បីឲ្យឈ្មោះថាទក្ខិណាក្នុងបទនេះ ព្រះសង្ឆលោករមែងគួរនូវទក្ខិណានោះ ។ មួយទៀត លោករមែងទំនុកបម្រុងដល់ទក្ខិណាទាននោះ គឺថាលោករមែងជម្រះទក្ខិណាទានរបស់ទាយកឲ្យបរិសុទ្ធបាន ព្រោះធ្វើទក្ខិណាទាននោះឲ្យមានផលច្រើនក្រៃពេក ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **ឧក្ខិណេយ្យោ** ជាអ្នកគួរនូវទក្ខិណា ។ **អញ្ជលិការណីយោ** លោកជាបុគ្គលគួរនូវអញ្ជលីកម្ម ក្រពុំហត្ថដែលលោកទាំងពួងតម្កល់ទុកលើសិរហើយធ្វើ សូម្បីយ៉ាងទាប សត្វលោកមិលមើលព្រះសង្ឆដោយចក្ខុប្រកបដោយមេត្តាប៉ុណ្ណោះ ចក្ខុនោះរមែងប្រាសចាកទោសមានឡើងបាយជាដើមក្នុងអនេកជាតិ **អនុត្តរំ បុញ្ញក្ខេត្តំ**

លោកស្ស ព្រះសង្ឆជាស្រែបុណ្យ ទីព្រោះពូជ គឺកុសលនៃសត្វលោកទាំងពួង មិនមានស្រែដទៃលើសជាង ឬស្មើបាន ដូចជាទីបណ្តុះព្រោះពូជស្រូវសាលី ឬស្រូវដំណើបនៃក្សត្រ ឬអាមាត្យ លោករមែងហៅថា ស្រែស្រូវសាលី ស្រែស្រូវដំណើប នៃក្សត្រនិងអាមាត្យ ដូចម្តេចក្តី ព្រះសង្ឆជាទីពន្ធកទីចម្រើនបុណ្យនៃលោកទាំងពួងទើបឈ្មោះថាស្រែបុណ្យនៃលោក មិនមានអ្នកណាស្មើលើស ព្រោះបុណ្យកុសលដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្តីសុខ មានប្រការផ្សេងៗ នៃសត្វលោក រមែងពន្ធកល្អចម្រើនឡើងក៏ព្រោះតែអាស្រ័យព្រះសង្ឆ ដែលថាព្រះសង្ឆជាស្រែបុណ្យ នៃលោកមិនមានស្រែដទៃក្រៃលែងជាងនោះ ដ្បិតព្រះសង្ឆជាស្រែបរិសុទ្ធប្រាសចាកទោស គឺកិលេសដែលជាគ្រឿងប្រទូសរ៉ាយក្នុងសន្តានៃខ្លួន និងទានការបូជានៃលោក ដូចស្រែបរិសុទ្ធប្រាសចាកទោស គឺស្មៅនិងក្រួសខ្សាច់ ដែលជារបស់ប្រទូសរ៉ាយដល់សន្ធូង ក៏ឯគុណនៃព្រះសង្ឆ ដែលមានក្នុងបទបាលីទាំងអម្បាលនេះ សម្តែងបង្ហូញឲ្យខ្ជីក៏មាន ២ ប៉ុណ្ណោះ គឺអត្តហិត: គុណទំនុកបម្រុងដល់ខ្លួនឯង ១ បរហិត: គុណទំនុកបម្រុងដល់អ្នកដទៃ ១ គុណទំនុកបម្រុងដល់ខ្លួនឯងនោះ បានតឹងបទថា **សុបដិបន្ណោ ឧជុបដិបន្ណោ ញាយ-បដិបន្ណោ សាមីចិបដិបន្ណោ** ដូច្នេះ គុណទំនុកបម្រុងដល់អ្នកដទៃនោះ បានតឹងបទដ៏សេស តាំងអំពី **អាហុនេយ្យោ** ជាដើមទៅ

ក៏ឯអ្នកដែលរំពឹងដល់គុណនៃព្រះសង្ឆ នឹងរំពឹងតាមបទគ្រប់ៗ បទ ក៏បាន ឬនឹងរំពឹងតែបទណាមួយក៏បាន ឬ ២ បទក៏បាន តែឲ្យដឹងអត្ថាធិប្បាយឲ្យច្បាស់ កុំកាន់យកតែព្យញ្ជនៈ មកទន្ទេញដោយវាចាធ្វើដូច្នេះមិនសម្រេចប្រយោជន៍ណាមួយឡើយ ។

សង្ឆរតនកថា ចប់

រតនត្តយបឺ ចប់

វិនយកថា

អាបត្តិនាមាទិបព្ទ

ឥតោ បរំ ឧតិយាទិ បញ្ចានំ វណ្ណនាតតា
វិនយោ យត្ត នេវញ្ញា សិក្ខិតព្ទំ រ សាធុកំ ។

លំដាប់នេះ នឹងពណ៌នាក្នុងបព្ទ:គម្រប់ ២ ជាដើម ដែលមានមកក្នុងវណ្ណនាឯណា ដែលជាវិន័យ ១ យ៉ាង មិនមែនជាធម៌ដទៃ កុលបុត្រដែលជាអ្នកមានសេចក្តីប្រាថ្នាដើម្បីនឹងសិក្សា គប្បីសិក្សាដោយប្រពៃចុះ ។

នឹងពណ៌នាក្នុងអាបត្តិនាមាទិបព្ទ: សម្តែងដោយឈ្មោះនៃអាបត្តិជាដើម អាបត្តិទាំងពួងដែលកិក្ខុត្រូវហើយ នឹងលើកឈ្មោះឡើងប្តេជ្ញាហើយពោលដោយកងមាន ៧ គឺ បារាជិក ១ សង្ឆាទិសេស ១ ថុល្ល-ច្ច័យ ១ បាចិត្តិយ ១ បាដិទេសនីយ: ១ ទុក្កដ ១ ទុព្ភាសិត ១ ដោយលំដាប់នៃទោសធ្ងន់ ទោសស្រាលដូច្នេះ ។

អាបត្តិនាមកថា

អាបត្តិនោះ ប្រែថា ការត្រូវ ការដល់ នូវវីតិក្កមទោស គឺការប្រព្រឹត្តកន្ទងសិក្ខាបទ ។ មួយទៀត ប្រែថាធម្មជាតិ គឺកិក្ខុគប្បីត្រូវគប្បីដល់ ដោយប្រព្រឹត្តអនាចារ ជាការក្រៅបញ្ញត្តិ ។

បារាជិកសព្ទនេះ បើសំឡឹងយកបុគ្គលជាប្រធាន ប្រែថាអ្នកដល់នូវសេចក្តីចាលចាញ់ បើសំឡឹងយកអាបត្តិជាប្រធាន ប្រែថាអាបត្តិញ៉ាំង

បុគ្គលឲ្យចាលចាញ់ ដ្បិតអាបត្តិនេះ ភិក្ខុណាត្រូវហើយ ភិក្ខុនោះឈ្មោះថា ជាអ្នកចាលចាញ់ ជាអ្នកចុតិ ឃ្លាតចាកព្រះសទ្ធម្ម ។

សង្ឆាទិសេស ប្រែថាកងនៃអាបត្តិ មានសង្ឆដែលភិក្ខុគប្បីប្រាថ្នាក្នុងកាលខាងដើម និងកាលដ៏សេស ដ្បិតអាបត្តិកងនេះ ភិក្ខុណាត្រូវហើយ ភិក្ខុនោះត្រូវអាស្រ័យសង្ឆក្នុងកាលខាងដើម គឺឲ្យបរិវាស និងកាលដ៏សេស គឺមូលាយបដិកស្សនៈ ហើយឲ្យមានត្តជាកណ្ដាល និងឲ្យអព្ភានកម្ម ក្នុងកាលដ៏សេស ទើបចេញចាកអាបត្តិនោះបាន ។

ថុល្លច្ចយ ប្រែថាទោសថ្ងៃស ទោសអាក្រក់ ដ្បិតថាបណ្ដាអាបត្តិទាំងពួង ដែលភិក្ខុត្រូវហើយ សម្ដែងក្នុងសំណាក់នៃភិក្ខុដទៃ សូម្បីតែមួយអង្គក៏ធ្ងាក់ទៅបាន អាបត្តិកងនេះអាក្រក់ជាងអាបត្តិដែលជាទេសនាគាមិនីទាំងពួង ។

បាចិត្តិយ ប្រែថាអាបត្តិញ៉ាំងកុសលធម៌ឲ្យធ្ងាក់ ដ្បិតថាភិក្ខុណាកៃងត្រូវអាបត្តិកងនេះហើយ ភិក្ខុនោះឈ្មោះថាធ្ងាក់ចាកកុសលធម៌ ប្រាសចាកអរិយមគ្គ ដល់នូវមោហដ្ឋាន ទីវង្វេងនៃចិត្ត ។

បាដិទេសនីយៈ ប្រែថាអាបត្តិដែលភិក្ខុគប្បីត្រឡប់សម្ដែងយ៉ាងដទៃ ដ្បិតអាបត្តិនេះ ភិក្ខុត្រូវហើយមិនបានសម្ដែងដូចអាបត្តិដទៃ គប្បីត្រឡប់ប្រើបាឡីសម្ដែងដូច្នេះថា : **ការយ្ហំ អាវុសោ ឧម្មុំ អាបជ្ជិ អសប្ប៉ាយំ ចាដិទេសនីយំ តំ បដិទេសេមិ** *ដូច្នេះ ។*

ទុក្កដ ប្រែថាធ្វើអាក្រក់ ដ្បិតកិក្ខុណាត្រូវហើយ កិក្ខុនោះឈ្មោះ ថាធ្វើអាក្រក់ ធ្វើមិនល្អ ធ្វើខុស ចំពោះអរិយមគ្គ ដូចបុគ្គលធ្វើបាបក្នុង ទីវាលឬទីកំបាំង លោកវមែងតិះដៀលថា ជាមនុស្សធ្វើអាក្រក់ ធ្វើមិន ល្អ ធ្វើខុស ។

ទុព្ភាសិត ប្រែថាពោលអាក្រក់ ដ្បិតថាពាក្យណាជាពាក្យអាក្រក់ ជាពាក្យដែលអ្នកប្រាជ្ញតិះដៀល កិក្ខុពោលពាក្យនោះទើបត្រូវអាបត្តិនោះ ។

មួយទៀត បារាជិកាបត្តិ ជាអតេកិច្ចា រក្សាតទៅដោយឧបាយ ឯណានីមួយមិនបាន សូម្បីនឹងកាន់យកកេទគ្រហស្ថ ហើយត្រឡប់មក សូមឧបសម្ប៉ាទទៀតក៏មិនបាន អាបត្តិក្រៅនោះ ៦ កង ជាសតេកិច្ចា ឲ្យមរក្សាតទៅបាន គឺថាត្រូវហើយធ្វើខ្ជួនឲ្យបរិសុទ្ធ ដោយវុដ្ឋានវិធីនិង ទេសនាវិធីបាន ។ មួយទៀត បារាជិក សង្ឆាទិសេស ២ នេះ ឈ្មោះថា គរុកាបត្តិ ជាអាបត្តិធ្ងន់ បារាជិកជាអាបត្តិធ្ងន់ដោយទោសជាមូលច្ឆេទ សង្ឆាទិសេសជាអាបត្តិធ្ងន់ដោយទោសផង ដោយវិធីចេញចាកអាបត្តិ នោះផង អាបត្តិក្រៅនោះ ៥ កង ឈ្មោះថាលហុកាបត្តិ ជាអាបត្តិ ស្រាល ដោយវិធីដែលនឹងចេញ ។

មួយទៀត សង្ឆាទិសេសាបត្តិ ឈ្មោះថាវុដ្ឋានគាមិនី ដល់នូវ វុដ្ឋានវិធី គឺអាស្រ័យសង្ឆអនុញ្ញាត ឲ្យនូវបរិវាសនិងមានត្ត ប្រព្រឹត្តកិច្ច ទើបរួចចាកទោស ជាមនុស្សបរិសុទ្ធបាន អាបត្តិក្រៅនោះ ៥ កង

ឈ្មោះថាទេសនាគាមិនី ដល់នូវទេសនាវិធី គឺសម្តែងក្នុងសំណាក់នៃភិក្ខុ សូម្បី១រូបក៏បរិសុទ្ធបាន។ មួយទៀត សូម្បីអាបត្តិបាចិត្តិយ៉ៈ ទេសនាគាមិនីដែរ ដ្បិតថាភិក្ខុណាត្រូវហើយ ភិក្ខុនោះប្តេជ្ញាខ្ជួនតាមត្រង់ចំពោះមុខនៃភិក្ខុដទៃ ហើយលះកេទភិក្ខុចេញ កាន់យកកេទគ្រហស្ថ ក៏រួចចាកទោសនោះបាន អាបត្តិនោះមិនជាសគ្គាវណៈ:ឃាត់ផ្លូវសួគ៌ដល់អ្នកនោះ។ មួយទៀត បាចិត្តិយ៉ៈ សង្ឆាទិសេស២នេះ ឈ្មោះថាទុដ្ឋុល្លាបត្តិ ជាអាបត្តិអាក្រក់ទន់ទាបដោយទោស អាបត្តិ៥កង៧ក្រៅនោះ ឈ្មោះថាអទុដ្ឋុល្លាបត្តិ មិនជាអាបត្តិអាក្រក់ ទន់ទាប ដោយទោស។ មួយទៀត បាចិត្តិយ៉ៈ ឈ្មោះថាអនវសេសាបត្តិ ជាអាបត្តិមិនមានសេស ភិក្ខុត្រូវហើយក៏ឃ្លាតចាកព្រហ្មចរិយ:ដោយពិត អាបត្តិ៦កង៧ក្រៅនោះ ឈ្មោះថាសាវសេសាបត្តិ ជាអាបត្តិនៅមានសេសសល់ គឺវុដ្ឋានវិធី និងទេសនាវិធី ជាចំណែកដ៏សេសដែលនឹងឲ្យបរិសុទ្ធបាន។ មួយទៀត អាបត្តិ បាចិត្តិយ៉ៈ សង្ឆាទិសេស២នេះ ជាសីលវិបត្តិ ជាទោសធំ ភិក្ខុត្រូវហើយឈ្មោះថាដល់នូវសេចក្តីវិបត្តិសីល ក្នុងអាបត្តិ ៥ កង៧ក្រៅនោះ អាបត្តិណា ដែលភិក្ខុត្រូវហើយមានទោសផង ទាំងអាចារ:មារយាទរបស់សមណ:ក៏ខូចទៅផង ដូច្នេះឈ្មោះថាអាចារវិបត្តិ ក្នុងអាបត្តិ ៥ កង៧នោះ អាបត្តិណា ដែលភិក្ខុត្រូវដោយទិដ្ឋិសេចក្តីឃើញវិបរិត ជាអន្តគាហិកទិដ្ឋិ ដូច្នេះឈ្មោះថា ទិដ្ឋិវិបត្តិ ដូចបាចិត្តិយ៉ៈ នៃភិក្ខុអ្នកពោលបង្ហាប់

ព្រះមានបុណ្យ ដូចក្នុងអរិដ្ឋសិក្ខាបទជាតួយ៉ាង ក្នុងអាបត្តិ ៥ កង នោះ អាបត្តិណា ភិក្ខុត្រូវហើយ អាជីវ: ការចិញ្ចឹមជីវិតវិនាសទៅ ដូចអាបត្តិព្រោះកុលទូសកកម្ម អាបត្តិនោះឈ្មោះថា អាជីវវិបត្តិ។ មួយទៀត អាបត្តិបារាជិក សង្ឆាទិសេស ដែលភិក្ខុត្រូវ ព្រោះអាស្រ័យ អាជីវ:ក៏ឈ្មោះថាអាជីវវិបត្តិដែរ ព្រោះហេតុនោះ ក្នុងគម្ពីរបរិវារ: លោក លើកយកសិក្ខាបទទាំង៦ ឡើងតម្កល់ទុក ដើម្បីឲ្យឃើញ នូវអាជីវវិបត្តិ ដូច្នេះថា ភិក្ខុអួតឧត្តរិមនុស្សធម្ម ដែលមិនមានក្នុងខ្លួន ព្រោះហេតុនៃ អាជីវ: ត្រូវបារាជិក ភិក្ខុដល់នូវសញ្ចរិត្ត នាំការព្រោះហេតុនៃអាជីវ: ត្រូវ សង្ឆាទិសេស ភិក្ខុអួតឧត្តរិមនុស្សធម្មដោយបរិយាយជាដើមថា អ្នក ណានៅក្នុងវិហារ អ្នកនោះ ជាព្រះអរហន្តដូច្នេះ ព្រោះហេតុនៃអាជីវ: អ្នកស្តាប់ដឹងសេចក្តីក្នុងខណ:នោះ ភិក្ខុនោះត្រូវបុល្លច្ច័យ ភិក្ខុមិនឈឺ សូមបណ្ដាតគោជន អំពីមនុស្សមិនមែនញាតិធាន់ ព្រោះហេតុនៃអាជីវ: ត្រូវបាចិត្តិយ នាងភិក្ខុនីមិនឈឺ សូមវត្ថុ៨ប្រការមានសប្បិជាដើម អំពី មនុស្សមិនមែនញាតិធាន់ ព្រោះហេតុនៃអាជីវ:ត្រូវបាដិទេសនីយ: ភិក្ខុ មិនឈឺ សូមសម្ងនិងបាយ អំពីមនុស្សមិនមែនញាតិធាន់ ព្រោះហេតុនៃ អាជីវ:ត្រូវទុក្កដ ដូច្នេះ។ ដោយលោកលើកសិក្ខាបទ៦ឡើង សម្ដែង ទុកនេះ គប្បីដឹងចុះថា ក្នុងសិក្ខាបទដែលជាសីលវិបត្តិ អាចារវិបត្តិ

ទិដ្ឋិវិបត្តិនោះ អាបត្តិណា ដែលកិក្ខុត្រូវ ដោយអាស្រ័យអាជីវ:ជាហេតុ អាបត្តិនោះ ក៏ជាអាជីវវិបត្តិដែរ ។

មួយទៀត បាចិត្តិយនោះមាន ២ គឺ និស្សគ្គិយបាចិត្តិយ ១ សុទ្ធិក-បាចិត្តិយ ១ ។ និស្សគ្គិយបាចិត្តិយនោះ ប្រែថាបាចិត្តិយមានកិរិយាលះជាវិនយកម្ម បានដល់បាចិត្តិយាបត្តិ ក្នុងនិស្សគ្គិយុទ្ទេស នៃកិក្ខុបាតិមោក្ខ ៣០ សិក្ខាបទ នៃកិក្ខុនីបាតិមោក្ខដែលជាអសាធារណ: ១២ សិក្ខាបទ ដ្បិតបាចិត្តិយាបត្តិអម្បាលនេះ កិក្ខុត្រូវព្រោះអាស្រ័យកណ្ឌ:ដែលខ្ជិចទៅដោយពុទ្ធប្បញ្ញត្តិ កិក្ខុនោះត្រូវយកកណ្ឌ:នោះមកលះក្នុងទីកណ្ដាលសង្ឆឬគណ: ឬក្នុងសំណាក់នៃកិក្ខុ ១ រូបជាវិនយកម្មសិន ទើបសម្ដែងអាបត្តិនោះធ្លាក់ ព្រោះហេតុនោះ បាចិត្តិយាបត្តិអម្បាលនេះ ទើបឈ្មោះថានិស្សគ្គិយបាចិត្តិយ ។ សុទ្ធិកបាចិត្តិយនោះ ប្រែថាបាចិត្តិយសុទ្ធ មិនមានវិនយកម្មណាមួយ ជាបុព្វកិច្ចនៃទេសនាវិធី បានដល់បាចិត្តិយា-បត្តិក្នុងបាចិត្តិយុទ្ទេស ក្នុងកិក្ខុបាតិមោក្ខ ៩២ សិក្ខាបទ ក្នុងកិក្ខុនីបាតិមោក្ខ ដែលជាអសាធារណ: ៩៦ សិក្ខាបទ សិក្ខាបទអម្បាលនេះឯង ឈ្មោះថាសុទ្ធិកបាចិត្តិយ ។ មួយទៀត សុទ្ធិកបាចិត្តិយមាន ២ គឺបកតិបាចិត្តិយ បាចិត្តិយ ដោយប្រក្រតី ១ ភេទកាទិបាចិត្តិយ បាចិត្តិយមានការទម្ងាយកណ្ឌ:ចេញមុនជាដើម ហើយទើបសម្ដែងអាបត្តិធ្លាក់ ១ ។

អាបត្តិនាមកថា ចប់

សិក្ខាបទបរិច្ឆេទកថា

នឹងសម្តែងដោយកំណត់សិក្ខាបទនៃអាបត្តិនោះៗ ។ សិក្ខាបទនៃបារាជិកាបត្តិ ចំណែកភិក្ខុ ៤ ចំណែកភិក្ខុនីដែលជាអសាធារណៈ មិនទូទៅដល់ភិក្ខុផង ៤ រួមជា ៨ ចំណែកសាធារណៈទូទៅដល់ភិក្ខុ ៤ ទៀត ផ្សំគ្នាទាំងអស់ត្រូវជា ១២ សិក្ខាបទអម្បាលនេះឡើងកាន់បាតិមោក្ខុទ្ទេស ។ សិក្ខាបទនៃសង្ឆាទិសេសាបត្តិ ចំណែកភិក្ខុ ១៣ ចំណែកភិក្ខុនី ដែលជាអសាធារណៈ ១០ រួមជា ២៣ ចំណែកដែលជាសាធារណៈ ៧ ទៀត ផ្សំគ្នាទាំងអស់ត្រូវជា ៣០ សិក្ខាបទនេះ ឡើងកាន់បាតិមោក្ខុទ្ទេស ។ ការបញ្ញត្តនៃថុល្លច្ចយាបត្តិ មានច្រើនមិនមានកំណត់មិនបានឡើងកាន់បាតិមោក្ខុទ្ទេស ហេតុដែលមិនមានកំណត់នោះ នឹងមានច្បាស់ទៅខាងមុខ ។ សិក្ខាបទនៃនិស្សគ្គិយបាចិត្តិយាបត្តិ ចំណែកភិក្ខុ ៣០ ចំណែកភិក្ខុនីដែលជាអសាធារណៈ ១២ រួមគ្នាទាំងអស់ត្រូវជា ៤២ បើផ្សំសាធារណៈ ១៨ សិក្ខាបទចូលផង ត្រូវជា ៦០ សិក្ខាបទនេះឡើងកាន់បាតិមោក្ខុទ្ទេស ។ សិក្ខាបទនៃសុទ្ធិកបាចិត្តិយាបត្តិ ចំណែកភិក្ខុ ៩២ ចំណែកភិក្ខុនី ដែលជាអសាធារណៈ ៩៦ រួមគ្នាត្រូវជា ១៨៨ បើផ្សំសាធារណៈ ៧០ សិក្ខាបទ ផង រួមគ្នាត្រូវជា ២៥៨ សិក្ខាបទទាំងនេះឡើងកាន់បាតិមោក្ខុទ្ទេស ។ សិក្ខាបទនៃបាដិទេសនីយាបត្តិ ចំណែកភិក្ខុ ៤ ចំណែកភិក្ខុនី ៨ រួមគ្នាត្រូវជា ១២ ឡើងកាន់បាតិមោក្ខុទ្ទេស ។ ការបញ្ញត្តនៃទុក្កដាបត្តិ មានច្រើន

មិនមានកំណត់ ដ្បិតថាទុក្ខដាបត្តិ ពោលដោយអាគតដ្ឋានយ៉ាងសង្ខេប មាន ២ គឺ មកក្នុងបាឬ្ចីព្រះពុទ្ធអង្គទ្រង់បញ្ញត្ត ១ យ៉ាង ឈ្មោះថាបាឬ្ចី-ទុក្ខដ មកក្នុងអដ្ឋកថា រួចចាកបាឬ្ចី ដែលព្រះសង្ខ្ចីតិកាចារ្យ លោកដឹងពុទ្ធាធិប្បាយតាំងទុក ១ យ៉ាង ឈ្មោះថាបាឬ្ចីមុត្តកទុក្ខដ សេចក្ដីពិស្តារនឹងមានច្បាស់ទៅខាងមុខ ព្រោះហេតុនោះ សិក្ខាបទនៃទុក្ខដាបត្តិឡើងកាន់បាតិមោក្ខុទ្ទេសតែសេខិយសិក្ខាបទប៉ុណ្ណោះ ក្រៅនោះមិនឡើងកាន់បាតិមោក្ខុទ្ទេសទេ ។ សិក្ខាបទនៃទុព្ភាសិតាបត្តិ ដែលមាននិទានខាងដើមនាំឲ្យព្រះអង្គទ្រង់បញ្ញត្តនោះមិនមាន ដ្បិតទុព្ភាសិតាបត្តិនេះ មានមកក្នុងវិភង្គនៃឱ្ចិមសវាទសិក្ខាបទ១យ៉ាង ព្រោះហេតុនោះ ដល់ទៅខាងមុខកាលវិនិច្ឆ័យឱ្ចិមសវាទសិក្ខាបទហើយ ទុព្ភាសិតាបត្តិ ក៏នឹងវិនិច្ឆ័យឲ្យបានដឹងផង ។ មួយទៀត ឧទ្ទេសសម្រាប់លើកសិក្ខាបទឡើងសូត្ររាល់ៗថ្ងៃឧបោសថក្នុងកន្ទុះខែម្ដង ដែលឈ្មោះថាបាតិមោក្ខុទ្ទេសនោះ ដោយឈ្មោះដែលមាននៅក្នុងបាតិមោក្ខមាន ៩ គឺ និទានុទ្ទេស ១ បារាជិ-កុទ្ទេស ១ សង្ឆាទិសេសុទ្ទេស ១ អនិយតុទ្ទេស ១ និស្សគ្គិយុទ្ទេស ១ បាចិត្តិយុទ្ទេស ១ បាដិទេសនីយុទ្ទេស ១ សេខិយុទ្ទេស ១ សមថុទ្ទេស ១ ។

និទានុទ្ទេស

ក្នុងនិទានុទ្ទេសខាងដើមនេះមិនជាឧទ្ទេសសម្រាប់ចង្អុលឈ្មោះសិក្ខា-បទទេ គ្រាន់តែជាពាក្យប្រកាសញ្ញត្តិនៃឧបោសថកម្មនិងប្រកាសពាក្យ

ដែលជានិទានខាងដើមនៃឧទ្ទេសដទៃប៉ុណ្ណោះ ។ ពាក្យថា "**សុណាតុ មេ ។ ល ។ ចាតិមោក្ខំ ឧទ្ទិសេយ្យ**" នេះឈ្មោះថាញត្តិ ប្រៃថាបពិត្រព្រះសង្ឆដ៏ចម្រើន ព្រះសង្ឆចូរស្តាប់ខ្ញុំ ថ្ងៃនេះជាថ្ងៃឧបោសថ ទី១៤-១៥ ថាបើឧបោសថកម្ម មានកាលដ៏សមគួរ គឺប្រកបដោយ អង្គ ៤ ហើយ ព្រះសង្ឆគប្បីធ្វើឧបោសថ គប្បីសម្តែងព្រះបាតិមោក្ខ ។ អង្គ ៤ នោះគឺថ្ងៃទី១៤-១៥ ថ្ងៃសាមគ្គី ថ្ងៃទាំង ៣ នេះ ថ្ងៃណាមួយ ចាត់ជាអង្គ ១ ភិក្ខុតាំងអំពី ៤ រូបឡើងទៅ មិនត្រូវឧក្ខេបនីយកម្ម ជាបកតត្ត ឋិតនៅក្នុងសីមាជាមួយគ្នា មិនលះហត្ថបាសគ្នាជាអង្គ ១ ភិក្ខុទាំងនោះ មិនត្រូវសកាគាបត្តិ មានវត្ថុស្មើគ្នា មានធាន់ភោជនក្នុងវេលារសៀលដូចគ្នាជាដើមជាអង្គ ១ វជ្ជនីយបុគ្គល ២១ មានគ្រហស្ថនិងបណ្ណកជាដើម មិនមានខាងក្នុងហត្ថបាសសង្ឆជាអង្គ ១ ឧបោសថប្រកបដោយអង្គ ៤ នេះ ទើបគួរពោលថា **បត្តកល្ល** ថាមានកាលដ៏សមគួរ បាន បើមិនប្រកបដោយអង្គ ៤ បានតែអង្គ ២ ឬអង្គ ៣ មិនគួរពោលថា **បត្តកល្ល** ។ មួយទៀត បើភិក្ខុអ្នកសម្តែងនោះខ្ជីជាងព្រះសង្ឆមួយ រូបក្តី ឲ្យសូត្រថា **ភន្តេ** បើចាស់ជាងព្រះសង្ឆទាំងអស់ ឲ្យសូត្រថា **អាវុសោ** បើថ្ងៃទី ១៥ ឲ្យសូត្រថា **បណ្ណារសោ** បើថ្ងៃទី ១៤ ឲ្យសូត្រថា **ចាតុទ្ទសោ...ឆ្លឹ សំឃស្ស ។ ល ។ ជាសុ ហោតិ** ពាក្យទាំងនេះ ឈ្មោះថានិទាន ជាពាក្យសួរពាក្យប្រដៅអ្នកស្តាប់បាតិ-

មោក្ខ សេចក្ដីនេះដូចម្ដេច បុព្វករណៈ បុព្វកិច្ច កម្មដែលត្រូវធ្វើមុន សង្ឆធ្វើហើយឬ គឺបោសពោធ១ឧបោសថ ១ បើវេលាយប់អុជប្រទីប ១ ក្រាលអាសនៈ ១ តម្កល់ទឹកប្រើ ទឹកធាន់ ១ បួននេះឈ្មោះថាបុព្វករណៈ ព្រោះគួរធ្វើមុនប្រជុំសង្ឆ ការនាំធនៈនៃភិក្ខុដែលគួរនាំធនៈមក ១ នាំបរិសុទ្ធិនៃភិក្ខុដែលគួរនាំបរិសុទ្ធិ ១ ប្រាប់រដូវ ១ រាប់ភិក្ខុ ១ ឲ្យឱវាទដល់ភិក្ខុនី ១ ប្រាំនេះឈ្មោះថាបុព្វកិច្ច ព្រោះត្រូវធ្វើមុនសម្ដែងបាតិមោក្ខ បុព្វករណៈ បុព្វកិច្ចទាំង ៩ នេះ សង្ឆធ្វើហើយ ឬ តាំងអំពីបាឡីថា **ចារិសុទ្ធី** *ទៅ ជាពាក្យប្រដៅ សេចក្ដីថា បពិត្រលោកដ៏មានអាយុ លោកទាំងឡាយ ចូរប្រាប់នូវសេចក្ដីបរិសុទ្ធរបស់ខ្លួនចុះ ខ្ញុំព្រះករុណា នឹងសម្ដែងនូវបាតិមោក្ខ យើងគ្រប់គ្នាចូរស្ដាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃ នូវបាតិមោក្ខនេះចុះ ។ តពីនេះទៅ ជាដំណើរដែលត្រូវប្រកាសសេចក្ដីបរិសុទ្ធ និងមិនបរិសុទ្ធរបស់ខ្លួន* **យស្ស សិយា ។ ល ។ ឧ្ចិ ស្ឆាមិ** *សេចក្ដីថាបើអាបត្តិនៃភិក្ខុណានៅមាន ភិក្ខុនោះគប្បីធ្វើឲ្យច្បាស់ ប្រាប់កណ្ដាលជំនុំសង្ឆឬភិក្ខុ ១ រូបដែលអង្គុយនៅជិត ថាខ្ញុំត្រូវអាបត្តិឈ្មោះនោះ។ ខ្ញុំក្រោកអំពីទីនេះហើយ នឹងសម្ដែងនូវអាបត្តិនោះ។ ថាបើសង្ឆរ័យឲ្យប្រាប់ដូច្នេះថា ខ្ញុំសង្ឆរ័យក្នុងអាបត្តិឈ្មោះនេះ។ កាលណាខ្ញុំមិនសង្ឆរ័យខ្ញុំនឹងសម្ដែងនូវអាបត្តិក្នុងកាលនោះ កាលបើអាបត្តិមិនមានគប្បីស្ងៀម អាការដែលប្រាប់អាបត្តិដោយស្ងៀមយ៉ាងដូច្នេះ ឈ្មោះ*

ថាប្រាប់នូវសភាពនៃខ្លួនបរិសុទ្ធ ខ្ញុំនឹងដឹងច្បាស់នូវលោកទាំងឡាយ ថាជាអ្នកបរិសុទ្ធដោយការស្ងៀមយ៉ាងនេះ ឯពាក្យថា **យថា ខោ ។ ល ។ ហោតិ** នេះ ជាពាក្យប្រាប់ឲ្យដឹងច្បាស់ នូវអនុសាវនៈនិងខ្ទង់ត្រនៃអាបត្តិ សេចក្ដីថា ដូចភិក្ខុ ១ រូប គឺភិក្ខុ ១ រូបសួរចំពោះខ្លួន និងពោលដោះសារដូចម្ដេច ពាក្យដែលយើងឲ្យឮហើយរឿយៗ ក្នុងភិក្ខុបរិស័ទមានសភាពដូច្នេះ លុះដល់ ៣ ដងថា **ततियम्पि पुच्छामि कच्चित्थ परिसुद्धा** ដូច្នេះគ្រប់ៗ ឧទ្ទេសទៅ ដូច្នោះ បើភិក្ខុរូបណាកាលខ្ញុំសួត្រ ឲ្យបានឮអស់វារៈ ៣ ដងថា **ततियम्पि पुच्छामि कच्चित्थ परिसुद्धा** ដូច្នេះ បើរឭកឃើញហើយ មិនបានធ្វើឲ្យច្បាស់ មិនប្រាប់នូវអាបត្តិដែលខ្លួនមាននោះ សម្ប្ជានមុសាវាទ ការពោលមិនពិតនៃអ្នកដឹង រមែងមានដល់ភិក្ខុនោះ គឺភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ព្រោះខ្លួនបិទអាបត្តិទុក ទើបកាត់ជាសម្ប្ជានមុសាវាទ បពិត្រលោកដ៏មានអាយុទាំងឡាយ ឯសម្ប្ជានមុសាវាទទុក្កដនេះ ព្រះដ៏មានបុណ្យ ព្រះអង្គទ្រង់បានសម្ដែងហើយ ថាជាធម៌ធ្វើឲ្យអន្ដរាយដល់ឈាននិងមគ្គ ផល ព្រោះហេតុនោះ ភិក្ខុកាលរឭកឃើញនូវអាបត្តិដែលមាន គប្ប្ធើធ្វើឲ្យច្បាស់ ដ្ឋិតថាការធ្វើឲ្យច្បាស់នេះ រមែងនាំមកនូវសេចក្ដីសុខ ដល់ភិក្ខុនោះ ។

និទានុទ្ទេស ចប់

ក្នុងបារាជិកុទ្ទេស ចំណែកភិក្ខុមានសិក្ខាបទ ៤ ចំណែកភិក្ខុនី មានសិក្ខាបទ ៨ ក្នុងសង្ឆាទិសេសុទ្ទេស ចំណែកភិក្ខុមានសិក្ខាបទ ១៣ ចំណែកភិក្ខុនីមានសិក្ខាបទ ១៧ ក្នុងអនិយតុទ្ទេស មានសិក្ខាបទ ២ អនិយតុទ្ទេសនេះ ក្នុងភិក្ខុនីបាតិមោក្ខមិនមាន ក្នុងនិស្សគ្គិយុទ្ទេស ចំណែកភិក្ខុមានសិក្ខាបទ ៣០ ចំណែកភិក្ខុនីក៏មាន ៣០ ដែរ ក្នុងបាចិត្តិយុទ្ទេស ចំណែកភិក្ខុមានសិក្ខាបទ ៩២ ចំណែកភិក្ខុនីមាន ១៦៦ ក្នុងបាដិទេសនីយុទ្ទេស ចំណែកភិក្ខុមានសិក្ខាបទ ៤ ចំណែកភិក្ខុនីមាន ៨ ក្នុងសេខិយុទ្ទេស ភិក្ខុនិងភិក្ខុនីមានសិក្ខាបទ ៧៥ ដូចគ្នា ក្នុងសមថុទ្ទេស មិនមានសិក្ខាបទ មានតែធម៌ ៧ ប្រការ មានសម្មុខាវិន័យជាដើម ឈ្មោះ ឋាសមថ: ព្រោះជារបស់សម្រាប់រម្ងាប់អធិករណ: ៤ មានវិវាទាធិករណ: ជាដើមប៉ុណ្ណោះ សម្តែងមកក្នុងបាតិមោក្ខុទ្ទេស ចំណែកភិក្ខុមាន ៩ ឧទ្ទេស ចំណែកភិក្ខុនីមាន ៨ ឧទ្ទេស សម្តែងតាមឈ្មោះដែលមាននៅ ក្នុងបាលីបាតិមោក្ខ បើសម្តែងតាមពុទ្ធប្បញ្ញត្តិមាន ៥ គឺនិទានុទ្ទេសទី ១ បារាជិកុទ្ទេស ទី ២ សង្ឆាទិសេសុទ្ទេសទី ៣ អនិយតុទ្ទេសទី ៤ តាំងអំពីនិស្សគ្គិយុទ្ទេស ដរាបដល់សមថុទ្ទេសជាទី ៥ ឈ្មោះវិត្ថារុទ្ទេស ជា ៥ ឧទ្ទេសដូច្នេះ ទ្រង់បញ្ញត្តទាំង ៥ ឧទ្ទេសនេះ ដើម្បីនឹងឲ្យដឹងច្បាស់ នូវបាតិមោក្ខ ដោយសង្ខេបនិងពិស្តារ ក្នុងវេលាដែលមានអន្តរាយ សេចក្តីនេះនឹងដឹងច្បាស់ក្នុងឧបោសថកថាខាងមុខ ។

ឧទ្ទេស ចប់

មួយទៀត ក្នុងបុព្វសិក្ខាសម្តែងសចិត្តក: និងវជ្ជ:ទុក ក្នុងកថានេះ នោះនឹងលើកទុកសិន នឹងសម្តែងក្នុងសមុដ្ឋានកថាខាងមុខ ។

សិក្ខាបទបរិច្ឆេទកថា ចប់

សមុដ្ឋានាទិកថា

នឹងសម្តែងក្នុងវិធីមានសមុដ្ឋានជាដើម សមុដ្ឋាន នោះ ប្រែថា ទីកើតនៃអាបត្តិ ក្នុងសិក្ខាបទនោះៗ ក៏ឯសមុដ្ឋានទីកើតនៃអាបត្តិ ក្នុងសិក្ខាបទទាំងពួងនោះមាន ៦ គឺកាយជាទី ១ វាចាជាទី ២ កាយវាចាជាទី ៣ កាយចិត្តជាទី ៤ វាចាចិត្តជាទី ៥ កាយវាចាចិត្តជាទី ៦ រួមគ្នាត្រូវជា ៦ ។ កាយ ១ យ៉ាង ឬ វាចា ១ យ៉ាង ជាសមុដ្ឋានទីកើត ១ ដូច្នេះឈ្មោះថាមានអង្គ ១ កាយនិងវាចា កាយនិងចិត្ត ឬ វាចានិងចិត្ត ជាសមុដ្ឋានទីកើត ១ ដូច្នេះឈ្មោះថាមានអង្គ ២ ។ ទាំងកាយទាំងវាចាទាំងចិត្ត ជាសមុដ្ឋានទីកើត ១ ដូច្នេះឈ្មោះថាមានអង្គ ៣ បីខាងដើមគឺ កាយ ១ វាចា ១ កាយវាចា ១ នេះឈ្មោះថា អចិត្តក-សមុដ្ឋាន ព្រោះមិនមានចិត្ត អាបត្តិក្នុងសិក្ខាបទណា ត្រូវដោយសមុដ្ឋានទាំង៣ នេះណាមួយ សិក្ខាបទនោះជាអចិត្តក: ។ បីខាងចុង គឺកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ នេះឈ្មោះថាសចិត្តកសមុដ្ឋាន ប្រកបដោយចិត្ត អាបត្តិក្នុងសិក្ខាបទណាត្រូវដោយសមុដ្ឋានទាំង ៣ នេះណាមួយ មិនមានសមុដ្ឋានខាងដើមលាយផងទេ សិក្ខាបទនោះ ជាសចិត្តក: ។

អាបត្តិទាំងពួង ភិក្ខុត្រូវដោយសមុដ្ឋានទីកើត ១ ខ្ទះ ២ ខ្ទះ ៣ ខ្ទះ ៤ ខ្ទះ ៦ ខ្ទះ ។ អាបត្តិក្នុងសិក្ខាបទណា ត្រូវដោយសមុដ្ឋានទី ៤ តែម្យ៉ាង ដូចក្នុងបឋមបារាជិក ត្រូវដោយសមុដ្ឋានទី ៥ តែម្យ៉ាង ដូចក្នុងធម្មទេសនាសិក្ខាបទ ត្រូវដោយសមុដ្ឋានទី ៦ តែម្យ៉ាង ដូចក្នុងសង្ឃភេទសិក្ខាបទ សិក្ខាបទទាំង ៣ នេះ ឈ្មោះថាមានសមុដ្ឋានទីកើត ១ ។ អាបត្តិក្នុងសិក្ខាបទណា ភិក្ខុត្រូវដោយសមុដ្ឋានទី ១ ឬ ទី ៤ ដូចក្នុងឯឡកលោមសិក្ខាបទក្តី ត្រូវដោយសមុដ្ឋានទី ២ ឬទី ៥ ដូចក្នុងបទសោធម្មសិក្ខាបទក្តី ត្រូវដោយសមុដ្ឋានទី ៣ ឬទី ៦ ដូចក្នុងបឋមកឋិនសិក្ខាបទក្តី ត្រូវដោយសមុដ្ឋានទី ៤ ឬទី ៦ ដូចក្នុងវេយ្យាវច្ចសិក្ខាបទក្តី ត្រូវដោយសមុដ្ឋានទី ៥ ឬទី ៦ ដូចក្នុងចោរីវុដ្ឋាបនសិក្ខាបទក្តី សិក្ខាបទទាំង ៥ នេះ ឈ្មោះថាមានសមុដ្ឋានទីកើត ២ ។ អាបត្តិក្នុងសិក្ខាបទណា ត្រូវដោយសមុដ្ឋានខាងដើមគឺទី ១ ទី ២ ឬទី ៣ ដូចភូតារោចនសិក្ខាបទក្តី ត្រូវដោយសមុដ្ឋានខាងចុងគឺទី ៤ ទី ៥ ទី ៦ ដូចក្នុងអទិន្នាទានសិក្ខាបទក្តី សិក្ខាបទទាំង ២ នេះ ឈ្មោះថាមានសមុដ្ឋានទីកើត ៣ ។ អាបត្តិក្នុងសិក្ខាបទណា ត្រូវដោយសមុដ្ឋានទី ១ ទី ៣ ទី ៤ ឬទី ៦ ដូចក្នុងអទ្ធានសិក្ខាបទក្តី ត្រូវដោយសមុដ្ឋានទី ២ ទី ៣ ទី ៥ ឬ ទី ៦ ដូចក្នុងអននុញ្ញាតសិក្ខាបទក្តី សិក្ខាបទទាំង ២ នេះ ឈ្មោះថាមានសមុដ្ឋានទីកើត ៤ ។ អាបត្តិក្នុងសិក្ខាបទណា ត្រូវដោយសមុដ្ឋាន ៦ គឺទី ១ ទី ២

ទី ៣ ទី ៤ ទី ៥ ឬ ទី ៦ ដូចក្នុងសញ្ចរិត្តសិក្ខាបទ សិក្ខាបទនេះ ឈ្មោះថាមានសមុដ្ឋានទីកើត ៦ ។

អាបត្តិទាំងពួង ពោលដោយសមុដ្ឋានមាន ១៣ អាបត្តិទាំង ១៣ នោះ មានឈ្មោះទាំង ១៣ ដោយសមុដ្ឋាន តាមសិក្ខាបទដែលជាបឋម-បញ្ញត្តិដូច្នេះថា បឋមបារាជិកសមុដ្ឋាន អទិន្នាទានសមុដ្ឋាន សញ្ចរិត្ត-សមុដ្ឋាន សមនុភាសនសមុដ្ឋាន បឋមកឋិនសមុដ្ឋាន ឯឡកលោម-សមុដ្ឋាន បទសោធម្មសមុដ្ឋាន អទ្ធានសមុដ្ឋាន ថេយ្យសត្ថសមុដ្ឋាន ធម្មទេសនាសមុដ្ឋាន ភូតារោចនសមុដ្ឋាន ចោរីវុដ្ឋាបនសមុដ្ឋាន អននុញ្ញាតសមុដ្ឋាន ជា ១៣ ដូច្នេះ ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពី កាយនិងចិត្ត សិក្ខាបទនោះ ឈ្មោះថា បឋមបារាជិកសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសចិត្តកសមុដ្ឋាន ៣ ខាងចុង សិក្ខាបទនោះឈ្មោះថា អទិន្នាទានសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពី សមុដ្ឋានទាំង ៦ សិក្ខាបទនោះ ឈ្មោះថា សញ្ចរិត្តសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ៦ តែ ១ សិក្ខាបទ នោះ ឈ្មោះថា សមនុភាសនសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ៣ និងទី ៦ សិក្ខាបទនោះ ឈ្មោះថា បឋមកឋិនសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ១ និងទី ៤ សិក្ខាបទនោះឈ្មោះថា ឯឡកលោមសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ២ និងទី ៥ សិក្ខាបទនោះ ឈ្មោះថា បទសោធម្មសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ១ ទី ៣ ទី ៤ និងទី ៦ សិក្ខាបទនោះ ឈ្មោះថា អទ្ធានសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ៤ និងទី ៦ សិក្ខាបទនោះ ឈ្មោះថា ថេយ្យសត្ថសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ៥ តែ ១ សិក្ខាបទនោះ ឈ្មោះថា ធម្មទេសនាសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីអចិត្តកសមុដ្ឋាន ៣ ខាងដើមសិក្ខាបទនោះឈ្មោះថា ភូតារោចនសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ៥ និងទី ៦ សិក្ខាបទនោះ ឈ្មោះថា ចោរីវុដ្ឋាបនសមុដ្ឋាន ជាមានសមុដ្ឋានចោរីវុដ្ឋាបន-សិក្ខាបទនៃនាងភិក្ខុនី ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋាន ទី ២ ទី ៣ ទី ៥ និង

ទី ៦ សិក្ខាបទនោះ ឈ្មោះថា អនុញ្ញាតសមុដ្ឋាន ថាមានសមុដ្ឋានដូចអនុញ្ញាតសិក្ខាបទនៃនាងកិក្ខុនី គ្រប់ជា ១៣ សិក្ខាបទដូច្នេះ ។

ឯពាក្យថា វិធីមានសមុដ្ឋានជាដើមនោះ សង្គ្រោះយក កិរិយា សញ្ញា ចិត្ត វជ្ជ: កម្ម តិក្ក: អាណត្តិ ផង ។

ក៏ឯអាបត្តិក្នុងសិក្ខាបទទាំងពួង ពោលដោយកិរិយាមាន ៥ គឺ កិរិយា ១ អកិរិយា ១ កិរិយាកិរិយា ១ សិយា កិរិយា សិយា អកិរិយា ១ សិយា កិរិយា សិយា កិរិយាកិរិយា ១ ជា ៥ ដូច្នេះ ។

អាបត្តិក្នុងសិក្ខាបទណា កើតដល់ភិក្ខុដែលធ្វើ នូវសេចក្តីប្រព្រឹត្ត កន្ទងដោយកាយ ឬ វាចា ដូចក្នុងបឋវីខណនសិក្ខាបទជាដើម សិក្ខាបទនោះ ឈ្មោះថាកិរិយា គឺកើតព្រោះធ្វើ ។

អាបត្តិក្នុងសិក្ខាបទណា កើតដល់ភិក្ខុដែលមិនធ្វើ នូវកម្មជាដើមដែលខ្លួនគប្បីធ្វើដោយកាយនិងវាចា ដូចក្នុងបឋមកឋិនសិក្ខាបទ មិនធ្វើ រិកប្បនិងអធិដ្ឋាន ទុកអតិរេកចីវរឲ្យកន្ទង ១០ ថ្ងៃទៅដូច្នេះ សិក្ខាបទនោះ ឈ្មោះថា អកិរិយា គឺកើតព្រោះមិនធ្វើ ។

អាបត្តិក្នុងសិក្ខាបទណា ត្រូវដល់ភិក្ខុដែលធ្វើផង និងមិនធ្វើផង ដូចក្នុងចីវរបដិគ្គហណសិក្ខាបទ ធ្វើនូវការទទួលចីវរអំពីដៃនាងកិក្ខុនីមិនមែនញាតិ មិនធ្វើនូវការផ្ទាស់ប្តូរជាមុនទើបត្រូវអាបត្តិ សិក្ខាបទនេះ ឈ្មោះថា កិរិយាកិរិយា កើតព្រោះធ្វើនិងមិនធ្វើ ។

អាបត្តិក្នុងសិក្ខាបទណា កើតដល់ភិក្ខុដែលធ្វើក៏មាន ដែលមិនធ្វើក៏មាន ដូចក្នុងរូបិយបដិគ្គហណសិក្ខាបទ ត្រូវដោយធ្វើនូវការទទួលរូបិយ: ក៏មាន ត្រូវដោយមិនធ្វើនូវការហាមឃាត់រូបិយ:ដែលគេឲ្យដល់ខ្លួនក៏មាន សិក្ខាបទនេះ ឈ្មោះថា សិយា កិរិយា សិយា អកិរិយា កើតព្រោះធ្វើក៏មាន ព្រោះមិនធ្វើក៏មាន ។

អាបត្តិក្នុងសិក្ខាបទណា កើតដល់ភិក្ខុដែលធ្វើខ្ទះក៏មាន ធ្វើនិងមិនធ្វើក៏មាន ដូចក្នុងកុដិការសិក្ខាបទ មានកាលត្រូវអាបត្តិដោយឲ្យសង្ឆសម្ដែងទីហើយ ធ្វើកុដិឲ្យលើសប្រមាណ មានកាលត្រូវអាបត្តិដោយមិនឲ្យសង្ឆសម្ដែងទីមុន នឹងធ្វើឲ្យលើសប្រមាណ សិក្ខាបទនេះ ឈ្មោះថា សិយា កិរិយា សិយា កិរិយាកិរិយា មានកាលកើតព្រោះធ្វើខ្ទះក៏មាន ព្រោះធ្វើនិងមិនធ្វើខ្ទះក៏មាន ។

មួយទៀត សិក្ខាបទទាំងពួង ពោលដោយសញ្ញាមាន ២ គឺសញ្ញាវិមោក្ខ ១ នោសញ្ញាវិមោក្ខ ១ ។ ក្នុងសិក្ខាបទណារួចចាកអាបត្តិបានដោយសម្គាល់និងមិនកន្ទងបញ្ញត្តិ ដូចទឹកមានតួសត្វសម្គាល់ថា មិនមានហើយបរិភោគ មិនត្រូវអាបត្តិ សិក្ខាបទនេះឈ្មោះថា សញ្ញាវិមោក្ខ ។ ក្នុងសិក្ខាបទណាមិនរួចចាកអាបត្តិបានដោយសម្គាល់ ដូចថ្ងៃរសៀលហើយសម្គាល់ថានៅមិនទាន់រសៀល ហើយធាន់របស់ដែលជា យាវកាលិកក៏ត្រូវអាបត្តិ សិក្ខាបទនោះឈ្មោះថា នោសញ្ញាវិមោក្ខ ។

មួយទៀត សិក្ខាបទទាំងពួង ពោលដោយចិត្តមាន ២ គឺសចិត្តក: ១ អចិត្តក: ១ ។ អាបត្តិក្នុងសិក្ខាបទណា កើតដោយសចិត្តកសមុដ្ឋាន ៣ ខាងចុង គឺកាយចិត្ត វាចាចិត្ត និងកាយវាចាចិត្តតែមួយ មិនលាយដោយ អចិត្តកសមុដ្ឋានណាមួយ សិក្ខាបទនេះឈ្មោះថា សចិត្តក: ។ អាបត្តិក្នុង សិក្ខាបទណា កើតដោយអចិត្តកសមុដ្ឋាន ៣ ខាងដើម គឺកាយ និងវាចា និងកាយវាចាតែ ១ យ៉ាងក្តី ឬឯណានីមួយ ជាសមុដ្ឋាន ១ និងមានសចិត្ត-កសមុដ្ឋានណាមួយមកលាយផងក្តី សិក្ខាបទដូច្នេះឈ្មោះថា អចិត្តក: ។ សិក្ខាបទណាជាសញ្ញាវិមោក្ខ សិក្ខាបទនោះជា សចិត្តក: ។ សិក្ខាបទ ណាជានោសញ្ញាវិមោក្ខ សិក្ខាបទនោះជា អចិត្តក: ។

មួយទៀត សិក្ខាបទទាំងពួង ពោលដោយវជ្ជ: គឺ ទោសមាន ២ គឺ លោកវជ្ជ: ១ បណ្ណត្តិវជ្ជ: ១ ។ អាបត្តិក្នុងសិក្ខាបទណា សូម្បីជា អចិត្តក: ដូចសុរាបានសិក្ខាបទជាដើម ចិត្តក្នុងខណ:ដែលត្រូវ ក្នុងចំណែក ខាងសចិត្តក: គឺមានចិត្តដឹងនោះ ជាអកុសលចិត្ត ដូចសុរាបានសិក្ខាបទ ជាអចិត្តក: សូម្បីកិក្ខុមិនដឹងថាសុរា ឲ្យកន្ទងបំពង់កចូលទៅក៏ត្រូវអាបត្តិ តែក្នុងចំណែកចិត្តដែលដឹងថាជាសុរាហើយឲ្យកន្ទងបំពង់កចូលទៅ ក៏ត្រូវ អាបត្តិនោះជាអកុសលចិត្ត ចំណែកលោកមូល សិក្ខាបទនេះឈ្មោះថា លោកវជ្ជ: ថាមានទោស គឺអ្នកប្រាជ្ញគប្បីវៀរ គប្បីតិះដៀលក្នុងលោក ដែលថាមានចិត្តដឹងនោះប្រាថ្នាយកដឹងវត្ថុដែលនឹងគប្បីសេព ដូចដឹងថា

សុរាជាដើម ហើយក្រេបផឹកដោយលោភចិត្ត មិនប្រាថ្នាយកចិត្តដឹងបញ្ញត្តិ គឺដឹងថាមិនគួរ បើដឹងថាមិនគួរហើយពុះពារអាជ្ញាព្រះពុទ្ធអង្គ ប្រព្រឹត្តកន្ទ្ធ៍សិក្ខាបទដោយចិត្តណា ចិត្តនោះជាបដិឃចិត្ត ចំណែកទោសមូល ព្រោះហេតុនោះសុរាបានសិក្ខាបទ និងឧយ្យុត្តសិក្ខាបទ និងឧយ្យោធិកសិក្ខាបទ ទាំងនេះទើបជាអចិត្តកលោកវជ្ជ: ។ ក៏ឯចិត្តដែលដឹងវត្ថុនៃអាបត្តិ ក្នុងសិក្ខាបទណា សូម្បីជាកុសលក៏មាន សិក្ខាបទនោះ ឈ្មោះថាបណ្ណត្តិវជ្ជ: ថាមានទោសគឺអ្នកប្រាជ្ញគប្បីវៀរដោយពុទ្ធប្បញ្ញត្តិ ។

មួយទៀត សិក្ខាបទទាំងពួង ពោលដោយកម្មមាន ៣ គឺ កាយកម្ម ក៏មាន វចីកម្មក៏មាន ទាំងកាយកម្មវចីកម្មក៏មាន ។

អាបត្តិក្នុងសិក្ខាបទណា ភិក្ខុត្រូវដោយកាយទ្វារ ១ ជំពូក ដូចអាបត្តិកើតអំពីសមុដ្ឋានទី ១ ឬ ទី ៤ សិក្ខាបទនោះឈ្មោះថា កាយកម្ម ។ អាបត្តិក្នុងសិក្ខាបទណាភិក្ខុត្រូវដោយវចីទ្វារ ១ ជំពូក ដូចអាបត្តិកើតអំពីសមុដ្ឋានទី ២ និងទី ៥ សិក្ខាបទនោះ ឈ្មោះថា វចីកម្ម ។ អាបត្តិក្នុងសិក្ខាបទណាភិក្ខុត្រូវដោយទ្វារទាំង ២ គឺកាយនិងវាចា សិក្ខាបទនោះ ឈ្មោះថា កាយកម្ម វចីកម្ម ថាជាកាយកម្មផង ថាជាវចីកម្មផង ។

មួយទៀត តិក្ក:មាន ២ គឺកុសលតិក្ក: ៣ ពួក កំណត់ដោយកុសលចិត្ត ១ យ៉ាង វេទនាតិក្ក: ៣ ពួក កំណត់ដោយវេទនា ១ យ៉ាង ។

ភិក្ខុកាលនឹងត្រូវអាបត្តិមានចិត្តជាកុសលក៏មាន មានចិត្តជា

អកុសលត្រូវក៏មាន មានចិត្តជាអព្យាក្រឹត ក៏មិនជាកុសល និងអកុសល ដូចជាដេកលក់ត្រូវក៏មាន ។ មួយទៀត សោយទុក្ខវេទនាត្រូវអាបត្តិ ក៏មាន សោយសុខវេទនាត្រូវអាបត្តិក៏មាន សោយឧបេក្ខាវេទនាត្រូវ អាបត្តិក៏មានដូច្នេះ ។ សិក្ខាបទណាបើពោលថា **ឯកចិត្តំ** *ថាមាន ចិត្តតែ ១ ឲ្យគប្បីដឹងថាបាននឹងអកុសលចិត្ត ក្នុងសិក្ខាបទណាបើ ពោលថា* **ទ្វិចិត្តំ** *ថាមានចិត្ត ២ ឲ្យគប្បីដឹងថាបាននឹងចិត្តដែលជា កុសលនិងអព្យាក្រឹត ក្នុងសិក្ខាបទណាដែលពោលថា* **តិចិត្តំ** *ថាមាន ចិត្ត ៣ ឲ្យគប្បីដឹងថាបានដល់ចិត្តជាកុសលអកុសលនិងអព្យាក្រឹត ។*

ក្នុងសិក្ខាបទណាដែលពោលថា **ឯកា វេទនា** *ថាមានវេទនា ១ ឲ្យគប្បីដឹងថាបានដល់ទុក្ខវេទនា បើពោលថា* **ទ្វេ វេទនា** *ថាមាន វេទនា ២ ឲ្យគប្បីដឹងថាបានដល់សុខវេទនានិងឧបេក្ខាវេទនា បើពោល ថា* **តិស្សោ វេទនា** *ថាមានវេទនា ៣ ឲ្យគប្បីដឹងថាបាននឹងសុខ ទុក្ខ ឧបេក្ខា ។*

មួយទៀត សិក្ខាបទទាំងពួង ជាសាណត្តិក:ក៏មាន ជាអនាណត្តិក: ក៏មាន ។ អាបត្តិក្នុងសិក្ខាបទណា ភិក្ខុធ្វើឯងក៏ត្រូវ ប្រើអ្នកដទៃឲ្យធ្វើក៏ត្រូវ សិក្ខាបទនោះឈ្មោះថាសាណត្តិក: ថាប្រកបដោយបង្គាប់ ។ អាបត្តិក្នុង សិក្ខាបទណា ភិក្ខុធ្វើឯងទើបត្រូវ ប្រើអ្នកដទៃឲ្យធ្វើមិនត្រូវ សិក្ខាបទនោះ ឈ្មោះថាអនាណត្តិក: ថាមិនប្រកបដោយបង្គាប់ ។ ឯសមុដ្ឋានវិធីជា

ដើមដូចពោលមកនេះ នឹងប្រកបក្នុងសិក្ខាបទដែលនឹងពោលទៅខាងមុខ នោះ ទុកជារបស់សម្រាប់កាត់អាបត្តិក្នុងសិក្ខាបទនោះៗ នឹងឲ្យកើតសេចក្តីឈ្វាសវាងវៃសង្កេតកំណត់អាបត្តិក្នុងសិក្ខាបទនោះៗ ។

សមុដ្ឋានាទិកថា ចប់

អាការៈដែលភិក្ខុនឹងត្រូវអាបត្តិ

អាការៈដែលភិក្ខុនឹងត្រូវអាបត្តិមាន ៦ យ៉ាងគឺ **អលជ្ជិតា** ត្រូវដោយសេចក្តីមិនអៀនអន់នឹងបាប ១ **អញ្ញាណតា** ត្រូវដោយមិនដឹងបញ្ញត្តិ ១ **កុក្កុច្ចបកតតា** ត្រូវដោយសេចក្តីរង្គៀសសង្ស័យហើយធ្វើ ១ **អកប្ប្យេ កប្ប្យសញ្ញិតា** ត្រូវដោយសេចក្តីសម្គាល់ថាគួរក្នុងវត្ថុដែលមិនគួរ ១ **កប្ប្យេ អកប្ប្យសញ្ញិតា** ត្រូវដោយសេចក្តីសម្គាល់ថាមិនគួរក្នុងវត្ថុដែលគួរ ១ **សតិសម្ម្ភោសា** ត្រូវដោយវង្វេងស្មារតី ១ ត្រូវជា ៦ ប្រការដូច្នេះ ។

ត្រូវដោយសេចក្តីមិនអៀនអន់នឹងបាបនោះដូចម្តេច? ភិក្ខុដែលជាអលជ្ជីមិនអៀនអន់នឹងបាប លុះដោយអគតិទាំង ៤ គឺឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិ ញ៉ាំញ៉ីកន្ធ៍សិក្ខាបទតូចធំ មិនខ្មាសបាបដូច្នេះ ឈ្មោះថាត្រូវអាបត្តិដោយមិនខ្មាសបាប ។

ត្រូវដោយមិនដឹងបញ្ញត្តិនោះដូចម្តេច? ភិក្ខុជាមនុស្សខ្ចៅមិនដឹងថា

វត្ថុនេះគួរធ្វើ វត្ថុនេះមិនគួរធ្វើ វត្ថុណាមិនគួរធ្វើក៏ធ្វើវត្ថុនោះ វត្ថុអ្វីគួរធ្វើ ក៏ធ្វើឲ្យខុសៗទៅ ខុសចាកធម៌វិន័យឲ្យកើតអាបត្តិ ឬមិនដឹងសិក្ខាបទ បញ្ញត្តិនៃព្រះដ៏មានបុណ្យ ក៏ធ្វើកន្ទ្ធងពុទ្ធប្បញ្ញត្តិ ដូច្នេះឈ្មោះថាត្រូវដោយ សេចក្ដីមិនដឹងបញ្ញត្តិ ។

ត្រូវដោយសេចក្ដីសង្ស័យដូចម្ដេច? ភិក្ខុមានសេចក្ដីសង្ស័យគួរសួរ វិន័យធរឲ្យកាត់សេចក្ដីជាមុន សឹមធ្វើ មិនដូច្នោះក៏ធ្វើដោយអំពើចិត្តខ្ជួន ដោយសេចក្ដីសង្ស័យក៏ត្រូវអាបត្តិ ។ ការសង្ស័យហើយធ្វើនោះ បើវត្ថុ ដែលមិនគួរ ក៏ត្រូវអាបត្តិគ្រប់ៗសិក្ខាបទ គឺវត្ថុណាគួរជាសង្ឆាទិសេស ថុល្លច្ច័យ បាចិត្តិយនិងទុក្កដ ក៏ត្រូវអាបត្តិតាមវត្ថុនោះៗ បើវត្ថុដែលគួរ ក៏គង់ត្រូវអាបត្តិទុក្កដ ព្រោះការសង្ស័យ ដូច្នេះឈ្មោះថាត្រូវដោយ សេចក្ដីសង្ស័យ ។

ត្រូវដោយសេចក្ដីសម្គាល់ថាគួរ ក្នុងវត្ថុដែលមិនគួរដូចម្ដេច? ភិក្ខុ សម្គាល់ក្នុងសាច់ដែលជាអកប្បិយ គឺសាច់ខ្លាឃ្មុំនិងសាច់ខ្លាធំ ប្រហែល នឹងសាច់ជ្រូកនិងសាច់គោ សម្គាល់ថាសាច់ជ្រូកសាច់គោជាកប្បិយគួរ ធាន់ ក៏ធាន់លេបចូលទៅត្រូវអាបត្តិ ឬកោជនជាអកប្បិយមិនគួរធាន់ សម្គាល់ថាកប្បិយគួរធាន់ ហើយធាន់លេបចូលទៅក៏ត្រូវអាបត្តិ ឬរសៀល ហើយសម្គាល់ថានៅព្រឹក ធាន់អាហារដែលជាយាវកាលិក ក៏ត្រូវអាបត្តិ ដូច្នេះឈ្មោះថាត្រូវដោយសេចក្ដីសម្គាល់ថា គួរក្នុងវត្ថុដែលមិនគួរ ។

ត្រូវដោយសេចក្តីសម្គាល់ថាមិនគួរ ក្នុងវត្ថុដែលគួរនោះដូចម្តេច? ភិក្ខុសម្គាល់ក្នុងសាច់ដែលគួរ គឺសាច់ជ្រូកនិងសាច់គោ ថាសាច់ខ្លាឃ្មុំ សាច់ខ្លាធំជាអកប្បិយមិនគួរធាន់ ហើយធាន់លេបចូលទៅ ក៏ត្រូវអាបត្តិ ឬភោជនជាកប្បិយគួរធាន់ សម្គាល់ថាជាអកប្បិយមិនគួរធាន់ ហើយធាន់លេបចូលទៅ ក៏ត្រូវអាបត្តិ ឬវេលានៅព្រឹក សម្គាល់ថាវេលារសៀល ហើយធាន់យាវកាលិកចូលទៅ ក៏ត្រូវអាបត្តិ ដូច្នេះឈ្មោះថាត្រូវដោយសេចក្តីសម្គាល់ថាមិនគួរក្នុងវត្ថុដែលគួរ ។

ត្រូវដោយវង្វេងស្មារតីនោះដូចម្តេច? ភិក្ខុដេកក្នុងទីប្រក់បាំងជាមួយនឹងអនុបសម្បន្ន គ្រប់ ៣ រាត្រីហើយ លុះដល់រាត្រីជាគម្រប់ ៤ ហើយភ្ញេចស្មារតីទៅដេករួមក្នុងទីប្រក់បាំងទៀត ក៏ត្រូវអាបត្តិ ឬ ភ្ញេចនៅប្រាសចាកត្រៃចីវរណាមួយកន្ទង ១ រាត្រី ក៏ត្រូវអាបត្តិ ឬ ទទួលប្រគេនកេសជ្ជៈទុកឲ្យកន្ទង ៧ ថ្ងៃទៅ ក៏ត្រូវអាបត្តិ ឬ ទទួលអតិរេកចីវរទុកភ្ញេចមិនបានអធិដ្ឋាន រ៉ាកប្ប ឲ្យកន្ទង ១០ ថ្ងៃទៅ សំពត់នោះជានិស្សគ្គិយ ខ្ជីនត្រូវបាចិត្តិយ ដូច្នេះឈ្មោះថាត្រូវដោយវង្វេងស្មារតី ។

ចប់ អាការៈដែលភិក្ខុនឹងត្រូវអាបត្តិ ៦ យ៉ាងតែប៉ុណ្ណោះ

អាបត្តិនាមាទិបព្ទ:គម្រប់ពីរ ចប់

បដិបត្តិមុខបព្វ

បដិបត្តិមុខបព្វៈគម្រប់បី ពោលអំពីសិក្ខាបទ ដែលជាផ្លូវនៃសេចក្ដីបដិបត្តិដោយច្រើន ក៏ឯក្នុងបុព្វសិក្ខានៃបព្វៈនេះ តាំងអំពីសិក្ខាបទនៃបារាជិកាបត្តិ ដរាបដល់សិក្ខាបទនៃទុក្កដាបត្តិ បានញែកទុកជា ២ ចំណែក គឺសចិត្តកៈ ១ អចិត្តកៈ ១ ដើម្បីនឹងឲ្យដឹងងាយ ដ្បិតបុព្វ-សិក្ខានោះជាពាក្យសង្ខេបណាស់ ឯបុព្វសិក្ខាវណ្ណនានេះ មិនបានសម្ដែងតាមលំដាប់ក្នុងបុព្វសិក្ខានោះទេ នឹងសម្ដែងតាមលំដាប់សិក្ខាបទដែលមានមកក្នុងបាតិមោក្ខុទ្ទេស លើកទុកតែបញ្ញត្តិនៃថុល្លច្ចយាបត្តិនិងបញ្ញត្តិនៃទុក្កដាបត្តិ ដែលមិនបានឡើងកាន់បាតិមោក្ខុទ្ទេស បណ្ដាសិក្ខាបទដែលមានមកក្នុងបាតិមោក្ខុទ្ទេសនោះ សិក្ខាបទដែលជាផ្លូវនៃសេចក្ដីបដិបត្តិដែលលើកឡើងពោលក្នុងបុព្វសិក្ខាក្ដី ដែលមិនបានលើកឡើងពោលក្នុងបុព្វសិក្ខាក្ដី នឹងពោលដោយពិស្ដារបន្ដិចតាមគួរ ហើយពណ៌នាតាមបាលីខ្លះ តាមអដ្ឋកថាឈ្មោះថាកង្ខាវិតរណីខ្លះ នឹងពោលអង្គនិងវិធីមានសមុដ្ឋានជាដើមផង នឹងពោលសិក្ខាបទដែលមិនជាផ្លូវនៃសេចក្ដីបដិបត្តិផង តែនឹងពោលដោយសង្ខេប ល្មមឲ្យដឹងសេចក្ដីតាមបទមាតិកា និងមិនប្រកបអង្គនិងវិធីមានសមុដ្ឋានជាដើមផង កាលបើដូច្នេះក៏នឹងបានសមតាមពាក្យដែលពោលថា បដិបត្តិមុខបព្វៈ ក៏ឯសេចក្ដីបញ្ញត្ត

ដែលមិនមានមកក្នុងបាតិមោក្ខ និងពោលដោយសង្ខេបខ្លះ ដោយពិស្តារ តាមគម្ពីរសមន្តបាសាទិកាខ្លះ តាមគម្ពីរដទៃខ្លះ ។

ចារាជិកុទ្ទេស

នឹងពណ៌នាក្នុងបារាជិកសិក្ខាបទនោះមុន ក៏ឯបារាជិកសិក្ខាបទនៃកិក្ខុ មាន ៤ គឺ មេថុន ១ អទិន្នាទាន ១ មនុស្សវិគ្គហ: ១ ឧត្តរិមនុស្សធម្ម ១ ។

មេថុនសិក្ខាបទជាបឋមនោះ សេចក្តីថា កិក្ខុណាមួយជាអ្នកដល់ព្រមហើយដោយអធិសីលសិក្ខា និងសិក្ខាបទជាទីចិញ្ចឹមជីវិត ជាមួយកិក្ខុទាំងឡាយ ហើយមិនបានពោលលានូវសិក្ខា មិនធ្វើឲ្យច្បាស់នូវភាពជាមនុស្សទុព្ភ៑ល មិនប្តេជ្ញាខ្លួនជាគ្រហស្ថមុន ហើយសេពមេថុនដោយហោចទៅសូម្បីតែសត្វតិរច្ឆាន កិក្ខុនោះត្រូវបារាជិកមិនមានសង្វាសជាមួយនឹងកិក្ខុដទៃ ។ ពាក្យថាកិក្ខុនោះ គឺកុលបុត្តអ្នកបានអរិយសម្មតិដ៏មានតមកអំពីព្រះពុទ្ធអង្គ ជាសម្មតិសម្រាប់គ្រប់គ្រងបាតិមោក្ខសំវរសីលជារបស់ធំ គឺសង្ឆព្រមព្រៀងគ្នាឲ្យឧបសម្ប៉ៃទដោយញត្តិចតុត្ថកម្មវាចាមិនកម្រើក គឺព្រមដោយវត្ថុសម្បត្តិ ញត្តិសម្បត្តិ អនុសាវនសម្បត្តិ សីមា-សម្បត្តិ បរិសសម្បត្តិ ដ៏គួរដល់ហេតុជាទីតាំងដូច្នេះឯង ឈ្មោះថាកិក្ខុ កិក្ខុប្រែថាអ្នកសូម គឺថាបានក្តី មិនបានក្តី សូមតាមលំអានព្រះអរិយ: វេលាព្រឹកឡើងស្ងៀកដណ្តប់ជាបរិមណ្ឌល បីបាត្រឈរ ចំពោះមុខផ្ទះនៃត្រកូលជាសម្គាល់ មិនស្រែកសូមដោយវាចា ។

ពាក្យថាណាមួយនោះ គឺថា ខ្ពស់ ទាប ស ខ្មៅ ណាៗក្តី ប្រកបការងារដូចម្តេចក្តី មានជាតិ មាននាម មានគោត្រ មានប្រក្រតី មានវិហារធម៌ មានគោចរដូចម្តេចក្តី ជាថេរៈ ឬ ភិក្ខុថ្មី ឬ ភិក្ខុកណ្តាលក្តី មិនកំណត់ បើសេពមេថុន ត្រូវបារាជិកគ្រប់រូប ។

ពាក្យថា មិនពោលលានូវសិក្ខាបទ និងមិនធ្វើឲ្យច្បាស់ នូវភាពជាមនុស្សទុព៌លនោះ គឺមិនបានលានូវសិក្ខាបទ ព្រមដោយចិត្ត និងខេត្ត និងកាល និងប្រយោគ និងបុគ្គល និងព្រមដោយវិជ្ជាធនៈគឺសេចក្តីដឹងខ្លួនឯព្រមដោយចិត្តនោះ គឺគិតនឹងឃ្លាតចាកភាពជាឧបសម្បន្ន ហើយពោលពាក្យលាសិក្ខា មិនពោលលេង មិនពោលភ្ជាំងភ្ជាត់ ទើបឈ្មោះថាលាសិក្ខាបទមួយយ៉ាង ក៏ឯខេត្តនោះមានច្រើនដល់ ២២ បទ នឹងពោលតែបទដែលគួរនឹងប្រើ ពោលថា **សិក្ខំ បចក្ខាមិ** ខ្ញុំពោលលានូវសិក្ខាក្តី **វិនយំ បចក្ខាមិ** ខ្ញុំពោលលានូវវិន័យក្តី នឹងពោលថា **តិហីតិ មំ ជានេហិ** លោកចូរចាំទុកនូវខ្ញុំថាជាគ្រហស្ថក្តី **ឧបាសកោតិ មំ ជានេហិ** លោកចូរចាំទុកនូវខ្ញុំថាជាឧបាសកក្តី ពោលតាមបទដូច្នេះ មិនពោលតាមបទដទៃដូចថា **រុក្ខំ បចក្ខាមិ** ជាដើម ដូច្នេះ ឈ្មោះថាលាសិក្ខាព្រមដោយខេត្ត ព្រមដោយកាលនោះ គឺពោលពាក្យលាដោយ វត្តមានកាល[1] ថា **បចក្ខាមិ** ខ្ញុំពោលលា **ជានេហិ** លោកចូរចាំទុកក្តី ពោលដោយពាក្យមិនអាស្រ័យកាលដូចជា

---

1. វត្តមានកាល គឺបច្ចុប្បន្នកាលដែលកំពុងប្រព្រឹត្តទៅ ។

អលំ មេ សិក្ខាយ មិនគួរឡើយដោយសិក្ខាដល់ខ្ញុំដូច្នេះជាដើមក្តី មិនពោលដោយពាក្យជាអតីតកាលថា **បច្ចក្ខាសឹ** ខ្ញុំពោលលាហើយ **ជាវេសិ** លោកចាំទុកហើយក្តី មិនពោលដោយអនាគតកាលថា **បច្ចក្ខិស្សុ** ខ្ញុំនឹងពោលលា **ជាវេស្សេសិ** លោកនឹងចាំទុកក្តី មិនពោលដោយពាក្យជាបរិកប្បថា **បច្ចក្ខេយ្យ** ខ្ញុំគប្បីពោលលាក្តី ដូច្នេះឈ្មោះថាលាសិក្ខាព្រមដោយកាល ក៏ឯព្រមដោយប្រយោគនោះ គឺប្រយោគនៃវាចាដែលពោលបញ្ចេញថា ខ្ញុំពោលលានូវសិក្ខាជាដើម ពោលដោយភាសាណាៗ មិនកំណត់ តែមិនលាដោយកាយប្រយោគ មានសរសេរសំបុត្រលាជាដើម ដូច្នេះឈ្មោះថា លាសិក្ខាព្រមដោយ ប្រយោគ ព្រមដោយបុគ្គលនោះ គឺអ្នកលាសិក្ខាមិនជាមនុស្សឆ្គួត មិនជាមនុស្សមានចិត្តអណ្តែតអណ្តូង មិនជាមនុស្សឈឺ គឺទុក្ខវេទនា ធ្ងន់គ្របសង្កត់ ជាមនុស្សប្រក្រតីល្អ អ្នកស្តាប់ពាក្យលាសោត ក៏ជាមនុស្សជាតិ មិនជាតិរច្ឆាន មិនជាទេវតា មិនជាមនុស្សឆ្គួត មិនជា មនុស្សមានចិត្តអណ្តែតអណ្តូង មិនជាមនុស្សឈឺ គឺទុក្ខវេទនាធ្ងន់គ្រប សង្កត់ ជាមនុស្សនៅចំពោះមុខ មិនត្រូវប្រាប់ដោយទូតនិងសំបុត្រ ដូច្នេះឈ្មោះថាព្រមដោយបុគ្គល ព្រមដោយសេចក្តីដឹងនោះ គឺអ្នកលា សិក្ខានិយមចំពោះអ្នកណា អ្នកនោះបានឮបានដឹងសេចក្តីក្នុងខណៈនោះ មិននឹកទៅយូរហើយទើបដឹងដូច្នេះក្តី បើមិននិយមបុគ្គលហើយលាសិក្ខា

ចំពោះមុខមនុស្សផងច្រើនគ្នា ក្នុងមនុស្សទាំងអម្បាលនោះ មនុស្សណាមួយដឹងសេចក្តីក្នុងខណៈនោះក្តី ដូច្នេះទើបឈ្មោះថាព្រមដោយសេចក្តីដឹង ភិក្ខុលាសិក្ខាព្រមដោយចិត្តជាដើម ដូចពោលមកនេះឯង ទើបឈ្មោះថាលាសិក្ខា បើមិនព្រមមិនឈ្មោះថាលាសិក្ខា ។

ក៏ឯសេពមេថុននោះ គឺឲ្យនិមិត្តរបស់ខ្លួន សូម្បីព័ន្ធព័ទ្ធឬរុំដោយវត្ថុណាមួយក្តី ឲ្យចូលទៅក្នុងវច្ចមគ្គទ្វារធ្ងន់ បស្សាវមគ្គទ្វារស្រាលមុខមគ្គទ្វារមាត់ ទ្វារណាមួយនៃអ្នកដទៃដែលមិនស្ងាប់ ឬ ស្ងាប់ហើយ ឯទ្វារមគ្គនោះនឹងទ្រាប់សសាប់ដោយវត្ថុណាមួយក្តី មិនទ្រាប់មិនសសាប់ក្តី ជាទ្វារគឺសត្វមិនទាន់កកេរដោយច្រើន ឲ្យកន្ទង ទីទទឹកទីសើម គឺខ្យល់ប្រក្រតីមិនពាល់ត្រូវ សូម្បីប៉ុនសំដីលូ ១ ឬ ប៉ុនចុងសក់ ដោយចិត្តត្រេកអរក្តី ឬ អ្នកដទៃកំហែងសង្កត់សង្កិនក្នុងនិមិត្តខ្លួន ហើយត្រេកអរក្នុងកាលទាំង ៤ គឺកាលដែលអង្គជាតិកំពុងចូលទៅក្តី ដែលចូលស៊ប់ទៅហើយក្តី ដែលកំពុងឋិតនៅក្តី ដែលដកថយចេញក្តី ណាមួយ ឬ អង្គជាតិនៃខ្លួនវៃងឲ្យចូលទៅក្នុងទ្វារធ្ងន់នៃខ្លួនឯងក្តី ឬ ខ្ជងទន់ខ្ជិនចុះបៀមអង្គជាតិនៃខ្លួន ដោយសេចក្តីត្រេកអរក្តី អាការដែលពោលមកទាំងអម្បាលនេះ ឈ្មោះថាសេពមេថុន ភិក្ខុសេពមេថុនដូច្នេះ ត្រូវបារាជិក មិនមានសង្វាស គឺរួមសង្ឆកម្មតូចធំជាមួយនឹងភិក្ខុដទៃតទៅមិនបាន ។

ក៏ឯខេត្តទ្វារដែលនឹងត្រូវបារាជិកនោះគឺស្រីមនុស្ស ស្រីអមនុស្ស តិរច្ឆានញី មានទ្វារ ៣ គឺទ្វារធ្ងន់ ទ្វារស្រាល ទ្វារមាត់ មួយពួកៗ មានទ្វារ ៣ ៗ ត្រូវជា ៩ ឧកតោព្យញ្ជនក: មនុស្សមានភេទស្រី ភេទប្រុសទាំង ២ យ៉ាង ដែលជាមនុស្ស ជាអមនុស្ស ជាតិរច្ឆានញី ក៏មានទ្វារ ៣ ៗ ត្រូវជា ១៨ មនុស្សប្រុស អមនុស្សប្រុស តិរច្ឆានឈ្មោល មានទ្វារ ២ គឺទ្វារធ្ងន់និងទ្វារមាត់ មួយពួកៗ មានទ្វារ ២ ៗ ត្រូវជា ៦ មនុស្សបណ្ឌក អមនុស្សបណ្ឌក តិរច្ឆានបណ្ឌក មានទ្វារ ២ ៗ ត្រូវជា ៦ រួមជា ១២ ផ្សំទាំងអស់ត្រូវជាទ្វារមគ្គ ៣០ ឲ្យកើតអាបត្តិបារាជិក ។

ក៏ឯការកំណត់សត្វតិរច្ឆានោះដូច្នេះ សត្វមិនមានជើងបាននឹងទីឃជាតិមានពស់ថ្នាន់និងពស់ផ្ទះជាដើម ឯជាតិសត្វទឹកមានត្រី និងអណ្តើកនិងកង្កែបជាដើម ដែលមានទ្វារមគ្គទាំង ៣ ណាមួយ ល្មមឲ្យអង្គជាតិចូលទៅបាន សូម្បីប៉ុនសំដីលួនិងប៉ុនចុងសក់ ១ អម្បាលនេះជាវត្ថុនៃបារាជិក តូចចុះទៅជាងនោះជាវត្ថុនៃទុក្កដ សត្វទ្វិបាទជើង ២ បាននឹងក្អែក មាន់ ព្រាប ជាដើម សត្វចតុបាទជើង ៤ បាននឹងឆ្មា និងកំប្រុក កង្កែន ស្ការ ត្រកួត ជាដើម ទាំងអម្បាលនេះជាសត្វតូចឲ្យគប្បីដឹងថាជាវត្ថុនៃបារាជិកនិងទុក្កដដូចពោលហើយក្នុងមុន ។

ភិក្ខុឲ្យផ្ទួត ឬ ពកដែលដុះឡើងក្នុងអង្គជាតិនៃខ្លួនមានកាយប្រសាទ

នៅមិនទាន់ស្ងាប់នៅដឹងសម្ផស្សឲ្យចូលទៅក្នុងទ្វារមគ្គទាំង ៣០ ដូចពោលហើយណាមួយ សូម្បីទ្វារនោះមានស្បែកនិងសាច់ជាដើមរបើកទៅអស់ហើយគ្រាន់តែសណ្ឋាននៃនិមិត្តមាននៅប្រាកដប៉ុណ្ណោះដូច្នេះ កាលមានចិត្តគិតថានឹងសេព ហើយសេពក៏ត្រូវបារាជិក ភិក្ខុឲ្យពោមឬផ្ងូត ឬពកដែលកើតក្នុងអង្គជាតិខ្ជូន មានកាយប្រសាទវិនាសហើយមិនដឹងសម្ផស្ស ឲ្យចូលទៅក្នុងទ្វារមគ្គដូចពោលហើយនោះ ត្រូវទុក្កដ បើទ្វារមគ្គនោះរបើកទៅអស់ហើយ សូម្បីគ្រាន់តែសណ្ឋាននៃនិមិត្តក៏មិនសល់ ភិក្ខុព្យាយាមក្នុងទីដូច្នេះ សង្ខេបថាជាដំបៅ ត្រូវបុល្ចច្ច័យ ទ្វារភ្នែក ទ្វារច្រមុះ ទ្វារត្រចៀក និងស្រោមនៃក្បាលសសាស់ គឺនិមិត្តនិងដំបៅដែលធ្វើដោយសស្ត្រាវុធក្នុងកាយនៃមនុស្ស អម្បាលនេះក្តី ឯស្រោមនៃសសាស់ និង រន្ធច្រមុះនៃសត្វតិរច្ឆានធំ មានដំរីនិងសេះជាដើមក្តី ឯនិមិត្តនៃមនុស្សស្ងាប់តាំងអំពីសត្វកកេរពាក់កណ្តាល នៅមិនទាន់ហើមប៉ោងឡើងក្តី និងអណ្តាត ឬធ្មេញដែលចេញមកក្រៅបបូរមាត់ក្តី អម្បាលនេះជាខេត្តជាវត្ថុនៃអាបត្តិបុល្ចច្ច័យ ទ្វារភ្នែក ទ្វារច្រមុះ និងដំបៅក្នុងកាយសត្វតិរច្ឆានក្តី និងនិមិត្តដ៏តូចនៃសត្វតិរច្ឆានមានពស់និងត្រីជាដើម ដែលមិនលួមប្រមាណនៃអង្គជាតិដំណើរចូលទៅបានក្តី និងសរីរាវយវៈដ៏សេសមានក្ងៀកជាដើមនៃមនុស្ស និងតិរច្ឆានក្តី និងនិមិត្តក្នុងសាកសពដែលហើមឡើងក្តី និងជុំសាច់

ដែលរលេះធ្លាក់ចុះអំពីនិមិត្តក្តី អម្បាលនេះជាខេត្តជាវត្ថុនៃអាបត្តិទុក្កដ ភិក្ខុ សង្កត់អង្គជាតិចូលទៅក្នុងមាត់សាកសពដែលហា មិនឲ្យទង្គិចខាងក្រោម និងខាងទាំង ៤ នោះត្រូវទុក្កដ ពោលមកនេះជាប្រភេទនៃអាបត្តិ ។

ឯវិធីដែលមិនត្រូវអាបត្តិក្នុងសិក្ខាបទនេះ គឺភិក្ខុមិនដឹង និងមិនត្រេកអរ និងធ្លត មានចិត្តអណ្តែតអណ្តូង និងវេទនាគ្របសង្កត់ និងភិក្ខុជាអាទិកម្មិក:អ្នកដើមបញ្ញត្តិ អម្បាលនេះមិនត្រូវអាបត្តិ ។ ភិក្ខុដេកលក់ អ្នកដទៃមកលបធ្វើមេថុនក្នុងនិមិត្តខ្លួន ភិក្ខុនោះមិនដឹងខ្លួន ឈ្មោះថា មិនដឹង មិនត្រូវអាបត្តិ ភិក្ខុណាសូម្បីដឹងតែមិនត្រេកអរ ឈ្មោះថា មិនត្រេកអរ មិនត្រូវអាបត្តិ ។

ភិក្ខុធ្លតវក់ខ្លាំងដោយពុះពារនៃប្រមាត់និងមានគេធ្វើឲ្យចិត្តអណ្តែតអណ្តូង ឈ្មោះថាជាមនុស្សមានចិត្តអណ្តែតអណ្តូង ២ ជំពូកនេះ ដែលមិនដឹងមិនមានស្មារតីឃើញក្ងើង និងមាស និងលាមក និងខ្ទឹមចន្ទន៍ ក៏ដូចគ្នា ដូច្នេះជាប្រមាណក្នុងវិធីដែលមិនត្រូវអាបត្តិ ។ ភិក្ខុណាមិនដឹងអ្វីសោះ ព្រោះរសាប់រសល់ទៅដោយទុក្ខវេទនាដ៏ខ្លាំង ដូច្នេះឈ្មោះថា គឺទុក្ខវេទនាគ្របសង្កត់មិនត្រូវអាបត្តិ ភិក្ខុណាជាដើមហេតុ ដែលនឹងឲ្យព្រះមានព្រះភាគបញ្ញត្តិសិក្ខាបទនោះ ដូចសុទិន្នភិក្ខុ ទៅសេពមេថុនធម្មមុនភិក្ខុដទៃដូច្នេះ ឈ្មោះថាអាទិកម្មិក:អ្នកដើមបញ្ញត្តិ មិនត្រូវអាបត្តិ ពោលមកនេះឈ្មោះថាពោលដោយអនាបត្តិ ។

មួយទៀតសិក្ខាបទនេះជាអនាណត្តិក: ព្រោះមិនត្រូវបារាជិកដោយ
បង្ហាប់អ្នកដទៃឲ្យសេពមេថុនអ្នកដទៃ ក៏ប៉ុន្តែថាបង្ហាប់ ឬញុះកិក្ខុផងគ្នាឲ្យ
សេពមេថុនសូម្បីមិនត្រូវបារាជិកក៏មែន តែគង់មិនរួចទុក្កដាបត្តិ ព្រោះជា
អកប្បិយសមាទាន មានអង្គ២ គឺ **សេវនចិត្តំ** *ចិត្តគិតនឹងសេពមេថុន ១*
មគ្គេន មគ្គបដិបាទនំ *ញ៉ាំងអង្គជាតិឲ្យចូលទៅក្នុងទ្វារមគ្គពាល់*
ត្រូវក្នុងទីណាមួយជាអង្គ ១ បើព្រមដោយអង្គ ២ ដូច្នេះទើបត្រូវបារាជិ-
កាបត្តិ បើមិនព្រមក៏មិនត្រូវ សិក្ខាបទនេះមានសមុដ្ឋាន ១ ឈ្មោះថា
បឋមបារាជិកសមុដ្ឋាន គឺកើតអំពីកាយនិងចិត្តជាសមុដ្ឋាន ១ ជាកិរិយា
ជាសញ្ញាវិមោក្ខ ជាសចិត្តក: ជាលោកវជ្ជ: ជាកាយកម្ម ជាអកុសល-
ចិត្ត ជាទ្វិវេទនា មានវេទនា ២ គឺសុខនិងឧបេក្ខា ។

<u>*បឋមបារាជិក ចប់*</u>

អទិន្នាទានសិក្ខាបទគម្រប់ពីរ សេចក្តីថាកិក្ខុណាលួចឯង ឬ ប្រើ
គេឲ្យលួចនូវទ្រព្យដែលមានជីវិតនិងមិនមានជីវិត មានតម្លៃអំពី ១ បាទ
ឡើងទៅដោយបាទក្នុងមគធ:ប្រទេស ដែលតាំងនៅក្នុងស្រុកឬក្នុងព្រៃ
និងក្នុងទឹកឬលើគោក ក្នុងអាកាសឬទីណាមួយក្តី ដែលមានម្ចាស់របស់
គេហួងហែង ដោយចេយ្យចិត្ត ដោយអាការនៃកិរិយាលួចផ្សេងៗ គឺ
ប្តឹងផ្តល់ បិទបាំង បំបាត់ប្រវ័ញ្ច ផ្ទាស់ប្តូរ ធ ដណ្តើម កំហែង
សង្កត់សង្កិន ចោះគ្រវែងចោលណាមួយក្តី កិក្ខុនោះត្រូវបារាជិក ។

ដែលថា ១ បាទនោះ ក្នុងបាលីថា ៥ មាសកជា ១ បាទ ក្នុងនគរ
រាជគ្រឹះ ដោយបាលីថា **តេន ខោ បន សមយេន រាជគហេ
បញ្ចមាសកោ ចាដោ ហោតិ** ក្នុងអដ្ឋកថា ថា ២០ មាសក
ជា ១ កហាបណៈ ក្នុងនគររាជគ្រឹះ ក្នុងកាលនោះ ព្រោះហេតុនោះ ៥
មាសកទើបជា ១ បាទ ដោយលក្ខណៈនោះគប្បីដឹងចុះថាចំណែកគម្រប់៤
នៃកហាបណៈជាមួយបាទ ក្នុងជនបទទាំងពួង ក៏ឯចំណែកគម្រប់ ៤ នៃ
កហាបណៈនោះគប្បីដឹងដោយអំណាចនៃបុរាណនីលកហាបណៈមិនមែន
កហាបណៈដទៃមានរុទ្ធាមកកហាបណៈជាដើម សូម្បីព្រះពុទ្ធជា
អម្ចាស់ទាំងឡាយ ក្នុងអតីតនិងអនាគត ព្រះអង្គក៏បញ្ញត្តទុតិយបារាជិក
ដោយបាទចំណែកគម្រប់ ៤ នៃនីលកហាបណៈនោះដោយបាឬថា: **បញ្ច-
មាសកោ ចាដោតិ តជ រាជគហេ រីសតិមាសកោ
កហាបណោ ហោតិ តស្មា បញ្ចមាសកោ ចាដោ
ឯតេន លក្ខណេន សព្វជនបទេសុ កហាបណាសុ
ចតុត្ថោ ភាគោ ចាដោតិ វេទិតព្ពោ សោ ច ខោ
ចោរាណាសុ នីលកហាបណាសុ វសេន ន ឥតរេសំ
រុទ្ធាមកាទីនំ តេន ហិ ចាដេន អតីតា ពុទ្ធាបិ
ចារាជិកំ បញ្ញាបេសុំ អនាគតាបិ បញ្ញាបេស្សន្តិ ។**

ក៏ឯវិនិច្ឆ័យបាទ មគធៈ ជាប្រាក់ ក្នុងកម្ពុជប្រទេសនេះ តាមអដ្ឋ-

កថានិងដីកា នឹងពោលទៅខាងមុខក្នុងទីបំផុតនៃការវិនិច្ឆ័យទាំងពួង ។

ក៏ឯអវហារ អាការដែលនឹងលួចនោះ គប្បីដឹងដោយបាលី ៦ បទ ដូច្នេះ គឺ អាទិយនៈ ១ ហរណៈ ១ អវហរណៈ ១ ឥរិយាបថ-វិកោបនៈ ១ ឋានាចាវនៈ ១ សង្កេតវីតិនាមនៈ ១ ។ អធិប្បាយក្នុងបទទាំង ៦ នោះតាមអដ្ឋកថាដូច្នេះ ៖

អាទិយនៈ នោះថាកាន់យក បាននឹងភិក្ខុចោទប្រកាន់យកស្រែ ចំការច្បារដំណាំទីដីរបស់អ្នកដទៃថាជារបស់ខ្លួន ក្នុងខណៈដែលចោទ នោះត្រូវអាបត្តិទុក្កដ មិនត្រូវបាចិត្តិយដោយមុសាវាទ ព្រោះជាបុព្ព-ប្រយោគនៃអទិន្នាទាន កាលម្ចាស់របស់សង្ស័យ ថាយើងនឹងបានឬ មិនបាន ភិក្ខុនោះត្រូវចុល្លច្ច័យ កាលម្ចាស់របស់លះបង់នូវធុរៈ ថានឹង មិនបានជារបស់យើងហើយ ភិក្ខុនោះក៏ដាក់ធុរៈថាជាក់ជាមិនឲ្យ ទើប ត្រូវបារាជិក បើភិក្ខុនៅមានចិត្តគិតថានឹងឲ្យ គ្រាន់តែសម្តែងអានុភាព ឲ្យខ្ជាចប៉ុណ្ណោះក្តី ឬម្ចាស់របស់នៅមិនទាន់ដាក់ធុរៈក្តី ក៏នៅមិនទាន់ត្រូវ បារាជិក កាលណាបើដាក់ធុរៈទាំងសងខាង គឺភិក្ខុច្បាស់ថាមិនឲ្យ ម្ចាស់ របស់ក៏កាត់ថាមិនបានរ្លើយចុះ ទើបត្រូវបារាជិក ។

ហរណៈ នោះថានាំទៅ បាននឹងភិក្ខុជួយនាំរបស់នៃអ្នកដទៃទៅ ដោយក្បាលជាដើម បើមានចេយ្យចិត្តនឹងលួច ចាប់ពាល់បបោស អង្ហែលរបស់នៅលើក្បាលនោះ ត្រូវទុក្កដ គ្រប់ប្រយោគ ធ្វើរបស់នោះ

ឲ្យកម្រើកទៅមកនៅលើក្បាល ត្រូវជុលច្ជុយ គ្រប់ប្រយោគ ដាក់ចុះ នូវរបស់នោះមកដល់ស្មា ត្រូវបាវជិក ឯកំណត់ក្បាលនោះ ខាងមុខ ត្រឹមបំពង់ក ខាងក្រោយត្រឹមដើងសក់ ខាងទាំងសងខាងត្រឹមគុម្ព ត្រចៀក ភិក្ខុរំកិលរបស់ចុះមកចាកក្បាលមិនឲ្យឃ្លាតអំពីក្បាល ល្មមតែ ហួសខេត្តក្បាលដែលកំណត់ទុកនោះ ត្រូវបាវជិក ថាបើលើកឡើងផុត ក្បាល សូម្បីតែមួយសរសៃសក់ក៏ត្រូវបាវជិក របស់ដែលវែកលើស្មា នឹងកណ្តៀតដោយចង្កេះនិងយួរដោយដៃ ក៏គប្បីវិនិច្ជុយ ដូចជារបស់ ដែលនៅលើក្បាលនោះចុះ ។

អវហារណ: នោះថានាំយក បាននឹងភិក្ខុទទួលរបស់បញ្ញើគេទុក លុះម្ចាស់របស់គេមកទារ ភិក្ខុកៃងពោលពាក្យបំភ្ញាត់ថា យើងមិនដឹងមិន បានទទួលទុកទេ ពោលដូច្នេះដោយថេយ្យចិត្តត្រូវទុក្កដ ធ្វើឲ្យម្ចាស់ របស់កើតមានសេចក្ដីសង្ស័យត្រូវជុលច្ជុយ លុះម្ចាស់របស់ដាក់ធុរ: ភិក្ខុ ក៏ដាក់ធុរ:ទាំងសងខាងដូចពោលហើយក្នុងអាទិយន:នោះ ភិក្ខុនោះក៏ត្រូវ បាវជិក ។

ឥរិយាបថវិកោបន: នោះថាញ៉ាំងឥរិយាបថឲ្យកម្រើក បាននឹងភិក្ខុ មានថេយ្យចិត្តនឹងលួចនាំរបស់ព្រមទាំងមនុស្សដែលនាំរបស់នោះទៅផង ហើយដេញមនុស្សដែលនាំរបស់ទៅនោះ ឲ្យលើកជំហានជាដំបូងឈាន

ទៅតាមប្រាជ្ញានៃខ្លួនត្រូវបុល្លច្ច័យ ដេញឲ្យលើកទុតិយបាទ គឺជំហានជាគម្រប់ពីរឈានទៅទៀត ត្រូវបារាជិក ។

ឋានាចារៈ នោះថាឲ្យកម្រើកចាកទី គឺឲ្យឃ្លាតចាកទី បានន័យកិក្ខុគិតនឹងលួចរបស់ដែលតាំងនៅលើគោក ឬក្នុងទឹក ឬដីទំនាប ឬទីដំបន់ណាមួយ ហើយចាប់ពាល់ត្រូវរបស់នោះត្រូវទុក្ខដ ធ្វើរបស់នោះឲ្យកម្រើកទៅមកត្រូវបុល្លច្ច័យ ធ្វើរបស់នោះឲ្យឃ្លាតចាកទី ត្រូវបារាជិក ។ ឯកំណត់ឋានទីតាំងនោះដូច្នេះ បើរបស់នោះជាធ្នាំងតាំងនៅក្នុងទឹក ឬក្នុងកក់មានឋាន ៦ គឺមាត់ធ្នាំងខាងលើឋាន ១ បាទធ្នាំងដែលពាល់ត្រូវផ្ទៃជាឋាន ១ ខាងទាំង ៤ ជាឋាន ៤ ត្រូវជា ៦ ឋានផងគ្នា ទាញមកខាងមុខឲ្យចំណែកធ្នាំងដែលពាល់ត្រូវផ្ទៃខាងណោះ ហួសចំណែកធ្នាំងដែលពាល់ត្រូវផ្ទៃខាងណោះមួយសរសៃសក់ក្តី ឬ រុញទៅខាងមុខឲ្យចំណែកធ្នាំងខាងណោះ ហួសចំណែកធ្នាំងដែលពាល់ត្រូវផ្ទៃខាងណោះមួយសរសៃសក់ក្តី ឬ ទាញទៅខាងធ្វេងឲ្យចំណែកធ្នាំងដែលពាល់ត្រូវផ្ទៃខាងស្តាំ ហួសចំណែកធ្នាំងដែលពាល់ត្រូវផ្ទៃខាងធ្វេងមួយសរសៃសក់ក្តី ឬ ទាញមកខាងស្តាំ ឲ្យចំណែកធ្នាំងដែលពាល់ត្រូវផ្ទៃខាងធ្វេង ហួសចំណែកធ្នាំងដែលពាល់ត្រូវផ្ទៃខាងស្តាំមួយសរសៃសក់ក្តី ឬលើកឡើងឲ្យបាទធ្នាំងហួសផ្ទៃមួយសរសៃសក់ក្តី ឬសង្កត់ធ្នាំងឲ្យលិចចុះទៅឲ្យមាត់ធ្នាំងហួស

ចំណែកដែលបាទធ្នាំងពាល់ត្រូវផ្ទៃចុះទៅមួយសរសៃសក់ក្តី ដូច្នេះឈ្មោះ ថាកម្រើកចាកទីឋាន គឺឃ្លាតចាកទី ត្រូវបារាជិក ។

ឲ្យគប្បីដឹងច្បាស់នូវឋានដែលជាទីតាំងនៃរបស់ទាំងពួង ដូច្នេះ របស់ដែលតម្កល់ទុកក្នុងទីទាំងពួង វត្ថុខ្លះមានឋាន ១ ខ្លះមានឋាន ២ ខ្លះ មានឋាន ៣ ខ្លះមានឋាន ៤ ខ្លះមានឋាន ៥ ថាបើប្រាក់នៅក្នុងធ្នាំង ភិក្ខុយកភាជនៈដួសយក ឬ យកដៃក្តាប់យកក្តី ប្រាក់នៅក្នុងភាជនៈនិងក្នុង ដៃនោះដាច់មិនជាប់គ្នានិងប្រាក់ដែលនៅក្នុងធ្នាំងនោះ មិនទាន់លើក ឡើង ក៏ត្រូវបារាជិក ។

សង្កេតវិតិនាមនៈ នោះថាឲ្យកន្ទងសង្កេត បានន័ងគយដែល ម្ចាស់ផែនដីតាំងបញ្ញត្តិទុកក្នុងចន្ទោះភ្នំ ក្នុងកំពង់ទឹក ក្នុងទ្វារស្រុកណា មួយ ថាអ្នកណាមកក្នុងទីនេះ ឲ្យហៅយកថ្លៃគយ ភិក្ខុទៅដល់គយ ដូច្នេះហើយគិតនឹងមិនឲ្យថ្លៃគយ មានចេយ្យចិត្តចាប់ពាល់អង្ផែលកណ្ណ ដែលខ្ជិនយកទៅគួរដល់តម្លៃគយ ១ បាទ នោះត្រូវទុក្កដ លើកជំហាន ជាបឋមឈានកន្ទងគយទៅ ត្រូវថុល្លច្ច័យ លើកជំហានជាគម្រប់ ២ កន្ទង ទៅទៀតត្រូវបារាជិក ។

មួយទៀត ភិក្ខុចូលទៅក្នុងបរិវេណជាដើម បានឃើញកណ្ណរបស់ អ្នកដទៃដែលគួរជាទីស្រឡាញ់ ហើយកំណត់ទ្វារល្ងែង ឬ មុខផ្ទះជាដើម ទីណាមួយទុកជាទីសង្កេតហើយគិតថា ក្នុងឱកាសទីនេះ បើម្ចាស់របស់

គេឃើញអញ អញនឹងធ្វើជាវើសលើកមើលលេង ហើយនឹងឲ្យទៅម្ចាស់គេវិញ បើម្ចាស់របស់មិនឃើញអញ អញនឹងលួចយក កំណត់ដូច្នេះ ហើយនាំរបស់នោះដើរទៅ លើកជំហានជាបឋមកន្ទងទ្វារល្ងែងជាដើម ដែលសង្កេតទុកនោះ ត្រូវចុល្លច្ចុ័យ លើកជំហានជាគម្រប់ ២ ឈានទៅទៀត ត្រូវបារាជិក ដូចពោលមកនេះឈ្មោះសង្កេតវីតិនាមនៃ ។

មួយទៀត អវហារប្រភេទអាការលួច ព្រះអដ្ឋកថាចារ្យលោកតាំងទុកថាមាន ២៥ ចាត់ជាពួក ៗ មាន ៥ ពួកដូច្នេះ នានាកណ្ហបញ្ចកៈ ពួក ១ ឯកកណ្ហបញ្ចកៈពួក ១ សាហត្ថិកបញ្ចកៈ ពួក១ បុព្វបយោគបញ្ចកៈ ពួក ១ ថេយ្យាវហារបញ្ចកៈ ពួក ១ ។

ក៏ឯនានាកណ្ហបញ្ចកៈ នោះថា កិរិយាលួចមានពួក ៥ មានរបស់ផ្សេងៗ ជាទីកំណត់ គឺ អាទិយនៈ ចោទយករបស់ដែលមានវិញ្ញាណ និងមិនមានវិញ្ញាណរបស់គេ ១ ហរណៈ ជួយនាំយករបស់ដែលមានវិញ្ញាណ និងមិនមានវិញ្ញាណរបស់គេទៅ ១ អវហរណៈ បិទបាំងលួចយករបស់មានវិញ្ញាណនិងមិនមានវិញ្ញាណ ដែលគេផ្ញើទុក ១ ឥរិយាបថវិកោបនៈ ធ្វើឥរិយាបថនៃអ្នកនាំរបស់ទៅឲ្យកម្រើក ១ ឋានាចារនៈ ធ្វើរបស់ដែលមានវិញ្ញាណ និងមិនមានវិញ្ញាណឲ្យឃ្លាតចាកឋាន ១ ។ អវហារ ៥ ពួកនេះ ឈ្មោះថា នានាកណ្ហបញ្ចកៈ ព្រោះកំណត់ដោយរបស់ផ្សេងៗ គឺរបស់មានវិញ្ញាណនិងមិនមានវិញ្ញាណ វិនិច្ឆ័យពិស្តារឲ្យគប្បីដឹងដូចសម្តែងហើយក្នុងបទទាំង ៦ ខាងដើមនោះចុះ ។

ក៏ឯ ឯកកណ្ឌបញ្ចក: នោះថាពួក ៥ នៃកិរិយាលួចវត្ថុមានចំណែក ១ ជាទីកំណត់ គឺ អាទិយន: ចោទយករបស់ដែលមានវិញ្ញាណគឺទាស:និងសត្វចិញ្ចឹមរបស់គេ ១ ហរណ: ជួយនាំយកទាស:និងសត្វចិញ្ចឹមរបស់គេទៅ ១ អវហរណ: បិទបាំងលាក់បង្ហេះយកទាស:និងសត្វចិញ្ចឹមរបស់ដែលគេផ្ញើទុក ១ ឥរិយាបថវិកោបន: ធ្វើឥរិយាបថនៃទាស:និងសត្វដែលគេចិញ្ចឹមរបស់គេឲ្យកម្រើក ១ ឋានាចាវន: ធ្វើទាស:និងសត្វចិញ្ចឹមរបស់គេឲ្យឃ្លាតចាកទី ១ ពួក ៥ នេះឈ្មោះថា ឯកកណ្ឌបញ្ចក: កំណត់ដោយរបស់មានវិញ្ញាណម្យ៉ាង វិនិច្ឆ័យដោយពិស្តារ ដូចបានពោលមកហើយអំពីមុន ។

ក៏ឯ សាហត្ថិកបញ្ចក: នោះថា ពួកនៃអាការ:លួចមាន ៥ មានលួចដោយដៃខ្លួនជាដើម គឺ សាហត្ថិក: ១ អាណត្តិក: ១ និស្សគ្គិយ: ១ អត្ថសាធក: ១ ធុរនិក្ខេប: ១ ត្រូវជា ៥ ។

សាហត្ថិក: នោះថា កិរិយាលួចកើតដោយដៃខ្លួន ឯង គឺភិក្ខុលួចរបស់ដែលបិតនៅលើគោក និងក្នុងទឹក ឬ ក្នុងទីណាមួយ ជារបស់អ្នកដទៃ ដោយខ្លួនឯង ។

អាណត្តិក: នោះថា កិរិយាលួចកើតដោយបង្គាប់ គឺភិក្ខុបង្គាប់ឲ្យភិក្ខុដទៃលួច ថាលោកចូរលួចយកវត្ថុនេះ អ្នកបង្គាប់ត្រូវទុក្កដក្នុងខណ:បង្គាប់ អ្នកដែលនឹងលួច សម្គាល់ថាវត្ថុនោះក្តី សម្គាល់ថាវត្ថុដទៃក្តី ហើយលួច

បានតាមបង្គាប់ដូច្នេះ ត្រូវបារាជិកទាំង២នាក់ ទាំងអ្នកលួច ទាំងអ្នកបង្គាប់ បើអ្នកលួចសម្គាល់ថា វត្ថុនោះក្តី សម្គាល់ថា វត្ថុដទៃក្តី ហើយលួចបាន វត្ថុដទៃក្រៅចាកវត្ថុដែលកំណត់នោះ ដូច្នេះ អ្នកបង្គាប់មិនត្រូវបារាជិក ត្រូវតែអ្នកលួច ។ មួយទៀត ដូចភិក្ខុជាអាចារ្យបង្គាប់ពុទ្ធរក្ខិតថា អ្នកចូរ ប្រាប់ធម្មរក្ខិតឲ្យប្រាប់ដល់សង្ឆរក្ខិតឲ្យលួចរបស់ឈ្មោះនេះ ដូច្នេះ ត្រូវ ទុក្កដក្នុងខណៈបង្គាប់ ពុទ្ធរក្ខិតទៅប្រាប់ធម្មរក្ខិត ក៏ត្រូវទុក្កដ ធម្មរក្ខិត ទៅប្រាប់សង្ឆរក្ខិត សង្ឆរក្ខិតទទួលនិងលួច អាចារ្យអ្នកបង្គាប់ដើម ត្រូវថុល្លច្ច័យ សង្ឆរក្ខិតលួចវត្ថុនោះ បានតាមបង្គាប់ ដូច្នេះ ត្រូវបារាជិក ព្រមគ្នាទាំង ៤ នាក់ បើពុទ្ធរក្ខិតរំលងធម្មរក្ខិត ទៅប្រាប់សង្ឆរក្ខិត សង្ឆរក្ខិត ក៏លួចបានតាមកំណត់ដូច្នេះ អាចារ្យអ្នកបង្គាប់ដើមមិនត្រូវ បារាជិក ត្រូវតែពុទ្ធរក្ខិតអ្នកបង្គាប់ និងសង្ឆរក្ខិតអ្នកលួចប៉ុណ្ណោះ ភិក្ខុ បង្គាប់អ្នកដទៃឲ្យលួច ហើយមានវិប្បដិសារៈក្តៅក្រហាយចិត្តហាមឃាត់ ឲ្យបានឮ អ្នកទទួលបង្គាប់មិនស្តាប់ខំចចេសតែលួច ដូច្នេះ អ្នកបង្គាប់មិន ត្រូវបារាជិក ត្រូវតែអ្នកលួច ដូច្នេះ ឈ្មោះថា អាណត្តិកៈ ។

ក៏ឯ និស្សគ្គិយៈ នោះថា លួចដោយកិរិយាបោះចោលវត្ថុនោះទៅ គឺភិក្ខុកំណត់ទីទុកមានទ្វារលែ្ងងជាដើម ថាខាងក្នុងលែ្ងងនេះ បើម្ចាស់គេ ឃើញយើងនឹងធ្វើជាមើលលេង បើម្ចាស់គេមិនឃើញយើងនឹងលួចយក កាលម្ចាស់របស់គេមិនឃើញ ហើយបោះចោលកន្ទងទ្វារលែ្ងងចេញមក

បើវត្ថុនោះនឹងធ្លាក់ហួសអំពីទ្វារលែងទៅបានប្រាកដ និមិត្តតែវត្ថុនោះ របូតផុតអំពីដៃ ត្រូវបារាជិក ។ មួយទៀត ភិក្ខុទៅដល់គយ យកវត្ថុ ដែលត្រូវបង់ថ្លៃគយនោះ ចោះកន្ទងគយទៅ ថាបើវត្ថុនោះនឹងធ្លាក់ទៅ ខាងក្រៅជាប្រាកដ និមិត្តតែរបស់នោះផុតអំពីដៃ ក៏ត្រូវបារាជិក ដូច្នេះ ឈ្មោះថា និស្សគ្គិយ: ។

ក៏ឯ អត្តសាធក: នោះថា ញ្ចាំងអត្តគឺប្រយោជន៍ឲ្យសម្រេចមុនកិរិយា លួច បានដល់ភិក្ខុបង្គាប់ភិក្ខុថា លោកអាចលួចវត្ថុនេះ របស់អ្នក ឯណោះបានក្នុងកាលណា ចូរលួចកាលណោះចុះ ដូច្នេះ បើអ្នកទទួល បង្គាប់នោះមិនមានអន្តរាយក្នុងចន្ទោះគង់នឹងលួចបានប្រាកដ អ្នកបង្គាប់ ក៏ត្រូវបារាជិកក្នុងខណ:បង្គាប់ អ្នកលួចត្រូវបារាជិកក្នុងវេលាដែលលួច ។ មួយទៀត ភិក្ខុយកស្បែកជើងជាដើម ដែលលួមជប់ប្រេងគ្រប់តម្លៃបាន មួយបាទ ដាក់ក្នុងធ្នាំងប្រេងរបស់អ្នកដទៃ និមិត្តតែស្បែកជើងធ្លាក់ ផុតអំពីដៃ ក៏ត្រូវបារាជិក ដូចពោលមកនេះឈ្មោះថា អត្តសាធក: ។

ក៏ឯ ធុរនិក្ខេប: នោះថា សម្រេចជាការលួច ដោយដាក់ធុរ: ដូចភិក្ខុចោទយកទីប្បារជាដើម និងរបស់អ្នកដទៃផ្ញើទុក ម្ចាស់របស់គេ មកទារមិនឲ្យក្តី និងរបស់ដែលខ្ជីគេមក ឬរបស់ជាកណ្ហាទេយ្យ គឺរបស់ ណា ។ ដែលភិក្ខុធ្វើរបស់គេឲ្យបាត់ទៅ មិនសងឲ្យម្ចាស់របស់គេវិញ កាលម្ចាស់របស់មកទារមិនឲ្យ ដូច្នេះ ត្រូវបារាជិក ព្រោះដាក់ធុរ:ព្រមគ្នា

ទាំងសងខាង ដូចបានពោលមកហើយ យ៉ាងនេះឈ្មោះថា ធុរនិក្ខេបៈ ។ ៥ ពួកនេះឈ្មោះថា សាហត្ថិកបញ្ចកៈ ។

ក៏ឯ បុព្វបយោគបញ្ចកៈ នោះថា ពួកនៃកិរិយាលួចមាន ៥ មានប្រយោគមុនជាខាងដើម គឺ បុព្វបយោគ ១ សហបយោគ ១ សំវិធាវហារ ១ សង្កេតកម្ម ១ និមិត្តកម្ម ១ ត្រូវជា ៥ ។

បុព្វបយោគ នោះថា កិរិយាលួចមានប្រយោគមុន បានដល់អាណត្តិកៈ ភិក្ខុបង្គាប់ឲ្យអ្នកដទៃលួចទ្រព្យគេ ដូចពោលមកហើយក្នុងអាណត្តិកៈ ឈ្មោះថាបុព្វបយោគ ព្រោះសេចក្តីបង្គាប់នោះជាប្រយោគមុន អំពីប្រយោគនៃអ្នកដទៃទទួលបង្គាប់និងកាន់យករបស់ទ្រព្យ ។

សហបយោគ នោះថា ជាអវហារ កិរិយាលួចព្រមដោយប្រយោគដែលកាន់យករបស់ បានដល់ភិក្ខុធ្វើរបស់ក្នុងទឹកនិងលើគោកជាដើមឲ្យឃ្វាតចាកទី និងបោះបង្គោលព្រំជាដើម ឲ្យចូលទៅក្នុងទីស្រែចំការរបស់គេដោយខ្លួនឯង ត្រូវបារាជិក ដូច្នេះឈ្មោះថាសហបយោគ ព្រោះសម្រេចកិរិយាលួចព្រមដោយប្រយោគដែលធ្វើរបស់គេឲ្យឃ្វាតចាកទី ។

សំវិធាវហារ នោះថា គឺភិក្ខុលួចជាមួយគ្នាទាំងអស់ ដោយបបួលគ្នាទៅលួច គឺភិក្ខុច្រើនគ្នា បបួលគ្នាទៅលួចវត្ថុណាហើយ សូម្បីតែភិក្ខុមួយអង្គលួចវត្ថុនោះបាន ក៏ត្រូវបារាជិកជាមួយគ្នាទាំងអស់ ។

សង្កេតកម្ម នោះថាធ្វើសង្កេត គឺភិក្ខុបង្គាប់ភិក្ខុដោយកំណត់កាល

មានវេលាព្រឹកជាដើម ថាលោកចូរលួចវត្ថុនេះ វត្ថុនោះ ក្នុងវេលាព្រឹក ហើយអ្នកទទួលបង្គាប់ទៅលួចក្នុងវេលាព្រឹកតាមកំណត់បង្គាប់ ដូច្នេះ ត្រូវបារាជិក ទាំងអ្នកប្រើ ទាំងអ្នកលួច បើអ្នកទទួលបង្គាប់ទៅលួចបាន ក្នុងវេលាដទៃមានវេលាល្ងាចជាដើម ដូច្នេះ ខុសសង្កេត អ្នកប្រើមិនត្រូវ បារាជិក ត្រូវតែអ្នកលួច យ៉ាងនេះឈ្មោះថាសង្កេតកម្ម ព្រោះជាអវហារ ដល់អ្នកប្រើ តាមដែលធ្វើសង្កេត ។

និមិត្តកម្ម នោះថា ធ្វើនិមិត្តក្នុងកិរិយាលួចមានប៉ប្រិចភ្នែកជាដើម បាននឹងកិក្ខុបង្គាប់ថា លោកចូរលួចក្នុងខណៈដែលយើងប៉ប្រិចភ្នែក ឬ ញាក់មុខដូច្នេះ អ្នកលួចក៏លួចក្នុងខណៈប៉ប្រិចភ្នែកនិងញាក់មុខ នៃអ្នក បង្គាប់នោះ ដូច្នេះ ត្រូវបារាជិក ទាំងអ្នកលួច ទាំងអ្នកបង្គាប់ បើអ្នក លួចទៅលួចមុន ឬលួចក្រោយប៉ប្រិចភ្នែក ញាក់មុខនោះ អ្នកបង្គាប់ មិនត្រូវបារាជិក ត្រូវតែអ្នកលួច ដូច្នេះ ឈ្មោះថានិមិត្តកម្ម ព្រោះជា អវហារ ដល់អ្នកធ្វើនិមិត្តឲ្យអ្នកលួច អ្នកលួចត្រូវតាមកំណត់ ៥ ពួក ដូចពោលមកនេះ ឈ្មោះថាបុព្វបយោគបញ្ចកៈ ។

ក៏ឯ ថេយ្យាវហារបញ្ចកៈ នោះថា ពួកនៃកិរិយាលួចមាន ៥ មាន ថេយ្យាវហារជាដើម គឺថេយ្យាវហារ ១ បសយ្ហាវហារ ១ បរិកប្ផាវហារ ១ បដិច្ឆន្នាវហារ ១ កុសាវហារ ១ ត្រូវជា ៥ ។

ថេយ្យាវហារ នោះថា លួចដោយមានសភាពដូចជាចោរ ដូចកិក្ខុ

កាត់ទីតមានជញ្ជាំងជាដើម លបលួចមិនឲ្យម្ចាស់របស់ឃើញ កាន់យកក្តី និងបំបាត់ដោយភ្នែកជញ្ជីងកាច នាឡិកោង និងប្រាក់ស្ពាន់សំណជាដើម ដូច្នេះ ត្រូវបារាជិក ដូចពោលមកនេះឈ្មោះថា ថេយ្យាវហារ ។

ក៏ឯ បសយ្ហាវហារ នោះថា កំហែងលួចយក បាននឹងកិក្ខុកំហែងសង្កត់សង្កិនដណ្តើមរឹបជ្ជន់យករបស់អ្នកដទៃ ដូចចោរជ្ជន់អ្នកស្រុកជាដើម និងកាន់យកសួយសារអាករលើសជាងចំណែកដែលខ្លួនត្រូវបាន ដូចរាជាមាត្យទារយកសួយសារអាករលើសអំពីបញ្ញត្តិក្តី ដូច្នេះ ត្រូវបារាជិក ដូចពោលមកនេះឈ្មោះថា បសយ្ហាវហារ ។

បរិកប្បាវហារ នោះថា លួចយកសម្រេចដោយសេចក្តីកំណត់ បរិកប្បាវហារនេះ មាន ២ គឺ កំណត់របស់ ១ កំណត់ឱកាស ១ ។ កំណត់របស់នោះដូច្នេះ កិក្ខុប្រាថ្នានឹងលួចសំពត់សាដក លបចូលទៅក្នុងលែ្ងងវេលាយប់កំណត់ថា បើជាសំពត់អញនឹងយក បើជាអម្ពោះអញមិនយក ហើយលើកការុងឡើង បើក្នុងការុងនោះជាសំពត់សាដកសោត ត្រូវបារាជិកក្នុងខណៈដែលលើក បើជាអម្ពោះសោតមិនទាន់ត្រូវបារាជិក លុះចេញមកខាងក្រៅស្រាយការុងចេញ មើលដឹងថាជាអម្ពោះហើយ យកទៅទុកដូចដើមវិញ ក៏នៅមិនទាន់ត្រូវបារាជិក សូម្បីដឹងថាជាអម្ពោះហើយ គិតថាអញបានវត្ថុអ្វីក៏យកវត្ថុនោះ ហើយនាំដើរទៅ ឲ្យវិនិច្ឆយធរគប្បីកាត់អាបត្តិ ដោយលើកនូវជំហានទីមួយទីពីរ

បើដាក់ចុះលើផ្ទៃ ហើយត្រឡប់កាន់យកទៀត និមិត្តតែលើកឡើងក៏ត្រូវបារាជិក បើម្ចាស់របស់គេស្រែកថាចោរៗ ហើយគេដេញតាមទៅ ភិក្ខុចោលរបស់ហើយរត់ទៅក៏គង់នៅរក្សាបាន បើម្ចាស់របស់គេឃើញគេកាន់យករបស់គេវិញ ក៏គង់នៅរក្សានៅឡើយ បើមនុស្សដទៃកាន់យកទៅសោត ភិក្ខុនោះត្រូវកណ្ហទេយ្យ លុះម្ចាស់របស់ត្រឡប់ទៅវិញ ភិក្ខុឃើញរបស់នោះ ហើយកាន់យកដោយបង្ស៊ីកូលសញ្ញា ដោយគិតថារបស់នេះយើងកាន់យកអំពីមុនហើយ សម័យនេះជាទ្រព្យរបស់យើង សូម្បីដូច្នេះ ក៏ត្រូវកណ្ហទេយ្យគប្បីសងគេ កំណត់ថាបើសំពត់យើងនឹងយក ដូចពោលមកនេះ ឈ្មោះថាកណ្ហបរិកប្ប គឺកំណត់របស់ ។

ក៏ឯ ឱកាសបរិកប្ប កំណត់ឱកាសនោះ គឺកំណត់ទ្វារល្វែងនិងមុខផ្ទះជាដើម ដូចពោលហើយក្នុងសង្ខេតវិតិនាមនៈនោះ កំណត់វត្ថុ ឬ ឱកាសទាំង ២ ណាមួយហើយលួច ដូចពោលមកនេះឈ្មោះថាបរិកប្ប្ជាវហារ ។

ក៏ឯ បដិច្ឆន្នាវហារ នោះថា បិទបាំងទុកហើយលួចយក ឲ្យគប្បីដឹងដូច្នេះ ភិក្ខុណាឃើញរបស់អ្នកដទៃ មានចិញ្ចៀនជាដើម គេដោះដាក់ទុកក្នុងសួនជាដើម កាន់យកដី ឬ ស្ទឹកឈើបិទបាំងទុកដោយគិតថាគ្រាក្រោយអញនឹងកាន់យក ប៉ុណ្ណោះនៅមិនទាន់ឈ្មោះថាលើកឡើង

ព្រោះហេតុនោះ នៅមិនទាន់ចូលជាអវហារនៅឡើយ កាលណាបើម្ចាស់គេមករកមិនឃើញ ហើយគេមានអាល័យនៅគិតថា ព្រឹកនេះសឹមយើងនឹងដឹង ហើយត្រឡប់ទៅផ្ទះ គ្រានោះ ភិក្ខុមកលើកយករបស់នោះឡើង និមិត្តតែលើកឡើង ក៏ជាអវហារ បើភិក្ខុនោះកាន់យកដោយសកសញ្ញាសម្គាល់ថា របស់នោះជារបស់យើង យើងបានបិទបាំងទុកហើយ ឬ កាន់យកដោយបង្ហុកូលសញ្ញាសម្គាល់ថា ម្ចាស់របស់ទៅហើយ គេចោលរបស់នេះហើយ យ៉ាងនេះជាកណ្ហាទេយ្យ សូម្បីក្នុងថ្ងៃគម្រប់ ២ ម្ចាស់របស់មកគន់រកមិនឃើញ គេដាក់ធុរៈហើយត្រឡប់ទៅ ភិក្ខុមកកាន់យក ក៏ត្រូវកណ្ហាទេយ្យ គ្រាក្រោយម្ចាស់ដឹងគេមកទារ ភិក្ខុមិនឲ្យ ម្ចាស់របស់ដាក់ធុរៈកាលណា ក៏ជាអវហារដល់ភិក្ខុកាលណោះ ព្រោះថារបស់នោះម្ចាស់របស់រកមិនឃើញ ដោយប្រយោគនៃភិក្ខុ ។ ក៏ឯភិក្ខុមិនបានបិទបាំងដូច្នោះ របស់ទុកនៅតាមទីឋាន ភិក្ខុមានចេយ្យចិត្តយកជើងជាន់ទុកឲ្យលិចចុះទៅ ក្នុងភក់ឬក្នុងខ្សាច់ក្តី និមិត្តតែរបស់លិចចុះទៅ ផុតចាកទីដើមក៏ជាអវហារ ដូចពោលមកនេះ ឈ្មោះថាបដិច្ចន្ទ្ធាវហារ ។

ក៏ឯ កុសាវហារ នោះថា កិរិយាលួចដោយប្ជូរស្ងាត ឲ្យគប្ជីដឹងដោយន័យនេះ ភិក្ខុណាឃើញស្ងាតគេធ្វើនឹងបន្ទោះឫស្សី ឬស្ទឹកត្នោតគេសរសេរឈ្មោះភិក្ខុទុកហើយដាក់លើសំពត់ជាចំណែកៗ ចែកគ្នា ភិក្ខុប្រាថ្នា

នឹងលើកយកចំណែករបស់អ្នកដទៃ ដែលមានតម្លៃតិចនិងតម្លៃច្រើនឬ មានតម្លៃស្មើគ្នា ដែលទុកនៅជិតចំណែករបស់ខ្លួន ក៏ក្ដុលើកស្វាករបស់ខ្លួនឡើង ដោយប្រាថ្នានឹងដាក់ក្នុងចំណែកនៃអ្នកដទៃ ក៏នៅរក្សានៅឡើយ ដាក់ស្វាករបស់ខ្លួនចុះក្នុងចំណែកអ្នកដទៃ ក៏នៅរក្សានៅឡើយ លុះខណៈលើកស្វាករបស់អ្នកដទៃឡើងចាកចំណែកអ្នកដទៃ និមិត្តតែលើកក៏ជាអវហារ ថាបើកិក្ខុលើកស្វាកចំណែកនៃអ្នកដទៃមុន ដោយប្រាថ្នានឹងដាក់ក្នុងចំណែករបស់ខ្លួន កាលដែលលើកឡើងក៏នៅរក្សានៅឡើយ កាលដាក់ចុះក៏នៅរក្សានៅឡើយ លុះលើកស្វាករបស់ខ្លួនចាកចំណែករបស់ខ្លួន កាលលើកឡើងក៏នៅរក្សានៅឡើយ លុះតែលើកឡើងហើយដាក់ស្វាករបស់ខ្លួនចុះក្នុងចំណែកនៃអ្នកដទៃកាលណា និមិត្តតែផុតអំពីដៃក៏ជាអវហារ អាការដែលលួចយ៉ាងនេះ ឯង ឈ្មោះថាកុសាវហារ ៥ ពួកនេះឈ្មោះថា ថេយ្យាវហារបញ្ចក: ក្នុងបញ្ចក:ទាំង ៥ នេះ ក្នុងបញ្ចក:នីមួយៗ មានអាការ:នៃការលួច ៥ ៗ ទើបត្រូវជាអវហារ ២៥ ដោយពិស្តារតាមអដ្ឋកថា ។

ក៏ឯ នានាកណ្ដាបញ្ចក: និងឯកកណ្ដាបញ្ចក:មិនបានប្លែកអំពីគ្នា បើលើកយកឯកកណ្ដាបញ្ចក:ចេញ គង់សល់នៅតែអវហារ ២០ ។

មួយទៀត សហបយោគនិងសាហត្ថិកបយោគ បុព្វបយោគនិងអាណត្ថិកបយោគក៏មិនប្លែកគ្នា បើផ្សំជាមួយគ្នាគង់សល់អវហារ ១៨ ។

មួយទៀត អាទិយនៈ និងអវហារណៈនិងធុរនិក្ខេបៈក៏មិនប្លែកអំពីគ្នា បើលើកធុរនិក្ខេបៈចេញ គង់សល់នៅអវហារ ១៧ ថាបើទុកធុរនិក្ខេបៈ លើកអាទិយនៈ និងអវហារណៈចេញ សល់នៅអវហារ ១៦ ។

មួយទៀត ភិក្ខុគិតនឹងទៅលួចទ្រព្យរបស់អ្នកដទៃ ក្នុងបុព្វបយោគ ទាំងពួង តាំងអំពីដើរទៅជាដើម ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ ចាប់បបោសអង្ផែលក៏ត្រូវទុក្កដ ធ្វើទ្រព្យដែលជាវត្ថុនៃបារាជិកឲ្យកម្រើក ត្រូវថុល្លច្ច័យ លុះលួចយកទ្រព្យ ១ មាសក ឬថយជាង ១ មាសក ត្រូវទុក្កដ បើទ្រព្យលើសជាង ១ មាសកឡើងទៅ ថយអំពី ៥ មាសក ចុះមក ត្រូវថុល្លច្ច័យ បើទ្រព្យនោះគ្រប់ ៥ មាសក ឬលើសជាង ៥ មាសកឡើងទៅ ត្រូវបារាជិក ។

មួយទៀត អទិន្នាទានសិក្ខាបទនេះល្អិតសុខុមណាស់ ព្រះអដ្ឋកថា-ចារ្យវិនិច្ឆ័យទុកដោយន័យវិចិត្រផ្សេងៗ ក្នុងគម្ពីរសមន្តបាសាទិកា ដែល ពោលមកនេះដោយសង្ខេប ហើយលោកប្រដៅទុកថា ជាសិក្ខាបទ ល្អិតសុខុមកម្រនឹងកាត់សេចក្ដីបាន ព្រោះហេតុនោះ កាលបើមាន គេមកចោទភិក្ខុដោយអទិន្នាទាន សូម្បីវិនិយធរសាកសួរដោយអវហារ ប្រកេទទៅ បើឃើញថាជាអវហារហើយ ក៏កុំអាលកាត់សេចក្ដីដោយ ប្រញាប់ពេក គប្បីសាកសួរដោយទី ៥ ស្ថាន គឺវត្ថុ ១ កាល ១ ប្រទេស ១ អគ្ឃៈ ១ បរិភោគ ១ ដូច្នេះជាមុនសិន ។

វត្ថុនោះ គឺ របស់ដែលភិក្ខុលួចមក ឲ្យសាកសួរមើលថា វត្ថុនោះ មានម្ចាស់របស់ ឬ មិនមាន ថាបើមានម្ចាស់របស់ ក្នុងវេលាដែលលួចមកនោះ ម្ចាស់របស់មានអាល័យ ឬ កាត់អាល័យហើយ បើម្ចាស់របស់នៅមានអាល័យឲ្យកាត់តាមតម្លៃរបស់ បើម្ចាស់របស់កាត់អាល័យហើយ កុំគប្បីកាត់អាបត្តិបារាជិក កាលម្ចាស់របស់ទារយកក៏គប្បីប្រគល់ឲ្យទៅ ដូច្នេះ ជាសេចក្តីគាប់ប្រសើរ នេះឯងឈ្មោះថា សាកសួរវត្ថុ ។ កាលនោះ គឺសម័យដែលលួចរបស់នោះមក ដ្ឋិតថារបស់នោះ មានកាលខ្លះមានតម្លៃស្មើ កាលខ្លះមានតម្លៃច្រើន ។

ក៏ឯប្រទេសនោះ គឺ ទីឋានដែលភិក្ខុលួចរបស់នោះមក របស់លួចមកក្នុងប្រទេសណា ឲ្យកាត់តម្លៃ ក្នុងប្រទេសនោះ ។ អគ្ឆ:នោះ គឺ តម្លៃរបស់ដែលលួចមក របស់ថ្មី លុះគ្រាក្រោយចាស់ហើយក៏ថយតម្លៃ ។ បរិភោគនោះ គឺរបស់នោះ បរិភោគប្រើប្រាស់ហើយ ឬ នៅបើរបស់នោះគេបរិភោគប្រើប្រាស់ហើយ ក៏ថយតម្លៃ ក៏ឯ ទី ៥ ស្ថាននោះ គប្បីឲ្យសាកសួរមើល ។

ឯវិធីដែលមិនត្រូវបារាជិកាបត្តិក្នុងសិក្ខាបទនេះ គឺភិក្ខុសម្គាល់ថាជាទ្រព្យរបស់ខ្លួនហើយកាន់យក ១ និងកាន់យកដោយវិស្សាស:ស្និទ្ធស្នាលគ្នា ១ ខ្ចីមកប្រើប្រាស់ ១ របស់នោះជារបស់យក្ខ ប្រេត ឬជារបស់សត្វតិរច្ឆានមិនមែនរបស់មនុស្ស ១ កាន់យកដោយបង្ករកូលសញ្ញា

សម្គាល់ថាមិនមានម្ចាស់របស់ ១ និងកិក្ខុធ្ងួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។

សិក្ខាបទនេះជាសាណត្តិក: ព្រោះប្រើអ្នកដទៃឲ្យលួចក៏ត្រូវអាបត្តិ មានអង្គ ៥ គឺ **អញ្ញស្ស មនុស្សជាតិកស្ស រសេន បរបរិក្ខហិតំ** *ទ្រព្យអ្នកដទៃជាមនុស្សជាតិហួងហែង ១* **បរបរិក្ខហិតសញ្ញិតា** *សម្គាល់ថាជារបស់អ្នកដទៃហួងហែងរក្សា ១* **ករុបរិក្ខារោ** *របស់នោះ តម្លៃមួយបាទ ឬតម្លៃលើសជាងមួយបាទឡើងទៅ ១* **ថេយ្យចិត្តំ** *ចិត្ត ក្លែងគិតលួច ១* **រុត្តប្ឍការានំ អវហារានំ រសេន អវហារណំ** *លួចបានមកដោយអវហារណាមួយ ដូចពោលមកហើយ ១ ព្រមដោយ អង្គ ៥ នេះទើបត្រូវបារាជិក ។ មួយទៀត សិក្ខាបទនេះ មានសមុដ្ឋាន ៣ ឈ្មោះអទិន្នាទាន សមុដ្ឋាន គឺ អាបត្តិកើតអំពីកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តក: លោកវជ្ជ: កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា ៣ ។*

ទុតិយបារាជិក ចប់

មនុស្សវិគ្គហសិក្ខាបទ គម្រប់ ៣ សេចក្តីថា កិក្ខុណាក្លែងដាក់បង់ នូវរាងកាយនៃមនុស្ស តាំងអំពីបឋមវិញ្ញាណតាំងចុះ កើតជាកលលរូប ក្នុងគភ៌មាតាឲ្យដាច់ចាកជីវិត គឺសម្ងាប់ឲ្យស្លាប់ សូម្បីប្រកបថ្នាំក្តៅ និងជាន់ច្រចាប់ជាដើម ឬតម្កល់គ្រឿងសស្ត្រាវុធផ្សេង ៗ ទុកដើម្បី

នឹងប្រហារជីវិតមនុស្ស ឬពណ៌នាសរសើរសេចក្ដីស្លាប់ថា អ្នកមានប្រយោជន៍អ្វី ដោយសេចក្ដីរស់នៅអាក្រក់លាមក មិនស្មើមុខនឹងគេស្លាប់ទៅប្រសើរជាជាង ស្លាប់ហើយនឹងបានទៅសុគតិ ឬប្រាប់ឧបាយឲ្យស្លាប់ គឺបង្គាប់ថាអ្នកចូរចាក់ក ចូរលេបថ្នាំពិសជាដើម បើកិក្ខុមានសេចក្ដីប្រាថ្នានឹងឲ្យស្លាប់ហើយធ្វើឧបាយផ្សេង ៗ ដើម្បីនឹងឲ្យគេស្លាប់ដូចសម្ដែងមកនេះ មនុស្សនោះស្លាប់ក្នុងខណៈនោះ ឬយូរទៅទើបស្លាប់ដោយហេតុនោះក្ដី កិក្ខុនោះក៏ត្រូវបារាជិក ។ មនុស្សជាវត្ថុនៃបាចិត្តិយ ។ អមនុស្សគឺ យក្ខ ប្រេត ជាវត្ថុនៃថុល្លច្ច័យ ។ តិរច្ឆានជាវត្ថុនៃបាចិត្តិយ ។

ក៏ឯប្រយោគនៃបាណាតិបាត មាន ៦ គឺ សាហត្ថិកបយោគ ១ និស្សគ្គិយបយោគ ១ អាណត្តិកបយោគ ១ ថាវរបយោគ ១ វិជ្ជ-មយបយោគ ១ ឥទ្ធិមយបយោគ ១ ដូច្នេះ ។

សាហត្ថិកបយោគនោះថា ប្រកបសេចក្ដីព្យាយាមនឹងសម្ងាប់សត្វដ៏មានជីវិតដោយដៃខ្លួនឯង គឺកិក្ខុប្រាថ្នានឹងសម្ងាប់សត្វដោយខ្លួនឯង នឹងប្រហារដោយកាយមានដៃនិងជើងជាដើម ឬវត្ថុជាប់ដោយកាយ មានដាវលំពែងជាដើម ឈ្មោះថាសាហត្ថិកបយោគ ជាប្រយោគធ្វើឲ្យគេស្លាប់ដោយដៃខ្លួនឯង ។

និស្សគ្គិយបយោគនោះថា ប្រកបដោយកិរិយាគឺបោះពួយទៅបាននឹងកិក្ខុមានបំណងនឹងឲ្យអ្នកដែលនៅឆ្ងាយស្លាប់ ហើយបាញ់ ពួយ

គ្រវែង ចោលទៅ នូវសស្ត្រាវុធមាន ធ្នូ ស្នា និងលំពែង យន្ត ដុំសិលា ជាដើម ដោយកាយ ឬវត្ថុជាប់ដោយកាយ ឈ្មោះថានិស្សគ្គិយបយោគ ជាប្រយោគធ្វើឲ្យគេស្លាប់ដោយគ្រវែង បោះ ពួយ ។

ក្នុងសាហត្ថិកនិងនិស្សគ្គិយបយោគទាំង ២ នេះ ចាត់ជាពីរ ។ គឺ ចំពោះនិងមិនចំពោះ ចំពោះនោះ បានន៏ងភិក្ខុចំពោះអ្នកណា ហើយ ប្រហារខ្លួនឯងក្តី ឬបោះគ្រវែងទៅក្តី ត្រូវអ្នកនោះស្លាប់ ក៏ជាកម្មពន្ធ គ្រឿងចងគឺកម្មតាមវត្ថុនោះ បើត្រូវអ្នកដទៃស្លាប់មិនជាកម្មពន្ធ ព្រោះ ថាចំពោះមនុស្សណា ត្រូវមនុស្សនោះស្លាប់ ទើបត្រូវបារាជិក ។ បើ ត្រូវមនុស្សដទៃ ឬ អមនុស្សនិងតិរច្ឆាន មិនត្រូវអាបត្តិ ។ បើចំពោះ អមនុស្សនិងតិរច្ឆាន ហើយអមនុស្សនិងតិរច្ឆាននោះស្លាប់ ត្រូវថុល្លច្ច័យ និងបាចិត្តិយតាមវត្ថុ ។ បើត្រូវមនុស្ស ឬអមនុស្ស ឬតិរច្ឆានដទៃស្លាប់ មិនត្រូវអាបត្តិ ។ មិនចំពោះនោះគឺ ភិក្ខុមិនចំពោះ ដោយគិតថា ទោះនរណា ។ ក៏ដោយ ក៏ចូរស្លាប់ចុះ ហើយប្រហារឬបោះពួយទៅ បើត្រូវព្រះអរហន្ត ឬ មាតាបិតានៃខ្លួនស្លាប់ ជាអនន្តរិយកម្មផង ជា បារាជិកផង បើត្រូវអមនុស្ស ឬ យក្ខ ប្រេត សត្វតិរច្ឆាន ស្លាប់ ត្រូវ អាបត្តិតាមវត្ថុនោះ ។ ក្នុងប្រយោគដែលចំពោះនិងមិនចំពោះ ២ នេះ អ្នកដែលភិក្ខុប្រហារនោះស្លាប់ក្នុងខណៈនោះ ឬមួយស្លាប់ខាងក្រោយ ដោយរោគនោះក្តី ជាកម្មពន្ធដល់ភិក្ខុអ្នកប្រហារក្នុងខណៈប្រហារនោះ ។

ឯអាណត្តិកបយោគនោះ ថាប្រយោគកើតអំពីបង្គាប់ គឺកិក្ខុបង្គាប់អ្នកដទៃថា "អ្នកចូរសម្ងាប់បុគ្គលនេះ ។" ដូច្នេះ ក្នុងប្រយោគនេះ ឲ្យគប្បីដឹងដោយនិយម ៦ យ៉ាងគឺ និយមវត្ថុ ១ និយមកាល ១ និយមឱកាស ១ និយមអាវុធ ១ និយមឥរិយាបថ ១ និយមកិរិយាវិសេស ១ ។ និយមវត្ថុនោះគឺកំណត់បុគ្គលដែលនឹងសម្ងាប់ គឺកំណត់បុគ្គលណា ហើយបង្គាប់ឲ្យសម្ងាប់បុគ្គលនោះ អ្នកទទួលបង្គាប់សម្ងាប់អ្នកនោះស្ងាប់ ត្រូវអាបត្តិទាំងអ្នកបង្គាប់ទាំងអ្នកសម្ងាប់ បើអ្នកសម្ងាប់ ទៅសម្ងាប់បុគ្គលដទៃ ដោយសម្គាល់ថាបុគ្គលនោះ អ្នកបង្គាប់រួចទោស ។ និយមកាលនោះ គឺកំណត់កាលមានវេលាព្រឹកជាដើម អ្នកសម្ងាប់ ទៅសម្ងាប់ក្នុងវេលាដទៃ មានវេលាល្ងាចជាដើម ដូច្នេះខុសសង្កេត ។ និយមឱកាសនោះគឺកំណត់ទី ឲ្យសម្ងាប់មនុស្សនៅក្នុងស្រុក ក្នុងវានជាដើម អ្នកសម្ងាប់ទៅសម្ងាប់ក្នុងទីដទៃ មានផ្ទះនិងក្រៅភូមិជាដើម ក៏ខុសសង្កេត ។ និយមអាវុធនោះគឺកំណត់អាវុធ ឲ្យសម្ងាប់ដោយដាវ លំពែង អ្នកសម្ងាប់ទៅសម្ងាប់ដោយអាវុធដទៃ ។ មានស្នូនិងឈើសម្រួចជាដើម ក៏ខុសសង្កេត ។ និយមឥរិយាបថនោះគឺកំណត់ឥរិយាបថ ឲ្យសម្ងាប់មនុស្សឈរ មនុស្សដើរ អ្នកសម្ងាប់ ទៅសម្ងាប់មនុស្សអង្គុយ មនុស្សដេក ក៏ខុសសង្កេត ។ និយមកិរិយាវិសេសនោះ គឺកំណត់ការធ្វើពិសេស ឲ្យសម្ងាប់ដោយចាក់ ឬកាប់ អ្នកសម្ងាប់ទៅសម្ងាប់ដោយកិរិយាដទៃ មានវាយ ឬអារកជាដើម

ក៏ខុសសង្កេត ។ ពាក្យដែលពោលថាខុសសង្កេតនោះ អ្នកបង្ហាប់មិនត្រូវអាបត្តិ ត្រូវតែអ្នកសម្ងាប់ បើត្រូវតាមសង្កេត ក៏ត្រូវអាបត្តិទាំង ២ នាក់ ។ មួយទៀត បើអ្នកទទួលបង្ហាប់នោះ ទៅសម្ងាប់មិនបាន ហើយត្រឡប់មកប្រាប់ដល់អ្នកបង្ហាប់ អ្នកបង្ហាប់ត្រឡប់បង្ហាប់ថែមជាថ្មីទៀតថា "បើអ្នកអាចសម្ងាប់បានកាលណា ចូរសម្ងាប់កាលណោះចុះ" ដូច្នេះ សូម្បីយូរដល់រាប់រយឆ្នាំក្តី អ្នកសម្ងាប់គង់នឹងសម្ងាប់បានប្រាកដ អ្នកបង្ហាប់ត្រូវអាបត្តិក្នុងខណៈបង្ហាប់ អ្នកសម្ងាប់ត្រូវអាបត្តិក្នុងខណៈសម្ងាប់ ។

ឯថាវរបយោគនោះថា ប្រយោគខ្ជាប់ខ្ជួន គឺភិក្ខុនឹងសម្ងាប់អ្នកដទៃដោយគ្រឿងសម្ងាប់ដ៏ខ្ជាប់ខ្ជួន បាននឹងជីកអណ្តូង ជីកអន្ទុង និងគ្រឿងយន្ត និងតម្កល់គ្រឿងសស្ត្រាវុធមាន ដាវ លំពែង ជាដើមទុក និងលាយថ្នាំពិសក្នុងបឹងនិងស្រះ ទាំងអម្បាលនេះជាដើម ដើម្បីនឹងឲ្យអ្នកដទៃដើរមកជ្រាក់ស្ងាប់ ត្រូវស្ងាប់ ក្រេបផឹកស្ងាប់ ឬនាំយក រូប សំឡេង ក្លិន រស សម្ផស្ស ធម្មារម្មណ៍ ដែលគួរស្រឡាញ់ គួរខ្ជាប ដើម្បីនឹងឲ្យអ្នកដទៃរីងស្ងួត ឬកំយតក់ស្ងួតស្ងាប់ ឬដាក់អន្ទាក់និងអង្គប់ទុក អម្បាលនេះឈ្មោះថា ថាវរបយោគ ។

មួយទៀត ភិក្ខុសរសេរសំបុត្រពណ៌នាសេចក្តីស្ងាប់ថា "អ្នកណាស្ងាប់ យ៉ាងនេះ។ នឹងបានលាភ បានយស បានទៅសុគតិ" ក៏ពាប់បញ្ជូលក្នុងថាវរបយោគ ។ ក្នុងថាវរបយោគនេះ ភិក្ខុចំពោះអ្នកណា បើ

អ្នកនោះស្លាប់ ក៏ត្រូវអាបត្តិតាមវត្ថុនោះ បើអ្នកដទៃស្លាប់មិនត្រូវអាបត្តិ ។ បើភិក្ខុមិនចំពោះ គឺ គិតថានរណាៗ ក៏ចូរស្លាប់ចុះ ដូច្នេះ ក៏ត្រូវកម្មពន្ធ តាមវត្ថុដែលស្លាប់ គឺព្រះអរហន្ត ឬមាតាបិតានៃភិក្ខុនោះស្លាប់ ក៏ត្រូវ អនន្តរិយកម្មផង ត្រូវបារាជិកផង បើមនុស្សដទៃ និងយក្ខ ប្រេត តិរច្ឆាន ស្លាប់ ក៏ត្រូវបារាជិក ថុល្លច្ច័យ បាចិត្តិយ តាមវត្ថុនោះៗ ។ ត្រឿង ដែលជា ថាវរបយោគនេះ ដូចអន្ទាក់ និងសំបុត្រជាដើម អន្ទាក់ និង សំបុត្រ ភិក្ខុឲ្យទៅគេទទេ ឬលក់ឲ្យគេ អ្នកដែលបានយកទៅតាក់តែង ចាត់ចែងជាថ្មី ក៏ត្រូវទោសទាំង ២ នាក់ បើភិក្ខុមានចិត្តក្តៅក្រហាយ នឹងបាប ថាសត្វស្លាប់ជាច្រើនណាស់ យកមកអំពីទីណា ក៏យកទៅទុក ដូចដើម ទើបរួចទោស បើគេទិញទៅ ក៏យកថ្លៃទៅទិញយកមកវិញ ទើបរួចទោស បើអន្ទាក់ភិក្ខុធ្វើឯង សំបុត្រភិក្ខុសរសេរឯង យកមកដុត ភ្លើងឲ្យអស់ ទើបរួចទោស បើដងអន្ទាក់ភ្លើងឆេះមិនអស់ អ្នកដទៃមក កាន់យកទៅប្រហារអ្នកដទៃស្លាប់ ម្ចាស់ដើមក៏មិនរួចទោស សំបុត្រ ភ្លើងឆេះមិនអស់ អ្នកណាមួយយកមករៀបផ្ទុំមើលដឹងសេចក្តីហើយ ស្លាប់តាមសំបុត្រនោះ ម្ចាស់សំបុត្រដើមក៏មិនរួចទោស ។

ឯវិជ្ជាមយបយោគនោះថា ប្រយោគដ៏ហើយដោយវិជ្ជា គឺ ភិក្ខុពាយ មន្ត អាគមផ្សេងៗ និងប្រើអំណាច ភូត បិសាច ណាៗ ក្តី ធ្វើឲ្យអ្នកដទៃ ចុកសៀតស្លាប់ ដូច្នេះឈ្មោះថាវិជ្ជាមយបយោគ ចំពោះអ្នកណា អ្នក

នោះស្ងាប់ មិនខុសសង្ដេតមិនរួចទោស បើអ្នកដទៃស្ងាប់ ខុសសង្ដេតរួចទោស បើមិនចំពោះ ត្រូវអាបត្តិតាមវត្ថុដែលស្ងាប់នោះ ។

ឯឥទ្ធិមយបយោគនោះថា ប្រយោគសម្រេចដោយឫទ្ធិដែលកើតអំពីកម្ម ដូចឫទ្ធិនាគ ឫទ្ធិគ្រុឌ ឫទ្ធិយក្ខ ឫទ្ធិទេវតា ឫទ្ធិព្រះរាជា បើកិក្ខុមានភ្នែកជាអាវុធ ខឹងសំឡឹងមើលអ្នកណា ដោយបំណងនឹងឲ្យស្ងាប់ បើអ្នកនោះស្ងាប់ត្រូវអាបត្តិ ដោយឥទ្ធិមយបយោគ ។

មួយទៀត កិក្ខុជីកអណ្ដូងជាដើម ដើម្បីនឹងឲ្យសត្វធ្លាក់ស្ងាប់ ក្នុងប្រយោគដែលជីកនោះ មិនត្រូវបាចិត្តិយ ត្រូវតែទុក្កដគ្រប់ៗ ប្រយោគព្រោះជាបុព្វបយោគនៃបាណាតិបាត បើជីកមិនចំពោះ សត្វណាៗ មកធ្លាក់ចុះ ក៏គង់ត្រូវទុក្កដ បើ យក្ខ ប្រេត មានកាយជាតិរច្ឆានងិងអមនុស្ស ឬតិរច្ឆានមានកាយជាមនុស្ស ឬសត្វតិរច្ឆានក្ដី ធ្លាក់ចុះកើតទុក្ខវេទនា ក៏ត្រូវទុក្កដ បើមនុស្សធ្លាក់ចុះកើតទុក្ខវេទនា ក៏ត្រូវថុល្លច្ច័យ បើយក្ខជាដើមធ្លាក់ស្ងាប់ ក៏ត្រូវថុល្លច្ច័យ បើមនុស្សធ្លាក់ស្ងាប់ ត្រូវបារាជិក ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺកិក្ខុមិនក្ងែងនឹងឲ្យស្ងាប់ ដូចអង្ក្រៃពីរផ្ដែកជិតគ្នា កិក្ខុចាប់យកអង្ក្រៃ ១ អង្ក្រៃ ១ រលំសង្ដត់ទារកស្ងាប់ មិនត្រូវអាបត្តិ កិក្ខុមិនដឹងថាគេនឹងស្ងាប់ដោយហេតុនេះ ដូចកិក្ខុឲ្យបិណ្ឌ-បាត្រលាយដោយថ្នាំពិសដល់កិក្ខុដទៃធាន់ កិក្ខុអ្នកធាន់នោះស្ងាប់ មិនត្រូវអាបត្តិ កិក្ខុមិនមានចិត្តបំណងនឹងឲ្យស្ងាប់ ដូចឲ្យកេសជ្ជ:ដល់អ្នក

ដទៃបរិភោគស្ងាប់ មិនត្រូវអាបត្តិ និងកិក្ខុធ្លួតជាដើម មិនត្រូវអាបត្តិ សិក្ខាបទនេះជាសាណត្តិក: ត្រូវព្រោះបង្ហាប់មានអង្គ ៥ គឺ **មនុស្ស-ជាតិកប្បាណោ** សត្វមានជាតិជាមនុស្ស ១ **ចាណសញ្ញិតា** ដឹងថាសត្វមានជីវិត ១ **វធកចិត្តំ** ចិត្តបំណងនឹងសម្ងាប់ ១ **ឧបក្កមោ** ព្យាយាមដោយប្រយោគទាំង ៦ ណាមួយ ១ **តេន មរណំ** សត្វនោះ ស្ងាប់ដោយព្យាយាម ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវបារាជិក ។ សិក្ខាបទនេះជាអទិន្នាទានសមុដ្ឋាន ជាកិរិយា សញ្ញាវិមោក្ខ សចិត្តក: លោកវជ្ជ: កាយកម្ម វចីកម្ម អកុសលចិត្ត ទុក្ខវេទនា ។

ततियपाराजिक ចប់

ឧត្តរិមនុស្សធម្មសិក្ខាបទ គម្រប់ ៤ សេចក្តីថា ភិក្ខុណាមិនបានត្រាស់ដឹងឡើយ តែជាមនុស្សប្រាថ្នាលាភ ប្រាថ្នាសេចក្តីសរសើរ ហើយពោលអួតឧត្តរិមនុស្សធម្ម ដែលជាគ្រឿងអាចដឹងឃើញនៃព្រះអរិយ:ជាម្ចាស់ បង្ហោនចូលមកក្នុងខ្លួនដោយពាក្យកុហកថា "យើងដឹង យើងឃើញឧត្តរិមនុស្សធម្មដូច្នេះ" ដោយកាយ ឬ វាចា ឬ ទាំងកាយវាចា ដល់អ្នកដទៃជាមនុស្សជាតិ គេដឹងសេចក្តីក្នុងខណ:នោះ ត្រាក្រោយមានគេសាកសួរក្តី មិនមានគេសាកសួរក្តី ភិក្ខុនោះក៏ត្រូវបារាជិក ក្នុងខណ:អួតនោះ សូម្បីប្រាថ្នាសេចក្តីបរិសុទ្ធ គឺសឹកជាគ្រហស្ថជាដើម

ហើយនឹងត្រឡប់ប្តេជ្ញាថា "ខ្ញុំមិនដឹង មិនឃើញទេ ក្លែងនិយាយថា ដឹង ថាឃើញ ខ្ញុំនិយាយកុហកបញ្ឆោតទេ" ដូច្នេះក៏មិនរួចទោស រៀងតែសម្គាល់ថាខ្លួនបានឧត្តរិមនុស្សធម្មនោះ ហើយពោលតាមសម្គាល់នោះ មិនត្រូវអាបត្តិ ។

ឧត្តរិមនុស្សធម្មនោះ ជាធម៌នៃមនុស្សដ៏លើសលុប គឺមហគ្គតធម៌ និងលោកុត្តរធម៌ ។ រូបាវចរជ្ឈាន ៤ គឺ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន អរូបាវចរជ្ឈាន ៤ គឺ អាកាសានញ្ចាយតនជ្ឈាន វិញ្ញាណញ្ចាយតនជ្ឈាន អាកិញ្ចញ្ញាយតនជ្ឈាន នេវសញ្ញានាសញ្ញា-យតនជ្ឈាន និងវិជ្ជា ៦ គឺ មនោមយិទ្ធិញ្ញាណ ការដឹងឫទ្ធិសម្រេចដោយចិត្ត គឺនិមិត្តកាយដទៃចេញចាកកាយខ្លួន ឥទ្ធិវិធិញ្ញាណ ការដឹងផ្ទែងឫទ្ធិផ្សេងៗ ទិព្វសោតញ្ញាណ ការដឹងដោយត្រចៀកទិព្វ ចេតោ-បរិយញ្ញាណ ការដឹងកំណត់ចិត្តអ្នកដទៃ បុព្វេនិវាសញ្ញាណ ការដឹងជាតិក្នុងកាលមុន ចុតូបបាតញ្ញាណ ការដឹងនូវចុតិ និងបដិសន្ធិនៃសត្វ អម្បាលនេះជាមហគ្គតធម៌ ។ សោតាបត្តិមគ្គ សោតាបត្តិផល សកទា-គាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផល ព្រះនិព្វាន អម្បាលនេះ ជាលោកុត្តរធម៌ ។ វិមោក្ខ ៣ គឺសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ សមាធិ ៣ គឺ សុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ មគ្គភាវនា ៣៧ គឺ

សតិបដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល: ៥ ពោជ្ឌង្គ ៧ មគ្គមានអង្គ ៨ ក្តី បហាន: ៣ គឺ លះរាគ: លះទោស: លះមោហ: វិនិវរណតា ៣ គឺ ចិត្តប្រាសចាករាគ: ទោស: មោហ: និងវិជ្ជាគម្រប់ ៣ គឺ អាសវក្ខយញាណ ទាំងអស់រាប់បញ្ចូលក្នុងមគ្គ ។ សមាបត្តិ ៣ គឺ សញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិតសមាបត្តិ អម្បាលនេះជាឈ្មោះនៃផល ។ មហគ្គតធម៌ និងលោកុត្តរធម៌ ទាំងអម្បាលនេះ ឈ្មោះថា ឧត្តរិមនុស្សធម្ម ដ្បិតថាអ្នកណាបាន អ្នកនោះ ឈ្មោះថាប្រសើរជាងសាមញ្ញជន ឧត្តរិមនុស្សធម្មនេះ មិនមានក្នុងខ្លួនកិក្ខុពោលថា យើងបានដល់បឋមជ្ឈានជាដើមក្តី យើងបានឥទ្ធិវិធិញាណ ជាដើមក្តី និងពោលថាយើងបានសោតាបត្តិមគ្គ សោតាបត្តិផល ជាដើមក្តី យើងបានមគ្គ បានផល យើងជាព្រះសោតាបន្ន ជាដើមក្តី យើងជាព្រះអរិយ: យើងលះរាគ:បានហើយជាដើមក្តី ពោលអួតឧត្តរិមនុស្សធម្មដូច្នេះ ដោយកាយ ឬវាចា កាលនឹងពោលក៏ដឹងថាខ្លួននឹងពោលកុហក កាលកំពុងពោល ក៏ដឹងថាខ្លួនកំពុងពោលកុហក ពោលអួតដល់អ្នកណា អ្នកនោះជាមនុស្ស ជាបព្វជិតក្តី ជាគ្រហស្ថក្តី ជាស្ត្រីក្តី ជាបុរសក្តី តែគេដឹងសេចក្តីក្នុងខណ:នោះ ថាលោកបានឈាន បានមគ្គ បានផល ជាដើម គេជឿថាពិតក្តី ថាមិនពិតក្តី កិក្ខុនោះត្រូវបារាជិក បើអ្នកស្តាប់មិនដឹងដំណើរសេចក្តី កិក្ខុនោះ

ត្រូវបុល្លច្ច័យ បើអាស្រ័យខ្លួន តែពោលអាងអ្នកដទៃថា អ្នកណានៅ ក្នុងវិហារ អ្នកនោះបានបឋមជ្ឈានជាដើម អ្នកស្តាប់ដឹងសេចក្តីក្នុងខណៈ នោះ ភិក្ខុនោះត្រូវបុល្លច្ច័យ អ្នកស្តាប់មិនដឹងត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិក្នុងសិក្ខាបទនេះ គឺប្រាប់ដោយសម្គាល់ថា ខ្លួនបាន ខ្លួនដល់ និងមិនមានប្រាថ្នាដើម្បីនឹងអួត និងភិក្ខុឆ្កួតជាដើម មិន ត្រូវអាបត្តិ ។ សិក្ខាបទនេះ ជាអនាណត្តិកៈមានអង្គ ៥ គឺ **ឧត្តរិមនុស្ស-ធម្មស្ស អត្តនិ អសន្តតា** ឧត្តរិមនុស្សធម្មមិនមានក្នុងខ្លួន ១ **ចាបិច្ចតាយ តស្ស អាភោចនំ** អួតដោយប្រាថ្នាលាភ ប្រាថ្នា សេចក្តីសរសើរ ១ **អនញ្ញាបនេសោ** មិនអាងអ្នកដទៃ ១ **យស្ស អាភោចតិ តស្ស មនុស្សជាតិកតា** ប្រាប់ដល់អ្នកណា អ្នកនោះជាមនុស្សជាតិ ១ **តំ ខណំ វិជានន** គេដឹងច្បាស់នូវសេចក្តី ក្នុងខណៈនោះ ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវអាបត្តិបារាជិក បើ មិនព្រមដោយអង្គ ៥ មិនត្រូវបារាជិក ។ សមុដ្ឋានវិធីជាដើម ដូច អទិន្នាទានសិក្ខាបទ ។

ចតុត្ថបារាជិក ចប់

រួមបារាជិកទាំងអស់ ២៤ គឺ មកក្នុងឧទ្ទេស ចំណែកភិក្ខុ ៤ ចំណែក នាងភិក្ខុនីដែលជាអសាធារណៈ ៤ ជា ៨ អភ័ព្វបារាជិក ១១ គឺបណ្ណក ១

ថេយ្យសង្វាស មនុស្សលួចកេទលួចសង្វាស ១ តិត្ថិយបក្កន្តក: ភិក្ខុចូលទៅកាន់លទ្ធិតិរ្ថិយ ១ តិរច្ឆាន ១ មាតុឃាត ១ បិតុឃាត ១ អរហន្ត-ឃាត ១ សង្ឆភេទ ១ លោហិតុប្បាទ ១ ទ្រុស្តនាងភិក្ខុនី ១ មានទាំងកេទស្រី កេទប្រុស ១ ជា ១៩ នាងភិក្ខុនីប្រាជ្ញាកេទជាគ្រហស្ត ស្ងៀកសំពត់ជ្រលក់ទឹកអម្ចត់ ដោយអាការដូចជាគ្រហស្ត ១ ជា ២០ និងអនុលោមបារាជិក ៤ គឺភិក្ខុមាននិមិត្តវែង ដាក់និមិត្តក្នុងទ្វារធ្ងន់របស់ខ្លួនឯង ១ ភិក្ខុខ្ជង់ទន់ ឱនចុះបៀមនិមិត្តរបស់ខ្លួនឯង ១ ភិក្ខុយកមាត់បៀមអង្គជាតិប្រុសដទៃ ១ ភិក្ខុអង្គុយសង្កត់អង្គជាតិប្រុសដទៃ ១ ទើបរួមជាបារាជិក ២៤ ដូច្នេះ ។

បារាជិកុទ្ទេស ចប់

សង្ឆាទិសេសុទ្ទេស

សង្ឆាទិសេសសិក្ខាបទនៃភិក្ខុមាន ១៣ សញ្ញតនិកសិក្ខាបទជាបឋមនោះ សេចក្ដីថា ភិក្ខុមានសេចក្ដីតម្រេក ក្ងៃងញ្ជាយាមក្នុងនិមិត្តខ្លួនឯង ដោយឧបាយណាមួយឲ្យសុក្ក: គឺអសុចិឃ្លាតចាកឋាន ត្រូវអាបត្តិសង្ឆាទិសេស រៀងតែឃ្លាតចេញដោយយល់សប្ដិ សុក្ក:មាន ១០ យ៉ាង មានពណ៌លឿង ក្រហម ស ជាដើម ។ ភិក្ខុមានសេចក្ដីប្រាជ្ញានឹងឲ្យទឹកអសុចិណាមួយឃ្លាត ដោយបំណងឲ្យបាត់រោគ និងឲ្យបានសេចក្ដី

សុខជាដើមណាមួយក្តី នឹងព្យាយាមក្នុងនិមិត្តខ្ជួនដោយដៃឯង ឬឲ្យអ្នកដទៃព្យាយាមក្នុងនិមិត្តខ្ជួនក្តី និងត្បៀតនិមិត្តទុកដោយអវយវៈណាមួយក្តី និងដេកផ្ទាប់សង្កត់និមិត្តនឹងផ្ទៃ នឹងសំពត់ ឬ ពើងចង្កេះក្នុងអាកាសក្តី ដោយហោចទៅ សូម្បីដាក់និមិត្តក្នុងចន្ទោះភ្ជៅ ដោយគិតនឹងឲ្យអសុចិឃ្លាតចេញក្នុងកាលយល់សប្តិក្តី ហើយអសុចិឃ្លាតចេញចាកឋានមិនច្រើនប៉ុន្មាន ល្មមតែរុយតូច ១ ក្រេបផឹកបាន ទោះមិនទាន់ចុះដល់ដងបស្សាវៈក៏ត្រូវសង្ឆាទិសេស ។

ក្នុងអដ្ឋកថាទាំងឡាយសម្តែងទុកថា អសុចិឃ្លាតចេញចាកឋានហើយ គង់នឹងចុះកាន់ប្រឡាយបស្សាវៈប្រាកដ ព្រោះហេតុនោះ និមិត្តតែអសុចិហូរចុះកាន់ដងបស្សាវៈ ហើយនឹងចេញមកខាងក្រៅក្តី មិនចេញក្តី ត្រូវសង្ឆាទិសេស បើភ្ជែងនឹងឲ្យឃ្លាតចេញ ហើយព្យាយាមដូចសម្តែងមកនេះ អសុចិមិនបានឃ្លាតចេញ ត្រូវបុល្លច្ច័យ ។

វិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុមិនមានព្យាយាម និងមិនមានបំណងឲ្យឃ្លាតចេញ យល់ចិត្តឃើញជាប្រក្រតី អសុចិឃ្លាតចេញក្តី ភិក្ខុធ្លួតជាដើមក្តី ទាំងអម្បាលនេះមិនត្រូវអាបត្តិ សិក្ខាបទនេះ ជាអនាណត្តិកៈ គឺបង្ហាប់អ្នកដទៃឲ្យព្យាយាមក្នុងអង្គជាតិអ្នកដទៃនោះ មិនត្រូវសង្ឆាទិសេស មានអង្គ ៣ គឺ **ចេតនា** *ចេតនាឲ្យឃ្លាតចេញ ១* **ឧបក្កមោ** *ព្យាយាម ១* **មោចនំ** *អសុចិឃ្លាតចេញ ១ ព្រម*

ដោយអង្គ ៣ នេះ ទើបត្រូវសង្ឆាទិសេស សមុដ្ឋានវិធីជាដើម ដូចបឋមបារាជិក ។

សញ្ចេតនិកសិក្ខាបទ ជាបឋម ចប់

កាយសំសគ្គសិក្ខាបទ ជាគម្រប់ ២ សេចក្តីថា ភិក្ខុណាមានចិត្តតម្រេក ដោយកាយសំសគ្គរាគ: បបោសអង្ផែលកាយមាតុគ្រាម គឺចាប់ដៃ ឬ ចាប់របៃសក់ ឬ ពាល់ត្រូវ បបោសអង្ផែលអវយវ:ណាមួយនៃស្ត្រីមនុស្ស សូម្បីកើតក្នុងថ្ងៃនោះ ត្រូវសង្ឆាទិសេស ។ ខ្ទើយ ស្រីយក្ខ ស្រីប្រេត ជាវត្ថុនៃថុល្លច្ច័យ ។ តិរច្ឆានញ្ជី តិរច្ឆានឈ្មោល និងមនុស្សប្រុស ជាវត្ថុនៃទុក្កដ ។ របៃនោះគឺ ចាប់សក់សុទ្ធក្តី និងលាយដោយវត្ថុដទៃ មានអំបោះនិងផ្ការឈើជាដើមក្តី គេចងរឹតទុកក្តី មិនចងរឹតទុកក្តី ឈ្មោះថារបៃ ទោះរោមសត្វក៏សង្ត្រោះជារបៃ ព្រោះហេតុនោះ ស្រីភិក្ខុដឹងថាជាស្រី ហើយពាល់ត្រូវដោយតម្រេក ដោយហោចទៅតែរោមនិងរោមប៉ះពាល់គ្នា គឺស្រីមកពាល់ភិក្ខុ ភិក្ខុមានតម្រេក ញ្ញាយាមទទួលសម្ផស្ស ត្រូវសង្ឆាទិសេស ។ បើស្រី ភិក្ខុសង្ស័យថាស្រី ឬមិនមែនស្រី ឬសម្គាល់ថាជាខ្ទើយ ជាប្រុស ជាតិរច្ឆានក្តី ហើយចាប់ពាល់ ឬ ពាល់ត្រូវដោយវត្ថុជាប់ដោយកាយខ្លួន ឬពាល់វត្ថុជាប់ដោយកាយស្រីមានសំពត់ស្ទៀក សំពត់ដណ្ដប់ជាដើម ដោយកាយខ្លួន ឬពាល់ត្រូវ

ស្រីអមនុស្ស និងខ្ទើយ ដោយតម្រេក អម្បាលនេះ ត្រូវចុលច្ចុ័យ ទាំងអស់ ។ ភិក្ខុពាល់ត្រូវវត្ថុជាប់ដោយកាយស្រី ដោយវត្ថុជាប់ដោយកាយ ខ្លួន ឬស្រីបោះរបស់មក ភិក្ខុបោះរបស់ទទួល ឬពាល់ត្រូវខ្ទើយដោយ វត្ថុជាប់នឹងកាយខ្លួនជាដើម ឬខ្ទើយ ភិក្ខុសង្ស័យ ឬសម្គាល់ថាជាស្រី ថាជាប្រុសជាដើម ឬប្រុស ភិក្ខុសម្គាល់ថាជាស្រី ជាខ្ទើយ ជាតិរច្ឆាន ឬសង្ស័យក្តី ហើយមានតម្រេកពាល់ត្រូវកាយនឹងកាយនៃខ្ទើយជាដើម នោះក្តី ពាល់របស់ដែលជាប់នឹងកាយនោះក្តី បោះរបស់ទទួលគ្នាក្តី អម្បាលនេះ ត្រូវទុក្កដទាំងអស់ ។ ក៏ឯអាបត្តិតិច ច្រើន ឲ្យរាប់តាមវត្ថុ និងប្រយោគដែលពាល់ត្រូវ ភិក្ខុចាប់រួបដៃស្រីទុក ពាល់ត្រូវក្នុងទីនោះ ១ ថ្ងៃដរាបដល់ល្ងាចក្តី ឬមិនចាប់ទុក ស្ទាបពីក្បាលរហូតដល់ជើង មិន ឲ្យដៃហួសខ្លួនឡើយ ឬរួបម្រាម ៥ ជាមួយគ្នាក្តី ទាំងអម្បាលនេះ ត្រូវ អាបត្តិតែ ១ បើវត្ថុផ្សេងៗ គ្នា ហើយរួបម្រាមទាំង ៥ ក៏ត្រូវអាបត្តិ ៥ ។

ឯវិធីដែលមិនត្រូវ អាបត្តិនោះ គឺស្រីមកពាល់ភិក្ខុ ភិក្ខុមានតម្រេក តែមិនព្យាយាមដោយកាយ ទោះដឹងសម្ងួសក្តី ឬប្រាថ្នានឹងឲ្យរួច ហើយប្រានទៅ ឬពាល់ដោយមិនភ្លេងក្តី មិនដឹងខ្លួនក្តី មិនមានស្មារតី ក្តី មិនមានតម្រេកក្តី ភិក្ខុធ្លុតជាដើមក្តី អម្បាលនេះមិនត្រូវអាបត្តិ ។ សិក្ខាបទនេះ ជាអនាណត្តិក: មានអង្គ ៥ គឺ **មនុស្សិត្ថី** ស្រីមនុស្ស ១ **ឥត្ថីសញ្ញិតា** សម្គាល់ថាជាស្រី ១ **កាយសំសគ្គរាគោ**

តម្រេកដោយកាយសំសគ្គ: ១ **តេន ភតេន ភយាមោ** *ព្យាយាម តាមតម្រេកនោះ ១* **ហត្ថតាហាឧិសមាបជ្ជនំ** *ចាប់ដៃជាដើម ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវសង្ឃាទិសេស សមុដ្ឋានវិធីជាដើម ដូចបឋមបារាជិក ។*

កាយសំសគ្គសិក្ខាបទ គម្រប់ ២ ចប់

ទុដ្ឋុល្លវាចាសិក្ខាបទគម្រប់ ៣ សេចក្ដីថា ភិក្ខុមានចិត្តតម្រេកត្រេកអរ ហើយនិយាយនឹងស្ត្រី ដោយពាក្យអាក្រក់ប្រកបដោយមេថុន ដូចប្រុសកម្ងោះនិយាយចង់ស្រីក្រមុំ ស្រីដឹងសេចក្ដីក្នុងខណៈនោះ ត្រូវសង្ឃាទិសេស ស្រីមនុស្ស ដែលដឹងពាក្យអាក្រក់ ល្អ ប្រកបដោយមេថុន ជាវត្ថុឲ្យកើតសង្ឃាទិសេស ។ ឯវត្ថុឲ្យកើតថុល្លច្ច័យ និងឲ្យកើតទុក្កដ ដូចក្នុងសិក្ខាបទមុន ។ ពាក្យពោលដែលអាស្រ័យទ្វារធ្ងន់ ទ្វារស្រាល និងអាស្រ័យមេថុនក្នុងរូបស្ត្រី អម្បាលនេះឈ្មោះថាពាក្យអាក្រក់ ពាក្យទន់ទាប ជាខេត្តនៃសង្ឃាទិសេស ។ ក្នុងកាយស្ត្រី តាំងអំពីដងកាំបិតចុះទៅ អំពីជង្គង់ឡើងមក ជាខេត្តនៃថុល្លច្ច័យ ។ អវយវ: ក្រៅនោះ ជាខេត្តនៃទុក្កដ ។ អាការ:ដែលនឹងពោលទុដ្ឋុល្លវាចា មាន ៩ គឺសរសើរ និងតិះដៀលទ្វារធ្ងន់ ទ្វារស្រាលនៃស្ត្រី សូមមេថុនដោយពាក្យអង្វរថា កាលណាយើងនឹងបានមេថុនធម្មជាមួយនាង សួរថានាងឲ្យមេថុនធម្ម

ដល់សហាយ ដល់ប្ដីនាងដូចម្ដេច បានឮថា នាងឲ្យមេថុនធម្មដល់សហាយ ដល់ប្ដី ដូច្នេះ ឬប្រដៅថា នាងឲ្យមេថុនដូច្នេះ។ ទើបសហាយ និងប្ដីនាងស្រឡាញ់ ភិក្ខុដេរថា មេមានសិខិរណី គឺសាច់ដុះ មេមានទ្វារធ្ងន់ ទ្វារស្រាលជាប់គ្នា មេមានទាំងនិមិត្តស្ត្រី និមិត្តប្រុស អាការៈនៃពាក្យពោលទាំង ៩ នេះ ពាក្យណាមួយ ភិក្ខុដឹងថាជាស្ត្រី មានសេចក្ដីតម្រេក ធ្វើដោយកាយវិការណាមួយ ឬពោលដោយវាចាក្ដី ស្រីដឹងសេចក្ដីក្នុងខណៈនោះ ត្រូវសង្ឆាទិសេស ។ បើស្រីមិនដឹងសេចក្ដីក្នុងខណៈនោះ ត្រូវថុល្លច្ច័យ ។ ស្រី ភិក្ខុសង្ស័យក្ដីសម្គាល់ថាជាបណ្ឌក ជាបុរស ជាតិរច្ឆានក្ដី ឬបណ្ឌក ដឹងថាជាបណ្ឌកក្ដី ហើយពោលទុដ្ឋុល្លវាចា ដូច្នេះ ត្រូវថុល្លច្ច័យ ។ បណ្ឌកភិក្ខុសង្ស័យ ឬសម្គាល់ថា ជាបុរស ជាតិរច្ឆាន ជាស្រីក្ដី ប្រុស ឬ តិរច្ឆាន ភិក្ខុសម្គាល់ខុសក្ដី ត្រូវក្ដី ហើយពោលទុដ្ឋុល្លវាចា ដូច្នេះ ត្រូវទុក្កដ ។ ពោលចំពោះអវយវៈស្រី អំពីដងកាំបិត ចុះទៅ អំពីជង្គង់ ឡើងមកក្ដី និងពោលចំពោះទ្វារធ្ងន់ ទ្វារស្រាល នៃបណ្ឌកក្ដី ត្រូវថុល្លច្ច័យ ។ ពោលចំពោះអវយវៈស្រី អំពីដងកាំបិតឡើងទៅ ខាងក្រោមអំពីជង្គង់ចុះទៅក្ដី ពោលចំពោះអវយវៈទាំងពួង នៃបណ្ឌកជាដើមក្ដី ពោលចំពោះរបស់ជាប់នឹងកាយ ត្រូវទុក្កដ ។ ឯត្រូវអាបត្តិ តិច ច្រើន ឲ្យរាប់តាមវត្ថុ និងពាក្យដែលពោល ។

វិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុធ្វើអត្តជាប្រធានក្តី ធ្វើធម៌ជាប្រធានក្តី ធ្វើពាក្យទូន្មានជាប្រធានក្តី ពោលដោយមិនមានតម្រេកនិងភិក្ខុឆ្ពួតជាដើមក្តី អម្បាលនេះមិនត្រូវអាបត្តិ ជាអនាណត្តិក: មានអង្គ ៥ គឺ **មនុស្សត្ថី** *ស្រីមនុស្ស ១* **ឥត្ថីសញ្ញិតា** *ដឹងថាជាស្ត្រី ១* **ទុដ្ឋុល្លវាចស្សាឧភតោ** *តម្រេកក្នុងការពោលពាក្យអាក្រក់ ១* **តេឧ ភតេឧ ឱកាសនំ** *ពោលតាមសេចក្តីតម្រេកនោះ ១* **តំ ខណំ វិជានឧំ** *ស្រីដឹងសេចក្តីក្នុងខណ:នោះ ១ ព្រមដោយអង្គ ៥ នេះទើបត្រូវសង្ឃាទិសេស សមុដ្ឋានវិធីជាដើម ដូចអទិន្នាទាន ប្លែកតែមានវេទនាពីរ ។*

ទុដ្ឋុល្លវាចាសិក្ខាបទ គម្រប់ ៣ ចប់

អត្តកាមបារិចរិយសិក្ខាបទគម្រប់ ៤ សេចក្តីថា ភិក្ខុណាមានចិត្តតម្រេក ហើយពោលសរសើរការបម្រើដោយកាមដើម្បីខ្លួន ក្នុងទីជិតស្រីដោយពាក្យប្រកបដោយមេថុនថា ម្នាលប្អូនស្រី បើស្រីណាបម្រើអ្នកមានសីលមានធម៌ដ៏ល្អ ប្រព្រឹត្តព្រហ្មចរិយដូចយើងនេះ ដោយមេថុនធម្ម កិរិយាបម្រើនោះ ជាកំពូលនៃការបម្រើទាំងពួង ដូច្នេះ បើស្រីដឹងសេចក្តីក្នុងខណ:នោះ ត្រូវសង្ឃាទិសេស សិក្ខាបទនេះ មានអង្គ ៥ គឺ **មនុស្ឃ្ជិត្ថី** *ស្រីមនុស្ស ១* **ឥត្ថីសញ្ញិតា** *សម្គាល់ថាស្រី ១*

អត្តកាមចារិចរិយាយ ភគោ ត្រេកអរនឹងការបម្រើដោយកាមដល់ខ្លួន ១ **តេ**ន **ភ**ត្តេន **ឧ**ណ្ណ**ាកណ**ាំ ពោលសរសើរដោយតម្រេកនោះ ១ **ត**ំ **ខ**ណ**ំ** **ជ**ានន**ំ** ស្រីដឹងសេចក្តីក្នុងខណៈនោះ ១ វិនិច្ឆ័យក្រៅនោះ ដូចសិក្ខាបទមុន ប្លែកតែសិក្ខាបទនេះ ថាដោយសេចក្តីសរសើរ ការបម្រើដោយមេថុន ១ យ៉ាងប៉ុណ្ណោះ ។

អត្តកាមចារិចរិយសិក្ខាបទ គម្រប់ ៤ ចប់

សញ្ចរិត្តសិក្ខាបទគម្រប់ ៥ សេចក្តីថា ភិក្ខុណាដល់នូវសញ្ចរិត្ត គឺប្រព្រឹត្តធ្វើជាមេអណ្តើក ប្រាប់សេចក្តីប្រាថ្នារបស់ប្រុសដល់ស្រី ប្រាប់សេចក្តីប្រាថ្នារបស់ស្រីដល់ប្រុស ដើម្បីនឹងឲ្យបានគ្នាជាប្តីប្រពន្ធ ដោយហេតុទៅ សម្បីប្រាប់ដល់ស្រីពេស្យា និងគប្បីបានសង្វាសក្នុងមួយខណៈប៉ុណ្ណោះក្តី ត្រូវសង្ឆាទិសេស ស្រី ប្រុស ជាជាតិមនុស្ស មិនមែនប្រេត មិនមែនយក្ខ ជាគ្រហស្ថក្តី ជាបព្វជិតក្តី គេមិនទាន់បានគ្នាជាប្តីជាប្រពន្ធ ឬជាប្តីជាប្រពន្ធហើយ ប៉ុន្តែលែងគ្នាហើយ ដោយហេតុទៅ សម្បីមាតាបិតានៃភិក្ខុនោះក្តី អម្បាលនេះជាវត្ថុនៃសញ្ចរិត្ត អង្គនៃអាការនាំសញ្ចរិត្តនោះមាន ៣ គឺ **ឧ**ដ**ិ**ក្ត**ណ្ហ**ាតិ ស្រីឬប្រុសឬមាតារបស់ស្រី ឬប្រុសពឹងភិក្ខុឲ្យមកប្រាប់ដល់ស្រី ឬប្រុសពឹងឲ្យមកប្រាប់មាតាបិតានៃស្រី ឬប្រុសណាមួយ ភិក្ខុទទួលពាក្យគេជាអង្គ ១ **វ**ិ**ម**ំ**ស**តិ គេពឹង

ឲ្យប្រាប់អ្នកណា ភិក្ខុប្រាប់អ្នកនោះថា អ្នកចូរជាប្តីជាប្រពន្ធគ្នា ជាសហាយនឹងគ្នាក្តី ជាអង្គ ១ **បច្ចាហរតិ** អ្នកណាពឹងឲ្យទៅ ភិក្ខុត្រឡប់មកប្រាប់ដល់អ្នកនោះវិញជាអង្គ ១ គេបានគ្នាជាប្តីជាប្រពន្ធក្តី ជាសហាយក្តី មិនបានក្តី នោះមិនមែនជាហេតុ កាលបើព្រមដោយអង្គ ៣ ក៏ត្រូវសង្ឆាទិសេស ។ បើបានតែអង្គ ២ គឺទទួលនឹងប្រាប់ ឬប្រាប់ហើយត្រឡប់មកប្រាប់ ណាមួយ ត្រូវថុល្លច្ច័យ ។ បើបានតែអង្គ ១ គឺទទួល ឬប្រាប់ ឬត្រឡប់មកប្រាប់ ណាមួយ ត្រូវទុក្កដ ។ បើប្រុសពឹងភិក្ខុឲ្យប្រាប់ដល់ស្រីដែលមាតារក្សា ភិក្ខុទៅប្រាប់ដល់ស្រីដែលបិតារក្សាដូច្នេះ ខុសសង្កេត មិនត្រូវសង្ឆាទិសេស ភិក្ខុនាំសញ្ញាវិត្តដល់បណ្ណាក: ត្រូវថុល្លច្ច័យ ។

វិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុនាំដំណឹងសង្ឆ ដំណឹងចេតិយ ដំណឹងភិក្ខុឈឺក្តី ភិក្ខុធ្លាតជាដើមក្តី មិនត្រូវអាបត្តិ សិក្ខាបទនេះ ជាសាណត្តិក: ត្រូវព្រោះភិក្ខុទទួលពាក្យគេហើយ ប្រើឲ្យអ្នកដទៃទៅប្រាប់ដល់ស្រីឬប្រុស ឬប្រាប់ហើយនិងប្រើអ្នកដទៃ ឲ្យត្រឡប់មកប្រាប់ដល់អ្នកពឹងវិញក្តី គង់ត្រូវអាបត្តិ ។ មានអង្គ ៥ គឺ **យេសុ សញ្ញាវិត្តំ សមាបជ្ជតិ តេសំ មនុស្សជាតិកតា** នាំសញ្ញាវិត្តក្នុងអ្នកណា អ្នកនោះជាជាតិមនុស្ស ១ **ន ជាលំវចនីយតា** គេមិនមែនជាប្តីជាប្រពន្ធនឹងគ្នាអំពីមុន ឬជាប្តីប្រពន្ធហើយ តែលែងគ្នា

ហើយ ១ **បដិគ្គណ្ហាតិ** ទទួលពាក្យគេ ១ **ឱមសតិ** ប្រាប់តាមគេផ្តាំ ១ **ឧច្ចារណាទិ** ត្រឡប់មកប្រាប់ដល់អ្នកពីង ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវសង្ឃាទិសេស មានសមុដ្ឋាន ៦ គឺ ភិក្ខុមិនដឹងបញ្ញត្តិ ឬមិនដឹងថាគេលៃងគ្នាដាច់ហើយ និងទទួលពាក្យបណ្តាំគេ ដោយកាយវិការមានញាក់មុខជាដើម និងប្រាប់ដោយកាយវិការ ត្រឡប់មកប្រាប់ដោយកាយវិការ ដូច្នេះ នេះអាបត្តិកើតដោយកាយ ១ យ៉ាង ។ ភិក្ខុអង្គុយនៅ ប្រុសមកផ្តាំទុកថា ស្រីនេះនឹងមករកអ្នក អ្នកចូរដឹងចិត្តគេ ភិក្ខុទទួលពាក្យថា អើប្រពៃហើយ លុះស្រីមក ភិក្ខុក៏ប្រាប់ លុះប្រុសត្រឡប់មកទៀត ភិក្ខុក៏ប្រាប់ ដូច្នេះ អាបត្តិកើតអំពីវាចា ១ យ៉ាង ព្រោះភិក្ខុមិនបានធ្វើវត្ថុណាដោយកាយ ។ មួយទៀត ភិក្ខុទទួលពាក្យរបស់ប្រុសដោយវាចា ហើយទៅកាន់ផ្ទះរបស់ស្រីដោយកិច្ចដទៃ ឬថាទៅក្នុងទីដទៃ ទៅជួបនឹងស្រីនោះ ហើយក៏ប្រាប់ដល់ស្រីនោះ ដោយវចីភេទ ហើយក៏ទៅដោយហេតុដទៃទៀត ត្រឡប់មកជួបនឹងប្រុសនោះហើយ ក៏ចូលទៅប្រាប់ដល់ប្រុសនោះ ដូច្នេះឈ្មោះថាកើតអំពីវាចា ១ យ៉ាង ។ ភិក្ខុមិនដឹងបញ្ញត្តិ សូម្បីជាព្រះខីណាស្រពបិតាប្រើទៅហើយ លោកទៅប្រាប់ដល់មាតាដែលលៃងគ្នាដាច់ហើយ ថាអ្នកចូរត្រឡប់មកបម្រើបិតាចុះ ហើយត្រឡប់មកប្រាប់ដល់បិតាវិញដូច្នេះ អាបត្តិកើតអំពីកាយវាចា ៣ នេះឈ្មោះថា អចិត្តកសមុដ្ឋាន ភិក្ខុដឹងក្តី

មិនដឹងក្តី ក៏ត្រូវអាបត្តិ ។ ភិក្ខុដឹងបញ្ញត្តិ ឬដឹងថា គេលែងគ្នាដាច់ហើយ នឹងនាំសញ្ចរិត្តដោយន័យទាំង ៣ យ៉ាងនោះ សមុដ្ឋាន ៣ នេះ ឈ្មោះថាសចិត្តកសមុដ្ឋាន ដ្បិតចិត្តដែលដឹងបញ្ញត្តិ និងដឹងថា លែងគ្នាដាច់ហើយ ឈ្មោះថាមានសមុដ្ឋាន ៦ ដូច្នេះ ជាកិរិយាត្រូវព្រោះធ្វើនោសញ្ញាវិមោក្ខ មិនរួចដោយសម្គាល់ ជាអចិត្តក: ដឹងក្តី មិនដឹងក្តី ក៏ត្រូវអាបត្តិ ជាបណ្ណត្តិវជ្ជ: មានទោសគឺបណ្ឌិតគប្បីវៀរតាមបញ្ញត្តិ ជាកាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។

សញ្ចរិត្តសិក្ខាបទ គម្រប់ ៥ ចប់

កុដិការសិក្ខាបទគម្រប់ ៦ សេចក្តីថា ភិក្ខុធ្វើឯង ឬប្រើគេឲ្យធ្វើនូវកុដិ លាបដោយកំបោរនិងដីស្អិត ខាងក្នុងដំបូល ឬក្រៅដំបូល ឬទាំងខាងក្នុងខាងក្រៅ ដោយគ្រឿងឧបករណ៍ មានកាំបិតនិងពូថៅជាដើម ដែលសូមគេមកដោយខ្លួនឯង ជាកុដិមិនមានអ្នកណាជាម្ចាស់របស់ ចំពោះជាទីលំនៅនៃខ្លួន គប្បីធ្វើឲ្យត្រូវប្រមាណ គឺបណ្តោយ ១២ ចំអាម ទទឹង ៧ ចំអាម ដោយចំអាមព្រះសុគត កុំវាស់ខាងក្រៅ ឲ្យវាស់ចំណែកខាងក្នុងជញ្ជាំង ភិក្ខុគប្បីជម្រះទីនោះឲ្យល្អ ហើយទៅនិមន្តភិក្ខុមកអំពីសង្ឆ ឲ្យមកមើលទីដែលប្រកបដោយសេចក្តីប្រាថ្នា គឺអន្តរាយ គឺជាទីលំនៅនៃស្រមោចក្រហមស្រមោចខ្មៅជាដើម ឬមិន

មែនជាទីប្រកបដោយប្រាវ៉ា ឬជាទីលួមបង្ខិលរនេះ និងជណ្តើរបាន ដោយជុំវិញ ឬបង្ខិលមិនបាន ភិក្ខុមកអំពីសង្ឆឃើញថាទីមិនមាន ប្រាវ៉ា លួមបង្ខិលរនេះ បង្ខិលជណ្តើរបានដោយជុំវិញហើយសោត ឲ្យ ភិក្ខុម្ចាស់របស់នាំភិក្ខុទាំងឡាយមកអំពីសង្ឆ ដើម្បីឲ្យសម្តែងទីឲ្យ ថា ជាទីមិនមានសេចក្តីប្រាវ៉ា ឬលួមបង្ខិលជណ្តើរនិងរនេះបាន បើភិក្ខុ ជាម្ចាស់របស់នោះ មិននាំភិក្ខុមកសម្តែងទីឲ្យ ឬធ្វើឲ្យហួសប្រមាណ ឯណានីមួយ ក្នុងប្រយោគដែលធ្វើទាំងពួង ត្រូវទុក្កដ នៅសល់ កំបោរ ២ ដុំទៀតនឹងហើយ ក្នុងដុំជាបឋមត្រូវថុល្លច្ច័យ ដុំជាគម្រប់ ២ ស្រេចការ ត្រូវសង្ឆាទិសេស ធ្វើក្នុងទីប្រកបដោយប្រាវ៉ានឹងបង្ខិល រនេះជណ្តើរមិនបាន ត្រូវទុក្កដ ។

(១២ ចំអាមព្រះសុគត ត្រូវជា ៨ ហត្ថ ១១ ផ្ទាប់ ២ ក្បៀសជាង ឈើសព្វថ្ងៃនេះ ។ ៧ ចំអាមព្រះសុគត ត្រូវជា ៤ ហត្ថ ១ ចំអាម ៤ ផ្ទាប់ ៣ ក្បៀស និង ២ អនុក្បៀស ជាងឈើសព្វថ្ងៃនេះ) សិក្ខាបទនេះ មានអង្គ ៧ គឺ **ឧលិត្តាឌីនំ អញ្ញតរតា** លាបបូក ខាងក្នុង ឬខាងក្រៅជាដើមណាមួយ ១ **ហេដ្ឋិមប្ឍមាណសម្ភវោ** មិនបានប្រកបដោយប្រមាណខាងក្រោម ១ **អនេសិតវត្ថុកតា** សង្ឆមិនបានសម្តែងទីឲ្យ ១ **បមាណាតិក្កន្តតា** ធ្វើហួសប្រមាណ ១

អត្តុទ្ទេសិកតា *ចំពោះខ្លួន ១* **ភាសាការតា** *កុដិជាទីលំនៅ ១* **លេបឃជនា** *លាបជាប់គ្នាទាំងដំបូលនិងជញ្ជាំង ១ សមុដ្ឋានវិធីជាដើម ដូចពោលហើយក្នុងសញ្ចរិត្តសិក្ខាបទ ។*

កុដិការសិក្ខាបទ គម្រប់ ៦ ចប់

មហាល្វកសិក្ខាបទគម្រប់ ៧ សេចក្តីថា ភិក្ខុធ្វើខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើ នូវវិហារធំមិនមានប្រមាណ មានអ្នកដទៃជាម្ចាស់របស់ចំពោះជាទីនៅរបស់ខ្លួន គប្បីនាំភិក្ខុទាំងឡាយមកសម្តែងទីឲ្យ បើមិននាំភិក្ខុមកឲ្យសម្តែងទីឲ្យសោត ភិក្ខុធ្វើស្រេចការត្រូវសង្ឆាទិសេស សេចក្តីក្រៅនោះដូចសិក្ខាបទមុន ប្លែកតែសិក្ខាបទនេះ មិនមានប្រមាណប៉ុណ្ណោះ ។

មហាល្លកសិក្ខាបទ គម្រប់ ៧ ចប់

អមូលកសិក្ខាបទជាគម្រប់ ៨ សេចក្តីថា ភិក្ខុណាមានសេចក្តីក្រោធប្រទុស្តនឹងភិក្ខុផងគ្នា ហើយភ្ជែងចោទដោយបារាជិកទាំង ៤ ណាមួយ មិនមានមូល ដោយបំណងរកហេតុនឹងឲ្យភិក្ខុនោះវិនាសចាកព្រហ្មចរិយ: គ្រាក្រោយមានគេសាកសួរក្តី មិនមានគេសាកសួរក្តី អធិករណ៍នោះមិនមានមូលប្រាកដហើយ ទោះភិក្ខុនោះនឹងប្តេជ្ញាថាយើងនិយាយកុហកក៏ត្រូវសង្ឆាទិសេស ក្នុងខណ:ចោទនោះ ។ បារាជិកមិនមានមូលនោះ គឺមិនបានឃើញដោយភ្នែកប្រក្រតី ឬភ្នែកទិព្ធ មិនបានឮដោយត្រចៀកប្រក្រតី ឬត្រចៀកទិព្ធ មិនបានរង្ស៊ៀសដោយចិត្តថា ភិក្ខុនោះត្រូវ

បារាជិកទាំង ៤ ណាមួយ ដោយខ្លួនបានឃើញអាការៈ ឬបានឮ សំឡេង និងធំក្ងិនណាមួយ ដែលគួរនឹងរង្កៀស អម្បាលនេះឈ្មោះ ថាមិនមានមូល ពោលដោយសង្ខេប ចោទនោះមាន ៤ គឺ ចោទដោយ ចង្អុលវត្ថុ ១ ចង្អុលអាបត្តិ ១ ឃាត់សង្ឆាស ១ ឃាត់សាមីចិកម្ម ១ ត្រូវ ជា ៤ ចោទថា "លោកសេពមេថុនជាដើម" ដូច្នេះ ឈ្មោះថាចង្អុល វត្ថុ ចោទថា "លោកត្រូវអាបត្តិព្រោះមេថុនធម្ម" ជាដើម ដូច្នេះ ឈ្មោះថាចង្អុលអាបត្តិ ចោទថា "នឹងធ្វើឧបោសថ បវារណា សង្ឆកម្ម ជាមួយលោកមិនបាន" នេះឈ្មោះថា ចោទដោយឃាត់សង្ឆាស ដោយគ្រាន់តែឃាត់សង្ឆាសប៉ុណ្ណោះ នៅមិនទាន់ត្រូវអាបត្តិទេ លុះតែ ពោលពាក្យថា "លោកមិនជាសមណៈជាដើម" មកតនឹងចុងពាក្យ មុនថា នឹងធ្វើឧបោសថ បវារណា សង្ឆកម្ម ជាមួយលោកមិនបាន ទើបត្រូវអាបត្តិ ។ បើមិនធ្វើអភិវាទនឹងក្រោកទៅទទួលនិងអញ្ជលិកម្ម និងសាមីចិកម្មមានបក់ជាដើម ដូច្នេះ ឈ្មោះថាចោទដោយឃាត់សាមីចិ-កម្ម ដូច្នេះនេះ ឲ្យគប្បីដឹងក្នុងវេលាដែលភិក្ខុធ្វើអភិវាទជាដើម ដោយ លំដាប់ ហើយមិនធ្វើដល់ភិក្ខុ ១ អង្គ រំលងទៅធ្វើដល់ភិក្ខុដ៏សេស ដូច្នេះ ឈ្មោះថាចោទ ប៉ុន្តែនៅមិនទាន់ត្រូវអាបត្តិទេ លុះតែភិក្ខុដែលគេមិន សំពះនោះសួរថា "ហេតុដូចម្តេចបានជាអ្នកមិនធ្វើអភិវាទជាដើមដល់ យើង ហើយភិក្ខុពោលពាក្យថា លោកមិនជាសមណៈជាដើម បន្ត

មកទៀត ទើបត្រូវអាបត្តិ ។ ភិក្ខុចោទបុគ្គលណា ដែលបានឧប-
សម្បទ្ធហើយជាអ្នកបរិសុទ្ធក្តី មិនបរិសុទ្ធក្តី ចោទដោយបារាជិកាបត្តិ
ណា ដឹងថាបុគ្គលនោះ មិនត្រូវបារាជិកាបត្តិនោះ មានបំណងនឹង
ឲ្យភិក្ខុនោះកក្រើកចាកព្រហ្មចរិយៈ មិនឲ្យភិក្ខុធ្វើឱកាសដោយពាក្យថា
ភវេតុ មេ អាយស្មា ឱកាសំ អហន្តំ វត្តុកាមោ
ប្រែថា លោកដ៏មានអាយុចូរធ្វើឱកាសដល់ខ្ញុំ ខ្ញុំចង់និយាយនឹងលោក
ដូច្នេះ ជាមុនហើយចោទ បើភិក្ខុនោះ ដឹងសេចក្តីក្នុងខណៈនោះ
ថាគេចោទខ្ជិនដូច្នេះ ត្រូវសង្ឆាទិសេសផង ត្រូវទុក្កដផង គ្រប់ៗ
ពាក្យដែលចោទ បើអ្នកចោទឲ្យអ្នកត្រូវចោទនោះ ធ្វើឱកាសដល់ខ្ជិន
មុនហើយ ទើបចោទត្រូវសង្ឆាទិសេសតែមួយយ៉ាង សូម្បីភិក្ខុចោទ
ចំពោះមុខដោយកាយវិការណាមួយ ក៏ដូចគ្នា ភិក្ខុចោទក្នុងទីកំបាំងមុខ
មិនជាប្រធាននៃអាបត្តិ ភិក្ខុបង្គាប់អ្នកដទៃដែលនៅជិតខ្ជិនឲ្យចោទ អ្នក
ទទួលបង្គាប់ ទៅចោទអ្នកនោះតាមពាក្យអ្នកប្រើ ត្រូវអាបត្តិដល់អ្នកប្រើ
ដូចន័យសម្តែងមកហើយ បើអ្នកទទួលបង្គាប់ទៅចោទថា យើង
ក៏បានឃើញ បានឮដែរ ត្រូវអាបត្តិទាំងពីរនាក់ ។ ភិក្ខុមិនឲ្យគេធ្វើ
ឱកាសជាមុនហើយ ពោលដោយបំណងនឹងដេរ ត្រូវបាចិត្តិយផង
ទុក្កដផង បើឲ្យធ្វើឱកាសជាមុនហើយចោទ ត្រូវតែបាចិត្តិយប៉ុណ្ណោះ
ភិក្ខុធ្វើកម្មទាំង ៧ ប្រការក្នុងទីកំបាំងដោយកម្មាធិប្បាយ ត្រូវទុក្កដ ។

មួយទៀត ភិក្ខុពោលថា លោកត្រូវអាបត្តិឈ្មោះនេះ លោកចូរសម្តែងអាបត្តិនោះចេញ ដូច្នេះ ដោយវុដ្ឋានាធិប្បាយ ឯឃាត់ឧបោសថ ឬបវារណាដល់ភិក្ខុដទៃ មិនបាច់សូមឱកាស តែឲ្យស្គាល់ខេត្តដែលនឹងឃាត់ សូម្បីភិក្ខុអ្នកសាកសួរសេចក្តី លុះកាលបើវត្ថុដែលគេចោទឡើងហើយពោលថា កម្មរបស់លោកនោះមាន ដោយបំណងនឹងសាកសួរ មិនបាច់សូមឱកាស សូម្បីភិក្ខុជាធម្មកថិកមិនចំពោះអ្នកណា សម្តែងធម៌ទៅដោយន័យថា អ្នកណាធ្វើដូច្នេះ អ្នកនោះមិនជាសមណៈជាដើម ដូច្នេះ ក៏មិនបាច់សូមឱកាស បើភិក្ខុកំណត់ចំពោះ ពោលថា អ្នកឯណោះ ១ ផង មិនជាសមណៈ មិនជាឧបាសក ដូច្នេះ ចុះចាកធម្មាសនៈហើយ ត្រូវសម្តែងអាបត្តិចេញសិមទៅ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុសម្គាល់ថាជាមនុស្សមិនបរិសុទ្ធ ក្នុងបុគ្គលបរិសុទ្ធក្តី ថាជាមនុស្សបរិសុទ្ធ ក្នុងបុគ្គលមិនបរិសុទ្ធក្តី ហើយទើបចោទ និងភិក្ខុធ្ជតជាដើម មិនត្រូវអាបត្តិ ជាសាណត្តិកៈ មានអង្គ ៥ គឺ **យំ ចោទេតិ វា ចោទាបេតិ វា តស្ស ឧបសម្បន្នោតិ សង្ខ្យមំ** *ចោទឯង ឬឲ្យអ្នកដទៃចោទនូវបុគ្គលណា បុគ្គលនោះជាឧបសម្បន្ន ១* **តស្មឹ សុទ្ធសញ្ញិតា** *សម្គាល់ថាអ្នកនោះ ជាមនុស្សបរិសុទ្ធ ១* **យេន ចាវជ្ជិកេន ចោទេតិ តស្ស ជិជ្ជាជិវសេន ច អមូលកតា** *ចោទដោយបាវជិកណា បាវជិកនោះមិនមានមូល*

ដោយការឃើញជាដើម ១ **ចាវនាធិប្ប៉ាយេន សម្ម៉ុខា ចោទនា ១ ចោទាបនា ១** ចោទឯង ឬប្រើអ្នកដទៃឲ្យចោទ ក្នុងទីចំពោះមុខ ដោយបំណងនឹងឲ្យឃ្លាតចាកព្រហ្មចរិយ: ១ **តស្ស តំ ខណំ វិជានន្ត** អ្នកត្រូវចោទដឹងក្នុងខណ:នោះ ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវសង្ឆាទិសេស ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាទុក្ខវេទនា ។

អមូលកសិក្ខាបទ គម្រប់ ៨ ចប់

អញ្ញភាគិយសិក្ខាបទ គម្រប់៩ សេចក្ដីថា ភិក្ខុណាមានសេចក្ដីក្រោធ ប្រទុស្តនឹងភិក្ខុដទៃ គិតនឹងឲ្យឃ្លាតចាកព្រហ្មចរិយ: ក្លែងកាន់យកលេស មានជាតិជាដើម មកចោទភិក្ខុនោះ ដោយបារាជិកមិនមានមូល ដូចយ៉ាងអ្នកដែលមានជាតិជាក្សត្រិយ៍ជាដើម សេពមេថុន ឬត្រូវបារាជិកណាៗ ហើយ កាន់យកជាតិនោះជាលេស មកដាក់ក្នុងភិក្ខុ ដែលជាជាតិក្សត្រិយ៍ដូចគ្នា ថាអ្នកជាក្សត្រិយ៍ សេពមេថុន នឹងត្រូវបារាជិកាបត្តិ ដោយហេតុនេះៗ យើងបានឃើញ បានឮ យើងរង្ការ ដូច្នេះ ត្រូវសង្ឆាទិសេសក្នុងខណ:ចោទ សូម្បីនឹងប្ដេជ្ញាខ្ជួនខាងក្រោយ ក៏មិនរួចចាកទោស ។

លេសមាន ១០ ប្រការ គឺជាតិ ១ នាម ១ គោត្រ ១ លិង្គ ១ អាបត្តិ ១ បាត្រ ១ ចីវរ ១ ឧបជ្ឈាយ៍ ១ អាចារ្យ ១ សេនាសន: ១ ។

ជាតិនោះមាន ៤ គឺក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ ពណ្ណជ ១ ពួកពិសេស ១ ។ នាមមាន ៣ គឺពុទ្ធរក្ខិត ១ ធម្មរក្ខិត ១ សង្ឆរក្ខិត ១ ។ គោត្រមាន ៤ គឺ គោតមគោត្រ ១ មោគ្គល្លានគោត្រ ១ កច្ចាយនគោត្រ ១ វាសិដ្ឋគោត្រ ១ ។ លិង្គមាន ៤ គឺ ខ្ពស់ ១ ទាប ១ ខ្មៅ ១ ស ១ ។ អាបត្តិនោះ ដូចភិក្ខុត្រូវទុក្កដ ហើយចោទថាត្រូវបារាជិក ១ ។ បាត្រមាន ៤ គឺ ភិក្ខុទ្រង់នូវបាត្រដែក ១ បាត្រដី ១ បាត្រខ្ទុក ១ បាត្រដីជាប្រក្រតី ១ ។ ចីវរមាន ២ គឺ ភិក្ខុទ្រង់នូវចីវរបង្សុកូល ១ គហបតិចីវរ ១ ។ ឧបជ្ឌាយ៍ក្តី អាចារ្យក្តី សេនាសនៈក្តី វិធីដែលចោទដូចពោលហើយក្នុងលេសទាំងឡាយមានជាតិជាដើមនោះ ។ សមុដ្ឋានវិធីជាដើម ដូចពោលហើយក្នុងអមូលកសិក្ខាបទ ។

អញ្ញភាគិយសិក្ខាបទ គម្រប់ ៩ ចប់

សង្ឆភេទសិក្ខាបទ គម្រប់ ១០ សេចក្តីថា ភិក្ខុណា ព្យាយាមស្វែងរកបក្ខពួក ដើម្បីនឹងទម្លាយសង្ឆដែលព្រមព្រៀងនៅក្នុងសីមាជាមួយគ្នា ឬលើកយកហេតុដែលនឹងទម្លាយសង្ឆ គឺភេទកវត្ថុ ១៨ ឡើងសម្តែង ភិក្ខុដទៃបានឃើញ បានឮ គប្បីហាមប្រាមថា លោកកុំធ្វើយ៉ាងនេះ លោកចូរព្រមព្រៀងដោយសង្ឆចុះ ដ្បិតថាសង្ឆព្រមព្រៀងមិនមានទាស់ទែង មានឧទ្ទេសជាមួយគ្នាហើយ ក៏នឹងនៅដោយសេចក្តីសប្បាយ បើភិក្ខុមិនស្តាប់ពាក្យហាមឃាត់ ត្រូវទុក្កដ បើភិក្ខុដទៃ

បានឃើញ បានឮ ហើយមិនហាមឃាត់ ត្រូវទុក្កដ ភិក្ខុដទៃហាមឃាត់ មិនស្តាប់ពាក្យហាមឃាត់ហើយ ឲ្យភិក្ខុទាំងឡាយនោះ ទង់ទាញភិក្ខុនោះទៅក្នុងកណ្តាលសង្ឆ គប្បីឲ្យឃាត់ទៀត ៣ ដង បើលះចេញក៏ជាការល្អ បើមិនលះចេញត្រូវទុក្កដ ហើយសង្ឆគប្បីសូត្រសមនុ-ភាសនកម្មដល់ភិក្ខុនោះដោយញត្តិចតុត្ថកម្មវាចា លុះសង្ឆសូត្រសមនុ-ភាសន:ចប់ញត្តិហើយ ភិក្ខុនោះមិនលះត្រូវទុក្កដ កាលបើចប់អនុស្សាវន:ទី ១-២ ភិក្ខុនោះមិនលះត្រូវថុល្លច្ច័យ លុះចប់អនុស្សាវន:គម្រប់ ៣ ត្រូវសង្ឆាទិសេស ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសង្ឆមិនបានសូត្រសមនុភាសន: ហើយភិក្ខុលះចេញ និងភិក្ខុធ្ពួតជាដើម សិក្ខាបទនេះមានអង្គ ៤ គឺ **ភេជ្ជាយ បវត្តិមនំ** *ព្យាយាមដើម្បីបំបែកសង្ឆ ១* **ធម្មកម្មេន សមនុភាសនំ** *សង្ឆធ្វើកម្មនោះដោយធម៌ ១* **កម្មវាចាបរិ-យោសានំ** *សូត្រចប់ចតុត្ថកម្មវាចា ១* **អប្ឋដិនិស្ឆ្ជនំ** *មិនបានលះទិដ្ឋិ ១ ជាសមនុភាសនសមុដ្ឋាន អកិរិយា សញ្ញាវិមោក្ខ សចិត្តក: លោកវជ្ជ: កាយកម្ម វចីកម្ម អកុសលចិត្ត ទុក្ខវេទនា ។*

សង្ឆភេទសិក្ខាបទ គម្រប់ ១០ ចប់

ភេទានុវត្តកសិក្ខាបទ គម្រប់ ១១ សេចក្តីថា ភិក្ខុទាំងឡាយ តាំងអំពី ៣ រូបចុះមក ជាបក្ខពួកប្រព្រឹត្តតាមភិក្ខុដែលជាអ្នកទម្ងាយសង្ឆ

នោះ ជួយស្រដីរាំងរកិក្ខុដទៃថា "លោកទាំងឡាយ កុំស្រដីអ្វីនឹងកិក្ខុនោះឡើយ កិក្ខុនុ៎ះជាអ្នកពោលធម៌ ពោលវិន័យ លោកកាន់យកនូវសេចក្តីពេញចិត្តនិងគាប់ចិត្តរបស់ពួកយើងហើយពោល លោកដឹងនូវសេចក្តីពេញចិត្តនិងគាប់ចិត្តរបស់យើង បានប្រឹក្សាជាមួយយើង កម្មនោះគួរដល់ពួកយើង" ដូច្នេះ ពួកកិក្ខុដទៃបានឃើញ បានឮ គប្បីហាមឃាត់កិក្ខុដែលជាបក្ខពួកនោះអស់វារៈ ៣ ដង បើកិក្ខុពួកទាំងនោះហាមឃាត់មិនស្តាប់ ឲ្យកិក្ខុទាំងនោះ គប្បីសូត្រសមនុភាសនៈដោយញត្តិចតុត្ថកម្មវាចា ដើម្បីឲ្យលះកម្មនោះចេញ បើលះចេញក៏ជាការល្អ បើមិនលះទេ លុះចប់អនុសាវនៈគម្រប់ ៣ ពួកកិក្ខុដែលជាបក្ខពួកនោះត្រូវសង្ឆាទិសេស ។ សេចក្តីក្រៅនោះដូចសិក្ខាបទមុន ។

ភេទានុវត្តកសិក្ខាបទ គម្រប់ ១១ ចប់

ទុព្ភូចជាតិកសិក្ខាបទ គម្រប់ ១២ សេចក្តីថា កិក្ខុមានជាតិជាអ្នកមុខរឹង ប្រដៅក្រ កាលកិក្ខុទាំងឡាយ ពោលប្រដៅដោយសិក្ខាបទបញ្ញត្តិ ធ្វើខ្ជិនមិនឲ្យអ្នកដទៃស្រដីដាស់តឿនបាន គឺពោលថា លោកទាំងឡាយ កុំនិយាយពាក្យអ្វី ទោះល្អឬអាក្រក់នឹងខ្ញុំ សូម្បីខ្ញុំក៏មិនពោលពាក្យអ្វីទោះល្អឬអាក្រក់នឹងលោកទាំងឡាយដែរ លោកទាំងឡាយ ចូរស្ងៀមកុំដាស់តឿនយើងឡើយ ដូច្នេះ កិក្ខុទាំងឡាយគប្បីហាមប្រាម កុំឲ្យជាមនុស្សមុខរឹង លុះកិក្ខុទាំងឡាយនិយាយដាស់តឿន កិក្ខុនោះនៅ

តែមុខរឹងចចេសដូច្នោះ កិក្ខុទាំងឡាយគប្បីទង់ទាញទៅកាន់កណ្តាលសង្ឆ សូត្រសមនុភាសនៈអស់វារៈ ៣ ដង ដើម្បីឲ្យលះកម្មនោះចេញ បើលះចេញក៏ជាការល្អ បើមិនលះទេ លុះចប់អនុស្សាវនៈ គម្រប់ ៣ ត្រូវសង្ឆាទិសេស ។ វិនិច្ឆ័យក្រៅនោះដូចសិក្ខាបទមុន ។

ទុព្ធចជាតិកសិក្ខាបទ គម្រប់ ១២ ចប់

កុលទូសកសិក្ខាបទ គម្រប់ ១៣ សេចក្តីថា កិក្ខុអាស្រ័យនៅក្នុងស្រុកឬនិគមណាមួយហើយទ្រូស្តត្រកូល គឺឲ្យផ្ទៃឈើ ផ្ការឈើ ជាដើម ដល់ត្រកូលឲ្យគេសាបសូន្យផលនៃទានដែលគេឲ្យមកដល់ខ្លួន ដូច្នេះឈ្មោះថាកុលទូសក ឯកិក្ខុជាមនុស្សមានមារយាទអាក្រក់ គឺជាំឈើ ដើម្បីនឹងសង្ត្រោះត្រកូលជាដើម សមាចារដ៏អាក្រក់នឹងត្រកូលដែលកិក្ខុប្រទូស្តនោះ ប្រាកដដល់ភ្នែកនិងត្រចៀកអ្នកដទៃ ឲ្យកិក្ខុទាំងឡាយដែលបានឃើញ បានឮ គប្បីធ្វើបញ្ជាជនីយកម្ម បណ្តេញចេញពីស្រុកនិគមនោះ ដោយញត្តិចតុត្ថកម្មវាចា លុះកិក្ខុត្រូវបញ្ជាជនីយកម្ម ហើយត្រឡប់ពោលតិះដៀលសង្ឆអ្នកបណ្តេញនោះ ថាធ្វើដោយអគតិទាំង ៤ គឺ ឆន្ទាគតិ ១ ទោសាគតិ ១ មោហាគតិ ១ ភយាគតិ ១ ដូច្នេះ ឲ្យកិក្ខុទាំងឡាយដទៃដែលបានឃើញ បានឮ គប្បីហាមឃាត់ កុំឲ្យតិះដៀលការកសង្ឆនោះ បើហាមប្រាមមិនស្តាប់ ឲ្យកិក្ខុទាំងឡាយនោះ ទង់ទាញទៅកណ្តាលសង្ឆ សូត្រសមនុភាសនៈអស់វារៈ ៣ ដង ដើម្បីឲ្យលះពាក្យតិះដៀល

នោះចេញ បើមិនលះទេ លុះចប់អនុស្សាវនៈគម្រប់ ៣ ត្រូវសង្ឆាទិសេស ។ វិនិច្ឆ័យក្រៅនោះដូចសិក្ខាបទមុន ។

កុលទូសកសិក្ខាបទ គម្រប់ ១៣ ចប់

តាំងអំពីសញ្ចេតនិកសិក្ខាបទ ដល់អញ្ញភាគិយសិក្ខាបទ ទាំង ៩ នេះ ឈ្មោះបឋមាបត្តិកា ព្រោះត្រូវអាបត្តិក្នុងខណៈដែលកន្ទ្ធងជាដំបូង សិក្ខាបទ ៤ ក្រៅនោះ ឈ្មោះយាវតតិយកា ព្រោះត្រូវអាបត្តិក្នុងខណៈចប់អនុស្សាវនៈ គម្រប់ ៣ ក្នុងសិក្ខាបទទាំង ១៣ នេះ សិក្ខាបទណាមួយ ភិក្ខុត្រូវហើយដឹងហើយ បិទទុកអស់ថ្ងៃប៉ុន្មាន គប្បីនៅបរិវាសអស់ថ្ងៃប៉ុណ្ណោះ លុះនៅបរិវាសហើយ ត្រូវប្រព្រឹត្តមានត្ត ៦ រាត្រីទៀត លុះប្រព្រឹត្តមានត្តហើយ គប្បីសុំអព្ភានកម្មក្នុងសង្ឆ មានភិក្ខុ ២០ អង្គជាគណៈសង្ឆ ឲ្យអព្ភានកម្មស្រេចហើយទើបរួចអាបត្តិនោះបាន ព្រោះហេតុនោះភិក្ខុត្រូវអាបត្តិហើយកុំបិទទុកដោយអៀនខ្មាស គប្បីប្រញាប់ប្រាប់ដល់ភិក្ខុដែលជាសភាគៈក្នុងថ្ងៃនោះ កុំឲ្យអរុណរះឡើងទាន់ កាលបើប្រាប់បានក្នុងថ្ងៃនោះ នឹងត្រូវប្រព្រឹត្តតែមានត្ត ៦ រាត្រី ហើយសូមអព្ភានកម្មនឹងសង្ឆ រួចទោសទៅដោយងាយ ត្រូវហើយឲ្យប្រាប់សូម្បីដោយភាសារបស់ខ្លួន ថាខ្ញុំត្រូវអាបត្តិសង្ឆាទិសេសឈ្មោះនេះ ខ្ញុំប្រាប់អាបត្តិនោះដល់លោក លក្ខណៈដែលនឹងបិទអាបត្តិទុកនោះដូច្នេះ អាបត្តិភិក្ខុត្រូវហើយដឹងថាត្រូវអាបត្តិផង ខ្លួនជាបកតត្ត សង្ឆមិនបានលើកវត្ត ដឹងថាខ្លួនជាបកតត្តផង មិនមាន

អន្តរាយទាំង ១០ ណាមួយ ដឹងថាមិនមានអន្តរាយផង ល្មមនឹងទៅប្រាប់ កិក្ខុដែលជាសភាគ:បាន ហើយដឹងថាល្មមនឹងប្រាប់បានផង ប្រាជ្ញា នឹងបិទ ហើយបិទទុកផង ដូច្នេះទើបឈ្មោះថាបិទ បើឃើញឧបជ្ឈាយ៍ អាចារ្យហើយអៀនមិនប្រាប់ឲ្យអ្ករណាថ្មីរះឡើងមក ក៏ឈ្មោះថា បិទទុក ប្រាកដ ដែលអៀននឹងឧបជ្ឈាយ៍អាចារ្យនោះ មិនជាប្រមាណទេ កិក្ខុ ដែលជាសភាគ:ដោយវត្តបដិបត្តិ ដឹងហើយមិនចំអកចំអន់តិះដៀលឡក ឡឺយ ដូច្នេះឯងជាប្រមាណគួរប្រាប់ ។

សង្ឆាទិសេសុទ្ទេស ចប់តែប៉ុណ្ណោះ

អនិយតុទ្ទេស

ពណ៌នាអំពីអនិយតសិក្ខាបទ អនិយតសិក្ខាបទមាន ២ គឺអលំកម្ម-និយសិក្ខាបទជាបឋម សេចក្ដីថា កិក្ខុណាតែម្នាក់ឯង អង្គុយឬដេក ក្នុងអាសន:ដែលស្ងាត់កំបាំងជាមួយនឹងស្ត្រី សូម្បីកើតក្នុងថ្ងៃនោះ (ទោះ ច្រើនគ្នា) អង្គុយឬដេក ឧបាសិកាដែលមានពាក្យគួរជឿ គឺជាអរិយ-សាវិកា បានឃើញកិក្ខុនោះ ហើយចោទដោយបារាជិក ព្រោះសេព មេថុន ឬដោយសង្ឆាទិសេស ព្រោះកាយសំសគ្គ: ឬដោយបាចិត្តិយ ព្រោះអង្គុយក្នុងទីកំបាំងជាមួយនឹងស្រី ណាមួយ កិក្ខុនោះប្ដេជ្ញា គឺ ទទួលដោយបទណា វិនិយធរគប្បីកាត់អាបត្តិតាមប្ដេជ្ញាក្នុងបទនោះ គឺប្ដេជ្ញាទទួលថា សេពមេថុន ឲ្យកាត់បារាជិក ប្ដេជ្ញាទទួលថា ចាប់

ពាល់ត្រូវស្រី ឲ្យកាត់ជា សង្ឆាទិសេស, ប្តេជ្ញាទទួលថា អង្គុយឬដេកក្នុងទីកំបាំងនឹងស្រី ដែលអង្គុយឬដេក ឲ្យកាត់ជាបាចិត្តិយ, បើប្តេជ្ញាថាខ្លួនឈរ ឬស្រីឈរ មិនបានធ្វើអ្វីទេ កុំឲ្យវិន័យធរកាត់អាបត្តិអ្វីឡើយ ដ្បិតការឃើញនោះ មានកាលក៏មែនដូចឃើញ មានកាលក៏មិនមែនដូចឃើញ មិនជាក់ច្បាស់ ភិក្ខុប្រាជ្ញានឹងទៅរកមាតុគ្រាមដោយសេចក្តីតម្រេកក្នុងទីស្ងាត់ប្រកបដោយកិលេសអាស្រ័យមេថុន តាំងអំពីប្រយោគដែលតាក់តែងខ្លួនមានផាត់មុខជាដើមទៅ ត្រូវទុក្កដគ្រប់ៗប្រយោគ លុះទៅដល់ទីអង្គុយឬដេក ហើយស្រីទើបមកអង្គុយឬដេក ឬស្រីអង្គុយ ឬដេកនៅហើយ ភិក្ខុទើបមកអង្គុយឬដេក ឬដេកនឹងអង្គុយព្រមគ្នាទាំងពីរក្តី ត្រូវបាចិត្តិយ ។ បើភិក្ខុនោះចាប់ពាល់ត្រូវស្រី ឬសេពមេថុន ឲ្យវិន័យធរគប្បីកាត់អាបត្តិភិក្ខុនោះដោយវត្ថុនោះៗ សូម្បីប្រុសអង្គុយនៅប្រមាត់ទ្វារលែងដែលមានសន្ទឹកបិទ ភិក្ខុអង្គុយខាងក្នុងលែងជាមួយនឹងស្រី ប្រុសនោះក៏ការពារអាបត្តិមិនបាន ប្រុសភ្នែកល្អអង្គុយក្នុងទីឱកាស ១២ ហត្ថលួមឃើញគ្នាបាន ជាមនុស្សមានចិត្តអណ្តែតអណ្តូង សូម្បីអង្គុយលក់ ក៏ការពារអាបត្តិមិនបាន ប្រុសភ្នែកល្អតែដេកលក់ ក៏ការពារអាបត្តិមិនបាន ប្រុសភ្នែកខ្វាក់ សូម្បីអង្គុយជិត ក៏ការពារអាបត្តិមិនបាន (សូម្បីស្រីមួយរយនាក់ ក៏ការពារអាបត្តិមិនបាន) ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺមានប្រុសដឹងសេចក្តី ភ្នែកមិន

ខ្ទាក់ ដេកមិនលក់ក្តី ឬប្រុសដូច្នោះនៅក្នុងទីឧបចារៈក្តី ឬកិក្ខុឈរក្តី ឬស្រីឈរមិនអង្គុយក្តី កិក្ខុមិនប្រាជ្ញក្នុងទីកំបាំងក្តី បញ្ជូនចិត្តទៅកាន់ទីដទៃក្តី អម្បាលនេះមិនត្រូវអាបត្តិបាចិត្តិយ ព្រោះអង្គុយក្នុងទីកំបាំងនឹងស្រី កិក្ខុធ្លួតជាដើម មិនត្រូវអាបត្តិ ទាំង ៣ ប្រការនេះជាអនាណត្តិកៈ ។ អង្គក្នុងសិក្ខាបទនេះ ឲ្យគប្បីដឹងតាមអាបត្តិដែលកិក្ខុប្តេជ្ញា ។ សមុដ្ឋានវិធីជាដើម ដូចបឋមបារាជិក ។

អលំកម្មនិយសិក្ខាបទ ចប់

នាលំកម្មនិយសិក្ខាបទ ជាគម្រប់ ២ សេចក្តីថា អាសនៈទីអង្គុយមិនបិទបាំងដោយវត្ថុអ្វី ជាទីវាលដូចកណ្តាលវត្ត កណ្តាលស្រុក មិនគួរសេពមេថុនបាន គួរតែនឹងនិយាយទុដ្ឋុល្លវាចានឹងមាតុគ្រាមបាន ប៉ុណ្ណោះ កិក្ខុណាតែមួយរូបមិនមានប្រុសដទៃដឹងសេចក្តីនៅជាមួយផង អង្គុយឬដេកនឹងស្រីដែលដឹងពាក្យអាក្រក់និងពាក្យល្អ តែម្នាក់ឯងមិនមានស្រីដទៃដែលដឹងសេចក្តីនៅជាមួយផង ក្នុងអាសនៈដូច្នោះ ជាទីកំបាំងត្រ-ចៀកមួយជំពូក ឧបាសិកាជាអរិយសាវិកា មានវាចាគួរជឿ បានឃើញកិក្ខុនោះ ហើយចោទដោយសង្ឆាទិសេស ព្រោះពោលទុដ្ឋុល្លវាចា ឬដោយបាចិត្តិយព្រោះអង្គុយក្នុងទីស្ងាត់ បទណាមួយ កិក្ខុអ្នកអង្គុយនោះទទួលប្តេជ្ញាដោយបទណា ឲ្យវិនិច្ឆយគប្បីកាត់អាបត្តិដោយបទនោះ ឬឧបាសិកាជាអរិយសាវិកាមានពាក្យគួរជឿនោះ ចោទដោយបទណា

ឲ្យវិន័យធរគប្បីកាត់អាបត្តិតាមបទនោះ បើភិក្ខុប្តេជ្ញាខ្ជួនថាឈរ មិនបានអង្គុយមិនបានដេក កុំឲ្យវិន័យធរកាត់អាបត្តិជាមុន វិនិច្ឆ័យក្រៅនោះដូចសិក្ខាបទមុន ប្លែកតែសិក្ខាបទនេះសូម្បីស្រី សូម្បីប្រុស ណាមួយដឹងសេចក្តី មិនខ្វាក់ មិនថ្ងង់ ឈរ ឬអង្គុយនៅក្នុងឱកាសខាងក្នុង ១២ ហត្ថ សូម្បីមានចិត្តអណ្តែតអណ្តូង ឬដេកលក់ ក៏ការពារអាបត្តិព្រោះទោសអង្គុយក្នុងទីកំបាំងនោះបាន ឯមនុស្សថ្ងង់សូម្បីភ្នែកល្អក្តី មនុស្សភ្នែកខ្វាក់សូម្បីមិនថ្ងង់ក្តី អម្បាលនេះ ក៏ការពារអាបត្តិមិនបាន ឯសមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ។

នាលំកម្មនិយសិក្ខាបទ ចប់

សិក្ខាបទទាំងពីរនេះឈ្មោះអនិយត: ប្រែថាមិនទៀង ព្រោះជាបាវជិកខ្លះ ជាសង្ឆាទិសេសខ្លះ ជាបាចិត្តិយខ្លះ ដោយបញ្ញត្តិនោះៗ តាមប្តេជ្ញានៃភិក្ខុ ។

មួយទៀត សិក្ខាបទទាំងពីរនេះ មើលទៅដូចជាព្រះពុទ្ធអង្គទ្រង់បញ្ញត្តទុកឲ្យជាសណ្ឋាប់ដល់វិន័យធរអ្នកនឹងកាត់សេចក្តី អ្នកចោទ និងអ្នកចម្ងើយ ក្នុងសិក្ខាបទទាំងពួង ឲ្យកាត់តាមលំអានអនិយតសិក្ខាបទទាំងពីរនេះចុះ ។

អនិយតុទ្ទេស ចប់

ថុល្លច្ចយាបត្តិ

ពណ៌នាអំពីអាបត្តិថុល្លច្ច័យសេចក្តីថា បទមួយភិក្ខុកុំលះ បទមួយ ភិក្ខុកុំគប្បីចែកគរុកណ្ឌរបស់សង្ឆ បើលះ បើចែក ត្រូវអាបត្តិថុល្លច្ច័យ ព្រោះពុទ្ធប្បញ្ញត្តិឃាត់ទុកថា ៖

បញ្ចិមានិ ភិក្ខវេ អវិសជ្ជនិយានិ ។ ល ។ អវ-ភណ្ដិយានិ ន វិភជ្ជិតព្វានិ សង្ឆេន វា គណេន វា បុគ្គលេន វា វិភត្តានិ បិ អវិភត្តានិ ហោន្តិ យោ វិភជ្ជេយ្យ អាបត្តិ ថុល្លច្ចយស្ស *ដូច្នេះ គរុកណ្ឌនោះមាន ៥ ពួកដូច្នេះ* **អាវាសោ** *ច្បារផ្ទៃឈើផ្ការឈើ* **អាវាសវត្ថុ** *ទីដីច្បារ ពីរនេះជាពួក ១,* **វិហារោ** *កុដិ ផ្ទះជាដើម* **វិហារវត្ថុ** *ទីដីនៃវិហារ ពីរនេះជាពួកគម្រប់ ២,* **មញ្ចោ** *គ្រែ* **បីឋំ** *តាំង* **ភិសិ** *ពួក* **ពិម្ពោហនំ** *ខ្នើយ បួន នេះជាពួកគម្រប់ ៣,* **លោហកុម្ភី** *ឆ្នាំងទង់ដែង* **លោហភាណកំ** *នាលិលោហ:* **លោហវារកោ** *បំពង់លោហ:ធំចុះទឹក ៥ នាលិមគធ: ឡើងទៅ* **លោហកដាហំ** *អាងលោហ:តូចចុះទឹកមួយទូកដៃ លោហ:នោះជាឈ្មោះនៃស្ពាន់ទង់ដែងសំរិទ្ធិ* **វាសី** *កាំបិតធំដែលកាប់ កាត់របស់ធំ រួចចាកកាត់ឈើស្ងួនិងលួសអំពៅបានឡើងទៅ* **ផរសុ** *ពូថៅគ្រឿងធ្វើឈើ* **កុឋារី** *កឹងគ្រឿងធ្វើឈើ* **កុទ្ទាលោ** *ចប-កាប់ចបជីកជាគ្រឿងជីកដី* **និខាទនំ** *ដែកកណ្ដារ ដែកស្ទាន ប្រាំបួន*

នេះជាពួកគម្រប់ ៤, **រល្ងី** រលៃវែងតាំងអំពីកន្ទុះលូកឡើងទៅ **ឧណ្ហ** ឫស្សីវែងអំពី ៨ ធ្នាប់ឡើងទៅ **មុញ្ជ** ស្មៅដំណេកទន្យាយ **បព្វជ** ស្មៅយ៉ាឫង **តិណ** ស្មៅផ្សេងៗ ដែលសម្រាប់ប្រក់ចាំងបាន អំពីមួយក្តាប់ឡើងទៅ **មត្តិកា** ដីប្រក្រតីនិងដីមានពណ៌ផ្សេងៗជាគ្រឿងសម្រាប់លាប **ឌារុភណ្ឌ** គ្រឿងប្រើធ្វើដោយឈើផ្សេងៗ ប្រវែង ៨ ធ្នាប់ឡើងទៅ **មត្តិកាភណ្ឌ** គ្រឿងប្រើ ធ្វើដោយដីផ្សេងៗ ទាំងអម្បាលនេះដែលហួងហែងទុក ទាំង ៨ វត្ថុនេះ ជាពួកគម្រប់ ៥, របស់ទាំង ២៥ នេះ របស់ណាមួយទាយកប្រគេនដល់សង្ឆក្តី កើតក្នុងទីសង្ឆក្តី ឈ្មោះថារបស់សង្ឆជាគរុភណ្ឌ ជាអវិសជ្ជនិយៈ ជាអវេកង្ខិយៈ ដែលសង្ឆ គណៈ ឬបុគ្គល មិនគប្បីលះ មិនគប្បីចែកបាន ទោះលះ ទោះចែកទៅ ក៏មិនបានឈ្មោះថាលះ ថាចែក របស់នោះក៏គង់នៅជារបស់សង្ឆដូចដើម, ភិក្ខុណាលះ ឬចែករបស់សង្ឆទាំងអម្បាលនេះ ដោយប្រកាន់ថាខ្លួនជាធំត្រូវថុល្លច្ច័យ បើលះបើចែកដោយថេយ្យចិត្ត ឲ្យវិនិច្ឆយធរកាត់អាបត្តិតាមតម្លៃរបស់នោះៗ គរុភណ្ឌទាំងអម្បាលនេះ បើកំណត់ឃើញថា ធ្វើដូច្នេះនឹងកើតឧបចារៈដល់សង្ឆ ហើយយករបស់ដែលជាឋានៈផ្ទាស់ប្តូរ យករបស់ដែលជាឋានៈដូចគ្នាក្តី យករបស់ក្រៅនេះ ដែលជាអកប្ប្ហិយ ឬជាកប្ប្ហិយ សូម្បីមានតម្លៃច្រើន ផ្ទាស់ប្តូររបស់ក្រៅនោះផងគ្នា ដោយកិរិយាផ្ទាស់ប្តូរជាកប្ប្ហិយក្តី ក៏គួរ ឬគរុ-

ក្ណដែលជារបស់ថោកទាប ហើយផ្ទាស់ប្តូរបិណ្ឌបាតជាដើម យកមកបរិភោគដើម្បីរក្សាសេនាសនៈជាដើម ដែលជារបស់ល្អ ក្នុងវេលាអត់បាយជាដើមក៏គួរ ក្នុងគរុកណ្ឌទាំងអម្បាលនេះ របស់ណាមួយមានឫស្សីជាដើម ភិក្ខុកាន់យកដើម្បីជាប្រយោជន៍ខ្លួន គប្បីធ្វើផាតិកម្ម ការសង់ជំនួសឲ្យស្មើគ្នា ឬ លើសជាង ទើបគួរកាន់យក ។ ឆ្នាំង បាត្រ ពែង ផ្ដិលស្ពាន់ ទីកោទឹក ដែលមិនចុះទឹកបាន ៥ នាលិមគធៈក្តី ចង្កឹះថ្នាំភ្នែក បំពង់ថ្នាំនត្ថុ ឈើចង្អៀលត្រចៀក ម្ជុលដេរសំពត់ ម្ជុលក្ងាស់ស្ងឹកឈើ កាំបិតបត់តូច ដែកកណ្ដារតូចៗ មេសោ កូនសោជាដើម គ្រឿងលោហៈក្តី គ្រឿងឈើក្តី ដែលនៅកំពុងធ្វើ ទាំងនេះជារបស់គួរចែកបាន រលិនិងឫស្សីជាដើម កាលបើធ្វើការសង្ឃ និងការចេតិយ រួចហើយសល់ នឹងបង្ហោនទៅកាន់ការបុគ្គលក៏គួរ ដែលសម្ដែងមកនេះជាសេចក្ដីសង្ខេប បើប្រាថ្នាចង់ដឹងសេចក្ដីពិស្តារ គប្បីមើលក្នុងចតុត្ត-សមន្តបាសាទិកាឯណោះចុះ ។

បទមួយ កុំឲ្យគេធ្វើសត្ថកម្មក្នុងទីចង្អៀត បទមួយ កុំឲ្យគេធ្វើសត្ថ-កម្ម ឬវត្ថិកម្មក្នុងឱកាសទីពីរជ្ជាប់អំពីទីជិតនៃទីចង្អៀតគឺទ្វារធ្ងន់ បើឲ្យគេធ្វើ ត្រូវបុល្លច្ច័យ ដ្ឋិតទ្រង់ឃាត់ទុកថា **ន ភិក្ខវេ សម្ពាធេ សត្ថកម្មំ ។ ល ។ សម្ពាធស្ស សាមន្តា ឧវ្ជ្ជុលេ សត្ថកម្មំ ។ វត្ថិកម្មំ ។ ការាបេតព្វំ យោ ការាបេយ្យ**

អាបត្តិ ចុល្លច្ចយស្ស ដូច្នេះ កាត់ ឬពុះ ឬចាក់ ឬក្រីដោយ សស្ត្រា ឬម្ជុល ឬបន្ទា ឬលំពែង ឬរំកាច់ថ្ម ឬក្រចកក្តី ណាមួយក្នុងឱកាសដែលកំណត់ក្នុងទ្វារធ្ងន់នោះ ឈ្មោះថាសត្តកម្មទាំងអស់, សូម្បីចង់រឹតក្បាលសសាល់ដោយស្បែក ឬសំពត់ណាមួយក៏កុំគប្បីធ្វើ ដ្បិតអាការទាំងពួងនោះឈ្មោះថាវត្ថិកម្ម ឯក្នុងឱកាសទីពីរធ្នាប់អំពីទីជិតនៃទីចង្អៀតគឺទ្វារធ្ងន់នោះ ឃាត់តែសត្តកម្មប៉ុណ្ណោះ មិនឃាត់វត្ថិកម្មឡើយ ឯវត្ថិកម្មឃាត់តែក្នុងទីចង្អៀតប៉ុណ្ណោះ ក៏ប៉ុន្តែថា ភិក្ខុនឹងបន្ត្ក់ទឹកផ្សាក្នុងក្បាលសសាល់ ឬនឹងយកខ្សែណាមួយចង់រឹតក្បាលសសាល់ក៏គួរ បើក្បាលសសាល់នោះដាច់ចេញមកដោយទឹកផ្សា ឬខ្សែនោះ ឈ្មោះថាដាច់ដោយប្រពៃ មិនមានទោស ។

នឹងធ្វើសត្តកម្មគឺពុះចោះក្នុងអណ្ហ:[1] ដែលមានរោគចម្រើនឡើងនោះមិនគួរ ព្រោះហេតុនោះ នឹងពុះចោះអណ្ហ:ទាញយកគ្រាប់ចេញមកដោយគិតនឹងឲ្យជារោគដូច្នេះកុំគប្បីធ្វើ ឯនឹងកម្ចៅដោយក្ងើងនឹងលាបថ្នាំទាំងអម្បាលនេះមិនបានឃាត់ ក្នុងទ្វារធ្ងន់ នឹងយកត្រួយស្ទឹកឈើយកខ្សែត្រកួញទាញ ឬបំពង់ឫស្សីដែលលាបថ្នាំដាក់ចុះហើយ យកទឹកផ្សាបន្ត្ក់ក្នុងបំពង់ ឬទឹកប្រេងដាក់ក្នុងបំពង់ឫស្សីនោះឲ្យហូរចូលទៅក្នុងទ្វារធ្ងន់ដូច្នេះក៏គួរ ចុល្លច្ចយទាំង ៤ នេះជាសចិត្តក: ។

១- អណ្ហ: ក្នុងទីនេះសំដៅយកពងស្វាស ។

បទមួយ ភិក្ខុកុំធាន់សាច់មនុស្ស បើធាន់ត្រូវបុល្លច្ច័យ ដ្ឋិតទ្រង់ឃាត់ទុកថា **ន ភិក្ខវេ មនុស្សមំសំ បរិភុញ្ជិតព្ពំ** *ដូច្នេះ មិនតែសាច់មនុស្សប៉ុណ្ណោះទេ សូម្បីធ្ពើងនិងឈាមស្បែកពោមក៏មិនគួរ សិក្ខាបទនេះជាអចិត្តក: ។*

មួយទៀត អាបត្តិបុល្លច្ច័យមានច្រើន ដែលមិនបានឡើងកាន់ បាតិមោក្ខុទ្ទេស ពោលដោយអាគតដ្ឋានទីមកមាន ៣ ស្ថាន គឺមកក្នុងខន្ធក: ១ ឈ្មោះខន្ធកបុល្លច្ច័យ, មកក្នុងវិនីតវត្ថុនៃបារាជិក និងសង្ឆាទិសេស ១ ឈ្មោះថាវិនីតវត្ថុបុល្លច្ច័យ, មកក្នុងវិភង្គនៃបារាជិក និងសង្ឆាទិសេស ១ ឈ្មោះថាវិភង្គបុល្លច្ច័យ, ព្រោះហេតុនោះបញ្ញត្តិនៃ បុល្លច្ចយាបត្តិ ទើបមានច្រើន មិនមានកំណត់ ។

ខន្ធកបុល្លច្ច័យនោះថាដូច្នេះ ភិក្ខុកុំគប្បីកាន់លទ្ធិតិរ្ថិយសមាទាន គឺវត្តបដិបត្តិនៃតិរ្ថិយ អាក្រាតកាយ មិនស្ងៀកដណ្ដប់ ភិក្ខុណាបដិបត្តិ ដូច្នេះ ត្រូវបុល្លច្ច័យ ភិក្ខុកុំស្ងៀកដណ្ដប់ស្ស្ងរក្រង កុំទ្រង់សំពត់ដែលក្រងទាក់ទៅដោយសំបកឈើ កុំទ្រង់សំពត់ដែលធ្វើដោយក្ដារ កុំទ្រង់សំពត់កម្ពលដែលធ្វើដោយសក់មនុស្ស កុំទ្រង់សម្ពត់កម្ពលធ្វើដោយពោមកន្ទុយសត្ត កុំទ្រង់សំពត់ធ្វើដោយស្ងាបមៀម កុំទ្រង់ស្បែកខ្ចី កុំទ្រង់សំពត់ដែលធ្វើដោយដើមរាក់ សំពត់ទាំងអស់នេះជាទង់នៃតិរ្ថិយ ភិក្ខុណាទ្រង់សំពត់ទាំងអម្បាលនេះ ត្រូវបុល្លច្ច័យ ។

បទមួយថា ភិក្ខុកុំពាល់ត្រូវអង្គជាតិ នៃតិរច្ឆានញ៉ីដោយចិត្តតម្រេក បើពាល់ត្រូវ ត្រូវថុល្លច្ចយ ។

បទមួយថា ថ្ងៃឧបោសថ ថ្ងៃបវារណា ភិក្ខុអាវាសិក:តាំងអំពី ៤ ឬ ៥ អង្គឡើងទៅ ដឹងថាភិក្ខុអាវាសិក:ផងគ្នា ឬភិក្ខុអាគន្តុក:មាននៅក្នុងសីមាជាមួយគ្នា តែថាមិនទាន់មកកាន់ពេងឧបោសថ ពេងបវារណា ចូលហត្ថបាស ក្ងែងនឹងឲ្យភិក្ខុនោះវិនាសអន្តរាយចាកឧបោសថ ចាកបវារណា ហើយប្រញាប់ធ្វើឧបោសថនិងបវារណាជាមុនត្រូវថុល្លច្ចយ ថុល្លច្ចយទាំងនេះក្តី ថុល្លច្ចយបទមុន ៥ នោះក្តី ជាខន្ធកថុល្លច្ចយ ។

វិនីតវត្ថុថុល្លច្ចយនោះ ភិក្ខុប្រាថ្នានឹងឲ្យអសុចិហូរចេញ ដើរតាមផ្លូវទៅ អសុចិមិនកក្រើកចាកទី ហើយកើតសង្ស័យ ទើបក្រាបទូលដល់ព្រះពុទ្ធអង្គ ព្រះពុទ្ធអង្គទ្រង់កាត់ថាត្រូវថុល្លច្ចយ ។ បទមួយថា ភិក្ខុបបោសអង្ហែលពាល់ត្រូវកាយស្រីដែលស្លាប់ហើយ ហើយកើតសង្ស័យ ទើបក្រាបទូលសួរដល់ព្រះពុទ្ធអង្គ ព្រះពុទ្ធអង្គទ្រង់កាត់ថាត្រូវថុល្លច្ចយ ថុល្លច្ចយដូច្នេះ ឈ្មោះថាវិនីតវត្ថុថុល្លច្ចយ ។

ឯវិកង្គថុល្លច្ចយនោះ មានច្រើនប្រការ គឺជាអនុស្សាវនថុល្លច្ចយ ១ វិមត្តិថុល្លច្ចយ១ យថាសញ្ញាថុល្លច្ចយ១ យថាខេត្តថុល្លច្ចយ១ យថាវត្ថុថុល្លច្ចយ១ យថាបយោគថុល្លច្ចយ១ យថាវជ្ជថុល្លច្ចយ១ ។

ឯអនុស្សាវនថុល្លច្ចយនោះ ដូចអាបត្តិថុល្លច្ចយ ព្រោះសង្ឆ្យធ្វើ

សមនុភាសនកម្ម ១១ ណាមួយ ដល់ភិក្ខុនិងភិក្ខុនី ដើម្បីនឹងឲ្យលះកម្ម នោះ។ចេញ ហើយភិក្ខុមិនលះចេញ លុះចប់អនុស្សាវនៈទី ២ ត្រូវ ថុល្លច្ចយ ថុល្លច្ចយដូច្នេះ ឈ្មោះថាអនុស្សាវនថុល្លច្ចយ អនុស្សាវន-ថុល្លច្ចយនេះ កាលបើចប់ អនុស្សាវនៈគម្រប់ ៣ ត្រូវគរុកាបត្តិហើយ ថុល្លច្ចយនោះរម្ងាប់បាត់ទៅឯង មិនត្រូវសម្តែង ។

ស្រី ភិក្ខុសង្ស័យថា ស្រី ឬមិនមែនស្រី ហើយមានចិត្តតម្រេកពាល់ ត្រូវកាយស្រីនោះដោយកាយខ្លួន ត្រូវថុល្លច្ចយ ថុល្លច្ចយដូច្នេះឈ្មោះថា វិមត្តិថុល្លច្ចយ ព្រោះត្រូវដោយសង្ស័យ ។

ស្រី ភិក្ខុសម្គាល់ថាជាបណ្ឌកៈ ហើយមានចិត្តតម្រេកពាល់ត្រូវកាយ ស្រីនោះ ដោយកាយខ្លួន ត្រូវថុល្លច្ចយ ថុល្លច្ចយដូច្នេះ ឈ្មោះថា យថាសញ្ញាថុល្លច្ចយ ព្រោះត្រូវអាបត្តិតាមសេចក្តីសម្គាល់ ។

ភិក្ខុមានចិត្តតម្រេក សរសើរឬតិះដៀលអវយវៈស្រី ខាងក្រោមអំពី ដងកាំបិតចុះទៅ ខាងលើអំពីជង្គង់ឡើងមក រៀរតែទ្វារធ្ងន់ទ្វារស្រាល ចេញ ត្រូវថុល្លច្ចយ ថុល្លច្ចយដូច្នេះ ឈ្មោះថា យថាខេត្តថុល្លច្ចយ ព្រោះត្រូវអាបត្តិតាមខេត្តដែន ។

ភិក្ខុចាប់ពាល់ត្រូវកាយបណ្ឌកៈដោយកាយខ្លួន ដោយចិត្តតម្រេក ត្រូវថុល្លច្ចយ ថុល្លច្ចយដូច្នេះឈ្មោះថា យថាវត្ថុថុល្លច្ចយ ព្រោះត្រូវ អាបត្តិតាមវត្ថុ ។

ភិក្ខុមានចេយ្យចិត្ត នាំខ្ញុំគេរត់ក្តី បបួលក្តី ដេញក្តី ឲ្យខ្ញុំគេនោះ លើកបាទាជាបឋម ត្រូវថុល្លច្ច័យ ថុល្លច្ច័យដូច្នេះឈ្មោះថា យថាបយោគ-ថុល្លច្ច័យ ព្រោះត្រូវអាបត្តិតាមប្រយោគដែលប្រកប ។

ភិក្ខុចំពោះខ្លួនឯង ហើយអាងយកអ្នកដទៃជាបរិយាយ អួតឧត្តរិ-មនុស្សធម្មថា អ្នកណានៅក្នុងវិហារ អ្នកនោះជាព្រះអរហន្តដូច្នេះជាដើម អ្នកស្តាប់ដឹងសេចក្តីក្នុងខណៈនោះ ភិក្ខុនោះត្រូវថុល្លច្ច័យ ថុល្លច្ច័យដូច្នេះ ឈ្មោះថា យថាវជ្ជថុល្លច្ច័យ ព្រោះត្រូវអាបត្តិតាមទោស ។ ព្រោះ អាបត្តិថុល្លច្ច័យមានច្រើនយ៉ាងផ្សេងៗ គ្នាដូច្នេះ ទើបមិនមានកំណត់ដូច បារាជិកនិងសង្ឆាទិសេសជាដើម ។

ថុល្លច្ច័យ ចប់

និស្សគ្គិយុទ្ទេស

សម្តែងអំពីនិស្សគ្គិយបាចិត្តិយ, និស្សគ្គិយបាចិត្តិយ មានសិក្ខាបទ ៣០ ចែកជា ៣ វគ្គ វគ្គជាបឋមឈ្មោះចីវរវគ្គ, ចីវរវគ្គនេះ មាន ១០ សិក្ខាបទ ៖

សិក្ខាបទទី ១ ឈ្មោះបឋមកឋិន សេចក្តីថា ចីវរភិក្ខុធ្វើសម្រេច ហើយ កឋិនដោះហើយ គឺអានិសង្សកឋិនទាំង ៥ រំដាប់ហើយ បលិពោធ ២ ដាច់ហើយ ភិក្ខុទុកអតិរេកចីវរ (គឺចីវរដែលមិនទាន់វិកប្ប ឬអធិដ្ឋាន)

បានតែត្រឹម ១០ ថ្ងៃជាយ៉ាងក្រៃពេក កាលភិក្ខុទុកអតិរេកចីវរនោះឲ្យ ហួស ១០ ថ្ងៃទៅ ដល់អរុណជាគម្រប់ ១១ រះឡើងមក ចីវរនោះត្រូវ និស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

កំណើតសំពត់មាន ៦ គឺ **ខោមំ** *សំពត់ដែលត្បាញដោយសរសៃ សំបកឈើ* **កប្ប**ាសិកំ *សំពត់ដែលត្បាញដោយអម្ពោះកប្បាស* **កោ**សេយ្យ*ំ សំពត់ដែលត្បាញដោយសរសៃសូត្រ* **ក**ម្ពលំ *សំពត់ដែលត្បាញដោយរោមសត្ត្ব រៀងតែរោមមនុស្ស រោមកន្ទុយសត្ត្ববេញ* **សាណ**ា *សំពត់ដែលត្បាញដោយសំបកផ្ទ្ធ* **ភ**ङ្គ*ិ សំពត់ដែលត្បាញ លាយដោយសរសៃវត្ថុទាំង ៥ មានសំបកឈើជាដើម ចីវរទាំង ៦ ប្រការនេះក្តី សំពត់ទុកូល និងសំពត់បគ្គុណ្ណ: និងសំពត់សោមារបដ: និងសំពត់ចីនបដ: និងសំពត់ឥទ្ធិជ: និងសំពត់ទេវតាឲ្យ ទាំងអស់នេះជា អនុលោមតាមសំពត់ ៦ ប្រការខាងដើមនោះ ឈ្មោះថាចីវរ បើមិនទាន់ អធិដ្ឋាននិងវិកប្បឈ្មោះថាអតិរេកចីវរ រាប់អំពីថ្ងៃដែលបានចីវរនោះមកទុក លុះអរុណគម្រប់ ១១ រះឡើងមក មិនបានអធិដ្ឋាន មិនបានវិកប្ប មិនលះ ចេញក្នុងខាងក្នុង ១០ ថ្ងៃនោះ ចីវរនោះត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។ បើមិនលះមិនធ្វើវិនយកម្ម ដល់សង្ឆ ឬគណ: ឬបុគ្គល ជាមុន យកមក បរិភោគគឺស្ងៀកដណ្តាប់ ត្រូវទុក្កដ ។ ឯវិធីអធិដ្ឋាន និងវិកប្ប និងលះចីវរ ដែលត្រូវនិស្សគ្គិយនោះ នឹងសម្តែងទៅខាងមុខ ។ ចីវរកន្ធងទៅ ១០*

ថ្ងៃហើយ ភិក្ខុដឹងថាកន្ទង ១០ ថ្ងៃហើយក្តី សង្ស័យក្តី សម្គាល់ថាមិនទាន់កន្ទងក្តី ក៏គង់ត្រូវនិស្សគ្គិយបាចិត្តិយ, បើនៅមិនទាន់បានអធិដ្ឋាន និងវិកប្ប មិនទាន់បានលះឲ្យអ្នកដទៃ ហើយមិនវិនាសដោយហេតុណាមួយក្តី សម្គាល់ថាអធិដ្ឋានជាដើមហើយក្តី កន្ទង ១០ ថ្ងៃទៅ ក៏គង់ត្រូវនិស្សគ្គិយបាចិត្តិយ ។ ចីវរមិនទាន់កន្ទង ១០ ថ្ងៃ សម្គាល់ថាកន្ទងហើយក្តី សង្ស័យក្តី យកមកប្រើប្រាស់ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះគឺ ភិក្ខុអធិដ្ឋានហើយ វិកប្បហើយ និងលះបង់ឲ្យអ្នកដទៃក្នុងខាងក្នុង ១០ ថ្ងៃ ចីវរនោះបាត់ទៅ វិនាសទៅ ភ្លើងឆេះទៅ ចោរដណ្តើមយកទៅ គេកាន់យកដោយវិស្សាស:ក្នុងខាងក្នុង១០ ថ្ងៃក្តី និងភិក្ខុធ្លួតជាដើមក្តី ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ សិក្ខាបទនេះជាអនាណត្តិក:មានអង្គ ៥ គឺ **ជាតិប្បមាណសម្បន្នស្ស ចីវរស្ស អត្តនោ សន្តកតា** ចីវរប្រកបដោយជាតិនិងប្រមាណជារបស់ខ្លួន ១ **កណ្ឌូបកតា** ចីវរនោះដល់នូវការរាប់ថ្ងៃបាន គឺថាដល់ដៃខ្លួនហើយ ឬបានឮហើយថាជាសំពត់របស់ខ្លួន ១ **ឆិន្ទបលិពោធភាវោ** បលិពោធទាំងពីរដាច់ហើយ ១ **អតិរេកចីវរតា** ចីវរនោះជាអតិរេក-ចីវរ ១ **ឧសាហាតិក្កមោ** កន្ទង ១០ ថ្ងៃទៅ ១ ព្រមដោយអង្គ ៥ នេះទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ ជាបឋមកឋិនសមុដ្ឋាន គឺអាបត្តិកើត

អំពីកាយវាចា ១ អំពីកាយវាចាចិត្ត ១ ជាអកិរិយា នោសញ្ញាវិមោក្ខ អចិត្តក: បណ្ណត្តិវជ្ជ: កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។

បឋមកឋិនសិក្ខាបទ ជាបឋម ចប់

សិក្ខាបទ គម្រប់ ២ ឈ្មោះទុតិយកឋិន មានកាលហៅឧទ្ទេសិត-សិក្ខាបទខ្ទះ សេចក្ដីថា ចីវរនៃភិក្ខុសម្រេចហើយ កឋិនដោះហើយ បើភិក្ខុនៅប្រាសចាកត្រៃចីវរទាំង ៣ ផ្នត់ ឬផ្នត់ណាមួយ សូម្បីតែមួយរាត្រី ចីវរនោះ ត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ លៀងតែភិក្ខុមានជំងឺ បានអវិប្បវាសសម្មតិ នៅប្រាសចាកត្រៃចីវរបាន សង្ឆាដិ ឧត្តរាសង្គ: អន្តរវាសក: ចីវរទាំង ៣ នេះ ភិក្ខុអធិដ្ឋានតាមឈ្មោះហើយ ក៏ហៅថា ត្រៃចីវរ ត្រូវរក្សា បើមិនរក្សាទុក ចោលឲ្យអរុណថ្មីរះឡើងមក ឈ្មោះថា នៅប្រាសចាកចីវរនោះ ។

ក៏ឯទីដែលនឹងរក្សាចីវរនោះមាន ១៥ គឺស្រុក ១ ផ្ទះ ១ ឃ្លាំង ១ បញ្ជា ១ ពោងមូល ១ ប្រាសាទ ១ ប្រាសាទរលីង ១ នាវា ១ ពួករទេះ ១ ស្រែ ១ លានស្រូវ ១ ច្ចារ ១ វិហារ ១ គល់ឈើ ១ ទីវាល ១ ទីទាំងអម្បាលនេះ បើម្ចាស់របស់ម្នាក់ព័ន្ធព័ទ្ធដោយកំផែង ឬរបង ឬគូរ ភិក្ខុទុកចីវរក្នុងទីទាំងអម្បាលនេះ ក៏ឲ្យនៅក្នុងទីព័ន្ធព័ទ្ធនោះ បើទីទាំងអម្បាលនេះមិនបានព័ន្ធព័ទ្ធ ទុកចីវរក្នុងទីណា ឲ្យនៅក្នុងទីនោះ កុំលះហត្ថបាសអំពីទីនោះ បើទីនោះមានម្ចាស់ផ្សេងៗ គ្នា

ជាទីព័ន្ធព័ន្ធ ទុកចីវរក្នុងទីណា ឲ្យនៅក្នុងទីនោះ ឬនៅក្នុងទីជាទីប្រជុំ និងប្រព័ន្ធជាទីចូលចេញ កុំលះហត្ថបាសអំពីទីនោះចេញ បើទីអម្បាលនោះគេមិនបានព័ន្ធព័ន្ធ ទុកចីវរក្នុងតំបន់ណា ឲ្យនៅក្នុងតំបន់នោះ កុំលះហត្ថបាសអំពីតំបន់នោះ បើភិក្ខុមិននៅក្នុងទីដូចសម្តែងនេះ ចីវរដែលនៅប្រាសចាកនោះ ត្រូវនិស្សគ្គិយ ព្រមដោយអរុណថ្មីរះឡើងមក ត្រូវលះចីវរនោះដល់សង្ឆ ឬគណៈ ឬបុគ្គល ទើបស្ងៀកដណ្តប់បាន វិធីលះជាដើម នឹងសម្តែងទៅខាងមុខ ព្រោះហេតុនោះ តទៅខាងមុខគប្បីដឹងចុះថា របស់ត្រូវនិស្សគ្គិយហើយ ត្រូវលះជាមុន ទើបសម្តែងអាបត្តិជាច់ តទៅនឹងមិនបានសម្តែងទៀត ។ ត្រៃចីវរភិក្ខុនៅប្រាសចាកហើយ ដឹងថានៅប្រាសចាកហើយក្តី សង្ស័យក្តី សម្គាល់ថាមិនបានប្រាសចាកក្តី ក៏គង់ត្រូវនិស្សគ្គិយបាចិត្តិយ, ត្រៃចីវរភិក្ខុនៅមិនទាន់បានបច្ចុទ្ធរណៈ មិនទាន់បានលះ មិនទាន់បាត់ទៅជាដើម ភិក្ខុសម្គាល់ថាបច្ចុទ្ធរណៈហើយជាដើមក្តី សង្ស័យក្តី ដឹងថាមិនទាន់បច្ចុទ្ធរណៈជាដើមក្តី ហើយនៅប្រាសចាកចីវរនោះ ក៏គង់ត្រូវនិស្សគ្គិយបាចិត្តិយ ។ ត្រៃចីវរភិក្ខុមិនបាននៅប្រាសចាក សម្គាល់ថានៅប្រាសចាកក្តី សង្ស័យក្តី យកមកបរិភោគត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះគឺ បច្ចុទ្ធរណៈចេញហើយក្តី លះបង់ហើយជាដើម ខាងក្នុងអរុណ និងភិក្ខុមានជំងឺដែលសង្ឆសម្មតឲ្យនៅ

ប្រាសចាកត្រៃចីវរក្តី និងកិក្ខុធ្លួតជាដើមក្តី មិនត្រូវអាបត្តិ ជាអនាណត្តិក: មានអង្គ ៤ គឺ **អនិដ្ឋិតចីវរតា** សំពត់កិក្ខុអធិដ្ឋានជាត្រៃចីវរហើយ ១ **អនត្ថតកឋិនតា** មិនមានអានិសង្សកឋិន ១ **អលទ្ធសម្មតិតា** មិនបានអវិប្ប្រវាសសម្មតិ ១ **រត្តិវិប្ប្រវាសោ** នៅប្រាសចាកចីវរនោះ មួយរាត្រី លុះអរុណថ្មីរះឡើងមក ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវ និស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិនសិក្ខាបទមុន ប្លែកតែសិក្ខាបទមុន មិនបានអធិដ្ឋានមិនបានវិកប្ប ឈ្មោះថាអកិរិយា ត្រូវព្រោះមិនធ្វើ ក្នុងសិក្ខាបទនេះ ត្រូវព្រោះមិនបច្ចុទ្ធរណ:ចេញក្នុងអរុណ ឈ្មោះថា អកិរិយា ត្រូវព្រោះមិនធ្វើ ។

ទុតិយកឋិនសិក្ខាបទ គម្រប់ ២ ចប់

សិក្ខាបទ គម្រប់ ៣ ឈ្មោះតតិយកឋិន សេចក្តីថា ចីវរនៃកិក្ខុសម្រេចហើយ កឋិនដោះហើយ សំពត់អកាលចីវរ គឺសំពត់ដែលកើតក្រៅចីវរកាល និងសំពត់ដែលទាយកឲ្យចំពោះជាអកាលចីវរ ប្រគេនក្នុងចីវរកាលក្តី សំពត់ដូច្នេះ បើកើតឡើងដល់កិក្ខុ កិក្ខុដែលប្រាថ្នាគប្បីទទួលហើយប្រញាប់ធ្វើក្នុងខាងក្នុង ១០ ថ្ងៃ បើសំពត់នោះមិនល្មមគ្រាន់ដល់ការធ្វើជាសង្ឆាដិ ឬឧត្តរាសង្គ: ឬអន្តរវាសក: ចីវរណាមួយ បើប្រាថ្នាថានឹងបានអំពីញាតិនិងមិត្រសំឡាញ់ជាដើម កិក្ខុគប្បីទុកសំពត់មុននោះជាអតិរេកចីវរបានមួយខែ ដើម្បីនឹងផ្សំគ្នានឹងសំពត់ដែលប្រាថ្នា

ចង់បាននោះ បើទុកឲ្យហួសមួយខែ ដោយមិនបានអធិដ្ឋាន មិនបានវិកប្ប សូម្បីប្រាជ្ញានឹងបានចីវរដទៃ ចីវរមុនគង់ត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិន ប្លែកតែសិក្ខាបទនេះកន្ទងមួយខែ ។

តតិយកឋិនសិក្ខាបទ គម្រប់ ៣ ចប់

សិក្ខាបទ គម្រប់ ៤ ឈ្មោះបុរាណចីវរ សេចក្តីថា ភិក្ខុណាប្រើភិក្ខុនីមិនមែនញាតិ ដែលបានឧបសម្បទាឧភតោសង្ឆ គឺភិក្ខុសង្ឆនិងភិក្ខុនីសង្ឆ ឲ្យគក់ ឲ្យជ្រលក់ ឬបោក នូវចីវរចាស់ គឺចីវរដែលស្លៀកដណ្តប់រួចហើយ សូម្បីស្លៀកតែម្តង ចីវរនោះត្រូវនិស្សគ្គិយបាចិត្តិយ ។

បុរាណចីវរសិក្ខាបទ គម្រប់ ៤ ចប់

សិក្ខាបទ គម្រប់ ៥ ឈ្មោះចីវរបដិគ្គហណៈ សេចក្តីថា ភិក្ខុណាទទួលចីវរទំហំប្រវែងគួរវិកប្ប អំពីដៃភិក្ខុនីមិនមែនញាតិ ដែលបានឧបសម្បទាក្នុងឧភតោសង្ឆ ចីវរនោះត្រូវនិស្សគ្គិយបាចិត្តិយ រៀងតែប្តូរគ្នា សូម្បីតែដោយរបស់តិចតួច មិនត្រូវអាបត្តិ ។

ចីវរបដិគ្គហណសិក្ខាបទ គម្រប់ ៥ ចប់

សិក្ខាបទ គម្រប់ ៦ ឈ្មោះអញ្ញាតកវិញ្ញត្តិ សេចក្តីថា ភិក្ខុណាសូមឯង ឬប្រើអ្នកដទៃឲ្យសូមនូវចីវរដែលគួរវិកប្ប សូម្បីជាបច្ចិមប្រមាណ អំពីគ្រហស្ថមិនមែនញាតិ ក្នុងប្រយោគដែលសូមត្រូវទុក្កដ បានមកត្រូវ

និស្សគ្គិយបាចិត្តិយ រៀរតែមានសម័យ គឺកាលភិក្ខុមានចីវរគេដណ្តើមយកអស់ ឬមានចីវរបាត់អស់ ទើបសូមបាន មិនត្រូវអាបត្តិ ។ អ្នកដែលជាប់សាច់សាលោហិត ចំណែកខាងមាតាក្តី ឬខាងបិតាក្តី (រាប់អំពីចៅទួត) ដរាបដល់គូនៃជីដូនជីតាជាគម្រប់ ៧ ឈ្មោះថាញាតិ ។ ក្នុងមនុស្សមិនមែនញាតិត្រូវតិកបាចិត្តិយ គឺគេមិនមែនញាតិ ដឹងថាគេមិនមែនញាតិក្តី សង្ស័យក្តី សម្គាល់ថាជាញាតិក្តី បើសូមគង់ត្រូវបាចិត្តិយ ។ តទៅខាងមុខក្នុងពាក្យថា តិកបាចិត្តិយដូច្នេះ គប្បីដឹងដោយន័យដូចសម្តែងហើយនេះចុះ នឹងមិនពោលឲ្យពិស្តារតទៅទៀត នឹងពោលត្រឹមតែពាក្យថាតិកបាចិត្តិយប៉ុណ្ណោះ ។ គេជាញាតិ ភិក្ខុសម្គាល់ថាមិនមែនញាតិក្តី សង្ស័យក្តី ហើយសូមសំពត់ ដូចពោលមកនោះ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសូមក្នុងសម័យក្តី សូមអំពីញាតិ ឬមនុស្សបវារណាក្តី សូមដើម្បីអ្នកដទៃក្តី ផ្ទាស់ប្តូរដោយទ្រព្យរបស់ខ្លួនដែលជាកប្បិយក្តី និងភិក្ខុធ្ជតជាដើមក្តី ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ចីវររបស់ភិក្ខុដែលស្តេច ឬអ្នកលេង ឬចោរ អ្នកណាមួយដណ្តើមយកទៅ ឈ្មោះថាភិក្ខុមានចីវរគេដណ្តើមយកទៅអស់, ចីវរភិក្ខុដែលភ្លើងឆេះទៅក្តី អណ្តែតទឹកបាត់ទៅក្តី កណ្តុរឬកណ្ណៀរកាត់ក្តី ចាស់ដាច់ដាចខ្ចីចដោយស្មៀកដណ្តាប់ក្តី ដូច្នេះឈ្មោះថាមានចីវរបាត់ ឈ្មោះថាមានសម័យ, ព្រះពុទ្ធទ្រង់អនុញ្ញាតឲ្យសូមចីវរអំពីគ្រហស្ថ

មិនមែនញាតិបាន បើមិនទាន់បានសូម ទៅដល់អាវាសណាមុន នឹងកាន់យកសំពត់សម្រាប់វិហារ និងសំពត់ក្រាលលើគ្រែ លើផ្ទៃ ស្រោមពួកជារបស់សង្ឆក្នុងអាវាសនោះ មកស្ងៀកដណ្តប់ ដោយគិតនឹងប្រគល់ឲ្យវិញក៏គួរ បើមិនបានចីវរដូច្នេះ គប្បីបិទបាំងកាយដោយស្មៅ ឬស្លឹកឈើហើយសឹមមក កុំអាក្រាតកាយដើរមក បើអាក្រាតកាយដើរមកត្រូវទុក្កដ, គ្រហស្ថមានសទ្ធាពោលថា "ខ្ញុំបវារណាដោយបច្ច័យ ៤ មានចីវរជាដើម បើលោកម្ចាស់ត្រូវការដោយបច្ច័យអ្វី គប្បីប្រាប់ឬសូមខ្ញុំ ខ្ញុំនឹងប្រគេនបច្ច័យនោះដូច្នេះ" ឈ្មោះថាមនុស្សបវារណា គេបវារណាជាសង្ឆ ដឹងប្រមាណទើបគួរ គេបវារណាជាបុគ្គលចំពោះខ្លួន ដោយបច្ច័យណា ឲ្យសូមតែបច្ច័យនោះ ទាយកគេបវារណាដោយបច្ច័យទាំង ៤ ហើយគេកំណត់ដោយខ្លួនឯង ហើយគេប្រគេនចីវរតាមកាល ប្រគេនបបរ-បាយជាដើមសព្វៗថ្ងៃ ត្រូវការដោយបច្ច័យណាគេប្រគេនបច្ច័យនោះដូច្នេះ កិច្ចដែលនឹងសូមមិនមាន ទាយកណាបវារណាហើយមិនបានឲ្យ ព្រោះជាមនុស្សខ្ជៅ ឬក្ងេចទៅ ទាយកដូច្នេះឲ្យគប្បីសូម ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសូមអំពីញាតិនិងមនុស្សបវារណារបស់ខ្លួន សូមដើម្បីកិក្ខុដទៃក្តី ឬគេជាញាតិ ជាមនុស្សបវារណានៃកិក្ខុអង្គណា សូមដើម្បីកិក្ខុអង្គនោះក្តី មិនត្រូវអាបត្តិ ។ ជាអនាណត្តិក:

ព្រោះពឹងឲ្យកិក្ខុសូមអំពីញាតិ និងមនុស្សបវារណានៃកិក្ខុ ឲ្យដល់ខ្លួន មិនត្រូវអាបត្តិ ។ មានអង្គ ៤ គឺ **វិកប្បទ្វយតចីវរតា** ចីវរទំហំប្រវែងគួរនឹងវិកប្ប ១ **សមយាភាវោ** មិនមានសម័យ ១ **អញ្ញាតក-វិញ្ញត្តិ** សូមអំពីមនុស្សមិនមែនញាតិ ១ **តាយ ច បដិលាភো** បានមកដោយការសូមនោះ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវនិស្សគ្គិយ បាចិត្តិយ ។ សិក្ខាបទនេះជាសញ្ចរិត្តសមុដ្ឋាន ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តក: បណ្ណត្តិវជ្ជ: កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។

អញ្ញាតកវិញ្ញត្តិសិក្ខាបទ គម្រប់ ៦ ចប់

សិក្ខាបទ គម្រប់ ៧ ឈ្មោះតទុត្តរិ សេចក្តីថា ភិក្ខុមានចីវរដែលមនុស្សដណ្តើមយក ឬបាត់ទៅ ដូចសម្តែងហើយក្នុងសិក្ខាបទមុន បើគ្រហស្ថមិនមែនជាញាតិនាំចីវរច្រើនមកបវារណាឲ្យកិក្ខុ ភិក្ខុនោះបើមានចីវរបាត់ទាំង ៣ គប្បីត្រេកអរតែចីវរ ២ គឺចីពរ និងសង្ឃាដិ, បើបាត់ ២ គប្បីត្រេកអរតែ ១ បើបាត់តែ ១ កុំត្រេកអរឡើយ បើកិក្ខុត្រេកអរឲ្យហួសកំណត់ទៅសោត ក្នុងប្រយោគដែលសូម ត្រូវទុក្កដ ។ ចីវរដែលបានមកនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ក្នុងមនុស្សមិនមែនញាតិ ត្រូវតិកបាចិត្តិយ ។ ញាតិកិក្ខុសម្គាល់ថាមិនមែនញាតិក្តី សង្ស័យក្តី សូមហើយត្រេកអរឲ្យហួសកំណត់ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះគឺ កិក្ខុពោលថាយើងនឹងធ្វើនូវចីវរ តែ ២ សល់ក្រៅអំពីនេះនឹងយកមកប្រគល់ឲ្យវិញ ហើយយកទៅច្រើនមុនក្តី ម្ចាស់របស់ពោលថាដែលសល់នៅនោះ ចូរជារបស់លោកក្តី នឹងកាន់យកចីវរដែលទាយកគេមិនបានឲ្យ ព្រោះថាកិក្ខុមានចីវរគេដណ្តើម ឬបាត់ទៅក្តី សូមអំពីញាតិ អំពីមនុស្សបវារណាក្តី ដូរយកដោយទ្រព្យខ្លួនដែលជាកប្បិយក្តី និងកិក្ខុឆ្លួតជាដើមក្តី ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មានអង្គ ៤ គឺ **ឥទុត្តរិតា** ត្រេកអរឲ្យហួសកំណត់ ១ **អច្ឆិន្ទនិការណតា** មិនមានហេតុជាដើមថាចីវរគេដណ្តើមយកអស់ ១ **អញ្ញាតកវិញ្ញត្តិ** សូមអំពីមនុស្សមិនមែនញាតិ ១ **តាយ ច បដិលាភো** បានមកដោយការសូមនោះ ១ ព្រមទាំងអង្គ ៤ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើមដូចសិក្ខាបទមុន ។

ឥទុត្តរិសិក្ខាបទ គម្រប់ ៧ ចប់

សិក្ខាបទ គម្រប់ ៨ ឈ្មោះ បឋមឧបក្ខដ: សេចក្តីថា គ្រហស្ថមិនមែនញាតិគេចំពោះកិក្ខុ តាំងតម្លៃចីវរមានប្រាក់មាសជាដើមទុកថា យើងនឹងយកតម្លៃចីវរប៉ុណ្ណោះ ទិញចីវរប្រគេនកិក្ខុឈ្មោះនេះ កិក្ខុនោះទាយកគេមិនបានបវារណាមុន ដឹងដំណឹងឯង ប្រាថ្នាចង់បានចីវរល្អ ហើយ

ចូលទៅនិយាយនឹងទាយកថាល្អហើយ អ្នកចូរយកតម្លៃចីវរនោះ ទិញសំពត់ ឲ្យវែង ឲ្យធំ ឲ្យមានសាច់ណែន ឲ្យមានសាច់ម៉ដ្ឋ ឲ្យអាត្មាចុះ ទាយកថែមតម្លៃទិញសំពត់ដែលល្អតាមពាក្យភិក្ខុ សំពត់ដែលបានមក ត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។ ទាយកគេជាញាតិសម្គាល់ថា មិនមែនញាតិ ឬសង្ស័យ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះគឺ ភិក្ខុដែលទាយកគេនឹងទិញឲ្យល្អ បង្គាប់ឲ្យគេទិញថយចុះមកក្តី ឬឲ្យគេរកចីវរតម្លៃស្មើនឹងតម្លៃដែលគេកំណត់ទុកក្តី ឬសូមអំពីញាតិ អំពីមនុស្សបវារណាក្តី ទិញយកដោយទ្រព្យរបស់ខ្លួនក្តី និងភិក្ខុធ្លួតជាដើមក្តី ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ សិក្ខាបទនេះជាអនាណត្តិក: ជាតិកបាចិត្តិយ មានអង្គ ៣ គឺ **ចីវរេ ភិយ្យោ កាមតា** ប្រាថ្នាចង់បានចីវរឲ្យល្អលើសជាងគេកំណត់ ១ **អញ្ញាតកវិញ្ញត្តិ** សូមអំពីទាយកមិនមែនញាតិ ១ **តាយ ច បដិ-លាភោ** បានចីវរមកដោយការសូមនោះ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ បើមិនព្រមមិនត្រូវអាបត្តិ ។ សមុដ្ឋានវិធីជាដើម ដូចតទុត្តរិសិក្ខាបទ ។

បឋមឧបក្ខដសិក្ខាបទ គម្រប់ ៨ ចប់

សិក្ខាបទ គម្រប់ ៩ ឈ្មោះទុតិយឧបក្ខដ: សេចក្តីដូចបឋមឧបក្ខដ: សិក្ខាបទមុន ប្លែកតែសិក្ខាបទមុននោះម្ចាស់របស់តែម្នាក់ ភិក្ខុធ្វើការ

បៀតបៀនដល់មនុស្សម្នាក់ៗ ក្នុងសិក្ខាបទនេះម្ចាស់របស់ច្រើននាក់ ភិក្ខុ ទៅនិយាយឲ្យគេចូលហ៊ុនគ្នាទិញ ឈ្មោះថាធ្វើការបៀតបៀនដល់ជន ច្រើននាក់ ម្ចៃកគ្នាតែប៉ុណ្ណោះ សេចក្ដីក្រៅពីនោះដូចសិក្ខាបទមុន ។

ទុតិយឧបក្ខដសិក្ខាបទ គម្រប់ ៩ ចប់

សិក្ខាបទ គម្រប់ ១០ ឈ្មោះរាជសិក្ខាបទ សេចក្ដីថា ព្រះរាជា រាជមាត្យ ព្រាហ្មណ៍ ឬគហបតី គេចំពោះភិក្ខុ ប្រើទូតឲ្យយកតម្លៃ ចីវរ ទៅទិញចីវរប្រគេនភិក្ខុ បើទូតនោះមិនទិញចីវរតាមពាក្យបង្គាប់ យកតម្លៃចីវរនោះទៅប្រគេនដល់ភិក្ខុដោយពោលថា "តម្លៃចីវរនេះ គេចំពោះមកលោកម្ចាស់ ឲ្យខ្ញុំនាំមក សូមលោកម្ចាស់ទទួលយកតម្លៃ ចីវរនេះ" ដូច្នេះ ភិក្ខុនោះ គប្បីពោលនឹងទូតនោះថា យើងទទួលតម្លៃ ចីវរមិនបាន យើងទទួលបានតែចីវរដែលជារបស់គួរ ក្នុងកាលដែល គួរទទួល បើទូតនោះសួរភិក្ខុថា វេយ្យាវច្ចករបស់លោកម្ចាស់មានឬគ្មាន ដូច្នេះសោត ភិក្ខុត្រូវការដោយចីវរ គប្បីសម្ដែងប្រាប់នូវអ្នករក្សាវត្ត ឬ ឧបាសក ឲ្យជាវេយ្យាវច្ចករ ដោយពាក្យថា អ្នកនោះគេជាវេយ្យាវច្ចករ នៃភិក្ខុទាំងឡាយ កុំពោលថា អ្នកចូរឲ្យដល់អ្នកនោះ អ្នកនោះគេនឹង ទុកដាក់ អ្នកនោះគេនឹងជួរ គេនឹងទិញចីវរ ពោលដូច្នេះមិនគួរ បើទូត នោះប្រគល់តម្លៃចីវរឲ្យវេយ្យាវច្ចករ ដែលភិក្ខុប្រាប់នោះហើយ

គេត្រឡប់មកប្រាប់ដល់ភិក្ខុ ឬគេប្រើអ្នកដទៃឲ្យមកប្រាប់ថា លោកម្ចាស់ប្រាប់វេយ្យាវច្ចករណា វេយ្យាវច្ចករនោះ ខ្ញុំផ្តាំឲ្យគេដឹងស្រេចហើយ លោកម្ចាស់ចូរនិមន្តទៅចុះ គេនឹងប្រគេនចីវរដល់លោកម្ចាស់ក្នុងកាលគួរ ដូច្នេះ ភិក្ខុមានសេចក្តីត្រូវការដោយចីវរ គប្បីចូលទៅរកវេយ្យាវច្ចករ គប្បីទារ ២ ដង ឬ ៣ ដង ដោយពាក្យថាយើងត្រូវការដោយចីវរ តែកុំពោលថា អ្នកចូរឲ្យចីវរដល់យើង យកចីវរមកឲ្យយើង ប្តូរចីវរឲ្យយើង ទិញចីវរមកឲ្យយើង ពោលដូច្នេះមិនគួរ ថាបើភិក្ខុទៅទារ ២ ដង ឬ ៣ ដង បានចីវរសម្រេចមកក៏ជាការប្រពៃ បើមិនបានចីវរមកសោត ភិក្ខុនោះគប្បីចូលទៅឈរស្ងៀមចំពោះមុខត្រឹម ៤ ដង ៥ ដង ៦ ដង ជាយ៉ាងច្រើន កុំអង្គុយលើអាសនៈ កុំទទួលអាមិស កុំសម្តែងធម៌ឲ្យគេ បើគេសួរថា លោកម្ចាស់និមន្តមកមានធុរៈអ្វី គប្បីពោលថា អ្នកចូរដឹងចុះ បើភិក្ខុអង្គុយលើអាសនៈ ឬទទួលអាមិស ឬសម្តែងធម៌ ឈ្មោះថាកាច់ឥរិយាបថឈរ ធ្វើហេតុដែលមកឲ្យវិនាសចេញ បើភិក្ខុស្ងៀមចំពោះមុខ អស់វារៈ ៦ ដងជាយ៉ាងច្រើន បានចីវរសម្រេចមកក៏ជាការល្អ បើមិនបានសម្រេច តទៅភិក្ខុព្យាយាមឈរលើសជាង ៦ ដង ក្នុងប្រយោគព្យាយាមត្រូវទុក្កដ បានចីវរសម្រេចមក ចីវរនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ បើមិនបានសម្រេចមកដោយឥរិយាបថឈរ ៦ ដងជាយ៉ាងច្រើនហើយ តម្លៃចីវរគេនាំមកអំពីអ្នកណា ភិក្ខុគប្បីទៅរកអ្នកនោះខ្ជួន

ឯង ឬគប្បីបញ្ជូនទូត ឲ្យទៅប្រាប់ថា អ្នកបញ្ជូនតម្លៃចីវរមកចំពោះ ភិក្ខុណា របស់នោះមិនសម្រេចប្រយោជន៍តិចតួចដល់ភិក្ខុនោះទេ អ្នក ចូរទារយកតម្លៃរបស់អ្នកចុះ កុំឲ្យតម្លៃរបស់អ្នកវិនាសទៅឡើយ នេះ ជាការសមគួរក្នុងការនោះ បើភិក្ខុមិនទៅដោយខ្លួនឯង ឬ មិនប្រើបម្រើឲ្យ ទៅប្រាប់ម្ចាស់របស់ដើម ត្រូវវត្តកេទទុក្កដ ឯកប្ចិយការក: ដែលភិក្ខុ សម្តែងដូច្នេះ ព្រះពុទ្ធអង្គ ទ្រង់អនុញ្ញាតឲ្យទារបាន ៣ ដង ឈរបាន ៦ ដង ដោយកំណត់យ៉ាងឧក្រិដ្ឋ ព្រោះហេតុនោះអនុញ្ញាតឲ្យឈរ ២ ដង ជួសទារ ១ ដង ដោយហេតុនេះ បើភិក្ខុទារតែមួយជំពូក មិនឈរ ទារបាន ៦ ដង បើគ្រាន់តែឈរមិនបានទារឡើយ ឈរបាន ១២ ដង បើធ្វើទាំងពីរប្រការ ទារម្តង ខាតឈរ ២ ដង ភិក្ខុអង្គណា ក្នុងមួយ ថ្ងៃទៅរៀយៗ ទារគ្រប់ ៦ ដង ឬទៅតែម្តង ទារគ្រប់ ៦ ដងក្តី មួយ ទៀត ក្នុងមួយថ្ងៃទៅរៀយៗ ឈរគ្រប់ ១២ ដង ឬទៅតែម្តង ឈរ ក្នុងទីនោះៗ ១២ អន្ទើ ភិក្ខុនោះ ឈ្មោះថាកាច់ឥរិយាបថឈរ កាច់ការ ទារចេញអស់ ដែលទៅទារទៅឈរក្នុងថ្ងៃផ្សេងៗ មិនត្រូវពោល ។ កប្ចិយការក:ដែលទាយកសម្តែងឯង ភិក្ខុមិនបានសម្តែងនោះ ភិក្ខុនឹង ទារ ១ រយដងក៏គួរ ។ កប្ចិយការក:ណា ដែលភិក្ខុនិងទាយកមិនបាន សម្តែងឡើយ គឺកប្ចិយការក:ទទួលតម្លៃយកអាសារខ្លួនឯង ចំពោះ មុខភិក្ខុ ចំពោះមុខទាយកក្តី និងកប្ចិយការក:ដែលទទួលតម្លៃទុកកំចាំង

ក្តី ទាំងពីរជំពូកនេះ ភិក្ខុនឹងទារមិនបាន ក្នុងការទារនិងការឈរ ហួសកំណត់ ត្រូវតិកបាចិត្តិយ ។ ទារនិងឈរមិនទាន់គ្រប់កំណត់ សម្គាល់ថាហួសក្តី សង្ស័យក្តី ព្យាយាមបានចីវរមកត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុទារតាមកំណត់ក្តី ឈរតាមកំណត់ក្តី មិនបានទារ កប្ប៊ិយការក:នោះទិញមកប្រគេនដោយខ្លួនឯងក្តី ម្ចាស់របស់ដើមទារមកប្រគេនដោយខ្លួនឯងក្តី និងភិក្ខុធ្ងួតជាដើមក្តី ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាអនាណត្តិក:មានអង្គ ៤ គឺ **កប្ប៊ិយ-ការកស្ស ភិក្ខុនា ជិទ្ធិដ្ឋភាវោ** *កប្ប៊ិយការក:ភិក្ខុសម្តែង ១* **ទូតេន អប្ប៊ិតតា** *ទូតប្រាប់កប្ប៊ិយការក:ឲ្យដឹងហើយប្រាប់ភិក្ខុឲ្យដឹងផង ១* **តទុត្តរឺ ភយាមោ** *ព្យាយាមទារនិងឈរឲ្យហួសកំណត់ ១* **តេន ភយាមេន បដិលាភោ** *បានចីវរមកដោយព្យាយាមនោះ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើមដូចអញ្ញាតកវិញ្ញត្តិសិក្ខាបទ ។*

រាជសិក្ខាបទ គម្រប់ ១០ ចប់

ចីវរវគ្គជាបឋម ចប់

កោសិយវគ្គ គម្រប់ ២ មាន ១០ សិក្ខាបទ៖

កោសិយសិក្ខាបទ ជាបឋម សេចក្តីថា ភិក្ខុណាស្មាច់ឯង ឬប្រើ

គេឲ្យស្មាច់នូវសំពត់សន្ទ្ធតលាយដោយសូត្រ សូម្បីតែមួយសរសៃដែលអណ្តែតតាមខ្យល់មកធ្លាក់ចូលក្នុងវេលាស្មាច់ សន្ទ្ធតនោះត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ សន្ទ្ធតនោះ គឺ គ្រឿង កម្រាលមួយជំពូក ដែលគេយករោមចៀម ឬ សរសៃសូត្រលាតតម្ងួតគ្នាក្រាលលើផ្ទៃដែលស្មើ ហើយយកទឹកបាយជាដើមចាក់ចុះធ្វើ ឈ្មោះថាស្មាច់មិនបានត្បាញ ហៅថាសន្ទ្ធត ក្នុងសន្ទ្ធតដែលភិក្ខុធ្វើឲ្យសម្រេចដោយខ្លួនឯង ត្រូវចតុក្ក-បាចិត្តិយ ក្នុងពាក្យថាចតុក្កបាចិត្តិយ នឹងពោលទៅខាងមុខ ។ ភិក្ខុធ្វើឯងឬប្រើឲ្យគេធ្វើដើម្បីអ្នកដទៃក្តី បាននូវសន្ទ្ធតដែលបុគ្គលដទៃធ្វើមកប្រើប្រាស់ក្តី ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុធ្វើដើម្បីជាពិតានជាដើមក្តី និងភិក្ខុធ្ងួតជាដើមក្តី មិនត្រូវអាបត្តិ ។ សិក្ខាបទនេះជាសាណត្តិក: មានអង្គ ៣ គឺ **កោសិយមិស្សកការោ** *សន្ទ្ធតលាយដោយសូត្រ ១* **អត្តនោ អត្ថាយ សន្ទ្ធតស្ស ការណការាបនំ** *ធ្វើឯងឬឲ្យគេធ្វើនូវសន្ទ្ធតដើម្បីខ្លួន ១* **បដិលាភো** *បានមក ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សិក្ខាបទនេះមានសមុដ្ឋាន ៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តក: បណ្ណត្តិវជ្ជ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។*

<u>កោសិយសិក្ខាបទ ជាបឋម ចប់</u>

សុទ្ធកាឡកសិក្ខាបទ គម្រប់ ២ សេចក្ដីថា ភិក្ខុណាស្មាច់ឯងឬប្រើគេឲ្យស្មាច់ នូវសន្ទ្ធតដោយពោមចៀមខ្មៅសុទ្ធ មិនមានពណ៌ដទៃលាយផង សន្ទ្ធតនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

សុទ្ធកាឡកសិក្ខាបទ គម្រប់ ២ ចប់

ទ្វេភាគសិក្ខាបទ គម្រប់ ៣ សេចក្ដីថា ភិក្ខុណាស្មាច់ឯងឬប្រើគេឲ្យស្មាច់ នូវសន្ទ្ធតថ្មី គឃ្ជីយកពោមចៀមខ្មៅសុទ្ធ ២ ភាគ ពោមចៀមសសុទ្ធ ១ ភាគ ជាគម្រប់ ៣ ពោមចៀមលឿង ១ ភាគជាគម្រប់ ៤ បញ្ជូលផ្សំគ្នាស្មាច់ បើភិក្ខុមិនថ្នឹងពោមចៀម ជា ៤ ចំណែកដូច្នេះ ឲ្យគេស្មាច់សន្ទ្ធតថ្មី សន្ទ្ធតនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ សន្ទ្ធតដែលត្រូវនិស្សគ្គិយទាំង ៣ ប្រការនេះ សូម្បីភិក្ខុលះហើយត្រឡប់បានមកវិញនឹងប្រើប្រាស់ក៏មិនគួរ ។

ទ្វេភាគសិក្ខាបទ គម្រប់ ៣ ចប់

ឆព្ជស្សសិក្ខាបទ គម្រប់ ៤ សេចក្ដីថា ភិក្ខុស្មាច់ឯងឬប្រើគេឲ្យស្មាច់ នូវសន្ទ្ធតថ្មី គឃ្ជីប្រើប្រាស់ឲ្យបាន ៦ វស្សាសិន បើមិនទាន់គ្រប់ ៦ វស្សា ភិក្ខុលះក្ដី មិនលះក្ដី នូវសន្ទ្ធតនោះ ហើយស្មាច់ឯងក្ដី ប្រើគេឲ្យស្មាច់ក្ដី នូវសន្ទ្ធតថ្មីដទៃទៀតខាងក្នុង ៦ វស្សា សន្ទ្ធតថ្មីនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ រ៉ៀរតែភិក្ខុមានជំងឺបានសន្ទ្ធតសម្ផតិ មិនត្រូវអាបត្តិ ។

ឆព្ជស្សសិក្ខាបទ គម្រប់ ៤ ចប់

និសីទនសន្ថតសិក្ខាបទ គម្រប់ ៥ សេចក្ដីថា ភិក្ខុណាស្មាច់ឯង ឬប្រើគេឲ្យស្មាច់នូវសន្ថតសម្រាប់រងបង្គុយដែលមានជាយ គឃ្លីកាត់យកសន្ថតចាស់ឲ្យមូលឬជាបួនជ្រុងមួយចំអាម ដោយចំអាមព្រះសុគត មកផ្សំបញ្ចូលផងក្នុងកន្ទែងណាមួយ នៃសន្ថតថ្មី ឬរុះចេញផ្សំបញ្ចូលគ្នាដើម្បីនឹងធ្វើសន្ថតថ្មីឲ្យខូចពណ៌ បើភិក្ខុមិនធ្វើដូច្នោះ ហើយស្មាច់ឯង ឬប្រើគេឲ្យស្មាច់នូវសន្ថតសម្រាប់រងបង្គុយថ្មី សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

និសីទនសន្ថតសិក្ខាបទ គម្រប់ ៥ ចប់

ឯឡកលោមសិក្ខាបទ គម្រប់ ៦ សេចក្ដីថា ភិក្ខុណាមានដំណើរទៅផ្លូវឆ្ងាយ មានរោមចៀមកើតឡើងអំពីសង្ឆ ឬគណៈជាដើម កាលបើប្រាថ្នាគឃ្លីទទួលនូវរោមចៀមនោះ លុះទទួលហើយ មិនមានអ្នកជួយនាំទៅ គឃ្លីនាំទៅដោយខ្លួនឯង បានចម្ងាយ ៣ យោជន៍ ជាយ៉ាងច្រើន បើនាំទៅឆ្ងាយជាង ៣ យោជន៍ សូម្បីមិនមានអ្នកជួយនាំទៅរោមចៀមនោះ ក៏គង់ជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

ឯឡកលោមសិក្ខាបទ គម្រប់ ៦ ចប់

ឯឡកលោមធោវាបនសិក្ខាបទ គម្រប់ ៧ សេចក្ដីថា ភិក្ខុណាប្រើភិក្ខុនី មិនមែនញាតិ ដែលឧបសម្បទាហើយក្នុងឧកតោសង្ឆ ឲ្យបោក

ឬជ្រលក់ ឬឲ្យសិតនូវពោមចៀម ពោមចៀមនោះជានិស្សគ្គិយ ភិក្ខុត្រូវ
បាចិត្តិយ ។

សិក្ខាបទទាំង ៦ នេះ មានសមុដ្ឋានវិធីជាដើមដូចកោសិយសិក្ខាបទ ។
សិក្ខាបទទាំង ៧ នេះ ពោលមកដោយសង្ខេប ។

ឯឡកលោមធោវាបនសិក្ខាបទ គម្រប់ ៧ ចប់

រូបិយសិក្ខាបទ គម្រប់ ៨ សេចក្តីថា ភិក្ខុណាទទួលឯង ឬប្រើគេ
ឲ្យទទួលនូវរូបិយ គឺមាសនិងប្រាក់ដែលគេឲ្យ ឬធ្លាក់នៅក្នុងទីណាមួយ
មិនមានគេកាន់គួចក្តី កាន់យកដើម្បីប្រយោជន៍ខ្លួនឯង ឬត្រេកអរក្នុង
រូបិយដែលគេទុកដាក់ឲ្យក្តី រូបិយនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

មាសជារូបព័ណ៌ក្តី មាសដុំក្តី ប្រាក់ជារូបព័ណ៌ក្តី ប្រាក់ដុំក្តី
កហាបណៈក្តី មាសកទង់ដែងក្តី មាសកស្ពាន់ក្តី មាសកធ្វើដោយឈើ
មាសកធ្វើដោយជ័រក្តី ដោយកាកល័ក្ខក្តីឬដោយវត្ថុណាមួយ ដែលគេប្រើ
ទិញដូរជួសប្រាក់បាន ប្រើជួសប្រាក់ក្នុងប្រទេសណា ក្នុងកាលណា
ឈ្មោះថាប្រាក់ក្នុងប្រទេសនោះ ក្នុងកាលនោះ មាសប្រាក់ទាំងនេះ
ហៅថារូបិយ ជានិស្សគ្គិយវត្ថុ ។

កែវមុត្តា កែវមណី កែវពិទូរ្យ ស័ង្ខ ដែលគេដុសខាត់ហើយ សិលាជាគ្រឿងប្រដាប់ កែវប្រពាឡ កែវទទឹម កែវមោរ៉ា ស្រូវប្រាំពីរប្រការ ខ្ញុំប្រុស ខ្ញុំស្រី ស្រែ ចម្ការ ទីដីចម្ការផ្លាឈើ ផ្ទៃឈើ ជាដើម ទាំងអម្បាលនេះជាទុក្កដវត្ថុ ឲ្យកើតអាបត្តិទុក្កដ ។

អម្ពោះធ្មៃ សំពត់កប្បាស អបរណ្ណជាតិ គឺសណ្តែក លូផ្សេងៗ ភេសជ្ជៈ មានសប្ប៊ី ប្រេង ទឹកឃ្មុំ ទឹកអំពៅជាដើម ទាំងអម្បាលនេះ ជាកប្ប៊ិយវត្ថុ ភិក្ខុទទួលមិនត្រូវអាបត្តិ ។

ក្នុងនិស្សគ្គិយវត្ថុ ភិក្ខុទទួលឯង ឬឲ្យអ្នកដទៃទទួលដើម្បីខ្លួន ឬគេទុកដាក់ឲ្យក្នុងទីចំពោះមុខ គេពោលថា របស់នេះជារបស់លោកម្ចាស់ ឬរបស់នោះនៅក្នុងទីកំបាំង គ្រាន់តែម្ចាស់របស់លះឲ្យដោយកាយនិងវាចា ឬឲ្យដោយកាយវិការឲ្យដឹងថា "ប្រាក់មាសរបស់ខ្ញុំ មាននៅក្នុងទីឯណោះ ប្រាក់មាសនោះ ចូរជារបស់លោកម្ចាស់ចុះ" ដូច្នេះ កាលគេពោលដូច្នោះ ភិក្ខុមិនឃាត់ដោយវាចា ក៏ឈ្មោះថាត្រេកអររូបិយដែលគេទុកដាក់ឲ្យ ជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ១០ តាមវត្ថុនោះ រូបិយត្រូវនិស្សគ្គិយដូច្នេះហើយ គប្ប៊ីលះកណ្តាលជំនុំសង្ឆមួយជំពូក ដោយពាក្យថា **អហំ ភន្តេ រូបិយំ បដិគ្គហេសឹ ឥទំ មេ និស្សគ្គិយំ ឥមាហំ សង្ឆស្ស និស្សជ្ជាមិ** ដូច្នេះ បពិត្រព្រះសង្ឆដ៏ចម្រើន ខ្ញុំទទួលនូវរូបិយហើយ រូបិយនេះជារបស់ខ្ញុំ

ត្រូវនិស្សគ្គិយ ខ្ញុំលះរូបិយនេះដល់សង្ឆដូច្នេះ បើគ្រហស្ថណាមួយមក ក្នុងទីលះនោះ ឲ្យសង្ឆគប្បីពោលនឹងគេថា អ្នកចូរដឹងវត្ថុនេះ បើគេសួរ ថារបស់នេះ នឹងឲ្យខ្ញុំយកអ្វីមក ភិក្ខុកុំគប្បីបង្គាប់ថា ឲ្យយកវត្ថុនោះ១ មក គប្បីប្រាប់តែរបស់គួរ ថាសប្ប៊ិ នវនីតជាដើម ជារបស់គួរដល់ភិក្ខុ បើគ្រហស្ថនោះគេរករបស់ដែលគួរមកដោយរូបិយនោះ ភិក្ខុទាំងពួងគប្បី ចែកគ្នាបរិភោគ រៀងតែភិក្ខុដែលទទួលរូបិយនោះ វត្ថុអ្វីដែលកើតអំពីរូបិយ នោះ សូម្បីអ្នកដទៃបានមកប្រគេនក្តី ដោយហោចទៅ សូម្បីតែម្ជុប់ដើម ឈើ ដែលកើតអំពីរូបិយនោះក្តី ភិក្ខុអ្នកទទួលរូបិយនោះមិនគួរនឹង បរិភោគឡើយ ថាបើគ្រហស្ថនោះគេមិនចង់យករូបិយនោះទៅទិញរបស់ មកឲ្យ សង្ឆគប្បីពឹងគេថាអ្នកចូរចោលរបស់នោះចេញ បើគេចោល ក្នុងទីណាមួយ ឬគេកាន់យកទៅក្តី កុំគប្បីឃាត់គេឡើយ បើគ្រហស្ថ នោះគេមិនចោលសោត សង្ឆគប្បីសម្មតភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យ ជាអ្នកចោលរូបិយ ភិក្ខុបានសម្មតិនោះ កុំធ្វើនិមិត្តកំណត់សម្គាល់ក្នុងទី ដែលធ្លាក់ចុះ ឲ្យគប្បីខ្ជើមដូចលាមកហើយចោលរូបិយនោះទៅ បើភិក្ខុ នោះ ធ្វើនិមិត្តកំណត់ទីដែលធ្លាក់នោះ ត្រូវទុក្កដ ។ ក្នុងរូបិយត្រូវតិក- បាចិត្តិយ ។ មិនមែនរូបិយ ភិក្ខុសម្គាល់ថារូបិយ ឬសង្ស័យហើយទទួល ឬទទួលនិស្សគ្គិយវត្ថុ ដើម្បីអ្នកដទៃមានសង្ឆនិងចេតិយជាដើម ឬទទួល ទុក្កដវត្ថុមានកែវមុក្តា កែវមណីជាដើម ដើម្បីខ្លួននិងអ្នកដទៃក្តី ទាំង អម្បាលនេះត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺគេប្រគេនរូបិយ ឬគេទុកដាក់ឲ្យក្នុងទីកំបាំង ឬចំពោះមុខ ពោលថារបស់នេះ ចូរជាបច្ច័យរបស់ព្រះករុណា បើភិក្ខុត្រេកអរដោយចិត្ត ចង់នឹងកាន់យក ហើយឃាត់ចេញដោយកាយ ឬវាចា ថារបស់នេះមិនគួរ ឬមិនឃាត់ដោយកាយនិងវាចា មានចិត្តបរិសុទ្ធមិនត្រេកអរដោយគិតថារបស់នេះមិនគួរដល់យើងក្តី ដូច្នេះក៏គួរ មិនមានទោស ។ ភិក្ខុកាន់យកឯង ឬឲ្យគេកាន់យកនូវរូបិយរបស់គ្រហស្ថដែលធ្លាក់នៅក្នុងអាវាម ឬខាងក្នុងទីលំនៅនៃខ្លួនដោយគិតថារបស់អ្នកណា អ្នកនោះគេនឹងមកយកទៅដូច្នេះ ដោយន័យក្នុងរតន-សិក្ខាបទក្តី និងភិក្ខុធ្លាប់ជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ជាសាណត្តិក: មានអង្គ ៣ គឺ **ជាតរូបរជតភាវោ** របស់នោះជាប្រាក់មាស ដែលជានិស្សគ្គិយវត្ថុ ១ **អត្តុទ្ទេសិកតា** ចំពោះជារបស់ខ្លួន ១ **បដិគ្គហណាទីសុ អញ្ញតរភាវោ** ទទួលឯង ឬប្រើគេឲ្យទទួល ឬគេទុកដាក់ឲ្យហើយត្រេកអរយក ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើមដូចសញ្ចរិត្ត-សិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាសិយា កិរិយា ត្រូវព្រោះធ្វើនូវការទទួលក៏មាន និងសិយា អកិរិយា ត្រូវព្រោះមិនធ្វើនូវការហាមឃាត់នូវរូបិយដែលគេទុកដាក់ឲ្យក៏មាន ។

រូបិយសិក្ខាបទ គម្រប់ ៨ ចប់

រូបិយសំវោហារសិក្ខាបទ គម្រប់ ៩ សេចក្តីថា ភិក្ខុណា លក់ ទិញ ផ្ទាស់ប្តូរដោយរូបិយមានប្រការផ្សេងៗ របស់នោះត្រូវនិស្សគ្គិយបាចិត្តិយ ព្រះពុទ្ធអង្គទ្រង់ឃាត់អាការដែលទទួលនិស្សគ្គិយវត្ថុ និងទុក្កដវត្ថុដោយសិក្ខាបទមុន ព្រះពុទ្ធអង្គទ្រង់ឃាត់អាការដែលផ្ទាស់ប្តូរនិស្សគ្គិយវត្ថុ និងទុក្កដវត្ថុដោយសិក្ខាបទនេះ ព្រោះហេតុនោះ ភិក្ខុយកទុក្កដវត្ថុនិងកប្បិយ-វត្ថុទិញផ្ទាស់ប្តូរដោយទុក្កដវត្ថុក្តី យកទុក្កដវត្ថុផ្ទាស់ប្តូរដោយអកប្បិយវត្ថុក្តី ត្រូវទុក្កដ ។ ក៏ឯភិក្ខុយកនិស្សគ្គិយវត្ថុទិញផ្ទាស់ប្តូរដោយនិស្សគ្គិយវត្ថុ ឬទុក្កដវត្ថុ ឬកប្បិយវត្ថុក្តី ឬយកទុក្កដវត្ថុនិងកប្បិយវត្ថុផ្ទាស់ប្តូរនិស្សគ្គិយវត្ថុក្តី ទាំងអម្បាលនេះ ត្រូវនិស្សគ្គិយបាចិត្តិយ ។ របស់ដែលបានមកជានិស្សគ្គិយ គប្បីលះក្នុងកណ្តាលសង្ឆ និងគប្បីបដិបត្តិក្នុងរបស់ដែលលះនោះ ដូចក្នុងសិក្ខាបទមុន និងភិក្ខុធ្លួតជាដើម មិនត្រូវអាបត្តិ ជាអនាណត្តិក: មានអង្គ ២ គឺ **យំ អត្តនោ ឧនេន បរិវត្តេតិ តស្ស ភ ឧនស្ស ភ រូបិយភាវោ ចេ** *របស់ដែលផ្ទាស់ប្តូរមកក្តី ទ្រព្យរបស់ខ្លួន ដែលនឹងយកទៅផ្ទាស់ប្តូរក្តី ខាងណាមួយ ជារូបិយដែលជានិស្សគ្គិយវត្ថុ ១* **បរិវត្តនញ្ច** *សម្រេចក្នុងការទិញលក់ផ្ទាស់ប្តូរគ្នា ១ ព្រមដោយអង្គ ២ នេះទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចសិក្ខាបទមុន ប្លែកតែសិក្ខាបទនេះជាកិរិយា កើតអំពីធ្វើនូវការផ្ទាស់ប្តូរ ។*

<u>រូបិយសំវោហារសិក្ខាបទ គម្រប់</u> ៩ ចប់

កយវិក្កយសិក្ខាបទ គម្រប់ ១០ *សេចក្ដីថា* *ភិក្ខុណាទិញលក់ផ្ទាស់ប្ដូរ*
កប្បិយវត្ថុដោយកប្បិយវត្ថុមានប្រការផ្សេងៗ *មានចីវរនិងបិណ្ឌបាតជា*
ដើមជាមួយគ្រហស្ថ *របស់នោះត្រូវនិស្សគ្គិយ* *ភិក្ខុត្រូវបាចិត្តិយ* ។

ភិក្ខុពោលនឹងគ្រហស្ថថា *អ្នកចូរឲ្យនូវរបស់នេះ* *ដោយរបស់នេះក្ដី*
អ្នកយករបស់នេះទៅ *ឲ្យរបស់នោះមកយើងក្ដី* *យករបស់នេះដូរនឹងរបស់*
នេះក្ដី *យករបស់នេះទៅ* *ចូរធ្វើរបស់នេះឲ្យយើងក្ដី* *ដូច្នេះជាដើមត្រូវ*
ទុក្កដ ។ *កាន់យកកប្បិយកណ្ដាំនៃអ្នកដទៃមក* *ឈ្មោះថាទិញ* *ឲ្យកប្បិយ-*
កណ្ដារបស់ខ្លួនទៅ *ឈ្មោះថាលក់* *ព្រោះហេតុនោះ* *ភិក្ខុឲ្យកប្បិយកណ្ដា*
របស់ខ្លួនទៅហើយ *កាន់យកកប្បិយកណ្ដាណានៃគ្រហស្ថមក* *រៀរចាក*
សហធម្មិកទាំង ៥ *សូម្បីជារបស់មាតា* *ដោយវាចាជាពាក្យផ្ទាស់ប្ដូរ*
កប្បិយកណ្ដានោះត្រូវនិស្សគ្គិយ *គប្បីលះវត្ថុដែលជានិស្សគ្គិយនោះដល់*
សង្ឆ *ឬគណៈ* *ឬបុគ្គល* *ភិក្ខុឲ្យរបស់បរិភោគ* *ឬវត្ថុអ្វីដល់គ្រហស្ថហើយ*
ពោលថា *អ្នកចូរបរិភោគរបស់នេះ* *អ្នកចូរកាន់យករបស់នេះ* *ហើយ*
យករបស់នោះមកឲ្យយើង *ឬធ្វើរបស់នេះឲ្យយើង* *ហើយប្រើឲ្យយក*
ទឹកជ្រលក់ជាដើមមកឲ្យក្ដី *ឬធ្វើបរិក្ខារមានធម្មក្រកជាដើម* *និងឲ្យ*
ធ្វើនវកម្មមានជម្រះដី *ស្មៅ* *ជាដើម* *ដូច្នេះត្រូវនិស្សគ្គិយបាចិត្តិយ* ។ *បើ*
របស់នឹងគប្បីលះមាន *ក៏គប្បីលះជាមុន* *បើរបស់មិនមាន* *គប្បីសម្ដែង*
អាបត្តិបាចិត្តិយ *តែប៉ុណ្ណោះ* ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុសួរថ្ងៃរបស់ថ្ងៃប៉ុន្មានក្តី ប្រាថ្នានឹងកាន់យកកណ្ដាអំពីដៃអ្នកណា រៀរចាកអ្នកនោះចេញ ពឹងអ្នកដទៃដោយហោចទៅ សូម្បីកូនឬបងអ្នកម្ចាស់របស់កណ្ដានោះឲ្យជាកប្ប៊ីយ-ការ:ផ្ទ្ងាស់ប្ដូរជួស ប្រាប់ថាអ្នកចូរយកវ:ប់ៈ ដូរ:ប់ៈ មកឲ្យយើងដូច្នេះក្តី នឹងពោលឲ្យ:ួចចាកកយ:ិក្ដយ: ដូចភិក្ខុដើ:ផ្ទ:ទៅមានតែអង្ករ ហើយប្រាថ្នាចង់បានបាយ និយាយនឹងម្ចាស់បាយថា អង្ករយើងមាន យើងមិនត្រូ:ការ យើងត្រូ:ការដោយបាយដូច្នេះ ម្ចាស់បាយយកអង្ករទៅ ឲ្យបាយមកភិក្ខុក្តី និងភិក្ខុ:ួតជាដើមក្តី មិនត្រូ:អាបត្តិ ។ ជាអនាណត្តិក: មានអង្គ ៣ គឺ **យំ អត្តនោ ឧនេន បរិ:ត្តេតិ យេន ច បរិ:ត្តេតិ តេសំ កប្ប៊ីយ:ត្ថុតា** ៖ របស់ខ្លួនដែលយកទៅដូ:ក្តី ៖ របស់អ្នកដទៃដែលខ្លួននឹងដូ:មកក្តី ទាំង ២ នេ:ជាកប្ប៊ីយកណ្ដា ៖ របស់គួ: ១ **អសហ:ធម្ម:ិកតា** ម្ចាស់ :ត្ថុនោ:ជាគ្ :ហស្ថមិនមែនសហ:ធម្ម:ិក ១ **ក:យ:ិ:ាយ:ាបជ្ជ:ំ** ដូ:ដោយ:ិ:ិយាដូ: ដូចពោលហើយ ១ ព្ :មដោយអង្គ ៣ នេ: ទើបត្រូ:និ:្ សគ្ គិ:ិ:ាបាចិ:ិ:ិ:

បត្តវគ្គ គម្រប់ ៣ មាន ១០ សិក្ខាបទ៖

បត្តសិក្ខាបទ ជាបឋម សេចក្ដីថា អតិរេកបាត្រ គឺបាត្រមិនទាន់បានអធិដ្ឋាន មិនទាន់បានវិកប្ប ភិក្ខុទុកបានត្រឹម ១០ ថ្ងៃជាយ៉ាងក្រៃពេក កាលបើភិក្ខុទុកបាត្រនោះឲ្យហួស ១០ ថ្ងៃទៅ មិនបានអធិដ្ឋាននិងវិកប្ប អរុណគម្រប់ ១១ រះឡើងមក បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

បាត្រមាន ២ យ៉ាង គឺបាត្រដែក ១ បាត្រដី ១ បាត្រប្រកបដោយប្រមាណជាសមណសារូបហើយ ទើបគួរអធិដ្ឋាននិងវិកប្ប ប្រមាណបាត្រដែលគួរអធិដ្ឋាននិងវិកប្បនោះ នឹងសម្ដែងទៅខាងមុខ វិនិច្ឆ័យក្រៅនោះ ដូចបឋមកឋិនសិក្ខាបទ ។

<u>បត្តសិក្ខាបទ ជាបឋម</u> ចប់

ឩនបញ្ចពន្ធនសិក្ខាបទ គម្រប់ ២ សេចក្ដីថា បាត្របែកប្រេះប្រមាណពីរធ្នាប់ខាងក្រោមអំពីកណ្ដាប់មាត់ឈ្មោះថាមានចំណង ១ អន្ទើ ភិក្ខុណាមានបាត្រ ដែលមានចំណងមិនទាន់គ្រប់ ៥ អន្ទើ ហើយសូមបាត្រថ្មីអំពីបុគ្គលមិនមែនញាតិ មិនមែនបវារណា បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ភិក្ខុនោះគប្បីយកបាត្រនោះទៅធ្វើវិនយកម្ម លះកណ្ដាលជំនុំសង្ឆ សង្ឆទាំងពួងគប្បីកាន់យកបាត្ររបស់ខ្លួនគ្រប់ៗអង្គទៅកាន់ទីប្រជុំ

សម្មតិកិក្ខុអ្នកប្រកបដោយអង្គ ៥ ឲ្យជាអ្នកប្ជូរបាត្រ កិក្ខុដែលបានសម្មតិនោះ គប្បីយកបាត្រដែលលះនោះប្រគេនដល់ព្រះមហាថេរ យកបាត្រព្រះមហាថេរប្រគេនដល់អនុត្ថេរ ប្ជូរដូច្នេះតាមលំដាប់ចុះទៅ លុះដល់កិក្ខុជាសង្ឃនវក:អង្គុយក្នុងទីបំផុតនៃអាស្នា ហើយយកបាត្រនៃកិក្ខុជាសង្ឃនវក:នោះ ឲ្យដល់កិក្ខុអ្នកលះបាត្រនោះ ហើយបង្គាប់ថាបាត្រនេះជាបាត្ររបស់លោក លោកចូរបរិភោគដរាបដល់បែកចុះ កុំលះចោល កុំឲ្យទៅអ្នកដទៃ បដិបត្តិដូច្នេះជាសេចក្តីប្រពៃក្នុងបាត្រនោះ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺកិក្ខុមានបាត្របាត់និងបែក និងសូមអំពីញាតិនិងបុគ្គលបវារណានៃខ្លួន និងសូមអំពីបុគ្គលជាញាតិ និងបវារណានៃកិក្ខុដទៃ និងសូមដើម្បីកិក្ខុដទៃក្តី និងកាន់យកដោយទ្រព្យនៃខ្លួនក្តី និងកិក្ខុធ្លុតជាដើមក្តី មិនត្រូវអាបត្តិ ជាអនាណត្តិក: មានអង្គ ៤ គឺ **អធិដ្ឋានូបគបត្តស្ស** **ឩនបញ្ចពន្ធនត្តា** *បាត្រគួរអធិដ្ឋានមានចំណង ៥ មិនទាន់គ្រប់ ១* **អត្តុទ្ទេសិកតា** *ចំពោះខ្លួន ១* **អកតវិញ្ញត្តិ** *សូមអំពីបុគ្គលមិនជាញាតិ មិនជាបវារណា ១* **តាយ ច បដិលាភো** *បានមកដោយការសូមនោះ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើមដូចធោវនសិក្ខាបទ ។*

ឩនបញ្ចពន្ធនសិក្ខាបទ គម្រប់ ២ ចប់

កេសជ្ជសិក្ខាបទ គម្រប់ ៣ សេចក្ដីថា កេសជ្ជ: ៥ ប្រការ គឺ **សប្ប**ិ *ទឹកដោះរាវ* **ណវនីតំ** *ទឹកដោះខាប់* **តេលំ** *ប្រេងលូ ប្រេងគ្រាប់ស្ពៃ ប្រេងស្រគំ ប្រេងល្ហុង និងខ្លាញ់មានខ្លាញ់ជ្រូកជាដើម* **មធุ** *ទឹកឃ្មុ* **ផាណิតំ** *ទឹកអំពៅ ។ កេសជ្ជ:ទាំង ៥ នេះជាថ្នាំ ភិក្ខុមានជំងឺក្ដី មិនមានជំងឺក្ដី នឹងគប្បីបរិភោគបានក្នុងកាលទាំងពួង កេសជ្ជ:ទាំង ៥ នេះ ភិក្ខុទទួលប្រគេន ហើយគប្បីទុកធាន់បាន ៧ ថ្ងៃជាយ៉ាងក្រៃពេក កាលបើភិក្ខុទុកកេសជ្ជ:នោះឲ្យលើស៧ ថ្ងៃ លុះអរុណគម្រប់ ៨ រះឡើងមក ត្រូវនិស្សគ្គិយបាចិត្តិយរាប់តាមកេសជ្ជ:នោះ បើតម្កល់ទុកក្នុងភាជន:ជាមួយគ្នាក៏ត្រូវអាបត្តិ ១ បើមិនតម្កល់ទុកក្នុងភាជន:ជាមួយគ្នា ត្រូវអាបត្តិតាមវត្ថុនោះ១ ក្នុងបទនេះនឹងសម្ដែងពិស្ដារទៅខាងមុខ ។ ថ្នាំទាំង ៥ ប្រការនេះ ត្រូវនិស្សគ្គិយហើយ បើលះចេញហើយ កាលបានត្រឡប់មកវិញ នឹងបរិភោគក្នុងកាយ មានលាបដំបៅជាដើម ឬក្រេបផឹកចូលទៅមិនគួរ គប្បីបង្ហោនទៅក្នុងប្រទីប ឬផ្សំថ្នាំខ្មៅលាបក្នុងទី ដែលដៃនិងកាយគប្បីពាល់ត្រូវ ភិក្ខុដទៃមិនមែនម្ចាស់របស់ នឹងបរិភោគលាបកាយជាដើមនោះគួរ នឹងធាន់ចូលទៅមិនគួរ ។ ថ្នាំទាំង ៥ ប្រការនេះណាមួយ ភិក្ខុលះឲ្យអនុបសម្បន្នដាច់ហើយ ខាងក្នុង ៧ ថ្ងៃ បានត្រឡប់មកទៀតនឹងធាន់ក៏គួរ ។ ថ្នាំទាំង ៥ នេះ ភិក្ខុទទួលប្រគេនហើយដោយគិតនឹងធាន់ ហើយទុកហួស ៧ ថ្ងៃទៅ ទើបត្រូវនិស្សគ្គិយ ។ បើមិនគិតនឹងធាន់ នឹងយកទុកលាប*

ដំបៅជាដើម សូម្បីកន្ទង ៧ ថ្ងៃទៅ ក៏មិនត្រូវនិស្សគ្គិយ ។ វិនិច្ឆ័យក្រៅនោះ ទាំងអង្គនិងសមុដ្ឋានឲ្យគប្បីដឹងដូចពោលហើយក្នុងបឋមកឋិនសិក្ខាបទ ។

ភេសជ្ជសិក្ខាបទ គម្រប់ ៣ ចប់

វស្សិកសាដិកសិក្ខាបទ គម្រប់ ៤ សេចក្តីថា អំពីមួយពេចខែជេស្ឋ ដរាបដល់ពេញបូណ៌មីខែអាសាធ ពីរបក្ខនេះឈ្មោះថាជាខែមួយ ជាខាងចុងរដូវក្តៅ ជាខេត្តគួរនឹងស្វែងរកវស្សិកសាដិកចីវរ គឺសំពត់ងូតទឹកភ្លៀង ភិក្ខុគប្បីស្វែងរកគឺគឿនស្មារតីទាយកដែលធ្លាប់ឲ្យមកពីមុនថា ឥឡូវនេះជាកាលនៃរដូវសំពត់ងូតទឹកភ្លៀងហើយ តាំងពីមួយកើតខែអាសាធដល់ថ្ងៃពេញបូណ៌មី ជាកន្ទុះខែនៃខែចុងរដូវក្តៅ ជាខេត្តដែលនឹងធ្វើសំពត់ងូតទឹកភ្លៀងដែលស្វែងរកបានមកហើយនោះ នឹងជាខេត្តដែលនឹងស្ងៀកដណ្តប់ផង តែនៅមិនទាន់ជាខេត្តដែលត្រូវអធិដ្ឋាន តាំងពីមួយពេចខែអាសាធដរាបអស់រដូវភ្លៀង ទើបជាខេត្តដែលត្រូវអធិដ្ឋាន បើមិនទាន់ដល់ចុងរដូវក្តៅមួយខែ ភិក្ខុខ្ជល់ខ្ចាយស្វែងរកសំពត់ងូតទឹកភ្លៀងជាមុនបានមក សំពត់នោះ ត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។ មិនទាន់ដល់កន្ទុះខែចុងរដូវក្តៅ ភិក្ខុខ្ជល់ខ្ចាយធ្វើសំពត់ងូតទឹកភ្លៀង ដែលស្វែងរកបានមកនោះស្ងៀកដណ្តប់ក្តី សំពត់នោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺកិក្ខុមានចីវរដែលចោរដណ្តើមយកទៅ ក្តី មានចីវរបាត់ក្តី ស្ងៀកដណ្តប់ដោយមានអន្តរាយដទៃក្តី និងកិក្ខុធ្លត់ជ ដើមក្តី ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ជាអនាណត្តិក: ជាបរិយេសនាបត្តិ មានអង្គ ៣ គឺ **វស្សិកសាដិកាយ អត្ថុទ្ធេសិកតា** វស្សិកសាដិក: នោះចំពោះខ្លួនឯង ១ **អសមយេ បរិយេសនតា** ស្វែងរកក្រៅ សម័យ ១ **តាយ ច បដិលាភো** បានមកដោយការស្វែងរកនោះ ១ ។ ជានិវាសនាបត្តិ មានអង្គ ៤ គឺ **សចីវរតា** កិក្ខុមានចីវរគ្រប់គ្រាន់ ១ **អាបជ្ជកាភো** មិនមានអន្តរាយ ១ **វស្សិកសាដិកាយ សក-ភাভো** វស្សិកសាដិក:ជារបស់ខ្លួន ១ **អសមយេ និវាសនំ** ស្ងៀក ដណ្តប់ក្រៅសម័យ ១ ។ សមុដ្ឋានវិធីជាដើមដូចធោវិបនសិក្ខាបទ ។

<u>វស្សិកសាដិកសិក្ខាបទ គម្រប់</u> ៤ ចប់

ចីវរាច្ឆិន្ទនសិក្ខាបទ គម្រប់ ៥ សេចក្តីថា កិក្ខុណាឲ្យចីវរគួរវិកប្ប ជាបច្ចិមប្រមាណដល់កិក្ខុដទៃ ដោយខ្លួនឯងប្រាថ្នានឹងឲ្យកិក្ខុធ្វើការខ្ជល់ខ្ចាយ ឧបដ្ឋាកជាដើមដល់ខ្លួន គ្រាក្រោយឃើញថាកិក្ខុនោះ មិនខ្ជល់ខ្ចាយ ឧបដ្ឋាកខ្លួន ហើយត្រឡប់ដណ្តើមយកឯង ដោយសម្គាល់ថាជារបស់ខ្លួន ត្រូវនិស្សគ្គិយបាចិត្តិយ រាប់តាមវត្ថុ ។ ប្រើឲ្យអ្នកដទៃដណ្តើមយកត្រូវ ទុក្កដ ដោយបង្ខាំ ។ អ្នកដទៃដណ្តើមបានមកត្រូវនិស្សគ្គិយបាចិត្តិយ

រាប់តាមពាក្យបង្គាប់នោះ។ ។ ក្នុងឧបសម្បន្នត្រូវតិកបាចិត្តិយ ។ ក្នុងអនុបសម្បន្ន អ្នកដែលឲ្យនោះសម្គាល់ថាជាឧបសម្បន្នក្តី សង្ស័យក្តី ឬ ដឹងថាជាអនុបសម្បន្នក្តី ឲ្យហើយដណ្តើមយកក្តី ឬឲ្យបរិក្ខារដទៃដល់ឧបសម្បន្នហើយដណ្តើមយកក្តី ដូច្នេះត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺអ្នកដែលបានទៅត្រេកអរ ឬ ខឹងហើយត្រឡប់ឲ្យមកវិញដោយខ្លួនឯងក្តី ឬកាន់យកដោយវិស្សាស:ក្នុងអ្នកដែលបានទៅក្តី និងភិក្ខុឆ្កួតជាដើមក្តី មិនត្រូវអាបត្តិ លះឲ្យដាច់ហើយត្រឡប់ដណ្តើមយកមកវិញ ឲ្យវិន័យធរគប្បីកាត់អាបត្តិ តាមតម្លៃរបស់ជាសាណត្តិក: មានអង្គ ៥ គឺ **វិកប្បទ្វយតបច្ឆិមចីវរតា** ចីវរទំហំប្រវែងគួរវិកប្បជាយ៉ាងទាប ១ **សាមំ ឌិន្នតា** ចីវរនោះភិក្ខុឲ្យខ្លួនឯង ១ **សកសញ្ញិតា** សម្គាល់ថាជារបស់ខ្លួន ១ **ឧបសម្បន្នតា** អ្នកដែលបានទៅជាឧបសម្បន្ន ១ **កោធវសេន អច្ឆិន្ទនំ វ អច្ឆិន្ទាបនំ វ** ដណ្តើមយកដោយខ្លួនឯង ឬឲ្យគេដណ្តើមយកដោយខឹង ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាទុក្ខវេទនា ។

ចីវរាច្ឆិន្ទនសិក្ខាបទ គម្រប់ ៥ ចប់

សុត្តវិញ្ញត្តិសិក្ខាបទ គម្រប់ ៦ សេចក្តីថា ភិក្ខុណា សូមអម្បោះ ៦ ប្រការណាមួយមកខ្លួនឯង អំពីបុគ្គលមិនមែនញាតិ មិនមែនបវារណា ឲ្យជាងតម្បាញ មិនមែនញាតិ មិនមែនបវារណា ត្បាញចីវរក្នុងប្រយោគ ដែលជាងតម្បាញតាក់តែងនោះ ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ ។ លុះត្បាញហើយ សំពត់ទំហំប្រវែងល្មមបានបច្ចិមប្រមាណ គួរកាប្ប សំពត់នោះត្រូវនិស្សគ្គិយបាចិត្តិយ ។ ភិក្ខុសម្គាល់នូវសំពត់ដែលជាងតម្បាញមិនទាន់ត្បាញ ថាត្បាញហើយក្តី ឬ សង្ស័យក្តី ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺ ភិក្ខុសូមនូវអម្បោះដើម្បីដេរចីវរ ឬ សំពត់អាយោគ និងវត្តពន្ធ យោគបាត្រ ថង់បាត្រ សំពត់តម្រងទឹក ឬឲ្យជាងតម្បាញជាញាតិនិងបវារណា ត្បាញនូវអម្បោះដ៏គួរក្តី សូមដើម្បីអ្នកដទៃក្តី ទិញដោយទ្រព្យនៃខ្លួនក្តី និងភិក្ខុធ្ជតជាដើមក្តី ទាំងអម្បាលនេះ មិនត្រូវអាបត្តិ សិក្ខាបទនេះជាអនាណត្តិកៈ មានអង្គ ៣ គឺ **ចីវរត្ថាយ វិញ្ញាបិតសុត្តតា** *សូមអម្បោះដើម្បីត្បាញចីវរ ១* **អត្តុទ្ទេសិកតា** *បំពោះខ្លួន ១* **អកប្ប្យតន្តវាយេន អកប្ប្យវិញ្ញត្តិយា ឋាយបនំ** *ឲ្យជាងតម្បាញជាអកប្ប្យនោះ ត្បាញដោយការសូមជាអកប្ប្យ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវអាបត្តិ ។ សមុដ្ឋានវិធីជាដើម ដូចធោវាបនសិក្ខាបទ ។*

សុត្តវិញ្ញត្តិសិក្ខាបទ គម្រប់ ៦ ចប់

មហាបេសការសិក្ខាបទ គម្រប់ ៧ សេចក្ដីថា គ្រហស្ថមិនមែនញាតិ ឲ្យជាងតម្បាញត្បាញចីវរចំពោះកិក្ខុណា កិក្ខុនោះគេមិនបានបវារណា ជាមុនហើយចូលទៅរកជាងតម្បាញប្រាប់ថា "ចីវរនេះគេឲ្យអ្នកត្បាញ ចំពោះយើង អ្នកចូរត្បាញឲ្យវែង ឲ្យធំ ឲ្យណែន ត្បាញឲ្យល្អ រឹតឲ្យល្អ ក្ងួតឲ្យល្អ សិតឲ្យល្អចុះ សិមយើងនឹងថែមវត្ថុណាមួយឲ្យដល់អ្នក" កិក្ខុ ពោលដូច្នេះហើយ ថែមនូវវត្ថុណាមួយឲ្យដល់ជាងតម្បាញ ដោយហោចទៅ សូម្បីតែបិណ្ឌបាតក្ដី បើជាងតម្បាញនោះថែមអម្ពោះឡើងហើយ ត្បាញឲ្យវែង ឲ្យធំ តាមពាក្យកិក្ខុបង្គាប់ ក្នុងប្រយោគដែលជាងតម្បាញ តាក់តែងនោះត្រូវទុក្កដ ត្បាញហើយបានមក សំពត់នោះជានិស្សគ្គិយ កិក្ខុត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើមដូចសុត្តវិញ្ញត្តិសិក្ខាបទ ប្ដូរតែ សិក្ខាបទនេះ មានអង្គ ៤ គឺ **អញ្ញាតកអប្បវារិតានំ តន្តវាយេ ឧបសង្កមិត្វា វិកប្បមាបជ្ជនតា** *កិក្ខុបង្គាប់ឲ្យជាងតម្បាញនៃ ទាយកមិនមែនញាតិ មិនមែនបវារណាឲ្យកំណត់ ១* **ចីវរស្ស អត្ថុទ្ធ-សិកតា** *ចីវរចំពោះខ្លួន ១* **តស្ស វចនេន សុត្តវណ្ណំ** *ជាងតម្បាញ ថែមអម្ពោះតាមពាក្យកិក្ខុ ១* **ចីវរប្បដិលាភো** *បានទូវចីវរមក ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចធោវាបនសិក្ខាបទ ។*

មហាបេសការសិក្ខាបទ គម្រប់ ៧ ចប់

អច្ចេកចីវរសិក្ខាបទ គម្រប់ ៨ សេចក្ដីថា អច្ចេកចីវរ គឺ ចីវរួសរាន់ ចីវរប្រញាប់ បានន៏ងមនុស្សដែលន៏ងទៅធ្វើសង្គ្រាម ឬមនុស្សមានកិច្ចន៏ង ទៅនៅយូរ និងមនុស្សមានជំងឺធ្ងន់ និងស្ត្រីមានគភ៌ ឬមនុស្សមានសទ្ធា ជ្រះថ្លាឡើងថ្មី ថ្វាយជាសំពត់ចំណាំវស្សាដល់សង្ឆក្នុងថ្ងៃ ៥ កើតខែ អស្សុជ សំពត់ដូច្នេះ ភិក្ខុបានចំណែកមកអំពីសង្ឆហើយ គប្បីសម្គាល់ចាំ ទុកដើម្បីវស្សាដាច់ ន៏ងបានប្រគល់ឲ្យដល់សង្ឆវិញ បើវស្សាមិនដាច់ ទុក ដាក់ដរាបអស់ចីវរកាល មិនវិកប្ប: អធិដ្ឋានក៏បាន បើទុកឲ្យហួសចីវរកាល ទៅ សំពត់នោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។ ចីវរកាលនោះតាំងអំពី មួយពេចខែអស្សុជ បើមិនបានក្រាលគ្រងកបិនទុកបានដល់ពេញបូណ៌មី ខែកត្តិកជា ១ ខែ បើបានក្រាលគ្រងកបិនទុកដល់ពេញបូណ៌មីខែផល្គុន ជា ៥ ខែ ឈ្មោះថាចីវរកាល ។ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិន-សិក្ខាបទ ប្លែកតែសិក្ខាបទនេះមានអង្គ ៤ គឺ **អច្ចេកចីវរស្ស អត្តនោ សន្ដកតា** *អច្ចេកចីវរមានប្រមាណយ៉ាងតូចគួរវិកប្បជារបស់ខ្លួន ១* **ឧប្ឋន្ដកាលោ** *ចីវរកើតឡើងអំពីថ្ងៃ ៥ កើតខែអស្សុជ ១* **អនធិដ្ឋិត-អវិកប្ឋិតតា** *ចីវរមិនបានអធិដ្ឋានមិនបានវិកប្ប ១* **ចីវរកាលា-តិក្កមោ** *កន្ទងចីវរកាលទៅ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវ និស្សគ្គិយបាចិត្តិយ ។*

អច្ចេកចីវរសិក្ខាបទ គម្រប់ ៨ ចប់

សាសង្គសិក្ខាបទ គម្រប់ ៩ សេចក្តីថា កាលបើព្រមដោយអង្គ ៤ ព្រះពុទ្ធអង្គក៏ទ្រង់អនុញ្ញាត ឲ្យផ្ញើត្រៃចីវរទុកក្នុងស្រុកបាន ។ ឯអង្គ ៤ នោះគឺ ភិក្ខុចូលបុរិមិកាវស្សា ហើយបានបវារណាក្នុងថ្ងៃមហាបវារណា ជាអង្គ ១ តាំងអំពីមួយរោចខែអស្សុជ ដល់ពេញបូណ៌មីខែកត្តិកឈ្មោះ កត្តិកមាស មួយខែនេះជាអង្គគម្រប់ ២ អរញ្ញិកសេនាសនៈប្រកបដោយ ប្រមាណ គឺវាស់ពីខែត្រស្រុកមកដល់ខែត្រវត្តចម្ងាយ៥រយជួរធ្នូ ជាយ៉ាងទាប ជាអង្គគម្រប់ ៣ សេនាសនៈព្រៃនោះប្រកបដោយសេចក្តីរង្គៀស គឺក្នុងអាវាមឬឧបចារនៃអាវាម ឱកាសទីលំនៅ ទីស៊ី ទីអង្គុយ នៃចោរក៏ឃើញប្រាកដ សេនាសនៈប្រកបដោយភ័យគឺ ក្នុងអាវាម ឬឧបចារនៃអាវាម ចោរចូលមកសម្ងាប់ មកប្លន់ មកវាយដំមនុស្ស ក៏ឃើញប្រាកដ សេនាសនៈប្រកបដោយរង្គៀសនិងភ័យដូច្នេះ ជាអង្គគម្រប់ ៤ ព្រមដោយអង្គ ៤ ដូច្នេះហើយ ភិក្ខុផ្ញើត្រៃចីវរក្នុងស្រុកគោរចរគ្រាមជុំវិញអាវាមស្រុកណាមួយបាន ១ ខែ ចីវរនោះមិនត្រូវនិស្សគ្គិយ បើមានហេតុភិក្ខុចេញចាកអរញ្ញិកសេនាសនៈទៅកាន់ទីដទៃ គប្បីនៅប្រាសចាកចីវរនោះបាន ៦ រាត្រីជាយ៉ាងច្រើន បើនៅប្រាសចាកចីវរលើស ៦ រាត្រីឡើងទៅ មិនត្រឡប់មកកាន់អរញ្ញិកសេនាសនៈ ឬស្រុកដែលទុកចីវរនោះខាងក្នុង ៦ រាត្រី អរុណគម្រប់ ៧ រះឡើងមក ចីវរដែលនៅក្នុងស្រុកនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ រៀងតែភិក្ខុមានជំងឺបានសម្មតិអំពីសង្ឆ ឲ្យនៅប្រាសចាកត្រៃចីវរបាន ។ សមុដ្ឋានវិធីជាដើម ដូចទុតិយកឋិនសិក្ខាបទ ។

សាសង្គសិក្ខាបទ គម្រប់ ៩ ចប់

បរិណតសិក្ខាបទ គម្រប់ ១០ សេចក្ដីថា ភិក្ខុដឹងថាលាភសង្ឆគឺបច្ច័យទាំង ៤ ដោយហោចទៅ សូម្បីតែលម្អិតនិងឈើស្ទន់អំបោះជើងតម្បាញ ទាយកសូម្បីជាសហធម្មិកទាំង ៥ ឬគ្រហស្ថសូម្បីជាមាតាបិតា គេបង្ហោនទៅហើយដើម្បីសង្ឆដោយវាចាថា "យើងនឹងថ្វាយ" ភិក្ខុដឹងដូច្នេះហើយ បង្ហោនមកដើម្បីខ្លួន ក្នុងប្រយោគដែលពោលបង្ហោនមកនោះ ត្រូវទុក្កដ ។ លាភនោះបានមកដល់ដៃត្រូវនិស្សគ្គិយបាចិត្តិយ ។ ថាបើលាភនោះទាយកថ្វាយដល់សង្ឆហើយសោត ភិក្ខុនឹងកាន់យកមិនគួរ គប្បីប្រគល់ឲ្យដល់សង្ឆវិញ លាភគេបង្ហោនទៅហើយដល់សង្ឆ ភិក្ខុសង្ឆ័យ បង្ហោនមកដើម្បីខ្លួនក្ដី លាភគេបង្ហោនទៅដល់សង្ឆពួក ១ ហើយបង្ហោនទៅសង្ឆពួកដទៃ ឬចេតិយក្ដី ដូច្នេះត្រូវទុក្កដ ។ លាភគេបង្ហោនទៅដល់ចេតិយ ១ ហើយភិក្ខុបង្ហោនទៅចេតិយដទៃឬបង្ហោនទៅដល់សង្ឆ ដល់គណៈ ដល់បុគ្គលក្ដី ឬលាភគេបង្ហោនទៅដល់បុគ្គលហើយ ដោយហោចទៅ សូម្បីបង្ហោនឲ្យទៅផ្ដែ ១ ហើយ ភិក្ខុបង្ហោនមកដល់បុគ្គល មកដល់ផ្ដែដទៃ ឬបង្ហោនទៅដល់សង្ឆ ដល់គណៈ ដល់ចេតិយក្ដី ឬលាភគេមិនទាន់បង្ហោនទៅ ភិក្ខុសម្គាល់ថាបង្ហោនទៅហើយក្ដី សង្ឆ័យក្ដី បង្ហោនមកដើម្បីខ្លួន ដើម្បីអ្នកដទៃ ទាំងអម្បាលនេះ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺ លាភគេបង្ហោនទៅហើយ ភិក្ខុសម្គាល់ថាគេមិនទាន់បានបង្ហោនទៅ ហើយបង្ហោនមកដើម្បីខ្លួន ដើម្បី

អ្នកដទៃក្តី ទាយកសួរថា ខ្ញុំនឹងឲ្យក្នុងទីណាស្រួល ភិក្ខុពោលថា "ទេយ្យធម៌របស់អ្នកនឹងគប្បីបានជាគ្រឿងបរិភោគ ជាគ្រឿងបរិក្ខារ បដិសង្ខរណៈ:ឋិតនៅបានយូរ ក្នុងទីឯណា ឬចិត្តអ្នកជ្រះថ្លា ក្នុងទីណា អ្នកចូរឲ្យក្នុងទីនោះចុះ" ពោលដូច្នេះក្តី និងភិក្ខុធ្លាតជាដើមក្តី ទាំងអម្បាលនេះមិនត្រូវអាបត្តិ ជាអនាណត្តិក: មានអង្គ ៣ គឺ **សង្ឆ្យ បរិណតភាវោ** *លាភនោះទាយកបង្ហោនទៅហើយក្នុងសង្ឆ ១* **តំ ញត្វា អត្តនោ បរិណាមនំ** *ដឹងហើយបង្ហោនមកដើម្បីខ្លួន ១* **បដិលាភោ** *បានមក ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវនិស្សគ្គិយ-បាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ។*

បរិណតសិក្ខាបទ គម្រប់ ១០ ចប់

បត្តវគ្គទី ៣ ចប់

និស្សគ្គិយុទ្ធេស ចប់

ចាចិត្តិយុទ្ធេស

ឧទ្ទេសនៃសុទ្ធិកបាចិត្តិយាបត្តិ សុទ្ធិកបាចិត្តិយាបត្តិមាន ៩២ សិក្ខាបទ ចែកជា ៩ វគ្គ ។ វគ្គទី ១ ឈ្មោះមុសាវាទវគ្គ មាន ១០ សិក្ខាបទ ៖

មុសាវាទសិក្ខាបទ ជាបឋមនោះ សេចក្តីថា ភិក្ខុមុននឹងនិយាយ និងខណៈកំពុងនិយាយ ដឹងថាជាសេចក្តីមិនពិត ហើយកុហកដោយកាយ ដូចគេសួរថា ឃើញឬមិនឃើញ ខ្លួនឃើញពិត ហើយគ្រវីក្បាលឲ្យគេដឹងថាមិនឃើញក្តី ស្រដីកុហកដោយវាចាក្តី ត្រូវបាចិត្តិយ ។

ភិក្ខុពោលកុហកដើម្បីអួតឧត្តរិមនុស្សធម្ម ត្រូវបារាជិក, ពោលកុហកដើម្បីចោទភិក្ខុដទៃ ដោយអាបត្តិបារាជិកមិនមានមូល ត្រូវសង្ឆា-ទិសេស, ពោលកុហកដើម្បីចោទភិក្ខុដទៃ ដោយអាបត្តិសង្ឆាទិសេសមិនមានមូល ត្រូវបាចិត្តិយ, ពោលកុហកដើម្បីចោទភិក្ខុដទៃ ដោយអាចារវិបត្តិ ត្រូវទុក្កដ ពោលកុហកដើម្បីអួតឧត្តរិមនុស្សធម្មដោយបរិយាយ អ្នកស្តាប់ដឹងសេចក្តី ត្រូវថុល្លច្ច័យ, អ្នកស្តាប់មិនដឹងសេចក្តី ត្រូវទុក្កដ ។ ភិក្ខុពោលកុហក បានឃើញថាមិនបានឃើញ បានឮថាមិនបានឮ ដឹងដោយ ច្រមុះ អណ្ដាត កាយ ថាមិនបានដឹង ដឹងដោយចិត្ត ថាមិនបានដឹងក្តី មិនឃើញ ថាបានឃើញ មិនឮ ថាបានឮ មិនដឹងដោយទ្វារទាំង ៣ ថាបានដឹង មិនដឹងដោយចិត្ត ថាដឹងក្តី ដូច្នេះ ត្រូវបាចិត្តិយ ក្នុងសិក្ខាបទនេះ ។

ឯវិធីដែលមិនត្រូវអាបត្តិ គឺមិនទាន់ត្រិះរិះ ពោលដោយរហ័ស ទៅក្តី គិតនឹងពោលពាក្យយ៉ាងដូច្នេះ ហើយភ្ញាត់ទៅពោលពាក្យដទៃ ក្តី ឃ្លាតចាកពាក្យពិតទៅ និងភិក្ខុធ្លត់ជាដើមក្តី ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ជាអនាណត្តិក: មានអង្គ ២ គឺ **វិសំវាទនបុរេក្ខារតា** *គិតនឹងពោលពាក្យឲ្យឃ្លាតចាកពិតជាប្រធាន ១* **វិសំវាទនចិត្តេន យមត្ថំ វត្តុកាមោ តស្ស បុគ្គលស្ស វិញ្ញាបនប្បយោគោ** *ធ្វើប្រយោគកាយឬវាចា ឲ្យអ្នកស្តាប់ដឹងសេចក្តីដែលខ្លួនប្រាថ្នានឹងពោល*

ដោយគិតឲ្យឃ្លាតចាកសេចក្តីពិត ១ ព្រមដោយអង្គ ២ នេះ ទើប ត្រូវអាបត្តិ បើមិនព្រមដោយអង្គ ២ នេះ មិនត្រូវអាបត្តិ ។ សមុដ្ឋាន-វិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ។

មុសាវាទសិក្ខាបទ ជាបឋម ចប់

ឱមសវាទសិក្ខាបទ គម្រប់ ២ សេចក្តីថា ភិក្ខុណា ពោលពាក្យចាក់ដោត ជេរស្តីភិក្ខុដទៃ អ្នកដែលត្រូវបារាជិកក្តី ឬមិនបានត្រូវក្តី ដោយ សម្គាល់ថាជាភិក្ខុ ពោលដោយកាយប្រយោគនិងវចីប្រយោគ មិនអាង អ្នកដទៃ ដោយអក្កោសវត្ថុ ១០ ប្រការណាមួយ ពិតក្តី មិនពិតក្តី ត្រូវ បាចិត្តិយ ។

អក្កោសវត្ថុ ១០ នោះ គឺជាតិទាបនិងឧក្រិដ្ឋ ជាតិចណ្ឌាល ជាតិ ជាងឈើ ជាតិជាងចាំង ជាតិជាងផ្ទៃង ជាតិព្រានម្រឹគ ជាតិជាងរថ ជាតិមនុស្សចាក់ផ្តា ចាក់សំរាមជាដើម ឈ្មោះថា ជាតិទាប, ជាតិ ក្សត្រ ជាតិព្រាហ្មណ៍ ឈ្មោះថា ជាតិឧក្រិដ្ឋ ១ ។ នាមគឺឈ្មោះ ដែលទាបនិងឧក្រិដ្ឋ ឈ្មោះអវកណ្ណក:ជាដើម និងឈ្មោះដែលគេចំអក ចំអន់ក្នុងប្រទេសនោះ។ ជាឈ្មោះទាប, ឈ្មោះប្រកបដោយពុទ្ធ: ដោយ ធម្ម: ដោយសង្ឆ: ដែលគេរាប់អានក្នុងប្រទេសនោះ ដូចឈ្មោះ ពុទ្ធរក្ខិត ធម្មរក្ខិត សង្ឆរក្ខិត ជាឈ្មោះ ឧក្រិដ្ឋ ១ ។ គោត្រគឺសៃ ដែលទាបនិងឧក្រិដ្ឋ គោត្រដែលគេចំអកចំអន់ក្នុងប្រទេសនោះ។ ដូច

កោសិយគោត្រ ការទ្វាជគោត្រ ជាគោត្រទាប, គោត្រដែលគេរាប់អានក្នុងប្រទេសនោះៗ ដូចគោតមគោត្រ មោគ្គល្លានគោត្រ កច្ចាយនគោត្រ វាសិដ្ឋគោត្រ ជាគោត្រឧក្រិដ្ឋ ១ ។ កម្ម គឺការងារដែលទាបនិងឧក្រិដ្ឋ ការងារដែលគេចំអកចំអន់ក្នុងប្រទេសនោះៗ ដូចការងារជាងចាំង មនុស្សចាក់ផ្ការ ចាក់សំរាមជាដើម ជាការងារទាប, ការងារដែលគេរាប់អានក្នុងប្រទេសនោះៗ ដូចការធ្វើស្រែ ការជួញ ការចិញ្ចឹមគោ ជាការងារឧក្រិដ្ឋ ១ ។ សិប្ប: គឺសិល្បសាស្ត្រ ដែលទាបនិងឧក្រិដ្ឋ សិប្ប:ដែលគេចំអកចំអន់ក្នុងប្រទេសនោះៗ ដូចជាងធ្វាក់ ជាងធ្នាំង ជាងតម្បាញ ជាងស្បែក ជាងសំណ ជាសិល្បសាស្ត្រទាប, សិប្ប:ដែលគេរាប់អានក្នុងប្រទេសនោះៗ ដូចវិជ្ជាគ្នេរ វិជ្ជារាប់ វិជ្ជាលេខ ជាសិល្បសាស្ត្រឧក្រិដ្ឋ ១ ។ អាពាធ គឺរោគផ្សេងៗ ទាំងអស់ជារបស់ទាប, ក៏ឯរោគឈ្នោះមធុមេហ: មានទឹកបស្សាវ:ផ្អែម មានទុក្ខវេទនាតិចជារោគឧក្រិដ្ឋ ១ ។ លិង្គ គឺពណ៌សណ្ឋានកាយ ដែលទាបនិងឧក្រិដ្ឋ កាយខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក ជាលិង្គទាប, កាយមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ជាលិង្គឧក្រិដ្ឋ ១ ។ កិលេស គឺលោភ: ទោស: មោហ: កិលេសទាំងអស់ជារបស់ទាប ១ ។

អាបត្តិ គឺចំណែកដែលនឹងគប្បីដល់ គប្បីត្រូវ មានបារាជិកាបត្តិជាដើម អាបត្តិទាំងពួងជារបស់ទាបទាំងអស់, ក៏ឯសោតាបត្តិ និងសមាបត្តិទាំង ៨

ជាអាបត្តិឧក្រិដ្ឋ ១ ។ អក្កោស: គឺពាក្យជេរដែលទាបនិងឧក្រិដ្ឋ ជេរថា ឯងជាឱ្ជ ឯងជាលា ឯងជាពពែ ឯងជាគោ ឯងជាតិរច្ឆាន ឯងជាសត្វនរក សុគតិរបស់ឯងមិនមាន ឯងមានតែទុគ្គតិមួយយ៉ាងប៉ុណ្ណោះ និងជេរដល់បុរិសនិមិត្ត ឥត្ថីនិមិត្ត និងពាក្យជេរប្រកបដោយ យ: ក: អក្ខរ ដោយបុរិសនិមិត្ត ឥត្ថីនិមិត្ត នេះជាពាក្យជេរដែលទាប, ជេរថាឯងជាអ្នកប្រាជ្ញ ឯងជាអ្នកធ្ងាត ឯងជាអ្នកមានបញ្ញា ឯងជាពហុស្សូត ឯងជាធម្មកថិក ទុគ្គតិរបស់ឯងមិនមាន មានតែសុគតិមួយយ៉ាង ដូច្នេះជាពាក្យជេរឧក្រិដ្ឋ ១ ឈ្មោះថាអក្កោសវត្ថុ ១០ ប្រការដូច្នេះ ។

ភិក្ខុប្រាថ្នានឹងឲ្យភិក្ខុផងគ្នាបានសេចក្ដីអាស្រូវ ហើយជេរភិក្ខុនោះ ដោយជាតិនិងគោត្រជាដើមដែលទាបនិងឧក្រិដ្ឋណាមួយ ដោយអក្កោស-វត្ថុដែលទាបនិងឧក្រិដ្ឋ ពិតក្ដី មិនពិតក្ដី មិនបានប្រៀបប្រាយ ជេរត្រង់ចំពោះខ្លួនថា ឯងជាក្សត្រ ឯងជាព្រាហ្មណ៍ជាដើម ដូច្នេះត្រូវបាចិត្តិយ គ្រប់ៗ ពាក្យ ។ បើជេរប្រៀបប្រាយមិនចំពោះខ្លួនថា មនុស្សជំពូកខ្ញុះ ក្នុងលោកនេះជាមនុស្សចណ្ឌាល ជាព្រានជាដើមដូច្នេះក្ដី និងពោលចាក់ដោតជេរស្ដីអនុបសម្បន្ន គឺសាមណេរ គ្រហស្ថ ស្ត្រី បុរស ដោយត្រង់ក្ដី និងជេរប្រៀបប្រាយមិនត្រង់ក្ដី ទាំងអម្បាលនេះ ក៏ត្រូវអាបត្តិទុក្កដ គ្រប់ៗពាក្យ ។ ភិក្ខុមិនមានប្រាថ្នានឹងជេរឲ្យបានសេចក្ដីអាប់យស បំណងនឹងឡកលេងនិងពោលឡកចំអន់លេងឧបសម្បន្នក្ដី អនុបសម្បន្នក្ដី

ដោយត្រង់ឬប្រៀបប្រាយ ដោយអក្កោសវត្ថុ ដែលមានមកក្នុងព្រះបាលី ឬមិនមានមកក្នុងព្រះបាលីថា ឯងជាក្សត្រ ឯងជាព្រាហ្មណ៍ ឯងជាតិរច្ឆាន ឯងជាអ្នកប្រាជ្ញ ឯងជាសៀម ឯងជាលាវ ឯងជាចោរ ជាដើមដូច្នេះ ត្រូវអាបត្តិទុព្ភាសិត គ្រប់ៗ ពាក្យ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុមិនមានបំណងនឹងជេរនិងឡកចំអកចំអន់ ពោលអត្ត ពោលធម៌ ពោលពាក្យប្រដៅជាប្រធាន ពោលថាជាតិនេះអ្នកជាមនុស្សចណ្ឌាលហើយ កុំធ្វើបាបឡើយដូច្នេះ និងភិក្ខុធ្ជតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ជាអនាណត្តិក: មានអង្គ ៤ គឺ **យំ អក្កោសតិ តស្ស ឧបសម្បន្នត្តា** ជេរអ្នកណា អ្នកនោះជាឧបសម្បន្ន ១ **អនញ្ញាបទេសេន ជាតិអាទីហិ អក្កោសនំ** ជេរដោយអក្កោសវត្ថុមានជាតិជាដើម មិនអាងអ្នកដទៃ ១ **មំ អក្កោ-សតីតិ ជានន្តា** អ្នកដែលគេជេរដឹងថាគេជេរខ្លួន ១ **អត្តជ្ឈមុបេ-ក្ខារតាទីនំ អភាវោ** មិនបានពោលអត្ត ពោលធម៌ ពោលពាក្យប្រដៅ ជាប្រធាន ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះជាទុក្ខវេទនាប៉ុណ្ណោះ ។

ឱមសវាទសិក្ខាបទ គម្រប់ ២ ចប់

បេសុញ្ញសិក្ខាបទ គម្រប់ ៣ សេចក្ដីថា ភិក្ខុញុះញង់ គឺបានឮភិក្ខុមួយអង្គ ជេរភិក្ខុផងគ្នា ដោយអក្កោសវត្ថុ ១០ មានជាតិជាដើម ហើយមានសេចក្ដីប្រាថ្នា ២ ប្រការ គឺនឹងឲ្យអ្នកដែលគេជេរនោះ ស្រឡាញ់ខ្លួន ១ ឬនឹងឲ្យអ្នកទាំងពីរនោះបែកចាកគ្នា ១ ទើបពោលពាក្យញុះញង់ គឺចែចូវរើសនាំយកពាក្យនៃភិក្ខុអ្នកជេរឯណោះ ទៅប្រាប់ដល់ភិក្ខុដែលគេជេរឯណោះ ត្រូវបាចិត្តិយ គ្រប់ៗ ពាក្យញុះញង់នោះ ។ បើនាំយកពាក្យនៃភិក្ខុអ្នកពោលញុះញង់ជេរស្ដី ប្រៀបប្រាយមិនត្រង់ មកប្រាប់ដល់ភិក្ខុដែលគេជេរ ឬ នាំយកពាក្យដែលអនុបសម្បន្នជេរ មកប្រាប់ដល់ឧបសម្បន្នក្ដី ដល់អនុបសម្បន្នក្ដី ឬនាំយកពាក្យជេរនៃឧបសម្បន្នមកប្រាប់ដល់អនុបសម្បន្នក្ដី ទាំងអម្បាលនេះ ត្រូវទុក្កដទាំងអស់ ។ ក្នុងសិក្ខាបទនេះ សូម្បីភិក្ខុនី ក៏គង់ឋិតនៅជាអនុបសម្បន្ន ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុមិនបំណងនឹងឲ្យអ្នកដែលគេជេរស្រឡាញ់ខ្លួន ១ ឬមិនមានប្រាថ្នានឹងឲ្យអ្នកទាំងពីរបែកគ្នា ១ ពោលពាក្យតិះដៀលមនុស្សអាក្រក់មួយជំពូក និងភិក្ខុធ្លួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ជាអនាណត្តិក: មានអង្គ ៣ គឺ **ជាតិអាឌីហិ អនញ្ញាបនេសេន អក្កោសន្ដស្ស ភិក្ខុនោ វចនំ សុត្វា ភិក្ខុស្ស ឧបសំហារណំ** *បានឮភិក្ខុជេរស្ដីដោយអក្កោសវត្ថុ មានជាតិជាដើម មិនអាងអ្នកដទៃ ហើយនាំយកមកប្រាប់ដល់ភិក្ខុ*

ដែលគេជេរ ១ **បិយកម្យតា ភេជ្ជានិប្ជាយេសុ អញ្ញតរតា** បំណងនឹងឲ្យអ្នកដែលគេជេរស្រឡាញ់ខ្លួន ឬនឹងឲ្យអ្នកទាំងពីរបែកចាកគ្នា ណាមួយ ជាអង្គ ១ **តស្ស វិជានតំ** អ្នកដែលគេជេរនោះ ដឹងសេចក្តី ១ ព្រមដោយអង្គទាំង ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ។

បេសុញ្ញសិក្ខាបទ គម្រប់ ៣ ចប់

បទសោធម្មសិក្ខាបទ គម្រប់ ៤ សេចក្តីថា ភិក្ខុណាប្រដៅអនុបសម្បន្ន គឺសាមណេរនិងគ្រហស្ថ ស្ត្រីបុរស ឲ្យរៀនធម៌ដោយបទ ត្រូវបាចិត្តិយ ។ បទ គឺបាទនៃគាថាមួយដូច **អសេវនា ច ពាលានំ** ១ *អនុបទ គឺបាទគម្រប់ ២ ដូច* **បណ្ឌិតានញ្ច សេវនា** ១ *អនុក្ខរៈ គឺអក្សរតួមួយៗ ដូចតួ* **រ** *តួ* **ំ** ១ ។ *អនុព្យញ្ជនៈ គឺព្យញ្ជនៈក្រោយ ដូចព្យញ្ជនៈមុន ដូច* **អនិច្ចំ អនិច្ចា** ១ ។ *បួននេះឈ្មោះថាបទ ជាចំណែកឲ្យកើតអាបត្តិ និងជាកំណត់នៃអាបត្តិ ឲ្យគប្បីដឹងផ្សេងៗ គ្នា ដូច្នេះ អក្សរតួមួយៗ ដូច តួ* **រ** *តួ* **ំ** *ឈ្មោះថាអនុក្ខរៈ ប្រជុំអក្សរចូលជាពាក្យមួយ ដូច* **រ**ំ *ឬ* **អនិច្ចំ** *ឈ្មោះថាអនុព្យញ្ជនៈ ប្រជុំអក្សរ និងអនុព្យញ្ជនៈ ចូលជាសេចក្តីជាមួយគ្នា ដូច* **រ**ំ **អនិច្ចំ** *ឈ្មោះថាបទ បទខាងដើមនោះឯង ឈ្មោះថាបទ បទជាគម្រប់ ២ ដូច* **ឧភយ អនិច្ចា**

ឈ្មោះថាអនុបទ ។ ភិក្ខុកាលប្រជៅធម៌ ដែលចង់ជាគាថា ថា **អសេ-
វនា ច ពាលានំ** ឡើងមុនហើយ អនុបសម្បន្ន ក៏ថាតាម ភិក្ខុក៏
ថាព្រមគ្នាជាមួយនឹងអនុបសម្បន្ន តទៅទៀតថា **អសេវនា ច
ពាលានំ** ឡើងព្រមគ្នា ចប់ព្រមគ្នា ដូច្នេះត្រូវបាចិត្តិយ ពាក់ដោយបទ ។
ភិក្ខុប្រជៅធម៌ម្តង ២ បាទគាថាដូច្នេះថា **អសេវនា ច ពាលានំ
បណ្ឌិតានញ្ច សេវនា** ហើយត្រឡប់ពោលទៀត ជាមួយនឹង
អនុបសម្បន្ន អនុបសម្បន្ន ពោលបាទជាដំបូងមិនទាន់ ពោលទាន់ដល់
បាទជាគម្រប់ ២ ថា **បណ្ឌិតានញ្ច សេវនា** ចូលព្រមគ្នាជាមួយនឹង
ភិក្ខុ ដូច្នេះឈ្មោះថាពោលឡើងផ្សេងគ្នា ចប់ចុះព្រមគ្នា ដូច្នេះត្រូវ
បាចិត្តិយ ពាក់ដោយអនុបទ ។ ភិក្ខុប្រជៅអនុបសម្បន្នឲ្យពោលថា **រូបំ
អនិច្ចំ** អនុបសម្បន្នពោលទាន់តែតួ **រ** ឡើងព្រមជាមួយនឹងភិក្ខុ ភិក្ខុ
ពោលទៅលុះតែចប់ ដូច្នេះត្រូវបាចិត្តិយ ពាក់ដោយអនុក្ខរៈ នំយនេះ
រមែងបានក្នុងបាលី សូម្បីដែលចង់ជាគាថាផង ។ ភិក្ខុប្រជៅអនុបសម្បន្ន
ឲ្យពោលថា **រូបំ អនិច្ចំ វេទនា អនិច្ចា** ហើយភិក្ខុពោលបាន
តែ **រូបំ អនិច្ចំ** អនុបសម្បន្នប្រាជ្ញារហ័ស មាត់រហ័ស ពោលបានដល់
វេទនា អនិច្ចា ដែលជាអនុបទ ព្រមចុះជាមួយនឹងពាក្យថា **អនិច្ចំ**
នៃភិក្ខុ ដូច្នេះត្រូវបាចិត្តិយ ពាក់ដោយអនុបទ ។ ធម៌នោះគឺបាលី
ដែលជាពុទ្ធភាសិត ព្រះពុទ្ធអង្គទ្រង់សម្តែងដោយព្រះអង្គឯង ១ យ៉ាង

សាវកកាសិត *បាលីដែលសាវ័កពាក់ចូលក្នុងពុទ្ធបរិស័ទបួនពោល* *ដូច*
អនង្គណសូត្រ *និងសម្មាទិដ្ឋិសូត្រ* *ជាដើម* ១ *យ៉ាង* *ឥសីកាសិត* *បាលី*
ដែលឥសី *បរិព្វាជក* *ខាងក្រៅសាសនាពោល* *ដូចបរិព្វាជកវគ្គទាំងអស់*
និងសោឡសបញ្ហាជាដើម ១ *យ៉ាង* *ទេវតាកាសិត* *បាលីដែលទេវតា*
ពោល *ដូចទេវតាសំយុត្ត* *និងទេវបុត្តសំយុត្ត* *ជាដើម* ១ *យ៉ាង* *កាសិត*
ទាំងបួននេះ *ដែលប្រកបដោយអត្ថនិងធម៌អាស្រ័យព្រះនិព្វាន* *សម្តែង*
ព្រះនិព្វាន ។ *ក្នុងអនុបសម្បន្នត្រូវតិកបាចិត្តិយ* ។ *ឧបសម្បន្ន* *ភិក្ខុ*
សម្គាល់ថាជាអនុបសម្បន្ន *ឬសង្ស័យ* *ហើយប្រដៅធម៌* *ត្រូវទុក្កដ* ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ *គឺរៀនបាលី* *ស្វាធ្យាយបាលី* *ជាមួយ*
នឹងអនុបសម្បន្ន *និងរៀនបាលីក្នុងសម្ផាក់នៃអនុបសម្បន្ន* *ពោលព្រម*
គ្នាក្តី *ទន្ទេញ* *សូត្រ* *គម្ពីរដែលស្ទាត់ដោយច្រើនជាមួយគ្នា* *ឬអនុប-*
សម្បន្នពោលភ្ជាត់ *ភិក្ខុប្រាប់ថា* *ឲ្យពោលដូច្នេះ* *ហើយពោលឡើងព្រម*
គ្នា *និងភិក្ខុឆ្ពួតជាដើម* *ទាំងអម្បាលនេះ* *មិនត្រូវអាបត្តិ* ។ *ជាអនាណត្តិក:*
មានអង្គ ៣ *គឺ* **អនុបសម្បន្នតា** *អនុបសម្បន្ន* ១ **រុត្តលក្ខណំ**
ឆម្មំ **បទសោ ភាចនតា** *ប្រដៅធម៌មានលក្ខណ:ដូចពោលហើយ*
ដោយបទ ១ **ឯកតោ ឋិសាបនំ** *ឲ្យចប់ចុះជាមួយគ្នា* ១ *ព្រម*
ដោយអង្គ ៣ *នេះ* *ទើបត្រូវបាចិត្តិយ* ។ *ជាបទសោធម្មសមុដ្ឋាន* *ជាកិរិយា*
ត្រូវអាបត្តិព្រោះធ្វើ *ជានោសញ្ញាវិមោក្ខ* *មិនរួចទោសដោយសម្គាល់*

ជាអចិត្តក:ទោះមិនដឹង មិនកែ្ងង ក៏ត្រូវអាបត្តិ ជាបណ្ណត្តិវជ្ជ: មានទោស ព្រោះពុទ្ធប្ញញ្ញត្តិ ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។

បទសោធម្មសិក្ខាបទ គម្រប់ ៤ ចប់

សហសេយ្យសិក្ខាបទ គម្រប់ ៥ សេចក្តីថា ភិក្ខុណា សម្រេចការដេកក្នុងសេនាសន: ដែលប្រក់ទាំងអស់ ជាំងទាំងអស់ ឬប្រក់ច្រើន ជាំងច្រើន មានឧបចារ:ជាមួយគ្នា ក្នុងខណ:មួយព្រមគ្នា ឬមុន ឬក្រោយ ជាមួយអនុបសម្បន្ន រៀរតែភិក្ខុផងគ្នា ដោយហោចទៅ សូម្បីតែសត្វ តិរច្ឆាន មានទ្វារជាវត្ថុឲ្យកើតបាវជិកាបត្តិបាន ឲ្យលើសជាង ៣ រាត្រីទៅ ត្រូវបាចិត្តិយ រាប់អំពីរាត្រីគម្រប់ ៤ ទៅ ។ សេនាសន:ដែលជាំងដោយ គ្រឿងជាំងមានជញ្ជាំងជាដើម មិនជាប់នឹងដំបូល ខ្ពស់ឡើង ១ ហត្ថ ១ ចំអាម ដោយជុំវិញ គប្បីដឹងថា សេនាសន:ជាំងទាំងអស់ ព្រោះហេតុដូច្នោះ សេនាសន:ប្រកបដោយលក្ខណ:ដូច្នេះ សូម្បីជាប្រាសាទ ៧ ជាន់ ឬជាផ្ទះមុខ ៤ មានលែ្ងងដល់មួយរយក្តី បើមានឧបចារ:គឺទ្វារប្រើប្រាស់ជាមួយគ្នា ក៏ឈ្មោះថាជាទីសេយ្យាសន៍ជាមួយគ្នា ។ ភិក្ខុណាដេកជាមួយនឹងអនុបសម្បន្នតែម្នាក់ ឬជាមួយអនុបសម្បន្នច្រើននាក់ក្តី ក្នុងសេនាសន:ជាមួយគ្នា ឬក្នុងទីដទៃដូច្នេះក្តី អស់ ៣ រាត្រីហើយ លុះដល់ថ្ងៃជាគម្រប់ ៤ កាលបើព្រះអាទិត្យអស្តង្គតទៅហើយ អនុបសម្បន្នដេក

មុន ភិក្ខុនឹងបិទទ្វារលែង ឬមិនបិទក្តីហើយដេក ឬភិក្ខុដេកមុនអនុបសម្បន្នដេកក្រោយ ភិក្ខុមិនក្រោកឡើងត្រូវបាចិត្តិយ រាប់ដោយប្រយោគដែលក្រោកឡើងនិងដេកចុះនៃខ្លួននិងអនុបសម្បន្ន ទាំងពីរនាក់ និងរាប់ដោយរូបអនុបសម្បន្នដែលដេកនៅនោះ ។ ក្នុងអនុបសម្បន្ន ត្រូវតិកបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសម្គាល់ថាជាអនុបសម្បន្ន ឬសង្ស័យហើយដេក ត្រូវទុក្កដ ។ សេនាសនៈប្រក់ពាក់កណ្តាលបាំងពាក់កណ្តាល ប្រក់ទាំងអស់បាំងតិច ប្រក់ច្រើនបាំងតិច បាំងទាំងអស់ប្រក់តិច បាំងច្រើនប្រក់តិច ទាំងអម្បាលនេះ ជាវត្ថុឲ្យកើតអាបត្តិទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសេនាសនៈប្រក់ទាំងអស់ មិនបានបាំងឡើយ ឬមិនបានប្រក់ឡើយ បាំងទាំងអស់ ឬមិនបានប្រក់ដោយច្រើន មិនបានបាំងដោយច្រើន ទាំងអម្បាលនេះ មិនជាវត្ថុឲ្យកើតអាបត្តិ ។ ដេកថយជាង ២ រាត្រី ៣ រាត្រី ឬក្នុងរាត្រីជាគម្រប់ ៣ ចេញទៅមុនអរុណហើយ ទើបនៅតទៅទៀត និងក្នុងរាត្រីជាគម្រប់ ៣ អនុបសម្បន្នដេក ភិក្ខុអង្គុយ ឬភិក្ខុដេក អនុបសម្បន្នអង្គុយ ឬអង្គុយជាជាមួយគ្នាទាំងពីរ ហើយនៅតទៅទៀត និងភិក្ខុធ្លាតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ៣ គឺ **ចាចិត្តិយ-វត្ថុកសេនាសនំ** សេនាសនៈជាវត្ថុឲ្យកើតបាចិត្តិយ ១ **តត្ត អនុបសម្បន្នេន សហ ឯបជ្ជនំ** ដេកជាមួយនឹងអនុបសម្បន្ន

ក្នុងសេនាសនៈដូច្នោះ ១ **ចតុត្ថេ ទិវសេ សុរិយត្ថង្គមនំ** ព្រះអាទិត្យអស្តង្គតទៅហើយ ក្នុងថ្ងៃគម្រប់បួន ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ បើមិនព្រមដោយអង្គ ៣ មិនត្រូវអាបត្តិ ។ ជាឯឡកៈ-លោមសមុដ្ឋាន អាបត្តិកើតអំពីកាយ អំពីកាយចិត្ត ជាកិរិយា នោសញ្ញា-វិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ។

សហសេយ្យសិក្ខាបទ គម្រប់ ៥ ចប់

ទុតិយសហសេយ្យសិក្ខាបទ គម្រប់ ៦ សេចក្តីថា ភិក្ខុណា កាលព្រះអាទិត្យអស្តង្គតហើយ សម្រេចការដេកក្នុងសេនាសនៈដូចពោលហើយ ក្នុងសិក្ខាបទមុន ជាមួយមាតុគ្រាម គឺស្រីមនុស្ស សូម្បីកើតក្នុងថ្ងៃនោះ ត្រូវបាចិត្តិយ ។ វិនិច្ឆ័យទាំងពួងដូចសិក្ខាបទមុន ប្លែកតែកំណត់រាត្រី ។ ក្នុងសិក្ខាបទមុនត្រូវអាបត្តិក្នុងថ្ងៃគម្រប់ ៤ ។ ក្នុងសិក្ខាបទនេះ ត្រូវអាបត្តិតាំងអំពីយប់ដំបូងទៅ ។ ស្រីយក្ខ ស្រីប្រេត មានរូបប្រាកដ និងបណ្ណក និងតិរច្ឆានញ៉ីជាវត្ថុកើតមេថុនបាន ត្រូវទុក្កដ ក្នុងសិក្ខាបទនេះ ។ ដេកជាមួយគ្នា លុះដល់រាត្រីជាគម្រប់ ៤ ឲ្យកើតបាចិត្តិយាបត្តិ ដូចពោលហើយក្នុងសិក្ខាបទមុន ។

ទុតិយសហសេយ្យសិក្ខាបទ គម្រប់ ៦ ចប់

ធម្មទេសនាសិក្ខាបទ គម្រប់ ៧ សេចក្តីថា ភិក្ខុណា សម្តែងធម៌មានលក្ខណៈដូចបានពោលហើយក្នុងបទសោធម្មសិក្ខាបទ ដល់មាតុគ្រាម គឺស្ត្រីមនុស្ស ដែលដឹងពាក្យល្អ-អាក្រក់ និងពាក្យទ្រគោះ មិនទ្រគោះ ក្តី ឲ្យលើស ៦ ម៉ាត់ឡើងទៅ ត្រូវបាចិត្តិយ រាប់ដោយរូបមាតុគ្រាម ។ សម្តែងដោយបទនិងអក្ខរៈ រាប់ដោយបទនិងអក្ខរៈ រៀងលែងតែមានមនុស្សប្រុសដឹងសេចក្តី មានលក្ខណៈដូចពោលហើយក្នុងអនិយតគម្រប់ ២ នៅជាមួយផង មិនត្រូវអាបត្តិ ។ បាទនៃគាថា ១ ជាមួយម៉ាត់ គប្បីដឹងប្រមាណនៃពាក្យ ក្នុងពាក្យទាំងអស់ដូច្នេះ ។ ក្នុងមាតុគ្រាម ត្រូវតិក-បាចិត្តិយ ។ មិនមែនស្ត្រីភិក្ខុសម្គាល់ថាស្ត្រី ឬសង្ស័យ និងសម្តែងធម៌ដល់ស្ត្រីយក្ខ ស្ត្រីប្រេត បណ្ឌក និងតិរច្ឆានញ្ជីដែលមានកាយដូចជាមនុស្ស ទាំងអម្បាលនេះ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុសម្តែងធម៌ត្រឹមតែ ៦ ម៉ាត់ ឬថយជាង ៦ ម៉ាត់ ឬបុរសមានលក្ខណៈដូចពោលហើយ នៅជាមួយផង ឬភិក្ខុក្រោកឡើងឯង ហើយត្រឡប់អង្គុយចុះវិញ សម្តែងធម៌តទៅទៀត ឬស្ត្រីក្រោកឡើងហើយអង្គុយចុះវិញ ភិក្ខុសម្តែងធម៌តទៅទៀត ឬសម្តែងដល់ស្ត្រីដទៃតទៅ ឬភិក្ខុសួរបញ្ហា ឬស្ត្រីសួរបញ្ហា ភិក្ខុដោះបញ្ហា ឬភិក្ខុសម្តែងធម៌ដើម្បីមនុស្សដទៃ ស្ត្រីមកអង្គុយស្តាប់ជាមួយផង និងភិក្ខុឆ្លួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ជាអនាណត្តិកៈ មានអង្គ ៥ គឺ

វុត្តលក្ខណាសុ ធម្មសុ ធម្មំ ភាចាមំ ឧបរិ ទេសនា *សម្តែងធម៌មានលក្ខណៈ ដូចពោលហើយ លើសប្រាំមួយម៉ាត់ ១* **វុត្ត-លក្ខណោ មាតុគាមោ** *មាតុគ្រាមមានលក្ខណៈដូចពោលមកហើយ ១* **ឥរិយាបថបរិវត្តាភាវោ** *មិនផ្ទាស់ឥរិយាបថ ១* **វិញ្ញូ-បុរិសាភាវោ** *មិនមានបុរសដឹងសេចក្តីនៅផង ១* **អប្ប ញ្ញាវិសុជ្ជនា** *មិនមែនជាកាលវិសជ្ជនានូវបញ្ហា ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបទសោធម្មសិក្ខាបទ ប្លែកតែសិក្ខាបទនេះជា កិរិយាកិរិយៈ គឺអាបត្តិកើតអំពីការធ្វើ និងមិនធ្វើ គឺកិក្ខុធ្វើនូវការសម្តែងធម៌លើស ៦ ម៉ាត់ និងមិនធ្វើនូវការផ្ទាស់ឥរិយាបថ ។*

ធម្មទេសនាសិក្ខាបទ គម្រប់ ៧ ចប់

ភូតារោចនសិក្ខាបទ គម្រប់ ៨ សេចក្តីថា ភិក្ខុណា ប្រាប់ឧត្តរិ-មនុស្សធម្ម មានឈានជាដើម ដែលមានពិតក្នុងខ្លួនដល់អនុបសម្បន្ន មិនមែនភិក្ខុនិងភិក្ខុនី ត្រូវបាចិត្តិយ ព្រោះឧត្តរិមនុស្សធម្មមានពិត ។

ភូតារោចនសិក្ខាបទ គម្រប់ ៨ ចប់

ទុដ្ឋុល្លារោចនសិក្ខាបទ គម្រប់ ៩ សេចក្តីថា ភិក្ខុណា ប្រាប់អាបត្តិអាក្រក់របស់ភិក្ខុ ព្រមទាំងវត្ថុដល់អនុបសម្បន្នដូច្នេះថា ភិក្ខុនេះកៃ្ងងធ្វើឲ្យ

អសុចិហូរចេញ ត្រូវសង្ឆាទិសេសាបត្តិដូច្នេះជាដើម ត្រូវបាចិត្តិយ រៀរលែងតែភិក្ខុដែលសង្ឆសន្ធត គឺសង្ឆកំណត់ទីបំផុតនៃអាបត្តិ ១ យ៉ាង ឬទីបំផុតនៃត្រកូល ១ យ៉ាង ឬកំណត់ទីបំផុតនៃអាបត្តិនិងត្រកូលផង ឬមិនកំណត់ទាំងពីរ ហើយអបលោកន៍ ៣ ដង ធ្វើកតិកាកំណត់ឲ្យប្រាប់ ឬដើម្បីនឹងឲ្យភិក្ខុដែលត្រូវអាបត្តិរឿយៗ នោះ សង្ស្រមរវាំងខ្ជួនល្ងិតល្ងតទៅ ភិក្ខុបានសម្មតិដូច្នេះ ប្រាប់តាមសម្មតិមិនត្រូវអាបត្តិ ។ ក្នុងបាលីថា បារាជិក ៤ សង្ឆាទិសេស ១៣ ឈ្មោះថាអាបត្តិអាក្រក់លាមក ឯក្នុងអដ្ឋកថា ថាក្នុងបាលីនេះពោលតែបារាជិក ដើម្បីនឹងសម្តែងទុដ្ឋុល្លស័ព្ទ ក៏ឯក្នុងសិក្ខាបទនេះ សង្គ្រោះយកសង្ឆាទិសេសផង ឈ្មោះថាទុដ្ឋុល្លាបត្តិ ។ ក្នុងអាបត្តិអាក្រក់ ត្រូវតិកបាចិត្តិយ ។ មិនមែនអាបត្តិអាក្រក់ ភិក្ខុសម្គាល់ថា អាបត្តិអាក្រក់ ឬសង្ស័យ ហើយប្រាប់ ឬប្រាប់អាបត្តិទាំង ៥ កង មានថុល្លច្ច័យជាដើម ដែលមិនមែនជាទុដ្ឋុល្លាបត្តិ ឬប្រាប់អជ្ឌាចារអាក្រក់ គឺការដែលកន្ទងសិក្ខាបទទាំង ៥ ខាងចុងរបស់អនុបសម្ប្ឫន្ធក្តី ទាំងអម្បាលនេះ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺប្រាប់តែវត្ថុ ១ យ៉ាង ថាភិក្ខុនេះកែងធ្វើឲ្យអសុចិហូរចេញមក និងបបោសអង្ហែលមាតុគ្រាមជាដើម ឬប្រាប់តែអាបត្តិ ១ យ៉ាង ថាភិក្ខុនេះត្រូវអាបត្តិសង្ឆាទិសេស ត្រូវអាបត្តិថុល្លច្ច័យ ជាដើមដូច្នេះក្តី ឬភិក្ខុដែលសង្ឆសន្ធតកំណត់ឲ្យប្រាប់ទុកត្រឹម

ណា ប្រាប់តាមតែកំណត់ មិនឲ្យហួសកំណត់ទៅក្តី និងកិក្ខុធ្លួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មានអង្គ ៣ គឺ **រុត្តលក្ខណាសួ កិក្ខុនោ សវត្ថុកោ សជ្ឈាឧិសេសោ** សង្ឆាទិសេសរបស់កិក្ខុ ព្រមទាំងវត្ថុមានលក្ខណ: ដូចពោលហើយ ១ **អនុបសម្ផន្នសួ អាភោចនំ** ប្រាប់ដល់អនុបសម្ផន្ន ១ **កិក្ខុ-សម្មតិយា អភាវោ** កិក្ខុដែលសង្ឆមិនបានសន្ទត ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នា-ទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាទុក្ខវេទនាប៉ុណ្ណោះ ។

ទុដ្ឋុល្លាភោចនសិក្ខាបទ គម្រប់ ៩ ចប់

បបវីខណនសិក្ខាបទ គម្រប់ ១០ សេចក្តីថា កិក្ខុណា ជីកដីដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យជីក ត្រូវបាចិត្តិយ ។ ដីមាន ២ យ៉ាង គឺជាតបបវី ១ អជាតបបវី ១ ។ ជាតបបវី មាន ៣ យ៉ាង គឺដីសុទ្ធ ១ ដីលាយដោយរបស់ដទៃ ១ ដីគំនរ ១ ។ ដីស្រួយសុទ្ធ ដីស្ងិតសុទ្ធ ដោយប្រក្រតី ឈ្មោះថាដីសុទ្ធ ។ ក្នុងផែនដីណាមានដីស្រួយ ឬដីស្ងិត ច្រើន ២ ចំណែក ឬអំបែង ក្រួស រ៉ាន ខ្សាច់ ទាំងអម្បាលនេះ ណាមួយតិចជាងចំណែកគម្រប់ ៣ ផែនដីនោះឈ្មោះថាដីលាយដោយរបស់ដទៃ ។ គំនរដីស្រួយ ឬដីស្ងិត បើភ្ជៀងធ្លាក់សង្កត់ហើយជាង ៤ ខែ ឈ្មោះថាដីគំនរ ដោយ

លក្ខណៈដូចពោលមកហើយនេះ សម្បីគំនរដីលាយដោយរបស់ដទៃ និង ធូលីដែលតាំងនៅលើខ្នងថ្ម ភ្ជៀងធ្លាក់សង្កត់ទទឹកម្ដង កន្ទងទៅ ៤ ខែ ឱកាសដែលទឹកភ្ជៀងទទឹកនោះរាប់ថាជាដីគំនរ ។ ផែនដីទាំង ៣ យ៉ាងនេះ គឺភ្លើងមិនបានឆេះ សម្បីជាគុកភ្លើង និងកន្ទែងដុតបាត្រជាដើម ឈ្មោះថាជាតបឋវី ។ ក៏ឯផែនដីដែលភ្លើងឆេះហើយ ឬដីលាយដោយ ថ្មជាដើម ច្រើនជាងចំណែកគម្រប់ ៣ នៃដីស្រួយ ឬដីស្អិតនោះ ឬគំនរ ដីស្អិតដែលភ្ជៀងធ្លាក់សង្កត់ថយចុះពី ៤ ខែ ឈ្មោះថាអជាតបឋវី ។ ផែនដី មានថ្មនិងក្រួសនិងអំបែងរវានខ្សាច់សុទ្ធមិនត្រូវអាបត្តិ ។ ដីដែលជាជាត-បឋវីនោះ ឈ្មោះថាអកប្បិយបឋវី ។ ភិក្ខុណាជីកឯង គឺធ្វើអកប្បិយបឋវី នោះឲ្យកម្រើក ដោយអាការជីក និងទម្ងាយ និងគូស និងដុត ជាដើម ភិក្ខុ នោះត្រូវបាចិត្តិយ រាប់ដោយប្រយោគ ។ ភិក្ខុណាឲ្យអ្នកដទៃជីកគឺធ្វើឲ្យ កម្រើកដោយន័យដូចពោលមកហើយ គឺបង្គាប់កំណត់ទីឲ្យជីកថា "អ្នក ចូរជីកទម្ងាយប្រទេសនេះ ផែនដីនេះ ដូច្នេះ" ជាដើម ត្រូវទុក្កដគ្រប់វារៈ បង្គាប់ ។ អ្នកទទួលបង្គាប់សម្បីជីកអស់មួយថ្ងៃ ត្រូវបាចិត្តិយដល់អ្នក បង្គាប់ តែមួយប៉ុណ្ណោះ ។ បើបង្គាប់រឿយៗ ក៏ត្រូវបាចិត្តិយរាល់ពាក្ស ដែលបង្គាប់នោះ ។ ផែនដី ភិក្ខុសង្ស័យក្ដី មិនមែនផែនដី សម្គាល់ ថាផែនដី ឬសង្ស័យក្ដី ធ្វើឲ្យកម្រើក ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុមិនបាននិយមឱកាស ថាទីនេះ និងបង្គាប់ថាអ្នកចូរជីកស្រះបោក្ខរណី ជីករណ្ដៅ ជីកអណ្ដូង ដូច្នេះ

ជាដើមក្តី ដីកក់ ឬដីស្នាមក្រចកជើងគោ ដែលស្ងួតបែករបើកឡើង មិនបានជាប់នឹងដីចាស់ខាងក្រោម និងច្រាំង ស្ទឹង ទន្ទ្រ ១ បេះធ្លាក់ក្នុងស្ទឹង ទន្ទ្រ ជារបស់ធំក្តី និងគំនរដីស្ថិតជាប់ដោយនង្គ័លជាដើម ទាំងអស់នេះឈ្មោះថាអជាតបឋវី ។ ព្រោះធ្វើអជាតបឋវីឲ្យកម្រើកក្តី និងពោលថា អ្នកចូរដឹងនូវរណ្ដាសសរនេះ អ្នកចូរឲ្យដីនេះ អ្នកចូរយកដីមកឲ្យយើង យើងត្រូវការដោយដី ចូរធ្វើដីឲ្យជាកប្បិយក្តី និងមិនក្ងែងធ្វើឲ្យផែនដីបែកដោយអាការប្រមៀលដើមឈើជាដើម និងយកមេជើងគូសដី ដោយមិនមានសតិ និងមិនដឹងថាជាជាតបឋវី ឬមិនដឹងខ្ជីនថាជីកដីក្តី គូសដីក្តី និងកិក្ខុធ្ងួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាសាណត្តិក: មានអង្គ ៣ គឺ **ជាតបឋវី** ដីជាជាតបឋវី ១ **បឋវីសញ្ញិតា** ដឹងថាជាផែនដី ១ **ខណនខណាបនាំ អញ្ញតរំ** ជីកឯងឬប្រើគេឲ្យជីកណាមួយជាដើម ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ មិនព្រមដោយអង្គ ៣ មិនត្រូវអាបត្តិ ។ សមុដ្ឋានវិធីជាដើមដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាបណ្ណត្តិវជ្ជ: មានចិត្ត ៣ មានវេទនា ៣ ។

បឋវីខណនសិក្ខាបទ គម្រប់ ១០ ចប់

មុសាវាទវគ្គ ជាបឋម ចប់

ភូតគាមវគ្គ គម្រប់ ២ មាន ១០ សិក្ខាបទ:

ភូតគាមសិក្ខាបទ ជាបឋម សេចក្តីថា ភិក្ខុធ្វើដើមឈើ ដើមស្មៅ

ដើមវល្លិ ឲ្យធ្លាក់វិនាសទៅ គឺកាត់និងទម្លាក់ជាដើម ត្រូវបាចិត្តិយ ។ ដើមឈើ ស្មៅ វល្លិ ដែលដុះលើគោក ឬក្នុងទឹកនិងលើដើមឈើ និងលើកំផែង ឯណានីមួយ ដោយហោចទៅ សូម្បីតែតិណជាតិ គឺស្មៅដែលសុខុមល្អិតក្រៃពេក ដូចស្មៅដែលដុះលើកំផែងនិងជ្ម និងសេវាល-ជាតិ គឺសារាយ ចក ពងទឹក ដែលតូចប៉ុនគ្រាប់ស្ពៃដ៏ស្រស់ខៀវ ដែលតាំងនៅក្នុងទីនោះៗ ឈ្មោះថាភូតគាមទាំងអស់ ។ ភិក្ខុដឹងហើយធ្វើឲ្យកម្រើក គឺដកឡើងចាកទី ឬលើកឡើងចាកទឹក និងកាត់ទម្លាយ ចាក់ កាប់ ជាដើម ធ្វើឯងឬប្រើអ្នកដទៃឲ្យធ្វើ ឲ្យកម្រើកដោយន័យដូចពោលហើយ ក្នុងបឋវីខណនសិក្ខាបទ ត្រូវអាបត្តិបាចិត្តិយ ។ ដើមឈើ ស្មៅ វល្លិទាំងអស់នេះ គេជម្រះចេញអំពីភូតគាម គឺ ដក កាត់ចេញ ចាកទីហើយ ទោះបីមានឫស ដើម មើម ថ្នាំង ត្រួយ និងគ្រាប់ ណាមួយ ជាពូជក្តី ឈ្មោះថាពីជគាម ។ ពីជគামនោះគេយកមកតាំងទុកក្នុងភាជន ឬគេធ្វើជាគំនរទុក ឬគេដាំទុកក្នុងទីឯទៀត ដែលបែកតែឫសមួយមុខ នៅមិនទាន់ចេញពន្ធក ឬចេញតែពន្ធក ១ យ៉ាង មិនទាន់លេចឫស ថាបើពន្ធកស្ងឹកប្រមាណមួយចំអាមលូតឡើង ឫសនៅមិនទាន់លេចចេញ ឬឫសលេចចេញហើយ ពន្ធកមិនទាន់ខៀវដរាបណា ក៏ឈ្មោះថាពីជគាមដរាបនោះ ។ កាលឲ្យពីជគាមទាំងអម្បាលនោះកម្រើក ត្រូវទុក្កដ ។ សង្ស័យក្នុងភូតគាម និងពីជគាមក្តី មិនមែនភូតគាម ពីជគាម សម្គាល់ថាភូតគាម ពីជគាម ឬសង្ស័យ ឲ្យកម្រើក ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភូតគាម ឬពីជគាម ភិក្ខុសម្គាល់ថា មិនមែនហើយឲ្យកម្រើក និងភិក្ខុធ្លួតជាដើម មិនត្រូវអាបត្តិ ។ មិនកៃ្ងងដូចប្រមៀលថ្មនិងដើមឈើជាដើម ឬអូសមែកឈើ និងយកមេជើងចុចផែនដីស្ទៅជាដើម ដាច់ទៅមិនត្រូវអាបត្តិ ព្រោះមិនកៃ្ងងនឹងឲ្យដាច់ មិនមានសតិ ដូចបញ្ជូនចិត្តទៅកាន់ទីដទៃនិយាយជាមួយគ្នា យកមេជើងឬដៃក្ដិចស្ទៅ ឬវល្លិ មិនត្រូវអាបត្តិ ព្រោះមិនមានសតិ មិនដឹង ដូចមិនដឹងថា ពីជ-គាម ឬភូតគាម នៅខាងក្នុង និងមិនដឹងថាខ្លួនធ្វើឲ្យដាច់ គ្រាន់តែយកដៃកកណ្ដារឬចបជីកចាក់ចូលទៅក្នុងប្រហោងឬគំនរចំបើង ដើម្បីនឹងទុកដាក់ ឬកៃ្ងងរលាកដៃហើយបោះទៅ ថាបើស្ទៅជាដើមក្នុងទីនោះដាច់ ឬធ្លេះ មិនត្រូវអាបត្តិ ។ មិននិយមថាដើមឈើនេះឈើនោះ គ្រាន់តែពោលថា អ្នកចូរកាត់ឈើ កាត់វល្លិក្ដី និងពោលថាអ្នកចូរដឹងផ្ការឈើនេះ អ្នកចូរដឹងផ្ទៃឈើនេះ អ្នកចូរឲ្យផ្ការឈើនេះ ផ្ទៃឈើនេះ អ្នកចូរយកផ្ការឈើនេះ ផ្ទៃឈើនេះមក ហើយត្រូវការដោយផ្ការឈើនេះផ្ទៃឈើនេះ អ្នកចូរធ្វើផ្ការឈើនេះ ផ្ទៃឈើនេះឲ្យជាកប្បិយ ពោលដូច្នេះក្ដី មិនត្រូវអាបត្តិ ។ ពីជ:មានឫសជាដើមកើតនៅក្នុងទី ឈ្មោះថាភូតគាម ។ ជម្រះឲ្យផុតចាកភូតគាមហើយ ឈ្មោះថាពីជគាម ជាវត្ថុឲ្យកើតទុក្ខដ ។ ពីជគាមនេះ កាលបើភិក្ខុនឹងបរិភោគ គប្បីឲ្យអនុបសម្បន្នកប្បិយជាមុន ដើម្បីឲ្យរួចចាកពីជគាម ឯអាការដែលធ្វើកប្បិយនោះ នឹងពោលទៅខាងមុខ ។

សិក្ខាបទនេះ ជាសាណត្តិក: មានអង្គ ៣ គឺ **ភូតគាមោ** *ភូតគាម ១* **ភូតគាមសញ្ញិតា** *ដឹងថាភូតគាម ១* **វិកោបនំ វ វិកោ-ចាបនំ វ** *ធ្វើឲ្យកម្រើកឯង ឬប្រើអ្នកដទៃធ្វើឲ្យកម្រើក ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវអាបត្តិបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋ-ខណានសិក្ខាបទ ។*

ភូតគាមសិក្ខាបទ ជាបឋម ចប់

អញ្ញវាទកសិក្ខាបទ គម្រប់ ២ សេចក្តីថា ភិក្ខុត្រូវអាបត្តិជាសាវសេសកាលសង្ឆសាកសួរក្នុងកណ្តាលសង្ឆ មិនបានប្រាជ្ញានឹងប្រាប់សេចក្តីនោះ ក្លែងបិទបាំង ពោលបំភ្ញាត់ដោយពាក្យដទៃជាដើមថា អ្នកណាត្រូវត្រូវនូវអាបត្តិអ្វី ត្រូវទីត្រង់ណា ដូច្នេះជាដើមក្តី ឬនៅស្ងៀមធ្វើឲ្យសង្ឆលំបាកក្តី ត្រូវទុក្កដ ។ លុះសង្ឆលើកអញ្ញវាទកកម្ម ព្រោះពោលបំភ្ញាត់ ឬលើកវិហេសកកម្ម ព្រោះនៅស្ងៀម ធ្វើឲ្យសង្ឆលំបាក ដោយញត្តិ-ទុតិយកម្មវាចា ហើយសង្ឆសាកសួរទៀត ពោលពាក្យត្រឡប់ត្រឡិនទៅវិញទៅមក ឬនៅស្ងៀមទៀត ត្រូវបាចិត្តិយ ។ ធ្វើទាំង ២ យ៉ាង ត្រូវបាចិត្តិយ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុមិនដឹងអាបត្តិ ឬមិនបានដឹងថាខ្លួនត្រូវអាបត្តិ ឬសួរថាលោកពោលដូចម្តេច នឹងមិនបានពោលដោយគិតថា ភិក្ខុមិនបានធ្វើកម្មនោះប្រកបដោយធម៌ និងភិក្ខុឆ្កួតជាដើម ទាំង

អម្បាលនេះ មិនត្រូវអាបត្តិ ។ សិក្ខាបទនេះមានអង្គ ៣ គឺ **ឩម្ម្ហកម្ម្ហ អាវេឋិតតា** *ការសូត្រលើកទោសនោះជាធម៌ ១* **អាបត្តិយា ឯ វត្ថុនា ឯ អនុយុញ្ជិយមានតា** *សង្ឆសាកសួរដោយអាបត្តិ ឬ វត្ថុ ១* **ឆាឧេតុកាមតាយ អញ្ញេនញ្ញេ្ជ ដិ ចរណំ ឯ តុណ្ហី-ភាវេ ឯ** *ក្ងែងពោលពាក្យបន្ទប់បំភ្ងាត់ ឬនៅស្ងៀមដោយប្រាថ្នាបិទបាំង ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាអនាណត្តិក: ។*

អញ្ញវាទកសិក្ខាបទ គម្រប់ ២ ចប់

ឧជ្ឌាបនកសិក្ខាបទ គម្រប់ ៣ សេចក្ដីថា ភិក្ខុលើកទោស ត្មុះតិះ-ដៀល និន្ទា ភិក្ខុដែលសង្ឆសន្ទតឲ្យជាអ្នកធ្វើការសង្ឆ មានក្រាលអាសន:និងចែកលាភជាដើម តិះដៀល ឬនិន្ទា ភិក្ខុដូច្នេះក្នុងសម្ងាត់ភិក្ខុផងគ្នា ថាភិក្ខុធ្វើដោយឆន្ទាគតិ ដូច្នេះ ដោយប្រាថ្នានឹងលើកទោសដល់ភិក្ខុ ឯភិក្ខុនោះមិនបានធ្វើដោយអគតិទាំង ៤ មានឆន្ទាគតិជាដើម ភិក្ខុអ្នកតិះដៀលត្រូវបាចិត្តិយ ។ ធ្វើទាំង ២ យ៉ាង ត្រូវបាចិត្តិយ ២ ។ ក្នុងសម្មតិកម្មដែលសង្ឆធ្វើដល់ភិក្ខុអ្នកធ្វើការសង្ឆនោះជាធម៌ ត្រូវតិក-បាចិត្តិយ ។ ក្នុងកម្មដែលមិនមែនជាធម៌ ត្រូវតិកទុក្កដ ។ ភិក្ខុត្មុះតិះដៀលនិន្ទា ភិក្ខុដែលសង្ឆសន្ទតនោះ ក្នុងសម្ងាត់អនុបសម្បន្ន ឬត្មុះតិះដៀលលើកទោស ឧបសម្បន្ន ដែលសង្ឆមិនបានសន្ទតឲ្យធ្វើការសង្ឆដោយ

ធម៌ ក្នុងសម្ងាត់អ្នកណាមួយក្តី ឬត្នះតិះដៀលអនុបសម្បន្ន ដែលសង្ឆ សន្ទតក្តី មិនបានសន្ទតក្តី ឲ្យធ្វើការសង្ឆដោយធម៌នោះ ក្នុងសម្ងាត់ អ្នកណាមួយក្តី ទាំងអម្បាលនេះ ត្រូវអាបត្តិទុក្កដទាំងអស់ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺកិក្ខុលើកទោស តិះដៀល នូវកិក្ខុ ជាអ្នកធ្វើការសង្ឆដោយអគតិទាំង ៤ មានឆន្ទាគតិជាដើម ថាមិនត្រូវតាម ធម៌ដោយប្រក្រតី និងកិក្ខុឆ្ពួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មានអង្គ ៦ គឺ **ធម្មកម្មេ សម្មតតា** កិក្ខុអ្នកធ្វើ ការសង្ឆបានសម្មតិដោយកម្មជាធម៌ ១ **ឧបសម្បន្នតា** អ្នកធ្វើការ សង្ឆនោះ ជាឧបសម្បន្ន ១ **អគតិគមនាភាវោ** មិនលុះក្នុងអគតិទាំង បួនណាមួយ ១ **តស្ស អវណ្ណកាមតា** ប្រាថ្នានឹងលើកទោស ដល់អ្នកនោះ ១ **យស្ស សន្តិកេ វទតិ តស្ស ឧបសម្បន្នតា** លើកទោសឬតិះដៀល ក្នុងសម្ងាត់អ្នកណា អ្នកនោះជាឧបសម្បន្ន ១ **ឧជ្ឈាបនំ វ ខីយនំ វ** បានឲ្យគេលើកទោស ឬតិះដៀលដោយខ្លួន ឯង ១ ព្រមដោយអង្គ ៦ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាទុក្ខវេទនាប៉ុណ្ណោះ ។

ឧជ្ឈាបនកសិក្ខាបទ គម្រប់ ៣ ចប់

បឋមសេនាសនសិក្ខាបទគម្រប់ ៤ សេចក្តីថា កិក្ខុណា តែងតាំង ក្រាលសេនាសន:ឯង ឬប្រើអ្នកដទៃឲ្យតែងតាំង ក្រាល នូវគ្រែ ឬ

តាំង ឬ ពួកស្បែក ពួកសំពត់ ឬ ភៅអី ដែលជារបស់សង្ឆ ក្នុងទីវាល ក្នុងរដូវក្ងៀង ៤ ខែ ឬក្នុងមណ្ឌបដែលក្ងៀងលេចបាន និងគល់ឈើជាទីលំនៅជានិច្ចនៃក្អែក និងសត្វត្រដក់ ជាដើម កាលនឹងចៀសចេញទៅ មិនរើទុកដាក់ឯង ឬមិនពឹងអ្នកដទៃឲ្យរើរបស់នោះទុកតាមសមគួរ ឬមិនបានផ្តាំផ្ញើប្រគល់ឲ្យកិក្ខុ ឬ សាមណេរ ឬ មនុស្សរក្សាវត្ត ឬ ឧបាសក ដែលជាលជ្ជី សម្គាល់ថាបីដូចជាធុរៈរបស់ខ្លួន ទាំងអម្បាលនេះ អ្នកឯណានីមួយ ហើយចៀសចេញទៅ កន្ទងលេខ្ចុបាត ដែលធ្លាក់ដុំដីនៃមជ្ឈិមបុរសចោលពីសេនាសនៈនោះទៅ ដោយជំហានជាបឋម ត្រូវទុក្កដ ។ ជំហានជាគម្រប់ ២ ត្រូវបាចិត្តិយ ។ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតឲ្យតែងតាំងលាតក្រាលគ្រែតាំងជាដើម ក្នុងរដូវរងា ៤ ខែ រដូវក្តៅ ៤ ខែ ជា ៨ ខែ នេះសង្កេតថា មិនមែនជាកាលក្ងៀង ឬក្នុងមណ្ឌបនិងគល់ឈើដែលក្អែក ត្រដក់ មិនបន្ទោឧច្ចារៈចុះ ក្នុងទីអម្បាលនេះ មិនទុកដាក់មុនហើយចៀសចេញទៅ មិនមានទោស ។ កិក្ខុតាំងទុក ក្រាលទុក ដើម្បីកិក្ខុដទៃ កិក្ខុដទៃនោះមិនបានអង្គុយក្នុងទីនោះ ឬមិនបានពោលថា អ្នកចូរទៅចុះដរាបណា ក៏នៅជាការៈរបស់អ្នកក្រាលដរាបនោះ ។ ឧបសម្បន្ន អង្គុយលើគ្រែនិងតាំងជាដើម ដែលខ្លួនតែងតាំងឯង ឬឲ្យអ្នកដទៃតែងតាំងលាតទុកហើយដោយប្រក្រតីឯណា របស់ទាំងនោះជាការៈនៃអ្នកអង្គុយនោះដោយពិត ។ កិក្ខុឈរនៅក្នុងរោងធាន់បង្ហាប់ថា អ្នកចូរទៅ

តាំងទុក លាតទុក ក្នុងទីសម្រាប់នៅវេលាថ្ងៃឯណោះ ហើយចូរទៅចុះ ហើយកិក្ខុនោះចេញចាកពោងធាន់នោះទៅកាន់ទីដទៃ ឲ្យវិន័យធរគប្បីកាត់អាបត្តិកិក្ខុនោះ ដោយលើកនូវជំហាន ។ ក្នុងសេនាសនៈរបស់សង្ឆ ត្រូវតិកបាចិត្តិយ ។ ក្នុងសេនាសនៈរបស់បុគ្គល ត្រូវតិកទុក្កដ ។ គ្រឿងកម្រាលរក្សាជូតផ្ទៃ និងគ្រឿងកម្រាលលើគ្រែ គ្រឿងកម្រាលលើផ្ទៃ កន្ទេលផ្ទៃង កន្ទេលរំចេក កំណាត់ស្បែក សំពត់ជូតជើង តាំងក្តារ ឬគ្រឿងឈើ គ្រឿងដី ដោយហោចទៅ សូម្បីគ្រឿងធ្វើដោយស្ទឹកឈើ ទាំងអម្បាលនេះ កិក្ខុតម្កល់ទុកក្នុងអជ្ឈោកាស មានលក្ខណៈដូចសម្តែងមកហើយ ចៀសចេញទៅ ត្រូវទុក្កដ ។

ក៏ឯកិក្ខុអ្នកនៅក្នុងព្រៃ កាលបើទីដែលភ្ជៀងមិនលេចទទឹកបាននោះ មិនមាន នឹងយករបស់ទាំងអស់ពួរទុកលើមែកឈើ ឬសត្វមានកណ្តៀរជាដើម នឹងមិនបានកាត់ដូចម្តេច សូម្បីនឹងធ្វើទុកដូច្នោះ ហើយទើបចៀសចេញទៅក៏គួរ ។ កិក្ខុកាន់អញ្ជោកាសិកង្គធុតង្គនៅក្នុងទីវាល ក៏គប្បីធ្វើកុដិដោយចីវររក្សានិងតាំងទុក ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសេនាសនៈរបស់ខ្លួន និងរបស់បុគ្គលអ្នកស្និទ្ធស្នាលគ្នា មិនត្រូវអាបត្តិ ទុកដាក់ឯង ឬផ្តាំផ្ញើឲ្យអ្នកដទៃទុកដាក់ ឬប្រាប់ប្រគល់ទុកហើយទើបទៅក្តី យកចេញទៅហាល ឬទៅដោយគិតថានឹងត្រឡប់មកទុកដាក់ ឬមានអ្នកមកឃាត់ឃាំងសេនាសនៈនោះ

ទុក គឺកិក្ខុចាស់មកបណ្តេញឲ្យក្រោក ឬអមនុស្សមកអង្គុយ ឬមនុស្ស ជាឥស្សរៈមកកាន់យក ឬសត្វសាហាវមានរាជសីហ៍ជាដើមមកឈរនៅ ក្នុងទីនោះ ទាំងអម្បាលនេះ ណាមួយ មិនបានទុកដាក់ក្តី ឬចៀស ចេញទៅព្រោះខ្ជាចអន្តរាយដល់ជីវិត និងព្រហ្មចរិយជាដើមក្តី និងកិក្ខុ ធ្ពត់ជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាសាណត្តិក: មានអង្គ ៦ គឺ **មញ្ចាទីនំ សជ្ជិកតា** គ្រែនិងតាំងជាដើម ជារបស់សង្ឆ ១ **រុត្តលក្ខណោ បទេសេ សណ្ឋារណំ វា សណ្ឋាបនំ វា** ក្រាលឯង ឬប្រើអ្នកដទៃឲ្យក្រាលក្នុងទីមានលក្ខណៈ ដូចពោលហើយ ១ **អបលិពុទ្ធតា** មិនមានអ្វីមកឃាត់ឃាំង ១ **អាបជ្ជាយ អភាវោ** មិនមានអន្តរាយ ១ **ឯរបេក្ខតា** មិនប្រាថ្នានឹងត្រឡប់មកទុកដាក់ ១ **លេឌ្ឌុចាតាតិក្កមោ** កន្ទងលេឌ្ឌុបាត ១ ព្រមដោយអង្គ ៦ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិនសិក្ខាបទ ប្លែក តែសិក្ខាបទនេះ ជាកិរិយាកិរិយ: ត្រូវព្រោះធ្វើ និងមិនធ្វើ គឺកិក្ខុធ្វើនូវ ការតែងតាំងលាតក្រាលហើយ មិនធ្វើនូវការសាទុកវិញ ។

បឋមសេនាសនសិក្ខាបទ គម្រប់ ៤ ចប់

ទុតិយសេនាសនសិក្ខាបទ គម្រប់ ៥ សេចក្តីថា កិក្ខុណា កាន់យក គ្រឿងក្រាលដេក ១០ យ៉ាងគឺ ពូក ១ គ្រឿងកម្រាលរក្សានូវពណ៌នៃ

ផ្ទៃ ១ គ្រឿងកម្រាលលើគ្រែលើតាំងជាដើម ១ គ្រឿងកម្រាលលើផ្ទៃ ១ កន្ទេលស្ទឹកឆ្នោតជាដើម ១ ស្បែកឯណានីមួយ ១ សំពត់និសីទន:មានជាយ ១ បច្ចត្ថរណ:សំពត់បាវ:និងសំពត់កោជវ: ១ គ្រឿងកម្រាលដ៏ហើយដោយស្នៅ ១ គ្រឿងកម្រាលដ៏ហើយដោយស្ទឹកឈើ ១ ទាំង ១០ នេះជារបស់សង្ឆ សូម្បីរបស់ណាមួយ កាន់យកដោយលំដាប់ រាស្ត្រាខ្ជួន មកលាតក្រាលឯង ឬប្រើអ្នកដទៃឲ្យលាតក្រាលក្នុងវិហារ ដែលជារបស់សង្ឆ និងចៀសទៅកាន់ទិស មិនបានសាទុកដាក់ឯង ឬ មិនឲ្យអ្នកដទៃសាទុកដាក់ ឬមិនប្រាប់ប្រគល់ឲ្យអ្នកណាមួយ ដូចពោលហើយក្នុងសិក្ខាបទមុន កន្ទងឧបចារ:នៃអាវាមចេញទៅ អាវាមមិនមានរបង កន្ទងឧបចារ:ចេញទៅ ក្នុងជំហានជាដំបូងត្រូវទុក្កដ ។ ជំហានជាគម្រប់ ២ ត្រូវបាចិត្តិយ ។ ក្នុងទីឯណាមិនមានសេចក្តីរង្ខៀសដោយកណ្តៀរ សូម្បីនឹងមិនប្រាប់ផ្តាំប្រគល់ហើយ នឹងទៅចាកទីនោះក៏គួរ ។ ក៏កិរិយាដែលប្រាប់ ផ្តាំ ប្រគល់នោះជាវត្តនៃភិក្ខុ ។ ក្នុងវិហាររបស់សង្ឆ ត្រូវតិក-បាចិត្តិយ ។ ក្នុងវិហារបស់បុគ្គល ត្រូវតិកទុក្កដ ។ លាតក្រាលឯង ឬឲ្យអ្នកដទៃលាតក្រាលទីដេកក្នុងឧបចារ:នៃវិហារ ក្នុងពោងធាន់ ឬមណ្ឌបដែលបាំងនិងមិនបានបាំង ឬក្នុងរុក្ខមូល ទីជាទីប្រជុំនៃជនដ៏ច្រើនក្តី តែងតាំងឯង ឬប្រើអ្នកដទៃឲ្យតែងតាំងនូវគ្រែ ឬតាំង ក្នុងវិហារ និងឧបចារ:នៃវិហារដូចពោលមកហើយ មិនធ្វើការទុកដាក់ឯងជាដើម ហើយចៀសចេញទៅ ត្រូវទុក្កដទាំងអស់ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺវិហារជារបស់ខ្លួន ឬរបស់បុគ្គលអ្នកស្និទ្ធស្នាល មិនត្រូវអាបត្តិ ធ្វើការទុកដាក់ឯងជាដើម ឬមានអ្នកដទៃមកឃាត់ឃាំងដូចពោលហើយក្នុងសិក្ខាបទមុនទុកចោលទៅក្តី ឬគិតថានឹងមកទុកដាក់ក្នុងថ្ងៃនេះ ឬទៅកាន់ស្ទឹង ឬលង្វែកភូមិ គិតថានឹងទៅតទៅទៀតក៏ឈប់នៅក្នុងទីនោះ ប្រាប់ផ្តាំ ប្រគល់ក្តី ឬទឹកជន់និងចោរជាដើមរាំងរាត្រឡប់មកមិនបានក្តី ឬមានអន្តរាយដល់ជីវិត ដល់ព្រហ្មចរិយក្តី និងកិក្ខុឆ្ពួតជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាសាណត្តិក:មានអង្គ ៧ គឺ **វុត្តលក្ខណា សេយ្យា** ទីដំណេកមានលក្ខណ:ដូចពោលមកហើយ ១ **តស្ស សជ្ជិកតា** ទីដំណេកនោះជារបស់សង្ឆ ១ **វុត្តលក្ខណេ វិហារេ សណ្ហារណំ វ សណ្ហាវបនំ វ** លាតក្រាលឯង ឬឲ្យអ្នកដទៃលាតក្រាលក្នុងវិហារមានលក្ខណ:ដូចពោលហើយ ១ **អបលិពុទ្ធតា** មិនមានអ្នកណាឃាត់ឃាំង ១ **អាបជ្ជាយ អភាវោ** មិនមានអន្តរាយ ១ **អនបេក្ខស្ស ឧិសាបក្ខមនំ** ចៀសទៅកាន់ទិស មិនប្រាថ្នានឹងត្រឡប់មក ១ **ឧបចារសីមា-តិក្កមោ** កន្ទងឧបចារសីមា ១ ព្រមដោយអង្គ ៧ នេះ ទើបត្រូវអាបត្តិបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចពោលហើយក្នុងសិក្ខាបទជាលំដាប់មកនោះ ។

ទុតិយសេនាសនសិក្ខាបទ គម្រប់ ៥ ចប់

អនុប្បទជ្ជសិក្ខាបទ គម្រប់ ៦ *សេចក្ដីថា* ភិក្ខុណា *ដឹងថាភិក្ខុអ្នកចូលទៅមុន ជាអ្នកមិនគួរនឹងឲ្យក្រោកចេញ* គឺ*ជាភិក្ខុចាស់វស្សាក្ដី ជាភិក្ខុឈឺក្ដី ជាភិក្ខុរក្សាឃ្លាំង ឬជាធម្មកថិក* វិ*នៃ*ធ*ម* *អាចារ្យអ្នកបង្ហាញគណៈណាមួយ ដែលសង្ឆ*ស*ន្ន*ត*ិ*ហារ*ឲ្យ*នៅ*ជានិ*ច*ក្ដី* *បីជ*ំ*ពួ*ក*នេ*ះ*នៅ*ក*ុ*ង*ិ*ហារ*ជ*ារ*ប*ស*ង*ឆ* *ឈ*ោ*ះ*ថ*ាជ*ាម*នុ*ស*្ស*ម*ិ*ន*គ*ួ*រ*នឹ*ង*ឲ*្យ*ក*្រ*ោ*ក* ។ *ភ*ិ*ក*ុ*ដ*ឹ*ង*ដ*ូ*ច*ន*េ*ះ* *ម*ា*ន*ប*្រ*ា*ថ*ា*ន*ឹ*ង*ឲ*្យ*ច*ង*្ហ*ៀ*ត*ច*ង*្ហ*ល*់*ចិ*ត*្ត*ឲ*្យ*ចេ*ញ*ទ*ៅ*ខ*្ជ*ួ*ន*ឯ*ង* *យ*ក*ទ*ី*ដ*ំ*ណ*ោ*ក*ម*ក*ល*ា*ត*ក*្រ*ា*ល*ឯ*ង* *ឬ*ឲ*្យ*អ*្ន*ក*ដ*ទ*ៃ*ល*ា*ត*ក*្រ*ា*ល* *ក*ុ*ង*ឧ*ប*ចា*រ*:*គ*្រ*ៃ*ន*ិ*ង*ត*ាំ*ង* *ឬ*ក*ុ*ង*ឧ*ប*ចា*រ*:*ទ*ី*ចូ*ល*ចេ*ញ* *ត*្រ*ូ*វ*ទ*ុ*ក*្ក*ដ* ។ *ក*ា*ល*អ*ង*្គ*ុ*យ* *ឬ*ដ*េ*ក* *ក*ុ*ង*ទ*ី*ដ*ំ*ណ*ោ*ក*ន*ោ*ះ* *ត*្រ*ូ*វ*ប*ា*ចិ*ត*្ត*ិ*យ* ។ *ធ*្វ*ើ*ទ*ាំ*ង*ព*ី*រ*យ*៉*ា*ង* *ត*្រ*ូ*វ*ប*ា*ចិ*ត*្ត*ិ*យ* ២ ។ *ធ*្វ*ើ*រ*ឿ*យ*ៗ* *ត*្រ*ូ*វ*ប*ា*ចិ*ត*្ត*ិ*យ*ត*ប*់*ដ*ោ*យ*ប*្រ*យ*ោ*គ* ។ *ក*ុ*ង*ិ*ហ*ារ*ធ*ំ* *ដ*ោ*យ*ជ*ុ*ំ*វ*ិ*ញ* *គ*្រ*ៃ*ន*ិ*ង*ត*ាំ*ង* ១ *ហ*ត*្ត* ១ *ច*ំ*អ*ា*ម* ។ *ក*ុ*ង*ិ*ហ*ារ*ត*ូ*ច* *ឈ*ួ*ម*ដ*ា*ក*់* *គ*្រ*ៃ*ន*ិ*ង*ត*ាំ*ង* *ប*ា*ន*ក*ុ*ង*ទ*ី*ណ*ា* *អ*ំ*ព*ី*ទ*ី*ន*ោ*ះ* ១ *ហ*ត*្ត* ១ *ច*ំ*អ*ា*ម* *ឈ*ោ*ះ*ថ*ាឧ*ប*ចា*រ*:*គ*្រ*ៃ*ន*ិ*ង* *ត*ាំ*ង* ។ *អ*ំ*ព*ី*ផ*ែ*ន*ថ*្ម*ជ*ា*ទ*ី*ល*ា*ង*ដ*ើ*ង* *ម*ក*ដ*ល*់*គ*្រ*ៃ*ន*ិ*ង*ត*ាំ*ង* *ឈ*ោ*ះ*ថ*ាឧ*ប*ចា*រ*:* *ទ*ី*ចូ*ល* ។ *អ*ំ*ព*ី*គ*្រ*ៃ*ន*ិ*ង*ត*ាំ*ង* *ម*ក*ដ*ល*់*ទ*ី*ប*ន*្ទ*ោ*ប*ស*្ស*ា*រ*: *ឈ*ោ*ះ*ថ*ាឧ*ប*ចា*រ*:* *ទ*ី*ចេ*ញ* ។ *ក*ុ*ង*ិ*ហ*ារ*ជ*ា*រ*ប*ស*ង*ឆ* *ត*្រ*ូ*វ*ត*ិ*ក*ប*ា*ចិ*ត*្ត*ិ*យ* ។ *ក*ុ*ង*ិ*ហ*ារ*ជ*ា*រ*ប*ស*់* *ប*ុ*គ*្គ*ល* *ត*្រ*ូ*វ*ត*ិ*ក*ទ*ុ*ក*្ក*ដ* ។ *ក*្រ*ា*ល*ឯ*ង* *ឬ*ប*្រ*ើ*អ*ក*ដ*ទ*ៃ*ឲ*្យ*ក*្រ*ា*ល*ន*ូ*វ*ទ*ី*ដ*ំ*ណ*ោ*ក* *ឬ*ទ*ី*អ*ង*្គ*ុ*យ* *ន*ិ*ង*ដ*េ*ក*ក*ុ*ង*ទ*ី*ខ*ា*ង*ក*្រ*ៅ*ឧ*ប*ចា*រ*:*ដ*ូ*ច*ព*ោ*ល*ហ*ើ*យ* *ឬ*ក*ុ*ង*ព*ោ*ង*ធ*ា*ន*់* *ជ*ា*ដ*ើ*ម* *ឬ*ក*ុ*ង*ឧ*ប*ចា*រ*:*ន*ៃ*ក*ុ*ដ*ិ*ហ*ារ* *ទ*ាំ*ង*អ*ម*្ព*ា*ល*ន*េ*ះ* *ត*្រ*ូ*វ*ទ*ុ*ក*្ក*ដ* ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺលាតក្រាលអង្គុយ ដេក ក្នុងសេនាសនៈជារបស់ខ្លួន ឬរបស់មនុស្សស្និទ្ធស្នាលក្តី ភិក្ខុឈឺ ឬភិក្ខុរងារក្តៅបៀតបៀនហើយចូលទៅក្តី ឬមានអន្តរាយ និងភិក្ខុធ្លុតជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ៤ គឺ **សង្ឃិកវិហារតា** វិហារទីលំនៅជារបស់សង្ឆ ១ **អនុដ្ឋាបនិយការជានតំ** ដឹងថាអ្នកនៅមុនមិនគួរនឹងឲ្យក្រោក ១ **សម្ពាធេតុកាមតា** ប្រាថ្នានឹងឲ្យភិក្ខុនោះចង្អៀតចង្អល់ ១ **ឧបចារេ និសីទនំ វា និបជ្ជនំ វា** អង្គុយឬដេកក្នុងឧបចារៈ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋមបារាជិក ប្លែកតែសិក្ខាបទនេះ ជាទុក្ខវេទនាប៉ុណ្ណោះ ។

អនុប្បទជ្ជសិក្ខាបទ គម្រប់ ៦ ចប់

និក្ខិត្តសិក្ខាបទ គម្រប់ ៧ សេចក្តីថា ភិក្ខុណា ក្រោធខឹងនឹងភិក្ខុ ហើយទង់ទាញឯង ឬប្រើអ្នកដទៃឲ្យទង់ទាញ ចាកវិហារគឺកុដិជារបស់សង្ឆ ឲ្យកន្ទង់ទ្វារចេញទៅ ត្រូវបាចិត្តិយ ។ ប្រាសាទច្រើនជាន់ ឬផ្ទះមុខបួន ក្ងោងទ្វារច្រើន ក្នុងសេនាសនៈដូច្នេះ ទង់ទាញដោយប្រយោគតែម្តងមិនឈប់ក្នុងចន្លោះ ត្រូវបាចិត្តិយតែ ១ ។ ទង់ទាញដោយប្រយោគផ្សេងៗ ឈប់ក្នុងចន្លោះ ត្រូវបាចិត្តិយ រាប់ដោយប្រយោគ សូម្បីមិន

ពាល់ដោយដៃ ហើយដេញឲ្យចេញដោយវាចាក៏ដូចគ្នា បង្ហាប់អ្នកដទៃឲ្យ ទង់ទាញ ខណៈដែលបង្ហាប់ ត្រូវទុក្កដ បង្ហាប់តែម្តងគេទង់ទាញឲ្យ កន្ទងទ្វារទៅសូម្បីច្រើនដង ត្រូវបាចិត្តិយ ដល់អ្នកបង្ហាប់តែ ១ ។ បើ ប្រើអ្នកដទៃកំណត់ថា អ្នកចូរទង់ទាញឲ្យហួសទ្វារប៉ុណ្ណោះ ឬថាអ្នកចូរ ទាញទៅឲ្យដល់ទ្វារធំ ដូច្នេះ ត្រូវបាចិត្តិយ រាប់ដោយទ្វារ ។ ក្នុងវិហារ ជារបស់សង្ឆ ត្រូវតិកបាចិត្តិយ ។ ក្នុងវិហារជារបស់បុគ្គល ត្រូវតិកទុក្កដ ។ ទង់ទាញភិក្ខុឬបរិក្ខារនៃភិក្ខុចេញចាកឧបចារៈនៃវិហារ មានពោងធាន់ជា ដើម និងទង់ទាញអនុបសម្បន្ន ឬបរិក្ខារនៃអនុបសម្បន្នចេញចាកវិហារ ឬឧបចារៈនៃវិហារ ទាំងអម្បាលនេះ ត្រូវទុក្កដ រាប់តាមបរិក្ខារ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺទង់ទាញចេញចាកវិហាររបស់ខ្លួន ឬរបស់អ្នកស្និទ្ធស្នាល ឬទង់ទាញនាំចេញនូវភិក្ខុអ្នកឈ្លោះ ឬបរិក្ខារ របស់អ្នកឈ្លោះ ចេញចាកសង្ឆារាមទាំងអស់ក្តី ឬទង់ទាញអលជ្ជីភិក្ខុ និងភិក្ខុឆ្គត និងសទ្ធិវិហារិក អន្តេវាសិក ជាអ្នកមិនបានប្រព្រឹត្តល្អ ឬទង់ទាញបរិក្ខារមនុស្សអម្បាលនេះចេញចាកទីលំនៅនៃខ្លួនក្តី និងភិក្ខុ ឆ្គតជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាសាណត្តិកៈមានអង្គ ៣ គឺ **សង្ឆិកវិហារតា** វិហារជារបស់សង្ឆ ១ **ឧបសម្បន្នស្ស ភណ្ឌានការកភាវនិវិនិមុត្តតា** ជាឧបសម្បន្ន ផុតទោសមាន ភាពជាអ្នកឈ្លោះជាដើម ១ **តោបេន និក្ខ្ឍនំ វ និក្ខ្ឍាបនំ វ** ទង់ទាញឯងឬប្រើអ្នកដទៃឲ្យទង់ទាញនូវឧបសម្បន្ននោះ ដោយ

សេចក្ដីខឹង ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋាន-
វិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះជាទុក្ខវេទនា ។

និក្កឌ្ឍនសិក្ខាបទ គម្រប់ ៧ ចប់

វេហាសកុដិសិក្ខាបទ គម្រប់ ៨ សេចក្ដីថា ក្នុងវិហាររបស់សង្ឆ
វេហាសកុដិ គឺកុដិ ២ ជាន់ ឬបីជាន់ ជាន់ខាងលើមិនបានក្រាល ជាន់
ខាងក្រោមជាទីបរិភោគ ខ្ពស់ល្មមផុតក្បាលមជ្ឈិមបុរស មិនទើសក្បាល
នឹងធ្នឹមខាងលើ ភិក្ខុណា អង្គុយ ឬដេក លើគ្រែ ឬតាំង មានជើងដែល
ចុចចុះគឺសិកចូលក្នុងមេគ្រែ មិនបានដាក់កន្ទុះ ដែលគេតម្កល់ទុកលើធ្នឹម
និងរតជាន់លើ ត្រូវបាចិត្តិយ ពាក់ដោយប្រយោគ ដោយន័យដូចពោល
ហើយក្នុងអនុឃ្ដសិក្ខាបទ ប្លែកតែសិក្ខាបទនេះ មានសមុដ្ឋានវិធីជា
ដើម ដូចឯឡកលោមសិក្ខាបទ ។

វេហាសកុដិសិក្ខាបទ គម្រប់ ៨ ចប់

មហាលូកវិហារសិក្ខាបទ គម្រប់ ៩ សេចក្ដីថា ភិក្ខុធ្វើឯង ឬឲ្យអ្នកដទៃធ្វើ
ឬជួសជុលនូវវិហារ គឺកុដិ លាបបូកទាំងខាងក្នុងខាងក្រៅ ខាងលើឬខាង
ក្រោមដោយកំបោរនិងដី ដែលជាវិហារធំ គឺមានម្ចាស់របស់ គប្បីលាប
បូក ឬឲ្យអ្នកដទៃលាបបូករឿយៗ ក្នុងទី ២ ហត្ថ ១ ចំអាម ដោយជុំវិញ
មេទ្វារ ដើម្បីនឹងឲ្យទីចងទ្វារ និងសន្ទឹកទ្វារ ជាប់មាំមិនរង្គោះ ដ្បិតទី

នោះជាទីប៉ះទង្គិចដោយសន្ទឹកទ្វារក្នុងវេលាបើកបិទ និងគប្បីលាបថែមឯង ឬ ឲ្យអ្នកដទៃលាបថែមទៀត នូវឱកាសនៃបង្ហួច ទំហំប៉ុនសន្ទឹកបង្ហួច ដោយជុំវិញ ដើម្បីនឹងធ្វើបរិកម្មបង្ហួចឲ្យមានពណ៌ផ្សេងៗ គប្បីប្រក់ ដំបូលដោយកំបោរ ឬក្បឿង ឬសិលា ឬស្មៅ ឬស្លឹកឈើណាមួយ ប្រក់ឯងពីរជាន់ ជាន់គម្រប់ ៣ គប្បីឲ្យអ្នកដទៃប្រក់ ថាបើប្រក់ឲ្យហួស ៣ ជាន់ឡើងទៅ ត្រូវបាចិត្តិយ ។ គប្បីឈរក្នុងទីប្រាសចាកវត្ថុខៀវ គឺឲ្យ ផុតស្រែចម្ការដែលគេព្រោះសាប នូវអបរណ្ណជាតិមានសណ្តែកជាដើម ។ ថាបើឈរក្នុងទីមានរបស់ខៀវដូច្នេះ ធ្វើការលាប ធ្វើការប្រក់ ត្រូវទុក្កដ ។ កំណត់ទីឈរដូច្នេះ មនុស្សអង្គុយខាងលើមេដំបូល ឬ កំពូលនៃផ្ទះមាន កំពូល និងក្រឡេកមើលមកដោយទីបំផុតសំយាប ឃើញមនុស្សខាង ក្រោមឈរ នៅលើចំណែកដីឯណា ហើយមនុស្សឈរនៅលើចំណែក ខាងក្រោមឯណា និងមើលឡើងទៅ ឃើញមនុស្សអង្គុយខាងលើ ដូច្នោះដែរ គប្បីឈរលើចំណែកខាងលើដូច្នេះ ឈ្មោះថាធ្វើការប្រក់ ។ សមុដ្ឋានវិធីជាដើម ដូចសញ្ចរិត្តសិក្ខាបទ ។

មហាល្លកវិហារសិក្ខាបទ គម្រប់ ៩ ចប់

សប្បាណកសិក្ខាបទ គម្រប់ ១០ សេចក្តីថា ភិក្ខុដឹងថាទឹកមាន តួសត្ត យកទៅស្រោចស្មៅ ស្រោចដីខ្លួនឯង ឬប្រើអ្នកដទៃឲ្យយក

ស្រោច ត្រូវបាចិត្តិយ ។ បើចាក់ឲ្យដាច់ឈ្ជរទឹកមួយក្អម ត្រូវអាបត្តិ បាចិត្តិយតែមួយ ។ ស្រោចឲ្យដាច់ឈ្ជរទឹករឿយៗ ត្រូវអាបត្តិរាប់ដោយ ប្រយោគ ។ បើធ្វើប្រឡាយឲ្យត្រង់ឲ្យទឹកហូរទៅសូម្បីអស់មួយថ្ងៃ ត្រូវ អាបត្តិតែមួយប៉ុណ្ណោះ ។ ទប់ទំនប់បង្ហូរទឹកឲ្យហូរទៅក្នុងទីដទៃ ត្រូវអាបត្តិ រាប់ដោយប្រយោគ ។ ចោលស្មៅនិងស្ទឹកឈើជាដើម សូម្បីច្រើនក្នុងទឹក ដែលតិច សត្វនឹងស្លាប់ដោយការចោលស្មៅនិងស្ទឹកឈើនោះ ចោល ដោយប្រយោគតែម្តងត្រូវអាបត្តិតែមួយ ។ ចោលម្តងៗ មួយមុខៗ រាប់ ដោយប្រយោគដែលចោល ។ ប្រើឲ្យអ្នកដទៃស្រោច ត្រូវទុក្កដដោយ បង្ហាប់ ។ អ្នកទទួលបង្ហាប់នោះស្រោចសូម្បីច្រើន ត្រូវបាចិត្តិយតែមួយ ដល់អ្នកបង្ហាប់ ។ ក្នុងទឹកមិនមានតួសត្វសម្គាល់ថាមានតួសត្វ ឬសង្ស័យ ក្នុងទឹកដែលមានតួសត្វក្តី ក្នុងទឹកដែលមិនមានតួសត្វក្តី កាន់យកស្រោច ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺស្រោចដោយសម្គាល់ថា ទឹកមិន មានតួសត្វ ដោយមិនក្ងែង មិនមានសតិ មិនដឹង និងកិក្ខុធ្លុតជាដើម ទាំង អម្បាលនេះមិនត្រូវអាបត្តិ ។ ជាសាណត្ថិក: មានអង្គ ៤ គឺ **ឧទកសួ សម្ជាណកតា** ទឹកមានតួសត្វ ១ **សិញ្ចនេន ចាណកា មវិស្ជន្តីតិ ជានន៎ំ** ដឹងថាសត្វនឹងស្លាប់ ដោយការចាក់ទឹក ១ **តញ្ច ឧទកំ តាឧិសមេវ** ទឹកគង់នឹងរីងទៅ ១ **វិនា វេឧក-ចេតនាយ យេន កេនចិ០ កវណីយេន តិណាឧីនំ**

សិញ្ចនំ ស្រោចស្មៅជាដើម ដោយកិច្ចណាមួយ រៀរចាកវធកចេតនា ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាបណ្ណត្តិវជ្ជ: មានទោសព្រោះពុទ្ធប្ញញ្ញត្តិ មានចិត្ត ៣ មានវេទនា ៣ ។

សប្បាណកសិក្ខាបទ គម្រប់ ១០ ចប់

ភូតគាមវគ្គគម្រប់ ២ ចប់

ឱវាទវគ្គ គម្រប់ ៣ មាន ១០ សិក្ខាបទ ៖

ឱវាទសិក្ខាបទ ជាបឋម សេចក្ដីថា ភិក្ខុណា ដែលសង្ឆមិនបានសន្ទតឲ្យជាអ្នកប្រដៅ ហើយពោលប្រដៅនាងភិក្ខុនីដោយគរុធម៌ ៨ ត្រូវបាចិត្តិយ ។ ភិក្ខុប្រកបព្រមដោយអង្គ ៨ ដូច្នេះ គឺជាអ្នកសង្រ្ដមដោយបាតិមោក្ខសំវរ: ១ ជាពហុស្សូត ១ ចេះចាំបាតិមោក្ខទាំងពីរ ដោយពិស្ដារ ១ សំឡេងពីរោះស្រួលបួល ១ ជាទីស្រឡាញ់នៃនាងភិក្ខុនី ១ មានកម្ទាំងល្មមនឹងប្រដៅនាងភិក្ខុនីបាន ១ មិនជ្ជាប់កន្ទ្ងគរុធម៌ជាមួយភិក្ខុនី ដែលស្ងៀកដណ្ដប់សំពត់កាសាវពស្ត្រ បួសឧទ្ទិសព្រះមានព្រះភាគអំពីកាលជាគ្រហស្ថ ១ មានវស្សា ២០ ឬលើសជាង ២០ ឡើងទៅ ១ ព្រមដោយអង្គ ៨ នេះ ទើបគួរសន្ទតឲ្យជាអ្នកប្រដៅនាងភិក្ខុនី ។

គរុធម៌ ៨ ដូច្នេះ គឺភិក្ខុនីមានវស្សាសូម្បី ១០០ គប្បីធ្វើអភិវាទជាដើមដល់ភិក្ខុ សូម្បីឧបសម្បទាក្នុងថ្ងៃនោះ ១ កុំគប្បីចាំវស្សាក្នុងអាវាស

មិនមានកិក្ខុ ១ គប្បីប្រាថ្នាការសួរឧបោសថ និងការចូលទៅដើម្បីទទួលឱវាទអំពីកិក្ខុសង្ឆគ្រប់កន្ទុះខែ ១ នៅចាំវស្សាហើយគប្បីបវារណាក្នុងសង្ឆពីរពួក ១ ត្រូវគរុធម៌គឺសង្ឆាទិសេសហើយ គប្បីប្រព្រឹត្តបក្ខ-មានត្តក្នុងសង្ឆពីរពួក ១ គប្បីស្វែងរកឧបសម្បទាដល់នាងសិក្ខមានាអ្នកសិក្សាក្នុងធម៌ប្រាំមួយ អស់ពីរឆ្នាំហើយក្នុងសង្ឆពីរពួក ១ កុំគប្បីបរិភាសន៍ ជេរផ្តាសាកិក្ខុដោយបរិយាយណាមួយ ១ បិទគន្ធងពាក្យកិក្ខុនីមិនឲ្យប្រដៅកិក្ខុ បើកឲ្យកិក្ខុប្រដៅកិក្ខុនីអំពីថ្ងៃខាងដើមទៅ ១ ។ គរុធម៌ទាំង ៨ នេះ ក្នុងមួយៗ កិក្ខុនីគប្បីគោរពរាប់អាន កុំគប្បីប្រព្រឹត្តកន្ទងដរាបអស់ជីវិត ។

ឱវាទ<u>សិក្ខាបទ</u> ជាបឋម ចប់

អដ្ឋង្គតសិក្ខាបទ គម្រប់ ២ សេចក្តីថា កិក្ខុណា សូម្បីសង្ឆសន្ធតឲ្យជាអ្នកប្រដៅកិក្ខុនីហើយ កាលព្រះអាទិត្យអស្តង្គតទៅហើយ ប្រដៅកិក្ខុនីដោយគរុធម៌ ឬដោយធម៌ដទៃ ត្រូវបាចិត្តិយ ។

អដ្ឋង្គ<u>តសិក្ខាបទ</u> គម្រប់ ២ ចប់

ឧបស្សយសិក្ខាបទ គម្រប់ ៣ សេចក្តីថា កិក្ខុចូលទៅកាន់ទីលំនៅនៃកិក្ខុនី ពោលប្រដៅកិក្ខុនី ដោយគរុធម៌ ត្រូវបាចិត្តិយ លុះតែមានសម័យគឺ កិក្ខុនីឈឺមកមិនបាន ។

ឧបស្ស<u>យសិក្ខាបទ</u> គម្រប់ ៣ ចប់

អាមិសសិក្ខាបទ គម្រប់ ៤ សេចក្តីថា ភិក្ខុណា ពោលតិះដៀលថា ភិក្ខុទាំងឡាយពោលប្រដៅភិក្ខុនី ព្រោះហេតុតែអាមិស មានបច្ច័យ ៤ ជាដើមដូច្នេះ ត្រូវបាចិត្តិយ ។

អាមិសសិក្ខាបទ គម្រប់ ៤ ចប់

ចីវរទានសិក្ខាបទ គម្រប់ ៥ សេចក្តីថា ភិក្ខុណា ឲ្យចីវរសូម្បីគ្រាន់តែឈ្មមវិកប្ប ដល់ភិក្ខុនីមិនមែនញាតិ ត្រូវបាចិត្តិយ រៀរលែងតែផ្ទាស់ប្តូរគ្នា សូម្បីប្តូរដោយវត្ថុតិចតួច មិនត្រូវអាបត្តិ ។

ចីវរទានសិក្ខាបទ គម្រប់ ៥ ចប់

ចីវរសិព្វនសិក្ខាបទ គម្រប់ ៦ សេចក្តីថា ភិក្ខុណា ដេរចីវរជារបស់ភិក្ខុនីមិនមែនញាតិ ដេរឯង ឬ ឲ្យអ្នកដទៃដេរ ត្រូវបាចិត្តិយ ។

ចីវរសិព្វនសិក្ខាបទ គម្រប់ ៦ ចប់

សំវិធានសិក្ខាបទ គម្រប់ ៧ សេចក្តីថា ភិក្ខុណា បបួល សន្យាពេលដើរផ្លូវជាមួយគ្នានឹងភិក្ខុនី ហើយដើរផ្លូវជាមួយគ្នា ដោយហោចទៅសូម្បីផុតលង្វែកភូមិមួយ ត្រូវបាចិត្តិយ រៀរលែងតែមានសម័យ គឺផ្លូវដែលត្រូវទៅដោយពួករនេះ ជាផ្លូវប្រកបដោយរង្គៀស គឺឱកាសដែលចោរតាំងនៅជាដើមប្រាកដ និងផ្លូវដែលប្រកបដោយភ័យធំ គឺចោរសម្ងាប់មនុស្សឃើញប្រាកដ មានសម័យដូច្នេះ មិនត្រូវអាបត្តិ ។

សំវិធានសិក្ខាបទ គម្រប់ ៧ ចប់

នាវាភិរូហនសិក្ខាបទ គម្រប់ ៨ សេចក្ដីថា ភិក្ខុណា បបួល សន្សាកំណត់នឹងភិក្ខុនី ឡើងជិះទូកជាមួយគ្នា ទៅច្រាសទឹកឬបណ្ដោយទឹក ត្រូវបាចិត្តិយ រៀរលែងតែធ្វងកាត់ទទឹង ទៅពីត្រើយខាងណោះទៅត្រើយខាងណោះដោយត្រង់ ។

នាវាភិរូហនសិក្ខាបទ គម្រប់ ៨ ចប់

បរិបាចនសិក្ខាបទ គម្រប់ ៩ សេចក្ដីថា ភិក្ខុណា ដឹងហើយធាន់បិណ្ឌបាតដែលភិក្ខុនីបបួលទាយកឲ្យចាត់ចែងថ្វាយ ត្រូវបាចិត្តិយ រៀរលែងតែទាយកគេតាក់តែងទុកមុន ឬគេជាញាតិ ឬជាមនុស្សបវរណានៃភិក្ខុ មិនត្រូវអាបត្តិ ។

បរិបាចនសិក្ខាបទ គម្រប់ ៩ ចប់

រហោនិសជ្ជសិក្ខាបទ គម្រប់ ១០ សេចក្ដីថា ភិក្ខុណា តែម្នាក់ឯងមិនមានបុរសដឹងក្ដីនៅផង សម្រេចការអង្គុយ ការដេក ក្នុងទីកំបាំងភ្នែកជាមួយនឹងភិក្ខុនីម្នាក់ឯង មិនមានភិក្ខុនីដទៃនៅផង ត្រូវបាចិត្តិយ ។

រហោនិសជ្ជសិក្ខាបទ គម្រប់ ១០ ចប់

សិក្ខាបទទាំង ១០ នេះ ភិក្ខុនីបានឧបសម្បទា ក្នុងឧភតោសង្ឆជាបាចិត្តិយវត្ថុ ។ ឧបសម្បទាក្នុងឯកតោសង្ឆជាទុក្កដវត្ថុ ។ សិក្ខាបទទាំង ១០ នេះពោលដោយសង្ខេប ព្រោះឥឡូវនេះមិនមានភិក្ខុនី មិនបានបដិបត្តិ ។

ឱវាទវគ្គ គម្រប់ ៣ ចប់

ភោជនវគ្គ គម្រប់ ៤ មាន ១០ សិក្ខាបទ ៖

អាវសថបិណ្ឌសិក្ខាបទ ជាបឋម សេចក្ដីថា ដុំបាយក្នុងពេងទាន គឺ ភោជន ៥ ប្រការគឺ បាយ ១ នំកុមាស ១ សម្ជូ ១ ត្រី ១ សាច់ ១ ទាំង-អម្បាលនេះ ណាមួយ ដែលមនុស្សអ្នកប្រាថ្នាបុណ្យ ក្នុងត្រកូលជាមួយគ្នា ឬត្រកូលផ្សេងគ្នា រួមចូលគ្នាជាទុនមួយ តម្កល់ទុកលួមធាន់ផ្ទៃត ក្នុងសាលាក្ដី មណ្ឌបក្ដី ក្រោមដើមឈើក្ដី ទីវាលក្ដី ជាមួយគ្នាឬផ្សេងៗ គ្នា ឬញ្ជែកទី ថ្ងៃនេះតម្កល់ទុកក្នុងទីមួយ ព្រឹកនេះតម្កល់ទុកក្នុងទីមួយដូច្នេះ មិនចំពោះអ្នកទទួល ថាឲ្យមនុស្សទាំងឡាយនេះ ឲ្យដល់មនុស្សប៉ុណ្ណោះ ឬមិនចំពោះរបស់ស៊ី ឲ្យទូទៅ ក្នុងភោជនដូច្នេះ ភិក្ខុមិនឈឺគឺអាចទៅ បានសូម្បីកន្ទុះយោជន៍ គប្បីទទួលធាន់បានក្នុងទីមួយក្នុងមួយថ្ងៃប៉ុណ្ណោះ តាំងពីថ្ងៃទីពីរហើយ ថាបើទទួលរបស់មនុស្សអម្បាលនេះ ក្នុងទីនោះ ឬទីដទៃទៀត ដោយប្រាថ្នានឹងធាន់ ត្រូវទុក្កដ ។ ធាន់ចូលទៅ ត្រូវ បាចិត្តិយ គ្រប់វារៈដែលលេបចូលទៅ ។ មិនមានជំងឺត្រូវតិកបាចិត្តិយ ។ មានជំងឺសម្គាល់ថាមិនមានជំងឺ ឬសង្ស័យ ទទួលធាន់ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុមានជំងឺក៏ដឹងថាមានជំងឺក្ដី ភិក្ខុធាន់តែម្ដង ឬកាលទៅធាន់ក្នុងពាក់កណ្ដាលផ្លូវមួយថ្ងៃ ឬធាន់ក្នុងទីដល់ហើយមួយថ្ងៃ សូម្បីកាលត្រឡប់មកវិញ ធាន់ក្នុងកណ្ដាលផ្លូវ មួយថ្ងៃ ឬមកដល់ហើយ ធាន់ក្នុងទីដែលមកដល់មួយថ្ងៃក្ដី គិតថានឹងទៅ

ធាន់ហើយចេញទៅមានអន្តរាយណាមួយក៏ត្រឡប់មកវិញ ដល់ដឹងថាផ្លូវក្សេមហើយ កាលនឹងទៅធាន់មួយថ្ងៃទៀតក្តី ឬម្ចាស់ទានគេនិមន្តឲ្យធាន់ក្តី ឬកិក្ខុធាន់របស់ដែលគេតាក់តែងចំពោះខ្លួនក្តី និងធាន់របស់ដែលគេតាក់តែងមិនលួមឆ្អែតក្តី ឬធាន់របស់ដទៃក្រៅពីភោជនទាំង ៥ និងកិក្ខុឆ្ពួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មានអង្គ ៣ គឺ **អាវសថបិណ្ឌាតា** ដុំបាយក្នុងពេងទាន ១ **អតិលា-ឌតា** មិនមានជំងឺ ១ **អនុវសិត្វា ភោជនំ** នៅធាន់ត្រាំត្រែង ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចឯឡកលោមសិក្ខាបទ ។

អាវសថបិណ្ឌសិក្ខាបទ ជាបឋម ចប់

គណភោជនសិក្ខាបទ គម្រប់ ២ សេចក្តីថា ត្រូវបាចិត្តិយព្រោះធាន់គណភោជន ។ កិក្ខុតាំងពី ៤ អង្គឡើងទៅ ឈ្មោះថាគណ: បើទាយកគេមកនិមន្តកិក្ខុ ៤ អង្គក្នុងទីជាមួយគ្នា ឬផ្សេងៗគ្នា មកនិមន្តដោយឈ្មោះភោជនទាំង ៥ ប្រការណាមួយ គឺអ្នកនិមន្តកាន់យកឈ្មោះភោជនទាំង ៥ ណាមួយ ហើយនិមន្តដោយអកប្បិយវោហារ ជាដើមថានិមន្ត ធាន់ បាយ ធាន់ត្រី ធាន់សាច់ លោកចូរទទួល បាយ ត្រី សាច់ នៃខ្ញុំដូច្នេះ ជាភាសាមគធ:ក្តី ឬភាសាដទៃក្តី កិក្ខុទាំងអម្បាលនេះ បើគេនិមន្តជាមួយគ្នា ឬផ្សេងៗ គ្នាដូច្នេះហើយ កិក្ខុទៅជាមួយគ្នា

ឬទៅផ្សេងៗគ្នា មួយអង្គម្ដង តែទទួលជាមួយគ្នា ឯក្រោយធាន់ជាមួយគ្នា ឬធាន់ក្នុងទីផ្សេងៗគ្នា ដូច្នេះឈ្មោះថាគណភោជន ធាន់គ្រប់គណ: ដ្ឋិតថាយកកិរិយាទទួលក្នុងទីជាមួយគ្នា ជាប្រមាណ សូម្បីភិក្ខុកាន់យកឈ្មោះនៃ បាយ ត្រី សាច់ សូមគេដោយពាក្យថា អ្នកចូរឲ្យ បាយ ត្រី សាច់ អំពីទីជាមួយគ្នា ឬផ្សេងៗគ្នា ហើយទៅជាមួយ ឬផ្សេងគ្នា តែទទួលក្នុងទីជាមួយគ្នា សូម្បីដូច្នេះក៏គង់ឈ្មោះថាគណភោជន គណភោជនដែលបានមកអំពីទីនិមន្ត្រន៍ ឬ វិញ្ញត្តិទាំងពីរនោះ ក្នុងខណ:ទទួលព្រមគ្នាដូច្នេះ ត្រូវទុក្ខដ ។ ធាន់ចូលទៅ ត្រូវបាចិត្តិយគ្រប់វារ:ដែលលេប រៀរតែមានសម័យ ៧ ប្រការ ដូច្នេះគឺ **កិណានសមយោ** កាលភិក្ខុមានជំងឺ មានជើងបែកដើរបិណ្ឌ-បាតមិនបាន ១ **ចីវរទានសមយោ** កាលទាយកឲ្យចីវរគឺតាំងពីថ្ងៃមួយ ពេចខែអស្សុជដល់ពេញបូណ៌មីខែកត្ដិក ចុងរដូវភ្ជៀងមួយខែ បើបានក្រាលគ្រងកបិនហើយជា ៥ ខែ អស់ហេមន្ដរដូវ ១ **ចីវរការសម-យោ** កាលភិក្ខុធ្វើចីវរ គឺកាត់ដេរនូវចីវរ ១ **អទ្ធានគមនសមយោ** កាលដើរផ្លូវឆ្ងាយតាំងពីកន្ទ:យោជន៍ កាលនឹងទៅ ក៏គប្បីធាន់បាន ទៅតាមផ្លូវក៏គប្បីធាន់បាន ទៅដល់ហើយក៏គប្បីធាន់បាន តែមួយថ្ងៃ ១ **នាវាភិរូហនសមយោ** កាលឡើងទៅក្នុងទូក គឺកាលនឹងឡើងទៅ ក៏គប្បីធាន់បាន ឡើងទៅហើយក៏គប្បីធាន់បាន ចុះពីទូកក៏គប្បីធាន់

បានតែមួយថ្ងៃ ១ **មហាសមយោ** *សម័យធំ គឺក្នុងទីឯណា កាលណា ភិក្ខុ ២-៣ អង្គល្មមដើរបិណ្ឌបាតចិញ្ចឹមជីវិតបាន លុះភិក្ខុមួយអង្គមកទៀតជាគម្រប់ ៤ មិនល្មមនឹងចិញ្ចឹមជីវិតបាន ១* **សមណភត្តសមយោ** *កាលភត្តនៃសមណៈ គឺអ្នកបួសជំពូកណាមួយធ្វើភត្ត និមន្តភិក្ខុដោយបាយ ១ មានសម័យទាំង ៧ នេះ ណាមួយ ធាន់គណភោជនបាន មិនត្រូវអាបត្តិ ។ ក្នុងគណភោជន ត្រូវតិកបាចិត្តិយ ។ មិនមែនគណ-ភោជន សម្គាល់ថាគណភោជនក្តី ឬសង្ស័យក្តី ធាន់ត្រូវទុក្កដ ។*

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺមិនមែនគណភោជន ដឹងថាមិនមែនគណភោជន ឬភិក្ខុ ២-៣ អង្គទទួលជាមួយគ្នាធាន់ ឬភិក្ខុច្រើនដើរបិណ្ឌបាត ហើយមករួមជាមួយគ្នា ធាន់ជាមួយគ្នា ។ មួយទៀត ក្នុងនិច្ចភត្តនិងសលាកភត្តជាដើម និងគ្រឿងធាន់ដទៃ ក្រៅចាកភោជនទាំង ៥ និងភិក្ខុឆ្លួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ៣ គឺ **គណភោជនតា** *គណ-ភោជន ១* **សមយាភាវោ** *មិនមានសម័យ ១* **អជ្ឌោហរណំ** *លេបចូលទៅ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចឯឡកលោមសិក្ខាបទ ដូចសម្តែងហើយ ក្នុងបឋមសហសេយ្យសិក្ខាបទ ។*

គណភោជនសិក្ខាបទ គម្រប់ ២ ចប់

បរម្ករកោជនសិក្ខាបទ គម្រប់ ៣ *សេចក្ដីថា* ភិក្ខុដែលទាយកគេនិមន្ត *ដោយ*កោជន ៥ *យ៉ាង ណាមួយ*ដោយ*នូវ*ដូចសម្ដែងហើយ ក្នុងគណ-*កោជន* មិនវិកប្ប*មុន* ហើយ*ធាន់*កោជនដែលទាយ*ក*និមន្ត*ក្រោយ* មុន*កោជ*ន*នៃ*ទាយ*ក*និ*ម*ន្ត*មុ*ន ឈ្ម*ោះ*ថ*ាប*រ*ម*្ករ*ក*ោ*ជ*ន ក្ន*ុ*ងខ*ណ*ៈ*ទ*ទ*ួ*ល*ត្រ*ូ*ว ទ*ុ*ក*ក*ដ ។ *ល*េ*ប*ចូ*ល*ទ*ៅ*ត្រ*ូ*ว*ប*ាចិ*ត*្ត*ិ*ย* *គ*្ម*ប*់*ว*ារ*:*ដ*ែ*ล*ล*េ*ป* *ว*ៀ*ร*ត*ែ*ម*ាន* *ส*ម*ั*យ ๓ *យ*ា*ง* គ*ឺ* *ค*ิ*ล*ា*น*ส*ม*ั*ย* ๑ *ช*ี*ว*ร*ท*ា*น*ส*ม*ั*ย* ๑ *ช*ี*ว*ร*ก*ា*ร*- *ส*ม*ั*ย ๑ *ด*ូ*จ*ส*ม*ដ*ែ*ง*ม*ក*ហ*ើ*យ*ក*ុ*ង*ค*ณ*ោ*ช*ន *ป*ើ*ม*ា*น*ส*ม*ั*ย*ទ*ាំ*ง*- *អ*ម*ป*ា*ล*ន*េ*ះ ណ*ា*ម*ួ*យ*ธ*ា*ន*ម*ិ*ន*ត*្ร*ូ*ว*អ*ា*ป*ត*ិ ។ ក*ុ*ង*ป*ร*ม*្ม*ร*ោ*ช*ន *ต*្ร*ូ*ว *ต*ิ*ก*ป*า*จ*ิ*ต*ិ*ย* ។ *ม*ិ*น*ม*ែ*ន*ช*ា*ป*ร*ม*្ม*ร*ោ*ช*ន *ส*ម*ា*ล*់*ป*ា*ร*ม*្ม*ร*ោ*ช*ន *ป*ុ *ส*ង*ว*ស* យ* *ห*ើ*យ*ธ*ា*ន* *ต*្ร*ូ*ว*ท*ុ*ก*ก*ដ ។

*ឯ*ว*ิ*ธ*ី*ដ*ែ*ล*ม*ិ*ន*ต*្ร*ូ*ว*អ*ា*ป*ต*ិ*ន*ោ*ះ* *ค*ឺ*ដ*ឹ*ง*ป*ា*ม*ិ*ន*ม*ែ*ន*ป*ร*ม*្ม*ร*ោ*ช*ន *ธ*ា*น*ម*ិ*ន*ต*្ร*ូ*ว*អ*ា*ป*ต*ិ *ว*ិ*ก*ป*ป*ោ*ช*ន*ដ*ែ*ล*ท*ា*ย*ก*ន*ិ*ม*ន*្ត*ม*ុ*ន *ด*ល*់*ส*ห*ธ*ม*្ម*ิ*ก *ท*ាំ*ง* ๕ *ณ*ា*ม*ួ*ย*ม*ុ*ន ក*ុ*ង*ท*ី*ច*ំ*ព*ោ*ះ*ม*ុ*ข*ด*ូ*ច*េ*ះ*ป* **ม*ยํ* *ภ*ต*ฺ*ต*ป*ฺ*ป*ท*ฺ*ท*ส*ํ** **ต*ุ*ยฺ*ห* *ช*ฺ*ม*ิ** *ก*ฺ*ค*ี *ป*ฺ*ร*ป* **ม*ยํ* *ภ*ต*ฺ*ต*ป*ฺ*ป*ท*ฺ*ท*ส*ํ* *ต*ุ*ยฺ*ห* *ว*ิ*ก*ป*ฺ*ป*ม*ิ** *ก*ฺ*ค*ี *ป*ฺ*ร*ว*ิ*ก*ป*ฺ*ป*ก*ฺ*ข*ง*ท*ี*ก*ํ*ป* า*ง*ม*ุ*ข*ด*ู*ច*េ*ះ*ป* **ม*ยํ* *ภ*ต*ฺ*ต*ป*ฺ*ป*ท*ฺ*ท*ส*ํ* *ส*ต*ฺ*ต*ฺ*ว*ม*ฺ*ม*ส*ฺ*ส* *ช*ฺ*ม*ิ** *ก*ฺ*ค*ี *ป*ฺ*ร*ป* **ม*ยํ* *ภ*ต*ฺ*ต*ป*ฺ*ป*ท*ฺ*ท*ส*ํ* *ส*ต*ฺ*ต*ฺ*ว*ม*ฺ*ม*ส*ฺ*ส* *ว*ิ*ก*ป*ฺ*ป*ม*ิ** *ด*ូ*ច*េ*ះ*ก*ី* *ป*ទ*ณ*ា*ม*ួ*យ* *ห*ើ*យ*ธ*ា*ន*ោ*ช*ន*ដ*ែ*ล*ป*ា*ន*ក*ុ*ង*ต*្ร*ก*ូ*ล*ន*ិ*ม*ន*្ត *ข*ា*ง*ក*្រ*ោ*យ*ន*ោ*ះ*ม*ុ*ន *ม*ិ*ន*ต*្ร*ូ*ว*អ*ា*ป*ต*ិ *ป*ុ*ธ*ា*น*ោ*ช*ន*ដ*ែ*ล*ป*ា*ន*ม*ុ*ន *น*ិ*ง*

ក្រោយជាមួយគ្នាក្តី ឬធ្វើភោជនដែលគេនិមន្ត ២-៣ កន្ទ្រែងនោះ រួមបញ្ចូលជាមួយគ្នាធាន់ក្តី ឬធាន់តាមលំដាប់និមន្តក្តី ឬភូមិទាំងអស់ ឬពពួកមនុស្សទាំងអស់ គេនិមន្តធាន់ក្នុងភូមិនោះ ក្នុងពពួកមនុស្សនោះ តំបន់ឯណានីមួយមុន ឬទាយកគេនិមន្ត ភិក្ខុពោលថា យើងនឹងទទួលកិក្ខាដូច្នេះ មិនត្រូវអាបត្តិ ។ ឯក្នុងនិច្ចភត្ត និងសលាកភត្តជាដើម ឬក្នុងរបស់ធាន់ដទៃ ក្រៅចាកភោជនទាំង ៥ យ៉ាង និងភិក្ខុឆ្លងជាដើមក្តី ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មានអង្គ ៣ គឺ **បរម្បរភោជនតា** ភោជននោះ ជាបរម្បរភោជន ១ **សមយាភាវោ** មិនមានសម័យ ១ **អជ្ឌោហារណំ** ធាន់ចូលទៅ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិនសិក្ខាបទ ប្លែកតែសិក្ខាបទនេះជាកិរិយាកិរិយ: ។

បរម្បរភោជនសិក្ខាបទ គម្រប់ ៣ ចប់

កាណមាតាសិក្ខាបទ គម្រប់ ៤ សេចក្តីថា ត្រកូលដែលគេធ្វើនំតាក់តែងទុក ដើម្បីនឹងបញ្ជូនកូនស្រីទៅកាន់ត្រកូលប្តី ឬគេតាក់តែងទុកដាក់ជាស្បៀងដើរផ្លូវ នាំមកបវារណាតាមប្រាថ្នាដល់ភិក្ខុដែលចូលទៅបិណ្ឌបាត ភិក្ខុគប្បីទទួលតែ ២-៣ បាត្រ ស្មើត្រឹមកណ្តាប់មាត់បាត្រខាងក្រោម ថាបើភិក្ខុទទួលពេញបាត្រគម្រប់ទាំង ៣ ឲ្យកំពុងជាកំពូលឡើងទៅ

ត្រូវតិកបាចិត្តិយ រាប់ដោយនំនិងសដូវដែលបិតនៅលើកណ្តាប់មាត់បាត្រ ខាងក្រោម ។ ភិក្ខុអង្គណាបានទទួលហើយពីរបាត្រ ភិក្ខុអង្គនោះចេញ មក ឃើញភិក្ខុខាងក្រៅ គប្បីប្រាប់ថា ក្នុងទីនោះយើងទទួលពីរបាត្រ ហើយ លោកគប្បីទទួលតែមួយបាត្រ សូម្បីភិក្ខុនោះឃើញភិក្ខុដទៃទៀត ក៏គប្បីប្រាប់ថា ភិក្ខុដែលមកមុនទទួលពេញពីរបាត្រហើយ យើងក៏ ទទួលមួយបាត្រហើយ លោកកុំទទួលឡើយ ភិក្ខុណាទទួលមុនមួយ បាត្រហើយ សូម្បីភិក្ខុនោះក៏គប្បីប្រាប់គ្នាតៗ ទៅដូច្នោះ ។ ភិក្ខុណា ទទួលឯងបីបាត្រ ភិក្ខុនោះបើឃើញភិក្ខុដទៃគប្បីហាមឃាត់ បើមិនហាម ឃាត់ត្រូវទុក្កដ សូម្បីភិក្ខុបានឮពាក្យហាមឃាត់ហើយ ខំចចេសទទួលក៏ ត្រូវទុក្កដ ។ ភិក្ខុនោះគប្បីទៅកាន់ព្រៃធាន់ ឬវិហារ ឬទីដែលធ្លាប់ត្រឡប់ មកអាស្រ័យ ឯណានីមួយ ដែលនៅជិតទីដែលបានរបស់មកនោះ ហើយតម្កល់ទុកដើម្បីខ្ជួនមួយបាត្រ ដែលសល់ពីនោះប្រគេនដល់សង្ឆ ។ ឯនឹងឲ្យតាមមិត្រសម្ងាញ់មិនបាន ។ ភិក្ខុណាទទួលមកមួយបាត្រហើយ ភិក្ខុនោះមិនប្រាថ្នា កុំគប្បីឲ្យឡើយ គប្បីធ្វើតាមចូលចិត្តចុះ ។

កាណមាតាសិក្ខាបទ គម្រប់ ៤ ចប់

បឋមបារណាសិក្ខាបទ គម្រប់ ៥ សេចក្តីថា ភិក្ខុណា កំពុងធាន់ ភោជនទាំង ៥ ណាមួយ ហើយហាមឃាត់ភោជនទាំង ៥ ណាមួយ

ដែលទាយកគេបិតនៅក្នុងហត្ថបាស ហើយបង្ហោនចូលមកឲ្យ ភិក្ខុក្រោកចាកទីនោះ ហើយត្រឡប់ធាន់ខាទនីយភោជនីយ: ដែលជាអនតិរិត្ត គឺមិនបានធ្វើវិនយកម្ម និងមិនមែនជាសំណល់នៃភិក្ខុឈឺ ក្នុងកាលថ្ងៃនោះ ត្រូវបាចិត្តិយ គ្រប់វារៈដែលលេប ។ បវារណាមានអង្គ ៥ គឺ ៖

អសនំ បញ្ញាយតិ ភិក្ខុកំពុងធាន់ ១ **ភោជនំ បញ្ញាយតិ** គេយកភោជនទាំងប្រាំ ណាមួយ មកប្រគេនទៀត ១ **ហត្ថចាសេ បិតោ** អ្នកឲ្យ នៅក្នុងហត្ថបាស ១ **អភិហរតិ** គេបង្ហោនភោជនមកចំពោះ ១ **បដិក្ខេបោ បញ្ញាយតិ** ភិក្ខុឃាត់ភោជន ១ ព្រមដោយអង្គ ៥ នេះ ទើបបានឈ្មោះថា ហាមឃាត់ ឈ្មោះថាបវារណា ។

ភោជន ៥ យ៉ាង គឺបាយកើតមកអំពីធញ្ញជាតិទាំងប្រាំពីរ នំកុមាសសដូវ ត្រី សាច់ ។ ឯធញ្ញជាតិទាំង ៧ នោះគឺ **សាលី** ស្រូវស ១ **វីហិ** ស្រូវក្រហម ១ **យវោ** ស្រូវដំណើប ១ **គោធុមោ** ស្រវ៉ែ ១ **កង្គុ** ល្ពៅ ១ **វរកោ** ស្ពយ ១ **កុទ្ទ្ធូសកោ** ស្មៅគ្រៃលលក ១ គេកាន់យកនូវធញ្ញជាតិទាំង ៧ នេះ ដណ្តាំជាបាយក្តី ជាបបរក្តី បើក្នុងវេលាកំពុងធាន់ នៅក្តៅក្តី ត្រជាក់ក្តី ស្ងាមដែលដួសមកនៅប្រាកដ នេះឈ្មោះថា ឱទនោ គឺបាយ ឲ្យកើតបវារណា ។ ក៏ឯបាយ បាយាស ឬយាគូ បបរលាយដោយរបស់ណាវ លុះលើកចេញអំពីចង្ក្រាន នៅក្តៅនៅឡើយ អាចគ្រៃលងហុតបាន សូម្បីស្ងាមក្នុង

ឱ្យកាសដែលគេកាន់យកដោយដៃមិនប្រាកដ មិនឲ្យកើតបវារណា ។ ថាបើចំហាយក្តៅអស់ហើយ បបរនោះជាខន់គោក សម្ដែងស្ពាមបានសោត ឲ្យកើតបវារណាបានទៀត កិរិយាដែលរាវអំពីមុន រក្សាមិនបានបើគេលាយដោយស្ងឹកឈើ ផ្ទៃឈើ និងទំពាំងច្រើន ដាក់អង្ករ សូម្បីមួយក្ដាប់ បើវេលាធាន់ស្ពាមប្រាកដសោត រមែងឲ្យកើតបវារណា ។ ក្នុងទីនិមន្តន៍មិនមានបបរ គេគិតនឹងប្រគេនបបរ គេយកទឹកនិងទឹកម្ជូរ ទឹកដោះជាដើម លាយចុះក្នុងបាយមកប្រគេនថា ចូរទទួលបបរ សូម្បីជារបស់រាវ ក៏រមែងឲ្យកើតបវារណាបានពិត ។ ថាបើគេចាក់បាយចុះក្នុងទឹកដែលពុះ ចម្អិនមកប្រគេន របស់នោះសង្គ្រោះថាជាបបរ បើគេយកដុំសាច់ ដុំត្រី សូម្បីប៉ុនគ្រាប់ស្ពៃ ដាក់ចុះក្នុងបបរ រមែងឲ្យកើតបវារណា ។ បាយគេដណ្ដាំដោយផ្ទៃឫស្សីជាដើម ឬដោយក្រឌីឈូក និងមើម និងផ្ទៃណាមួយ ដទៃក្រៅអំពីអង្ករនៃធញ្ញជាតិទាំង ៧ នេះ មិនឲ្យកើតបវារណា ។ នំកុមាសនោះ គេធ្វើដោយធញ្ញជាតិ ៧ ប្រការជាដើម ឲ្យកើតបវារណា ។ នំកុមាសនិងបបរគេធ្វើដោយរបស់ដទៃ មានសណ្ដែកបាយជាដើម មិនឲ្យកើតបវារណា ។ សជ្ជវនោះ គេលីងដោយធញ្ញជាតិទាំង ៧ ប្រការណាមួយ ធ្វើឡើងដោយហោចទៅ សូម្បីតែលម្អិតនិងកន្ទក់ដែលគេបុកអង្ករនៃស្រូវដែលលីងឲ្យក្រៀមឆ្ងិន ធ្វើឡើងនោះសង្គ្រោះថាជាសជ្ជវ ឲ្យកើតបវារណា ។

ក៏ឯកន្ទក់ ឬអង្ករ ឬលាជនៃស្រូវដែលគេលីងឲ្យធ្ជិនមិនក្រៀម ឬធ្ជិន ដោយកម្តៅព្រះអាទិត្យ ឬបាយនិងសណ្ដូវជាដើម ដែលគេធ្វើដោយ អង្ករនិងលាជនោះ មិនឲ្យកើតបវារណា ។ ក្នុងមំសៈ គឺសាច់ និងត្រី សោត កាលបើកិក្ខុកំពុងធាន់យាគូ ហើយគេប្រគេនដុំសាច់ ឬដុំត្រី សូម្បីប៉ុនគ្រាប់ស្ពៃដាក់ចុះក្នុងភាជនៈ ១ ឬផ្សេងៗសោត បើកិក្ខុមិន បានធាន់ត្រីសាច់ទេ ហើយឃាត់របស់ដទៃណាមួយ ដែលឲ្យ កើតបវារណាសោត មិនឈ្មោះថាឃាត់ តែដុំសាច់ ដុំត្រីនោះ ភិក្ខុ ទំពាធាន់ ១ ដុំ នៅក្នុងដៃ ឬក្នុងបាត្រ ១ ដុំ បើកិក្ខុឃាត់សាច់ត្រីដទៃ សោត ឈ្មោះថាឃាត់ទាំង ២ ដុំ ។ ភិក្ខុទំពាធាន់ហើយក្នុងមាត់ សូម្បី នៅសល់ប៉ុនគ្រាប់ស្ពៃ មិនមាន ថាបើឃាត់សាច់និងត្រីដទៃសោត មិនឈ្មោះថាឃាត់ ។ ភិក្ខុណាធាន់របស់ធាន់ជាកប្ជិយ ឬអកប្ជិយដទៃ ឃាត់អកប្ជិយមំសៈ និងអកប្ជិយភោជន ដែលកើតអំពីកុលទូសកៈ វេជ្ជកម្ម និងកើតអំពីអួតឧត្តរិមនុស្សធម្ម និងត្រេកអរូបិយជាដើម ភិក្ខុ នោះមិនឈ្មោះថាឃាត់ ព្រោះជារបស់មិនគួរបរិភោគ ។ បាយសូម្បី ១ គ្រាប់ ភិក្ខុណាធាន់ទៅហើយ ភោជនក្នុងបាត្រនិងមាត់ និងដៃណាមួយ មាននៅ បើភិក្ខុនោះមានអាល័យនៅឡើយ ហើយឃាត់នូវភោជនដទៃ មានលក្ខណៈដូចសម្តែងហើយសោត ឈ្មោះថាឃាត់ ។ បើភិក្ខុមិនមាន អាល័យ គឺវត្ថុណាដែលសល់នៅក្នុងបាត្រជាដើម វត្ថុនោះភិក្ខុមិនប្រាថ្នា

នឹងធាន់ ឬប្រាថ្នានឹងឲ្យអ្នកដទៃ ឬប្រាថ្នានឹងទៅធាន់ក្នុងទីដទៃ ភិក្ខុនោះសូម្បីឃាត់ ក៏មិនឈ្មោះថាឃាត់ ។

នឹងសម្តែងដោយហត្ថបាស បើភិក្ខុអង្គុយ កំណត់អំពីទីបំផុតខាងក្រោយ បើឈរកំណត់អំពីទីបំផុតខាងកែង បើដេកផ្ទៀងខាងណា កំណត់អំពីទីបំផុតខ្នងខាងនោះ ទៅដល់ចំណែកទីបំផុតអវយវៈដែលជិតនៃអ្នកឲ្យ ដែលអង្គុយ ឬឈរ ឬដេក រៀរតែដៃដែលគេលូកហុចមកនឹងឲ្យ ឲ្យបាន ២ ហត្ថ ១ ចំអាមឈ្មោះថាហត្ថបាស ។ គេឈរនៅក្នុងហត្ថបាស ហើយបង្ហោនចូលមក ហាមឃាត់ចេញ ទើបជាបវារណា ។ បើផុតហត្ថបាសនោះចេញទៅ ហើយហាម មិនជាបវារណា ។

នឹងសម្តែងដោយការបង្ហោនរបស់ចូលមក បើភិក្ខុអង្គុយនៅជាលំដាប់គ្នា មិនបង្ហោនបាត្រដែលនៅក្នុងដៃ ឬនៅលើជើង គ្រាន់តែប្រាប់ថា "អ្នកចូរកាន់យកបាយដូច្នេះសោត" បើភិក្ខុហាម មិនជាបវារណា សូម្បីក្នុងវត្ថុដែលគេលើកកញ្ជើបាយ ចូលមកតម្កល់ទុកលើផ្ទៃខាងមុខ ហើយប្រាប់ដូច្នេះក៏ដូចគ្នា កាលគេលើកឡើង ឬបង្ហោនចូលមកបន្តិច ហើយគេពោលថា "លោកចូរទទួល" កាលបើឃាត់ ទើបជាបវារណា ។ ម្នាក់កាន់កញ្ជើបាយអង្ក្ដាស អ្នកដទៃថានឹងជួយលើក ហើយគ្រាន់តែចាប់ប៉ុណ្ណោះ អ្នកអង្ក្ដាសនោះឯង លើកកញ្ជើនោះទុក ព្រោះហេតុ

នោះវត្ថុនោះឈ្មោះថាគ្រាន់តែបង្ហោនចូលមកប៉ុណ្ណោះ កាលបើហាមអ្នកកាន់កញ្ជើដែលបម្រុងនឹងឲ្យអំពីកញ្ជើនោះ ជាបវារណា ។ ថាបើអ្នកអង្គាសគ្រាន់តែពាល់កញ្ជើនោះប៉ុណ្ណោះ មានអ្នកដទៃលើកកញ្ជើនោះ ។ កាលបើឃាត់អ្នកកាន់យកដែលប្រាថ្នានឹងឲ្យអំពីកញ្ជើនោះ មិនជាបវា-រណា ។ លុះតែដួសដោយដៃកឡើងហើយកិក្ខុឃាត់ ទើបជាបវារណា ។ សូម្បីមនុស្សលើក ២ នាក់ លើកឡើងស្មើគ្នា កាលដែលឃាត់នោះ ក៏ជាបវារណាពិត ។ បើគេប្រគេនកិក្ខុអង្គុយជាលំដាប់ ហើយកិក្ខុក្រៅនោះ ជួយបិទបាត្រ ឈ្មោះថាឃាត់របស់ដែលគេបង្ហោនដល់អ្នកដទៃ ព្រោះហេតុនោះ មិនជាបវារណា ។

នឹងពោលអំពីរឿងហាមឃាត់ ។ ក្នុងរបស់ដែលគេបង្ហោនចូលមកដោយវាចា ហាមមិនឡើង ។ របស់គេបង្ហោនចូលមកដោយកាយ លុះតែហាមដោយកាយវិការ មានរាងដៃជាដើម ឬដោយវចីវិការជាដើមថា ល្មមហើយ កុំឲ្យឡើយ ដូច្នេះ ទើបជាបវារណា ។ មនុស្សម្នាក់បង្ហោនសម្ងាយដោយសាច់ចូលមកថា លោកចូរទទួលសម្ង កិក្ខុបានឮ ហាមអ្នកនោះ នេះមិនជាបវារណា ។ បើគេពោលថា លោកចូរទទួលសម្ងសាច់ កិក្ខុហាម ទើបជាបវារណា ។ បើគេពោលថាចូរទទួលរបស់នេះ កិក្ខុឃាត់ ក៏គង់ជាបវារណា ។ សូម្បីគេធ្វើសាច់ឲ្យផ្សេងគ្នាហើយពោលថា ចូរទទួលសម្ងសាច់ ថាបើដុំសាច់ប៉ុនគ្រាប់ស្ពៃមាននៅ

សោត កាលឃាត់របស់នោះចេញ រមែងជាបវារណា ។ បើមិនមានក៏គួរ ។ បាយ សម្ង ត្រី សាច់ លាយដោយខ្ទុរនិងទំពាំងជាដើម ហើយគេកាន់យកមកពោលថា ព្រះករុណាចូរទទួលសម្ងខ្ទុរ សម្ងទំពាំង សូម្បីដូច្នេះ ទោះនឹងហាម ក៏មិនឈ្មោះថាហាម ព្រោះគេពោលឈ្មោះរបស់ដែលមិនគួរឲ្យកើតបវារណា ។ បើគេពោលថា លោកចូរទទួលសម្ងត្រី សម្ងសាច់ ឬថាចូរទទួលរបស់នេះ ទើបឲ្យកើតបវារណា ។ ក្នុងឥរិយាបថទាំង ៤ គឺ ដេក ដើរ ឈរ អង្គុយ នេះ ភិក្ខុឃាត់ក្នុងឥរិយាបថណា កុំញ៉ាំងឥរិយាបថនោះឲ្យកម្រើក គប្បីធាន់ចុះ មិនមានទោស ។ របស់ធាន់ដែលមិនបានធ្វើវិនយកម្មដោយអាការ: ៧ ប្រការ និងមិនមែនជាសំណល់ភិក្ខុឈឺ ឈ្មោះថាអនតិរិត្ត: ធាន់មិនបាន ។ របស់ដែលធ្វើវិនយកម្មហើយ និងរបស់ជាសំណល់ភិក្ខុឈឺ ឈ្មោះអតិរិត្ត: គួរធាន់បាន ។

អាការនៃវិនយកម្មមាន ៧ យ៉ាង ដូច្នេះ គឺ **កប្ប្យកតំ ហោតិ** *របស់ដែលគេធ្វើឲ្យជាវត្ថុគួរ ១* **បដិគ្គហិតកតំ ហោតិ** *របស់ដែលភិក្ខុបានទទួលហើយធ្វើឲ្យជារបស់គួរ ១* **ឧច្ចារិតកតំ ហោតិ** *របស់ដែលភិក្ខុលើកឡើង ឬ បានបង្ហោនទៅជិតដើម្បីធ្វើឲ្យជារបស់គួរ ១* **ហត្ថបាសេ កតំ ហោតិ** *ភិក្ខុនៅក្នុងហត្ថបាសហើយធ្វើ ១* **ភុត្តាវិនា កតំ ហោតិ** *ភិក្ខុធាន់រួចហើយទើបធ្វើ ១*

ភុត្តាវិនា បវារិតេន អាសនា អុដ្ឋិតេន ភតំ ហោតិ *របស់ដែលកិក្ខុឆាន់ហើយ ហាមភោជនហើយ មិនទាន់ក្រោកចាកអាសន: ហើយធ្វើ ១* **អលមេតំ សព្វន្តិ រុត្តំ ហោតិ** *របស់ដែលកិក្ខុ ពោលថា របស់ទាំងអស់នេះគួរហើយ ១ ។ លុះរបស់នោះធ្វើឲ្យជា កប្ប៊ិយហើយដោយអាការនៃវិនយកម្ម ៧ យ៉ាងដូច្នេះ កាលកិក្ខុកំពុងឆាន់ បើគេយកអាមិសដទៃមកថែមទៀត ភិក្ខុនោះនឹងធ្វើកប្ប៊ិយរបស់នោះទៀត មិនបាន ដ្ឋិតលោកពោលទុកថា វត្ថុណាមិនបានធ្វើកប្ប៊ិយ គប្ប៊ីធ្វើ វត្ថុនោះ ភិក្ខុណាមិនបានធ្វើ ភិក្ខុនោះគប្ប៊ីធ្វើ ព្រោះហេតុដូច្នោះ របស់ដែលដាក់ចុះក្នុងភាជន:នៃរបស់ដែលកប្ប៊ិយហើយពីមុននោះ នឹង កប្ប៊ិយរបស់នោះមិនគួរ ក៏ឯភិក្ខុនោះឬភិក្ខុដទៃនឹងធ្វើក្នុងភាជន:ដទៃ ទើបគួរ ធ្វើហើយដូច្នេះនឹងលាយដោយរបស់ដែលធ្វើអំពីមុន ឆាន់ក៏គួរ នឹងគួរដល់ភិក្ខុមួយអង្គនោះក៏ទេ សូម្ប៊ីភិក្ខុដទៃ ដែលហាមបាយហើយ រ៉ៀរតែភិក្ខុធ្វើវិនយកម្មឲ្យ នឹងឆាន់ក៏គួរ តែនឹងមិនលាយដោយរបស់ ដែលមិនបានធ្វើកប្ប៊ិយយ៉ាងណា គប្ប៊ីធ្វើមាត់និងដៃឲ្យស្អាតយ៉ាងនោះ ហើយឆាន់ចុះ ។*

ក្នុងអដ្ឋកថា ពោលថា របស់ដែលជាសំណល់ភិក្ខុឈឺនោះ មិន មែនតែរបស់ដែលភិក្ខុឈឺឆាន់សល់មួយជំពូកប៉ុណ្ណោះទេ សូម្ប៊ីវត្ថុណា មួយដែលគេចំពោះភិក្ខុឈឺ ហើយនាំមកទុកថា បើភិក្ខុចង់ឆាន់ថ្ងៃនេះ

ឬកាលណានឹងបានធាន់កាលនោះ របស់ទាំងអស់នោះក៏ឈ្មោះថា ជាសំណល់នៃកិក្ខុឈឺ ពាក្យដែលពោលនោះធូរណាស់ ។

ភិក្ខុហាមបាយហើយដោយន័យដូចពោលមក ឲ្យឥរិយាបថកម្រើកហើយ ទទួលអាមិសណាមួយដែលជាអនតិរិត្ត:ដើម្បីនឹងធាន់ ត្រូវទុក្កដព្រោះទទួល ។ លេបចូលទៅត្រូវបាចិត្តិយគ្រប់វារៈដែលលេប ។ ក្នុងអាមិសជាអនតិរិត្ត:ត្រូវតិកបាចិត្តិយ ។ ទទួលយាមកាលិកជាដើម ដើម្បីអាហារធាន់ប្រាសចាកអាមិស ដើម្បីអាហារ ឬអាមិសជាអតិរិត្ត: សម្គាល់ថាជាអនតិរិត្ត: ឬសង្ស័យហើយធាន់ ទាំងអម្បាលនេះ ត្រូវទុក្កដទាំងអស់ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺទទួលអាមិសជាអនតិរិត្ត: ដោយគិតថានឹងឲ្យកិក្ខុដទៃធ្វើកប្បិយឲ្យ ហើយធាន់ នឹងទទួលដើម្បីអ្នកដទៃ និងធាន់យាមកាលិក សត្តាហកាលិក យាវជីវិក ប្រាសចាកអាមិស ដោយវិធីបរិភោគដែលព្រះពុទ្ធអង្គទ្រង់អនុញ្ញាត និងកិក្ខុឆ្ពត់ជាដើម ទាំងអម្បាលនេះ ជាអនាបត្តិ ជាអនាណត្តិក: មិនត្រូវព្រោះបង្ហាប់ ។ មានអង្គ ៣ គឺ **ឧបារិតភាវោ** ភិក្ខុហាមឃាត់បាយហើយក្រោកចាកអាសន: ១ **អាមិ-សស្ស អនតិរិត្តតា** អាមិសមិនបានធ្វើវិនយកម្មឲ្យជាអតិរិត្ត: ១ **កាលេ អជ្ឌោហារណំ** ធាន់ក្នុងកាល ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិនសិក្ខាបទ ប្ញែក

តែសិក្ខាបទនេះ ជាកិរិយាកិរិយៈ ត្រូវព្រោះធ្វើ និងមិនធ្វើ គឺកិក្ខុធ្វើនូវការហាមឃាត់ភោជនហើយ ធាន់នូវអនតិរិត្តភោជន ដែលខ្លួនមិនបានធ្វើឲ្យជាអតិរិត្តភោជន ។

<u>បឋមបវារណាសិក្ខាបទ គម្រប់</u> ៥ ចប់

ទុតិយបវារណាសិក្ខាបទ គម្រប់ ៦ សេចក្តីថា កិក្ខុណា ដឹងថាកិក្ខុដទៃហាមឃាត់បាយហើយ ដូចសិក្ខាបទមុន ហើយយកអាមិសរបស់ធាន់ដែលជាអនតិរិត្តៈ មិនបានធ្វើកប្ញិយមកបង្ខំឬអង្វរ ឲ្យកិក្ខុដទៃធាន់ដោយប្រាថ្នានឹងចោទលើកទោស ដើម្បីនឹងឲ្យអៀនអន់ ។ កាលបង្ហោនចូលទៅ ឬកាលកិក្ខុនោះទទួលនឹងធាន់ ត្រូវទុក្កដដល់កិក្ខុអ្នកបង្ហោនចូលទៅ ។ កិក្ខុនោះធាន់ ក៏ត្រូវអាបត្តិទុក្កដដល់កិក្ខុអ្នកបង្ហោនចូលទៅ គ្រប់វារៈនៃកិក្ខុនោះលេបចូលទៅ ។ កិក្ខុនោះធាន់ហើយ អ្នកបង្ហោនចូលទៅត្រូវបាចិត្តិយ ។ កិក្ខុអ្នកហាមឃាត់បាយហើយ ដឹងថា កិក្ខុនោះហាម-ឃាត់បាយហើយ ត្រូវបាចិត្តិយ ។ សង្ឆ្ស័យត្រូវទុក្កដ ។ កាលបង្ហោនយាមកាលិកចូលទៅ ដើម្បីជាអាហារក្តី លុះកិក្ខុទទួលនឹងធាន់នូវយាមកាលិកជាដើមក្តី កិក្ខុមិនឃាត់បាយ សម្គាល់ថាហាមឃាត់ក្តី សង្ឆ្ស័យក្តី ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺឲ្យធ្វើជាអតិរិត្តៈ ឬឲ្យដោយពាក្យថា លោកចូរឲ្យគេធ្វើជាអតិរិត្តៈហើយសឹមធាន់ ឬយកទៅឲ្យអ្នកដទៃក្តី

ឬឲ្យយាមកាលិកជាដើមថា កាលមានហេតុហើយចូរធាន់ចុះ និងកិក្ខុធ្លួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ជាអនាណត្តិក: មានអង្គ ៥ គឺ **បារិតតា** កិក្ខុហាមឃាត់បាយហើយ ១ **បារិតសញ្ញិតា** ដឹងថាកិក្ខុនោះ ហាមឃាត់បាយហើយ ១ **អាសាឧនាបេក្ខតា** សម្ងឹងក្នុងកិរិយាលើកទោស ១ **អនតិរិត្តេន អភិហដ្ឋុं បវារណាតា** យករបស់ដែលជាអនតិរិត្ត:បង្ហោនចូលទៅឲ្យ ១ **ភោជនបរិយោសានំ** កិក្ខុនោះធាន់ហើយ ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាទុក្ខវេទនា ។

ទុតិយបវារណាសិក្ខាបទ គម្រប់ ៦ ចប់

វិកាលភោជនសិក្ខាបទ គម្រប់ ៧ សេចក្តីថា ក្នុងវេលាវិកាល គឺតាំងអំពីព្រះអាទិត្យជ្រេពីត្រង់ទៅដរាបអរុណថ្មីរះឡើងមក ។ ខាទនីយ:ដែលជាអាមិសណាមួយ តាំងអំពីឫសឈើ ផ្ទៃឈើឡើងទៅ ឬរបស់ធាន់គឺភោជនទាំង ៥ ។ កិក្ខុទទួលដើម្បីធាន់ ត្រូវទុក្កដ ព្រោះទទួល ។ លេបចូលទៅត្រូវបាចិត្តិយគ្រប់វារ:ដែលលេប ។ ក្នុងវេលាវិកាលត្រូវតិកបាចិត្តិយ ។ ទទួលយាមកាលិកជាដើម ដើម្បីជាអាហារ ឬធាន់ដើម្បីជាអាហារ ក្នុងវិកាល ឬក្នុងកាលគឺអំពីព្រឹកដល់ថ្ងៃត្រង់ សម្គាល់ថាវិកាល ឬសង្ស័យទាំងអស់នេះ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺក្នុងកាលដ៏ងជាកាល បរិភោគ មិនត្រូវអាបត្តិ កាលបើមានហេតុធាន់យាមកាលិកជាដើមក្នុងវិកាលបាន និងភិក្ខុឆ្ពួតជាដើម ទាំងអម្បាលនេះ ជាអនាបត្តិ សូម្បីភិក្ខុជាអ្នកច្រើនកើ ច្រើនរើអាហារចេញមកដល់បំពង់ក ហើយត្រឡប់ចូលទៅវិញ ក៏មិន ត្រូវអាបត្តិ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកក្នុងខន្ធក: ជាអនាណត្តិក: មានអង្គ ៣ គឺ **វិកាលតា** វេលាវិកាល ១ **យាវកាលិកតា** របស់ធាន់ជាយាវកាលិក ១ **អជ្ឌោហារណំ** លេបចូលទៅ ១ ព្រម ដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចឯឡ្ក-លោមសិក្ខាបទ ដែលសម្តែងហើយក្នុងបឋមសហសេយ្យសិក្ខាបទ ។

វិកាលភោជនសិក្ខាបទ គម្រប់ ៧ ចប់

សន្និធិការកសិក្ខាបទ គម្រប់ ៨ សេចក្តីថា របស់ធាន់ដែលជាយាវកា-លិកណាមួយ ភិក្ខុទទួលប្រគេនទុកឲ្យកន្ធងមួយរាត្រី ឈ្មោះថា សន្និធិ ។ ទទួលរបស់សន្និធិនោះ ដើម្បីនឹងធាន់ ត្រូវទុក្ខដ ព្រោះទទួល ។ លេបចូលទៅត្រូវបាចិត្តិយគ្រប់ភារ:ដែលលេប ។ សូម្បីបើបាត្រលាងមិន ស្អាត លុះជូតដោយម្រាមដៃ ស្នាមនៅប្រាកដ ឬជ័របាយចូលទៅក្នុង មុខបន្សារបាត្រ ជ័របាយនោះ លុះយកបាត្រហាលក្នុងទីក្តៅ ឬទទួល បបរដែលក្តៅ ញើសហូរចេញមក សូម្បីភិក្ខុធាន់ក្នុងបាត្រដូច្នោះ

ក្នុងថ្ងៃព្រឹកឡើងទៀត ត្រូវបាចិត្តិយ ។ របស់ណាដែលកិក្ខុលះដល់សាមណេរដាច់មិនមានអាល័យ ហើយសាមណេរទុកដាក់ ភិក្ខុនោះបានរបស់នោះមកធាន់ក៏គួរ ។ ក្នុងអាមិសជាសន្និធិ ត្រូវតិកបាចិត្តិយ ។ ទទួលយាវកាលិកនិងយាមកាលិក ណាមួយដែលជាសន្និធិ ដើម្បីធាន់ក្តី ឬក្នុងអាមិស ដែលមិនជាសន្និធិ សម្គាល់ថាជាសន្និធិ ឬសង្ស័យក្តី ទាំងអម្បាលនេះ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាមិនជាសន្និធិ ជាអនាបត្តិ ទុកយាវកាលិក យាមកាលិក សត្តាហកាលិក មិនឲ្យកន្ធងកាល ភិក្ខុក៏ធាន់តាមកាល មួយទៀត សូម្បីកាលមានហេតុហើយធាន់យាវជីវិកក្តី និងភិក្ខុឆ្លួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មានអង្គ ៣ គឺ **អាមិសំ** អាមិសជាយាវកាលិក ១ **សន្និធិភាវោ** អាមិសនោះទទួលប្រគេនទុកទៅជាសន្និធិ ១ **តស្ស អជ្ឌោហារណំ** ធាន់របស់នោះចូលទៅ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចឯឡកលោមសិក្ខាបទ ដែលសម្តែងហើយក្នុងបឋមសហសេយ្យសិក្ខាបទ ។

សន្និធិការកសិក្ខាបទ គម្រប់ ៨ ចប់

បណីតភោជនសិក្ខាបទ គម្រប់ ៩ សេចក្តីថា បាយដែលកើតអំពីធញ្ញជាតិទាំង ៧ លាយដោយរបស់ឧត្តម ៩ ប្រការគឺ សប្បិ នវនីត

ប្រេង ទឹកឃ្មុំ ទឹកអំពៅ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ ណាមួយឈ្មោះថាបណីតភោជនៈ ។ ភិក្ខុណាមិនមានជំងឺ សូមបណីត-ភោជនៈ អំពីមនុស្សមិនមែនញាតិ មិនមែនបវារណា ដោយពាក្យជាដើមថា អ្នកចូរឲ្យបាយទាំងសប្ដិផង ឬថាអ្នកចូរឲ្យបាយទាំងត្រីផង ដូច្នេះត្រូវអាបត្តិទុក្កដ ព្រោះវិញ្ញត្តិមុនអំពីបានមក ។ ទទួលនឹងធាន់ ត្រូវទុក្កដព្រោះទទួល ។ លេបចូលទៅត្រូវបាចិត្តិយគ្រប់វារៈដែលលេប ។ សូមបានមកធាន់ទាំង ៥ ត្រូវបាចិត្តិយទាំង ៥ ។ ភិក្ខុណាមិនមានជំងឺ សូមសប្ដិ នវនីត ប្រេង ទឹកឃ្មុំ ទឹកអំពៅសុទ្ធ មិនលាយដោយបាយ ដើម្បីកេសជ្ជៈ គប្បីកាត់អាបត្តិបាចិត្តិយដល់ភិក្ខុនោះ ដោយមហានាម-សិក្ខាបទ ។ សូមត្រីជាដើម ៦ ប្រការសុទ្ធ មិនលាយ គប្បីកាត់អាបត្តិទុក្កដ ដោយសុបោទនវិញ្ញត្តិក្នុងសេខិយៈ ។ សូមភោជនលាយដោយសប្ដិ ជាដើម គប្បីកាត់បាចិត្តិយដោយសិក្ខាបទនេះ ។ សូមបាយនិងត្រីផង គេឲ្យបាយនិងសាច់ ខុសសង្កេត មិនត្រូវអាបត្តិ ដោយសិក្ខាបទនេះ ។ មិនមានជំងឺ ត្រូវតិកបាចិត្តិយ ។ មានជំងឺ សម្គាល់ថាមិនមានជំងឺ ឬសង្ស័យ សុំមកធាន់ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាមានជំងឺជាអនាបត្តិ សូមក្នុងសម័យដែលមានជំងឺជាហើយធាន់ ឬធាន់របស់សំណល់ភិក្ខុឈឺ ឬសូមអំពីមនុស្សជាញាតិ ជាបវារណា ឬសូមដើម្បីអ្នកដទៃ ឬដូរយកដោយ

ទ្រព្យរបស់ខ្លួន និងកិក្ខុឆ្ពួតជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មានអង្គ ៤ គឺ **បណីតភោជនតា** បណីតភោជន ១ **អកិលានតា** មិនមានជំងឺ ១ **ករតវិញ្ញត្តិយា បដិលាភោ** បានមកដោយវិញ្ញត្តិ ១ **អជ្ឌោហារណំ** ធាន់ចូលទៅ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ ជាអជ្ឌានសមុដ្ឋាន អាបត្តិកើតអំពីកាយ អំពីកាយវាចា អំពីកាយចិត្ត អំពីកាយវាចាចិត្ត ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តក: បណ្ណត្តិវជ្ជ: កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។

បណីតភោជនសិក្ខាបទ គម្រប់ ៩ ចប់

ទន្តបោណសិក្ខាបទ គម្រប់ ១០ សេចក្តីថា របស់នឹងគប្បីធាន់ទាំងពួងអនុបសម្បន្នមិនបាននៅក្នុងហត្ថបាស ហើយឲ្យដោយកាយ ឬរបស់ជាប់ដោយកាយ ឬបោះឲ្យដល់កិក្ខុដែលទទួលដោយកាយ ឬរបស់ជាប់ដោយកាយ របស់នោះឈ្មោះថា គេមិនបានប្រគេន ។ កិក្ខុណាកាន់យកឯងនូវរបស់ដែលមិនបានប្រគេនដូច្នោះ សូម្បីជារបស់ល្អិតដូចធូលីដើម្បីនឹងធាន់ត្រូវទុក្កដព្រោះទទួល ។ ធាន់ឲ្យកន្ទងបំពង់កចូលទៅដោយមុខទ្វារ ឬឃានទ្វារ ត្រូវបាចិត្តិយ រៀងតែទឹកនិងឈើស្ងួន ។ ទឹកមិនបាច់ប្រគេនធាន់បានតាមសប្បាយ ឈើស្ងួនមិនបាច់ប្រគេន ព្រោះជារបស់មិនកន្ទងបំពង់ក ថាបើកន្ទងបំពង់កចូលទៅ សូម្បីមិនដឹងក៏ត្រូវអាបត្តិ

បាចិត្តិយ ។ ក្នុងរបស់ដែលមិនបានទទួលប្រគេន ត្រូវតិកបាចិត្តិយ ។ ក្នុងរបស់ដែលទទួលប្រគេនហើយ សម្គាល់ថាមិនទាន់ទទួលប្រគេន ឬសង្ស័យ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាទទួលប្រគេនហើយឲ្យកន្ទុងបំពង់ក មិនត្រូវអាបត្តិ ។ ទឹកនិងឈើស្ងួនប្រើមិនឲ្យកន្ទុងបំពង់ក និងថ្នាំមហាវិកត: ៤ ប្រការគឺ មូត្រ លាមក ផេះ ដី កាលមានហេតុគឺពស់ចឹកកប្ប៊ិយការក:មិនមាន កាន់យកមកធាន់ខ្លួនឯងក្តី និងភិក្ខុឆ្លួតជាដើមទាំងអម្បាលនេះ មិនត្រូវអាបត្តិ សូម្បីកប្ប៊ិយការក:មាន តែជាមនុស្សប្រើលំបាក ឬមិនអាចនឹងធ្វើបាន ក៏ពាប់ចូលក្នុងចំណែកថាមិនមាន ។ កាលបើផេះមិនមាន ភិក្ខុនឹងដុតឈើស្ងួត ឬឈើស្ងួតមិនមាន សូម្បីនឹងកាប់កាច់ឈើស្រស់អំពីដើមឈើមកដុតធ្វើជាផេះក៏គួរ សូម្បីនឹងជីកផែនដីដោយត្រូវការដីក៏គួរ ក៏ឯថ្នាំមហាវិកត: ទាំង ៤ នេះឈ្មោះថា **ការ-ណោ**ឯ**ិ**ស្ស ចំពោះកាលពស់ចឹក ក្នុងខណ:ពស់ចឹកមួយយ៉ាងប៉ុណ្ណោះ នឹងកាន់យកដោយខ្លួនឯងក៏គួរ ក្នុងកាលដទៃគប្ប៊ីទទួលប្រគេនធាន់ ជាអនាណត្តិក: មិនត្រូវព្រោះបង្ហាប់ មានអង្គ ៤ គឺ **អ**ប្ប**ដិ**ក្ខ**ហិ**ត**ត**តា របស់មិនបានទទួលប្រគេន ១ **អ**ន**ុ**ញ្ញ**ាត**តា របស់នោះមិនមែនព្រះពុទ្ធអង្គអនុញ្ញាត ១ **ជ**ូ**ម**ាឯ**ិ**អ**ព្ភ**ោ**ហ**ារ**ិ**ត**ា**ភ**ាវ**ោ** របស់នោះមិនមែនជាអព្ភោហារិកដូចផ្សែងភ្ញើងជាដើម ១ **អ**ជ្ឈ**ោ**ហ**ារ**ណ**ំ**

លេបចូលទៅក្នុងបំពង់ក ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវអាបត្តិ
បាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចឯឡកលោមសិក្ខាបទ ដែលពោល
ហើយក្នុងបឋមសហសេយ្យ ។

ទន្តបោណសិក្ខាបទ គម្រប់ ១០ ចប់

ភោជនវគ្គ គម្រប់ ៤ ចប់

អចេលកវគ្គ គម្រប់ ៥ មាន ១០ សិក្ខាបទ ៖

អចេលកសិក្ខាបទ ជាបឋម សេចក្ដីថា ភិក្ខុឲ្យខាទនីយ:ឬភោជនី-
យាហារ ដែលជាអាមិសណាមួយដោយដៃខ្លួនឯង ដល់តិរ្ថិយទាំងឡាយ
មានអចេលក: អ្នកបួសអាក្រាតកាយ និងបរិព្វាជកនិងនាងបរិព្វាជិកា
ជាដើម ដែលជាអ្នកបួសក្រៅព្រះពុទ្ធសាសនា មិនមែនសហធម្មិកទាំង ៥
អ្នកទាំងអម្បាលនេះណាមួយ ត្រូវបាចិត្តិយ រាប់តាមប្រយោគដែលឲ្យ ។

អចេលកសិក្ខាបទ ជាបឋម ចប់

ឧយ្យោជនសិក្ខាបទ គម្រប់ ២ សេចក្ដីថា ភិក្ខុបបួលភិក្ខុផងគ្នាទៅ
បិណ្ឌបាត ក្នុងស្រុក និគម ហើយនិងឲ្យគេឲ្យអាមិសដល់ភិក្ខុនោះក្ដី
មិនឲ្យគេឲ្យក្ដី ភិក្ខុប្រាថ្នានឹងដំបូចសើចលេង ឬនឹងអង្គុយក្នុងទីកំបាំង
ជាមួយមាតុគ្រាម ឬនឹងប្រព្រឹត្តអនាចារណាមួយ ហើយ

បណ្តេញភិក្ខុនោះចេញត្រូវទុក្កដ ។ ភិក្ខុនោះកន្ទងឧបចារៈដោយជំហានជាបឋម អ្នកបណ្តេញត្រូវទុក្កដ ។ កន្ទងជំហានជាគម្រប់ ២ អ្នកបណ្តេញត្រូវបាចិត្តិយ ។ ក្នុងឱកាសទីវាល ប្រមាណទស្សនូបចារៈ ១២ ហត្ត សវនូបចារៈក៏ ១២ ហត្តដូចគ្នា ។ បើជញ្ជាំង ឬទ្វារ ឬកំផែង បាំង ការកន្ទងទីបាំង ដោយរបស់ទាំងអម្បាលនោះឯង ឈ្មោះថាកន្ទងឧបចារៈ ។ ក្នុងឧបសម្បន្ន ត្រូវតិកបាចិត្តិយ ។ ក្នុងអនុបសម្បន្ន ត្រូវតិកទុក្កដ ។ ពោលកលិសាសនៈ[1] ប្រាប់ដល់ឧបសម្បន្ន និងអនុបសម្បន្ន ទាំង-ពីរថា អ្នកទាំងឡាយមកមើលចុះ មនុស្សនេះឈរដូចដង្គត់ អង្គុយដូចផ្តែ និងក្រឡេកដូចពានរ ដូច្នេះ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺបណ្តេញឲ្យទៅដោយហេតុដ៏សមគួរជាដើមថា ពីរអង្គនៅក្នុងតំបន់ជាមួយគ្នា នឹងមិនលួមចិញ្ចឹមជីវិត ឬឃើញរបស់ល្អមានតម្លៃ ឬឃើញស្ត្រីនឹងកើតលោភចេតនា និងសេចក្តីអផ្សុក ឬឲ្យយករបស់ទៅឲ្យមនុស្សមានជំងឺជាដើម ឬមិនប្រាថ្នាប្រព្រឹត្តអនាចារ បញ្ជូនត្រឡប់ទៅដោយកិច្ច និងភិក្ខុឆ្ពួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ជាសាណត្តិកៈ ត្រូវព្រោះបង្ហាប់ គឺបណ្តេញដោយខ្លួនឯង ឬឲ្យអ្នកដទៃបណ្តេញ មានអង្គ ៣ គឺ **អនាចារំ អាចរិតុកាមតា** *ប្រាថ្នានឹងប្រព្រឹត្តអនាចារ ១* **តទត្ថមេវ ឧបសម្បន្នស្ស**

---

[1] ពាក្យបញ្ឈឺចិត្ត ។

ឧយ្យោជនតា *បណ្តេញឧបសម្បន្ន ដើម្បីប្រយោជន៍នោះ ១* **ឯវं ឧយ្យោជេន្តស្ស ឧបចារាតិក្កមោ** *អ្នកត្រូវបណ្តេញកន្ទ្ធ ឧបចារ: ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ។*

ឧយ្យោជនសិក្ខាបទ គម្រប់ ២ ចប់

សភោជនសិក្ខាបទ គម្រប់ ៣ សេចក្តីថា ក្នុងត្រកូលណា ប្តីប្រពន្ធ មិនមែនព្រះអនាគামី ជាអ្នកនឿយណាយចាកសេចក្តីតម្រេកត្រេកអរ ហើយចូលទៅនៅក្នុងផ្ទះជាទីដំណេក ដែលគេមិនទាន់ចេញមកក្រៅ បើផ្ទះធំ ភិក្ខុកន្ទ្ធ១ហត្ថបាសមេទ្វារផ្ទះចូលទៅ បើផ្ទះតូច ភិក្ខុកន្ទ្ធ១ពាក់កណ្តាលផ្ទះចូលទៅ អង្គុយក្នុងទីជិតនៃដំណេក មិនមានភិក្ខុដទៃជាគម្រប់ពីរផង ត្រូវបាចិត្តិយ ។

សភោជនសិក្ខាបទ គម្រប់ ៣ ចប់

បឋមរហោនិសជ្ជសិក្ខាបទ គម្រប់ ៤ សេចក្តីថា ភិក្ខុណាអង្គុយ ឬដេក ក្នុងទីដែលបាំងដោយគ្រឿងបាំង កំបាំងភ្នែកជាមួយនឹងមាតុគ្រាម សូម្បីកើតក្នុងថ្ងៃនោះ ត្រូវបាចិត្តិយ ។

បឋមរហោនិសជ្ជសិក្ខាបទ គម្រប់ ៤ ចប់

ទុតិយរហោនិសជ្ជសិក្ខាបទ គម្រប់ ៥ សេចក្តីថា ភិក្ខុណា តែម្នាក់ឯង អង្គុយ ឬដេកក្នុងទីវាល កំបាំងត្រចៀក ជាមួយនឹងមាតុគ្រាមដែលដឹងសេចក្តី ត្រូវបាចិត្តិយ ។

សមុដ្ឋានវិធីជាដើម នៃសិក្ខាបទទាំង ២ នេះ ដូចបឋមបារាជិកសេចក្តីក្រៅនោះ គប្បីដឹងដោយន័យដែលបានសម្តែងហើយក្នុងអនិយតទាំងពីរ ។

ទុតិយរហោនិសជ្ជសិក្ខាបទ គម្រប់ ៥ ចប់

ចារិត្តសិក្ខាបទ គម្រប់ ៦ សេចក្តីថា ភិក្ខុណា ដែលទាយកគេនិមន្ត ដោយភោជនទាំង ៥ ប្រការ ភោជនណាមួយហើយ ភិក្ខុធាន់ភោជនដែលគេនិមន្តនោះហើយ ឬនៅមិនបានធាន់ក្តី មិនលាភិក្ខុដែលមាននៅ ហើយទៅកាន់ត្រកូលដទៃចាកត្រកូលអ្នកនិមន្តនោះ តាំងអំពីវេលាព្រឹក រហូតដល់ថ្ងៃត្រង់ ។ កាលចុះកាន់ឧបចារៈផ្ទះនៃត្រកូលដទៃនោះ ត្រូវទុក្កដ ។ ឈានកន្ទ្រង់ធរណីទ្វារផ្ទះដោយបាទាជាបឋម ត្រូវទុក្កដទៀត ។ ឈានកន្ទ្រង់ដោយជំហានគម្រប់ ២ ត្រូវបាចិត្តិយ រៀរតែមានចីវរទានសម័យ គឺសម័យគេឲ្យចីវរ និងចីវរកាលសម័យ សម័យធ្វើចីវរ ដូចពោលហើយក្នុងគណភោជនសិក្ខាបទ ។ ភិក្ខុណា នៅក្នុងទស្សនូបចារៈក្នុងខាងក្នុងឧបចារៈសីមា ល្មមនឹងប្រាប់បានដោយពាក្យប្រក្រតី ភិក្ខុនោះ

ឈ្មោះថាមាននៅ ផុតហួសអំពីនោះទៅឈ្មោះថាមិនមាន ។ ក្នុងភិក្ខុ ដែលគេនិមន្តហើយ ត្រូវតិកបាចិត្តិយ ។ គេមិនបាននិមន្ត សម្គាល់ថា គេនិមន្ត ឬសង្ស័យ ហើយទៅ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះគឺ ដឹងថាគេមិនបាននិមន្ត មិនត្រូវ អាបត្តិ ឬមានសម័យទាំងពីរ ឬលាភិក្ខុដែលមាននៅ ថាយើងនឹងទៅ ផ្ទះមនុស្សនោះ ហើយទៅ ឬភិក្ខុមិនមាន មិនលាហើយទៅ ឬផ្លូវក្បែរ ផ្ទះនិងឧបចារៈផ្ទះរបស់អ្នកដទៃ ដើរទៅតាមផ្លូវនោះ ឬទៅកាន់អាវាម នៅក្នុងចន្ទោះស្រុក ទៅកាន់ទីលំនៅនាងភិក្ខុនី ទៅកាន់ទីលំនៅតិរ្ថិយ ទៅពោងធាន់ ទៅផ្ទះដែលគេនិមន្ត ឬទៅផ្ទះអ្នកឲ្យសលាកកត្តជាដើម និងទៅព្រោះមានអន្តរាយ និងភិក្ខុឆ្ពួតជាដើម ទាំងអម្បាលនេះ មិនត្រូវ អាបត្តិ ។ ជាអនាណត្តិកៈ មិនត្រូវព្រោះបង្ហាប់ ។ មានអង្គ ៥ គឺ **បញ្ចន្នំ ភោជនានំ អញ្ញតរេន និមន្តនសាឋិយនំ** ត្រេកអរនឹងសេចក្តី និមន្តដោយភោជនទាំង ៥ ណាមួយ ១ **សន្តំ ភិក្ខុំ អនា-បុច្ឆនា** មិនប្រាប់ លាដល់ភិក្ខុដែលមាននៅ ១ **ភត្តិយឃរតោ អញ្ញស្ស ឃរស្ស បវេសនំ** ទៅកាន់ផ្ទះដទៃចាកផ្ទះអ្នកនិមន្ត ១ **មជ្ឈន្ហិកានតិក្កមោ** មិនទាន់កន្ទងវេលាថ្ងៃត្រង់ទៅ ១ **សម-យស្ស វ អាបទានំ វ អភាវោ** មិនមានសម័យឬអន្តរាយ ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋម-

កឋិនសិក្ខាបទ ប្លែកតែសិក្ខាបទនេះជាកិរិយាកិរិយៈ ត្រូវព្រោះធ្វើ និងមិនធ្វើ គឺភិក្ខុធ្វើ នូវការទទួលនិមន្តន៍ដោយភោជន និងមិនធ្វើនូវការ លាភិក្ខុដែលមាននៅហើយទៅ ។

ចារិត្តសិក្ខាបទ គម្រប់ ៦ ចប់

មហានាមសិក្ខាបទ គម្រប់ ៧ សេចក្តីថា បើទាយកបវារណាដោយ បច្ច័យគឺ ថ្នាំមានសប្បាយជាដើម រវាង ៤ ខែ ឬបវារណាថែមថ្មីទៀត ឬ បវារណាជានិច្ចក្តី ភិក្ខុមិនមានជំងឺកុំគប្បីឃាត់ឡើយ គប្បីត្រេកអរទទួល ចុះ បើគេបវារណាកំណត់ដោយរាត្រី ឬកំណត់ដោយថ្នាំទុកដរាបណា គប្បីសូមគេតាមកំណត់ដរាបនោះ បើភិក្ខុសូមគេឲ្យលើសកំណត់រាត្រី នឹងថ្នាំដែលគេកំណត់ទុកនោះ និងកិច្ចដែលត្រូវការដោយថ្នាំមិនមាន សូមថ្នាំមកក្តី ឬសូមថ្នាំដទៃចាកថ្នាំដែលត្រូវការក្តី ត្រូវបាចិត្តិយ ។ ក្នុងកិរិយាដែលសូមលើសជាងកំណត់ ត្រូវតិកបាចិត្តិយ ។ មិនលើស កំណត់ សម្គាល់ថាលើសកំណត់ ឬសង្ស័យ ហើយសូមត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថានៅមិនទាន់លើសកំណត់ សូមមិនត្រូវអាបត្តិ កាលបើមានសេចក្តីត្រូវការ ប្រាប់គេតាមពិតហើយ សូម មិនឲ្យលើសកំណត់ថ្នាំ កំណត់រាត្រីទៅ ឬសូមអំពីញាតិ និងមនុស្ស បវារណាដោយបវារណាជាបុគ្គល និងបវារណាមិនមានទីបំផុត ឬសូម ដើម្បីអ្នកដទៃ ឬផ្ទាស់ប្តូរយកដោយទ្រព្យរបស់ខ្លួន និងភិក្ខុធ្លួតជាដើម

ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មិនត្រូវព្រោះបង្ហាប់ ។ មានអង្គ ៤ គឺ **សង្ឆ្យុ្ជ្ជ្ជ

ណាមួយ ត្រូវទុក្កដ ដោយន័យដូចពោលហើយ ។ មិនមែនកងនេសនា-ព្យូហ: លើកទ័ព សម្គាល់ថាកងនេសនាលើកទ័ព ឬសង្ស័យ ទៅមើល ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះគឺ ដឹងថាមិនមែនកងនេសនាព្យូហ:លើកទ័ព ទៅមើលមិនត្រូវអាបត្តិ ឬឈរក្នុងអាវាសហើយឃើញ ឬឃើញគេលើកមកកាន់ទីលំនៅនៃខ្លួន ឬដើរស្ងួនផ្លូវទៅប្រទះ ឬមានហេតុ មានអន្តរាយ និងភិក្ខុឆ្លួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនា-ណត្តិក: មិនត្រូវព្រោះបង្ការ ។ មានអង្គ ៤ គឺ **ឧយ្យុត្តសេនា** កងនេ-ចតុរង្គិនីសេនាលើកទ័ពចេញ ១ **ឧស្សេនត្ថាយ គមនំ** ទៅដើម្បីនឹងមើល ១ **អនុញ្ញាតោ កាសតោ អញ្ញត្រ ឧស្សេនំ** មើលក្នុងទីដទៃ ក្រៅចាកឱកាសដែលព្រះពុទ្ធអង្គទ្រង់អនុញ្ញាត ១ **តថារូបប្ប-ច្ចយេ ឋ អាបជ្ជាយ ឋ អភាវេ** មិនមានហេតុដ៏សមគួរ ឬអន្តរាយ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋាន-វិធីជាដើម ដូចឯឡកលោមសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាលោកវជ្ជ: មានទោសតាមធម្មតាលោក ជាអកុសលចិត្ត មានវេទនា ៣ ។

ឧយ្យុត្តសិក្ខាបទ គម្រប់ ៨ ចប់

សេនាវាសសិក្ខាបទ គម្រប់ ៩ សេចក្ដីថា ហេតុណាមួយដែលនឹងគប្ប៊ីទៅកាន់កងទ័ព បើមានឡើងដល់ភិក្ខុ ភិក្ខុនោះគប្ប៊ីនៅក្នុងកងទ័ពបាន

ត្រឹមពីរបីរាត្រី បើកិក្ខុណានៅក្នុងកងទ័ពលើស ៣ រាត្រីឡើងទៅ ក្នុងថ្ងៃគម្រប់ ៤ ព្រះអាទិត្យអស្តង្គតហើយ កិក្ខុឈរ ឬអង្គុយ ឬដេកនៅក្នុងកងទ័ពក្តី ឬនឹងហោះទៅលើអាកាសក្តី គង់ត្រូវបាចិត្តិយាបត្តិ ។

សេនាវាសសិក្ខាបទ គម្រប់ ៩ ចប់

ឧយ្យោធិកសិក្ខាបទ គម្រប់ ១០ សេចក្តីថា កិក្ខុកាលទៅនៅក្នុងកងទ័ពពីរបីរាត្រី ដោយហេតុដ៏សមគួរ បើត្រាច់ទៅមើលទីដែលគេចម្បាំងគ្នា ឬកាន់ទីត្រួតពល ឬទីចាត់ពល ឬទៅមើលកងដំរី កងសេះ កងរថ កងថ្មើរជើង ត្រូវអាបត្តិទុក្កដ គ្រប់ៗ បទវារៈ ។ ឈរក្នុងទស្សនូបចារៈ មើលឃើញត្រូវបាចិត្តិយ ។ ដំរីពី ៣ ឡើងទៅឈ្មោះថា ហត្ថានិកៈ កងដំរី, សេះពី ៣ ឡើងទៅឈ្មោះថា អស្សានិកៈ កងសេះ, រថពី ៣ ឡើងទៅឈ្មោះថា រថានិកៈ កងរថ, ទាំង ៣ នេះ មានមនុស្សសម្រាប់ដួចពោលហើយគ្រប់ៗ កង កងថ្មើរជើង តាំងពី ៤ នាក់ឡើងទៅ មានអាវុធក្នុងដៃ ឈ្មោះថា បត្តានិកៈ កងថ្មើរជើង ។

ឧយ្យោធិកសិក្ខាបទ គម្រប់ ១០ ចប់

អចេលកវគ្គ គម្រប់ ៥ ចប់

សុរាបានវគ្គ គម្រប់ ៦ មាន ១០ សិក្ខាបទ ៖

សុរាបានសិក្ខាបទ ជាបឋម សេចក្ដីថា ទឹកស្រវឹងដែលគេធ្វើដោយសម្ភារៈមានម្សៅជាដើម ឈ្មោះថាសុរា ។ ទឹកតម្រាំដែលគេធ្វើដោយផ្លាឈើជាដើម ឈ្មោះថាមេរ័យ ។ វត្ថុទាំងពីរនេះតាំងអំពីពូជទៅ ភិក្ខុផឹកសូម្បីដោយចុងស្លាវ ត្រូវបាចិត្តិយគ្រប់ៗ ប្រយោគ ។ ក្នុងទឹកស្រវឹងត្រូវតិកបាចិត្តិយ ។ មិនមែនទឹកស្រវឹងសម្គាល់ថាទឹកស្រវឹង ឬសង្ស័យហើយផឹក ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាមិនមែនទឹកស្រវឹង ផឹកមិនត្រូវអាបត្តិ ផឹកថ្នាំឈ្មោះលោណសោចិរកៈ និងថ្នាំសុរត្តៈ ដែលមិនមែនជាគ្រឿងស្រវឹង តែមានពណ៌និងក្លិនរសដូចទឹកស្រវឹង ឬសម្ងួតប្រេងកន្ទួតព្រៃ និងស្ករដែលគេដាក់ទឹកស្រវឹងបន្ដិចចុះ ដើម្បីនឹងកាត់ក្លិនធ្ពាបនិងអប់ក្លិន ដើម្បីឲ្យខ្លាំងក្ដី ក្លិនពណ៌រសមិនប្រាកដ ឬផឹកថ្នាំអរិដ្ឋៈដែលគេធ្វើដោយរសកន្ទួតព្រៃជាដើម មិនស្រវឹងតែដូចទឹកស្រវឹងក្ដី និងភិក្ខុឆ្ពួតជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មិនត្រូវព្រោះបង្ហាប់ ។ មានអង្គ ២ គឺ **មជ្ជភាវោ ច** *ទឹកស្រវឹង ១* **តស្ស ចានំ** *ផឹកទឹកស្រវឹងនោះ ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចឯឡកលោមសិក្ខាបទ ប្ដូកតែសិក្ខាបទនេះ ជាលោកវជ្ជៈ មានទោសតាមធម្មតាលោក ជាអកុសលចិត្ត មានវេទនា ៣ ។*

សុរាបានសិក្ខាបទ ជាបឋម ចប់

អង្គុលិបតោទកសិក្ខាបទ គម្រប់ ២ *សេចក្ដីថា* ភិក្ខុ*ប្រាថ្នានឹងដំបូចសើចលេង ហើយចាក់ប្រឡែងឧបសម្បន្ន ត្រង់អវយវ:ណាមួយ* មាន*ក្ងៀកជាដើម ដោយម្រាមដៃ ឬអវយវ:ណាមួយរបស់ខ្លួន ត្រូវ*បាចិ*ត្តិ*យ ។ *ក្នុងឧបសម្បន្ន ត្រូវ*តិ*ក*បាចិ*ត្តិ*យ ។ *ក្នុងអនុបសម្បន្ន ត្រូវ*តិ*ក*ទុ*ក្ក*ដ ។ *ក្នុងសិក្ខាបទនេះ សូ*ម្បីនាងភិ*ក្ខុ*នី*ឈ្មោះ*ថា*អនុ*ប*ម*ម្ប*ន្ន*នៃ*ភិ*ក្ខុ* ភិ*ក្ខុ*ឈ្មោះ*ថា*អនុ*ប*ម*ម្ប*ន្ន*នៃ*នាងភិ*ក្ខុ*នី ។ *ការ*ចាក់ប្រ*ឡែ*ងដោ*យ* រ*ប*ស*ដ*ែ*ល*ជាប់ដោ*យ*កា*យ ឬ*ចោ*ល*ទ*ៅ*ឲ* យ*ត្រ*ូ*វ*ខ*ាងម្ខ*ាង ឬ*ទ*ាំ*ងស*ងខ*ាង ត្រ*ូ* វ*ទ*ុ*ក*្ក*ដ* *ទ*ាំ*ងអ*ស* ។

ឯិ*ធ*ីដ*ែ*ល*ម*ិ*ន*ត*្រ*ូ*ว*អ*ាប*ត*្ត*ិ*ន*ោ*ះ* *គ*ឺ*ម*ិ*ន*ប*្រ*ាថ*្ន*ានឹ*ង*ដ*ំ*ប*ូ*ច*ស*ើ*ច*ល*េ*ង*ហ*ើ*យ* *ព*ាល*់*ត*្ត*ូ*ว* ឬ*ម*ាន*ก*ิ*ច*ត*្ត*ូ*ว*ច*ាប*់*ព*ាល*់*អ*្ន*ก*ដ*ទ*ៃ* *ន*ិ*ង*ภ*ิ*ก*ុ*ធ*្ម*ត*ជ*ា*ដ*ើ*ม* *ទ*ាំ*ง* *អ*ម*្ព*ាล*ន*េ*ះ* *ม*ิ*ន*ต*ร*ู*ว*អ*ាป*ต*ิ* ។ *ជ*ា*ม*ิ*น*ว*ณ*ิ*ก*: *ม*ิ*ន*ต*ร*ู*ว*ព*្រ*ោ*ะ*ป*ห*ារ*ป*ห*ារ* ។ *ม*ี*น*อ*ง*ค*์* ๒ *ค*ื **ห*ส*ฺ*ฐ*ิ*ป*ฺ*ป*ว*ย*ต*า** *ป*ំ*ณ*ង*ន*ឹ*ง*ส*ើ*ច*ล*េ*ง* ๑ **ข*ป*ส*ม*ฺ*ป*ท*ฺ*ส*ฺ*ส ก*า*ย*ะ ก*า*ย*ม*ส*ํ** *ព*ាล*់*ต*ร*ู*ว*ก*ា*យ *ข*ป*ส*ม*ฺ*ป*ท*ฺ*ธ*ដោ*យ*ก*ា*យ*ร*ប*ស*ខ*ួ*ន ๑ *ព*្រ*ម*ដោ*យ*អ*ង*្ค ๒ *ន*េ*ះ* *ទ*ើ*ป*ต*ร*ู*ว* *ป*า*จ*ิ*ต*ฺ*ต*ิ*ย* ។ *ส*ม*ุ*ฏ*ฐ*า*น*ว*ิ*ธ*ីជ*ា*ដ*ើ*ม* *ด*ู*จ*ป*ป*ม*ป*า*ร*ช*ิ*ก* ។

*អ*ង*ฺ*ค*ุ*ล*ิ*ป*ต*ោ*ท*ก*ส*ิ*ก*ฺ*ข*า*ป*ท* *ค*ម្ម*ป*់ ๒ *ช*ប*ป*

*ห*ส*ฺ*ส*ธ*ม*ฺ*ม*ส*ิ*ก*ฺ*ข*า*ป*ท* *ค*ម្ម*ป*់ ๓ *ส*េ*จ*ก*ฺ*ต*ี*ថ*า *ภ*ิ*ก*ุ*ป*្រ*ាថ*្ន*ានឹ*ง*ล*េ*ง*ទ*ឹ*ก* *ก*ុ*ง*ទ*ឹ*ก*ជ*ម*្រ*ៅ*ត*ាំ*ง*ព*ីត*្រ*ឹ*ม*ក*ែ*ក*ค*ោ*ร*ឡ*ើ*ง*ទ*ៅ* *ห*ើ*យ*ច*ុ*ះ*ទ*ៅ*ដ*ើ*ម*្ប*ីនឹ*ง*ล*េ*ง*ទ*ឹ*ก*

ត្រូវទុក្កដគ្រប់ៗ ជំហាន ។ មុជចុះក្តី ងើបឡើងក្តី ត្រូវបាចិត្តិយគ្រប់ប្រ-យោគ ។ ហែលទៅក្នុងទឹកត្រូវបាចិត្តិយគ្រប់រាវ:ដៃ រាវ:ជើង ។ បើហែលទៅលើទឹកដោយអវយវ:ណាមួយ ត្រូវបាចិត្តិយគ្រប់ៗ ប្រយោគនៃអវយវ:នោះ ។ ក្នុងការលេងសប្បាយក្នុងទឹកលិចភ្នែកគោរ ត្រូវតិក-បាចិត្តិយ ។ មិនមែនការលេងសប្បាយក្នុងទឹក សម្គាល់ថាលេង ឬសង្ស័យ ត្រូវទុក្កដ ។ ភិក្ខុលេងទឹករាក់ជាងភ្នែកគោរ ឬលេងដោយទូក ឬខ្ជប់ទឹកលេងដោយដៃ ដោយជើង ដោយឈើ ដោយអំបែង ឬលេងទឹកនៅក្នុងភាជន:មានទឹកជ្រក់ជាដើម និងកក់ និងបាចសាចលេងក្តី ត្រូវទុក្កដទាំងអស់ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសរសេរអក្សរពន្យល់សេចក្តីគួរ មិនប្រាថ្នានឹងលេង ចុះងូតទឹកដោយប្រក្រតី ឬចុះមុជទឹកជាដើមដោយកិច្ច ឬហែលឆ្លងទៅកាន់ត្រើយ ឬមានអន្តរាយ និងភិក្ខុធ្លាតជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មិនត្រូវព្រោះបង្ហាប់ ។ មានអង្គ ២ គឺ **ឧបរិតោបួកតា** ទឹកជ្រៅលិចភ្នែកគោរ ១ **ហាសាធិប្បាយេន** **កីឬ**ំ ចុះលេងដោយប្រាថ្នានឹងលេងសប្បាយ ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋមបារាជិក ។

ហាស្យធម្មសិក្ខាបទ គម្រប់ ៣ ចប់

អនាទរិយសិក្ខាបទ គម្រប់ ៤ សេចក្តីថា ភិក្ខុណា ដែលឧបសម្បន្នគឺ ភិក្ខុផងគ្នាដាស់តឿន ស្តីប្រដៅ ណែនាំ ហាមប្រាម ដោយសិក្ខាបទដែល ព្រះពុទ្ធអង្គបញ្ញត្ត មិនអើពើចំពោះបុគ្គលនោះ ឬចំពោះធម៌ត្រូវបាចិត្តិយ ។ គិតថាអ្នកនេះជាមនុស្សដែលអ្នកដទៃ គេលើកទោសចំអកចំអន់តិះដៀល ពាក្យរបស់អ្នកនេះយើងនឹងមិនធ្វើតាម ហើយធ្វើសេចក្តីមិនអើពើដូច្នេះ ឈ្មោះថាមិនអើពើចំពោះបុគ្គល ។ គិតថាដូចម្តេច ធម៌ខ្លះនឹងគប្បី វិនាសទៅក្តី ឬមិនចង់សិក្សាធម៌ដូច្នេះក្តី ហើយធ្វើសេចក្តីមិនអើពើដូច្នេះ ឈ្មោះថាមិនអើពើចំពោះធម៌ ។ ក្នុងឧបសម្បន្នត្រូវតិកបាចិត្តិយ ។ ក្នុង អនុបសម្បន្ន ត្រូវតិកទុក្កដ ។ ឧបសម្បន្ន ឬអនុបសម្បន្ន ពោលដាស់ តឿនដោយធម៌ដទៃ មិនមែនសិក្ខាបទបញ្ញត្តិជាដើមថា វត្ថុនេះមិនប្រព្រឹត្ត ទៅដើម្បីសល្ងេខ: គឺកោសរួសកិលេសដូច្នេះ មិនអើពើ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុណា បានរៀនឧគ្គហ:ដែលមាន មកតាមប្រវេណី និងពោលតបថា ឧគ្គហ:និងបរិបុច្ឆា ការសូត្ររៀន បាលីនិងអដ្ឋកថា នៃអាចារ្យរបស់យើងយ៉ាងនេះក្តី និងភិក្ខុធ្ពតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មិនត្រូវព្រោះបង្ខាប់ ។ មានអង្គ ២ គឺ **ឧបសម្បន្នស្ស** **បញ្ញត្តេន** **វចនំ** ឧបសម្បន្ន ពោលដាស់តឿនដោយវិនយបញ្ញត្តិ ១ **អនាទរិយការណំ** ធ្វើសេចក្តី

មិនអើពើ ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះជាទុក្ខវេទនា ។

អនាទរិយសិក្ខាបទ គម្រប់ ៤ ចប់

ភ័ណ្ឌបនសិក្ខាបទ គម្រប់ ៥ សេចក្ដីថា ភិក្ខុលងបន្ទាចភិក្ខុដទៃផងគ្នា ឬនាំយករូបសំឡេងកិនរសផោដ្ឋព្វារម្មណ៍ ណាមួយចូលទៅ ឬពោលពាក្យលេងដែលគួរខ្ជាចជាដើមថា ទីនេះចោរកាច ខ្ជាកាច ដូច្នេះ ដើម្បីនឹងឲ្យខ្ជាច ភិក្ខុនោះខ្ជាចក្ដី មិនខ្ជាចក្ដី អ្នកលេងបន្ទាចត្រូវបាចិត្តិយ ។ ក្នុងឧបសម្បន្ន ត្រូវតិកបាចិត្តិយ ។ ក្នុងអនុបសម្បន្ន ត្រូវតិកទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺ មិនគិតនឹងលងបន្ទាចឲ្យខ្ជាច នាំយករូបជាដើមចូលទៅ ឬប្រាប់ទីដាច់ស្រយាលដោយចោរជាដើម និងភិក្ខុឆ្ពួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មិនត្រូវព្រោះបង្ហាប់ ។ មានអង្គ ២ គឺ **ឧបសម្បន្នតា** *អ្នកនោះជាឧបសម្បន្ន ១* **តស្ស ឧស្សុនស្សវនវិសយេ ភ័ណ្ឌបេតុកាមតាយ វាយមនំ** *ព្យាយាមដោយប្រាថ្នានឹងឲ្យឧបសម្បន្ននោះខ្ជាចក្នុងវិស័យដែលគេបានឃើញនិងបានឮ ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចសិក្ខាបទជាលំដាប់មក ។*

ភ័ណ្ឌបនសិក្ខាបទ គម្រប់ ៥ ចប់

ជោតិសមាទហនសិក្ខាបទ គម្រប់ ៦ សេចក្ដីថា ភិក្ខុណាមិនមានជំងឺប្រាថ្នាចង់អាំងភ្លើង បង្ហាត់ខ្លួនឯង តាំងអំពីតាក់តែងរកឈើពំនួតអណ្ដាតភ្លើង មិនទាន់ឆេះឡើងដរាបណា ក្នុងប្រយោគទាំងអស់ត្រូវទុក្កដដរាបនោះ ។ អណ្ដាតភ្លើងឆេះឡើង ត្រូវបាចិត្តិយ ។ ប្រើអ្នកដទៃបង្ហាត់ ត្រូវទុក្កដដោយបង្ហាប់ បង្ហាប់តែម្ដងសូម្បីតែបង្ហាត់ឲ្យឆេះច្រើនឡើង ត្រូវបាចិត្តិយតែមួយប៉ុណ្ណោះ រៀងតែមានហេតុដ៏សមគួរ គឺអុជប្រទីបឬបង្ហាត់ដុតបាត្រជាដើម មិនត្រូវអាបត្តិ ។ ភិក្ខុណាមានជំងឺ រៀងភ្លើងចេញមិនសប្បាយ ឈ្មោះថាមានជំងឺ តែរងាតាមរដូវនឹងឈ្មោះថាមានជំងឺមិនបាន ។ ក្នុងភិក្ខុមិនមានជំងឺ ត្រូវតិកបាចិត្តិយ ។ មានជំងឺសម្គាល់ថាមិនមានជំងឺ ឬសង្ស័យហើយបង្ហាត់ភ្លើងអាំង ត្រូវទុក្កដ ។ អង្គត់ភ្លើងធ្លាក់ចុះហើយលើកផ្ទុំឡើងវិញ ត្រូវទុក្កដ ។ បើអង្គត់ភ្លើងនោះរលត់ទៅ ហើយបង្ហាត់ឲ្យឆេះឡើង គង់ត្រូវបាចិត្តិយ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាមានជំងឺ បង្ហាត់ភ្លើងអាំង មិនត្រូវអាបត្តិ អាំងភ្លើងដែលអ្នកដទៃបង្ហាត់ ភ្លើងធ្យូងមិនមានអណ្ដាត និងបង្ហាត់ព្រោះហេតុដ៏សមគួរ ឬមានអន្ដរាយ និងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាសាណត្តិក: ត្រូវព្រោះបង្ហាប់ ។ មានអង្គ ៤ គឺ **អតិលាឧតា** មិនមានជំងឺ ១ **អនុញ្ញាតការណាការោ** មិនមានហេតុដែលព្រះពុទ្ធអង្គអនុញ្ញាត ១ **វិសេឞេតុកាមតា** ប្រាថ្នា

នឹងអាំង ១ **សមាឧហានំ** បង្ការ៉ាត់ឯងឬប្រើអ្នកដទៃឲ្យបង្ការ៉ាត់ឆេះឡើង ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម គប្បីដឹងដោយន័យដូចពោលហើយក្នុងសញ្ចរិត្តសិក្ខាបទ ។

ជោតិសមាទហានសិក្ខាបទ គម្រប់ ៦ ចប់

នហានសិក្ខាបទ គម្រប់ ៧ សេចក្ដីថា ភិក្ខុណា នៅក្នុងមជ្ឈិមប្រទេស រាប់អំពីថ្ងៃងូតទឹកមុនមក មិនទាន់គ្រប់កន្ទះខែ ភិក្ខុគិតនឹងងូតទឹក តាក់តែងចុណ្ណ:គឺលម្អិត ឬដី តាំងអំពីកាលតាក់តែងនោះមក ក្នុងប្រយោគទាំងអស់ត្រូវទុក្កដ ។ ងូតស្រេចហើយត្រូវបាចិត្តិយ រៀងតែមានសម័យទាំងអម្បាលនេះ ណាមួយ មិនត្រូវអាបត្តិ គឺចុងរដូវក្តៅ មួយខែកន្ទះ ឈ្មោះថា ឧណ្ហសមយ: គឺសម័យក្តៅ, ដើមរដូវភ្លៀងមួយខែ ឈ្មោះថា បរិឡាហសមយ: សម័យក្រវល់ក្រវាយ, មានជំងឺ មិនបានងូតទឹក មិនសប្បាយ ឈ្មោះថា គិលានសម័យ, ធ្វើការងារដោយហោចទៅ សូម្បីបោសច្រាសបរិវេណ ឈ្មោះថា កម្មសម័យ, សម័យដើរផ្លូវ ប្រមាណកន្ទះយោជន៍ ឬកំពុងតែដើរទៅ ឬមកដល់ហើយ ឈ្មោះថា អទ្ធានគមនសមយ: សម័យដើរផ្លូវឆ្ងាយ, ខ្យល់បក់ធូលីជាប់ខ្ជួន និងភ្លៀង ២ គ្រាប់ ឬ ៣ គ្រាប់ធ្លាក់ត្រូវខ្ជួន ឈ្មោះថា វាតវុដ្ឋិសមយ: សម័យ

ភ្ជៀងខ្យល់ ។ សិក្ខាបទនេះ ជាបទេសបញ្ញត្តិ បញ្ញត្តចំពោះតែភិក្ខុក្នុងមជ្ឈិមប្រទេស ឯបច្ចន្តប្រទេស ងូតទឹកបានជានិច្ច មិនត្រូវអាបត្តិ ។

នហានសិក្ខាបទ គម្រប់ ៧ ចប់

ទុតិ្ជ្ជ្ជ

សំពត់បន្ទាប ដេរភ្ជាប់ចូលជាមួយនឹងសំពត់ដែលធ្វើកប្បពិន្ទុហើយពេលក្រោយ បរិភោគប្រើប្រាស់ចីវរទាំងអម្បាលនេះក្តី និងភិក្ខុឆ្លួតជាដើម មិនត្រូវអាបត្តិ ។ ជាអនាណត្តិក:មិនត្រូវព្រោះបង្ហាប់ ។ មានអង្គ ៣ គឺ **រុត្តប្ប-ការេ ចីវរេ អកតកប្ប** *ចីវរដូចពោលមកហើយមិនបានធ្វើកប្បពិន្ទុ ១* **ន ជ្ជ ចីវរ** *មិនមែនភិក្ខុមានចីវរបាត់ជាដើម ១* ** និវាសនំ វ ចារុបនំ ** *ស្បៃកឬដណ្តប់ចីវរនោះ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចឯឡកលោម-សិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាកិរិយាកិរិយ: ត្រូវព្រោះធ្វើ និងមិនធ្វើ គឺភិក្ខុធ្វើនូវការស្បៃកដណ្តប់ និងមិនធ្វើនូវកប្បពិន្ទុជាមុន ។*

ទុព្ធណ្ណករណសិក្ខាបទ គម្រប់ ៨ ចប់

វិកប្បនសិក្ខាបទ គម្រប់ ៩ សេចក្តីថា ភិក្ខុវិកប្បចីវរទុកដល់សហ-ធម្មិកទាំង ៥ គឺភិក្ខុ ភិក្ខុនី នាងសិក្ខមានា សាមណេរ សាមណេរីណាមួយ ហើយបរិភោគស្បៃកដណ្តប់ចីវរ ដែលមិនទាន់បានដកវិកប្បនោះ ត្រូវបាចិត្តិយ ។ ឯវិធីវិកប្បនឹងសម្តែងទៅខាងមុខ ។ ក្នុងចីវរមិនបានដកវិកប្ប ត្រូវតិកបាចិត្តិយ ។ អធិដ្ឋានឬលះចីវរដែលមិនបានដកវិកប្បនោះត្រូវទុក្កដ ។ ដកវិកប្បហើយ សម្គាល់ថាមិនទាន់ដកវិកប្ប ឬសង្ស័យ ហើយប្រើប្រាស់ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាដកវិកប្ប ហើយប្រើប្រាស់ មិនត្រូវអាបត្តិ អ្នកទទួលវិកប្ប ដកវិកប្ប ឬ ឬបរិភោគដោយស្និទ្ធ-ស្នាលនៃអ្នកដែលខ្ជីនវិកប្ប ទុក និងកិក្ខុធ្លាតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មិនត្រូវព្រោះបង្ហាប់ ។ មានអង្គ ៣ គឺ **សាមំ** **វិកប្បិតស្ស** **អប្ប**ច**ុ**ន្ធ**ាវ**ោ មិនដកចីវរដែលខ្ជីន វិកប្ប ១ **វិ**ក**ប្ប**ជ**ូ**ប**ត**ចី**ព**ាវ**ត**ា សំពត់នោះ ទទឹងបណ្ដាយ ល្មមវិកប្ប ១ **ប**រ**ិ**ភ**ោ**គ**ោ** បរិភោគ ស្ងៀកដណ្ដប់ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវ ១ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិនសិក្ខាបទ ១ ១ ១

ភិក្ខុអ្នកបង្ហាប់នោះ ត្រូវបាចិត្តិយ ។ ក្នុងឧបសម្បន្ន ត្រូវតិកបាចិត្តិយ ។ អនុបសម្បន្ន ត្រូវតិកទុក្កដ ។ លាក់ឯង ឬប្រើអ្នកដទៃឲ្យលាក់នូវបរិក្ខារដទៃជារបស់ឧបសម្បន្ន ឬអនុបសម្បន្នក្តី រៀរតែបរិក្ខារមានបាត្រជាដើមដែលពោលហើយនោះចេញ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺបរិក្ខារអ្នកដទៃទុកដាក់មិនល្អ ជួយរើសទុកដាក់ឲ្យ ឬរើសទៅទុក ដោយគិតនឹងប្រដៅម្ចាស់របស់ហើយទើបឲ្យ និងភិក្ខុធ្លត់ជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាសាណត្តិក: ត្រូវព្រោះបង្ហាប់ ។ មានអង្គ ២ គឺ **ឧបសម្បន្នស្ស សន្តកានំ បត្តាទីនំ អបនិធានំ** *លាក់បាត្រជាដើមជារបស់ឧបសម្បន្ន ១* **វិហេសេតុកាមតា ឯ ហស្ឆាធិប្ប៉ាយតា ឯ** *ប្រាថ្នានឹងឲ្យម្ចាស់របស់លំបាក ឬនឹងសើចលេង ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ។*

អបនិធានសិក្ខាបទ គម្រប់ ១០ ចប់

សុរាបានវគ្គ គម្រប់ ៦ ចប់

សប្ប៉ាណកវគ្គ គម្រប់ ៧ មាន ១០ សិក្ខាបទ ៖

សញ្ចិច្ចបាណសិក្ខាបទ ជាបឋម សេចក្តីថា ភិក្ខុណាកៃ្ងងសម្ងាប់សត្វតិរច្ឆានដែលមានជីវិត សូម្បីតូចប្រមាណប៉ុនពងចៃ ពងសង្កើច ឬធំក្តី

ឲ្យស្លាប់ត្រូវបាចិត្តិយ ។ បើសត្វធំ ជាអកុសលកម្មធំ ព្រោះប្រយោគធំ ។ សង្ស័យក្នុងសត្វមានជីវិត ឬមិនមែនសត្វមានជីវិត សម្គាល់ថាសត្វមានជីវិត ឬសង្ស័យ ហើយសម្ងាប់ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាមិនមែនសត្វ ជាអនាបត្តិ មិនក្ងែង មិនមានសតិ មិនដឹង មិនប្រាជ្ញានឹងឲ្យស្លាប់ និងភិក្ខុធ្លួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ វិនិច្ឆ័យក្រៅនេះ មានន័យដូចពោលហើយ ក្នុងមនុស្សវិគ្គហសិក្ខាបទ ។

សញ្ចិច្ចបាណសិក្ខាបទ ជាបឋម ចប់

សប្បាណកសិក្ខាបទ គម្រប់ ២ សេចក្តីថា ភិក្ខុណា ដឹងថាទឹកមានតួសត្វ សត្វនឹងស្លាប់ដោយការបរិភោគទឹកនោះ ភិក្ខុបរិភោគទឹកនោះ គឺផឹក ឬងូត ឬលាងភាជនៈ ឬចាក់ស្រោច ក្នុងទីណាៗ ត្រូវបាចិត្តិយគ្រប់ៗ ប្រយោគ ។ វិនិច្ឆ័យក្រៅនោះ គប្បីដឹងដោយន័យដូចពោលហើយ ក្នុងសញ្ចិច្ចបាណសិក្ខាបទនោះចុះ ។

សប្បាណកសិក្ខាបទ គម្រប់ ២ ចប់

ឧក្កោដនសិក្ខាបទ គម្រប់ ៣ សេចក្តីថា អធិករណ៍ទាំង ៤ គឺ វិវាទ ប្រកែកទាស់ទែងគ្នាដោយធម្មវិន័យឈ្មោះថា វិវាទាធិករណៈ ។ ចោទ

ដោយសីលវិបត្តិ អាចារវិបត្តិ ទិដ្ឋិវិបត្តិ អាជីវវិបត្តិ ណាមួយ ឈ្មោះ ថាអនុវាទាធិករណ: ។ អាបត្តិទាំង ៧ កងណាមួយដែលភិក្ខុត្រូវហើយ ឈ្មោះថាអាបត្តាធិករណ: ។ អបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្មទាំង ៤ នេះ ណាមួយ កើតឡើងដល់សង្ឆ សង្ឆនឹង គប្បីធ្វើ ឈ្មោះថាកិច្ចាធិករណ: ។ អធិករណ៍ទាំង ៤ នេះ ណាមួយ កើតឡើង សង្ឆរម្ងាប់ហើយដោយសមថ: ៧ ណាមួយ ដោយធម៌ ។ ភិក្ខុណាដឹងថា សង្ឆរម្ងាប់ស្រេចហើយ ទៅកាន់សម្នាក់ភិក្ខុនោះ។ ពោលថាកម្មដែលរម្ងាប់អធិករណ៍នោះសង្ឆធ្វើមិនល្អទេ ត្រូវធ្វើជាថ្មីទៀត ជាដើម ដូច្នេះហើយ សើរើចេញ ដើម្បីនឹងឲ្យធ្វើជាថ្មីទៀត ត្រូវ បាចិត្តិយ ។ ភិក្ខុសង្ស័យក្នុងកម្មជាធម៌ក្តី ឬកម្មមិនជាធម៌ សម្គាល់ថា ជាធម៌ក្តី ឬសង្ស័យក្តី ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសម្គាល់ថាមិនជាធម៌ ក្នុងកម្មនោះ។ និងដឹងថាសង្ឆធ្វើកម្មមិនជាធម៌ ឬធ្វើជាពួក ឬធ្វើដល់មនុស្សមិនគួរដល់កម្ម និងភិក្ខុឆ្គួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មានអង្គ ៣ គឺ **យថាធម្មំ នីហតភាវោ** អធិករណ៍សង្ឆរម្ងាប់ហើយ តាមធម៌ ១ **ជានតា** មានការដឹង ១ **ឧក្លោដនំ** សើរើ ១ ព្រម ដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នា-ទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាទុក្ខវេទនា ។

ឧក្លោដនសិក្ខាបទ គម្រប់ ៣ ចប់

ទុដ្ឋុល្លបដិច្ចាទនសិក្ខាបទ គម្រប់ ៤ សេចក្ដីថា ភិក្ខុណា ដឹងថាភិក្ខុដទៃត្រូវទុដ្ឋុល្លាបត្តិ គឺសង្ឆាទិសេស ហើយជួយបិទបាំងអាបត្តិនៃភិក្ខុនោះទុក ដោយឧបាយណាមួយ ត្រូវបាចិត្តិយ ។ បើដាក់ធុរៈថា នឹងមិនប្រាប់ដល់ភិក្ខុណាមួយ ហើយខាងក្រោយត្រឡប់ប្រាប់ ឈ្មោះថាត្រូវបាចិត្តិយហើយទើបប្រាប់ ។ បើដាក់ធុរៈដូច្នេះហើយ ប្រាប់ដល់អ្នកដទៃដើម្បីនឹងឲ្យជួយបិទតៗទៅទៀតដោយឧបាយដូច្នេះ សូម្បីសមណៈ ១ រយអង្គ កាលបើតំណមិនទាន់ដាច់ដរាបណា ក៏គង់ត្រូវអាបត្តិបាចិត្តិយដរាបនោះ ។ ធ្វើដូចម្ដេចតំណទើបនឹងដាច់ បើអ្នកត្រូវអាបត្តិនោះប្រាប់ដល់អ្នកម្នាក់ឲ្យជួយបិទអាបត្តិ សូម្បីអ្នកម្នាក់នោះ ក៏ប្រាប់ដល់អ្នកដទៃឲ្យជួយបិទតៗ ទៅទៀត ភិក្ខុដែលគេប្រាប់ឲ្យជួយបិទបាំងទី ៣ នោះមិនបិទត្រឡប់មកប្រាប់ដល់ភិក្ខុទី ២ វិញ ដូច្នេះហើយតំណទើបនឹងដាច់ ។ ក្នុងទុដ្ឋុល្លាបត្តិ ភិក្ខុសង្ស័យ ឬសម្គាល់ថាមិនមែនទុដ្ឋុល្លាបត្តិ ត្រូវទុក្កដ ។ មិនមែនទុដ្ឋុល្លាបត្តិ ត្រូវតិកទុក្កដ ។ ជួយបិទបាំងអជ្ឈាចារអាក្រក់និងមិនអាក្រក់ នៃអនុបសម្បន្ន ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺគិតថាការឈ្លោះវិវាទនឹងមានដល់សង្ឆ ឬគិតថាអ្នកនេះកាចអាក្រក់នឹងធ្វើអន្តរាយដល់ជីវិត ឬព្រហ្មចរិយៈដូច្នេះ ហើយមិនប្រាប់ក្ដី មិនបានឃើញភិក្ខុដែលសមគួរមិនទាន់ប្រាប់ក្ដី ឬមិនប្រាថ្នានឹងបិទដោយគិតថាលោកនេះនឹងប្រាកដដោយកម្ម

របស់ខ្លួនឯង និងកិក្ខុធ្លួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មានអង្គ ២ គឺ **ឧបសម្បន្នស្ស ទុដ្ឋុល្លាបត្តិជ-ឌនំ** *ដឹងថាឧបសម្បន្ន ត្រូវទុដ្ឋុល្លាបត្តិ ១* **បដិច្ឆាទេតុកាមតាយ ជាវោចេស្សាមីតិ ឧរនិក្ខេចោ** *ជាក់ធុរ:ថានឹងមិនប្រាប់ដោយ ប្រាជ្ញាបិទបាំង ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ ជាសមនុកាសនសមុដ្ឋាន អាបត្តិកើតអំពីកាយវាចាចិត្ត ជាកិរិយា សញ្ញ-វិមោក្ខ សចិត្តក: លោកវជ្ជ: កាយកម្ម វចីកម្ម អកុសលចិត្ត ទុក្ខវេទនា ។*

ទុដ្ឋុល្លបដិច្ឆាទនសិក្ខាបទ គម្រប់ ៤ ចប់

ឩនវីសតិវស្សសិក្ខាបទ គម្រប់ ៥ សេចក្តីថា ភិក្ខុណា ជាឧបជ្ឈាយ៍ ដឹងថាបុគ្គលមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំ គឺរាប់តាំងអំពីចាប់បដិសន្ធិមក ហើយឲ្យឧបសម្បទាជាភិក្ខុ ឧបជ្ឈាយ៍នោះត្រូវបាចិត្តិយ ។ ភិក្ខុក្រៅនោះ ជាគណបូរក:ទាំងអស់ត្រូវទុក្កដ ។ ចំណែកបុគ្គលនោះ សូម្បីឧបជ្ឈាយ៍ ដឹង ឬមិនដឹងក្តី ឲ្យឧបសម្បទា គង់មិនបានជាឧបសម្បទា ។ បើអ្នកនោះកន្ទង ១០ វស្សាទៅ បានជាឧបជ្ឈាយ៍ឲ្យកុលបុត្រដទៃឧបសម្បទា បើលើកឧបជ្ឈាយ៍នោះចេញ គណបូរក:គ្រប់សោត អ្នកឧបសម្បទាថ្មី ឈ្មោះថាឧបសម្បទាហើយដោយប្រពៃ សូម្បីអ្នកដែលមិនជាឧបសម្បទា

នោះ មិនទាន់ដឹងខ្លួនដរាបណា ក៏មិនទាន់អន្តរាយសូគ៌និងនិញ្ជានដល់អ្នកនោះដរាបនោះ ដឹងហើយគប្បីឧបសម្បទាជាថ្មីទៀត ។

ឩនវីសតិវស្សសិក្ខាបទ គម្រប់ ៥ ចប់

ថេយ្យសត្ថសិក្ខាបទ គម្រប់ ៦ សេចក្តីថា ពួកឈ្មួញជាចោរទាំងឡាយធ្វើចោរកម្មហើយក្តី មិនទាន់បានធ្វើក្តី ដល់នូវកិរិយាលួចរបស់ព្រះរាជាក្តី គេចវាងឲ្យរួចពន្ធគយក្តី ពួកណាមួយ ជាពួកដើរផ្លូវ ឈ្មោះថាថេយ្យសត្ថ: ពួកឈ្មួញជាចោរ ភិក្ខុណា ដឹងថាពួកឈ្មួញជាចោរដូច្នោះ ហើយបបួលកំណត់កាលជាមួយគ្នាទាំងសងខាងថា យើងនឹងទៅក្នុងថ្ងៃនេះ ឬព្រឹកនេះ ត្រូវទុក្កដ ព្រោះបបួលមុនហើយ ។ ធ្វើមិនឲ្យខុសសង្កេតកាលដែលកំណត់ទុក ដើរផ្លូវទៅជាមួយគ្នា សូម្បីខុសសង្កេតផ្លូវ ខុសសង្កេតដងព្រៃក្តី បើដើរទៅក្នុងស្រុក មិនទាន់ចុះកាន់ឧបចារ:ស្រុកដទៃ ដែលជិតគ្នាល្មមមាន់ហ៊ីរដល់ មិនទាន់ត្រូវអាបត្តិនៅឡើយ កាលកន្ទងឧបចារ:ស្រុកដទៃ ក្នុងជំហានជាបឋម ត្រូវទុក្កដ ។ ក្នុងជំហានជាគម្រប់ ២ ត្រូវបាចិត្តិយ ។ ដើរផ្លូវក្នុងព្រៃមិនមែនជាស្រុក កន្ទងកន្ទះយោជន៍ ក៏ត្រូវបាចិត្តិយ ។ ត្រូវអាបត្តិច្រើនតិច រាប់ដោយកន្ទងឧបចារ:ស្រុកដទៃមួយៗ និងកន្ទងកន្ទះយោជន៍មួយៗ ។ មនុស្សមិនបានបបួលភិក្ខុបបួលតែម្នាង ឬជាពួកចោរ ភិក្ខុសង្ស័យ ហើយបបួលក្តី ឬមិនមែនជាពួកចោរ ភិក្ខុសម្គាល់ថាជាពួកចោរ ឬសង្ស័យហើយបបួលក្តី ទាំងអម្បាលនេះ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺកិក្ខុសម្គាល់ថាមិនមែនពួកចោរក្តី មិនបានបបួលគ្រាន់តែដើរទៅជាមួយគ្នា ឬមនុស្សបបួលតែម្នាង់ កិក្ខុមិនបានបបួលក្តី និងទៅខុសសង្កេតកាល ឬបបួលគ្នាទៅព្រោះមានអន្តរាយក្តី និងកិក្ខុធ្លាតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មានអង្គ ៤ គឺ **ថេយ្យសត្ថការោ** ពួកឈ្មួញជាចោរ ១ **ជានន្តំ** បានដឹង ១ **សំវិធានំ** បបួលគ្នាទាំងសងខាង ១ **អវិសង្ខ្លេតេន គមនំ** ទៅកន្ទ្រង់ឧបចារ:ស្រុកដទៃ ឬកន្ទ្រង់កន្ទ្រះយោជន៍មិនខុសសង្កេត ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ ជាថេយ្យសត្ថសមុដ្ឋាន អាបត្តិកើតអំពីកាយចិត្ត អំពីកាយវាចាចិត្ត ជាកិរិយា សញ្ញាវិមោក្ខ សចិត្តក: បណ្ណត្តិវជ្ជ: កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។

ថេយ្យសត្ថសិក្ខាបទ គម្រប់ ៦ ចប់

សំវិធានសិក្ខាបទ គម្រប់ ៧ សេចក្តីថា កិក្ខុណា បបួលស្ត្រីដែលដឹងសេចក្តី ទាំងស្ត្រីក៏បបួលព្រមគ្នាទាំងសងខាង ដើរទៅក្នុងផ្លូវជាមួយគ្នា មិនខុសសង្កេតកាល ត្រូវអាបត្តិទុក្កដ និងបាចិត្តិយ ដូចពោលហើយក្នុងសិក្ខាបទមុន ។ ក្នុងមាតុគ្រាមត្រូវតិកបាចិត្តិយ ។ ស្ត្រីយក្ខ ស្ត្រីប្រេត និងបណ្ឌក និងតិរច្ឆានញ្ជី មានកាយដូចមនុស្ស ត្រូវទុក្កដ ។ កិក្ខុបបួលតែម្នាង់ ស្ត្រីមិនបានបបួល ឬមិនមែនស្ត្រី សម្គាល់ថាស្ត្រី ឬសង្ស័យ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាមិនមែនស្ត្រី ជាអនាបត្តិ ។ ក្នុងអនាបត្តិក្រោយនេះដូចសិក្ខាបទមុន លើកតែអន្តរាយម្យ៉ាង ។ ជាអនាណត្តិក: មានអង្គ ៣ គឺ **ទ្វិន្នំបិ សំវិឌហិត្វា មក្ខបដិបន្ធតា** បបួលជាមួយគ្នាទាំងសងខាងហើយដើរផ្ទូរទៅ ១ **អវិសង្កេតតា** មិនខុសសង្កេត ១ **តាមន្តរេ តមដ្ឋំ វ អឌ្ឍយោជនាតិក្កមោ វ** កន្ទ្រងឧបចារ:ស្រុកដទៃ ឬកន្ទ្រងកន្ទ្រះយោជន៍ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ ជាអទ្ធានសមុដ្ឋាន អាបត្តិកើតអំពីកាយ វាចា អំពីកាយចិត្ត អំពីកាយវាចាចិត្ត ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តក: បណ្ណត្តិវជ្ជ: កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។

សំវិធានសិក្ខាបទ គម្រប់ ៧ ចប់

អរិដ្ឋសិក្ខាបទ គម្រប់ ៨ សេចក្ដីថា ភិក្ខុណា មានទិដ្ឋិសេចក្ដីឃើញខុសថា សមួសរ្ស្ត្រីមិនមានទោស ព្រោះដូចសមួសរគ្រឿងកម្រាលដ៏ទន់ មិនឃើញទោសក្នុងការកន្ទ្រងមេថុនដូច្នេះ ហើយពោលបង្ហាច់ព្រះពុទ្ធជាម្ចាស់ថា អាណាវីតិក្កមន្តរាយ ការកន្ទ្រងសិក្ខាបទបញ្ញត្តិ ដូចត្រេកអរសមួសរ្ស្ត្រីនេះ ព្រះមានព្រះភាគត្រាស់ថាជាអន្តរាយដល់សួគ៌ និព្វានោះ យើងឃើញថាមិនជាអន្តរាយដល់មនុស្ស ដែលត្រេកអរដោយសមួសរ្ស្ត្រី ភិក្ខុពោលដូច្នេះ ឲ្យភិក្ខុទាំងឡាយដទៃដែលបានឮ

បានឃើញ គប្បីសម្តែងទោសកាមគុណហាមប្រាមកិក្ខុនោះបានពីរដង បីដង កាលបើកិក្ខុនោះមិនលះទិដ្ឋិនោះចេញ ត្រូវទុក្កដ ។ សូម្បីកិក្ខុនោះមិនលះទិដ្ឋិហើយ គប្បីនាំខ្លួនកិក្ខុនោះទៅកណ្តាលសង្ឆ សង្ឆហាមប្រាមទៀត លុះកិក្ខុនោះមិនលះ ត្រូវទុក្កដទៀត កាលកិក្ខុនោះមិនលះដូច្នេះ សង្ឆគប្បីសូត្រសមនុភាសនកម្មចំពោះកិក្ខុនោះដរាបអស់រាវ:បីដង ដោយញត្តិចតុត្ថកម្មវាចា ដើម្បីនឹងឲ្យលះទិដ្ឋិនោះចេញ កាលកិក្ខុនោះមិនលះបង់ចេញ ត្រូវទុក្កដ ក្នុងខណ:ចប់ញត្តិជាបឋម និងខណ:ចប់កម្មវាចា ទី ១ ទី ២ ។ កាលចប់កម្មវាចាទី ៣ ត្រូវបាចិត្តិយ ។

អរិដ្ឋសិក្ខាបទ គម្រប់ ៨ ចប់

ឧក្ខិត្តសម្ភោគសិក្ខាបទ គម្រប់ ៩ សេចក្តីថា កិក្ខុណា ត្រូវឧក្ខេប-និយកម្ម ព្រោះមិនឃើញអាបត្តិ មិនសម្តែងអាបត្តិ ឬមិនលះទិដ្ឋិ ទាំង ៣ ជំពូកនេះណាមួយ សង្ឆមិនទាន់រម្ងាប់កម្មនោះនៅឡើយ កិក្ខុណាបានដឹងដូច្នេះ ហើយធ្វើអាមិសសម្ភោគ គឺឲ្យអាមិស ឬទទួលអាមិសជាមួយនឹងកិក្ខុនោះ ឬធ្វើធម្មសម្ភោគ គឺប្រដៅធម៌ រៀនធម៌នឹងកិក្ខុនោះក្តី ធ្វើសង្ឆកម្ម មានឧបោសថនិងបវារណាជាដើម និងដេកក្នុងទីប្រក់បាំងជាមួយគ្នា សូម្បីមានឧបចារ:ផ្សេងអំពីកិក្ខុនោះ ត្រូវបាចិត្តិយគ្រប់ ៣ ប្រយោគ ។ កិក្ខុសង្ស័យក្នុងកិក្ខុដែលសង្ឆលើកទោស ឬសម្គាល់ក្នុងកិក្ខុដែលសង្ឆមិនបានលើកទោស ថាសង្ឆលើកទោសក្តី សង្ស័យក្តី ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសម្គាល់ថា ភិក្ខុដែលសង្ឆមិនបានលើកទោស ឬដឹងថាសង្ឆសូត្រសមនុភាសនកម្ម និងដឹងថាភិក្ខុលះទិដ្ឋិ ហើយនិងភិក្ខុធ្ពតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មានអង្គ ៣ គឺ **អកតានុធម្មតា** សង្ឆមិនបានធ្វើតាមធម៌ ១ **ជានន** ដឹងច្បាស់ ១ **សម្ភោតានិការណ** ធ្វើកិច្ចមានសេពគប់ជាដើម ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាបណ្ណត្តិវជ្ជ: មានចិត្ត ៣ មានវេទនា ៣ ។

ឧក្ខិត្តសម្ភោគសិក្ខាបទ គម្រប់ ៩ ចប់

កណ្ហកសិក្ខាបទ គម្រប់ ១០ សេចក្តីថា សូម្បីសាមណេរមានទិដ្ឋិ-វិបរិត ពោលបង្ការ៉ាប់ព្រះមានព្រះភាគ ដូចក្នុងអរិដ្ឋសិក្ខាបទមុន ភិក្ខុទាំងឡាយដែលបានឃើញ បានឮ គប្បីសម្តែងទោសកាមគុណហាម-ឃាត់ពីរដង បីដង បើសាមណេរនោះ លះទិដ្ឋិនោះចេញ ជាការប្រពៃ បើសាមណេរនោះ មិនលះទិដ្ឋិសោត គប្បីធ្វើនាសន:ដល់សាមណេរនោះចុះ ដោយពាក្យថា "**អជ្ជតគ្គេ តេ អាវុសោ សមណុ-ទ្ទេស ន ចេវ សោ ភគវា សត្ថា អបទិសិតព្ពោ, យម្ពិ ចញ្ញេ សមណុទ្ទេសា លភន្តិ ភិក្ខូហិ សទ្ធឹ ទ្វិរត្តតិរត្តំ សហាសេយ្យំ, សាបិ តេ ជត្តិ, ចរ បិរេ វិនស្សាតិ**"

ម្នាលសាមណេរដ៏មានអាយុ តាំងអំពីថ្ងៃនេះទៅ អ្នកកុំអាងព្រះមានព្រះភាគនោះ ថាជាសាស្តានៃអ្នកឡើយ សាមណេរទាំងឡាយដទៃ រមែងបានដេករួមនឹងភិក្ខុទាំងឡាយ ពីរយប់ បីយប់ ជាកំណត់ សូម្បីការដេករួមគ្នាយ៉ាងនោះ ក៏មិនមានដល់អ្នក អ្នកចៀសចេញចុះ អ្នកជាមនុស្សអាក្រក់ ចូរវិនាសចុះ ដូច្នេះ ។ ភិក្ខុណា ដឹងថាសាមណេរដែលសង្ឆឲ្យវិនាសដូច្នេះហើយ បញ្ចុះបញ្ចូលដោយគិតថាអញនឹងឲ្យបរិក្ខារ ឬប្រដៅធម៌ក្តី ឲ្យឧបដ្ឋាកខ្លួន គឺត្រេកអរទទួលចុណ្ណៈនិងឈើស្ងួនជាដើមក្តី ឬធ្វើសម្ភោគៈទាំងពីរក្តី ឬរួមសហសេយ្យនឹងសាមណេរនោះ ដូចពោលហើយក្នុងមុនក្តី ត្រូវបាចិត្តិយ គ្រប់ៗ ប្រយោគ ។

កណ្ឌកសិក្ខាបទ គម្រប់ ១០ ចប់

សប្បាណកវគ្គ គម្រប់ ៧ ចប់

សហធម្មិកវគ្គ គម្រប់ ៨ មាន ១២ សិក្ខាបទ ៖

សហធម្មិកសិក្ខាបទ ជាបឋម សេចក្តីថា ភិក្ខុណា ប្រព្រឹត្តអនាចារ ភិក្ខុទាំងឡាយដទៃហាមប្រាមប្រដៅ ពោលដោយសិក្ខាបទបញ្ញត្តិ ភិក្ខុខ្ជាចនឹងត្រូវអាបត្តិព្រោះមិនអើពើ ក៏ភ្ជែងពោលដោយលេសឧបាយថា យើងមិនបានសួរភិក្ខុដទៃ ដែលជាវិន័យធរអ្នកឈ្វាសវៃដរាបណា យើងមិនទាន់សិក្ខាក្នុងសិក្ខាបទនោះដរាបនោះ ដូច្នេះ ត្រូវបាចិត្តិយ គ្រប់ៗ

ពាក្យដែលពោល ។ ភិក្ខុអ្នកសិក្សាគួរតែដឹងច្បាស់ ត្រូវពិនិត្យសាកសួរ ពិចារណាឲ្យបានសេចក្តីពិត ដូច្នេះឯង ជាការគាប់ប្រសើរក្នុងសិក្ខា-បទនោះ ។ ក្នុងឧបសម្បន្ន ត្រូវតិកបាចិត្តិយ ។ ក្នុងអនុបសម្បន្ន ត្រូវ តិកទុក្កដ ។ ឧបសម្បន្ន ឬអនុបសម្បន្ន ដាស់តឿនពោលប្រដៅដោយ សេចក្តី ក្នុងព្រះសូត្រ ឬព្រះអភិធម្ម មិនមែនជាវិនយបញ្ញត្តិ ភិក្ខុពោល គេចវៀសវាងចេញ ដោយអាការណាមួយ ត្រូវទុក្កដ ប៉ុណ្ណោះ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុពោលថា ខ្ញុំនឹងដឹង នឹងសិក្សា ដូច្នេះក្តី និងភិក្ខុធ្លត់ជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនា-ណត្តិក: មិនត្រូវអាបត្តិព្រោះបង្គាប់ ។ មានអង្គ ២ គឺ **ឧបសម្បន្នស្ស បញ្ញត្តេន** *ឧបសម្បន្នពោលដាស់តឿនដោយបញ្ញត្តិ* ១ **អសិក្ខិតុកាមតាយ** *ឯ* *ឯ* *ពោលបញ្ជៀសទៅដូច្នោះ ដោយមិនប្រាថ្នានឹងសិក្សា* ១ *ព្រមដោយអង្គ* ២ *នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះជាទុក្ខ-វេទនាប៉ុណ្ណោះ ។*

សហធម្មិកសិក្ខាបទ ជាបឋម ចប់

វិលេខនសិក្ខាបទ គម្រប់ ២ សេចក្តីថា ភិក្ខុណា កាលភិក្ខុដទៃ សម្តែង ស្វាធ្យាយ សិក្សាបាតិមោក្ខ ហើយពោលតិះដៀលសិក្ខាបទថា ប្រយោជន៍អ្វី ដោយការសូត្ររៀន សិក្សា សិក្ខាបទតូចនិងតូចដោយ

លំដាប់អម្បាលនេះ អ្នកណាស្វាធ្យាយ រៀនសូត្រ សិក្ខាបទទាំងអម្បាលនេះ រមែងប្រព្រឹត្តទៅដើម្បីនឹងកើតសេចក្តីលំបាក រង្គៀស ក្តៅក្រហាយ ចង្អៀតចង្អល់ចិត្ត ប៉ុណ្ណោះឯង ភិក្ខុតិះដៀលសិក្ខាបទដូច្នេះ ត្រូវបាចិត្តិយ ។ តិះដៀលក្នុងសម្ងាត់ឧបសម្បន្ន ត្រូវតិកបាចិត្តិយ ។ ក្នុងសម្ងាត់អនុបសម្បន្ន ត្រូវតិកទុក្កដ ។ តិះដៀលធម៌ដទៃ គឺព្រះសូត្រ និងព្រះអភិធម្ម ក្នុងសម្ងាត់ឧបសម្បន្ន និងអនុបសម្បន្នទាំង ២ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺមិនប្រាថ្នានឹងតិះដៀល ពោលថា អ្នកចូររៀនព្រះសូត្រ ឬព្រះអភិធម្ម និងគាថាសិនចុះ គ្រាក្រោយទើបរៀនវិន័យដូច្នេះ និងភិក្ខុធ្ពតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មិនត្រូវអាបត្តិព្រោះបង្គាប់ ។ មានអង្គ ២ គឺ **ករហិតុ-កាមតា ច** ប្រាថ្នានឹងតិះដៀល ១ **ឧបសម្បន្នស្ស សន្តិកេ សិក្ខាបទវិណ្ណនកំ ច** តិះដៀលសិក្ខាបទក្នុងសម្ងាត់ឧប-សម្បន្ន ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើមដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះជាទុក្ខវេទនាប៉ុណ្ណោះ ។

វិលេខនសិក្ខាបទ គម្រប់ ២ ចប់

មោហនសិក្ខាបទ គម្រប់ ៣ សេចក្តីថា ភិក្ខុណា ប្រព្រឹត្តអនាចារ មុនហើយ កាលបាតិមោក្ខ ដែលសង្ឆស្ងូត្រក្នុងថ្ងៃឧបោសថគ្រប់កន្ទុះខែ

ដោយលំដាប់អស់វារៈ ២-៣ ដង ហើយបានដឹង បានឮ ប្រាថ្នានឹងឲ្យ
ភិក្ខុដទៃសម្គាល់ថាខ្លួនត្រូវអាបត្តិដោយមិនដឹង ក្លែងពោលថា ខ្ញុំទើបនឹង
ដឹងឥឡូវនេះឯងថា សិក្ខាបទនេះមកក្នុងបាតិមោក្ខ មកកាន់ឧទ្ទេសគ្រប់
កន្ទុះខែដូច្នេះ បើភិក្ខុទាំងឡាយដទៃ ក៏ដឹងថាភិក្ខុនេះធ្លាប់ស្តាប់បាតិមោក្ខ
ដែលសង្ឆស្សូត្រមក ២-៣ ដងហើយដូច្នេះ ភិក្ខុនោះត្រូវទុក្កដ ព្រោះ
ក្លែងធ្វើពើ ។ អាបត្តិណាដែលភិក្ខុត្រូវ ព្រោះប្រព្រឹត្តអនាចារពីមុន
ភិក្ខុនឹងរួចចាកអាបត្តិនោះដោយក្លែងធ្វើមិនដឹងក៏ទេ ឲ្យវិន័យធរគប្បីកាត់
អាបត្តិតាមទោសដែលជាទេសនាគាមិនី និងវុដ្ឋានគាមិនីនោះចុះ ហើយ
សង្ឆគប្បីធ្វើបន្ថែមនូវមោហារោបនកម្ម ដល់ភិក្ខុនោះ ដោយញត្តិទុតិយ-
កម្មវាចា លុះកម្មនោះសង្ឆធ្វើជាធម៌ស្រេចហើយ ភិក្ខុក្លែងធ្វើពើទៀត
ត្រូវបាចិត្តិយ ។

មោហានសិក្ខាបទ គម្រប់ ៣ ចប់

បហារទានសិក្ខាបទ គម្រប់ ៤ សេចក្តីថា ភិក្ខុណា ក្រោធខឹងហើយ
ប្រហារភិក្ខុដទៃដោយកាយ ឬរបស់ជាប់ដោយកាយ ឬចោលទៅ ត្រូវ
បាចិត្តិយ ។ សូម្បីភិក្ខុត្រូវប្រហារនោះស្លាប់ ក៏គង់ត្រូវបាចិត្តិយ ព្រោះ
ប្រាថ្នានឹងប្រហារម្យ៉ាង ។ ក្នុងឧបសម្បន្ន ត្រូវតិកបាចិត្តិយ ។ ក្នុងអនុប-
សម្បន្ន ត្រូវតិកទុក្កដ ។ មានបំណងនឹងធ្វើឲ្យបង់រូបកាយ គឺចៀរ កាត់
អវយវៈ មានត្រចៀកជាដើមនៃឧបសម្បន្ន ឬអនុបសម្បន្ន ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុដែលអ្នកណាមួយមកបៀតបៀនវាយ ដំ ដាល់ តប់ ហើយប្រាថ្នានឹងឲ្យខ្លួនរួចចាកអន្តរាយ ក៏ប្រហារដោះខ្លួនក្តី និងភិក្ខុធ្លត់ជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មិនត្រូវអាបត្តិព្រោះបង្ហាប់ ។ មានអង្គ ៣ គឺ **ការុណ្យតា** ក្រោធខឹង ១ ន **មោក្ខាធិប្ប**ាយតា មិនប្រាថ្នានឹងឲ្យខ្លួនរួចចាកអន្តរាយ ១ **ឧបសម្ប**ន្ន**ស្ស បហារ**ទានំ ប្រហារនូវឧបសម្ប**ន្ន** ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋមបារាជិក ប្លែកតែសិក្ខាបទនេះជាទុក្ខវេទនាប៉ុណ្ណោះ ។

បហារទានសិក្ខាបទ គម្រប់ ៤ ចប់

តលសត្តិកសិក្ខាបទ គម្រប់ ៥ សេចក្តីថា ភិក្ខុណា យារលើកឡើងនូវលំពែងគឺបាតដៃ ឬរបស់ជាប់ដោយកាយ សូម្បីស្ទឹកឧប្បលដល់ភិក្ខុដទៃដោយសេចក្តីក្រោធខឹង ត្រូវបាចិត្តិយ ។ បើភិក្ខុយារលើកដៃឡើងនឹងគំរាមហើយភ្ជាត់ទៅជាប្រហារ ត្រូវទុក្កដ ព្រោះមិនប្រាថ្នានឹងប្រហារ ។ បើត្រូវអវយវ: ណាមួយ មានដៃជាដើម បែកបាក់ទៅក៏ត្រូវតែទុក្កដ ។ វិនិច្ឆ័យទាំងអស់ ក្រៅនោះ គប្បីដឹងដោយន័យដូចពោលហើយក្នុងសិក្ខាបទមុននោះចុះ ។

សិក្ខាបទទាំង ២ នេះ សូម្បីសត្វតិរច្ឆានក៏ឈ្មោះថាអនុបសម្ប**ន្ន** ។

តលសត្តិកសិក្ខាបទ គម្រប់ ៥ ចប់

អមូលកសិក្ខាបទ គម្រប់ ៦ *សេចក្ដីថា* ភិក្ខុណា *ចោទ*ឯង *ឬ*ឲ្យ*អ្នក*ដទៃ*ចោទ*ភិក្ខុ *ដោយ*អាបត្តិ*សង្ឃាទិ*សេ*ស* ១៣ ណាមួយ *ដែ*ល *មិ*នមានមូ*ល* *គឺ*មិ*ន*បានឃើ*ញ* *មិ*ន*បានឮ* *មិ*ន*បាន*រង្ការ*ស* *ថា*ភិ*ក្ខុ*នោ*ះ* *ត្រូ*ว*អា*ប*ត្ដិ*ស*ង្ឃា*ទិ*ស*េ* *បើ*ភិ*ក្ខុ*ដែ*ล*គេ*ចោ*ទ*នោ*ះ*ដឹ*ង*ខ្ជ*ួ*ន*ថា* *គេ*ចោ*ទ* *យើ*ង*ដូ*ច*ន*ះ*ក្ន*ង*ខ*ណ*:*នោ*ះ*សោ*ត* *ភិ*ក្ខ*ុ*អ*្ន*ក*ចោ*ទ*ក*៏*ត្រូ*ว*ប*ា*ចិ*ត្ដ*ិ*យ ។ *ក្ន*ង*ឧ*ប-*ส*ម*ป*ន*ន*ត្រូ*ว*ត*ិ*ក*ป*ា*ចិ*ត្ដ*ិ*យ ។ *ចោ*ទ*ដោ*យ*អ*ា*ចา*ร*ว*ិ*ป*ត្ដ*ិ* *ឬ*ទ*ិ*ដ្ឋ*ិ*ว*ិ*ป*ត្ដ*ិ* *មិ*ន*មាន* *មូ*ล *ត្រូ*ว*ទ*ុ*ក*ដ ។ *ក្ន*ង*អ*ន*ุ*ป*ส*ม*ป*ន*ន* *ត្រូ*ว*ត*ិ*ក*ទ*ុ*ក*ដ ។

*ឯ*ว*ិ*ធ*ីដ*ែ*ล*មិ*ន*ត្រូ*ว*អា*ป*ត្ដ*ិ*នោ*ះ*គ*ឺ* *ส*ម*ា*ค*ល*់*ថ*ា*ភ*ិ*ក*ុ*ត*្រ*ូ*ว*អ*ា*ป*ត*ិ* *ส*ង*ា*ค*ទ*ិ*ส*េ*ส*ហ*ើ*យ *ហ*ើ*យ*ចោ*ទ*ត*ា*ม*ส*ม*ា*ค*ล*់* *ន*ិ*ង*ภ*ิ*ก*ุ*ข*ู*ต*ជ*ា*ដ*ើ*ม *ទ*ាំ*ង*អ*ម*ា*ป*ล*ន*េ*ះ *មិ*ន*ត្រូ*ว*អ*ា*ป*ត*ិ* ។ *ជ*ា*ส* า*ณ*ต*ิ*ก: *ត្រូ*ว*ព្រ*ះ*ป*ង*ា*ค*ប*់* ។ *ม*ា*ន*អ*ង*្ค ៤ *គ*ឺ **ឧ*ป*ส*ม*ป*ន*ន*ត*ា** *អ*ក*ដ*ែ*ล*គ*េ*ចោ*ទ*ជ*ា*ឧ*ป*ส*ม*ป*ន*ន* ១ **ส*ง*ฺ*ฆ*ាទ*ิ*ส*េ*ส*ส*ฺ** **អ*ม*ូ*ล*ก*ต*ា** *អ*ា*ป*ត*ិ*ส*ង*ា*ค*ទ*ិ*ส*េ*ส*ม*ិ*ន*ม*ា*ន* *ម*ូ*ล* ១ **អ*ณ*ุ*ฐ*ំ*ส*ต*ា** *ចោ*ទ*ឯ*ង*ឬ*ឲ*្យ*អ*ក*ដ*ែ*ล*ចោ*ទ* ១ **ត*ំ* ข*ณ*ำ** **ว*ิ*ช*ា*ต*ំ** *អ*ក*ដ*ែ*ล*គ*េ*ចោ*ទ* *ដ*ឹ*ង*ខ*ួ*ន*ក*ុ*ង*ខ*ណ*:*នោ*ះ* ១ *ព*្រ*ម*ដ*ោ*យ *អ*ង*្ค* ៤ *ន*េ*ះ* *ទ*ើ*ป*ត*្រ*ូ*ว*ป*ា*ចិ*ត*្ដ*ិ*យ ។ *ส*ม*ุ*ฐ*ា*ន*ว*ิ*ธ*ីជ*ា*ដ*ើ*ม *ដ*ូ*ច*អ*ท*ิ*ฐ*ា*ฐ*ា*ท*-*ส*ิ*ก*ข*ា*ป*ท *ป*្ញ*ូ*ก*ต*ែ*ส*ิ*ก*ข*ា*ป*ท*ន*េ*ះ*ជ*ា*ท*ุ*ก*ข*ว*ท*ា*ป*ុ*ណ*្ណ*ោ*ះ ។

អ*ម*ូ*ล*ก*ส*ิ*ก*ข*ា*ป*ท គ*ម*្ร*ប*់ ៦ ច*ប*់

សញ្ចិច្ចសិក្ខាបទ គម្រប់ ៧ *សេចក្ដីថា* *ភិក្ខុណា* *ក្ងែងបង្ក*ហេតុ*ឲ្យ*
*មានសេចក្ដីរង្គៀសសង្ស័យ*កើ*ត*ឡើ*ងដ*ល*ភិ*ក្ខុ*ដ*ទ*ៃ* *ដោ*យ*ពោ*ល*ពាក្យ*ថា
ខ្ជូ*ន*លោ*ក*ប្រ*ហ*ែ*ល*ជ*ាមានអ*ាយ*ុ*មិ*ន*ទ*ាន*ត*្រ*ប*់ ២*០ *ឆ*្ន*ាំ* *មិ*ន*ប*ាន*ជ*ាឧ*ប*ស*ម*្ប*ន*្ន
ទេ*ដ*ឹ*ង* *ល*ោ*ក*ប្រ*ហ*ែ*ល*ជ*ាធ*ាន*់*អ*ាមិ*ស*ក*្ន*ុ*ង*វ*េ*ល*ា*វ*ិ*ក*ា*ល*ទ*េ*ដ*ឹ*ង* *ល*ោ*ក*
ប្រ*ហ*ែ*ល*ជ*ាផ*ឹ*ក*ទ*ឹ*ក*ស*្រ*ូ*ង*ទ*េ*ដ*ឹ*ង* *ល*ោ*ក*ប្រ*ហ*ែ*ល*ជ*ាអ*ង*្គ*ុ*យ*ក*្ន*ុ*ង*ទ*ី*ស*្ង*ាត*ត*
ជាម*ួ*យ*ម*ាតុ*គ*្រ*ាម*ទ*េ*ដ*ឹ*ង* *។* *គ*្ម*ាន*ហ*េ*ត*ុ* *ហ*ើ*យ*ក*្ង*ែ*ង*ប*ង*្ក*ហ*េ*ត*ុ*ឲ*្យ*ម*ាន
សេ*ច*ក*្ត*ីរ*ង*្គ*ៀ*ស*ស*ង*្ស*័*យ*ដ*ល*ភ*ិ*ក*្ខ*ុ* *ដ*ូ*ច*ន*ះ* *ត*្រ*ូ*វ*ប*ា*ចិ*ត*្ត*ិ*យ*គ*្រ*ប*់*។* *ព*ា*ក*្យ* *។*
កុ*ង*ឧ*ប*ស*ម*្ប*ន*្ន* *ត*្រ*ូ*វ*ត*ិ*ក*ប*ា*ចិ*ត*្ត*ិ*យ* *។* *ក*ុ*ង*អ*ន*ុ*ប*ស*ម*្ប*ន*្ន* *ត*្រ*ូ*វ*ត*ិ*ក*ទ*ុ*ក*្ក*ដ* *។*

*ឯ*ក*ា*រ*ិ*ធ*ីដ*ែ*ល*ម*ិ*ន*ត*្រ*ូ*វ*អ*ាប*ត*្ត*ិ*ន*ោ*ះ* *គ*ឺ*ម*ិ*ន*ប*្រ*ា*ថ*្ន* *ដ*ើ*ម*្ប*ី*ន*ឹ*ង*ឲ*្យ*ភ*ិ*ក*្ខ*ុ*ដ*ទ*ៃ*
*អ*ផ*ុ*ក*ចិ*ត*្ត* *ព*ោ*ល*ដ*ូ*ច*ន*ះ* *ដ*ោ*យ*ស*្ង*ែ*ង*រ*ក*ប*្រ*យ*ោ*ជ*ន*ៈ*ដ*ល*ភ*ិ*ក*ខ*ុ*ន*ោ*ះ*ប*ុ*ណ*្ណ*ោ*ះ*
និ*ង*ភ*ិ*ក*ខ*ុ*ធ*ូ*ត*ជ*ាដ*ើ*ម* *ទ*ាំ*ង*អ*ម*្ប*ាល*ន*េ*ះ* *ម*ិ*ន*ត*្រ*ូ*ว*អ*ាប*ត*្ត*ិ* *។* *ជ*ាអ*ន*ា*ណ*ត*ិ*ក*:
មិ*ន*ត*្រ*ូ*ว*ព*្រ*ោ*ះ*ប*ង*្ក*ាប*់* *។* *ម*ា*ន*អ*ង*្គ* ៣ *គ*ឺ **ឧ*ប*ស*ម*្ប*ន*្ន*ត*ា** *អ*ន*ក*ដ*ទ*ៃ*ជ*ា*
*ឧ*ប*ស*ម*្ប*ន*្ន* ១ **អ*ផ*ាសុ*ក*ាម*ត*ា** *ប*្រ*ា*ថ*្ន*ាស*េ*ច*ក*ី*ម*ិ*ន*ស*ប*្ប*ាយ*ដ*ល*
ភិ*ក*ខ*ុ*ន*ោ*ះ* ១ **ក*ុ*ក*្ក*ុ*ច*ឧ*ប*្ប*ាឌ*ំ** *ធ*្វ*ើ*ស*េ*ច*ក*ី*រ*ង*្គ*ៀ*ស*ស*ង*្ស*័*យ*ឲ*្យ*ក*ើ*ត*
ឡើ*ង* *ដ*ូ*ច*ព*ោ*ល*ហ*ើ*យ* ១ *ព*្រ*ម*ដ*ោ*យ*អ*ង*្គ* ៣ *ន*េ*ះ* *ទ*ើ*ប*ត*្រ*ូ*ว*ប*ា*ចិ*ត*្ត*ិ*យ* *។*
*ស*ម*ុ*ដ*្ឋ*ា*ន*ว*ិ*ធ*ីជ*ា*ដ*ើ*ម* *ដ*ូ*ច*ក*ុ*ង*ស*ិ*ក*្ខ*ា*ប*ទ*ជ*ាល*ំ*ដ*ាប*់*ម*ក* *។*

សញ្ចិច្ចសិក្ខាបទ គម្រប់ ៧ ចប់

ឧបស្សុតិសិក្ខាបទ គម្រប់ ៨ សេចក្តីថា ភិក្ខុណា កាលភិក្ខុដទៃ កំពុងឈ្លោះ ប្រកែក ទាស់ទែងគ្នា ហើយលបចាំស្តាប់ថា បើភិក្ខុទាំងនេះ និយាយដូចម្តេច យើងនឹងស្តាប់ ដោយប្រាថ្នានឹងចោទ ហើយដើរទៅ ត្រូវទុក្កដគ្រប់ៗ ជំហាន ។ សូម្បីនៅខាងក្រោយ ដើរប្រញាប់ទៅមុខឲ្យធាប់រហ័ស ឬនៅខាងមុខក្ងែងធ្វើឲ្យយឺតយូរថយ ក្រោយមកក៏ដូចគ្នា ។ ឈរក្នុងទីណាបានឮសំឡេង ឈរស្តាប់ក្នុងទីនោះ ត្រូវបាចិត្តិយ ។ កាលមកកាន់ទីលំនៅភិក្ខុទាំងនោះ បានឮភិក្ខុកំពុងប្រឹក្សាគ្នា ឬភិក្ខុដើរប្រឹក្សាគ្នាមកជិតទីលំនៅរបស់ខ្លួន បានឮគប្បីក្អកគ្រហែម ឬប្រាប់ថាយើងនៅក្នុងទីនេះ ឲ្យភិក្ខុនោះដឹង ។ សូម្បីមិនធ្វើដូច្នេះ សម្ងំស្តាប់ទៅក៏គង់ត្រូវបាចិត្តិយ ។ ក្នុងឧបសម្បន្ន ត្រូវតិកបាចិត្តិយ ។ ក្នុងអនុបសម្បន្ន ត្រូវតិកទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺទៅលបស្តាប់ដោយគិតថា យើងបានឮលោកទាំងនោះ យើងនឹងថយ យើងនឹងវៀរ យើងនឹងអត់ យើងនឹងរម្ងាប់ យើងនឹងដោះខ្លួនចេញដូច្នេះក្តី និងភិក្ខុឆ្លួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មិនត្រូវព្រោះបង្ហាប់ ។ មានអង្គ ៣ គឺ **ឧបសម្បន្នតា** អ្នកដទៃជាឧបសម្បន្ន ១ **ចោទនា-ជិប្ប**ាយោ ប្រាថ្នានឹងចោទ ១ **សវនំ** លបចាំស្តាប់បានឮ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ ជាវេយ្យសត្តសមុដ្ឋាន ជាសិយា-

កិរិយា ត្រូវព្រោះធ្វើ គឺលបស្តាប់ក៏មាន ជាសិយាអកិរិយា ត្រូវព្រោះមិនធ្វើ គឺមិនក្អកគ្រហែមឲ្យគេដឹងក៏មាន ជាសញ្ញាវិមោក្ខ រួចចាកទោសដោយសម្គាល់ ជាសចិត្តក: មានចិត្តកៃ្ងងទើបត្រូវអាបត្តិ ជាលោកវជ្ជ: មានទោសតាមធម្មតាលោក ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត ជាទុក្ខវេទនា ។

ឧបស្សុតិសិក្ខាបទ គម្រប់ ៨ ចប់

កម្មប្បដិញ្ញាតសិក្ខាបទ គម្រប់ ៩ សេចក្តីថា សង្ឆកម្មទាំង ៤ មានអបលោកនកម្មជាដើម សង្ឆធ្វើប្រពៃហើយដោយធម៌ ភិក្ខុណា នៅខាងក្នុងសីមា មិនមកកាន់សង្ឆកម្មនោះដោយកិច្ចណាមួយ ឲ្យតែឆន្ទ: ដើម្បីកម្មនោះមកដល់ភិក្ខុដទៃ លុះកម្មនោះសង្ឆធ្វើហើយដោយធម៌វិន័យ គ្រាក្រោយត្រឡប់តិះដៀលការកសង្ឆ ត្រូវបាចិត្តិយគ្រប់ៗ ពាក្យ ។ ភិក្ខុសង្ស័យក្នុងកម្មជាធម៌ក្តី ឬសម្គាល់ក្នុងកម្មជាធម៌ ថាជាកម្មមិនប្រកបដោយធម៌ក្តី ឬសង្ស័យក្នុងកម្មមិនប្រកបដោយធម៌ក្តី ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុដឹងថាកម្មដែលសង្ឆធ្វើមិនប្រកបដោយធម៌ក្តី ប្រកបដោយពួកក្តី ដល់ភិក្ខុមិនគួរដល់កម្មក្តី ហើយតិះដៀល និងភិក្ខុឆ្ពួតជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជា

អនាណត្តិក: ។ មានអង្គ ៣ គឺ **ធម្មកម្មតា** *កម្មប្រកបដោយធម៌ ១* **ធម្មកម្មន្តិ សញ្ញា** *សម្គាល់ថាកម្មជាធម៌ ១* **ឆន្ទំ ឧត្វា ទីយនំ** *ឲ្យធ្ន:ហើយតិះដៀល ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះជាទុក្ខវេទនា ។*

កម្មប្បដិពាហានសិក្ខាបទ គម្រប់ ៩ ចប់

ឆន្ទំ អទត្វា បក្តមនសិក្ខាបទ គម្រប់ ១០ សេចក្តីថា សង្ឆប្រជុំគ្នាក្នុងសីមានឹងរម្ងាប់អធិករណ៍ ភិក្ខុអ្នកចោទ អ្នកចម្ងើយ សម្តែងរឿងរបស់ខ្លួនៗ ហើយ សង្ឆសន្ទតភិក្ខុអ្នកសាកសួរឡើងហើយ តែនៅមិនទាន់បានសាកសួរ ឬសង្ឆធ្វើសង្ឆកម្មទាំងបួនណាមួយ តាំងញត្តិហើយក្តី កម្មវាចាសង្ឆធ្វើមិនទាន់ចប់ក្តី យ៉ាងនេះឈ្មោះថាពាក្យវិនិច្ឆ័យ (កំពុងប្រព្រឹត្តទៅ) ក្នុងសង្ឆ ។ ភិក្ខុណានៅក្នុងហត្ថបាសសង្ឆ ប្រាថ្នានឹងឲ្យកម្មនោះកម្រើក មិនឲ្យធ្ន:មុន ក្ងែងក្រោកចេញទៅ ។ កាលកំពុងលះហត្ថបាសសង្ឆបរិស័ទ ត្រូវទុក្កដ ។ លុះលះហត្ថបាសហើយ ត្រូវបាចិត្តិយ ។ សង្ស័យក្នុងកម្មជាធម៌ក្តី ឬកម្មមិនជាធម៌សម្គាល់ថាជាធម៌ ឬសង្ស័យក្តី ក្រោកចេញទៅ ទាំងអម្បាលនេះ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាកម្មមិនជាធម៌ក្រោកទៅ មិនត្រូវអាបត្តិ ដឹងថាការជម្លោះវិវាទនឹងមានដល់សង្ឆ ឬសង្ឆនឹងធ្វើកម្ម មិនជាធម៌ ជាពួក និងធ្វើដល់មនុស្សមិនគួរដល់កម្ម ក្រោកចេញទៅក្តី ឬមានជំងឺ ឬក្រោកទៅដោយកិច្ចនៃកិក្ខុឈឺ ឬឧច្ចារៈបស្សាវៈ ឬមិនប្រាថ្នានឹងឲ្យកម្មកម្រើក ឬក្រោកទៅដោយគិតថានឹងត្រឡប់មកវិញក្តី និងកិក្ខុឆ្ពួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មិនត្រូវព្រោះបង្ហាប់ ។ មានអង្គ ៦ គឺ **វិនិច្ឆយកថាយ វត្តមានតា** កំពុងកាត់សេចក្តី ឬធ្វើសង្ឆកម្ម ១ **ធម្មកម្មតា** កម្មនោះជាធម៌ ១ **ធម្មកម្មសញ្ញិតា** ដឹងថាកម្មជាធម៌ ១ **សមានសីមាយ ឋិតត្តា** ឋិតនៅក្នុងសីមាសង្ឆ ១ **សមានសំវាសកតា** ខ្លួនមានសង្វាសស្មើនឹងសង្ឆ ១ **ពោបេតុកាមតាយ ហត្ថបាស-វិជហនំ** ប្រាថ្នានឹងឲ្យកម្មកម្រើកហើយក្រោកទៅលះហត្ថបាសសង្ឆ ១ ព្រមដោយអង្គ ៦ នេះ ទើបត្រូវបាចិត្តិយ ។ ជាសមនុភាសនសមុដ្ឋាន អាបត្តិកើតអំពីកាយវាចាចិត្ត ជាកិរិយាកិរិយៈ ត្រូវអាបត្តិព្រោះធ្វើ និងមិនធ្វើ ជាសញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ទុក្ខវេទនា ។

ឆន្ទំ អទត្វា <u>បក្ខមនសិក្ខាបទ គម្រប់</u> ១០ ចប់

ទព្ធសិក្ខាបទ គម្រប់ ១១ សេចក្តីថា ភិក្ខុណា ព្រមព្រៀងដោយ សង្ឆដែលនៅក្នុងសីមា ឲ្យចីវរដែលគួរវិកប្បជាយ៉ាងតូចឡើងទៅ ដល់ ភិក្ខុដែលសង្ឆសន្ទុតឲ្យជាកត្តុទ្ទេសក:ជាដើមដោយធម៌ គឺភិក្ខុធ្វើការសង្ឆ ដោយប្រពៃ ។ ត្រាក្រោយត្រឡប់តិះដៀលថា ភិក្ខុទាំងអម្បាលនេះ បង្ហោនលាកសង្ឆឲ្យភិក្ខុ តាមគាប់ចិត្ត តាមមិត្ត តាមសម្ងាញ់ ដូច្នេះ ត្រូវបាចិត្តិយគ្រប់ៗ ពាក្យ ។

ទព្ធសិក្ខាបទ គម្រប់ ១១ ចប់

បរិណាមនសិក្ខាបទ គម្រប់ ១២ សេចក្តីថា ភិក្ខុណា ដឹងថាលាក ទាយកបង្ហោនទៅហើយដល់សង្ឆ ដោយវាចាថានឹងថ្វាយសង្ឆ ហើយ បង្ហោនមកដើម្បីបុគ្គល ត្រូវបាចិត្តិយ ។ វិនិច្ឆ័យក្រៅនេះ ដូចបរិណត-សិក្ខាបទក្នុងនិស្សគ្គិយ ប្លែកតែបរិណតសិក្ខាបទ ត្រូវនិស្សគ្គិយបាចិត្តិយ ព្រោះបង្ហោនមកដើម្បីខ្លួន ក្នុងសិក្ខាបទនេះត្រូវតែសុទ្ធិកបាចិត្តិយ ព្រោះ បង្ហោនទៅដើម្បីបុគ្គលដទៃប៉ុណ្ណោះ ។

បរិណាមនសិក្ខាបទ គម្រប់ ១២ ចប់

សហធម្មិកវគ្គ គម្រប់ ៨ ចប់

ភាជវគ្គ គម្រប់ ៩ មាន ១០ សិក្ខាបទ ៖

អន្តេបុរសិក្ខាបទ ជាបឋម សេចក្តីថា ម្ចាស់ផែនដីដែលជាជាតិ

ក្សត្រិយ៍បានមុទ្ធាភិសេក សោយរាជ្យសម្បត្តិជាស្តេចផែនដីហើយ ទាំងព្រះមហេសីផង នៅក្នុងក្រឡាព្រះបន្ទំទាំងពីរព្រះអង្គ អង្គណាមួយមិនទាន់យាងចេញមក ។ ភិក្ខុណា មិនឲ្យទូតទៅក្រាបទូលឲ្យទ្រង់ជ្រាបជាមុន កន្ទងធរណីមេទ្វារលែងក្រឡាព្រះបន្ទំចូលទៅ ។ ក្នុងជំហានជាបឋមត្រូវទុក្កដ ។ ជំហានជាគម្រប់ ២ ត្រូវបាចិត្តិយ ។

អន្តេបុរសិក្ខាបទ ជាបឋម ចប់

រតនសិក្ខាបទ គម្រប់ ២ សេចក្តីថា ភិក្ខុណា រើសយកឯង ឬឲ្យអ្នកដទៃរើសយក នូវរតន:មានកែវមុត្តាជាដើម ឬរបស់ដែលគេសន្មតថាជារតន: គឺគ្រឿងប្រើប្រាស់ណាមួយ នៃមនុស្សដែលភ្ជួចធ្លាក់នៅលើផែនដី ជាទីដទៃ ក្រៅអំពីអារាម និងក្រៅទីសម្ងាត់អាស្រ័យនៅរបស់ខ្លួន ត្រូវបាចិត្តិយ ។ រើសយកខ្លួនឯង ឬឲ្យអ្នកដទៃរើសយកនូវមាសនិងប្រាក់ដើម្បីខ្លួន ត្រូវនិស្សគ្គិយបាចិត្តិយ ។ ដើម្បីសង្ឆ ឬគណ: ឬបុគ្គល ឬចេតិយ ឬនវកម្ម ត្រូវទុក្កដ ។ ក្នុងកែវមុត្តាជាដើមដ៏សេសនោះ បើរើសដើម្បីខ្លួន ឬអ្នកដទៃមានសង្ឆជាដើម ត្រូវទុក្កដទាំងអស់ ។ កប្ប-ិយវត្ថុ ឬអកប្ប-ិយវត្ថុ ដោយហោចទៅ សូម្បីតែរបស់មាតា បើភិក្ខុទុកដាក់ដូចមនុស្សរក្សាឃ្លាំង ត្រូវបាចិត្តិយ ។ ធ្វើរបស់ដូច្នោះ ឲ្យជារបស់ខ្លួនហើយទើបទុកដាក់គួរ ។ បើគ្រហស្ថពោលថាលោកចូរជួយទុកដាក់

របស់នេះ គប្បីហាមឃាត់ដោយពាក្យថាមិនគួរ ។ បើគេខឹងចោលរបស់
នោះហើយទៅ ឈ្មោះថាជាកង្វល់នៃភិក្ខុ ភិក្ខុគប្បីទុកដាក់ចុះ ។ ជាង
ឈើឬខ្ទុំរាជការ ធ្វើការក្នុងវត្ត គេផ្ញើគ្រឿងឧបករណ៍ ឬទីដំណេកណា
មួយ ឲ្យជួយទុកដាក់ឲ្យផង ។ កុំគប្បីធ្វើដោយយល់មុខ ដោយខ្ជាច ។
គួរសម្តែងទីទុកដាក់ឲ្យ ។ សូម្បីខាងក្នុងអាវាម ឬខាងក្នុងទីសម្នាក់
អាស្រ័យរបស់ខ្លួនណាមួយ ដែលគេមានសេចក្តីរង្កៀសថាប្រហែលជា
ភិក្ខុ ឬសាមណេរ នឹងរើសយករបស់ដែលធ្លាក់ ។ បើក្នុងទីដូច្នោះ គប្បី
រើសយកឯង ឬឲ្យអ្នកដទៃរើសយក ធ្វើនូវការចំណាំ ហើយទុកដាក់ ។
គប្បីប្រាប់ថារបស់អ្នកណាបាត់ អ្នកនោះចូលមកយកចុះ ។ បើអ្នកណា
មក គប្បីសួរអ្នកនោះថា របស់អ្នកយ៉ាងដូចម្តេចដែលបាត់ទៅនោះ ។
បើគេប្រាប់ត្រូវតាមចំណាំសោត ក៏គប្បីឲ្យ ។ បើគេប្រាប់មិនត្រូវសោត
គប្បីពោលនឹងគេថា អ្នកចូររកខ្លួនឯងចុះ ។ បើភិក្ខុនឹងទៅចាកអាវាសនោះ
គប្បីផ្ញើទុកក្នុងដៃភិក្ខុដ៏សមគួរ ។ កាលបើភិក្ខុដូច្នោះមិនមាន គប្បីផ្ញើទុក
ក្នុងដៃគហបតីដែលមានសភាពដ៏សមគួរ ហើយសឹមទៅ ។ ក៏ឯភិក្ខុណា
មិនបានចៀសទៅ ចាកអាវាស និងមិនបានឃើញម្ចាស់របស់ ភិក្ខុនោះ
គប្បីយករបស់នោះឲ្យគេធ្វើសេនាសនៈ ឬចេតិយ ឬស្រះបោក្ខរណី
ដែលជារបស់ថាវរៈ ។ បើកន្ធងកាលយូរទៅ ម្ចាស់របស់មកសោត គប្បី
ចង្អុលបង្ហាញរបស់ ថាវរៈនោះ ថាអ្នកចូរអនុមោទនាយកចុះ ។ បើម្ចាស់

របស់មិនបានអនុមោទនា ហើយគេទារយកសោត គប្បីញ៉ាំងអ្នកដទៃ ឲ្យទទួលយកនូវរបស់ថាវរៈនោះឲ្យជារបស់ខ្លួន ហើយឲ្យអ្នកនោះសង់ របស់ដែលគេទារយកនោះ ។ ក្នុងទីដែលព្រះពុទ្ធជាអម្ចាស់ទ្រង់អនុញ្ញាត ឲ្យរើសទុកដាក់ ភិក្ខុមិនបានរើសទុកដាក់ ព្រោះមិនអើពើត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺរបស់គេធ្លាក់ក្នុងទីដែលព្រះពុទ្ធជា អម្ចាស់ទ្រង់អនុញ្ញាត ភិក្ខុរើសទុកដាក់ និងរបស់ណាដែលជាអាមាសៈ គួរពាល់ត្រូវបាន រើសយករបស់នោះដោយស្និទ្ធស្នាល ឬកាន់យកជា របស់ខ្ញី ឬកាន់យកដោយបង្ហុកូលសញ្ញា និងភិក្ខុធ្ជតជាដើម ទាំង អម្បាលនេះ មិនត្រូវអាបត្តិ ។ ជាសាណត្តិកៈ មានអង្គ ៤ គឺ **អនុញ្ញា-តការណំ** *មិនមែនហេតុដែលព្រះពុទ្ធជាអម្ចាស់ទ្រង់អនុញ្ញាត ១* **បរសន្តកតា** *ជារបស់អ្នកដទៃ ១* **វិស្សាសគ្គាហាបជ្ជុកូល-សញ្ញានំ អកាវេ** *មិនមានការកាន់យកដោយវិស្សាសៈ និងបង្ហុ-កូលសញ្ញា ១* **ឧគ្គហាណំ វ ឧគ្គហាបនំ វ** *រើសយកឯង ឬឲ្យ អ្នកដទៃរើសយករបស់នោះ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចសញ្ចរិត្តសិក្ខាបទ ។*

រតនសិក្ខាបទ គម្រប់ ២ ចប់

វិកាលគាមប្បវេសនសិក្ខាបទ គម្រប់ ៣ សេចក្ដីថា ភិក្ខុណាមួយ មិនលាភិក្ខុដទៃដែលមាននៅ ដូចពោលហើយក្នុងចារិត្តសិក្ខាបទ ហើយចូលទៅកាន់ស្រុក ក្នុងវេលាវិកាលគឺតាំងអំពីថ្ងៃជ្រៃពីត្រង់ទៅ ដរាបលុះដល់អរុណរះឡើងថ្មី ។ បើស្រុកមានរបង ឬកំផែង កន្ទងរបង ឬកំផែងចូលទៅ ។ បើស្រុកមិនមានរបង ឬកំផែង កន្ទងឧបចារៈស្រុកទៅ ។ ក្នុងជំហានជាបឋម ត្រូវទុក្កដ ។ ជំហានគម្រប់ ២ ត្រូវបាចិត្តិយ រៀងតែមានកិច្ចប្រញាប់ គឺសព្រហ្មចារី ភិក្ខុផងគ្នាពស់ចឹកជាដើម ។ សូម្បីភិក្ខុច្រើនគ្នានឹងចូលទៅស្រុកដោយកិច្ចណាមួយ ភិក្ខុទាំងអស់នោះក៏គប្បីលាគ្នានឹងគ្នា បើកិច្ចក្នុងស្រុកនោះមិនទាន់សម្រេច នឹងទៅស្រុកដទៃ ការដែលត្រូវលាទៀតមិនមាន ។ កាលបើរម្ងាប់ឧស្សាហ៍នោះហើយដើរទៅវត្ត ប្រាថ្នានឹងទៅស្រុកដទៃក្នុងចន្លោះផ្លូវ ត្រូវលាដោយពិត ។ ភិក្ខុធាន់ក្នុងផ្ទះ ត្រកូលឬក្នុងពោងធាន់ ហើយប្រាថ្នានឹងត្រាច់ទៅបិណ្ឌបាតប្រេង ឬសប្បិ បើមានភិក្ខុនៅខាងឆ្វេង ឬខាងស្តាំ គប្បីលា កាលបើភិក្ខុមិនមាន គប្បីគិតថាមិនមាន ហើយទៅចុះ ។ លុះចុះកាន់ថ្នល់ហើយ សូម្បីឃើញភិក្ខុ ការដែលត្រូវលាមិនមាន ។ ក៏ឯផ្លូវណាទៅកណ្ដាលស្រុក បើភិក្ខុដើរទៅតាមផ្លូវនោះ ហើយមានចិត្តគិតថា នឹងត្រាច់ទៅបិណ្ឌបាតប្រេងជាដើមកើតឡើង ឃើញភិក្ខុខាងឆ្វេង ឬខាងស្តាំ គប្បីលា បើមិនចៀសចេញអំពីផ្លូវដើរទៅសោត ការដែលត្រូវលាមិនមាន ។ ពាក្យលាថាដូច្នេះ

វិកាលេ គាមប្បវេសនំ អាបុច្ឆាមិ ប្រែថាខ្ញុំលាចូលទៅក្នុងស្រុក ក្នុងវេលាវិកាល ។ ក្នុងវេលាវិកាលត្រូវតិកបាចិត្តិយ ។ ក្នុងកាលសម្គាល់ថា វិកាល ឬសង្ស័យ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាវេលាព្រឹក មានការប្រញាប់ ឬលាភិក្ខុដែលមាននៅ ឬភិក្ខុមិនមានមិនលាចូលទៅ ឬទៅកាន់អារាមក្នុងចន្ទោះស្រុក និងទីលំនៅនៃនាងភិក្ខុនី ទីលំនៅតិរ្ថិយ ឬទៅកាន់ទីធាន់ ហើយត្រឡប់វិញ ឬដើរទៅតាមផ្លូវដែលមាននៅក្នុងស្រុក ឬមានអន្តរាយ និងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មានអង្គ ៣ គឺ **សន្តំ ភិក្ខុំ អនាបុច្ឆនា** មិនលាភិក្ខុដែលមាននៅ ១ **អនុញ្ញាតការណាភាវោ** មិនមានហេតុដែលព្រះពុទ្ធជាអម្ចាស់ទ្រង់អនុញ្ញាត ១ **វិកាលេ គាមប្បវេសនំ** ចូលទៅស្រុកក្នុងវេលាវិកាល ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើមដូចបឋមកឋិនសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាកិរិយាកិរិយ:ប៉ុណ្ណោះ ។

វិកាលគាមប្បវេសនសិក្ខាបទ គម្រប់ ៣ ចប់

សូចិឃរសិក្ខាបទ គម្រប់ ៤ សេចក្តីថា ភិក្ខុណា ធ្វើឯង ឬប្រើអ្នកដទៃឲ្យធ្វើ នូវបំពង់ម្ជុល ដ៏ហើយដោយឆ្អឹង ឬដោយក្ងុក ឬស្ពែង ក្នុង

ប្រយោគដែលធ្វើ ត្រូវទុក្កដ ។ ធ្វើហើយបានមក ត្រូវកេទនកបាចិត្តិយ ។ ត្រូវទម្លាយបំពង់ម្ជុលនោះចេញជាមុន ហើយទើបសម្តែងអាបត្តិនោះ ជ្រាក់ ។ ជាចតុក្កបាចិត្តិយ គឺខ្លួនធ្វើមិនទាន់ហើយ ហើយធ្វើបង្ហើយ ដោយខ្លួនឯងក្តី ឬញ្ចាំងអ្នកដទៃឲ្យធ្វើ ឲ្យហើយស្រេចក្តី អ្នកដទៃធ្វើមិនទាន់ហើយ ខ្លួនយកមកធ្វើឲ្យហើយក្តី ញ្ចាំងអ្នកដទៃឲ្យបង្ហើយក្តី ទាំង ៤ យ៉ាងនេះ ណាមួយ ហើយបានមក ត្រូវបាចិត្តិយ ។ ធ្វើឯង ឬប្រើអ្នកដទៃឲ្យធ្វើ ដើម្បីអ្នកដទៃក្តី និងអ្នកដទៃធ្វើហើយ ខ្លួនបានមកបរិភោគ ប្រើប្រាស់ក្តី ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺធ្វើឡេវក្ដុំ និងធ្នូឈើពំនួតក្ងើង ក្រវិលវត្តពន្ធ បំពង់ថ្នាំក្អែក និងចង្កើសថ្នាំក្អែក និងមៀនកាំបិត និងរបស់សម្រាប់ជូតទឹក ឬធម្មក្រក ទាំងអម្បាលនេះ ណាមួយ ដ៏ហើយដោយធ្នើងជាដើមក្តី និងកិក្ខុធ្លួតជាដើម មិនត្រូវអាបត្តិ ។ ជាសាណត្តិក: មានអង្គ ៣ គឺ **សូចិយរតា** បំពង់ម្ជុល ១ **អដ្ឋិមយាឌិតា** ដ៏ហើយដោយធ្នើងជាដើម ១ **អត្តនោ អត្ថាយ ការណំ វ ការាបេត្វា វ បដិលាភো** ធ្វើឯងឬប្រើអ្នកដទៃឲ្យធ្វើដើម្បីខ្លួន ហើយបានមក ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចសញ្ចរិត្តសិក្ខាបទ ។

សូចិយរសិក្ខាបទ គម្រប់ ៤ ចប់

ឆេទនកសិក្ខាបទ គម្រប់ ៥ សេចក្ដីថា ភិក្ខុកាលនឹងធ្វើឯង ឬប្រើអ្នកដទៃឲ្យធ្វើ នូវគ្រែ ឬតាំង គប្បីធ្វើឲ្យមានជើងកម្ពស់ ៨ ផ្ទាប់ ដោយផ្ទាប់ព្រះសុគត រាស់ពីត្រឹមមេគ្រែខាងក្រោមចុះទៅ (បើធ្វើ) ជើងឲ្យខ្ពស់ជាងប្រមាណនោះ ត្រូវឆេទនកបាចិត្តិយ ។ ត្រូវកាត់ជើងឲ្យលួមប្រមាណមុន ទើបសម្ដែងអាបត្តិជ្ងាក់ តាំងនោះប្រវែងមិនវែងពេកណាស់ដូចគ្រែ មិនបួនជ្រុងដូចអាសន្ទិ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺឲ្យគេធ្វើឲ្យលួមប្រមាណ ឬបានមកលើសប្រមាណ តែកាត់ចេញឲ្យលួមប្រមាណ និងបង្ក្ដប់ចុះក្នុងផ្ទៃឲ្យសល់នៅលួមប្រមាណ ឬធ្វើជាពិតាន ចងជារានប្រើប្រាស់ក្ដី និងកិក្ខុឆ្ពិតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ មានអង្គ ២ គឺ **បមាណាតិក្កន្តមញ្ចបីឋតា** គ្រែ ឬតាំង កន្ទងប្រមាណ ១ **អត្តនោ អត្ថាយ ការណំ វ ការាបេត្វា វ ឧដ្ឋិលាកោ** ធ្វើឯងឬឲ្យអ្នកដទៃធ្វើ ដើម្បីខ្លួនហើយបានមក ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ វិនិច្ឆ័យក្រៅនោះដូចសូចិយសិក្ខាបទ ។

ឆេទនកសិក្ខាបទ គម្រប់ ៥ ចប់

តូលោនទ្ធសិក្ខាបទ គម្រប់ ៦ សេចក្ដីថា ភិក្ខុណា ធ្វើឯង ឬប្រើអ្នកដទៃឲ្យធ្វើ នូវគ្រែ ឬតាំង ញាត់ដោយសំឡីខាងក្នុង ត្រូវឧទ្ទាលនក-បាចិត្តិយ ត្រូវរើសំឡីចេញមុន ទើបសម្ដែងអាបត្តិជ្ងាក់ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺកិក្ខុធ្វើជាសំពត់អាយោគ និងវត្ត-ពន្ធចង្កេះ និងខ្សែយោគបាត្រ ថង់បាត្រ សំពត់តម្រងទឹក ខ្ទើយទាំងអម្បាលនេះញាត់ដោយសំឡី មិនមានទោស ។ ត្រៃ តាំង មនុស្សដទៃធ្វើញាត់ដោយសំឡី បានមកវើយកសំឡីចេញប្រើប្រាស់ក្តី និងកិក្ខុធ្លួតជាដើម មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មានអង្គ ២ គឺ **តូលោនទ្ធ-មញ្ចបីបតា** ត្រៃ ឬតាំង ញាត់ដោយសំឡី ១ **អត្តនោ អត្តាយ ការណំ វ ការាបេត្វា វ បដិលាភោ** ធ្វើឯង ឬប្រើអ្នកដទៃឲ្យធ្វើដើម្បីខ្លួនហើយបានមក ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ វិនិច្ឆ័យក្រៅនោះ គប្បីដឹងដោយន័យដូចពោលហើយក្នុងសិក្ខាបទមុននោះចុះ ។

តូលោនទ្ធសិក្ខាបទ គម្រប់ ៦ ចប់

និសីទនសិក្ខាបទ គម្រប់ ៧ សេចក្តីថា ភិក្ខុណា ធ្វើឯង ឬប្រើអ្នកដទៃ ឲ្យធ្វើ នូវនិសីទន: គឺសំពត់រងបង្គុយមានជាយ គប្បីធ្វើឲ្យប្រកបដោយប្រមាណ ប្រមាណនោះ បណ្តោយ ២ ចំអាម ទទឹង ១ ចំអាមកន្ទុះជាយ ១ ចំអាម ដោយចំអាម ព្រះសុគត បើធ្វើទទឹងបណ្តោយ ឲ្យលើសប្រមាណនោះទៅ ត្រូវឆេទនកបាចិត្តិយ ។ កាត់ចេញឲ្យល្មមប្រមាណមុន ទើបសម្តែងអាបត្តិធ្លាក់ ។ និសីទន:នោះ ជាឈ្មោះបរិក្ខារ រងបង្គុយ

១ យ៉ាងមានជាយ សម្រាប់ក្រាលដូចសន្ទ្ធ ដែលគេពុះចូលពីរកន្ទ្ធ ចំនួនមួយចំអាម ព្រះសុគត នៅត្រង់ទីបំផុតម្ខាង ធ្វើឲ្យទៅជា ៣ ជាយ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺធ្វើឲ្យលួមប្រមាណ ឬថយជាង ប្រមាណ ឬអ្នកដទៃធ្វើហួសប្រមាណ បានមកកាត់ចេញឲ្យលួម ប្រមាណប្រើប្រាស់ និងយកធ្វើពិតានជាដើម ណាមួយក្តី និងកិក្ខុធ្ងត ជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ មានអង្គ ២ គឺ **និសីឌនស្ស បមាណាតិក្កន្តតា** សំពត់និសីទន:នោះកន្ទ្ធងប្រមាណ ១ **អត្តនោ អត្ថាយ ការណំ វ ការាបេត្វា វ បដិលាភো** ធ្វើឯង ឬប្រើអ្នកដទៃឲ្យធ្វើ ហើយបានមក ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវ បាចិត្តិយ ។ វិនិច្ឆ័យក្រៅនោះ គប្បីដឹងដោយន័យដូចពោលហើយ ។

និសីទនសិក្ខាបទ គម្រប់ ៧ ចប់

កណ្ដុបដិច្ចាទិសិក្ខាបទ គម្រប់ ៨ សេចក្ដីថា ភិក្ខុណា ធ្វើឯង ឬ ប្រើអ្នកដទៃឲ្យធ្វើ នូវសំពត់បិទបូស គប្បីធ្វើឲ្យប្រកបដោយប្រមាណ ប្រមាណនោះបណ្ដោយ ៤ ចំអាម ទទឹង ២ ចំអាម ដោយចំអាមព្រះសុគត ធ្វើទទឹងនិងបណ្ដោយ ឲ្យលើសប្រមាណនោះទៅ ត្រូវឆេទនកបាចិត្តិយ ។

កាត់ចេញឲ្យល្មមប្រមាណជាមុន ទើបសម្តែងអាបត្តិធ្លាក់ ។ សំពត់បិទ
បូសនេះ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតដល់ភិក្ខុដែលកើតបូសនិងស្វាកស្នាម
កមរលាយ ខាងក្រោមតាំងពីក្រោមផ្ទិតចុះទៅ ខាងលើតាំងពីជង្គង់
ឡើងមក ដើម្បីនឹងបិទស្វាកស្នាមទាំងអម្បាលនោះ ។

កណ្ឌ្ការបដិច្ឆាទិសិក្ខាបទ គម្រប់ ៨ ចប់

វស្សិកសាដិកសិក្ខាបទ គម្រប់ ៩ សេចក្តីថា ភិក្ខុណា ធ្វើឯង ឬប្រើ
អ្នកដទៃឲ្យធ្វើ នូវវស្សិកសាដិកា គឺសំពត់ងូតទឹកភ្លៀង គប្បីធ្វើឲ្យប្រកប
ដោយប្រមាណ ប្រមាណនោះបណ្តាយ ៦ ចំអាមទទឹង ២ ចំអាមកន្ទុះ
ដោយចំអាមព្រះសុគត ធ្វើទទឹងនិងបណ្តាយឲ្យលើសប្រមាណនោះ
ត្រូវឆេទនកបាចិត្តិយ ។ កាត់ចេញឲ្យល្មមប្រមាណជាមុន ទើបសម្តែង
អាបត្តិធ្លាក់ ។

វស្សិកសាដិកសិក្ខាបទ គម្រប់ ៩ ចប់

នន្ទសិក្ខាបទ គម្រប់ ១០ សេចក្តីថា ភិក្ខុណា ធ្វើឯង ឬប្រើអ្នកដទៃ
ឲ្យធ្វើនូវចីវរធំ ប្រមាណប៉ុនចីវរព្រះសុគត ឬលើសជាងនោះ ត្រូវឆេទ-
នកបាចិត្តិយ ។ កាត់ចេញឲ្យខ្វីជាងប្រមាណចីវរព្រះសុគត ទើបសម្តែង

អាបត្តិធ្លាក់ ប្រមាណនៃចីវរព្រះសុគតនោះ បណ្តោយ ៩ ចំអាម ទទឹង ៦ ចំអាមដោយចំអាមព្រះសុគត ។ វិនិច្ឆ័យទាំងពួងក្រៅនោះ ក្នុងសិក្ខាបទទាំង ៣ នេះ គប្បីដឹងដោយន័យដូចពោលហើយក្នុងនិសី-ទនសិក្ខាបទនោះចុះ ។

នន្ទសិក្ខាបទ គម្រប់ ១០ ចប់

រាជវគ្គ គម្រប់ ៩ ចប់

ប្រមាណនៃចំអាមព្រះសុគត

សម្តែងប្រមាណតាមគម្ពីរសុគតវិទត្ថិវិធានបករណៈ ចំអាមព្រះ

សុគតនោះ ១៦ ធ្នាប់ និង២ អនុក្បៀសនៃជាងឈើសព្វថ្ងៃនេះ $\begin{cases} ០ \\ ០ \\ ១ \\ ០ \\ ២ \end{cases}$ ប៉ុណ្ណោះ

ជាសុគតិវិទត្ថិ ១ ។

ជើងគ្រែ ជើងតាំង ប្រវែង ១០ ធ្នាប់ និង ៣ ក្បៀស នៃជាងឈើ សព្វថ្ងៃនេះ ។

សំពត់និសីទនៈ បណ្តោយ ១ ហត្ថ ៨ ធ្នាប់ និង ១ ក្បៀស ទទឹង ១ ហត្ថ និង ៣ អនុក្បៀស ជាយ ១ ចំអាម ៤ ធ្នាប់ និង ២ អនុក្បៀស នៃជាងឈើសព្វថ្ងៃនេះ ។

សំពត់បិទបូស បណ្តោយ ២ ហត្ថ ១ ចំអាម ៤ ធ្នាប់ ២ ក្បៀស ទទឹង ១ ហត្ថ ៨ ធ្នាប់ ១ ក្បៀស នៃជាងឈើសព្វថ្ងៃនេះ ។

សំពត់ងូតទឹកក្បៀង បណ្ដោយ ៤ ហត្ថ ៣ ក្បៀស ទទឹង ១ ហត្ថ ១ ចំអាម ៤ ជ្ជាប់ និង ១ ក្បៀស និង ១ អនុក្បៀស នៃជាងឈើសព្ទ ថ្ងៃនេះ ។

សំពត់សុគតចីវរ បណ្ដោយ ៦ ហត្ថ ១ ជ្ជាប់ និង ២ អនុក្បៀស ទទឹង ៤ ហត្ថ ៣ ក្បៀស នៃជាងឈើសព្ទថ្ងៃនេះ ។

ក្បៀសមួយបែងជា ៤ ចំណែក ចំណែកមួយឈ្មោះថាអនុក្បៀស ។

បាចិត្តិយុទ្ធេស ចប់

ចាដិទេសនិយុទ្ធេស

ពណ៌នាអំពីសិក្ខាបទនៃបាដិទេសនិយាបត្តិ ។ បាដិទេសនិយាបត្តិ មាន ៤ សិក្ខាបទ ៖

សិក្ខាបទ ជាបឋម សេចក្ដីថា នាងភិក្ខុនី បានឧបសម្បទាក្នុងឧក-តោសង្ឆ មិនមែនជាញាតិ នៅក្នុងលង្វែកភូមិ មានច្រកជាដើម ប្រគេនខាទនីយ:ដោយដៃខ្លួន ភិក្ខុណានៅក្នុងស្រុក ឬនៅក្នុងទីដទៃក្ដី ទទួលអំពីដៃនាងភិក្ខុនីនោះដោយដៃខ្លួន ដើម្បីនឹងធាន់ ត្រូវទុក្កដព្រោះទទួល ។ លេបចូលទៅត្រូវអាបត្តិបាដិទេសនីយ: គ្រប់ភារ:ដែលលេប ។

សិក្ខាបទ ជាបឋម ចប់

សិក្ខាបទ គម្រប់ ២ សេចក្តីថា ភិក្ខុទាំងឡាយច្រើនរូប ទាយក និមន្តដោយភោជនទាំង ៥ ណាមួយ ទៅធាន់ក្នុងត្រកូល ។ ក្នុងត្រកូលនោះ បើមានភិក្ខុនីមកតឿនទាយក ឲ្យថែមសម្ង ថែមបាយ ដល់ភិក្ខុតាមមិត្រ តាមសម្ងាញ់ ភិក្ខុទាំងឡាយគប្បីបណ្តេញនាងភិក្ខុនីនោះ ឲ្យទៅសិន ទម្រាំនឹងធាន់ហើយ សូម្បីតែភិក្ខុមួយអង្គបណ្តេញចេញ ក៏គួរ បើមិនបណ្តេញចេញទេ លុះភិក្ខុទាំងឡាយទទួលអាមិស ដើម្បីនឹងធាន់ ត្រូវទុក្កដ ព្រោះទទួល ។ លេបចូលទៅត្រូវបាដិទេសនីយ: គ្រប់វារៈដែលលេប ។

សិក្ខាបទ គម្រប់ ២ ចប់

សិក្ខាបទ គម្រប់ ៣ សេចក្តីថា ត្រកូលណា ដែលសង្ឆឲ្យសេខសម្មតិ ថាជាសេខត្រកូល ដោយញត្តិទុតិយកម្មវាចាហើយ ភិក្ខុណា ដែលគេមិនទាន់បាននិមន្តជាមុន ហើយជាភិក្ខុមិនមានជំងឺ បើទៅកាន់ឧបចារៈផ្ទះ ទទួលអាមិសក្នុងសេខត្រកូលនោះ ត្រូវទុក្កដ ព្រោះទទួល ។ ទទួលហើយធាន់ក្នុងទីណាមួយ ត្រូវបាដិទេសនីយ: គ្រប់វារៈដែលលេប ។

សិក្ខាបទ គម្រប់ ៣ ចប់

សិក្ខាបទ គម្រប់ ៤ សេចក្ដីថា អារញ្ញកសេនាសនៈ គឺវត្ថុក្នុងព្រៃណា ប្រកបដោយសេចក្ដីរង្គៀសនិងភ័យ ដូចពោលហើយក្នុងសាសង្គ៌សិក្ខា-បទ ភិក្ខុណានៅក្នុងសេនាសនៈដូច្នោះ កាលបើយាវកាលិក គឺខាទនីយៈ ភោជនីយៈណា ដែលស្ត្រី បុរស គ្រហស្ថ និងបព្វជិត ណាមួយ នៅ មិនបានចូលមកក្នុងអាវាម ឬឧបចារៈនៃអាវាម ប្រាប់ឲ្យដឹងច្បាស់ជាមុន ថា ត្រកូលឈ្មោះនេះ គេនឹងនាំខាទនីយៈភោជនីយៈ មកប្រគេន ដូច្នេះ ភិក្ខុមិនបានប្រាប់ឲ្យគេដឹងជាមុន ថាអន្តរាយ គឺ ចោរកំណាចជា ដើមមាននៅដូច្នេះ បើគេនាំយកខាទនីយៈ ភោជនីយៈមក ភិក្ខុមិន មានជំងឺ ទទួលខាទនីយៈ ភោជនីយៈដោយដៃខ្លួន ខាងក្នុងអាវាម ឬឧបចារៈនៃអាវាម ដើម្បីនឹងធាន់ត្រូវទុក្កដព្រោះទទួល ។ លេបចូល ទៅត្រូវបាដិទេសនីយៈ គ្រប់រាវៈដែលលេប ។ ភិក្ខុទទួលកាលិក មាន យាមកាលិកជាដើម ដើម្បីជាអាហារ ឬលេបចូលទៅ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុប្រាប់ឲ្យដឹងដូច្នោះ សម្គាល់ថា មិនបានប្រាប់ឲ្យដឹងក្ដី សង្ស័យក្ដី ឬសម្គាល់ថាប្រាប់ឲ្យដឹងហើយក្ដី ឈឺក្ដី និងបរិភោគនូវខាទនីយៈភោជនីយៈ ដែលទាយកនាំមកដោយហេតុដែល ខ្លួនប្រាប់ឲ្យដឹងក្ដី និងបរិភោគរបស់ដែលសល់អំពីភិក្ខុឈឺក្ដី និងបរិភោគ វត្ថុមានមើមឈើ និងផ្ទៃឈើជាដើម ដែលខ្លួនទទួលខាងក្រៅអាវាមក្ដី

បរិភោគកាលិកណាមួយ មានយាមកាលិកជាដើម ដែលខ្លួនបានហើយ ក្តី និងភិក្ខុឆ្លួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ សិក្ខាបទនេះ មានអង្គ ៧ គឺ **យថាវុត្តអារញ្ញកសេនាសនតា** *សេនាសនៈ នៅក្នុងព្រៃដូចពោលហើយ ១* **យាវកាលិកស្ស អតត្តជាត-កតា** *យាវកាលិកមិនបានកើតក្នុងទីនោះ ១* **អតិលាឆតា** *មិនមានជំងឺ ១* **អតិលាឆាវសេសកតា** *យាវកាលិកមិនជាសំណល់អំពីភិក្ខុឈឺ ១* **អប្ឋដិសំវិទិតតា** *របស់នោះគឺគេមិនបានប្រាប់ឲ្យដឹង (ជាមុន) ១* **អជ្ឈារាមេ បដិក្ខហណំ** *ទទួលក្នុងអារាម ១* **អជ្ឈោ-ហរណំ** *លេបចូលទៅ ១ ព្រមដោយអង្គ ៧ នេះ ទើបត្រូវអាបត្តិបាដិ-ទេសនិយៈ ។ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិនសិក្ខាបទ ប្លែកតែ សិក្ខាបទនេះ ជាកិរិយាកិរិយៈ ត្រូវព្រោះធ្វើនិងមិនធ្វើ គឺភិក្ខុធ្វើនូវការទទួលយាវកាលិក និងមិនធ្វើនូវការប្រាប់រឿងឲ្យគេដឹងជាមុន ។*

សិក្ខាបទ គម្រប់ ៤ ចប់

អាបត្តិបាដិទេសនីយៈទាំង ៤ សិក្ខាបទនេះ ពាក្យសម្តែងក្នុងខាងដើមថា **ការយ្ហំ អាវុសោ[១] ឆម្ចំ អាបជ្ជិ[២] អសប្ឋាយំ ចាដិទេសនីយំ តំ បដិទេសេមិ[៣]** *។*

---

(១) បើភិក្ខុខ្វីវស្សា សម្តែងអាបត្តិនឹងភិក្ខុចាស់វស្សាជាងខ្លួន គប្បីថា **ភន្តេ** ជួស **អាវុសោ** ។ បើភិក្ខុច្រើនរូបត្រូវអាបត្តិជាមួយដូចក្នុងសិក្ខាបទទីពីរថា (២) **អាបជ្ជិម្ហា** ជួស **អាបជ្ជិ** ។ (៣) **បដិទេសេម** ជួស **បដិទេសេមិ** ។

ប្រៃថា ខ្ញុំត្រូវហើយនូវអាបត្តិឈ្មោះបាដិទេសនីយ: មិនជាទីសប្បាយ ដែលព្រះពុទ្ធទ្រង់តិះដៀល ខ្ញុំសម្តែងនូវអាបត្តិនោះ ។ ពាក្យសួរនិង ពាក្យទទួលតទៅ ដូចពាក្យសម្តែងអាបត្តិដទៃ ។ ។

បាដិទេសនីយុទ្ទេស ចប់

សេខិយុទ្ទេស

ពណ៌នាអំពីសេខិយវត្ត វត្តដែលបពូជិតគប្បីសិក្សាឲ្យដឹងជាមុន បើមិនសិក្សាឲ្យដឹង ឬដឹងហើយតែមិនបានបដិបត្តិតាម ត្រូវអនាទរិយ-ទុក្កដ គឺអាបត្តិទុក្កដ ព្រោះមិនអើពើ ។

សេខិយវត្តនោះ ចែកជា ៤ ពួក គឺពួកទី ១ ឈ្មោះសារុប្ប: ប្រកប ដោយការបដិបត្តិសមគួរដល់សមណ:, ពួកទី ២ ឈ្មោះកោជនប្បដិសំយុត្ត ប្រកបដោយកោជន, ពួកទី ៣ ឈ្មោះធម្មទេសនាបដិសំយុត្ត ប្រកប ដោយធម្មទេសនា, ពួកទី ៤ ឈ្មោះបកិណ្ណក: ពោលអំពីកិច្ចផ្សេងៗ បន្ទិចបន្ទួច ។

ពួកទី ១ ឈ្មោះសារុប្ប មាន ២៦ សិក្ខាបទ ៖

សិក្ខាបទ ជាបឋម សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងស្ងៀក ឲ្យជាបរិមណ្ឌលដូច្នេះ ស្ងៀកខាងលើបិទមណ្ឌលផ្ចិត

ខាងក្រោមបិទមណ្ឌលជង្គង់ គឺស្បៃកស្បង់ឲ្យស្រុងចុះទៅខាងក្រោម អំពីជង្គង់ប្រមាណ ៨ ផ្ទាប់ ស្បៃកដូច្នេះ ឈ្មោះថាស្បៃកជាបរិមណ្ឌល កាលបើមិនស្បៃកដូច្នេះ ស្បៃកឲ្យស្ទុយចុះទៅខាងមុខ ឬខាងក្រោយ ដោយសេចក្តីមិនអើពើ ត្រូវអនាទរិយទុក្កដ ។

សេខិយវត្តនេះ ក្នុងសិក្ខាបទទាំងពួង ត្រូវតែអាបត្តិទុក្កដមួយជំពូក ប្រភេទនៃអាបត្តិដទៃមិនមាន ។ ភាវៈដែលមិនត្រូវអាបត្តិក្នុងសិក្ខាបទ នេះមាន ៧ យ៉ាងគឺ ភិក្ខុមិនក្ងែង មិនមានសតិ មិនដឹងខ្លួន មានជំងឺ មានអន្តរាយផ្សេងៗ ភិក្ខុឆ្កួត ភិក្ខុដើមបញ្ញត្តិ ទាំងអម្បាលនេះ មិនត្រូវ អាបត្តិ ។ មិនក្ងែងនោះ គឺគិតថានឹងស្បៃកឲ្យជាបរិមណ្ឌលប្រាកដ តែ ភ្ជាត់ទៅជាស្បៃកមិនបរិមណ្ឌល ដូច្នេះឈ្មោះថាមិនក្ងែង មិនត្រូអាបត្តិ ភិក្ខុបញ្ជូនចិត្តទៅកាន់ទីដទៃ ស្បៃកមិនជាបរិមណ្ឌល ដូច្នេះឈ្មោះថាមិន មានសតិ ជាអនាបត្តិ ភិក្ខុមិនដឹងនូវនិវាសនវត្ត គឺវិធីស្បៃកឲ្យជាបរិ-មណ្ឌល ដូច្នេះឈ្មោះថាមិនដឹង ជាអនាបត្តិ ក៏ប៉ុន្តែថា និវាសនវត្ត ទំនៀមក្នុងកិរិយាស្បៃកចីវរ ភិក្ខុគប្បីរៀនសិក្សាឲ្យដឹងជាមុន កាលបើ មិនសិក្សាឲ្យដឹង ឈ្មោះថាមិនអើពើ គង់នឹងមិនរួចចាក អនាទរិយទុក្កដ ភិក្ខុណាស្នងវែង ឬកំភួនជើងធំ ភិក្ខុនោះនឹងស្បៃកឲ្យស្ទុយចុះទៅជាង ៨ ផ្ទាប់ ដើម្បីឲ្យជាសារូបក៏គួរ, ភិក្ខុណាមានដំបៅស្នង ឬដំបៅជើង ដូច្នេះឈ្មោះថាមានជំងឺ ភិក្ខុនោះនឹងស្បៃកឲ្យខ្ទើចឡើងមក ឬស្រុង

ចុះទៅក៏គួរ សត្វសាហាវ ឬចោរដេញ ឈ្មោះថាមានអន្តរាយ ក្នុងអន្តរាយ ដូច្នេះជាអនាបត្តិ ។ ហេតុនៃអនាបត្តិ មានមិនក្នែងជាដើម ដូចពោលមកនេះ គប្បីដឹងក្នុងសេខិយសិក្ខាបទទាំងពួង ដែលនឹងពោលទៅខាងមុខ ព្រោះហេតុនោះ បើសិក្ខាបទណាមានសេចក្តីប្លែកគ្នា ទើបនឹងពោលក្នុងសិក្ខាបទនោះទៀត បើមិនប្លែកគ្នាទេ នឹងមិនពោល ។ ក្នុងសេខិយវត្ត សិក្ខាបទទាំងពួងជាអនាណត្តិកៈទាំងអស់ តែមិនរួចអំពីអកប្បិយសមាទានទុក្កដ ក្នុងសិក្ខាបទជាបឋមនេះ មានអង្គ ៣ គឺ **អនាឧរិយំ** មិនអើពើ ១ **អនាបត្តិការណាការោ** មិនមានហេតុនៃអនាបត្តិ ១ **អបរិមណ្ឌលំ ឌិវាសនំ** ស្បៃកមិនជាបរិមណ្ឌល ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវអាបត្តិទុក្កដ ។ ក្នុងមាតិកានៃសេខិយៈទាំងពួងមានអង្គ ៣ ដូចក្នុងសិក្ខាបទនេះទាំងអស់គឺ មិនអើពើ ១ មិនមានហេតុនៃអនាបត្តិ ១ ធ្វើឲ្យខុសចាកសេចក្តីដែលពោលក្នុងសិក្ខាបទនោះ ១ ព្រោះហេតុនោះ តទៅខាងមុខ នឹងមិនពោលប្រភេទនៃអង្គទៀតទេ ។ សមុដ្ឋានវិធីជាដើម កាលបើចប់សេខិយវត្តហើយ ទើបនឹងសម្តែង ។ ក្នុងមាតិកានៃសេខិយៈទាំងពួង មិនមានឈ្មោះអាបត្តិខាងចុងសិក្ខាបទ ដូចសិក្ខាបទនៃអាបត្តិដទៃ មានតែពាក្យថា **សិក្ខា ការណីយា** ថាភិក្ខុគប្បីធ្វើសេចក្តីសិក្សាដូច្នេះ គ្រប់ៗ សិក្ខាបទ ដែលដឹងថាត្រូវអាបត្តិទុក្កដនោះ ដោយបាឡីដែលជាបទកាជនីយ៍ថាមិនអើពើ ខំធ្វើ

ត្រូវអាបត្តិទុក្កដ ។ ព្រោះហេតុនោះ តទៅខាងមុខ សូម្បីមិនចេញឈ្មោះអាបត្តិ ក៏គប្បីដឹងថា ត្រូវអាបត្តិ ដោយមិនអើពើក្នុងវិធីដែលនឹងធ្វើតាមក្នុងសិក្ខាបទទាំងពួង ។

សិក្ខាបទ គម្រប់ ២ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងដណ្តប់ចីវរឲ្យជាបរិមណ្ឌល គឺធ្វើមុំចីវរទាំង ២ ឲ្យស្មើគ្នា ហើយទើបឃ្ងុំឲ្យជាបរិមណ្ឌល ដូចសំពត់ស្បៃកដូច្នោះ ។ សិក្ខាបទទាំងពីរនេះ មិនមានពាក្យថា **អន្តរឃរេ** ដូចគ្នា ព្រោះហេតុនោះ គប្បីស្បៃកនិងដណ្តប់ឲ្យជាបរិមណ្ឌល ទាំងក្នុងវត្ត និងក្នុងលង្វែកភូមិ ។

សិក្ខាបទ គម្រប់ ៣ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងបិទកាយដោយប្រពៃ គឺដាក់ក្ដុំហើយបិទក ដោយទីបំផុតនៃអនុវាតធ្វើមុំទាំងពីរឲ្យស្មើគ្នាមូរចូលមក បិទរហូតដល់កដៃ ហើយទើបដើរទៅក្នុងលង្វែកភូមិ កាលមិនធ្វើដូច្នេះ បើកជង្គង់ ឬបើកទ្រូងដើរទៅត្រូវទុក្កដ ។

សិក្ខាបទ គម្រប់ ៤ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងបិទកាយដោយប្រពៃ អង្គុយក្នុងលង្វែកភូមិ គឺអង្គុយបើកសិរ: (ក្បាល) អំពីកញ្ចឹងកឡើងទៅ បើកដៃអំពីកដៃចេញទៅចុងម្រាម បើកជើងតាំងអំពីចុងកំភួនជើងនិងស្មងចុះទៅក្រោម បិទអវយវ:ដ៏សេសក្រៅនោះ ដូច្នេះឈ្មោះថាបិទដោយប្រពៃ ចូលទៅដើម្បីនឹងនៅក្នុងលង្វែកភូមិ សូម្បីអង្គុយបើកកាយក្នុងវេលាថ្ងៃ ឬវេលាយប់ មិនត្រូវអាបត្តិ **ឱ្យ**

ពាក្យនេះក្នុងអដ្ឋកថា ថាចូលទៅដើម្បីនឹងនៅ តែមិនកំណត់ថានៅឃាំងរាត្រី ឬនៅដោយការងារ តែក្នុងទីដទៃ **ឱ្យ**ចតោ នេះ បានសេចក្តីថាចូលទៅនៅឃាំងរាត្រី ព្រោះហេតុនោះ តទៅខាងមុខក្នុងពាក្យ ថាចូលទៅនៅក្នុងលង្វែកភូមិ គប្បីដឹងដូចពោលហើយនេះចុះ ។

សិក្ខាបទ គម្រប់ ៥ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងសង្រួមដោយប្រពៃ គឺមិនក្រមាច់ដៃ ក្រមាច់ជើង ដើរទៅក្នុងលង្វែកភូមិ ។

សិក្ខាបទ គម្រប់ ៦ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងសង្រួមដោយប្រពៃ គឺមិនក្រមាច់ដៃ ក្រមាច់ជើង អង្គុយក្នុងលង្វែកភូមិ ។

សិក្ខាបទ គម្រប់ ៧ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមានភ្នែកសម្ងឹងចុះក្រោម គឺរមិលមើលខាងមុខ ចម្ងាយ ១ ជួរនឹម គឺ ៤ ហត្ថ ដើរទៅក្នុងលង្វែកភូមិ ក៏ឯណាប់ឈរក្នុងទីណាមួយ ហើយរមិលមើលអន្តរាយ មានដំរី សេះ ជាដើម ក៏គួរ ។

សិក្ខាបទ គម្រប់ ៨ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមានភ្នែកសម្ងឹងចុះក្រោម ចម្ងាយ ១ ជួរនឹម អង្គុយក្នុងលង្វែកភូមិ ។

សិក្ខាបទ គម្រប់ ៩ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសើយចីវរឡើងម្ខាង ឬទាំងសងខាង ដើរទៅក្នុងលង្វែកភូមិ សូម្បី

កាលទទួលបិណ្ឌបាត ក៏កុំគប្បីសើយចីវរឡើង គប្បីនាំបាត្រចេញ ដោយស្រទាប់ចីវរ ។

សិក្ខាបទ គម្រប់ ១០ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសើយចីវរឡើងម្ខាង ឬទាំងសងខាង អង្គុយក្នុងលង្វែកភូមិ ក្នុងវេលាដែលអង្គុយនៅ សូម្បីនាំធម្មក្រកចេញ ក៏កុំគប្បីសើយចីវរឡើងនាំចេញមក បើចូលទៅនៅឃាំងពាត្រីក្នុងលង្វែកភូមិ សូម្បីសើយឡើងមិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ១១ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសើចខ្ចាំង ដើរទៅក្នុងលង្វែកភូមិ សូម្បីភិក្ខុមានជំងឺ ក៏មិនរួចអាបត្តិ ។

សិក្ខាបទ គម្រប់ ១២ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសើចខ្ចាំង អង្គុយក្នុងលង្វែកភូមិ កាលមានហេតុគួរនឹងសើចក៏គ្រាន់តែធ្វើញញឹម មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ១៣ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមានសំឡេងតិច មិននិយាយសំឡេងខ្ចាំង សំឡេងធំ ដើរក្នុងលង្វែកភូមិ ។

សិក្ខាបទ គម្រប់ ១៤ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមានសំឡេងតិច មិននិយាយសំឡេងខ្ចាំង សំឡេងធំ អង្គុយក្នុងលង្វែកភូមិ ។ ក៏ឯកំណត់សំឡេងតិចដូច្នេះ ក្នុងផ្ទះមានប្រវែង ១២ ហត្ថ បើព្រះសង្ឆត្ថេរ អង្គុយនៅខាងដើមផ្ទះ ព្រះថេរៈគម្រប់ ២ អង្គុយនៅកណ្តាលផ្ទះ

ព្រះថេរៈ គម្រប់ ៣ អង្គុយក្នុងទីបំផុតផ្ទះដូច្នេះ ព្រះសង្ឆត្ថេរនិយាយប្រឹក្សាសេចក្តីណាមួយនឹងព្រះថេរៈគម្រប់ ២ ព្រះថេរគម្រប់ ២ បានឮសំឡេងផង កំណត់ពាក្យកំណត់សេចក្តីបានផង ព្រះថេរៈគម្រប់ ៣ បានឮតែសំឡេង ១ យ៉ាង កំណត់ពាក្យ កំណត់សេចក្តីមិនបាន ទាំងអម្បាលនេះ ឈ្មោះថាសំឡេងតិច បើសំឡេងរបស់ព្រះសង្ឆត្ថេរខ្លាំងឮរហូតដល់ព្រះថេរៈគម្រប់ ៣ កំណត់ពាក្យ កំណត់សេចក្តីបាន ឈ្មោះថាសំឡេងខ្លាំង ។ ក្នុងអដ្ឋកថា កំណត់សំឡេងតិចសំឡេងខ្លាំងដូច្នេះ បានន៏ងមនុស្សដែលមានសំឡេងជាប្រក្រតី មិនតូចមិនធំ ក៏ប៉ុន្តែថាមនុស្សខ្លះសំឡេងធំ មនុស្សខ្លះសំឡេងតូច កំណត់យកសំឡេងដោយប្រក្រតីជាប្រមាណចុះ ។

សិក្ខាបទ គម្រប់ ១៥ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនដើរគ្រលែងកាយ ឃ្លាងកាយ ធ្វេង ស្តាំ មុខ ក្រោយ ចូលទៅក្នុងលង្វែកភូមិ ។

សិក្ខាបទ គម្រប់ ១៦ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនអង្គុយគ្រលែងកាយ ឃ្លាងកាយ ធ្វេង ស្តាំ មុខ ក្រោយ ក្នុងលង្វែកភូមិ ។

សិក្ខាបទ គម្រប់ ១៧ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនដើរបង់ចោយ ចូលទៅក្នុងលង្វែកភូមិ ។

សិក្ខាបទ គម្រប់ ១៨ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនធ្លាក់ដៃ អង្គុយក្នុងលង្វែកភូមិ ។

សិក្ខាបទ គម្រប់ ១៩ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនគ្រវីក្បាល គ្រលែងក្បាល ឡកមុខ ដើរទៅក្នុងលង្វែកភូមិ ។

សិក្ខាបទ គម្រប់ ២០ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនគ្រវីក្បាល គ្រលែងក្បាល ឡកមុខ អង្គុយក្នុងលង្វែកភូមិ ត្រូវតែផ្ចង តម្រង់ក្បាលឲ្យស្រួល អង្គុយនិងដើរក្នុងលង្វែកភូមិ ។ ក្នុងសិក្ខាបទទាំង ៣ ដែលពោលដោយអង្គុយនោះ ភិក្ខុចូលទៅនៅក្នុងលង្វែកភូមិនោះឃាំងរាត្រី សូម្បីឃ្លាងកាយជាដើម មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ២១ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនស្ទឹមចង្កេះម្ខាង ឬទាំងសងខាង ដើរទៅក្នុងលង្វែកភូមិ ។

សិក្ខាបទ គម្រប់ ២២ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនស្ទឹមចង្កេះម្ខាង ឬទាំងសងខាង អង្គុយក្នុងលង្វែកភូមិ ។ ចូលទៅនៅក្នុងលង្វែកភូមិឃាំងរាត្រី សូម្បីស្ទឹមចង្កេះ មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ២៣ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនទទួរក្បាលដើរទៅក្នុងលង្វែកភូមិ ។

សិក្ខាបទ គម្រប់ ២៤ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនទទួរក្បាលអង្គុយក្នុងលង្វែកភូមិ ។ ចូលទៅនៅក្នុងលង្វែកភូមិឃាំងរាត្រី សូម្បីទទួរក្បាល មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ២៥ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹង

មិនដើរចំអើតជើង ក្នុងលង្វែកកូមិ ។ លើកកែងជើងឡើង ត្រូវដីតែចុងជើង លើកចុងជើងឡើង ត្រូវដីតែកែងជើង ១ យ៉ាង ឈ្មោះថាចំអើតជើង ។

សិក្ខាបទ គម្រប់ ២៦ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនអង្គុយត្រចោមក្បាលជង្គង់ដោយដៃ ឬដោយសំពត់ក្នុងលង្វែកកូមិ ។ ចូលទៅនៅក្នុងលង្វែកកូមិយាំងរាត្រី សូម្បីអង្គុយត្រចោមក្បាលជង្គង់ មិនត្រូវអាបត្តិ ។

សិក្ខាបទទាំង ២៦ នេះ ភិក្ខុណា អាស្រ័យសេចក្ដីមិនអើពើ ភ្លេងប្រព្រឹត្តកន្ទង ត្រូវអនាទរិយទុក្កដ ។ ភិក្ខុមិនភ្លេង មិនមានសតិ មិនដឹងខ្លួន មានជំងឺ មានអន្ដរាយ និងភិក្ខុឆ្កួតជាដើម ជាអនាបត្តិគ្រប់សិក្ខាបទ ។ ក៏ឯ **អន្ដរឃរំ** *នេះ បើប្រែតាមព្យញ្ជនៈ ប្រែថាទីមានផ្ទះក្នុងចន្ទោះ ប្រែតាមអត្ថ ថាលង្វែកកូមិ ដើម្បីនឹងឲ្យរួចចាកសព្ទថា គាមោ ។ ដ្បិតក្នុងវិកប្ដនៃបាដិទេសនីយៈ លោកពោលទុកមិនដូច* **គាម** *សព្ទ ដូច្នេះថា* **អន្ដរឃរំ ជាម រថិកា ព្យូហំ សង្ខ្យាជកំ ឃរំ** *ប្រែថា ច្រកបររថទៅមកបាន ច្រកមិនធ្ងុះរហូតទៅ ផ្លូវ ៤ តំបន់ ឬផ្លូវ ៣ តំបន់ និងផ្ទះ ឈ្មោះថា* **អន្ដរឃរំ** *។*

ពួកទី ១ ឈ្មោះ<u>សារុប្ប</u> មាន ២៦ សិក្ខាបទ ចប់

ពួកទី ២ ឈ្មោះភោជនប្បដិសំយុត្ត មាន ៣០ សិក្ខាបទ ៖

សិក្ខាបទ ជាបឋម សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងទទួលបិណ្ឌបាត ដោយគោរព គឺមិនធ្វើអាការដូចជាយកទៅចាក់ចោលដោយខឹង ។

សិក្ខាបទ គម្រប់ ២ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងសម្គាល់តែក្នុងបាត្រ ហើយទទួលបិណ្ឌបាត គឺមិនមើលក្នុងទីនោះៗ ។

សិក្ខាបទ គម្រប់ ៣ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងទទួលបិណ្ឌបាត ឲ្យល្មមគ្នានឹងសម្ង ។ ដែលហៅថាសម្ង បានដល់សម្ងពីរយ៉ាងគឺ សម្ងសណ្ដែកបាយ ១ សម្ងសណ្ដែកពាជមាស ១ ដែលគួរជននឹងនាំទៅដោយដៃបាន ។ សម្ងដែលមានប្រមាណប៉ុនភាគទី ៤ នៃកត្ត មានក្នុងបិណ្ឌបាតណា បិណ្ឌបាតនោះ ឈ្មោះថាមានសម្ងល្មមប្រ-មាណ ។ កាលទទួលសម្ងឲ្យលើសប្រមាណនោះ ត្រូវទុក្កដ ។ ទទួលសម្ងដ៏ហើយដោយសាច់និងត្រីនិងស្ងឹកឈើ ក្រៅអំពីសម្ងសណ្ដែកឲ្យច្រើនក្ដី ឬទទួលសម្ងសណ្ដែក អំពីញាតិនិងមនុស្សបវារណា ឬទទួលដើម្បីអ្នកដទៃ ឬផ្ទាស់ប្តូរដោយទ្រព្យរបស់ខ្លួន សូម្បីច្រើនក៏មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ៤ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងទទួលបិណ្ឌបាតដែលជាយាវកាលិកណាមួយ ឲ្យស្មើត្រឹមកណ្ដាប់មាត់បាត្រ មិនឲ្យកំពុងហៀរលើសកណ្ដាប់មាត់បាត្រខាងក្នុងនៃបាត្រ

ដែលគួរអធិដ្ឋាន ។ ក៏ឯបាត្រដែលតូចនិងធំមិនគួរអធិដ្ឋាន សូម្បីយាវកាលិក នឹងពេញកំពុងឡើងមកក្តី និងបាត្រដែលគួរអធិដ្ឋាន ឬមិនគួរអធិដ្ឋានក៏ដោយ សូម្បីយាមកាលិក សត្តាហកាលិក យាវជីវិក នឹងពេញកំពុងឡើងមកក្តីក៏គួរ ។ ភិក្ខុទទួលរបស់ណា ២ បាត្រ ហើយផ្ទេរដាក់ចុះក្នុងបាត្រ ១ ហើយបញ្ជូនមកវត្តក្តី ឬនំ កំណាត់អំពៅ ផ្លែឈើជាដើមណា ដែលគេដាក់ចុះកំពុងឡើង សូម្បីរលាក់ក៏ស្រុតចុះទៅ ឬគេយកស្នែងក្រាញជាដើម ដាក់ខាងលើប្រគេន ឬរបស់ណាដែលទ្រាប់ដោយស្ងឹកឈើ ឬចាន គេដួសដាក់ហើយតម្កល់លើមាត់បាត្រក្តី របស់ទាំងអម្បាលនេះ ឈ្មោះថាពួនកំពុង ជាកំពូល ក៏មិនមែន ព្រោះហេតុដូច្នោះ ទទួលរបស់ទាំងពួងនោះ ក៏គួរ ។ ក្នុងសិក្ខាបទនេះ សូម្បីភិក្ខុឈឺក៏មិនរួចអាបត្តិ ទទួលពួនកំពុងមាត់បាត្រ មិនគួរក្នុងទីទាំងពួង តែថាទទួលហើយ ក៏ឈ្មោះថាទទួលដោយប្រពៃ នឹងឆាន់ក៏គួរ ។

សិក្ខាបទ គម្រប់ ៥ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងឆាន់បិណ្ឌបាតដោយគោរព គឺតាំងសតិទុកដោយប្រពៃ ។

សិក្ខាបទ គម្រប់ ៦ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងសម្គាល់តែក្នុងបាត្រ គឺឆាន់បិណ្ឌបាត មិនក្រឡេកមើលក្នុងទីនោះ។ ។

សិក្ខាបទ គម្រប់ ៧ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹង

ធាន់បិណ្ឌបាត ប្រមូលឲ្យស្មើដោយលំដាប់ ។ គឺមិនធ្វើបាយឲ្យខ្ជ ចុះទៅក្នុងទីនោះ ។ នឹងឲ្យបាយទៅអ្នកដទៃ ឬនឹងចាក់បាយចុះទៅក្នុងភាជនៈដទៃ សង្កត់ឲ្យខ្ជ ទៅក្នុងទីនោះ ក្តី ឬចាប់ចិចម្ហូបមិនជាលំដាប់ចុះទៅក្តី មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ៨ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងធាន់បិណ្ឌបាតឲ្យល្មមគ្នានឹងសម្ង ។ បើសម្ងសណ្តែកត្រូវឲ្យស្មើភាគគម្រប់ ៤ នៃបាយ ដូចពោលមកហើយអំពីមុន ។ ក្នុងសម្ងសាច់ សម្ងត្រី ឬសម្ងសណ្តែករបស់ញាតិ របស់បវារណា ឬដូរមកដោយទ្រព្យរបស់ខ្លួន សូម្បីធាន់ច្រើន ក៏មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ៩ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនច្រមត្រង់កំពូលបាយ ហើយធាន់បិណ្ឌបាត ។ គឺមិនច្រមចុចចុះទៅត្រង់កណ្តាល ១ យ៉ាង ។ បាយតិចបោសប្រមូលបាយជាកំពូល ចាប់ធាន់មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ១០ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនយកបាយបិទលុបសម្ង ឬម្ហូប ដោយអាស្រ័យសេចក្តីប្រាថ្នាចង់បានច្រើន ។ សូម្បីភិក្ខុឈឺក៏មិនរួចអាបត្តិ ។ ក្នុងមាឃាតសម័យ កាលហាមមិនឲ្យសម្ងាប់សត្ត ទាយកគេបិទលុបឲ្យឯង ឬមិនអាស្រ័យសេចក្តីចង់បានច្រើន បិទលុបឯងក្តី មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ១១ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងមិនឈឺនឹងមិនសូមសម្ង ឬបាយដើម្បីធាន់ខ្លួនឯង ។ សូមអំពីញាតិនិងមនុស្សបវារណា ឬសូមដើម្បីអ្នកដទៃ ឬផ្ទាស់ប្ដូរយកដោយទ្រព្យរបស់ខ្លួនឯង មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ១២ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនសម្គាល់ដើម្បីលើកទោស ហើយរមិលមើលបាត្រភិក្ខុដទៃ ។ សូម្បីភិក្ខុឈឺ មិនរួចអាបត្តិ ។ រមិលមើលដោយគិតថានឹងថែមរបស់អ្វីឲ្យ ឬឲ្យអ្នកដទៃឲ្យ ឬរមិលមើលដោយមិនគិតនឹងលើកទោស មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ១៣ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនធ្វើពំនូតបាយឲ្យធំពេក ។ ពំនូតបាយប៉ុនពងក្ងោក ឈ្មោះថាធំពេក តូចជាងនោះឈ្មោះថាមិនធំពេក ។ ក្នុងរបស់ទំពាស៊ីទាំងពួងជាដើមថាឫសឈើ ឬផលាផលនិងសម្ង សូម្បីចំណុកធំ មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ១៤ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងធ្វើពំនូតបាយឲ្យជាបរិមណ្ឌល គឺឲ្យមូល មិនឲ្យវែង ។ ក្នុងរបស់ជាខាទនីយ:ទាំងពួង និងផលាផល និងសម្ងសណ្ដែក ជាអនាបត្តិ ។

សិក្ខាបទ គម្រប់ ១៥ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា កាលពំនូតបាយមិនទាន់មកដល់មាត់ យើងនឹងមិនហាមាត់ទុកមុន ។

សិក្ខាបទ គម្រប់ ១៦ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើង

កាលធាន់បាយ នឹងមិនញាត់ម្រាមដៃទាំងអស់ចូលទៅក្នុងមាត់ ។ ក្នុងដីកាថា **ហត្ថ** *សព្ទ ក្នុងទីនេះ ឲ្យគប្បីឃើញក្នុងម្រាមដៃ ដោយឯកទេសនៃដៃ ដូចក្នុងពាក្យថា* **ហត្ថមុទ្ធា** *ព្រោះហេតុនោះនឹងស៊ីកសូម្បីម្រាមមួយ ឬឯកទេសនៃម្រាមនោះចូលទៅក្នុងមាត់ មិនគួរ ។*

សិក្ខាបទ គម្រប់ ១៧ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងមានពំនូតបាយក្នុងមាត់ នឹងមិននិយាយ ។ ព្រោះថាពំនូតបាយមាននៅក្នុងមាត់ ពាក្យនិយាយនឹងមិនច្បាស់ បើនិយាយត្រូវអាបត្តិ ។ ភិក្ខុណាសម្ដែងធម៌ មានសម៉ាដើមនៅក្នុងមាត់ សម្ដែងទៅដោយសម៉ាប៉ុន្មានពាក្យបរិបូណ៌ពិត ហៀមសម៉ាតែត្រឹមប៉ុណ្ណោះ មាននៅក្នុងមាត់ ក៏គួរ ។

សិក្ខាបទ គម្រប់ ១៨ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនបោះពំនូតបាយ ចូលទៅក្នុងមាត់ធាន់ ។ ក្នុងរបស់ទំពាស៊ីនិងផលាផល ជាអនាបត្តិ ។

សិក្ខាបទ គម្រប់ ១៩ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនធាន់ខាំកាត់ពំនូតបាយ ។ ក្នុងសម្ងួនិងរបស់ទំពាស៊ីនិងផលាផលជាអនាបត្តិ ។

សិក្ខាបទ គម្រប់ ២០ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងធាន់នឹងមិនធ្វើពំនូតបាយ ឲ្យទូញក្នុងថ្នក់ថ្ពាល់ដូចពានរ ។ ក្នុងផលាផលជាអនាបត្តិ ។

សិក្ខាបទ គម្រប់ ២១ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនធាន់រលាស់ដៃ ។ បើបេះកាកកញ្ជាក់ បេះសំរាមចោល រលាស់ដៃ មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ២២ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនធាន់ធ្វើគ្រាប់បាយឲ្យធ្លាក់រោយរាយ ។ បើបេះកាកកញ្ជាក់និងសំរាមចោល គ្រាប់បាយធ្លាក់ចុះ មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ២៣ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនធាន់លៀនអណ្ដាតចេញមក ។

សិក្ខាបទ គម្រប់ ២៤ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនធាន់ធ្វើសំឡេងឲ្យឮផ្ទប់ៗ ។

សិក្ខាបទ គម្រប់ ២៥ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនធាន់ធ្វើសំឡេងឮសូរគ្រូកៗ ។

សិក្ខាបទ គម្រប់ ២៦ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនធាន់លិទ្ធដៃ ។ កាលកំពុងធាន់ សូម្បីនឹងលិទ្ធតែម្រាមដៃក៏មិនគួរ ។ ក៏ឯនឹងចាប់ឃ្លាខ្ទ ទឹកអំពៅ បាយបាយាសជាដើម ដែលស្អិតជាប់ដោយម្រាមដៃ ហើយសឹកម្រាមដៃចូលទៅក្នុងមាត់ ក៏គួរ ។

សិក្ខាបទ គម្រប់ ២៧ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនធាន់លិទ្ធបាត្រ ។ បើកោសបបោសបាយ ដែលសល់នៅបន្ដិចបន្ដួច ប្រមូលមកដើម្បីនឹងធាន់ មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ២៨ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនធាន់លិទ្ធបបូរមាត់ សូម្បីតែម្ជាងដោយអណ្ដាត ។ ក៏ឯនឹងលិទ្ធបបូរមាត់ឲ្យអាមិសដែលជាប់នៅចូលទៅក្នុងមាត់វិញ ក៏គួរ ។

សិក្ខាបទ គម្រប់ ២៩ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងមានដៃប្រឡាក់ដោយអាមិស នឹងមិនចាប់កាន់ភាជនៈដាក់ទឹកធាន់ ។ សេចក្ដីដែលហាមនេះ ព្រោះដៃប្រឡាក់អាមិសជាបដិកូល ព្រោះហេតុនោះ សូម្បីស័ង្ខនិងផ្ដិលនិងសៀនដាក់ទឹកជារបស់សង្ឆ ឬរបស់បុគ្គល ឬរបស់គ្រហស្ថ ឬរបស់ខ្លួនឯងក្ដី កុំគប្បីចាប់ពាល់ឡើយ កាលបើចាប់ពាល់ ត្រូវទុក្កដ ។ បើឯកទេសនៃដៃម្ជាងដែលអាមិសមិនប្រឡាក់មាននៅសោត នឹងចាប់ដោយឯកទេសនៃដៃនោះក៏គួរ គិតថានឹងលាង ឬនឹងឲ្យគេលាង ហើយនឹងចាប់ពាល់ មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ៣០ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនចាក់ទឹកលាងបាត្រទាំងគ្រាប់បាយចុះ ក្នុងលង្វែកភូមិ ។ បើរើសគ្រាប់បាយឡើងអំពីទឹកប្រមូលទុកមួយអន្ទ្ធ ហើយចាក់តែទឹក ឬញ្ជីគ្រាប់បាយឲ្យលិ្ចតទៅក្នុងទឹកហើយចាក់ចោល ឬចាក់ក្នុងកន្ទោរ ហើយយកទៅចាក់ចោល ឬនាំទៅចាក់ចោលខាងក្រៅ ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។

សិក្ខាបទ ទាំង ៣០ នេះ ភិក្ខុណា អាស្រ័យសេចក្ដីមិនអើពើ ក្ងៃ

ប្រព្រឹត្តកន្ទ្ធ១ត្រូវអាបត្តិទុក្កដ ។ មិនក្ងែ១ មិនមានសតិ មិនដឹ១ខ្លួន មានជំងឺ មានអន្តរាយ និ១ភិក្ខុធ្ងួតជាដើម មិនត្រូវអាបត្តិ គ្រប់សិក្ខាបទ ។ តែភិក្ខុឈឺនោះជាអនាបត្តិ ក្នុ១សិក្ខាបទ ២៦ រៀរតែទទួលពេញ កំពុ១មាត់បាត្រ និ១ធាន់ប្រមកំពូលបាយឲ្យខូ១ចុះទៅ និ១យកបាយបិទ លុបសម្ងួនិ១រមិលមើលបាត្រភិក្ខុដទៃ ដើម្បីនឹ១លើកទោស ទាំ១ ៤ សិក្ខាបទនេះចេញ ។

ពួកទី ២ ឈ្មោះភោជនប្បដិសំយុត្ត មាន ៣០ សិក្ខាបទចប់

ធម្មទេសនាបដិសំយុត្ត មាន ១៦ សិក្ខាបទ ៖

សិក្ខាបទ ជាបឋម សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើ១នឹ១ មិនសម្ដែ១ធម៌ដល់មនុស្សគ្មានជំងឺ មានឆត្រនៅក្នុ១ដៃ ។ គេតម្កល់ឆត្រ ទុកលើអវយវៈ នៃសរីរៈណាមួយ គេមិនទាន់លែ១អំពីដៃ នេះឈ្មោះ ថាមានឆត្រក្នុ១ដៃ ។ នឹ១សម្ដែ១ធម៌ដល់អ្នកនោះមិនគួរ ។ បើអ្នក ដទៃគេបាំ១ឲ្យ ឬឆត្រផ្អែកទុកខា១ខ្លួន ល្មមតែឆត្រផុតចេញពីដៃហើយ ឈ្មោះថាមនុស្សមិនមានឆត្រក្នុ១ដៃ ។ នឹ១សម្ដែ១ធម៌ដល់អ្នកនោះ ក៏គួរ ។ ឯការកំណត់ធម៌ក្នុ១សិក្ខាបទនេះ គប្បីដឹ១ដោយន័យដូច សម្ដែ១ហើយ ក្នុ១បទសោធម្មសិក្ខាបទនោះចុះ ។

សិក្ខាបទ គម្រប់ ២ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើ១ នឹ១មិនសម្ដែ១ធម៌ដល់មនុស្សគ្មានជំងឺ មានដំបង១នៅក្នុ១ដៃ ។ កំណាត់

ឈើប្រវែង ៤ ហត្ថ នៃមជ្ឈិមបុរស ហៅថាដំបង បើវែងឬខ្លីជាងនេះ មិនហៅថាដំបងទេ ។ ឯសេចក្ដីថា មនុស្សមានដំបងនៅក្នុងដៃនេះ គប្បីដឹងដោយន័យដូចសម្ដែងហើយ ក្នុងមនុស្សមានឆត្រនៅក្នុងដៃនោះចុះ ។

សិក្ខាបទ គម្រប់ ៣ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ មានគ្រឿងសស្ត្រានៅក្នុងដៃ ។ ឯសស្ត្រានោះ ទោះមានមុខមុតម្ខាងក្ដី ទាំងសងខាងក្ដី ដោយលក្ខណៈដូចពោលហើយក្នុងសិក្ខាបទមុន ។ បុគ្គលគ្រាន់តែស្ពាយ ឬសៀតជាវ ឈរនៅ មិនរាប់ថាមនុស្សមានសស្ត្រាក្នុងដៃ ។

សិក្ខាបទ គម្រប់ ៤ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ មានអាវុធនៅក្នុងដៃ ។ ធ្នូវិសេសទាំងពួង ទាំងព្រួញផង ឈ្មោះថាអាវុធ ។ ព្រោះហេតុនោះ អ្នកកាន់ធ្នូទាំងព្រួញផង ឬកាន់តែដងធ្នូទទេ ឬកាន់តែព្រួញទទេក្ដី ឬកាន់ធ្នូមានបន្ទោះ ឬមិនមានបន្ទោះក្ដី អង្គុយក្ដី ឈរក្ដី នឹងសម្ដែងធម៌ដល់អ្នកនោះមិនគួរ ។ បើអ្នកនោះសូម្បីយកធ្នូពាក់ចុះនៅក មិនទាន់ចាប់ធ្នូមុន នឹងសម្ដែងធម៌ឲ្យក៏គួរ ។ គ្រឿងប្រហារមានមុខមុត ឈ្មោះថាសស្ត្រា មិនមានមុខមុតឈ្មោះថាអាវុធ ព្រោះហេតុនោះ សូម្បីធ្នូខ្វែកនិងកាំភ្លើង ឈ្មោះថាអាវុធ ។

សិក្ខាបទ គម្រប់ ៥ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ពាក់ទ្រនាប់ជើងសម្រាប់ដើរ ។ សូម្បីមិនបានដាក់ចង្កៃកជើងចុះក្នុងបង្ហោល គ្រាន់តែជាន់ ឬពាក់ ឬដោះបង្ហើបកែងបន្ទិចក្តី ក៏ឈ្មោះថាឡើងកាន់ស្បែកជើង ។

សិក្ខាបទ គម្រប់ ៦ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ពាក់ស្បែកជើង ។ ឯវិធីពាក់ដូចពោលហើយក្នុងទ្រនាប់ជើង សូម្បីស្រាយខ្សែចងកែងជើងចេញហើយឈរនៅ ក៏ឈ្មោះថាឡើងកាន់ស្បែកជើង នឹងសម្តែងធម៌ដល់អ្នកនោះមិនគួរ ។ ស្បែកជើងធ្វើដោយឈើនិងស្មៅជាដើម ហៅថាទ្រនាប់ជើង ស្បែកជើងធ្វើដោយស្បែក ហៅថាស្បែកជើង ។

សិក្ខាបទ គម្រប់ ៧ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ នៅលើយាន ។ រ រថ ១ទេ១ អង្រឹង-ស្នែង គ្រែស្នែងជាដើម ឈ្មោះថាយាន ។ សូម្បីមនុស្សពីរនាក់យកដៃកាន់គ្នាឲ្យដិះទៅក្តី ឬឲ្យអង្គុយក្នុងអង្រឹងសំពត់ ស្ពាយទៅក្តី ឬអង្គុយក្នុងយានដែលគេមិនបានទឹម សូម្បីនឹងអង្គុយលើកង់ ១ទេ១ដែលគេ១ើដោះចេញទុកដាក់ក្តី ឈ្មោះថានៅលើយានទាំងអស់ ។ បើមនុស្សពីរនាក់អង្គុយក្នុងយានជាមួយគ្នានឹងសម្តែងធម៌ដល់គ្នានិងគ្នាក៏គួរ សូម្បីអង្គុយលើយានផ្សេងគ្នា អ្នកអង្គុយលើយានខ្ពស់ នឹងសម្តែងធម៌ឲ្យអ្នកអង្គុយក្នុង

យានទាបក៏គួរ សូម្បីក្នុងយានប្រមាណស្មើគ្នាក៏គួរ អ្នកអង្គុយក្នុងយានមុខ នឹងសម្តែងធម៌ឲ្យអ្នកអង្គុយក្នុងយានក្រោយក៏គួរ ។ អ្នកអង្គុយក្នុងយានក្រោយ សូម្បីខ្ពស់ជាងក៏ដោយ នឹងសម្តែងធម៌ដល់អ្នកអង្គុយក្នុងយានមុខ មិនគួរ ។

សិក្ខាបទ គម្រប់ ៨ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ហើយដេក ។ ភិក្ខុនឹងឈរ ឬអង្គុយលើគ្រែ លើតាំង ឬលើផែនដី សូម្បីខ្ពស់ នឹងសម្តែងធម៌ដល់មនុស្សដែលដេក ដោយហោចទៅ សូម្បីលើកនេ្ទល ឬលើផែនដីប្រក្រតីមិនគួរ ។ ឯអ្នកដេកនឹងសម្តែងធម៌ដល់អ្នកដេកផងគ្នាក៏គួរ តែដេកក្នុងទីខ្ពស់ជាង ឬស្មើគ្នាទើបគួរ ។ ក៏ឯអ្នកដេកនឹងសម្តែងឲ្យអ្នកឈរ ឬអង្គុយ ឬដេកក្តី ឬអង្គុយនឹងសម្តែងឲ្យអ្នកឈរ ឬអង្គុយផងគ្នាក្តី អ្នកឈរនឹងសម្តែងដល់អ្នកឈរផងគ្នាក្តី ទាំងអស់នេះគួរ ។

សិក្ខាបទ គម្រប់ ៩ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ដែលអង្គុយត្រចោមក្បាលជង្គង់ដោយដៃ ឬដោយសំពត់ណាមួយ ។

សិក្ខាបទ គម្រប់ ១០ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ដែលមានក្បាលព័ន្ធព័ទ្ធដោយសំពត់ជាដើម ទាល់តែជើងសក់មិនប្រាកដ ។ ឲ្យគេបើកឲ្យឃើញជើងសក់ហើយទើបសម្តែង មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ១១ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ ដែលមានក្បាលទទួរទាំងអស់ ។ ឲ្យគេបើកសំពត់ទទួរក្បាលចេញហើយទើបសម្ដែង មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ១២ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងអង្គុយលើផែនដី នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ ដែលអង្គុយលើអាសនៈគ្រឿងកម្រាល ដោយហេតុទៅ សម្បីសំពត់ ឬស្មៅ មិនគួរ ។

សិក្ខាបទ គម្រប់ ១៣ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងអង្គុយលើអាសនៈទាប នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ ដែលអង្គុយលើអាសនៈខ្ពស់ជាង ដោយហេតុទៅ សម្បីតែផែនដីខ្ពស់ក្ដី ក៏មិនគួរ ។

សិក្ខាបទ គម្រប់ ១៤ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងឈរ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺដែលអង្គុយស្ដាប់ ។ ក្នុងសិក្ខាបទនេះ ព្រះអដ្ឋកថាចារ្យលោកពោលទុកថា សម្បីភិក្ខុកំលោះទៅកាន់ទីឧបដ្ឋាកព្រះថេរៈ ហើយភិក្ខុកំលោះឈរ បើព្រះមហាថេរអង្គុយលើអាសនៈសួរបញ្ហាសោត ភិក្ខុកំលោះកុំគប្បីសម្ដែងឡើយ ។ បើភិក្ខុកំលោះមិនអាចពោលនឹងព្រះថេរៈថា សូមព្រះករុណាក្រោកឡើងហើយសឹមសួរ ដោយសេចក្ដីគោរពក្នុងព្រះថេរៈ ហេតុនោះ នឹងគិតថាយើងនឹងសម្ដែងដល់ភិក្ខុកំលោះដែលឈរនៅជិតខាងដូច្នេះ ហើយសម្ដែង ក៏គួរ ។

សិក្ខាបទ គម្រប់ ១៥ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើង

ដើរទៅខាងក្រោយ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ដែលដើរទៅខាងមុខ ។ ក្នុងសិក្ខាបទនេះ ព្រះអដ្ឋកថាចារ្យលោកពោលទុកថា បើអ្នកដើរទៅខាងមុខសួរបញ្ហាសោត កុំគប្បីសម្តែង ។ ត្រូវគិតថា យើងនឹងសម្តែងដល់អ្នកមកតាមក្រោយដូច្នេះហើយគប្បីសម្តែងចុះ ។ នឹងស្វាធ្យាយធម៌ដែលរៀនមកជាមួយគ្នា ឬនឹងសម្តែងដល់អ្នកដើរទៅទន្ទឹមគ្នាក៏គួរ ។

សិក្ខាបទ គម្រប់ ១៦ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងដើរទៅក្រៅផ្លូវ នឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជំងឺ ដែលដើរទៅក្នុងផ្លូវ ។ សូម្បីក្នុងផ្លូវរនេះ ភិក្ខុពីរអង្គដើរទន្ទឹមគ្នាទៅតាមផ្លូវរនេះ មួយអង្គម្ខាង ឬក្រៅផ្លូវដូចគ្នា នឹងសម្តែង ក៏គួរ ។

សិក្ខាបទទាំង ១៦ នេះ ភិក្ខុណា អាស្រ័យសេចក្តីមិនអើពើ ក្ងៃ ប្រព្រឹត្តកន្ទងត្រូវអនាទរិយទុក្កដ ។ មិនក្ងៃ មិនមានសតិ មិនដឹងខ្លួន អ្នកដែលស្តាប់មានជំងឺ មានអន្តរាយ និងភិក្ខុធ្លួតជាដើម មិនត្រូវអាបត្តិគ្រប់សិក្ខាបទ ។

ពួកទី ៣ ឈ្មោះធម្មទេសនាបដិសំយុត្ត មាន ១៦ សិក្ខាបទ ចប់

ពួកទី ៤ ឈ្មោះបកិណ្ណកៈមាន ៣ សិក្ខាបទ ៖

សិក្ខាបទ ជាបឋម សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងមិនឈឺ នឹងមិនឈរបន្ទោបង់ឧច្ចារៈបស្សាវៈ ។ បើភិក្ខុទៅរកទីកំបាំងមិនទាន់ឧច្ចារៈបស្សាវៈហៀរហូរមកមុន ឈ្មោះថាមិនក្ងៃ មិនត្រូវអាបត្តិ ។

សិក្ខាបទ គម្រប់ ២ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងមិនឈឺ នឹងមិនបន្ទោបង់ឧច្ចារៈបស្សាវៈ ឬស្តោះទឹកមាត់ ញើសទឹកសំបោរ ចុះក្នុងទីមានវត្ថុខៀវគឺដើមឈើ ដើមស្មៅ ដែលស្រស់ សូម្បីឫសឈើ ដែលរស់វារទៅលើដីឃើញប្រាកដ ឬមែកឈើវារពន្ធកជាប់ដីទៅក្តី ទាំងអម្បាលនេះរាប់ថាជារបស់ខៀវទាំងអស់ ។ ឯនឹងឡើងអង្គុយលើដើមឈើ បន្ទោបង់ឧច្ចារៈបស្សាវៈចុះ ក្នុងទីមិនមានវត្ថុខៀវនោះក៏គួរ ។ បើដើរទៅរកទីប្រាសចាកវត្ថុខៀវ ទោះបីឧច្ចារៈបស្សាវៈហៀរហូរមកជាមុនសោត ឈ្នោះថាបិតនៅក្នុងភាពជាមនុស្សឈឺ មិនមានទោស ។ សូម្បីរកទីប្រាសចាកវត្ថុខៀវមិនបាន គប្បីយករង្វេលស្មៅ ឬស្ទឹកឈើរងហើយបន្ទោ-បង់ចុះ សូម្បីឧច្ចារៈបស្សាវៈហូរទៅសង្កត់លើវត្ថុខៀវជាក្រោយ ក៏គួរដោយពិត ។

សិក្ខាបទ គម្រប់ ៣ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងមិនឈឺ នឹងមិនបន្ទោបង់ឧច្ចារៈបស្សាវៈ ស្តោះទឹកមាត់ ញើសសំបោរ ចុះក្នុងទឹក ។ ទឹកនោះសង្គ្រោះយកទឹកដែលបរិភោគប្រើប្រាស់បាន ។ ទឹកក្នុងវច្ចកុដិជាដើមដែលបរិភោគមិនបាន មិនត្រូវអាបត្តិ ។ ភ្ជៀងធ្លាក់ ជំនន់ជន់ ទឹកលិចទៅទាំងអស់ រកទីទួលមិនបាន នឹងបន្ទោបង់ចុះក្នុងទឹកនោះក៏គួរ បន្ទោបង់ចុះលើគោក ឧច្ចារៈបស្សាវៈហៀរហូរទៅក្នុងទឹក មិនត្រូវអាបត្តិ ។

សិក្ខាបទទាំង ៣ នេះ ភិក្ខុណា អាស្រ័យសេចក្តីមិនអើពើ ក្ងែង ប្រព្រឹត្តកន្ទ្ងត់ត្រូវអនាទរិយទុក្កដ ។ មិនក្ងែង មិនមានសតិ មិនដឹងខ្លួន មានជំងឺ មានអន្តរាយ និងភិក្ខុឆ្កួតជាដើម មិនត្រូវអាបត្តិ គ្រប់សិក្ខាបទ ។

ពួកទី ៤ ឈ្មោះបកិណ្ណក:មាន ៣ សិក្ខាបទ ចប់

សើចខ្ទាំង ២ និយាយសំឡេងខ្ទាំង ២ និយាយទាំងចំណុកបាយ ១ ជា ៥ សិក្ខាបទ អង្គុយលើផែនដី សម្តែងធម៌ដល់មនុស្សអង្គុយលើអាសន: ១ អង្គុយលើអាសន:ទាប សម្តែងធម៌ដល់មនុស្សអង្គុយលើអាសន:ខ្ពស់ ១ ឈរសម្តែងធម៌ដល់មនុស្សអង្គុយ ១ ដើរខាងក្រោយ សម្តែងធម៌ដល់មនុស្សដើរទៅខាងមុខ ១ ដើរក្រៅផ្លូវសម្តែងធម៌ដល់មនុស្សដើរទៅក្នុងផ្លូវ ១ ជា ៥ សិក្ខាបទ ផ្សំគ្នាត្រូវជា ១០ សិក្ខាបទ ទាំង ១០ សិក្ខាបទនេះ ជាសមនុភាសនសមុដ្ឋាន គឺអាបត្តិកើតអំពីកាយ-វាចាចិត្ត ជាកិរិយា សញ្ញាវិមោក្ខ សចិត្តក: លោកវជ្ជ: កាយកម្ម វចីកម្ម អកុសលចិត្ត ទុក្ខវេទនា គ្រប់សិក្ខាបទ ។

សុបោទនវិញ្ញត្តិសិក្ខាបទ សូមសម្ង សូមបាយ ជាវេយ្យសត្ត-សមុដ្ឋាន អាបត្តិកើតអំពីកាយចិត្ត កើតអំពីកាយវាចាចិត្ត ជាកិរិយា សញ្ញាវិមោក្ខ សចិត្តក: លោកវជ្ជ: កាយកម្ម វចីកម្ម អកុសលចិត្ត ទុក្ខវេទនា ។

សម្តែងធម៌ដល់មនុស្សមានឆត្រក្នុងដៃ មានដំបងក្នុងដៃ មានសស្ត្រាក្នុងដៃ មានអាវុធក្នុងដៃ ពាក់ទ្រនាប់ជើង ពាក់ស្បែកជើង មនុស្សនៅលើយាន មនុស្សដេក មនុស្សអង្គុយត្រចោមក្បាលជង្គង់ មនុស្សជួតក្បាល មនុស្សទទួរក្បាល ១១ សិក្ខាបទនេះ ជាធម្មទេសនា-សមុដ្ឋាន គឺអាបត្តិកើតអំពីវាចាចិត្ត ជាកិរិយាកិរិយ: សញ្ញាវិមោក្ខ សចិត្តក: លោកវជ្ជ: វចីកម្ម អកុសលចិត្ត ទុក្ខវេទនា គ្រប់សិក្ខាបទ ។ ក្រៅអំពីនោះ ៥៣ សិក្ខាបទ មានសមុដ្ឋានវិធីជាដើមដូចបឋមបារាជិក ។

មួយទៀត ក្នុងសេខិយ:នេះ ខាងដើមឧទ្ទេសនិងចុងឧទ្ទេសក្នុងបាតិមោក្ខ មិនមានសំខ្យាកំណត់ថា **ឥមេ ខោ បញ្ចសត្តតិ សេខិយា ធម្មា** *ដូច្នេះទេ ថាតែ* **ឥមេ ខោ សេខិយា ធម្មា** *ប៉ុណ្ណោះ ដែលមិនកំណត់នោះ សម្តែងសេចក្តីថា ឯវិធីដែលភិក្ខុនឹងគប្បីសិក្សានឹងមានតែប៉ុណ្ណោះក៏ទេ សូម្បីវត្តដែលព្រះពុទ្ធអង្គ ទ្រង់បញ្ញត្តទុកក្នុងវត្តខន្ធ ក៏ឈ្មោះថាសេខិយ: ព្រោះជាវត្តដែលភិក្ខុគប្បីសិក្សាមួយទៀត ដែលមិនកំណត់នោះ ដើម្បីនឹងសម្តែងចារិត្តន័យផង ។*

<u>សេខិយុទ្ទេស ចប់</u>

ចីវរបដិសំយុត្តកថា

ពណ៌នាអំពីបញ្ញត្តិនៃទុក្កដាបត្តិ ដែលមានមកក្នុងខន្ធក:ជាដើម តាមលំដាប់បុព្វសិក្ខា និងថែមបញ្ចូលខ្ទះ ។ ក្នុងបញ្ញត្តិដែលមានមកក្នុងបុព្វសិក្ខា នឹងពោលថា ១មួយ ។ ក្នុងពុទ្ធប្បញ្ញត្តិដែលថែមបញ្ចូល នឹងពោលថា ១មួយទៀត ឲ្យជាទីសង្កេត ។ ហើយនឹងអញ្ជើញ ព្រះពុទ្ធប្បញ្ញត្តិដែលមានមកក្នុងខន្ធក:នោះ។ និងមានមកក្នុងវិនីតវត្ថុជាដើម មករៀបរៀងពោលដោយន័យ ដើម្បីនឹងឲ្យយល់ ៖

សម្តែងចីវរបដិសំយុត្តកថាជាមុន ។ ១មួយ ភិក្ខុកុំគប្បីស្លៀកដូចគ្រហស្ថ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ភិហិនិវត្ថំ និវាសេតព្វំ ហត្ថិសោណ្ឌិកំ មច្ឆវាឡកំ ចតុក្កណ្ណកំ តាលវណ្ដកំ សតវលិកំ យោ និវាសេយ្យ អាបត្តិ ទុក្កដស្ស** សេចក្ដីថា ភិក្ខុកុំគប្បីស្លៀកដូចគ្រហស្ថ បើស្លៀកដូចគ្រហស្ថត្រូវទុក្កដ ។ ស្លៀកដូចគ្រហស្ថនោះដូច្នេះ ស្លៀកសំយុងចុះទៅអំពីផ្ចិត មានសណ្ឋានដូចប្រមោយដំរី ដូចសម្ងៀកនៃស្ត្រីក្នុងចោទ-ប្រទេសក្ដី ស្លៀកឲ្យទីបំផុតជាយម្ខាងនិងវង់ជាយម្ខាង សំយុងចុះទៅដូចកន្ទុយត្រីក្ដី និងស្លៀកបួនមុំ គឺសម្ដែងមុំលើពីរ ខាងក្រោមពីរក្ដី និងស្លៀកឲ្យសំយុងចុះទៅ ដោយអាការដូចកំពូលភ្នោត និងស្លៀកព័ទ្ធបត់សំពត់ដែលវែងឲ្យមានជាន់ច្រើនជាស្រទាប់ជាត្រុបក ឬស្លៀកជា

ល្ងរជាត្រូបកដោយលំដាប់គ្នាខាងធ្វេងខាងស្តាំ មានត្រូបកស្រទាប់ច្រើនប្រមាណមួយរយ ដូច្នេះ ឈ្មោះថាស្ងៀកដូចគ្រហស្ថ មិនគួរ បើតាំងពីជង្គង់ឡើងមកប្រាកដជាល្ងរ ១ ឬ ២ ក៏គួរ ។

ខមួយ ទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ សំវេល្ហិយំ និវាសេតុំ** ថាភិក្ខុកុំគប្បីស្ងៀកចងក្បិន ដោយអាការ: ដូចអ្នកចំបាប់ និងអ្នកធ្វើការជាដើម បើស្ងៀកចងក្បិនត្រូវទុក្កដ ។ ស្ងៀកដូច្នេះសូម្បីមានជំងឺឬដើរផ្លូវក៏មិនគួរ ។ មនុស្សទាំងឡាយដើរផ្លូវទៅ គេលើកមុំសំពត់ឡើងម្ខាងឬទាំងសងខាង ចុកខាងលើសំពត់ស្ងៀកក្តី ស្ងៀកសំពត់ខាងក្នុងមួយជាន់ដូច្នោះ ហើយស្ងៀកសង្ក្ត់មួយជាន់ខាងក្រៅទៀតក្តី ទាំងអម្បាលនេះ មិនគួរដល់ភិក្ខុ ។ ក៏ឯមានជំងឺ ក្នុងសំពត់នឹងសម្តែងឲ្យជាល្ងរខាងក្នុងហើយស្ងៀកខាងលើមួយជាន់ទៀតក៏បាន មិនមានជំងឺ កាលនឹងស្ងៀកពីរជាន់ គប្បីតម្រួតគ្នាឲ្យជាជាន់ ហើយស្ងៀកចុះ កិរិយាស្ងៀកដែលឃាត់ក្នុងបទនេះក្តី ក្នុងសេខិយ:ក្តី ទាំងអម្បាលនេះ គប្បីវៀរចេញ គប្បីបិទមណ្ឌលបី ស្ងៀកឲ្យជាបរិមណ្ឌល កុំឲ្យមានវិការ: កាលបើភិក្ខុណា ធ្វើឲ្យមានវិការ:ណាមួយ មិនរួចអាបត្តិទុក្កដ ។

ខមួយទៀតភិក្ខុកុំគប្បីដណ្តប់ដូចគ្រហស្ថ ដ្ឋិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ឱហិតាវុតំ ចារុបិតុំ** ថាភិក្ខុកុំគប្បីដណ្តប់ដូចគ្រហស្ថ បើដណ្តប់ត្រូវទុក្កដ ។ ដណ្តប់បិទកាយពីខាងលើខាងក្រោម សំយុងទុក

ដូចនិគ្រន្ថក្តី នឹងដណ្តប់យកចីពរដាក់លើចង្ហ្ងយស្មាទាំងសងខាង ហើយ
បើកទ្រូងដូចបរិព្វាជកជំពូកខ្ទះក្តី នឹងដណ្តប់យកជាយសំពត់ស្ដៀកបិទ
ខ្នង យកជ្រុងទាំងសងខាងដាក់លើចង្ហ្ងយស្មាសងខាង ដូចមនុស្សមាន
សំពត់តែមួយក្តី នឹងដណ្តប់យកសំពត់ព័ន្ធព័ទ្ធកសំយុងជាយទាំងពីរ ចុះ
មកខាងពោះ ឬបោះជាយទាំងពីរទៅខាងខ្នង ដូចអ្នកលេងសុរាជាដើមក្តី
នឹងដណ្តប់ទទួរទាំងអស់ សម្ដែងតែរង់ក្ដែក ដូចស្ត្រីក្នុងរាំងជាដើម នឹង
ដណ្តប់សំពត់រែងយកជាយសំពត់ម្ខាងព័ទ្ធខ្ជួនទាំងអស់ ដូចគហបតីអ្នកធំ
និងរុំជាយសំពត់សាដកចេញហើយសិកចូលក្នុងក្ដៀក ព័ទ្ធខ្ជួនដោយ
ជាយសំពត់ម្ខាង ដូចអ្នកស្រែនឹងចូលខ្ទមស្រែក្តី នឹងដណ្តប់យកសំពត់
សិកចូលក្នុងចន្ទោះក្ដៀកទាំងពីរដាក់ឡើងលើចង្ហ្ងយស្មា ដូចព្រាហ្មណ៍ក្តី
នឹងដណ្តប់បើកដើមដៃធ្វេង ដោយសំពត់ដណ្តប់ធ្ងៀងស្មាម្ខាង និងឃ្ងុំ
ហើយលើកចីវរឡើងដាក់លើចង្ហ្ងយស្មាម្ខាង ដូចភិក្ខុអ្នកចាត់ចែងឲ្យអង្គុយ
ជាជួរគ្នាជាលំដាប់ ដណ្តប់ដូច្នេះ ឬដណ្តប់យ៉ាងដទៃ ក្រៅចាក
លក្ខណៈនៃបរិមណ្ឌលទាំងពួងនោះ ឈ្មោះថាដណ្តប់ដូចគ្រហស្ថទាំង
អស់ ភិក្ខុកុំគប្បីដណ្តប់ដូច្នេះ គប្បីវៀរទោសនៃកិរិយាដណ្តប់ទាំងពួង
យ៉ាងនេះក្តី យ៉ាងដទៃក្រៅអំពីនេះក្តី ហើយគប្បីដណ្តប់ឲ្យជាបរិមណ្ឌល
កុំឲ្យមានវិការ: កាលមិនដណ្តប់ដូច្នោះ នឹងធ្វើឲ្យមានវិការ:ណាមួយ
ក្នុងទីអារាម ឬក្នុងលង្វែកភូមិ ដោយសេចក្ដីមិនអើពើ ត្រូវទុក្កដ ។

ខមួយទៀត ភិក្ខុកុំគប្បីទ្រង់សំពត់មានពណ៌ផ្សេងៗ មានពណ៌ខៀវជាដើម ដ្បិតព្រះពុទ្ធអង្គទ្រង់បញ្ញត្តទុកថា **ន ភិក្ខវេ សព្ព-នីលកានិ ចីវរានិ ន សព្ពបីតកានិ ន សព្ពលោ-ហិតកានិ ន សព្ពមញ្ជិដ្ឋកានិ ន សព្ពកណ្ហានិ ន សព្ពមហារង្គរត្តានិ ន សព្ពមហាជាមរត្តានិ ន អច្ឆិន្ន-ឧសានិ ន ឌីឃឧសានិ ន បុប្ផឧសានិ ន ផលឧសានិ ន ផណាឧសានិ ចីវរានិ ជាវេតព្វានិ ន ឧកញ្ចុកំ ន តីរិដំ ន វេដ្ឋនំ ជាវេតព្វំ** សេចក្តីថា ភិក្ខុកុំគប្បីទ្រង់សំពត់ពណ៌ខៀវទាំងអស់ដូចផ្កាត្រកៀត ពណ៌លឿងទាំងអស់ដូចផ្កាកណិការ ពណ៌ក្រហមទាំងអស់ដូចផ្កាច្បា ពណ៌ក្រហមប្រឿងទាំងអស់ដូចចំបើង ពណ៌ខ្មៅទាំងអស់ដូចពណ៌ផ្ទៃផ្ការ ពណ៌ក្រហមចាស់ទាំងអស់ដូចខ្នងកន្ទ្រៃ ពណ៌ក្រហមលាយគ្នាទាំងអស់ដូចស្លឹកឈើទុំ (ក្នុងអដ្ឋកថា ឈ្មោះកុរុន្ទីថាពណ៌ដូចផ្កាឈូក) និងសំពត់មានជាយ មិនបានកាត់ សំពត់មានជាយវែង សំពត់មានជាយដូចផ្កាឈើ សំពត់មានជាយដូចផ្ទៃឈើ សំពត់មានជាយជាផែន និងអាវ និងមួក និងសំពត់ឈ្នួតក្បាល ភិក្ខុអង្គណាទ្រង់សំពត់ទាំងអម្បាលនេះ ត្រូវទុក្កដ ។ សំពត់ខៀវជាដើម គប្បីគក់យកទឹកជ្រលក់ចេញ ហើយជ្រលក់ជាថ្មី ស្ងៀកដណ្តប់ចុះ បើមិនអាចនឹងគក់ចេញបាន ក៏គប្បីធ្វើជាសំពត់ក្រាលដេក ឬជាក់ក្នុងជាន់កណ្តាល

នៃចីវរពីរជាន់ សំពត់មានជាយមិនបានកាត់ និងមានជាយវែង គប្បីកាត់ជាយចេញស្ងៀកដណ្តប់ចុះ អាវ ខោ បានមកហែកវះចេញហើយជ្រលក់ប្រើប្រាស់ក៏គួរ សូម្បីក្នុងសំពត់ឈ្នួតក្បាលក៏ដូចគ្នា មួកដែលគេធ្វើដោយសម្បកឈើ គួរធ្វើជាសំពត់ជូតជើងបាន ។

ខមួយទៀត សូម្បីសំពត់សម្បកឆ្មែ ក៏មិនគួរ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ចោជ្ជកោ ឯវាសេតព្វោ** សេចក្តីថា ភិក្ខុកុំគប្បីស្ងៀកដណ្តប់សំពត់សម្បកឆ្មែ បើស្ងៀកត្រូវទុក្កដ ។ សំពត់ធ្វើដោយសម្បកវាក់ សម្បកចេក សម្បកវៃទឹកជាដើម ក៏មានគតិដូចសម្បកឆ្មែដោយពិត ។

ខ មួយទៀត ទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ពាហិរ-លោមិ ឧណ្ណា ធារេតព្វា** សេចក្តីថា ភិក្ខុគប្បីកុំស្ងៀកដណ្តប់សំពត់បាវរ: ធ្វើដោយពោមចៀម ធ្វើឲ្យពោមចេញខាងក្រៅ បើដណ្តប់ដូច្នោះត្រូវទុក្កដ ។ ដណ្តប់ធ្វើឲ្យពោមចូលខាងក្នុងនោះគួរ ។

ខ មួយទៀត ភិក្ខុកុំគប្បីអង្គុយត្រចោមជង្គង់ដោយសំពត់សង្ឆាដី បើអង្គុយត្រចោមដូច្នោះត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ សង្ឆាដិបល្លត្ថិកាយ និសីទិតព្វំ** ។ អង្គុយត្រចោមជង្គង់ដោយអាយោគគួរ ដ្បិតជារបស់ដែលព្រះពុទ្ធអង្គទ្រង់អនុញ្ញាត ។

ខ មួយទៀត ទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ចាតុម្មាសំ និសីទនេន វិប្ប្រវសិតព្ពំ** *ថាភិក្ខុកុំគប្បីនៅប្រាសចាកសំពត់រងបង្គុយមានជាយ ៣ ដែលឈ្មោះថានិសីទន: អស់ ៤ ខែ បើនៅប្រាសចាកដូច្នេះ ត្រូវទុក្កដ ។*

ខមួយទៀត ភិក្ខុកុំគប្បីមានតែសំពត់ស្មៀកសំពត់ដណ្តប់ពីរផ្នត់ប៉ុណ្ណោះ មិនគ្រប់ត្រៃចីវរចូលទៅក្នុងស្រុក បើចូលទៅដូច្នោះត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ សន្តរុត្តរេន គាមោ បវិសិតព្ពោ** *។ បច្ច័យគឺហេតុដើម្បីនឹងទុកសំពត់សង្ឆាដីនិងចីពរស្បង់ណាមួយ មិនត្រូវយកទៅផងនោះ មាន ៥ គឺ* **តិណាឡោ ឯ ហោតិ** *ភិក្ខុមានជំងឺ ១* **វស្សិកសង្ខេតំ ឯ ហោតិ** *មានកំណត់ដោយរដូវភ្លៀង ៤ ខែ ១* **ឆឌ្ឌិតាសំ ឯ ហោតិ** *ភិក្ខុទៅកាន់ត្រើយស្ទឹងខាងនាយ ១* **អត្ថឌ្ឍកុត្តិវិហារោ ឯ ហោតិ** *វិហារមានការរក្សាទ្វារមាំមួន ១* **អត្ថតកឋិនំ ឯ ហោតិ** *ភិក្ខុបានក្រាលកឋិនហើយ ១ ។ ដាក់គន្ធ:រក្សាកុដិមួយចំណែកនេះជាប្រមាណ ។ ក្នុងកិរិយាមានជំងឺ និងសង្កេតថារដូវភ្លៀង និងទៅកាន់ឆ្នេរស្ទឹង និងបានក្រាលកឋិនហើយ ៤ នេះ កាលបើកុដិវិហាររក្សាហើយ នឹងចេញទៅក្រៅវត្តក៏គួរ ។ កាលបើមិនរក្សាមិនគួរ ។ ឯភិក្ខុនៅក្នុងព្រៃ វិហារកុដិដែលរក្សាដោយគន្ធ:សន្ធាក់មិនមាន ភិក្ខុនោះគប្បីយកសំពត់ទុកដាក់ក្នុងធ្នាំងសម្រាប់ដាក់របស់លាក់ទុកក្នុងទីកំបាំង មានក្រហែងថ្មនិងរូងឈើជាដើម ហើយសឹមទៅ ។*

បច្ច័យគឺហេតុដែលនឹងទុកជាក់សំពត់ងូតទឹកភ្ជៀងហើយទៅ ក៏មាន ៥ ទី ១ ទី ៣ ទី ៤ ដូចបទមុន ទី ២ ថា **ជិណ្ណាមំ ឧទ្ធំ ឯ ហោតិ** *ភិក្ខុទៅកាន់ទីឥតមានសីមា ១ ទី ៥ ថា* **វស្សិកសាដិកា អកតា ឯ ហោតិ វិប្ផកតា ឯ** *សំពត់ងូតទឹកភ្ជៀងភិក្ខុមិនទាន់បានធ្វើ ឬធ្វើមិនទាន់ហើយ ១ ។*

ចីវរបដិសំយុត្តកថា ចប់

យានាទិកថា

ពណ៌នាអំពីយានជាដើម ។ ១មួយ ភិក្ខុគ្មានជំងឺកុំគប្បីទៅដោយយានមានដំរី សេះ រទេះជាដើម បើទៅត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ យានេន យាយិតព្ពំ យោ យាយេយ្យ អាបត្តិ ទុក្កដស្ស** *ដូច្នេះ ។ ភិក្ខុមានជំងឺទៅដោយយានគួរ ។ យានទោះទឹមដោយបុរស ឬគោឈ្មោល មានស្ត្រីជានាយសារថី ឬបុរសជានាយសារថី ក៏គួរ ។ យានទឹមដោយគោញី មិនគួរ ។ ភិក្ខុមានជំងឺក៏មិនគួរ ។ ឯយានរុញអូសទៅដោយដៃ ស្ត្រី ឬបុរស រុញអូសទៅក៏គួរ ។ ត្រែសែងនិងអង្រឹងសំពត់ចងក្នុងឫស្សី ក៏គួរ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា* **អនុជានាមិ ភិក្ខវេ តិលានស្ស យានំ ។ អនុជានាមិ ភិក្ខវេ បុរិសយុត្តំ ហត្ថវដ្ដកំ ។ អនុជានាមិ ភិក្ខវេ សិវិកំ ចាជង្ហ្លិ** *ដូច្នេះ ។*

ខមួយទៀត ភិក្ខុគ្មានជំងឺ កុំពាក់ស្បែកជើងចូលស្រុក បើពាក់ចូលស្រុកត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ សឧចាហានេន គាមោ បវិសិតព្ពោ យោ បវិសេយ្យ អាបត្តិ ទុក្កដស្ស** *ដូច្នេះ ។ បើមានជំងឺ ពាក់ស្បែកជើងចូលស្រុកក៏គួរ ដ្បិតទ្រង់អនុញ្ញាតទុកថា* **អនុជានামិ ភិក្ខវេ តិណានេន ភិក្ខុនា សឧចាហានេន គាមំ បវិសិតុំ** *ដូច្នេះ ។*

ខមួយទៀត ថាភិក្ខុកុំគប្បីពាក់ស្បែកជើង ២ ជាន់ ៣ ជាន់ បើពាក់ត្រូវទុក្កដ ។ ស្បែកជើង ១ ជាន់ និង ៤ ជាន់ គួរក្នុងប្រទេសទាំងពួង ។ ដ្បិតទ្រង់អនុញ្ញាតនិងហាមឃាត់ទុកថា **អនុជានামិ ភិក្ខវេ ឯកបលាសិកំ ឧចាហានំ ន ភិក្ខវេ ឌិកុណា ឧចាហានា ធារេតព្ពា ន តិកុណា ឧចាហានា ធារេតព្ពា ន ឯណាជ្ជណ្ហ-ចាហានា ធារេតព្ពា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស** *ដូច្នេះ ។ ស្បែកជើង ៤ ជាន់ជារបស់ថ្មី នៅមិនទាន់បានប្រើប្រាស់ គួរតែក្នុងបច្ចន្តប្រទេសប៉ុណ្ណោះ ក្នុងមជ្ឈិមប្រទេសមិនគួរ ដ្បិតបញ្ញត្តិនេះជាបទេសបញ្ញត្តិ ។ ឯបញ្ញត្តិដែលជាបទេសបញ្ញត្តិនោះ អនុញ្ញាតចំពោះតែក្នុងបច្ចន្តប្រទេសមួយជំពូក មាន ៤ ប្រការ ដ្បិតទ្រង់អនុញ្ញាតទុកថា* **អនុជានামិ ភិក្ខវេ សព្ពបច្ចន្តិមេសុ ជនបទេសុ រិនយ-ឆរបញ្ចមេន គណេន ឧបសម្ប៎ទំ ។ ល ។ គណ-ឋ្ឋណាចាហានំ ។ ល ។ ឆុវនហានំ ។ ល ។ ចម្មានិ**

អត្ថរណានិ ឯឬកចម្ម៏ អ៨ចម្ម៏ មិ០ចម្ម៏ *សេចក្ដីថា តថាគតអនុញ្ញាតឲ្យគណ:សង្ឆមានវិន័យធរជាគម្រប់ប្រាំ ឲ្យឧបសម្បទាកុលបុត្ត១ប្រការ ១ អនុញ្ញាតស្បែកជើង ៤ ជាន់ ឡើងទៅប្រការ ១ អនុញ្ញាតងូតទឹកជានិច្ចប្រការ ១ អនុញ្ញាតស្បែកចៀម ស្បែកពពែ ស្បែកម្រ៉ឹគជាគ្រឿងកម្រាលប្រការ ១ ទាំង ៤ ប្រការនេះ គួរក្នុងបច្ចន្តជនបទទាំងពួង ក្នុងមជ្ឈិមប្រទេស មិនគួរ ។ ក្នុងមជ្ឈិមប្រទេស គណ:សង្ឆទាំងវិន័យធរផង តាំងពី ១០ អង្គឡើងទៅ ឲ្យឧបសម្បទាកុលបុត្ត១ទើបគួរ ដ្ឋិតទ្រង់បញ្ញត្តទុកថា* **ន ភិក្ខវេ ២ណ១ណ១សវ០ណ្ដ១ ០ណ០ណ ២ប-សម្ប០ណ១ត០ំ អនុជានាមិ ភិក្ខវេ ១ណ១សវ០ណ្ដ១ ០ ០ អ០ិ-២ណ១ណ១សវ០ណ្ដ១ ០ ០ណ០ណ ២ប១ណ១ណ១ត០ុ** *សេចក្ដីថា គណ:សង្ឆមានវគ្គ ១០ បើខ្ទះកុំឲ្យឧបសម្បទាដល់កុលបុត្ត បើឲ្យឧបសម្បទាត្រូវទុក្ខដតថាគតអនុញ្ញាតសង្ឆមានវគ្គ ១០ ឬលើសជាង ១០ ឲ្យឧបសម្បទាកុលបុត្តក្នុងមជ្ឈិមប្រទេស មជ្ឈិមប្រទេសស្បែកជើង ៤ ជាន់ជារបស់ថ្មីមិនគួរ ដូចសម្ដែងហើយអំពីមុននោះ ។ ក្នុងមជ្ឈិមប្រទេស មិនមានសម័យកន្ទ:ខែទើបងូតទឹកបានម្ដង ដូចសម្ដែងហើយក្នុងនហានសិក្ខាបទ ស្បែកណាមួយក្នុងមជ្ឈិមប្រទេសមិនគួរឡើយ ដ្ឋិតទ្រង់ហាមឃាត់ទុកថា* **ន ០ក០ញ្ចិ ០ ០ម្ម៏ ០ ០ ០

ទុកថា **ឯណិមិគো** ទ្រាយ **រាតមិគো** ស្មាន់ **បសទមិគো** ក្តាន់ **ការុន្ធមិគো** ប្រើស **មិតមាតុកោ** ម្រឹគត្រាស **ពោហិត-មិគោ** រមាំង ស្បែកម្រឹគទាំងអស់នេះ គួរក្នុងបច្ចន្តប្រទេស ។ សត្វដទៃ គឺ **មកដោ** ស្វា **ការ្ចសីហោ** រាជសីហ៍ខ្មៅ **សរភោ** ការ-ប្រមា **ការលិមិគោ** ឈ្វូស **ពាឍ្ឍមិគោ** ម្រឹគកាច ខ្ទះថា ម្រឹគសាហាវ ស្បែកសត្វទាំងអស់នេះ មិនគួរក្នុងប្រទេសទាំងពួង ។ **សីហាឲ្យ្ឆអច្ឆតរច្ឆា** បានន៏ងរាជសីហ៍ ខ្លាធំ ខ្លាឃ្មុំ ខ្លារខិន ឈ្មោះ ថាពាឡម្រឹគ មិនមែនតែពួកសត្វប៉ុណ្ណោះឡើយ សូម្បីស្បែកនៃសត្វ ជំពូកណា ដែលពោលទុកថាគួរ លើកតែសត្វជំពូកនោះចេញ សត្វ សល់ពីនោះ ដោយហោចទៅសូម្បីតែ គោ ក្របី ទន្សាយ ធ្នា ជាដើម ទាំងអស់នេះ ឈ្មោះថាពាលម្រឹគក្នុងរឿងនេះ ស្បែកនៃសត្វទាំងពួងនោះ មិនគួរ ។ ដែលថាមិនគួរនោះ អាស្រ័យគេហួងហែងទុកប្រើប្រាស់ដេក អង្គុយ ជារបស់បុគ្គល បើជាគ្រឿងសម្រាប់ប្រើប្រាស់ក្នុងសេនាសនៈជា របស់សង្ឆ គួរទាំងអស់ ។ តាមពាក្យក្នុងអដ្ឋកថាថា **សីហចម្មាឌីនំ ហិ បរិហារណោយេវ បដិក្ខេ្ចបោ សេនាសនបរិភោគេ បន អកប្ប្យិយំ ជាម ជត្តិ** ដូច្នេះ ។ ស្បែកទាំងពួងជាគិហិវិកដ ជារបស់គ្រហស្ថ ឬគ្រាន់តែជាគ្រឿងចងព័ន្ធ នឹងអង្គុយផ្ទែក នឹងអង្គុយ សង្ត្ត់ក៏គួរ នឹងដេកសង្ត្ត់មិនគួរ ដ្ឋិតទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ កិហិវិកដំ អភិនិសីឌិតុំ ន ត្ថេវ អភិនិបជ្ជិតុំ**

អនុជានាមិ ភិក្ខវេ ពន្ធនមត្តំ អភិនិសីទិតុំ ដូច្នេះ ។ ក្នុងស្បែកជើង លើកតែស្បែកមនុស្សចេញ នឹងធ្វើដោយស្បែកណាមួយក៏គួរទាំងអស់ សូម្បីក្នុងស្រោមស្បែកជើង ស្រោមកាំបិត និងស្រោមកូនសោ ក៏ដូចគ្នា ។

ខមួយទៀត ភិក្ខុកុំគប្បីពាក់ស្បែកជើងពណ៌ផ្សេងៗ មានពណ៌ខៀវជាដើម ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ សព្វនីលកា ឧចាហាជា ។ ល ។ ន សព្វមហាជាមរត្តា ឧចាហាជា ជាវេតព្វា** ភិក្ខុកុំគប្បីពាក់ស្បែកជើងពណ៌ខៀវទាំងអស់ ដូចពណ៌ផ្កាត្រកៀត និងលឿងទាំងអស់ ដូចផ្កាកណិការធំ និងក្រហមទាំងអស់ ដូចផ្កាច្បា និងពណ៌ក្រហមប្រឿងៗ ដូចភ្ជុកដំរី ដូចចំបើង និងខ្មៅទាំងអស់ ដូចពណ៌ផ្ទៃផ្ការ និងក្រហមក្រមៅទាំងអស់ ដូចពណ៌ខ្ជង្ហែ និងស្បែកជើងពណ៌ក្រហមលាយគ្នា ដូចពណ៌ស្ទឹកឈើទុំ (ក្នុងអដ្ឋកថា ការុន្ទី ថាដូចពណ៌ផ្ការ) បើភិក្ខុណា ពាក់ស្បែកជើងពណ៌ដូច្នេះ ត្រូវទុក្កដ ។ ក្នុងស្បែកជើងទាំងអស់នេះណាមួយ បានមកហើយជូតទឹកថ្នាំដោយកំណាត់សំពត់ ទម្លាយពណ៌ចេញហើយពាក់ក៏គួរ ។ សូម្បីនឹងទម្លាយពណ៌ចេញតែបន្តិចក៏គួរ ។

ខមួយទៀត សូម្បីស្បែកជើងមានខ្សែពណ៌ខៀវ លឿងក្រហមប្រឿងៗ ពណ៌ខ្មៅ ពណ៌ក្រហម ពណ៌ច្រាលលាយគ្នា ក៏មិនគួរ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ នីលកាវ ទ្ធិកា**

ឧចាហរណ៍ ។ ល ។ ន សព្វមហាតាមវត្ថវិកា ឧចាហរណ៍ ជាវេតញ្ច *ដូច្នេះ ។ ឯស្បែកជើងដែលមានខ្សែពណ៌ខៀវជាដើមទាំងអស់នោះ គប្បីទម្លាយពណ៌នោះចេញជាមុន ទើបគួរពាក់ ។*

ខមួយទៀត ភិក្ខុកុំគប្បីពាក់ស្បែកជើងបិទកែងជើង បិទខ្នងជើងជាដើម ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ១ល្ហកពន្ធា ន បុដ-ពន្ធា ន ចាលិកុណ្ឌិកា ន តូលបុណ្ណិកា ន តិត្តិរបត្តិកា ន មេណ្ឌាវិសាណវិកា ន អជវិសាណវិកា ន ១ិច្ឆិ-កាឍ្ឍិកា ន មោរបិញ្ជបរិសិត្ថិតា ន ចិត្រា ឧចាហរណ៍ ជាវេតញ្ច** *ភិក្ខុកុំគប្បីពាក់ស្បែកជើងដែលចងស្បែកតាំងអំពីផ្នែកឡើងមក បិទកែង និងស្បែកជើងបិទខ្នងជើងទាំងអស់រហូតដល់ស្មង បីដូចស្បែកជើងអ្នកស្រុកយោនក: និងស្បែកជើង បិទតែខ្នងជើងប៉ុណ្ណោះ មិនបានបិទស្មង និងស្បែកជើងញាត់ដោយគរ និងស្បែកជើងមានខ្សែដ៏វិចិត្រដូចស្ងាបទទា និងស្បែកជើងមានខ្សែសណ្ឋានដូចស្នែងកែះត្រង់ទីដែលធ្វាក់ និងស្បែកជើងមានខ្សែសណ្ឋានដូចស្នែងពពែត្រង់ទីដែលធ្វាក់ និងស្បែកជើងមានខ្សែសណ្ឋានដូចកន្ទុយខ្ជួយត្រង់ទីដែលធ្វាក់ និងស្បែកជើងដែលស្រែះដេរដោយវង់កន្ទុយក្ងោកត្រង់ផ្នែ ឬត្រង់ខ្សែដូចដេរនឹងអំបោះ និងស្បែកជើងវិចិត្រដោយសណ្ឋានផ្សេងៗ ភិក្ខុណាពាក់*

ស្បែកជើងទាំងនេះ ត្រូវទុក្កដ ។ ក្នុងស្បែកជើងណាមួយបានមក អាចនឹងនាំយកស្បែកបិទកែងជាដើមចេញបាន ក៏គប្បីនាំចេញប្រើប្រាស់ចុះ ។ ស្បែកបិទកែងជាដើមនោះមាននៅ កាលបើប្រើប្រាស់ ត្រូវទុក្កដ ។

ខមួយទៀត សូម្បីស្បែកជើងប្រកបដោយស្បែកពាជសីហ៍ជាដើមក្នុងទីបំផុតដោយជុំវិញ ដូចប្រក អនុវាតចីវរ ក៏មិនគួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ សីហចម្មបរិក្ខ្ជា ឧចាហានា ធារេតព្វា ។ ល ។ ន ព្យគ្ឃចម្ម- ន ឌីបិចម្ម- ន អជិនចម្ម- ន ឧទ្ធចម្ម- ន មជ្ជារិចម្ម- ន ការាកចម្ម- ន ឧលូកចម្មបរិក្ខ្ជា ឧចាហានា ធារេតព្វា យោ ធារេ-យ្យ អាបត្តិ ទុក្កដស្ស**[1] *ភិក្ខុ កុំគប្បីពាក់ស្បែកជើងដែលចំព័ទ្ធដោយជុំវិញ ដោយស្បែកពាជសីហ៍ ដោយស្បែកខ្លាធំ ដោយស្បែកខ្លាដំបង ដោយស្បែកខ្លារខិន ដោយស្បែកកេ ដោយស្បែកធ្នា ដោយស្បែកកង្កែន ដោយស្បែកមៀម បើភិក្ខុណា ពាក់ស្បែកជើងដូចសម្តែងមកនេះ ត្រូវទុក្កដ ។ សូម្បីបានស្បែកជើងទាំងអម្បាលនេះណាមួយមក គប្បីយកស្បែកទាំងអម្បាលនោះចេញ ហើយប្រើចុះ ។*

ខមួយទៀត ព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ភិក្ខុមិនត្រូវពាក់ទ្រនាប់ជើងឈើ ទ្រនាប់ជើងធ្វើដោយស្ពឹកត្នោត ធ្វើដោយស្ពឹកឫស្សី ធ្វើដោយស្មៅ ធ្វើដោយស្មៅយាប៉ូង ធ្វើដោយស្មៅដំណេកទន្សាយ ធ្វើ

១- វិនយបិដក មហាវគ្គ ទុតិយភាគ ចម្មក្ខន្ធក: ទំព័រ ១៧៨ ។

ដោយស្ពឹកទន្សៃ ធ្វើដោយស្មៅមានពណ៌ដូចផ្កាឈូក ធ្វើដោយសំពត់កម្ពល ទ្រនាប់ជើងធ្វើដោយមាស ដោយប្រាក់ ដោយកែវមណី ដោយកែវពិទូរ្យ ដោយកែវផ្ទេក ដោយសំរិទ្ធ ដោយកែវ ដោយសំណប៉ាហាំង ដោយសំណកក់ ដោយទង់ដែង ទាំងអម្បាលនេះ ទ្រនាប់ជើងណាមួយ ដែលនាំឈានដើរទៅបាន បើភិក្ខុណាពាក់ទ្រនាប់ជើងដូច្នេះ ត្រូវទុក្កដ ។

ខមួយទៀត ព្រះពុទ្ធអង្គទ្រង់ហាមឃាត់ និងអនុញ្ញាតទុកថា ន ច ភិក្ខវេ ការិ សង្ហ្គមនីយា ចាឧការ ជាវេតព្ជ យោ ជាវយ្យ អាបត្តិ ឧក្ក្ជ ្ជ ្ជ

ខមួយទៀត ភិក្ខុជាអាចារ្យ ឬភិក្ខុឈ្មមធ្វើជាអាចារ្យក្តី ឧបជ្ឌាយ៍ ឬភិក្ខុ ឈ្មមធ្វើជាឧបជ្ឌាយ៍ក្តី មិនបានពាក់ស្បែកជើងដើរទៅ ភិក្ខុកំលោះពាក់ ស្បែកជើងដើរទៅ ត្រូវទុក្កដ ។ ដ្ឋិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ អាចរិយេសុ អាចរិយមត្តេសុ ឧបជ្ឌាយេសុ ឧបជ្ឌាយ-មត្តេសុ អនុចាហានេសុ ចង្ក្រមមានេសុ សឧចាហានេន ចង្ក្រមិតព្ពំ យោ ចង្ក្រមេយ្យ អាបត្តិ ទុក្កដស្ស** ដូច្នេះ ។ បព្ជ្ជាចារ្យ អ្នកឲ្យសរណគមន៍ បំបួសជាសាមណេរ ១ ឧបសម្ប្ជាទាចារ្យ អ្នកសូត្រកម្មវាចា ឲ្យឧបសម្ប្ជាទាជាភិក្ខុ ១ និស្សយាចារ្យ អ្នកឲ្យនិស្សយ ១ ឧទ្ទេសាចារ្យ អ្នកឲ្យឧទ្ទេស គឺបាលីនិងអដ្ឋកថា ១ ទាំង ៤ នេះឈ្មោះថា អាចារ្យក្នុងបទនេះ ។ ភិក្ខុមានវស្សា ៦ ឈ្មោះថាអាចរិយមត្ត ឈ្មមជា អាចារ្យនៃភិក្ខុដែលមិនទាន់មានវស្សា ដ្ឋិតថាភិក្ខុមិនទាន់មានវស្សានោះ នឹងសូមនិស្សយ៍លោក ក្នុងកាលដែលខ្លួនមានវស្សា ៤ ក៏បាន ភិក្ខុមាន វស្សា ៧ ឈ្មោះថាអាចរិយមត្តនៃភិក្ខុ ១ វស្សា, ភិក្ខុមានវស្សា ៨ ឈ្មោះថា អាចរិយមត្តនៃភិក្ខុ ២ វស្សា, ភិក្ខុមានវស្សា ៩ ឈ្មោះថាអាចរិយមត្តនៃ ភិក្ខុ ៣ វស្សា, ភិក្ខុមានវស្សា ១០ ឈ្មោះថាអាចរិយមត្តនៃភិក្ខុ ៤ វស្សា, ភិក្ខុជាមិត្តធ្ងាប់ជួប ធ្ងាប់គប់រក របស់ឧបជ្ឌាយ៍ខ្លួន ឬភិក្ខុណាមួយដែល ចាស់ជាងខ្លួន តាំងពីវស្សា ១០ ឡើងទៅ ភិក្ខុទាំងពួងនោះ ឈ្មោះ ថា ឧបជ្ឌាយមត្ត ឈ្មមជាឧបជ្ឌាយ៍បាន កាលភិក្ខុទាំងនេះ មិនបាន ពាក់ស្បែកជើងដើរទៅ ភិក្ខុខ្វីវស្សាពាក់ស្បែកជើងដើរទៅ ត្រូវទុក្កដ ។

យានាទិកថា ចប់

មំសកថា

ពណ៌នាអំពីសាច់ ។ ខមួយ ភិក្ខុកុំទទួលសាច់ឆៅត្រីឆៅ ។ ខមួយ ភិក្ខុកុំធាន់សាច់ឆៅត្រីឆៅ ។ បើទទួល បើធាន់ ត្រូវទុក្កដ ។ ដ្បិតព្រះអដ្ឋកថាចារ្យលោកអាស្រ័យពាក្យក្នុងព្រះសូត្រ ដែលទ្រង់ហាមទុកថា **អាមកមំសបដិក្ខេបាណា** ភិក្ខុជាអ្នកវៀរចាកការទទួលសាច់ឆៅ ។ នឹងអាស្រ័យពុទ្ធានុញ្ញាតថា **អនុជានាមិ ភិក្ខវេ អមនុស្សិកាពាធេន អាមកមំសំ ខាទិតុំ បិវិតុំ អាមកលោហិតំ** តថាគតអនុញ្ញាតឲ្យភិក្ខុដែលអមនុស្សចូលបៀតបៀន ធាន់សាច់ឆៅ ផឹកឈាមឆៅបាន ព្រោះអាបត្តិទាំងពីរនេះ ឈ្មោះថាបាលីមុត្តកទុក្កដ ។

ខមួយ ភិក្ខុកុំគប្បីធាន់ឧទ្ទិសមំសៈ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ និងអនុញ្ញាតទុកថា **ន ភិក្ខវេ ជានំ ឧទ្ទិស្ស កតំ មំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ តិកោដិបរិសុទ្ធំ មច្ឆមំសំ អទិដ្ឋំ អសុតំ អបរិសង្ការ៉ាតំ**[1] សាច់ ដែលគេធ្វើចំពោះភិក្ខុ គឺសម្រាប់ដើម្បីភិក្ខុ កាលភិក្ខុដឹងកុំគប្បីធាន់ បើធាន់ត្រូវទុក្កដ ។ តថាគតអនុញ្ញាតត្រី សាច់ ដែលបរិសុទ្ធដោយចំណែក ៣ គឺមិនបានឃើញ

១- វិនយបិដក មហាវគ្គ ទុតិយភាគ ភេសជ្ជក្ខន្ធក: ទំព័រ ៣៣៧ ។

មិនបានឮ មិនបានរង្គៀស ថាគេសម្ងាប់ចំពោះភិក្ខុ ។ គប្បីដឹង ការរង្គៀសដោយបានឃើញ រង្គៀសដោយបានឮ និងរង្គៀសដោយមិនបានឃើញ មិនបានឮ ។ ឯរង្គៀសដោយបដិបក្ខនោះ ភិក្ខុណាឃើញមនុស្សកាន់សំណាញ់និងអង្រ្ពតជាដើម ចេញចាកភូមិឬត្រាច់ទៅក្នុងព្រៃ វេលាព្រឹកចូលទៅបិណ្ឌបាតក្នុងស្រុកនោះ អ្នកស្រុកគេថ្វាយបិណ្ឌបាតទាំងត្រីនិងសាច់ផង ភិក្ខុនោះអាស្រ័យបានឃើញអំពីដើម ហើយរង្គៀសថា គេធ្វើដើម្បីភិក្ខុទាំងឡាយទេដឹង ដូច្នេះឈ្មោះថារង្គៀសដោយបានឃើញ ។ ភិក្ខុមិនបានឃើញសោះឡើយ គ្រាន់តែបានឮថា មនុស្សទាំងឡាយកាន់សំណាញ់និងអង្រ្ពតជាដើម ចេញអំពីស្រុកឬត្រាច់ទៅក្នុងព្រៃ វេលាព្រឹកភិក្ខុចូលទៅបិណ្ឌបាតក្នុងស្រុកនោះ គេបង្ហោនបិណ្ឌបាតទាំងត្រីនិងសាច់ចូលមកប្រគេន ភិក្ខុរង្គៀសថា គេធ្វើចំពោះភិក្ខុទេដឹង ដូច្នេះឈ្មោះថារង្គៀសដោយបានឮ ។ ឯមិនបានឃើញ មិនបានឮនោះគឺ គ្រាន់តែចូលទៅបិណ្ឌបាតក្នុងស្រុក ទាយកទទួលបាត្រទៅ តាក់តែងបិណ្ឌបាត ទាំងត្រី ទាំងសាច់ នាំមកប្រគេន ភិក្ខុរង្គៀសថា គេធ្វើចំពោះភិក្ខុទេឬ ដូច្នេះ ឈ្មោះថារង្គៀសដោយមិនបានឃើញ មិនបានឮ ។ បើរង្គៀសដោយហេតុទាំង ៣ នេះ ក្នុងរបស់ណា នឹងទទួលរបស់នោះមិនគួរ របស់ណាមិនរង្គៀសដូច្នេះ របស់នោះទើបគួរ ។ ថាបើគេសួរថា ហេតុអ្វីទើបលោកមិនទទួល ភិក្ខុប្រាប់ថា អាត្មារង្គៀសដូច្នេះ ។ បើគេពោលថារបស់នេះ ខ្ញុំមិនបានធ្វើដើម្បី

ភិក្ខុទាំងឡាយ ខ្ញុំធ្វើដើម្បីខ្លួនខ្ញុំទេ ឬពោលថា ខ្ញុំធ្វើដើម្បីពលីកម្មមាន ឲ្យដល់ឥស្សរជនជាដើម ដូច្នេះគួរ ។ បើទាយកពោលថា សាច់សត្វ ស្ងាប់ ទិញមកអំពីវានផ្សារ ដូច្នេះក៏គួរ ។ សូម្បីក្នុងសាច់និងត្រីដែលគេ ធ្វើដើម្បីបេតកិច្ច ឲ្យដល់មនុស្សស្ងាប់ ឬដើម្បីមង្គលក៏ដូចគ្នា ។ សាច់ និងត្រីឯណាគេមិនបានសម្ងាប់ដើម្បីភិក្ខុក្តី ភិក្ខុមិនសង្ស័យក្នុងសាច់និងត្រី ឯណាក្តី របស់ទាំងពួងនោះរមែងគួរ ។ បើគេសម្ងាប់ចំពោះភិក្ខុក្នុងវិហារ ភិក្ខុនោះ មិនដឹងថាគេសម្ងាប់ចំពោះខ្លួន តែភិក្ខុដទៃដឹង ភិក្ខុណាដឹងមិនគួរ ដល់ភិក្ខុនោះ គួរតែភិក្ខុដែលមិនដឹង ។ ភិក្ខុក្នុងវិហារដទៃមិនដឹង ភិក្ខុដែល នៅក្នុងវិហារនោះឯងដឹង រមែងមិនគួរដល់ភិក្ខុក្នុងវិហារនោះ គួរដល់តែ ភិក្ខុក្នុងវិហារដទៃ ។ បើភិក្ខុក្នុងវិហារនោះក៏ដឹង ភិក្ខុក្នុងវិហារដទៃក៏ដឹង មិនគួរទាំងអស់គ្នា ។ ភិក្ខុទាំងអស់មិនដឹងក៏គួរដល់ភិក្ខុទាំងអស់ ។ សាច់ និងត្រី ដែលគេសម្ងាប់ចំពោះសហធម្មិកទាំង ៥ ណាមួយក្តី ក៏មិនគួរដល់ សហធម្មិកទាំង ៥ ។ បើគេចំពោះភិក្ខុមួយអង្គ សម្ងាប់សត្វ តាក់តែងបិណ្ឌ-បាតមកប្រគេនដល់ភិក្ខុនោះ បើភិក្ខុនោះដឹងថា គេសម្ងាប់ចំពោះខ្លួន ទទួលមកឲ្យភិក្ខុដទៃ ភិក្ខុដទៃធាន់ដោយជឿភិក្ខុនោះ ដូច្នេះមិនត្រូវអាបត្តិ ទាំងពីរអង្គ ព្រោះគេចំពោះភិក្ខុណា ភិក្ខុនោះមិនបានធាន់ ភិក្ខុដែល ធាន់នោះមិនដឹង ទើបមិនត្រូវអាបត្តិ ។ នឹងត្រូវអាបត្តិ ព្រោះទទួល សាច់ជាកប្ប្ដិយមំសៈ ក៏ទេ មិនដឹងថាគេសម្ងាប់ចំពោះភិក្ខុ ភិក្ខុធាន់ហើយ ទើបដឹងខាងក្រោយ កិច្ចដែលសម្ដែងអាបត្តិនោះមិនមាន ។ ភិក្ខុមិនដឹងជា

អកប្ប៊ិយមំសៈហើយធាន់ លុះខាងក្រោយទើបបានដឹង គប្ប៊ីសម្ដែងអាបត្តិចេញ ព្រោះថាសាច់និងត្រីដែលគេសម្ងាប់ចំពោះកិក្ខុ កិក្ខុដឹងហើយធាន់ទើបត្រូវអាបត្តិ ។ សាច់ជាអកប្ប៊ិយ សូម្ប៊ីមិនដឹង ធាន់ហើយក៏គង់ត្រូវអាបត្តិប្រាកដ ។ ព្រោះហេតុនោះ កិក្ខុដែលខ្ជាចអាបត្តិ គប្ប៊ីកំណត់ឲ្យសមគួរ សួរមុនហើយទើបទទួលសាច់ ឬគប្ប៊ីគិតថា កាលធាន់សឹមសួរទទួលហើយគប្ប៊ីសាកសួរឲ្យបានសេចក្ដីសឹមធាន់ ដ្ប៊ីតថាក្រណាស់ដែលនឹងដឹង ព្រោះសាច់ខ្ជាឃ្ចុំប្រហែលគ្នានឹងសាច់ជ្រូក សាច់ខ្ជាដំបងជាដើមប្រហែលនឹងសាច់ម្រ៊ីគជាដើម ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យពោលថាសួរមុនហើយទើបទទួលនេះឯងជាវត្ត ។

មំសកថា ចប់

តិរច្ឆានវិជ្ជាឧ៊ីកថា

ខមួយ កិក្ខុមិនត្រូវរៀន និងមិនត្រូវប្រាប់ តិរច្ឆានវិជ្ជា បើរៀនបើប្រាប់ ត្រូវទុក្ខដ ។ ដ្ប៊ីតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន កិក្ខវេ តិរច្ឆានវិជ្ជា បរិយាបុណិតព្វា ។ ល ។ ភាចេតព្វា យោ ភាចេយ្យ អាបត្តិ ទុក្កដស្ស** *ដូច្នេះ ។ សិល្ប្ប៊ីសាស្ត្រដំរីសេះ -អាវុធ -លេខ សៃកមន្ត ជន់ជាស់អាគម យន្ត ស្នេហ៍ ថ្នាំស្ពោះអចព្ជ វ៊ីជ្ជាផ្សេងៗ ជាខាងក្រៅ ពុទ្ធសាសនា មិនប្រកបដោយប្រយោជន៍ ជាគ្រ៊ីងបៀតបៀនអ្នកដទៃ លើកតែវ៊ីជ្ជាលេខក្រៅនោះឈ្មោះថាតិរច្ឆានវ៊ីជ្ជាទាំងអស់ កិក្ខុរៀន និងប្រាប់ ត្រូវទុក្ខដ*

ភាប់ដោយបទនិងអក្ខរៈ ។ រៀនលេខ រៀនគម្ពីរមួយឈ្មោះថាជារណ-សត្ថបដិបត្តិ ហើយនិងឲ្យដឹងគម្ពីរដទៃៗ ច្រើនក្តី និងរៀនវិជ្ជាជាបវិត្ត ការពារយក្ខ -បិសាច ពស់ជាដើម ដើម្បីរក្សាខ្លួនទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។

ខមួយទៀត ភិក្ខុមិនត្រូវរៀន មិនត្រូវប្រាប់គម្ពីរលោកាយតៈទេ បើរៀន បើប្រាប់ ត្រូវទុក្កដ ។ ដ្ឋិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ លោកាយតំ បរិយាបុណិតព្ពំ ។ ល ។ ភាសិតព្ពំ យោ ភាសេយ្យ អាបត្តិ ទុក្កដស្ស**[១] ដូច្នេះ ។ គម្ពីររបស់តិរ្ថិយ ប្រកបដោយហេតុឥតប្រយោជន៍មានដើមថា វត្ថុទាំងពួងជារបស់ដែល (សំណាល់) និងវត្ថុទាំងពួងមិនមែនជារបស់ដែល (គឺជារបស់ថ្នោង) ក្អែកស កុកខ្មៅ ដូច្នេះឈ្មោះថាគម្ពីរលោកាយតៈ ។

ខមួយទៀត ព្រះពុទ្ធអង្គទ្រង់ហាមឃាត់និងអនុញ្ញាតទុកថា **ន ភិក្ខវេ ពុទ្ធវចនំ ឆន្ទសោ អាភោតេតព្ពំ យោ អាភោតេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ សកាយ និរុត្តិយា ពុទ្ធវចនំ បរិយាបុណិតុំ**[២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវលើកពុទ្ធវចនៈតាមឆន្ទ (ភាសាសំស្ត្រឹត) ទេ ភិក្ខុណាលើក ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរៀនពុទ្ធវចនៈ តាមសកភាសា (មគធភាសា) ដែលព្រះសម្មាសម្ពុទ្ធតែងពោល ។

(១- ២ វិនៃយបិដក ចុល្លវគ្គ ទុតិយភាគ ខុទ្ទកវត្ថុក្ខន្ធកៈ ទំព័រ ២៣០

ខមួយទៀត ព្រះថេរៈមិនបានអាវធនា កុំគប្បីសម្តែងធម៌ ។ ដ្បិត ព្រះពុទ្ធអង្គទ្រង់ហាមឃាត់និងអនុញ្ញាតទុកថា **ន ភិក្ខវេ សង្ឆមជ្ឌេ អនជ្ឌិជ្ជេន ឩម្ហោ ភាសិតព្វោ អនុជានាមិ ភិក្ខវេ ថេរេន ភិក្ខុនា សាមំ វា ឩម្ហំ ភាសិតុំ បរំ វា អជ្ឌេសិតុំ** ភិក្ខុមិនមានថេរៈអាវធនា កុំគប្បីសម្តែងធម៌ក្នុងទីកណ្តាលសង្ឆ បើសម្តែងត្រូវទុក្កដ ។ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈសម្តែងធម៌ខ្លួនឯង ឬនិមន្តអ្នកដទៃឲ្យសម្តែង ។ កិរិយានិមន្តសម្តែងធម៌នេះជាប់នៅនឹងភិក្ខុអ្នកនិមន្តដែលសង្ឆសន្ធតទុក ឬជាប់នៅនឹងព្រះសង្ឆត្តេរ ។ កាលបើភិក្ខុអ្នកនិមន្តមិនមាន ត្រូវប្រាប់ព្រះសង្ឆត្តេរមុនសិន ឬព្រះសង្ឆត្តេរនិមន្តហើយ ទើបសម្តែងបាន ។ សូម្បីព្រះសង្ឆត្តេរសោត បើភិក្ខុធម្ម-កថិកមានច្រើនក្នុងវិហារ ក៏គប្បីបង្គាប់ទុកតាមលំដាប់វារៈធម្មកថិក គឺព្រះថេរៈបង្គាប់ថា លោកចូរពោលធម៌ ឬចូរសម្តែងធម៌ ឬចូរឲ្យធម្មទានដូច្នេះ ហើយគប្បីសម្តែងធម៌ដោយវិធី ៣ ប្រការ គឺលោកបង្គាប់ឲ្យសូត្របាលី សូត្របានតែបាលីមួយជំពូក, លោកបង្គាប់ឲ្យសម្តែង បានតែសម្តែងមួយជំពូក, លោកបង្គាប់ឲ្យពោលសរភញ្ញ បានតែពោលសរភញ្ញប៉ុណ្ណោះ ។ សូម្បីព្រះសង្ឆត្តេរនឹងគង់លើអាសនៈខ្ពស់ អាវធនា ក៏មិនបានឡើយ បើមានតែឧបជ្ឌាយ៍និងសទ្ធិវិហារិកប៉ុណ្ណោះ ឧបជ្ឌាយ៍លោកគង់នៅលើអាសនៈខ្ពស់ បង្គាប់ថាលោកចូរសម្តែងធម៌ ឲ្យសទ្ធិវិហារិកគប្បីអធិដ្ឋានជាស្វាធ្យាយហើយទើបសម្តែង ។ បើភិក្ខុកំលោះមាននៅក្នុង

ទីនោះផង ក៏គប្បីធ្វើអាភោគចិត្តថា យើងនឹងសម្តែងដល់ភិក្ខុកំលោះហើយ ទើបសម្តែង ។ បើក្នុងវិហារ ព្រះសង្ឆត្តេរបង្គាប់តែសិស្សនៃខ្លួនប៉ុណ្ណោះ មិនអាចធនាភិក្ខុដទៃ ដែលជាអ្នកសម្តែងពីរោះខ្លះ ភិក្ខុដទៃគប្បីពោលនឹងព្រះសង្ឆត្តេរថា ខ្ញុំព្រះករុណានឹងនិមន្តភិក្ខុឈ្មោះនោះឲ្យសម្តែង ។ បើព្រះសង្ឆត្តេរទទួលឬស្ងៀមនៅក្តី នឹងអាចធនាឲ្យភិក្ខុដទៃសម្តែងក៏គួរ ។ ថាបើព្រះសង្ឆត្តេរឃាត់ចេញសោត ក៏កុំគប្បីអាចធនាភិក្ខុដទៃឲ្យសម្តែង ។ កាលបើព្រះសង្ឆត្តេរនៅមិនទាន់មកឡើយ ភិក្ខុប្រារព្ធធម្មស្សវនៈឡើង ហើយព្រះសង្ឆត្តេរទើបនិមន្តមកទៀតសោត កិច្ចដែលនឹងឈប់ហើយនឹងប្តឹងមិនមាន ។ កាលបើសូត្របាលីចប់ហើយ នឹងសម្តែងសេចក្តី គប្បីប្តឹង ឬកុំឈប់នឹងសម្តែងទៅតែម្តងក៏បាន ។ សូម្បីកំពុងសម្តែងសេចក្តី ព្រះសង្ឆត្តេរមកទៀតសោតក៏ដូចគ្នា សូម្បីតែក្នុងឧបនិសិន្នកថា សម្តែងដល់មនុស្សចូលមកអង្គុយជិតហើយសាកសួរ ព្រះសង្ឆត្តេរមែងជាធំ ព្រោះហេតុនោះ ព្រះសង្ឆត្តេរគប្បីសម្តែងដោយខ្លួនឯង ឬបង្គាប់ភិក្ខុដទៃឲ្យសម្តែង ក៏ប៉ុន្តែថា ព្រះសង្ឆត្តេរកុំអង្គុយលើឧច្ចាសនៈបង្គាប់ ក៏ឯភិក្ខុកំលោះនឹងគិតថា យើងនឹងពោលដល់គ្រហស្ថ សូម្បីនឹងសម្តែងក៏គួរ ។ គ្រហស្ថគេសួរបញ្ហានឹងភិក្ខុដែលគេស្គាល់ ភិក្ខុនោះគប្បីប្តឹងព្រះថេរៈជាមុនសិន សឹមវិសជ្ជនា បើព្រះសង្ឆត្តេរ កាលភិក្ខុកំលោះប្តឹងថា គេសួរបញ្ហានឹងខ្ញុំព្រះករុណាដូច្នេះហើយ លោកបង្គាប់ឲ្យវិសជ្ជនា ឬលោកស្ងៀមនៅ ភិក្ខុកំលោះនឹងសម្តែងក៏គួរ ។ សូម្បីក្នុងការអនុមោទនា

ជាដើម ក្នុងលង្វែកភូមិក៏ដូចគ្នា បើព្រះសង្ឆត្ថេរអនុញ្ញាតទុកឲ្យអំពីដំបូងថា ក្នុងវិហារឬក្នុងលង្វែកភូមិក្តី លោកកុំគប្បីប្រាប់យើងឡើយ គប្បីសម្តែងទៅចុះដូច្នេះ ឈ្មោះថាមានកាលដ៏សមគួរហើយ នឹងសម្តែងធម៌ក្នុងទីទាំងពួងក៏គួរ ។ សូម្បីគួរនឹងស្វាធ្យាយក៏ត្រូវប្រាប់ព្រះថេរៈជាមុនប្រាប់ព្រះថេរៈតែមួយអង្គ ហើយកំពុងតែស្វាធ្យាយនៅឡើយ ព្រះថេរៈអង្គដទៃនិមន្តមកទៀតសោត កិច្ចដែលនឹងត្រូវប្រាប់នោះមិនមាន បើចង់ចិត្តថាយើងនឹងឈប់សម្រាកសិនហើយ ហើយក៏ឈប់ស្ងៀម ព្រះថេរៈអង្គដទៃមកទៀត កាលបើប្រារព្ធនឹងសម្តែងទៀត ក៏គប្បីប្រាប់សិន ។ សូម្បីព្រះថេរៈមិនទាន់និមន្តមក កំពុងតែប្រារព្ធស្វាធ្យាយក៏ដូចគ្នា ។ ព្រះសង្ឆត្ថេរមួយអង្គអនុញ្ញាតទុកអំពីដំបូងថា លោកកុំគប្បីប្រាប់ដល់យើងទៀតឡើយ ចូរទន្ទេញ ស្វាធ្យាយ តាមសប្បាយចុះ ដូច្នេះនឹងទន្ទេញសូត្ររៀនតាមសប្បាយក៏គួរ ។ កាលបើព្រះថេរៈអង្គដទៃនិមន្តមកទៀតសោត គប្បីប្តឹងលោកជាមុនហើយ សឹមទន្ទេញសូត្ររៀន ។

ខមួយទៀត ថាភិក្ខុកុំគប្បីច្រៀងសូត្រសម្តែងធម៌ដោយសំឡេងដ៏រ៉ែង គឺទម្លាយបង់នូវវត្តនោះៗ ញ៉ាំងអក្ខរៈឲ្យវិនាសទៅ បើច្រៀងសូត្រសម្តែងដូច្នោះ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ អាយតកេន ឧគ្គណ្ហិតព្ពោ យោ ការយេយ្យ អាបត្តិ ទុក្កដស្ស**[1] ដូច្នេះ ។ រីឯវត្ត

១- វិនយបិដក ចុល្លវគ្គ ទុតិយភាគ ខុទ្ទកវត្ថុក្ខន្ធកៈ ទំព័រ ១៣៥

ឈ្មោះថា សុត្តន្តវត្តក៏មាន ជាតកវត្តក៏មាន ឈ្មោះថា គាថាវត្តក៏មាន នៅក្នុងធម៌ ញ្ចាំងវត្តនោះ។ ឲ្យវិនាស ធ្វើសំឡេងឲ្យវែងណាស់មិនគួរ គប្បីសម្តែងបទនិងព្យញ្ជនៈឲ្យជាបរិមណ្ឌលដោយវត្តដ៏មូល ។ សរភញ្ញ គឺសូត្រនិងពោលដោយសំឡេងជាទំនង ជាឃ្លា។ ដែលព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុក ។ បានឮថាក្នុងសរភញ្ញមានវត្ត ៣២ មានតវង្គវត្ត ទំនងដូចរលក ទោហកវត្ត ទំនងដូចរឹតទឹកដោះគោ គលិតវត្ត ទំនងដូចជាវត្ថុដែលភ្ជាត់ធ្លាក់ចុះជាដើម ។ ក្នុងទំនងវត្តទាំងអម្បាលនោះ ភិក្ខុប្រាជ្ញាធ្វើទំនងណា ធ្វើទំនងនោះក៏បាន តែថាកុំញ្ចាំងបទនិងព្យញ្ជនៈទាំងពួងឲ្យវិនាស កុំធ្វើឲ្យមានវិការៈ ហើយធ្វើសំឡេងឲ្យប្រព្រឹត្តទៅដោយន័យដ៏មានជ្រុងបួន សមគួរដល់សមណៈ នេះឯងជាលក្ខណៈក្នុងសរភញ្ញ ។ ការច្រៀងដោយសំឡេងច្រៀងដ៏វែងៗ មានទោស ៥ ប្រការដូច្នេះ គឺ អ្នកច្រៀងនោះ រមែងត្រេកអរក្នុងសំឡេងនៃខ្លួននោះ ១ អ្នកដទៃរមែងត្រេកអរក្នុងសំឡេងនោះ ១ គហបតីទាំងឡាយរមែងពោលទោស ១ បុគ្គលដែលពេញចិត្តនឹងការសូត្ររលាក់រលៃកសំឡេង រមែងខូចសមាធិ ១ ពួកជនខាងក្រោយមានសិស្សជាដើម រមែងនឹងដល់នូវទិដ្ឋានុគតិ (យកតម្រាប់តាម) ថា សូម្បីអាចារ្យនិងឧបជ្ឌាយ៍នៃយើង លោកក៏ស្រែកសូត្រច្រៀងដូច្នេះដែរ ហើយក៏ស្រែកច្រៀងសូត្របទដូច្នោះ ១ ត្រូវជា ៥ ប្រការដូច្នេះ ។

ខមួយទៀត ភិក្ខុដទៃខ្ជីសំពត់តម្រង់ទឹកកុំកំណាញ់ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ អជ្ឌានមគ្គបដិបន្នេន ភិក្ខុនា បរិស្សាវនំ យាចិយមានេន ន ទាតព្ពំ យោ ន ददेय्य អាបត្តិ ទុក្កដស្ស** ម្នាលភិក្ខុទាំងឡាយ ភិក្ខុដើរផ្លូវធ្ងាយដាច់ស្រយាល កាលបើគេខ្ជីសំពត់តម្រង់ទឹក កុំគប្បីមិនឲ្យ បើភិក្ខុណាមិនឲ្យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុណាមានសំពត់តម្រង់ទឹកក្នុងដៃខ្លួនហើយ ក្ងែងខ្ជី បើមិនប្រាថ្នានឹងឲ្យដល់ភិក្ខុនោះ កុំគប្បីឲ្យឡើយ ។

ខមួយទៀត ភិក្ខុគ្មានសំពត់តម្រង់ទឹកកុំដើរផ្លូវធ្ងាយ ភិក្ខុណាដើរទៅ ត្រូវអាបត្តិទុក្កដ ។ បើសំពត់តម្រង់ទឹកនិងធម្មក្រកមិនមានសោតសូម្បីតែមុំសង្ឃាដី ក៏គប្បីអធិដ្ឋានថា យើងនឹងត្រង់ដោយមុំសង្ឃាដីនេះ ក្រេបផឹកដូច្នេះ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់និងអនុញ្ញាតទុកថា **ន ច ភិក្ខវេ អបរិស្សាវនកេន អជ្ឌានមគ្គោ បដិបជ្ជិ-តព្ពោ ។ ល ។ បរិស្សាមីតិ** ដូច្នេះ ។

តិរច្ឆានវិជ្ជាទិកថា ចប់

សទ្ធាទេយ្យាទិកថា

ខមួយ ភិក្ខុកុំគប្បីធ្វើរបស់សទ្ធាទេយ្យឲ្យធ្លាក់ចុះ គឺកុំឲ្យអនាមដ្ឋ-បិណ្ឌបាតជាដើមដល់គ្រហស្ថ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតនិងហាម

ឃាត់ទុកថា **អនុជានামិ ภิกฺขเว มาตาปิตูสํ ฐาตุํ ฉ จ ภิกฺขเว สทฺธาเทยฺยํ วินิจาเตตฺวํ** . . . ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតដើម្បីឲ្យរបស់ដែលទាយកឲ្យដោយសទ្ធា ដល់មាតា-បិតា តែថាកុំញ៉ាំងរបស់ដែលគេឲ្យដោយសទ្ធា ឲ្យធ្លាក់ចុះ ឲ្យវិនាស ឲ្យខូច គឺឲ្យដល់ញាតិដ៏សេស បើឲ្យធ្លាក់ចុះដូច្នោះ ត្រូវទុក្កដ ។ សូម្បីមាតានិងបិតាបិតនៅក្នុងរាជសម្បត្តិ បើប្រាថ្នាហើយក៏គួរឲ្យ ។ របស់ធាន់ដែលបានមកថ្មីនៅមិនទាន់បានធាន់សោះ ឈ្មោះថាអនាមដ្ឋបិណ្ឌបាត អនាមដ្ឋបិណ្ឌបាតនេះ ក៏ឈ្មោះថាសទ្ធាទេយ្យ របស់គេឲ្យដោយសទ្ធា ។ ក្នុងរឿងធ្វើថ្នាំ អដ្ឋកថាចារ្យលើកយកអនាមដ្ឋបិណ្ឌបាតមួយជំពូកឡើងពោលផង ហាក់ដូចជានឹងចង្អុលឲ្យជាប្រធាន ក្នុងបច្ច័យដ៏សេស អ្នកមានបញ្ញាគប្បីពិចារណាមើលចុះ ។

ខមួយ ភិក្ខុកុំគប្បីធ្វើថ្នាំឲ្យដល់មនុស្សមិនមែនញាតិ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកក្នុងវិនីតវត្ថុថា **អាបត្តិ ธุกฺกฏสฺส** ដូច្នេះ ។ ព្រោះហេតុនោះ អ្នកដទៃមកសូមថ្នាំ កុំគប្បីធ្វើឲ្យ បើធ្វើឲ្យត្រូវទុក្កដ ។ ភិក្ខុ ភិក្ខុនី នាងសិក្ខមានា សាមណេរ សាមណេរី ទាំង ៥ នេះ ឈ្មោះថាសហធម្មិក គប្បីធ្វើថ្នាំឲ្យចុះ ដ្បិតជនទាំងអម្បាលនេះ មានសីល សទ្ធា បញ្ញាស្មើគ្នា ប្រកបក្នុងត្រៃសិក្ខា នឹងមិនធ្វើថ្នាំឲ្យមិនបាន កាលនឹងធ្វើឲ្យ បើគ្រឿងថ្នាំមនុស្សអម្បាលនេះមានសោត ក៏គប្បីយកមកផ្សំឲ្យ បើមិនមានក៏គប្បីយកគ្រឿងថ្នាំរបស់ខ្លួនមកធ្វើឲ្យ បើរបស់ខ្លួនមិនមានសោត ក៏

គប្បីស្វែងរកដោយកិច្ចាចារវត្ត ឬស្វែងរកអំពីញាតិនិងមនុស្សបវារណា កាលបើមិនបាន ក៏គប្បីរក សូម្បីដោយអកតវិញ្ញត្តិ ដើម្បីមនុស្សឈឺនេះ ហើយគប្បីធ្វើឲ្យ សូម្បីមនុស្សទាំង ៥ ជំពូកគឺ មាតា បិតា អ្នកឧបដ្ឋាក មាតាបិតា វេយ្យាវច្ចករបស់ខ្លួន បណ្ដុបលាស: គឺមនុស្សអ្នកនឹងមកបួស ចាត់ចែងដុតបាត្រជ្រលក់ចីវរនៅក្នុងវិហារ នឹងធ្វើថ្នាំឲ្យដល់មនុស្សទាំង អម្បាលនេះក៏គួរ ។ បើមាតាបិតាជាឥស្សរជនមិនប្រាថ្នា នឹងមិនធ្វើឲ្យក៏ គួរ ។ បើបិតនៅក្នុងរាជសម្បត្តិហើយ តែប្រាថ្នានឹងឲ្យធ្វើ នឹងមិនធ្វើឲ្យមិន គួរ ។ មាតាបិតាកាលបើប្រាថ្នាថ្នាំ គប្បីឲ្យថ្នាំ កាលបើមិនចេះផ្សំ គប្បីផ្សំ ឲ្យ គប្បីស្វែងរកថ្នាំ ដើម្បីប្រយោជន៍ដល់មនុស្ស ៥ ជំពូកនេះ ដោយ ន័យដូចពោលហើយក្នុងសហធម្មិកចុះ ។ បើនាំមាតាមកបដិបត្តិក្នុងវិហារ កុំចាប់ពាល់ គប្បីធ្វើនូវបរិកម្មទាំងពួង គប្បីឲ្យខាទនីយ:ភោជនីយ:ដោយ ដៃខ្លួន ចំណែកបិតា គប្បីធ្វើការឧបដ្ឋាក មានផ្ងូតទឹកនិងច្រចាប់ដោយ ដៃខ្លួនជាដើម ដូចឧបដ្ឋាកសាមណេរ សូម្បីអ្នកឧបដ្ឋាកមាតាបិតា ក៏គួរ ធ្វើឲ្យ ដូចមាតាបិតាចុះ ។ មនុស្សវេយ្យាវច្ចករនោះ ជំពូកណាកាន់យក ឈ្នួលហើយ ទៅកាប់ឧសក្នុងព្រៃ ឬកំពុងតែធ្វើការណាមួយ កាលមាន រោគកើតឡើង គប្បីធ្វើថ្នាំឲ្យដល់អ្នកនោះ ទម្រាំញាតិគេនឹងមកឃើញ ។ អ្នកណាជាសិស្សនៃភិក្ខុនៅធ្វើការទាំងពួង អ្នកនោះគួរភិក្ខុនឹងធ្វើថ្នាំឲ្យជា ប្រាកដ សូម្បីក្នុងបណ្ដុបលាស: ក៏គួរបដិបត្តិដូចសាមណេរនោះចុះ ។ មនុស្ស ១០ ជំពូកទៀត គឺបងប្រុស ប្អូនប្រុស បងស្រី ប្អូនស្រី បង

ស្រីមាតា ប្អូនស្រីមាតា បងប្រុសបិតា ប្អូនប្រុសបិតា បងស្រីប្អូនស្រីបិតា បងប្រុសប្អូនប្រុសមាតា ធ្វើថ្នាំឲ្យដល់មនុស្ស ១០ ជំពូកនេះក៏គួរ ។ កាលនឹងធ្វើឲ្យ គប្បីកាន់យកគ្រឿងថ្នាំរបស់មនុស្សជំពូកនោះមក គ្រាន់តែផ្សំឲ្យ បើគ្រឿងថ្នាំមនុស្សអម្បាលនោះមិនមាន គេសូមថា លោកចូរឲ្យចុះ ខ្ញុំព្រះករុណានឹងសងវិញ ក៏គប្បីឲ្យជារបស់ខ្ញី បើគេមិនសូម ក៏គប្បីប្រាប់ថា ថ្នាំរបស់យើងមាន អ្នកចូរខ្ចីយកទៅចុះ ឬគប្បីចងចិត្តថា របស់គេមានកាលណា គេនឹងឲ្យកាលណោះវិញ ដូច្នេះ ធ្វើឲ្យទៅចុះ ។ បើគេសងវិញក៏គួរកាន់យក បើគេមិនសងក៏កុំទារអំពីគេ ។ កុំគប្បីឲ្យថ្នាំដល់មនុស្សដទៃក្រៅអំពីញាតិ ១០ ជំពូកនោះ ។ ឯភិក្ខុកាលឲ្យគេយកចតុប្បច្ច័យ ៤ មកឲ្យដល់ខ្លួន ដោយលំដាប់បុត្តនៃញាតិ ១០ នោះ ដរាបដល់វង្សត្រកូល ៧ តំណ មិនជាអកតវិញ្ញូ ធ្វើថ្នាំឲ្យមិនជាវេជ្ជកម្ម និងជាអាបត្តិ ព្រោះកុលទូសក: ។ បើភរិយានៃបងប្អូនប្រុស ឬស្វាមីនៃបងប្អូនស្រី គេមានជំងឺ បើគេជាញាតិពិត ធ្វើថ្នាំឲ្យគេផងក៏គួរ បើគេមិនមែនជាញាតិ គប្បីធ្វើឲ្យដល់បងប្អូនប្រុស ឬបងប្អូនស្រីរបស់ខ្លួនថា អ្នកចូរឲ្យក្នុងទីបដិបត្តិនៃអ្នកចុះ ។ មួយទៀត គប្បីធ្វើឲ្យដល់បុត្តនៃមនុស្សទាំងអម្បាលនោះ ហើយប្រាប់ថា ឯងចូរឲ្យដល់មាតាបិតារបស់ឯងចុះ ។ វិនិច្ឆ័យក្នុងបទទាំងពួង គប្បីដឹងដោយឧបាយនេះ ។ កាលនឹងប្រើសាមណេរឲ្យរកថ្នាំមកអំពីព្រៃ ដើម្បីញាតិទាំងអម្បាលនោះ គប្បីប្រើសាមណេរដែលជាញាតិឲ្យរកមក ឬឲ្យរកមកដើម្បីខ្លួន សូម្បីសាមណេរ

សោត គប្បីរកមកដោយវត្តនៃសិស្សថា យើងនឹងយកមកឲ្យឧបជ្ឈាយ៍ដូច្នេះ ។ មាតាបិតានៃឧបជ្ឈាយ៍មានជំងឺមកកាន់វិហារ ឧបជ្ឈាយ៍ចៀសចេញទៅកាន់ទិស សទ្ធិវិហារិកគប្បីកាន់យកគ្រឿងថ្នាំរបស់ឧបជ្ឈាយ៍ធ្វើឲ្យ បើគ្រឿងថ្នាំរបស់ឧបជ្ឈាយ៍មិនមាន គប្បីលះថ្នាំរបស់ខ្លួនដើម្បីឧបជ្ឈាយ៍ហើយធ្វើឲ្យចុះ បើរបស់ខ្លួនមិនមាន គប្បីស្វែងរកដោយកិច្ច-ចារវត្តជាដើមដូចពោលហើយ ធ្វើឲ្យជារបស់ឧបជ្ឈាយ៍ហើយទើបឲ្យចុះ ។ សូម្បីតែឧបជ្ឈាយ៍សោត ក៏គួរតែបដិបត្តិក្នុងមាតាបិតានៃសទ្ធិវិហារិកដូចគ្នានោះចុះ ។ ក្នុងអាចារ្យនិងអន្តេវាសិកក៏ដូចគ្នា ។ សូម្បីមនុស្សដទៃណាជាអាគន្ទុក: ឬជាចោរ ឬជាមនុស្សចាញ់ទ័ពរត់មក ឬជាមនុស្សឥស្សរ:ឬជាមនុស្សគឺញាតិលះបង់ចោល ជាមនុស្សដំណើរ មនុស្សទាំងអម្បាលនេះមានជំងឺចូលមកកាន់វត្ត ភិក្ខុកាលមិនប្រាថ្នាវត្ថុអ្វី ក៏គប្បីធ្វើថ្នាំឲ្យដល់មនុស្សទាំងអម្បាលនោះចុះ ។ ត្រកូលអ្នកមានសទ្ធាឧបដ្ឋាកដោយចតុ-ប្បច្ច័យបិតនៅក្នុងទីជាមាតាបិតានៃសង្ឆ ក្នុងត្រកូលនោះ បើអ្នកណាមួយមានជំងឺ គេអាស្រ័យមនុស្សឈឺ ពោលដោយវិស្សាស:ថា លោកចូរធ្វើថ្នាំឲ្យដូច្នេះ កុំគប្បីឲ្យ កុំគប្បីធ្វើឡើយ បើគេដឹងកាលដ៏សមគួរហើយសួរថា រោគដូច្នេះគេធ្វើថ្នាំដូចម្តេច នឹងពោលថា គេយកវត្ថុនេះផង វត្ថុនោះផង មកផ្សំធ្វើជាថ្នាំដូច្នេះគួរ បើគេថាមាតាខ្ញុំព្រះករុណាឈឺ លោកចូរប្រាប់ថ្នាំដល់ខ្ញុំព្រះករុណាចុះ កុំគប្បីប្រាប់ គប្បីនិយាយនូវគ្នានិងគ្នាថា ភិក្ខុឈ្មោះឯណោះ កើតរោគដូច្នេះ គេផ្សំថ្នាំដូចម្តេច ភិក្ខុផងគ្នានិយាយ

ឡើងថា គេយកវត្ថុនេះ។ មកផ្សំថ្នាំ គ្រហស្ថគេបានឮចាំបាន យកទៅ ធ្វើថ្នាំឲ្យដល់មាតាគេដូច្នេះក៏គួរ ។ បានឮថា សូម្បីព្រះមហាបទុមត្ថេរ លោកក៏បដិបត្តិដូច្នេះដែរ គប្បីបដិបត្តិក្នុងកេសជ្ជ: ដូច្នេះ ។ ក៏ឯក្នុង បវិត្ត បើគ្រហស្ថពោលថា លោកចូរធ្វើបវិត្តឲ្យដល់មនុស្សឈឺដូច្នេះ ភិក្ខុ កុំគប្បីធ្វើ កាលណាបើគេពោលថា លោកចូរសូត្របវិត្តឲ្យដល់មនុស្ស ឈឺស្តាប់ គប្បីធ្វើចុះ បើនឹងគិតថា ធម្មតាមនុស្សរមែងមិនដឹងអ្វី កាល បើយើងមិនបានធ្វើឲ្យ ក៏នឹងកើតក្តៅក្រហាយចិត្តផ្សេងៗ ដូច្នេះ គប្បីធ្វើ ឲ្យចុះ ។ គេពោលថា លោកចូរធ្វើទឹកបវិត្ត ធ្វើខ្សែបវិត្តឲ្យដូច្នេះ គប្បីយក ដៃកកូរទឹកច្រចាប់អម្ពោះហើយឲ្យទៅគេចុះ ។ បើឲ្យទឹកទៅអំពីវត្ត ឬឲ្យ អម្ពោះរបស់ខ្លួនសោត ត្រូវទុក្កដ ។ បើគេយកទឹកនិងអម្ពោះមកអង្គុយ ហើយពោលថា លោកចូរសូត្របវិត្ត ដូច្នេះ គប្បីធ្វើចុះ បើគេមិនដឹង សោត ហើយប្រាប់ភិក្ខុឲ្យអង្គុយនៅ រួចយកទឹកមកចាក់លាងជើង យក អម្ពោះដាក់ចុះហើយពោលថា លោកចូរធ្វើបវិត្ត ចូរសូត្របវិត្តដូច្នេះហើយ គេក៏ទៅ ភិក្ខុកុំគប្បីទាញជើងចេញ ដ្បិតថា គេនឹងមានចិត្តក្តៅក្រហាយ ។ គេអាស្រ័យមនុស្សឈឺនៅក្នុងភូមិ បញ្ជូនដំណឹងមកកាន់វត្តថា ព្រះករុ- ណាទាំងឡាយចូរសូត្របវិត្តដូច្នេះ គប្បីសូត្រចុះ ។ រោគ ឬ ឧបទ្ទវ:កើត ឡើងក្នុងស្រុកនិងរាជវាំងជាដើម គេនិមន្តឲ្យចូលទៅសូត្របវិត្ត ក៏គប្បី សូត្រអាដានាដិយសូត្រ ជាដើម ។ គេនិមន្តឲ្យទៅឲ្យសិក្ខាបទ និង សម្តែងធម៌ក្នុងព្រះរាជវាំង ឬ ផ្ទះអាមាត្យ ក៏គប្បីទៅឲ្យសិក្ខាបទ និង

សម្តែងធម៌ចុះ ។ គេនិមន្តឲ្យទៅជាបរិវារកំដរមនុស្សស្លាប់ កុំគប្បីទៅ ។ បើទៅដោយកម្មដ្ឋានជាប្រធាន គឺគិតថា នឹងបានមរណស្សតិ ព្រោះឃើញព្រៃស្មសាន និងឃើញអសុកដូច្នេះក៏គួរ គប្បីបដិបត្តិក្នុងបរិត្តដូចពណ៌នាមកដូច្នេះឯង ។

ក៏ក្នុងបិណ្ឌបាតទៀតសោត របស់ធាន់ ដែលមិនទាន់ធាន់ឈ្មោះថាអនាមដ្ឋបិណ្ឌបាត គួរគប្បីឲ្យដល់អ្នកណា មិនគួរគប្បីឲ្យដល់អ្នកណា គួរគប្បីឲ្យដល់មាតាបិតាប៉ុណ្ណោះ សូម្បីបិណ្ឌបាតនោះតម្លៃ ១ កហាបណៈ ក្តី មិនជាសទ្ធាទេយ្យវិនិបាត មនុស្សឧបដ្ឋាកមាតាបិតា វេយ្យាវច្ចការ ធ្វើការសង្ឃ បណ្ណុបលាសៈ សូម្បីមនុស្សទាំងអម្បាលនេះ ក៏គប្បីឲ្យអនាមដ្ឋបិណ្ឌបាតចុះ ។ បណ្ណុបលាសនោះ សូម្បីដាក់ចុះក្នុងភាជនៈរបស់ខ្លួនហើយឲ្យក៏គួរ មនុស្សក្រៅនោះជាគ្រហស្ថ សូម្បីជាមាតាបិតាដាក់ចុះក្នុងភាជនៈរបស់ខ្លួនឲ្យ មិនគួរ ព្រោះជាបរិក្ខារគ្រឿងប្រើប្រាស់នៃបព្វជិត ឋិតនៅក្នុងទីជាចេតិយដ្ឋាននៃគ្រហស្ថ ។

មួយទៀត អនាមដ្ឋបិណ្ឌបាត គប្បីឲ្យដល់ទាមរិកចោរ និងមនុស្សជាឥស្សរៈដែលមកដល់ ដ្បិតមនុស្សទាំងអម្បាលនោះ កាលមិនឲ្យក៏ក្រោធខឹងថាមិនឲ្យ បើឲ្យរបស់ដែលធាន់សល់ហើយក៏ក្រោធខឹងថា ឲ្យរបស់ជាសំណល់ ក្រោធខឹងហើយក៏នឹងសម្ងាប់ នឹងធ្វើឲ្យអន្តរាយដល់សាសនាផង គប្បីបដិបត្តិក្នុងអនាមដ្ឋបិណ្ឌបាតដូចពោលមកនេះ ។ ក៏ឯបដិសណ្ឋារនោះ គប្បីធ្វើដល់អ្នកណា មិនគប្បីធ្វើដល់អ្នកណា ឯ

បដិសណ្ឋារៈនេះ គួរធ្វើដល់អាគន្ដុកៈ មនុស្សមកថ្មី ឬមនុស្សក្រ ឬចោរ ឬមនុស្សជាឥស្សរៈ ណាមួយក្ដី ដែលមកដល់វិហារ នឹងគួរគប្បីធ្វើដូចម្ដេច បើឃើញមនុស្សអាគន្ដុកៈអស់ស្បៀងមកដល់វិហារ គប្បីឲ្យទឹកផឹក ឲ្យប្រេងលាបជើង បើគេមកដល់ក្នុងវេលាព្រឹក គប្បីឲ្យបបរនិងបាយ គេមកដល់ក្នុងវិកាល បើអង្ករមានសោតគប្បីឲ្យអង្ករ កុំគប្បីពោលថា អ្នកមកដល់ខុសពេល អ្នកចូរទៅចុះ គប្បីរកទីដំណេកឲ្យ កុំប្រាថ្នានូវវត្ថុណាមួយឡើយ គប្បីធ្វើនូវកិច្ចទាំងពួងចុះ គិតថា វិស័យមនុស្សរមែងជាអ្នកឲ្យចតុប្បច្ច័យ កាលបើយើងសង្គ្រោះគេដូច្នេះ គេនឹងជ្រះថ្លារឿយៗ ហើយគេនឹងធ្វើឧបការៈ គំនិតគិតដូច្នេះ កុំឲ្យបង្កើតឡើងបាន ។ ក៏ឯចោរ សូម្បីកណ្ដាៈរបស់សង្ឆ ក៏គប្បីឲ្យទៅចុះ ដើម្បីនឹងការពារកុំឲ្យមានអន្ដរាយខ្ជិចដល់កណ្ដាៈសង្ឆដទៃបាន ។ ក្នុងអដ្ឋកថាលោកនិទានរឿង ភិក្ខុសង្គ្រោះដល់ចោរដោយកណ្ដាៈសង្ឆដូច្នេះ ទុកជាច្រើនរឿង ដើម្បីនឹងសម្ដែងអានិសង្សនៃបដិសណ្ឋារៈ អ្នកមានប្រាថ្នាចង់ដឹងគប្បីមើលយកចុះ គប្បីបដិបត្ដិក្នុងបដិសណ្ឋារៈដូចពណ៌នាមកនេះចុះ ។

សទ្ធាទេយ្យាទិកថាចប់

កុលទូសកកម្ម

ខមួយ ភិក្ខុកុំគប្បីនាំសាសនៈគឺដំណឹងគ្រហស្ថ ។ ខមួយ ភិក្ខុកុំគប្បីសង្គ្រោះត្រកូលដោយឲ្យផ្ការឈើ ផ្លែឈើជាដើម ។ ដ្បិតក្នុងវិកប្ដនៃកុល-

ទូសកសិក្ខាបទ ពោលថា ភិក្ខុឲ្យផ្ការណ្ដៃ ផ្លែណ្ដៃ លម្អិត ដី ណ្ដៃស្ងួត ឬស្សី ធ្វើវេជ្ជកម្ម ឬនាំសាសនៈ គឺដំណឹងនៃគ្រហស្ថមិនមែនញាតិ ទាំងអម្បាលនេះ ឈ្មោះថា កុលទូសក ប្រទូសត្រកូល គឺធ្វើសេចក្ដីជ្រះថ្លានៃត្រកូលឲ្យសាបសូន្យទៅ ដោយកិរិយាបដិបត្តិអាក្រក់ ខុសចាកកិច្ចនៃខ្លួន និងឈ្មោះថា ធ្វើផលទានរបស់គេឲ្យសាបសូន្យទៅផង ដោយធ្វើការសង្គ្រោះដល់គេ គេមិនបានឲ្យដោយសេចក្ដីជ្រះថ្លាក្នុងគុណ មានសីលជាដើម ។ វេជ្ជកម្ម វិធីធ្វើថ្នាំនោះ គប្បីដឹងដូចពោលហើយក្នុងមុននោះចុះ ។

មួយទៀត បុរាណាចារ្យលោកពោលថា គ្រូមើល ឫក្ស យាម ក៏ឈ្មោះថាវេជ្ជកម្មដែរ ។

ពណ៌នាអំពីជង្ឃបេសនិយៈជាមុន ភិក្ខុទទួលសាសនៈ គឺដំណឹងនៃគ្រហស្ថហើយដើរទៅ ត្រូវអាបត្តិទុក្កដ គ្រប់ៗ បទវារៈ ។ សូម្បីធាន់ភោជន ដែលខ្លួនបានមកព្រោះអាស្រ័យកម្មនោះ ក៏ត្រូវទុក្កដ គ្រប់វារៈដែលលេប ។ សូម្បីអំពីដំបូងមិនទទួលពាក្យបណ្ដាំគេ លុះគ្រាក្រោយគិតថា ប្រទេសនេះជាស្រុកដែលគេផ្ដាំនោះ ឥឡូវយើងមកដល់ហើយ យើងជួយប្រាប់ឲ្យគេចុះ សូម្បីចុះចាកផ្លូវទៅ ក៏ត្រូវទុក្កដគ្រប់ ៗ ជំហាន ។ កាលធាន់ភោជនដែលខ្លួនបានព្រោះប្រាប់នូវពាក្យបណ្ដាំនោះក៏ត្រូវទុក្កដ ដោយន័យដូចពោលហើយក្នុងមុន ។ ក៏ឯមិនបានទទួលពាក្យបណ្ដាំគេ មកដល់ហើយគេសួរថា មនុស្សឈ្មោះនេះ

នៅក្នុងភូមិនោះ ដំណឹងតើដូចម្តេចខ្លះ ដូច្នេះនឹងប្រាប់គេក៏គួរ ។ ក្នុងប្រស្នាដែលគេសួរ ប្រាប់គេមិនមានទោស ។ ក៏ឯការនាំសាសនៈដំណឹងនៃសហធម្មិកទាំង ៥ និងមាតាបិតាក្តី និងបណ្ឌិតលាសៈ និងមនុស្សវេយ្យាវច្ចករនៃខ្លួនក្តី ទាំងអម្បាលនេះក៏គួរ ។ ឬគេផ្តាំថា លោកចូរនមស្តារចេតិយ បដិមា ពោធិព្រឹក្ស ព្រះសង្ឆត្តេរ តាមពាក្យខ្ញុំព្រះករុណាក្តី លោកចូរឲ្យភិក្ខុប្រជុំគ្នា ខ្ញុំព្រះករុណានឹងថ្វាយទាន នឹងស្តាប់ធម៌ក្តី ក្នុងដំណឹងទាំងអម្បាលនេះ កុំរង្គៀសឡើយ ដំណឹងទាំងអស់នេះ ជាកប្ប៊ិយសាសនៈ មិនប្រកបទៅដោយកម្មនៃគ្រហស្ថ មិនជាជង្ឍបេសនិយៈ ។

ពណ៌នាអំពីអាការៈមានឲ្យផ្តាឈើជាដើម ភិក្ខុណា នាំទៅឯង ឬឲ្យអ្នកដទៃនាំទៅ ហៅមកឯង ឬឲ្យអ្នកដទៃហៅមក ឬគេមកខ្លួនឯង ឲ្យផ្តាឈើ វត្ថុណាមួយដែលជារបស់ខ្លួនដើម្បីសង្គ្រោះដល់ត្រកូល ត្រូវទុក្កដ ។ ឲ្យផ្តាឈើរបស់អ្នកដទៃក៏ត្រូវទុក្កដ ឲ្យដោយចេយ្យចិត្ត គប្ប៊ីកាត់អាបត្តិតាមតម្លៃរបស់ ។ សូម្ប៊ីក្នុងផ្តាឈើរបស់សង្ឆក៏ដូចគ្នា ក៏ប៉ុន្តែវិសេសប្លែកគ្នា ដោយផ្តាឈើ ដែលគេនិយមដើម្ប៊ីសេនាសនៈ ឲ្យដោយសេចក្តីជាឥស្សរៈត្រូវបុល្ចច្ច័យ ។ ផ្តាឈើនឹងគួរឲ្យដល់អ្នកណា មិនគួរឲ្យដល់អ្នកណា គួរឲ្យដល់មាតាបិតាមុន នឹងយកទៅឲ្យដោយខ្លួនឯង ឬឲ្យអ្នកដទៃយកទៅឲ្យ និងហៅមកឯង ឬឲ្យគេហៅមកឲ្យក៏គួរ ញាតិដ៏សេសឲ្យគេហៅមក ហើយទើបឲ្យគួរ ។ ក្នុងកិរិយាឲ្យនោះ ដើម្ប៊ីនឹងបូជាវត្ថុទាំង ៣ ទើបគួរ បើឲ្យដល់អ្នកណាមួយ ដើម្ប៊ីប្រដាប់ ឬបូជាសិវលិង្គជាដើម

មិនគួរ ។ កាលនឹងឲ្យមនុស្សយកទៅឲ្យដល់មាតាបិតា គប្បីឲ្យសាមណេរ ជាញាតិយកទៅឲ្យ បើសាមណេរមិនមែនជាញាតិ ប្រាថ្នានឹងយកទៅឲ្យ ខ្ជិនឯងសោត នឹងឲ្យយកទៅក៏គួរ ។ ភិក្ខុអ្នកចែកផ្លាឈើដែលសង្ឆ្យសន្ទ្ធ ទុក នឹងឲ្យចំណែកពាក់កណ្តាលដល់សាមណេរ ដែលមកទាន់ក្នុងវេលា ចែកក៏គួរ ។ ក្នុងកុរុន្ទី ថា ឲ្យដល់គ្រហស្ថពាក់កណ្តាលចំណែក ក្នុង មហាបច្ចរី ថាឲ្យតែបន្ដិចក៏គួរ ។ ភិក្ខុដែលសង្ឆ្យមិនបានសន្ទ្ធ ទុក គប្បី អបលោកន៍សិនសឹមឲ្យ ។ សាមណេរគោរពក្នុងអាចារ្យនិងឧបជ្ឌាយ៍ បេះ ផ្លាឈើមកច្រើនគរទុក ព្រះថេរៈប្រាប់ដល់សទ្ធិវិហារិកជាដើម ឬដល់ ឧបាសកដែលមកទាន់អំពីព្រឹក ថាអ្នកចូរកាន់យកផ្លាឈើនេះដូច្នេះ មិន ឈ្មោះថាបុប្ផទាន (ឲ្យផ្លាឈើ) ។ ភិក្ខុកាន់យកផ្លាឈើទៅ គិតនឹងបូជា ព្រះចេតិយ ឬធ្វើការបូជា ឲ្យផ្លាឈើដល់គ្រហស្ថដែលមកដល់ក្នុងទីនោះ ដើម្បីនឹងបូជាព្រះចេតិយ សូម្បីដូច្នេះក៏មិនឈ្មោះថាបុប្ផទាន ។ ភិក្ខុ ឃើញឧបាសក គេបូជាដោយផ្លាវាក់ជាដើម ហើយពោលថាផ្លាកណិការ ជាដើមក៏មាននៅក្នុងវិហារ ឧបាសកចូរកាន់យកទៅបូជាចុះ ដូច្នេះក៏គួរ ។ ភិក្ខុបូជាដោយផ្លាឈើ ហើយចូលទៅស្រុកថ្ងៃណាស់ គេសួរថា ហេតុអ្វី ទើបចូលមកថ្ងៃពេក ប្រាប់ថាផ្លាឈើក្នុងវិហារច្រើន យើងរវល់ធ្វើការ បូជា មនុស្សគេគិតថា ផ្លាឈើក្នុងវិហារមានច្រើន ព្រឹកឡើងគេកាន់ យកខាទនីយភោជនីយាហារមកកាន់វិហារ ធ្វើបុប្ផបូជាហើយថ្វាយទាន ផងក៏គួរ ។ មនុស្សទាំងឡាយគេសូមវារៈបូជាផ្លាឈើថា ដល់ថ្ងៃនោះ

ខ្ញុំព្រះករុណានឹងទៅបូជា ហើយគេមកក្នុងថ្ងៃដែលភិក្ខុអនុញ្ញាតឲ្យផ្តាឈើ តែផ្តាសាមណេរបេះមកទុកអំពីព្រឹកហើយ គេមកមិនឃើញផ្តានៅដើម គេសួរថា ផ្តាទៅណាអស់ទៅ ភិក្ខុប្រាប់ថា សាមណេរបេះមកអស់ហើយ អ្នកចូរយកផ្តានោះទៅបូជាចុះ សង្ឆនឹងបូជាថ្ងៃដទៃដូច្នេះ គេទើបយកផ្តានោះបូជា ហើយទើបថ្វាយទានតទៅ ដូច្នេះក៏គួរ ។ ក្នុងមហាបច្ចរីនិងកុរុន្ទីពោលថា ព្រះថេរៈនឹងប្រើសាមណេរឲ្យយកផ្តាឲ្យគេនោះមិនបានបើសាមណេរឲ្យផ្តានោះដល់គេ ដោយខ្លួនឯងក៏គួរ ។ ចំណែកព្រះថេរៈគប្បីពោលត្រឹមតែពាក្យថា សាមណេរបេះអស់ទៅហើយប៉ុណ្ណោះ បើគេសូមវារៈផ្តាឈើទុកហើយ ផ្តានោះនៅមិនទាន់បានបេះ គេកាន់យកបបរ បាយជាដើម មកពឹងសាមណេរឲ្យបេះ និងឲ្យសាមណេរជាញាតិបេះឲ្យក៏គួរ ។ សាមណេរមិនមែនញាតិ គេលើកឡើងដាក់លើមែកឈើ ក៏កុំគប្បីចុះរត់ចេញទៅ នឹងបេះឲ្យក៏គួរ ។ បើធម្មកថិកណាមួយពោលថា អ្នកឧបាសកផ្តាឈើក្នុងវត្តមានច្រើន អ្នកចូរកាន់យកបបរ បាយ ទៅធ្វើការបូជាចុះដូច្នេះ ក្នុងមហាបច្ចរីនិងកុរុន្ទីពោលថា មិនគួរ ដល់ធម្មកថិកតែមួយអង្គនោះ ។ ឯក្នុងមហាអដ្ឋកថាពោលមិនវិសេស ថាត្រឹមតែរបស់នោះ ជាអកប្បិយៈមិនគួរដូច្នេះ ។ សូម្បីផ្លែឈើជារបស់ខ្លួននឹងឲ្យដល់មាតាបិតានិងញាតិដ៏សេស តាមន័យដែលពោលហើយនោះក៏គួរ ។ ក៏កាលឲ្យ ដើម្បីសង្គ្រោះត្រកូល ក្នុងផ្លែឈើជារបស់ខ្លួន និងជារបស់អ្នកដទៃ ឬជារបស់សង្ឆ ឬជារបស់គេនិយមទុក ដើម្បីសេនាសនៈ ឲ្យគប្បី

ដឹងថាត្រូវអាបត្តិទុក្កដជាដើម តាមន័យដូចពោលហើយនោះចុះ ។ នឹងឲ្យផ្ទៃឈើរបស់ខ្លួនដល់មនុស្សឈឺ ឬមនុស្សជាឥស្សរៈ និងមនុស្សអស់ស្បៀងចូលមកដល់ក៏គួរ មិនជាផលទាន (ឲ្យផ្ទៃឈើ) ។ សូម្បីភិក្ខុអ្នកចែកផ្ទៃឈើ ដែលសង្ឆស្ងួតទុកហើយ និងឲ្យកន្ទុះភាគដល់មនុស្សចូលមកដល់ក្នុងខណៈចែកដល់សង្ឆក៏គួរ ។ អ្នកដែលសង្ឆមិនបានសន្ធតទុកគប្បីអបលោកន៍មុនសឹមឲ្យ សូម្បីក្នុងសង្ឆារាម ក៏គប្បីធ្វើកតិកាគ្នាទុកដោយកំណត់ផ្ទៃ ឬកំណត់ដើមឈើ កាលមនុស្សឈឺ ឬមនុស្សដទៃមកសូមផ្ទៃឈើអំពីចំណែកនោះ គប្បីឲ្យផ្ទៃ ៤ ឬ ៥ ឬចង្អុលដើមឈើនោះឲ្យ តាមកំណត់ថា នឹងកាន់យកអំពីដើមនេះបានដូច្នេះ កុំពោលថាផ្ទៃដើមនេះល្អ អ្នកចូរកាន់យកអំពីដើមនេះចុះដូច្នេះ ។ លម្អិត ឬទឹកអម្ចត់ដទៃជារបស់នៃខ្លួន យកមកឲ្យដើម្បីសង្ត្រោះត្រកូល ត្រូវទុក្កដ ។ សូម្បីលម្អិតជារបស់នៃអ្នកដទៃជាដើម គប្បីវិនិច្ឆ័យតាមន័យដូចពោលហើយនោះចុះ ប៉ុន្តែបែកគ្នាដូច្នេះ ក្រមរឈើជារបស់សង្ឆ សូម្បីមានអ្នករក្សាហួងហែង ក៏ជាគរុកណ្ហ សូម្បីដីនិងឈើស្ងួន ឬស្ងឹកឫស្សី ក៏គប្បីដឹងវត្ថុដែលគួរជាគរុកណ្ហ ហើយវិនិច្ឆ័យតាមន័យដូចពោលហើយក្នុងចុណ្ណៈគឺ លម្អិតនោះចុះ ។ ក៏ឯបណ្ណាទាន ឲ្យស្ងឹកឈើ មិនមានមកក្នុងបទនេះផង ក៏អាការៈដែលឲ្យស្ងឹកឈើនោះ ក៏គប្បីដឹងតាមន័យដូចបានពណ៌នាហើយចុះ ។ បច្ច័យកើតអំពីកុលទូសកកម្មទាំង ៨ នេះ មិនគួរដល់សហធម្មិកទាំង ៥ ដូចបច្ច័យដែលកើតអំពីអួតឧត្តរិមនុស្សធម្ម

នឹងផ្ទាស់ប្តូរដោយរូបិយ ។ កុលទូសកកម្មនេះមិនគួរដល់សហធម្មិកទាំង ៥ ផង ។

កុលទូសកកម្ម ចប់

ចាបសមាចារកថា

*ខមួយ ភិក្ខុកុំគប្បីប្រព្រឹត្តអនាចារផ្សេងៗ និងកុំលេងល្បែងផ្សេងៗ មានចត្រង្គ*ជាដើម ។ *ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា* **ន ភិក្ខវេ រ**ីរ**ំ អ**ន**ាចារ**ំ **អ**ាចរ**ិ**ត**ុ**ំ **យ**ោ **អ**ាចរ**ិ**យ**្**យ **យ**ថា-**ន**ម្ហ**ា **ក**ារ**ណ**ា**ត**ោ** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំគប្បីប្រព្រឹត្ត អនាចារ សេចក្តីប្រព្រឹត្តមិនគួរ មានប្រការផ្សេងៗ បើភិក្ខុណាប្រព្រឹត្ត វិន័យធរគប្បីកាត់អាបត្តិតាមធម៌ គឺវត្ថុគួរត្រូវបាចិត្តិយ ក៏កាត់អាបត្តិបាចិត្តិយ វត្ថុគួរត្រូវទុក្កដ ក៏កាត់អាបត្តិទុក្កដ ។* **យ**ថា**ន**ម្ហ**ា** *ក្នុងបទនេះ មិនដូចក្នុងបទដទៃទេ សង្គ្រោះយកតែបាចិត្តិយមួយជំពូក ។ ក្នុងវិភង្គនៃកុលទូសកសិក្ខាបទថា ដាំឯង ឬប្រើគេឲ្យដាំនូវគុម្ពឈើ ស្រោចឯង ឬប្រើអ្នកដទៃឲ្យស្រោច បេះឯង ឬឲ្យអ្នកដទៃបេះ ដោតក្រងឯង ឬឲ្យអ្នកដទៃដោតក្រង ឈ្មោះថាបាបសមាចារ: (ប្រព្រឹត្តមារយាទអាក្រក់) ។*

នឹងពណ៌នាតាមលំដាប់នេះជាមុន វិធីដាំឯង ឬឲ្យអ្នកដទៃដាំ ស្រោចឯង ឬឲ្យអ្នកដទៃស្រោចនេះ គប្បីដឹង អកប្បិយវោហារ កប្បិយវោហារ *បរិយាយ ឱកាស និងនិមិត្តកម្ម ៥ ប្រការនេះជាមុន* *បុកបោកឯង ឬឲ្យអ្នក*

ដទៃបុកបោកនូវដើមឈើស្រស់ខៀវ ជីកឯង ឬឲ្យអ្នកដទៃជីករណ្តៅ ដាំ ឯង ឬឲ្យអ្នកដទៃដាំគុម្ពឈើ ពូនឯង ឬឲ្យអ្នកដទៃពូនកំពែង ស្រោចឯង ឬឲ្យអ្នកដទៃស្រោចនូវទឹក ធ្វើប្រឡាយឲ្យត្រង់ហូរទៅកាន់គុម្ពឈើ និង ស្រោចដោយទឹកជាអកប្បិយ និងចាក់ទឹកលាងដៃលាងជើងចុះ លុបមុខ ងូតក្នុងគុម្ពឈើទាំងអម្បាលនេះ ឈ្មោះថាអកប្បិយវោហារមិនគួរ ។ ពោល ថា អ្នកចូរដឹងនូវដើមឈើនេះ ចូរដឹងរណ្តៅនេះ ចូរដឹងគុម្ពឈើនេះ ចូរដឹង ទឹកក្នុងទីនេះដូច្នេះក្តី ហើយធ្វើប្រឡាយដែលស្ងួត ឲ្យត្រង់ទៅកាន់គុម្ពឈើ ក្តី ទាំងអម្បាលនេះ ឈ្មោះថាកប្បិយវោហារ គួរ ។ ពោលថាអ្នកឆ្នាត គេគប្បីដាំដើមឈើជាដើមទុក មិនយូរក៏ប្រព្រឹត្តទៅដើម្បីឧបការ: ពាក្យ ដូច្នេះជាដើមឈ្មោះថាបរិយាយ ។ ភិក្ខុកាន់ចបជីក ចបកាប់ ជ្រនីក កាំបិត ពូថៅ និងដើមឈើ ឈរនៅ ឈ្មោះថាឱកាស ដ្បិតថាឈរនៅដូច្នេះ សាមណេរជាដើមបានឃើញហើយនឹងគិតថា ព្រះថេរ:មានបំណងឲ្យដាំ ដើមឈើ ហើយមកធ្វើឲ្យ ។ យកចបកាប់ ចបជីក ជ្រនីក កាំបិត ពូថៅ ភាជន:ដងទឹកមកតម្កល់ទុក ក្នុងទីជិតឈ្មោះថានិមិត្តកម្ម អាការទាំង ៥ ប្រការនេះ កាលបើដាំដើម្បីសង្ត្រោះត្រកូល មិនគួរទាំងអស់ ដាំដើម្បី បរិភោគផ្ទៃ មិនគួរតែកប្បិយវោហារ និងអកប្បិយវោហារ ពីរប្រការ ប៉ុណ្ណោះ អាការ: ៣ ប្រការក្រៅនោះគួរ ។ តែក្នុងមហាបច្ចរីពោលថា សូម្បីកប្បិយវោហារក៏គួរ ។ ដាំដោយអាការ:ណាមួយ ដើម្បីនឹងបរិភោគ ដោយខ្លួនឯងក៏គួរ ។ អាការ:នោះសូម្បីដើម្បីបុគ្គលដទៃ ឬចេតិយ ឬសង្ឆ

ក៏គួរដូចគ្នា ។ ដាំដើម្បីជាទីអកិរម្ស ដើម្បីជាពួកឈើ និងដើម្បីជាម្ទប់ មិនគួរតែអកប្ចិយវោហារមួយជំពូក ក្រៅនោះគួរ ។ មិនមែនតែប៉ុណ្ណោះ សូម្បីធ្វើប្រឡាយឲ្យត្រង់ទៅ និងស្រោចទឹកជាកប្ចិយ ធ្វើបន្ទប់ងូតទឹក ហើយងូតចុះក្តី សូម្បីចាក់ទឹកលាងដៃលាងជើងនិងទឹកលុបមុខចុះក្នុងគុម្ព-ឈើនោះក្តីក៏គួរ ។ ក្នុងមហាបច្ចរី និងកុរុន្ទីពោលថា ក្នុងផែនដីជាកប្ចិយ និងដាំឯងដើម្បីម្ទប់ក៏គួរ ។ ឯដាំឯងឬឲ្យអ្នកដទៃដាំ ដើម្បីជាទីតម្រេកត្រេកអរជាដើម បើមានផ្ទៃហើយ សូម្បីបរិភោគក៏គួរ ។ ដាំដើមឈើខ្ជូនឯងក្នុងផែនដីជាអកប្ចិយ ដើម្បីកុលទូសកកម្ម ត្រូវបាចិត្តិយផង ទុក្កដផង ។ ដាំដោយអកប្ចិយវោហារក៏ដូចគ្នា ។ ដាំឯងឬប្រើអ្នកដទៃឲ្យដាំក្នុងផែនដីជាកប្ចិយ ត្រូវតែទុក្កដ ។ ក្នុងប្រយោគប្រើគេឲ្យដាំទាំង ២ នោះ ប្រើឲ្យគេដាំតែម្តង គេដាំសូម្បីច្រើនដង ត្រូវបាចិត្តិយ និងទុក្កដ ឬទុក្កដសុទ្ធតែ ១ ។ ឲ្យគេដាំក្នុងដីជាកប្ចិយឬអកប្ចិយ ដោយកប្ចិយវោហារ ដើម្បីបរិភោគ មិនត្រូវអាបត្តិ ។ ដាំឯងក្នុងអកប្ចិយបបរី ឬឲ្យគេដាំដោយពាក្យអកប្ចិយ ដើម្បីជារមណីយដ្ឋានជាដើម ត្រូវបាចិត្តិយ ។ ន័យដូច្នេះលោកមិនបានចែកទុកដោយប្រពៃក្នុងមហាអដ្ឋកថា ចែកទុកតែក្នុងមហាបច្ចរី ។ ក៏ឯស្រោចទឹកឯងនិងឲ្យអ្នកដទៃស្រោចដោយទឹកជាអកប្ចិយ ត្រូវបាចិត្តិយក្នុងទីទាំងពួង ។ ដើម្បីកុលទូសក: និងដើម្បីបរិភោគ ត្រូវទុក្កដ ព្រោះឲ្យគេស្រោចដោយទឹកជាកប្ចិយ ។ ដើម្បីកុលទូសក: និងដើម្បីបរិភោគទាំង ២ នោះត្រូវទុក្កដ ។ ឲ្យគេស្រោចដោយកប្ចិយវោហារ ដើម្បីនឹង

បរិភោគ មិនត្រូវអាបត្តិ ។ ក្នុងទីដែលនឹងត្រូវអាបត្តិព្រោះស្រោចទឹក គប្បីដឹងថា ត្រូវអាបត្តិ តិច-ច្រើន ដោយជាប់ឈ្នួរទឹក និងប្រយោគ ដែលស្រោចទឹកច្រើន-តិចចុះ ។ ក្នុងការបេះឯងនិងប្រើអ្នកដទៃឲ្យបេះនូវ ផ្កាឈើ ដើម្បីកុលទូសក:ជាដើម គប្បីដឹងថា ត្រូវទុក្កដ និងបាចិត្តិយ តិច-ច្រើន ដោយរាប់តាមផ្កាឈើ និងប្រយោគ និងពាក្យបង្គាប់ ដូច ពោលមកហើយក្នុងបទមុន ។

ក្នុងការដោតក្រងផ្កាឈើជាដើម គប្បីដឹងបុប្ផវិកតិ ៦ ប្រការដូច្នេះ **កណ្ឌិមំ** ដោតក្រង **គោច្ឆិមំ** ផ្ទុំជាបាច់ **វេឋិមំ** ចោះដោត **វេធិមំ** ចងព័ន្ធព័ទ្ធ **ឱ្ហរិមំ** បង្ហង់ធ្វើឲ្យពេញ **ភយិមំ** ប្រទាក់ស្រែះ ។ ឯ **កណ្ឌិមំ** នោះដោតនូវទង់ដោយទង់ គប្បីដឹងក្នុងផ្កាឧប្បលនិងផ្កា ឈូកជាដើម ដែលមានទង់វែង និងផ្កាឈើដទៃ ដែលមានសណ្ដាន់វែង យកទង់និងទង់ ឬសណ្ដាន់និងសណ្ដាន់ ដោតក្រងជាកញ្ចុំ ឈ្មោះថា **កណ្ឌិមំ** ។ ភិក្ខុឬភិក្ខុនី ធ្វើខ្លួនឯង ឬឲ្យអ្នកដទៃធ្វើ ដោយពាក្យជា អកប្បិយវោហារ មិនគួរ ។ ឲ្យគេធ្វើដោយពាក្យជាកប្បិយជាដើម ថាអ្នក គប្បីដឹងដូច្នេះ កាលណាបើធ្វើដូច្នេះទើបល្អ ផ្កាឈើនឹងមិនរោយរាយ ទៅដូចម្ដេច គប្បីធ្វើដូច្នោះ ពោលដូច្នេះគួរ ។ យកអម្បោះ ឬសំបក ឆ្មៃជាដើម ដោតគួបនូវផ្កា មានផ្កាម្ជុះជាដើម ឲ្យជារបៀបមានទង់តែម្ខាង ឬទាំងសងខាង ឈ្មោះថា **គោច្ឆិមំ** ។ ធ្វើសសៃឆ្មៃ ឬខ្សែជាចេសពីរ ហើយយកផ្កាឈើមិនមានទង់ មានផ្កាពាក់ជាដើមដោតចូលនឹងចេសនោះ

ចងព័ន្ធព័ទ្ធទៅដោយលំដាប់ក៏ឈ្មោះថា **គោច្ឆិមំ** ដែរ កិរិយាទាំងពួង មិនគួរដូចមុន ។ យកជក់ស្នោតជាដើមដោតក្នុងទងផ្កាម្ជុះ ឬក្នុងប្រហោងផ្កាឈើមិនមានទង មានផ្កាផ្ទុលជាដើម ដូច្នេះឈ្មោះថា **វេឌិមំ** ថាចោះដោត និងដោតបន្ទាចុះក្នុងកំណាត់ដើមចេក ហើយយកផ្កាឈើដោតចូលក្នុងបន្ទានោះជាដើមក្តី សូម្បីចងបន្ទាក្នុងពិតានធម្មាសនៈទុក ដើម្បីនឹងដោតផ្កាឈើ ឬនឹងយកបន្ទាចាក់ចុះក្នុងផ្កាឈើតែមួយក្តី ឬនឹងយកផ្កាឈើតម្រួតចូលគ្នាក្តី ទាំងអម្បាលនេះ មិនគួរទាំងអស់ ។ នឹងយកផ្កាឈើបំពាក់ក្នុងក្រឡាសំណាញ់ជាដើម នឹងបំពាក់ក្នុងចន្ទោះកញ្ចុំផ្កាអសោក មិនមានទោស ព្រោះមិនជា **វេឌិមំ** សូម្បីក្នុងខ្សែពាក់ចេតិយ ក៏ដូចជាពោលហើយដូច្នោះ ។ **វេឌិមំ** នោះគប្បីដឹងក្នុងកម្រងផ្កា និងបាច់ផ្កាឈើ យកអម្បោះនិងខ្សែចងក្នុងទងផ្កាឧប្បលជាដើមធ្វើជាបាច់ៗ មួយបាច់ប្រាំបីៗ ជាដើមក្តី ផ្កាឧប្បល សាមណេរដកឡើងតម្កល់ទុកលើគោក នឹងយកសំពត់ចងជាបង្ហ្ចេចក្តី មិនគួរទាំង-អស់ ។ នឹងយកសំបក ឬទងផ្កាឈើនោះឯងចងចូល ឬយកសំពត់តម្កល់លើស្មា ចាប់ជាយទាំងពីរក្របួចចូល យកផ្កាឈើដាក់ចុះក្នុងសំពត់នោះ ដូចដាក់ចុះក្នុងការុង ទាំងអម្បាលនេះគួរ ។ យកទងឈូកចាក់ចុះក្នុងស្ទឹកឈូក យកស្ទឹកក្ដោបផ្កាកាន់ទៅ ឯនឹងចងស្ទឹកឈូកខាងលើផ្កានោះក៏គួរ ។ តែនឹងចងទងផ្ទោបគ្នាខាងក្រោមមិនគួរ ។ ឯ **ឫរិមំ** ធ្វើឲ្យពេញនោះ គប្បីដឹងក្នុងភ្ជងរបៀបនឹងផែនផ្កាឈើចុះ យកកម្រងផ្កាព័ន្ធព័ទ្ធ

ចេតិយ ឬពោធិ ឬថ្នាក់ចេតិយ ព័ទ្ធមកឲ្យហួសទីដំបូងឈ្មោះថា **ឫរិមំ** ព័ន្ធព័ទ្ធវង់ច្រើនជុំមិនត្រូវពោល យកកម្រងផ្កាឈើ ព័ទ្ធវង់ដៃកែវឲ្យយារសំយុងចុះមក ហើយព័ន្ធព័ទ្ធទៅទៀត ក៏ឈ្មោះថា **ឫរិមំ** ដែរ យកកម្រងផ្កាដូចវល័យគឹកង បំពាក់ក្នុងដៃកែវគួរ ។ យកកម្រងផ្កាធ្វើជាផែនព័ទ្ធវង់ទៅមួយជុំគួរ ។ ព័ទ្ធវង់លើសទៅទៀតឈ្មោះថា **ឫរិមំ** មិនគួរ ។ បានកម្រងផ្កាដែលគេធ្វើជាកញ្ចុំមកចងខាងលើអាសនៈគួរ ។ នឹងយកកម្រងផ្កាដែលវែងពាក់ទៅ ឬព័ន្ធព័ទ្ធទៅតែមួយជុំ ដល់មុខប្រសពូខាងដើមហើយឲ្យទៅភិក្ខុដទៃក៏គួរ ។ សូម្បីភិក្ខុដទៃនោះនឹងធ្វើដូច្នោះទៀតក៏គួរ ។ **ភយិមំ** ក្រងទាក់នោះ គប្បីដឹងក្នុងក្រឡាសំណាញ់ផ្កាឈើ និងផែនផ្កា និងរូបធ្វើដោយផ្កាឈើចុះ កាលធ្វើនូវផ្កាឈើជាក្រឡាសំណាញ់ក្នុងចេតិយ ត្រូវទុក្ខដ គ្រប់ក្រឡា ។ ផែនផ្កាឈើ សូម្បីអ្នកដទៃគេធ្វើឲ្យពេញទុកហើយ នឹងក្រងទាក់ចូលទៀតមិនបានឡើយ យកផ្កាឈើឈ្មោះ **គោឋិមំ** មកធ្វើជារូបដំរី រូបសេះជាដើម ក៏នៅក្នុងបទឈ្មោះថា **ភយិមំ** ទាំងអស់ មិនគួរដូចមុន ។ មិនមែនតែកម្រងផ្កាមួយជំពូកទេ សូម្បីកម្រងម្សៅ កម្រងផ្កាអម្បោះក៏ដូចគ្នា សូម្បីភិក្ខុនិងនាងភិក្ខុនី ធ្វើឯង ឬឲ្យអ្នកដទៃធ្វើក៏មិនគួរ ព្រោះព្រះបញ្ញត្តិនេះជាសាធារណបញ្ញត្តិទូទៅ និងបូជា ពោលពាក្យជាកឋិយ គួរក្នុងទីទាំងពួងបរិយាយឱកាស និមិត្តកម្ម គួរ ។

បាបសមាចារ ចប់

អនាចារកថា

កិរិយាប្រព្រឹត្តផ្សេងៗ មិនសមគួរដល់ភេទសមណៈ គឺលេងចត្រង្គ ខ្ទាធ្លាក់អណ្តូង ខ្ទាស៊ីគោ ចាក់អន្ទាក់ស្តា បាយខ្ទុំ លេងទាយរូប លេងផ្ទុំស្ទឹកឈើ លេងន័ង្គលតូចៗ លេងដាំដូង លេងកង្ហារ លេងវាស់ខ្សាច់ដោយស្ទឹកឈើ លេងរថតូចៗ លេងធ្នូតូចៗ លេងសរសេរទាយក្នុងអាកាសនិងខ្នង លេងទាយចិត្ត លេងត្រាប់មនុស្សខ្វាក់ មនុស្សកៃ្ងង មនុស្សខ្ជូក ជាដើម ហាត់សិល្បសាស្ត្រដំរីសេះជាដើម លេងហាត់រត់មុខដំរីសេះជាដើម លេងទះដៃ លេងចំបាប់ ដាល់ជាដើម និងលេងល្បែងដោយអាការផ្សេងៗ យ៉ាងដទៃ ដែលមិនមានមកក្នុងបាលីមានដើមថា ពិណាពាទ្យ ហួច រុញទូកតូចៗ ផ្ទះតូចៗ ទាំងអម្បាលនេះ ឈ្មោះអនាចារ: មិនគួរសមដល់ភេទសមណៈ គឺភិក្ខុនិងសាមណេរ ។

ខមួយ ភិក្ខុកុំគប្បីប្រមៀលថ្មលេង បើប្រមៀលត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ឃាត់ទុកក្នុងវិនីតវត្ថុថា **ន ច ភិក្ខវេ ឧភាយ សិលា បវិជ្ឌិតព្ពា**... *ដូច្នេះ ។ មិនមែនតែសិលាមួយមុខ សូម្បីជារបស់ដទៃ គឺកំណាត់ឈើ ដុំឥដ្ឋ ណាមួយ នឹងប្រមៀល នឹងបោះដោយដៃ ឬដោយយន្ត ក៏មិនគួរ ។ សើចបណ្តើរ ប្រមៀលបណ្តើរ ឬលើកដុំសិលាទៅបណ្តើរ ដើម្បីប្រយោជន៍ដល់ចេតិយជាដើម ជាកម្ម-សម័យ ព្រោះហេតុនោះគួរ ។ ធ្វើនវកម្មដទៃដូច្នេះ ឬលាងរបស់*

លើកដើមឈើ ឬកំណាត់ឈើ សម្រាប់លាង សម្រាប់គក់ ប្រមៀលបោះទៅគួរ ។ ក្នុងវេលាធាន់ជាដើម នឹងគ្រវែងឈើ ឬក្បៀង ដេញក្អែក ឬសុនខ ក៏គួរ ។

ខមួយ ភិក្ខុកុំគប្បីឡើងដើមឈើ បើឡើងត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ រុក្ខោ អភិរូហិតព្ពោ...** ដូច្នេះ ។ កាលបើមានកិច្ចត្រូវការកាន់យកមែកឈើស្ងួតជាដើម នឹងឡើងទៅបានកម្ពស់ត្រឹម ១ ជួរបុរស ឃើញសត្វកាចប្រាថ្នានឹងរត់ ឬវង្វេងផ្លូវ ប្រាថ្នានឹងមើលទិស ឬឃើញភ្លើងព្រៃនិងជំនន់ទឹកហូរមក ក្នុងអន្តរាយដូច្នេះនឹងឡើងដើមឈើសូម្បីឲ្យខ្ពស់ក៏គួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ សតិ ការណីយេ ចោរិសិយំ រុក្ខំ អភិរូហិតុំ អាបជ្ជាសុ យាវជ្ជតំ** ដូច្នេះ ។

ខមួយ ភិក្ខុកុំគប្បីដុតព្រៃ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ជាយោ អាឌ្ឍេបេតព្ពោ** ... ភិក្ខុមិនត្រូវដុតព្រៃ បើដុតព្រៃ ត្រូវទុក្កដ ។ បើដុតចំពោះវត្ថុណា វត្ថុនោះស្ងាប់ ត្រូវបារាជិក និងអនន្តរិយកម្ម និងថុល្លច្ច័យ និងបាចិត្តិយ និងជាអកុសលរាសីតាមវត្ថុនោះៗ ។ ដុតព្រៃចំពោះឲ្យស្មៅនិងដើមឈើស្រស់ឆេះ ត្រូវបាចិត្តិយ ។ ចំពោះឲ្យគ្រឿងទព្វូបករណ៍វិនាស ត្រូវទុក្កដ ។ សូម្បីដុតដោយប្រាថ្នានឹងលេង ត្រូវទុក្កដ ។ ពាក្យនេះពោលទុកក្នុងសង្ខេបដ្ឋកថា ដុតចំពោះឲ្យដើមឈើស្រស់ និងវត្ថុដែលមានឥន្ទ្រីយ៍ឆេះ គប្បីដឹងថា ត្រូវបារាជិក

ថុល្លច្ច័យ បាចិត្តិយ និងទុក្កដ តាមវត្ថុនោះ។ ចុះ ។ ឃើញភ្លើងនេះព្រៃ គេដុត ឬភ្លើងកើតឡើងឯងនេះមក នឹងមិនឲ្យកុដិស្មៅវិនាស ហើយដុតភ្លើងទទួលទប់ទុកក្តី និងធ្វើការពារគឺជម្រះដី ជីកគូរទុកជុំវិញកុដិស្មៅក្តី ធ្វើដូចម្តេចភ្លើងមិនបានរាលមក នឹងរលត់ទៅឯង ធ្វើដូច្នោះការនោះក៏គួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ ឧវ្ហាហេ ឧយ្ហមានេ បដក្តឺ ជាតុំ បរិត្តំ ការតុំ** ដូច្នេះ ។ ធ្វើការទាំងពួងនោះ កាលភ្លើងនេះឡើងហើយទើបគួរ កាលភ្លើងមិនទាន់នេះឡើង គប្បីប្រើអនុបសម្បន្នឲ្យធ្វើ កាលលត់ដោយទឹក គប្បីយកទឹកដែលប្រាសចាកតួសត្វ មកចាក់ស្រោចលត់ ។

អនាចារកថា ចប់

បរិក្ខារកថា

ខមួយ ភិក្ខុកុំគប្បីប្រើបរិក្ខារផ្សេងៗ ដ្បិតព្រះអដ្ឋកថាចារ្យ លោកវិនិច្ឆ័យបរិក្ខារដែលគួរនិងមិនគួរ ជាបាលីមុត្តក:រួចចាកបាលីទុកដូច្នេះថា មនុស្សជំពូកខ្លះគេដេរធ្រស្ងឹកនោ្នត ខាងក្នុងឬខាងក្រៅ ដោយអម្ពោះបញ្ចពណ៌ធ្វើឲ្យរលើងស្អាតល្អដោយពណ៌ ធ្រនោះមិនគួរ នឹងដេរប៉ាក់ខាងក្នុងឬខាងក្រៅ រួចចងរឹតក្បាលធ្រ និងក្រាញដងដោយអម្ពោះខៀវ ឬលឿងណាមួយតែពណ៌មួយ ដើម្បីនឹងឲ្យខ្ជាប់ខ្ជួនគួរ ។ ដើម្បីនឹងឲ្យល្អមិនគួរ។ ក្នុងស្ងឹកធ្រនិងកាត់ជាផ្ទេញម្ករឬរូបព្រះចន្ទមួយចំហៀងមិនគួរ ។

ធ្វើជារូបក្អមរូបសត្វសាហាវក្នុងដងត្រដូចសសរផ្ទះមិនគួរ ។ សម្បីក្នុងដងត្រទាំងពួងធ្ងតជាខ្សែដោយចុងដៃកស្រួច ខ្សែនោះមិនគួរ គប្បីទម្ងាយរូបក្អមរូបសត្វកាចចេញ ដុសរូសខ្សែចេញ ឬយកអម្ពោះរុំព័ទ្ធដងចេញ បាំងប្រើចុះ ក្នុងគល់ដងសណ្ឋានដូចជាផ្សិតក្បាលពស់គួរ ។ ក្នុងទីដែលយកខ្សែចងមណ្ឌលត្រយោងមកចងក្នុងដង ដើម្បីនឹងការពារខ្យល់និងរំលេចឡើងជាខ្សែដូចវល័យ ខ្សែនោះគួរ ។ ក្នុងចីវរបើដេរភ្ជាប់អាគន្ទុ-កបដ:ដូចខ្នងក្អែប និងធ្វើវិការដោយជើងចេសណាមួយមិនគួរ ឬក្នុងរឹមសំពត់ដែលផ្ទៃនសំពត់ទាំង ២ ខ្ទប់គ្នា និងក្នុងទីបំផុតដោយជុំវិញនៃចីវរ និងដេរជាប្រហោង ឬជាខ្សែច្រវាក់ជាដើមដោយចេសផ្សេងៗ ដើម្បីនឹងប្រដាប់ ទាំងពួងនោះមិនគួរទាំងអស់ ។ ដេរទៅដោយប្រក្រតីមួយជំពូកទើបគួរ ផ្ទាំងសំពត់ក្ដុំ និងផ្ទាំងសំពត់ក្រវិល ធ្វើជា ៨ ជ្រុង ឬ ១១ ជ្រុងក្ដី ក្នុងផ្ទាំងសំពត់នោះធ្វើជាក្ដុំឡើងដូចចេតិយ និងដងរៃកកន្ទុយគោជាដើមក្ដី រំលេចឡើងដូចជាភ្នែកក្ដាមក្ដី ទាំងពួងមិនគួរ ។ ផ្ទាំងសំពត់ក្ដុំ ក្រវិលជា ៤ ជ្រុងមួយជំពូកទៀតទើបគួរ កំនួចកន្ទុយចេសក្នុងជ្រុងនោះគួរ ដ្បិតថាកាលជ្រលក់ហើយក៏នឹងបាត់ទៅ នឹងត្រាំចីវរចុះក្នុងទឹកបាយនិងទឹកមេរ៉ានិងទឹកម្ជូរជាដើមមិនគួរ ។ តែនឹងត្រាំចុះដើម្បីនឹងគក់ដុសលាងមន្ទិលដៃនិងចេសជាដើមដែលប្រឡាក់ក្នុងកាលដេរ និងចីវរចាស់ ដើម្បីបោកលាងក៏គួរ ។ នឹងលាយរបស់ក្រអូប ឬល័ត្ត ឬប្រេង ដាក់ចុះក្នុងទឹកជ្រលក់មិនគួរ ។ ចីវរជ្រលក់ហើយកុំគប្បីខាត់ដុសដោយស័ង្ខ ឬកែវណាមួយ

ជ្រលក់ចីវរកុំលុតជង្គង់ចុះទាំងពីរលើផែនដី យកដៃចាប់ឈ្វីច្រចាប់ទៅ
ក្នុងស្នូក តែនឹងដាក់សំពត់ក្នុងស្នូក ឬលើក្តារ ហើយឲ្យមនុស្សចាប់ក្នុង
ទីបំផុតទុក ហើយទះដោយបាតដៃក៏គួរ តែកុំតប់ដោយដៃដែលក្តាប់ ។
ព្រះថេរៈទាំងឡាយអំពីមុន លោកមិនដាក់ចីវរក្នុងស្នូក មួយអង្គកាន់ចីវរ
ឈរ មួយអង្គចាប់ ហើយយកដៃទះ ។ ចេសក្នុងមុំចីវរ មិនគួរ ជ្រលក់
ហើយគប្បីកាត់ចេញ ចេសក្នុងមុំចីវរណា ដែលព្រះពុទ្ធអង្គទ្រង់អនុ-
ញ្ញាតទុក ចេសនោះគប្បីចងធ្វើជាអន្ទាក់ក្នុងអនុវាត ដើម្បីនឹងបានព្ជួរក្នុង
វេលាជ្រលក់ សូម្បីក្នុងកុ្ដ ធ្វើជាគំនូស ឬជាពកដើម្បីឲ្យល្អមិនគួរ គប្បី
ធ្វើឲ្យវិនាសចេញប្រើប្រាស់ចុះ ។ ក្នុងបាត្រឬថាលកកាជនៈគ្រឿងប្រើ
ប្រាស់នឹងយកដៃកក្រឡឹង ក្រឡឹងជាខ្សែខាងក្នុងខាងក្រៅមិនគួរ នឹង
យកបាត្រដាក់ចូលគ្រឿងក្រឡឹងដុសខាត់ ហើយដុតដោយសេចក្តីប្រាថ្នា
នឹងធ្វើឲ្យមានពណ៌ដូចកែវមណីមិនគួរ តែបាត្រមានពណ៌ដូចប្រេងគួរ ។
ក្នុងមណ្ឌលជារង្វេលរងបាត្រនឹងធ្វាក់គួរជាគំនូរក្បាច់មិនគួរ ជាកិត្តិកម្ម
មិនគួរ ឬក្ងីក៏មិនគួរ តែប៉ាក់ជាផ្ទេញម្ករគួរ ខាងលើឬខាងក្រោមនៃធត្រ
ធម្មក្រក ឬក្នុងផ្ទៃធម្មក្រក ធ្វើជាខ្សែមិនគួរ ក៏ប៉ុន្តែខ្សែក្នុងកណ្ដាប់មាត់
អាការដូចធ័ត្រនោះគួរ ។ វត្ថុពន្ធចង្កេះត្បាញអម្បោះគួបចុះក្នុងទីនោះ។ នឹង
រំលេចដូចធត្រនោះគួរ ។ វត្ថុពន្ធចង្កេះត្បាញអម្បោះគួបចុះក្នុងទីនោះ។ នឹង
រំលេចជាភ្នែកក្តាមឡើង ដើម្បីនឹងឲ្យល្អ មិនគួរ។ នឹងត្បាញអម្បោះគួបក្នុង
ទីបំផុតទាំងសងខាង ដើម្បីនឹងឲ្យរឹមជាយជាប់មាំគួរ តែក្នុងរឹមជាយនឹងធ្វើ
ជារូបក្អម ឬម្ករ ឬក្បាលពស់ទឹក ឲ្យជារូបដែលជាវិការៈណាមួយមិនគួរ ។

សូម្បីវត្ថុពន្ធដែលជារំយោល ឬធ្វើជាផ្កាឈើជាដើមក្នុងទីនោះ។ មិនគួរ ។ ក៏ប៉ុន្តែនឹងត្បាញឲ្យត្រង់ទៅ ធ្វើជាធ្នុងត្រី ឬស្ទឹកបេង ឬធ្វើជាផ្ទៃរលីងនោះគួរ ។ ជាយនៃវត្ថុពន្ធ ខ្សែ ១-២-៣ សូម្បីខ្សែ ៤ ក៏គួរ ។ លើសឡើងទៅជាងនោះមិនគួរ ។ វត្ថុពន្ធខ្សែមួយសរសៃទើបគួរ ។ តែវត្ថុពន្ធមានសណ្ឋានបីដូចជាសង្វារសូម្បីតែមួយសរសៃមិនគួរ ។ តែជាយសូម្បីមានសណ្ឋានដូចសង្វារ ក៏គួរ ។ វត្ថុពន្ធដែលគេរួបគួបខ្សែច្រើនផងគ្នា ក្នុងឋានជាមួយគ្នាហើយយកខ្សែមួយសរសៃព័ទ្ធចងភ្ជាប់គ្នាទៅដូច្នេះកុំ គប្បីពោលថាមានខ្សែច្រើនឡើយ វត្ថុពន្ធនោះគួរ ។ ក្នុងក្រវិលក្បាលវត្ថុពន្ធ ធ្វើជារូបវិការ:ណាមួយ មានមង្គ្ល ៨ ជាដើមមិនគួរ ។ ធ្វើល្មមជាស្នាមកំណត់ទីចងគួរ ។ ក្នុងទីបំផុតទាំងពីរនៃក្បាលក្រវិល សូម្បីនឹងធ្វើជារូបក្អមដើម្បីនឹងឲ្យជាប់មាំក៏គួរ ។ ក្នុងបំពង់ថ្នាំភ្នែក នឹងធ្វើជារូបស្ត្រី ឬបុរសនិងរូបសត្វចតុបាទ គឺខ្ញា ឬរាជសីហ៍ ទ្វិបាទគឺសកុណាបក្សី នឹងធ្វើរូបវិការ: មានផ្កាឈើ រលិ ធ្នេញម្ករ គោបុត្រ រូបព្រះចន្ទមួយចំហៀងជាដើមមិនគួរ គប្បីដុស ឬកាត់ចេញ ឬចងរុំព័ទ្ធដោយអម្បោះកុំឲ្យប្រាកដ ប្រើបាន ។ បំពង់ថ្នាំភ្នែកដ៏ត្រង់ជា ៤ ជ្រុង ឬ ៨ ជ្រុង ១៦ ជ្រុង ក៏គួរ សូម្បីបាតបំពង់ធ្វើជាខ្សែមូលពីរ ឬបីក៏គួរ ។ សូម្បីក្នុងកបំពង់ថ្នាំភ្នែក ធ្វើជាខ្សែមូលមួយគំនូសដើម្បីនឹងចងគ្របក៏គួរ ។ សូម្បីចង្កើះថ្នាំភ្នែក នឹងតាក់តែងឲ្យមានពណ៌រលីងល្អមិនគួរ ។ ក្នុងថង់បំពង់ថ្នាំភ្នែក នឹងធ្វើឲ្យល្អយ៉ាងណាមួយដោយអម្បោះមានពណ៌ផ្សេងៗ មិនគួរ ។ សូម្បីក្នុងស្រោមកូនសោ

ក៏ដូចគ្នា ក្នុងតួសោទៀត នឹងតាក់តែងឲ្យមានពណ៌ល្អមិនគួរ ។ ក្នុងស្រោមកាំបិតកោរក៏ដូចគ្នា ឯស្រោមនោះនឹងដេរយ៉ាងណាមួយដោយអម្បោះណាមួយ តែពណ៌មួយក៏គួរ ។ សូម្បីក្នុងដែកក្រឡឹងនិងកាំបិតចុងស្រួចធ្វើជាពកមូល ឬតាក់តែងឲ្យមានពណ៌ស្អាតល្អយ៉ាងដទៃ មិនគួរ ។ តែត្រង់កធ្វើជាខ្សែសម្រាប់សម្ពាល់គួរ សូម្បីក្នុងកាំបិតកាត់ក្រចកនឹងរំលេចឲ្យជាម្រះ ជាផ្ទូត ឬជាដុំណាមួយមិនគួរ ។ តែក្នុងដងកាំបិតធ្វើជាខ្សែសម្រាប់កំណត់នោះគួរ កាំបិតកាត់ក្រចកធ្វើជារមូលទៅដើម្បីនឹងឲ្យកាន់មាំគួរ ។ ក្នុងឈើព្រនួតពួតភ្ជើង ខាងលើ ឬខាងក្រោម ឬធ្នូនិងដងសម្រាប់ទាញខាងលើនឹងតាក់តែងឲ្យល្អបែបណាមួយ មានមាលាកម្មជាដើម មិនគួរ ។ តែក្នុងមណ្ឌលកណ្ដាលនៃដងសម្រាប់កាន់ពួតនោះ ធ្វើល្មមជាខ្សែសម្រាប់កំណត់នោះគួរ ។ ក្នុងដំបៀតសម្រាប់ជ្ដៀបម្ជុលសំលៀងនោះ នឹងតាក់តែងឲ្យល្អបែបណាមួយ មានមាត់ម្ករជាដើមមិនគួរ តែធ្វើឲ្យល្មមជាមាត់ក្រាញ់ដើម្បីនឹងជ្ដៀបម្ជុលនោះគួរ ។ សូម្បីក្នុងកាំបិតកាត់ឈើស្ងួន នឹងតាក់តែងឲ្យល្អបែបណាមួយក៏មិនគួរ នឹងយកលោហៈជាកប្ដិយភ្ជាប់ឲ្យត្រង់ទៅ ក្នុងខាងទាំងសងខាង ឬម្ខាងនៃដងឲ្យជា ៤ ជ្រុង ឬ ៨ ជ្រុងគួរ ។ សូម្បីឈើច្រត់ នឹងតាក់តែងឲ្យល្អបែបណាមួយ ក៏មិនគួរ គល់ខាងក្រោមនឹងធ្វើជាខ្សែមូលមួយ ឬពីរក្ដី ចុងខាងលើ ធ្វើល្មមជាផ្សិតក្បាលពស់ក្រពុំក្ដីគួរ ។ ក្នុងភាជនៈប្រេងធ្វើដោយស្ពែង ឬអំបែង ឬលលាដ៍ឃ្មោក ឬសូនដោយកាកល័ក្ដក្ដី នឹងតាក់តែងឲ្យមានពណ៌ល្អទាំងអស់

លើកតែរូបស្ត្រី ឬបុរសចេញ ក៏គួរ ។ ក្នុងគ្រែ តាំង ពូក ខ្នើយ គ្រឿងកម្រាល សំពត់ជូតជើង ពូកសម្រាប់ចង្ក្រម អំបោស កញ្ជ្រែងសម្រាប់ចាក់សំរាម ស្នូកជ្រលក់សំពត់ ចោយដងទឹក ក្អមទឹក ក្បឿងជូតជើង តាំងដ៏ហើយដោយក្តារ ជើងបាត្រដូចកង នឹងជើងបាត្រធ្វើដោយកំណាត់ឈើ គ្របបាត្រ ផ្ទៃតស្ទឹកនោ្នត ផ្ទៃតវ៉ែនទី របស់ទាំងអម្បាលនេះ នឹងធ្វើឲ្យល្អដោយពណ៌ទាំងពួងមានផ្ការឈើជាដើមគួរ ។ តែក្នុងសេនាសនៈ ក្នុងសន្ទឹកទ្វារ និងស្ទឹកបង្ហួចជាដើម សូម្បីតាក់តែងឲ្យល្អស្រស់ និងប្រដាប់ដោយកែវទាំងពួងក៏គួរ ។ ក្នុងសេនាសនៈ វត្ថុណាមួយដែលនឹងគប្បីឃាត់នោះមិនមាន រៀរលែងតែនិរុទ្ធសេនាសនៈ ។

បាលីមុត្តកវិនិច្ឆយកថា ចប់

វិនិច្ឆ័យទាំងពួងនេះ មិនមែននឹងផុតចាកបាលីទៅតែម្តងទេ របស់ខ្ញុំ អាស្រ័យបាលីថា: ន ភិក្ខវេ ឧច្ចាវចា វិថា ជាវេតព្ជា... កណ្ហិកា... អញ្ជនី.. អញ្ជនីសលាកា... សត្ថ ឧណ្ហា... បដិក្ខហា... ឆត្ត ការណី... កណ្ណ ្ជ ្ជ ្ជ

ភិក្ខុកុំគប្បីប្រើ ថាបើប្រើត្រូវទុក្កដ ។ ក្ដុំក្រវិលទាំងពីរនេះ ដ៏ហើយ ដោយធ្នើង និងភ្ជុក និងស្នែង និងកាកល័ក្ត និងឫស្សី ដ៏ហើយដោយ ត្រឡោក និងស័ង្ខ និងអម្បោះ ក៏គួរ ព្រោះជារបស់ព្រះពុទ្ធអង្គទ្រង់ អនុញ្ញាត ។ បំពង់ថ្នាំភ្នែក ចង្កើះថ្នាំភ្នែកជាដើមដ៏ហើយដោយធ្នើង ភ្ជុក ស្នែង ពីងពង់ និងឫស្សី ដ៏ហើយដោយឈើ កាកល័ក្ត និងផ្ទៃឈើ ដ៏ហើយដោយលោហៈ ត្រលោកនិងស័ង្ខក៏គួរ ។ ដ្បិតជារបស់ព្រះពុទ្ធ-អង្គទ្រង់អនុញ្ញាត ។ រង្វេលរងបាត្រ ដ៏ហើយដោយសំណនិងសង្ក្ដសី ទើបគួរ ព្រោះជារបស់ទ្រង់អនុញ្ញាត ។ ក៏ឯឧច្ចាវចាក្នុងបាលីថា ដ៏ហើយ ដោយប្រាក់និងមាសខ្លះ មានកាលជាវត្ថុដទៃខ្លះដូចជាវត្តពន្ធចង្កើះថា **ន ភិក្ខវេ ឧច្ចាវចានិ ការយពន្ធនានិ ជាវតញ្ចានិ ការណ្ណាពុកំ ឌេឌ្ឌុភកំ មុរជ្ជំ មច្ចរិណ្ណ** ... ថាវត្តពន្ធចង្កើះ ខ្ពស់និងទាប គឺមាន ខ្សែរច្រើននិងមានសណ្ឋានដូចក្បាលពស់ទឹក និងព័ទ្ធទៅមានសណ្ឋាន ដូចត្រកួញខ្សែ និងមានសណ្ឋានដូចសង្ហារ ភិក្ខុកុំគប្បីប្រើ បើប្រើត្រូវ ទុក្កដ ។ តែព័ទ្ធដោយសណ្ឋានដូចត្រកួញខ្សែ សណ្ឋានដូចសង្ហារនេះ ក្នុងជាយវត្តពន្ធក៏គួរ ។ ដ្បិតទ្រង់អនុញ្ញាតថា **អនុជានាមិ ភិក្ខវេ មុរជ្ជំ មច្ចរិណ្ណ** ដូច្នេះ ។ **បដ្ដិកំ** វត្តពន្ធផ្ទៃសំពត់ត្បាញ ដោយប្រក្រតី និងត្បាញដូចធ្នើងត្រី **សូការន្ដកំ** វត្តពន្ធដូចពោះវៀន ជ្រូក និងស្រោមកូនសោ វត្តពន្ធទាំងពីរប្រការនេះជារបស់ព្រះពុទ្ធអង្គ ទ្រង់អនុញ្ញាត ។

ខមួយ ទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ចិត្រានិ បត្ត-មណ្ឌលានិ ជាវេតព្ពានិ រូបកាកិណ្ណានិ ភិត្តិកម្ម-កតានិ...** ភិក្ខុមិនត្រូវប្រើដើងបាត្រដ៏វិចិត្រ ធ្លាក់ដេរដាសដោយរូបស្រីនិងប្រុសជាដើម និងលាបឲ្យមានពណ៌ផ្សេងៗទេ បើប្រើត្រូវទុក្កដ ។

ខមួយ ភិក្ខុកុំគប្បីប្រើផ្ទិតវីជនី ៤ ជ្រុងធ្វើដោយពោមចាមរី បើប្រើប្រាស់ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ចាមរីវីជនី ជាវេតព្ពា** ដូច្នេះ ។ **ទ្វិបដំ** ផ្ទិតបួនជ្រុង **តាលវណ្ដ** ផ្ទិតធ្វើដោយស្លឹកត្នោត ឬធ្វើដោយបន្ទោះ ឬដោយពោមក្ងោក ឬដោយស្បៃក **មកសវីជនំ** ផ្ទិតបក់មូស សូម្បីមានដងដ៏ហើយដោយកូកនិងស្នែងក្តី របស់ទាំងអម្បាលនេះ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាត ។

មួយទៀតផ្ទិត ៣ ប្រការគឺ **ភាកមយំ** ផ្ទិតធ្វើដោយសម្បកឈើ **ឧសិរមយំ** ផ្ទិតធ្វើដោយស្ស្ងរ**ក**ាំង **មោរបិញ្ជមយំ** ផ្ទិតធ្វើដោយពោមកន្ទុយក្ងោក របស់ទាំងអស់នេះជារបស់ព្រះពុទ្ធអង្គទ្រង់អនុញ្ញាត ។

ខមួយ ភិក្ខុកុំគប្បីប្រើឈើស្ងួនវ៉ែងពេក ខ្វីពេក ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ឌីឃំ ឧន្ធកដ្ឋំ ខាទិតព្ពំ ។ ល ។ អនុជានামិ ភិក្ខវេ អដ្ឋង្គុលបរមំ ឧន្ធកដ្ឋំ ។ ល ។ ន ភិក្ខវេ អតិមហាហកំ ឧន្ធកដ្ឋំ ខាទិតព្ពំ ។ ល ។ អនុ-ជានামិ ភិក្ខវេ ចតុរង្គុលំ បច្ឆិមំ ឧន្ធកដ្ឋំ** ថាភិក្ខុកុំគប្បីប្រើប្រាស់ឈើស្ងួនវ៉ែង បើប្រើប្រាស់ត្រូវទុក្កដ ។ តថាគតអនុញ្ញាត

ឈើស្ទន់ដែងត្រឹមតែ ៨ ធ្នាប់ ដោយធ្នាប់មនុស្សជាយ៉ាងក្រៃពេក ។ ភិក្ខុកុំគប្បីប្រើប្រាស់ឈើស្ទន់ខ្វីពេក បើប្រើប្រាស់ត្រូវទុក្កដ ។ តថាគតអនុញ្ញាតឈើស្ទន់ ៤ ធ្នាប់ជាយ៉ាងខ្វី ។ មិនប្រើឈើស្ទន់មានទោស ៥ ប្រការ គឺ **អចក្ខុស្សុ** មិនឧបត្ថម្ភដល់ភ្នែក ១ **មុខំ ទុក្ខនំ ហោតិ** មាត់មានក្លិនស្អុយ ១ **រសហរណិយោ ន វិសុជ្ឌន្តិ** សរសៃទទួលរស់អាហារមិនបរិសុទ្ធ ១ **បិត្តំបិ សេម្ហំបិ ភត្តំ បរិយោនន្ធតិ** ប្រមាត់និងសេម្ហៈរមែងរ៉ាតបាយ ១ **ភត្តមស្ស ន ធាតេតិ**[1] អាហារមិនធ្វាញ់ដល់អ្នកនោះ ១ ត្រូវជា ៥ ប្រការ ។ បើប្រើឈើស្ទន់មានអានិសង្ស ៥ ប្រការ គប្បីដឹងដូចន័យដែលជាបដិបក្ខដល់ទោសនោះចុះ ។

ខមួយ ភិក្ខុកុំគប្បីធ្វើការសន្សំគ្រឿងធ្វើដោយលោហៈ និងគ្រឿងធ្វើដោយសំរិទ្ធិ បើធ្វើការសន្សំទុក ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ លោហភណ្ឌំ ការេតុំ សន្ធិចយោ ការេតុ...** ដូច្នេះ ។ បំពង់ថ្នាំភ្នែក ចង្កើះថ្នាំភ្នែក ឈើចង្ការ ត្រចៀក ស្រោមកាំបិតជាដើម ដ៏ហើយដោយលោហៈ និងសំរឹទ្ធិគួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ អញ្ជនឺ អញ្ជនិសលាកំ ការណ្ណមលហរណឺ ពន្ធនមត្តំ** ដូច្នេះ ។

១-វិនយបិដក ចុល្លវគ្គ ទុតិយភាគ ខុទ្ទកវត្ថុក្ខន្ធកៈ ទំព័រ ២២៦

ខមួយ បព្វជិតកុំគប្បីបបួលបព្វជិត គឺសហធម្មិកទាំង ៥ ក្នុងកម្មដ៏មិនគួរ បើភិក្ខុណាបបួលនាំឲ្យធ្វើ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ បព្វជិតេន អកប្ប្យិយេ សមាទបេ-តព្ពំ**... ដូច្នេះ ។

ខមួយ ភិក្ខុធ្លាប់ជាជាងកោរសក់អំពីមុនមកហើយ កុំគប្បីរក្សាគ្រឿងកាំបិតកោរទុក បើភិក្ខុណារក្សាទុក ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ឆ្លាបិតបុព្វកេន ខុរភណ្ឌ បរិហរិតព្ពំ** ដូច្នេះ ។ កាន់យករក្សាទុកមួយជំពូកមិនគួរ ក៏ប៉ុន្តែនឹងកោរដោយកាំបិតអ្នកដទៃនោះគួរ បើភិក្ខុទទួលស៊ីឈ្នួលកោរសក់ ក៏មិនគួរ ។ ភិក្ខុណាមិនធ្លាប់ជាជាងកោរសក់អំពីមុនមក ហើយភិក្ខុនោះ សូម្បីនឹងរក្សាកាំបិតកោរទុកក៏គួរ សូម្បីនឹងកាន់យកកាំបិតកោរនោះ ឬកាំបិតដទៃមកកោរសក់ក៏គួរ ។

ខមួយ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ បមេត្តា បហរណឺ សព្ពំ លោហភណ្ឌ បមេត្តា អាសនឺ បល្ល ង្ក ជារុបត្ត ជារុចាឧ ុកំ សព្ពំ ជារុភណ្ឌ បមេត្តា ភតភ ញ្ជ ភុ ម្ភ ការ ិ ភ ញ្ជ សព្ពំ មត្ត ិ ការ ភ ណ្ឌ ។** *តថាគត អនុញ្ញាត នូវគ្រឿងលោហៈទាំងពួង រឿងលែងតែលោហៈដែលជាគ្រឿងសម្រាប់ប្រហារ, នូវគ្រែទាំងពួង រឿងលែងតែអាសនៈកន្ទងហួសប្រមាណដែលហៅថាអាសន្ទិ និងគ្រែតាំងមានជើងវិចិត្រដោយរូប*

សត្វសាហាវ ដែលហៅថាបល្ល, នូវគ្រឿងឈើទាំងពួង រៀរលែងតែ បាត្រឈើនិងទ្រនាប់ដើងឈើ, នូវគ្រឿងដីទាំងពួង រៀរលែងតែគ្រឿង ជូតដើងដែលគេធ្វើជាពកឲ្យស្រួចៗ ឡើង មានអាការដូចពកគ្រាប់ផ្ទៃ ឈូក និងកុដិធ្វើដោយដីសុទ្ធ (ដូចកុដិធនិយភិក្ខុ) ។

បរិក្ខារកថាចប់

មណ្ឌនាទិកថា

ខមួយ ភិក្ខុកុំគប្បីលាប ផាត់ ជ្រលក់មុខ ជ្រលក់ខ្លួន ដោយគ្រឿង លាបដោយគ្រឿងជ្រលក់ ។ ដ្បិតទ្រង់បញ្ញត្តទុកថា **ន ភិក្ខវេ មុខំ អាលិម្ពិតុំ ន មុខំ ឧម្មទ្ទិតុំ ន មុខំ ចុណ្ណេតុំ ន មនោសិលកាយ មុខំ លញ្ជេតុំ ន អង្ក្ខភកោ ការេតោ ន មុខភកោ ការេតោ ន អង្ក្ខភកមុខភកោ ការេតោ...** *ភិក្ខុកុំគប្បីលាបមុខដោយគ្រឿងលាប ដែលធ្វើឲ្យមុខមានពណ៌សម្ផ្ស ស្រស់ កុំផាត់មុខដោយគ្រឿងផាត់ផ្សេងៗ កុំប្រោះមុខដោយគ្រឿង លម្អិតសម្រាប់ប្រោះមុខ កុំចឹមមុខដោយមនោសិលា និងហរិតាលជាដើម កុំជ្រលក់អវយវៈ កុំជ្រលក់មុខ កុំជ្រលក់ទាំងខ្លួនទាំងមុខ បើភិក្ខុណា ធ្វើដូច្នេះ ត្រូវទុក្កដ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា* **អនុជានামិ ភិក្ខវេ អាពាធប្ប ច្ចយា មុខំ អាលិម្ពិតុំ** *ដូច្នេះ ។ ព្រោះបច្ច័យ គឺ អាពាធនឹងលាបមុខក៏គួរ ។ ន័យមួយទៀតថា ភិក្ខុកុំគប្បីទ្រង់គ្រឿង*

ប្រដាប់ត្រចៀកមានការជាដើម ។ ដ្បិតទ្រង់បញ្ញត្ត ទុកថា **ន ភិក្ខវេ វលិកំ ជាវេតពុ ន ចាមជ្ជំ ជាវេតពុ ន កណ្ណសុត្តកំ ន កដិសុត្តកំ ន ឱវដ្ដិកំ... ន ការយុរ... ន ហត្ថាភ-រណ... ន អង្ខុលិមុទ្ធិកំ ជាវេតពុ...** *ភិក្ខុកុំគប្បីទ្រង់ការគ្រឿងប្រដាប់ត្រចៀក ដោយហោចទៅសូម្បីតែស្ទឹកត្នោត និងអម្ពោះសង្វារ និងគ្រឿងប្រដាប់ចង្កេះណាមួយ ដោយហោចទៅ សូម្បីតែអម្ពោះខ្សែចង្កេះក្តី និងកង និងខ្សែខ្ជូន និងគ្រឿងប្រដាប់ដៃ និងចិញ្ចៀន ភិក្ខុណាទ្រង់គ្រឿងប្រដាប់ទាំងអម្បាលនេះ ដូចពោលមកហើយនេះ ត្រូវទុក្កដ ។*

ខមួយ ភិក្ខុកុំគប្បីឲ្យគេដកសក់ស្លូវ បើឲ្យគេដកត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ បលិតំ តាហាបេតពុ** *ដូច្នេះ ។ ពេមឯណាដែលដុះឡើងនៅចិញ្ចើម ឬនៅថ្ងាស ឬអមគាងជារបស់គួរខ្ពើម ពេមអម្បាលនេះ ទោះស្លូវក្តី មិនស្លូវក្តី សូម្បីឲ្យគេដកក៏គួរ ។*

ខមួយ ភិក្ខុកុំគប្បីឲ្យគេកាត់សក់នឹងកន្ត្រៃ បើឲ្យគេកាត់ ត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ កត្តរិការយ កេសា ឆេជាបេតព្វា** *ដូច្នេះ ។ កើតពេគមានដំបៅជាដើមលើក្បាល នឹងឲ្យគេកាត់សក់ដោយកន្ត្រៃ ដើម្បីនឹងឲ្យគេលាបថ្នាំក៏គួរ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា* **អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា ។ កត្តរិការយ កេសេ ឆេជាបេតុំ** *ដូច្នេះ ។*

ខមួយ ភិក្ខុកុំគប្បីឲ្យគេកាត់ពុកមាត់ដោយកន្ត្រៃ បើឲ្យគេកាត់ ត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ មស្សុ កប្បាបេតុំ** *ដូច្នេះ ។*

ខមួយ ភិក្ខុកុំគប្បីសិតសក់ដោយស្ងិត កុំសិតដោយវត្ថុណាមួយ មានក្រាសភ្ជុកជាដើម កុំយកដៃធ្វើជាក្រាសសិតសក់នឹងម្រាមដៃ កុំ សិតលាបដោយប្រេងលាយនឹងក្រមួន កុំសិតលាបដោយប្រេងលាយ នឹងទឹក បើសិតដូច្នេះ ត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ភោជ្ជេន ភេសា ឱសណ្ហាតព្វា ន ផណ្ណេភេន... ន ហត្ថផណ្ណេភេន... ន សិត្ថតេលេភេន... ន ឧទកតេលេភេន ភេសា ឱសណ្ហាតព្វា...** *ដូច្នេះ ។ សិតដើម្បីនឹងតែងខ្លួន ត្រូវទុក្កដ ក្នុងទីទាំងពួង ។ ក៏ឯចុងសក់រាបះឡើង លើ គប្បីជ្រលក់ដៃឲ្យទទឹក ហើយស្ទាបក្បាលដើម្បីឲ្យធ្លាក់ចុះតាមគ្នា សូម្បីក្បាលក្តី ឬប្រឡាក់ដោយធូលី នឹងជូតដោយដៃទទឹកក៏គួរ ។*

ខមួយ ភិក្ខុគ្មានជំងឺ កុំគប្បីធ្ងុះមុខនឹងកញ្ចក់នឹងភាជនៈដាក់ទឹក បើធ្ងុះត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ អាទាសេ វា ឧទកបត្តេ វា មុខនិមិត្តំ ឱលោកេតុំ** *ដូច្នេះ ។ និមិត្តនៃមុខប្រាកដក្នុងវត្ថុណា សូម្បីផ្ទៃនសំរឹទ្ធិជាដើម វត្ថុទាំង ពួងនោះរាប់ថា អាទាសៈ កញ្ចក់ទាំងអស់ សូម្បីទឹកថ្ងា ទឹកជ្រក់ជាដើមក្តី ក៏រាប់ថា ឧទកបត្តទាំងអស់ ព្រោះហេតុនោះ កាលបើមើលស្រមោលមុខ*

ក្នុងទីណាមួយ ត្រូវទុក្កដ ។ កើតដំហៅនៅមុខហើយមើលស្រមោលមុខក្នុងកញ្ចក់ជាដើម ដើម្បីនឹងឲ្យដឹងថា ដំហៅយើងដុះសាច់ហើយ ឬនៅឡើយ នេះគួរ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា ។ ល ។ ឱលោកេតុំ** ដូច្នេះ ។

ក្នុងអដ្ឋកថា ថានឹងមើលដើម្បីឲ្យដឹងអាយុសង្ខារ ថាយើងចាស់ហើយ ឬនៅ នេះគួរ ។

ខមួយ ភិក្ខុកុំគប្បីសម្ងឹងមើលនិមិត្តស្ត្រី ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកក្នុងវិនីតវត្ថុថា **ន ច ភិក្ខវេ សារត្តេន មាតុគាមស្ស អង្គជាតំ ឧបនិជ្ឌាយិតព្ពំ...** ភិក្ខុកុំគប្បីសម្ងឹងមើលអង្គជាតនៃមាតុគ្រាមដោយតម្រេក បើភិក្ខុណាមើលត្រូវទុក្កដ ។ សូម្បីស្ត្រីស្ងៀកសំពត់មួយរយជាន់ ឈរពីមុខ ឬពីក្រោយ រមិលមើលដោយគិតថានិមិត្តនៅក្នុងឱកាសឈ្មោះនេះ ត្រូវទុក្កដ ។ ដែលសម្ងឹងមើលនិមិត្តនៃស្ត្រីក្មេងអ្នកស្រុកមិនទាន់ស្ងៀកសំពត់ មិនបាច់ពោល សូម្បីសម្ងឹងមើលនិមិត្តតិរច្ឆានញ៉ី ក៏ត្រូវអាបត្តិដូចគ្នា ។ បើមិនរមិលមើលខាងណោះខាងណេះ សម្ងឹងមើលដោយប្រយោគតែមួយ សូម្បីអស់មួយថ្ងៃ ត្រូវទុក្កដ តែមួយ ។ បើក្រឡេកសម្ងឹងមើលរឿយៗ ត្រូវទុក្កដគ្រប់ប្រយោគ ។ កុំគប្បីកាត់អាបត្តិដោយភិក្ខុធ្មេចភ្នែក ហើយបើកភ្នែកឡើងមើល សម្ងឹងមើលហើយត្រឡប់គិតតាំងនៅក្នុងសំវរៈវិញដោយប្រញាប់ មិនត្រូវអាបត្តិ ។ លះសំវរៈចេញហើយ សម្ងឹងមើលទៀតគង់ត្រូវអាបត្តិទុក្កដ ដោយពិត ។

ខមួយ ភិក្ខុកាលងូតទឹក កុំគប្បីដុសកាយនឹងដើមឈើ នឹងសសរ នឹងជញ្ជាំង បើដុសកាយក្នុងទីទាំងអម្បាលនេះ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធ-អង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ន្ហាយមានេន រុក្ខេ កាយោ ន ថម្ភេ ន ការុ្ជ្ជ្ជ កាយោ ឧត្ឆ្ឃ៌ សេតព្ជ** ដូច្នេះ ។

ខមួយ ភិក្ខុកុំគប្បីងូតទឹកក្នុងទីឈ្មោះអដ្ឋាន: និងកុំងូតទឹកដោយឈើឈ្មោះគន្ធព្ជហត្ថក: កុំងូតទឹកដោយការ៉ុ្ជ្ជ្ជ

ដូចគ្នា ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ទ្វិក្ខ្យ្ហ បរិកម្មំ ការេបេតព្ពំ**... ដូច្នេះ ។

មួយទៀត ព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ មលៃ្ហ ជហាយិតព្ពំ**... ភិក្ខុកុំគប្បីផ្ងួតទឹកដោយឈើឈ្នោះមលៃ្ហ: បើភិក្ខុណាផ្ងួតដោយឈើឈ្នោះមលៃ្ហ:ត្រូវទុក្កដ ។ ឈើគេធ្វាក់ធ្វើជាធ្មេញម្ករ ធ្វើសណ្ឋានដូចឫសដំឡូងឈ្នោះមលៃ: ឈើមលៃ្ហ: នេះ សូម្បីភិក្ខុឈឺក៏មិនគួរ ។ ឈើមលៃ្ហ: គេមិនបានធ្វាក់ជាធ្មេញម្ករ គួរដល់ភិក្ខុឈឺ ភិក្ខុមិនឈឺមិនគួរ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ តិលានស្ស អកតមលៃ្ហ** ដូច្នេះ ។ កំណាត់អំបែងក្បឿង ឬកំណាត់ឫ គួរដល់ភិក្ខុទាំងពួង ធ្វើសំពត់និងបាតដៃជារបស់គួរ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ ឧណ្ហាសិកំ**... **បុថុចាណិកំ** ដូច្នេះ ។ **ឧណ្ហាសិកំ** ប្រែថាធ្វើសំពត់ ព្រោះហេតុនោះ ភិក្ខុណាមួយ ផ្ងួតទឹកនិងយកធ្វើសំពត់ដុសខ្លួននោះក៏គួរ ។ **បុថុចាណិកំ** ប្រែថាហត្ថបរិកម្ម ព្រោះហេតុនោះ ភិក្ខុទាំងពួងនឹងធ្វើ បិដ្ឋិបរិកម្ម គឺដុសខ្នងគ្នាដោយដៃក៏គួរ ។ ក៏ឯនហានវត្ត ទំនៀមផ្ងួតទឹកដូច្នេះ ទៅដល់កំពង់ទឹកហើយ កុំយកចីវរចោលទុកក្នុងទីណាមួយ ហើយប្រញាប់ចុះទៅ គប្បីក្រឡេកមើលក្នុងទិសទាំងពួងដឹងថាស្ងាត់ហើយ គប្បីកំណត់ដង្គត់នឹងគុម្ពឈើនិងវល្លិជាដើម ហើយក៏ឈរឱនខ្លួនចុះ ដោះចីពរចេញហាលទុក ស្រាយវត្ថពន្ធចង្កេះដាក់ទុក

លើចីវរ បើសំពត់ងូតមិនមាន គប្បីអង្គុយច្រហោងចុះក្នុងទីជិតទឹក ក្រើចស្បង់ចេញ បើទីហាលមានសោត គប្បីសំដិលទុកក្នុងទីមានកម្តៅថ្ងៃ បើទីហាលមិនមាន គប្បីអង្ការាញ់ពាក់ទុក កាលបើចុះទៅត្រឹមផ្ចិត កុំធ្វើឲ្យជារលក ជាសំឡេង គប្បីបែរត្រឡប់មុខមកខាងទិសដែលខ្ជូនមកហើយមុជចុះ កាលបើធ្វើដូច្នេះនេះក៏នឹងបានរក្សានូវចីវរនោះផង កាលបើងើបឡើង កុំធ្វើសំឡេងខ្លាំង សន្សឹមៗ ហើយងើបឡើង ងូតរួចហើយគប្បីអង្គុយច្រហោងទៀបមាត់ទឹក ព័ទ្ធសំពត់ស្ងៀកហើយក្រោកឡើងស្ងៀកឲ្យជាបរិមណ្ឌលដោយប្រពៃ ហើយចងវត្ថពន្ធចង្កេះដណ្តប់ចីពរឈរនៅ បើងូតមានសំពត់ងូតសោត ឡើងមកហើយគប្បីឲ្យឈ្នួរទឹកធ្លាក់ដាច់ពីខ្ជូន ហើយសឹមស្ងៀកដណ្តប់ ។

មួយទៀត ភិក្ខុកុំអាក្រាតកាយគឺមិនមានស្បង់ចីពរ សំពះអ្នកអាក្រាតកាយផងគ្នា កុំអាក្រាតកាយសំពះអ្នកដទៃ កុំអាក្រាតកាយឲ្យអ្នកអាក្រាតកាយសំពះខ្ជូន កុំអាក្រាតកាយឲ្យគេសំពះខ្ជូន កុំអាក្រាតកាយធ្វើបរិកម្មឲ្យអ្នកអាក្រាតកាយផងគ្នា កុំអាក្រាតកាយឲ្យរបស់ដល់អ្នកអាក្រាតកាយផងគ្នា កុំអាក្រាតកាយទទួលរបស់ កុំអាក្រាតកាយទំពាធាន់ កុំអាក្រាតកាយធាន់ កុំអាក្រាតកាយលិទ្ធវត្ថុទាំងពួង កុំអាក្រាតកាយធាន់ទឹក បើអាក្រាតកាយ ធ្វើនូវអាការអម្បាលនេះ ណាមួយត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ន ក្ខេន ន ក្ខោ អភិវាទេតព្ពោ ។ ល ។ ន ន ក្ខេន ចាតព្ពំ** ដូច្នេះ ។ ទ្រង់

អនុញ្ញាតគ្រឿងបិទកាយ ៣ ប្រការគឺ **ឆន្ទាយរបដិច្ឆាទិ** គ្រឿងបិទកាយគឺរោងភ្លើង ១ **ឧទកបដិច្ឆាទិ** គ្រឿងបិទកាយ គឺទឹក ១ **វត្ថបដិច្ឆាទិ** គ្រឿងបិទកាយ គឺ សំពត់ ១ ។ ក៏ឯគ្រឿងបិទកាយគឺរោងភ្លើង និងគ្រឿងបិទកាយគឺទឹក គួរក្នុងកាលដែលធ្វើបរិកម្មមានដុសខ្នងជាដើមប៉ុណ្ណោះ មិនគួរក្នុងកម្មដ៏សេសមានអភិវាទនកម្មជាដើម ។ គ្រឿងបិទកាយគឺសំពត់ គួរក្នុងកម្មទាំងពួង ។

មួយទៀត ភិក្ខុកុំគប្បីប្រើអំបែងជូតជើង ដែលគេធ្វើជាបន្ទា ជាពកមានសណ្ឋានដូចពកផ្ការីកយ៉ូក ដើម្បីនឹងជូតជើង បើប្រើអំបែងជូតជើងដូច្នេះ ត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ពាតកំ បរិភុञ្ជិតព្វំ** ដូច្នេះ ។ អំបែងជូតជើងនោះ ទោះមូលក្តី បួនជ្រុងជាដើមក្តី ព្រះពុទ្ធអង្គទ្រង់ហាមឃាត់ ព្រោះជាពហុល្យានុយោគ នឹងទទួលក៏មិនគួរ នឹងប្រើប្រាស់ក៏មិនគួរ ។ គ្រឿងជូតជើង ៣ ប្រការ គឺ ក្រួសឬសិលា ១ អំបែងក្បឿងឬឥដ្ឋ ១ ផ្សិតដែលកើតពីពពុះទឹកសមុទ្ទ ១ បីនេះជារបស់គួរ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ តិស្សោ ចាឧយំសនិយោ សក្ខរំ កបលំ សមុទ្ទផេណកំ** ដូច្នេះ ។

មួយទៀត ព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ចេឡបដិកា អក្ខមិតព្វា** ភិក្ខុកុំគប្បីជាន់ផែនសំពត់ បើជាន់ត្រូវទុក្កដ ។ រឿងនេះ ព្រះពុទ្ធអង្គទ្រង់ប្រារព្ធនឹងពោធិរាជកុមារ កាល

សាងកោកនុទប្រាសាទឡើងថ្មី ក្រាលប្រាសាទដោយសំពត់ស ដរាបដល់ជណ្តើរជាបឋម ហើយប្រើមនុស្សឲ្យទៅនិមន្តព្រះពុទ្ធអង្គមកសោយលើប្រាសាទ ។ គ្រានោះព្រះពុទ្ធអង្គស្តេចយាងមក ពោធិរាជកុមារនិមន្តឲ្យព្រះពុទ្ធអង្គជាន់លើសំពត់ស ព្រះពុទ្ធអង្គក៏មិនជាន់ បែរព្រះកត្រៃទៅព្រះអានន្ទ ព្រះអានន្ទបង្គាប់ឲ្យរើចេញ ទើបយកទៅក្រាលជាអាសនៈលើប្រាសាទ ព្រះពុទ្ធអង្គសោយស្រេច ស្តេចក៏យាងត្រឡប់មក ទើបព្រះពុទ្ធអង្គទ្រង់បញ្ញត្តហាមឃាត់ដូច្នេះ ។ ក្នុងអដ្ឋកថាថា ពោធិរាជកុមារផ្សងទុកថា បើយើងនឹងមានកូន ព្រះពុទ្ធអង្គគង់នឹងជាន់លើកម្រាល ថាបើមិនមានកូន ព្រះពុទ្ធអង្គនឹងមិនបានជាន់ ព្រះពុទ្ធអង្គឃើញថាមិនមានកូន បើជាន់ចុះ ពោធិរាជកុមារនឹងឃើញវិបល្លាសទៅ ទើបទ្រង់មិនជាន់ នេះជាហេតុដែលទ្រង់មិនជាន់ ។ ចំណេរមកខាងមុខភិក្ខុទាំងឡាយមិនដឹង បើជាន់សំពត់ដូច្នោះទៅ គ្រហស្ថទាំងឡាយគេនឹងមើលងាយបាន ព្រោះហេតុនោះ ព្រះពុទ្ធអង្គទើបទ្រង់បញ្ញត្តហាមឃាត់រឿងនេះទុក ។ ស្រីមានគភ៌ចាស់ ឬសម្រាលកូនថ្មីៗ អាចធនាឲ្យជាន់ចុះក្តី នឹងជាន់សំពត់ដែលគេក្រាលទុកសម្រាប់ជូតជើងក្តី ទាំងអស់នេះគួរ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ តិហីនំ មង្គ្លសត្ថាយ យាចិយមានេន ។ ល ។ អនុជានាមិ ភិក្ខវេ ឧោត-ចានកំ អក្ក្រមិតុំ** ដូច្នេះ ។

មួយទៀត ភិក្ខុមិនមានជំងឺកុំបាំងឆត្រក្រៅឧបចារវត្ត ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ឆត្តំ ធារេតព្វំ...** *ភិក្ខុកុំគប្បីបាំងឆត្រ បើបាំងត្រូវទុក្កដ ។ បើខ្លួនក្តៅក្រវល់ក្រវាយ ឬឈឺក្បាលឬស្រវាំងភ្នែក ឬអាពាធដទៃណាមួយ បើរៀរឆត្រចេញហើយ បង្កើតជាជំងឺ ភិក្ខុឈឺនោះនឹងបាំងឆត្រក្នុងស្រុកក្នុងព្រៃក៏គួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា* **អនុជានামិ ភិក្ខវេ តិណានិ ឆត្តំ** *ដូច្នេះ ។ បើភ្ញៀង នឹងរក្សាចីវរ ឬខ្ជាចសត្វសាហាវនិងចោរ សូម្បីបាំងឆត្រដើម្បីនឹងរក្សាខ្លួនក៏គួរ ។ ឯបាំងឆត្រស្ទឹកឈើគួរក្នុងទីទាំងពួងមិនឈឺបាំងបានតែក្នុងវត្ត ឬឧបចារៈនៃវត្ត ។ ដ្បិតទ្រង់អនុញ្ញាតទុកថា* **អនុជានামិ ភិក្ខវេ អតិណានេនបិ ភិក្ខុនា អារាមេ អារាមុបចារេ ឆត្តំ ធារេតុំ** *ដូច្នេះ ។*

មួយទៀត ភិក្ខុកុំគប្បីឲ្យគេគូរគំនូររូបភាព បើឲ្យគេគូរ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ បដិភាណចិត្តំ ការាបេតព្វំ ឥត្ថីរូបកំ បុរិសរូបកំ...** *ដូច្នេះ ។*

មិនត្រឹមតែរូបស្ត្រី រូបប្រុសមួយជំពូកប៉ុណ្ណោះទេ សូម្បីតែរូបសត្វតិរច្ឆាន ដោយហោចទៅតែរូបជន្ទេន ភិក្ខុនឹងធ្វើឯង ឬបង្គាប់ឲ្យគេធ្វើ មិនគួរ ។ សូម្បីនឹងពោលថា ឧបាសកអ្នកចូរធ្វើមនុស្សរក្សាទ្វារដូច្នេះក៏មិនគួរ ។ ឯនឹងឲ្យអ្នកដទៃគួររឿងជាតកនិងរឿងអសទិសទានជាដើម ឬរឿងដែលជាទីតាំងនៃសេចក្តីជ្រះថ្លា និងប្រកបដោយសេចក្តី

ទៀយណាយនោះបាន ។ សូម្បីគ្ងរដើមឈើវល្ងិជាដើមក៏បាន ។ ដ្ឋិត ទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ មាឡាកម្មំ ឧតា-កម្មំ មការឧត្តកំ បញ្ចមដិកំ** *ដូច្នេះ ។*

<u>មណ្ឌនាទិកថា</u> ចប់

បត្តបដិសំយុត្តកថា

ខមួយ ភិក្ខុកុំគប្ដីយកបាត្រព្ជួរក្នុងទីណាមួយ បើព្ជួរត្រូវទុក្កដ ។ ដ្ឋិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ បត្តោ ឧត្ដ្ដ្ដ្ដ្ដ** *ដូច្នេះ ។ សូម្បីនឹងចងព្ជួរក្នុងខ្សែស្ជៀងចីវរទុកក៏មិនគួរ ។ មួយទៀត កុំយកបាត្រ ដាក់លើគ្ងែ លើតាំង លើកន្ទ្ធ លើធ្ងត លើក្ដ្ដ្ដ្ដ្ដ និងក្នុងទីបំផុត នៃបរិកណ្ណ បើដាក់ក្នុងទីទាំងអម្ជ្ជ្ជ្ជ្ជ ត្រូវទុក្កដ ។ ដ្ឋិតព្ជ្ជ្ជ្ជ អង្ក្ជ្ជ្ជ្ជ ទុកថា* **ន ភិក្ខវេ ម្ជ្ជ្ជ្ជ ឧត្ដ្ដ ដ ដ ដ ... ...

ក៏គួរ ។ នឹងយកខ្សែយោគពាក់ចូលក្នុងចង្ហួយស្នាហើយតម្កល់លើក្នែន ក៏គួរ ។ សូម្បីបាត្រពេញដោយបាយស្ពាយលើចង្ហួយស្នា នឹងយកតម្កល់ទុកលើធត្រមិនគួរ ។ ឯនឹងចងបាត្រទេ នឹងបាត្រដែលពេញដោយបាយជាមួយនឹងកណ្ដា ហើយតម្កល់លើធត្រ ឬនឹងតម្កល់បាត្រដូច្នេះលើធត្រ ដែលចងជារន្ធាតម្កល់ទុកក្ដីក៏គួរ ។ នឹងតម្កល់បាត្រលើក្របនៃរបៀងជាដើមនឹងក្ដារបង្ហែកមិនគួរ ។ បើបាត្រសូម្បីរមៀលទៅក៏ឋិតនៅក្នុងក្រប ក្នុងភ្នាក់ដៃនោះឯង នឹងតម្កល់បាត្រលើក្របដែលធំទូលាយយ៉ាងនេះគួរ ។ ទីបំផុតនៃបរិកណ្ណនោះ គឺឋានផ្ទៃក្រៅ ក្របក្រៅភ្នាក់ដៃ វិនិច្ឆ័យក្នុងទីបំផុតនៃបរិកណ្ណនេះ គប្បីដឹងដោយន័យដូចសម្ដែងហើយក្នុងក្របនោះចុះ ។

មួយទៀត ភិក្ខុកុំគប្បីដាក់បាត្រ ផ្ដាប់បាត្រលើផ្ទៃដែលមុតដែលរឹង ។ ដ្បិតទ្រង់អនុញ្ញាតគ្រឿងរងទុកគឺ **តិណាសន្ថារកំ** គ្រឿងកម្រាលរងធ្វើដោយស្មៅ ១ **ចោឡកំ** កំណាត់សំពត់ក្រាលរងបាត្រ ១ ។ បើកំណាត់សំពត់នោះមិនមាន នឹងដាក់បាត្រលើកន្ទេលផ្ដៅ ឬកន្ទេលផ្ដែង ឬនឹងដាក់លើផ្ទៃដែលគេលាបដីស្អិតក្នុងទីណា ដែលមិនប្រទូសវ៉ាយបាត្រ នឹងដាក់ក្នុងទីដូច្នោះ ឬលើខ្សាច់ក៏គួរ ។ កាលបើដាក់ក្នុងទីមានដីស្រួយ និងធូលីជាដើម ឬលើផ្ទៃដែលមុតដែលរឹង ត្រូវទុក្ខដ ។ **បត្តមាឡកំ** រោងសម្រាប់ទុកបាត្រ ធ្វើដោយឥដ្ឋ ឬឈើ **បត្តកុណ្ណោលិកំ** អាងសម្រាប់ដាក់របស់មានសណ្ឋានដូចផើងមាត់ធំ របស់ទាំងនេះព្រះពុទ្ធ

*អង្គ*ទ្រង់*អនុ*ញ្ញា*ត*ទុ*ក* *ដើ*ម្ប*ីឲ*្យ*ជ*ាទ*ីទ*ុ*ក*ប*ាត្រ **បត្តត្ថ*ិ*ក*ំ** *ប*ង*ប*ាត្រ **អ*ំ*ស*ា*ដ*ុ*ក*ំ** **ព*ន*ធ*ន*ស*ុ*ត*ត*ក*ំ** *យ*ោ*ក*ប*ាត្រ* *និ*ង*ខ*្ស*ម*្រ*ាប*ៃ*ចង* *ร*ប*ស*ទ*ាំ*ង*ព*ីរ*ន*េ*ះ* *ព*្រ*ះ*អ*ង*្ក*ទ*្រ*ង*ៃ*អ*ន*ុ*ញ*ា*ត*ទ*ុ*ក*ឲ*្យ*ដ*ើ*ម*្ប*ីន*ឹ*ង*រ*ក*ា*ប*ាត្រ* ។ **ប*ត*ា*ជ*ារ*ក*ំ** *ដ*ើ*ង*ប*ាត្រ*ន*េ*ះ* *ព*្រ*ះ*ព*ុ*ទ*ធ*អ*ង*ក*ទ*្រ*ង*ៃ*អ*ន*ុ*ញ*ា*ត*ទ*ុ*ក*ជ*ា*ត*្រ*ៀ*ង* *ត*ម*ក*ល*ប*ាត្រ* ។ *ក*ុ*ង*អ*ដ*ក*ថ*ា*ក*ុ*រ*ុ*ន*ទ*ី*ព*ោ*ល*ទ*ុ*ក*ថ*ា* *ដ*ើ*ង*ប*ាត្រ*ម*ាន*ស*ណ*ា*ន* *ដ*ូ*ច*ក*ង* គ*ឺ*ប*ុ*គ*ា*ល*ធ*ៃ*ដ*ោ*យ*ក*ុ*ក* *និ*ង*ว*ល*ិ* *និ*ង*ផ*ៅ*ជ*ា*ដ*ើ*ម* *និ*ង*ត*ម*ក*ល*ប*ាត្រ*ប*ី* *ត*ម*ូ*ត*ល*ើ*គ*ា*ប*ាន* *ឬ*ដ*ើ*ង*ប*ាត្រ*ធ*ៃ*ដ*ោ*យ*ឈ*ើ* *និ*ង*ត*ម*ក*ល*ប*ាត្រ*ព*ីរ*ត*ម*ូ*ត* *ล*ើ*គ*ា*គ*ួ*រ* ។ *ត*ែ*ក*ុ*ង*ม*ห*ា*អ*ដ*ក*ថ*ា*ព*ោ*ล*ទ*ុ*ក*ថ*ា* *ก*ុ*ง*ด*ើ*ง*ป* า*ต*ร*ม* า*น* *ส*ณ*ฑ*า*น*ด*ู*จ*ก*ง* *ม*ิ*น*ม*า*น*ข*ิ*ก*า*ส*ล*ួ*ม*ต*ម*ក*ล*ป*ា*ត*្ร*ป*ី*ป*ា*ន* *និ*ង*ต*ม*ก*ล* *ป*า*ต*ร*ต*ร*ึ*ม*ต*ែ*ព*ี*ร*ค*ู*ร* ។ *ส*ู*ม*ป*ี*ด*ើ*ง*ป*า*ต*ร*ธ*ว*ี*ด*ว*ย*ล*ว*ี* *ห*ร*ือ*ก*ำ*ณ*า*ต*ล*ว*ี*ก*็* *ด*ู*จ*ค*ว*า* ។ *ด*ើ*ง*ป*า*ต*ร*ธ*ว*ี*ด*ว*ย*ล*ว*ี*ด*ู*จ*ต*ร*ฉ*า*จ*ก*ร*ฉ*ี*ง* *និ*ง*ด*ើ*ง*ป*า*ต*ร* *ธ*ว*ี*ด*ว*ย*ก*ำ*ณ*า*ต*ล*ว*ี* *ค*ื*ย*ก*ล*ว*ี*ป*ี*ก*ำ*ณ*า*ต*ง*ภ*ั*ก*ป*ា*ន*ค*ា*ត*ី* *ก*็*ม*ิ*น*ช*า* *ข*ิ*ก*า*ส*ន*ៃ*ป*า*ต*ร* ។ *ส*ู*ม*ป*ី*ต*ែ*ม*ួ*យ* *ป*ា*ห*ើ*ต*ម*ក*ล*ป*ា*ต*ร*ล*ើ*ด*ើ*ง*ป*า*ต*ร*ห*ោ*ะ* *ค*ป*ี*អ*ង*ុ*យ*ย*ก*ដ*ៃ*ป*า*ห*ป*ា*ห*ท*ุ*ก* *ป*ើ*ม*ផ*ៃ*ค*ป*ี*ห*ป*ា*ห*ท*ุ*ก*ต*ែ*ม*ួ*យ* *ห*ើ*ย*ต*ม*ก*ล* *ท*ุ*ก*ป*ุ*ะ* ។

มួ*យ*ท*ៀ*ต *ภ*ิ*ก*ข*ุ*ก*ำ*ค*ป*ី*ย*ก*ร*ป*ส*ំ*ณ* า*ล*ป*ា*ก*ก*ុ*ง*ป*า*ต*ร *ก*ำ*ล*า*ง*ด*ៃ*ก*ុ*ง* *ป*า*ต*ร *ค*ป*ี*ล*า*ง*ก*ុ*ง*ก*ន*្ត*ារ ។ *ด*ู*ป*ิ*ต*ព*ระ*ព*ុ*ท*ธ*អ*ง*ค*ទ*្ร*ง*ห*ា*ม*ห*ា*ต*់*និ*ง*អ*ន*ុ*ญ* า*ต* *ท*ุ*ก*ป*า* **ณ ภิกฺขเว จลกานิ ปา อฏฺฐิกานิ ปา ฉฺฉิฏฺฐา-ณกํ ปา ปตฺเตน นีหริตพฺพํ...** ។ **อนุชานามิ ภิกฺขเว**

បដិក្ខេបំ ម្នាលភិក្ខុទាំងឡាយអាមិសដែលខ្ជាក់ចេញ និងធ្ពឹងត្រី ឬធ្ពឹងសាច់ ឬទឹកខ្ទុះមាត់ ដែលជាសំណល់ណាមួយ ភិក្ខុកុំគប្បីនាំទៅដោយបាត្រ បើនាំទៅត្រូវទុក្កដ ។ តថាគតអនុញ្ញាតកន្ទោរជាគ្រឿងរងទទួល សូម្បីនឹងយកបាត្រធ្វើជាកន្ទោរលាងដៃ មិនបានឡើយ ។ សូម្បីនឹងដាក់ទឹកលាងដៃលាងជើងក្នុងបាត្រ ហើយនាំយកទៅចាក់ចោលក៏មិនគួរ នឹងចាប់បាត្រដែលស្អាតមិនប្រឡាក់ ដោយដៃដែលប្រឡាក់ក៏មិនគួរ ។ ដែលនឹងយកដៃធ្វេងចាក់ទឹកក្នុងបាត្រ ហើយយកដៃស្តាំដែលប្រឡាក់ចាប់យកទឹកខ្ទុះមាត់នោះគួរ ព្រោះបាត្រនោះឈ្មោះថាបាត្រប្រឡាក់ដោយហេតុមានប្រមាណប៉ុណ្ណោះ ។ នឹងយកដៃដែលប្រឡាក់ លាងទឹកខាងក្រៅឲ្យជ្រាសចាកអាមិសសិន ហើយកាន់យកក៏គួរ ។ កាលធាន់ត្រីសាច់ផលាផលជាដើម ក្នុងរបស់ទាំងអម្បាលនេះ ឬវត្ថុណាមួយជាធ្ពឹងក្តី សំណល់ក្តី ប្រាថ្នានឹងចោលនឹងយកដាក់ក្នុងបាត្រនោះ មិនបានឡើយ ។ របស់ណាដែលប្រាថ្នានឹងចង់ធាន់តទៅទៀត នឹងយករបស់នោះដាក់ក្នុងបាត្រនោះបាន នឹងដាក់ធ្ពឹងត្រីជាដើមទុកក្នុងបាត្រហើយយកដៃហូតចេញធាន់ក៏គួរ ។ របស់ណាមួយនាំចេញអំពីមាត់ហើយ ប្រាថ្នានឹងធាន់ទៀត នឹងយករបស់នោះដាក់ក្នុងបាត្រ មិនបាន ។ ចំណិតខ្ញី និងចំណិតដូងជាដើមខាំធាន់ហើយដាក់ចុះវិញនេះបាន ។

មួយទៀត ភិក្ខុកុំគប្បីធាន់ក្នុង អាសិត្តកុបធាន ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ អាសិត្តកុបធានេ**

ភុញ្ជិតព្វំ... ភិក្ខុកុំគប្បីធាន់ក្នុងអាសិត្តកុបជាន បើធាន់ត្រូវទុក្កដ ។ អាសិត្តកុបជាននេះ ប្រែថា ទៀបខ្ទះ ថាប្រអប់ខ្ទះ តែក្នុងវិមត្តិវិនោទនី ថាជាឈ្មោះនៃជ្រញ់សម្រាប់រងកាជន: មានអាការ:ដូចកាជន:មួយយ៉ាង គេធ្វើជា ៨ ជ្រុងខ្ទះ ជា ១៦ ជ្រុងខ្ទះ ដាក់បាយបាយាសជាដើមដែលនៅក្តៅ ហើយតម្កល់ថាសរងកាជន:ខាងលើ ដើម្បីនឹងមិនឲ្យបាយដែលក្តៅនោះ បាត់ក្តៅ ជ្រញ់សម្រាប់រងដូច្នេះ គេធ្វើដោយទង់ដែងខ្ទះ ដោយប្រាក់ខ្ទះ ព្រោះជារបស់ព្រះពុទ្ធអង្គទ្រង់ហាមឃាត់ហើយ សូម្បីធ្វើដោយឈើក៏ មិនគួរ គួរតែគ្រឿងរងដែលធ្វើដោយកំណាត់ឈើដែលឈ្មោះថាមណ្ឌ-រិក: ជារបស់ទ្រង់អនុញ្ញាតដល់ភិក្ខុឈឺ ដែលមិនអាចនឹងកាន់បាត្រទុកធាន់បាន ។ ដើងបាត្រព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកក្នុងបទមុននេះ ដើម្បីនឹងឲ្យរក្សាបាត្រ មណ្ឌរិក:នេះ ទ្រង់អនុញ្ញាតដើម្បីនឹងឲ្យរងធាន់ សូម្បីគ្រឿងរងធ្វើនឹងឈើសារនឹងស្វឹកឈើនឹងកញ្ជើនឹងជាល ក៏រាប់ចូលក្នុងមណ្ឌរិក:ទាំងអស់ គ្រឿងរងនោះប្រហោងក្តី ឈ្ទុះធ្លាយក្តី មិនធ្ទុះធ្លាយក្តី នេះគួរដោយពិត ។

មួយទៀត ភិក្ខុកុំគប្បីយកលលាដ์ឃ្លោកធ្វើជាបាត្រ ដើរបិណ្ឌបាត កុំយកអំបែងពាង អំបែងផ្ទាំងធ្វើជាបាត្រដើរបិណ្ឌបាត បើបិណ្ឌបាតដោយ របស់ទាំងអម្បាលនេះ ត្រូវទុក្កដ ។ ដ្ឋិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ តុម្ពកជាហេន បិណ្ឌាយ ចរិតព្វំ**... ដូច្នេះ ។ លលាដ์ឃ្លោកនឹងរក្សាទុកមិនគួរ បើបានមកហើយ ធ្វើជារបស់ខ្ជីប្រ-ប្រាស់គួរ សូម្បីក្នុងអំបែង ក៏ដូចគ្នា ។

មួយទៀត កុំគប្បីយកលលាដ៍ក្បាលខ្មោចធ្វើជាបាត្រ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ឆវសីសម្ប បត្តោ ជាវេតព្ពោ យោ ជាវេយ្យ អាបត្តិ ទុក្កដស្ស ន ច ភិក្ខវេ សព្ពមំសុកូលិកេន ភវិតព្ពំ...** *ភិក្ខុកុំគប្បីទ្រង់បាត្រលលាដ៍ក្បាលខ្មោច បើទ្រង់ត្រូវទុក្កដ ។ ម្យ៉ាងទៀត ភិក្ខុមិនត្រូវជាអ្នកប្រព្រឹត្តកាន់យកវត្ថុបង្សុកូលទាំងពួងគ្រប់ប្រការទេ បើភិក្ខុណាកាន់យកវត្ថុបង្សុ-កូលគ្រប់ប្រការ ត្រូវទុក្កដ ។ ឯគ្រែនិងតាំងដែលគេបោះបង់ចោលកាន់យកដោយខ្លួនឯងក៏គួរ ។ ឯរបស់ដែលគួរគប្បីបរិភោគ គេឲ្យក៏គួរទទួលចុះ ។ មួយទៀតនឹងកាន់យករបស់បង្សុកូលក្នុងសាកសពដែលមិនទាន់បែក មិនគួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកក្នុងវិនីតវត្ថុថា* **ន ច ភិក្ខវេ អភិន្នេ សរីរេ បំសុកូលំ ឧហោតព្ពំ** *ដូច្នេះ ។ កាន់យករបស់បង្សុកូលក្នុងសាកសពដែលនៅស្រស់មិនគួរ ឧបទ្ទវន្តរាយរមែងមាន បើកាន់យកត្រូវទុក្កដ នឹងកាន់យកអំពីសាកសពដែលបែកហើយគួរ ។ ដូចម្តេចដែលឈ្មោះថាសាកសពបែកហើយ ។ ដែលឈ្មោះថាសាកសពបែកហើយ គឺសាកសពដែលសត្វមានក្អែកនិងតា-ដក់ និងឆ្កែ និងឆ្កែចចកជាដើម ចិកប្រជែងដោយចំពុះ ដោយមាត់និងចង្កូមសូម្បីបន្ដិច សាកសពនោះឈ្មោះថាបែកហើយ ។ សាកសពណាដែលដួលចុះរលាត់ មាត្រាតែសម្ផ្ទុរថ្ងៃដាច់ទៅ ស្បែកមិនទាន់ដាច់ សាក-សពនោះឈ្មោះថាមិនទាន់បែក លុះតែស្បែកដាច់ហើយទើបឈ្មោះថា*

បែក ។ សូម្បីសាកសពណាកាលរស់នៅឡើយ កើតបូស ឃ្ងង់រលក កែវ ឬដំបៅ សាកសពនោះក៏ឈ្មោះថាបែកហើយ ។ សូម្បីសាក-សពណាអំពីថ្ងៃគម្រប់ ៣ ឡើងទៅ ហើយហើមឡើង ក៏ឈ្មោះថាបែកដោយពិត ។ សូម្បីសាកសពដែលមិនទាន់បែកដោយប្រការទាំងពួង ភិក្ខុនឹងប្រើអ្នករក្សាប៉ាធា ឬមនុស្សដទៃឲ្យកាន់យកក៏គួរដោយពិត ថាបើមិនមានអ្នកដទៃ គប្បីធ្វើដោយសស្ត្រា ឬវត្ថុដទៃ ធ្វើឲ្យដាច់ជាស្នាមហើយ គប្បីកាន់យកបង្សុកូលចុះ ។ ឯក្នុងសរីរៈជាវិសភាគ គឺសាក-សពស្ត្រី នឹងតាំងស្មារតីញ៉ាំងសមណសញ្ញា ឲ្យកើតឡើង ហើយធ្វើឲ្យដាច់ជាស្នាមត្រង់ក្បាល ឬខ្នងដៃ ខ្នងជើង ទើបកាន់យកគួរ ។

មួយទៀត ភិក្ខុកុំគប្បីប្រើបាត្រឈើ បាត្រមាស បាត្រប្រាក់ បាត្រកែវមណី បាត្រកែវពិទូរ្យ បាត្រកែវផ្ទេក បាត្រសំរឹទ្ធិ បាត្រកែវស្ង បាត្រសំណរកក់ បាត្រស័ង្ខសី បាត្រទង់ដែង ទាំងអស់នេះ បើប្រើប្រាស់ត្រូវទុក្កដ ។ បាត្រពីរប្រការ គឺបាត្រដែក ១ បាត្រដី ១ ប្រើគួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់និងអនុញ្ញាតទុកថា ន ភិក្ខវេ ជារូ-បត្តោ ជាវតញ្ចោ យោ ជាវយ្យ អាបត្តិ ទុក្កដស្ស ន សោ-វណ្ណមយោ... ន រូបិយមយោ... ន មណិមយោ... ន វេឡុ-រិយមយោ... ន ផលិកមយោ... ន កំសមយោ... ន កាច-មយោ... ន តិបុកមយោ... ន សីសមយោ... ន តម្ពលោ-ហមយោ បត្តោ ជាវតញ្ចោ... ។ អនុជានាមិ ភិក្ខវេ ទ្វេ

បត្តេ អយោបត្តំ មត្តិកាបត្តំ ដូច្នេះ ។ ក្នុងរោងធាន់បើគ្រហស្ថ គេដាក់ម្ហូបក្នុងថាសមាសជាដើម បង្ហោនចូលមកប្រគេន សូម្បីនឹងចាប់ពាល់ក៏មិនគួរ ។ ភាជនៈមានថាសជាដើម ធ្វើដោយកែវផ្ទេក កែវស្ងួ នឹងសំរិទ្ធិជាដើម ជាបុគ្គលិកបរិភោគ មិនគួរ ។ ជាសង្ឆិកបរិភោគ ឬជាគិហិវិកដ (គ្រឿងប្រើនៃគ្រហស្ថ) នោះគួរ ។ បាត្រដ៏ហើយដោយទង់ដែង មិនគួរ ។ តែបើជាចាន ឬជាពែងក៏គួរ ពាក្យទាំងអម្បាលនេះពោលទុកក្នុងកុរុន្ទីអដ្ឋកថា ។

មួយទៀត ភិក្ខុកុំគប្បីយកបាត្រទាំងទទឹកទៅទុកដាក់ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ សោឧកោ បត្តោ បដិសាមេតព្ពោ...** ភិក្ខុកុំគប្បីយកបាត្រទាំងទទឹកទៅទុកដាក់ បើទុកដាក់ត្រូវទុក្កដ ។ គប្បីហាលថ្ងៃឲ្យស្ងួតជាមុនហើយសឹមទុក ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ ឋិតាបេត្វា បត្តំ បដិសាមេតុំ** ដូច្នេះ ។

មួយទៀត ភិក្ខុកុំគប្បីហាលបាត្រទាំងទទឹក បើហាលត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ សឧឧកោ បត្តោ ឋិតាបេតព្ពោ...** ដូច្នេះ ។ គប្បីធ្វើឲ្យស្រស់ដាច់ទឹកជាមុន ហើយសឹមហាល ។ ដ្បិតទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ ជិវុឧកំ ឧត្ថ ។ ល ។** ដូច្នេះ ។

មួយទៀត ភិក្ខុកុំគប្បីហាលបាត្រឲ្យក្តៅយូរពេក ។ ដ្បិតព្រះពុទ្ធ
អង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ឧណ្ហោ បត្តោ និឧហិ-**
តព្ពោ... *ភិក្ខុកុំគប្បីតម្កល់បាត្រទុកក្នុងទីក្តៅ បើតម្កល់ទុក ត្រូវ*
ទុក្កដ ។ គប្បីហាលទុកកណ្តាលថ្ងៃ ដែលក្តៅបន្ទិចហើយទុកដាក់ ។
ដ្បិតទ្រង់អនុញ្ញាតទុកថា **អនុជានামិ ភិក្ខវេ មុហុត្តំ ឧណ្ហោ**
ឱតាបេត្វា ។ ល ។ *ដូច្នេះ ។*

បត្តបដិសំយុត្តកថា ចប់

សេនាសនបដិសំយុត្តកថា

ខមួយ ភិក្ខុកុំគប្បីអង្គុយលើអាសនៈវែងជាមួយនឹងស្ត្រី នឹងខ្ទើយ
នឹងបណ្ឌក នឹងឧភតោព្យញ្ជនកៈ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា
អនុជានামិ ភិក្ខវេ បវេត្វា បណ្ឌកំ មាតុគាមំ ឧភតោ-
ព្យញ្ជនំ អសមានាសនិកេហិ សហ ឌីឃាសនេ និសី-
ទិតុំ *តថាគតអនុញ្ញាតឲ្យអង្គុយលើអាសនៈវែង ជាមួយនឹងអ្នកមាន*
អាសនៈមិនស្មើគ្នាបាន រៀងលែងតែបណ្ឌកគឺខ្ទើយ និងស្ត្រី និងឧភតោ-
ព្យញ្ជនក (មនុស្សមានទាំងភេទស្រីភេទប្រុស) អម្បាលនេះចេញ ព្រោះ
ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អាសនៈណាល្មមអង្គុយបាន ៣ នាក់
អាសនៈដូច្នេះឈ្មោះថាអាសនៈវែងយ៉ាងតូច ដ្បិតពាក្យថា **អនុជានামិ**
ភិក្ខវេ យំ តិណ្ណន្នំ បហោតិ ឯត្តកំ បច្ឆិមំ ឌីឃាសនំ

ដូច្នេះ ។ អាសនៈវែងដូច្នេះគួរនឹងនាំទៅបានក្តី ឬជារបស់ធ្ងន់មិនគួរនាំទៅក្តី ក្នុងអាសនៈដូច្នោះ សូម្បីជាកំណាត់ក្តារ នឹងអង្គុយជាមួយនឹងអនុបសម្បន្នក៏គួរ បើអង្គុយជាមួយនឹងបណ្ណកជាដើម មិនគួរ ។

មួយទៀត ភិក្ខុកុំគប្បីអង្គុយលើគ្រែ លើតាំង ជាមួយអសមានាសនិកៈ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានামិ ភិក្ខវេ សមានាសនិកេហិ សហ និសីទិតុំ ។ អនុជានামិ ភិក្ខវេ តិវស្សន្តរេន សហ និសីទិតុំ ។ អនុជានামិ ភិក្ខវេ ឧវត្តស្ស មញ្ចំ ឧវត្តស្ស ពីឬ** *តថាគតអនុញ្ញាតឲ្យអង្គុយជាមួយគ្នានឹងភិក្ខុមានអាសនៈស្មើគ្នា នឹងអនុញ្ញាតឲ្យអង្គុយជាមួយនឹងអ្នកមានវស្សាបីជាលំដាប់ និងអនុញ្ញាតគ្រែមួយដល់ភិក្ខុពីររូប និងតាំងមួយដល់ភិក្ខុពីររូប គឺអង្គុយបានតែពីរនាក់ ។ ភិក្ខុមានវស្សាចាស់ជាងគ្នា ឬខ្ចីជាងគ្នាពីរវស្សា ឈ្មោះថា តិវស្សន្តរ (ភិក្ខុមានលំដាប់នៃវស្សាបី) ឈ្មោះថាសមានាសនិកៈ (ភិក្ខុមានអាសនៈស្មើគ្នា) អង្គុយជាមួយគ្នាបានមិនត្រូវអាបត្តិ ។ ឯភិក្ខុដែលចាស់ជាងគ្នា ឬខ្ចីជាងគ្នា ១ វស្សា ឬភិក្ខុដែលមានវស្សាស្មើគ្នាទាំងអស់នេះមិនបាច់ពោល ភិក្ខុទាំងអម្បាលនេះពីរអង្គ នឹងអង្គុយរួមគ្រែ ឬតាំងជាមួយគ្នាបាន មិនត្រូវអាបត្តិ ។ ភិក្ខុដែលចាស់ ឬខ្ចីជាងគ្នាក្រៃលែងកំណត់នោះ ឈ្មោះថា អសមានាសនិក (ភិក្ខុមានអាសនៈមិនស្មើគ្នា) អង្គុយរួមគ្នាត្រូវអាបត្តិ ។ ក្នុងវិមតិវិនោទនី ថាសូម្បីភិក្ខុមានអាសនៈមិនស្មើគ្នា នឹងអង្គុយជាមួយគ្នាបីអង្គ លើ*

អាសនៈមិនមែនជាគ្រែ ជាតាំង នោះបាន តែក្នុងគ្រែ តាំង អង្គុយបានតែ ពីរអង្គ ក្នុងគ្រែនិងតាំងមិនមែនជាអាសនៈវែង ភិក្ខុមានអាសនៈស្មើគ្នា អង្គុយបានតែពីរអង្គប៉ុណ្ណោះ ព្រោះព្រះអង្គទ្រង់អនុញ្ញាតគ្រែនិងតាំងដល់ ភិក្ខុមានពួកពីរ មួយយ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះ សាមណេរនឹង អង្គុយ ឬដេក លើគ្រែតាំងតែ ១ ជាមួយគ្នា ស្មើនឹងភិក្ខុមិនបាន ។ ភិក្ខុកំណោះកាលសម្តែងធម៌ នឹងអង្គុយលើអាសនៈស្មើគ្នា ឬខ្ពស់ជាងគ្នា ដោយគោរពក្នុងធម៌ក្តី នឹងភិក្ខុដែលជាថេរៈ កាលបើឲ្យភិក្ខុកំណោះ សម្តែងធម៌ នឹងអង្គុយលើអាសនៈស្មើគ្នា ឬទាបជាង ដោយគោរពក្នុង ធម៌ក្តី ក៏គួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ ឧវគោឧ ភិក្ខុនា ។ ល ។ ធម្មការវេន** ដូច្នេះ ។

មួយទៀត ភិក្ខុកុំគប្បីដេកលើអាសនៈធំ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ ហាមឃាត់ទុកថា **ន ភិក្ខវេ ឧচ្ចាសយនមហាសយនានិ ធារេតព្វានិ សេយ្យថីទំ អាសន្ទិ... ឧកតោលោហិតកុប-ធានំ** ភិក្ខុកុំគប្បីទ្រង់ គឺដេកអង្គុយ លើទីដេក ទីអង្គុយ ដ៏ខ្ពស់ដ៏ធំ បើទ្រង់ត្រូវទុក្ខដ ។ ទីដំណេកខ្ពស់ ទីដំណេកធំនោះដូច្នេះ គឺ **អាសន្ទិ** អាសនៈ គ្រែ តាំង ខ្ពស់ហួសប្រមាណ **បល្ល ង្ក** បល្ល ង្ក ទីអង្គុយ ដែលគេធ្វើប្រដាប់ដោយរូបសត្វសាហាវនៅជើង **គោណ ១ ១** សំពត់ ១ ១ ១

បដិកា គ្រឿងកម្រាលមានពណ៌សធ្វើពីរោមសត្ត **បដលិកា** គ្រឿងកម្រាលធ្វើដោយរោមសត្តមានក្ដីវល្ងិជាផ្ការចង្កោម គេហៅថាសំពត់អ្នកស្រុកយោនក:ខ្ទះ សំពត់ទមិលខ្ទះ **តូលិកា** កម្រាលដែលញាត់គរប្រក្រតីមួយជំពូក **វិកដិកា** គ្រឿងកម្រាលធ្វើដោយរោមសត្ត វិចិត្រដោយរូបរាជសីហ៍និងរូបខ្ទាធំជាដើម **ឧទ្ធលោមី** គ្រឿងកម្រាលធ្វើដោយរោមសត្ត មានរោមច្រាងឡើងតែម្ខាង **ឯកន្ដលោមី** គ្រឿងកម្រាលធ្វើដោយរោមសត្ត មានរោមច្រាងឡើងទាំងពីរខាង **កដិស្សុំ** កម្រាលដែលធ្វើពីឱ្ជនមាសឬខ្សែសយចាក់ស្រែះដោយរតនវត្ថុ **គោ-សេយ្យំ** គ្រឿងកម្រាលដែលធ្វើពីសរសៃសូត្រ និងអំបោះ ចាក់ស្រែះដោយរតនវត្ថុ **កុត្ដកំ** គ្រឿងកម្រាលធ្វើដោយរោមសត្ត ធំល្មមចំណុះស្រីរបាំ ១៦ នាក់ឈរវាំបាន **ហត្ដត្ដរំ** គ្រឿងកម្រាលសម្រាប់ក្រាលលើខ្នងដំរី **អស្សត្ដរំ** គ្រឿងកម្រាលសម្រាប់ក្រាលលើខ្នងសេះ **រថត្ដរំ** គ្រឿងកម្រាលសម្រាប់ក្រាលរថ **អជិនប្បវេណិ** គ្រឿងកម្រាលធ្វើដោយស្បែកខ្ចី ឈ្មោះថាអជិន: ធំប្រមាណប៉ុនគ្រែ ដ្ឋិតថាស្បែកសត្ដជំពូកនោះ សាច់ទន់សុខុមល្អណាស់ ទើបដេរតម្ងួតគ្នាបាន **កទលិមិគបវរបច្ចត្ដរណំ** គ្រឿងកម្រាលយ៉ាងល្អ គេធ្វើពីស្បែកឈ្មុស បានឮថាមនុស្សទាំងឡាយ គេក្រាលស្បែកឈ្មុសចុះលើសំពត់សធ្វើជាគ្រឿងកម្រាលខាងលើ **សឧត្ដរច្ឆទំ** គ្រឿងកម្រាលមានពិតានក្រហមពាសខាងលើផង សូម្បីពិតានស តែខាងក្រោម

មានគ្រឿងកម្រាលជាអកប្បិយក៏មិនគួរ កាលបើមិនមានទើបគួរ **ឧកតោលោហិតកុបធានំ** *ទីដេកមានខ្នើយក្រហមនៅខាងទាំងពីរនៃគ្រែដេក គឺខ្នើយក្បាលនិងខ្នើយជើង ទីដំណេកនោះមិនគួរ។ ថាបើខ្នើយណា តែមួយប៉ុណ្ណោះ ក្នុងខាងទាំងពីរ សូម្បីក្រហម ឬពណ៌ដូចផ្កាឈូក ឬវិចិត្រក្តី បើប្រកបដោយប្រមាណហើយក៏គួរ ឃាត់តែខ្នើយធំមួយមុខ ។ ក្នុងដីកានៃខុទ្ទកសិក្ខាកំណត់ទុកថា អាសន្ទិនិងបល្ល័ঙ្ককឈ្មោះ ថាឧচ্চាសនៈ ក្រៅពីនោះឈ្មោះមហាសយនៈ ។ អាសនៈខ្ពស់ អាសនៈធំ ដូចពោលមកនេះមិនគួរ ដ្ឋានទៅមួយសង្ហាត់ហៅថាគ្រែឬតាំង ។ គ្រែនិងតាំងទាំងពួង ចាក់ទាក់ដោយផ្ដៅនិងបន្ទោះ ឬចងដោយសំពត់ធ្វើដោយក្ការមានជើងកោង ជើងត្រង់ ជើងច្រើនក្តី តែជើងកម្ពស់ ៨ ធ្នាប់ដោយធ្នាប់ព្រះសុគត លើកតែជើងរងខាងក្រោមចេញ គួរទាំងអស់ ។ ទ្រនាប់ជើងគ្រែកម្ពស់ត្រឹម ៨ ធ្នាប់ជាងឈើ ទើបគួរ ខ្ពស់លើសជាងនោះមិនគួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់និងអនុញ្ញាតទុកថា* **ន ភិក្ខវេ ឧচ্চា មញ្ចបដិចាឧកា ធារេតព្ពា... ។ អនុជានামិ ភិក្ខវេ អដ្ឋង្គុលបរមំ មញ្ចបដិចាឧកំ** *ភិក្ខុកុំគប្បីប្រើប្រាស់ទ្រនាប់ជើងគ្រែខ្ពស់ បើប្រើប្រាស់ ត្រូវទុក្កដ ។ តថាគតអនុញ្ញាតទ្រនាប់ជើងគ្រែត្រឹម ៨ ធ្នាប់ជាងឈើជាយ៉ាងក្រៃពេក ។ អាសន្ទិ គឺតាំងបួនជ្រុងសូម្បីជើងខ្ពស់ជាង ៨ ធ្នាប់ព្រះសុគតក៏គួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា* **អនុជានামি ភិក្ខវេ ឧচ্চកម្បិ អាសន្ទិកំ** *តថាគត*

អនុញ្ញាតតាំងបួនជ្រុង សូម្បីមានដើងខ្ពស់ ។ គ្រែបួនជ្រុងធ្វើបង្ហែកបីជ្រុង សូម្បីខ្ពស់ក្រៃលែងប្រមាណក៏គួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ ឧច្ចកម្បិ សត្តង្គំ** តថាគតអនុញ្ញាតគ្រែមានអង្គ ៧ សូម្បីខ្ពស់ ។ ចំពោះ ៤ ជ្រុងទើបគួរ លើសប្រមាណមិនគួរ ។ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតគ ៣ យ៉ាង **រុក្ខតូលំ** គនៃដើមឈើបាននឹងដើមគ ដើមរកាជាដើម ១ **លតាតូលំ** គនៃវល្លិមានប្រទ្បាអំពៃនិងផ្ទៃចុងអង្ករជាដើម ១ **ចោឌកីតូលំ** គរនៃតិណជាតិណាមួយមានផ្ការអំពៅព្រៃជាដើម ដោយហោចទៅសូម្បីផ្ការអំពៅ ផ្ការ បបុសជាដើមក៏ឈ្មោះថាផ្ការស្មៅ ១ ដ្បិតគ ៣ ប្រការនេះ សង្គ្រោះយកក្នុងភូតគាមទាំងអស់ ដ្បិតថាហួសជាតិនៃដើមឈើនិងវល្លិនិងស្មៅ ដទៃអំពីភូតគាមមិនមាន ព្រោះហេតុនោះ គនៃភូតគាមណាមួយ រមែងគួរក្នុងខ្នើយតែមួយជំពូក គទាំងពួងនេះ សូម្បីច្រកពួក ឈ្មោះថាអកប្ប្ដិយតូលទាំងអស់ មិនមែនតែគនោះគួរក្នុងខ្នើយមួយមុខទេ សូម្បីរោមនៃសត្វទាំងពួង មានហង្សនិងក្ងោកជាដើមនិងរោមនៃសត្វចតុប្ប្ដាទ មានរាជសីហ៍ជាដើមនេះក៏គួរ ។ ក៏ឯផ្ការឈើណាមួយ មានផ្ការប្រយង់និងផ្ការ ពុ្ពលជាដើមធ្វើជាគមិនគួរ ឬស្ងឹកឈើ **តមាលបត្តំ** ស្ងឹកពុំសៃនសុទ្ធ មិនគួរ បើលាយដោយស្ងឹកដទៃទើបគួរ ។ សូម្បីគ ៥ ជំពូកមានគគឺ រោមកែះជាដើម ដែលព្រះពុទ្ធអង្គទ្រង់អនុញ្ញាតក្នុងពួក ក៏គួរក្នុងខ្នើយផង ព្រះពុទ្ធអង្គអនុញ្ញាតពួក ៥ យ៉ាងគឺ **ឧណ្ណាភិសិ** ពួកញ្ជាត់ដោយ

ពោមកែះ ១ **ចោឌ្ឍកិសិ** ពួកញាត់ដោយកំណាត់សំពត់ ១ **ឯកកិសិ** ពួកញាត់ដោយសំបកឈើ ១ **តិណកិសិ** ពួកញាត់ដោយស្មៅ ១ **បណ្ណកិសិ** ពួកញាត់ដោយស្លឹកឈើ ១ ។ ឈ្មោះពួកទាំង ៥ នេះ រាប់តាមរបស់ដែលជាគជាក់ខាងក្នុង ។ ដែលពោលថាពោមកែះនោះ មិនមែនតែពោមកែះមួយមុខទេ សូម្បីពោមនៃសត្វស្វាបនិង សត្វជើងបួន ដែលជាជាតិនៃសត្វមានសាច់ជាកប្ដិយ ឬអកប្ដិយណាមួយមិនឃាត់ លើកតែពោមមនុស្សចេញ ពោមក្រៅពីនោះសង្គ្រោះចូលជាពោមកែះក្នុងបទនេះទាំងអស់ ។ ព្រោះហេតុនោះ នឹងធ្វើចីវរដោយកំណើតសំពត់ ៦ យ៉ាង គឺសំពត់ដែលអនុលោម ៦ ប្រការ ណាមួយធ្វើជាសំបកពួកហើយ ញាត់ដោយពោមសត្វទាំងពួងចូលខាងក្នុង ហើយធ្វើជាពួកក៏គួរ សូម្បីពួកដែលបត់សំពត់កម្ពស់ចូលជា ៤ ជាន់ ឬ ៥ ជាន់ មិនបានញាត់ដោយពោមសត្វ ហើយធ្វើជាពួកក៏រាប់ថាពួកពោមកែះផង ។ ឯពួកញាត់ដោយស្លឹកឈើនោះ លើកតែស្លឹកពុំសែនចេញ ស្លឹកឈើក្រៅពីនោះគួរទាំងអស់ តែស្លឹកពុំសែនលាយដោយស្លឹកឈើដទៃ គួរ ស្លឹកពុំសែនសុទ្ធមិនគួរ ។ ក្នុងអដ្ឋកថាកុរុន្ទីពោលថា គ ៥ យ៉ាងមានពោមកែះជាដើម ដែលគួរក្នុងពួកគនោះ សូម្បីក្នុងមស្សុរកៈក៏គួរដូចគ្នា ដ្ឋិតពាក្យនោះជាការសម្រេចសេចក្ដីថានឹងបរិភោគប្រើប្រាស់មស្សុរកៈក៏គួរ ។ ក្នុងសារត្ថទីបនីខៃបទមស្សុរកៈថាចម្មមយកិសិ ប្រែថាពួកស្បែក កំណត់ប្រមាណនៃពួកមិនមាន ពួកគ្រែ ពួកតាំង ពួកកម្រាល

ពួកក្រាលផ្ទៃ ពួកទីចង្ក្រម ពួកជូតជើង ទាំងអម្បាលនេះ គប្បីកំណត់តាមសមគួរ ហើយធ្វើប្រមាណតាមគាប់ចិត្តចុះ ។

មួយទៀត ភិក្ខុកុំគប្បីទ្រង់ខ្នើយធំប្រមាណពាក់កណ្តាលកាយ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់និងកំណត់អនុញ្ញាតទុកថា **ន ភិក្ខវេ អឌ្ឍកាយិកានិ ពិម្ពោហនានិ ធារេតព្វានិ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានামិ ភិក្ខវេ សីសប្ឋមាណំ ពិម្ពោហនំ ការេតុំ** ភិក្ខុកុំគប្បីទ្រង់ខ្នើយប្រមាណពាក់កណ្តាលកាយ គឺកើយតាំងអំពីចង្កេះដរាបដល់ក្បាល បើទ្រង់ត្រូវទុក្កដ ។ តថាគតអនុញ្ញាតខ្នើយប្រមាណល្មមប៉ុនក្បាល គឺទទឹងល្មមដាក់ក្បាលទាំងអស់ជាមួយនឹងកផងបាន ។ លក្ខណៈធ្វើខ្នើយ យកសំពត់ត្បូងខ្នើយបួនជ្រុង បត់កាច់ជ្រុងឲ្យជា ៣ ជ្រុង រាស់ចន្ទោះជ្រុងដានទាំងពីរ ទទឹង ១ ចំអាម ៤ ធ្នាប់ ទីពាក់កណ្តាល ១ គក់ប្រវែងតួខ្នើយ ១ គក់កន្ទុះ ឬពីរគក់ក៏បាន ខ្នើយទទឹងបណ្តោយប្រមាណប៉ុណ្ណោះ ឈ្មោះថាខ្នើយប្រមាណប៉ុនក្បាល ពាក្យនេះពោលទុកក្នុងកុរុន្ទី បើខ្នើយផ្ទែកឬខ្នើយប៉ាក់ថៅ ដូចក្នុងប្រទេសខ្មែរ សៀមនេះ គប្បីធ្វើចំណែកទទឹងអំពីកឡើងទៅដល់ក្បាល ឲ្យបាន ១ ចំអាម ៤ ធ្នាប់ ពាក្យនេះជាពាក្យអត្តនោមតិ អាស្រ័យន័យក្នុងវិមតិវិនោទនី ថាខ្នើយមូលនឹងដេរឲ្យមូល ឬឲ្យជា ៤ ជ្រុងក្តី គប្បីដេរដោយទទឹងកាច់ជ្រុងត្បូងខ្នើយ ឲ្យបានប្រមាណ ១ គក់ដូច្នេះ កំណត់យ៉ាងឧក្រិដ្ឋនៃខ្នើយមាន

ក្បាលជាប្រមាណ ខាងលើអំពីប្រមាណនោះឡើងទៅមិនគួរ ទាបចុះ
មកទើបគួរ ។ ភិក្ខុមិនមានជំងឺនឹងប្រើខ្នើយក្បាល ខ្នើយជើងទាំងពីរនេះ
ក៏គួរ ព្រះបុស្សទេវត្ថេរ លោកពោលថា ខ្នើយធ្វើដោយគ ជាកប្បិយ ៥
ដែលព្រះពុទ្ធទ្រង់អនុញ្ញាតក្នុងពួកសូម្បីធំក៏គួរ ព្រះឧបតិស្សត្ថេរ លោក
ទ្រង់វិន័យ លោកពោលទុកថា កាលបើគិតនឹងធ្វើខ្នើយ ហើយញាត់គ
ជាកប្បិយក្តីអកប្បិយក្តី ប្រកបដោយប្រមាណទើបគួរ ។ ឯគ្រឿងកម្រាល
ជាអកប្បិយមានព្រំធំ មានពោមវែង ដូចសម្តែងហើយក្នុងបទមុនជាដើម
នឹងក្រាលប្រើប្រាស់លើគ្រែ ឬតាំងក្នុងវិហាររបស់សង្ឆ ឬរបស់បុគ្គល
មិនគួរ ។ បើក្រាលប្រើប្រាស់លើធម្មាសនៈដោយនិយមនៃគិហិវិកដរបស់
គ្រហស្ថរមែងបាន តែនឹងដេកក្នុងទីនោះមិនគួរ ។ ក្នុងគ្រឿងកម្រាល
ជាអកប្បិយដូច្នោះ ជាគិហិវិកដ របស់គ្រហស្ថ នៅលើធម្មាសនៈ ឬក្នុង
រោងធាន់ ឬក្នុងលង្វែកភូមិនឹងអង្គុយលើក៏គួរ ដេកលើមិនគួរ ។ ដ្ឋិត
ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ ឋបេត្វា
តីណិ អាសន្ទឿ បល្លঙ្ក្ខំ តូលិកំ អវសេសំ គិហិវិកដំ
អភិនិសីទិតុំ ន ត្វេវ អភិនិបជ្ជិតុំ** តថាគតអនុញ្ញាតឲ្យអង្គុយលើ
គ្រឿងកម្រាលដ៏សេសជាគិហិវិកដ គឺអាសនៈដែលប្ងែកសម្រាប់គ្រហស្ថ
បាន តែដេកមិនបាន រៀរលែងតែរបស់ ៣ ប្រការ គឺគ្រែតាំងខ្ពស់ក្រៃ
លែងប្រមាណ និងបល្ល្ងកដែលប្រដាប់ដោយរូបសត្វសាហាវនៅជើង
និងពួកញាត់ដោយគ ៣ ប្រការ ទាំងអម្បាលនេះ ។ ចាបើនឹងអង្គុយ

លើគ្រែតាំងដែលញាត់ដោយសំឡីគខាងក្នុង ក្នុងរោងធាន់ ក្នុងលង្វែក ភូមិមួយយ៉ាងគួរ នឹងដេកលើគ្រែតាំងនោះមិនគួរ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា **អនុជានামិ ភិក្ខវេ តិហិរិកដំ អកិនិសីទិតុំ ន ត្វេវ អកិនិបជ្ជិតុំ** ដូច្នេះ ។ ឯគ្រែនិងតាំងដែលញាត់ភ្ជាប់ (ដោយគ្រឿងញាត់) ជាដើមក៏គួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានামិ ភិក្ខវេ ឱនទ្ធមញ្ចំ ឱនទ្ធបីឋំ** ដូច្នេះ ។ **ចាវោ** សំពត់បាវារ: **តោសេយ្យំ** សំពត់សូត្រ **តោជវោ** សំពត់កោជវ: **ឧម្ពលំ** សំពត់ឧម្ពល ទាំងអម្បាលនេះ ជារបស់សង្ឆក្តី ជារបស់បុគ្គលក្តី បរិភោគប្រើប្រាស់ក្នុងវិហារ ឬក្នុងលង្វែកភូមិ ឬតំបន់ឯណានីមួយ តាមសប្បាយក៏គួរ ដ្បិតជារបស់ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកហើយ ។ ក៏ឯសំពត់កោជវ:នោះ ជាសំពត់កោជវ:ដោយប្រក្រតីមួយយ៉ាងទើបគួរ ។ សំពត់កោជវ: មានខ្នងធំ រោមវែង មិនគួរ ។ សន្ទឹកទ្វារគ្រែតាំងផ្ទិតស្ទឹកត្នោត ទាំងអម្បាលនេះ វិចិត្រដោយវត្ថុមាសប្រាក់ជាដើម ឬធ្នាំងទឹក ផ្ដិលទឹក ដ៏ហើយដោយមាស ប្រាក់ និងវត្ថុណាមួយជារបស់ប្រកបដោយចិត្តកម្ម គួរជាក្ងី រលិក្ដី ទាំងពួងនេះ ជាសេនាសនបរិភោគ គឺជាគ្រឿងប្រើប្រាស់សម្រាប់សេនាសន: រមែងគួរទាំងអស់ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា **អនុជានামិ ភិក្ខវេ សព្វំ ចាសាឧបរិភោគំ** តថាគត អនុញ្ញាតគ្រឿងប្រើប្រាស់ក្នុងប្រាសាទទាំងពួង ។ ទាយកទាំងឡាយពោលថា ខ្ញុំប្រគេន នូវខ្ញុំប្រុស

ខ្ញុំស្រី ស្រែ ចម្ការ ដី គោ ក្របី ដើម្បីប្រាសាទដូច្នេះ កិច្ចដែលនឹងទទួលផ្សេងគ្នាមិនមាន កាលបើទទួលប្រាសាទហើយ ក៏ឈ្មោះថាទទួលដោយពិត ។

មួយទៀត ទ្រង់អនុញ្ញាតទុកថា **អនុជានামិ ភិក្ខវេ អាសន្ទិយា ចាឧេ ឋិន្ទិត្វា បរិភុញ្ជិតុំ បល្លঙ্ক្ខ ឯ្ឍ ឋិន្ទិត្វា បរិភុញ្ជិតុំ តូលិកំ រិជ្ជេត្វា ពិម្ពោហនំ ការាតុំ អវសេសំ ភុម្ម ត្ថ រណ ការាតុំ** តថាគត អនុញ្ញាតឲ្យកាត់ជើងគ្រែ ជើងតាំងដែលខ្ពស់ហួសប្រមាណចេញ ហើយទើបបរិភោគ និងឲ្យទម្លាយរូបសត្វសាហាវ ដែលជាប់នៅជើងបល្ល ង្ក ចេញហើយទើបបរិភោគ ពួកគឲ្យរើរុះយកតែគចេញធ្វើជាខ្នើយ គ្រឿងកម្រាលជាអកប្ជាយក្រោ នោះមានសំពត់ កោជវ:ពោមវែង និងគ្រឿងកម្រាលធ្វើដោយពោមកែះ វិចិត្រ ដោយក្ងីវ ល្ងិ ដេរ ប៉ាក់ជាដើម ឲ្យធ្វើជាគ្រឿងកម្រាលផ្ទៃក្នុងសេនាសន: ។

មួយទៀត អាសន:ដែលគេក្រាលទុក មិនបានពិចារណាមុន កុំអង្គុយចុះ បើអង្គុយចុះ ត្រូវទុក្កដ ។ ដ្ឋិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកក្នុងវិនីតវត្ថុថា **ន ច ភិក្ខវេ អបច្ចវេក្ខិត្វា អាសនេ និសីទិតព្ពំ** ដូច្នេះ ។ អាសន: ដូចម្តេច ទើបត្រូវពិចារណា អាសន:ដូចម្តេច មិនត្រូវពិចារណា? អាសន:ណា ជាអាសន:ទទេ មិនមានកម្រាលក្តី និងអាសន:ណា កាលគេក្រាល ភិក្ខុមកដល់ ឈរ ហើយបានឃើញក្តី អាសន:អម្បាលនេះ មិនបានពិចារណានឹងអង្គុយ

ក៏គួរ ។ សូម្បីអាសនៈណា មនុស្សទាំងឡាយគេយកដៃទះចុះដោយខ្លួនឯងហើយស្រែកនិមន្តថា លោកចូរអង្គុយក្នុងទីនេះ សូម្បីក្នុងអាសនៈនោះក៏គួរ ។ បើភិក្ខុទាំងឡាយអង្គុយមុនហើយ គ្រាក្រោយខិតឡើងលើឬខាងក្រោម កិច្ចដែលនឹងពិចារណានោះគ្មាន ។ សូម្បីអាសនៈណា គេយកសំពត់ស្តើងក្រាលបិទទុក ឃើញផ្ទៃខាងក្រោមប្រាកដ កិច្ចដែលពិចារណាក្នុងអាសនៈនោះមិនមាន ។ ក៏ឯអាសនៈណា គេក្រាលដោយសំពត់បាវរ: និងសំពត់កោជវ:ជាដើមទុកមុនហើយ អាសនៈនោះត្រូវពិចារណា គឺយកដៃស្ទាបកំណត់មើលហើយ សឹមអង្គុយ ។ ក្នុងអដ្ឋកថាមហាបច្ចរីពោលទុកថា ក្នុងអាសនៈដែលគេក្រាលដោយសំពត់ក្រាលមានជ្រួញៗ មិនបានប្រាកដ អាសនៈនោះត្រូវពិចារណា ។

មួយទៀត ភិក្ខុកុំគប្បីដេកលើទីដំណេកទាំងឡាយ ដ៏ពោយពាយដោយផ្កាឈើ បើភិក្ខុណាដេកត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ បុប្ផាភិកិណ្ណេសុ សយនេសុ សយិតព្វំ**... ដូច្នេះ ។ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា បានរបស់ក្រអូបហើយឲ្យចឹមក្នុងសន្ទឹកទ្វារ បានផ្កាឈើឲ្យតម្កល់ទុកក្នុងកុដិ វិហារ ។

មួយទៀត ភិក្ខុកុំគប្បីឃាត់អាសនៈភិក្ខុចាស់ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតនិងហាមឃាត់ទុកថា **អនុជានាមិ ភិក្ខវេ យថាវុឌ្ឍំ អភិវាទនំ ។ ល ។ ឥមេ ខោ ភិក្ខវេ តយោ វិនិយា** តថាគត អនុញ្ញាតកិរិយាសំពះ និងកិរិយាក្រោកទទួល និងអញ្ជលិកម្ម

និងសាមីចិកម្ម និងអាសនៈដ៏ប្រសើរ និងទឹកដ៏ប្រសើរ គឺទឹកទក្ខិណោទក និងដុំបាយដ៏ប្រសើរ គឺដុំបាយដែលគួរដល់ព្រះមហាថេរទាំងអម្បាលនេះ តាមលំដាប់នៃកិក្ខុចាស់វស្សា កិក្ខុកុំគប្បីឃាត់អាសនៈរបស់សង្ឆ តាមលំដាប់កិក្ខុចាស់វស្សា បើកិក្ខុណាឃាត់ត្រូវអាបត្តិទុក្កដ ។ តទៅព្រះពុទ្ធអង្គទ្រង់សម្តែង អំពីបុគ្គលមិនគួរសំពះ និងបុគ្គលគួរសំពះ ទុកថា ម្នាលកិក្ខុទាំងឡាយ បុគ្គលដែលកិក្ខុមិនគួរសំពះមាន ១០ ជំពូកគឺ **បុរេ ឧបសម្ជ្ជេន បច្ឆា ឧបសម្ជ្ជោ អវន្ទិយោ** អ្នកឧបសម្បទាក្រោយ គឺអ្នកឧបសម្បទាមុនមិនគួរសំពះ ១ **អនុបសម្ជ្ជោ** សាមណេរនិងគ្រហស្ថ ១ **ជាជាសំវាសកោ រុឌ្ឍតរោ អធម្មវាទី** អ្នកមានសង្វាសផ្សេងគ្នាដោយលទ្ធិ សូម្បីចាស់ជាងតែជាអ្នកពោលនូវពាក្យមិនមែនជាធម៌ ១ **មាតុកាមោ** ស្រី ១ **បណ្ឌកោ** ខ្ទើយ ១ **ចារិវាសកោ** កិក្ខុត្រូវគរុកាបត្តិ កំពុងនៅបរិវាស ១ **មូលាយបដិកស្សជារហោ** កិក្ខុត្រូវគរុកាបត្តិ ហើយកំពុងតែប្រព្រឹត្តវត្ត ត្រឡប់ត្រូវគរុកាបត្តិទៀតក្នុងចន្ទោះនោះ គួរនឹងទទួលបដិកស្សនៈទាញត្រឡប់មកកាន់អាបត្តិដើមទៀត ១ **មានត្តារហោ** កិក្ខុនៅបរិវាសហើយគួរនឹងទទួលមានត្ត ១ **មានត្តចារិកោ** កិក្ខុដែលកំពុងប្រព្រឹត្តមានត្ត ១ **អព្ភានារហោ** កិក្ខុដែលប្រព្រឹត្តមានត្តគ្រប់ ៦ រាត្រីហើយគួរដល់អព្ភានកម្ម ១ ទាំង ១០ ជំពូកនេះឈ្មោះថាអវន្ទិយៈជាបុគ្គលដែលកិក្ខុមិនគួរសំពះ ។ បុគ្គលដែលកិក្ខុគួរសំពះមាន ៣ ជំពូកគឺ

**បច្ឆា ឧបសម្ប្ជេន បុរេ ឧបសម្ប្ជោ ១ ១ ១

មនុស្សមានវេរ ១ (អ្នកនេះបើសំពះ នឹងអាចប្រហារអ្នកសំពះដោយ ដើងបាន ព្រោះហេតុនោះ ទើបមិនគួរសំពះ) **អញ្ញាវិហិតោ** *កិក្ខុបញ្ជូនចិត្តទៅកាន់ទីដទៃ ១* **ឌណ្ដោ** *កិក្ខុអាក្រាតកាយមិនមានសំពត់ស្ងៀកដណ្ដប់ ១ ជា ៥ ។* **ទាឌណ្ដោ** *កិក្ខុកំពុងធាន់ខាទនីយៈមានទំជាដើម ១* **ភុញ្ជណ្ដោ** *កិក្ខុកំពុងធាន់ភោជនទាំងប្រាំណាមួយ ១* **ឧច្ចារំ ករោណ្ដោ** *កិក្ខុកំពុងបន្ទោបង់ឧច្ចារៈ ១* **បស្សាវំ ករោណ្ដោ** *កិក្ខុកំពុងបន្ទោបង់បស្សាវៈ ១ (ពីរនេះ មិនគួរសំពះ ព្រោះថានៅក្នុងទីមិនមែនជាឱកាស)* **ឧក្ខិត្ដកោ** *កិក្ខុដែលសង្ឆស្យលើកវត្ដដោយឧក្ខេបនីយកម្មទាំងបី ១ ក៏ឯកិក្ខុដែលសង្ឆស្យលើកវត្ដដោយកម្មដទៃមានតជ្ជនីយកម្មជាដើម ៤ ជំពូកនេះ គួរនឹងសំពះ ដ្ឋិតថានឹងធ្វើឧបោសថ បវារណា ជាមួយនឹងកិក្ខុទាំងឡាយនេះក៏បាន ជា ៥ ។ ក្នុងអវន្ទិយបុគ្គល ១៥ តាំងអំពីដើមមកនេះ បើសំពះបុគ្គលពីរជំពូក គឺកិក្ខុអាក្រាតកាយ និងកិក្ខុដែលសង្ឆស្យលើកវត្ដទើបត្រូវអាបត្ដិ ។ ក៏ឯការឃាត់មិនឲ្យសំពះកិក្ខុ ១៣ ជំពូកក្រៅនោះ ដ្ឋិតជាអសារុប្ប:មិនសមគួរ មិនល្អ នឹងឃាត់ព្រោះហេតុដូចសម្ដែងហើយក្នុងចន្ទោះវង់ក្រចក ។*

មួយទៀត សូម្បីសេនាសន:ដែលទាយកគេចាត់ចែងទុកសម្រាប់ព្រះសង្ឆ ក៏មិនគួរឃាត់ខាំង ។ ដ្ឋិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ឧទ្ទិស្សកតម្ឫ យថាវុឌ្ឍំ បដិពាហិតព្ពំ...** *ម្ចាលកិក្ខុទាំងឡាយ សូម្បីសេនាសន:ដែលគេធ្វើឧទ្ទិស្សដល់សង្ឆ កិក្ខុមិនត្រូវឃាត់ខាំងទៅតាមលំដាប់វស្សាចាស់ខ្ចីទេ កិក្ខុណាឃាត់ខាំង ត្រូវទុក្កដ ។*

មួយទៀត ភិក្ខុកុំគប្បីយកគ្រឿងសេនាសនៈដែលនឹងគប្បីប្រើប្រាស់ក្នុងទីឯទៀត ទៅបរិភោគក្នុងទីឯទៀតឡើយ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ អញ្ញត្រ បរិភោគো អញ្ញត្រ បរិ-ភុញ្ជិតព្ពោ...** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវយកគ្រឿងប្រើប្រាស់ក្នុងទីឯទៀត ទៅប្រើប្រាស់ក្នុងទីឯទៀតទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ឯនឹងសូមខ្ចីទៅប្រើប្រាស់ ឬយកទៅថែរក្សាទុកក្នុងទីដទៃដើម្បីនឹងមិនឲ្យវិនាសអន្តរាយក៏គួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា* **អនុជានামិ ភិក្ខវេ តាវកាលិកំ ហរិតុំ អនុជានামិ ភិក្ខវេ កុត្តត្ថាយ ហរិតុំ** *ដូច្នេះ ។ ព្រោះហេតុនោះ កាលយកទៅប្រើប្រាស់ជាសង្ឃិកបរិភោគក្នុងទីដទៃ សូម្បីបាត់ទៅ ឬគ្រាំគ្រាទៅឈ្មោះថាបាត់ នឹងគ្រាំគ្រាទៅដោយប្រពៃ បើមិនគ្រាំគ្រាខ្ជិលទេ កាលបើវិហារកុដិនោះ គេជួសជុលឡើងជាថ្មី ក៏គប្បីធ្វើរបស់នោះឲ្យជាប្រក្រតីឡើងវិញ ។ កាលបើយកប្រើប្រាស់ជារបស់បុគ្គល របស់នោះបាត់ទៅ ឬគ្រាំគ្រាទៅរមែងជាសំណង កាលវិហារកុដិនោះ គេត្រឡប់ជួសជុលឡើងជាថ្មីហើយ គប្បីសងវិញ បើយកគ្រឿងអាវាស មានបង្ក្ងន់ជាដើម មកអំពីសេនាសនៈចាស់មកប្រកបផ្សំចូលក្នុងអាវាសជារបស់សង្ឆដទៃហើយសោត ឈ្មោះថាប្រកបចូលដោយប្រពៃ បើយកមកប្រកបចូលក្នុងអាវាសជារបស់បុគ្គល គប្បីឲ្យតម្លៃ ឬគប្បីធ្វើឲ្យជាប្រក្រតី កាលកាន់យកគ្រែនិងតាំងជាដើម មកអំពីវិហារ*

ដែលគេចោលដោយថេយ្យចិត្ត ឲ្យវិនិច្ឆយធរគប្បីកាត់អាបត្តិតាមតម្លៃរបស់ក្នុងខណៈលើករបស់នោះ កាលបើកាន់យកដោយគិតថា នឹងឲ្យក្នុងសម័យដែលភិក្ខុមកនៅក្នុងអាវាសនោះទៀត ហើយយកមកបរិភោគប្រើប្រាស់ជារបស់សង្ឆ របស់នោះវិនាសបាត់ទៅ ឬគ្រាំគ្រាទៅ ក៏ឈ្មោះថាវិនាសនិងគ្រាំគ្រាទៅដោយប្រពៃ បើមិនវិនាសទេ ក៏គប្បីធ្វើឲ្យជាប្រក្រតីចុះ កាលយកមកបរិភោគជារបស់បុគ្គល បើបាត់ទៅត្រូវសងបើយកសន្ទឹកទ្វារឬសន្ទឹកបង្ហួចជាដើម អំពីវិហារដែលគេចោល មកប្រកបប្រើក្នុងអាវាសជារបស់សង្ឆ ឬជារបស់បុគ្គល ត្រូវបង្វែរឲ្យទៅវិញ នឹងយកបរិក្ខាររបស់សង្ឆមានសំពត់កម្ពលជាដើម ទៅផ្ទាស់ប្តូរសេនាសនៈមានគ្រែនិងតាំងជាដើមមកក៏គួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ ជាតិកម្មត្ថាយ បរិវត្តេតុំ** តថាគតអនុញ្ញាតឲ្យផ្ទាស់ប្តូរ ដើម្បីប្រយោជន៍ជាផ្ទាតិកម្ម គឺឲ្យចម្រើនបរិក្ខាររបស់សង្ឆឡើងបាន ។ ក៏ឯផ្ទាតិកម្មផ្ទាស់ប្តូរឲ្យចម្រើនរបស់សង្ឆនេះ បើតម្លៃស្មើគ្នា ឬលើសជាង ជាសេនាសនៈមានគ្រែនិងតាំងជាដើម មួយយ៉ាងទើបគួរ ។

មួយទៀត ភិក្ខុមិនត្រូវបណ្តេញភិក្ខុដែលកំពុងនៅធាន់មិនទាន់ហើយ ឲ្យក្រោកចេញទេ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ឱ្យកតភោជនេ អនត្តរិកោ ភិក្ខុ រុដ្ឋោ-តញ្ចោ ។ ល ។ ១ជានាមិ** ភិក្ខុមិនត្រូវបណ្តេញភិក្ខុកំពុងធាន់ ក្នុងលង្វែកភូមិ ឬក្នុងវិហារ ឬក្នុងព្រៃ ទីណាមួយដែលមិនទាន់លៃងឲ្យ

ក្រោកចេញទេ បើភិក្ខុណាបណ្តេញ ឲ្យក្រោកចេញត្រូវទុក្កដ ។ ក្នុងលង្វែកភូមិ ភិក្ខុអ្នកមកក្នុងខាងក្រោយ កាន់យកកិក្ខាហើយគប្បីទៅកាន់ទីសមគួរ បើមនុស្ស ឬភិក្ខុទាំងឡាយ ស្រែកនិមន្តឲ្យចូលទៅក្នុងរោងធាន់ គប្បីប្រាប់ថា កាលបើយើងចូលទៅ ភិក្ខុទាំងឡាយនឹងក្រោកឡើង លុះគេពោលថានិមន្តចូលមកចុះ អាសនៈមាននៅដូច្នេះ គប្បីចូលទៅចុះ ។ ថាបើគ្មានអ្នកណាពោលពាក្យតិចតួចសោះទេ គប្បីទៅក្នុងរោងធាន់ហើយឈរនៅក្នុងទីសមគួរ កុំឲ្យជិតពេក កាលគេធ្វើឱកាសហើយស្រែកនិមន្តឲ្យចូលទៅ គប្បីចូលទៅចុះ ។ បើភិក្ខុមិនបានធាន់ អង្គុយនៅលើអាសនៈដែលនឹងដល់ភិក្ខុនោះសោត នឹងឲ្យភិក្ខុអង្គុយនោះក្រោកចេញក៏គួរ ។ ក៏ឯភិក្ខុធាន់វត្ថុណាមួយមានបបរនិងបង្អែមជាដើម ហើយអង្គុយរង់ចាំទម្រាំភិក្ខុដទៃនិមន្តមក សូម្បីមានដៃទទេ នឹងឲ្យភិក្ខុនោះក្រោកទៅមិនគួរ ដ្បិតថាភិក្ខុនោះ ក៏ឈ្មោះថាធាន់មិនទាន់ហើយ បើកៃ្ងងកន្ទងអាបត្តិ ធ្វើឲ្យភិក្ខុអ្នកធាន់មិនទាន់រួចក្រោកចេញ ថាបើភិក្ខុដែលក្រោកឡើងនោះឃាត់បាយសោត ភិក្ខុនោះគប្បីបង្គាប់ភិក្ខុអ្នកបណ្តេញនោះ ឲ្យទៅយកទឹកមកឲ្យ ។ ការដែលភិក្ខុកំលោះបង្គាប់ភិក្ខុចាស់បាន មានតែមួយនេះឯង ។ បើបានទឹកមកក៏ជាការល្អ បើភិក្ខុនោះមិនយកមកឲ្យទេ ភិក្ខុអ្នកឃាត់បាយនោះ គប្បីលេបគ្រាប់បាយឲ្យអស់ដោយប្រពៃ ហើយគប្បីឲ្យអាសនៈដល់ភិក្ខុចាស់ចុះ ព្រោះព្រះអង្គមិនបានអនុញ្ញាតឲ្យភិក្ខុកំលោះឃាត់អាសនៈភិក្ខុចាស់ ដោយបរិយាយណាមួយឡើយ បើភិក្ខុកំលោះណាឃាត់ ត្រូវអាបត្តិទុក្កដ ។

មួយទៀត ទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ភណ្ឌាការិកោ វុដ្ឋាបេតព្ពោ...** *ភិក្ខុកុំគប្បីបណ្តេញភិក្ខុអ្នករក្សាឃ្លាំងឲ្យក្រោកចេញទៅ បើភិក្ខុណាបណ្តេញ ត្រូវអាបត្តិទុក្កដ ។*

មួយទៀត ភិក្ខុកុំគប្បីបណ្តេញភិក្ខុមានជំងឺឲ្យក្រោកចេញ បើភិក្ខុណាបណ្តេញ ត្រូវអាបត្តិទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ គិលានោ វុដ្ឋាបេតព្ពោ** *ដូច្នេះ ។ ភិក្ខុ ៤ ជំពូក មិនគួរនឹងបណ្តេញឲ្យក្រោកគឺ ភិក្ខុចាស់វស្សាជាង ភិក្ខុកំលោះមិនគួរបណ្តេញឲ្យក្រោក ព្រោះជាភិក្ខុចាស់វស្សាជាង ១ ភិក្ខុអ្នករក្សាឃ្លាំងមិនគួរបណ្តេញឲ្យក្រោកចេញទៅ ដ្បិតថាឃ្លាំងនោះ សង្ឆសន្ទតឲ្យលោកហើយ ១ ភិក្ខុជាពហុស្សូត មានឧបការៈច្រើនដោយឧទ្ទេសនិងបរិបុច្ឆាជាដើម ហើយជាអ្នកទទួលធុរៈសង្ឆ សង្ឆឲ្យទីលំនៅជាទីសប្បាយ មិនគួរនឹងបណ្តេញឲ្យក្រោកចេញទៅ ដ្បិតលោកមានឧបការៈ និងបានទីលំនៅអំពីសង្ឆហើយ ១ ភិក្ខុមានជំងឺ មិនគួរនឹងបណ្តេញឲ្យក្រោកចេញ ដ្បិតភិក្ខុនោះមានជំងឺ គប្បីកំណត់ទីដំណេកដែលគួរឲ្យដល់ភិក្ខុឈឺនោះ ១ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា* **អនុជានាមិ ភិក្ខវេ គិលានស្ស បដិរូបំ សេយ្យំ ទាតុំ** *ដូច្នេះ ។ ភិក្ខុណាមានរោគហឺត ឬឫសដូងបាត ឬមួលជាដើម នឹងត្រូវតម្កល់កន្ទោរ និងអំបែងក្បឿងរងលាមកជាដើម ទុកសម្រាប់ ឬកើតរោគឃ្ងង់ និងប្រទូសរ៉ាយសេនាសនៈ គប្បីឲ្យសេនាសនៈមួយចំណែក ។*

តាមសមគួរមានខាងក្រោមប្រាសាទ និងមណ្ឌប សាលា ជាដើម ដល់ភិក្ខុឈឺដូច្នេះ ភិក្ខុណាឈឺ កាលនៅមិនខូចសេនាសន: ភិក្ខុឈឺដូច្នេះ សូម្បីទីដំណេកដែលល្អក៏គប្បីឲ្យចុះ សូម្បីភិក្ខុណាធាន់ភេសជ្ជ: មានថ្នាំត្រាំនិងថ្នាំបញ្ចុះនិងថ្នាំនត្ថុជាដើម ភិក្ខុទាំងអម្បាលនេះ ឈ្មោះថាឈឺទាំងអស់ គប្បីកំណត់សេនាសន:ដែលសមគួរឲ្យដល់ភិក្ខុទាំងអម្បាលនោះ ។

មួយទៀត ភិក្ខុគប្បីឧបដ្ឋាកភិក្ខុឈឺ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ត្រាស់ទុកថា **ឧត្ថិ ភេ ភិក្ខវេ មាតា ។ ល ។ ឧ្ឋាតុ** ម្នាលភិក្ខុទាំងឡាយ មាតាបិតានៃអ្នកទាំងឡាយក៏មិនមាន អ្នកណាសោតនឹងគប្បីឧបដ្ឋាកអ្នកទាំងឡាយ ថាបើអ្នកទាំងឡាយមិនឧបដ្ឋាកនូវគ្នានិងគ្នាក្នុងកាលឥឡូវនេះអ្នកណានឹងឧបដ្ឋាកអ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកណាឧបដ្ឋាកតថាគត ដោយធ្វើតាមឱវាទពាក្យប្រដៅ អ្នកនោះគប្បីឧបដ្ឋាកភិក្ខុមានជំងឺចុះ ។ បើឧបជ្ឈាយ៍ ឬអាចារ្យ នៃភិក្ខុដែលឈឺនៅមានសោត ឧបជ្ឈាយ៍ និងអាចារ្យ គប្បីឧបដ្ឋាកទម្រាំអស់ជីវិត ឬចាំទ្រាំទ្រដរាបដល់ជា ។ ថាបើសទ្ធិវិហារិក អន្តេវាសិក អ្នករួមឧបជ្ឈាយ៍ជាមួយគ្នា អ្នករួមអាចារ្យជាមួយគ្នាមានសោត ភិក្ខុទាំងអម្បាលនោះ គប្បីឧបដ្ឋាកដរាបដល់អស់ជីវិត ឬរង់ចាំទ្រាំទ្រដរាបដល់ជាពេគ ។ បើឧបជ្ឈាយ៍ អាចារ្យ សទ្ធិវិហារិក អន្តេវាសិក ឬភិក្ខុមានឧបជ្ឈាយ៍ជាមួយគ្នា មានអាចារ្យជាមួយគ្នា នៃភិក្ខុដែលឈឺមិនមានសោត សូម្បីភិក្ខុជាអាគន្ត្ដុក:ដើរមកតែម្នាក់ឯងមានជំងឺ ភិក្ខុនោះសង្ឆគប្បីឧបដ្ឋាក

បើមិនឧបដ្ឋាកទេ ត្រូវទុក្ខដទាំងអស់គ្នា ។ កាលបើភិក្ខុទាំងអស់គ្នាដាក់រវនគ្នាបដិបត្តិ ភិក្ខុណាមិនបដិបត្តិក្នុងរវនខ្លួន ត្រូវអាបត្តិដល់ភិក្ខុនោះ ។ សូម្បីសង្ឆត្តេរក៏មិនរួចរវនបាន ។ ថាបើសង្ឆទាំងអស់ប្រគល់ការ: ដល់ភិក្ខុមួយអង្គ ឬភិក្ខុមួយអង្គប្រកបដោយវត្តបដិបត្តិទទួលថា ខ្ញុំនឹងបដិបត្តិតែម្នាក់ឯងសោត ព្រះសង្ឆក៏រួចអាបត្តិបាន ។ ភិក្ខុឈឺដែលអ្នកបម្រើលំបាក ប្រកបដោយអង្គ ៥ គឺ មិនធ្វើសេចក្តីសប្បាយ ១ មិនដឹងប្រមាណក្នុងការសប្បាយ ១ មិនខ្នះខ្នែងប្រើកេសជ្ជ: ១ មិនធ្វើឲ្យច្បាស់នូវជំងឺតាមពិត គឺរោគទ្វេឡើង ក៏មិនប្រាប់ថាទ្វេឡើង ឬថយចុះ ក៏មិនប្រាប់ថាថយចុះ ឬនៅនឹងក៏មិនប្រាប់ថានៅនឹង ដល់អ្នកឧបដ្ឋាកដែលប្រាថ្នានូវប្រយោជន៍ ១ ជាមនុស្សមិនអត់ធន់នូវទុក្ខវេទនា ដ៏រឹងក្លា ផ្សា ក្តៅ ដែលកើតឡើងក្នុងសរីរកាយ មិនធ្ងាញ់ពិសា មិនគាប់ចិត្តជាទីនាំឲ្យខូចជីវិត ភិក្ខុឈឺដែលប្រកបដោយអង្គ ៥ ងាយគេបម្រើ គឺ បុគ្គលចេះធ្វើខ្លួនឲ្យសប្បាយ ១ ដឹងប្រមាណក្នុងការសប្បាយ ១ ខ្នះខ្នែងប្រើកេសជ្ជ: ១ ធ្វើឲ្យច្បាស់នូវជំងឺតាមពិត...១ ជាមនុស្សអត់ធន់នូវទុក្ខវេទនា... ១ ភិក្ខុអ្នកឧបដ្ឋាកភិក្ខុឈឺ ប្រកបដោយអង្គ ៥ មិនគួរនឹងឧបដ្ឋាកអ្នកជំងឺទេ គឺជាអ្នកមិនប្រសប់ចាត់ចែងថ្នាំ ១ មិនស្គាល់ហេតុសប្បាយ និងមិនសប្បាយ ១ នាំវត្ថុដែលមិនសប្បាយចូលទៅ នាំវត្ថុដែលសប្បាយចេញមក ១ ឧបដ្ឋាកមនុស្សឈឺ ដោយឃើញតែអាមិស មិនមានចិត្តប្រកបដោយមេត្តា មានតែខ្ជើមរអើម ក្នុងការនាំទៅនូវឧច្ចារ:

បស្សាវ: ឬទឹកមាត់ និងកម្ជូត មិនអាចនឹងពន្យល់អ្នកជំងឺ ឲ្យឃើញ ច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា សព្វៗ កាល ១ ភិក្ខុប្រកបដោយអង្គ ៥ រួចចាកអង្គដែលជាទោស ៥ ដូចពោល ហើយ ទើបសមគួរនឹងឧបដ្ឋាកភិក្ខុឈឺបាន ។

មួយទៀត ភិក្ខុ-សាមណេរធ្វើមរណកាលហើយ បរិក្ខារក៏ទៅជារបស់ សង្ឆ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា **ភិក្ខុស្ស ភិក្ខវេ កាលកតេ សង្ឆោ សាមី បត្តចីវរេ ។ ល ។ អវេភង្គិកំ** *ម្នាលភិក្ខុ ទាំងឡាយ បើមានភិក្ខុធ្វើមរណកាលហើយ (សាមណេរធ្វើមរណកាល ហើយ) ត្រូវសង្ឆជាម្ចាស់របស់ ក្នុងបាត្រនិងចីវរ ប៉ុន្តែថា អ្នកឧបដ្ឋាក បុគ្គលឈឺ មានឧបការ:ច្រើនជាងគេ ។ តថាគតអនុញ្ញាតឲ្យសង្ឆឲ្យ បាត្រ និងត្រៃចីវរនៃភិក្ខុដែលធ្វើមរណកាលហើយ (និងបាត្រនិងចីវរនៃ សាមណេរដែលធ្វើមរណកាលហើយ) ដល់អ្នកឧបដ្ឋាកជំងឺចុះ ក្នុងរបស់ អម្បាលនេះ បើរបស់ណាមួយជាលហុកណ្ហ ជាលហុបរិក្ខារ របស់ អម្បាលនោះ តថាគតអនុញ្ញាតឲ្យសង្ឆដែលមានក្នុងទីចំពោះមុខ ព្រម ព្រៀងគ្នាចែកគ្នាប្រើប្រាស់ក្នុងរបស់អម្បាលនោះ របស់ណាជាគរុកណ្ហ ជាគរុបរិក្ខារ របស់ទាំងនោះត្រូវជារបស់ចាតុទ្ទិសសង្ឆ ដែលមកហើយ និងមិនទាន់បានមក ជារបស់លះមិនបាន ចែកគ្នាមិនបាន ។*

ក៏ឯវិធីឲ្យបាត្រ ចីវរដល់ភិក្ខុអ្នកឧបដ្ឋាកជំងឺនោះដូច្នេះ គឺអ្នកឧបដ្ឋាក នោះ គប្បីចូលទៅរកសង្ឆ ហើយពោលថា **ឥត្ថន្នាមោ ភន្តេ ភិក្ខុ**

កាលកតោ ឥទំ តស្ស តិចីវរញ្ច បត្តោ ច... ។ *បើជារបស់សាមណេរថា* **ឥត្ថន្នាមោ ភន្តេ សាមណេរោ កាលកតោ ឥទំ តស្ស ចីវរញ្ច បត្តោ ច... ។** *បាលីទាំងពីរនេះ ប្រែថា បពិត្រព្រះសង្ឆដ៏ចម្រើន ភិក្ខុឈ្មោះនេះធ្វើមរណកាលហើយ ត្រៃចីវរនិងបាត្រនេះរបស់ភិក្ខុនោះ (សាមណេរឈ្មោះនេះធ្វើមរណកាលហើយ ចីវរនិងបាត្រនេះ របស់សាមណេរនោះ) គប្បីធ្វើដូច្នេះជាមុនហើយ សង្ឆគប្បីសូត្រប្រកាសដោយញត្តិទុតិយកម្មវាចា ប្រគល់របស់នោះឲ្យថា* **សុណាតុ មេ ភន្តេ សង្ឆោ ឥត្ថន្នាមោ ភិក្ខុ កាលកតោ ឥទំ តស្ស តិចីវរញ្ច បត្តោ ច ។ យទិ សង្ឆស្ស បត្តកល្លំ សង្ឆោ ឥមំ ចីវរញ្ច បត្តញ្ច កិលាឧបដ្ឋាកានំ ឧនេយ្យ... ។** *បើរបស់សាមណេរឲ្យថាតែ* **ចីវរំ ។**

មួយទៀត នឹងឲ្យដោយអបលោកនកម្មក៏គួរ សូម្បីសាមណេរ អ្នកឧបដ្ឋាកភិក្ខុឈឺ ក៏បានចំណែកស្មើនឹងភិក្ខុ ។ ដ្បិតទ្រង់អនុញ្ញាតទុកដូច្នេះថា **អនុជានាមិ ភិក្ខវេ កិលាឧបដ្ឋាកស្ស សាមណេរស្ស សមកំ បជិរីសំ ទាតុំ** *ដូច្នេះ ។ ពាក្យទាំងអម្បាលនេះ ពោលដោយសង្ខេបតាមបាលី បើចង់ដឹងដោយពិស្តារ គប្បីមើលក្នុងតតិយសមន្តបាសាទិកាចុះ ។*

មួយទៀត ភិក្ខុឈឺតិចតួច មានឈឺក្បាលជាដើម នឹងឃាត់សេនាសនៈមិនគួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ**

លេសកប្បេន សេនាសនំ បដិពាហិតព្ពំ... *ភិក្ខុកុំគប្បីហាមឃាត់សេនាសនៈ ដោយកលមាយាអាក្រក់ បើហាមឃាត់ ត្រូវទុក្កដ ។*

មួយទៀត ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានামិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតំ ភិក្ខុំ សេនាសនគ្គាហាបកំ សម្មន្ដិតុំ ។ ល ។ ជានយាមីតិ** *តថាគតអនុញ្ញាត ឲ្យសន្ទតភិក្ខុដែលប្រកបដោយអង្គ ៥ គឺ ភិក្ខុប្រាសចាកអគតិទាំងបួនជាអង្គ ៤ អាចដឹងច្បាស់នូវសេនាសនៈដែលខ្លួនបានប្រគល់ និងមិនទាន់បានប្រគល់ ១ ឲ្យភិក្ខុនោះ ជាសេនាសនគ្គាហាបកៈ អ្នកបង្គាប់ភិក្ខុដទៃឲ្យកាន់យកសេនាសនៈ និងសន្ទតដោយញត្តិទុតិយកម្មវាចា ឬអបលោកនកម្មក៏បាន ។ ភិក្ខុបានសន្ទតជាអ្នកប្រគល់សេនាសនៈហើយ ក្នុងថ្ងៃចូលវស្សា គប្បីប្រកាសភិក្ខុទាំងពួងឲ្យប្រជុំគ្នាហើយ គប្បីប្រគល់សេនាសនៈដូច្នេះ គឺ រាប់ភិក្ខុមុន ហើយរាប់សេនាសនៈ លុះរាប់ហើយ បើគ្រែ តាំង សេនាសនៈតិច ភិក្ខុច្រើន គប្បីប្រគល់តាមកំណត់ទីដំណេក បើកុដិវិហារមានច្រើនល្មមគ្រាន់ គប្បីប្រគល់តាមកំណត់កុដិ និងតាមកំណត់បរិវេណ បើកុដិវិហារសល់នៅច្រើនសោត គប្បីឲ្យចំណែកថែមទៀត ។ ដ្ឋិតទ្រង់អនុញ្ញាតទុកថា* **អនុជានামិ ភិក្ខវេ បឋមំ ភិក្ខូ ឧណ្ណេតុំ ភិក្ខូ ឧណ្ណេត្វា សេយ្យា ឧណ្ណេតុំ សេយ្យា ឧណ្ណេត្វា សេយ្យត្ថេន ការេតុំ អនុជានামិ ភិក្ខវេ អនុភាគម្ពិ ជានុំ ឧហិតេ អនុភាគេ អញ្ញោ ភិក្ខុ**

អាកច្ឆតិ ន អកាមា ទាតព្ពោ ដូច្នេះ ។ លុះចំណែកដែលថែម ភិក្ខុសន្ទតបានបង្គាប់ឲ្យកាន់យកហើយ បើភិក្ខុដទៃមកដល់មិនត្រូវការ មិនត្រូវឲ្យទេ ។ បើភិក្ខុអង្គណាកាន់យកហើយ ភិក្ខុអង្គនោះ នឹងឲ្យចំណែកថែមឬចំណែកដំបូង តាមគាប់ចិត្តនៃខ្លួនក៏គួរ ។

មួយទៀត ភិក្ខុកុំគប្បីឲ្យភិក្ខុអ្នកឋិតនៅក្រៅឧបចារសីមា កាន់យកសេនាសនៈផង បើឲ្យកាន់យកត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ឌិស្ឋីមេ ឋិតស្ស សេនាសនំ ការាបេតព្ពំ** ដូច្នេះ ។ ឲ្យបានតែភិក្ខុដែលឋិតនៅខាងក្នុងឧបចារសីមាមួយជំពូកកាន់យក សូម្បីធ្វើយក៏បាន ។

មួយទៀត ភិក្ខុបានចំណែកសេនាសនៈ ដែលចែកហើយនោះ កុំគប្បីឃាត់ខាំងទុកអស់កាលទាំងពួង បើឃាត់ខាំងទុកដូច្នេះ ត្រូវទុក្កដ ។ ឃាត់ខាំងបានតែត្រឹម ៣ ខែ ក្នុងវស្សានរដូវ (ប៉ុណ្ណោះ) មិនត្រូវឃាត់ខាំងគ្រប់រដូវទេ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់និងអនុញ្ញាតទុកថា **ន ភិក្ខវេ សេនាសនំ ឧហេត្វា សព្ពកាលំ បដិពាហិ-តព្ពំ ។ ល ។ អនុជានាមិ ភិក្ខវេ វស្សានំ តេមាសំ បដិពាហិតុំ ឧតុកាលំ ន បដិពាហិតុំ** ដូច្នេះ ។ ការប្រគល់សេនាសនៈនេះមាន ៣ ប្រការគឺ **បុរិមកោ** ត្រូវភិក្ខុប្រគល់ឲ្យតាំងអំពីថ្ងៃ ១ រោច ខែ អាសាឍទៅ ១ **បច្ឆិមកោ** ត្រូវភិក្ខុប្រគល់ឲ្យតាំងអំពីថ្ងៃ ១ រោចខែស្រាពណ៍ទៅ ១ **អន្តរាមុត្តកោ** ត្រូវភិក្ខុប្រគល់

ឲ្យតាំងអំពីថ្ងៃបវារណាក្នុងខែអស្សុជទៅ ដើម្បីនៅចាំវស្សាតទៅ ១ ដោយ
ព្រះបាលីថា **តយោមេ ភិក្ខវេ សេនាសនក្ខន្ធា បុរិមកោ ។ ល ។ ឥមេ ខោ ភិក្ខវេ តយោ សេនាសនក្ខន្ធា**
ដូច្នេះ ។ សេនាសនៈណាមានលាកច្រើន គឺទាយកម្ចាស់របស់
គេប្រគេនសំពត់ចំណាំវស្សា និងសមណបរិក្ខារច្រើនដល់ភិក្ខុដែលនៅ
ក្នុងសេនាសនៈ មហាថេរមកអំពីចម្ងាយចាំវស្សា ចេញវស្សាបាន
លាកហើយក៏ទៅ សេនាសនៈនោះក៏ទ្រុឌទ្រោម ម្ចាស់អាវាសមិនមើល
ថែទាំ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតឲ្យកាន់យកសេនាសនៈនោះ ជាអន្តរ-
មុត្តកៈ ដើម្បីនឹងនៅតទៅទៀតក្នុងវស្សាខាងមុខ ដើម្បីនឹងបានបដិបត្តិ
សេនាសនៈនោះ ដល់វស្សាខាងមុខហើយព្រះថេរៈមកអំពីទីដទៃ នឹង
មកកាន់យកមិនបាន តែភិក្ខុដែលបានសេនាសនៈក្នុងឧតុកាល នឹង
អាស្រ័យនៅក្នុងវេលាថ្ងៃ វេលាយប់បាន បើភិក្ខុដែលចាស់មក កុំឃាត់
កុំហួងហែង ។ មួយទៀត កាលកាន់សេនាសនៈមានពីរ ក្នុងឧតុកាល
ប្រាំបីខែ ១ ក្នុងវស្សកាលបីខែ ១ ។ ក្នុងឧតុកាល អាគន្តុកៈមកដល់កាល
ណា គប្បីឲ្យភិក្ខុដែលនៅមុនចៀសចេញ ឲ្យសេនាសនៈដល់អាគន្តុកៈ ។
ក្នុងវស្សកាល ភិក្ខុជាអាគន្តុកៈនឹងចេញចាកទីលំនៅខ្លួន ទៅនៅទីដទៃ
កុំទៅក្នុងថ្ងៃចូលវស្សា នឹងមានការចង្អៀតចង្អល់លំបាក នៅប្រមាណ
១ ខែទៀតនឹងចូលវស្សាគួរទៅ នឹងមិនលំបាកដោយទីលំនៅជាដើម ។
ចំណែកភិក្ខុម្ចាស់អាវាសសោត គប្បីជម្រះវិហារ ជូសជុលទីបាក់បែក

មុនថ្ងៃចូលវស្សា ភិក្ខុជាអាគន្ត្ដុក:មកអាស្រ័យនៅ នឹងបានសូត្ររៀនសិក្សាសប្បាយ ហើយភិក្ខុចៅអាវាស គប្បីប្រជុំគ្នាសន្ទ្ធតសេនាសនគ្គ-ហាបក:អ្នកប្រគល់សេនាសន:ឡើង ប្រមាណពីរអង្គ ឬបីអង្គ ភិក្ខុកំណោះ នឹងបានប្រគល់ឲ្យភិក្ខុចាស់ ភិក្ខុចាស់នឹងបានប្រគល់ឲ្យភិក្ខុកំណោះ ។ ឯភិក្ខុបានសម្ដ្ដតិនោះ គប្បីកំណត់ស្គាល់ទីសេនាសន: និងទីមិនមែនសេនាសន: ដល់ថ្ងៃចូលវស្សាគប្បីកំណត់លាកដែលកើតក្នុងសេនាសន:នោះ ហើយប្រគល់ឲ្យតាំងអំពីថេរ:ចុះទៅដោយកំណត់សេនាសន:តិចនិងច្រើន ដូចពោលហើយអំពីមុន បើមានទាយកគេប្រគេនសំពត់ចំណាំវស្សាដល់ភិក្ខុ ដែលនៅក្នុងសេនាសន:នោះ គប្បីប្រគល់ឲ្យដោយវិធីដូចនេះ ៖

បើលោកចាស់ប្រគល់ឲ្យលោកខ្ចី គប្បីសូត្រថា

អាវុសោ តុយ្ហំ អសុកំ[១] **សេនាសនំ ចាបុណាតិ បច្ចុយ្យ តណ្ហា** *ម្ចាលលោកដ៏មានអាយុ សេនាសន:ឯណោះ (ត្រូវបាន) ដល់លោក លោកចូរកាន់យកបច្ច័យ ។*

បើលោកខ្ចីប្រគល់ឲ្យលោកចាស់ គប្បីសូត្រថា

ភន្ដេ តុម្ហាកំ អសុកំ[២] **សេនាសនំ ចាបុណាតិ បច្ចុយ្យ តណ្ហាថ** *បពិត្រព្រះករុណាដ៏ចម្រើន សេនាសន:ឯណោះ (ត្រូវបាន) ដល់ព្រះករុណា ព្រះករុណាចូរកាន់យកបច្ច័យ ។*

១-២- បើសេនាសន:នៅជិតថា ឥទំ (សេនាសនំ ចាបុណាតិ) ជួស អសុកំ ។

បើពុំមានលាភផងទេ ត្រូវថា **តុម្ហាកំ អសុកសេនាសនំ ចាបុណាតិ** *ដូច្នេះ ។ ថេរៈគប្បីទទួលថា* **តណ្ហាមិ អាវុសោ** *។ ភិក្ខុកំណោះគប្បីទទួលថា* **តណ្ហាមិ ភន្តេ** *ថាខ្ញុំកាន់យកដូច្នេះ ។ ភិក្ខុទទួលយកសេនាសនៈហើយ គប្បីរារាំងបដិបត្តិសេនាសនៈនោះទម្រាំនឹងចេញអំពីទីនោះ ពាក្យនេះពោលដោយសង្ខេប បើចង់ដឹងដោយពិស្តារ គប្បីមើលក្នុងចតុត្ថសមន្តបាសាទិកាចុះ ។*

មួយទៀត ភិក្ខុមួយអង្គ កុំគប្បីហួងហែងសេនាសនៈពីរកន្លែងបើហួងហែង ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ឯកេន ទ្វេ បដិពាហិតព្វា**... *ដូច្នេះ ។ ភិក្ខុអង្គខ្លះក្នុងថ្ងៃចូលវស្សាកាន់យកសេនាសនៈក្នុងវិហារមួយកន្លែងហើយ ទៅកាន់យកសេនាសនៈក្នុងវិហារដទៃទៀត ការកាន់យកសេនាសនៈមុននៃភិក្ខុនោះ រមែងរម្ងាប់ដោយការកាន់យកសេនាសនៈថ្មី ឬមួយធ្វើអាល័យថានឹងនៅក្នុងវិហារនេះ ហើយទៅកាន់យកសេនាសនៈក្នុងវិហារដទៃទៀត អាល័យមុននៃភិក្ខុនោះ រមែងរម្ងាប់ដោយការកាន់យកសេនាសនៈថ្មីនេះ ។ មួយទៀត ការកាន់យកសេនាសនៈ ឬធ្វើអាល័យថានឹងនៅក្នុងវិហារនេះ ហើយទៅកាន់យកសេនាសនៈ ឬធ្វើអាល័យថានឹងនៅក្នុងវិហារដទៃដូច្នេះ ការកាន់យកសេនាសនៈនៃភិក្ខុនោះរមែងរម្ងាប់ដោយអាល័យ ឬអាល័យរមែងរម្ងាប់ដោយអាល័យ ភិក្ខុនោះរមែងបិតនៅតែក្នុងការកាន់យកសេនាសនៈ ឬអាល័យខាងក្រោយ តែមួយយ៉ាងគ្រប់កន្លែង ។ ភិក្ខុណា*

កាន់យកសេនាសនៈក្នុងវិហារមួយកន្លែង ហើយទៅដោយគិតថានឹងនៅ ក្នុងវិហារដទៃ លុះកន្ទងឧបចារសីមានៃវិហារនោះចេញទៅ អាការ ដែលកាន់យកសេនាសនៈក្នុងវិហារមុននៃភិក្ខុនោះក៏រម្ងាប់ ។ បើភិក្ខុទៅ ដោយគិតថា សប្បាយក្នុងវិហារឯណោះក៏នឹងនៅ បើមិនសប្បាយទេ ក៏នឹងត្រឡប់មកវិញ ដូច្នេះហើយទៅ ដឹងថាមិនសប្បាយហើយត្រឡប់ មកវិញដូច្នេះ ក៏គួរ ។

សេនាសនបដិសំយុត្តកថា ចប់

អនាមាសាទិកថា

ខមួយ ភិក្ខុចាប់ពាល់មាតាជាដើម ដោយប្រកាន់ថាជាមាតា ធីតា បងស្រី និងប្អូនស្រី ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុក ក្នុងវិនីតវត្ថុនៃកាយសំសគ្គសិក្ខាបទថា **អាបត្តិ ឧក្ក្ជ្ជ**ស្ស *ដូច្នេះ ។ ព្រោះមាតុគ្រាមរមែងជាសត្រូវដល់ព្រហ្មចរិយៈ ហេតុនោះ កាលរពឹក ដល់អាជ្ញាព្រះពុទ្ធអង្គ សូម្បីឃើញមាតាធ្លាក់ទឹក អណ្តែតទៅតាមខ្សែទឹក ក៏កុំគប្បីចាប់ពាល់ដោយដៃឡើយ ភិក្ខុអ្នកធ្វាត គប្បីយកទូក ឬក្តារ ឬកំណាត់ដើមចេក ឬកំណាត់ឈើបោះទៅ កាលរបស់នោះមិនមាន សូម្បីសំពត់កាសាវៈ ក៏គប្បីបោះទៅអំពីខាងមុខចុះ តែកុំប្រាប់ឲ្យចាប់ យក លុះមាតាចាប់សំពត់ដោយខ្លួនឯង ក៏គប្បីទាញមកដោយគិតថា យើងទាញបរិក្ខារបស់យើង បើមាតាខ្លាច ក៏គប្បីហែលទៅអំពីមុខ*

លួងលោមថាកុំខ្វាចឡើយ បើមាតាឡើងជិះក ឬតោងដៃសោត ក៏កុំគប្បីរលាស់ចេញឡើយ គប្បីបញ្ជូនឲ្យដល់គោក សូម្បីមាតាជាប់ភក់និងធ្លាក់ចុះក្នុងអណ្តូងក៏ដូចគ្នា គប្បីយកខ្សែ ឬសំពត់ចោះចុះទៅក្នុងទីនោះ ដឹងថាមាតាចាប់យកហើយ គប្បីទាញឡើងមក តែកុំចាប់ពាល់ ។ មិនមែនតែសរីរៈ នៃមាតុគ្រាមប៉ុណ្ណោះទេ ដែលជាអនាមាស សូម្បីសំពត់ស្បៃកសំពត់ដណ្តប់និងគ្រឿងប្រដាប់ ដោយហោចទៅ គ្រាន់តែក្រវិលស្មៅនិងចិញ្ចៀនស្ទឹកត្នោត ជារបស់ដែលស្ត្រីហួងហែង ដើម្បីជាគ្រឿងប្រដាប់ ក៏ជាអនាមាសទាំងអស់ ចាប់ពាល់មិនបាន ។ ថាបើសំពត់ស្បៃកសំពត់ដណ្តប់គេផ្ទាស់តម្កល់ទុកទៀបបាទមូល ដើម្បីថ្វាយជាចីវរ ចាប់ពាល់ក៏គួរ ។ ក្នុងគ្រឿងប្រដាប់ វត្ថុដែលជាកប្ចិយមានពិណក្ងុកជាដើម ថាបើគេថ្វាយ គប្បីទទួលមកជាគ្រឿងឧបការ មានកន្ទាស់ក្ងាស់ស៊ីងជាដើមចុះ តែវត្ថុដ៏ហើយដោយមាសនិងប្រាក់កែវមុក្តានិងត្បូងពេជ្រ ជាអនាមាសពិត សូម្បីគេឲ្យ ក៏កុំគប្បីទទួល ។

មួយទៀត បើចាប់ពាល់រូបភាពឈើ ដែលធ្វើជារូបស្ត្រី ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកក្នុងវិនីតវត្ថុថា **អាបត្តិ ឧក្ក**ដ**ស្ស** ដូច្នេះ ។ សូម្បីរូបក្ងុក រូបដែក រូបលោហៈ រូបសំណកក់ រូបស្ទឹករឹត រូបសូនដោយកំបោរ រូបកែវទាំងពួង ដោយហោចទៅ សូម្បីតែរូបសូនដោយម្សៅ ដៃគេធ្វើសណ្ឋានដូចស្ត្រី ក៏ជាអនាមាសទាំងអស់ ចាប់ពាល់មិនបាន គេថ្វាយដើម្បីបរិភោគ រូបដ៏សេស រៀងតែរូប

ដ៏ហើយដោយកែវទាំងពួង បើនឹងទម្លាយចេញ គួរជាឧបការ:បាន គប្បីនាំចូលទៅជាគ្រឿងឧបការ: ដែលគួរបរិភោគ បង្ហោនចូលទៅជាគ្រឿងបរិភោគក៏គួរ ។ មិនមែនតែរូបស្ត្រីមួយយ៉ាង សូម្បីស្រូវ ៧ ប្រការ ក៏ជាអនាមាសទាំងអស់ដូចគ្នា ។ ព្រោះហេតុនោះ កាលដើរទៅកណ្ដាលស្រែកុំគប្បីចាប់ពាល់ផ្ទៃស្រូវ សូម្បីកើតក្នុងស្រែនោះ ។ បើគេហាលស្រូវទុកប្រេបទ្វារស្រុក ឬកណ្ដាលផ្លូវ ផ្លូវដែលទៅដោយខាងៗ នោះមានកុំគប្បីជាន់ហើយដើរទៅ កាលបើផ្លូវមិនមាន គប្បីអធិដ្ឋានថាផ្លូវហើយដើរទៅចុះ ។ ក្នុងលង្ហែកភូមិ គេក្រាលអាសន:លើគំនរស្រូវឲ្យអង្គុយ នឹងអង្គុយក៏គួរ ។ មនុស្សជំពូកខ្លះ គេចាក់ស្រូវទុកក្នុងរោងធាន់ ថាបើអាចឲ្យគេជញ្ជូនចេញបាន ក៏គប្បីឲ្យគេជញ្ជូនចេញ ថាបើមិនអាចជញ្ជូនចេញ កុំគប្បីជាន់ញ៉ីញ៉ាក់ គប្បីឲ្យគេតម្កល់តាំងក្នុងទីម្ខាងហើយអង្គុយចុះ ។ ថាបើឱកាសមិនមាន គេក្រាលអាសន:ក្នុងកណ្ដាលគំនរស្រូវ គប្បីអង្គុយចុះ សូម្បីស្រូវនៅក្នុងទូកក៏ដូចគ្នា សូម្បីអបរណ្ណជាតិ មានសណ្ដែកបាយនិងសណ្ដែកវាជមាសជាដើម ឬផ្ទៃត្នោតផ្ទៃខ្ទុរជាដើម ដែលកើតនៅក្នុងដើមនោះ ក៏កុំគប្បីបបោសអង្ហែលលេង សូម្បីគេធ្វើជាគំនរទុកក៏ដូចគ្នា ។ ផ្ទៃឈើជ្រុះចុះក្នុងព្រៃនឹងកាន់យកដោយគិតថានឹងឲ្យអនុប-សម្បន្ន គួរ ។

កែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវពពាល ប្រាក់ មាស កែវទទឹម កែវផ្ទេក ទាំង ១០ នេះឈ្មោះថារតន: ។ កែវមុក្តា គេមិនទាន់

បានខាត់មិនទាន់បានចោះ នៅដូចដើមចាប់ពាល់បាន ក្រៅនោះជាអនា-
មាសចាប់ពាល់មិនបាន ។ ក្នុងមហាបច្ចរីពោលថា កែវមុត្តា សូម្បីគេខាត់
ហើយឬនៅមិនទាន់បានខាត់ក្តី ក៏ជាអនាមាស នឹងទទួលដើម្បីតម្លៃនៃ
ភណ្ឌមិនគួរ តែនឹងទទួលដើម្បីជាថ្នាំរក្សាកុដ្ឋរោគក៏គួរ ។ កែវមណីជាដើម
មានពណ៌ខៀវលឿងទាំងអស់ ដោយហោចទៅ ជាតិនៃកែវផ្ទុកគេខាត់
ចោះច្នៃហើយក៏ជាអនាមាស តែបើនៅជាកំណើតដើម លោកពោលថា
នឹងទទួលដើម្បីជាតម្លៃបាត្រជាដើមក៏គួរ ។ ក្នុងមហាបច្ចរី លោកឃាត់ថា
មិនគួរ លោកពោលថា កែវកញ្ចក់ដែលគេស្ងមួយយ៉ាងប៉ុណ្ណោះគួរ
ក្នុងកែវពិទូរ្យឲ្យវិនិច្ឆ័យដូចកែវមណីចុះ ។ ស័ង្ខសម្រាប់ផ្ទុំគេខាត់ចោះហើយ
វិចិត្រលាយដោយរតនៈជាអនាមាស ។ ស័ង្ខសម្រាប់ផឹកទឹក សូម្បីគេខាត់
ហើយឬមិនទាន់បានខាត់ក្តី ចាប់ពាល់បាន ស័ង្ខក្រៅនោះនឹងទទួលដើម្បី
ជាថ្នាំភ្នែកឬតម្លៃភណ្ឌក៏គួរ ។ សិលាមានពណ៌ដូចសណ្ដែកបាយ គេដុស
ខាត់ចោះហើយ គេប្រកបរតនៈចូលផងជាអនាមាស ។ សិលាក្រៅនោះនឹង
ទទួលដើម្បីជាថ្មសំលៀងកាំបិត ថ្មកិនជាដើមក៏គួរ ។ កែវពពាលគេខាត់
ចោះហើយជាអនាមាស ។ ក្រៅនោះជាអាមាស នឹងទទួលដើម្បីតម្លៃ
ភណ្ឌក៏គួរ ។ តែក្នុងមហាបច្ចរីពោលថា សូម្បីគេខាត់ហើយ ឬនៅមិន
ទាន់បានខាត់ក្តី ទាំងអស់នេះជាអនាមាស នឹងទទួលក៏មិនគួរ ។ ប្រាក់
មាស គេធ្វើជារូបភាពហើយ ឬនៅមិនទាន់បានធ្វើក្តី តាំងតែអំពីពូជ
ឡើងទៅ ជាអនាមាស មិនគួរទទួលដោយប្រការទាំងពួង ។ បានឮថា

ឧត្តរាជបុត្រសាងចេតិយមាស ហើយបញ្ជូនទៅដល់ព្រះមហាបទុមត្ថេរ ព្រះមហាបទុមត្ថេរ លោកឃាត់ថា មិនគួរ ។ ក្នុងផ្ទះចេតិយមានឈូកមាសនិងផ្ការមាសជាដើម សូម្បីរបស់ទាំងអម្បាលនោះក៏ជាអនាមាស ។ តែភិក្ខុជាអ្នករក្សាផ្ទះចេតិយ តាំងនៅក្នុងទីជាអ្នកចោលរូបិយ ព្រោះហេតុនោះ លោកពោលថា ភិក្ខុនោះនឹងចាបពាល់រំកិលរបស់នោះក៏គួរ ។ តែក្នុងកុរុន្ទីលោកឃាត់ថាមិនគួរ លោករមែងអនុញ្ញាតតែត្រឹមថា នឹងនាំសំរាមក្នុងចេតិយទៅចោលបានប៉ុណ្ណោះ ។ សូម្បីសំរឹទ្ធិវិសេសមានពណ៌ដូចមាស មានគតិនៃមាសក៏ជាអនាមាស ។ ពាក្យទាំងអម្បាលនេះ ពោលទុកក្នុងអដ្ឋកថាទាំងឡាយ ។ គ្រឿងបរិភោគក្នុងសេនាសនៈជាកប្បិយទាំងអស់ ព្រោះហេតុនោះ បរិក្ខារបស់សេនាសនៈទាំងអស់ សូម្បីវិចិត្រដោយប្រាក់ និងមាស ក៏ចាប់ពាល់បាន ។ គេធ្វើរតនមណ្ឌប ជាទីសម្តែងធម៌និងវិនិច្ឆយរបស់ភិក្ខុ មានសសរដ៏ហើយដោយកែវផ្ទេក ប្រដាប់ដោយកម្រងផ្ការតនៈ គ្រឿងឧបការក្នុងមណ្ឌបនោះ ភិក្ខុនឹងសម្អាតក៏គួរ ។ កែវទទឹម ១ កែវផ្ទេក ១ គេខាត់ចោះហើយជាអនាមាស ។ ក្រៅនោះជាអាមាស លោកពោលថានឹងទទួលដើម្បីជាតម្លៃនៃកណ្ណាក៏គួរ ។ តែក្នុងមហាបច្ចរី ពោលថា សូម្បីគេខាត់ហើយ ឬនៅមិនទាន់ខាត់ក្តី ជាអនាមាសទាំងអស់ នឹងទទួលក៏មិនគួរ ។

គ្រឿងអាវុធទាំងអស់ជាអនាមាស សូម្បីគេថ្វាយដើម្បីជាតម្លៃកណ្ណាក៏កុំគប្បីទទួល នឹងទៅជាឈ្មោះថា លក់គ្រឿងសស្ត្រាជាការមិនគួរ ។

ដងធ្នូសុទ្ធ ឬខ្សែបន្ទោះទេ និងកង្វេរ ជន្ធញ ដោយហោចទៅ សូម្បីតែកាំបិត និងពូថៅជាដើម ដែលគេធ្វើសង្ខេបថាជាអាវុធ ក៏ចាប់ ពាល់មិនបាន ។ ថាបើគេយកលំពែង ឬលំពែងពួយ មកតម្កល់ទុក ក្នុងវិហារ កាលនឹងសម្អាតនូវវិហារ គប្បីប្រាប់ម្ចាស់របស់ឲ្យគេយក ទៅវិញ ថាបើគេមិនយកទៅវិញ កុំគប្បីធ្វើឲ្យរបស់នោះកម្រើក សម្អាតតែវិហារនោះចុះ ។ ឃើញដាវ លំពែង ឬ លំពែងពួយ ធ្លាក់ចុះ ក្នុងទីចម្ការ យកដុំសិលាទម្លាយដាវចេញ ដកដងលំពែងចេញ ផ្ទៃដាវ កាន់យកទៅ ដើម្បីធ្វើជាកាំបិត ដងដើម្បីធ្វើជាឈើច្រត់ជាដើមក៏គួរ ។ បើគេប្រគេន នឹងធ្វើឲ្យវិនាសចេញហើយ ទទួលយកទៅធ្វើកឬ្យ-ភណ្ឌក៏គួរ ។ សូម្បីសំណាញ់ បង្ការ ជាគ្រឿងដាក់ត្រីដាក់សត្វជាដើម គ្រឿងការពារកូនសរមានខ្ទេលជាដើមក្តី ទាំងអស់មិនគួរចាប់ពាល់ជា អនាមាស បានមកដើម្បីបរិភោគ បង្ការ៖ នឹងយកមកចងជាអាសនៈ ឬ ចេតិយ ឬដងធ័ត្រក៏គួរ ។ គ្រឿងការពារកូនសរទាំងអស់ នឹងទទួលដើម្បី ជាតម្លៃនៃភណ្ឌក៏គួរ ដ្បិតថារបស់នោះ គ្រាន់តែជាគ្រឿងការពារ សេចក្តីបៀតបៀន មិនបានធ្វើសេចក្តីបៀតបៀនអ្នកដទៃ ។ ខ្ទេលនឹង ទទួលមកធ្វើជាភាជនៈរងឈើស្ងួនក៏គួរ ។

គ្រឿតន្ត្រីមានពិណនិងស្គរជាដើម ដែលគេដាសដោយស្បែកមិន គួរចាប់ពាល់ ជាអនាមាស ។ តែក្នុងកុរុន្ទីពោលថា សូម្បីវាងពិណ វាង ស្គរនិងស្នូកទេ និងស្បែកដែលគេដាសក្នុងកណ្តាប់មាត់ និងដងពិណក្តី

ទាំងអស់ចាប់ពាល់មិនបាន ជាអនាមាស ។ នឹងដាសឯងឬប្រើឲ្យគេដាសប្រគំឯង ឬប្រើគេឲ្យប្រគំ មិនបានឡើយ សូម្បីគ្រឿងតន្ត្រីដែលគេបូជាហើយ ចោលទុកក្នុងលានចេតិយ ក៏កុំគប្បីធ្វើឲ្យកម្រើក គប្បីបោសតែក្នុងចន្ទោះ។ តែក្នុងវេលានឹងចោលសំរាមនឹងនាំទៅដោយនិយមថាជាសំរាមហើយតាំងទុកខាងម្ខាងក៏គួរ ។ ពាក្យនេះពោលទុកក្នុងមហាបច្ចរីថា សូម្បីនឹងទទួលគ្រឿងតន្ត្រី ដើម្បីជាតម្លៃនៃកណ្ណក៏គួរ តែដែលបានមកដើម្បីបរិភោគ នឹងកាន់យកដើម្បីធ្វើបរិក្ខារនោះ។ គឺរាងពិណរាងស្គរធ្វើជាភាជន:រងឈើស្ងួន ស្បែកនឹងធ្វើជាស្រោមកាំបិតក៏គួរ ។

មួយទៀត កុំចាប់ពាល់ផ្ទៃឈើមានចេកនិងដូងជាដើម ដែលជាប់នៅនឹងដើម ឬមែក ថាបើចាប់ពាល់ ត្រូវទុរ្ភបចិណ្ណទុក្កដ ។

មួយទៀត ដើរទៅបិណ្ឌបាត ធ្លាលីធ្លាក់ចុះក្នុងបាត្រ គប្បីឲ្យគេប្រគេនបាត្រជាថ្មី ឬលាងចេញមុនសឹមទទួលភិក្ខា ថាបើមិនឲ្យគេប្រគេនឬលាងចេញមុនហើយទទួល ក៏ត្រូវវិន័យទុក្កដ ។

អនាមាសាទិកថា ចប់

តាំងអំពីភិក្ខុជាអាគន្ទុក:នឹងចូលវត្តដទៃទៅ រហូតដល់ចៀសចេញទៅកាន់ទិស នឹងទុកពោលក្នុងវត្តខន្ធក:ខាងមុខ ដែលព្រះពុទ្ធអង្គទ្រង់បញ្ញត្តនៃទុក្កដាបត្តិ ។ តាំងអំពីដើមមកលុះដល់វិន័យទុក្កដនេះ ជាសចិត្តក: ក្ងែងប្រព្រឹត្តកន្ទងដោយចិត្តដែលដឹង ទើបត្រូវអាបត្តិ ។

សចិត្តកវណ្ណនា ចប់

អចិត្តកបញ្ញត្តិកថា

ខមួយ ភិក្ខុកុំគប្បីទៅមើលរាំ-ច្រៀង-ប្រគំ បើទៅមើលត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ន្ចំ វ កីតំ វ ១ចិតំ វ ១ស្សរ១ាយ ១ន្ត១ាំ** ដូច្នេះ ។ រាំ ច្រៀង ណាមួយ ដោយហោចទៅ សូម្បីក្ងោក សេក ស្វា រាំ ពង់ ជាដើម ហើយទៅដើម្បីនឹងមើលត្រូវទុក្កដ ។ រាំ ច្រៀងឯង ឬឲ្យអ្នកដទៃរាំច្រៀង ត្រូវទុក្កដ ។ ចម្រៀងនៃអ្នករបាំ ឬក្ងេងចម្រៀង ប្រកបដោយគុណព្រះរតនត្រ័យ ក្នុងកាលព្រះអរិយនិព្វាន ឬចម្រៀងនៃភិក្ខុអ្នកសម្តែងធម៌មិនសង្រួម ដោយហោចទៅ សូម្បីច្រៀងដោយធ្មេញក៏ឈ្មោះថាគីត: គឺច្រៀងទាំងអស់ គិតថានឹងច្រៀង ហើយសង្កត់ចុះក្នុងចំណែកមុន គឺច្រៀងតាំងអំពីដើមក្ងេងឡើង សូម្បីដូច្នោះក៏មិនគួរ ។ ច្រៀងឯងឬឲ្យអ្នកដទៃច្រៀងត្រូវទុក្កដ ។ ប្រគំគ្រឿងតន្ត្រីណាមួយ មិនគួរ ។ ក៏ឯភិក្ខុដកដង្ហើម ឬតាំងនៅក្នុងទីរង្គៀស គិតនឹងដេញមនុស្ស ឬសត្ត ផ្ទាត់ម្រាមដៃ ឬទះដៃក្តី ក្នុងការនោះ មិនត្រូវអាបត្តិ ។ ច្រៀងរាំប្រគំទាំងអស់ ឈរនៅខាងក្នុងអាវាម ក្រឡេកឃើញ មិនត្រូវអាបត្តិ ។ គិតនឹងមើលដើរទៅ ត្រូវអាបត្តិ ។ អង្គុយនៅក្នុងពោងធាន់ ក្រឡេកមើលឃើញ មិនត្រូវអាបត្តិ ។ គិតនឹងមើលក្រោកឡើងដើរទៅ ត្រូវអាបត្តិ ។ ឈរនៅថ្នល់សូម្បីងាកកទៅមើលក៏ត្រូវអាបត្តិ ។

ខមួយទៀត ភិក្ខុមិនចង់វត្តពន្ធចង្កេះ កុំចូលទៅក្នុងស្រុក បើចូលទៅត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ អកាយពន្ធនេន គាមោ បវិសិតព្ពោ** ដូច្នេះ ។ មិនបានចង់វត្ត-ពន្ធចង្កេះចេញចាកវត្ត រឭកបានក្នុងទីណា គប្បីចង់ក្នុងទីនោះ គិតថានឹងទៅចង់ទៀបរោងធាន់ ជិតភូមិ ហើយទៅ ក៏គួរ ។ រឭកបានហើយមិនបានចង់ កុំគប្បីត្រាច់ទៅបិណ្ឌបាត ។

ខមួយទៀត ភិក្ខុមានបាត្រក្នុងដៃ កុំគប្បីប្រាន សន្ទឹកទ្វារ បើប្រានត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ បត្តហត្ថេន ឆារជ្ជំ បណ្ណាមេតព្ពំ** ដូច្នេះ ។ បាត្រនៅក្នុងដៃភិក្ខុណា ភិក្ខុនោះឈ្មោះថាមានបាត្រក្នុងដៃ មិនត្រឹមតែមានបាត្រក្នុងដៃប៉ុណ្ណោះ កុំគប្បីប្រាន សន្ទឹកទ្វារ មិនត្រឹមតែសន្ទឹកទ្វារប៉ុណ្ណោះទេ សូម្បីបាត្រនៅក្នុងដៃ ឬខ្នងជើង ឬសរីរាវយវៈណាមួយក្តី នឹងប្រានសន្ទឹកទ្វារ ឬដកចន្ទាស់ ឬគន្ទឹះ ចាក់សោដោយដៃ ដោយខ្នងជើង ដោយក្បាល ឬដោយសរីរាវយវៈណាមួយក៏មិនបានទាំងអស់ ។ តែបើយកបាត្រញ្ជូរចូលក្នុងចង្ហួយស្មា បើកទ្វារ ចាក់សោ ក៏បាន ។

ខមួយទៀត ភិក្ខុកុំគប្បីដេកលើគ្រែជាមួយគ្នា កុំគប្បីដេកលើគ្រឿងកម្រាលជាមួយគ្នា កុំគប្បីដេកលើទីមានសំពត់ដណ្តប់ជាមួយគ្នា កុំគប្បីដេកលើទីមានគ្រឿងកម្រាលនិងសំពត់ដណ្តប់ជាមួយគ្នា បើដេកដូច្នោះត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ឯកមញ្ចេ ន**

ឯកត្តរណោ ន ឯកចាមូរណោ ន ឯកត្តរណាចាមូរណោ តុវដ្ដិតព្ពំ ដូច្នេះ ។ ក្នុងគ្រែនិងគ្រឿងកម្រាល ឃាំងសំពត់ ឬឈើច្រត់ ដោយហោចទៅ សូម្បីវត្ថុពន្ធចង្កេះដាក់ឃាំងកណ្ដាល សម្ដែងទីកំណត់ ប្រាកដហើយ ទើបដេកទាំងពីរនាក់ មិនត្រូវអាបត្តិ ។ ឯភិក្ខុទាំងឡាយ យកជាយម្ខាងនៃសំពត់បាវារ: ឬគ្រឿងកម្រាល ឬកន្ទេលរំចេកជាដើម ដែលគួរមូរលើកវើទៅបាន ក្រាលចុះជាយម្ខាង យកជាយម្ខាងដណ្ដប់ ដេកក្ដី ឈ្មោះថាមានគ្រឿងកម្រាលនិងសំពត់ដណ្ដប់ជាមួយគ្នា ។

ខមួយទៀត ភិក្ខុកុំគប្បីធាន់ក្នុងភាជន:ជាមួយគ្នា កុំគប្បីផឹកទឹកក្នុងផ្ដិលជាមួយគ្នា បើធាន់និងផឹកដូច្នោះ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ឯកភាជនេ ភុញ្ជិតព្ពំ ន ឯកថាលកេ ចាតព្ពំ** ដូច្នេះ ។ បើភិក្ខុមួយអង្គកាន់យកផ្ទៃឈើ ឬនំអំពីភាជន:ទៅធាន់ ភិក្ខុមួយអង្គធាន់របស់ដែលសល់នៅក្នុងភាជន: នោះក៏គួរ សូម្បីភិក្ខុដទៃកាន់យកទៅធាន់អស់ហើយ នឹងកាន់យកទៀតក្នុងខណ:នោះក៏គួរ ។

ខមួយទៀត ភិក្ខុកុំគប្បីធាន់ខ្ទឹម បើធាន់ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ លសុណំ ខាទិតព្ពំ** ដូច្នេះ ។ បើលាយខ្ទឹមចុះ ក្នុងសូប:របស់ធាន់ជាដើមក៏គួរ ។ បើជំងឺត្រូវនឹងថ្នាំលាយដោយខ្ទឹមនឹងធាន់ក៏គួរ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា លសុណំ ខាទិតុំ** ដូច្នេះ ។

ខមួយទៀត ភិក្ខុមានជើងមិនបានលាងកុំជាន់សេនាសន: មានគ្រែ និងតាំងជាដើម និងផ្ទៃដែលគេធ្វើបរិកម្មជារបស់សង្ឆ ។ ខមួយទៀត ជើងទទឹកដោយទឹក កុំជាន់សេនាសន:ដូច្នោះ ។ ខមួយទៀត បើពាក់ស្បែកជើង កុំជាន់សេនាសន:ដូច្នោះ បើជាន់ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ អនោតេហិ ចាឧេហិ អលេ្វហិ ចាឧេហិ សឧចាហានេន សេនាសនំ អក្ក្រមិតពុ្ធ** ដូច្នេះ ។ ក្នុងទីដែលជាន់ចុះដោយជើង ទឹកប្រាកដនៅដូច្នោះឈ្មោះថាជើងទទឹក កុំគប្បីជាន់ផ្ទៃដែលគេធ្វើបរិកម្ម ឬសេនាសន: បើគ្រាន់តែសើមប្រាកដទឹកមិនប្រាកដនឹងជាន់ក៏គួរ ។ ជើងប្រឡាក់ នឹងជាន់សំពត់ជូតជើងក៏គួរពិត ។

ខមួយទៀត ភិក្ខុកុំគប្បីស្ពោះទឹកមាត់ លើផ្ទៃដែលគេធ្វើបរិកម្ម បើស្ពោះត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ បរិកម្មកតាយ ភូមិយា ឧជ្ឈហិតពុ្ធ** ដូច្នេះ ។ ស្ពោះទឹកមាត់ញើសសំបោរ ក្នុងកន្ទោរក៏គួរ ដ្បិតជារបស់ទ្រង់អនុញ្ញាត ។

ខមួយទៀត ភិក្ខុកុំគប្បីផ្ងែកនឹងជញ្ជាំង ដែលគេធ្វើបរិកម្ម និងជញ្ជាំងដែលគេធ្វើចិត្តកម្មគឺគូរវាស បើផ្ងែកត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ បរិកម្មកតា ភិត្តិ អបស្សេតពា** ដូច្នេះ ។ មិនមែនតែជញ្ជាំងមួយជំពូកឡើយ សូម្បីសន្ទឹកទ្វារ និងសន្ទឹកបង្ហួច ក្ដារបង្ហែក សសរថ្ម សសរឈើក្ដី មិនបានទ្រាប់ដោយសំពត់

ឬវត្ថុណាមួយមុនហើយ ផ្ទែកមិនបានឡើយ ។ មួយទៀត កាលនឹងតម្កល់ទុកនូវគ្រែនិងតាំងលើផ្ទៃលាបដោយកំបោរ ឬផ្ទៃដែលគេប្រោះព្រំ បើកន្ទេលផ្ទែងនិងកន្ទេលរំចេក ដែលនឹងក្រាលមិនមាន គប្បីយកសំពត់ព័ន្ធព័ទ្ធជើងគ្រែ ជើងតាំងជាមុនសិន ។ ដ្ឋិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ ចោឡកេន បលិវេឋេតុំ**[1] ដូច្នេះ ។ កាលបើសំពត់ព័ន្ធព័ទ្ធមិនមាន សូម្បីយកឈើរងក៏គួរ កាលបើមិនបានកាន់យករបស់ណាមួយរងមុន តម្កល់គ្រែ តាំង ត្រូវទុក្ខដ ។ បើចៅ-អាវាសតម្កល់ទុកគ្រែនិងតាំងលើផ្ទៃ មិនមានរបស់អ្វីមួយរង នឹងប្រើប្រាស់ជាន់ដោយជើងមិនបានលាង និងប្រើប្រាស់ដូចចៅអាវាសក៏គួរ ។

ខមួយទៀត គ្រែនិងតាំងរបស់សង្ឆ ឬទីដែលគេធ្វើប្រោះព្រំ ឬគ្រឿងកម្រាល សេនាសនៈដែលនឹងគប្បីជាន់ដោយជើងដែលលាងហើយ គប្បីយករបស់ជារបស់ខ្លួនក្រាលមុន សឹមដេក ។ ដ្ឋិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ បចូត្តរិត្វា ឯបជ្ជិតុំ** ដូច្នេះ ។ ក្រាលហើយសូម្បីដេកលក់ទៅ គ្រឿងកម្រាលនោះរមូរចូលសរីរាវយវៈណាមួយពាល់ត្រូវគ្រែឬតាំង ត្រូវអាបត្តិដោយពិត ។ តែរោមពាល់ត្រូវ ក៏ត្រូវអាបត្តិរាប់ដោយរោម ។ សូម្បីផ្ទែកនឹងគ្រែនឹងតាំងដោយអាការនៃការបរិភោគក៏ដូចគ្នា តែពាល់ត្រូវដោយបាតដៃ ឬជាន់ដោយបាតជើងក៏គួរ ។ កាលបើនាំគ្រែនិងតាំងទៅហើយប៉ះពាល់នឹងកាយមិនត្រូវអាបត្តិ ។

១- វិនយវណ្ណនាច្បាប់ដើមថា បតិវេឋេតុំ ។

ខមួយទៀត ភិក្ខុកុំគប្បីទុកសក់វែង ។ ដ្បិតព្រះពុទ្ធអង្គត្រង់ហាម-ឃាត់ និងអនុញ្ញាតទុកថា **ន ភិក្ខវេ ឌីឃា កេសា ធារេតព្វា... អនុជានামិ ភិក្ខវេ ឧម្ហាសិកំ**[1] **វា ឧវដ្ដុំ វា** ភិក្ខុកុំគប្បីទុកសក់ឲ្យវែង បើទុកឲ្យវែង ត្រូវទុក្កដ ។ តថាគត អនុញ្ញាតឲ្យទុកសក់ត្រឹម ២ ខែ ឬវែងប្រវែង ២ ធ្នាប់ ។ បើខាងក្នុង ២ ខែ សក់វែងដល់ ២ ធ្នាប់ គប្បីកោរចេញក្នុងខាងក្នុង ២ ខែ បើនឹងឲ្យលើស ២ ធ្នាប់ឡើងទៅមិនគួរ ។ បើមិនទាន់វែងដល់ ២ ធ្នាប់ នឹងឲ្យកន្ទងហួស ២ ខែទៅ សូម្បីមួយថ្ងៃ ក៏មិនបានឡើយ ដ្បិតពាក្យទាំង ២ នេះ កំណត់ ចំណែកជាឧក្រិដ្ឋ តែខ្វីចុះមកជាងនោះ ដែលថាមិនគួរនោះ មិនមាន ។

ខមួយទៀត ភិក្ខុកុំគប្បីទុកពុកមាត់ និងពុកចង្កាឲ្យវែង ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ មស្សុ ឋបេតព្វំ ន មស្សុ វឌ្ឍេតព្វំ ន តោលេមិកំ... ន ចតុរស្សកំ... ន បរិមុខំ... ន អឌ្ឍរុកំ ការាបេតព្វំ ន ធារិការ ជបេតព្វា...** ភិក្ខុមិនត្រូវឲ្យគេកាត់ពុកមាត់ (ដោយកន្ត្រៃ) កុំទុកពុកមាត់ឲ្យវែង កុំឲ្យគេធ្វើពុកចង្កាឲ្យវែង (ដូចពុកចង្កាពពែ) កុំឲ្យគេធ្វើពុកមាត់ជាបួនជ្រុង គឺថានឹងប្រាកដជា ៤ ជ្រុង ឬ ៤ អន្ទើយ៉ាងណា កុំឲ្យគេធ្វើយ៉ាងនោះ កុំឲ្យគេប្រមូលរោមទ្រូងឲ្យជាជួរជាកំពូល កុំឲ្យគេធ្វើរោមពោះ តាំងទុកជាជួរជាកំពូល កុំទុកពុកមាត់ដូចចង្ហូម កុំឲ្យគេដករោមក្នុងទីចង្ការ ថាបើឲ្យគេធ្វើដូចពោលមកនេះ ត្រូវទុក្កដ ។

១- វិនយវណ្ណនា ច្បាប់ដើមថា ទ្វេមាសិកំ ។

ខមួយទៀត ភិក្ខុកុំគប្បីទុកពោមច្រមុះឲ្យវែង បើទុកឲ្យវែងត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ឌីឃំ ជាសិកា-លោមំ ធារេតព្វំ** ដូច្នេះ ។ ពោមច្រមុះគប្បីដកចេញដោយសណ្ហាសដែលជារបស់ព្រះពុទ្ធអង្គទ្រង់អនុញ្ញាត តែនឹងឲ្យគេដកពោមច្រមុះដោយក្រូសជាដើមមិនត្រូវអាបត្តិ តែព្រះពុទ្ធអង្គទ្រង់អនុញ្ញាត សណ្ហាសទុកដើម្បីនឹងឲ្យរក្សាខ្លួន ។

ខមួយទៀត ភិក្ខុកុំគប្បីទុកក្រចកឲ្យវែង បើទុកឲ្យវែងត្រូវទុក្កដ ។ គប្បីកាត់ចេញដោយកាំបិតកាត់ក្រចក ឲ្យស្មើនឹងសាច់ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់និងអនុញ្ញាតទុកថា **ន ភិក្ខវេ ឌីឃា ឧ១ា ធារេតព្វា អនុជានាមិ ភិក្ខវេ ឧ១ច្ឆេទនំ អនុ-ជានាមិ ភិក្ខវេ មំសប្បមាណេន ឧ១ំ ឆិន្ទិតុំ** ដូច្នេះ ។ កាត់ក្រចកដោយក្រចកជាដើម មិនត្រូវអាបត្តិ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតកាំបិតកាត់ក្រចកទុកដើម្បីនឹងឲ្យរក្សាខ្លួន ។

ខមួយទៀត ភិក្ខុកុំគប្បីឲ្យគេខាត់ក្រចកទាំង ២០ បើឲ្យគេខាត់ត្រូវទុក្កដ គប្បីនាំតែមន្ទិលក្រចកចេញចាកក្រចក ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់និងអនុញ្ញាតទុកថា **ន ភិក្ខវេ រីសតិមដ្ឋំ ការាបេតព្វំ អនុជានាមិ ភិក្ខវេ មលមត្តំ អបកឌ្ឍិតុំ** ដូច្នេះ ។

ខមួយទៀត ភិក្ខុគ្មានជំងឺកុំគប្បីឲ្យគេដកពោមក្នុងទីចង្អៀត ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់និងអនុញ្ញាតទុកថា **ន ភិក្ខវេ សម្ពាធេ**

លោមំ សំហរាបេតុំ អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា សម្ពាធេ លោមំ សំហរាបេតុំ ភិក្ខុកុំគប្បីឲ្យគេដករោមក្នុងទីចង្អៀតនិងក្ងៀក បើឲ្យគេដកត្រូវទុក្កដ តថាគតអនុញ្ញាតឲ្យប្រើគេដកនូវរោមក្នុងទីចង្អៀត ព្រោះអាពាធគឺបូសនិងដំបៅ ដើម្បីលាបថ្នាំ ។

ខមួយទៀត ភិក្ខុកុំគប្បីចោលឯង និងកុំឲ្យគេចោល នូវឧច្ចារៈ បស្សាវៈ សំវាម របស់សំណល់ ក្រៅជញ្ជាំង ក្រៅកំពែង ។

ខមួយទៀត ភិក្ខុកុំគប្បីចោលឯង និងកុំឲ្យគេចោល របស់ ៤ យ៉ាងនោះ លើទីខ្ទៀ គឺចម្ការ ស្រែ របស់គេ ដ្បិតសិក្ខាបទ ២ នេះ មកក្នុងបាចិត្តិយនៃនាងភិក្ខុនី ព្រះអដ្ឋកថាចារ្យ លោកពោលថា ក្នុងភិក្ខុត្រូវទុក្កដ ។ ចោលឯងនូវរបស់ ៤ យ៉ាង ក្រៅជញ្ជាំង ឬក្រៅកំពែងដោយប្រយោគតែមួយ ត្រូវទុក្កដតែមួយ ។ កាលបើចោលផ្សេងៗគ្នា ត្រូវទុក្កដ រាប់ដោយវត្ថុ ។ ក្នុងការបង្គាប់ឲ្យគេចោលក៏ដូចគ្នា សូម្បីចោលឈើស្ងួនក៏គង់ត្រូវទុក្កដ ។ បើមើលសិនទើបចោលឧច្ចារៈជាដើម ឬចោលក្នុងទីមិនមានមនុស្សទៅមក ជាទីធ្លាប់ចោល មិនត្រូវអាបត្តិ ។ ចម្ការស្រែជាទីព្រោះដាំពូជផ្ទៃរបស់មនុស្ស ឬសួនដូងជាដើមក្តី ក្នុងទីណាមួយជាទីមានរបស់ខ្ទៀ គឺពូជផ្ទៃគេសាបព្រោះដាំទុកហើយ នឹងចោលរបស់ ៤ យ៉ាងនោះ មិនគួរ ។ កាលបើចោលឲ្យគប្បីដឹងប្រភេទអាបត្តិដោយន័យមុន ។ អង្គុយធាន់ ឬទំពាអំពៅជាដើម ក្នុងចម្ការស្រែ ឬសួន កាលបើនឹងទៅហើយ ចាក់ចោលទឹកសំណល់និងកាកជាដើម

ទុកក្នុងទីមានរបស់ខ្ញៀវ ដោយហោចទៅ សូម្បីផ្ទៃដូងដែលចោះក្បាលផឹកទឹកហើយចោល ក៏គង់ត្រូវទុក្កដ ។ ក្នុងស្រែគេភ្ជួរហើយសាបពូជទុកហើយ ពន្ធកបែកឡើងហើយ ឬនៅមិនទាន់បែកក្តី ក៏គង់ត្រូវទុក្កដ ។ ចោលក្នុងចម្ការស្រែដែលគេមិនទាន់សាបពូជ ឬក្នុងមុំចម្ការស្រែ ឬភ្ជឹដែលគេមិនបានព្រោះដាំ និងចោលក្នុងទីដែលមនុស្សគេចោលសំរាមក៏គួរ ។ មនុស្សគេប្ចូតស្រូវចេញអស់ហើយ ឈ្មោះថាស្រែគេលែងធ្វើ ក្នុងស្រែដូច្នោះក៏គួរ ។ បើស្រែណាមានបុព្វណ្ណជាតិជាដើម សូម្បីគេប្ចូតកាត់ហើយ តែគេនៅរក្សាថានឹងដុះឡើងទៀត ក្នុងចម្ការស្រែដូច្នោះមិនគួរ ។

ខមួយទៀត ភិក្ខុមិនបានពិចារណាសួរមុន កុំគប្បីធាន់សាច់ បើធាន់ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ច ភិក្ខវេ អប្ប-ដិវេក្ខិត្វា មំសំ បរិភុញ្ជិតព្វំ** ដូច្នេះ ។ បើដឹងថាជាសាច់ឈ្មោះនេះហើយ កិច្ចដែលនឹងសាកសួរមិនមាន បើមិនដឹងគប្បីសួរមុនសឹមធាន់ ។

ខមួយទៀត ភិក្ខុកុំគប្បីធាន់សាច់ដំរី សាច់សេះ សាច់ឆ្កែ សាច់ពស់ សាច់រាជសីហ៍ សាច់ខ្លាធំ សាច់ខ្លាដំបង សាច់ខ្លាឃ្មុំ សាច់ឆ្កែព្រៃ (សាច់ខ្លាត្រី) បើធាន់សាច់ទាំងអម្បាលនេះ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ហត្ថិមំសំ អស្ស-សុនខ - អហិ - សីហ - ព្យគ្ឃ - ឌីបិ - អច្ឆ - តរច្ឆមំសំ បរិភុញ្ជិតព្វំ** ដូច្នេះ ។ សុនខព្រៃឈ្មោះថាកោក:ដូចឆ្កែស្រុក

សាច់នៃឆ្កែព្រៃនោះគួរ ។ ឆ្កែណាកើតដោយមេឆ្កែស្រុក បាជាឆ្កែព្រៃ ឬមេឆ្កែព្រៃ បាជាឆ្កែស្រុក ផ្សំគ្នា សាច់នៃឆ្កែនោះមិនគួរ ដ្បិតថាឆ្កែនោះ សេពជាតិពីរពួក ។ សាច់នៃទីឃជាតិ សត្វវែងមិនមានដើងជំពូកណា មួយ ទាំងអស់ឈ្មោះថាសាច់ពស់ មិនគួរ ។ សាច់រាជសីហ៍ជាដើមជា របស់ប្រាកដដោយពិត ។ សាច់មនុស្សដែលជាវត្ថុនៃចុល្លច្ច័យ ដូច ពោលមកហើយខាងដើម ព្រះពុទ្ធអង្គទ្រង់ហាម ព្រោះមានជាតិស្មើគ្នា ។ សាច់ដំរី សាច់សេះ ទ្រង់ហាម ព្រោះជារាជយាន ។ សាច់ឆ្កែ សាច់ពស់ ទ្រង់ហាម ព្រោះជារបស់បដិកូល សាច់ ៥ យ៉ាង មានរាជសីហ៍ជាដើម ទ្រង់ហាម ដើម្បីមិនឲ្យបៀតបៀនខ្លួន ។ សូម្បីធ្នើងឈាមស្បែកពោមនៃ សត្វ ១០ ជំពូក មានមនុស្សជាដើមទាំងពួង មិនគួរទាំងអស់ ។ សាច់ ទាំងអម្បាលនោះណាមួយ ភិក្ខុដឹងក្តី មិនដឹងក្តី ធាន់គង់ត្រូវអាបត្តិ ។ ដឹងច្បាស់កាលណា គប្បីសម្តែងអាបត្តិចេញក្នុងកាលនោះ ។ គិតថានឹង មិនសួរ ហើយទទួលដើម្បីនឹងធាន់ ត្រូវទុក្កដ ព្រោះទទួល ។ ទទួល ដោយគិតថានឹងសួរ ហើយទើបធាន់ មិនត្រូវអាបត្តិ ។ តែសាច់ដែល គេសម្ងាប់មកចំពោះភិក្ខុ ដឹងហើយធាន់ ទើបត្រូវអាបត្តិ ។ បើមិនដឹង ហើយធាន់ មិនត្រូវអាបត្តិ ។

ខមួយទៀត ភិក្ខុដេកក្នុងវេលាថ្ងៃត្រូវបិទទ្វារ ។ ដ្បិតព្រះពុទ្ធអង្គ ទ្រង់អនុញ្ញាតទុកក្នុងវិនីតវត្ថុថា **អនុជានាមិ ភិក្ខវេ ឌិវា បដិ-សល្ងិយន្តេន ទ្វារំ សំវរិត្វា បដិសល្ងិយិតុំ** *ដូច្នេះ ។ ព្រោះ*

ពាក្យនេះ កាលបើមិនបិទទ្វារដេកក្នុងវេលាថ្ងៃ លោកពោលថា ត្រូវ
ទុក្កដ ។ ដ្ឋិតថាព្រះឧបាលិត្ថេរជាដើម លោកដឹងអធិប្បាយនៃព្រះ
ពុទ្ធអង្គ តែងតាំងអដ្ឋកថាទុក ។ ដែលពោលថាត្រូវទុក្កដនោះ សម្រេច
ដោយពាក្យក្នុងបរិវារៈថា **អត្ថាបត្តិ ឌិវា អាបជ្ជតិ នោ រត្តឹ**
អាបត្តិដែលភិក្ខុត្រូវតែក្នុងវេលាថ្ងៃ មិនត្រូវក្នុងវេលារាត្រី ដូច្នេះ ។
ទ្វារដូចម្តេចដែលត្រូវបិទ? ទ្វារដូចម្តេចដែលមិនត្រូវបិទ? ទ្វារដែលគេ
ធ្វើដោយបន្ទះឈើ ឬដោយប្រដឹសរនាប ឬដោយបន្ទះផ្ទាំ ឬដោយ
ស្ទឹកឈើណាមួយ បញ្ចូលទៅក្នុងដំណាប់ខាងក្រោម បញ្ចូលទៅក្នុង
ក្រវិលខាងលើ រ៉ាលទៅបាន ទ្វារដូច្នេះត្រូវបិទ ។ ទ្វារដទៃដូចទ្វារ
ក្រាលគោ និងទ្វារប្រកបដោយជើងគុលសម្រាប់បិទស្រុក ទ្វារដែលគេ
ប្រកបដោយក្រវិល ២ ឬ ៣ អន្ទើ ក្នុងផ្ទៃនក្ការ ឬប្រដឹសរូតទៅមកបាន
ទ្វារប្រដឹសដែលគេទល់ឡើងដូចក្នុងវានផ្សារ ទ្វារបន្ទះឫស្សីដែលគេក្រង
នូវបន្ទះឫស្សីក្នុងទី ២ អន្ទើ ៣ អន្ទើ ធ្វើទុកក្នុងបណ្ណកុដិក្តី ទ្វារសំពត់ក្តី ដូច្នេះ
មិនត្រូវបិទ ។ ឯក្នុងបទថាភិក្ខុមានបាត្រនៅក្នុងដៃ ច្រានសន្ទឹកទ្វារនោះ
ទ្វារសំពត់មួយជំពូក មិនធ្វើឲ្យត្រូវអាបត្តិ ច្រានទ្វារក្រៅនោះត្រូវអាបត្តិ ។
ឯដេកក្នុងវេលាថ្ងៃ ទ្វារដែលរ៉ាលបានមួយយ៉ាង ធ្វើឲ្យត្រូវអាបត្តិ ទ្វារដ៏
សេសនឹងបិទក្តី មិនបិទក្តី ដេកមិនត្រូវអាបត្តិ តែគប្បីបិទហើយដេកចុះ
នេះជាវត្ត ។ ទ្វារដែលបង្វិលទៅបាន បិទដូចម្តេច ទើបនឹងបានហៅថាជា
ការបិទ ដាក់ចន្ទាស់និងដាក់គន្ធ៏ះជាដើមហើយ ឈ្មោះថាជាការបិទដោយ

ប្រពៃ នឹងទាស់តែចន្ទាស់និងគន្ធ៏ តែមួយយ៉ាងក៏គួរ ឬបិទតែលួមឲ្យ មេទ្វារពាល់គ្នាបន្ដិចក៏គួរ ថយចុះសូម្បីមិនជិតគ្នាលួមក្បាលចូលមិនបាន ក៏គួរ ។ បើជាទីប្រើប្រាស់របស់មនុស្សច្រើនគ្នា សូម្បីនឹងផ្ដាំភិក្ខុ ឬសាមណេរឲ្យជួយបិទហើយដេក ក៏គួរ ។ បើភិក្ខុទាំងឡាយអង្គុយធ្វើ ចីវរកម្ម ឬការងារដទៃ សូម្បីនឹងចងចិត្តថា ភិក្ខុទាំងអម្បាលនោះ គង់ នឹងជួយរារាំងទ្វារ ហើយដេកក៏គួរ ។ តែក្នុងអដ្ឋកថាកុរុន្ទីថា នឹងប្រាប់ សូម្បីដល់ឧបាសក ឬចងចិត្តថា គេគង់នឹងជួយថែទាំហើយដេកក៏គួរ ។ នឹងផ្ដាំនាងភិក្ខុនី ឬស្ត្រី មិនគួរ ។ បើធរណី ឬក្រវិលខាងលើ នៃទ្វារ បែកធ្លាក់ចេញ ឬគេមិនទាន់បានផ្ដុំ មិនអាចបិទបាន ឬគេ គរឥដ្ឋ គរដី ជាដើម ទុកបៀតទ្វារ ឬគេចងរន្ធាដើម្បីនឹងធ្វើនវកម្មណា មួយ មិនអាចបិទបាន មានអន្ដរាយដូច្នេះ សូម្បីនឹងមិនបិទហើយដេកក៏គួរ បើសន្ធឹកទ្វារនោះពុំមានសោត ឈ្មោះថាបានកប្ប ដោយពិត កាល នឹងដេកក្នុងជាន់ខាងលើ គប្ប៊ីលើកជណ្ដើរចេញសិន ទើបដេក គួរ ។ បើ គ្រឿងបិទនៅក្បាលជណ្ដើរមានសោត គប្ប៊ីបិទសិនហើយដេកចុះ កាល បើនឹងដេកក្នុងលែ្ងង បិទទ្វារលែ្ងង ឬទ្វារមុខណាមួយហើយដេកក៏គួរ ។ បើផ្ទះជញ្ជាំងជាប់គ្នា គេធ្វើទ្វារខាងទាំង ២ ប្រើប្រាស់ គប្ប៊ីបិទទ្វារទាំងពីរ សូម្បីក្នុងប្រាសាទ ៣ ជាន់ ក៏ត្រូវបិទទ្វារដោយពិត ។ ភិក្ខុច្រើនផង គ្នាត្រឡប់មកអំពីភិក្ខាចារ ចូលទៅក្នុងប្រាសាទ ដូចលោហប្រាសាទ ដើម្បីដេកក្នុងវេលាថ្ងៃ ព្រះសង្ឆវេគប្ប៊ីផ្ដាំមនុស្សអ្នករក្សាទ្វារឲ្យបិទ

ឬធ្វើអាភោគចិត្តថា ឯការបិទទ្វារជាធុរៈរបស់គេ ហើយទើបចូលទៅដេកចុះ គប្បីធ្វើយ៉ាងនេះ គ្រប់អង្គដរាបដល់សង្ឃនវកៈ ។

មួយទៀត សូម្បីអ្នកចូលទៅមុននឹងធ្វើអាភោគចិត្តថា ការបិទទ្វារជាការៈរបស់មនុស្សខាងក្រោយក៏គួរ ។ កាលបើមិនផ្តាំ ឬមិនធ្វើអាភោគចិត្ត ហើយចូលទៅដេកខាងក្នុងលែង ដែលមិនបានបិទទ្វារ ឬដេកខាងក្រៅលែង គង់ត្រូវអាបត្តិ ។ សូម្បីក្នុងវេលាកាលដេកក្នុងលែង ឬក្រៅលែងនឹងចងចិត្តថា ឯការបិទទ្វារជាការៈរបស់អ្នកឆ្នាំទ្វារ នៅទ្វារធំ ហើយដេកក៏គួរ ។ សូម្បីដេកក្នុងទីវាល ក្នុងលោហប្រាសាទជាដើម ត្រូវបិទទ្វារដោយពិត ។ សេចក្តីសង្ខេបដូច្នេះ ដេកក្នុងវេលាថ្ងៃនេះ ពោលក្នុងទីដែលគេប្រកបទ្វារ និងបិទចាំងដោយវត្ថុណាមួយ ព្រោះហេតុនោះ កាលនឹងដេកក្នុងកណ្តាលវាល ឬគល់ឈើ ឬមណ្ឌបទីកន្ទែងណាមួយដែលគេប្រកបទ្វារ គប្បីបិទទ្វារសិន សឹមដេក ថាបើបរិវេណធំដូចលានមហាពោធិ និងលានលោហប្រាសាទ ជាទីប្រជុំមនុស្សច្រើនក្នុងទីឯណា សូម្បីនឹងបិទទ្វារ ក៏មិនបានឈ្មោះថាបិទ មនុស្សទាំងឡាយមិនបានចូលតាមទ្វារ រមែងឡើងលើកំពែងដើរទៅ ក្នុងទីដូច្នោះ កិច្ចដែលនឹងបិទមិនមាន ។ បើកទ្វារដេកក្នុងវេលាយប់ អរុណរះឡើងមក ក្រោកឡើងមិនត្រូវអាបត្តិ បើភ្ញាក់ហើយត្រឡប់ដេកថែមទៀត ក៏ត្រូវអាបត្តិ ។ ភិក្ខុណាកំណត់ទុកថា អរុណរះឡើងមកយើងនឹងក្រោក ហើយបើកទ្វារដេកក្នុងវេលាយប់ មិនបានក្រោកឡើងតាមកំណត់ ត្រូវអាបត្តិដល់ភិក្ខុ

នោះដោយពិត ។ តែក្នុងមហាបច្ចរីពោលថា កាលបើដេកយ៉ាងនេះមិន
រួចអនាទរិយទុក្កដ ។ បើភិក្ខុណាក្នុងវេលាយប់បដិបត្តិសមណធម៌ច្រើន ឬ
ដើរផ្ទូរហាលថ្ងៃនឿយណាស់ អង្គុយលើគ្រែមិនឲ្យជើងផុតអំពីផ្ទៃឡើយ
ដេកលក់ទៅ មិនមានអាបត្តិដល់ភិក្ខុនោះ បើភិក្ខុដេកលក់ហើយសូម្បី
មិនដឹង លើកជើងឡើងលើគ្រែ ត្រូវអាបត្តិពិត ។ អង្គុយផ្អែកលក់ទៅមិន
មានអាបត្តិ ។ ភិក្ខុណាគិតនឹងបន្ទោបង់នូវងងុយដើរចង្ក្រមដួលចុះ ហើយ
ក្រោកឡើងដោយប្រញាប់ មិនមានអាបត្តិដល់ភិក្ខុនោះ ។ បើភិក្ខុណា
ដួលចុះហើយដេកបណ្ដោយក្នុងទីនោះមិនក្រោកឡើង មានអាបត្តិដល់
ភិក្ខុនោះ ។ ភិក្ខុណារួចចាកអាបត្តិ? ភិក្ខុណាមិនរួចចាកអាបត្តិ? ក្នុងមហា-
បច្ចរីពោលថា ភិក្ខុដេកសំយុងជើង មិនលើកជើងឲ្យផុតចាកផ្ទៃប៉ុណ្ណោះ
រួចចាកអាបត្តិបាន ។ ភិក្ខុលើកជើងឲ្យផុតចាកផ្ទៃហើយដេក សូម្បីសញ្ជប់
នៅ ក៏មិនរួចចាកអាបត្តិបាន ។ តែក្នុងមហាអដ្ឋកថា ព្រះមហាបទុ-
មត្ថេរពោលថា អ្នកដើរចង្ក្រមងុយងប់ដួលចុះទៅក្នុងទីនោះ អាបត្តិមិន
មានដល់លោកនោះ ព្រោះមិនមែនជាវិស័យ តែអាចារ្យទាំងឡាយមិន
បានពោលយ៉ាងនោះ ព្រោះហេតុនោះ ជាអាបត្តិពិត ។ តែភិក្ខុខ្មោចចូល
និងភិក្ខុដែលគេចងឲ្យដេកនៅ ពីរនេះរួចចាកអាបត្តិ ។ ក្នុងអដ្ឋកថាកុរុន្ទីថា
បើភិក្ខុខ្មោចចូលនិងភិក្ខុដែលគេចងឲ្យដេក ពីរពួកនេះ ទើបរួចចាកអាបត្តិ
បាន ។ តាំងអំពីមើលរបាំស្ដាប់ច្រៀងមក រហូតដល់ព្រះពុទ្ធប្បញ្ញត្តិនេះ
ជាអចិត្តក: សូម្បីមិនភ្ញែង បើប្រព្រឹត្តកន្ទងក៏ត្រូវអាបត្តិ ។ មួយទៀត

ក្នុងពួកសិក្ខាបទដែលជាសចិត្តក:មុន រៀនតិរច្ឆានវិជ្ជា ប្រាប់តិរច្ឆានវិជ្ជា ពីរនេះក្នុងបាចិត្តិយនៃភិក្ខុនី ជាអចិត្តក: តែក្នុងមូលសិក្ខាចាត់ជាសចិត្តក: ដែលកំណត់សិក្ខាបទជាសចិត្តក:និងអចិត្តក:នេះ តាមបែបក្នុងមូលសិក្ខា តែក្នុងសចិត្តកសិក្ខាបទ សិក្ខាបទខ្លះមិនមានក្នុងមូលសិក្ខា គ្រាន់តែសង្កេត ឃើញថាជាសចិត្តក:ហើយពោលទុក ដើម្បីនឹងមិនឲ្យខ្ជិលដាប់ ។ អ្នកប្រាជ្ញ (អ្នកមានបញ្ញា) គប្បីផ្ទៀងផ្ទាត់ពិនិត្យមើលយកចុះ ។

អចិត្តកបញ្ញត្តិកថា ចប់

វិញ្ញត្តិកថា

ពោលអំពីការសូម ដែលមកក្នុងអដ្ឋកថានៃកុដិការសិក្ខាបទ ។

សេចក្ដីថា នឹងសូមបុរសមកផ្ទាប់ថ្ងៃមិនគួរ ។ សូមដើម្បីជាសម្ងាញ់ ដើម្បីធ្វើការក៏គួរ ។ នឹងសូមហត្ថកម្មកម្ចាំងដៃក៏គួរ ។ ឯហត្ថកម្មនេះជាវត្ថុ អ្វីក៏ដោយ ព្រោះហេតុនោះ ហត្ថកម្មទាំងអស់ លើកតែកម្មរបស់ព្រាន ម្រឹគ ព្រានបក្សី ជាដើមចេញ ក្រៅនោះគួរទាំងអស់ ភិក្ខុទៅដល់ហើយ គេសួរក្ដី មិនសួរក្ដី នឹងសូមក៏គួរ ដែលជាទោសព្រោះវិញ្ញត្តិក៏មិនមាន ។ ព្រោះហេតុនោះ កុំគប្បីសូមហត្ថកម្មមិននិយម នឹងព្រានម្រឹគជាដើមថា អ្នកចូរឲ្យហត្ថកម្ម ព្រោះថាសូមមិននិយមដូច្នេះ គេនឹងគប្បីបញ្ជូន ភិក្ខុទៅហើយ សម្ងាប់ម្រឹគនាំមកឲ្យ ។ គប្បីសូមមាននិយមថាការ ដែលគួរគប្បីធ្វើក្នុងវត្ថុមាន អ្នកចូរឲ្យហត្ថកម្មក្នុងការនោះ ដូច្នេះចុះ ។

អ្នកស្រែគេកាន់គ្រឿងឧបការៈមានផាលនិងនង្គ័លជាដើម ដើម្បីនឹងភ្ជួរ ឬព្រោះ ឬច្រូត ឬគេខ្ជល់ខ្ជាយក្នុងកិច្ចរបស់គេហើយ ឬមនុស្សពួកដទៃ នឹងសូមហត្ថកម្មនឹងគេ ក៏គួរដោយពិត ។ មនុស្សស៊ីដែល ឬមនុស្សដទៃ មិនមានការងារ ពោលតែពាក្យលេងមិនមានប្រយោជន៍ ឬចូលចិត្តតែដេក មនុស្សដូច្នេះ សូម្បីមិនសូម នឹងប្រើឲ្យធ្វើតាមប្រាថ្នាក៏គួរ ។ អាចារ្យ ទាំងឡាយសម្តែងតួយ៉ាងទុក ដើម្បីប្រកាសហត្ថកម្មថាគួរ ដូច្នេះថា បើភិក្ខុ ប្រាថ្នានឹងឲ្យគេធ្វើប្រាសាទសោត ត្រូវការដោយសសរ គប្បីទៅកាន់ផ្ទះជាងសិលាពោលថា ម្នាលឧបាសក ឲ្យហត្ថកម្មដ៏គួរ គេសួរថា នឹងគប្បីធ្វើនូវរបស់អ្វី គប្បីប្រាប់ថាអ្នកចូរជួយរើសសរសិលាឡើងឲ្យ ថាបើគេរើឡើងឲ្យ ឬគេឲ្យសសរដែលគេរើឡើងទុកស្រាប់ ក៏គួរ ថាបើគេពោលថា ឱកាសដើម្បីនឹងធ្វើនវកម្មមិនមាន លោកចូរឲ្យអ្នកដទៃរើឡើងចុះ ខ្ញុំនឹងឲ្យតម្លៃដល់គេ ភិក្ខុឲ្យអ្នកដទៃរើឡើងហើយប្រាប់ថាអ្នកចូរឲ្យតម្លៃដល់អ្នករើចុះ ដូច្នេះក៏គួរ ដោយឧបាយនោះ ត្រូវការដោយឈើធ្វើប្រា-សាទនឹងទៅរកជាងឈើ ត្រូវការឥដ្ឋនឹងទៅរកជាងឥដ្ឋ ត្រូវការគ្រឿងប្រក់នឹងទៅរកជាងប្រក់ ត្រូវការចិត្តកម្មទៅរកជាងគំនូរ ត្រូវការរបស់អ្វីនឹងទៅរកជាងពួកនោះដូច្នេះ ហើយសូមហត្ថកម្មក៏គួរ ។ ដ្បិតសូមហត្ថ-កម្ម សូម្បីបានដាច់ថ្ងៃមក ឬបានថ្ងៃឈ្នួលដែលជាកប្ប៊ិយមក នឹងទទួលក៏គួរ នឹងឲ្យគេយករបស់មកអំពីព្រៃ គប្បីឲ្យគេយករបស់ទាំងពួងដែលមិនមានម្ចាស់របស់ហួងហែងមក មិនមែនតែឲ្យគេធ្វើប្រាសាទមួយយ៉ាង

ឡើយ សូម្បីនឹងឲ្យគេធ្វើគ្រែ តាំង បាត្រ សំពត់តម្រងទឹក ធម្មក្រក ចីវរជាដើម បានរបស់មានឈើ និងលោហៈ និងអំបោះ ជាដើមហើយ គប្បីទៅរកជាងជំពូកនោះ។ ហើយសូមហត្ថកម្ម ដូចពោលហើយនោះ ចុះ ដ្បិតសូមហត្ថកម្មបានមកដាច់ថ្ងៃ ឬបានថ្ងៃឈ្នួលជាកប្បិយមកទាំងពួង គប្បីទទួលចុះ ថាបើជាងគេមិនចង់ធ្វើ គេប្រាថ្នាថ្ងៃឈ្នួលសោតរបស់ជាអកប្បិយ មានកហាបណៈជាដើម កុំគប្បីឲ្យ នឹងស្វែងរកអង្ករជាដើមដោយកិច្ចាចារវត្តហើយឲ្យក៏គួរ ។ ឲ្យគេធ្វើបាត្រថ្មី ឬឲ្យគេដុតបាត្រថ្មី ដោយសូមហត្ថកម្មហើយ ត្រូវការប្រេងលាបបាត្រដែលដុតថ្មី ចូលទៅក្នុងភូមិដើម្បីប្រយោជន៍ដល់ប្រេងលាបបាត្រ គេសម្គាល់ថាមកបិណ្ឌបាត គេបង្ហោនបបរ ឬបាយចូលមក គប្បីយកដៃបិទបាត្រ បើឧបាសិកាគេសួរថា ហេតុអ្វីទើបបិទបាត្រ គប្បីប្រាប់ថា បាត្រដុតថ្មីត្រូវការប្រេងលាប បើគេទទួលយកបាត្រទៅលាបប្រេងហើយ នាំមកប្រគេន ព្រមទាំងបបរនិងបាយ មិនឈ្មោះថាជាវិញ្ញត្តិ គួរទទួល ។

ភិក្ខុទៅបិណ្ឌបាតអំពីព្រឹក ទៅកាន់ពោងធាន់ មិនឃើញអាសនៈ ក៏ឈរនៅ ឧបាសិកាទាំងឡាយ គេឃើញឈរនៅ គេឲ្យមនុស្សនាំអាសនៈមកក្រាល បើអង្គុយហើយ កាលនឹងទៅគប្បីប្រាប់មុនហើយសឹមទៅ សូម្បីមិនបានប្រាប់មុនហើយទៅ អាសនៈបាត់ទៅ ត្រូវសង់គេឯប្រាប់មុនហើយទើបទៅជាវត្ត ។ ថាបើភិក្ខុប្រើឲ្យគេនាំអាសនៈមក ទើបគេនាំមក កាលនឹងទៅគប្បីប្រាប់មុន ហើយសឹមទៅ មិនប្រាប់មុនហើយ

ជៀសទៅជាវត្តភេទផង បាត់ទៅត្រូវសងគេផង សូម្បីក្នុងគ្រឿងកម្រាលដទៃៗ ក៏ដូចគ្នា ។

បើមានមមង់ច្រើន គប្បីពោលថា អ្នកចូរយកផ្ទៃតបក់មមង់មក គេយកមែកស្ពៅជាដើមមក គប្បីឲ្យគេធ្វើកប្បិយមុនសិន សឹមទទួល ។

ភាជនៈទឹកក្នុងភោជនាន់ ទទេ មិនមានទឹក កុំគប្បីពោលថាអ្នកចូរកាន់យកធម្មក្រក ដោយហេតុថា គេចាប់ធម្មក្រកផ្ទៀងចុះក្នុងភាជនៈទទេ នឹងគប្បីបែកទៅ បើទៅកាន់ស្ងឹងឬបឹងនឹងពោលថា អ្នកចូរនាំទឹកមកក៏គួរ នឹងពោលថាអ្នកចូរនាំទឹកមកអំពីផ្ទះ មិនគួរឡើយ កាលបើគេនាំមកអំពីផ្ទះដោយបង្ហាប់ដូច្នោះ កុំនាន់ ។

ធ្វើកត្តកិច្ចក្នុងភោជនាន់ឬក្នុងព្រៃ នឹងប្រើអ្នកធ្វើការណាមួយឲ្យយកស្ងឹកឈើឬផ្ទៃឈើដែលគួរជាអន្ទក់ណាមួយ ដែលកើតក្នុងទីនោះ មិនមានអ្នកណាហួងហែងមក ដោយសូមហត្ថកម្មហើយទើបនាន់ក៏គួរ តែកុំប្រើភិក្ខុឬសាមណេរដែលជាអលជ្ជីឲ្យធ្វើហត្ថកម្ម ដូច្នេះជាបែបយ៉ាងក្នុងហត្ថកម្ម ។

នឹងឲ្យគេនាំគោមកអំពីទីមិនមែនជាញាតិ មិនមែនបវារណា មិនគួរ កាលបើឲ្យគេនាំមកត្រូវទុក្កដ ។ នឹងសូមអំពីញាតិ អំពីមនុស្សបវារណា ដើម្បីឲ្យដាច់ថ្ងៃមិនគួរ នឹងសូមខ្ចីមកគួរក្នុងទីទាំងពួង ។ ខ្ចីគោគេមកដូច្នោះហើយ គប្បីរក្សាថែទាំហើយប្រគល់ឲ្យម្ចាស់របស់វិញ ថាបើជើងឬស្នែងនៃគោនោះបាក់ទៅ ឬគោបាត់ទៅ បើម្ចាស់របស់គេទទួលក៏ជាការ

ល្អ បើគេមិនទទួលក៏ជាសំណាង បើគេពោលថា ខ្ញុំអម្ចាស់ថ្វាយដល់លោកតែម្តង កុំគប្បីទទួល បើគេថាខ្ញុំថ្វាយដល់វិហារ គប្បីប្រាប់ថា អ្នកចូរប្រាប់មនុស្សរក្សាវត្ត ដើម្បីឲ្យគេរក្សាថែទាំចុះ សូម្បីនឹងពោលជាមួយមនុស្សមិនមែនញាតិ មិនមែនបវារណាថា អ្នកចូរឲ្យរទេះដូច្នេះ មិនគួរ ជាវិញ្ញត្តិ ត្រូវទុក្កដ ។ សូមអំពីញាតិនិងមនុស្សបវារណាគួរ នឹងខ្ចីក៏គួរ ធ្វើការហើយគប្បីប្រគល់ឲ្យគេវិញ ថាបើកង់ជាដើមបាក់ទៅ គប្បីធ្វើឲ្យជាប្រក្រតីហើយប្រគល់ឲ្យ កាលបើបាត់ទៅជាសំណាង កាលបើគេថា ថ្វាយដល់លោកតែម្តង ឈ្មោះថាជាគ្រឿងឈើ នឹងទទួលក៏គួរ សូម្បីកាំបិតនិងប៉ូវថៅ ចបដីក ចបកាប់ ដែកស្ទាន ក៏ដូចគ្នា រលីជាដើមដែលមនុស្សដទៃហួងហែងទុក ល្មមជាគរុភណ្ឌបាន ឈ្មោះថាជាវិញ្ញត្តិ តូចចុះទៅជាងនោះ មិនជាវិញ្ញត្តិ តែនឹងឲ្យគេយកវត្ថុណាមួយ ដែលមិនមានមនុស្សហួងហែងទុកក៏គួរ ព្រោះថា ពាក្យពោលជាវិញ្ញត្តិនោះ បានក្នុងរបស់ដែលគេរក្សា និងហួងហែងទុកមួយយ៉ាង ។

បច្ច័យពីរ គឺ ចីវរនិងបិណ្ឌបាត វិញ្ញត្តិការសូមមិនគួរដោយប្រការទាំងពួង ។ ឯក្នុងសេនាសនប្បច្ច័យ សូមថាអ្នកចូរយកមកឲ្យមួយយ៉ាងមិនគួរ បើពោលជា បរិកថា ឱកាស និមិត្តកម្ម ក៏គួរ ។

ចង់បានពោងឧបោសថ ឬពោងធាន់ ឬសេនាសនៈណាមួយ ពោលពាក្យបញ្ជៀងថា ក្នុងឱកាសនេះនឹងធ្វើសេនាសនៈ ដូច្នេះគួរឬ ដូច្នេះ ឈ្មោះថាបរិកថា ។ សួរឧបាសកថា អ្នកនៅក្នុងទីណា គេប្រាប់ថានៅ

ក្នុងប្រាសាទ ពោលតទៅទៀតថា ប្រាសាទមិនគួរដល់ភិក្ខុខ្លះទេឬ ដូច្នេះឈ្មោះថាឱកាស ។ ឃើញមនុស្សមក ឲ្យគេទាញខ្សែនិងឲ្យគេបោះចោះ គេសួរថា លោកម្ចាស់នឹងធ្វើអ្វី ពោលថា នឹងធ្វើអាវាសក្នុងទីនេះ ធ្វើអាការដូច្នេះជាដើម ឈ្មោះថានិមិត្តកម្ម ។ ក្នុងគិលានប្បច្ច័យ សូម្បីវិញ្ញត្តិ សូមគេក៏គួរ ។ បរិកថាជាដើមមិនត្រូវពោល ។

<u>វិញ្ញត្តិកថា</u> ចប់

មេណ្ឌកបញ្ញត្តិ

ខមួយទៀត ព្រះពុទ្ធអង្គ ទ្រង់អនុញ្ញាតទុកក្នុងមេណ្ឌកបញ្ញត្តិ ថា

**សន្តិ ភិក្ខវេ មក្ខា ឆាត្តា ឆាត្តរា អប្បេ ឧកា អប្ប-ភក្ខា ន សុករា អចាវេយ្យេ ឧត្តុំ ។ អនុជានាមិ ភិក្ខវេ ចាវេយ្យំ បរិយេសិតុំ ។ ល ។ សន្តិ ភិក្ខវេ មនុស្សា សទ្ធា បសន្នា តេ ឆប្ប៉ាយការ ការ ជ ហត្ថ ហិរញ្ញសុវណ្ណ ឧបនិក្ខិបន្តិ ។ ល ។ អនុជានាមិ ភិក្ខវេ យ ត ឆ ឆ ឆ ត ។ ល ។ ១ ១ ១

សណ្តែករាជមាស ទឹកអំពៅ ប្រេង ឬសប្ប៊ី ស្វែងរកវត្ថុមានសណ្តែក បាយជាដើមបាន តាមត្រូវការចុះ ។ ម្នាលភិក្ខុទាំងឡាយ បើមានមនុស្សទាំងឡាយដែលមានសទ្ធាជ្រះថ្លា គេទុកដាក់ប្រាក់និងមាសក្នុងដៃនៃកប្បិយការក:ទាំងឡាយថា វត្ថុណាគួរដល់លោកម្ចាស់ អ្នកចូរប្រគេនទូវត្ថុនោះ ដោយទ្រព្យនេះចុះ ដូច្នេះ ។ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរចំពោះវត្ថុជាកប្បិយ (ដែលកើត) អំពីមាសប្រាក់នោះបាន ម្នាលភិក្ខុទាំងឡាយ តែថា តថាគតមិនពោលថា ត្រូវអ្នកត្រេកអរ ត្រូវអ្នកស្វែងរកមាសនិងប្រាក់ដូច្នេះ ដោយបរិយាយណាមួយឡើយ ក្នុងការស្វែងរកស្បៀងនោះ ។ អដ្ឋកថា ពោលថាបើទាយកជំពូកខ្ទះគេដឹង គេថ្វាយឯងក៏ជាការល្អ បើគេមិនថ្វាយសោត គប្បីស្វែងរកអំពីញាតិ អំពីមនុស្សបវារណា ឬដោយកិច្ចាចារវត្ត ។ កាលបើមិនបានដោយប្រការដូច្នេះ អដ្ឋកថាចារ្យលោកពោលថា គប្បីសូមអំពីបុគ្គលមិនមែនញាតិ មិនមែនបវារណា កាន់យកចុះ ។ ផ្លូវនឹងគប្បីទៅត្រឹមមួយថ្ងៃ គប្បីស្វែងរកដើម្បីបាយក្នុងមួយវេលា ។ ផ្លូវដាច់ស្រយាលឆ្ងាយ ជាផ្លូវកន្ដារ: ស្បៀងប៉ុន្ដានទើបល្មមគ្រាន់ ស្វែងរកប៉ុណ្ណោះបាន ។ ក្នុងកប្បិយការក:ទទួលមាសប្រាក់ទុកនោះ បើម្ចាស់របស់ដើមគេប្រាប់ឲ្យភិក្ខុដឹង ឬគេប្រើទូតឲ្យទៅប្រាប់ ភិក្ខុមិនត្រេកអរនឹងតម្លៃ ត្រេកអរតែកប្បិយកណ្ដាមួយយ៉ាង នឹងទារសូម្បីមួយពាន់ដងក៏គួរ មិនមានកំណត់ដូចក្នុងរាជសិក្ខាបទ ។ បើកប្បិយការក:នោះ គេមិនឲ្យកប្បិយកណ្ដាសោត គប្បីតាំងមនុស្សដទៃឲ្យជាកប្បិយការក:នាំមកក៏បាន បើភិក្ខុ

នៅចង់បាន ក៏គប្បីប្រាប់ដល់ម្ចាស់របស់តម្លៃដើម បើមិនចង់បានសោត កុំគប្បីប្រាប់ឡើយ កប្បិយការក:ដែលម្ចាស់តម្លៃមិនបានប្រាប់ដល់ភិក្ខុ ឬមិនបានផ្តាំទូតឲ្យប្រាប់ដល់ភិក្ខុ គ្រាន់តែគេឲ្យគ្នាឯងចំពោះមុខភិក្ខុឬកំពាំងមុខភិក្ខុហើយគេក៏ទៅ ក្នុងកប្បិយការក:ដូច្នេះ គប្បីបដិបត្តិដូចមនុស្ស មិនមែនញាតិ មិនមែនបវារណា បើគេឲ្យកប្បិយកណ្ណដោយខ្លួនឯង ក៏គប្បីទទួល បើគេមិនឲ្យ កុំគប្បីពោលពាក្យអ្វីឡើយ ។

មេណ្ឌកបញ្ញត្តិ ចប់

គោបកទានកថា

ខមួយ ទ្រង់អនុញ្ញាតទុកក្នុងវិនីតវត្ថុនៃអទិន្នាទានថា **អនាបត្តិ ភិក្ខវេ គោបកស្ស ទានេ** ថាមិនត្រូវអាបត្តិ ព្រោះមនុស្ស រក្សាសួនគេឲ្យ ។ អ្នករក្សាសួនគេឲ្យដូចម្តេចទើបគួរ? ឲ្យដូចម្តេចមិនគួរ? ព្រះមហាសុមនត្ថេរពោលថា របស់ណាមួយម្ចាស់របស់គេកំណត់ឲ្យ មនុស្សអ្នករក្សាថា អ្នកចូរកាន់យកតែប៉ុណ្ណោះសព្វថ្ងៃ១ របស់នោះគួរ ច្រើនលើសជាងនោះមិនគួរ ។ តែព្រះមហាបទុមត្ថេរពោលថា ម្ចាស់ របស់គេធ្វើសំបុត្រ ឬធ្វើនិមិត្តកំណត់ឲ្យដល់មនុស្សអ្នកនៅរក្សា ឬម្ចាស់ របស់គេប្រគល់ឲ្យជាធំ ក្នុងរបស់ដែលគេលះទុកក្នុងដៃនៃអ្នករក្សា ព្រោះ ហេតុនោះ មនុស្សអ្នករក្សាឲ្យរបស់ណា របស់នោះសូម្បីច្រើនក៏គួរ ។ ក្នុង អដ្ឋកថាកុរុន្ទីពោលថា កូនក្មេងរក្សាសួនឬផលាផលដទៃ ជារបស់មនុស្ស

របស់ដែលក្មេងឲ្យនោះក៏គួរ តែកុំបង្គាប់ឲ្យក្មេងយកមកឲ្យ ។ អ្នករក្សាសួនរបស់សង្ឆ ឬរបស់ចេតិយ កាលបើទៅនៅរក្សា គេឲ្យក៏គួរ អ្នកស៊ីឈ្នួលរក្សាឲ្យតែចំណែកដែលដល់ខ្លួនទើបគួរ ។ ក្នុងមហាបច្ចរី ថាមនុស្សរក្សាសួននៃគ្រហស្ថ គេឲ្យចំណែកណាដល់ភិក្ខុ ចំណែកនោះគួរ ឯមនុស្សជាអ្នករក្សាសួនរបស់សង្ឆ គេបែងចំណែករបស់ណាអំពីថ្ងៃឈ្នួលខ្លួនមកឲ្យ ចំណែកនោះទើបគួរ សម្បីអ្នកណាស៊ីឈ្នួលរក្សាសួន ពាក់កណ្តាលចំណែក ឬដើមឈើមួយដើម អ្នកនោះឲ្យចំណែកអំពីដើមឈើដែលដល់ខ្លួនទើបគួរ បើអ្នករក្សាសួននៅរក្សាហើយឲ្យ គួរទាំងអស់ ពាក្យទាំងអម្បាលនោះផ្សេងអំពីគ្នាតែញ្ញនៃ: ឯសេចក្តីក៏ដូចគ្នា ព្រោះហេតុនោះ អ្នកមានបញ្ញាគប្បីដឹងអធិប្បាយ កាន់យកចុះ ។

មួយទៀត គប្បីដឹងវិនិច្ឆ័យ ក្នុងការបរិភោគផលដូច្នេះ ក្នុងទីណាចៅអាវាសមិនឲ្យដល់អាគន្តុក: កាលបើវារ:ផ្ទៃឈើដល់ហើយ ឃើញថាភិក្ខុដទៃមិនមាន ទើបចែកគ្នាធាន់តែពួកខ្លួនក្នុងទីនោះ អាគន្តុក:ទាំង-ឡាយ នឹងវាយរគាំងហើយចែកគ្នាធាន់ក៏គួរ ក្នុងទីណាចៅអាវាសរក្សាដើមឈើ កាលបើវារ:ផ្ទៃឈើចូលមកដល់ហើយចែកគ្នាធាន់ នឹងបង្ហោនចូលទៅដោយប្រពៃក្នុងបច្ច័យទាំង ៤ ក្នុងទីនោះ អាគន្តុក:មិនបានជាធំ ។ សម្បីដើមឈើណាគេនិយមថ្វាយដើម្បីជាតម្លៃចីវរ ដើមឈើនោះ អាគន្តុក: ក៏មិនបានជាធំ ក្នុងដើមឈើដែលគេនិយមថ្វាយដើម្បីជាតម្លៃបច្ច័យដ៏សេស ក៏ដូចគ្នាដែរ ។ តែដើមឈើណាគេមិនបាននិយមដូច្នោះ

តែចៅអាវាសរក្សាហួងហែងដើមឈើនោះ លបធាន់ផ្ទៃក្នុងដើមឈើនោះ អាគន្ដុក:កុំគប្បីតាំងនៅក្នុងកតិកានៃចៅអាវាសឡើយ ។ ដើមឈើណា គេនិយមថ្វាយដើម្បីបរិភោគផ្ទៃ តែចៅអាវាសរក្សាហួងហែងទុក ហើយ បង្ហោនចូលទៅដោយប្រពៃក្នុងបច្ច័យ ក្នុងដើមឈើនោះ អាគន្ដុក:គប្បី តាំងនៅក្នុងកតិកានៃចៅអាវាស ។ តែក្នុងមហាបច្ចរី ថាដើមឈើគេនិយម ថ្វាយដើម្បីបច្ច័យ ៤ បើលួចធាន់ដោយចេយ្យចិត្ត ឲ្យវិន័យធរគប្បីវាយ ថ្ងៃរបស់ហើយកាត់អាបត្តិដល់ភិក្ខុ កាលបើភិក្ខុចែកគ្នាធាន់ដោយអំណាច បរិភោគ ជាកណ្ដូទេយ្យ តែដើមឈើណាគេនិយមដើម្បីសេនាសន: ដើមឈើនោះ កាលបើចែកគ្នាធាន់ដោយអំណាចបរិភោគ ត្រូវចុលច្ច័យ ផង ជាកណ្ដូទេយ្យផង ។ ដើមឈើគេឧទ្ទិសថ្វាយដើម្បីជាតម្ងៃចីវរ គប្បីបង្ហោនចូលទៅក្នុងចីវរតែមួយយ៉ាង ។ បើស្រ្ដីវ ភិក្ខុលំបាកដោយ បិណ្ឌបាត តែចីវរកបានងាយ នឹងធ្វើអបលោកនកម្មដើម្បីសង្ឆឃើញ ថាប្រពៃ ហើយបង្ហោនចូលទៅក្នុងបិណ្ឌបាតក៏គួរ ។ កាលបើភិក្ខុលំបាក ដោយសេនាសន: ឬគិលានប្បច្ច័យ នឹងធ្វើអបលោកនកម្មដើម្បីសង្ឆ ឃើញថាល្អ ហើយបង្ហោនចូលទៅដើម្បីបច្ច័យនោះក៏គួរ ។ សូម្បីរបស់ គេឧទ្ទិសថ្វាយ ដើម្បីជាតម្ងៃបិណ្ឌបាតឬគិលានប្បច្ច័យ ក៏ដូចគ្នាយ៉ាង នោះ ។ តែរបស់គេឧទ្ទិសថ្វាយ ដើម្បីជាតម្ងៃសេនាសន:ជាគរុកណ្ដ គប្បីរក្សាហួងហែងទុក ហើយបង្ហោនចូលទៅដើម្បីសេនាសន:ប៉ុណ្ណោះ បើស្រ្ដីវ ភិក្ខុទាំងឡាយចិញ្ចឹមជីវិតដោយបិណ្ឌបាតមិនបាន ភិក្ខុទាំង

អម្ចាលនោះចេញទៅកាន់ទីដទៃព្រោះរាជភ័យ ភោគភ័យ ចោរភ័យក្តី វិហារនោះវិនាសទៅ មនុស្សទាំងឡាយធ្វើគ្នោតនិងដូងជាដើមឲ្យវិនាសផង តែបើបានអាស្រ័យសេនាសនប្បច្ច័យអាចចិញ្ចឹមជីវិតក្នុងកាលដូច្នេះ សូម្បីនឹងលះសេនាសនបរិភោគ ដើម្បីនឹងប្រតិបត្តិថែទាំសេនាសន: ព្រះពុទ្ធអង្គទ្រង់អនុញ្ញាត ។ ព្រោះហេតុនោះ សេនាសន: ១ ឬ ២ ដែលអាក្រក់ លើកតែសេនាសន:ដែលល្អចេញ គួរនឹងលះដើម្បីជាតម្លៃបិណ្ឌបាត តែកុំធ្វើឲ្យដាច់ថ្ងៃ តែចំណែកណាដែលគេនិយមថ្វាយដើម្បីបច្ច័យទាំង ៤ ក្នុងចំណែកនោះ មិនត្រូវធ្វើអបលោកនកម្ម ខ្ទះខាតដោយបច្ច័យណា នឹងបង្ហោនទៅដើម្បីបច្ច័យនោះគួរ ។ អ្នកដទៃបដិបត្តិថែទាំសួន សូម្បីនឹងឲ្យថ្ងៃឈ្នួលដល់គេ ឲ្យគេប្រតិបត្តិថែទាំក៏គួរ ។ តែអ្នកណាបានថ្ងៃឈ្នួលហើយធ្វើផ្ទះនៅក្នុងអារាមហើយរក្សាសួន បើអ្នកនោះឲ្យផ្ទែដូងឬគ្នោតដល់ភិក្ខុដែលមកដល់ ចំណែកណាដែលសង្ឆអនុញ្ញាតឲ្យដល់អ្នកនោះ ថាអ្នកចូរស៊ីតែប៉ុណ្ណោះសព្វថ្ងៃ អ្នកនោះឯងឲ្យចំណែកនោះបាន សូម្បីអ្នកនោះនឹងឲ្យច្រើនឡើងទៅជាងនោះ ទទួលមិនគួរ ។ តែអ្នកណាជួលទៅហើយឲ្យកប្បិយកណ្ឌដល់សង្ឆដើម្បីបច្ច័យ ៤ អ្នកនោះនឹងឲ្យសូម្បីច្រើនក៏បាន សូម្បីសួនគេថ្វាយដល់ចេតិយដើម្បីជាតម្លៃប្រទីប ឬសម្រាប់ជួសជុលនូវទីបាក់បែក ត្រូវប្រតិបត្តិថែទាំឬឲ្យឈ្នួលឲ្យគេប្រតិបត្តិថែទាំតែក្នុងសួននោះ នឹងឲ្យឈ្នួលសូម្បីជារបស់ចេតិយនិងសង្ឆក៏គួរ ។ អ្នកនៅរក្សាសួនដោយឈ្នួលនិងអ្នក

ជួលសួន ឲ្យកប្ដាយកណ្ដាក្ដី ឬគេឲ្យផ្ទៃឈើដែលកើតក្នុងសួននោះក្ដី ឲ្យគប្ដីដឹងដោយន័យដូចសម្ដែងមកហើយនោះចុះ ។

គោបកទានកថា ចប់

អារក្ខាយាចនកថា

ពណ៌នាអំពីធម្មិការក្ខា ដែលមានមកក្នុងអនាបត្តិវារៈនៃភិក្ខុនី បឋមសង្ឆាទិសេស ។

សេចក្ដីថា ភិក្ខុកាលបើនឹងសូមអារក្ខា គឺការរក្សាត្រូវតាមគន្ធងធម៌ នឹងប្រារព្ធកាលជាអតីតឬអនាគត ប្រាប់ចំពោះខ្លួនមិនគួរ ប្រារព្ធកាលជាអតីត ប្រាប់ចំពោះក៏មាន មិនចំពោះក៏មាន ប្រារព្ធកាលជា-អនាគត ប្រាប់ចំពោះក៏មាន មិនចំពោះក៏មាន ក្នុងអ្នកស្រុកឬក្នុងអ្នកលេងជាដើមណាមួយ មកប្រព្រឹត្តអនាចារក្នុងវត្ត គឺកាប់ដើមឈើឬលួចផលាផលទៅ ឬដណ្ដើមបរិក្ខារក្នុងវិហារនៃភិក្ខុ ភិក្ខុចូលទៅរកតុលាការពោលថា ក្នុងវិហាររបស់យើង គេមកធ្វើយ៉ាងនេះ។ តុលាការសួរថា អ្នកណា ប្រាប់ថាមនុស្សឯណោះ។ ដូច្នេះឈ្មោះថាប្រារព្ធកាលជាអតីត ប្រាប់ចំពោះខ្លួនមិនគួរ បើតុលាការគេបានឮពាក្យនោះ គេពិន័យដល់អ្នកធ្វើអាក្រក់នោះ របស់ដែលគេពិន័យប៉ុន្មាន ត្រូវភិក្ខុសង្ឆទាំងអស់ សូម្បីកាលបើមានបំណងនឹងឲ្យគេពិន័យលក់ត្រូវតែសង្ឆមួយយ៉ាង បើពោលថា អ្នក

ចូរពិន័យលក់ដល់អ្នកនោះ កាលបើគេលក់យកថ្ងៃ ៥ មាសក:ក៏ត្រូវបារាជិក តែកាលបើតុលាការសួរថា អ្នកណាមកធ្វើអាក្រក់ បើប្រាប់ថាមនុស្ស ឈ្មោះឯណោះៗ ដូច្នេះមិនគួរ ព្រោះតុលាការនឹងដឹង គប្បីពោលថា អាត្មាគ្រាន់តែសូមសេចក្តីរក្សាប៉ុណ្ណោះ លោកចូរឲ្យអារក្ខានោះហើយ ចូរយកកណ្ដាដែលគេលួចយកទៅ មកឲ្យផង ដូច្នេះឈ្មោះថាប្រារព្ធ កាលជាអតីត ប្រាប់មិនចំពោះគួរ ។ កាលបើពោលដូច្នេះ តុលាការគេ ចាប់បានខ្លួនមនុស្សអាក្រក់ ហើយពិន័យលក់ សូម្បីគេកាន់យកទ្រព្យ ទាំងអស់ ភិក្ខុមិនត្រូវសង មិនត្រូវអាបត្តិ ។ ភិក្ខុឃើញចោរលួចយក បរិក្ខារទៅ ប្រាថ្នាវត្ថុមិនជាប្រយោជន៍ដល់ចោរ សូម្បីពោលថាចោរ១ ដូច្នេះមិនគួរ ព្រោះថាកាលពោលដូច្នេះ គេពិន័យលក់របស់ណាដល់ ចោរនោះ ភិក្ខុត្រូវសងរបស់ពិន័យទាំងអស់ តែនឹងពោលជាមួយនឹង មនុស្សអ្នកធ្វើតាមពាក្យរបស់ខ្លួនថាបរិក្ខាររបស់យើង មនុស្សឈ្មោះនេះ គេកាន់យកទៅ អ្នកចូរឲ្យគេយកបរិក្ខារនោះមកឲ្យ តែអ្នកកុំពិន័យលក់ ដល់គេឡើយ ដូច្នេះក៏គួរ ។ កើតក្តីនឹងគ្នា ដើម្បីទាសាទាសីជាដើមឈ្មោះ ថាក្តីជាអកប្បិយ មិនគួរ ។ មនុស្សដទៃមកធ្វើអនាចារជាដើមក្នុងវិហារដូច ពោលហើយ ប្រាប់ដល់តុលាការថា គេមកធ្វើយ៉ាងនេះ១ ក្នុងវិហារ លោក ចូរឲ្យសេចក្តីរក្សាដើម្បីនឹងមិនឲ្យធ្វើតទៅទៀត ដូច្នេះកាលបើតុលាការ សួរថា អ្នកណាធ្វើយ៉ាងនេះ ភិក្ខុប្រាប់ថាមនុស្សឈ្មោះឯណោះ១ ដូច្នេះ ឈ្មោះថាប្រារព្ធកាលជាអនាគត ប្រាប់ចំពោះដូច្នេះក៏មិនគួរ ។ ដ្បិត

ថា កាលបើគេពិន័យដល់អ្នកធ្វើអាក្រក់នោះ ភិក្ខុត្រូវសងរបស់ពិន័យទាំងអស់ដូចន័យមុន រិនិច្ឆ័យក្រៅនោះដូចពោលហើយក្នុងបទមុន ។ បើតុលាការគេប្រកាសទុកថា យើងនឹងពិន័យយ៉ាងនេះ ដល់អ្នកធ្វើអាក្រក់យ៉ាងនេះ ក្នុងវិហាររបស់ភិក្ខុ ហើយគេស្វែងរកមនុស្សដែលមិនបានតាំងនៅតាមអាជ្ញា បានខ្ជួនហើយពិន័យលក់ ភិក្ខុមិនត្រូវសង មិនត្រូវអាបត្តិឡើយ ។ មនុស្សដទៃកាប់ដើមឈើជាដើមក្នុងទីវត្ត ភិក្ខុនឹងដណ្តើមយកកាំបិតនិងប៉ូវថៅជាដើម មកគប់ឬវាយបំបែកដោយសិលាមិនគួរ បើមុខធ្លៃបទៅ គប្បីធ្វើឲ្យគេ ឬស្ទុះទៅដណ្តើមយកបរិក្ខាររបស់អ្នកមកកាប់ដើមឈើនោះ សូម្បីដូច្នេះ ក៏កុំគប្បីធ្វើ ដ្បិតថាចិត្តប្រែប្រួលទៅរហ័សណាស់ កាលបើវេយ្យាចេតនាកើតឡើង ក៏នឹងដល់នូវមូលច្ចេទ ដាច់ឫសទៅផង ។

<u>អារក្ខាយចនកថា</u> ចប់

បរិភោគកថា

ពណ៌នាអំពីការបរិភោគដែលមានមកក្នុងអដ្ឋកថានៃរូបិយសិក្ខាបទ

សេចក្តីថា បរិភោគមាន ៤ គឺ លជ្ជីបរិភោគ គប់ជាមួយលជ្ជី ១ អលជ្ជីបរិភោគ គប់ជាមួយអលជ្ជី ១ ធម្មិយបរិភោគ បរិភោគរបស់ដែលកើតឡើងប្រកបដោយធម៌ ១ អធម្មិយបរិភោគ បរិភោគរបស់ដែលកើតឡើងមិនប្រកបដោយធម៌ ១ ជា ៤ ។ ភិក្ខុជាអលជ្ជី បរិភោគជាមួយនឹងភិក្ខុ

លជ្ជីគួរ ព្រះវិន័យធរកុំគប្បីកាត់អាបត្តិ លជ្ជីបរិភោគជាមួយអលជ្ជី ភិក្ខុ លជ្ជីមិនបានដឹងដរាបណា ក៏គួរដរាបនោះ ។ ដ្បិតថាភិក្ខុដែលឈ្មោះថា អលជ្ជីមកអំពីដើមក៏មិនមាន ព្រោះហេតុនោះ ភិក្ខុលជ្ជីដឹងថាភិក្ខុនោះ អលជ្ជីកាលណា គប្បីឃាត់ភិក្ខុនោះចេញកាលនោះ ថាអ្នកកុំប្រព្រឹត្ត កន្ទ្ធ១សិក្ខាបទក្នុ១កាយទ្វារនិ១វចីទ្វារ កម្មដូច្នេះមិនសមគួរ អ្នកកុំធ្វើឡើយ បើភិក្ខុនោះមិនអើពើចចេសតែធ្វើ ទោះបីអ្នកលជ្ជីក៏នៅធ្វើការបរិភោគ ជាមួយនឹ១ភិក្ខុនោះ ភិក្ខុជាលជ្ជីនោះក៏ជាអលជ្ជីទៅផ១គ្នាដោយពិត ។ ភិក្ខុណាបរិភោគជាមួយនឹ១អលជ្ជី ដែលជាមនុស្សទទួលការ:របស់ខ្លួន សូម្បីភិក្ខុនេះឲ្យភិក្ខុជាលជ្ជីគប្បីហាមប្រាម បើភិក្ខុអលជ្ជីមិនលះចេញទេ ភិក្ខុលជ្ជីនេះក៏ទៅជាអលជ្ជីដូចគ្នា ហេតុនោះ១ង អលជ្ជីម្នាក់ ធ្វើភិក្ខុដទៃ ឲ្យទៅជាអលជ្ជីបានរាប់រយ តែអលជ្ជីនិ១អលជ្ជី បរិភោគជាមួយគ្នាមិនត្រូវ អាបត្តិ ។ លជ្ជីនិ១លជ្ជីបរិភោគជាមួយគ្នាល្អរុ១រឿ១ដូចខត្តិយកុមារទាំ១ពីរ សោយរួមភាជន:ជាមួយគ្នា ។ ធម្មិយបរិភោគនិ១អធម្មិយបរិភោគពីរនេះ គប្បីដឹ១តាមបច្ច័យ បើបុគ្គលជាអលជ្ជីផ១ បិណ្ឌបាតក៏មិនប្រកបដោយ ធម៌ផ១ គប្បីខ្ពើមទាំ១ពីរចំណែក ។ បុគ្គលជាអលជ្ជី តែបិណ្ឌបាតប្រកប ដោយធម៌ គប្បីខ្ពើមតែបុគ្គល កុំគប្បីទទួលបិណ្ឌបាត ។ ក្នុ១មហាបច្ចរី ពោលថា ភិក្ខុទ្រុស្តសីល បានឧទ្ទេសភត្តជាដើម អំពីសង្ឆមកថ្វាយ ដល់សង្ឆ បិណ្ឌបាតជាដើមនោះគួរ ព្រោះថា កាលដើមជារបស់ សង្ឆហើយត្រឡប់ទៅជារបស់សង្ឆទៀត ។ បុគ្គលជាលជ្ជី តែបិណ្ឌបាត

មិនប្រកបដោយធម៌ បិណ្ឌបាតជារបស់គួរខ្ពើម កុំគប្បីទទួល ។ បុគ្គលជាលជ្ជី បិណ្ឌបាតក៏ប្រកបដោយធម៌ផង ទើបគួរ ។ សេចក្តីកាន់ទ្រង់ទៀតមានពីរយ៉ាងគឺ លជ្ជីបគ្គហៈ កាន់ទ្រង់លជ្ជី ១ អលជ្ជីបគ្គហៈ កាន់ទ្រង់អលជ្ជី ១ ។ ឯបរិភោគទៀតមានពីរគឺ ធម្មបរិភោគ បរិភោគរួមធម៌ ១ អាមិ-សបរិភោគ បរិភោគរួមអាមិស ១ ។ អលជ្ជីនឹងកាន់ទ្រង់លជ្ជីគួរ វិន័យធរកុំគប្បីកាត់អាបត្តិដល់ភិក្ខុនោះ ។ បើលជ្ជីកាន់ទ្រង់អលជ្ជី គប្បីដឹងថាគឺនិមន្តឲ្យអនុមោទនា ឲ្យសម្តែងធម៌ នឹងឧបត្ថម្ភក្នុងត្រកូលទាំងឡាយ សូម្បីអលជ្ជីក៏នឹងសរសើរគុណនៃលជ្ជីនោះ ក្នុងពពួកនៃបរិស័ទថាអាចារ្យនៃខ្ញុំល្អដូច្នេះៗ គប្បីដឹងចុះថា ភិក្ខុជាលជ្ជីនេះ ធ្វើសាសនាឲ្យទន់ទាបឲ្យសាបសូន្យទៅ ។ ក៏ឯក្នុងធម្មបរិភោគនិងអាមិសបរិភោគនោះ រួមអាមិសគួរក្នុងអ្នកណា សូម្បីរួមធម៌ក៏គួរក្នុងអ្នកនោះផង តែគម្ពីរណាតាំងនៅក្នុងទីបំផុត មានតែមនុស្សទ្រុស្តសីលទ្រទ្រង់ទុក កាលបើកន្ទ្ងមនុស្សទ្រុស្តសីលនោះហើយនឹងវិនាស នឹងរៀនយកគម្ពីរនោះ ក្នុងសំណាក់មនុស្សទ្រុស្តសីលដោយអនុគ្រោះដល់ធម៌ លោកពោលថាគួរ ។

ដូចបានឮថា ភិក្ខុទ្រុស្តសីលមួយអង្គ ទ្រង់គម្ពីរមហានិទ្ទេសស្ទាត់តែម្នាក់ឯង មិនមានអ្នកដទៃទ្រទ្រង់ទុកបាន ព្រះតិស្សត្ថេរជាឧបជ្ឈាយ៍បង្គាប់មហារក្ខិតត្ថេរឲ្យទៅរៀន លោកទៅរៀនមួយថ្ងៃចប់គម្ពីរមហា-និទ្ទេស ហើយបានឃើញស្ត្រីនៅក្រោមគ្រែ ។

បរិភោគកថា ចប់

វត្តកថា

ពណ៌នាអំពីវត្ត ១៤ មានអាគន្ទុកវត្តជាដើម ។ សម្តេចព្រះពុទ្ធអង្គ ទ្រង់បញ្ញត្តទុកថា ភិក្ខុអាគន្ទុក:ជាដើម គប្បីបដិបត្តិប្រពៃដោយប្រការ ដូចម្តេច តថាគតនឹងបញ្ញត្តអាគន្ទុកវត្តជាដើម ដោយប្រការដូច្នោះ ។

អាគន្ទុកវត្ត

វត្តរបស់ភិក្ខុអ្នកមកដល់ថ្មី ។ សេចក្តីថា អាគន្ទុក:មកអំពីវត្តដទៃ មកជិតឧបចារសីមានៃអាវាម ដែលខ្ជិនបំណងនឹងចូលទៅ គប្បីធ្វើសេចក្តីគោរព បើពាក់ស្បែកជើងមក គប្បីដោះស្បែកជើងនោះ បោសធូលីចេញ ហើយពាក់លើឈើច្រត់កាន់ចូលទៅ បើបាំងច័ត្រមកគប្បីតម្លោះចេញ បើទទួរក្បាលមកគប្បីបើកចេញ បើយកសំពត់ចីវរដាក់លើសិរសាមកគប្បីយកចុះចេញពាក់លើស្មា អំពីក្រៅឧបចារ:នៃអាវាមឲ្យហើយ កុំប្រញាប់ គប្បីសន្សឹមៗ ចូលទៅក្នុងអាវាមដោយប្រពៃ កាលបើចូលទៅគប្បីកំណត់ថា ភិក្ខុចៅអាវាសប្រជុំគ្នានៅក្នុងទីណា ក្នុងរោងធាន់ ឬមណ្ឌប ឬគល់ឈើ ហើយគប្បីទៅក្នុងទីនោះ លុះទៅដល់ហើយ គប្បីតម្កល់បាត្រទុកក្នុងទីម្ខាង តម្កល់ចីវរទុកក្នុងទីម្ខាង គប្បីកាន់យកអាសន:ដ៏សមគួរ ហើយសឹមអង្គុយចុះ គប្បីសួរទឹកធាន់និងទឹកប្រើ ថាឯណាទឹកធាន់ ឯណាទឹកប្រើ បើត្រូវការដោយទឹកធាន់ គប្បីកាន់យកធាន់ បើត្រូវការដោយទឹកប្រើ គប្បីកាន់យកលាងជើង កាលបើលាង គប្បីស្រោចដោយ

ដៃម្ខាង លាងជើងដោយដៃម្ខាង ស្រោចទឹកដោយដៃខាងណា កុំលាងជើងដោយដៃខាងណោះ លាងជើងដោយដៃខាងណា កុំស្រោចទឹកដោយដៃខាងណោះ ហើយគប្បីសួរកសំពត់ជូតស្បែកជើងនឹងចៅអាវាស ហើយគប្បីយកមកជូតស្បែកជើង កាលជូតស្បែកជើង គប្បីយកសំពត់ស្ងួតជូតមុន ហើយសឹមយកសំពត់ទទឹកជូតជាខាងក្រោយ ហើយគប្បីគក់សំពត់នោះចេញ ពូតរលាស់ហាលទុកក្នុងទីម្ខាង ។ បើភិក្ខុចៅអាវាសចាស់ជាងគប្បីក្រាបសំពះភិក្ខុចៅអាវាសនោះ បើចៅអាវាសខ្ចីវស្សាជាងក៏គប្បីឲ្យសំពះខ្លួន គប្បីសួរសេនាសនៈថា សេនាសនៈណាគួរដល់ខ្ញុំ ហើយគប្បីសួរថា សេនាសនកុដិនោះភិក្ខុអាស្រ័យនៅខ្លះ ឬមិនបានអាស្រ័យនៅ គប្បីសួរគោចរគ្រាម ទីកិក្ខាចារថាជិតឬឆ្ងាយ នឹងត្រូវទៅពីព្រឹកឬថ្ងៃ គប្បីសួរទីអគោចរ គឺស្រុកនៃមិច្ឆាទិដ្ឋិ និងស្រុកដែលគេកំណត់ភិក្ខុ ឲ្យតែបន្ដិចបន្ដួចប្រមាណមួយវែក ឬឲ្យតែមួយអង្គឬពីរអង្គ គប្បីសួរសេក្ខត្រកូល ដែលសង្ឃសន្ធតទុក គប្បីសួរទីបន្ទោបង់ឧច្ចារៈ បស្សាវៈ គប្បីសួរទឹកប្រើ ទឹកធាន់ ថាទឹកទាំងប្រើទាំងធាន់ក្នុងស្រះបោក្ខរណីតែមួយនេះទេឬ គប្បីសួរទីតាំងទុកឈើច្រត់និងកតិកានៃសង្ឃ ក្នុងទីខ្លះដែលមានសត្វកាចឬអមនុស្សនៅ ។ គប្បីសួរថា ទៅនិងចូលវេលាណា ចេញវេលាណា បើកុដិនៅទំនេរ គប្បីគោះសន្ទឹកទ្វារ ឈរវង់ចាំមួយរំពេច ហើយដកចន្ទាស់ច្រានសន្ទឹកទ្វារឈរនៅខាងក្រៅ ក្រឡេកមើលផ្ទូវពស់ឬអមនុស្ស ដែលនឹងចេញមកឲ្យសព្វគ្រប់ ។ បើកុដិនោះមាន

សំរាម គ្រែតម្រួតនៅលើគ្រែ តាំងតម្រួតនៅលើតាំង ខាងលើសេនា-
សន:ពេញពាសទៅដោយសំបុកសរសៃពីងពាង បើអាចនឹងសម្អាតបាន
គប្បីសម្អាតឲ្យល្អ កាលបើមិនអាចនឹងសម្អាតបាន គប្បីសម្អាតតែទី
លំនៅរបស់ខ្លួន បើអាចសម្អាតឲ្យស្អាតទាំងអស់បានសោត ក៏គប្បីសម្អាត
ដោយន័យដូចពោលក្នុងសេនាសនវត្ត តាំងអំពីជញ្ជូនគ្រឿងកម្រាលលើ
ផ្ទៃចេញ ហើយបដិបត្តិដូចន័យសេនាសនវត្ត ដែលនឹងពោលខាងមុខ
រហូតដល់សេចក្តីថា បើទឹកក្នុងភាជន:គ្មាន គប្បីដងមកទុកជាក់ដូច្នេះ
នេះឯងជាវត្តនៃភិក្ខុជាអាគន្តុក: គឺភិក្ខុជាអាគន្តុក: គប្បីបដិបត្តិដោយ
ប្រពៃ ថាបើអាស្រ័យសេចក្តីមិនអើពើនឹងបដិបត្តិតាម ត្រូវអាបត្តិទុក្កដ
ក្នុងខណ:ដាក់ចិត្តថាមិនធ្វើតាម គប្បីដឹងដូច្នេះ គ្រប់ៗ វត្តចុះ ។

អាគន្តុកវត្ត ចប់

អាវាសិកវត្ត

វត្តរបស់ភិក្ខុចៅអាវាស ។ សេចក្តីថា ភិក្ខុចៅអាវាសបានឃើញភិក្ខុ
អាគន្តុក:ចាស់ជាងខ្លួនមកដល់ គប្បីក្រាលអាសន: តម្កល់ទឹកលាងជើង
តម្កល់តាំងរងជើងក្បឿងជូតជើងទុករង់ចាំមុន ហើយក្រោកទៅទទួលបាត្រ
ចីវរ ហើយគប្បីសួរដោយទឹកធាន់ទឹកប្រើ បើឧស្សាហ៍មានគប្បីជូតស្បែក
ជើងឲ្យ កាលជូតគប្បីជូតដោយសំពត់ស្ងួតជាមុន ហើយសឹមជូត ដោយ
សំពត់ទទឹកជាឯក្រោយ ហើយគប្បីគក់សំពត់នោះពូតរលាស់ហាលទុក
ក្នុងទីសមគួរ គប្បីក្រាបសំពះអាគន្តុកភិក្ខុដែលចាស់ គប្បីរៀបចំក្រាល

សេនាសនៈ ហើយប្រាប់ថា សេនាសនៈនោះបានដល់លោក បើអាគន្ដុកៈខ្ជីជាងខ្លួន គប្បីអង្គុយប្រាប់ថា លោកចូរដាក់បាត្រក្នុងទីនោះ ដាក់ចីវរក្នុងទីនោះ នេះជាទីអង្គុយ ចូរអង្គុយចុះ គប្បីប្រាប់ទឹកប្រើ ទឹកធាន់ និងសំពត់ជូតស្បែកជើង គប្បីឲ្យអាគន្ដុកភិក្ខុដែលខ្ជីវស្សាជាង ក្រាបសំពះខ្លួន គប្បីប្រាប់សេនាសនៈ ថាសេនាសនៈនោះគួរដល់លោក តទៅទាំងចាស់ទាំងខ្ជី គប្បីប្រាប់សេនាសនៈដែលមានអ្នកគ្រប់គ្រងមក ហើយ ឬមិនមានគេគ្រប់គ្រងមកហើយ ហើយគប្បីប្រាប់គោចរគ្រាមនិង អគោចរគ្រាម ប្រាប់សេក្ខត្រកូលដែលបានសន្ដតអំពីសង្ឆ ប្រាប់ទីបន្ទោ-បង់ឧច្ចារបស្សាវៈ ទឹកប្រើទឹកធាន់ និងឈើច្រត់ ប្រាប់កតិកាសង្ឆដែល តាំងទុកថាគប្បីចូលក្នុងកាលនេះ ចេញក្នុងកាលនេះដូច្នេះ ។ កាលដែល អាគន្ដុកភិក្ខុចាស់ជាងមកដល់ហើយ សូម្បីកំពុងធ្វើចីវរកម្មឬនវកម្ម ក៏ គប្បីបញ្ឈប់សិន ធ្វើអាគន្ដុកវត្ដទាំងពួងទៅចុះ កាលកំពុងបោសលាន ចេតិយគប្បីទុកអំបោសសិន ប្រារព្ធដើម្បីនឹងធ្វើអាគន្ដុកវត្ដដល់ភិក្ខុចាស់ បើអាគន្ដុកៈជាអ្នកឈ្វាសក៏នឹងពោលថា លោកចូរបោសលានព្រះចេតិយ ទៅសិនចុះ ។ កាលកំពុងធ្វើថ្នាំឲ្យភិក្ខុមានជំងឺ បើជំងឺមិនធ្ងន់ទេ កុំអាល ធ្វើថ្នាំ គប្បីធ្វើវត្ដដល់អាគន្ដុកៈសិន តែបើឈឺជាទម្ងន់ គប្បីធ្វើថ្នាំសិន បើអាគន្ដុកៈជាអ្នកឈ្វាសសោត ក៏នឹងពោលថាលោកចូរធ្វើថ្នាំសិនចុះ ។ ដែលសួរដោយទឹកធាន់នោះ បើយកមកឲ្យតែម្ដង អាគន្ដុកៈក៏ធាន់អស់ទៅ គប្បីសួរទៀត ។ មួយទៀត កាលបក់គប្បីបក់ឲ្យ គប្បីបក់ពីខាងខ្នងជើង

អស់រ:ម្ដង កណ្ដាលខ្ជនអស់រ:ម្ដង សិរសាអស់រ:ម្ដង បើលោកឃាត់ គប្បីបក់ឲ្យស្រាលចុះ បើលោកឃាត់ម្ដងទៀត គប្បីបក់ឲ្យស្រាលចុះជាង នោះ បើឃាត់ជាគម្រប់៣ គប្បីដាក់ផ្ងិតចុះ ។ គប្បីលាងជើងឲ្យអាគន្ដុក:ផង បើប្រេងរបស់ខ្ជនមាន គប្បីយកមកលាបជើងឲ្យ បើមិនមានទេ គប្បីយក ប្រេងអាគន្ដុក:នោះលាបឲ្យ ឯការជូតស្បែកជើងនោះ គប្បីធ្វើតាមចូល ចិត្ដខ្ជនចុះ បើមិនជូតឲ្យ ក៏មិនត្រូវអាបត្ដិ ព្រោះក្នុងបាលីពោលទុកថា **សចេ ឧស្សហតិ ឧចាហាបា បុញ្ជិតញ្ជ** *កាលបើឧស្សាហ៍ គប្បីជូតស្បែកជើងឲ្យ ។ បើអាគន្ដុក:សួររកសេនាសន: ត្រូវក្រាល បោសច្រាសហើយសឹមប្រាប់ទើបគួរ សេចក្ដីនេះសម្ដែងចំពោះអាគន្ដុក: ចាស់ជាង ។ បើអាគន្ដុក:ខ្ចីជាងខ្ជន គប្បីអង្គុយនៅលើអាសន:ប្រាប់ថា លោកចូរកាន់យកទឹកធាន់នោះធាន់ចុះ ដូច្នេះជាដើមទៅ ។*

បើអាវាសធំ អាគន្ដុក:មកដល់សំណាក់ខ្ជន នឹងមិនធ្វើវត្ដនោះមិន បាន នេះជាវត្ដនៃភិក្ខុចៅអាវាស ភិក្ខុចៅអាវាស គប្បីប្រព្រឹត្ដដោយ ប្រពៃចុះ ។

អាវាសិកវត្ត ចប់

កមិកវត្ត

វត្ដរបស់ភិក្ខុអ្នកធ្វើដំណើរ ។ សេចក្ដីថា គមិកភិក្ខុ ភិក្ខុអ្នកនឹងចេញ ចាកអាវាសទៅកាន់ទីដទៃ គប្បីទុកដាក់គ្រឿងឈើមានគ្រែនិងតាំងជាដើម

ដែលជារបស់សង្ឆ និងគ្រឿងដី ហើយបិទទ្វារ បិទបង្ហួច ប្រគល់សេនា-
សនៈឲ្យស្រេច បើមិនមានភិក្ខុ គប្បីប្រគល់ឲ្យសាមណេរ បើសាមណេរ
មិនមាន គប្បីប្រគល់ឲ្យអ្នករក្សាវត្ត បើអ្នករក្សាវត្តមិនមាន គប្បីប្រាប់
ដល់ឧបាសក បើមិនមានអ្នកណាមួយ គប្បីតម្កល់ត្រែលើដុំសិលា ៤ ដុំ
ហើយលើកត្រែតម្រួតលើត្រែ តាំងតម្រួតលើតាំង ដាក់គ្រឿងសេនាសនៈ
នេះមានពួកខ្ទើយជាដើមទុកខាងលើ ទុកដាក់គ្រឿងឈើ គ្រឿងដី បិទ
ទ្វារបង្ហួចហើយសឹមជៀសចេញទៅ បើកុដិភ្ជៀងលេចបាន កាលអាចនឹង
ប្រក់បានគប្បីប្រក់ ឬគប្បីធ្វើឧស្សាហ៍ថាធ្វើម្តេចគប្បីនឹងប្រក់បាន បើ
បានយ៉ាងនេះជាការល្អ បើមិនបានសោតគប្បីតម្កល់ត្រែលើដុំថ្ម ៤ ដុំ ទុក
ក្នុងឱកាសដែលភ្ជៀងមិនបានលេច ហើយរៀបចំទុកដាក់ដូចមុននោះចុះ
បើកុដិវិហារទាំងអស់ភ្ជៀងលេចបាន កាលអាចនឹងនាំទៅបាន ក៏គប្បីនាំ
សេនាសនៈទៅផ្ញើទុកក្នុងស្រុក ឬគប្បីធ្វើឧស្សាហ៍ថា ដូចម្តេចនឹងគប្បីនាំ
សេនាសនៈចូលទៅផ្ញើទុកក្នុងស្រុកបាន បើបានដូច្នេះជាការល្អ បើមិន
បានទេ គប្បីតម្កល់ត្រែតាំងលើដុំសិលា ៤ ដុំក្នុងទីវាល ហើយរៀប
ទុកដាក់របស់ទាំងពួងដូចមុន ហើយគ្របដោយស្មៅឬស្លឹកឈើ ហើយ
សឹមជៀសទៅដោយគិតថា ធ្វើម្តេចហ្ន៎ សូម្បីអវយវៈមានមេត្រែ មេ
តាំងជាដើមនឹងគប្បីសល់នៅខ្ទះដូច្នេះ ។ សេនាសនៈដែលត្រូវប្រគល់នោះ
ចំពោះតែសេនាសនៈដែលធ្វើដោយស្មៅនិងស្លឹកឈើ ដែលគួរកណ្តៀរ
កាត់និងឡើងបាន សេនាសនៈណាគេធ្វើលើខ្នងសិលា ឬលើសសរថ្ម

ក្នុងទីដែលកណ្តៀរឡើងមិនបាន សេនាសនៈនោះ សូម្បីមិនប្រាប់ មិនប្រគល់ហើយទៅ ក៏មិនត្រូវអាបត្តិ នេះជាវត្តរបស់គមិកភិក្ខុ គមិក-ភិក្ខុ គប្បីបដិបត្តិដោយប្រពៃចុះ ។

គមិកវត្ត ចប់

អនុមោទនវត្ត

វត្តគឺការធ្វើអនុមោទនា ។ ខមួយ ទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ ភត្តគ្គេ អនុមោទិតុំ** *តថាគតអនុញ្ញាតឲ្យអនុមោ-ទនាក្នុងរោងធាន់ ។ ខមួយ ទ្រង់អនុញ្ញាតទុកថា* **អនុជានាមិ ភិក្ខវេ ថេរេន ភិក្ខុនា ភត្តគ្គេ អនុមោទិតុំ** *តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈអនុមោទនាក្នុងរោងធាន់ ។ ខមួយ ទ្រង់អនុញ្ញាតទុកថា* **អនុជានាមិ ភិក្ខវេ ភត្តគ្គេ ចតូហិ បញ្ចហិ ថេរានុត្តរេហិ ភិក្ខូហិ អាគមេតុំ** *តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរានុត្តរ ៤ អង្គ ៥ អង្គ អង្គុយចាំនៅក្នុងរោងធាន់ ។*

អដ្ឋកថាថា ព្រះសង្ឆត្ថេរអង្គុយចាំ ដើម្បីនឹងអនុមោទនា ភិក្ខុជាលំដាប់ចុះទៅ គប្បីអង្គុយចាំ ៤ អង្គដោយលំដាប់ កាលអនុត្តរអង្គុយចាំ ដើម្បីអនុមោទនា ឲ្យព្រះមហាថេរជាមួយនឹងភិក្ខុបន្ទាប់ចុះទៅទៀត ៣ អង្គ អង្គុយរង់ចាំ កាលថេរៈទី ៥ អង្គុយដើម្បីអនុមោទនា ឲ្យថេរៈ ៤ អង្គ ខាងលើអង្គុយរង់ចាំ កាលព្រះសង្ឆត្ថេរនិមន្តឲ្យភិក្ខុកំណោះអង្គុយខាង

ចុងអនុមោទនា នោះទាំង ៤ អង្គតាំងអំពីព្រះសង្ឆត្ថេរចុះទៅ គប្បីអង្គុយរង់ចាំ បើភិក្ខុអ្នកអនុមោទនាពោលថា លោកចូរទៅចុះ ដូច្នេះ កិច្ចដែលនឹងគប្បីចាំមិនមាន ដូច្នេះនឹងទៅក៏គួរ ។ កាលព្រះថេរៈពោលថា យើងនឹងទៅ លោកចូរនៅចុះ អ្នកអនុមោទនាពោលថា លោកចូរទៅចុះ សូម្បីដូច្នេះក៏គួរ ។ សូម្បីចង់ចិត្តថាយើងនឹងទៅរង់ចាំនៅក្រៅភូមិ ទៅក្រៅភូមិហើយ សូម្បីនឹងបង្គាប់ភិក្ខុជាសិស្សរបស់ខ្លួនឲ្យអង្គុយនៅចាំអ្នកអនុមោទនា ហើយទៅក៏គួរ ។ បើគ្រហស្ថគេនិមន្តភិក្ខុមួយអង្គឲ្យអនុមោទនាតាមគាប់ចិត្តរបស់គេ ភិក្ខុនោះកាលបើអនុមោទនាក៏មិនត្រូវអាបត្តិ ព្រោះមិនជាការៈរបស់មហាថេរ តែថាក្នុងឧបនិសិន្ន-កថាពោលថា កាលមនុស្សគេនិមន្តឲ្យសម្តែងធម៌ ត្រូវប្រាប់ព្រះមហា-ថេរជាមុន ។ ដែលត្រូវរង់ចាំនោះ ចំពោះតែភិក្ខុដែលព្រះមហាថេរនិមន្តឲ្យអនុមោទនា នេះឯងជាលក្ខណៈក្នុងវត្តជំពូកនេះ ។

ខមួយ ទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ សតិ ការណេ អនន្តរិកំ ភិក្ខុំ អាបុច្ឆិត្វា ឧដ្ឋុំ** តថាគតអនុញ្ញាតឲ្យភិក្ខុដែលរង់ចាំនោះ បើមានការណ៍យកិច្ចមានការឈឺបន្ទោបង់ឧច្ចារៈជាដើម គប្បីលាភិក្ខុដែលអង្គុយជាលំដាប់សិនហើយសឹមទៅ ។

អនុមោទនវត្ត ចប់

ភត្តក្តវត្ត

វត្តក្នុងរោងភត្ត ។ សេចក្តីថា បើគេចូលមកប្រាប់ភត្តកាលក្នុងអាវាម និមន្តឲ្យទៅកាន់រោងធាន់ គប្បីបិទកាយឲ្យជាបរិមណ្ឌល ៣ យ៉ាង ស្មៀកឲ្យជាបរិមណ្ឌល ក្រវាត់វត្តពន្ធចង្កេះ តម្រួតសង្ឆាដី និងឧត្តរាសង្គជាពីរជាន់ ដណ្តប់ពាក់ក្ដុំ លាងបាត្រ កាន់យកបាត្រហើយ កុំប្រញាប់ គប្បីដើរសន្សឹមៗចូលទៅក្នុងភូមិដោយប្រពៃ ។ ក្នុងអដ្ឋកថាថា ក្នុងភូមិក្តី ក្នុងវត្តក្តី កាលនឹងទៅកាន់ទីអង្គាសចង្ហាន់នៃមនុស្ស គប្បីដណ្តប់ ឃ្ពុំ ក្រវាត់វត្តពន្ធចង្កេះ ទើបគួរ កាលដើរទៅ កុំដណ្តើមដើរមុនភិក្ខុចាស់ គប្បីបិទកាយដោយប្រពៃ ដើរទៅក្នុងលង្វែកភូមិ រក្សាសេខិយវត្តគ្រប់ៗ សិក្ខាបទ ដរាបដល់កុំដើរចំអើតដើងក្នុងលង្វែកភូមិ កាលអង្គុយក្នុងលង្វែកភូមិ គប្បីបិទកាយដោយប្រពៃ រក្សាសេខិយវត្តគ្រប់ៗសិក្ខាបទ ដរាបដល់កុំអង្គុយត្រចោមជង្គង់ ។ មួយទៀត កុំអង្គុយប្រជ្រៀតភិក្ខុចាស់ បើអាសនៈស្មើគ្នានឹងអាសនៈដែលព្រះមហាថេរអង្គុយ បើទីអង្គុយមានច្រើន គប្បីអង្គុយឲ្យឆ្ងាយ រៀរទុកឲ្យសល់អាសនៈ ១ ឬ ២ អាសនៈដែលគេក្រាលទុកតាមចំនួនភិក្ខុ ភិក្ខុកំលោះមិនហ៊ានអង្គុយ បើព្រះមហាថេរប្រាប់ឲ្យអង្គុយ ក៏គប្បីអង្គុយចុះ តែបើព្រះមហាថេរមិនប្រាប់ឲ្យអង្គុយទេ ក៏គប្បីពោលថាអាសនៈនេះខ្ពស់ កាលបើព្រះមហាថេរប្រាប់ឲ្យអង្គុយក៏គប្បីអង្គុយចុះ បើប្រាប់យ៉ាងនេះហើយ ព្រះមហាថេរមិនប្រាប់ឲ្យអង្គុយ សូម្បី

អង្គុយក៏មិនត្រូវអាបត្តិ ត្រូវអាបត្តិចំពោះតែព្រះមហាថេរមួយអង្គ ព្រោះ ថាអាសនៈដូច្នេះ ភិក្ខុកំលោះមិនប្រាប់មុនហើយអង្គុយចុះ ត្រូវអាបត្តិ ដូចព្រះមហាថេរដែលភិក្ខុកំលោះបានប្រាប់ហើយ មិនអនុញ្ញាត ត្រូវ អាបត្តិដូចគ្នា ។

មួយទៀត ភិក្ខុចាស់កុំគប្បីឃាត់អាសនៈភិក្ខុកំលោះ និងកុំអង្គុយ សង្កត់លើសំពត់សង្ឆាដីក្នុងលង្វែកភូមិ កាលបើគេប្រគេនទឹកលាងបាត្រ គប្បីផ្ដងបាត្រដោយដៃទាំងពីរទទួលទឹកដោយគោរព កុំឲ្យខ្ចាំងខ្ជប់បាត្រ លាងបាត្រដោយប្រពៃ បើមានកន្ទោរគប្បីចាក់ចុះក្នុងកន្ទោរដោយគោរព កុំឲ្យទឹកខ្ជប់កន្ទោរខ្ចាតឡើងទៅត្រូវភិក្ខុអង្គុយជិត ឬត្រូវសំពត់សង្ឆាដី បើមិនមានកន្ទោរ គប្បីចាក់ចុះលើដីដោយគោរព កុំឲ្យទឹកខ្ចាតត្រូវភិក្ខុ ដែលអង្គុយជិត ឬត្រូវសំពត់សង្ឆាដី កាលទាយកប្រគេនបាយ គប្បី ផ្ដងបាត្រដោយដៃទាំងពីរទទួលចុះ គប្បីទុកឱកាសដើម្បីទទួលសូបៈ សប្បិ ប្រេង ឬសម្ភ ក៏គួរ ។ ព្រះមហាថេរគប្បីពោលនឹងទាយក ថា អ្នកចូរប្រគេនឲ្យស្មើគ្នាដល់ភិក្ខុទាំងពួង បើរបស់តិចល្មមគ្រាន់តែភិក្ខុ ១ អង្គ ឬ ២ អង្គប៉ុណ្ណោះ កាលប្រាប់ថាចូរប្រគេនស្មើគ្នាទួទៅ ជាការបៀត បៀនទាយក ព្រោះហេតុនោះ គប្បីទទួលរបស់នោះតែម្ដង ឬពីរដង សល់អំពីនោះកុំទទួល គប្បីតាំងសតិ មានសេចក្ដីសម្គាល់តែក្នុងបាត្រ ទទួលបិណ្ឌបាត គប្បីទទួលសម្ងសណ្ដែក ប្រមាណមួយភាគបួននៃ បិណ្ឌបាត គប្បីទទួលបិណ្ឌបាតត្រឹមស្នើកណ្ដាប់មាត់បាត្រខាងក្រោម

ចង្ហាន់នៅមិនទាន់បានគ្រប់ភិក្ខុទាំងពួងដរាបណា ព្រះថេរៈកុំគប្បីធាន់មុន រឿងនេះអាស្រ័យពោងធាន់តូចហើយមានកំណត់ភិក្ខុ គឺពោងធាន់ណាដែលទាយកគេប្រាថ្នានឹងប្រគេនឲ្យទួទៅដល់ភិក្ខុដទៃផង ។ តែបើពោងធាន់ធំ កន្ទែងមួយភិក្ខុកំពុងធាន់ កន្ទែងមួយគេប្រគេនទឹក ក្នុងពោងធាន់ដូច្នេះ គប្បីធាន់តាមសប្បាយចុះ ។ កាលធាន់បិណ្ឌបាត គប្បីតាំងសតិបដិបត្តិតាមសេខិយវត្តគ្រប់ៗ សិក្ខាបទ ដរាបដល់ថាដៃប្រឡាក់អាមិស កុំចាប់ កុំទទួលភាជនៈដាក់ទឹកធាន់ ។ មួយទៀត ភិក្ខុទាំងពួងធាន់មិនទាន់រួចដរាបណា ព្រះថេរៈកុំអាលទទួលទឹកលាងបាត្រដរាបនោះ កាលទាយកប្រគេនទឹកលាងបាត្រ គប្បីផ្ដងបាត្រដោយដៃទាំងពីរទទួលទឹកមកលាងបាត្រ បដិបត្តិដូចលាងបាត្រនោះចុះ និងកុំគប្បីចាក់ទឹកលាងបាត្រទាំងគ្រាប់បាយក្នុងលង្វែកផ្ទះ កាលត្រឡប់មកអំពីពោងធាន់ ភិក្ខុកំលោះគប្បីត្រឡប់មកមុន ព្រះថេរៈគប្បីត្រឡប់មកជាក្រោយ គឺថាបើផ្ទះចង្អៀតមិនមានឱកាសដែលព្រះមហាថេរចេញមុនបាន គប្បីបដិបត្តិដូច្នេះ ។ កាលចេញមកហើយ ភិក្ខុកំលោះគប្បីឈរនៅទីប្របទ្វារផ្ទះ លុះព្រះថេរៈចេញមកដល់សឹមទៅតាមលំដាប់ បើព្រះមហាថេរអង្គុយនៅជិត ភិក្ខុកំលោះអង្គុយនៅខាងក្នុងផ្ទះ គប្បីចេញទៅតាមលំដាប់ តាំងអំពីអាសនៈនៃព្រះថេរ: កុំឲ្យកាយនិងកាយប៉ះគ្នា ដើរឲ្យជាជួរទុករយៈ ចន្ទោះល្មមមនុស្សដើរឆ្ងងបាន គប្បីបិទកាយឲ្យប្រពៃ ដើរទៅក្នុងលង្វែកផ្ទះ បដិបត្តិតាមសេខិយវត្តគ្រប់ៗ សិក្ខាបទ រហូតដល់ថាកុំដើរចំអើត

ដើងក្នុងលង្វែកផ្ទះនោះចុះ នេះឯងជាវត្តក្នុងរោងធាន់ ភិក្ខុគប្បីបដិបត្តិ ដោយប្រពៃចុះ ។

ភត្តគ្គវត្ត ចប់

បិណ្ឌាចារិកវត្ត

វត្តរបស់ភិក្ខុអ្នកត្រាច់ទៅដើម្បីបិណ្ឌបាត ។ សេចក្ដីថា ភិក្ខុត្រាច់ទៅដើម្បីបិណ្ឌបាត គិតថាយើងនឹងចូលទៅកាន់ភូមិ ក្នុងកាលនេះហើយ គប្បីបិទកាយឲ្យមានមណ្ឌលបី ស្ងៀកឲ្យជាបរិមណ្ឌល ចងវត្ថពន្ធចង្កេះ តម្រួតសំពត់សង្ឆាដីនិងឧត្តរាសង្គ:ជាពីរជាន់ ដណ្ដប់ឃ្ពុំពាក់ក្ដុំ លាងបាត្រ ហើយកាន់យកបាត្រកុំប្រញាប់ សន្សឹមៗ ចូលទៅក្នុងភូមិដោយប្រពៃ គប្បីបិទកាយដោយល្អដើរទៅក្នុងលង្វែកភូមិ បដិបត្តិតាមសេខិយវត្ត សម្រាប់ចូលទៅក្នុងលង្វែកផ្ទះគ្រប់ៗ សិក្ខាបទ រហូតដល់ថាកុំដើរចំអើតដើង ក្នុងលង្វែកភូមិ កាលចូលទៅកាន់ផ្ទះ គប្បីកំណត់សម្គាល់ថា អាត្មាអញនឹងចូលតាមផ្លូវនេះនឹងចេញតាមផ្លូវនេះ ហើយកុំចូលទៅរហ័សពេក កុំចេញមករហ័សពេក កុំឈរឲ្យធ្វាយពេកជិតពេក កុំត្រឡប់ឲ្យធាប់ពេក យឺតយូរពេក គប្បីឈរកំណត់មើលទាយកគេប្រាថ្នានឹងឲ្យ ឬមិនឲ្យ បើទាយកគេបញ្ឈប់ការងារ ឬក្រោកចាកអាសន:ចាប់ដៃ ឬចាប់ភាជន: ឬក៏ស្រែកនិមន្តឲ្យឈប់សិន កាលដឹងថាគេប្រាថ្នានឹងឲ្យហើយ គួរឈរនៅចុះ កាលដែលទាយកប្រគេនចង្ហាន់ គប្បីដៃកសង្ឆាដីដោយ

ដៃធ្វេង បង្ហោនបាត្រចេញដោយដៃស្តាំ ផ្ដងបាត្រដោយដៃទាំងពីរ ទទួលចង្ហាន់ចុះ តែកុំសម្លឹងមើលមុខទាយកអ្នកប្រគេនចង្ហាន់ថាស្ត្រី ឬបុរស ហើយគប្បីកំណត់មើលថា គេនឹងឲ្យម្ហូបចំណី ឬមិនឲ្យ បើគេចាប់ដៃកឬភាជនៈ ឬក៏ស្រែកនិមន្តឲ្យឈប់នៅសិន កាលដឹងថាគេប្រាថ្នានឹងឲ្យហើយ គួរឈប់នៅចុះ កាលគេឲ្យចង្ហាន់រួចហើយ គប្បីបិទបាត្រដោយសង្ឆាដី កុំប្រញាប់ សន្សឹមៗ ត្រឡប់ដោយប្រពៃ ហើយរក្សាសេខិយវត្តក្នុងលង្វែកភូមិគ្រប់ៗ សិក្ខាបទ រហូតដល់ថាកុំដើរចំអើតដើងក្នុងលង្វែកភូមិ ។ ភិក្ខុណាត្រឡប់អំពីបិណ្ឌបាតមកដល់វត្តមុន ភិក្ខុនោះគប្បីក្រាលអាសនៈទុកក្នុងរោងធាន់ តម្កល់ទឹកលាងជើង តម្កល់តាំងរងជើង ក្បឿងជូតជើងទុក ហើយលាងភាជនៈដាក់របស់ធាន់តាំងទុក តម្កល់ទឹកប្រើ ទឹកធាន់ទុក ។ បើភិក្ខុណាត្រឡប់មកអំពីភូមិជាខាងក្រោយ បើមានរបស់ធាន់ ប្រាថ្នានឹងធាន់សោត គប្បីធាន់ចុះ បើមិនប្រាថ្នានឹងធាន់ទេ ភិក្ខុនោះគប្បីយកទៅចាក់ចោលក្នុងទីប្រាសចាកវត្តខ្ទៀ គឺដើមឈើឬដើមស្មៅឬយកទៅបំផ្ងេងចោលក្នុងទឹកដែលមិនមានតួសត្ត ភិក្ខុនោះគប្បីរើអាសនៈទុកដាក់និងទុកដាក់ទឹកលាងជើង តាំងរងជើង ក្បឿងជូតជើង និងលាងភាជនៈដាក់របស់ធាន់ទុកចុះ រៀបចំទឹកធាន់ ទឹកប្រើទុក ហើយបោសសម្អាតរោងធាន់ចេញ ភិក្ខុណាឃើញក្អមទឹកធាន់ ទឹកប្រើ ឬក្អមទឹកក្នុងវច្ចកុដិទេ មិនមានទឹក ភិក្ខុនោះគប្បីដងមកតម្កល់ទុក បើម្នាក់ឯងលើកមិនរួច គប្បីបោយដៃហៅគ្នា បានជាពីរនាក់ឲ្យមកជួយ

លើកតាំងទុក តែកុំបញ្ចេញវាចាថាអ្វីឡើយ នេះឯងជាវត្តនៃភិក្ខុអ្នកត្រាប់ទៅបិណ្ឌបាត ភិក្ខុគប្បីបដិបត្តិដោយប្រពៃចុះ ។

បិណ្ឌចារិកវត្ត ចប់

អារញ្ញិកវត្ត

វត្តរបស់ភិក្ខុអ្នកនៅក្នុងព្រៃ ។ សេចក្ដីថា ភិក្ខុអ្នកនៅព្រៃ គប្បីក្រោកឡើងអំពីព្រឹក យកបាត្រដាក់ថង់ ហើយយកខ្សែយោគពាក់លើចង្ហួយស្មា ពាក់ចីវរលើស្មា ពាក់ស្បែកជើង ហើយរៀបចំទុកដាក់ គ្រឿងឈើ គ្រឿងដី បិទទ្វារបង្ហួចហើយគប្បីចុះអំពីទីលំនៅមក ដឹងថានឹងចូលទៅកាន់ភូមិ ក្នុងកាលនេះហើយគប្បីដោះស្បែកជើងចេញដោយគោរព ហើយដាក់ក្នុងស្ងោកបាត្រយកខ្សែយោគពាក់លើចង្ហួយស្មា បិទកាយឲ្យមានមណ្ឌលបី ស្ងៀកឲ្យជាបរិមណ្ឌល តទៅគប្បីប្រតិបត្តិដូចពោលហើយក្នុងបិណ្ឌបាតចារិកវត្តគ្រប់ៗ សិក្ខាបទ ដរាបដល់ត្រឡប់អំពីភូមិមក បើខាងក្រៅភូមិមិនមានទឹកគប្បីធ្វើកត្តកិច្ចនៅក្នុងភូមិ បើខាងក្រៅភូមិមានទឹកគប្បីចេញទៅធ្វើកត្តកិច្ចខាងក្រៅភូមិ ហើយលាងបាត្រ ធ្វើឲ្យប្រាសចាកទឹក ហើយច្រកបាត្រក្នុងថង់ ពាក់ខ្សែយោគលើចង្ហួយស្មា បត់ចីវរពាក់លើក្បាល ពាក់ស្បែកជើង ដើរមកកាន់សេនាសនៈវិញ ។ មួយទៀត ភិក្ខុនៅព្រៃ ត្រូវតម្កល់ទឹកផាន់ ទឹកប្រើទុក បើខ្វះភាជនៈ ក៏គប្បីធ្វើទឹកផាន់នោះឯងឲ្យជាទឹកប្រើតាំងទុកចុះ កាលបើមិនមានភាជនៈ គប្បីតម្កល់

ទុកក្នុងបំពង់ឫស្សី បើមិនមានបំពង់ឫស្សី គប្បីឲ្យអនុបសម្បន្នធ្វើអណ្ដូងក្នុងទីជិតហើយបំពក់ភ្ជើងទុក ឬតម្កល់ពំនួតភ្ជើងទុក បើពំនួតភ្ជើងមានហើយ មិនបាច់បំពក់ភ្ជើងទុកក៏គួរ ។ សូម្បីភិក្ខុអ្នកដើរផ្លូវធ្វាយដាច់ស្រយាល ក៏គប្បីប្រាថ្នាពំនួតភ្ជើងដូចភិក្ខុនៅព្រៃដូច្នោះដែរ តែបើនៅជាពួក ជាគណៈ សូម្បីប្រាសចាកពំនួតភ្ជើងក៏គួរ ។ មួយទៀត ភិក្ខុនៅព្រៃត្រូវតម្កល់ឈើច្រត់ទុក ហើយត្រូវរៀនឲ្យដឹងផ្ការយនក្ខត្តឫក្សទាំងអស់ ឬដោយឯកទេសក៏បាន ហើយត្រូវជាអ្នកឈ្វាសស្គាល់ជាក់នូវទិសនោះ។ តាំងអំពីតម្កល់ទឹកធាន់ជាដើម ទាំងអម្បាលនេះ ត្រូវធ្វើដើម្បីរក្សាខ្លួនឲ្យរួចចាកអន្ដរាយអំពីចោរ នេះឯងជាវត្ដនៃភិក្ខុអ្នកនៅព្រៃ ភិក្ខុអ្នកនៅព្រៃគប្បីបដិបត្ដិដូច្នេះចុះ ។

អារញ្ញិកវត្ត ចប់

សេនាសនវត្ត

វត្ដដែលភិក្ខុត្រូវធ្វើចំពោះទីសេនាសនៈ ។ សេចក្ដីថា ភិក្ខុអ្នកនៅក្នុងវិហារ កុដិ ណា បើកុដិនោះខ្ជាំដោយសំរាម បើអាចនឹងបោសច្រាសបាន គប្បីបោសច្រាសចេញ កាលបោសច្រាសកុដិ គប្បីជញ្ជូនបាត្រ និងចីវរចេញ យកទៅទុកដាក់ឲ្យសមគួរមួយអន្ទើជាមុន ហើយជញ្ជូនសំពត់និសីទនៈ គ្រឿងកម្រាលលើគ្រែ លើតាំង យកទៅគរទុកក្នុងទីដ៏សមគួរ គប្បីជញ្ជូនពួកខ្នើយ យកទៅគរទុកក្នុងទីសមគួរ គ្រែតាំង

គប្បីធ្វើដោយគោរព កុំឲ្យប៉ះទង្គិចកោសរួសសន្ទឹកទ្វារ ជញ្ជូនចេញ ដោយប្រពៃ តាំងទុកមួយចំណែក ហើយជញ្ជូនទ្រនាប់រងជើងគ្រែ កន្ទោរ និងក្ដារបង្អែក ចេញទៅតម្កល់មួយចំណែក គ្រឿងកម្រាលផ្ទៃ គប្បីកំណត់ទីក្រាលហើយជញ្ជូនចេញទៅដាក់តម្កល់មួយចំណែក បើក្នុងវិហារមានសរសៃពីងពាងញ្ជរសំយុង គប្បីបោសអំពីពិតានចុះមកមុន ។ បង្ហួចដុះផ្សិតសៅហ្មង គប្បីជូតចេញ ។ បើជញ្ជាំងគេធ្វើបរិកម្មដោយរង្គ ឬផ្ទៃគេលាបពណ៌ខ្មៅ ដុះផ្សិតឡើង គប្បីយកកំណាត់សំពត់ជ្រលក់ទឹកពូតឲ្យស្រស់ជូតចេញ បើផ្ទៃគេមិនលាបពណ៌ទេ គប្បីយកទឹកបំព្រំចុះមុនហើយសឹមជូត ។ កុំឲ្យល្អងធូលីហុយឡើងធ្លាក់ប្រឡាក់កុដិ គប្បីរើសសំរាមទៅចាក់ចោលក្នុងទីសមគួរ កុំបោកកុំគោះសេនាសនៈគ្រឿងកម្រាលជិតភិក្ខុដទៃ ជិតវិហារ កុដិ ឬជិតទឹកធាន់ទឹកប្រើ កុំបោក គោះក្នុងទីវាលលើខ្យល់ គប្បីបោក-គោះក្នុងទីក្រោមខ្យល់ ។ គ្រឿងកម្រាលផ្ទៃ គប្បីហាលក្នុងទីសមគួរ ហើយបោសច្រាសចេញជញ្ជូនត្រឡប់ទៅក្រាលទុកដូចដើមវិញ ។ ទ្រនាប់រងជើងគ្រែ គប្បីហាលទុកមួយចំណែក ហើយដុសជូតជញ្ជូនត្រឡប់ចូលទៅតាំងទុកដូចដើម គ្រែតាំងក៏គប្បីគោះ បោសហាល ធ្វើដោយគោរព កុំឲ្យប៉ះពាល់ជល់ទង្គិច ជញ្ជូនត្រឡប់យកទៅទុកកន្លែងដើម ។ ពួកខ្នើយនិងនិសីទនៈគ្រឿងកម្រាល លើគ្រែ លើតាំង គប្បីហាលទុកមួយចំណែក ហើយគោះបោសជញ្ជូនត្រឡប់ចូលទៅតាំងទុកតាមកន្លែងដើម ។ កន្ទោរ ក្ដារបង្អែក ក៏គប្បីហាលជូត

ដុសលាង ហើយជញ្ជូនទៅតាំងទុកដូចដើម ។ បាត្រចីវរក៏គប្បីតម្កល់ទុកដាក់ ។ កាលទុកបាត្រ ដៃម្ខាងកាន់បាត្រ ដៃម្ខាងស្ទាបក្រោមគ្រែ ក្រោមតាំង ហើយសឹមទុកដាក់ កុំតម្កល់បាត្រលើផ្ទៃ ដែលមិនមានរបស់ណាមួយរងមានស្ទឹកឈើជាដើម ។ កាលទុកដាក់ចីវរយកដៃម្ខាងកាន់ចីវរ ដៃម្ខាងជូតស្ងួចីវរ ឬខ្សែស្បៃង លូកដៃពីខាងក្រោមស្ងួចីវរ សន្សឹមៗ ហើយពាក់បត់ជាយចីវរខាងនាយមកខាងមុខខ្លួន ។ បើខ្យល់ប្រកបដោយល្អងធូលី បក់មកអំពីទិសណា គឺទិសខាងកើត ទិសខាងត្បូង ទិសខាងលិច ឬទិសខាងជើង គប្បីបិទបង្ហួចខាងទិសនោះចេញ ។ បើក្នុងរដូវរងា វេលាថ្ងៃគប្បីបើកបង្ហួច វេលាយប់គប្បីបិទបង្ហួច បើក្នុងរដូវក្តៅ វេលាថ្ងៃគប្បីបិទបង្ហួច វេលាយប់គប្បីបើកទុក ។ បើបរិវេណ បន្ទប់ទឹក ពោងធាន់ ពោងភ្ជើង ឬវច្ចកុដិ ទាំងនេះ ណាមួយពេញស្តុកដោយសំរាម គប្បីបោសចេញ បើមិនមានទឹកធាន់ ទឹកប្រើ គប្បីដងមកតាំងទុក បើទឹកក្នុងក្អមជម្រះមិនមាន គប្បីដងមកដាក់ទុក ។ បើនៅក្នុងកុដិជាមួយនឹងភិក្ខុចាស់ជាង មិនប្រាប់ភិក្ខុចាស់មុន កុំឲ្យឧទ្ទេសនិងបរិបុច្ឆា គឺកុំប្រាប់បាលីនិងអដ្ឋកថា កុំស្វាធ្យាយទន្ទេញសូត្រ កុំសម្តែងធម៌ កុំអុជប្រទីប កុំលត់ប្រទីប កុំបើក កុំបិទបង្ហួច តែទ្វារជាធំក្នុងការប្រើប្រាស់ ត្រូវការបិទត្រូវការបើក កិច្ចដែលនឹងប្រាប់ភិក្ខុចាស់ជាមុនមិនមាន តែការឲ្យឧទ្ទេសជាដើមក្រៅពីនោះ ត្រូវប្រាប់ភិក្ខុចាស់ជាមុនទើបធ្វើបាន នឹងប្រាប់រាល់ៗថ្ងៃក៏គួរ ។ បើភិក្ខុកំលោះប្រាប់ទុកឲ្យស្រេច

តែម្តង គឺថាមិនបាច់ប្រាប់ទៀត បើភិក្ខុចាស់ទទួលថាសាធុ ឬភិក្ខុចាស់ពោលខ្លួនឯងថា លោកចូរនៅតាមសប្បាយចុះ បើអនុញ្ញាតដូច្នេះហើយក៏គួរ ឬជាសភាគ:ស្និទ្ធស្នាលគ្នា បើមិនប្រាប់ ព្រោះសេចក្តីស្និទ្ធស្នាលក៏គួរ ។ បើដើរក្នុងទីចង្រ្ទមជាមួយនឹងភិក្ខុចាស់ជាងសោត កុំគប្បីត្រឡប់ឲ្យជួបមុខនឹងភិក្ខុចាស់ជាង កុំឲ្យប៉ះភិក្ខុចាស់ជាងដោយជាយសង្ឆាដី នេះឯងជាសេនាសនវត្ត ភិក្ខុទាំងឡាយ គប្បីប្រតិបត្តិដោយប្រពៃចុះ ។

សេនាសនវត្ត ចប់

ជន្លាយវត្ត

វត្តដែលភិក្ខុត្រូវធ្វើចំពោះផ្ទះជាទីរក្សាកាយ ។ ខមួយ ព្រះអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ ជន្លាយវេ ថេរេន ភិក្ខុនា និវារិយមានេន អនាទរិយំ បដិច្ច បហូតំ ភដ្ដំ អាហ-រិត្វា អត្ថិ ជាតញ្ចោ យោ ឧនេយ្យ អាបត្តិ ទុក្ខដស្ស**[1] *ម្នាលភិក្ខុទាំងឡាយ បើភិក្ខុជាព្រះថេរ:ហាមឃាត់ក្នុងផ្ទះជាទីរក្សាកាយហើយ មិនត្រូវនាំគ្នាដាក់ឧសច្រើនបង្ហាត់ភ្លើង ព្រោះអាស្រ័យសេចក្តីមិនអើពើទេ ភិក្ខុណាដាក់ ត្រូវអាបត្តិទុក្កដ ។*

ខមួយ ព្រះអង្គទ្រង់ហាមឃាត់ទុកថា **ន ច ភិក្ខវេ ទ្វារំ ថកេត្វា ទ្វារេ និសីទិត្វា យោ និសីនេយ្យ អាបត្តិ ទុក្ខដស្ស**[2] *ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុមិនគប្បីបិទ*

១-២- វិ. ចុល្លវគ្គ តតិយភាគ វត្ថុក្ខន្ធ: ទំព័រ ១២៩ ។

ទ្វារ ហើយអង្គុយនៅប្រហទ្វារឡើយ បើភិក្ខុណាអង្គុយត្រូវអាបត្តិទុក្កដ ។

សេចក្តីក្នុងជន្លាយវត្តថា ភិក្ខុណាទៅកាន់ជន្លាយ: គឺរោងភ្ជើងជាទីអាំងកាយឲ្យរម្ងាប់រោគមុនគេ បើមានផេះក្នុងរោងភ្ជើងក្រាស់សោតភិក្ខុនោះ គប្បីកើបចាក់ចោលចេញ បើរោងភ្ជើងនិងបរិកណ្ណ: គឺលានខាងក្រៅរោងភ្ជើង និងបរិវេណ បន្ទប់ ឬ សាលានៃរោងភ្ជើង អម្បាលនេះ ខ្ជាំទៅដោយសំរាម គប្បីបោសចោលចេញ គប្បីកិនចុណ្ណ: គឺលម្អិតដីទុក គប្បីយកដីសម្រាប់លាបមុខត្រាំទឹកទុក គប្បីយកទឹកដាក់ស្នូកទុកមុនហើយសឹមចូលទៅកាន់រោងភ្ជើង កាលចូលទៅកាន់រោងភ្ជើងត្រូវលាបមុខដោយដីស្អិត ហើយបិទបាំងទាំងខាងមុខខាងក្រោយ ហើយសឹមចូលទៅ កុំអង្គុយប្រជ្រៀតភិក្ខុជាថេរ: និងកុំហាមអាសន: ភិក្ខុកំណោះ បើអាចគប្បីធ្វើបរិកម្ម គក់ច្រចាប់ឲ្យភិក្ខុជាថេរ:ក្នុងរោងភ្ជើងកាលចេញចាករោងភ្ជើង គប្បីកាន់យកតាំងសម្រាប់រោងភ្ជើងហើយបិទទាំងខាងមុខខាងក្រោយ ចេញចាករោងភ្ជើង ។ បើអាចគប្បីធ្វើបរិកម្មគឺដុសខាត់ខ្ជួនឲ្យភិក្ខុជាថេរ:ក្នុងទឹកផង និងកុំផ្ងូតខាងមុខនៃភិក្ខុទាំងឡាយជាថេរ: កុំផ្ងូតទឹកខាងលើព្រះថេរ: កាលផ្ងូតទឹកហើយនឹងឡើងមកវិញ គប្បីឲ្យផ្ងូវដល់ភិក្ខុទាំងឡាយដែលកំពុងចុះទៅ ។ ភិក្ខុណាចេញចាករោងភ្ជើងក្រោយគេ បើរោងភ្ជើងរអិលប្រឡាក់ ភិក្ខុនោះត្រូវលាងចេញ គប្បីលាងស្នូកដាក់ដីស្អិតរៀបទុកដាក់តាំងសម្រាប់រោងភ្ជើង លត់ភ្ជើងបិទទ្វារហើយគប្បីចៀសទៅ នេះឯង ជាជន្លាយវត្ត ភិក្ខុទាំងឡាយ គប្បីបដិបត្តិដោយ

ប្រពៃចុះ ពោងក្ងើងនេះព្រះអង្គទ្រង់អនុញ្ញាតទុកដើម្បីជាទីអាំងកាយ ដែលក្រាស់ដោយទោសធាន់អាហារដ៏ប្រណីត តាមពាក្យពេទ្យជីវកកោមារភ័ត ក្រាបទូល សព្វថ្ងៃនេះមិនប្រើពោងក្ងើង តែគប្បីប្រតិបត្តិក្នុងទំនៀមផ្ងូតទឹកនោះចុះ ។

ជន្ទាឃរវត្ត ចប់

វច្ចកុដិវត្ត

វត្តដែលភិក្ខុត្រូវធ្វើចំពោះវច្ចកុដិ (បង្គន់) ។ ខមួយ ព្រះអង្គទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ វច្ចំ កត្វា សតិ ឧឌកេ ន អាចមេតព្ពំ យោ ជាចមេយ្យ អាបត្តិ ទុក្កដស្ស** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុបន្ទោបង់ឧច្ចារៈហើយ កាលមានទឹកគប្បីលាងជម្រះ បើភិក្ខុណាមិនលាងជម្រះ ត្រូវទុក្កដ ។ បើមានទឹកតែមិនមានទីកំបាំង គប្បីដងទឹកទៅដោយភាជនៈលាងជម្រះចេញក្នុងទីកំបាំងចុះ ។ បើមិនមានភាជនៈ គប្បីដងទឹកទៅដោយបាត្រ បើមិនមានបាត្រ និងមិនមានភាជនៈឯទៀត គប្បីតាំងចិត្តថា ទីនេះវាលណាស់ ទៅឯមុខគង់នឹងមានទឹកទៀត ហើយទៅ កាលទៅពុំបានទឹកសោះ បើវេលាប្រញាប់នឹងទៅកិច្ចាការទៀត ក៏គប្បីជូតកិតដោយឈើ ឬដោយវត្ថុណាមួយហើយសឹមទៅ សូម្បីធាន់ ឬធ្វើអនុមោទនាក៏គួរ ។*

ខមួយ ព្រះអង្គទ្រង់ហាមឃាត់និងអនុញ្ញាតទុកថា **ន ភិក្ខវេ** **វច្ចកុដិយា យថាវុឌ្ឍំ វច្ចោ ការេតព្ពោ យោ ការេយ្យ** **អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ អាគតបដិ-** **ចាដិយា វច្ចំ ការេតុំ** ក្នុងវច្ចកុដិ ភិក្ខុកុំគប្បីទៅបន្ទោបង់ឧច្ចារៈ តាមលំដាប់វស្សា បើភិក្ខុណាទៅបន្ទោបង់ឧច្ចារៈតាមលំដាប់ភិក្ខុចាស់ខ្ចី ត្រូវអាបត្តិទុក្កដ ។ តថាគតអនុញ្ញាតឲ្យទៅបន្ទោបង់ឧច្ចារៈតាមលំដាប់ដែលមកមុនក្រោយ ។ ក្នុងវច្ចកុដិ និងទីបន្ទោបង់បស្សាវៈ និងកំពង់ទឹកទាំង ៣ ស្ថានេះ យកលំដាប់ភិក្ខុមកដល់មុននោះឯង ជាប្រមាណ ។

សេចក្តីក្នុងវច្ចកុដិវត្តថា ភិក្ខុណាទៅវច្ចកុដិ ភិក្ខុនោះគប្បីឈរនៅខាងក្រៅ ក្អកគ្រហែមឡើងមុន សូម្បីភិក្ខុអង្គុយខាងក្នុង ក៏គប្បីក្អកគ្រហែមទទួល ហើយគប្បីពាក់ចីវរលើឈើស្ម ខ្សែស្បៃង ហើយកុំប្រញាប់ សន្សឹមៗ ចូលទៅក្នុងវច្ចកុដិដោយប្រពៃ កុំចូលទៅឲ្យរហ័សពេក កុំសើយស្បង់ចូលទៅ គប្បីឈរលើទ្រនាប់ជើងសម្រាប់បន្ទោបង់វច្ចៈ ហើយសឹមសើយស្បង់ កុំប្រឹងរមាត់ឮអ៊ីៈៗ បន្ទោបង់ឧច្ចារៈ កុំបន្ទោបង់ឧច្ចារៈទាំងទំពាឈើស្ទន់ ។

មួយទៀត កុំបន្ទោបង់ឧច្ចារៈក្រៅទរនៃវច្ចៈ កុំបន្ទោបង់បស្សាវៈក្រៅទរបស្សាវៈ កុំស្ពោះទឹកមាត់ ទឹកសំបោរចុះក្នុងទរបស្សាវៈ កុំជូតកិតដោយឈើចម្រៀក ឈើមុត ឈើបន្ទា ឈើពក ឬឈើប្រហោងឈើពុក ឈើអម្បាលនេះ កុំជូតកិត បើមានទឹកហើយមិនកាន់យកឈើជម្រះចូលទៅក្នុងវច្ចកុដិ មិនត្រូវអាបត្តិ ។

មួយទៀត កុំចោលឈើជម្រះចុះក្នុងរណ្ដៅវច្ច: បន្ទោបង់ឧច្ចារ:ហើយ គប្បីឈរលើទ្រនាប់សម្រាប់បន្ទោបង់ បិទស្បង់ឲ្យជិតសិន កុំចេញមកធាប់ពេក កុំសើយស្បង់ចេញមក គប្បីឈរលើទ្រនាប់សម្រាប់ជម្រះហើយ សឹមសើយស្បង់ ជម្រះដោយទឹកកុំធ្វើឲ្យឮសំឡេងច:បុ:ៗ កុំឲ្យទឹកសល់នៅក្នុងភាជន:ដាក់ទឹកជម្រះ រឿងនេះសង្ក្រាះតែក្នុងទីសាធារណ:ទូទៅ ដល់ភិក្ខុទាំងពួង ដ្បិតថាក្នុងទីដូច្នោះ ភិក្ខុដទៃៗ មកក្រោយៗ ទៀតនឹងមានសេចក្ដីរង្កៀសក្នុងទឹកដែលសល់នៅនោះ ព្រោះហេតុនោះ ជម្រះហើយកុំធ្វើឲ្យទឹកសល់នៅក្នុងទីណាមួយឡើយ ប៉ុន្តែបើទីណាគេធ្វើទុកជាឯកទេសក្នុងវិហារសូម្បីរបស់សង្ឆ សម្រាប់ទៅបន្ទោបង់ឧច្ចារ:ជានិច្ច ឬវច្ចកុដិរបស់បុគ្គល ក្នុងទីដូច្នោះនឹងទុកទឹកឲ្យសល់នៅក៏គួរ បើធាន់ថ្នាំបញ្ចុះ ទៅបន្ទោបង់ឧច្ចារ:រឿយៗ នឹងឲ្យសល់នៅក៏គួរដោយពិត ។

មួយទៀត ជម្រះហើយ គប្បីឈរលើទ្រនាប់សម្រាប់ជម្រះ បិទដោយសំពត់ បើវច្ចកុដិប្រឡាក់ដោយឧច្ចារ: គប្បីដងទឹកមកលាងចេញ ទឹកមាន តែភាជន:មិនមាន ឬភាជន:មាន តែទឹកមិនមាន ក៏ឈ្មោះថាមិនមាន កាលមិនមានទាំង ២ ឈ្មោះថា មិនមានដោយពិត ។ គប្បីជូតដោយឈើ ឬវត្ថុណាមួយហើយសឹមទៅ បើកញ្ជើដាក់ឈើជម្រះពេញសោត គប្បីយកទៅចាក់ចេញ បើវច្ចកុដិឬទីបរិភណ្ឌ: គឺទីវាល ឬក្ងោងទ្វារ ឬបរិវេណនៃវច្ចកុដិ ទាំងអម្បាលនេះណាមួយ ស្ពុកដោយសំពាម គប្បីបោសចោលចេញ បើទឹកក្នុងក្អមជម្រះមិនមានសោត គប្បីដងទឹក

យកមកដាក់ នេះឯងជាវច្ចកុដិវត្តនៃភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ គប្បីបដិបត្តិដោយប្រពៃចុះ ។

វច្ចកុដិវត្ត ចប់

ឧបជ្ឌាយវត្ត

វត្តដែលភិក្ខុត្រូវធ្វើចំពោះឧបជ្ឌាយ៍ ។ សេចក្ដីថា ភិក្ខុជាសទ្ធិវិហារិក គប្បីបដិបត្តិដោយប្រពៃក្នុងឧបជ្ឌាយ៍ ។ ឯសេចក្ដីបដិបត្តិប្រពៃនោះដូច្នេះ សទ្ធិវិហារិក គឺភិក្ខុនិងសាមណេរ គប្បីក្រោកឡើងអំពីព្រឹក បើពាក់ស្បែកជើងដើរចង្ក្រម គប្បីដោះចេញ ហើយឃ្ជុំចីវរធ្វៀងស្មាម្ខាង គប្បីប្រគេនឈើស្ទន់ ប្រគេនទឹកលុបមុខ ទឹកខ្ពុរមាត់ ហើយក្រាលអាសនៈទុក បើបបរមាន គប្បីលាងភាជនៈ ដួសដាក់បបរនាំចូលទៅប្រគេន លុះព្រះឧបជ្ឌាយ៍ឆាន់បបររួចហើយ គប្បីប្រគេនទឹកឆាន់ ហើយទទួលភាជនៈបបរមកដោយគោរព កុំធ្វើឲ្យប៉ះទង្គិចអ្វីៗ លាងទុកដាក់ឲ្យល្អ កាលឧបជ្ឌាយ៍ក្រោកឡើងហើយ គប្បីមូរអាសនៈទុក បើឧបជ្ឌាយ៍រៀបចូលទៅកាន់ស្រុក គប្បីប្រគេនស្បង់ និងទទួលស្បង់បន្ទាស់ គប្បីប្រគេនវត្ត្ពន្ធចង្កេះ គប្បីតម្រួតឧត្តរាសង្គ:ជាមួយនឹងសង្ឆាដី ជាពីរជាន់ហើយប្រគេន គប្បីជូតបាត្រដែលទទឹករួចហើយសឹមប្រគេន បើឧបជ្ឌាយ៍ត្រូវការឲ្យជាបច្ចាសមណ:តាមទៅផង គប្បីបិទកាយឲ្យជាបរិមណ្ឌល បើស្ងៀកឲ្យជាបរិមណ្ឌលហើយ ចងវត្ត្ពន្ធចង្កេះ តម្រួតចីវរនិងសង្ឆាដី

ជាពីរជាន់ ឃ្ងុំពាក់ក្ដុំ លាងបាត្រ កាន់យកបាត្រហើយ ជាបច្ចា-
សមណៈទៅតាមក្រោយនៃឧបជ្ឈាយ៍ កុំដើរឲ្យជិតពេក ឲ្យឆ្ងាយពេក
ប្រមាណឲ្យលួមឧបជ្ឈាយ៍បែរមកនិយាយផងបាន គឺលួមឈានទៅមួយ
ជំហាន ពីរជំហានក៏ដល់ បើបាត្រឧបជ្ឈាយ៍ក្តៅ ឬពេញដោយបបរ
ឬបាយ គប្បីទទួលបាត្រឧបជ្ឈាយ៍មក ផ្ទាស់ប្រគេនបាត្ររបស់ខ្លួនឲ្យ
ទៅឧបជ្ឈាយ៍ កាលឧបជ្ឈាយ៍និយាយផង កុំពោលទទឹងស្ទាក់ឡើងក្នុង
ចន្ទោះៗ កាលឧបជ្ឈាយ៍ពោលពាក្យជិតនឹងត្រូវអាបត្តិ ក៏ធ្វើជាសួរថា
ពោលដូច្នេះគួរឬទេ មិនត្រូវអាបត្តិទេឬ គប្បីឃាត់ដូច្នេះ កុំឃាត់
ដោយពាក្យផ្ទួញ់ផ្ទាល់ កាលត្រឡប់មកអំពីភូមិ គប្បីត្រឡប់មកមុន
ហើយក្រាលអាសនៈបម្រុងទុក តម្កល់ទឹកលាងជើង តាំងរងជើង និង
ទ្រនាប់ជូតជើងបម្រុងទុក ហើយក្រោកទៅទទួលបាត្រចីវរ គប្បី
ប្រគេនស្បង់បន្ទាស់ ហើយទៅទទួលស្បង់ដែលស្ងៀកនោះមក បើចីវរ
ទទឹកដោយញើស គប្បីសំដិលក្នុងទីក្តៅមួយរំពេច តែកុំហាលទុក
ឲ្យយូរពេក ហើយគប្បីបត់ កាលនឹងបត់ចីវរ គប្បីបន្ថយជាយម្ខាងឲ្យ
ហួសទៅក្នុងជាយម្ខាង ប្រមាណ ៤ ធ្នាប់ហើយសឹមបត់ កុំឲ្យបាក់ពាក់
កណ្ដាល គប្បីយកវត្ថុពន្ធចង្កេះទុកក្នុងផ្ទត់ចីវរ ។ បើបិណ្ឌបាតមាន
ឧបជ្ឈាយ៍ប្រាជ្ញានឹងធាន់ គប្បីប្រគេនទឹក ហើយគប្បីបង្ហោនបិណ្ឌបាត
ចូលទៅ គប្បីសួរឧបជ្ឈាយ៍ដោយទឹកធាន់ លុះឧបជ្ឈាយ៍ធាន់រួច
ហើយ គប្បីប្រគេនទឹក ហើយគប្បីទទួលបាត្រមកកាន់បន្ទាបដោយប្រពៃ

កុំឲ្យប៉ះទង្គិច ហើយលាងចេញធ្វើឲ្យស្អាតល្អដោយប្រពៃ ឲ្យអស់ទឹក ហើយទើបហាលទុក ក្នុងទីក្តៅមួយរំពេច តែកុំហាលបាត្រចោលទុកក្នុងទីក្តៅឲ្យយូរពេក ហើយគប្បីទុកដាក់បាត្រ ចីវរ កាលទុកដាក់បាត្រ ចីវរ គប្បីទុកដូចពោលហើយក្នុងសេនាសនវត្តនោះចុះ ។ កាលឧបជ្ឌាយ៍ក្រោកឡើងហើយ គប្បីសាអាសនៈនោះចេញ ទុកទឹកលាងជើង តាំងរងជើង ទ្រនាប់ជូតជើង បើទីនោះខ្ជាំដោយសំរាម គប្បីបោសច្រាសចេញ ។ បើឧបជ្ឌាយ៍ចង់ស្រង់ទឹក គប្បីចាត់ចែងទឹកប្រគេន បើត្រូវការដោយទឹកត្រជាក់ គប្បីចាត់ចែងទឹកត្រជាក់ប្រគេន បើត្រូវការដោយទឹកក្តៅ គប្បីចាត់ចែងទឹកក្តៅប្រគេន បើឧបជ្ឌាយ៍ប្រាថ្នានឹងចូលទៅកាន់រោងភ្ជើង គប្បីកិនចុណ្ណៈគឹលម្ជិត យកដីស្អិតសម្រាប់លាបមុខ ត្រាំទឹកទុកហើយ កាន់តាំងសម្រាប់រោងភ្ជើងដើរតាមក្រោយឧបជ្ឌាយ៍ទៅ ហើយប្រគេនតាំងសម្រាប់រោងភ្ជើងដល់ឧបជ្ឌាយ៍ ទទួលយកចីវរមកទុកក្នុងទីសមគួរ គប្បីប្រគេនចុណ្ណៈ គឹលម្ជិតនិងដីស្អិតសម្រាប់លាបមុខ បើអាចគប្បីចូលទៅក្នុងរោងភ្ជើងជាមួយ កាលនឹងចូលទៅ គប្បីប្រតិបត្តិដូចពោលហើយក្នុងជន្តាឃរវត្តនោះចុះ គប្បីធ្វើបរិកម្ម គក់ច្រចាប់ប្រគេនឧបជ្ឌាយ៍ក្នុងរោងភ្ជើង កាលនឹងចេញមកគប្បីប្រតិបត្តិដូចពោលហើយក្នុងជន្តាឃរវត្តនោះចុះ គប្បីធ្វើបរិកម្មជុសលាងប្រគេនឧបជ្ឌាយ៍ក្នុងទឹកផង ស្រង់ទឹករួចគប្បីឡើងមកមុន ជូតកាយរបស់ខ្លួនឲ្យស្រស់ទឹកហើយផ្ទាស់ស្បង់ ហើយគប្បីជូតទឹកប្រគេនឧបជ្ឌាយ៍ ហើយ

គប្បីប្រគេនស្បង់បន្ទាស់ ប្រគេនសំពត់សង្ឆាដី ហើយគប្បីកាន់យកតាំងសម្រាប់ពោងភ្ជើងមកតាំងទុកមុន គប្បីតម្កល់ទឹកលាងជើង ទ្រនាប់ជូតជើងទុកមុន គប្បីសួរឧបជ្ឈាយ៍ដោយទឹកធាន់ ។

បើប្រាថ្នារៀនបាលី គប្បីឲ្យឧបជ្ឈាយ៍បង្រៀនចុះ បើប្រាថ្នាសាកសួរអដ្ឋកថា ក៏គប្បីសាកសួរអដ្ឋកថាចុះ ឧបជ្ឈាយ៍នៅក្នុងវិហារកុដិណា បើវិហារកុដិនោះ ខ្ជាំដោយសំរាម បើអាចគប្បីបោសចេញ កាលនឹងជម្រះកុដិ គប្បីប្រតិបត្តិដូចពោលហើយក្នុងសេនាសនវត្តគ្រប់ប្រការរហូតដល់ដងទឹកដាក់ក្នុងក្អមជម្រះទុកចុះ ។

បើសេចក្តីអផ្សុក មិនត្រេកអរក្នុងព្រហ្មចរិយៈចង់លាសិក្ខា កើតឡើងដល់ឧបជ្ឈាយ៍សោត សទ្ធិវិហារិកគប្បីរំងាប់ ឬពឹងភិក្ខុដទៃឲ្យជួយរំងាប់ ឬធ្វើធម្មកថាលួងលោមឲ្យឧបជ្ឈាយ៍បាត់អផ្សុក បើសេចក្តីរង្គៀសសង្ស័យកើតឡើងដល់ឧបជ្ឈាយ៍ សទ្ធិវិហារិកគប្បីបន្ទោបង់ចេញ ឬពឹងគេឲ្យជួយបន្ទោបង់ឬធ្វើធម្មកថាឲ្យឧបជ្ឈាយ៍រំងាប់ចេញ បើទិដ្ឋិសេចក្តីឃើញខុសកើតឡើងដល់ឧបជ្ឈាយ៍ សទ្ធិវិហារិកគប្បីណែនាំឲ្យលះបង់ចេញ ឬពឹងភិក្ខុដទៃឲ្យណែនាំ ឬធ្វើធម្មកថាឲ្យឧបជ្ឈាយ៍រំងាប់បង់ចេញ ។

បើឧបជ្ឈាយ៍ត្រូវគរុកាបត្តិ គឺសង្ឆាទិសេស គួរនៅបរិវាសកម្ម ឬនៅបរិវាសត្រូវអន្តរាបត្តិ ជាអ្នកគួរដល់មូលាយបដិកស្សនៈគឺទាញមកដាក់ក្នុងមូលាបត្តិ ឬនៅបរិវាសហើយ ជាអ្នកគួរដល់មានត្ត ឬនៅមានត្តហើយជាអ្នកគួរដល់អព្ភានកម្ម កិច្ចទាំងអស់នេះ សទ្ធិវិហារិកគប្បីធ្វើសេចក្តីខ្វល់

ខ្វាយថា សង្ឆនឹងគប្បីឲ្យបរិវាស និងមូលាយបដិកស្សនៈ និងមានត្ត និងអព្ភានកម្មដល់ឧបជ្ឌាយ៍ ដោយឧបាយដូចម្តេចហ្ន៎ ដូច្នេះ ។

បើសង្ឆប្រាថ្នានឹងធ្វើនូវតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្ម ក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដល់ឧបជ្ឌាយ៍សោត សទ្ធិ-វិហារិកគប្បីខ្ជល់ខ្វាយថា ធ្វើដូចម្តេចសង្ឆនឹងមិនគប្បីធ្វើកម្មដល់ឧបជ្ឌាយ៍ ឬនឹងបង្ហោនទៅដើម្បីកម្មស្រាល ដូច្នេះ ។ បើកម្មនោះ សង្ឆធ្វើ ដល់ឧបជ្ឌាយ៍ហើយសោត សទ្ធិវិហារិកគប្បីធ្វើសេចក្តីខ្ជល់ខ្វាយថា ធ្វើដូចម្តេចហ្ន៎ ឧបជ្ឌាយ៍នឹងគប្បីបដិបត្តិប្រពៃ សង្ឆនឹងគប្បីរំដាប់កម្ម នោះឲ្យដូច្នេះ ។

បើចីវរឧបជ្ឌាយ៍ល្មមនឹងលាង ចីវរឧបជ្ឌាយ៍គួរនឹងធ្វើ ទឹកជ្រលក់ ឧបជ្ឌាយ៍គួរនឹងស្ងោរ ឬចីវរឧបជ្ឌាយ៍គួរនឹងជ្រលក់ កិច្ចទាំងអម្បាលនេះ សទ្ធិវិហារិកគប្បីធ្វើ ឬសទ្ធិវិហារិកគប្បីធ្វើសេចក្តីខ្ជល់ខ្វាយ ក្នុងកិច្ចទាំង អម្បាលនេះ ។ កាលដែលជ្រលក់ចីវរនៃឧបជ្ឌាយ៍ គប្បីជ្រលក់ជ្ជមៗ ត្រឡប់ចុះឡើងដោយប្រពៃ កាលហាលគន់មើលឈ្ជរទឹកក្នុងចីវរ នៅ មិនទាន់ដាច់ កុំអាលចៀសចេញទៅ ត្រូវនៅចាំសិន ។

មិនបានប្រាប់ឧបជ្ឌាយ៍មុន កុំឲ្យបាត្រចីវរបរិក្ខារ កុំអាលកោរសក់ ធ្វើបរិកម្មនិងធ្វើសេចក្តីខ្ជល់ខ្វាយឲ្យដល់ភិក្ខុណាមួយ និងកុំទទួលបាត្ર ចីវរភិក្ខុណាមួយ កុំឲ្យភិក្ខុដទៃកោរសក់ឲ្យ ធ្វើបរិកម្មឲ្យ ធ្វើសេចក្តីខ្ជល់ ខ្វាយឲ្យដល់ខ្លួន និងកុំធ្វើបច្ឆាសមណៈតាមក្រោយភិក្ខុដទៃទៅ កុំកាន់

យកភិក្ខុដទៃជាបច្ចាសមណៈ កុំនាំបិណ្ឌបាតទៅឲ្យភិក្ខុដទៃ កុំឲ្យភិក្ខុដទៃនាំបិណ្ឌបាតមកឲ្យ ដែលថាភិក្ខុដទៃនោះ គឺកំណត់យកភិក្ខុដែលជាវិសភាគ មិនត្រូវនឹងឧបជ្ឈាយ៍ គប្បីប្តឹងឧបជ្ឈាយ៍ជាមុនទើបធ្វើការទាំងអម្បាលនេះបាន ។

បើមិនលាឧបជ្ឈាយ៍ជាមុន កុំគប្បីចូលទៅក្នុងភូមិ កុំគប្បីទៅកាន់សុសានប្រទេស គឺទីដុតខ្មោច ដើម្បីនឹងនៅឬនឹងមើល កុំគប្បីទៅកាន់ទិស បើប្រាថ្នានឹងចូលទៅភូមិ ឬបិណ្ឌបាត ឬក៏ទៅដោយកិច្ចដទៃ គប្បីលាឧបជ្ឈាយ៍ជាមុនហើយសឹមទៅ ។ បើឧបជ្ឈាយ៍ប្រាថ្នានឹងក្រោកឡើងអំពីព្រឹកទៅកាន់ទីកិច្ចាចារធ្វាយសោត ឧបជ្ឈាយ៍ក៏គប្បីប្រាប់ភិក្ខុកំណើរៈថា អ្នកចូលទៅបិណ្ឌបាតចុះ ប្រាប់ដូច្នេះជាមុនហើយសឹមទៅ កាលបើមិនប្រាប់ដូច្នេះហើយទៅ សទ្ធិវិហារិកចូលទៅក្នុងបរិវេណមិនឃើញឧបជ្ឈាយ៍ នឹងចូលទៅក្នុងស្រុកក៏គួរ បើចូលទៅឃើញសោតតាំងអំពីទីដែលឃើញនិងលាក៏គួរ សទ្ធិវិហារិកចង់ចៀសចេញទៅកាន់ទិសដទៃ គប្បីប្រាប់កាលហើយអង្វរលា ៣ ដង បើឧបជ្ឈាយ៍អនុញ្ញាតក៏ជាការល្អ បើមិនអនុញ្ញាតទេ តែបើនៅអាស្រ័យនឹងឧបជ្ឈាយ៍ហើយរៀន ឧទ្ទេស ឬបរិបុច្ឆា ឬកម្មដ្ឋាន ឬប្រារព្ធសេចក្តីព្យាយាម ទាំងអម្បាលនេះ មិនបានបរិបូណ៌ ព្រោះឧបជ្ឈាយ៍ជាមនុស្សល្ងង់មិនឆ្ងាត មិនព្រមអនុញ្ញាត ចង់ឲ្យនៅតែក្នុងសំណាក់នៃខ្ជូនម្យ៉ាងប៉ុណ្ណោះ ឧបជ្ឈាយ៍ដូច្នេះ សូម្បីហាមឃាត់ឲ្យនៅ បើនឹងទៅក៏គួរ ។

បើឧបជ្ឈាយ៍មានជំងឺសោត សទ្ធិវិហារិកគប្បីឧបដ្ឋាកដរាបអស់កាលដែលលោកមានជីវិតរស់នៅ ឬទម្រាំអាពាធសះជា កុំគប្បីទៅក្នុងទីណាៗ បើមានភិក្ខុអ្នកឧបដ្ឋាកដទៃនៅសោត គប្បីស្វែងរកថ្នាំមកទុកក្នុងដៃភិក្ខុនោះ ហើយប្រាប់ថា ភិក្ខុអង្គនេះនឹងឧបដ្ឋាកបម្រើព្រះករុណា ហើយសឹមទៅ ។ សទ្ធិវិហារិក គប្បីបដិបត្តិប្រពៃក្នុងឧបជ្ឈាយ៍ទាំងឡាយយ៉ាងណា នេះឯង ជាឧបជ្ឈាយវត្តនៃសទ្ធិវិហារិក ។

ឧបជ្ឈាយវត្ត ចប់

សទ្ធិវិហារិកវត្ត

វត្តដែលឧបជ្ឈាយ៍គប្បីធ្វើចំពោះសទ្ធិវិហារិក ។ សេចក្តីថា ឧបជ្ឈាយ៍គប្បីបដិបត្តិប្រពៃ ក្នុងសទ្ធិវិហារិកទាំងឡាយ ។ សេចក្តីបដិបត្តិដោយប្រពៃនោះដូច្នេះ ឧបជ្ឈាយ៍គប្បីសង្គ្រោះ គប្បីអនុគ្រោះសទ្ធិវិហារិក ដោយឧទ្ទេស គឺប្រាប់បាលី ដោយបរិបុច្ឆា គឺប្រាប់សេចក្តីនៃបាលី ដោយឱវាទ គឺដំបូន្មាន ដោយអនុសាសនី គឺពាក្យប្រៀនប្រដៅ ។ បើឧបជ្ឈាយ៍មានបាត្រចីវរនិងសមណបរិក្ខារ ហើយសទ្ធិវិហារិកមិនមានសោត ឧបជ្ឈាយ៍គប្បីឲ្យ ឬគប្បីធ្វើសេចក្តីខ្ជល់ខ្ជាយថា ដូចម្តេចហ្ន៎ បាត្រ ចីវរ និងសមណបរិក្ខារ គប្បីកើតឡើងដល់សទ្ធិវិហារិកដូច្នេះ ។ បើសទ្ធិវិហារិកឈឺ ឧបជ្ឈាយ៍គប្បីបដិបត្តិដូចពោលហើយក្នុងឧបជ្ឈាយវត្តគ្រប់ៗប្រការចុះ ដ្បិតថាតាំងអំពីឲ្យ

ឈើស្ទន់ទៅ ដូចឧបជ្ឈាយវត្តគ្រប់ៗរឿង រៀងតែឧបជ្ឈាយ៍ មិនត្រូវ សំពះលាសទ្ធិវិហារិក គ្រាន់តែជ្រាប់ប៉ុណ្ណោះ តាំងអំពីឲ្យឈើស្ទន់ទៅ លុះដល់ដងទឹកទុកក្នុងក្អមជម្រះ វត្តទាំងអម្បាលនេះ ឧបជ្ឈាយ៍គប្បីធ្វើ ដល់សទ្ធិវិហារិក ក្នុងកាលដែលមានជំងឺមួយជំពូក ។ តែការដែល នាំសទ្ធិវិហារិកទៅ ដើម្បីរំដាប់សេចក្តីរសាប់រសល់ក្រវល់ក្រវាយជាដើម ទៅ សូម្បីសទ្ធិវិហារិកមិនឈឺ ឧបជ្ឈាយ៍ក៏ត្រូវធ្វើដោយពិត ។ ការគក់លាងចីវរ ស្ងោរទឹកជ្រលក់ ជ្រលក់ចីវរ ទាំងអម្បាលនេះ ឧបជ្ឈាយ៍គប្បីប្រដៅសទ្ធិវិហារិកឲ្យធ្វើដោយគោរពចុះ ឧបជ្ឈាយ៍ទាំង-ឡាយ គប្បីបដិបត្តិប្រពៃ ក្នុងសទ្ធិវិហារិកយ៉ាងណា នេះឯង ជា សទ្ធិវិហារិកវត្ត របស់ឧបជ្ឈាយ៍ ។

សទ្ធិវិហារិកវត្ត ចប់

អាចរិយវត្ត

វត្តដែលអន្តេវាសិក គប្បីធ្វើចំពោះអាចារ្យ ។ សេចក្តីថា អន្តេវាសិក អ្នកកាន់និស្សយនៅជាមួយនឹងអាចារ្យ គប្បីបដិបត្តិដោយប្រពៃក្នុងអាចារ្យ សេចក្តីបដិបត្តិដោយប្រពៃក្នុងអាចារ្យ ដូចឧបជ្ឈាយវត្តគ្រប់ប្រការ ។

អាចរិយវត្ត ចប់

អន្តេវាសិកវត្ត

វត្តដែលអាចារ្យគប្បីធ្វើចំពោះអន្តេវាសិក ។ សេចក្ដីថា អាចារ្យ អ្នកឲ្យនិស្សយ គប្បីបដិបត្តិប្រពៃក្នុងអន្តេវាសិក សេចក្ដីបដិបត្តិប្រពៃ ក្នុងអន្តេវាសិក ដូចសទ្ធិវិហារិកវត្តគ្រប់ប្រការ ។

អន្តេវាសិកវត្ត ចប់

វត្តទាំង ១៤ នេះ ភិក្ខុអាស្រ័យសេចក្ដីមិនអើពើ មិនធ្វើតាម ត្រូវ ទុក្កដ ក្នុងខណៈកាលដាក់ធុរៈថានឹងមិនធ្វើគ្រប់វត្តទៅ ។ តែក្នុងរឿង ណាជាពាក្យបដិសេធហាមប្រកបដោយ ន អក្ខរៈ ថាកុំ។ មិន។ បើ ព្យាយាមធ្វើក្នុងរឿងនោះ។ ត្រូវទុក្កដ ក្នុងខណៈកាលប្រព្រឹត្តកន្ទ គ្រប់ៗខ ។

វិធីកាន់យកនិស្សយ

កុលបុត្រអ្នកនឹងបួស គប្បីកោរសក់ កោរពុកមាត់ ហើយ ទទួលសំពត់កាសាវពស្ត្រអំពីភិក្ខុ រួចស្មៀកដណ្ដប់ហើយ ទទួលសរណ-គមន៍ក្នុងសំណាក់ភិក្ខុ ហើយអង្គុយច្រហោង ថ្វាយបង្គំបាទាទាំងពីរ លើកដៃប្រណម្យ ក្នុងសំណាក់ភិក្ខុណាហើយពោលថា **ឧបជ្ឈាយោ មេ ភន្តេ ហោហិ** *អស់វារៈ ៣ ដង សេចក្ដីថា លោកចូរជាឧប-ជ្ឈាយ៍នៃខ្ញុំដូច្នេះ ។ ភិក្ខុនោះឲ្យកុលបុត្រនោះដឹងសេចក្ដីដោយពាក្យថា* **សាហុ** *ឬ* **លហុ** *ឬ* **ឧចាយិកំ** *ឬ* **បដិរូបំ** *ឬ* **ចាសាឌិកេន**

សម្ជាឧេហិ ពាក្យទាំងអម្បាលនេះ ដោយបទណាមួយ ភិក្ខុអ្នកឲ្យកុលបុត្រដឹងនោះឈ្មោះថាឧបជ្ឈាយ៍ កុលបុត្រអ្នកសូមនោះជាសាមណេរក្តី ឬបានឧបសម្បទាជាភិក្ខុក្តី ឈ្មោះថាសទ្ធិវិហារិក ។ សទ្ធិវិហារិកនោះគប្បីបដិបត្តិដោយប្រពៃក្នុងឧបជ្ឈាយ៍ បើជាភិក្ខុមិនបដិបត្តិដោយប្រពៃ ត្រូវទុក្កដ ។ សទ្ធិវិហារិក កាលមិនធ្វើវត្តតាំងអំពីឲ្យឈើស្ទន់ជាដើម រហូតដល់ជ្រលក់ចីវរ សេចក្តីសាបសូន្យរមែងមានដល់ឧបជ្ឈាយ៍ ព្រោះហេតុនោះ សទ្ធិវិហារិក កាលមិនធ្វើវត្តនោះ សូម្បីជានិស្សយមុត្ត (រួចនិស្សុយហើយ) ក្តី នៅមិនទាន់រួចក្តី គង់ត្រូវអាបត្តិដោយពិត ។ កាលមិនធ្វើវត្តតាំងអំពីមិនប្រាប់ឧបជ្ឈាយ៍មុន ហើយឲ្យបាត្រចីវរជាដើមដល់បុគ្គលជំពូកខ្ទះ ចំពោះតែដែលនៅមិនទាន់រួចនិស្សុយម្យ៉ាង ទើបត្រូវអាបត្តិ ។ ឧបជ្ឈាយ៍មិនបដិបត្តិប្រពៃក្នុងសទ្ធិវិហារិក ក៏ត្រូវអាបត្តិទុក្កដដល់ឧបជ្ឈាយ៍ ។ ឧបជ្ឈាយ៍បដិបត្តិល្អ សទ្ធិវិហារិកទាំងឡាយមិនបដិបត្តិល្អ ត្រូវអាបត្តិដល់សទ្ធិវិហារិកទាំងឡាយនោះ ។ កាលឧបជ្ឈាយ៍ត្រេកអរនឹងធ្វើវត្ត សទ្ធិវិហារិកសូម្បីច្រើនគ្នាមិនធ្វើ ក៏ត្រូវអាបត្តិដូចគ្នាទាំងអស់ ។ បើឧបជ្ឈាយ៍ពោលថា មនុស្សអ្នកឧបដ្ឋាកយើងមាន លោកទាំងឡាយចូរធ្វើសេចក្តីព្យាយាម ក្នុងការស្វាធ្យាយន៍និងមនសិការកម្ម-ដ្ឋានជាដើមនៃខ្លួនចុះ ដូច្នេះមិនត្រូវអាបត្តិ ដល់សទ្ធិវិហារិកទាំងឡាយ ។ ឧបជ្ឈាយ៍ជាមនុស្សខ្ចៅ មិនដឹងនូវការដែលគួរត្រេកអរ ឬមិនគួរត្រេកអរនឹងវត្ត កាលសទ្ធិវិហារិកច្រើនគ្នា អង្គណាមួយ ជាអ្នកបរិបូណ៌ដោយវត្ត

បដិបត្តិធ្វើឲ្យជាការៈលើខ្លួនថា ខ្ញុំនឹងធ្វើកិច្ចដល់ឧបជ្ឈាយ៍ដោយខ្លួនខ្ញុំ លោកទាំងឡាយ ចូរមានសេចក្តីខ្ជល់ខ្ជាយតិចចុះ ដូច្នេះចាប់តាំងអំពីលោកអង្គនោះធ្វើឲ្យជាការៈខ្លួនហើយ មិនមានអាបត្តិដល់សទ្ធិវិហារិកទាំងអម្បាលនោះឡើយ ។

ភិក្ខុមិនមានឧបជ្ឈាយ៍ សូមនិស្សរ័យដោយអាការដូចពោលមកហើយខាងដើម ក្នុងសំណាក់នៃភិក្ខុដែលជាពហុស្សូត មានវស្សា ១០ ឡើងទៅ អង្គណាមួយ ដោយពាក្យថា **អាចរិយោ មេ ភន្តេ ហោហិ អាយស្មតោ និស្សាយ វត្ថាមិ** ដូច្នេះ (អស់វារៈ ៣ ដង) ហើយភិក្ខុនោះឲ្យដឹងសេចក្តីដោយពាក្យថា សាធុ ជាដើម ពាក្យណាមួយ លោកនោះឈ្មោះថាអាចារ្យអ្នកឲ្យនិស្សរ័យ ។ អ្នកសូមនិស្សរ័យ ឈ្មោះថានិស្សយន្តេវាសិក ជាសិស្សនៅក្នុងខាងក្នុងដោយនិស្សរ័យ ដែលនឹងត្រូវអាបត្តិដល់អន្តេវាសិកបែបនេះ គប្បីដឹងដោយលក្ខណៈដូចពោលហើយក្នុងសទ្ធិវិហារិក ដែលមិនធ្វើវត្តដល់ឧបជ្ឈាយ៍នោះចុះ ព្រោះថានិស្សយន្តេវាសិក អ្នកអាស្រ័យនៅ នៅអាស្រ័យអាចារ្យដរាបណា ត្រូវធ្វើអាចរិយវត្តដរាបនោះ ។ តែបព្វជ្ជន្តេវាសិក សិស្សអ្នកទទួលសរណគមន៍បួសជាសាមណេរ ឬឧបសម្បទន្តេវាសិក សិស្សដែលលោកសូត្រកម្មវាចា ឲ្យជាឧបសម្បន្នភិក្ខុ ឬធម្មន្តេវាសិក សិស្សអ្នករៀនធម៌ ៣ នេះ សូម្បីជានិស្សយមុត្ត រួចនិស្សរ័យហើយ ក៏នៅត្រូវធ្វើអាចរិយវត្ត តាំងអំពីដើមលុះដល់ជ្រលក់ចីវរ តែក្នុងវត្តជាដើមថា

មិនប្រាប់អាចារ្យជាមុន កុំឲ្យបាត្រចីវរដល់មនុស្សដទៃជាដើម ដរាបទៅ មិនមានអាបត្តិ ដល់អន្តេវាសិក ៣ ជំពូកនោះទេ ។ បព្វជ្ជន្តេវាសិក និង ឧបសម្ផទន្តេវាសិក ២ នេះ ជាការៈនៅលើអាចារ្យដរាបដល់អស់ជីវិត ។ តែនិស្សយន្តេវាសិក និងធម្មន្តេវាសិក ២ នេះ នៅក្នុងទីជិតអាចារ្យដរាប ណា ជាការៈលើអាចារ្យដរាបនោះ ។ ព្រោះហេតុនោះ សូម្បីអាចារ្យ ក៏គប្បីប្រតិបត្តិប្រពៃក្នុងអន្តេវាសិកទាំងអម្បាលនេះ ព្រោះថា បណ្ណ អាចារ្យ និងអន្តេវាសិកទាំងឡាយ អ្នកណា មិនប្រតិបត្តិប្រពៃតាម វត្តត្រូវអាបត្តិដល់អ្នកនោះ ព្រោះថាព្រះអង្គទ្រង់ប្រាថ្នានឹងឲ្យគោរពដល់ គ្នានិងគ្នា ទើបបានទ្រង់អនុញ្ញាតឧបជ្ឌាយ៍និងអាចារ្យទុកដូច្នេះថា តថា-គតអនុញ្ញាតឧបជ្ឌាយ៍ តថាគតអនុញ្ញាតអាចារ្យ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឌាយ៍និងអាចារ្យ គប្បីតាំងចិត្តដោយសេចក្តីស្រឡាញ់ក្នុងសទ្ធិវិហា-រិក និងអន្តេវាសិក ថាជាបុត្ររបស់ខ្លួន ។ សទ្ធិវិហារិកនិងអន្តេវាសិក គប្បីតាំងចិត្តដោយសេចក្តីស្រឡាញ់ ក្នុងឧបជ្ឌាយ៍និងអាចារ្យ ថាជា បិតារបស់ខ្លួន ។ កាលបើបដិបត្តិដូច្នេះ ភិក្ខុទាំងឡាយនោះ នឹងគោរព កោតក្រែងដល់គ្នានិងគ្នា នឹងមានការចិញ្ចឹមជីវិតស្មើគ្នា ហើយនឹងដល់ នូវសេចក្តីចម្រើនលូតលាស់ល្អពេញបរិបូណ៌ក្នុងធម្មវិន័យនេះ ព្រោះហេតុ នោះ គួរប្រតិបត្តិឲ្យប្រពៃដល់គ្នានិងគ្នា ។

<u>វិធីកាន់យកនិស្សៃ</u> ចប់

ការរម្ងាប់និស្សយ

ការរម្ងាប់និស្សយចាកឧបជ្ឈាយ៍មាន ៥ គឺ **បក្ខ្លាន្តោ វ ហោតិ** ឧបជ្ឈាយ៍ចៀសចេញទៅកាន់ទិស ចាកអាវាស ១ **វិព្ភន្តោ វ** ឧបជ្ឈាយ៍សឹកទៅ ១ **កាលកតោ វ** ឧបជ្ឈាយ៍ ធ្វើមរណកាល ១ **បក្ខ្ជសង្ខ្លន្តោ វ** ឧបជ្ឈាយ៍ទៅជាពួកអន្យតិ្ថិយ ១ **អាណត្តិ យេវ បញ្ចមី** សទ្ធិវិហារិកប្រកបដោយអង្គជាទោសប្រាំ(១) ដែលឧបជ្ឈាយ៍ប្រណាមចេញ ជាគម្រប់ ៥ ។ ដែលថានិស្សយរំងាប់ដោយឧបជ្ឈាយ៍ប្រាសចាកអាវាសចៀសទៅកាន់ទិសដទៃនោះ កាលលោកទៅហើយ បើក្នុងវិហារនោះអាចារ្យអ្នកឲ្យនិស្សយណាមួយមាននៅសោត គឺក្នុងកាលមុនធ្លាប់កាន់និស្សយនៅក្នុងសំណាក់លោកអង្គណា ឬថាលោកអង្គណាដែលមានសម្ភោគ:នឹងបរិភោគជាមួយគ្នាក៏គប្បីកាន់និស្សយក្នុងសំណាក់នៃលោកអង្គនោះ ។ ព្រោះសូម្បីតែមួយថ្ងៃក៏ពុំមានការបរិហារឡើយ ។ បើអាចារ្យបែបនោះ មិនមានសោតភិក្ខុដទៃជាលជ្ជីមានសីលជាទីស្រឡាញ់មាននៅ កាលដឹងថាលោកនោះជាអ្នកមានសីលជាទីស្រឡាញ់ហើយ ក៏គប្បីសូមនិស្សយនឹងលោកនោះក្នុងថ្ងៃនោះ បើលោកនោះឲ្យជាការល្អ តែបើលោកសួរថា ឧបជ្ឈាយ៍

(១) អង្គ ៥ នោះគឺសទ្ធិវិហារិក គ្មានសេចក្តីស្រឡាញ់ឧបជ្ឈាយ៍ដោយពិត ១ គ្មានសេចក្តីជ្រះថ្លាដោយពិត ១ គ្មានសេចក្តីអៀនខ្មាសដោយពិត ១ គ្មានសេចក្តីគោរពដោយពិត ១ គ្មានសេចក្តីចម្រើនមេត្តាភាវនាដោយពិត ១ ។ វិន័យបិដក មហាវគ្គ បឋមភាគ ទំព័រ ១៦៥ ។

នៃអ្នកនឹងមកធាប់ឬ ហើយបើឧបជ្ឌាយ៍ផ្តាំទុកថា នឹងមកធាប់សោត ក៏គប្បីប្រាប់ថា លោកនឹងមកធាប់ បើលោកប្រាប់ថា បើដូច្នោះ លោកចូររង់ចាំឧបជ្ឌាយ៍លោកមកចុះ ដូច្នេះក៏គួរ ។ បើមិនដឹងថា ភិក្ខុនោះមានសីលជាទីស្រឡាញ់ ក៏គប្បីសង្កេតមើលថា ភិក្ខុនោះ ជាសភាគ: ឬមិនជាសភាគ: ប្រមាណ ពីរបីថ្ងៃសិនហើយ សឹមឲ្យ ធ្វើឱ្យកាស រួចកាន់និស្សយក្នុងសំណាក់ភិក្ខុនោះ ថាបើក្នុងវិហារ ភិក្ខុឲ្យ និស្សយមិនមានសោត តែឧបជ្ឌាយ៍ប្រាប់ទុកថា យើងនឹងទៅប្រមាណ ពីរបីថ្ងៃ លោកកុំអផ្សុកឡើយ ដូច្នេះរមែងមានការបរិហារដរាបដល់ ឧបជ្ឌាយ៍ត្រឡប់មក ។ ថាបើទាយកគេនិមន្តឧបជ្ឌាយ៍ ឲ្យនៅក្នុងទីនោះ ទៀត ៥ ថ្ងៃ ឬ ១០ ថ្ងៃ លើសជាងកាលកំណត់ឡើងទៅ ឧបជ្ឌាយ៍នោះ គប្បីបញ្ជូនដំណឹងមកកាន់វិហារថា ភិក្ខុកំលោះទាំងឡាយ កុំអផ្សុកឡើយ យើងនឹងមកក្នុងថ្ងៃឯណោះ សូម្បីដូច្នេះក៏នៅមានការបរិហារទៀត ។ កាលឧបជ្ឌាយ៍ត្រឡប់មក បើមានសេចក្តីអន្តរាយកើតឡើងកណ្តាលផ្លូវ ដោយទឹកជន់ពេញក្នុងស្ទឹង ឬចោរជាដើមសោត ឧបជ្ឌាយ៍រង់ចាំទឹក ស្រកទៅ ឬស្វែងរកមិត្រសម្ងាញ់ បើភិក្ខុកំលោះបានឮដំណឹងដូច្នោះ សោត ក៏នៅមានបរិហារដរាបដល់ឧបជ្ឌាយ៍មក ។ បើឧបជ្ឌាយ៍ផ្តាំថា យើងនឹងនៅក្នុងទីនោះសោត ដូច្នេះការបរិហារមិនមានឡើយ ។ បាន និស្សយក្នុងទីណា គប្បីទៅទីនោះ ។ កាលបើឧបជ្ឌាយ៍សឹកឃ្លាតចាក សាសនា ឬទទួលអនិច្ចធម្ម ឬត្រឡប់ទៅជាអន្យតិរ្ថិយ ៣ យ៉ាងនេះ

ការបរិហារសូម្បីតែមួយថ្ងៃ ក៏គ្មានឡើយ ធ្លាប់បាននិស្សម្ភយក្នុងទីណា គប្បីទៅក្នុងទីនោះចុះ ។ ដែលថានិស្សម្ភយរំដាប់ដោយឧបជ្ឈាយ៍ប្រណាមនោះ សទ្ធិវិហារិកមិនប្រតិបត្តិប្រពៃ ឧបជ្ឈាយ៍គប្បីប្រណាមចេញ ដោយពាក្យថា **បណាមេមិ តំ** ឬថា **មាយិ ឧ បដិ ក្ខ្ញមិ** ឬថា **នីហារ តេ បត្តចីវរំ** ឬថា **ឆាហំ តយា ឧបដ្ឋាតព្ពោ** ដូច្នេះ បទណាមួយ ឬពោលពាក្យផុតចាកបាលីជាដើមថា អ្នកកាលចូលទៅស្រុក កុំប្រាប់ដល់យើងឡើយដូច្នេះ ឈ្មោះថាប្រណាមចេញចាកនិស្សម្ភយ និស្សម្ភយរំដាប់ ។ ភិក្ខុនោះគប្បីសូមឧបជ្ឈាយ៍ឲ្យអត់ទោស បើឧបជ្ឈាយ៍មិនអត់ទោសអំពីដើមទៅ សោត ភិក្ខុនោះគប្បីធ្វើទណ្ឌកម្មខ្លួនឯង មានដង្ហមទឹកជញ្ជូនខ្សាច់ជាដើម ហើយសូមខមាទោសខ្លួនឯង ៣ ដង្ហមសិន បើឧបជ្ឈាយ៍មិនអត់ទោសឲ្យសោត គប្បីនាំមហាថេរ ក្នុងវិហារនោះទៅជួយសូមខមាទោសឲ្យ ។ ថាបើឧបជ្ឈាយ៍មិនអត់ទោសឲ្យទៀតសោត គប្បីនាំភិក្ខុទាំងឡាយ ក្នុងវិហារជិតមកឲ្យជួយសូមខមាទោសឲ្យ ថាបើធ្វើដូច្នេះហើយ ឧបជ្ឈាយ៍មិនអត់ទោសឲ្យទៀតសោត គប្បីទៅក្នុងទីដទៃហើយនៅក្នុងទីសំណាក់ភិក្ខុទាំងឡាយដែលជាសភាគ:ដល់ឧបជ្ឈាយ៍ ដោយគិតថា ក្រែងឧបជ្ឈាយ៍ដឹងថានៅក្នុងសំណាក់ភិក្ខុជាសភាគ:របស់លោកហើយ នឹងអត់ទោសឲ្យ សូម្បីដូច្នេះ លោកនៅតែមិនអត់ទោសឲ្យ ក៏គប្បីនៅក្នុងទីនោះចុះ ។ បើមិនអាចនៅក្នុងទីនោះបាន ដោយទោសមានអត់ចាយ

ជាដើម នឹងត្រឡប់មកវិហារដើមនោះ រួចកាន់និស្សរ្ជ័យក្នុងសំណាក់ភិក្ខុដទៃក៏គួរ ។ នេះជាសេចក្តីវិនិច្ឆ័យនិស្សរ្ជ័យរំងាប់ចាកឧបជ្ឈាយ៍ ។

ឯការរំងាប់និស្សរ្ជ័យចាកអាចារ្យមាន ៦ គឺ អាចារ្យចៀសចេញទៅកាន់ទិស ១ សឹកទៅ ១ ផ្ងើមរណកាល ១ ទៅជាពួកអន្យតិរ្ថិយ ១ និងប្រណាមចេញជាគម្រប់ ៥ **ឧបជ្ឈាយេន វា សមោធានកតោ** ឬបានជួប បានឃើញឧបជ្ឈាយ៍ បានឮសំឡេងឧបជ្ឈាយ៍ហើយក៏ចាំបានជាគម្រប់ ៦ ។ ដែលថាចៀសចេញទៅកាន់ទិសនោះ មានកាលអាចារ្យប្រាប់មុនទើបចៀសទៅ ។ មានកាលអាចារ្យមិនប្រាប់ សូម្បីអន្តេវាសិកក៏ដូចគ្នា ។ ថាបើអន្តេវាសិកលាអាចារ្យថា ខ្ញុំប្រាថ្នានឹងទៅកាន់ទីឯណោះ ដោយកិច្ចណាមួយ អាចារ្យសួរថានឹងទៅក្នុងកាលណា ប្រាប់ថានឹងទៅវេលាល្ងាច ឬនឹងក្រោកឡើងទៅក្នុងវេលាយប់ សូម្បីអាចារ្យទទួលថាប្រពៃហើយ និស្សរ្ជ័យក៏រំងាប់ក្នុងខណៈនោះ ។ បើលាថា ខ្ញុំប្រាថ្នានឹងទៅកាន់ទីឯណោះ អាចារ្យប្រាប់ថា លោកទៅបិណ្ឌបាតក្នុងភូមិឯណោះហើយ ទើបនឹងដឹងក្នុងកាលជាខាងក្រោយ ទាំងអន្តេវាសិកនោះក៏ទទួលថាប្រពៃហើយ បើទៅចាកភូមិនោះឈ្មោះថាទៅដោយប្រពៃ បើមិនទៅនិស្សរ្ជ័យក៏មិនរំងាប់ ។ បើលាថានឹងទៅ អាចារ្យថាកុំអាលទៅ ចាំវេលាយប់ យើងនឹងប្រឹក្សាមើលសិនទើបដឹង ប្រឹក្សាហើយទៅ ឈ្មោះថាទៅដោយប្រពៃ ថាបើមិនទៅសោត និស្សរ្ជ័យក៏មិនរំងាប់ ។ ឯមិនលាអាចារ្យហើយចៀសចេញទៅ សូម្បីកន្ទងផុតឧបចារសីមា និស្សរ្ជ័យក៏រំងាប់ កាល

ត្រឡប់មកវិញចាកខាងក្នុងឧបចារសីមា មិនរំងាប់ បើអាចារ្យប្រាប់អន្តេ-
វាសិកថា យើងនឹងទៅកាន់ទីឯណោះ តែអន្តេវាសិកសួរថាលោកនឹងទៅ
វេលាណា ប្រាប់ថានឹងទៅក្នុងវេលារសៀល ឬរាត្រីក្តី សូម្បីអន្តេវាសិក
ទទួលថាប្រពៃហើយ និស្សរ្ជយក៏រំងាប់ក្នុងខណៈនោះ ។ បើអាចារ្យ
ប្រាប់ថាព្រឹកស្អែកទៅបិណ្ឌបាតហើយសឹមទៅ ឯអន្តេវាសិកក៏ទទួលថា
ប្រពៃហើយ និស្សរ្ជយនៅមិនទាន់រំងាប់ ក្នុងថ្ងៃមួយនោះទេ លុះដល់ក្នុង
ថ្ងៃព្រឹកស្អែកទើបបានរំងាប់ ។ បើអាចារ្យប្រាប់ថានឹងទៅបិណ្ឌបាតក្នុង
ភូមិឯណោះ ហើយទើបនឹងដឹងថាទៅឬមិនទៅ ថាបើមិនទៅទេ និស្សរ្ជយ
ក៏មិនរំងាប់ ។ បើប្រាប់ថានឹងទៅ អន្តេវាសិកឃាត់ថាកុំអាលទៅ
ចាំវេលារាត្រីប្រឹក្សាមើលទើបនឹងដឹង បើប្រឹក្សាហើយមិនទៅ និស្សរ្ជយ
មិនរំងាប់ ។ កាលអាចារ្យនិងអន្តេវាសិក ទាំងពីរទៅក្រៅសីមា ដោយ
កិច្ចណាមួយ បើអាចារ្យមានចិត្តគិតនឹងទៅកើតឡើងក្នុងទីនោះ មិនប្រាប់
ហើយទៅ រួចត្រឡប់មកវិញក្នុងខាងក្នុង ២ លេខ្ទុបាតសោត និស្សរ្ជយ
មិនរំងាប់ បើកន្ទង ២ លេខ្ទុបាតចេញទៅហើយត្រឡប់មក និស្សរ្ជយ
ទើបរំងាប់ អាចារ្យនិងឧបជ្ឈាយ៍ កន្ទង ២ លេខ្ទុបាតចេញទៅ ហើយនៅ
ក្នុងវិហារដទៃ និស្សរ្ជយក៏រំងាប់ ។ កាលអាចារ្យឃ្លាតចាកសាសនា និង
ទទួលអនិច្ចធម្ម ឬត្រឡប់ទៅជាអន្យតិរ្ថិយ និស្សរ្ជយរំងាប់ក្នុងខណៈនោះ
ឯង ។ ឯក្នុងការប្រណាមអន្តេវាសិក ដែលមិនបានប្រព្រឹត្តល្អ ដោយ
ពាក្យជាដើមថា **បណ្ណាមេមិ តំ** នោះ ថាបើអាចារ្យប្រាថ្នានឹងបោះ

បង់ចោល ដោយប្រណាមនិស្សរ័យ តែអន្តេវាសិកនៅមានអាល័យថា អាចារ្យប្រណាមយើងក៏ពិតមែនហើយ ប៉ុន្តែលោកនៅមានចិត្តទន់នៅ ឡើយដូច្នេះ និស្សរ័យមិនរំដាប់ ។ បើអាចារ្យមានអាល័យនៅឡើយ តែអន្តេវាសិកមិនមានអាល័យ ដាក់ធុរៈថា ឥឡូវនេះ យើងមិនអាស្រ័យ លោកទេ សូម្បីដូច្នេះក៏មិនទាន់រំដាប់ ។ បើមានអាល័យទាំងសងខាង និស្សរ័យក៏មិនរំដាប់ កាលអ្នកទាំងពីរដាក់ធុរៈ ទាំងសងខាង ទើបរំដាប់ ។ អន្តេវាសិកដែលត្រូវអាចារ្យប្រណាមចេញហើយ គប្បីធ្វើទណ្ឌកម្មខ្លួនឯង ឲ្យលោកអត់ទោសអស់វារៈ ៣ ដង បើលោកមិនអត់ទោសទេ គប្បី បដិបត្តិដោយន័យដូចពោលហើយក្នុងឧបជ្ឈាយ៍នោះចុះ ។ ដែលពោលថា បានជួបនឹងឧបជ្ឈាយ៍នោះ គប្បីដឹងដោយកិរិយាឃើញ និងឮនោះចុះ បើសទ្ធិវិហារិកនៅអាស្រ័យនឹងអាចារ្យ បានឃើញឧបជ្ឈាយ៍ថ្វាយបង្គំ ព្រះចេតិយនៅក្នុងវិហារជាមួយគ្នា ឬទៅបិណ្ឌបាតក្នុងស្រុកជាមួយគ្នា និស្សរ័យក៏រំដាប់ចាកអាចារ្យ ។ បើឧបជ្ឈាយ៍ឃើញ តែសទ្ធិវិហារិកមិន ឃើញមិនរំដាប់ ឃើញឧបជ្ឈាយ៍ដើរទៅឬទៅដោយអាកាស ស្គាល់ថាជា ភិក្ខុអំពីចម្ងាយ មិនស្គាល់ថាជាឧបជ្ឈាយ៍ និស្សរ័យមិនរំដាប់ បើស្គាល់ទើប រំដាប់ ។ ឧបជ្ឈាយ៍នៅលើប្រាសាទ សទ្ធិវិហារិកនៅខាងក្រោម មិន ឃើញឧបជ្ឈាយ៍ឡើយ ធាន់បបរហើយក៏ចៀសចេញទៅ ឬឧបជ្ឈាយ៍ អង្គុយក្នុងរោងធាន់ មិនឃើញឧបជ្ឈាយ៍ឡើយ ធាន់នៅក្នុងទីម្ខាង ហើយក៏ចៀសទៅ ឬឧបជ្ឈាយ៍អង្គុយក្នុងមណ្ឌបជាទីស្តាប់ធម៌ មិនឃើញ

លោកឡើយ ស្តាប់ធម៌ហើយ ក៏ចៀសចេញទៅ និស្សយមិនរំដាប់ យ៉ាងនេះឯង គប្បីដឹងថា បានជួបឧបជ្ឈាយ៍ដោយកិរិយាបានឃើញ ។ បានឮសំឡេងឧបជ្ឈាយ៍សម្តែងធម៌ ឬធ្វើអនុមោទនាក្នុងវិហារ ឬក្នុងលង្វែកផ្ទះ បើចាំបានថាសំឡេងឧបជ្ឈាយ៍យើងដូច្នេះ និស្សយរំដាប់ បើចាំមិនបាន មិនរំដាប់ ។ វិនិច្ឆ័យក្នុងនិស្សយរំដាប់ចាកអាចារ្យដូច្នេះឯង ។

សទ្ធិវិហារិកនិងអន្តេវាសិក ប្រកបដោយអង្គជាទោស ៥ ដូច្នេះគឺ **ជានិមត្តំ បេមំ ហោតិ** មិនស្រឡាញ់ឧបជ្ឈាយ៍អាចារ្យដោយពិត ១ **ជានិមត្តោ បសាទោ ហោតិ** មិនជ្រះថ្លាដោយពិត ១ **ជានិមត្តា ហិរី ហោតិ** មិនអៀនខ្មាសដោយពិត ១ **ជានិមត្តោ ការោ ហោតិ** មិនគោរពដោយពិត ១ **ជានិមត្តា ភាវនា ហោតិ** មិនចម្រើនមេត្តាភាវនាដោយពិត ១ ។ សទ្ធិវិហារិក អន្តេវាសិក ប្រកបដោយអង្គជាទោស ៥ ប្រការដូច្នេះ គួរប្រណាម បើឧបជ្ឈាយ៍អាចារ្យមិនប្រណាមទេ ត្រូវទុក្កដ ។

សទ្ធិវិហារិកអន្តេវាសិក ប្រកបដោយអង្គជាគុណ ៥ គឺស្រឡាញ់ឧបជ្ឈាយ៍អាចារ្យដោយពិត ១ ជ្រះថ្លាដោយពិត ១ អៀនខ្មាសដោយពិត ១ គោរពដោយពិត ១ ចម្រើនមេត្តាភាវនាដោយពិត ១ ព្រមដោយអង្គជាគុណ ៥ ប្រការដូច្នេះ មិនគួរប្រណាម បើឧបជ្ឈាយ៍អាចារ្យប្រណាម ត្រូវទុក្កដ ។ សទ្ធិវិហារិកអន្តេវាសិក ដែលឧបជ្ឈាយ៍អាចារ្យប្រណាមហើយ គប្បីសូមខមាទោសលោកដូចពោលមកហើយខាងដើម បើមិនសូមខមា

ទោស ត្រូវទុក្កដ ។ ឧបជ្ឈាយ៍អាចារ្យទៀត ដែលសទ្ធិវិហារិក អន្តេវាសិក សូមខមាទោស មិនអត់ទោសឲ្យក៏ត្រូវទុក្កដ ។

មួយទៀត ភិក្ខុជាមនុស្សឈ្លាសអង់អាចជាពហុស្សូត ទ្រង់គុណជាដើមថា ដឹងអាបត្តិនិងអនាបត្តិ រក្សាខ្លួនឯងនិងអ្នកដទៃបាន មានវស្សាអំពី ១០ ឡើងទៅ ទើបគួរជាឧបជ្ឈាយ៍ ជាអាចារ្យ ឲ្យនិស្សយ ដល់ភិក្ខុ និងសាមណេរបាន ។

មួយទៀត ភិក្ខុជាមនុស្សឈ្លាសអង់អាច ជាពហុស្សូត ទ្រង់គុណជាដើមថា ដឹងអាបត្តិនិងអនាបត្តិ រក្សាខ្លួនឯងបាន ហើយមានវស្សាអំពី ៥ ឡើងទៅ ទើបជានិស្សយមុត្ត រួចចាកនិស្សយបាន ។ បើមិនឈ្លាស សូម្បីមានវស្សាដល់ ១០ ក៏មិនជានិស្សយមុត្ត រួចចាកនិស្សយបាន ។ ភិក្ខុមិនទាន់បាននិស្សយមុត្ត មិនកាន់យកនិស្សយនៅបាន ចំពោះតែភិក្ខុឈឺ និងភិក្ខុអ្នកឧបដ្ឋាកភិក្ខុឈឺដែលភិក្ខុឈឺអង្វរ (ឲ្យនៅកំដរ) ភិក្ខុដើរផ្លូវ និងភិក្ខុនៅព្រៃកំណត់ផាសុវិហារ គឺបានសមថ: និងវិបស្សនាឡើងថ្មី ទាំងអម្បាលនេះ កាលមិនមានអ្នកឲ្យនិស្សយ មិនកាន់យកនិស្សយក៏គួរ ព្រោះព្រះអង្គទ្រង់អនុញ្ញាត ។ ភិក្ខុក្រៅនោះ បើមិនកាន់យកនិស្សយមិនគួរ ។ តែភិក្ខុនៅព្រៃឲ្យចង់ចិត្តថា កាលណាមានអ្នកឲ្យនិស្សយដ៏សមគួរមក យើងនឹងអាស្រ័យលោកនោះ ។ ឯអាចារ្យអ្នកឲ្យនិស្សយ បើឲ្យនិស្សយដល់ភិក្ខុដែលជាអលជ្ជី ត្រូវអាបត្តិទុក្កដ ។ ឯភិក្ខុកំលោះបើកាន់និស្សយក្នុងសំណាក់ភិក្ខុជាអលជ្ជី ត្រូវអាបត្តិទុក្កដ ។ ព្រោះ

ហេតុនោះទាំងអាចារ្យនិងភិក្ខុកំណោះ កាលមិនធ្វាប់ឲ្យនិស្សរ័យនិងមិនធ្វាប់នៅជាមួយគ្នា គប្បីរង់ចាំមើលថាជាសភាគ: ឬមិនជាសភាគ: បានចំនួន ៤-៥ ថ្ងៃសិន ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ ចតូហបញ្ចាហំ អាគមេតុំ យាវ ភិក្ខុសភាគំ ជានាមិ** ដូច្នេះ ។ ថាមិនត្រូវអាបត្តិដល់ភិក្ខុកំណោះដែលរង់ចាំមើលនោះ ។

វត្ថុកថា ចប់

ប្រភេទនៃទុក្កដាបត្តិ

ប្រភេទនៃទុក្កដាបត្តិនោះ ពោលដោយអាគតដ្ឋាន គឺទីមក ដោយសង្ខេបមាន ២ ប្រការគឺ មកក្នុងបាលីដែលព្រះពុទ្ធអង្គទ្រង់បញ្ញត្ត ហៅថាបាលីទុក្កដ ១ មកក្នុងអដ្ឋកថា ក្រៅពីបាលី ដែលព្រះសង្គីតិកាចារ្យ លោកជាអ្នកដឹងពុទ្ធាធិប្បាយ តែងតាំងទុក ហៅថា បាលីមុត្តកទុក្កដ ១ ។ បាលីទុក្កដ ពោលដោយទីមកមាន ៥ ស្ថាន គឺ មកក្នុងសេខិយ: ឈ្មោះថាសេខិយទុក្កដ ១ មកក្នុងនិទានៃសិក្ខាបទឈ្មោះថា និទានទុក្កដ ១ មកក្នុងវិនីតវត្ថុនៃបារាជិក និងសង្ឆាទិសេស ឈ្មោះថាវិនីតវត្ថុទុក្កដ ១ មកក្នុងវិភង្គនៃបារាជិកជាដើមឈ្មោះថា វិភង្គទុក្កដ ១ មកក្នុងមហាខន្ធកជាដើម ឈ្មោះថាខន្ធកទុក្កដ ១ ។

ចាលីឧក្ក

សេខិយទុក្កដ មកក្នុងបាលីនៃសេខិយសិក្ខាបទ ៧៥ ដូចបានពោលហើយក្នុងសេខិយវត្ត ។ និទានទុក្កដ មាន ២ ប្រការ ខមួយ មកក្នុងនិទាននៃទុតិយបារាជិក ថាព្រះអង្គឃើញព្រះធនិយត្ថេរធ្វើកុដិដោយដីសុទ្ធ ត្រាស់បង្គាប់ឲ្យកិក្ខុទាំងឡាយទៅទម្លាយចេញ ហើយទ្រង់បញ្ញត្តទុកថា **ជ ច ភិក្ខវេ សព្ពមត្តិកាមយា កុដិ ការេតព្ពា...** *ថាកិក្ខុកុំគប្បីធ្វើកុដិដោយដីសុទ្ធ បើធ្វើត្រូវទុក្កដ ។ សូម្បីបានកុដិដីសុទ្ធដែលអ្នកដទៃកន្ទងសិក្ខាបទធ្វើទុកហើយ ទៅនៅក្នុងកុដិនោះ ត្រូវទុក្កដ ។ តែបើលាយដោយគ្រឿងទព្វសម្ភារ: ឬលាយដោយរបស់ណាមួយក៏គួរធ្វើដោយដីសុទ្ធមិនគួរ ។ សូម្បីកុដិនោះគេធ្វើសង្ខេបថា ជាផ្ទះដោយឥដ្ឋក៏គួរ ។ ព្រោះព្រះអង្គត្រាស់បង្គាប់ឲ្យកិក្ខុទៅទម្លាយចេញ សូម្បីក្នុងកាលឥឡូវនេះ កិក្ខុជាពហុស្សុតចេះដឹងវិន័យ បើឃើញកិក្ខុដទៃកាន់គ្រឿងបរិក្ខារ ដែលមិនគួរដើរទៅ កាត់ទម្លាយចេញខ្លួនឯង ឬឲ្យអ្នកដទៃកាត់ទម្លាយនូវបរិក្ខារនោះ កិក្ខុជាម្ចាស់របស់តិះដៀលមិនបាន កុំគប្បីចោទកិក្ខុនោះ កុំគប្បីពោលរំលឹកថាបរិក្ខាររបស់យើង លោកធ្វើឲ្យវិនាសហើយ លោកចូរសងយើងវិញដូច្នេះឡើយ ។ រឿងនេះក្នុងអដ្ឋកថា លោកវិនិច្ឆ័យ កប្ប៊ិយាកប្ប៊ិយបរិក្ខារ ជាបាលីមុត្តក: ដូចពោលហើយក្នុងបរិក្ខារកថា ។ ខមួយ ព្រះពុទ្ធអង្គទ្រង់បញ្ញត្តទុក*

ក្នុងនិទានៃសុរុសុរុសិក្ខាបទថា **ន ភិក្ខវេ ពុទ្ធំ វា ធម្មំ វា សង្ឆំ វា អារព្ភ ឧភោ កាតព្ពោ...** ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវនិយាយឡកលេងប្រារព្ធព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឆ ដោយបរិយាយណាមួយជាដើម ថាព្រះពុទ្ធអ្វី ព្រះអង្គទើបនឹងភ្ជាក់អំពីសិង និងមិនទាន់ភ្ជាក់អំពីសិង ព្រះធម៌អ្វី ព្រះធម៌គោ ព្រះធម៌ពពែ ព្រះសង្ឆថាពួក ពួកអ្វី ពួកម្រឹគ ពួកសត្វចិញ្ចឹម បើភិក្ខុណានិយាយឡកលេងដូច្នេះ ត្រូវទុក្កដ ។

វិនីតវត្ថុទុក្កដនោះ បានពោលអំពីមុនខ្លះហើយ គប្បីដឹងក្នុងពាក្យដែលពោលអាងថា ព្រះអង្គទ្រង់បញ្ញត្តទុក ក្នុងវិនីតវត្ថុទុក្កដនោះចុះ ។ ដែលសល់នៅនោះគឺ ១មួយ ក្នុងវិនីតវត្ថុនៃទុតិយបារាជិកទ្រង់ហាមឃាត់ទុកថា **ន ច ភិក្ខវេ រុត្តោ រជ្ជេមីតិ វត្តព្ពោ ន ច រុត្តោ រជ្ជេហីតិ វត្តព្ពោ យោ វនេយ្យ អាបត្តិ ឧក្ក្ជ្ជ**ម្នាលភិក្ខុទាំងឡាយ តែភិក្ខុកុំគប្បីពោលថាលោកផ្ដាំនឹងខ្ញុំហើយ ខ្ញុំនឹងប្រាប់ដូច្នេះ ម្យ៉ាងទៀត កុំគប្បីពោលថា ខ្ញុំផ្ដាំនឹងលោកហើយលោកប្រាប់ចុះ តែភិក្ខុណាពោល ភិក្ខុនោះត្រូវទុក្កដ ។

១មួយ ទ្រង់ហាមឃាត់ទុកថា ភិក្ខុកុំគប្បីពោលនឹងភិក្ខុផងគ្នាថាយើងពោលបង្គាប់លោក លោកចូរនិយាយតាមពាក្យយើង បើភិក្ខុណាពោលសេចក្ដីមិនច្បាស់ចេញទៅដូច្នេះ ត្រូវទុក្កដ ។ ក្នុងបទទាំងពីរ

នេះ កំណត់ពាក្យពោលឲ្យច្បាស់ចេញទៅជាដើមថា យើងបង្គាប់លោកឲ្យទៅកាន់យកវត្ថុនេះ។ លោកចូរទៅកាន់យកវត្ថុនេះ។ ក្នុងទីឯណោះដូច្នេះក៏គួរ ដ្បិតពោលប៉ុណ្ណោះទើបរួចចាកទោសឧបារម្ភៈបាន ។

ខមួយ ក្នុងវិនីតវត្ថុនៃតតិយបារាជិក ទ្រង់ហាមឃាត់ទុកថា **ន ច ភិក្ខវេ អត្ថាយ ចាតេតព្ពំ យោ ចាតេយ្យ អាបត្តិ ទុក្កដស្ស** ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែភិក្ខុកុំគប្បីធ្វើខ្លួនឲ្យធ្លាក់ចុះ (គឺលោតទម្លាក់ក្នុងជ្រោះ ឲ្យស្លាប់ជាដើម) ភិក្ខុណាទម្លាក់សម្លាប់ខ្លួនឯង (ភិក្ខុនោះ) ត្រូវទុក្កដ។ មិនមែនគ្រាន់តែមិនឲ្យទម្លាក់ខ្លួនទៅមួយជំពូកប៉ុណ្ណោះទេ គឺកុំគប្បីសម្លាប់ខ្លួនដោយសេចក្តីព្យាយាមណាមួយ ឬដោយហេតុដទៃ ដោយហោចទៅ សូម្បីដោយអាហារ សូម្បីមានជំងឺ កាលបើមានថ្នាំនិងមនុស្សឧបដ្ឋាកបម្រើ តែចង់ឲ្យស្លាប់ ផ្តាច់អាហារចេញ ត្រូវទុក្កដ ។ តែបើមានអាពាធធ្ងន់គ្រាំគ្រាមកយូរ ភិក្ខុទាំង-ឡាយអ្នកឧបដ្ឋាកលំបាកក៏នឿយណាយ បើភិក្ខុនោះគិតថា អត្តភាពនេះ សូម្បីនឹងបដិបត្តិទៅក៏មិនបិតនៅយូរប៉ុន្មាន ភិក្ខុទាំងអម្បាលនោះនឹងមានសេចក្តីលំបាកផង ហើយភិក្ខុនោះផ្តាច់អាហារចេញ មិនបរិភោគថ្នាំក៏គួរ ។ ភិក្ខុណាផ្តាច់អាហារចេញគិតថា ពោគនេះកម្រើកខ្លាំងឡើងណាស់ អាយុសង្ខារនឹងតាំងនៅមិនបាន ឯសេចក្តីត្រាស់ដឹងវិសេស ហាក់បីដូចជានឹងដល់ក្នុងដៃដូច្នេះគួរពិត សូម្បីមិនមានជំងឺកើតសេចក្តីសង្វេគឡើងគិតថា ត្រាប់ស្វែងរកអាហារជាដំណើរយឺតយូរ យើងនឹងប្រកបតែកម្មដ្ឋាន

មួយជំពូក និងផ្ទាប់អាហារដោយកម្មដ្ឋានជាប្រធានដូច្នេះ ក៏គួរ តែបើ ផ្ទាប់អាហារចេញ ព្រោះនឹងព្យាករសេចក្ដីត្រាស់ដឹងវិសេសមិនគួរ ដ្បិត ថាបើនិយាយគ្នានឹងភិក្ខុជាលជ្ជីដែលជាសភាគៈស្មើគ្នា ទើបគួរ ។

ខមួយទៀត ក្នុងវិនីតវត្ថុ នៃចតុត្ថបារាជិក ទ្រង់បញ្ញត្តទុកថា ‌ ‌ **ភិក្ខវេ បណ្ឌិតាយ អញ្ញេ វុត្តំ យោ វសេយ្យ អាបត្តិ ទុក្ការ** ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែ អ្នកទាំងឡាយ មិនត្រូវតាំង ចិត្តនឹងនៅក្នុងព្រៃ ឲ្យគេសរសើរឡើយ ភិក្ខុណានៅ (ដោយតាំង ចិត្តយ៉ាងនេះ) ភិក្ខុនោះ ត្រូវទុក្កដ ។ ប្រាថ្នានឹងឲ្យគេសរសើរទៅ នៅក្នុងព្រៃ ដើរទៅត្រូវទុក្កដគ្រប់ៗ រ៉ាវៈនៃជំហាន ប្រាថ្នាដូច្នោះទៅ នៅក្នុងព្រៃ ក្នុងកិច្ចទាំងពួង ជាដើមថា ធ្វើកុដិ ដើរចង្ក្រម អង្គុយ ស្ងៀក ដណ្ដប់ ត្រូវទុក្កដគ្រប់ៗ ប្រយោគ ព្រោះហេតុនោះ ភិក្ខុកុំនៅ ព្រៃដោយសេចក្ដីប្រាថ្នាយ៉ាងនេះ ដ្បិតថា នៅយ៉ាងនេះបានសេចក្ដី សរសើរក្ដី មិនបានក្ដី ត្រូវទុក្កដ ។ តែបើភិក្ខុណាសមាទានធុតង្គ ហើយ គិតថានឹងរក្សាធុតង្គ ឬគិតថានៅជិតស្រុក ចិត្តរមែងរវើរវាយ នៅព្រៃជាទីសប្បាយ ឬគិតថានឹងបានដល់នូវវិវេកទាំង ៣ ណាមួយក្នុង ព្រៃជាប្រាកដ ឬគិតថាចូលទៅក្នុងព្រៃហើយមិនបានដល់ព្រះអរហន្ត និងមិនចេញមក ឬគិតថាអាការដែលនៅក្នុងព្រៃនេះ ព្រះមានព្រះភាគ ទ្រង់សរសើរ កាលបើយើងទៅនៅព្រៃ មិត្រសម្ងាញ់សព្រហ្មចារី

ជាច្រើន និងលះសេនាសនៈជិតស្រុកទៅនៅព្រៃតាមគ្នា ប្រាថ្នានឹងទៅដូច្នេះ មិនមានទោស ភិក្ខុនោះគប្បីនៅចុះ ។

ខមួយទៀត ភិក្ខុកុំគប្បីត្រាច់ទៅបិណ្ឌបាត និងចង្ក្រម និងឈរ និងអង្គុយ និងសម្រេចឥរិយាបថដេក ដោយសេចក្តីប្រាថ្នានឹងឲ្យគេសរសើរដូច្នោះ បើភិក្ខុណាប្រាថ្នាដូច្នោះ ហើយត្រាច់ទៅបិណ្ឌបាតជាដើម ត្រូវទុក្កដ ។ គិតថានឹងធ្វើអាការជាដើមថាត្រាច់ទៅបិណ្ឌបាត ដោយសេចក្តីប្រាថ្នានឹងឲ្យគេសរសើរ តាំងអំពីស្ទៀកដណ្តប់ទៅ រហូតដល់ធាន់ហើយ ត្រូវទុក្កដគ្រប់ៗប្រយោគ ទោះបីបានសេចក្តីសរសើរក្តី មិនបានក្តី ក៏ត្រូវទុក្កដ ។ តែត្រាច់ទៅដើម្បីបិណ្ឌបាត ដោយមារយាទជាដើមថា ឈានទៅ ត្រឡប់ថយមកដែលគួរជាទីជ្រះថ្លា ដើម្បីនឹងបំពេញខន្ធកវត្ត និងសេខិយវត្តឲ្យបរិបូណ៌ ឬដើម្បីនឹងឲ្យពួកសព្រហ្មចារីដល់នូវទិដ្ឋានុគតិ ឃើញជាតួយ៉ាង មិនមានទោស អ្នកប្រាជ្ញលោកមិនបានតិះដៀលសូម្បីដើរចង្ក្រមជាដើម ក៏មានន័យដូចពោលមកនោះឯង ។

វិនីតវត្តុទុក្កដ ចប់

វិភង្គទុក្កដ

វិភង្គទុក្កដនោះមានច្រើន គឺជាញាតទុក្កដខ្ញុះ ញត្តិទុក្កដខ្ញុះ អនុសាវនទុក្កដខ្ញុះ អាណត្តិទុក្កដខ្ញុះ វិមតិទុក្កដខ្ញុះ សញ្ញាទុក្កដខ្ញុះ យថាខេត្តទុក្កដខ្ញុះ យថាវត្ថុទុក្កដខ្ញុះ យថាបយោគទុក្កដខ្ញុះ យថាវជ្ជទុក្កដខ្ញុះ ។

ញាតទុក្កដនោះ ដូចជាភិក្ខុបានឃើញ ឬបានឮ ភិក្ខុដទៃព្យាយាម ដើម្បីនឹងទម្លាយសង្ឆជាដើម និងបានឃើញ ឬបានឮ ភិក្ខុដទៃមានទិដ្ឋិខុស ដូចជាអរិដ្ឋភិក្ខុ បើមិនហាមឃាត់ត្រូវទុក្កដ ។

ញត្តិទុក្កដនោះ ដូចភិក្ខុព្យាយាម ដើម្បីនឹងទម្លាយសង្ឆជាដើម សង្ឆធ្វើសមនុភាសនកម្ម ចប់ញត្តិចុះ មិនលះកម្មនោះចេញត្រូវទុក្កដ ។ ទុក្កដដូច្នេះ ចំណែកសមនុភាសនកម្មក្នុងសង្ឆាទិសេសថា កាលបើចប់អនុសាវនាគម្រប់ ៣ ដង ត្រូវគរុកាបត្តិហើយរំដាប់ទៅឯង ។ ចំណែកក្នុងសមនុភាសន:ដទៃមិនពោលថារំដាប់ទៅទេ ។

អនុសាវនទុក្កដនោះ ដូចភិក្ខុមានទិដ្ឋិឃើញខុស សង្ឆសូត្រសមនុភាសន:ចប់អនុសាវនាទី ១ ទី ២ ត្រូវទុក្កដ ។

អាណត្តិទុក្កដនោះ ដូចជាភិក្ខុប្រើនាងភិក្ខុនីមិនមែនញាតិ ឲ្យបោកគក់ចីវរចាស់ ត្រូវទុក្កដ ដោយការបង្គាប់មុន ជាតួយ៉ាង ។

រៃមតិទុក្កដនោះ ដូចសំពត់អតិរេកចីវរនៅមិនទាន់កន្ធង ១០ ថ្ងៃ ភិក្ខុមានសេចក្ដីរង្គៀសសង្ស័យ ហើយបរិភោគប្រើប្រាស់ ត្រូវទុក្កដ ព្រោះការសង្ស័យ ជាតួយ៉ាង ។

សញ្ញាទុក្កដនោះ ដូចភិក្ខុសម្គាល់ថាស្រីក្នុងបណ្ណាក ចាប់ពាល់ត្រូវដោយសេចក្ដីតម្រេកក្ដី និងសំពត់អតិរេកចីវរនៅមិនទាន់កន្ធង ១០ ថ្ងៃ សម្គាល់ថាកន្ធងហើយយកមកបរិភោគក្ដី ទាំងអម្បាលនេះជាដើម ត្រូវទុក្កដ ដោយសញ្ញា ។

យថាខេត្តទុក្កដនោះ ដូចកិក្ខុសរសើរ ឬតិះដៀលអវយវៈស្រីអំពីដងកាំបិតឡើងទៅ អំពីក្បាលជង្គង់ចុះមក ត្រូវទុក្កដ តាមខេត្តជាប្រធាន ។

យថាវត្ថុទុក្កដនោះ ដូចកិក្ខុចាប់ពាល់ត្រូវកាយបុរសដោយសេចក្តីតម្រេក ត្រូវទុក្កដតាមវត្ថុ ជាតួយ៉ាង ។

យថាបយោគទុក្កដនោះ បានដូចក្នុងបុព្វបយោគ នៃបារាជិក និងសង្ឆាទិសេស និងបាចិត្តិយ ដូចកិក្ខុមានចេយ្យចិត្ត ចាប់ពាល់បបោសអង្ហែលកណ្ហៈរបស់អ្នកដទៃ ត្រូវទុក្កដ ជាតួយ៉ាង ។

យថាវជ្ជទុក្កដនោះ ដូចកិក្ខុអួតឧត្តរិមនុស្សធម៌ដោយបរិយាយ អ្នកស្តាប់មិនដឹងសេចក្តីក្នុងខណៈនោះ ត្រូវទុក្កដតាមទោស ជាតួយ៉ាង ។

វិភង្គទុក្កដ ចប់

ខន្ធកទុក្កដ

ខន្ធកទុក្កដនោះ បានពោលមកអំពីមុនខ្ញុះហើយ គប្បីដឹងក្នុងព្រះពុទ្ធបញ្ញត្តិ ដែលបានពោលហើយនោះចុះ បទដែលមិនបានអាងទីមកជាខន្ធកទុក្កដទាំងអស់ បទដែលសល់នៅនោះដូច្នេះ បទណាគួរនឹងដឹងគួរបដិបត្តិបានខ្ញុះ និងពោលបទនោះដោយសង្ខេបៈ

ខមួយទៀត ព្រះពុទ្ធអង្គទ្រង់បញ្ញត្តទុកថា **ន ភិក្ខវេ បញ្ចហិ អាពាធេហិ ផុដ្ឋោ បញ្ចាជេតព្ពោ...** ម្នាលភិក្ខុទាំងឡាយ មនុស្សប្រកបដោយអាពាធ ៥ ប្រការ គឺ ឃ្លង់ ពក ស្រែង ពោគរីងរៃ ឆ្ពួតជ្រូក កុំគប្បីបំបួស បើភិក្ខុណាបំបួស ត្រូវអាបត្តិ ។

ខមួយ ថាមនុស្សដែលស្តេចផែនដីចិញ្ចឹមជាខ្ញុំរាជការ កុំគប្បីបំបួស... ។ ខមួយ ថាចោរប្រាកដដូចជាទង់ជ័យ កុំគប្បីបំបួស... ។ ខមួយ ថាចោរទម្ងាយគុករត់មក... ។ ខមួយ ថាចោរដែលម្ចាស់ផែនដីប្រកាសទុកថា បើឃើញចូលទៅក្នុងទីកន្លែងណាឲ្យសម្ងាប់ចេញ... ។ ខមួយ ថាចោរដែលគេវាយដោយរំពាត់មានស្នាម ធ្វើទណ្ឌកម្មហើយ... ។ ខមួយ ថាមនុស្សដែលគេបៀតបៀនឲ្យមានស្លាកស្នាម មានសាក់មុខ សាក់ថ្ងាសជាដើម ធ្វើទណ្ឌកម្មហើយ... ។ ខមួយ ថាមនុស្សជំពាក់បំណុលគេ... ។ ខមួយថា មនុស្សជា ខ្ញុំគេ... ។ ខមួយ ថា កូនដែលមាតាបិតាមិនទាន់អនុញ្ញាត មនុស្សទាំងអម្បាលនេះ ភិក្ខុកុំគប្បីបំបួស បើភិក្ខុណាបំបួស ត្រូវទុក្កដ ។

ខមួយ មនុស្សកំបុតដៃ មនុស្សកំបុតជើង មនុស្សកំបុតទាំងដៃទាំងជើង មនុស្សកំបុតត្រចៀក មនុស្សកំបុតច្រមុះ មនុស្សកំបុតទាំងត្រចៀកទាំងច្រមុះ មនុស្សកំបុតម្រាមដៃ មនុស្សកំបុតមេដៃមេជើង មនុស្សជាប់សរសៃធំ មនុស្សមានម្រាមដៃជាប់គ្នា មនុស្សគម មនុស្សតឿ មនុស្សពកក មនុស្សខ្វិន មនុស្សជើងស្ពក់ មនុស្សមានរោគអាក្រក់ជាដើមថា ឫសដូង មនុស្សមានរូបទ្រុស្តបរិស័ទ ព្រោះមានរូបប្លែកអំពីមនុស្សផងគ្នា មនុស្សខ្វាក់ម្ខាង មនុស្សកែងដៃ-ជើង មនុស្សខ្ជក មនុស្សស្ងាប់កាយម្ខាង មនុស្សមានឥរិយាបថដាច់ មនុស្សចាស់ទុព្វល មនុស្សខ្វាក់ទាំងសងខាង មនុស្សគ មនុស្សថ្ងង់ មនុស្សទាំងខ្វាក់ទាំងគ

មនុស្សទាំងខ្វាក់ទាំងថ្ងង់ មនុស្សទាំងគទាំងថ្ងង់ មនុស្សទាំងខ្វាក់ទាំងគ ទាំងថ្ងង់ មនុស្សទាំងអម្បាលនេះ ភិក្ខុកុំគប្បីឲ្យបព្វជ្ជា បើភិក្ខុណា ឲ្យបព្វជ្ជា ត្រូវទុក្កដ ។ មនុស្សបណ្ឌក មនុស្សលួចសង្វាស មនុស្ស ដែលបួសជាភិក្ខុហើយ ត្រឡប់ចូលទៅជាតិរ៉ៃយ សត្វតិរច្ឆាន មនុស្ស សម្លាប់មាតា មនុស្សសម្លាប់បិតា មនុស្សសម្លាប់ព្រះអរហន្ត មនុស្ស ប្រទូសនាងភិក្ខុនី មនុស្សធ្វើសង្ឆកេទ មនុស្សមានចិត្តប្រទូសរ៉ាយ ធ្វើលោហិតុប្បាទក្នុងកាយព្រះពុទ្ធអង្គ មនុស្សមានភេទ ២ គឺភេទប្រុស និងភេទស្រី មនុស្សទាំងអម្បាលនេះ សូម្បីបួសក៏មិនជាឧបសម្បន្ន បើបួសហើយគប្បីឲ្យសឹកចេញ ។

ខមួយ សាមណេរគ្មានឧបជ្ឈាយ៍ ភិក្ខុកុំគប្បីឲ្យឧបសម្បទាជាភិក្ខុ ។ ខមួយ កុំយកសង្ឆជាឧបជ្ឈាយ៍ ។ ខមួយ កុំយកគណៈជាឧបជ្ឈាយ៍ ។ ខមួយ កុំយកបណ្ឌកជាដើមជាឧបជ្ឈាយ៍ ។ បើភិក្ខុណាយកបុគ្គល ទាំងអម្បាលនេះ ធ្វើជាឧបជ្ឈាយ៍ ឲ្យឧបសម្បទាដល់កុលបុត្រជាភិក្ខុ ត្រូវទុក្កដ ។

ខមួយ ទ្រង់អនុញ្ញាតឲ្យអបលោកន៍ប្រាប់សង្ឆ ដើម្បីធ្វើកណ្ឌកម្ម គឺការសក់មនុស្សអ្នកបព្វជ្ជា វិធីអបលោកន៍ដោយសង្ខេប ដូច្នេះ ត្រូវប្រជុំ ភិក្ខុដែលនៅក្នុងសីមា ហើយនាំកុលបុត្រអ្នកបព្វជ្ជាទៅក្នុងទីប្រជុំនោះ ហើយគប្បីបញ្ជូញវាចាថា **សង្ឆម្ភន្តេ ឥមស្ស ការកស្ស កណ្ឌកម្មំ អាបុច្ឆាមិ** *ប្រែថា ខ្ញុំព្រះករុណាប្រាប់កណ្ឌកម្ម នៃ*

ទារកនេះដល់សង្ឆ ដូច្នេះ អស់វារៈ ៣ ដង ២ ដង ឬតែម្តងក៏បាន តែអ្នកណាកោរសក់ថ្មី ឬសឹកថ្មី ឬជានិគ្រន្ថជាដើម ឬជាមនុស្សមានសក់ខ្ចីជាង ២ ធ្នាប់ ឬត្រឹម ២ ធ្នាប់ក្តី កិច្ចដែលនឹងកោរសក់នៃកុលបុត្រនោះមិនមាន ព្រោះហេតុនោះ សូម្បីមិនប្រាប់ភណ្ឌកម្ម នឹងឲ្យកុលបុត្រដូច្នោះបព្វជ្ជា ក៏គួរ ។ តែបើអ្នកណាមានសក់រៃលើសជាងពីរធ្នាប់ ដោយហេចទៅ សូម្បីទ្រទ្រង់ត្រឹមតែកំប៉ោយជក់មួយក្តី គប្បីប្រាប់ភណ្ឌកម្មជាមុនសិន សឹមឲ្យអ្នកនោះបព្វជ្ជា ។ ១ មួយ នឹងធ្វើទណ្ឌកម្មដល់សាមណេរ កុំគប្បីធ្វើអាការមានរាំងរាអាវមសង្ឆទាំងមូល សាមណេរធ្នាប់នៅ ឬធ្នាប់ចូលទៅក្នុងទីណា គប្បីរាំងរាតែក្នុងទីនោះ ។ ១ មួយ កុំធ្វើអាការឃាត់អាហារ គឺឃាត់មិនឲ្យធាន់ ។ ១ មួយ មិនប្រាប់ឧបជ្ឈាយ៍មុន កុំធ្វើការហាមឃាត់ បើភិក្ខុណាធ្វើការហាមឃាត់រាំងរាដល់សាមណេរដូច្នេះ ត្រូវទុក្កដ ។ ១ មួយ កុំប្រលោមលួងលោមបរិស័ទនៃភិក្ខុដទៃ ដើម្បីឲ្យមកឧបដ្ឋាកដល់ខ្លួនដោយពាក្យថា យើងនឹងឲ្យបាត្រចីវរដល់អ្នក ភិក្ខុណាប្រលោមលួងលោមដូច្នេះ ត្រូវទុក្កដ ។ បរិស័ទនៃភិក្ខុដទៃជាសាមណេរក្តី ជាភិក្ខុក្តី ដោយហេចទៅ សូម្បីជាបរិស័ទនៃភិក្ខុទ្រុស្តសីល នឹងញុះញង់ឲ្យបែកនាំយកមកជាបរិស័ទរបស់ខ្លួនមិនគួរ ។ តែនឹងសម្តែងទោសថា អ្នកអាស្រ័យនឹងមនុស្សទ្រុស្តសីល បីដូចមកប្រាថ្នានឹងផ្ទួតលាងជម្រះ ត្រឡប់ជាយកលាមកលាបខ្លួនដូច្នេះ ក៏គួរ ។ បើអ្នកនោះនឹងមកសូមឧបជ្ឈាយ៍ ឬនិស្សិតខ្លួនឯង នឹងឲ្យក៏គួរ ។

ខមួយ មិនឲ្យភិក្ខុដទៃធ្វើឱកាសមុនសិនហើយ កុំចោទភិក្ខុដោយអាបត្តិ បើភិក្ខុណាចោទដូច្នោះត្រូវទុក្កដ ។ ទ្រង់អនុញ្ញាតឲ្យសូមឱកាសមុនថា **ककतो मे अयस्मा ओकासं अहाम्हि वत्तुकामो** ថាលោកមានអាយុ ចូរធ្វើឱកាសដល់ខ្ញុំ ខ្ញុំប្រាថ្នានឹងពោលដល់លោកដូច្នេះ ហើយសឹមចោទដោយអាបត្តិ ។

ខមួយ កុំទ្រង់ទណ្ឌ: គឺឈើវែង ៤ ហត្ថ (ឈើច្រត់) និងសង្ក្រែក បើភិក្ខុណា ទ្រង់ទណ្ឌ:និងសង្ក្រែក ត្រូវទុក្កដ ។ ភិក្ខុមានជំងឺ ប្រាសចាកទណ្ឌ: ត្រាច់ទៅមិនបាន ព្រះអង្គទ្រង់អនុញ្ញាតឲ្យសូមទណ្ឌសម្មតិអំពីសង្ឆ ។ ភិក្ខុមានជំងឺវៀរសង្ក្រែកចេញ បរិហារក្សានាំបាត្រទៅមិនបាន ព្រះអង្គទ្រង់អនុញ្ញាតឲ្យសូមសិក្ការសម្មតិអំពីសង្ឆ ។ បើមានជំងឺវៀរបស់ទាំងពីរយ៉ាងនោះត្រាច់ទៅនឹងនាំបាត្រទៅមិនបាន ព្រះអង្គទ្រង់អនុញ្ញាតឲ្យសូមទណ្ឌសិក្ការសម្មតិអំពីសង្ឆ បានសម្មតិវត្ថុណាមួយហើយប្រើវត្ថុនោះបាន ។

ខមួយ ដងវែកមានរបស់ពួរទាំងសងខាង ភិក្ខុកុំគប្បីវែកនាំទៅ បើភិក្ខុណាវែកនាំទៅត្រូវទុក្កដ ។ ដងវែកមានរបស់ម្ខាង (ពុនទៅផង) យករបស់ពួរកណ្ដាល ពីរអង្គសែងទៅ ទូលដោយក្បាល លីដោយស្មា កណ្ដៀតដោយចង្កេះ យួរដោយដៃ ទាំងអម្បាលនេះនាំទៅក៏គួរ ព្រោះព្រះអង្គទ្រង់អនុញ្ញាត ។

ខមួយ កាលអ្នកដទៃកណ្ដាស់ កុំពោលថាអ្នកចូររស់នៅ ចូររួចចុះ បើពោលដូច្នេះ ត្រូវទុក្កដ ។ គ្រហស្ថអ្នកប្រាថ្នាមង្គលគេពោលនឹងភិក្ខុថា លោកចូររស់នៅ នឹងពោលតបទៅថា អ្នកចូររស់នៅអស់កាលអង្វែងដូច្នេះគួរ ដ្បិតទ្រង់អនុញ្ញាតឲ្យពោល ។

ខន្ធកទុក្កដ ចប់

ទុក្កដាបត្តិទាំងអម្បាលនេះ មានមកក្នុងបាលី ដូចពោលហើយ ទើបឈ្មោះថាបាលីទុក្កដ ។

បាលីទុក្កដ ចប់

ចាលីមុត្តកទុក្ខ

បាលីមុត្តកទុក្កដនោះ បានពោលហើយក្នុងខាងដើមនោះខ្ញុះ ដូចទុក្កដត្រូវព្រោះទទួលនិងធាន់សាច់ ត្រីស្រស់ និងអនាមាសទុក្កដនៃភិក្ខុ អ្នកចាប់ពាល់បញ្ចោសអង្ផែលរតន: ១០ យ៉ាង ស្រូវ ៧ ប្រការ និងគ្រឿងដូរ្យដន្ត្រីជាដើមដែលនឹងពោលទៅខាងមុខ និងទ្ធុបចិណ្ណទុក្កដ វិនយ-ទុក្កដ ដែលសល់នៅ ដូច្នេះ ៖

ខមួយ ភិក្ខុកុំទទួលស្រូវខ្ចី ។ ខមួយ កុំទទួលចំការស្រែ ទីដីជាដើម បើទាយកណាមួយពោលថា បឹងធំសម្រេចសន្ធូងបានមួយឆ្នាំ ៣ ដងរបស់ខ្ញុំព្រះករុណាមាន ខ្ញុំព្រះករុណានឹងថ្វាយបឹងនោះដល់សង្ឆ បើ

សង្ឆទទួលបឹងនោះត្រូវអាបត្តិ ព្រោះទទួល ព្រោះបរិភោគ បើភិក្ខុណា ឃាត់ទៅទាយក ភិក្ខុនោះ គឺភិក្ខុណាមួយ កុំគប្បីពោលពាក្យអ្វី នឹងភិក្ខុ អ្នកឃាត់នោះឡើយ ដ្បិតថាចោទភិក្ខុអ្នកឃាត់នោះ ភិក្ខុនោះឯងត្រូវ អាបត្តិ ព្រោះភិក្ខុមួយអង្គនោះធ្វើភិក្ខុច្រើនមិនឲ្យត្រូវអាបត្តិ ។ ទាយកណា សូម្បីពោលថា ខ្ញុំព្រះករុណាថ្វាយបឹងធំប្រាកដដូច្នោះ ភិក្ខុទាំងឡាយ ឃាត់គេ ថាមិនគួរ បើគេសួរថាបឹងរបស់សង្ឆឯណោះ។ ក៏មាន នោះ ហេតុថ្វីក៏គួរ គប្បីពោលតបទៅគេថា ប្រហែលជាគេធ្វើឲ្យជាកប្ចិយ ហើយថ្វាយ ។ បើគេសួរថាថ្វាយដូចម្តេចទើបជាកប្ចិយ គប្បីពោល តបទៅគេថា គេថ្វាយថា លោកចូរបរិភោគបច្ច័យទាំង ៤ ដូច្នេះ ទើប បានជាកប្ចិយ ថាបើទាយកត្រឡប់ថ្វាយ ដោយពាក្យថាប្រពៃហើយព្រះ ករុណា លោកចូរបរិភោគបច្ច័យទាំង ៤ នោះចុះ ដូច្នេះគួរ ។ ថាបើពោលថា ព្រះករុណាចូរទទួលបឹង ឃាត់គេថា មិនគួរ គេសួរថាមានកប្ចិយការក ឬទេ ប្រាប់ថាមិនមាន គេពោលថាមនុស្សឯណោះនឹងចាត់ចែងបឹងនោះ ឬថានឹងនៅក្នុងដៃអ្នកនោះ ឬថានឹងនៅក្នុងដៃខ្ញុំព្រះករុណា សង្ឆចូរ បរិភោគរបស់ដែលគួរចុះ ដូច្នេះក៏គួរ ។ បើឃាត់គេថាមិនគួរដូច្នេះ គេ ពោល មនុស្សទាំងឡាយ នឹងបានបរិភោគទឹក នឹងបានលាងរបស់ សត្ត ម្រឹគ បក្សីនឹងបានផឹក សូម្បីពោលដូច្នេះក៏គួរ ។ បើឃាត់គេថាមិនគួរដូច្នោះ ហើយ គេពោលថាលោកចូរកាន់យកដោយប្រធាននៃកប្ចិយកណ្ហ:ចុះ ភិក្ខុពោលថាល្អហើយឧបាសក សង្ឆនឹងបានក្រេបផឹកទឹក និងលាងរបស់

ម្រ៉ឹគ បក្សីនឹងបានផឹកដូច្នេះ ហើយបរិភោគក៏គួរ ។ មួយទៀត បើគេ
ពោលថា ខ្ញុំព្រះករុណាថ្វាយបឹង ថ្វាយស្រះបោក្ខរណីរបស់ខ្ញុំ
ព្រះករុណាដល់សង្ឆ ភិក្ខុនឹងពោលថាល្អហើយឧបាសក សង្ឆនឹងបាន
ផឹកទឹកដូច្នេះជាដើម ហើយបរិភោគក៏គួរ ។ ថាបើភិក្ខុសូមហត្ថកម្មគេក្តី
នឹងជីកដីជាកប្បិយដោយដៃខ្លួនក្តី ធ្វើជាបឹងដើម្បីបរិភោគទឹក បើមនុស្ស
មកអាស្រ័យបឹងត្រពាំងនោះ សម្រេចស្រូវសន្ធូងហើយ ឲ្យកប្បិយ-
ភណ្ឌក្នុងវិហារក៏គួរ ។ ក្នុងរឿងនេះ ព្រះអដ្ឋកថាចារ្យពោលពិស្តារ តែ
សេចក្តីសង្ខេបថា នឹងធ្វើចំការស្រែខ្លួនឯង ឬឲ្យអ្នកដទៃធ្វើ មិនគួរ ។ បឹង
ត្រពាំងដែលគេថ្វាយ ដើម្បីបច្ច័យទាំង ៤ ទទួលហើយ នឹងតាំងកប្បិយ-
ការកទុក ក៏គួរ ប៉ុន្តែបើធ្វើការជីកដីពួនជាភ្ជួមិនគួរ ។ បើត្រពាំងដែល
ទទួលទុកដើម្បីនឹងបរិភោគទឹក ចិត្តបរិសុទ្ធនឹងធ្វើការជីកដីនិងពួនទប់ភ្ជួ
ឡើងថ្មីដោយកប្បិយវោហារគួរ តែឃើញគេមកអាស្រ័យធ្វើសន្ធូង និង
តាំងកប្បិយការកទុកមិនគួរ ។ មួយវិញទៀត គេពោលថាខ្ញុំព្រះករុណា
ថ្វាយចំការ ស្រែ ភូមិ គ្រាន់ជាទីបណ្តុះសណ្តែកលូអំពៅដូងជាដើម គប្បី
ឃាត់ថាមិនគួរ ហើយបដិបត្តិដូចពោលមកហើយក្នុងបឹងនោះចុះ ។ កាល
ណាបើគេពោលដោយកប្បិយវោហារថា ខ្ញុំព្រះករុណាថ្វាយដើម្បីបរិភោគ
បច្ច័យ ៤ កាលនោះគប្បីទទួលចុះ ។ បើគេពោលថា ខ្ញុំព្រះករុណាថ្វាយ
ពួកឈើ ថ្វាយព្រៃក៏គួរ ។ គេអាស្រ័យទីធ្វើសន្ធូង ហើយពោលថា
ខ្ញុំព្រះករុណាថ្វាយសីមា ដូច្នេះក៏គួរ តែកុំបោះគោលឈើ កុំបោះគោល

សិលា ដើម្បីនឹងកំណត់ដែនដោយខ្លួនឯង ព្រោះផែនដីមានតម្លៃច្រើន នឹងគប្បីត្រូវបារាជិក ដោយរបស់បន្ទិចបន្ទួច គប្បីប្រាប់អ្នករក្សាវត្តថា សីមារបស់យើងទៅតាមទីត្រង់នេះ ថាបើមនុស្សរក្សាវត្តបោះគោលយកលើសទៅ មិនត្រូវអាបត្តិ ព្រោះពោលដោយបរិយាយថា បើមហា-ក្សត្រនិងមហាអមាត្យ ជាដើម លោកឲ្យមនុស្សបោះគោលខ្លួនឯងហើយ ថ្វាយ ថាលោកចូរបរិភោគបច្ច័យ ៤ ដូច្នេះ ក៏គួរ ។ ១មួយ ភិក្ខុកុំគប្បីទទួលខ្ញុំស្រី ខ្ញុំប្រុស គោ ក្របី ដំរី សេះ ពពែ ជ្រូក និង មាន់ ជាដើម បើទទួលត្រូវទុក្កដ ។ គេពោលថា ខ្ញុំព្រះករុណាថ្វាយទាស: មិនគួរ ។ បើគេពោលថា ខ្ញុំព្រះករុណាថ្វាយមនុស្សរក្សាអារាម ថ្វាយវេយ្យាវច្ចករ ថ្វាយកប្ចិយការក ដូច្នេះ ក៏គួរ ។ បើមនុស្សដែលរក្សាអារាមនោះធ្វើការសង្ឆ ទាំងវេលាព្រឹកវេលាល្ងាច ភិក្ខុគប្បីធ្វើការបដិបត្តិដោយកេសជ្ជ: ទាំងពួងដល់អ្នកនោះ បីដូចជាធ្វើដល់សាមណេរចុះ ។ ថាបើអ្នករក្សាវត្តនោះ ធ្វើការរបស់សង្ឆតែវេលាព្រឹក វេលាបច្ឆាកត្តធ្វើការរបស់ខ្លួន វេលាល្ងាចភិក្ខុកុំគប្បីឲ្យគ្រឿងបរិភោគ សូម្បីមនុស្សរក្សាវត្តធ្វើការសង្ឆជាវេន ៥ ថ្ងៃ ឬកន្ទះខែ កាលក្រៅពីនោះធ្វើការរបស់ខ្លួន គប្បីឲ្យបាយ និងគ្រឿងបរិភោគដល់អ្នកនោះ តែក្នុងវេលាធ្វើកិច្ចការសង្ឆមួយជំពូក បើកិច្ចការសង្ឆមិនមាន គេទៅធ្វើកិច្ចការរបស់ខ្លួនគេចិញ្ចឹមជីវិត បើគេយកតម្លៃហត្ថកម្មមកថ្វាយគប្បីទទួលចុះ បើគេមិនឲ្យកុំគប្បីពោលពាក្យអ្វីឡើយ ។ នឹងទទួលទាស: ជាជាងជ្រលក់ ឬជាងតម្បាញណាមួយ

ដោយឈ្មោះថាអារាមិក: មនុស្សរក្សាអារាមនឹងញ្ជាមវត្តគួរ ។ ថាបើគេ
ពោលថា ខ្ញុំព្រះករុណាថ្វាយគោ ក៏គប្បីឃាត់ថាមិនគួរ បើគេសួរថា
គោទាំងអម្បាលនេះ បានមកអំពីណា គប្បីប្រាប់ថា មនុស្សឈ្លាសគេ
ថ្វាយដើម្បីបរិភោគបញ្ចគោរស កាលបើគេពោលថា ខ្ញុំព្រះករុណាថ្វាយ
ដើម្បីបរិភោគបញ្ចគោរសដែរ ដូច្នេះគួរ សូម្បីក្នុងសត្វទាំងឡាយ មាន
ពពែជាដើមក៏ដូចគ្នា ។ គេពោលថា ខ្ញុំព្រះករុណាថ្វាយដំរី ថ្វាយ
សេះ ក្របី មាន់ ជ្រូក នឹងទទួលមិនគួរ ។ បើមនុស្សជំពូកខ្ទះពោលថា
លោកទាំងឡាយ ចូរមានសេចក្តីខ្ជាប់ខ្ជួនតិចចុះ ខ្ញុំព្រះករុណា នឹង
កាន់យកសត្វទាំងអម្បាលនេះទៅហើយ នឹងឲ្យកប្បិយភណ្ឌដល់លោក
ហើយគេកាន់យកទៅក៏គួរ ។ មាន់ ជ្រូក នឹងលែងក្នុងព្រៃដោយគិតថា
ចូរចិញ្ចឹមជីវិតតាមសប្បាយចុះដូច្នេះក៏គួរ ។ កាលបើគេពោលថា ខ្ញុំព្រះ
ករុណាថ្វាយបឹងនេះ ស្រែនេះ ចំការនេះ ទីភូមិនេះ ដល់វិហារ នឹងឃាត់
មិនបាន ត្រូវការដោយពិស្តារចូលមើលក្នុងទុតិយសមន្តបាសាទិកាចុះ ។

បទដែលហាមឃាត់ តាំងអំពីចំការស្រែមកនេះ ព្រះអដ្ឋកថាចារ្យ
លោកអាស្រ័យបាលីក្នុងព្រះសូត្រជាដើមថា **ខេត្តវត្ថុបដិគ្គហណា**
រៀរចាកការទទួលស្រែនិងច្បារជាគោលទុក ។

មួយទៀត ទុក្ខជាបត្តិ មិនមានមកក្នុងបាលី តែថាអនុលោមនៃ
ថុល្លច្ចយាបត្តិជាដើម អដ្ឋកថាចារ្យលោកតែងតាំងទុក ក៏ឈ្មោះថាបាលី-
មុត្តកទុក្កដ ដូចជាភិក្ខុកាត់អង្គជាតិខ្លួន ត្រូវថុល្លច្ច័យ ។ កាត់អវយវ:ដទៃ

មានត្រចៀក ច្រមុះ ម្រាមដៃ ណាមួយជាដើម ឬធ្វើទុក្ខដូច្នោះឲ្យកើតឡើង ត្រូវទុក្កដ ។ តែក្នុងអវយវៈដែលពស់និងមូសខាំជាដើម ឬអាពាធដទៃ កាលបើកាត់អវយវៈ ឬឈាមខន់ មិនត្រូវអាបត្តិ ។

មួយទៀត ក្នុងនាងភិក្ខុនី ត្រូវបាចិត្តិយ ក្នុងភិក្ខុ ព្រះអដ្ឋកថាចារ្យពោលថា ត្រូវទុក្កដ ដូចភិក្ខុចោលឧច្ចារៈជាដើមខាងក្រៅជញ្ជាំងក្រៅកំផែង និងក្នុងស្រែចំការ ដូចពោលហើយខាងដើម ទាំងអម្បាលនេះ នឹងហៅថាបាលីមុត្តកទុក្កដផងក៏បាន ដែលសល់នៅមិនទាន់បានពោលនោះមានន័យដូចតទៅ៖

ខមួយថា ភិក្ខុឲ្យសមណាចីវរ គឺសំពត់ដែលគួរស្ងៀកដណ្តប់បានដែលធ្វើកប្ប:ហើយដល់គ្រហស្ថ ឬបព្វជិតណាមួយ ដទៃក្រៅចាកសហធម្មិកទាំង ៥ និងមាតាបិតា ត្រូវទុក្កដ ។ លះឲ្យដល់មាតាបិតានិងឲ្យដល់មនុស្សដទៃជារបស់ខ្ញុំ មិនត្រូវអាបត្តិ ។

ខមួយទៀត ភិក្ខុទៅដើម្បីនឹងមើលផ្ទះជាទីប្រពាតក្រសាលលេងនៃព្រះមហាក្សត្រ និងផ្ទះសាលាដែលវិចិត្រដោយគំនូរ និងច្បារជាទីមនោរម្យ តម្រេកចិត្ត និងឧទ្យាន ឬស្រះបោក្ខរណី អម្បាលនេះ ដែលជាទីលេងសប្បាយ កាលដើរទៅត្រូវទុក្កដគ្រប់បទវារៈ ឈប់ក្នុងទីណាមិនបានលើកជើងឡើង បើមើលទៅទីទាំង ៥ ក្នុងទីនោះ ត្រូវអាបត្តិទុក្កដតែមួយ ។ បើក្រឡេកមើលទៅក្នុងទីនោះ។ ត្រូវអាបត្តិរាប់ដោយប្រយោគដែលងាកមើល មិនរាប់ដោយធ្មេចភ្នែក ហើយបើកឡើង ។

បើមានកិច្ចដោយសលាកភត្តជាដើម ហើយដើរទៅក្តី ឬទៅព្រោះអន្តរាយក្តី មិនត្រូវអាបត្តិ ។

មួយទៀត សូម្បីទុក្កដ ព្រោះប្រើអកប្បិយបរិក្ខារវត្ថុខ្លះ ដូចពោលហើយ ក្នុងបរិក្ខារកថា នឹងពោលថាជាបាលីមុត្តកទុក្កដផងក៏បាន ។

បាលីមុត្តកទុក្កដ ចប់

ទុក្កដាបត្តិ ដែលពណ៌នាមកនេះ នឹងអស់តែប៉ុណ្ណោះក៏ទេ ដែលពោលមកនេះចំពោះតែបទដែលគួរដឹង និងគួរបដិបត្តិខ្លះ មានសល់នៅទៅខាងមុខខ្លះ ព្រោះទុក្កដាបត្តិមានច្រើនដូច្នេះ ទើបបានពោលថាមិនមានកំណត់ ។

ទុក្កដវណ្ណនា ចប់

នឹងពណ៌នាក្នុងទុព្ភាសិតាបត្តិ ថាភិក្ខុក្ងែងនិយាយឡកឡឺយ ចំអកចំអន់ ឧបសម្បន្ន ឬអនុបសម្បន្ន ដោយអក្កោសវត្ថុទាំង ១០ មានជាតិជាដើម ត្រូវអាបត្តិទុព្ភាសិត វិនិច្ឆ័យក្រៅអំពីនោះ គប្បីដឹងដូចក្នុងឱ្យមសវាទសិក្ខាបទនោះចុះ ប្លែកតែទុព្ភាសិតាបត្តិនេះ ជាធម្មទេសនា-សមុដ្ឋាន អាបត្តិកើតអំពីវាចាចិត្ត ជាកិរិយា ត្រូវព្រោះធ្វើ គឺនិយាយចំអកចំអន់គ្នាលេង សញ្ញាវិមោក្ខ សចិត្តក: វចីកម្ម អកុសលចិត្ត មានវេទនាពីរ គឺសុខនិងឧបេក្ខាប៉ុណ្ណោះ ។

ទុព្ភាសិតវណ្ណនា ចប់

បដិបត្តិមុខសិក្ខាបទ្ធ គម្រប់ ៣ ចប់

កាលិកបព្វៈគម្រប់ ៤

សេចក្ដីគម្រប់ ៤ ឈ្មោះកាលិកបព្វ: ពណ៌នាអំពីកាលិក របស់ប្រកបដោយកាល ។ កាលិកមាន ៤ គឺយាវកាលិក ១ យាមកាលិក ១ សត្តាហកាលិក ១ យាវជីវិក ១ ។ ការរៀងលំដាប់ដូច្នេះនេះ តាមបុព្វសិក្ខា ។ តែក្នុងទីនេះនឹងពោលអំពីយាវជីវិកជាមុន ដើម្បីនឹងឲ្យវិនិច្ឆ័យបានដោយងាយ ហើយនឹងពោលឲ្យពិស្តារជាងបុព្វសិក្ខាបន្ដិច ។

យាវជីវិក

ថ្នាំកើតអំពីដើមឈើ ដើមស្មៅដែលព្រះពុទ្ធអង្គទ្រង់អនុញ្ញាតមាន ៥ ប្រការ គឺ ឫស ១ ទឹកអម្ចត់ ១ ស្លឹក ១ ផ្លែ ១ ជ័រ ១ និងអំបិលផង ត្រូវជា ៦ ឈ្មោះថាយាវជីវិក ។ ឫសឈើ មើមឈើជាថ្នាំដែលទ្រង់អនុញ្ញាតនោះគឺ **ហលិទ្ទំ** *រមៀត ១* **សិង្ហេរ** *ខ្ញី ១* **វចំ** *លំពាន់ ១* **វចត្ថុ** *ប្រស់ ១* **អតិវិសំ** *អាចម៍ធ្ពើស ១* **កដុកពោហិណី** *រំដេង ១* **ឧសីរ** *ស្ស្ងរ ១* **ភទ្ទមុត្ថកំ** *ក្រវាញជ្រូក ១ ជាវត្ថុ ៨ មិនមែនតែមើម ឫស រលិ្ម នៃវត្ថុទាំង ៨ មួយជំពូកប៉ុណ្ណោះទេ សូម្បីដើម សម្ពក ផ្កា និងផ្លែ នៃវត្ថុទាំង ៨ នោះ ក៏ឈ្មោះថាយាវជីវិកដែរ ។*

ទឹកអម្ចត់ជាថ្នាំដែលទ្រង់អនុញ្ញាតនោះ គឺ **ឩម្ពតសាវោ** *ទឹកអម្ចត់ស្ពៅ ១* **ការជសាវោ** *ទឹកអម្ចត់ក្ងែងគង់ ១* **បលោលកសាវោ** *ទឹកអម្ចត់អំបែងផ្ទៃ ឬពុលឯក ១* **បត្តវតសាវោ** *ទឹកអម្ចត់បណ្ដូលពេជ្រ ឬអង្ករាញ ១* **ញត្ថមាលកសាវោ** *ទឹកអម្ចត់ទន្ទ្រា ឬ ថ្ងាន់ (សំបូរទេស) ១ ត្រូវជា ៥ ដូច្នេះ ។*

ស្វឹកឈើ ជាកេសជ្ជៈ ដែលទ្រង់អនុញ្ញាតនោះ គឺ **ឌិម្ពបណ្ណ** *ស្វឹកស្ពៅ* **ការ៉ជ្ជបណ្ណ** *ស្វឹកក្ងែងគង់* **បដោលបណ្ណ** *ស្វឹកអំបែងថ្ងៃ ឬពុលឯក* **សុលសិបណ្ណ** *ស្វឹកម្រះព្រៅឬស្វឹកដីលីងលាក់* **ការ្ហាសិបណ្ណ** *ស្វឹកការ្ហាស ត្រូវជាវត្ថុ ៥ មិនមែនតែស្វឹកនៃវត្ថុទាំង ៥ នេះ មួយជំពូកប៉ុណ្ណោះទេ្បីយ សូម្បីផ្កានិងផ្លែជាដើមនៃវត្ថុទាំង ៥ នោះ ក៏ឈ្មោះថាយាវជីវិកដែរ ។*

ផ្លែឈើដែលជាកេសជ្ជៈ គឺថ្នាំដែលទ្រង់អនុញ្ញាតនោះគឺ **វិលង្ខ** *ផ្លែពីលង្គ* **បិឃ្ឍលិ** *ដីប្ញ* **មរិចំ** *ម្រេច* **ហរីតកំ** *សម៉ង់ធំឬសម៉ូ* **វិភីតកំ** *សម៉ង់ពីកេត* **អាមលកំ** *ក្ងន្ធ*ត្ងៃ **គោឃដលំ** *ផ្លែក្រវាញ ត្រូវជាវត្ថុ ៧ ។*

ជ័រឈើដែលជាកេសជ្ជៈ ជាថ្នាំ ដែលព្រះអង្គទ្រង់អនុញ្ញាតនោះគឺ **ហិង្គុ** *ជ័រឈើដែលហូរចេញអំពីដើមហិង្គុ ១* **ហិង្គុជតុ** *ជ័រឈើដែលគេយកមែកនិងស្វឹក នៃដើមហិង្គុមករំងាស់ ១* **ហិង្គុសិចាតិកា** *ជ័រដែលគេយកត្រដង់ហិង្គុមករំងាស់ និងជ័រដែលគេយកស្វឹកហិង្គុមករំងាស់ ហើយលាយដោយរបស់ដទៃក៏ថា ១* **តកំ** *ជ័រដែលហូរចេញអំពីត្រួយឈើ ១* **តកបត្តិ** *ជ័រដែលហូរចេញអំពីស្វឹកឈើ ១* **តក-បណ្ណិ** *ជ័រដែលគេបេះស្វឹកឈើយកមកធ្វើ ១* **សជ្ជុលសំ** *កំញ្ជាណ ១ ត្រូវជាវត្ថុ ៧ ប្រការ ។*

អំបិលដែលព្រះអង្គទ្រង់អនុញ្ញាតនោះ គឺ **សាមុទ្ទំ** *អំបិលកើតក្បែរឆ្នេរសមុទ្រមានបែបដូចដីខ្សាច់ ១* **កាឬលោណំ** *អំបិលមានពណ៌ខ្មៅ (គឺអំបិលប្រក្រតី) ១* **សិន្ធវំ** *គឺសិន្ធៅលោកពោលថាអំបិលពណ៌សកើតលើភ្នំ ១* **ឧព្ភិជ្ជំ** *អំបិលដែលមានពន្ធកដុះអំពីផែនដី (គឺអំបិលដែលកើតអំពីអាចម៍ដីមានរសប្រៃ) ១* **ពិលំ** *អំបិលវិសេសលោកពោលថា អំបិលស្វយសម្ភារ:ទាំងពួងមានពណ៌ក្រហម ១ ។*

ក៏ឯកេសជ្ជ: គឺថ្នាំវត្ថុទាំង ៦ ប្រការមានឫសជាដើម ព្រះអង្គទ្រង់អនុញ្ញាតចង្អុលបង្ហាញឈ្មោះដូច្នេះហើយ តទៅទៀតព្រះអង្គមានប្រាជ្ញាដើម្បីនឹងសម្តែងលក្ខណ:នៃឫសឈើជាដើមដទៃ ដែលមិនមានមកក្នុងបាលីគួរជាថ្នាំបាន ទើបពោលបាលីថា **យានិ ឯ បនញ្ញានិបិ អត្ថិ មូលានិ ឥសាវានិ បណ្ណានិ ផលានិ ផត្ថូនិ លោណានិ ភេសជ្ជានិ ឯវ ខាទនីយេ ខាទនីយត្ថំ ផរន្តិ ន ភោជនីយេ ភោជនីយត្ថំ ផរន្តិ** *ម្យ៉ាងទៀត ឫសឈើ ទឹកអម្ចត់ ស្វឹកឈើ ផ្លែឈើ ជ័រឈើ អំបិល វត្ថុដទៃឯណានីមួយ ដែលមិនបានចេញឈ្មោះក្នុងបាលី ដែលមិនបានផ្សាយទូទៅ ដើម្បីខាទនីយ: ក្នុងខាទនីយ: វត្ថុទំពាស៊ី មិនបានផ្សាយទៅ ដើម្បីភោជនីយ: ក្នុងភោជនីយ វត្ថុបរិភោគ ធ្វើជាថ្នាំបាន ។ នៅមានទៀតគឺ ឫសឈើដទៃជាដើម ដែលមិនបានសម្រេចអាហារកិច្ច បរិភោគជាអាហារដោយប្រក្រតីនៃមនុស្សក្នុងជនបទណា ឫសឈើជាដើមនោះឈ្មោះថាជា*

ភេសជ្ជៈក្នុងជនបទនោះ ព្រោះហេតុនោះ មើម ឫស ក្រឌ ត្រួយ ពន្ធ្ក សម្ពក ស្លឹក ផ្កា ផ្លែ គ្រាប់ ម្សៅ ជ័រ នៃដើមឈើ រលិ ស្មៅ វត្ថុណាមួយក្តី និងអំបិលណាមួយក្តី ដែលមានមកក្នុងបាលី មិនបានសម្រេចអាហារកិច្ចនៃមនុស្សក្នុងប្រទេសនោះ។ ដូចមើមក្ពាតក្រហម មើកក្ពាតស ឫសត្នោត ឫសដូង ស្លឹកម្ទូ ស្លឹកឈូក ផ្កាបុស្សនាគ ផ្កាចម្ប៉ា ផ្កាចន្ទន៍ ផ្លែក្រវាញ ជាដើម ជាភេសជ្ជៈក្នុងប្រទេសយើងនេះ ឫសឈើជាដើមដូចពោលមកនេះ ឈ្មោះថាយាវជីវិក ទទួលប្រគេនហើយ កាលមានជំងឺណាមួយ ធាន់បានដរាបត្រាតែអស់ជីវិតក្នុងកាលទាំងពួង បើធ្វើសន្និធិទុក ឫធាន់ក្នុងវេលាវិកាល ដើម្បីជាអាហារ មិនធាន់ដើម្បីថ្នាំត្រូវអាបត្តិទុក្កដ ។ ព្រោះបាលីដែលព្រះពុទ្ធជាអម្ចាស់ពោលទុកក្នុងខាងចុងគ្រប់ៗភេសជ្ជៈថា **តានិ បដិក្ខេបោ យាវជីវំ បរិហារិតុំ សតិ បច្ចយេ បរិភុញ្ជិតុំ អសតិ បច្ចយេ បរិភុញ្ជន្តស្ស អាបត្តិ ទុក្កដស្ស** *សេចក្តីថា តថាគតអនុញ្ញាតឲ្យទទួល ឫសឈើ ទឹកអម្ជ័ត ស្លឹកឈើ ផ្លែឈើ ជ័រឈើ អំបិល វត្ថុឯណានីមួយ អម្បាលនេះហើយ បរិហារ រក្សាទុកដរាបអស់ជីវិត កាលមានបច្ច័យ គឺហេតុ ឲ្យបរិភោគធាន់ចុះ កាលមិនមានបច្ច័យ គឺហេតុ ធាន់ត្រូវទុក្កដ ដូច្នេះ ។*

យាវជីវិក ចប់

យាវកាលិក

នឹងសម្តែងក្នុងយាវកាលិក របស់ធាន់ ដែលមានអាយុត្រឹមកាលគឺពីព្រឹកដល់ថ្ងៃត្រង់ ។ កាលបើពោលយាវកាលិកហើយ យាវជីវិកក៏នឹងដឹងផងទៀត **ខាទនីយ៌** របស់ទំពាស៊ី **ភោជនីយ៌** របស់ស៊ី ឈ្មោះថាយាវកាលិក ។ ភោជន ៥ គឺបាយ នំកុម្មាស សដូវ ត្រី សាច់ ឈ្មោះថាភោជនីយ:របស់ស៊ី ។ លើកតែភោជន ៥ យាមកាលិក សត្តាហ-កាលិក និងយាវជីវិកចេញ អាមិសក្រៅនោះ ឈ្មោះថាខាទនីយ:របស់ទំពាស៊ីទាំងអស់ ។ ក្នុងរបស់ទំពាស៊ី ដែលធ្វើដោយបុព្វណ្ណជាតិ គឺបាយ និងអបរណ្ណជាតិ គឺសណ្តែក លូ ឡើងជានំ ជាដើម ទាំងអម្បាលនេះ មិនត្រូវពោល ។ សម្បីឫស មើម ក្រឌ ត្រួយ ដើម សម្បក ស្វឹក ផ្កា ផ្លែ គ្រាប់ ម្សៅ ជ័រ នៃដើមឈើ គុម្ពឈើ រលិ ស្មៅ ណាដែលជាគតិនៃអាមិស សម្បីរបស់ទាំងអម្បាលនេះ ក៏សង្គ្រោះថាខាទនីយ:ដោយពិត ។

នឹងសម្តែងក្នុងរបស់ទំពាស៊ី គឺមើមជាមុន មើមដំឡូងទៀន ដំឡូងបបោស ដំឡូងបាស ដំឡូងឈាមមាន់ ដំឡូងដូង ដំឡូងស្សា ស្ពៃ ដំឡូងឈើជាដើម និងដំឡូងមានស្វឹកគួរស្ងមបាន ឈ្មោះថាគតិនៃអាមិសឫសសំយាយក្នុងមើមត្រាវ ដែលគេកាត់ចោលចេញ ជាយាវជីវិក សម្បីឫសសំយាយដទៃដូច្នេះ បណ្ឌិតគប្បីដឹងដោយន័យនោះចុះ ។ តែឫសសំយាយនៃដំឡូងទៀន ដំឡូងបបោស និងឫសស្ពៃជាគតិនៃអាមិសមើមរមៀតជាដើមដែលជាយាវជីវិក ដូចពោលហើយអំពីមុននោះ នឹងរាប់ថាឫសតូចឫសធំទៅក៏មិនមានទីបំផុត ដែលមិនសម្រេចកិច្ចជាខាទនីយ:

ភោជនីយៈនោះផង ជាលក្ខណៈនៃយាវជីវិក ព្រោះហេតុនោះ មើម ឫស ណាមួយ ផ្សាយទៅជារបស់ទំពាស៊ី របស់ស៊ីនៃមនុស្ស ដោយ អំណាចជាអាហារប្រក្រតី មិនត្រូវប្រកបដោយយាវកាលិកដទៃ ក្នុង ជនបទនោះៗ មើម ឫសនោះ ឈ្មោះថាជាយាវកាលិក ក្នុងជនបទ នោះៗ ។ ឫស មើម ក្រៅនោះ គប្បីដឹងថាជាយាវជីវិកចុះ ។ សូម្បី ពោលដោយច្រើនទៅ ក៏គង់តាំងនៅក្នុងលក្ខណៈនេះឯង ។ កាលបើលើក ឈ្មោះឡើងពោល ក៏រង្វើងព្រោះមិនស្គាល់ឈ្មោះនោះៗ ហេតុដូច្នោះ នឹងមិនអើពើឈ្មោះនោះ នឹងសម្តែងតែលក្ខណៈមួយយ៉ាង សម្តែង លក្ខណៈក្នុងឫសដូចម្តេច ក្នុងមើមក៏វិនិច្ឆ័យដូច្នោះ ។ មើមមាន ២ គឺវែង ១ មូល ១ ។ ឯមើមវែងនោះមានក្រឌីឈូកនិងចារជាដើម ។ មើមមូល នោះ គឺមើមឧប្បលនិងមើមបុងជាដើម ។ មើមចាស់និងសំបក និងឫស ល្អិតនៃមើមទាំងអម្បាលនេះ ជាយាវជីវិក ។ តែមើមខ្ចីនឹងគប្បីទំពាស៊ីបាន ដូចភ្ជៀនាង ចារ ម្ការ៉ក់ ក្ជូច និងគល់ចេកជាដើម និងមើមណាមួយដែល សម្រេចជាអាហារកិច្ច ដោយប្រក្រតីបាន ជាយាវកាលិក ។ មើមក្ជូច ដែលគេមិនបានយករសពុលចេញ ជាយាវជីវិក ។ គេយករសកាចចេញ ហើយ ជាយាវកាលិក ។ មើមទាល់ក្រហមទាល់សជាដើម ជាយាវជីវិក សង្ត្រោះក្នុងមូលកេសជ្ជៈ ។ នឹងសម្តែងក្នុងក្រឌីតូច ដូចក្រឌីឈូកក្រហម ឈូកស ក៏ដូចគ្នា ។ ឫសរៃទឹកក្តី ឫសដទៃដែលសម្រេចជាអាហារកិច្ច បានក្តី ជាយាវកាលិក ឫសរមៀត ខ្ចី បណ្ដូលពេជ្រ រលិ្ចត្រឡុង ឫស

ស្វា ជាដើម ជាយាវជីវិក សង្ក្រោះក្នុងមូលកេសជ្ជ: ។ នឹងសម្ពែង ក្នុងត្រួយ និងកំពូល ត្នោត ទន្សែ ចាក ជាដើម និងត្រួយ អំពៅ ស្ពៃ ស្រូវ ៧ ប្រការ នៃដើមឈើនិងវល្លិជាដើម វត្ថុណាដែលសម្រេចអាហារ-កិច្ចបាន ជាយាវកាលិក ។ គល់ត្រួយចាស់នៃរមៀត ខ្ចី លំពាន់ ខ្ចីមក្តី នៃត្នោត ទន្សែ ស្វា ដូងក្តី ជាគល់ត្រួយដែលចាស់ គេកាត់ចោលចេញ ជាយាវជីវិក ។ នឹងពោលដើមភ្ជៅនាងដែលចាក់ចុះទៅក្នុងដី ដើមអំពៅ ដើមឧប្បលខ្ចៀ ឧប្បលក្រហម កុមុទ ចង្កុលណា ដើមណាដែល សម្រេចអាហារកិច្ចបាន ជាយាវកាលិក ។ ទង ស្ងឹក នៃឧប្បលជាតិ និង ទងស្ងឹក នៃបទុមជាតិទាំងពួងក្តី និងដើមទាំងពួងដ៏សេសមានដើមសម្ជរ-មាសជាដើម ដែលមិនសម្រេចអាហារកិច្ចបាន ជាយាវជីវិក ។

នឹងពោលក្នុងសម្ពក សំបកអំពៅមួយជំពូក ដែលមានរសជាប់ នៅជាយាវកាលិក ។ សំបកឈើទាំងពួងដ៏សេសជាយាវជីវិក សង្ក្រោះ ក្នុងកសាវ: គឺទឹកអម្ងត់ ។ នឹងពោលក្នុងស្ងឹក ស្ងឹកដំឡូងទៀនជាដើម និងស្ងឹកស្ពៃ ស្ងឹកត្រុំ ស្ងឹកសណ្តែកបាយ ស្ងឹកសណ្តែកពាជមាស ស្ងឹកញ្ជ្រៃ ស្ងឹកបាស និងស្ងឹកណាដែលសម្រេចអាហារកិច្ចបាន ជា យាវកាលិក អ្នកស្រុកលង្ការ ជ្រម្ម គឺស្ងឹកកំពីងពួយឈើ ជាយាវជីវិក ស្ងឹកស្ងាយខ្ចី ជាយាវកាលិក ស្ងឹកសោកខ្ចី ជាយាវជីវិក ។ នឹងពោល ក្នុងផ្ការ ផ្ការដំឡូងទៀន ជាដើម និងផ្ការស្ពៃ ផ្ការញ្ជ្រៃ ផ្ការញ្ជ្រុក ផ្ការខ្ចីនៃដូងត្នោតនិងកេត ផ្ការឧប្បល ផ្ការឈូក និងផ្ការឈើណាដែល

សម្រេចអាហារកិច្ចបានជាយាវកាលិក ផ្ការសោក ផ្ការពុល ផ្ការសូរកី ផ្ការបុស្សនាគ ផ្ការចម្បា ជាដើម ជាយាវជីវិក សង្គ្រោះក្នុងកសាវកេសជ្ជ: ។ នឹងពោលក្នុងផ្លែ ផ្លែនៃខ្នុរ សាកេរ ត្នោត ដូង ស្វាយ ព្រីង ជាដើម និងផ្លែឈើដទៃ ដែលសម្រេចអាហារកិច្ចបាន ជាយាវកាលិក ។ ផ្លែចន្ទន៍ និងផ្លែក្រាយ និងផ្លែដែលមិនសម្រេចអាហារកិច្ចបាន ជាយាវ-ជីវិក ។ នឹងពោលក្នុងគ្រាប់ គ្រាប់នៃខ្នុរសម្ងួ គ្រាប់នៃខ្នុរណាំង គ្រាប់នៃម្ការ៉ាក់ជាដើម និងគ្រាប់ដទៃដែលសម្រេចអាហារកិច្ចបាន ជាយាវកាលិក គ្រាប់បុស្សនាគ ស្រគំ ស្រម៉ ជាដើម និងគ្រាប់ដទៃដែលមិនសម្រេចអាហារកិច្ចបាន ជាយាវជីវិក សង្គ្រោះក្នុងផលកេសជ្ជ: ។ នឹងពោលក្នុងម្សៅនៃស្រូវ ៧ ប្រការ និងស្រូវអនុលោម និងម្សៅនៃសណ្តែក លូ ជាដើម ម្សៅខ្នុរ ម្សៅសាកេរ និងម្សៅម្ការ៉ាក់ ម្សៅត្នោត ម្សៅក្ជូច ដែលជម្រះចេញហើយ និងម្សៅដទៃ ដែលសម្រេចអាហារកិច្ចបាន ជាយាវកាលិក ។ ម្សៅត្នោត ម្សៅក្ជូច ដែលមិនទាន់ជម្រះរសកំណាច ជាយាវជីវិក សង្គ្រោះក្នុងទឹកអម្ងត់ និងឫសនិងផ្លែ ដែលមានមកក្នុងបាលី ។ នឹងពោលក្នុងជ័រ ជ័រនៃអំពៅមួយជំពូក ជាសត្តាហកាលិក ជ័រឈើក្រៅនោះ ជាយាវជីវិកទាំងអស់ សង្គ្រោះក្នុងជតុកេសជ្ជ: ។ មើម និងក្រឌីជាដើម ដែលជាយាវកាលិក ដូចពោលមកនេះ សង្គ្រោះក្នុងខាទនីយ:របស់ទំពាស៊ី និងភោជនីយ:របស់ស៊ី នេះឈ្មោះថាយាវកាលិក

ធាន់បានពីព្រឹកដល់ថ្ងៃត្រង់ រសៀលហើយធាន់ត្រូវបាចិត្តិយ ទទួលប្រគេនទុកឲ្យកន្ធង៣ត្រី ជាសន្និធិ ធាន់ត្រូវបាចិត្តិយ ។

យាវកាលិក ចប់

យាមកាលិក

នឹងសម្តែងក្នុងយាមកាលិក ។ ទឹក ៨ ប្រការដែលគួរក្រេបផឹកគឺ **អម្ពុចាន់** ទឹកធ្វើដោយផ្ទៃស្វាយខ្ចី ឬទុំ ១ **ជម្ពុចាន់** ទឹកធ្វើដោយផ្ទៃព្រីងផ្ទៃជម្ពូក៏បាន ១ **ចោចចាន់** ទឹកធ្វើដោយផ្ទៃចេកមានគ្រាប់ ១ **មោចចាន់** ទឹកធ្វើដោយផ្ទៃចេកគ្មានគ្រាប់ ១ **មធុចាន់** ទឹកធ្វើដោយរសជាតិនៃស្រគំ ១ **មុទ្ធិកចាន់** ទឹកធ្វើដោយផ្ទៃចាន់ផ្ទៃទំពាំងបាយជូរក៏បាន ១ **សាលុកចាន់** ទឹកធ្វើដោយឫស និងក្រឌីនៃឈូកឧប្បលក្រហម ឧប្បលខៀវជាដើម ១ **ផារុសកចាន់** ទឹកធ្វើដោយផ្ទៃមាក់ប្រាង ផ្ទៃគូលេនក៏បាន ១ ទឹកអដ្ឋបានទាំង ៨ ប្រការនេះ ឈ្មោះថាយាមកាលិក មានយាម ១ ជាកាល គឺមានអាយុត្រឹមថ្ងៃ ១ យប់ ១ ប៉ុណ្ណោះ ។

នឹងពោលដោយវិធីធ្វើទឹកស្វាយជាមុន កាលនឹងធ្វើដោយផ្ទៃស្វាយខ្ចី គប្បីបុកទម្វាយស្វាយខ្ចីដាក់ក្នុងទឹកហើយហាលថ្ងៃទុកឲ្យផ្ទ្ងិនដោយកម្តៅព្រះអាទិត្យ ហើយត្រងចេញ ផ្សំដោយទឹកឃ្មុំ ឬស្ករកបូរ បញ្ចូលគ្នាជាដើម ដែលទទួលប្រគេនក្នុងថ្ងៃនោះហើយធ្វើចុះ ។ ធ្វើខ្ជួនឯងគួរក្នុងបុរេភត្ត គឺវេលាព្រឹកមួយយ៉ាង ។ បើអនុបសម្បន្នធ្វើបានមក

ទទួលប្រគេនក្នុងបុរេភត្ត សូម្បីបរិភោគជាមួយនឹងអាមិសក្នុងបុរេភត្តក៏គួរ ក្នុងបច្ឆាភត្ត គួរបរិភោគប្រាសចាកអាមិស ត្រាតែអរុណរះឡើងមក ។ ក្នុងទឹកជម្ពូជាដើម ក៏ដូចគ្នា ។ តែមធុបាន:ធ្វើដោយស្រគំនោះ លាយដោយទឹកទើបគួរ តែទឹកស្រគំសុទ្ធមិនគួរ ។ ដ្ឋិតក្នុងអដ្ឋកថាថា **មធុកចានន្តិ មុទ្ធិកានំ[1] ជាតិរសេន កតចានំ តំ បន ឧទកសម្ភិន្នំ[1] វដ្ដតិ សុទ្ធំ ន វដ្ដតិ** ដូច្នេះ ។ **មុទ្ធិកចានំ** បុពណ្ណាថាទឹកផ្ងែចាន់ តែអ្នកស្រុកលង្ការថាទឹកទំពាំងបាយជូរ បើទឹកទំពាំងបាយជូរហើយសោត គួរតែទឹកស្រស់ ទឹកទំពាំងបាយជូរដូចប្រទេសអ៊ីរ៉ុបជាដើម គេផឹកសព្វថ្ងៃនេះ ជាមេរ័យមិនគួរ គួរតែទឹកស្រស់ សមដូចជាពាក្យក្នុងអដ្ឋកថាថា **មុទ្ធិកចានន្តិ មុទ្ធិកា ឧទកេ មទ្ធិត្វា អម្ពចានំ វិយ កតចានំ** ដូច្នេះ ។ អដ្ឋបានអម្បាលនោះ សូម្បីត្រជាក់ ឬក្ដៅ ដោយព្រះអាទិត្យគួរ ចម្អិនដោយភ្លើងមិនគួរ ។

មួយទៀត ព្រះអង្គទ្រង់អនុញ្ញាតទុកថា **អនុ... សព្ពំ ផលរសំ ថបេត្វា ឩញ្ញផលរសំ ។ អនុ... សព្ពំ បត្តរសំ ថបេត្វា បក្ខ្លាឆាករសំ ។ អនុ... សព្ពំ បុប្ផរសំ ថបេត្វា មធុកបុប្ផរសំ ។ អនុ... ឧច្ឆុរសំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរសនៃផ្ងែឈើទាំងពួង លើកតែស្រូវ ៧ ប្រការចេញ ។ មួយទៀត តថាគត អនុញ្ញាតរសនៃស្លឹកឈើទាំងពួង លើកតែរសនៃស្លឹកអន្ទក់ឆ្អិនចេញ ។

---

១. ក្នុងវិនយសង្គហដ្ឋកថា ថា "មធុកបានន្តិ មធុកានំ ជាតិរសេន កតបានំ។ តំ បន ឧទកសម្ភិន្នំ វដ្ដតិ, សុទ្ធំ ន វដ្ដតិ" បែបនេះ។

មួយទៀត តថាគតអនុញ្ញាតរសនៃផ្កាឈើ ទាំងពួង លើកតែផ្កាស្រគំ ចេញ ។ មួយទៀត តថាគតអនុញ្ញាតរសនៃទឹកអំពៅសុទ្ធ ។

រឿងដែលអនុញ្ញាតរសនៃផ្លែឈើទាំងពួង រៀរតែរសនៃផ្លែស្រូវ ៧ ប្រការចេញ នោះនឹងដឹងច្បាស់ក្នុងមហាបទេស ៤ ខាងមុខ ។ រឿងដែលទ្រង់អនុញ្ញាតរសនៃស្លឹកឈើទាំងពួង លើកតែរសនៃស្លឹកឆ្អិនចេញនោះ ព្រោះថារសនៃស្លឹកឈើដែលជាយាវកាលិក គួរតែក្នុងបុរេភត្តមួយយ៉ាង ។ រសនៃស្លឹកឈើជាយាវជីវិក គេធ្វើឲ្យឆ្អិនលាយគ្នានឹងសប្បិជាដើម ដែលទទួលប្រគេនទុកនេះ គួរ ៧ ថ្ងៃ បើគេចម្អិនដោយទឹកទទេសុទ្ធ គួរដរាបដល់អស់ជីវិត ។ នឹងស្ងោររសនៃស្លឹកឈើជាយាវ-ជីវិក មួយអន្ទើនឹងទឹកដោះស្រស់ជាដើមមិនគួរ សូម្បីគេស្ងោរជាមួយនឹងរបស់ដទៃ ដែលហៅថាជារសនៃស្លឹកអន្ទក់ឆ្អិន ។ តែក្នុងកុរុន្ទីពោលថារសនៃស្លឹកឈើ សូម្បីជាយាវកាលិក គេច្របាច់ដោយទឹកត្រជាក់ធ្វើមក ឬឲ្យឆ្អិនដោយកម្តៅព្រះអាទិត្យក្តីក៏គួរ ។ រឿងដែលអនុញ្ញាតរសនៃផ្កាឈើទាំងពួង លើកតែរសនៃផ្កាស្រគំចេញនោះ រសនៃផ្កាស្រគំ នឹងឆ្អិនដោយភ្លើង ឬដោយព្រះអាទិត្យក្តី មិនគួរក្នុងបច្ឆាភត្ត ។ រសស្រគំណាដែលចម្អិន ហើយគេកាន់យកធ្វើជាទឹកស្រវឹង រសនោះតាំងអំពីដំបូងទៅ សូម្បីក្នុងបុរេភត្តក៏មិនគួរ ឬផ្កាស្រគំស្រស់ ឬស្ងួតគេលីងហើយក្តី ឬផ-ណិត គេធ្វើដោយផ្កាស្រគំ គឺផ្កាស្រគំផែន តែវត្ថុណា គេមិនបានធ្វើជាទឹកស្រវឹង វត្ថុទាំងពួងនោះ រមែងគួរក្នុងបុរេភត្តមួយយ៉ាង ។ ទឹក

អំពៅស្រស់ដែលទ្រង់អនុញ្ញាតនោះ មិនមានកាក គួរក្នុងបច្ចាកត្ត ព្រះអង្គកាលទ្រង់អនុញ្ញាតបាន: គឺទឹកក្រេបផឹក ព្រះអង្គបានទ្រង់អនុញ្ញាតរសនៃផ្ទៃនិងស្ទឹកនិងផ្កា និងអំពៅបួននេះ ដោយប្រការដូច្នេះ ។ ក្នុងវិមតិ-វិនោទនីដែលពោលថាទឹកអំពៅស្រស់មិនមានកាក ក្នុងយាមកាលិកកថានោះពោលដោយសាមញ្ញថា ជារបស់នឹងគប្បីក្រេបផឹក តែឲ្យគប្បីកាន់យកថា ទឹកអំពៅស្រស់នោះ ជាសត្តាហកាលិកចុះ ។ យាមកាលិកនេះទទួលប្រគេនហើយ ធាន់បានតែមួយថ្ងៃមួយយប់ អរុណថ្មីរះឡើងមក ជាសន្និធិ ធាន់ត្រូវទុក្កដ ។

<u>យាមកាលិក</u> ចប់

សត្តាហកាលិក

នឹងពណ៌នាក្នុងសត្តាហកាលិក ថ្នាំមានអាយុកាលត្រឹម ៧ ថ្ងៃ គឺ **សប្ពិ** *ខ្លាញ់ពាវ* **នវនីត** *ខ្លាញ់ខាប់* **តេលំ** *ប្រេង* **មធុ** *ទឹកឃ្មុំ* **ផាណិតំ** *ទឹកអំពៅ ទាំង ៥ នេះឈ្មោះថាសត្តាហកាលិក ទទួលប្រគេនហើយទុកធាន់បាន ៧ ថ្ងៃ កន្ទង ៧ ថ្ងៃទៅ ដល់អរុណគម្រប់ ៨ រះឡើងមក ជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ជានិស្សគ្គិយហើយធាន់ត្រូវទុក្កដ បរិភោគក្នុងកាលមិនគួរ ។ សប្ពិគោ សប្ពិពពៃ សប្ពិក្របី សាច់នៃសត្វជំពូកណាគួរ សប្ពិនៃសត្វជំពូកនោះឈ្មោះថាសប្ពិ ។ នវនីត នៃសត្វជំពូកនោះឯងឈ្មោះថានវនីត ។ គប្ពីដឹងក្នុងគោរស ៥ ជាមុន ទឹកដោះស្រស់នៃគោ នៃពពៃ នៃក្របី នៃសត្វ ដែលមានសាច់គួរ ឈ្មោះថា* **ទីរ** *ថា*

ទឹកដោះស្រស់ ទឹកដោះស្រស់នោះទុកចោលយូរ លុះជូរឈ្មោះថា **ឧធិ** ទឹកដោះជូរ ទឹកដោះជូរនោះគេចម្រាញ់ឡើងឈ្មោះថា **តក្ក** ប្រេង ប្រេងនោះ គេចម្រាញ់ឡើងឈ្មោះថា **ឧវនីតំ** គឺខ្លាញ់ខាប់ ខ្លាញ់ខាប់នោះ គេចម្រាញ់ឡើងទៀតឈ្មោះថា **សប្បិ** គឺខ្លាញ់រាវ ទឹកដោះស្រស់ ទឹកដោះជូរ ប្រេង ជាយាវកាលិក គួរតែក្នុងវេលាព្រឹក ។ នវនីត សប្បិ ជាសត្តាហកាលិក ខ្លាញ់ទាំង ២ នេះ ក្នុងប្រទេសយើងមានប្រើតិច ព្រោះហេតុនោះ នឹងមិនបានវិនិច្ឆ័យឲ្យពិស្តារទេ នឹងវិនិច្ឆ័យតែថ្នាំ ៣ យ៉ាងក្រៅនេះ **តេលំ** ប្រេង **មធុ** ទឹកឃ្មុំ **ផាណិតំ** ស្ករអំពៅ ។ សប្បិ និងនវនីត ទទួលប្រគេនក្នុងវេលាព្រឹក គួរធាន់ដោយអាមិសបានក្នុងវេលាព្រឹក រសៀលទៅហើយមិនគួរ ។ បើធាន់ប្រាសចាកអាមិសបាន ៧ ថ្ងៃ កន្ទង ៧ ថ្ងៃទៅ ត្រូវនិស្សគ្គិយរាប់តាមវត្ថុនិងភោជនដែលដាក់ទុក ។ ប្រេងកើតអំពីលូ កើតអំពីគ្រាប់ស្ពៃ គ្រាប់ស្រគំ គ្រាប់ល្ហុង និងកើតអំពីកន្សោមខ្លាញ់សត្ត ទាំងអម្បាលនេះមានក្នុងបាលី ។ គ្រាប់លូ គ្រាប់ស្រគំ គ្រាប់ល្ហុង កន្សោមខ្លាញ់ ជាយាវកាលិក ។ គ្រាប់ក្រៅនោះ គឺគ្រាប់ស្ពៃជាយាវជីវិក ។ នឹងពោលក្នុងប្រេងលូជាមុន ប្រេងលូទទួលប្រគេនក្នុងវេលាព្រឹក សូម្បីធាន់ជាមួយអាមិស ក្នុងវេលាព្រឹកថ្ងៃនោះ ក៏គួរ តែរសៀលទៅធាន់ប្រាសចាកអាមិសទើបគួរ កន្ទង ៧ ថ្ងៃទៅ ត្រូវនិស្សគ្គិយរាប់តាមភាជនៈដែលដាក់ទុក ។ ប្រេងលូទទួលប្រគេនក្នុងបច្ឆាភត្ត គឺវេលាល្ងាច គួរធាន់ប្រាសចាកអាមិសមួយជំពូក បាន ៧ ថ្ងៃ

ធ្វើឲ្យជាខ្ពស់ហិតហើយ ទុកដាក់និងបរិភោគមិនគួរ គប្បីបង្ហោនចូលទៅ ក្នុងកិច្ចដទៃមានលាបសិរជាដើម កន្ទ ៧ ថ្ងៃទៅមិនត្រូវអាបត្តិ ។ ទទួលប្រគេនគ្រាប់ល្ងក្នុងបុរេភត្ត គឺវេលាព្រឹក ហើយធ្វើជាប្រេងគួរធាន់ បាន សូម្បីដោយអាមិសក្នុងបុរេភត្ត អំពីបច្ចាភត្តទៅជារបស់មិនគួរលេប ស៊ី គប្បីបង្ហោនចូលទៅក្នុងកិច្ចដទៃមានលាបសិរជាដើម បើកន្ទ ៧ ថ្ងៃទៅមិនត្រូវអាបត្តិ ។ ទទួលប្រគេនគ្រាប់ល្ងក្នុងបច្ចាភត្តធ្វើឡើងជា ប្រេង ជារបស់មិនគួរបរិភោគឡើយ ព្រោះទទួលទាំងវត្ថុ បើកន្ទ ៧ ថ្ងៃទៅមិនត្រូវអាបត្តិ គប្បីបង្ហោនចូលទៅក្នុងកិច្ចដទៃ មានលាបសិរ ជាដើម សូម្បីក្នុងប្រេងដែលធ្វើដោយគ្រាប់ល្ងខ្ពស់ហិត ក្នុងបុរេភត្ត ឬបច្ចាភត្តក៏ដូចគ្នាដូច្នោះ ។ ប្រេងចម្រាញ់គ្រាប់ល្ង ឬចំហុយម្សៅល្ង ដែលទទួលប្រគេនក្នុងបុរេភត្ត ឬឲ្យទទឹកសើមដោយទឹកក្តៅធ្វើក្តី បើអនុ-បសម្បន្នធ្វើគួរ សូម្បីធាន់លាយដោយអាមិសក្នុងបុរេភត្តក៏គួរ ធ្វើខ្ជូនឯង គួរធាន់ប្រាសចាកអាមិសក្នុងបុរេភត្ត ព្រោះកិក្ខុបកខ្ជូនឯងធាន់ជាមួយ អាមិសមិនគួរ ព្រោះហេតុឲ្យឆ្អិនឯង អំពីបច្ចាភត្តទៅ ប្រេងទាំង ២ យ៉ាងនោះមិនគួរធាន់ ព្រោះទទួលទាំងវត្ថុ គប្បីបង្ហោនចូលទៅ ក្នុងកិច្ច ដទៃមានលាបសិរជាដើម កន្ទ ៧ ថ្ងៃទៅមិនត្រូវអាបត្តិ ថាបើទឹកក្តៅ តិច ល្មមតែបំព្រំចុះប៉ុណ្ណោះ រមែងជាអព្ជោហារិក មិនដល់នូវការ រាប់ថាជាសាមបក្ក ។ បើក្នុងប្រេងគ្រាប់ស្ពៃជាដើម ដែលទទួលទាំងវត្ថុ ក៏វិនិច្ឆ័យដូចពោលហើយ ក្នុងប្រេងល្ងដែលមិនបានទទួលទាំងវត្ថុ តែ

ថាអាចយកលម្អិតនៃគ្រាប់ស្ពៃជាដើម ដែលទទួលប្រគេនហើយក្នុងបុរេភត្តមកធ្វើជាប្រេង ចម្អិនដោយកម្តៅព្រះអាទិត្យ ប្រេងនោះគួរធាន់សូម្បីដោយអាមិសបានក្នុងបុរេភត្ត តែអំពីបច្ឆាភត្តទៅ គួរធាន់ប្រាសចាកអាមិស កន្ទង ៧ ថ្ងៃទៅគង់ត្រូវនិស្សគ្គិយ ។ គេចំហុយលម្អិតគ្រាប់ស្ពៃ និងស្រគំជាដើម ឬលីងគ្រាប់ល្ហុងធ្វើជាប្រេងយ៉ាងនោះ ព្រោះហេតុនោះ ប្រេងនៃរបស់អម្បាលនោះ អនុបសម្បន្នធ្វើ សូម្បីធាន់ដោយអាមិសក្នុងបុរេភត្តក៏គួរ ដែលនឹងមានទោស ព្រោះទទួលទាំងវត្ថុនោះមិនមានព្រោះគ្រាប់ស្ពៃជាដើម ជាយាវជីវិក ។ ភិក្ខុធ្វើឯងគប្បីបរិភោគប្រាសចាកអាមិស ប្រេងដែលធ្វើដោយគ្រាប់ស្ពៃជាដើម ដែលជាឧគ្គហិតមិនគួរនឹងបរិភោគ គួរបរិភោគតែខាងក្រៅ កន្ទង ៧ ថ្ងៃទៅមិនត្រូវអាបត្តិ ទទួលប្រគេនគ្រាប់ស្ពៃ ស្រគំ ល្ហុង ទុកដើម្បីធ្វើជាប្រេងហើយ ធ្វើឡើងជាប្រេងក្នុងថ្ងៃនោះ គួរ ៧ ថ្ងៃ ។ ធ្វើក្នុងថ្ងៃគម្រប់ ២ គួរ ៦ ថ្ងៃ ។ ធ្វើក្នុងថ្ងៃគម្រប់ ៣ គួរ ៥ ថ្ងៃ ។ ធ្វើក្នុងថ្ងៃគម្រប់ ៤ គួរ ៤ ថ្ងៃ ។ ធ្វើក្នុងថ្ងៃគម្រប់ ៥ គួរ ៣ ថ្ងៃ ។ ធ្វើក្នុងថ្ងៃគម្រប់ ៦ គួរ ២ ថ្ងៃ ។ ធ្វើក្នុងថ្ងៃគម្រប់ ៧ គួរ ក្នុងថ្ងៃ ១ នោះ ។ បើទុកឲ្យអរុណរះឡើងមក ត្រូវនិស្សគ្គិយ ។ ធ្វើក្នុងថ្ងៃគម្រប់ ៨ ជារបស់មិនគួរនឹងបរិភោគ គួរតែបរិភោគប្រើប្រាស់ខាងក្រៅ ព្រោះមិនមែនជានិស្សគ្គិយ ។ ថាបើមិនធ្វើគ្រាប់ស្ពៃជាដើម ដែលទទួលទុកដើម្បីធ្វើជាប្រេងនោះ កន្ទង ៧ ថ្ងៃទៅត្រូវទុក្កដ ។ តែប្រេងនៃដូង និងស្ពៃ ពង្រ សង្ឃ្ស៊ែ សំរោង ជាដើមដទៃ ដែលមិនមានក្នុងបាលី ទទួលប្រគេនទុកឲ្យ

ហួស៧ថ្ងៃ ត្រូវទុក្កដ ។ នេះឯងជាសេចក្ដីប្លែកគ្នាក្នុងប្រេងទាំងអម្បាលនេះ គប្បីកំណត់ប្រេងក្រៅនោះ ដែលមានវត្ថុជាយាវកាលិក ឬមានវត្ថុជាយាវជីវិក ហើយគប្បីដឹងដោយវិធីទាំងពួង គឺសាមបក្ក និងទទួលទាំងវត្ថុ ទទួលក្នុងវេលាព្រឹក ឬល្ងាច ឬមានវត្ថុជាឧគ្គហិត ដោយន័យដូចពោលហើយនោះចុះ។ ខ្លាញ់នៃកន្សោមសត្ត ដែលព្រះអង្គទ្រង់អនុញ្ញាតទុក ៥ យ៉ាង គឺកន្សោមខ្លាញ់ខ្លាឃ្មុំ កន្សោមខ្លាញ់ត្រី កន្សោមខ្លាញ់ឆ្មាម កន្សោមខ្លាញ់ជ្រូក កន្សោមខ្លាញ់លា ដ្បិតទ្រង់អនុញ្ញាតកន្សោមខ្លាញ់ខ្លាឃ្មុំ និងកន្សោមខ្លាញ់នៃសត្ថមានសាច់ជាអកប្បិយទាំងពួងនោះព្រះអង្គទ្រង់អនុញ្ញាតផង រឿងតែកន្សោមខ្លាញ់មនុស្សមួយជំពូក ។ ដ្បិតកាន់យកត្រីឡើងពោល សូម្បីឆ្មាមក៏ជាសេចក្ដីកាន់យកឡើងពោលផង ព្រោះរាប់បញ្ចូលក្នុងពួកត្រី តែព្រះអង្គទ្រង់ពោលថាឆ្មាមប្លែកចេញទៅ ព្រោះជាត្រីកំណាច ដ្បិតកាន់យកត្រីជាដើមឡើងពោល ខ្លាញ់នៃសត្ថមានសាច់ជាកប្បិយទាំងពួងឈ្មោះថាទ្រង់អនុញ្ញាតផង ដ្បិតថាក្នុងសាច់សត្ថទាំងឡាយ សាច់នៃមនុស្ស និងដំរី សេះ ឆ្កែ ពស់ រាជសីហ៍ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ខ្លារខិន ១០ នេះជាអកប្បិយ ។ ចំណែកក្នុងខ្លាញ់ ខ្លាញ់នៃមនុស្សមួយជំពូកជាអកប្បិយ ។ ចំណែកក្នុងទឹកដោះស្រស់ជាដើមវត្ថុដែលជាអកប្បិយមិនមាន ។ ប្រេងនៃខ្លាញ់ដែលអនុបសម្ផន្នធ្វើហើយត្រង់ទទួលប្រគេនក្នុងវេលាព្រឹក គួរធាន់សូម្បីដោយអាមិសក្នុងវេលាព្រឹកបាន តែរសៀលទៅហើយ គួរធាន់ប្រាសចាកអាមិសម្យ៉ាង

បាន ៧ ថ្ងៃ ។ ក៏ឯសាច់សរសៃធ្ងឹងឈាមឯណាដែលល្អិតដូចធូលីដ៏ល្អិត មានក្នុងប្រេងនោះ របស់អម្ពាលនោះ ក៏ជាអញ្ជើហារិក ថាបើទទួលប្រគេនខ្ញាញ់ធ្វើដោយខ្លួនឯង ទទួលហើយចម្រាញ់ ហើយត្រង់ឲ្យស្រេចក្នុងវេលាព្រឹកនោះ គប្បីបរិភោគប្រាសចាកអាមិសបាន ៧ ថ្ងៃ ព្រោះព្រះអង្គទ្រង់អនុញ្ញាតចំពោះខ្ញាញ់ឲ្យជាកេសជ្ជៈ ។ រឿងដែលព្រះអង្គទ្រង់អនុញ្ញាតឲ្យទទួលខ្ញាញ់ក្នុងកាល ចម្រាញ់ក្នុងកាល ត្រង់ក្នុងកាល បរិភោគប្រេងនោះ អាស្រ័យបរិភោគប្រាសចាកអាមិស សូម្បីក្នុងប្រេងនោះមានសាច់ជាដើមដ៏ល្អិតជាអញ្ជើហារិកពិត តែនឹងទទួល ឬចម្រាញ់ក្នុងបច្ចាកត្តមិនគួរឡើយ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា **វិកាលេ ចេ ភិក្ខវេ បដិក្ខហាណំ ។ ល ។ អាបត្តិ តិណ្ណំ ទុក្ខដានំ** ម្នាលភិក្ខុទាំងឡាយ បើទទួលខ្ញាញ់ក្នុងវិកាល ចម្រាញ់ក្នុងវិកាល ត្រង់ក្នុងវិកាលបរិភោគត្រូវអាបត្តិទុក្កដ ៣ ។ បើទទួលក្នុងកាល ចម្រាញ់ក្នុងវិកាល ត្រង់ក្នុងវិកាល បរិភោគត្រូវអាបត្តិទុក្កដ ២ ។ បើទទួលក្នុងកាល ចម្រាញ់ក្នុងកាល ត្រង់ក្នុងវិកាល បរិភោគត្រូវអាបត្តិទុក្កដ ១ ។ បើទទួលចម្រាញ់ ត្រង់ក្នុងកាល បរិភោគមិនត្រូវអាបត្តិ ។ សប្ជិ នវនីត លាយគ្នាចម្រាញ់ត្រង់ជាមួយគ្នា មានតេជៈសង្កត់សង្កិនរោគបាន គួរ ។ សូម្បីខ្ញាញ់នៃខ្ទាឃ្មុំ និងខ្ញាញ់ជ្រូកដាក់ចុះក្នុងបបរ ដែលលាយដោយឫសឈើ ៥ និងទឹកអម្ចត់ ធាន់មានតេជៈក្លា អាចសង្កត់រោគខ្សល់បានក៏គួរ ។ នឹងពោលក្នុងទឹកឃ្មុំ ទឹកឃ្មុំដែលមេឃ្មុំធំ តូចវាធ្វើ ទើបឈ្មោះថាមធុ

ទឹកឃ្មុំនោះទទួលប្រគេនក្នុងកាល គួរធាន់ជាមួយអាមិសបានក្នុងកាល តែ
រសៀលទៅហើយ គួរធាន់ប្រាសចាកអាមិសបាន ៧ ថ្ងៃ កន្ទ ៧ ថ្ងៃទៅ
បើជាទឹកឃ្មុំនៃឃ្មុំធំស្ងួតដូចជាដ័ររឈើធ្វើជាដុំ តម្ពស់ទុក ឬទឹកឃ្មុំ
ដាក់នៅក្នុងភាជន:ផ្សេងៗ ត្រូវនិស្សគ្គិយ រាប់តាមវត្ថុ ។ បើជាដុំតែមួយ
ប៉ុណ្ណោះ ឬរាវនៅក្នុងភាជន:តែមួយ ត្រូវនិស្សគ្គិយ តែមួយប៉ុណ្ណោះ ។
ទឹកឃ្មុំជាឧគ្គហិត គប្បីដឹងដោយន័យដូចពោលហើយនោះចុះ ។ គប្បី
បង្ហោនចូលទៅក្នុងកិច្ចមានលាបដំបៅជាដើម សំណុសឃ្មុំ ឬក្រមួន
មិនបានប្រឡាក់ដោយទឹកឃ្មុំ ដ៏បរិសុទ្ធជាយាវជីវិត បើប្រឡាក់ដោយ
ទឹកឃ្មុំក៏ជាគតិនៃទឹកឃ្មុំពិត ។ ឃ្មុំវែងមានស្ងាបម្យ៉ាងឈ្មោះចិរិក: កន្ទង់ធំ
ពណ៌ខ្មៅម្យ៉ាងមានធ្នឹងជាស្ងាប ឈ្មោះតុម្ពល: ក្នុងទីលំនៅនៃសត្វទាំង
អម្បាលនោះ មានទឹកផ្អែមស្ងួតដូចដ័ររឈើ ទឹកផ្អែមនោះជាយាវជីវិត ។

នឹងពណ៌នាក្នុងផាណិត ផាណិតកើតអំពីអំពៅតាំងអំពីទឹកអំពៅ
ចៅទៅ ឬធ្ងិនមិនបានលាយដោយកាក ទឹកអំពៅគេធ្វើវិសេសទាំងពួង
មិនលាយដោយកាក គប្បីដឹងថាជាផាណិតចុះ ទឹកអំពៅនោះទទួលប្រ-
គេនក្នុងកាល គួរធាន់សូម្បីដោយអាមិសបានក្នុងកាល តែរសៀលទៅគួរ
ធាន់ប្រាសចាកអាមិសបាន ៧ ថ្ងៃ កន្ទ ៧ ថ្ងៃទៅ ត្រូវនិស្សគ្គិយរាប់តាម
វត្ថុ ។ ដុំស្ករអំពៅ សូម្បីច្រើន គេកិនល្ងិតដាក់ក្នុងភាជន:តែមួយ ណែន
ចង្អៀតគ្នា ត្រូវនិស្សគ្គិយតែមួយប៉ុណ្ណោះ ។ ទឹកអំពៅជាឧគ្គហិត គប្បី
ដឹងដូចន័យដែលបានពោលហើយនោះ គប្បីបង្ហោនចូលទៅក្នុងកិច្ចមាន

លាបកុដិជាដើម ។ ស្ករអំពៅផែនធ្វើដោយទឹកអំពៅមិនទាន់បានត្រង ទទួលប្រគេនក្នុងកាល បើអនុបសម្បន្នធ្វើ សូម្បីធាន់ប្រកបដោយអាមិសគួរ បើធ្វើខ្ជនឯងធាន់ប្រាសចាកអាមិសតែម្យ៉ាងគួរ រសៀលទៅហើយជារបស់មិនគួរបរិភោគ ព្រោះទទួលទាំងវត្ថុ សូម្បីកន្ទង ៧ ថ្ងៃទៅមិនត្រូវអាបត្តិ ។ ស្ករអំពៅផែនគេធ្វើដោយទឹកអំពៅធៅ តែនៅមិនទាន់បានត្រង ទទួលប្រគេនក្នុងវិកាលជារបស់មិនគួរបរិភោគឡើយ សូម្បីកន្ទង ៧ ថ្ងៃទៅក៏មិនត្រូវអាបត្តិ ។ សូម្បីក្នុងផាណិត ទទួលប្រគេនដើមអំពៅមកធ្វើក៏ដូចគ្នាយ៉ាងនោះ ផាណិតដែលធ្វើដោយទឹកអំពៅធៅត្រងហើយ ទទួលប្រ-គេនក្នុងកាល បើអនុបសម្បន្នធ្វើ សូម្បីធាន់ប្រកបដោយអាមិសក្នុងកាលក៏គួរ តែរសៀលទៅហើយ គួរធាន់ប្រាសចាកអាមិស បាន ៧ ថ្ងៃ ធ្វើខ្ជនឯង សូម្បីក្នុងកាល ធាន់ប្រាសចាកអាមិសតែម្យ៉ាងក៏គួរ បើវិកាលទៅហើយ គួរធាន់ប្រាសចាកអាមិសបាន ៧ ថ្ងៃ ឯផាណិតធ្វើដោយទឹកអំពៅស្រស់ដែលត្រងហើយ ទទួលប្រគេនក្នុងវិកាល ធាន់ប្រាសចាកអាមិសបាន ៧ ថ្ងៃ ផាណិតជាឧគ្គហិតមានន័យដូចពោលមកហើយនោះឯង ។ ក្នុងមហា-អដ្ឋកថាពោលថា ផាណិតធ្វើដោយអំពៅដុត ឬធ្វើដោយអំពៅដាំរម្ងាស់ គួរក្នុងកាល តែក្នុងមហាបច្ចរី សួរថា ផាណិតចម្អិនទាំងវត្ថុគួរឬមិនគួរ ? ឆ្វើយថា ផាណិតធ្វើដោយទឹកអំពៅ ដែលនឹងពោលថាមិនគួរក្នុងវិកាលនោះ មិនមាន ដូច្នេះពាក្យនេះគួរ ។ ផាណិតផ្ការ្ជកគំ ធ្វើដោយទឹកត្រជាក់ សូម្បីធាន់លាយដោយអាមិសក្នុងកាលក៏គួរ តែរសៀលទៅហើយ

គួរធាន់ប្រាសចាកអាមិសបាន ៧ ថ្ងៃ កន្ទ ៧ ថ្ងៃទៅត្រូវទុក្កដ រាប់ដោយ
រត្ត ។ តែផាណិតផ្ការ្រគំគេលាយទឹកដោះស្រស់ចុះផងជាយាវកាលិក តែ
ខណ្ឌសក្ករៈគឺស្ករដុំ ស្ករក្រួស គេយកទឹកដោះស្រស់ចេញហើយ ធ្វើឲ្យ
បរិសុទ្ធ ព្រោះហេតុនោះ ខណ្ឌសក្ករៈនោះទើបគួរក្នុងវេលាវិកាល តែផ្ការ
ស្រគំស្រស់ឬគេលីងហើយ លុះលីងហើយបុកលាយដោយរបស់ដទៃ ឬ
មិនលាយក្តីក៏គួរក្នុងកាល ។ ថាបើគេកាន់យកផ្ការ្រគំនោះផ្សំដើម្បីជា
មេរ័យ គេផ្សំហើយតាំងអំពីពួជទៅ មិនគួរ ។ ផាណិតនៃផ្លែឈើជា
យាវកាលិកទាំងពួង មានផ្លែចេក ផ្លែម្ទេ ផ្លែស្វាយ ផ្លែសាកេ ផ្លែខ្ទ
អំពិល ជាយាវកាលិកពិត ។ ជនទាំងឡាយគេធ្វើផាណិតដោយម្ទេសទុំ
ផាណិតគឺម្ទេសផែននោះជាយាវជីវិក ។

មួយទៀត ស្ករតាំងសុិន ស្ករស ស្ករក្ទម ស្ករផែន សង្ត្រោះក្នុង
ផាណិត ថ្នាំ ៥ យ៉ាងនោះ ទទួលប្រគេនហើយមិនឲ្យកន្ទ ៧ ថ្ងៃទៅ សូម្បី
មានជំងឺឬមិនមានជំងឺក្តី គប្បីធាន់តាមស្រួលចុះ ដ្ឋិតរបស់ដែលព្រះអង្គ
ទ្រង់អនុញ្ញាតចំពោះមាន ៧ ប្រការគឺ ចំពោះព្យាធិ ១ ចំពោះបុគ្គល ១
ចំពោះកាល ១ ចំពោះសម័យ ១ ចំពោះប្រទេស ១ ចំពោះកន្ទ្ធាម
ខ្ទាញ់ ១ ចំពោះថ្នាំ ១ ។ អនុញ្ញាតចំពោះព្យាធិនោះ ដូចទ្រង់អនុញ្ញាត
ឲ្យភិក្ខុដែលខ្ទ្ចាចចូលធាន់សាច់ស្រស់ ឈាមស្រស់ក៏បាន សាច់ស្រស់
ឈាមស្រស់នោះ គួរដល់ភិក្ខុដែលមានអាពាធដូច្នោះ តែមួយចំណែក
ប៉ុណ្ណោះ មិនគួរដល់ភិក្ខុដទៃ ។ សាច់ឈាមនោះជាកប្ដិយ ឬជា

អកប្បិយ គួរដល់ភិក្ខុអាពាធនោះទាំងត្រឹកទាំងស្ងាច ។ អនុញ្ញាតចំពោះ
បុគ្គលនោះ ដូចទ្រង់អនុញ្ញាតអាហារដែលកើរើចេញដល់បំពង់ក ហើយ
ត្រឡប់ចូលទៅវិញ មិនត្រូវអាបត្តិ ដល់ភិក្ខុអ្នកធ្លាប់កើរើ អនុញ្ញាតនោះ
គួរដល់ភិក្ខុអ្នកធ្លាប់កើរើតែមួយជំពូក មិនគួរដល់ភិក្ខុដទៃ តែរើចេញមក
ដល់ក្រៅមាត់ហើយ កុំត្រឡប់លេបចូលទៅ ។ អនុញ្ញាតចំពោះ
កាលនោះ ដូចទ្រង់អនុញ្ញាតថ្នាំមហាវិកដ ៤ គឺ លាមក មូត្រ ផេះ ដី
ចំពោះក្នុងកាលភិក្ខុពស់ចឹកប៉ុណ្ណោះ សូម្បីមិនបានទទួលប្រគេន ធាន់
ក៏គួរ ក្នុងកាលដទៃមិនគួរ ។ អនុញ្ញាតចំពោះសម័យនោះ ដូចអនុញ្ញាត
មិនឲ្យត្រូវអាបត្តិ ព្រោះធាន់គណភោជន ក្នុងសម័យអាពាធជាដើម
មិនត្រូវអាបត្តិ តែក្នុងសម័យដូច្នោះមួយជំពូក ក្នុងសម័យដទៃត្រូវ
អាបត្តិ ។ អនុញ្ញាតចំពោះប្រទេសនោះ ដូចទ្រង់អនុញ្ញាតការឧបសម្បទា
ដោយគណៈសង្ឆ មានវិន័យធរជាគម្រប់ ៥ ជាដើម ក្នុងបច្ចន្តប្រទេស
ប៉ុណ្ណោះ ក្នុងមជ្ឈិមប្រទេសមិនគួរ ។ អនុញ្ញាតចំពោះកនេ្សាមខ្ចាញ់
នោះ ដូចទ្រង់អនុញ្ញាតខ្ចាញ់ ៥ ប្រការ ដើម្បីឲ្យជាថ្នាំ ដោយឈ្មោះ
នៃកនេ្សាមខ្ចាញ់ កនេ្សាមខ្ចាញ់នោះ ទទួលចម្រាញ់ត្រង់ក្នុងកាល ធាន់
បានតែខ្ចាញ់ភាវ ។ ដែលទ្រង់អនុញ្ញាតនោះ គួរតែភិក្ខុដែលត្រូវការ
ដោយខ្ចាញ់ភាវ យកខ្ចាញ់នៃសត្វមានសាច់ជាកប្បិយ ឬអកប្បិយទាំងពួង
រៀងតែខ្ចាញ់នៃមនុស្សចេញ ខ្ចាញ់ក្រៅអំពីនោះ មកធ្វើជាខ្ចាញ់ធាន់
បាន ។ អនុញ្ញាតចំពោះថ្នាំនោះ ទ្រង់អនុញ្ញាត សប្បិ នវនីត ប្រេង

ទឹកឃ្មុំ ទឹកអំពៅ សូម្បីសម្រេចអាហារកិច្ចបាន ក៏ទ្រង់អនុញ្ញាតដោយ ឈ្មោះថាជាភេសជ្ជ: ថ្នាំនោះទទួលប្រគេនហើយ គប្បីធាន់តាមគាប់ចិត្ត ចុះ ក្នុងវេលាព្រឹកថ្ងៃនោះ តែរសៀលទៅ កាលបើមានហេតុគប្បីធាន់ បាន ៧ ថ្ងៃ តែស្ករអំពៅ ស្ករតាំស៊ិន ស្ករស ស្ករក្អម ដែលរឹងខាប់ ថាបើមានអាពាធ គប្បីទំពាបរិភោគបាន មិនមានអាពាធមិនគួរបរិភោគ គប្បីលាយដោយទឹកធាន់ ។ ដ្ឋិតទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ តិលានសប្ប កុដ្ឋំ អតិលានសប្ប កុដ្ឋោ**ឧកំ ដូច្នេះ ។ ថ្នាំ ៥ ប្រការនេះ បើមិនធាន់ នឹងទុកបរិភោគខាងក្រៅ មានលាបសិរ និងអុចប្រទីបជាដើម គប្បីអធិដ្ឋានថានឹងទុកបរិភោគ ខាងក្រៅ ក្នុង ៧ ថ្ងៃ បើនឹងយកប្រេងដែលអធិដ្ឋាននោះ ដាក់ក្នុងភាជន: ប្រេងដែលមិនទាន់អធិដ្ឋាន បើក្នុងភាជន:ប្រហោងតូចល្អិត ប្រេងថ្មី ជ្រាបហូរចូលទៅ ប្រេងចាស់សង្គ្រត់លិចបាន គប្បីអធិដ្ឋានជាថ្មី បើ ប្រហោងមាត់ធំ ប្រេងច្រើនចូលទៅធាប់សង្គ្រត់ប្រេងចាស់បាន កិច្ច ដែលនឹងត្រូវអធិដ្ឋានទៀតមិនមាន ព្រោះថាប្រេងថ្មីក៏ជារបស់មានគតិនៃ ប្រេងដែលអធិដ្ឋានហើយ សូម្បីចាក់ប្រេងដែលមិនបានអធិដ្ឋានចុះក្នុង ភាជន:ប្រេងដែលបានអធិដ្ឋានហើយ ក៏គប្បីដឹងដោយន័យនោះចុះ ។

មួយទៀត ថ្នាំ ៥ ប្រការនេះ ដែលទទួលប្រគេនទុកហើយ បើធាន់ ពុំអស់ គប្បីលះចេញក្នុង ៧ថ្ងៃ បើជារបស់មានម្ចាស់ពីរនាក់ ម្នាក់ទទួល ប្រគេនទុកនោះមិនទាន់បានចែកគ្នា កន្ទង ៧ ថ្ងៃទៅ មិនត្រូវអាបត្តិផងគ្នា

ទាំងពីរនាក់ ប៉ុន្តែនឹងធាន់មិនគួរ សូម្បីអ្នកទទួលប្រគេនប្រាប់អ្នកដទៃ ឲ្យធាន់ អ្នកនោះមិនធាន់ កន្ទង ៧ ថ្ងៃទៅ ក៏មិនត្រូវអាបត្តិផងគ្នាទាំងពីរនាក់ ព្រោះអ្នកទទួលក៏លះទៅហើយ អ្នកម្នាក់នោះ ក៏ពុំបានទទួល ។

សត្តាហកាលិក ចប់

កាលិកសំសគ្គកថា

នឹងពោលក្នុងកាលិកសំសគ្គកថាទាំង ៤ ដែលលាយច្រឡំគ្នាដោយបាលីថា **យាវកាលិកេន ភិក្ខវេ យាមកាលិកំ តទ-ហុបដិក្ខហិតំ ។ ល ។ សត្តាហាតិក្កន្តេ ន ភុញ្ជតិ** ម្នាលភិក្ខុទាំងឡាយ យាមកាលិក សត្តាហកាលិក យាវជីវិក ទាំង ៣ នេះ វត្ថុណាមួយ ទទួលប្រគេនទុកក្នុងថ្ងៃនោះជាមួយគ្នា នឹងយាវកាលិក រមែងគួរតែក្នុងកាល មិនគួរក្នុងវិកាល ។ សត្តាហកាលិក យាវជីវិកទាំងពីរនេះ វត្ថុណាមួយ ទទួលប្រគេនក្នុងថ្ងៃនោះ ជាមួយគ្នាដោយយាមកាលិក គួរតែក្នុងយាម គឺថ្ងៃ ១ យប់ ១ កន្ទងយាមទៅ គឺដល់អរុណឡើងមក មិនគួរ ។ យាវជីវិកទទួលប្រគេនជាមួយនឹងសត្តាហ-កាលិក គួរ ៧ ថ្ងៃ កន្ទង ៧ ថ្ងៃទៅមិនគួរ ។ ក្នុងអដ្ឋកថា ថាពាក្យទាំងពួងក្នុងបាលីនោះ អាស្រ័យយកកាលិកទាំងអម្បាលនោះ ដែលមានរសលាយចូលគ្នា ពោលដោយសេចក្តីថា បើទឹកអដ្ឋបាន លាយនឹងផ្ទៃដូងទាំងផ្ទៃ មិនបានយកសំបកចេញ ទទួលប្រគេនជាមួយគ្នា ហើយយកផ្ទៃដូងចេញ ទឹកអដ្ឋបាននោះ សូម្បីក្នុងវិកាលក៏គួរ ។ ទាយកទាំង

ឡាយគេដាក់ដុំសប្ប៊ីលើបាយបាយាសដែលត្រជាក់ប្រគេន សប្ប៊ីណា ដែលមិនច្រឡំដោយបាយបាយាស សប្ប៊ីនោះ នឹងយកចេញ ទុកធាន់ បាន ៧ ថ្ងៃគួរ សូម្បីក្នុងទឹកឃ្មុំដែលស្ងួតនិងស្ករអំពៅ ដាក់លើបាយបា-យាសក៏ដូចគ្នាដូច្នោះ ទាយកគេយកក្រវាញនិងផ្ទៃច័ន្ទន៍ជាដើម ប្រដាប់តាក់តែងបិណ្ឌបាតមកថ្វាយ គប្ប៊ីលើកយកក្រវាញ និងផ្ទៃនៃច័ន្ទន៍នោះ ឡើងមកលាងចេញ ទុកធាន់ដរាបលុះត្រាតែអស់ជីវិត ។ សូម្បីគេយកខ្ទីជាដើមដាក់ចុះក្នុងយាគូ គឺបបរ ប្រគេន នឹងយកឈើឯមជាដើមដាក់ចុះក្នុងវត្ថុទាំងឡាយមានប្រេងជាដើម ក៏ដូចជានិ័យនោះ ។ កាលិកណាៗ ដែលមានរសមិនលាយចូលគ្នា កាលិកនោះៗ សូម្បីទទួលប្រគេនជាមួយគ្នា នឹងបរិសុទ្ធដោយប្រការដូចម្តេច លាងឬចិតចោលដោយប្រការដូច្នោះ ហើយបរិភោគតាមកាលកំណត់នៃកាលិកនោះៗក៏គួរ ថាបើមានរសលាយ ច្រឡំចូលគ្នាមិនគួរ ។ ដ្ឋិតថា យាវកាលិករមែងទាញកាលិកទាំង ៣ មានយាមកាលិកជាដើម ដែលមានរសលាយច្រឡំគ្នានឹងខ្លួន ចូលទៅកាន់សភាវៈសេចក្ដីកើតឯងនៃខ្លួន ឲ្យជាយាវកាលិកទៅ ។ សូម្បីយាមកាលិកក៏ទាញកាលិកទាំង ២ មានសត្តាហកាលិកជាដើម ចូលទៅកាន់សភាវៈសេចក្ដីកើតឯងនៃខ្លួន ឲ្យជាយាមកាលិកទៅ សូម្បីសត្តាហកាលិកក៏រមែងទាញយាវជីវិក ដែលច្រឡំនឹងខ្លួន ចូលទៅកាន់សភាវៈសេចក្ដីកើតឯងនៃខ្លួន ឲ្យជាសត្តាហកាលិកទៅ ។ ព្រោះហេតុនោះ យាវជីវិក ដែលភិក្ខុទទួលប្រគេនក្នុងថ្ងៃនោះ ឬទទួលប្រគេនក្នុងថ្ងៃមុន លាយគ្នាដោយ

សត្តាហកាលិក ដែលទទួលប្រគេនក្នុងថ្ងៃនោះ រមែងគួរ ក្នុងរវាង ៧ ថ្ងៃ ។ យាវជីវិកនោះ លាយគ្នាដោយសត្តាហកាលិក ដែលទទួលប្រគេនហើយ ២ ថ្ងៃ រមែងគួរ ក្នុងរវាង ៦ ថ្ងៃ ។ លាយដោយសត្តាហកាលិក ដែលទទួលប្រគេនហើយ ៣ ថ្ងៃ រមែងគួរ តែក្នុងរវាង ៥ ថ្ងៃ ។ លាយគ្នាដោយសត្តាហកាលិក ដែលទទួលប្រគេនហើយ ៧ ថ្ងៃ គប្បីដឹងថាគួរ ក្នុងថ្ងៃ ១ នោះចុះ ។ ព្រោះហេតុនោះ ទើបក្នុងបាលីព្រះអង្គមិនពោលថា យាវជីវិក ទទួលប្រគេនក្នុងថ្ងៃនោះ ជាមួយគ្នានឹងសត្តាហកាលិក នឹងពោលតែត្រឹមថាទទួលប្រគេនជាមួយសត្តាហកាលិក រមែងគួរ ក្នុងរវាង ៧ ថ្ងៃប៉ុណ្ណោះ ថាបើកាលិកនោះ។ កន្ទងកាល និងយាម និង ៧ ថ្ងៃ ទៅ គប្បីដឹងថាត្រូវអាបត្តិដោយវិកាលភោជនសិក្ខាបទ និងសន្និធិការ-សិក្ខាបទនោះចុះ ។ ក៏ឯកាលិកទាំង ៤ នេះ យាវកាលិក យាមកាលិកទាំង ២ នេះ ជាអន្តោវុត្ថបានផង ជាសន្និធិបានផង ។ តែសត្តាហកាលិក និងយាវជីវិក សូម្បីនឹងទុកដាក់ក្នុងអកប្បិយកុដិក៏គួរ មិនឲ្យកើតសន្និធិបានផង ។

កាលិកសំសគ្គកថា ចប់

នឹងពណ៌នាក្នុងអន្តោវុត្ត ។ យាវកាលិក យាមកាលិក ២ នេះ ទុកក្នុងអកប្បិយកុដិឈ្មោះថាអន្តោវុត្ត ។ ដណ្តាំ ស្ង ឲ្យធ្ពិនក្នុងអកប្បិយកុដិនោះ ឈ្មោះថាអន្តោបក្ក: ។ ភិក្ខុដណ្តាំស្ងឲ្យធ្ពិនឯងឈ្មោះថាសាមបក្ក: ។ ទាំង ៣ យ៉ាងនេះ ធាន់ត្រូវទុក្កដ ៣ បើធាន់តែ ២ យ៉ាង ត្រូវទុក្កដ ២ បើធាន់

តែ ១ យ៉ាង ត្រូវទុក្កដ ១ ដ្បិតទ្រង់ហាមឃាត់ទុកថា **ន ភិក្ខវេ អន្ដោ រុត្ដំ អន្ដោ បក្ខំ សាមំ បក្ខំ បរិកុញ្ជិតព្ពំ ។ ល ។ អន្ដោ ចេ ភិក្ខវេ រុត្ដំ អន្ដោ បក្ខំ សាមំ បក្ខំ តញ្ចេ បរិកុញ្ជេយ្យ អាបត្ដិ តិណ្ណ្ហ ឧក្ខ្លាជានំ ។ ល ។ ពហិ ចេ ភិក្ខវេ រុត្ដំ ។ ល ។ អនាបត្ដិ** *ដូច្នេះ ។ ភិក្ខុនឹងដណ្ដាំស្ងួតវអាមិសវត្ថុណាមួយមិនគួរ នឹងដណ្ដាំស្ងួកម្ដៅនូវរបស់ដែលឆ្អិនហើយទើបគួរ ។ បើទាយកគេដាក់ស្ងឹកម្រះព្រៀងឬខ្ទីអំបិលចុះក្នុងបបរក្ដៅ ឲ្យដល់ភិក្ខុសោត សូម្បីភិក្ខុនឹងកូរបបរនោះដើម្បីឲ្យឆ្អិនមិនគួរ តែនឹងកូរដោយគិតថានឹងឲ្យបបរត្រជាក់ក៏គួរ ។ សូម្បីបានបាយជាពងបង្ហួយមកនឹងគ្របទុកឲ្យងំឆ្អិនមិនគួរ ថាបើទាយកគេគ្របប្រគេន និងគ្របដោយគិតថា មិនឲ្យបាយត្រជាក់ក៏គួរ តែទឹកដោះស្រស់និងប្រេងជាដើម កាលពុះលោតឡើងម្ដងហើយ នឹងដុតភ្ជើងក៏គួរ ព្រោះរបស់ឆ្អិនស្រាប់ហើយនឹងឲ្យឆ្អិនទៀតក៏គួរ ។ ដ្បិតព្រះអង្គទ្រង់អនុញ្ញាតថា* **អនុជានামិ ភិក្ខវេ បុនចាកំ បចិតុំ** *ដូច្នេះ ។*

កឋិយភូមិកថា

លំដាប់នេះនឹងបានសម្ដែងក្នុងរឿងកឋិយកុដិ ដែលជាទីធ្វើអាមិសឲ្យរួចចាកអន្ដោវុត្ដ អន្ដោបក្ខ:តទៅ ។ ព្រះអង្គទ្រង់អនុញ្ញាតទុកថា **អនុជានামិ ភិក្ខវេ ចតស្សោ កឋិយភូមិយោ**

ឧស្សាវនន្តិកំ គោនិសាទិកំ គហបតិកំ សម្មតិកំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវកប្បិយភូមិ ៤ យ៉ាង គឺ **ឧស្សាវនន្តិកា** ទីដែលឲ្យបានឮឡើងថា កប្បិយកុដិជាទីបំផុត ១ **គោនិសាទិកា** ទីដែលជាទីអាស្រ័យនៃគោ ១ **គហបតិកា** ទីជារបស់គហបតី ១ **សម្មតិកា** ទីគឺសង្ឆសម្មតិ ១ ។ នឹងពោលក្នុងឧស្សាវនន្តិកានេះជាមុន គប្បីធ្វើដូច្នេះ កុដិណានឹងធ្វើលើសសរទាំងឡាយ ឬនឹងកប់ជើងជញ្ជាំងចុះទៅ សិលាសម្រាប់រងជើងសសរខាងក្រោមនៃកុដិនោះ ជាគតិនៃផ្ទៃនៃធរណីមែនពិត តែកាលនឹងតម្កល់សសរជាដំបូង ឬជើងជញ្ជាំងជាដំបូង ភិក្ខុតាំងអំពី ៣ អង្គ ឬ ៤ អង្គ ឡើងទៅ កាលឈរព័ទ្ធជុំវិញសសរ បញ្ចេញវាចាថា **កប្បិយ-កុដី ភន្តេ** ដូច្នេះ ៣ ដង ឬនឹងថាតែ **កប្បិយកុដីៗ** ប៉ុណ្ណោះក៏បាន កាលមនុស្សទាំងឡាយគេលើកឡើង នឹងឲ្យសសរនិងជើងជញ្ជាំងតម្កល់ចុះ គប្បីពាល់ត្រូវ ឬលើកដោយខ្លួនឯងនូវសសរនិងជើងជញ្ជាំងហើយតម្កល់ចុះ ។ តែក្នុងកុរុន្ទីនិងមហាបច្ចរី ពោលថា ឲ្យភិក្ខុទាំងឡាយគប្បីពោលថា **កប្បិយកុដីៗ** ដូច្នេះ ហើយតម្កល់ចុះ ។ ក្នុងអដ្ឋកថាថា ឲ្យភិក្ខុទាំងឡាយគប្បីពោលថា **សង្ឆ្យ កប្បិយ-កុដី អធិដ្ឋាម** ដូច្នេះ ។ សូម្បីនឹងមិនពោលនូវពាក្យនោះ នឹងពោលតាមន័យដូចសម្តែងហើយ ក្នុងអដ្ឋកថាទាំងឡាយក៏មិនមានទោស តែន័យនេះជាលក្ខណៈទូទៅ ។ ក្នុងអដ្ឋកថាទាំងឡាយនោះ ថាគឺតម្កល់

សសរចុះដល់ផែនដី នឹងចប់ពាក្យដែលពោលព្រមជាមួយគ្នាទើបគួរ ។ ដ្បិតថាកាលបើពាក្យមិនទាន់ចប់ សសរដល់ផែនដីមុន ឬសសរមិនទាន់ដល់ផែនដី ពាក្យពោលចប់មុន ក៏មិនឈ្មោះថាធ្វើកឋិយកុដិ ។ ព្រោះហេតុនោះ ក្នុងមហាបច្ចរី ទើបពោលថា ឲ្យភិក្ខុច្រើនអង្គគប្បីឈរព័ទ្ធជុំវិញពោលចុះ ដ្បិតថាក្នុងភិក្ខុទាំងអម្បាលនោះ ការចប់ពាក្យជាមួយនឹងតម្កល់សសរចុះដល់ផែនដី គង់មានព្រមគ្នា ដោយពាក្យនៃភិក្ខុមួយអង្គដោយពិត ។ តែក្នុងកុដិមានជញ្ជាំងធ្វើដោយឥដ្ឋ ឬសិលា ឬដីក្តី នឹងធ្វើកឡើង ឬមិនកឡើងក្តី ប្រាជ្ញានឹងបណ្តុះជញ្ជាំងឡើងអំពីឥដ្ឋ និងសិលា និងដុំដីណា គប្បីកាន់យកឥដ្ឋ ឬសិលា ឬដុំដីទាំងពួងនោះ ជាដំបូងជាសម្គាល់ហើយ ទើបធ្វើកឋិយកុដិ ដោយន័យដូចពោលមកហើយនោះចុះ ដ្បិតថាឥដ្ឋនិងសិលានិងដុំដី ដែលនៅខាងក្រោមនៃឥដ្ឋនិងសិលានិងដុំដី ដែលកជាជញ្ជាំងដំបូងនោះ នឹងធ្វើឲ្យជាសម្គាល់មិនគួរ ព្រោះថាជារបស់លិចនៅក្នុងដី អំពីសសរដែលតម្កល់ចុះខ្ពស់ឡើងមកលើដី ។ ព្រោះហេតុនោះ នឹងចាប់សសរនោះបញ្ចេញវាចាថា **ឋិយកុដី ឋោម** *ទើបគួរ ។ ក្នុងអន្ធកដ្ឋកថា ពោលថាកុដិកាលនឹងធ្វើដោយសសរទាំងឡាយ គប្បីអធិដ្ឋានសសរទាំង ៤ ដើម ក្នុងមុមទាំង ៤ កាលនឹងធ្វើដោយឥដ្ឋជាដើម គប្បីអធិដ្ឋានឥដ្ឋ ២ ដុំ ឬ ៣ ដុំ ក្នុងមុមទាំង ៤ សូម្បីមិនធ្វើដូច្នោះក៏មិនមានទោស ។ ដ្បិតថាពាក្យដែលពោលក្នុងអដ្ឋកថាទាំងឡាយនោះជាប្រមាណ ។ នឹងពោលក្នុង* **ឋោនិ-**

សាឌិកា *កប្បិយភូមិឈ្មោះថាគោនិសាទិកា មាន ២ យ៉ាង គឺ* **អាវាមគោនិសាតិកា ១ វិហារគោនិសាឌិកា ១** *។ អាវាមក្នុងទីណាដែលគេមិនបានព័ន្ធព័ទ្ធ សេនាសនៈគឺកុដិក៏មិនបានព័ន្ធព័ទ្ធ ដូច្នេះ ឈ្មោះថា អាវាមគោនិសាទិកា ។ ក្នុងទីណាសេនាសនៈទាំងអស់ក្តី មួយតំបន់ក្តី ដែលគេព័ន្ធព័ទ្ធ តែអាវាមគេមិនបានព័ន្ធព័ទ្ធ ដូច្នេះ ឈ្មោះថា វិហារគោនិសាទិកា ។ សេចក្តីថា ទីអាវាមមិនបានព័ន្ធព័ទ្ធ នោះជាប្រមាណក្នុងកប្បិយភូមិឈ្មោះថា គោនិសាទិកាទាំង ២ ។ ក៏ឯអាវាម ដែលគេព័ន្ធព័ទ្ធពាក់កណ្តាល ឬព័ន្ធព័ទ្ធជាច្រើន ឈ្មោះថាព័ន្ធព័ទ្ធ ពាក្យនេះ ពោលទុកក្នុងកុរុន្ទី និងមហាបច្ចរី ព្រោះហេតុនោះ មិនជាកប្បិយភូមិ គួរនឹងបានជាកប្បិយភូមិជាយ៉ាងដទៃ ក្នុងអាវាមដែលឈ្មោះថាព័ន្ធព័ទ្ធនោះ ។ នឹងពោលក្នុងកប្បិយភូមិឈ្មោះថា គហបតិកា មនុស្សទាំងឡាយធ្វើអាវាសហើយពោលថា ខ្ញុំព្រះករុណាថ្វាយកប្បិយកុដិនេះលោកចូរបរិភោគចុះ ដូច្នេះ កប្បិយកុដិនោះឈ្មោះថា គហបតិកា សូម្បីគេពោលថា ខ្ញុំព្រះករុណាថ្វាយ ដើម្បីធ្វើជាកប្បិយកុដិដូច្នេះក៏គួរ ។ តែក្នុងអន្ធកដ្ឋកថាពោលថា ទទួលប្រគេនអំពីដៃនៃសហធម្មិកដ៏សេស រៀរលែងតែកិក្ខុចេញ ឬទទួលប្រគេនអំពីដៃទេវតា មនុស្សទាំងពួងក្តី នឹងសន្ធិ និងអន្ទោរ៉ុត្ត ដែលជារបស់នៃជនអម្ចាលនេះ រមែងគួរដល់កិក្ខុ ព្រោះហេតុនោះ ផ្ទះនៃជនអម្ចាលនោះជាដើម សហធម្មិកដ៏សេសក្តី ឬកប្បិយកុដិដែលជនអម្ចាលនោះថ្វាយក្តី ឈ្មោះថា គហបតិកា

ទាំងអស់ ។ ក្នុងអដ្ឋកថានោះ លោកពោលទៀតថា លើកតែវិហារនៃភិក្ខុ-សង្ឆរចេញ ទីលំនៅនៃនាងភិក្ខុនី និងទីលំនៅនៃមនុស្សរក្សាវត្ត និងទីលំនៅនៃតិរ្ថិយ នៃទេវតា នៃនាគ សូម្បីវិមាននៃព្រហ្ម ក៏ឈ្មោះថាជាកប្ប៊ិយកុដិ ។ ពាក្យក្នុងអន្ធកដ្ឋកថានេះ ឈ្មោះថាលោកពោលដោយប្រពៃ ដ្ឋិតថាកុដិជារបស់សង្ឆ ឬជារបស់ភិក្ខុម្យ៉ាង មិនឈ្មោះថាគហបតិកុដិបាន ។ នឹងពោលក្នុងកប្ប៊ិយភូមិឈ្មោះថាសម្មតិកា កប្ប៊ិយកុដិដែលសង្ឆសូត្រសម្មតិដោយញត្តិទុតិយកម្មវាចា ឈ្មោះថាសម្មតិកា ដើមហេតុព្រះអង្គទ្រង់អនុញ្ញាត កប្ប៊ិយកុដិឈ្មោះថាសម្មតិកានេះ មានព្រះបន្ទូលនឹងព្រះអានន្ទត្ថេរថា ម្នាលអានន្ទ ថាបើដូច្នោះ ចូរសង្ឆសន្ទតវិហារគឺកុដិដែលតាំងនៅក្នុងទីបំផុត ឲ្យជាកប្ប៊ិយភូមិ ហើយឲ្យទាយកយកអាមិសចូលទៅទុកក្នុងកប្ប៊ិយភូមិនោះ សង្ឆនឹងប្រាថ្នាសេនាសនៈណាជាវិហារ ឬអឌ្ឍយោគ ឬប្រាសាទ ឬហម្មិយៈក្តី គប្ប៊ីសន្ទតកប្ប៊ិយភូមិដូច្នេះ ឲ្យភិក្ខុអ្នកឈ្វាសអាចញ៉ាំងសង្ឆឲ្យដឹង ដោយញត្តិទុតិយកម្មវាចាដូច្នេះថា សុណាតុ មេ ភន្តេ សង្ឆោ យទិ សង្ឆស្ស បត្តកល្លំ សង្ឆោ ឥត្ថន្នាមំ វិហារំ កប្ប៊ិយភូមឹ សម្មន្ជេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឆោ ឥត្ថន្នាមំ វិហារំ កប្ប៊ិយភូមឹ សម្មន្ជតិ ។ យស្ស-យស្មតោ ខមតិ ឥត្ថន្នាមស្ស វិហារស្ស កប្ប៊ិយភូមិ-យា សម្មតិ សោ តុណ្ហស្ស យស្ស ន ក្ខមតិ សោ ភា-

សេយ្យ ។ សម្ផតោ សង្ឆេ ឥត្ថន្នាមោ វិហារោ កប្បិយ-ភូមិ ។ ១មតិ សង្ឆ្ស្ស ត្ថ្ម តុណ្ហី ។ ឯវមេតំ ធារយាមិ ។ *បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះសង្ឆស្តាប់ពាក្យខ្ញុំព្រះករុណា បើកម្ម មានកាលសមគួរដល់សង្ឆហើយ សង្ឆគប្បីសន្ថតវិហារឈ្មោះនេះ ឲ្យ ជាកប្បិយភូមិ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឆដ៏ចម្រើន សូមព្រះ សង្ឆស្តាប់ខ្ញុំ សង្ឆសន្ថតវិហារឈ្មោះនេះឲ្យជាកប្បិយភូមិ ។ ការ សន្ថតវិហារឈ្មោះនេះជាកប្បិយភូមិ សមគួរដល់លោកដ៏មានអាយុអង្ត ណា លោកដ៏មានអាយុអង្តនោះ គប្បីស្ងៀមនៅ បើមិនសមគួរដល់ លោកដ៏មានអាយុអង្តណា លោកដ៏មានអាយុអង្តនោះ គប្បីពោល ឡើង ។ សង្ឆបានសន្ថតវិហារឈ្មោះនេះ ឲ្យជាកប្បិយភូមិហើយ ។ ការសន្ថតនេះសមគួរដល់សង្ឆ ហេតុនោះទើបសង្ឆស្ងៀមនៅ ។ ខ្ញុំព្រះ ករុណាសូមចាំទុកនូវសេចក្តីនេះ ដោយអាការសង្ឆស្ងៀមនៅដូច្នេះ ។*

ក្នុងអដ្ឋកថា ថាពាក្យដែលថា **បច្ចន្តិមំ** *វិហារតាំងនៅក្នុងទីបំផុត នោះ គ្រាន់តែថាជាពាក្យពោលទេ ព្រោះព្រះអង្តត្រាស់ថា សង្ឆ នឹងប្រាជ្ញាសេនាសនៈណាដែលជាវិហារ ឬអឌ្ឍយោគជាដើមក្តី ដូច្នេះ សូម្បីនឹងសន្ថតកុដិជិតក៏គួរ ។ នឹងមិនពោលកម្មវាចាសូម្បីនឹងសន្ថតកប្ប-យកុដិនេះ ដោយអបលោកនកម្មក៏គួរ ។ អាមិសណាដែលទុកជាក់ក្នុង កប្បិយភូមិ ទាំង ៤ ដូចពោលមកនេះ អាមិសទាំងអស់នោះ មិនដល់ នូវការរាប់ថាជាអន្តោវុត្ត ។ ព្រះអង្តទ្រង់អនុញ្ញាតកប្បិយភូមិ ៤ នេះ ដើម្បី*

នឹងឲ្យរួចចាកអន្ទោរ្ត អន្ទោបក្ក: ដល់ភិក្ខុនិងភិក្ខុនីទាំងឡាយ តែអាមិសណាដែលជារបស់សង្ឆ ឬរបស់បុគ្គល របស់ភិក្ខុ ឬរបស់ភិក្ខុនី ទុកដាក់ក្នុងផ្ទះ ដ៏ល្មមនឹងឲ្យកើតសហសេយ្យក្នុងកប្បិយភូមិ សូម្បីតាំងទុកអស់រាត្រី១ អាមិសនោះ បានឈ្មោះថាជាអន្ទោរ្ត ដណ្តាំស្ងក្នុងទីដូច្នោះ ក៏ឈ្មោះថាជាអន្ទោបក្ក:ផង អាមិសនោះមិនគួរ ។ តែសត្តាហកាលិក មានសប្បិជាដើម និងយាវជីវិក ទាំង ២ នេះរមែងគួរ គឺថាទុកដាក់ក្នុងទីដូច្នោះបាន មិនជាអន្ទោរ្ត ។

នឹងវិនិច្ឆ័យ ក្នុងសេចក្តីអម្បាលនោះ ដូចសាមណេរនាំយកអាមិសមានអង្ករជាដើមជារបស់ភិក្ខុ ទៅទុកដាក់ក្នុងកប្បិយកុដិ ព្រឹកឡើងដណ្តាំមកប្រគេន អាមិសនោះមិនជាអន្ទោរ្ត ។ យកសត្តាហកា-លិក មានសប្បិជាដើម វត្ថុណាមួយ ដែលទុកដាក់ក្នុងអកប្បិយកុដិ លាយនឹងអាមិសនោះផង ហើយយកមកប្រគេន ឈ្មោះថាមុខ សន្ធិ មិនគួរ ធាន់ត្រូវទុក្កដ ។ តែក្នុងមហាបច្ចរីពោលថា ជាអន្ទោរ្ត ក្នុងពាក្យអម្បាលនោះ ប្ងៃកគ្នាតែត្រឹមឈ្មោះប៉ុណ្ណោះឯង ។ ភិក្ខុយកសប្បិ ដែលជាសត្តាហកាលិក និងស្ងឹកឈើ ដែលជាយាវជីវិក យកទៅទុកដាក់ក្នុងអកប្បិយកុដិ ចម្អិនជាមួយគ្នាទុកបរិភោគ របស់នោះគួរធាន់ប្រាសចាកអាមិស បាន ៧ ថ្ងៃ ។ បើធ្វើសប្បិនិងស្ងឹកឈើនោះឲ្យច្រឡំនឹងអាមិស បរិភោគ ជាអន្ទោរ្តផង ជាសាម-បក្ក:ផង ។ ការលាយឡំគ្នា ដោយកាលិកទាំងពួង គប្បីដឹងដោយឧបាយ

នោះចុះ ។ ក៏ឯកប្ប៊ិយកុដិទាំង ៤ នោះ កាលណានឹងលះវត្ថុ គឺថា កាលណានឹងវិនាសក្ងាយទៅជាអកប្ប៊ិយកុដិ ? នឹងពោលក្នុងឧស្សាវនន្ត-កាជាមុន កប្ប៊ិយកុដិ ឈ្មោះថាឧស្សាវនន្តិកាណា ដែលធ្វើលើសសរ ឬកប់ជើងជញ្ជាំងចុះទៅធ្វើឡើង កប្ប៊ិយកុដិនោះ កាលសសរនិងជើងជញ្ជាំងទាំងអស់ គេដកអូសចេញអស់ ទើបឈ្មោះថាលះវត្ថុ លះទី មិនជាកប្ប៊ិយកុដិ ។ បើមនុស្សទាំងឡាយគេផ្ជួលសសរ និងជើងជញ្ជាំងចេញ សសរនិងជើងជញ្ជាំងណាដែលបិតនៅ ភាពដែលជាកប្ប៊ិយកុដិ ក៏បិតនៅក្នុងសសរនិងជើងជញ្ជាំងនោះ កាលសសរនិងជើងជញ្ជាំងទាំងអស់ គេផ្ជួលឲ្យរលំចេញអស់ កប្ប៊ិយកុដិនោះ ឈ្មោះថាលះវត្ថុ លះទី មិនជាកប្ប៊ិយកុដិ ។ តែកុដិដែលគេកសាងដោយឥដ្ឋនោះ កាលវិនាសទាំងអស់ ដរាបដល់ឥដ្ឋ ឬសិលា ឬដុំដីដំបូង ដែលកសាងឡើងលើឋាន ដើម្បីនឹងធ្វើជាជញ្ជាំងអស់ហើយកាលណា កាលនោះទើបឈ្មោះថាលះវត្ថុ លះទី គឺមិនជាកប្ប៊ិយកុដិ ។ តែឥដ្ឋនិងសិលា និងដុំដីជាបឋម ដែលអធិដ្ឋានទុកនោះ សូម្បីគេរើយកទៅអស់ ឥដ្ឋជាដើមដែលគេកសាងជញ្ជាំងដទៃមាននៅសល់ ភាពជាកប្ប៊ិយកុដិនោះ ក៏គង់បិតនៅក្នុងឥដ្ឋសិលា ឬដុំដីដទៃដែលសល់នៅនោះ មិនទាន់ឈ្មោះថាលះទីនៅឡើយ ។ កប្ប៊ិយកុដិឈ្មោះថា គោនិសាទិកា នោះ កាលបើគេព័ន្ធព័ទ្ធដោយកំពែងជាដើមហើយ ក៏ឈ្មោះថាលះវត្ថុ ត្រឡប់ទៅជាអកប្ប៊ិយកុដិវិញ គួរនឹងបានកប្ប៊ិយកុដិដទៃ ក្នុងអារាមនោះថ្មីទៀត ។ បើកំពែងវត្ថុជាដើម

បាក់ដាច់ក្នុងទីនោះៗ គោទាំងឡាយចូលបានអំពីទីនោះៗ ក៏ត្រឡប់ជាកប្ប៊ិយកុដិវិញទៀត ។ ចំណែកកប្ប៊ិយកុដិទាំងពីរក្រៅនោះ គឺគហ-បតិកា និងសម្មតិកា កាលដំបូលទាំងអស់វិនាសរបើកអស់ទៅហើយ នៅសល់តែបង្គន់ ទើបឈ្មោះថាលះវត្ថុ បើបក្ខបាសកមណ្ឌល សូម្បីតែមួយខាងលើ នៃបង្គន់ទាំងឡាយសល់នៅ ក៏នៅរក្សាបាននៅឡើយ មិនទាន់លះវត្ថុ គ្រឿងប្រក់មានស្មៅនិងស្លឹកឈើជាដើម ដែលតាំងនៅខាងលើនៃបង្គន់ទាំងឡាយ ៣ កណ្ដាបម្ខាងៗ នោះ ឈ្មោះថាបក្ខបាសក-មណ្ឌល ។

បុច្ឆាសួរថា កប្ប៊ិយភូមិទាំង ៤ នេះ មិនមានក្នុងទីណា ក្នុងទីនោះ ភិក្ខុនឹងគប្ប៊ីបដិបត្តិធ្វើដូចម្ដេច?

វិសជ្ជនាថា ភិក្ខុគប្ប៊ីឲ្យអាមិសដល់អនុបសម្ផ្ន ធ្វើអាមិសនោះ ឲ្យជារបស់អនុបសម្ផ្ន ឲ្យដាច់អាល័យហើយ គប្ប៊ីបរិភោគចុះ ។

កប្ប៊ិយភូមិកថា ចប់

ខុទ្ទកកថា

ពោលអំពីខុទ្ទកកថារបស់ធាន់បន្ដិចបន្ដួច ដែលព្រះអង្គទ្រង់អនុ-ញ្ញាតទុកក្នុងកេសជ្ជខន្ធ ដែលគួរនឹងគប្ប៊ីដឹង ។ រឿងមួយ ភិក្ខុកើតពោគ ខ្យល់ ព្រះអង្គទ្រង់អនុញ្ញាតឲ្យស្ងប្រេង ។

រឿងមួយ ប្រេងនោះ នឹងត្រូវលាយដោយគ្រឿងស្រវឹងមានសុវាជាដើម ព្រោះព្រះអង្គទ្រង់អនុញ្ញាត ឲ្យលាយក្នុងប្រេងដែលស្ងនោះបាន ។

រឿងមួយ ទ្រង់ឃាត់ថា ប្រេងលាយរបស់ស្រវឹងច្រើនពេក កុំគប្បីក្រេបផឹក បើភិក្ខុណាក្រេបផឹក ឲ្យវិន័យធរគប្បីកាត់អាបត្តិភិក្ខុនោះតាមធម៌[1] ហើយទ្រង់អនុញ្ញាតថា ក្នុងប្រេងដែលស្ងណា ពណ៌នឹងរសក្ងិននៃគ្រឿងស្រវឹងមិនប្រាកដ ឲ្យក្រេបផឹកប្រេងដែលលាយរបស់ស្រ-វឹងដូច្នោះបាន ។

រឿងមួយ ទ្រង់អនុញ្ញាតឲ្យភិក្ខុដែលពស់ចឹក ធាន់ថ្នាំមហាវិកដ ៤ គឺលាមក ១ មូត្រ ១ ផេះ ១ ដី ១ ដូចពោលហើយ ។

រឿងមួយ ទ្រង់អនុញ្ញាត ឲ្យភិក្ខុដែលផឹកថ្នាំពិសចូលទៅហើយ ឲ្យក្រេបផឹកលាមក និងទ្រង់អនុញ្ញាតថា កាលរបស់ណាជាប់នៅនឹងកាយ មិនទាន់របូតចាកកាយ របស់នោះឈ្មោះថាទទួលប្រគេនហើយ មិនបាច់ទទួលប្រគេនទៀតទេ បើលាមកនោះធ្លាក់ដល់ផែនដីហើយ ឲ្យគប្បីទទួលប្រគេនជាថ្មី បើមិនទាន់ដល់ដីនឹងកាន់យកខ្លួនឯងក៏គួរ ។

រឿងមួយ ទ្រង់អនុញ្ញាត ឲ្យភិក្ខុដែលមានអាពាធព្រោះត្រូវថ្នាំស្នេហ៍ ឲ្យកាន់យកដីដែលជាប់ក្នុងផ្ទាលក្ជរស្រែមកលាយនឹងទឹកក្រេបផឹក ។

រឿងមួយ ទ្រង់អនុញ្ញាត ឲ្យភិក្ខុដែលក្ងើងធាតុបក់តិច ឧច្ចារៈចេញដោយលំបាក ក្រេបផឹកទឹកក្ជុងអាមិស ទឹកក្ជុងនោះដែលគេយកបាយដុតនឹងក្ងើងឲ្យឆេះជាផេះហើយច្រោះត្រង ឈ្មោះថាទឹកក្ជុងអាមិស ។

១- ត្រូវភិក្ខុនោះសម្តែងអាបត្តិបាចិត្តិយ ។

រឿងមួយ ទ្រង់អនុញ្ញាត ឲ្យភិក្ខុដែលមានរោគស្គមលឿង ក្រេបផឹកទឹកផ្សំត្រាំដោយមូត្រគោ ។

រឿងមួយ ទ្រង់អនុញ្ញាតឲ្យភិក្ខុ ដែលមានអាពាធគឺខ្ទួចសម្បុរ ឲ្យធ្វើការលាប ដោយគ្រឿងក្រអូបបាន ។

រឿងមួយ ទ្រង់អនុញ្ញាត ឲ្យភិក្ខុដែលមានកាយប្រកបដោយរោគទល់ (លាមក) ក្រេមផឹកថ្នាំបញ្ចុះបាន ។

រឿងមួយ ភិក្ខុត្រូវការដោយ **អច្ឆកញ្ជិក** គឺទឹកលាងអង្ករដែលថ្ម ព្រះអង្គក៏ទ្រង់អនុញ្ញាត ។

រឿងមួយ ភិក្ខុត្រូវការដោយ **អកាដយូសក** ទឹកសណ្ដែកបាយស្ងោរ ដែលគេមិនបានធ្វើឲ្យស្ងិទ្ធ (គឺគេមិនបានត្រងឲ្យស្អាត) ព្រះអង្គទ្រង់អនុញ្ញាតឲ្យធាន់បាន ។

រឿងមួយ ភិក្ខុត្រូវការដោយ **ពជាពជ** ទឹកសណ្ដែកបាយស្ងោរ ដែលគេធ្វើឲ្យស្ងិទ្ធ (គឺគេបានត្រងឲ្យស្អាត) ព្រះអង្គទ្រង់អនុ-ញ្ញាតឲ្យធាន់បាន ។

រឿងមួយ ភិក្ខុមានសេចក្ដីត្រូវការដោយ **បដិច្ឆាទនីយ** គឺទឹកសាច់ដែលគេចម្រាញ់ឬគៀប ព្រះអង្គទ្រង់អនុញ្ញាត ។

រឿងមួយ ព្រះអង្គត្រាស់ថា បើគេលាយម្សៅនឹងផេះក្នុងទឹកអំពៅដើម្បីឲ្យជាប់ ដើម្បីឲ្យស្ងិតរឹង ទឹកអំពៅនោះក៏រាប់ថា ជាទឹកអំពៅសុទ្ធ តថាគតអនុញ្ញាតឲ្យបរិភោគទឹកអំពៅដូច្នោះ តាមសប្បាយ ។

រឿងមួយ ព្រះអង្គត្រាស់ថា បើសណ្តែកឆ្អិនហើយត្រឡប់ដុះបានទៀត តថាគតអនុញ្ញាតឲ្យបរិភោគសណ្តែកនោះតាមសប្បាយ ។

រឿងមួយ ព្រះអង្គទ្រង់អនុញ្ញាត ឲ្យភិក្ខុមានជំងឺដោយរោគខ្យល់ក្នុងពោះ បរិភោគថ្នាំ **លោណសោចិរក** មិនមានជំងឺឲ្យលាយទឹកបរិភោគដូច **ចាន** ទឹកគួរផឹក ។

រឿងមួយ ទ្រង់អនុញ្ញាតស្ករអំពៅដុំដល់ភិក្ខុឈឺ មិនឈឺឲ្យលាយដោយទឹកហើយបរិភោគ ។

របស់ធាន់ដែលព្រះអង្គទ្រង់អនុញ្ញាតដូចពោលមកនេះ ក្នុងបាលីមិនកំណត់ថា ឲ្យធាន់ក្នុងកាល ឬក្នុងវិកាល តែក្នុងអដ្ឋកថាខ្ញុះ កំណត់របស់ឲ្យធាន់ក្នុងវិកាលបាន ដូចថ្នាំ **មហាវិកដ** តែទឹកលាងអង្ករថ្ងៃនិងទឹកសាច់ ទឹកសណ្តែកស្ងោរនោះ ក្នុងអដ្ឋកថាក៏មិនកំណត់កាល តែទឹកលាងអង្ករថ្ងៃនោះ ជាយាវជីវិក ឬយាវកាលិក ក៏មិនប្រាកដ ក៏ប៉ុន្តែឃើញថាគួរកាន់ទុកក្នុងចំណែកយាវកាលិកចុះ ទើបនឹងអស់សង្ស័យ តែទឹកសាច់ ទឹកសណ្តែកស្ងោរ នេះជាយាវកាលិកមែន តែទឹកអំពៅដែលលាយម្សៅនោះ ជាសត្តាហកាលិក របស់ក្រៅនោះ ជាយាវជីវិក អ្នកមានប្រាជ្ញាគប្បីពិចារណាយកចុះ ។

រឿងមួយថា សម័យនោះ ក្នុងនគរសាវត្ថី មានរបស់ទំពាស៊ីគឺផ្លែឈើកើតឡើងច្រើន តែកប្បិយការក: មនុស្សអ្នកធ្វើឲ្យជាកប្បិយគ្មាន ភិក្ខុទាំងឡាយរង្គៀស មិនហ៊ានធាន់ផ្លែឈើ ទើបទូល

សេចក្ដីនោះដល់ព្រះពុទ្ធអង្គ ព្រះអង្គទ្រង់អនុញ្ញាតថា **អនុជានামិ ភិក្ខវេ អពីជំ ឌិព្ពជ្ជពីជំ អកតកប្បំ ផលំ បរិភុញ្ជិតុំ** *ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យធាន់ផ្ទៃឈើដែលមិនមានពីជ: (គឺនៅខ្ចីមិនពន្ធក) និងផ្ទៃដែលគប្បីបន្ទេចយកពូជចេញបាន (ដូចខ្ទុ-ជាដើម) សូម្បីមិនបានធ្វើឲ្យជាកប្បិយក៏គួរ (ធាន់បាន) ។ ដែលពោលថា ភិក្ខុទាំងឡាយរង្គៀសមិនហ៊ានធាន់នោះ ប្រហែលជារង្គៀសថាជាកូត-គាម និងពីជគាមសមារម្ភ: គឺធ្វើកូតគាម និងពីជគាមឲ្យកម្រើក ក្នុងខុទ្ទក-ខន្ធកថា ថាព្រះអង្គទ្រង់ប្រារព្ធនឹងធព្ធគ្ដិយភិក្ខុ ដែលធាន់ផ្ទៃស្វាយក្នុងឧទ្យានស្ដេចដែលព្រះបាទពិម្ពិសារទ្រង់អនុញ្ញាត ទាល់តែអស់តាំងអំពីនៅខ្ចីនៅឡើយ ហើយទ្រង់បញ្ញត្ដឃាត់ថា កុំគប្បីធាន់ផ្ទៃស្វាយ បើធាន់ត្រូវទុក្កដ ។ សម័យនោះទាយកមួយពួក ថ្វាយសង្ឆកត្ត យកចំណិតស្វាយលាយក្នុងសូប: គឺសម្ងមកផង ភិក្ខុទាំងឡាយរង្គៀសមិនហ៊ានទទួល ព្រះអង្គត្រាស់ថា ទទួលចុះ ធាន់ចុះ ហើយទ្រង់អនុញ្ញាតថា* **អនុជានামិ ភិក្ខវេ អម្ពបេសិកំ** *ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចំណិតស្វាយ ។ សម័យនោះទាយកមួយពួកថ្វាយសង្ឆកត្តដល់សង្ឆម្ដងទៀត ទាយកទាំងឡាយនោះ មិនទាន់ធ្វើស្វាយនោះឲ្យជាចំណិត ទើបអង្គាសផ្ទៃស្វាយទាំងមូលក្នុងរោងធាន់ ភិក្ខុទាំងឡាយរង្គៀសមិនហ៊ានទទួល ព្រះអង្គត្រាស់ថា ទទួលចុះ ធាន់ចុះ ហើយទ្រង់អនុញ្ញាតថា* **អនុជានামិ ភិក្ខវេ បញ្ចហិ សម-**

ណាកប្បេហិ ផលំ បរិភុញ្ជិតុំ អក្ដិបរិចិតំ សត្ថបរិចិតំ ឆទបរិចិតំ អពីជំ និព្ពីជ្ជតីជមេវ បញ្ចមំ

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យបរិភោគផ្លែឈើដោយ សមណកប្ប: កម្មដែលគួរដល់សមណ: ៥ ប្រការ គឺផ្លែដុតដោយភ្លើង ១ ផ្លែចាក់ដោយគ្រឿងសស្ត្រា ១ ផ្លែចុចដោយក្រចក ១ ផ្លែមិនមានពីជ: ១ និងផ្លែមានពីជ:ដែលគប្បីបន្ទេចចេញបាន ១ ត្រូវជា ៥ ប្រការ ។

ក្នុងអដ្ឋកថានៃភូតគាមសិក្ខាបទ លើកយកបាលីនេះទៅពោលថា ពីជ:មានឫសឈើជាដើម ដែលកើតនៅក្នុងទីឈ្មោះថាភូតគាម ជាវត្ថុនៃបាចិត្តិយ ។ ពីជ:នោះ កាលធ្វើឲ្យឃ្លាតចាកទីហើយ ឈ្មោះថា ពីជគាម ជាវត្ថុនៃទុក្កដ ។ ពីជគាមនោះ កាលបរិភោគ គប្បីបង្គាប់អនុ-បសម្បន្នថា **ការ្យំ ការោហិ** *អ្នកចូរធ្វើឲ្យជារបស់គួរ ដូច្នេះសិន ហើយសឹមបរិភោគ កាលធ្វើដូច្នេះឈ្មោះថារួចចាកពីជគាម ។*

ឯនឹងធ្វើកប្ប្យិយនោះ គប្បីធ្វើដោយភ្លើង សស្ត្រា ឬក្រចក ។ កាលនឹងធ្វើកប្ប្យិយដោយភ្លើង គប្បីយកភ្លើងណាមួយ អុចចុះក្នុងប្រទេសនៃពីជ:នោះ ហើយពោលថា **ការ្យំ** *ដូច្នេះហើយធ្វើចុះ ។ កាលនឹងធ្វើដោយសស្ត្រា គប្បីសម្ដែងនូវអាការ:ចាក់ឬកាត់ដោយដែកស្លួច ឬមុខនៃសស្ត្រាដែលមុត ណាមួយ ដោយហោចទៅ សូម្បីម្ជុលនិងកាំបិតកាត់ក្រចកជាដើម ដូចធ្វើដោយភ្លើងនោះចុះ ។ កាលធ្វើកប្ប្យិយដោយក្រចក គប្បីយកក្រចកនៃមនុស្ស ឬក្រចកនៃសត្វតិរច្ឆានណាមួយ ដែលមិនពុក*

រៀរតែក្រចកគោនិងក្រចកក្របីជាដើមចេញ ក្រចកក្រៅនោះដោយ ហោចទៅ កាត់យកមកក៏បាន គប្បីធ្វើដោយន័យដូចពោលហើយក្នុង សន្ត្រានោះចុះ ។ ម្ទេសស្រស់គេដាក់ក្នុងបបរមកមិនជាប់ជិតគ្នា គប្បី ចាក់គ្រប់ៗ គ្រាប់ធ្វើកប្បិយ ។ ផ្ទៃខ្ចីតជាដើម បើពីជ:ខាងក្នុងរន្ធោះ ចាកលលាដ៍រលុងនៅ គប្បីឲ្យគេបំបែកចេញធ្វើកប្បិយ បើនៅជាប់គ្នាពិត សូម្បីនឹងធ្វើកប្បិយក្នុងលលាដ៍ក៏គួរ ។ ឯផ្ទៃណាជារបស់ខ្ចី មិនមានពីជ: និងផ្ទៃណាដែលមានពីជ:បន្ទេចចេញបរិភោគបានកិច្ចដែលនឹងធ្វើកប្បិយ ក្នុងផ្ទៃនោះមិនមាន ដ្បិតទ្រង់អនុញ្ញាតទុក តែប៉ុណ្ណោះ គប្បីដឹងចុះថា ផ្ទៃស្វាយនិងផ្ទៃឈើដទៃ និងពីជគាមទាំងពួង ខ្ចីឬចាស់ ណាៗ ជារបស់ គួរតាមកាលនៃខ្ជួនៗ ។

ខុទ្ទកកថា ចប់

មហាបទេស

មហាបទេស ១ជាគ្រឿងអាងដ៏ធំមាន ៤ ប្រការ ។ មានវារ:ព្រះ ***បាលីថា យំ ភិក្ខវេ មយា ឥទំ ន កប្បតីតិ អប្ជ៊ិ-ក្ខ៊ិត្តំ តញ្ចេ អកប្ជ៊ិយំ អនុលោមេតិ កប្ជ៊ិយំ ២ជ៊ិ-ញ្ចាតិ តំ ១ ន កប្ជ៊ិតិ ។ ២ ។ យំ ភិក្ខវេ មយា ឥទំ កប្ជ៊ីតិ អ១ជ្ជ៊ាតំ តញ្ចេ កប្ជ៊ិយំ អនុលោមេតិ***

អកប្ប្យិយំ បដិ១ាហាតិ តំ ០ៅ ០ាកប្ប្យតីតិ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានហាមទុកថា របស់នេះមិនគួរទេ បើ របស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះមិនគួរ ដល់អ្នកទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគត មិនបានហាមទុកថា របស់នេះមិនគួរ បើរបស់នោះអនុលោមចូលរបស់គួរ ឃាត់របស់មិនគួរ របស់នោះគួរដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានអនុញ្ញាតទុកថា របស់នេះគួរ បើរបស់ នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះមិនគួរដល់ អ្នកទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិន បានអនុញ្ញាតទុកថា របស់នេះគួរ បើរបស់នោះអនុលោមចូលរបស់គួរ ឃាត់របស់មិនគួរ របស់នោះគួរដល់អ្នកទាំងឡាយ ។

ក្នុងមហាបទេស ៤ ប្រការនេះ ពីរប្រការខាងដើម ពោលដោយ បញ្ញត្តិ ពីរប្រការខាងចុងពោលដោយអនុញ្ញាត ។

ក្នុងអដ្ឋកថា ថាព្រះអង្គទ្រង់សម្តែងមហាបទេស ៤ នេះ ដើម្បី នឹងឲ្យភិក្ខុទាំងឡាយកាន់យកន័យ គឺឲ្យជាតួយ៉ាង ។

ព្រះធម្មសង្គាហកត្ថេរទាំងឡាយ លោកកាន់យកសូត្រគឺបាលី ដែលទ្រង់បញ្ញត្តនិងអនុញ្ញាតក្នុងទីនោះៗ មករួបរួមបញ្ចូលក្នុងមហា-បទេស ៤ នេះ ឲ្យឃើញសេចក្តីដូច្នេះថា បាលីដែលទ្រង់អនុញ្ញាតរស នៃផ្លែឈើទាំងពួងជា **ចានៈ** ឃាត់តែរសនៃផ្លែស្រូវថា **ឋបេត្វា**

ឩញ្ញផលសំ ដូច្នេះ ដ្ឋិតពាក្យនេះឈ្មោះថាឃាត់ស្រូវ ៧ ប្រការ ថាមិនគួរក្នុងបច្ចាកត្ត និងមហាផល ៥ ទៀត គឺផ្ទៃត្នោត ផ្ទៃដូង ផ្ទៃខ្ទុ ផ្ទៃសាកេរ ផ្ទៃឃ្លាក ផ្ទៃត្រឡាច ផ្ទៃត្រសក់ ផ្ទៃឪឡឹក ផ្ទៃល្ពៅក្តី និងអបរណ្ណជាតិទាំងពួង មានសណ្ដែកលូជាដើមក្តី ជាគតិនៃស្រូវមែនពិតរបស់អម្បាលនោះ សូម្បីព្រះអង្គមិនបានឃាត់ក៏ពិតមែន តែរមែងអនុលោមតាមរបស់ដែលជាអកប្បិយ គឺស្រូវ ៧ ប្រការ ព្រោះហេតុនោះ មហាផលនិងអបរណ្ណជាតិទាំងពួង រមែងមិនគួរក្នុងបច្ចាកត្ត ។ ព្រះអង្គទ្រង់អនុញ្ញាត អដ្ឋបាន ៨ ជាទឹកគួរក្រេបផឹក ហើយនិងទឹកធ្វើដោយផ្ទៃឈើតូចៗ ក្រៅពីនោះ មានផ្ទៃផ្ដៅ ផ្ទៃអម្ពិល ផ្ទៃក្រូចភ្ញា ផ្ទៃខ្ចិត ផ្ទៃពង្រ ផ្ទៃសង្ឃ្ស៍ជាដើម អម្បាលនេះក៏ជាគតិនៃអដ្ឋបាន ៨ ដោយពិត ។ ទឹកផឹកធ្វើដោយផ្ទៃឈើតូចៗ អម្បាលនោះ សូម្បីព្រះអង្គមិនបានទ្រង់អនុញ្ញាតក៏ពិតមែន តែរមែងអនុលោមតាមវត្ថុដែលជាកប្បិយ គឺអដ្ឋបាន ៨ ប្រការ ព្រោះហេតុនោះ ទឹកផឹកធ្វើដោយផ្ទៃឈើតូចៗ នោះរមែងគួរលើកតែរសនៃផ្ទៃស្រូវ មួយអន្ទើដោយវត្ថុដែលជាអនុលោមតាមធញ្ញជាតិចេញ ទឹកផឹកធ្វើដោយផ្ទៃឈើដទៃ ឈ្មោះថាមិនគួរនោះមិនមាន ជាយាម-កាលិកបានប្រាកដ ពាក្យនេះពោលទុកក្នុងកុរុន្ទី ។

ឯព្រះអង្គទ្រង់អនុញ្ញាតចីវរ ៦ គឺសំពត់ខោម: ១ កប្បាសិក: ១ កោសេយ្យ: ១ កម្ពល:១ សាណ: ១ ភង្គ: ១ ទុកដូច្នេះ ។

ព្រះធម្មសង្គាហកត្ថេរទាំងឡាយ លោកអនុញ្ញាតសំពត់ដទៃ ៦ យ៉ាង គឺសំពត់ ទុកូល: ១ សំពត់ បគុណ្ណ: ១ សំពត់ ចីនបដ: ១ សំពត់ សោមារបដ: ១ សំពត់ ឥទ្ធិមយិក: ១ សំពត់ ទេវទត្តិយ: ១ អម្បាលនេះ ឲ្យជាអនុលោមដល់ចីវរ ៦ យ៉ាងខាងដើមនោះ ។ សំពត់ដែលកើតដោយសត្វទាំងឡាយ ក្នុងបគុណ្ណប្រទេស ឈ្មោះថាបគុណ្ណ: ។ ឯសំពត់ចីនបដ: សោមារបដ: ២ នេះ ហៅតាមឈ្មោះនៃប្រទេស ។ សំពត់ ៣ យ៉ាងមុននោះ ជាអនុលោមតាមសំពត់កោសេយ្យ: ។ សំពត់ទុកូល: ជាអនុលោមតាមសំពត់សាណ: ។ សំពត់ ២ ក្រៅនោះ អនុ-លោមតាមសំពត់កប្ប៉ាសិក: ឬអនុលោមតាម សំពត់ទាំងពួងក៏បាន ។

ព្រះអង្គទ្រង់ហាមឃាត់បាត្រ ១១ យ៉ាង មានបាត្រឈើជាដើម ទ្រង់អនុញ្ញាតបាត្រ ២ យ៉ាងគឺបាត្រដែក ១ បាត្រដី ១ ។ ចំណែកថាលក: គឺភាជន:គ្រឿងប្រើប្រាស់ដែលធ្វើដោយលោហ: ឬធ្វើដោយដី ធ្វើដោយទង់ដែង ៣ នេះ អនុលោមតាមបាត្រ ២ យ៉ាងនោះប្រាកដ ។

ព្រះអង្គទ្រង់អនុញ្ញាតតុម្ព: គឺភាជន:សម្រាប់រាល់ ៣ យ៉ាង គឺធ្វើដោយលោហ: ធ្វើដោយឈើ ធ្វើដោយផ្ទៃឈើដូច្នេះ ។

ចំណែកកុណ្ឌីទឹក និងផ្ដិលស្ពាន់ និងក្ងមទឹក អនុលោមតាមតុម្ព: ៣ នោះ ដោយពិត តែក្នុងកុរុន្ទី ពោលថាស័ង្ខ សម្រាប់ដាក់ទឹកផឹក និងផ្ដិលទឹក អនុលោមតាមតុម្ព: ៣ នេះ ។

ព្រះអង្គទ្រង់អនុញ្ញាតវត្តពន្ធចង្កេះ ២ ប្រការ គឺវត្តពន្ធដែលត្បាញជាផែន និងវត្តពន្ធដែលត្បាញដូចពោះរៀនជ្រូកទុកដូច្នេះ ។ ចំណែកវត្តពន្ធធ្វើដោយផែនសំពត់ និងធ្វើដោយខ្សែ អនុលោមតាមវត្តពន្ធ ២ ប្រការនោះ ។

ព្រះអង្គទ្រង់អនុញ្ញាតឆត្រ ៣ ប្រការ គឺឆត្រពាសសំពត់ស និងឆត្រត្បាញដោយបន្ទោះឫស្សី និងឆត្រធ្វើដោយស្លឹកឈើទុកដូច្នេះ ។

ឆត្រស្លឹកឈើមួយជំពូក ដូចស្លឹកត្នោត ស្លឹករឹត អនុលោមតាមឆត្រ ៣ ប្រការនោះពិត សូម្បីរបស់ដទៃដែលអនុលោមតាមវត្ថុដែលជាកប្ប្ៃយនិងអកប្ប្ៃយ វិនិយធរគប្បីពិចារណាមើលតាមបាលីនិងអដ្ឋកថាឲ្យដឹងច្បាស់ ដោយន័យដូចពោលមកនោះចុះ ។

មហាបទេស ៤ ចប់

<u>កាលិកបព្ធ:គម្រប់</u> ៤ ចប់

ពិន្ធាធិដ្ឋានាទិបព្ធ:គម្រប់ ៤

វិធីអធិដ្ឋានានិងបច្ចុទ្ធារសំពត់

ពោលអំពីសំពត់គួរអធិដ្ឋានជាមុន ។ សំពត់គួរអធិដ្ឋានមាន ៧ យ៉ាងគឺ **តិចីវរំ** *ចីវរទាំងបី ១* **វស្សិកសាដិកា** *សំពត់ងូតទឹកភ្លៀង ១* **និសីទនំ** *សំពត់ទ្រាប់អង្គុយ ១* **បច្ចត្ថរណំ** *កម្រាល ១* **កណ្ឌុប្បដិច្ឆាទិ** *សំពត់បិទបូស ១* **មុខបុញ្ឆនចោលំ** *សំពត់ជូតមុខ ១* **បរិក្ខារ-**

ចោលំ *សំពត់បរិក្ខារសម្រាប់ប្រើបន្ទិចបន្ទួច មានតម្រង់ទឹកនិងថង់យាម ថង់ចាត្រជាដើម ១ សំពត់អម្បាលនេះត្រូវអធិដ្ឋានតាមឈ្មោះ ដ្បិតទ្រង់អនុញ្ញាតថា* អនុជានាមិ ភិក្ខវេ តិចីវរំ អធិដ្ឋាតុំ ន វិកប្បេតុំ វស្សិកសាដិកំ វស្សានំ ចាតុម្មាសំ អធិដ្ឋាតុំ តតោ បរំ វិកប្បេតុំ និសីទនំ អធិដ្ឋាតុំ ន វិកប្បេតុំ បច្ចត្ថរណំ អធិដ្ឋាតុំ ន វិកប្បេតុំ កណ្ឌុបដិច្ឆាទឺ យាវ អាពាធា អធិដ្ឋាតុំ តតោ បរំ វិកប្បេតុំ មុខបុញ្ឆនចោលំ អធិដ្ឋាតុំ ន វិកប្បេតុំ បរិក្ខារចោលំ អធិដ្ឋាតុំ ន វិកប្បេតុំ ។ *ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុអធិដ្ឋានត្រៃចីវរ មិនឲ្យវិកប្បទេ ឲ្យអធិដ្ឋានសំពត់ សម្រាប់ផ្ងួតទឹកភ្លៀង អស់ ៤ ខែនៃរដូវភ្លៀង ខាងមុខអំពី ៤ ខែនោះទៅ ត្រូវវិកប្បទុក ឲ្យអធិដ្ឋានសំពត់សម្រាប់ទ្រាប់អង្គុយ មិនឲ្យវិកប្បទេ ឲ្យអធិដ្ឋានសំពត់កម្រាល មិនឲ្យវិកប្បទេ ឲ្យអធិដ្ឋានសំពត់សម្រាប់គ្របកម ដរាបអំពីមានអាពាធ ខាងមុខអំពីអាពាធជាហើយ ត្រូវវិកប្បទុក ឲ្យអធិដ្ឋានសំពត់ សម្រាប់ជូតមុខ មិនឲ្យវិកប្បទេ ឲ្យអធិដ្ឋានសំពត់ បរិក្ខារចោល មិនឲ្យវិកប្បទេ ។*

ត្រៃចីវរនោះ គឺសង្ឆាដិ សំពត់សម្រាប់តម្រួតដណ្តប់ ឧត្តរាសង្គ: សំពត់ដណ្តប់ អន្តរវាសក: សំពត់ស្មៀក សំពត់ទាំង ៣ នេះត្រូវកាត់ដេរ

ធ្វើឲ្យត្រូវតាមលក្ខណៈ ឲ្យបានប្រមាណហើយជ្រលក់ឲ្យបានពណ៌ ធ្វើកប្បពិន្ទុ ហើយទើបអធិដ្ឋាន បើមិនកាត់មិនគួរ ។ ដ្បិតទ្រង់ហាមឃាត់ថា **ន ភិក្ខវេ អច្ឆិន្នកានិ ចីវរានិ ធារេតព្វានិ** ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំគប្បីប្រើប្រាស់ ចីវរមិនបានកាត់ បើភិក្ខុណាប្រើប្រាស់ ចីវរមិនបានកាត់ ត្រូវអាបត្តិទុក្កដ ។

កាលធ្វើឲ្យត្រូវលក្ខណៈ គប្បីធ្វើដូចព្រះអង្គត្រាស់ចំពោះនឹងព្រះអានន្ទថា **បណ្ហិតោ ភិក្ខវេ អានន្ទោ ។ ល ។ កុសិម្បិ ជាម ការិស្សតិ អឌ្ឍកុសិម្បិ ជាម ការិស្សតិ ។ ល ។ ធិន្នកំ អន្តរវាសកំ** ម្នាលភិក្ខុទាំងឡាយ អានន្ទជាអ្នកមានបញ្ញាច្រើន ព្រោះពាក្យដែលតថាគតពោលហើយដោយសង្ខេប អានន្ទអាចដឹងសេចក្តីដោយពិស្តារបាន ហើយចេះធ្វើសំពត់កុសិ ទាំងអឌ្ឍកុសិផង ធ្វើសំពត់មណ្ឌលទាំងអឌ្ឍមណ្ឌលផង ធ្វើសំពត់រ៉ាវដ្ត:ទាំងអនុរ៉ាវដ្ត:ផង ធ្វើសំពត់គីវេយ្យក: ទាំងជង្ឃេយ្យក:ផង ធ្វើសំពត់ពាហន្ត:ផង ជាសំពត់កាត់ដាច់ ឲ្យសៅហ្មងដោយមុខកាំបិត ជាសមណសារុប្ប ឲ្យជាសំពត់ដែលមនុស្សជាសត្រូវ គឺចោរមិនប្រាថ្នាចង់បាន តថាគតអនុញ្ញាតសង្ឃាដិកាត់ ឧត្តរាសង្ត:កាត់ អន្តរវាសក:កាត់ ដូច្នេះ ។

នឹងពោលតាមអដ្ឋកថាជាមុន **កុសិ** *នោះជាឈ្មោះនៃផ្ទាំងសំពត់ដែលវែងមានអនុវាតជាដើម ដោយដានបណ្តោយនិងទទឹង ។* **អឌ្ឍកុសិ** *នោះ ជាឈ្មោះនៃផ្ទាំងសំពត់ខ្វីដែលមាន ក្នុងចន្លោះ ។ ។*

មណ្ឌលធំ ក្នុងខណ្ឌមួយៗ នៃចីវរប្រកបដោយខណ្ឌ ៥ នេះឈ្មោះថា មណ្ឌល ។ មណ្ឌលតូច ក្នុងខណ្ឌមួយៗ នៃចីវរដូច្នោះ ឈ្មោះថាអឌ្ឍ-មណ្ឌល ។ ខណ្ឌគឺផ្ទាំងកណ្តាលដែលដេរមណ្ឌលនិងអឌ្ឍមណ្ឌល ភ្ជាប់ជាមួយគ្នាឈ្មោះថាវិវដ្ដ: ។ ខណ្ឌគឺផ្ទាំងទាំង ២ អមសងខាងនៃវិវដ្ដ:នោះ ឈ្មោះថាអនុវិវដ្ដ: ។ អាគន្ទុកបដ: គឺផ្ទាំងសំពត់ដទៃ ដែលដេរ ដោយចេសដើម្បីឲ្យមាំក្នុងទីដែលព័ន្ធព័ទ្ធក ឈ្មោះថាគីវយ្យក: ។ ផ្ទាំងសំពត់ដែលដេរភ្ជាប់ដោយចេសដូច្នោះ ក្នុងទីដែលត្រូវប៉ះស្នងឈ្មោះថាជង្ឆ-យ្យក: ។ អាចារ្យពួកខ្លះថាគីវយ្យក: និងជង្ឆយ្យក:នោះ ជាឈ្មោះនៃផ្ទាំងសំពត់ទាំងឡាយ ដែលតម្កល់ទុកក្នុងទីព័ន្ធព័ទ្ធក និងក្នុងទីត្រូវប៉ះស្នងដូច្នេះ ។ ខណ្ឌគឺផ្ទាំងមួយៗ ឲ្ជដ៏ខាងក្រៅនៃអនុវិវដ្ដ:នេះ ឈ្មោះថាពាហន្ត: ។ ពាក្យដូច្នេះនោះពិចារណាទៅ គឺពោលសំដៅចីវរប្រកបដោយខណ្ឌ ៥ ។ មួយយ៉ាងទៀត អនុវិវដ្ដ:នោះ ជាឈ្មោះនៃខណ្ឌគឺផ្ទាំងទាំងពីរអមសងខាងនៃវិវដ្ដ: និងជាឈ្មោះនៃខណ្ឌ គឺផ្ទាំងទាំង ៣ ឬ ៤ ក្នុងម្ខាងៗ នៃវិវដ្ដ:នោះ ។ កាលឃ្ជុំចីវរមានប្រមាណស្មើគ្នា ប្រមូលមូរឡើងព័ទ្ធដាក់លើដើមដៃ ទីបំផុតទាំងពីរនៃខណ្ឌនោះរមែងមានមុខចេញមកខាងក្រៅ ក៏ឯពាហន្ត:នោះជាឈ្មោះនៃខណ្ឌនោះដែលមានទីបំផុតទាំងពីរមានមុខខាងក្រៅនោះឯង ។ ន័យដូច្នេះ លោកពោលទុកក្នុងមហាអដ្ឋ-កថា ។ ដែលព្រះអដ្ឋកថាចារ្យ លើកយកអនុវាតជាសំពត់ដែលព្រះអង្គទ្រង់អនុញ្ញាតខាងក្រោយវិធីធ្វើចីវរនេះ មកពោលថាជាកុសិផងនោះ

ដើម្បីសម្តែងថាខ្ទង់សំពត់ដែលតូចវែងឈ្មោះថាកុសិទាំងអស់ តែថា តាមវិធីធ្វើចីវរនេះ ខ្ទង់សំពត់ដែលតូចវែងស្មើមណ្ឌលឈ្មោះថាកុសិ ខ្ទង់សំពត់ដែលតូចខ្វីបញ្ឈរតាមអឌ្ឍមណ្ឌលក្តី នៅក្នុងចន្ទោះមណ្ឌលនិងអឌ្ឍមណ្ឌលក្តី ឈ្មោះថាអឌ្ឍកុសិទាំងអស់ ។ ផ្ទាំងកណ្តាលឈ្មោះថាវិវដ្ដ: ។ ផ្ទាំងទាំង ២ អមសងខាងឈ្មោះថាអនុវិវដ្ដ: ។ សំពត់អឌ្ឍមណ្ឌលដែលប៉ះព័ទ្ធកក្នុងវេលាឃ្ងុំឈ្មោះគីវេយ្យក: ។ សំពត់អឌ្ឍមណ្ឌល ដែលប៉ះស្មងឈ្មោះថា ជង្ឆេយ្យក: ។ សំពត់អឌ្ឍមណ្ឌលដែលប៉ះត្រូវដៃ ឈ្មោះថា ពាហន្ត: ។ រួមសេចក្តីតាមវាទ:ក្នុងអដ្ឋកថា បានសេចក្តីដូច្នេះឯង ។

នឹងពោលតាមអ្នកប្រាជ្ញដែលឈ្វាសវៃ លោកគិតទុកថា កុសិនោះជាឈ្មោះខ្ទង់សំពត់ដែលតូចវែងបញ្ឈរឡើងទៅ ដានទទឹងតាមមណ្ឌល ។ អឌ្ឍកុសិជាឈ្មោះខ្ទង់សំពត់ដែលតូចខ្វី បញ្ឈរឡើងទៅ ដានទទឹងតាមអឌ្ឍមណ្ឌល ។ មណ្ឌលនោះជាឈ្មោះនៃកំណាត់សំពត់ដែលធំវែងបញ្ឈរឡើងទៅ ដានទទឹងតាមកុសិ ។ អឌ្ឍមណ្ឌល ជាឈ្មោះកំណាត់សំពត់ដែលធំខ្វី បញ្ឈរឡើងទៅ ដានទទឹងតាមអឌ្ឍកុសិ ។ វិវដ្ដ:នោះជាឈ្មោះផ្ទាំងសំពត់ដែលតូចវែងទៅតាមដានវែង នៅក្នុងចន្ទោះមណ្ឌលនិងអឌ្ឍ-មណ្ឌលនិងចន្ទោះកុសិនិងអឌ្ឍកុសិ ក្នុងខណ្ឌកណ្តាល ។ អនុវិវដ្ដ: ជាឈ្មោះផ្ទាំងសំពត់ដែលតូចវែង ទៅតាមដានវែងក្នុងចន្ទោះមណ្ឌលនិងអឌ្ឍមណ្ឌល តែទៅក្នុងចន្ទោះនៃកុសិ និងអឌ្ឍកុសិខាងក្រៅ ក្នុងផ្ទាំងទាំងពីរអមសងខាង ។ គីវេយ្យក:នោះ គឺខណ្ឌកណ្តាល ព្រោះអឌ្ឍមណ្ឌល

ក្នុងផ្ទាំងនោះប៉ះត្រូវកក្នុងពេលឃ្ងុំ ។ ជង្ឍយ្យក:នោះ គឺផ្ទាំងទាំងពីរ អមសងខាង ព្រោះអឌ្ឍមណ្ឌលក្នុងផ្ទាំងអំបាលនោះ ប៉ះត្រូវស្មងក្នុងពេលឃ្ងុំ ។ ពាហន្ត:នោះ គឺផ្ទាំងទាំងពីរក្នុងទីបំផុត ព្រោះអឌ្ឍ-មណ្ឌលក្នុងផ្ទាំងនោះនៅក្នុងទីបំផុតដើមដៃក្នុងពេលឃ្ងុំ ។ ពាក្យនេះ ពិចារណាក្នុងចីវរដែលប្រកបដោយខណ្ឌ ៥ គឺ ៥ ផ្ទាំង អ្នកប្រាជ្ញដែលមានប្រាជ្ញាគប្បីពិចារណាមើលចុះ ។

ខមួយ ព្រះអង្គទ្រង់អនុញ្ញាតទុកថា **អនុជានামិ ភិក្ខវេ តិចីវរំ ទ្វិកុណ្ឌំ សង្ឆ្យាដឺ ឯកចិ្ចយំ ឧត្តរាសង្គំ ឯកចិ្ចយំ អន្តរវាសកំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចីវរ ៣ គឺសំពត់សង្ឆ្យាដីពីរជាន់ ឧត្តរាសង្គ:ចីពរមួយជាន់ អន្តរវាសក:ស្បង់ ១ ជាន់ ។

ខមួយទៀត ទ្រង់អនុញ្ញាតទុកថា **អនុជានামិ ភិក្ខវេ អហតានំ ឧស្សាន្ទំ អហតកប្ប៉ានំ ទ្វិកុណ្ឌំ សង្ឆ្យាដឺ ។ ល ។ ឧតុទ្ធតានំ ឧស្សាន្ទំ ចតុក្កុណ្ឌំ សង្ឆ្យាដឺ ទ្វិកុណ្ឌំ ឧត្តរាសង្គំ ទ្វិកុណ្ឌំ អន្តរវាសកំ បំសុកូលេ យាវ-ជត្តំ ចាបណ្ឌិកេ ឧស្សាហោ ការណ្ឌិយោ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយធ្វើសង្ឆ្យដីពីរជាន់ ឧត្តរ-សង្គ:មួយជាន់ អន្តរវាសក:មួយជាន់ ដោយសំពត់ថ្មី និងសំពត់ដែលគក់ម្ពងហើយ ។ បើសំពត់ហួសចាករដូវ (គឺសំពត់ចាស់ហើយ) ឲ្យធ្វើ

សង្ឆាដិ ២ ជាន់ ឧត្តរាសង្គ: ២ ជាន់ អន្តរវាសក: ២ ជាន់ ។ អ្នកទាំងឡាយគួរធ្វើនូវសេចក្តីប្រឹងប្រែងស្វែងរកសំពត់បង្សុកូល សំពត់ធ្លាក់ចុះក្បែររានផ្សារតាមត្រូវការ ។ ក៏ឯសំពត់បង្សុកូល និងសំពត់ធ្លាក់ចុះក្បែររានផ្សារមិនមានកំណត់ សូម្បីមួយរយជាន់ក៏គួរ សំពត់ទាំងអម្បាលនេះព្រះអង្គអនុញ្ញាតទុកដល់ភិក្ខុដែលត្រេកអរ ។

ក៏ឯត្រៃចីវរនេះ កាលសំពត់ដែលនឹងកាត់ទាំង ៣ ផ្នត់មិនគ្រាន់គប្បីធ្វើជាសំពត់កាត់ ២ ផ្នត់ ធ្វើសំពត់មិនបានកាត់មួយផ្នត់ ។ បើសំពត់ដែលនឹងកាត់មិនគ្រាន់ ២ ផ្នត់សោត ឲ្យធ្វើជាសំពត់មិនបានកាត់ ២ ផ្នត់ ធ្វើជាសំពត់កាត់មួយផ្នត់ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា **អនុជានামិ ភិក្ខវេ ទ្វេ ឆិន្នកានិ ឯកំ អច្ឆិន្នកំ ។ អនុជានামិ ភិក្ខវេ ទ្វេ អច្ឆិន្នកានិ ឯកំ ឆិន្នកំ** *ដូច្នេះ ។ បើកាត់សូម្បីតែមួយផ្នត់មិនគ្រាន់ ឲ្យក្លាប់សំពត់អន្ទាធិក: គឺអាគន្ធុកបដ: ផ្ទាំងសំពត់បន្សាបចូល និងមិនកាត់សោះ សូម្បីមួយផ្នត់មិនគួរ ។ ដ្បិតទ្រង់អនុញ្ញាតនិងឃាត់ទុកថា* **អនុជានামិ ភិក្ខវេ អន្ធាធិកំ ឧ អាហរេតុំ ន ច ភិក្ខវេ សព្វំ អច្ឆិន្នកំ ជាវេតព្វំ...** *ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលើកឡើង (គឺប៉ះ) បន្សាបទៀត ក៏ប៉ុន្តែ ភិក្ខុកុំគប្បីទ្រទ្រង់សំពត់មិនបានកាត់ទាំងអស់ឡើយ បើភិក្ខុណាទ្រទ្រង់សំពត់ដូច្នោះ ត្រូវទុក្កដ ។ ក៏ឯសំពត់បន្សាបនេះ បើសំពត់*

ដែលនឹងធ្វើមិនល្មមគ្រាន់ គប្បីលើកឡើងបន្ទាបចុះ បើសំពត់ដែលនឹងធ្វើ ល្មមគ្រាន់ អាគន្ទុកបដ:គឺសំពត់បន្ទាបមិនគួរ គប្បីកាត់ឲ្យបានតែម្យ៉ាង ។

នឹងពោលអំពីប្រមាណ ឯប្រមាណត្រៃចីវរនោះ កំណត់ដោយ ឧក្រិដ្ឋយ៉ាងធំ ត្រូវឲ្យតូចជាងសុគតចីវរទើបគួរ កំណត់យ៉ាងតូចសំពត់ សង្ឆាដិនិងសំពត់ឧត្តរាសង្គ: ពីរនេះ ដោយវែង ៤ ហត្ថ ១ គក់ គឺវាស់ បាន ៤ ហត្ថហើយ មួយគក់ទៀតជាគម្រប់ ៥ ទទឹង ២ ហត្ថ និងមួយគក់ ដូចមុនទើបគួរ ។ ចំណែកសំពត់អន្តរវាសក: ដោយវែង ៤ ហត្ថនិងមួយគក់ ទទឹងសូម្បី ២ ហត្ថក៏គួរ ដ្បិតថាអាចដើម្បីបិទនូវមណ្ឌលផ្ទៃត ដោយ ស្មៀកនិងដណ្តប់ ។ សំពត់ដែលធំនិងតូចជាងប្រមាណ ដូចពោល ហើយនោះ មិនគួរអធិដ្ឋានជាត្រៃចីវរ ។

សំពត់ដែលធ្វើហើយ គប្បីជ្រលក់ដោយទឹកជ្រលក់ ៦ យ៉ាង គឺ ទឹកជ្រលក់កើតអំពីឫស និងមើមនៃឈើទាំងពួង លើកតែ **ហលិទ្ទំ** រមៀតនិងព្រះអង្គោលចេញ ក្រៅពីនោះគួរទាំងអស់ ។ ទឹកជ្រលក់ កើតអំពីដើមឈើទាំងពួង លើកតែ **មញ្ជេដ្ឋំ** ស្បែង **តុង្គ្គហារ** ឃ្ងរ ពីរនេះចេញ ក្រៅនោះគួរទាំងអស់ ។ ឈើមានបន្ទាមួយយ៉ាងនោះ ឈ្មោះថា **តុង្គ្គហារ** ទឹកជ្រលក់កើតអំពីដើមឈើនោះ ពណ៌ដូចហរ-ដាន ។ ទឹកជ្រលក់កើតអំពីសម្បកឈើទាំងពួង លើកតែ **លោទ្ធំ** សម្បកលោទ្ធ **ការ្ណាសំ** សម្បកព្រហូត ទាំងពីរនេះចេញ ក្រៅពី នោះគួរទាំងអស់ ។ ទឹកជ្រលក់កើតអំពីស្លឹកឈើទាំងពួង លើកតែ

អលិបត្តំ ស្លឹកមក្ងៀ **ជិលបត្តំ** ស្លឹកត្រុំ ពីរនេះចេញ ក្រៅពីនោះគួរទាំងអស់ ។ តែសំពត់ដែលគ្រហស្ថបរិភោគហើយនោះ និងជ្រលក់ដោយស្លឹកអលិបត្តម្ដងក៏គួរ ។

ទឹកជ្រលក់កើតអំពីផ្លាឈើទាំងពួង លើកតែ **ភ្លីសុកបុប្ផំ** ផ្លាចារ ១ **ការុសុម្ភបុប្ផំ** ផ្លាដកគាំ ១ ទាំង ២ នេះចេញ ក្រៅពីនោះគួរទាំងអស់ ។

ទឹកជ្រលក់កើតអំពីផ្ទៃឈើទាំងពួង ដែលមិនគួរនោះមិនមានឡើយ បាលីដែលទ្រង់អនុញ្ញាតទឹកជ្រលក់នោះថា **អនុជានាមិ ភិក្ខវេ ឆ រជនានិ មូលរជនំ ខន្ធរជនំ តចរជនំ បត្តរជនំ បុប្ផរជនំ ផលរជនន្តិ** ដូច្នេះ ។

ទឹកជ្រលក់ដែលឃាត់ទុកនោះ តាមអដ្ឋកថា ថា ទឹកជ្រលក់ទាំង ៦ នេះ ជ្រលក់ទៅហើយឲ្យផុតចាកពណ៌ដែលទ្រង់ឃាត់ទុក ៧ ប្រការ មានពណ៌ខៀវជាដើម ដូចពោលហើយក្នុងចីវរបដិសំយុត្ត និងឲ្យផុតចាកពណ៌ដូចក្ងុកដំរី និងចំបើង អម្បាលនេះចេញទើបគួរ អាការដែលនឹងជ្រលក់សំពត់នោះ គប្បីបដិបត្តិដូចពោលហើយក្នុងបរិក្ខារកថានោះចុះ ។

ជ្រលក់ហើយគប្បីធ្វើកប្បពិន្ទុ ដោយវត្ថុខៀវ ឬកក់ ឬវត្ថុខ្មៅណាមួយ ក្នុងទីណាមួយ លើកតែក្រវ៉ិលក្ងុំចេញ ឲ្យធំប៉ុនភ្នែកក្ងោកដោយពាក្យថា **ឥមំ ពិន្ទុកប្បំ ករោមិ** ដូច្នេះហើយគប្បីអធិដ្ឋានចុះ ។

ក៏ឯអធិដ្ឋានចីវរមានពីរ គឺអធិដ្ឋានដោយកាយ ១ អធិដ្ឋានដោយវាចា ១ ។ បើសំពត់សង្ឃាដិចាស់មាន គប្បីដកអធិដ្ឋានចេញដោយពាក្យថា **ឥមំ សង្ឃាដឺ បច្ចុទ្ធរामि** ខ្ញុំដកនូវសំពត់សង្ឃាដិនេះ ហើយយកដៃចាប់សំពត់សង្ឃាដិថ្មី ឬតម្កល់ទុកលើអវយវៈខ្ជួនហើយ ធ្វើអាភោគចិត្តថា **ឥមំ សង្ឃាដឺ អធិដ្ឋាមិ** យើងអធិដ្ឋានសំពត់សង្ឃាដិផ្ទត់នេះ ធ្វើនូវកាយវិការ អធិដ្ឋានដោយកាយចុះ ដូច្នេះឈ្មោះថាអធិដ្ឋានដោយកាយ អធិដ្ឋានដោយកាយនោះ នឹងមិនពាល់ត្រូវដោយអវយវៈខ្ជួនណាមួយមិនគួរ ។ ឯអធិដ្ឋានដោយវាចានោះ គប្បីធ្វើវចីភេទអធិដ្ឋានដោយពាក្យថា **ឥមំ សង្ឃាដឺ អធិដ្ឋាមិ** ដូច្នេះ ។ អធិដ្ឋានដោយវាចាមាន ២ គឺ ក្នុងហត្ថបាស ១ ក្រៅហត្ថបាស ១ ។ បើសំពត់នៅក្នុងហត្ថបាសឲ្យបញ្ចេញវាចាថា **ឥមំ សង្ឃាដឺ អធិដ្ឋាមិ** ដូច្នេះ ។ បើសំពត់នៅខាងក្នុងលែ្ងង ឬលើប្រាសាទ ឬក្នុងកុដិ ដ៏ធ្ងាយ ត្រូវកំណត់ទីដែលតម្កល់ទុក ហើយបញ្ចេញវាចាថា **ឯតំ សង្ឃាដឺ អធិដ្ឋាមិ** យើងអធិដ្ឋានសំពត់សង្ឃាដិផ្ទត់នុ៎ះដូច្នេះចុះ ។ ការអធិដ្ឋានឧត្តរាសង្គៈ និងអន្តរវាសកៈ ក៏ដូចគ្នាដែរ ប្លែកគ្នាតែឈ្មោះប៉ុណ្ណោះ ព្រោះហេតុនោះ សំពត់ទាំងពួង គប្បីបច្ចុទ្ធរនិងអធិដ្ឋានតាមឈ្មោះសំពត់នោះ១ ចុះ ។

ឯវិធីបច្ចុទ្ធរៈ (ដកអធិដ្ឋាន) នោះដូច្នេះគឺ

បើចីពរនៅជិតថា **ឥមំ ឧត្តរាសङ्गं បច្ចុទ្ធរामि** ។

បើចីពរនៅធ្វាយថា ឯតំ ឧត្តរាសङ្គំ *បច្ចុទ្ធរामि* ។

បើស្បង់នៅជិតថា ឥមំ អន្តរវासकं *បច្ចុទ្ធរामि* ។

បើស្បង់នៅធ្វាយថា ឯតំ អន្តរវासकं *បច្ចុទ្ធរामि* ។

ឯវិធីអធិដ្ឋានៗ ដូចនេះគឺ

បើចីពរនៅជិតថា ឥមំ ឧត្តរាសङ्गं *អធិដ្ឋामि* ។

បើចីពរនៅធ្វាយថា ឯតំ ឧត្តរាសङ्गं *អធិដ្ឋामि* ។

បើស្បង់នៅជិតថា ឥមំ អន្តរវासकं *អធិដ្ឋामि* ។

បើស្បង់នៅធ្វាយថា ឯតំ អន្តរវासकं *អធិដ្ឋामि* ។

ត្រៃចីវរនឹងអធិដ្ឋានជាបរិក្ខារចោល: គួរឬមិនគួរ?

មិនគួរ ។ ដ្បិតបានឮថា ព្រះមហាបទុមត្ថេរ លោកពោលទុកថា ត្រៃចីវរត្រូវអធិដ្ឋានជាត្រៃចីវរពិត ថាបើត្រៃចីវរអធិដ្ឋានជាបរិក្ខារចោល: បានសោត បរិហារការរក្សាត្រៃចីវរក្នុងឧទ្ទេសិតសិក្ខាបទ ក៏នឹងទៅជាការឥតប្រយោជន៍ ពាក្យព្រះមហាបទុមត្ថេរពោលនេះប្រពៃពិត ។

ក៏ឯសំពត់ងូតទឹកភ្លៀងនិងសំពត់ទ្រាប់អង្គុយ និងសំពត់បិទបូសកម ៣ នេះ អាការដែលនឹងធ្វើ នឹងប្រមាណ គប្បីដឹងដូចពោលហើយក្នុងបាចិត្តិយនោះចុះ ។ តែសំពត់ក្រាលដេក សំពត់ជូតមុខ សំពត់បរិក្ខារ-ចោល: ៣ នេះ វិធីដែលនឹងធ្វើ នឹងប្រមាណ ព្រះអង្គនឹងបានពោលទុកក៏ទេ ។ សំពត់ងូតទឹកភ្លៀងដែលមិនលើសប្រមាណ គប្បីអធិដ្ឋានអស់ ៤ ខែក្នុងរដូវភ្លៀង ដោយន័យដូចពោលហើយនោះចុះ ។ ពាក្យ

អធិដ្ឋានថា **ឥមំ វស្សិកសាដិកំ អធិដ្ឋামি** *ដូច្នេះ ។ តអំពីរដូវភ្លៀងនោះទៅ គប្បីដកអធិដ្ឋានហើយវិកប្បទុក សំពត់ផ្ទួតទឹកភ្លៀងនេះ សូម្បីជ្រលក់ល្មមទម្ងាយពណ៌ក៏គួរ តែពីរផ្នត់មិនគួរ ។*

សំពត់ទ្រាប់អង្គុយ គប្បីអធិដ្ឋានដោយពាក្យថា **ឥមំ និសីទនំ អធិដ្ឋামি** *ដូច្នេះ ។ ក៏ឯសំពត់ទ្រាប់អង្គុយនោះ ប្រកបដោយប្រមាណនឹងមួយផ្នត់ទើបគួរ ពីរផ្នត់មិនគួរ ។ សូម្បីសំពត់ក្រាលដេកត្រូវអធិដ្ឋានពិតពាក្យអធិដ្ឋានថា* **ឥមំ បច្ចត្ថរណំ អធិដ្ឋামি** *ដូច្នេះ ។ តែសំពត់ក្រាលដេក សូម្បីធំក៏គួរ សូម្បីមួយផ្នត់ឬច្រើនក៏គួរ ។ ច្រើនគប្បីអធិដ្ឋានថា* **ឥមានិ បច្ចត្ថរណានិ អធិដ្ឋামি** *ដូច្នេះ ។ សំពត់ក្រាលដេកនេះ សូម្បីខ្ចៀវ ឬលឿង មានជាយ ឬមិនមានជាយ ដូចផ្ការណើទាំងពួងគួរទាំងអស់ អធិដ្ឋានម្តងហើយក៏ឈ្មោះថា អធិដ្ឋានដោយពិត ។*

សំពត់បិទបូស ប្រកបដោយប្រមាណ អាពាធមាននៅដរាបណា គប្បីអធិដ្ឋានដរាបនោះ ពាក្យអធិដ្ឋានថា **ឥមំ ពណ្ណាបដិច្ឆាទឺ អធិ-ដ្ឋামি** *ដូច្នេះ ។ កាលអាពាធរំងាប់ហើយ គប្បីបច្ចុទ្ធរដកចេញហើយវិកប្បទុក សំពត់បិទបូសនេះគួរតែមួយផ្នត់ប៉ុណ្ណោះ ។ សំពត់ជូតមុខត្រូវអធិដ្ឋានប្រាកដ ពាក្យអធិដ្ឋានថា* **ឥមំ មុខបុញ្ឆនចោលំ អធិដ្ឋামি** *ដូច្នេះ ។ សំពត់មួយបោកគក់នៅដរាបណា បើត្រូវការប្រើប្រាស់សំពត់ដទៃទៀត ប្រើប្រាស់បានដរាបនោះ ព្រោះហេតុនោះ សំពត់ជូតមុខនេះ សូម្បីពីរផ្នត់ក៏គួរ ។*

សំពត់បរិក្ខារចោល: សម្បីជាថង់បាត្រ និងសំពត់ត្រងទឹក ដែលមានប្រមាណប៉ុនបច្ចិមចីវរដែលគួរវិកប្ប ត្រូវអធិដ្ឋានជាបរិក្ខារចោល: ដោយពិត ពាក្យអធិដ្ឋានថា **ឥមំ ចីវរំ បរិក្ខារចោលំ អធិដ្ឋামি** *ដូច្នេះ ។ បើច្រើនសូម្បីនឹងរួមចូលគ្នាអធិដ្ឋានថា* **ឥមានិ ចីវរានិ បរិក្ខារចោលានិ អធិដ្ឋামি** *ដូច្នេះ ក៏គួរពិត ។ តែក្នុងពួក ខ្នើយ គ្រែ តាំង សំពត់បាវារ: សំពត់កោជវ: អម្បាលនេះក្តី និងសំពត់បច្ចត្ថរណ: គ្រឿងកម្រាល ដែលគេប្រគេន ដើម្បីជាបរិក្ខារនៃសេនាសន:ក្តី អម្បាលនេះ កិច្ចដែលនឹងអធិដ្ឋានមិនមានឡើយ ។ សំពត់ដែលអធិដ្ឋានទាំងពួង បើមួយផ្នត់នៅក្រៅហត្ថបាសឲ្យថា* **ឯតំ** *ជួស* **ឥមំ** *បើច្រើនផ្នត់ឲ្យថា* **ឯតានិ** *ជួស* **ឥមានិ** *ដូច្នេះចុះ ។*

វិធីដករបស់អធិដ្ឋានមួយៗ ថាដូច្នេះ ៖

ឥមំ សង្ឆាដឺ បច្ចុទ្ធរামি ។

ឥមំ ឧត្តរាសង្គំ បច្ចុទ្ធរামি ។

ឥមំ អន្តរវាសកំ បច្ចុទ្ធរামি ។

ឥមំ និសីទនំ បច្ចុទ្ធរামি ។

ឥមំ វស្សិកសាដិកំ បច្ចុទ្ធរামি ។

ឥមំ កណ្ឌុបដិច្ឆាឌឺ បច្ចុទ្ធរামি ។

ឥមំ បច្ចត្ថរណំ បច្ចុទ្ធរামি ។

ឥមំ មុខបុញ្ឆនចោលំ បច្ចុទ្ធរামি ។

ឥមំ បរិក្ខារចោលំ បច្ចុទ្ធរामि ។ *បើដកកម្រាលច្រើនថា* **ឥមានិ បច្ចត្ថរณานิ បច្ចុទ្ធរामि** ។ *បើដកកន្ទៃរ៉ងជូតមុខច្រើនថា* **ឥមานิ មុខបุญ្ជនចោลานิ បច្ចុទ្ធរामि** ។ *បើដកបរិក្ខារចោលៈច្រើនថា* **ឥมานิ បរิក្ខารจोลานิ** *ជ* **ច្ចុទ្ធរामि** ។

វិធីអធិដ្ឋាននិងបច្ចុទ្ធរសំពត់ចប់

វិកប្បនកថា

ពណ៌នាអំពីវិធីវិកប្បសំពត់ ។ ឯវិធីវិកប្បនោះ គប្បីដឹងដូច្នេះ សំពត់ក្រៅចាកសំពត់ដែលទ្រង់អនុញ្ញាតឲ្យអធិដ្ឋានទាំង ៧ យ៉ាង មានប្រមាណល្មមបានបច្ចិមចីវរ ត្រូវវិកប្បខាងក្នុង ១០ ថ្ងៃ ព្រោះទ្រង់អនុញ្ញាតថា **អនุชานามิ ภิกฺขเว อติเรกจีวรํ วิกเปฺปตุํ ។ อนุชานามิ ภิกฺขเว อายาเมน อฏฺฐงฺคุลํ สุคต-ตฺถํเลน จตุรงฺคุลวิตฺถตํ ปจฺจิมํ จีวรํ วิกเปฺปตุํ ។** *ម្នាលភិក្ខុទាំងឡាយ តថាគតអនุญ្ជาតឲ្យวิกปฺปสํพต់អติเรกจีวร ។ តថាគតអនุญ្ជาតឲ្យวิกปฺปสํพต់ปจฺจิมจีวร គឺสํพต់យ៉ាងតូចបំផុតបណ្ដោយ ៨ ផ្ទាប់ ទទឹង ៤ ផ្ទាប់ ដោយផ្ទាប់ព្រះสุคต ។ ก็สํพต់យ៉ាងតូចគួรวิกปฺปនោះ ពោលតามสุคตวิทัตติวิธานบกรณ:ថา ប្រมาณដោយផ្ទាប់ជាងឈើสพฺวัตถ ១០ ផ្ទាប់ និง ๓ ก็ปฺปิสทទឹง ๙ ផ្ទាប់ និง ๑ ก็ปฺปิส ๒ อนุก็ปฺปิส ។*

មួយទៀត សំពត់ជូតទឹកភ្នែង សំពត់បិទបូស ផ្ទុតកាលអធិដ្ឋាន ហើយ គប្បីវិកប្បដូចគ្នាដែរ ។

វិធីវិកប្បមាន ២ យ៉ាងគឺ វិកប្បចំពោះមុខ ១ វិកប្បកំបាំងមុខ ១ ។ វិកប្បចំពោះមុខនោះដូច្នេះ គប្បីដឹងថាសំពត់មួយផ្នត់ ឬ ច្រើនផ្នត់ នឹងតាំងនៅក្នុងទីជិតហត្ថបាសឬឆ្ងាយហត្ថបាស ។ បើមួយផ្នត់នៅក្នុងហត្ថ-បាស គប្បីពោលថា **ឥមំ ចីវរំ** *។ ច្រើនផ្នត់ថា* **ឥមានិ ចីវរានិ** *។ បើមួយផ្នត់នៅឆ្ងាយគប្បីពោលថា* **ឯតំ ចីវរំ** *។ ច្រើនផ្នត់ថា* **ឯតានិ ចីវរានិ** *ហើយចុះចុងពាក្យថា* **តុយ្ហំ វិកប្បេមិ** *ដូច្នេះគ្រប់ៗ បទ ក្នុងសំណាក់ភិក្ខុមួយអង្គចុះ នេះឈ្មោះថាវិកប្បចំពោះមុខម្យ៉ាង ដោយ វិកប្បប៉ុណ្ណោះនឹងទុកដាក់ក៏គួរ និងបរិភោគ ឬលះបង់ ឬអធិដ្ឋាន មិនគួរ កាលបើអ្នកទទួលវិកប្បពោលថា* **ឥមំ ចីវរំ មយ្ហំ សន្តកំ** *ឬថា* **ឥមានិ ចីវរានិ មយ្ហំ សន្តកានិ** *តាមផ្នត់ មួយ និងច្រើន ហើយ ចុះចុងពាក្យថា* **បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ** *ដូច្នេះហើយ ឈ្មោះថាបច្ចុទ្ធរដក តាំងអំពីបច្ចុទ្ធរដកហើយ សូម្បីនឹងបរិភោគ ជាដើមក៏គួរ ។*

ម្យ៉ាងទៀត គប្បីដឹងថា សំពត់មួយផ្នត់ ឬច្រើនផ្នត់ ដែលតាំង នៅក្នុងទីជិត ឬឆ្ងាយ ។ ជិតពោលថា **ឥមំ ចីវរំ** *ឬថា* **ឥមានិ ចីវរានិ** *។ ឆ្ងាយថា* **ឯតំ ចីវរំ** *ឬថា* **ឯតានិ ចីវរានិ** *ដូចមុន ក្នុងសំណាក់ភិក្ខុមួយអង្គ ហើយកាន់យកឈ្មោះនៃសហធម្មិកទាំង ៥ ណា*

មួយ ដែលខ្ជួនគាប់ចិត្ត ដែលមិននៅក្នុងទីនោះ ទើបចុះចុងពាក្យថា **តិស្សស្ស ភិក្ខុនោ វិកប្បេមិ** *ឬថា* **តិស្សស្ស សាមណេ-រស្ស វិកប្បេមិ** *ដូច្នេះ តាមឈ្មោះសហធម្មិក ដែលខ្ជួនគាប់ចិត្ត នោះគ្រប់ៗបទ ក្នុងសំណាក់ភិក្ខុមួយអង្គនោះ សូម្បីដូច្នេះក៏ឈ្មោះថា វិកប្បចំពោះមុខ ម្យ៉ាងទៀតដូចគ្នា ។ បើនឹងទុកដាក់ ដោយវិកប្ប ប៉ុណ្ណោះក៏គួរ តែក្នុងកិច្ចមានបរិភោគជាដើម សូម្បីតែវត្ថុណាមួយ ក៏មិន គួរ កាលបើភិក្ខុដែលទទួលវិកប្បចំពោះមុខនោះ ពោលថា* **តិស្សស្ស ភិក្ខុនោ សន្តកំ ។ ល ។ តិស្សស្ស សាមណេរស្ស សន្តកំ បរិភុញ្ជ ភ វិសជ្ជេហិ ភ យថាបច្ចយំ ភ ករោហិ** *ដូច្នេះ តាមឈ្មោះសហធម្មិកដែលវិកប្បទុកនោះហើយ ទើប បានឈ្មោះថាបច្ចុទ្ធរដក តាំងអំពីបច្ចុទ្ធរដកហើយ សូម្បីនឹងបរិភោគ ជាដើមក៏គួរ ។*

វិកប្បកំចាំងមុខនោះដូច្នេះ គប្បីដឹងថា សំពត់មួយផ្ទត់ ឬច្រើន ផ្ទត់ ដែលតាំងនៅក្នុងទីជិត ឬឆ្ងាយ ។ បើនៅជិតពោលថា **ឥមំ ចីវរំ** *ឬថា* **ឥមានិ ចីវរានិ** *។ បើនៅឆ្ងាយពោលថា* **ឯតំ ចីវរំ** *ឬថា* **ឯតានិ ចីវរានិ** *ដូចមុន ហើយទើបចុះចុងពាក្យថា* **តុយ្ហំ វិកប្បនត្ថាយ ទជ្ជិ** *ដូច្នេះ ក្នុងសំណាក់ភិក្ខុមួយអង្គចុះ ភិក្ខុនោះគប្បីសួរម្ចាស់សំពត់ ថា សហធម្មិកណាធ្លាប់ជាមិត្ត ជាសម្ងាញ់គ្នា ឬជាមិត្តធ្លាប់បរិភោគ ជាមួយគ្នានឹងលោកដូច្នេះ ហើយម្ចាស់សំពត់គប្បីប្រាប់ឈ្មោះតាមគាប់ចិត្ត*

ថាភិក្ខុឈ្មោះ តិស្ស ឬសាមណេរឈ្មោះ តិស្ស ជាមិត្រសម្ងាញ់នៃខ្ញុំ តាមគាប់ចិត្តខ្លួនហើយ ភិក្ខុអ្នកទទួលវិកប្បនោះ គប្បីពោលទៀតថា **អហំ តិស្សស្ស ភិក្ខុនោ ឧម្មិ** ឬថា **អហំ តិស្សស្ស សាមណេរស្ស ឧម្មិ** ដូច្នេះ តាមឈ្មោះដែលម្ចាស់សំពត់ប្រាប់នោះ ចុះ ដូច្នេះឈ្មោះថា វិកប្បកំបាំងមុខ នឹងទុកដាក់ដោយវិកប្បប៉ុណ្ណោះ ក៏គួរ ។ កិច្ចមានបរិភោគជាដើម សូម្បីតែកិច្ចណាមួយក៏មិនគួរ លុះតែកាលណាភិក្ខុអ្នកជួយទទួលវិកប្បនោះ ពោលពាក្យជាដើមថា **តិស្ស-ស្ស ភិក្ខុនោ សន្តកំ បរិភុញ្ជ វា វិសជ្ជេហិ វា យថា-បច្ចយំ វា ករោហិ** ដោយន័យដូចពោលហើយក្នុងវិកប្បចំពោះមុខបទគម្រប់ ២ នោះហើយ ទើបឈ្មោះថាបច្ចុទ្ធរដក តាំងអំពីបច្ចុទ្ធរដកហើយ សូម្បីនឹងបរិភោគជាដើមក៏គួរ ។

បុ. វិកប្បចំពោះមុខនិងកំបាំងមុខ ទាំង ២ នោះ ប្លែកគ្នាដូចម្តេច?

វិ. ក្នុងវិកប្បចំពោះមុខនោះ វិកប្បដោយខ្លួនឯងឲ្យអ្នកដទៃដក ក្នុងវិកប្បកំបាំងមុខនោះ ឲ្យអ្នកដទៃវិកប្បឲ្យ ឲ្យអ្នកដទៃដកឲ្យ វិកប្បពីរយ៉ាងនេះ ប្លែកគ្នាដូច្នេះ បើនឹងវិកប្បដល់អ្នកណា អ្នកនោះជាមនុស្ស មិនឈ្វាសក្នុងបញ្ញត្តិ មិនដឹងនូវកិច្ចដែលដក គប្បីកាន់យកសំពត់នោះ ទៅរកភិក្ខុដទៃដែលជាមនុស្សឈ្វាស គប្បីវិកប្បថែមទៀតហើយ ឲ្យភិក្ខុនោះដកឲ្យ វិកប្បថែមទៀត នូវសំពត់ដែលវិកប្បទុកហើយនោះវមែងគួរ ។ ក្នុងវិមតិវិនោទនីពោលថា ឯពាក្យក្នុងអដ្ឋកថា ពោលថាតាំងអំពី

បច្ចុទ្ធរដកហើយទៅ សូម្បីនឹងបរិភោគជាដើមរមែងគួរ ពាក្យនេះសម្តែងថាសូម្បីធ្វើការបច្ចុទ្ធរដកហើយ សំពត់នោះក៏គង់ជាសំពត់វិកប្បនៅដូចដែល នឹងត្រឡប់ទៅជាអតិរេកចីវរវិញមិនបាន តែសំពត់នោះភិក្ខុប្រាថ្នានឹងអធិដ្ឋានដោយឈ្មោះនៃត្រៃចីវរជាដើម គប្បីអធិដ្ឋានចុះ បើភិក្ខុមិនប្រាថ្នានឹងអធិដ្ឋាន ក៏គប្បីធ្វើឲ្យជាសំពត់វិកប្បនៅដូច្នោះ បរិភោគចុះ ពោលដូច្នេះហើយឃាត់ពាក្យអាចារ្យពួកខ្លះ ដែលពោលថា វិកប្ប ហើយបានតែទុកមួយយ៉ាង បើដកវិកប្បហើយ គប្បីអធិដ្ឋានបរិភោគដូច្នេះ ព្រោះអាងហេតុនិងឧទាហរណ៍ផ្សេងៗ សេចក្តីសង្ខេបថា វិកប្ប ហើយឲ្យដកវិកប្បចេញ ហើយបរិភោគចុះ សូម្បីកន្ទង ១០ ថ្ងៃទៅ មិនត្រូវនិស្សគ្គិយ អ្នកមានបញ្ញាគប្បីពិចារណាយកចុះ ។

វិកប្បនកថា ចប់

អធិដ្ឋាននិងវិកប្ប ២ នេះ គប្បីធ្វើក្នុងសំពត់អតិរេកចីវរតែខាងក្នុង ១០ ថ្ងៃ បើទុកឲ្យកន្ទង ១០ ថ្ងៃទៅ សំពត់នោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ដោយបឋមកឋិនសិក្ខាបទ ។

វិធីអធិដ្ឋាននិងវិកប្បចីវរ ចប់

វិធីអធិដ្ឋានបាត្រ

ពណ៌នាអំពីអធិដ្ឋានបាត្រ ។ បាត្រដែក បាត្រដី ប្រកបដោយប្រមាណ ទើបគួរអធិដ្ឋាននិងវិកប្ប ។ ប្រមាណនៃបាត្រ មាន ៣ គឺ

ឧក្កដ្ឋោ បាត្រខ្នាតធំ ១ **មជ្ឈិមោ** បាត្រខ្នាតកណ្តាល ១ **ឱមកោ** បាត្រខ្នាតតូច ១ ។ បាត្រខ្នាតធំនោះ ចុះបាយនៃអង្ករកន្ទះអាឡ្ហក: គឺ អង្ករ ២ នាឡិមគធ: ។ ក្នុងអន្ធកដ្ឋកថាពោលទុកថា ឯនាឡិមគធ:នោះ ១២ បល:កន្ទះ ។ ក្នុងមហាអដ្ឋកថាពោល **បកតិនាឡ្យ** នាឡិដោយប្រក្រតី ក្នុងសីហឬទ្ធីបក៏ធំពេកទៅ **ឧមិឌ្ឍនាឡ្យ** នាឡិទមិឬ:ក៏តូចពេក ទៅ **មកធនាឡ្យ** នាឡិមគធ:ទើបប្រកបដោយប្រមាណ មួយនាឡិ កន្ទះនៃនាឡិមគធ:នោះ ត្រូវជាមួយនាឡិក្នុងសីហឬ: ។ ឯវិធីដែលនឹង គិតបល:និងប្រមាណ មគធនាឡិតាមដីកា និងគម្ពីរដ៏សេស នឹងទុក ពោលក្នុងទីបំផុតនៃវណ្ណនាទាំងពួង ។ ប្រមាណបាត្រខ្នាតធំ ឲ្យយកអង្ករ នៃស្រូវសាលីដែលមិនបាក់ ដែលចាស់កន្ទងឆ្នាំ គេស្រិតបរិសុទ្ធល្អ ហើយវាស់ឲ្យបាន ២ នាឡិមគធ:ដូចពោលហើយនោះ ដណ្តាំកុំឲ្យជាត់ ទឹកចេញ កុំឲ្យនៅពងបង្ហួយ កុំឲ្យជ្រាយ កុំឲ្យជាដុំ ឲ្យស្រួយស្រស់ ដាច់ចាកពីគ្នា បីដូចគំនរផ្ការុន និងផ្ការ៉ាមិ:ក្រពុំ ហើយដាក់ចុះក្នុងបាត្រ ឲ្យអស់ យកសម្ងសណ្តែកដែលផ្សំដោយគ្រឿងទាំងពួង មិនខាប់ ណាស់ មិនពាវណាស់ល្មមចាប់ដោយដៃបាន ស្មើចំណែកគម្រប់ ៤ នៃបាយ នោះដាក់ចុះផង ហើយយកម្ហូបមានត្រីនិងសាច់ជាដើម ដ៏សមគួរដល់ ពំនូតៗ ដរាបល្មមគ្រាន់ដល់ពំនូតជាបំផុត គឺស្មើចំណែកគម្រប់ ៤ នៃបាយ ដាក់ចុះផង តែសប្បិនិងប្រេងនិងខ្ទាញ់និងទឹកសម្ងនិងទឹកជ្រក់ជាដើម នឹងរាប់ចូលផងមិនបាន ដ្បិតថាវត្ថុទាំងអម្បាលនោះ ជាគតិនៃបាយ

មិនអាចឲ្យបាយថយនិងចម្រើនឡើងបាន វត្ថុទាំងពួងនោះដាក់ចុះហើយ ដូច្នោះបើលួមស្មើកណ្ដាប់មាត់បាត្រខាងក្រោម យកអម្ពោះ ឬជក់ត្នោត ក្ងៀរទៅលួមចំណែកខាងក្រោមនៃអម្ពោះនិងជក់ត្នោត ត្រូវវត្ថុក្នុងបាត្រ ដោយពិត បាត្រដូច្នេះឈ្មោះថាបាត្រខ្ជាតធំយ៉ាងកណ្ដាល ។ បើវត្ថុ ក្នុងបាត្រនោះពួនលើសកណ្ដាប់មាត់បាត្រឡើងមកសោត បាត្រដូច្នេះ ឈ្មោះថាបាត្រខ្ជាតធំយ៉ាងតូច ។ បើវត្ថុក្នុងបាត្រនោះមិនដល់កណ្ដាប់ មាត់បាត្រ ស្រុតចុះទៅនៅក្នុងបាត្រសោត បាត្រដូច្នេះឈ្មោះថាបាត្រ ខ្ជាតធំយ៉ាងធំ ។

បាត្រខ្ជាតកណ្ដាលនោះ ឲ្យយកអង្ករមួយនាឡិមគធ: ដណ្ដាំ ឡើងដូចមុនដាក់ចុះ យកសម្ងសណ្ដែកស្ងើចំណែកគម្រប់ ៤ នៃបាយ និង ម្ហូបមានត្រីសាច់ជាដើម ក៏ស្ងើចំណែកគម្រប់ ៤ នៃបាយ វត្ថុអម្បាលនេះ ដាក់ចុះក្នុងបាត្រទាំងអស់ បើស្មើកណ្ដាប់មាត់បាត្រខាងក្រោមដូចពោល ហើយក្នុងមុន បាត្រដូច្នេះឈ្មោះថាបាត្រខ្ជាតកណ្ដាលយ៉ាងកណ្ដាល ។ បើវត្ថុនោះកំពុងមាត់បាត្រឡើងមកសោត បាត្រដូច្នេះឈ្មោះថាបាត្រខ្ជាត កណ្ដាលយ៉ាងតូច ។ បើវត្ថុនោះមិនដល់កណ្ដាប់មាត់បាត្រស្រុតចុះទៅ នៅក្នុងបាត្រសោត បាត្រដូច្នេះឈ្មោះថាបាត្រខ្ជាតកណ្ដាលយ៉ាងធំ ។

បាត្រខ្ជាតតូចនោះ ឲ្យយកអង្ករកន្ទុះនាឡិមគធ: ដណ្ដាំឡើង ដូចមុនដាក់ចុះក្នុងបាត្រ យកសម្ងសណ្ដែកស្ងើចំណែកគម្រប់ ៤ នៃបាយ និងម្ហូបមានត្រីសាច់ជាដើម ក៏ស្ងើចំណែកគម្រប់ ៤នៃបាយ វត្ថុទាំងពួងនេះ

ដាក់ចុះក្នុងបាត្រទាំងអស់ហើយ បើស្មើកណ្ដាប់មាត់បាត្រខាងក្រោមដូចមុន បាត្រដូច្នេះឈ្មោះថា បាត្រខ្នាតតូចយ៉ាងកណ្ដាល ។ បើវត្ថុនោះកំពុងមាត់បាត្រឡើងមកសោត បាត្រដូច្នេះឈ្មោះថាបាត្រខ្នាតតូចយ៉ាងតូច ។ បើវត្ថុនោះមិនដល់កណ្ដាប់មាត់បាត្រ ស្រុតចុះទៅនៅក្នុងបាត្រសោត បាត្រដូច្នេះឈ្មោះថាបាត្រខ្នាតតូចយ៉ាងធំ ។ ត្រូវជាបាត្រប្រកបដោយខ្នាត ៩ យ៉ាងដូច្នេះ ។

ឯបាត្រខ្នាតធំយ៉ាងធំ បាត្រខ្នាតតូចយ៉ាងតូច ពីរនេះមិនឈ្មោះថាជាបាត្រ គប្បីប្រើជាភាជន:ចុះ មិនគួរអធិដ្ឋាន មិនគួរវិកប្ប តែបាត្រ ៧ ក្រៅនោះ គប្បីអធិដ្ឋាន ឬវិកប្ប អំពីខាងក្នុង ១០ ថ្ងៃបរិភោគចុះ បើទុកឲ្យកន្ទ្ធ ១០ ថ្ងៃទៅ បាត្រនោះត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយដោយបត្តសិក្ខាបទ ។

បាត្រសូម្បីប្រកបដោយប្រមាណ ក៏គប្បីដឹងថាគួរអធិដ្ឋាននិងវិកប្ប ដូច្នេះទៀត បាត្រដែកដុតហើយ ៥ ភ្ជើង បាត្រដីដុតហើយ ២ ភ្ជើង ទើបគួរអធិដ្ឋាន ។ បាត្រទាំង ២ នោះ សូម្បីតម្លៃ ក៏គប្បីឲ្យ ឲ្យហើយ បើដុតសូម្បីខ្ទះមួយភ្ជើង ឬតម្លៃខ្ទះសូម្បីមួយកាកណិកមិនទាន់បានឲ្យ ក៏នៅមិនគួរអធិដ្ឋាន បើម្ចាស់បាត្រ គេពោលថា កាលណាតម្លៃរបស់លោកមាន លោកក៏ចូរឲ្យកាលនោះ លោកចូរអធិដ្ឋានបរិភោគចុះ សូម្បីដូច្នេះ ក៏មិនគួរអធិដ្ឋានឡើយ ដ្បិតនឹងរាប់ថាជាបាត្រមិនបាន ព្រោះដុតនៅស្ទើរភ្ជើង និងនៅមិនទាន់ជារបស់នៃខ្លួន

នៅជារបស់អ្នកដទៃនៅឡើយ ព្រោះតម្លៃទាំងអស់ ឬតែមួយចំណែក មិនទាន់បានឲ្យ ព្រោះហេតុនោះ កាលដុតហើយ ឬមានតម្លៃឲ្យ អស់ហើយ ទើបគួរអធិដ្ឋាន ។

បាត្រណាគួរអធិដ្ឋាន បាត្រនោះឯងគួរវិកប្ប បាត្រនោះមកដល់ដៃហើយ ឬនៅមិនទាន់មកដល់ក្តី គប្បីអធិដ្ឋានឬវិកប្ប អំពីខាងក្នុង ១០ ថ្ងៃ ។ បើជាងបាត្រគេបានថ្ងៃឈ្នួលហើយ ឬគេប្រាថ្នាដើម្បីធ្វើប្រគេនដោយខ្លួនឯង គេប្រាប់ថា ខ្ញុំព្រះករុណានឹងធ្វើបាត្រហើយនឹងដុតក្នុងថ្ងៃឯណោះ តាំងទុកដូច្នេះ តាំងអំពីថ្ងៃដែលជាងបាត្រគេកំណត់ទុក ភិក្ខុឲ្យកន្ទង ១០ ថ្ងៃទៅ បាត្រនោះជានិស្សគ្គិយ ខ្លួនត្រូវបាចិត្តិយ ។ ចាបើជាងបាត្រគេពោលថា ខ្ញុំព្រះករុណានឹងធ្វើបាត្រដុតស្រេចហើយ នឹងបញ្ជូនដំណឹងទៅដល់លោកដូច្នេះ ហើយគេធ្វើដូច្នោះ តែភិក្ខុដែលជាងបាត្រផ្តាំមក មិនប្រាប់ដល់ភិក្ខុម្ចាស់បាត្រនោះ ភិក្ខុដទៃបានឃើញ ឬបានឮ មកប្រាប់ថាបាត្ររបស់លោកសម្រេចហើយដូច្នេះ ពាក្យនៃភិក្ខុដទៃនោះ មិនជាប្រមាណ លុះតែកាលណាភិក្ខុដែលជាងបាត្រគេផ្តាំមកឲ្យប្រាប់ បានប្រាប់ដល់ម្ចាស់របស់បាត្រហើយ តាំងអំពីថ្ងៃបានឮពាក្យនៃភិក្ខុប្រាប់នោះទៅ កាលឲ្យកន្ទង ១០ ថ្ងៃទៅ ជានិស្សគ្គិយបាចិត្តិយ ។ បើជាងបាត្រគេថា ខ្ញុំព្រះករុណានឹងធ្វើបាត្រ ដុតស្រេចហើយនឹងផ្ញើក្នុងដៃនៃភិក្ខុឲ្យនាំបាត្រនោះមកប្រគេនដល់លោក ដូច្នេះហើយ គេធ្វើដូច្នោះ តែភិក្ខុអ្នកទទួលបាត្រមក យកទៅទុកដាក់ក្នុងបរិវេណនៃខ្លួន

សិន មិនប្រាប់ដល់ភិក្ខុម្ចាស់បាត្រ ភិក្ខុដទៃសួរថាបាត្ររបស់លោកដែលបានមកថ្មីល្អឬអាក្រក់ ភិក្ខុនោះត្រឡប់សួរថាបាត្រឯណា ភិក្ខុដទៃប្រាប់ថា គេផ្ញើមកក្នុងដៃនៃភិក្ខុឈ្មោះនេះ សូម្បីពាក្យនៃភិក្ខុដទៃនោះក៏មិនជាប្រមាណ លុះតែកាលណាភិក្ខុអ្នកទទួល នាំយកបាត្រនោះមកឲ្យ តាំងអំពីថ្ងៃដែលបានមកហើយនោះ កាលឲ្យកន្ធង ១០ ថ្ងៃទៅ ជានិស្សគ្គិយ-បាចិត្តិយ ។ ព្រោះហេតុនោះ កុំឲ្យកន្ធង ១០ ថ្ងៃ គប្បីអធិដ្ឋានឬវិកប្បទុក ។ ក្នុងបាត្រដែលជាងបាត្រទទួលធ្វើប្រគេននេះយ៉ាងណា សូម្បីក្នុងសំពត់ ដែលជួលជាងតម្បាញឲ្យត្បាញ ឬជាងតម្បាញត្បាញប្រគេនដោយខ្លួនឯង ក៏ដូចគ្នាយ៉ាងនោះ ។ ព្រោះហេតុនោះ សំពត់នោះកុំឲ្យកន្ធង ១០ ថ្ងៃទៅ គប្បីអធិដ្ឋានឬវិកប្បទុកក្នុងខាងក្នុង ១០ ថ្ងៃ ។

វិធីអធិដ្ឋានបាត្រមាន ២ យ៉ាងគឺ ដោយកាយ ១ ដោយវាចា ១ ។ កាលនឹងអធិដ្ឋានដោយវិធីទាំង ២ បើបាត្រចាស់មាននៅក្នុងទីចំពោះមុខ គប្បីបច្ចុទ្ធរដកចេញ ថា **ឥមំ បត្តំ បច្ចុទ្ធរामि** *ដូច្នេះ ។ បើនៅក្នុងទីកំបាំងមុខ (ក្រៅហត្ថបាស) គប្បីបច្ចុទ្ធរថា* **ឯតំ បត្តំ បច្ចុទ្ធរामि** *ដូច្នេះ ។ ឬឲ្យបាត្រនោះដល់ភិក្ខុដទៃហើយ យកដៃស្តាបបាត្រថ្មីដែលតម្កល់ទុកក្នុងតំបន់ណាមួយហើយធ្វើអាភោគចិត្តថា* **ឥមំ បត្តំ អធិដ្ឋាមि** *ធ្វើកាយវិការគឺស្តាបផង នេះឈ្មោះថាអធិដ្ឋានដោយកាយ ឬបញ្ចេញវាចាឲ្យឮថា* **ឥមំ បត្តំ អធិដ្ឋាមि** *ដូច្នេះ ឈ្មោះថាអធិដ្ឋានដោយវាចា ។ អធិដ្ឋានដោយវាចា មាន ២ យ៉ាងគឺ នៅក្នុងហត្ថបាស ១ ក្រៅហត្ថ-*

បាស ១ ។ បើបាត្រនៅក្នុងហត្ថបាស គប្បីបញ្ចេញវាចាថា **ឥមំ បត្តំ អធិដ្ឋামិ** *។ បើនៅខាងក្នុងលែង ឬលើប្រាសាទ ឬនៅក្នុងវិហារធ្វាយ សោត គប្បីកំណត់ទីតាំងហើយបញ្ចេញវាចាថា* **ឯតំ បត្តំ អធិដ្ឋামិ** *។ កាលនឹងអធិដ្ឋាន សូម្បីនឹងអធិដ្ឋានម្នាក់ឯងក៏គួរ ឬនឹងអធិដ្ឋានក្នុងសំណាក់នៃភិក្ខុដទៃក៏គួរ ។ ឯអធិដ្ឋានក្នុងសំណាក់នៃភិក្ខុដទៃ មានអានិសង្សដូច្នេះ បើសង្ស័យថា យើងអធិដ្ឋានហើយឬនៅ កើតឡើងដល់ភិក្ខុនោះសោត នោះភិក្ខុដទៃនឹងជួយរំឭកកាត់សេចក្តីសង្ស័យឲ្យបាន ។ បើភិក្ខុមួយអង្គបានបាត្រមក ១០ ភិក្ខុនោះ ប្រាថ្នានឹងបរិភោគឲ្យអស់ទាំង ១០ សោត កុំគប្បីអធិដ្ឋានឲ្យអស់ទាំង ១០ គប្បីអធិដ្ឋានបាត្រមួយឡើងម្តង ហើយត្រឹកឡើងទៀត គប្បីបច្ចុទ្ធរបាត្រនោះចេញទៅ អធិដ្ឋានបាត្រដទៃឡើងទៀត ដោយឧបាយដូច្នេះ អាចនឹងបរិហាររក្សាបានសូម្បីអស់មួយរយឆ្នាំក៏បាន ។*

វិធីអធិដ្ឋានបាត្រ ចប់

វិធីវិកប្បចាត្រ

ឯវិធីវិកប្បបាត្រនោះ មាន ២ យ៉ាងគឺ វិកប្បក្នុងទីចំពោះមុខ ១ កំបាំងមុខ ១ ដូចវិកប្បចីវរដែរ ។

វិកប្បចំពោះមុខទី ១ បើបាត្រមួយនៅជិតថា **ឥមំ បត្តំ តុយ្ហं វិកប្បេមិ** *។ បើបាត្រច្រើននៅជិតថា* **ឥមេ បត្តេ តុយ្ហं វិកប្បេមិ** *។*

*វិកប្ប*ចំពោះមុខទី ២ *បើ*វិកប្ប*នឹ*ងសហ*ធ*ម្មិ*ក*ទាំ*ង ៥ *ណ*ាមួ*យ* *ค*ប្ប*ី* *ចេ*ញ*ឈ*្ម*ោ*ះ*ส*ห*ธ*ម្ម*ិ*ก*នោ*ះ* *ដ*ូ*ច*វ*ិ*ก*ป*្ป*នឹ*ง*ภ*ิ*ก*្ខ*ុ*ឈ*្ម*ោ*ះ*ติ*ส*្ส*:*ថ*ា* **ส**ํ **ป**ตฺ**ต**ํ **ติ**ส**ฺส**ส **ภ**ิ**ก**ฺ**ขุ**ํ **ว**ิ**ก**ป**เ**ป**มิ** ។

វិ*ก*ป*្ป*ก*ំ*ពុ*ំ*ង*ម*ុ*ข*ថ*ា* **ส**ํ **ป**ตฺ**ต**ํ **ต**ุ**ย**ฺ**ห**ํ **ว**ิ**ก**ป**ฺป**ะ**ต**ฺ**ถา**ย **ฉ**ํ**ท**ิ ។ *អ*្*ก*ក*ជ*ួ*យ*ទ*ទ*ួ*ล*វ*ិ*ก*ป*្ป*ค*ป*្ป*ី*ส*ួ*រ*ម*្*ห*ា*ส*់*ป*ា*ต*្*ร*ថ*ា* *វ*ិ*ก*ป*្ป*នឹ*ง*ណ*ោ*ก* *ណ*ា? *អ*្*ก*ក*ម*្*ห*ា*ส*់*ป*ា*ต*្*ร* *ค*ป*្ป*ី*ป*្*ร*ា*ป*់*ឈ*្*ม*ោ*ះ*ส*ห*ธ*ม*្*ม*ิ*ก*ទ*ាំ*ง ៥ *ณ*ាមួ*យ* *ต*ាម*ค*ា*ป*់*จ*ิ*ต*្*ต*ร*ป*ស*់*ข*្*ข*ួ*ន* *ដ*ូ*ច*ឈ*ោ*ះ*ติ*ส*្ส*:*ជ*ា*ដ*ើ*ម* ។ *អ*្*ก*ក*ជ*ួ*យ*ទ*ទ*ួ*ล* *វ*ិ*ก*ป*្ป* *ค*ป*្ป*ី*យ*ក*ป*ា*ต*្*ร*ទ*ៅ*វ*ិ*ก*ป*្ป*នឹ*ง*ណ*ោ*ก*ติ*ส*្ส*:*ន*ោ*ះ* *ห*ើ*យ*ป*្ร*ា*ป*់*ม*្*ห*ា*ส*់* *ป*ា*ต*្*ร*ថ*ា* **อ**ํ**ห**ํ **ติ**ส**ฺส**ส **ภ**ิ**ก**ฺ**ขุ**ํ **ฉ**ํ**ท**ิ ។ *វ*ิ*ก*ป*្ป*ห*ើ*យ* *ន*ឹ*ง*ទ*ុ*ก*ก*៏*ค*ួ*រ* *ป*ើ*ป*ว*ิ*ภ*ោ*ค*ជ*ា*ដ*ើ*ม*ម*ิ*ន*ค*ួ*រ* *ล*ុ*ះ*ต*ែ*ដ*ก*វ*ิ*ก*ป*្ป*ห*ើ*យ*ដ*ូ*ច*ป*ា* น* *ពោ*ล*ก*ុ*ง*ว*ិ*ธ*ី*ដ*ก*ส*ំ*ต*ត់ *ท*ើ*ป*ค*ួ*ร*ป*ว*ิ*ภ*ោ*ค*ជ*ា*ដ*ើ*ม*ป*ា*น ។ *ឯ*ន*ៅ*ជ*ិ*ต*ឬ*ន*ៅ* *ឆ*្*ง*ាយ *ป*ា*ต*្*ร*ម*ួ*យ *ឬ*ป*ា*ต*្*ร*ច*្*ร*ើ*ន* *ន*ឹ*ง*ឈ*ោ*ះ*ន*ៃ*ส*ห*ธ*ม*្*ม*ิ*ก* *ค*្*ร*ូ*ว*ផ*្*ទ*ា*ส*់*ด*ូ*ច* *ពោ*ล*ห*ើ*យ*ก*ុ*ง*ช*ี*ว*ร*ន*ោ*ះ*ចុ*ះ ។

<u>*ว*ิ*ธ*ី*ว*ิ*ก*ป*្ป*ป*ា*ต*្*ร* * จ*ប់</u>

สេ*จ*ក*្ដ*ី*ป*្*ร*ែ*អ*ំ*ព*ី*ว*ិ*ธ*ី*ม*ា*น*ព*ិ*ន*្*ទ*ុ*ជ*ា*ด*ើ*ม*

สํ **พ**ิ**น**ฺ**ทุ**ํ **ก**ะ**โร**ม**ิ** *ป*្*ร*ែ*ថ*ា *យ*ើ*ง*ធ*្*វ*ើ*ว*ង*់*ម*ូ*ล*ដ*៏*ค*ួ*ร*ន*េ*ះ ។

สํ **จ**ี**ว**ร**ํ ป**ะ**จ**ุ**ท**ฺ**ท**ะ**ม**ิ *ป*្*ร*ែ*ថ*ា *យ*ើ*ง*ដ*ក*ន*ូ*ว*จ*ี*ว*ร*ន*េ*ះ ។

สํ **ป**ตฺ**ต**ํ **ป**ะ**จ**ุ**ท**ฺ**ท**ะ**ม**ิ *ป*្*ร*ែ*ថ*ា *យ*ើ*ง*ដ*ក*ន*ូ*ว*ป*ा*ต*្*ร*ន*េ*ះ ។

ឥមំ សង្ឆាដឺ អធិដ្ឋាមិ *ប្រែថា យើងតាំងទុកនូវសង្ឆាដនេះ ។*

ឥមំ បត្តំ អធិដ្ឋាមិ *ប្រែថា យើងតាំងទុកនូវបាត្រនេះ ។*

ឥមំ ចីវរំ បរិក្ខារចោលំ អធិដ្ឋាមិ *ប្រែថា យើងតាំងទុកនូវសំពត់នេះ ជាកំណាត់សំពត់បរិក្ខារ ។*

ឥមំ ចីវរំ តុយ្ហំ វិកប្បេមិ *ប្រែថា ខ្ញុំកំណត់ពិសេសទុកនូវសំពត់នេះដល់លោក ។*

ឥមំ បត្តំ តុយ្ហំ វិកប្បេមិ *ប្រែថា ខ្ញុំកំណត់ពិសេសទុកនូវបាត្រនេះដល់លោក ។*

ឥមំ ចីវរំ តិស្សស្ស ភិក្ខុនោ វិកប្បេមិ *ប្រែថា ខ្ញុំកំណត់ពិសេសទុកនូវចីវរនេះដល់តិស្សភិក្ខុ ។*

ឥមំ បត្តំ តិស្សស្ស ភិក្ខុនោ វិកប្បេមិ *ប្រែថា ខ្ញុំកំណត់ពិសេសទុកនូវបាត្រនេះដល់តិស្សភិក្ខុ ។*

ឥមំ ចីវរំ តុយ្ហំ វិកប្បនត្ថាយ ឧម្មុ *ប្រែថា ខ្ញុំឲ្យនូវសំពត់នេះដល់លោក ដើម្បីវិកប្ប (កំណត់ពិសេសទុក) ។*

ឥមំ បត្តំ តុយ្ហំ វិកប្បនត្ថាយ ឧម្មុ *ប្រែថា ខ្ញុំឲ្យនូវបាត្រនេះដល់លោក ដើម្បីវិកប្ប (កំណត់ពិសេសទុក) ។*

អហំ តិស្សស្ស ភិក្ខុនោ ឧម្មុ *ប្រែថា ខ្ញុំឲ្យដល់តិស្សភិក្ខុ ។*

មយ្ហं សន្តកं បរិភុញ្ជ ภ วิสเชฐหิ ภ យថាបច្ចយं ภ **ก**ោ**ห**ិ *ប្រែថា លោកចូរបរិភោគ ឬចូរលះបង់ ឬចូរធ្វើតាមហេតុ នូវវត្ថុជារបស់នៃខ្ញុំ ។*

ติสฺสสฺส ภิกฺขุโน สนฺตกํ **ปริภุญฺช ภ วิสเชฐ-หิ ภ** **ยถาปจฺจยํ ภ กโรหิ** *ប្រែថា លោកចូរបរិភោគ ឬចូរលះបង់ ឬចូរធ្វើតាមហេតុ នូវវត្ថុជារបស់នៃតិស្សភិក្ខុ ។*

មួយទៀត ក្នុងពាក្យដកបាត្រ ចីវរនេះ គួរប្រកបឈ្មោះសំពត់ ឈ្មោះបាត្រចូលផងថា

ឥមํ ចีวรํ **มยฺหํ สนฺตกํ** **ปริภุญฺช ภ วิสเชฐหิ ภ** **ยถาปจฺจยํ ภ กโรหิ** ។

ឥมํ ចีวรํ **ติสฺสสฺส ภิกฺขุโน สนฺตกํ** **ปริภุญฺช ภ** **วิสเชฐหิ ภ ยถาปจฺจยํ ภ กโรหิ** ។

ឥมํ **ปตฺตํ** **มยฺหํ สนฺตกํ** **ปริภุญฺช ภ วิสเชฐหิ ภ** **ยถาปจฺจยํ ภ กโรหิ** ។

ឥมํ **ปตฺตํ** **ติสฺสสฺส ภิกฺขุโน สนฺตกํ** **ปริภุญฺช ภ** **วิสเชฐหิ ภ ยถาปจฺจยํ ภ กโรหิ** ។

បើសំពត់ច្រើនថា **ឥมานิ ចีวรานิ มยฺหํ สนฺตกานิ** **ปริภุญฺช ภ ฯ ล ฯ กโรหิ** ។

បើបាត្រច្រើនថា **ឥមេ បត្តេ មយ្ហំ សន្តកេ បរិភុញ្ជ ភ ។ ល ។ ភ្ជេមិ ។**

បើអ្នកដកវិកប្បខ្ជីវិស្សាជាង់ម្ចាស់របស់ គប្បីពោលដោយពហុវចៈ-ន:ថា... **បរិភុញ្ជថ ភ វិសជ្ជេថ ភ យថាបច្ចយំ ភ ភ្ជេថ ។**

មួយទៀត នឹងពោលតែបទថា **បរិភុញ្ជ** *ឬ* **បរិភុញ្ជថ, វិស-ជ្ជេមិ** *ឬ* **វិសជ្ជេថ, យថាបច្ចយំ ភ ភ្ជេមិ** *ឬ* **យថា-បច្ចយំ ភ ភ្ជេថ** *បទណាមួយក៏បាន ។*

មួយទៀត ការវិកប្បចីវរនិងបាត្រដល់សហធម្មិកទាំង ៥ នោះណា មួយ បើសហធម្មិកអ្នកទទួលវិកប្បនោះជាមនុស្សស្និទ្ធស្នាលនឹងគ្នា នឹងកាន់យកដោយសេចក្តីស្និទ្ធស្នាលក្នុងទីចំពោះមុខឬកំពាំងមុខក៏គួរ ។

ពិន្ទ្វាធិដ្ឋានាទិបញ្ច:គម្រប់ ៥ ចប់

វិជ្ជមានាទិបញ្ច: គម្រប់ ៦

វិជ្ជមានកថា

ពោលអំពីវិធីដាច់អធិដ្ឋាន ។ ចីវរដែលភិក្ខុអធិដ្ឋានដោយឈ្មោះដូចពោលហើយនោះ នឹងដាច់អធិដ្ឋានដោយហេតុ ៩ ប្រការគឺ **អញ្ញ-ស្ស** *ជានេន ឲ្យដល់អ្នកដទៃ ១* **អច្ឆិន្ទិត្វា** *ឬ* **ឧ**ហ**ណេ**ន *ចោ*

ដណ្តើមយកទៅ ១ **វិស្ស្ជាសកាហេន** មិត្រសម្ងាញ់កាន់យកទៅ ដោយវិស្សាស: ១ **ហីនាយាវត្តនេន** ត្រឡប់ទៅដើម្បីជាមនុស្ស ថោកទាប ១ **សិក្ខាបច្ចក្ខានេន** លាសិក្ខា ១ **កាលកិរិយាយ** ធ្វើកាលកិរិយាស្លាប់ទៅ ១ **លិង្គ្គបរិវត្តនេន** ភេទត្រឡប់ គឺ ភេទបុរសត្រឡប់ជាស្ត្រី ភេទស្ត្រីត្រឡប់ជាបុរស ១ **បច្ចុទ្ធរណេន** ដកអធិដ្ឋាន ១ **ឆិទ្ធកាវេន** ធ្ទុះប្រហោង ១ ត្រូវជា ៩ ប្រការ ។ ក្នុងវិមតិវិនោទនីពោលថា ខដែលថាត្រឡប់ទៅដើម្បីជាមនុស្សថោក ទាបនោះ សំដៅយកភិក្ខុត្រូវបារាជិក ហើយស្ថិតនៅក្នុងភិក្ខុបដិញ្ញា ហើយទៅកាន់ភេទគ្រហស្ថក្តី ឬទៅកាន់លទ្ធិតិរ្ថិយ ជាតិត្ថិយបក្កន្ត:ក្តី និងនាងភិក្ខុនីអស់សេចក្តីប្រាថ្នា ក្នុងភេទជាភិក្ខុនី ទៅកាន់ភេទគ្រហស្ថក្តី ឈ្មោះថាត្រឡប់ទៅដើម្បីជាមនុស្សថោកទាប ។ អាចារ្យខ្ទះពោលថា សំដៅយកមិនបានលាសិក្ខាបទទៅជាគ្រហស្ថ ឈ្មោះថាត្រឡប់ទៅ ដើម្បីជាមនុស្សថោកទាប ។ លោកជំទាស់ថា ពាក្យអាចារ្យនោះ មិនត្រឹមត្រូវទេ ព្រោះថា សូម្បីទៅកាន់ភេទជាគ្រហស្ថដូច្នេះ កាលអ្នក នោះនៅជាឧបសម្ប្ទនៅឡើយ ចីវរនោះនៅមិនបានលះនូវភាព ជា របស់អ្នកនោះ ។ ឯចីវរទាំងពួង ដាច់អធិដ្ឋានដោយហេតុ ៨ ប្រការ ខាងដើម តែដាច់អធិដ្ឋាន ដោយធ្ទុះប្រហោងនោះ ក្នុងអដ្ឋកថាទាំងពួង លោកពោលចំពោះត្រៃចីវរមួយយ៉ាងប៉ុណ្ណោះ ។ ក៏ឯធ្ទុះប្រហោងនោះ ប្រមាណប៉ុនខ្នងក្រចកកូនដៃ ប្រហោងនោះ គឺ ធ្ទុះដាច់ ទើបដាច់

អធិដ្ឋាន ។ ដ្ឋិតថាក្នុងចន្ទោះប្រហោងនោះ បើអម្ពោះ សូម្បីមួយ សរសៃ នៅមិនទាន់ដាច់ទេ ក៏គង់នៅរក្សាបាននៅឡើយ ។ សង្ឆ្ការ ដ និងឧត្តរាសង្ខ: ដានវែងអំពីទីបំផុតជាយចូលទៅ ប្រមាណមួយចំអាម ដានទទឹងអំពីទីបំផុតជាយចូលទៅប្រមាណ ៨ ធ្នាប់ ធ្ទុះប្រហោងខាងក្នុង កំណត់នោះចូលទៅ ទើបដាច់អធិដ្ឋាន ។ ឯអន្តរវាសក:នោះ ដានវែងអំពីទីបំផុតជាយចូលទៅ ប្រមាណមួយចំអាមដានទទឹងអំពីទីបំផុត ជាយចូលទៅ ប្រមាណ ៤ ធ្នាប់ ធ្ទុះប្រហោងខាងក្នុងកំណត់នោះចូល ទៅ ទើបដាច់អធិដ្ឋាន ក្រៅនោះចេញមកក្នុងទីកំណត់ មិនបានដាច់ អធិដ្ឋាន ។ ព្រោះហេតុនោះ កាលបើធ្ទុះប្រហោងហើយ ចីវរនោះរមែង តាំងនៅក្នុងទីជាអតិរេកចីវរ គប្បីធ្វើសូចិកម្ម៖ជុលសិន ហើយអធិដ្ឋាន ឡើងជាថ្មីចុះ (ក្នុងខាងក្នុង ១០ ថ្ងៃ) ។ ភិក្ខុណាមានចីវរចាស់គ្រាំគ្រា យកសំពត់មក៖ជុលមុនហើយ ទើបកាត់សំពត់ចាស់ចេញជាក្រោយ ចីវរ នោះមិនដាច់អធិដ្ឋាន សូម្បីក្នុងការផ្ទាស់ប្តូរសំពត់មណ្ឌលក៏ដូចគ្នាដែរ ។ ចីវរពីរជាន់ធ្ទុះមួយជាន់ ឬថាឃ្លាតលឿនមួយជាន់ ក៏មិនដាច់អធិដ្ឋាន ។ ធ្វើចីវរតូចឲ្យជាចីវរធំ ឬធ្វើចីវរធំឲ្យជាចីវរតូច ក៏មិនដាច់អធិដ្ឋាន ។ កាលបើនឹងផ្ញើញចីវរឲ្យជាយជាប់គ្នា បើកាត់មុនទើបផ្ញើញតចូលខាង ក្រោយសោត ក៏ដាច់អធិដ្ឋាន ។ ថាបើផ្ញើញតគ្នាមុនសិនហើយ ទើបកាត់ ខាងក្រោយសោត មិនដាច់អធិដ្ឋាន សូម្បីឲ្យជាងគេគក់លាងធ្វើឲ្យសទៅ អធិដ្ឋានក៏គង់ជាអធិដ្ឋាននៅដូចដែល ។ សូម្បីបាត្រដែលអធិដ្ឋានទុក

ហើយ ក៏ដាច់អធិដ្ឋាន ដោយហេតុ ៩ ប្រការដូចគ្នា តែធ្នុះប្រហោង នោះធំប៉ុនគ្រាប់ផ្ដៅចូលចេញបាន ទើបដាច់អធិដ្ឋាន ព្រោះថាធញ្ញជាតិ ទាំង ៧ ប្រការ គ្រាប់ផ្ដៅនេះជាយ៉ាងតូច ប្រហោងធ្នុះនោះ កាលបើ បិទដោយកម្ទេចដែក ឬព្រមរហើយ គប្បីអធិដ្ឋានទៀត ក្នុងខាង ក្នុង ១០ ថ្ងៃចុះ ។

វិជហនកថា ចប់

ទានាទិកថា

ពោលអំពីការឲ្យនិងការកាន់យកជាដើម ។ ដូចម្ដេចឈ្មោះថា ការឲ្យ? ដូចម្ដេចឈ្មោះថាការកាន់យក?

អ្នកឲ្យពោលថា យើងឲ្យវត្ថុនេះដល់លោក ឬយើងប្រគល់ឲ្យ ឬយើងបរិច្ចាគ យើងលះវត្ថុនេះ ឲ្យដល់លោក ក្នុងទីចំពោះមុខ ។ ពោលថា យើងឲ្យ ឬយើងប្រគល់ឲ្យ ឬយើងបរិច្ចាគ យើងលះវត្ថុនេះ ឲ្យដល់បុគ្គលឈ្មោះនេះ ក្នុងទីកំបាំងមុខ ដូច្នេះជាការឲ្យពិត ។ អ្នកឲ្យ ពោលថា លោកចូរកាន់យកដើម្បីខ្លួនលោកចុះ អ្នកទទួលពោលថា ខ្ញុំកាន់យកដើម្បីខ្លួនខ្ញុំដូច្នេះ (អ្នកឲ្យក៏ឲ្យដោយបច្ចុប្បន្នកាល អ្នក ទទួលក៏កាន់យកដោយបច្ចុប្បន្នកាល) ឈ្មោះថាឲ្យ (និងកាន់យក) ដោយប្រពៃ ។ អ្នកឲ្យពោលថា លោកចូរទទួលវត្ថុនេះធ្វើជារបស់

លោកចុះ ឬពោលថាវត្ថុនេះ ចូរជារបស់លោកចុះ ឬពោលថា លោកនឹងធ្វើវត្ថុនេះឲ្យជារបស់លោក អ្នកទទួលពោលថា ខ្ញុំធ្វើវត្ថុនេះ ឲ្យជារបស់ខ្ញុំ ឬពោលថាវត្ថុនេះ ចូរជារបស់ខ្ញុំ ឬពោលថាខ្ញុំនឹងធ្វើ វត្ថុនេះឲ្យជារបស់ខ្ញុំ ដូច្នេះឈ្មោះថាឲ្យ និងកាន់យកមិនប្រពៃ ព្រោះអ្នក ឲ្យមិនចេះឲ្យ អ្នកទទួលមិនចេះទទួល (គឺឲ្យនិងទទួលខុសចាកបច្ចុប្បន្ន-កាល) ។ តែបើអ្នកឲ្យពោលថា លោកចូរធ្វើវត្ថុនេះ ឲ្យជារបស់លោកចុះ អ្នកទទួលពោលថាប្រពៃហើយ ខ្ញុំកាន់យកដើម្បីខ្លួនខ្ញុំ ដូច្នេះ ឈ្មោះ ថាឲ្យមិនប្រពៃ កាន់យកប្រពៃ ។ បើអ្នកទទួលម្នាក់ពោលថាលោក ចូរកាន់យកចុះ អ្នកម្នាក់ទៀតពោលថាខ្ញុំមិនកាន់យកទេ អ្នកឲ្យត្រឡប់ ពោលទៀតថា យើងឲ្យហើយ លោកចូរកាន់យកដើម្បីខ្លួនលោកចុះ សូម្បីអ្នកទទួលពោលថា ខ្ញុំមិនត្រូវការដោយវត្ថុនេះទេ សូម្បីអ្នកឲ្យមុន ក៏សម្គាល់ថាយើងឲ្យទៅគេហើយ និងឲ្យអតិរេកចីវរនោះកន្ទង ១០ ថ្ងៃទៅ សូម្បីអ្នកទទួលក៏សម្គាល់ថា យើងហាមឃាត់គេហើយ ដូច្នេះ មិនត្រូវ អាបត្តិដល់អ្នកណាមួយឡើយ ព្រោះថាអ្នកណាចូលចិត្ត អ្នកនោះក៏គប្បី អធិដ្ឋានឡើងបរិភោគ ។ ក្នុងអដ្ឋកថានៃចីវរាច្ឆិន្ទនសិក្ខាបទពោលថា ឲ្យចីវរ ដល់ភិក្ខុដោយពាក្យថា យើងឲ្យដល់លោកដែលកាន់យកឧបជ្ឈាយ៍ក្នុង សំណាក់យើង យើងមិនឲ្យដល់លោកដែលកាន់យកឧបជ្ឈាយ៍ក្នុងទីដទៃ យើងឲ្យដល់អ្នកធ្វើវត្តក្នុងសំណាក់យើងមួយជំពូក យើងមិនឲ្យដល់អ្នកមិន ធ្វើវត្តក្នុងសំណាក់យើងទេ យើងឲ្យដល់អ្នករៀនធម៌ក្នុងសំណាក់យើង

ប៉ុណ្ណោះ យើងមិនឲ្យដល់អ្នកមិនរៀនធម៌ក្នុងសំណាក់យើងទេ យើងឲ្យដល់អ្នកមិនលាសិក្ខាប៉ុណ្ណោះ យើងមិនឲ្យដល់អ្នកដែលនឹងលាសិក្ខាឲ្យដូច្នេះ មិនគួរ កាលបើឲ្យដូច្នេះ ត្រូវទុក្កដ តែនឹងឲ្យយកត្រឡប់មកវិញក៏គួរ ។ កាលបើត្រឡប់ដណ្តើមកាន់យកចីវរដែលលះឲ្យដាច់ហើយ ឲ្យវិន័យធរគប្បីកាត់តាមតម្លៃកណ្ណៈ ។

ខមួយ ព្រះអង្គទ្រង់អនុញ្ញាតដល់ភិក្ខុ ឲ្យកាន់យកដោយវិស្សាសៈ ព្រមដោយអង្គ ៥ គឺ **សន្ធិដ្ឋោ ច ហោតិ** ជាមិត្របានឃើញគ្នាមក ១ **សម្ភត្តោ ច ហោតិ** ជាមិត្រមាំមួនធ្លាប់បរិភោគជាមួយគ្នាមក ១ **អាលបិតោ ច** បាននិយាយគ្នាទុកថា ទ្រព្យរបស់យើង បើលោកចង់បានរបស់អ្វី គប្បីកាន់យកនូវរបស់នោះចុះ ១ **ជីវតិ ច** មានជីវិតរស់នៅ ១ **តហិតេ អត្តមនោ ហោតិ** ដឹងថាយើងកាន់យកហើយ ហើយត្រេកអរ ១ ។ ក្នុងអដ្ឋកថា ថាវិស្សាសៈរមែងឡើងដោយអង្គ ៣ គឺ មិត្រធ្លាប់ឃើញ មិត្រធ្លាប់ស៊ី និងមិត្រដែលផ្តាំទុកថា ចង់បានរបស់អ្វីគប្បីកាន់យករបស់នោះ ទាំង ៣ ពួកនេះណាមួយ ចាត់ជាអង្គ ១ កំពុងរស់នៅជាអង្គ ១ កាន់យកហើយត្រេកអរជាអង្គ ១ ។

ខមួយទៀត ព្រះអង្គទ្រង់អនុញ្ញាត ឲ្យកាន់យកដោយវិស្សាសៈ ដូច្នេះថា ភិក្ខុផ្ញើចីវរទៅក្នុងដៃនៃភិក្ខុ ផ្តាំថាលោកចូរឲ្យចីវរនេះ ដល់ភិក្ខុឈ្មោះនេះ អ្នកទទួលទៅ ទៅដល់កណ្តាលផ្ទះកាន់យកដោយវិស្សាសៈនៃអ្នកផ្ញើ ឈ្មោះថាកាន់យកដោយប្រពៃ ម្ចាស់របស់ផ្ញើទៅភិក្ខុណា

*កាន់យកដោយវិស្សាសៈនៃភិក្ខុនោះ ឈ្មោះថាកាន់យកមិនប្រពៃ ថាបើ
បានព័ត៌មានកណ្ដាលផ្លូវថា ភិក្ខុអ្នកផ្ញើទៅនោះដល់អនិច្ចធម្មទៅហើយ
នឹងអធិដ្ឋានយកជាចីវរមត៌កនៃភិក្ខុនោះ ឈ្មោះថាអធិដ្ឋានដោយប្រពៃ
បើកាន់យកដោយវិស្សាសៈ នៃភិក្ខុដែលម្ចាស់របស់ផ្ញើទៅឲ្យ ឈ្មោះ
ថាកាន់យកមិនប្រពៃ ថាបើបានឮថាផ្ញើទៅដល់ភិក្ខុណា ភិក្ខុនោះដល់
នូវអនិច្ចធម្មហើយ នឹងអធិដ្ឋានយកជាចីវរមត៌កនៃភិក្ខុនោះ ឈ្មោះថា
អធិដ្ឋានយកមិនប្រពៃ បើកាន់យកដោយវិស្សាសៈនៃអ្នកផ្ញើទៅ ឈ្មោះ
ថាកាន់យកដោយប្រពៃ បើបានឮថាអ្នកទាំងពីរនាក់ អនិច្ចធម្មទៅ
ហើយ នឹងអធិដ្ឋានយកជាចីវរមត៌កនៃភិក្ខុអ្នកផ្ញើទៅនោះ ឈ្មោះថាអធិ-
ដ្ឋានយកដោយប្រពៃ ផ្ញើទៅដើម្បីភិក្ខុណា អធិដ្ឋានយកជាចីវរមត៌កនៃ
ភិក្ខុនោះ ឈ្មោះថាអធិដ្ឋានយកមិនប្រពៃ ។ មួយទៀត ភិក្ខុផ្ញើចីវរទៅ
ក្នុងដៃនៃភិក្ខុ ថាយើងឲ្យចីវរនោះដល់ភិក្ខុឈ្មោះនេះ ភិក្ខុទទួលទៅ ទៅ
ដល់កណ្ដាលផ្លូវ កាន់យកដោយវិស្សាសៈនៃភិក្ខុអ្នកផ្ញើ ឈ្មោះថាកាន់
យកមិនប្រពៃ ផ្ញើទៅដើម្បីភិក្ខុណា កាន់យកដោយវិស្សាសៈនៃភិក្ខុនោះ
ឈ្មោះថាកាន់យកដោយប្រពៃ ថាបើបានឮថា ភិក្ខុអ្នកផ្ញើ ឬភិក្ខុដែល
ត្រូវបាន ដល់នូវអនិច្ចធម្ម ឬដល់នូវអនិច្ចធម្មទាំងពីរនាក់ក្តី ថាបើកាន់
យកដោយវិស្សាសៈរបស់ភិក្ខុដែលត្រូវបាន ឬអធិដ្ឋានយកជាចីវរមត៌កនៃ
ភិក្ខុដែលត្រូវបានឈ្មោះថាកាន់យកដោយប្រពៃ អធិដ្ឋានយកដោយប្រពៃ
ថាបើកាន់យកដោយវិស្សាសៈ នៃភិក្ខុដែលផ្ញើទៅ ឬអធិដ្ឋានយកជា*

ចីវរមត់ករបស់ភិក្ខុអ្នកផ្ញើ ឈ្មោះថាកាន់យកមិនប្រពៃ អធិដ្ឋានយកមិនប្រពៃ ។

ទានាទិកថា ចប់

បដិគ្គហណកថា

ពោលអំពីការទទួលប្រគេន ។ ការប្រគេនប្រកបដោយអង្គ ៥ ទើបឡើងគឺ **ថាមមជ្ឈិមស្ស បុរិសស្ស ឧច្ចារណមត្តំ ហោតិ** *របស់ល្មមមជ្ឈិមបុរសលើកឡើងបាន ១* **ហត្ថបាសោ បញ្ញាយតិ** *ហត្ថបាសប្រាកដ ១* **អភិហារោ បញ្ញាយតិ** *បង្ហោនចូលមកចំពោះប្រាកដ ១* **ទេវោ វ មនុស្សោ វ តិរច្ឆានគតោ វ កាយេន វ កាយបដិពន្ធេន វ និស្សគ្គិយេន វ ទេតិ** *ទេវតា ឬមនុស្ស ឬសត្វតិរច្ឆាន ឲ្យដោយកាយ ឬវត្ថុជាប់ដោយកាយ ឬបោះឲ្យ ១* **តំ បន ភិក្ខុ កាយេន វ កាយបដិពន្ធេន វ បដិគ្គណ្ហាតិ** *ភិក្ខុទទួលរបស់នោះ ដោយកាយ ឬវត្ថុជាប់ដោយកាយ ១ ទទួលប្រគេនព្រមដោយអង្គ ៥ នេះ ទើបឡើង ។ ក៏ឯហត្ថបាសកំណត់ត្រឹម ២ ហត្ថ ១ ចំអាម នឹងដេកទទួល ឬឈរ អង្គុយទទួលក្តី គប្បីឲ្យបាន ២ ហត្ថ ១ ចំអាមទើបគួរ រៀរលែងតែដៃដែលលូកហុចទៅទទួល និងដៃដែល*

គេហុចមកឲ្យ មិនរាប់បញ្ចូលក្នុងហត្ថបាស គប្បីដឹងដោយន័យដូចពោលហើយក្នុងបឋមបារាជិកាសិក្ខាបទនោះចុះ បើអ្នកឲ្យ ឬអ្នកទទួលម្នាក់នៅលើអាកាស ម្នាក់នៅលើផែនដី គប្បីកំណត់ប្រមាណហត្ថបាសដោយ ក្បាល នៃអ្នកឈរនៅលើផែនដី ដោយទីបំផុតខាងក្នុងនៃអវយវ:ដ៏ជិតនៃអ្នកឈរនៅលើអាកាស រៀរតែដៃដែលនឹងលូកចេញទៅ ដើម្បីនឹងប្រ-គេន និងទទួល ឲ្យបាន ២ ហត្ថ ១ ចំអាមថាបើអ្នកម្នាក់នៅក្នុងអណ្ដូង និងម្នាក់នៅលើអណ្ដូង ឬអ្នកម្នាក់នៅលើដើមឈើ ម្នាក់ឈរលើផែនដី ក៏គប្បីកំណត់ប្រមាណហត្ថបាស ដោយន័យដូចពោលហើយនោះចុះ ។ ឈរនៅក្នុងហត្ថបាសដូច្នេះហើយ បើជាសត្វបក្សីឲ្យដោយចំពុះ មាត់ ឬដំរីកាន់យកដោយប្រមោយឲ្យផ្ការឈើ ឬផ្លែឈើ ទទួលប្រគេន ក៏ឡើង ថាបើអង្គុយលើកដំរី សូម្បីខ្ពស់រៀង ៧ ហត្ថមួយចំអាមទទួលរបស់ដែលដំរីនោះប្រគេនដោយប្រមោយក៏គួរពិត ។ បើទាយកម្នាក់យកភាជន:បាយនិងម្ហូបតម្រួតគ្នា ទូលលើក្បាលមកឈរជិតភិក្ខុ ប្រាប់ឲ្យភិក្ខុទទួលយក ការបង្ហោនមកមិនទាន់ប្រាកដជាមុន ព្រោះហេតុនោះ កុំគប្បីទទួលឡើយ ថាបើគេបង្ហោនមកសូម្បីបន្ដិច ភិក្ខុគប្បីលូកដៃទៅចាប់ភាជន:ខាងក្រោម សូម្បីប្រទេសមួយប៉ុណ្ណោះ ភាជន:ទាំងពួងឈ្មោះថាទទួលប្រគេនទាំងអស់ តទៅនឹងឲ្យគេដាក់ចុះ ឬបើកឡើងប្រាជ្ញាវត្ថុណា នឹងចាប់យកវត្ថុនោះក៏គួរ ។ ឯក្នុងភាជន:ជាមួយជាដើមថាកញ្ជើបាយមិនចាំបាច់ពោលឡើយ សូម្បីគេរៃកបាយមកបើគេបង្ហោន

អម្រែកមកឲ្យ នឹងទទួលក៏គួរ សូម្បីឫស្សីវែង ៣០ ហត្ថ ខាងម្ខាងចងធ្នាំង ទឹកអំពៅ ខាងម្ខាងចងធ្នាំងសប្ដិ បើទទួលដងវែកនោះ របស់ទាំងពួង ឈ្មោះថាទទួលទាំងអស់ ។ គេប្រាប់ឲ្យទទួលទឹកអំពៅដែលហូរចេញចាក ឃ្នាប ការបង្ហោនចូលមកចំពោះមិនប្រាកដ ព្រោះហេតុនោះ កុំគប្បីទទួល បើគេរើសកាកចោលចេញ យកដែសន្សឹមក្ឍង់ឲ្យក៏គួរ បាត្រច្រើនផង គ្នា តម្កល់ទុកលើគ្រែ ឬតាំង ឬកន្ទេល ឬស្នាច ឬផែនក្ដារ ភិក្ខុនៅលើ ទីណា ទាយកនៅក្នុងហត្ថបាស នៅលើទីនោះ ឈរ ឬអង្គុយ ឬដេកក្ដី គិតនឹងទទួល យកម្រាមដៃពាល់គ្រែជាដើម របស់ណាគេចាក់ចុះក្នុង បាត្រអម្បាលនោះ របស់ទាំងពួងនោះ ឈ្មោះថាទទួលប្រគេនទាំងអស់ ថាបើគិតនឹងទទួលក្រោកឡើងអង្គុយលើគ្រែជាដើមក៏គួរពិត ។ ថាបើបាត្រ តាំងនៅលើផែនដី ក្ដេងនិងក្ដេងប្រកិតជិតជាប់គ្នាសោត ភិក្ខុអង្គុយ យកម្រាមដៃ ឬម្ជុល ឬវត្ថុណាមួយ ពាល់ត្រូវបាត្រណាៗ របស់គេ ឲ្យក្នុងបាត្រនោះៗ ឈ្មោះថាជារបស់ទទួលប្រគេន លោកពោលទុកថា ក្នុងបាត្រដែលតាំងនៅលើគ្រឿងកម្រាល មានកន្ទេលដ៏ធំ និងគ្រឿង កម្រាលលើខ្នងដំរីជាដើមណាមួយ ទទួលប្រគេនមិនឡើង ពាក្យនោះគប្បី ដឹងថាលោកពោលទុកព្រោះអាស្រ័យកន្ទងហត្ថបាស ពោលទុកតែកាល បានហត្ថបាស ទទួលក្នុងគ្រឿងកម្រាលណាមួយរមែងគួរ រ៉ៀរតែរបស់កើត ក្នុងទីនោះ ។ ឯរបស់កើតក្នុងទីនោះ ដូចស្ងឹកឈូកឬស្ងឹកចារជាដើម យក មកវងទទួលមិនគួរ ដ្ឋិតពោលថា របស់នោះមិនរាប់ថាជារបស់ជាប់

ដោយកាយ ក៏ឯរបស់កើតក្នុងទីនោះយ៉ាងណា ក្នុងគ្រែជាដើម ដែលគេចងភ្ជាប់ទុកនឹងបង្គោល ឬក្តារ ឬថ្មដែលលើកមិនរួច យកមកវងទទួលក៏មិនឡើងដូច្នោះ ព្រោះថាគ្រែជាដើមនោះ ក៏សង្ខេបថាជារបស់កើតក្នុងទីនោះ សូម្បីស្ទឹកអម្ពិលជាដើមដែលតូច យកមកក្រាលលើផែនដីនឹងទទួលប្រគេនក៏មិនឡើង ព្រោះថាស្ទឹកនោះមិនអាចនឹងទ្ទ្ររបស់បានទទួលឡើងតែនឹងស្ទឹកឈូកជាដើមដែលធំ ។ ថាបើគេឈរនៅក្រៅហត្ថ-បាស យកបោយដងវែងដួសហុចចូលមកឲ្យ គប្បីពោលនឹងគេឲ្យចូលមកជិត គេមិនបានឮ ឬមិនបានអើពើឡើយ គេចាក់ចុះក្នុងបាត្រ គប្បីទទួលប្រគេនជាថ្មី ។ គេឈរនៅឆ្ងាយ ចោះដុំបាយចូលមកក៏ដូចគ្នា ។ ថាបើនាំបាត្រចេញអំពីថង់បាត្រ លម្អិតគ្រឿងជ្រលក់ធ្លាក់ចុះក្នុងបាត្រសោត កាលបើទឹកមានគប្បីលាងចេញ កាលបើមិនមានគប្បីជូតលម្អិតនោះចេញ ឬទទួលប្រគេនទៀតជាមុនហើយទើបទៅបិណ្ឌបាត ។ ថាបើដើរទៅបិណ្ឌ-បាតធូលីធ្លាក់ចុះសោត គប្បីទទួលប្រគេនបាត្រទៀតហើយទើបទទួលភិក្ខ: កាលបើមិនបានទទួលប្រគេនបាត្រ ទៅទទួលភិក្ខ:ត្រូវវិនយទុក្កដ តែកាលបើទទួលប្រគេនរបស់នោះទៀតហើយធាន់ មិនត្រូវអាបត្តិ កាលបើពឹងគេឲ្យប្រគេនគេមិនឮ ឬគេមិនបានអើពើនឹងពាក្យខំឲ្យភិក្ខ:សោត មិនត្រូវវិនយទុក្កដ គួរគប្បីទទួលជាថ្មីហើយសូមទទួលភិក្ខ:ដទៃចុះ ។ ថាបើខ្យល់ព្យុះបក់ធូលីមកអំពីទីនោះ។ មិនអាចនឹងទទួលភិក្ខ:បាន មានចិត្តបរិសុទ្ធចង់ចិត្តថា នឹងយកទៅឲ្យអនុបសម្បន្នហើយទទួលក៏គួរ ។ ដើរ

ទៅបិណ្ឌបាតហើយត្រឡប់ទៅវិហារឬរោងធាន់ ឲ្យរបស់នោះដាច់ដល់អនុបសម្បន្នហើយ អនុបសម្បន្នត្រឡប់ឲ្យមកវិញ ឬនឹងកាន់យកដោយវិស្សាស:នៃអនុបសម្បន្នហើយបរិភោគក៏គួរ ។ ថាបើភិក្ខុឲ្យបាត្រព្រមទាំងបាយដែលធូលីធ្លាក់ក្នុងវេលាដើរទៅបិណ្ឌបាតដល់ភិក្ខុផងគ្នា គប្បីប្រាប់ភិក្ខុថា លោកគប្បីទទួលប្រគេនជាថ្មីទៀត កាន់យកនូវភិក្ខ:ចុះ ឬធាន់ចុះ ភិក្ខុនោះក៏គប្បីធ្វើតាមដូច្នោះ ។ ថាបើធូលីធ្លាក់ចុះអណ្តែតនៅខាងលើ គប្បីសម្រិតទឹកខាងលើចេញ ដែលសល់នៅនោះគប្បីធាន់ចុះ ។ ថាបើធូលីចូលចុះទៅខាងក្នុងសោត គប្បីទទួលប្រគេនទៀត ។ កាលបើអនុបសម្បន្នមិនមាន កុំលែងឲ្យផុតអំពីដៃ គប្បីនាំទៅកាន់ទីដែលមានអនុបសម្បន្នឲ្យប្រគេនទៀត ។ ធូលីធ្លាក់ចុះក្នុងបាយនឹងនាំធូលីចេញហើយធាន់ក៏គួរ ។ ថាបើធូលីល្អិតណាស់គប្បីនាំចេញទាំងបាយខាងលើ ឬគប្បីទទួលប្រគេនទៀតហើយធាន់ចុះ ។ កាលបើគេយកបបរឬសម្ង ត្រមល់អំពីមុខនៃខ្ជូនគេកូរមានពពុះខ្ចាត់ចាកភាជន:មកធ្លាក់ចុះក្នុងបាត្រ គប្បីទទួលប្រគេនបាត្រទៀត ។ កាលបើយកបោយដួសចូលមកប្រគេន ពពុះស្រក់អំពីបោយធ្លាក់ចុះក្នុងបាត្រមុន ឈ្មោះថាធ្លាក់ចុះដោយប្រពៃ មិនមានទោស ព្រោះគេបង្ហោនចូលមកចំពោះហើយ ថាបើគេយកបាយព្រមទាំងចង្ក្រានបង្ហោនចូលមក ធ្យូងឬផេះធ្លាក់ចុះក្នុងបាត្រមិនមានទោស ព្រោះគេបង្ហោនចូលមកជិតហើយ ។ កាលបើប្រគេនភិក្ខុនៅក្នុងលំដាប់ របស់ខ្ចាត់ចេញចាកបាត្រទៅធ្លាក់ចុះក្នុងបាត្រនៃភិក្ខុដទៃ ឈ្មោះថាធ្លាក់ចុះដោយប្រពៃ

ជាកិរិយាទទួលពិត ។ ថាបើគេពុះត្រាវនិងត្រឡាចជាដើមឲ្យដល់ភិក្ខុមួយអង្គ ចំណិតកម្ទេចខ្ចាត់ទៅធ្លាក់ចុះក្នុងបាត្រនៃភិក្ខុដទៃ គប្បីទទួលប្រគេនបាត្រទៀត ។ គេពុះលើបាត្រភិក្ខុណា កាលបើចំណិតតូចធ្លាក់ចុះក្នុងបាត្រនៃភិក្ខុនោះមិនមានទោស ព្រោះគេបង្ហោនចូលទៅដើម្បីនឹងឲ្យហើយ ទាយកគេយកបាត្រដ៏ពេញដោយបាយបាយាសមកប្រគេន ភិក្ខុមិនអាចនឹងចាប់ខាងក្រោមបាន ព្រោះកំពុងក្តៅ នឹងចាប់សូម្បីក្នុងកណ្តាប់ មាត់បាត្រក៏គួរពិត ថាបើមិនអាចនឹងចាប់កណ្តាប់មាត់បាត្របានក៏គប្បីយកជើងបាត្រងទទួល ។ ភិក្ខុកាន់បាត្រអង្គុយនៅក្នុងរោងធាន់ហើយលក់ទៅ គេបង្ហោនរបស់ចូលមកក៏មិនដឹង គេឲ្យក៏មិនដឹង មិនមែនជាការទទួលប្រគេន ។ ថាបើចង់ចិត្តទុកថា នឹងទទួលហើយអង្គុយនៅសោតក៏គួរ ។ ថាបើភិក្ខុអង្គុយលៃងដៃចាកជើងបាត្រ យកជើងជាន់ទុកអង្គុយលក់ទៅសោត ជាការទទួលប្រគេនពិត តែយកជើងជាន់ជើងបាត្រទទួល សូម្បីដល់ភ្ញាក់ឡើងក៏ឈ្មោះថាជាការទទួលដោយមិនអើពើ ព្រោះហេតុនោះ កុំគប្បីធ្វើ ។ អាចារ្យទាំងឡាយជំពូកខ្ទះពោលថា ទទួលដោយជើងបាត្រដូច្នោះ ឈ្មោះថាទទួលដោយរបស់ជាប់ជាមួយនឹងរបស់ដែលជាប់ដោយកាយ ព្រោះហេតុនោះមិនគួរ ។ ពាក្យអាចារ្យអម្បាលនោះគ្រាន់តែជាពាក្យពោលប៉ុណ្ណោះ តែថាដោយសេចក្តីរបស់ទាំងពួងនោះឈ្មោះថាជារបស់ជាប់ដោយកាយពិត សូម្បីក្នុងកាយ-សំសគ្គលោកក៏សម្តែងន័យដូច្នោះ សូម្បីរបស់ណាមួយគេប្រគេនដល់ភិក្ខុ

ហើយធ្លាក់ចុះ នឹងរើសយករបស់នោះខ្លួនឯងធាន់ក็គួរ ។ ព្រោះព្រះអង្គ
ទ្រង់អនុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ យំ ឧិយមានំ បតតិ
តំ សាមំ ឧហេត្វា បរិភុញ្ជិតុំ ។ ល ។ ឧាយកេហីតិ**
ម្នាលភិក្ខុទាំងឡាយរបស់ណាកាលបើគេឲ្យហើយធ្លាក់ចុះ គប្បីកាន់យក
ដោយខ្លួនឯងធាន់ចុះ ព្រោះរបស់នោះទាយកគេលះហើយ ។ ក็ឯសូត្ર
នេះជានេយ្យត្ថ: ព្រោះហេតុនោះ គប្បីដឹងអធិប្បាយក្នុងសូត្រដូច្នេះថា
របស់ណាគេឲ្យ របួតអំពីដៃទាយកធ្លាក់ចុះលើផែនដីដែលស្អាត ឬលើ
ស្ទឹកឈូកនិងសំពត់ និងកន្ទេលជាដើម នឹងរើសខ្លួនឯងនូវរបស់នោះធាន់
ក็គួរ តែរបស់ណាធ្លាក់ចុះលើផែនដីដែលមានធូលី របស់នោះគប្បីជូត
ឬលាងចេញ ឬឲ្យគេប្រគេនទៀតហើយធាន់ចុះ ។ ថាបើរបស់នោះរមៀល
ទៅជិតភិក្ខុដទៃ សូម្បីនឹងឲ្យភិក្ខុដទៃនោះរើសមកឲ្យក็គួរ ។ ថាបើប្រាប់
ឲ្យភិក្ខុដទៃនោះធាន់ សូម្បីភិក្ខុដទៃនោះនឹងធាន់ក็គួរ តែភិក្ខុដទៃនោះម្ចាស់
របស់មិនបានបង្គាប់កុំគប្បីកាន់យក សូម្បីម្ចាស់របស់មិនបានបង្គាប់នឹងកាន់
យកដោយគិតនឹងឲ្យដល់ម្ចាស់របស់ក็គួរពិត ពាក្យនេះពោលទុកក្នុងកុរុន្ទី
ក็ឯភិក្ខុដទៃកាន់យករបស់នោះ មិនគួរ ព្រោះព្រះអង្គមិនទ្រង់អនុញ្ញាត
ដ្បិតព្រះអង្គពោលទុកថា ឲ្យកាន់យកធាន់ខ្លួនឯងនេះ គឺថាអនុញ្ញាតថា
របស់ធាន់នោះគេឲ្យដល់ភិក្ខុណាហើយធ្លាក់ចុះ សូម្បីមិនបានប្រគេន ភិក្ខុ
នោះកាន់យកធាន់បាន ក็តែដោយពាក្យថារបស់នោះទាយកគេលះហើយ
នេះសម្តែងថា របស់នោះនៅជារបស់អ្នកដទៃនៅឡើយ ព្រោះហេតុ

នោះ ភិក្ខុដទៃកាន់យកធាន់ខ្លួនឯងមិនគួរ តែនឹងកាន់យកធាន់ដោយ បង្គាប់នៃភិក្ខុម្ចាស់របស់នោះក៏គួរ បានឮថានេះឯងជាពាក្យអធិប្បាយក្នុង សូត្រនេះ ។ ក៏ឯរបស់នោះព្រះអង្គទ្រង់អនុញ្ញាតព្រោះមិនបានទទួល ប្រគេន ព្រោះហេតុដូច្នោះ របស់នោះតម្កល់នៅដូចម្តេចមិនបានពាល់ ត្រូវឡើយ យកវត្ថុណាមួយគ្របបិទទុក សូម្បីក្នុងថ្ងៃគម្រប់ ២ នឹងធាន់ក៏គួរ មិនត្រូវអាបត្តិព្រោះសន្និធិ តែគប្បីទទួលប្រគេនហើយធាន់ចុះ ។ ដ្បិត ថាព្រះអង្គអនុញ្ញាត ឲ្យភិក្ខុនោះកាន់យកធាន់ដោយខ្លួនឯងតែក្នុងថ្ងៃនោះ ប៉ុណ្ណោះ ខាងមុខអំពីថ្ងៃនោះទៅ មិនអនុញ្ញាត បានឮថាពាក្យដូច្នេះ ក៏ជាអធិប្បាយក្នុងសូត្រនេះ ។

អំពីនេះនឹងពោលអំពីអញ្ញហារិកន័យ កាលបើធាន់ ធ្មេញនិងក្រចក និងស្ម៉ែមនៃបាត្រសឹករេចអស់ទៅ របស់ទាំងពួងជាអញ្ញហារិកទាំងអស់ កាលបើយកកាំបិតមុតលួសអំពៅ ស្ម៉ែមក៏ប្រាកដនៅ ស្ម៉ែមនោះឈ្មោះ ថាកើតឡើងថ្មី គប្បីទទួលប្រគេនហើយធាន់ ។ កាលបើសំលៀងកាំបិត ហើយទើបលួស ស្ម៉ែមមិនប្រាកដ គ្រាន់តែធុំក្ងិនប៉ុណ្ណោះ របស់នោះ ជាអញ្ញហារិក សូម្បីអំពៅដែលលួសដោយកាំបិតដែលកាន់យករក្សា ទុកក៏ដូចគ្នា ព្រោះថាមិនបានរក្សាកាំបិតទុកដើម្បីនឹងបរិភោគ ។ កាល បើកិនឬបុកថ្នាំឫសឈើជាដើម ថ្មនិងកូនថ្មកិន ឬត្បាល់ ឬអង្ក្រែសឹករិល ទៅអស់ក្តី ឬយកកាំបិតដែលរក្សាទុកពោលភ្ជើងជ្រលក់ក្នុងខ្ចាញ់ និង ទឹកដោះស្រស់ ដើម្បីនឹងឲ្យជាថ្នាំក្តី បើពណ៌ខៀវប្រាកដក្នុងរបស់នោះ

វិនិច្ឆ័យដូចពោលហើយក្នុងកាំបិតលួសអំពៅ តែខ្ញាញ់ជាដើម ដែលជារបស់ពៅ កុំគប្បីដាក់កាំបិតនោះចុះដោយខ្លួនឯង ថាបើដាក់ចុះដោយខ្លួនឯងមិនរួចអំពីសាមបក្ក: ។ កាលទៅបិណ្ឌបាតក្នុងពេលកំពុងភ្លៀងទឹកភ្លៀងហូរអំពីខ្លួន ឬចីវរ ស្រក់ចុះទៅក្នុងបាត្រ គប្បីទទួលប្រគេនបាត្រ សូម្បីកំពុងធាន់ក្រោមម្ទប់ឈើជាដើម ទឹកភ្លៀងធ្លាក់ចុះក៏ដូចគ្នា ។ បើភ្លៀងធ្លាក់៧ថ្ងៃ ទឹកភ្លៀងថ្លា ឬទឹកភ្លៀងធ្លាក់អំពីអាកាសដ៏គួរ ។ កាលនឹងឲ្យបាយដល់សាមណេរ កុំគប្បីពាល់ត្រូវរបស់នៅក្នុងបាត្រនៃសាម-ណេរនោះឡើយ ឬគប្បីទទួលប្រគេនបាត្រនៃសាមណេរសិន ព្រោះថាពាល់ត្រូវបាយក្នុងបាត្រដែលមិនបានប្រគេនហើយ មកកាន់យកបាយក្នុងបាត្រនៃខ្លួនទៀត បាយដែលជាប់មកនោះជាឧគ្គហិត បើប្រាថ្នានឹងឲ្យហើយពោលថា ម្នាលសាមណេរ អ្នកចូរយកបាត្រមកទទួលយកបាយចុះ ចំណែកខាងសាមណេរក៏ឃាត់ថាល្មមហើយ សូម្បីភិក្ខុនឹងពោលទៀតថា របស់យើងលះដល់អ្នកហើយ សាមណេរពោលថាខ្ញុំមិនត្រូវការ សូម្បីនឹងលះដល់មួយរយដង របស់នោះក៏គង់នៅក្នុងដៃរបស់ខ្លួន ក៏គង់ជារបស់ប្រគេននៅដោយពិត ថាបើបាត្រតាំងទុកលើជើងបាត្រមិនមានអាល័យ ប្រាប់ឲ្យសាមណេរកាន់យកហើយ គប្បីទទួលប្រគេនជាថ្មី ថាបើមានអាល័យតាំងទុកលើជើងបាត្រ ប្រាប់ដល់សាមណេរថា ម្នាលសាមណេរ អ្នកចូរកាន់យកនំ ឬបាយអំពីបាត្រនោះ សាមណេរលាងដៃហើយកាន់យកសូម្បីមួយរយដង ថាបើដាក់ចុះក្នុងបាត្រខ្លួន

ដៃមិនបានពាល់បាយក្នុងបាត្រខ្លួនឡើយ កិច្ចដែលនឹងទទួលប្រគេនទៀតមិនមាន ថាបើពាល់បាយក្នុងបាត្រខ្លួនហើយ មកកាន់យកបាយអំពីបាត្រភិក្ខុនោះ បាយនោះក៏ច្រឡំដោយបាយរបស់សាមណេរ គប្បីទទួលប្រគេនជាថ្មីទៀត តែអាចារ្យទាំងឡាយជំពូកខ្ទះពោលថា បើសូម្បីបាយដែលសាមណេរកាន់យកដាច់ ហើយធ្លាក់ចុះក្នុងបាត្ររបស់ភិក្ខុ គប្បីទទួលប្រគេនជាថ្មី ពាក្យនោះគប្បីដឹងក្នុងរបស់ដែលភិក្ខុកំណត់ថា អ្នកចូរកាន់យកដុំបាយមួយដុំ អ្នកចូរកាន់យកនំមួយ ចូរកាន់យកក្នុងប្រទេសប៉ុណ្ណោះនៃដុំស្ករនេះដូច្នេះ តែក្នុងពាក្យមុននេះ មិនមានកំណត់ ព្រោះហេតុនោះ របស់ណាធ្លាក់ចុះក្នុងបាត្រនៃសាមណេរ របស់នោះគង់ដាច់ប្រគេន តែរបស់ដែលនៅក្នុងដៃសាមណេរ សាមណេរមិនបានពោលថាលួមហើយ ឬភិក្ខុមិនទាន់ឃាត់ចេញដរាបណា របស់នោះនៅជារបស់ភិក្ខុនៅឡើយ ព្រោះហេតុនោះ មិនដាច់ប្រគេន ។ ថាបើចាក់បាយចុះក្នុងធ្នាំងបបរនៃខ្លួនឬភិក្ខុដទៃ ដើម្បីដណ្តាំ គប្បីនិយាយនឹងសាម-ណេរឲ្យយកដៃទទួលទុកលើមាត់ធ្នាំង ហើយដាក់ចុះក្នុងដៃសាមណេរនោះ បាយនោះធ្លាក់ចុះចាកដៃសាមណេរ ធ្លាក់ចុះក្នុងធ្នាំងបាយនោះមិនធ្វើធ្នាំងឲ្យជាអកប្បិយទៅក្នុងថ្ងៃគម្រប់ ២ ព្រោះថាលះហើយ ថាបើមិនធ្វើដូច្នេះដាក់ចុះទេ គប្បីធ្វើធ្នាំងឲ្យប្រាសចាកអាមិសដូចបាត្រ បរិភោគចុះ ។ ទាយកទាំងឡាយគេតម្កល់ធ្នាំងបបរទុកហើយចេញទៅ សាមណេរមិនអាចនឹងលើកធ្នាំងនោះឡើងប្រគេនបាន ភិក្ខុផ្ទៀងបាត្រចូលទៅ សាម-

ណេរផ្ទៀងមាត់ឆ្នាំងចុះលើមាត់បាត្រសម្រិតចុះ បបរដែលជ្ងាក់ចុះក្នុងបាត្រ ជាការប្រគេនដោយពិត ។

ម្យ៉ាងទៀត ភិក្ខុដាក់ដៃចុះលើផែនដី សាមណេររំកិលឆ្នាំងឲ្យឡើងលើ ដៃនោះក៏គួរ ។ សូម្បីក្នុងកញ្ជើបាយ បាច់អំពៅ ក៏ដូចគ្នាយ៉ាងនោះ ថា បើបាច់អំពៅល្មមមជ្ឈិមបុរសម្នាក់លើកប្រគេនបាន សាមណេរពីរនាក់ បីនាក់ជួយលើកគ្នាប្រគេន ឬម្នាក់ឯងមានកម្លាំងលើករួច ភិក្ខុពីរអង្គ បីអង្គ ជួយទទួលគ្នាក៏គួរ ។ យកឆ្នាំងប្រេងឬឆ្នាំងទឹកអំពៅព្ជរទុកនឹងជើងគ្រែ ឬ ជើងតាំង ភិក្ខុឡើងអង្គុយលើគ្រែនិងតាំងក៏គួរ មិនជាឧគ្គហិត ។ ឆ្នាំងពីរ តម្រួតគ្នាព្ជរនឹងដៃកែវឬទំពក់ ឆ្នាំងខាងលើទទួលប្រគេនហើយ ឆ្នាំង ក្រោមមិនបានទទួលប្រគេន នឹងកាន់យកឆ្នាំងខាងលើក៏គួរ ។ ឆ្នាំងខាង ក្រោមទទួលប្រគេនហើយ ឆ្នាំងខាងលើមិនបានទទួលប្រគេន កាលបើ លើកឆ្នាំងខាងលើឡើងកាន់យកឆ្នាំងខាងក្រោម ឆ្នាំងលើក៏ជាឧគ្គហិត ។ ភាជនៈដាក់ប្រេងមិនបានទទួលប្រគេននៅក្រោមគ្រែ ថាបើបោសទៅ យកអំបោសខ្ជាំងខ្ជប់ភាជនៈនោះមិនជាឧគ្គហិត ។ គិតនឹងកាន់យក របស់ដែលទទួលប្រគេនហើយ ទៅចាប់យករបស់ដែលមិនបានទទួល ប្រគេន ដឹងហើយត្រឡប់តម្កល់ទុកក្នុងទីដូចដើមវិញ មិនជាឧគ្គហិត ។ នាំចេញទៅខាងក្រៅហើយទើបដឹង កុំគប្បីតម្កល់ទុកខាងក្រៅ គប្បីនាំ មកតម្កល់ទុកក្នុងទីដើម មិនមានទោសឡើយ ។ ថាបើរបស់នោះគេបើក គ្របមុនហើយតម្កល់ទុក ក៏កុំគប្បីគ្របចុះ កាលដើមតាំងទុកយ៉ាងណា

គប្បីតាំងទុកយ៉ាងនោះ ថាបើតាំងទុកខាងក្រៅកុំគប្បីពាល់ត្រូវទៀត ។ ថាបើនាំយកចុះមកខាងក្រោមប្រាសាទ ដល់ពាក់កណ្តាលជណ្តើរទើបដឹងព្រោះមិនមានឱកាស គប្បីនាំទៅខាងលើឬខាងក្រោម តាំងទុកចុះមិនជាឧគ្គហិត ។ ផ្សិតកើតឡើងក្នុងប្រេងដែលទទួលប្រគេនទុកហើយ លម្អិតខ្ចូតកើតឡើងក្នុងខ្ទីជាដើមដែលទទួលប្រគេនហើយ របស់នោះឈ្មោះថាកើតឡើងក្នុងទីនោះឯង កិច្ចដែលទទួលប្រគេនទៀតមិនមាន មនុស្សឡើងទៅលើដើមត្នោតឬដើមដូង យកខ្សែចងធ្វាយសម្រួតចុះមក មនុស្សដែលនៅលើស្រែកប្រាប់ឲ្យទទួលយកកុំគប្បីទទួល ថាបើមនុស្សដទៃនៅលើផែនដីគេកាន់ក្រវ៉ាលខ្សែលើកប្រគេនឲ្យក៏គួរ ។ ឲ្យគេធ្វើកប្ដិយមែកឈើធំដែលមានផ្លែហើយទទួលប្រគេន ផ្លែឈើទាំងឡាយជារបស់ទទួលប្រគេនដោយពិត នឹងបរិភោគតាមសប្បាយក៏គួរ ។ មនុស្សឈរនៅខាងក្នុងរបងដែលធ្ងុះប្រហោង លូកដៃចេញទៅប្រគេនអំពៅឬទន្ទាប់ កាលបើបានហត្ថបាសហើយនឹងទទួលក៏គួរ របស់នោះមិនបានទង្គិចនឹងបង្គោលរបងចេញទៅ កាលបើទទួលយកក៏គួរ ក្នុងរបស់ដែលខ្ជាំងខ្ជប់នឹងរបងចេញទៅ លោកមិនបានសម្ដែងទោសទុកក្នុងអដ្ឋកថាទាំងឡាយ តែយើងទាំងឡាយពិចារណាឃើញថា របស់នោះខ្ជាំងខ្ជប់នឹងទីណា មើលទៅដូចជារបស់ធ្លាក់ចុះឯងចាកទីនោះ សូម្បីពាក្យនោះកាលបើរបស់នោះមិនឈប់លឿនទៅក៏ត្រឹមត្រូវ ដូចយ៉ាងកណ្ហៈដែលរមៀលចេញទៅខាងក្រៅផ្ទះគេ មនុស្សបោះរបស់រំលងរបងឬកំពែងមកឲ្យ ថាបើកំពែងមិន

បានក្រាល កាលបើឈរនៅក្នុងកំពែងឬក្រៅកំពែងល្មមបានហត្ថបាស
របស់នោះអណ្តែតឡើងទៅសូម្បីមួយរយហត្ថធ្លាក់ចូលមកដល់ នឹងទទួល
យកក៏គួរ ។ ភិក្ខុបញ្ជិះសាមណេរលើស្មាទៅ សាមណេរឃើញផលាផល
ក៏បេះ អង្គុយនៅលើស្មានោះហុចឲ្យក៏គួរ សាមណេរបញ្ជិះភិក្ខុទៅ
ប្រគេនរបស់ឲ្យដល់ភិក្ខុអង្គុយនៅលើស្មាក៏គួរពិត ។ ភិក្ខុកាន់មែកឈើមាន
ផ្លែដើម្បីជាឆត្រដើរទៅ ចិត្តចង់នឹងធាន់ផ្លែឈើនោះ នឹងឲ្យគេប្រគេន
ហើយធាន់ក៏គួរ ឲ្យគេធ្វើកប្បិយហើយទទួលប្រគេនមែកឈើដើម្បីបក់រុយ
បើចង់ធាន់សោត ទទួលប្រគេនមុននោះក៏គួរ កាលធាន់មិនមានទោស ។
ភិក្ខុតម្កល់របស់គួរប្រគេន ក្នុងរវេងនៃមនុស្សហើយដើរផ្លូវទៅ រវេងជាប់
ភក់ ភិក្ខុចាប់កង់រវេងលើកឡើងក៏គួរ មិនឈ្មោះថាឧគ្គហិត ។ តម្កល់
របស់ទុកក្នុងទូក ដោលទូកទៅឬអូសទៅដោយដៃក៏គួរ សូម្បីក្នុងក្បូន
ក្នុងផែក៏ដូចគ្នា សូម្បីនឹងយករបស់ទុកក្នុងពាង ឬឌីទិន ឬក្នុងថ្ងាងហើយ
ឲ្យអនុបសម្បន្នកាន់ភាជនៈនោះ ហើយចាប់ដើមដៃ អនុបសម្បន្ននាំធ្វង
ទឹកទៅក៏គួរ ។ សូម្បីកាលបើភាជនៈនោះមិនមាន នឹងឲ្យអនុបសម្បន្ន
កាន់របស់នោះ ហើយចាប់ដើមដៃអនុបសម្បន្ននាំធ្វងទឹកទៅក៏គួរ ។
ឧបាសកទាំងឡាយ ប្រគេនអង្ករជាស្បៀងដល់ភិក្ខុដើរផ្លូវ សាមណេរ
កាន់យកអង្ករនៃភិក្ខុហើយ មិនអាចកាន់យកនូវអង្កររបស់ខ្លួនទៅបាន ភិក្ខុ
ទាំងឡាយកាន់យកអង្ករនៃសាមណេរទៅ សាមណេរទាំងឡាយ កាល
បើអង្ករដែលខ្លួនកាន់យកទៅអស់ហើយ យកអង្ករដែលភិក្ខុកាន់ទៅដណ្តាំ

ឡើងហើយ យកបាត្រនៃភិក្ខុនិងបាត្រនៃខ្លួនតម្កល់ទុកដោយលំដាប់ហើយ ដួសបបរដាក់ចុះ សាមណេរជាមនុស្សឈ្វាសយកបាត្ររបស់ខ្លួនប្រគេនដល់ព្រះមហាថេរ យកបាត្រមហាថេរប្រគេនដល់អនុថេរ ផ្ទាស់ប្តូរដូច្នេះ រៀងរាបដរាបដល់អស់ទៅ ភិក្ខុទាំងពួងឈ្មោះថាធាន់វត្ថុជារបស់សាម-ណេរគួរ បើសាមណេរមិនឈ្វាស ប្រារព្ធនឹងធាន់នូវបបរក្នុងបាត្ររបស់ខ្លួន ព្រះថេរទាំងឡាយនឹងសូមថាអ្នកចូរឲ្យបបររបស់អ្នកដល់យើងដូច្នេះ ដោយលំដាប់ហើយធាន់ក៏គួរ ភិក្ខុទាំងពួងឈ្មោះថាធាន់វត្ថុជារបស់សាម-ណេរនោះឯង មិនត្រូវទោស ព្រោះឧគ្គហិត មិនត្រូវទោសព្រោះ សន្និធិ ។ ឯក្នុងទីនេះភិក្ខុយករបស់មានប្រេងជាដើមទៅដើម្បីឲ្យដល់ មាតាបិតា នឹងកាន់យកមែកឈើទៅដើម្បីនឹងធ្វើឆត្រជាដើម ជាមួយ នឹងភិក្ខុដែលកាន់អង្ករសាមណេរទៅនោះ ឃើញដូចមិនប្លែកគ្នា ព្រោះ ហេតុនោះ គប្បីពិចារណាមើលហេតុចុះ ។ សាមណេរប្រាថ្នានឹងដណ្តាំ បាយហើយលើកឆ្នាំងឡើង ភិក្ខុគប្បីទទួលប្រគេនអង្ករ និងឆ្នាំងហើយ ច្រកអង្ករ លើកឆ្នាំងឡើងតម្កល់លើចង្ក្រាន កុំបង្ក្រាត់ភ្លើង កាលបើឆ្អិន ហើយ គប្បីបើកឡើងមើលឲ្យដឹងថាឆ្អិនហើយឬនៅ ថាបើមិនទាន់ឆ្អិនទេ នឹងគ្របចុះដើម្បីឲ្យឆ្អិនមិនគួរ បើគ្របចុះដើម្បីមិនឲ្យធ្លាយ ឬផេះធ្លាក់ ចុះក៏គួរ កាលបើឆ្អិនហើយនឹងដាក់ចុះហើយនឹងធាន់ក៏គួរ តទៅកិច្ចដែល នឹងប្រគេនទៀតមិនមាន ។ សាមណេរអាចនឹងចម្អិនបាន តែគ្មានឱកាស ទំនេរដោយប្រាថ្នានឹងទៅទីណាមួយ ភិក្ខុគប្បីនិយាយថា អ្នកចូរប្រគេន

ឆ្នាំងទាំងអង្ករនិងទឹកសិន ហើយលើកឆ្នាំងដាក់លើចង្ក្រាន បង្ហាត់ភ្លើងឲ្យ
ឆេះ ហើយទៅចុះដូច្នេះ តទៅភិក្ខុធ្វើកិច្ចទាំងពួងដោយន័យដូចមុនក៏គួរ ។
ភិក្ខុត្រូវការដោយបបរ លើកឆ្នាំងដែលលាងស្អាតឡើងដាក់លើចង្ក្រាន
ហើយដាំទឹកឲ្យក្តៅក៏គួរ កាលបើទឹកក្តៅហើយ សាមណេរច្រកអង្ករចុះ
តែតពីនោះទៅ ភិក្ខុកុំគប្បីបង្ហាត់ភ្លើង បបរឆ្អិនហើយនឹងទទួលប្រគេន
ធាន់ក៏គួរ ។ សាមណេរកំពុងបបរ ភិក្ខុរពឹសដៃ យកដៃស្ទាបឆ្នាំង
ស្ទាបគ្របឆ្នាំង គៀរពពុះ ដែលពោរឡើងលេង ភិក្ខុនោះនឹងធាន់មិនគួរ
ឈ្មោះថាទុរុបចិណ្ណសន្ធ្ងាអាក្រក់ ។ ថាបើកាន់ដៃក ឬបោយ មិនលើកឡើង
គ្រាន់តែកូរសោត មិនគួរដល់ភិក្ខុទាំងពួង ព្រោះជាសាមបក្ក:ផង ជា
ទុរុបចិណ្ណ:ផង ថាបើលើកឡើងចេញសោតជាឧគ្គហិតផង ។ ភិក្ខុដើរ
ទៅបិណ្ឌបាត មកហើយយកបាត្រមកតម្កល់ទុកលើដើងបាត្រ របស់
នោះដាច់ប្រគេនហើយ ថាបើភិក្ខុរឡេះរឡោះ លូកដៃទៅស្ទាបបាត្រ
ស្ទាបគ្របបាត្រលេងសោត បាយដែលបានមកក្នុងបាត្រនោះ មិនគួរ
ដល់ភិក្ខុនោះតែមួយអង្គ ថាបើភិក្ខុនោះលើកបាត្រឡើងហើយដាក់ចុះវិញ
បាយនោះមិនគួរដល់ភិក្ខុទាំងពួង ។ ភិក្ខុចាប់មែកឈើ ឬវល្លិ មានផ្លែ
ដែលកើតនៅក្នុងទីនោះ អង្ច្រួនឲ្យរញ្ជួយ ផ្លែឈើដែលបានមកអំពីអង្ច្រួន
ដើមនោះ មិនគួរដល់ភិក្ខុតែមួយអង្គ ត្រូវទុរុបចិណ្ណទុក្ខដផង និងផ្ទែក
ឬចាប់ពាល់ត្រូវដើមឈើដែលមានផ្លែ ឬបន្ទា ក្នុងដើមឈើនោះ ក៏គួរ
មិនត្រូវទុរុបចិណ្ណ ពាក្យនេះពោលទុកក្នុងមហាបច្ចរី ភិក្ខុឃើញផ្លែ

ស្វាយជាដើមជ្រុះចុះក្នុងព្រៃ គិតនឹងឲ្យដល់សាមណេរ នាំយកមកឲ្យ ក៏គួរ ឃើញសាច់ជាអំពាវាជសីហ៍ជាដើម គិតនឹងឲ្យដល់សាមណេរ នឹងទទួលប្រគេន ឬមិនទទួលប្រគេនក្តី យកមកឲ្យក៏គួរ ថាបើអាចនឹង ជម្រះវិតក្កបានសោត សូម្បីនឹងធាន់របស់ដែលបានមកអំពីសំណល់នោះ ក៏គួរ មិនត្រូវទោសព្រោះទទួលសាច់ស្រស់ និងមិនត្រូវទោស ព្រោះ ឧគ្គហិត កាលបើកាន់យកប្រេងជាដើមដើរទៅ ដើម្បីនឹងឲ្យដល់មាតា បិតា ព្យាធិបង្កើតឡើងកណ្តាលផ្លូវ របស់អម្បាលនោះខ្ជូនប្រាថ្នារបស់ ណានឹងទទួលប្រគេនរបស់នោះបរិភោគក៏គួរ តែបើទទួលទុកហើយអំពី ដើម កិច្ចដែលនឹងទទួលទៀតមិនមាន ។ ប្រាថ្នានឹងឲ្យដល់មាតាបិតានាំ អង្ករនោះទៅ កាលបើឲ្យទៅហើយ មាតាបិតាតាក់តែងបបរជាដើម ដោយអង្ករនោះ ប្រគេនដល់ភិក្ខុនោះក៏គួរ មិនត្រូវទោសព្រោះសន្និធិ ឬឧគ្គហិត ។ ភិក្ខុគ្របមាត់ធ្នាំងហើយដាំទឹកក្តៅ នឹងធាន់ទៅត្រាតែអស់ ក៏គួរ ថាបើផេះធ្លាក់ចុះក្នុងទឹកនោះគប្បីទទួលប្រគេនទៀត យកដំបៀត រ៉ែងត្បៀតភាជនរំងាស់ប្រេង ផេះធ្លាក់ចុះកុំលែងដែចេញ រំងាស់ហើយ គប្បីដាក់ចុះ ហើយទទួលប្រគេនទៀតចុះ ថាបើធ្ងងឬខ្ស ទទួលប្រ-គេនទុកហើយសោត ទទួលប្រគេននោះក៏គួរ ។ ភិក្ខុកំពុងធាន់អំពៅ សាមណេរសូមអំពៅភិក្ខុប្រាប់ឲ្យកាត់យកប្ររ៉ែងណោះ សាមណេរក៏ កាត់យកតាមបង្គាប់ ដែលសល់នៅនោះ កិច្ចដែលនឹងឲ្យប្រគេនទៀតមិន មាន ។ សូម្បីភិក្ខុកំពុងធាន់ស្ករអំពៅក៏ដូចគ្នាយ៉ាងនោះ ព្រោះថារបស់

ដែលសល់នៅ ចាកចំណែកដែលអនុបសម្បន្នកាន់យកអំពីឱកាសដែលភិក្ខុប្រាប់ឲ្យនោះ មិនដាច់ប្រគេនពិត ។ ភិក្ខុចែកដុំស្ករអំពៅទទួលប្រគេនហើយចាត់ជាចំណែកៗទុក ភិក្ខុខ្លះសាមណេរខ្លះមកទទួលចំណែក សាម-ណេរនោះ មកកាន់យកចំណែកមួយៗ ចាប់តែម្តងហើយទៅ ចំណែកដែលសល់នៅនោះជារបស់ទទួលប្រគេននៅពិត ។ ថាបើសាមណេររឡេះ-រឡោះកាន់យកហើយដាក់ចុះវិញ ចំណែកដែលសាមណេរកាន់យកសល់នៅនោះដាច់ប្រគេន ។ ភិក្ខុទទួលបារីមកជក់ មាត់នឹងកជាប់ផ្សែងដូចមនោសិលា ថាបើនឹងធាន់យាវកាលិកក៏គួរ នឹងមានទោសព្រោះច្រឡំយាវជីវិកជាមួយនឹងយាវកាលិក មិនមាន ។ កាលបើដុតបាត្រ ឬដាំទឹកជ្រលក់ ផ្សែងចូលទៅក្នុងប្រហោងត្រចៀកប្រហោងច្រមុះប្រហោងមាត់នឹងបើបផ្ការឈើ ឬផ្ទៃឈើ ព្រោះអាពាធក្តីរមែងគួរ ព្រោះរបស់អម្បាលនោះ ជាអព្វោហារិក ទាំងអស់ ។ ភើរចង្ហ្ការ ឲ្យរបស់ធាន់ចេញមកទល់នឹងពិតាន ហើយត្រឡប់ចូលទៅខាងក្នុងក៏គួរ ព្រោះមិនមែនវិស័យ ។ ចេញមកដល់មាត់ហើយ ត្រឡប់លេបទៅទៀត ក្នុងវិកាលត្រូវអាបត្តិ សូម្បីរសនៃអាមិសជាប់នៅក្នុងចន្ទោះធ្មេញ ត្រឡប់ចូលទៅក៏ត្រូវអាបត្តិដោយពិត ។ ថាបើអាមិសល្អិតមិនប្រាកដ គង់ជាចំណែកខាងអព្វោហារិក កាលវេលាជិតថ្ងៃត្រង់ធាន់ចង្ហាន់ក្នុងទីមិនមានទឹកហើយ គប្បីខាកស្ពោះទឹកមាត់ចេញ ២ ដុំ ៣ ដុំ ហើយទៅកាន់ទីមានទឹកលាងមាត់ចេញ ។ ខ្ញីជាដើមទទួលប្រគេនហើយ តម្កល់ទុកពន្ធកបែកចេញ កិច្ចដែលនឹងទទួល

ប្រគេនទៀតមិនបាន ។ កាលបើអំបិលមិនមានយកទឹកសមុទ្រមកធ្វើអំបិលក៏គួរ ទឹកប្រៃទទួលប្រគេនហើយ តម្កល់ទុកត្រឡប់ទៅជាអំបិលឬអំបិលរលាយទៅជាទឹកអស់ ឬទឹកអំពៅទៅជាស្ករឬស្ករអំពៅរលាយទៅជាទឹកក្តី ទទួលប្រគេនពេលមុននោះឯងរមែងគួរ ។ គ្រាប់ព្រឹលក៏ជាគតិនៃទឹកពិត យកគ្រាប់ផ្ទៃល្បៀងដែលរក្សាទុក ត្រាំក្នុងទឹកដើម្បីនឹងឲ្យថ្លា របស់នោះជាអញ្ជោហារិក ឆាន់ទឹកនោះជាមួយនឹងអាមិសក៏គួរ ។ ទឹកដែលយកផ្ទៃខ្ចីតជាដើម ដែលជាគតិនៃអាមិស ដាក់ក្នុងទឹកឲ្យថ្លារមែងគួរ តែក្នុងវេលាព្រឹកមួយយ៉ាង ។ ទឹកក្នុងស្រះបោក្ខរណីជាដើមជាទឹកល្អក់ក៏គួរ ថាបើជាប់មាត់ជាប់ដៃបានសោតមិនគួរ ទឹកនោះគប្បីទទួលប្រគេនចុះ ថាបើទឹកនោះហូរចុះទៅកាន់ប្រឡាយហើយ ចុះទៅពេញក្នុងស្ទឹងរមែងគួរ ។ ត្រពាំងជាដើម ដែលមានដើមទន្ទា មានទឹកនោះដេរដាសទៅដោយផ្កាទន្ទាដែលជ្រុះចាកដើម បើរសនៃផ្កាឈើមិនប្រាកដសោត កិច្ចដែលនឹងទទួលប្រគេននោះមិនមាន ។ ទឹកតិចរសនោះប្រាកដគប្បីទទួលប្រគេនសិន សម្បីក្នុងទឹកដែលមានស្លឹកឈើចាស់ពណ៌ខ្មៅពាសពេញនៅក្នុងជ្រោះទៀបភ្នំជាដើមក៏ដូចគ្នា យកផ្កាឈើដែលមានកេសរឬជ័រក្នុងទង ដាក់ចុះក្នុងក្អមទឹកឆាន់ គប្បីទទួលប្រគេនទឹកសិនឬទទួលប្រគេនផ្កាឈើហើយ គប្បីដាក់ទុកចុះ ។ គេដាក់ផ្កាច្រនៀងនិងផ្កាម្ទិះចុះគ្រាន់តែអប់ក្ងិន របស់នោះជាអញ្ជោហារិក សម្បីក្នុងថ្ងៃគម្រប់ពីរនឹងឆាន់ទឹកនោះជាមួយអាមិសក៏គួរ សាមណេរដងទឹកអំពីទឹកដែលអប់ដោយ

ផ្ការឈើដែលកិក្ខុតម្កល់ទុក ហើយត្រឡប់ចាក់ទឹកដែលខ្ជួនធាន់សល់ចុះក្នុងទឹកនោះ។ គប្បីប្រគេនសិន ។ ក្នុងស្រះឈូកជាដើម កេរសផ្ការឈើដេរជាសនៅលើទឹក នឹងយកក្ដមជ្រមុជចុះដងយកទឹកក៏គួរ ។ ឈើស្ងួនដែលកិក្ខុឲ្យគេធ្វើកប្ជាយទទួលប្រគេនតាំងទុក ថាបើកិក្ខុនឹងក្រេបរសនៃឈើស្ងួនោះសោត ទទួលប្រគេនមុននោះឯងក៏គួរ ។ ឈើស្ងួនដែលមិនបានទទួលប្រគេនតាំងទុក កាលបើមិនដឹងរសចូលទៅក្នុងក ត្រូវអាបត្តិដោយពិត ដ្ឋិតថាសិក្ខាបទនេះជាអចិត្តក: ។ ក្នុងមហាភូត វត្ថុណាគួរ វត្ថុណាមិនគួរ ទឹកដោះរមែងគួរ ជាទឹកដោះនៃសត្វមានសាច់ជាកប្ជាយ ឬនៃសត្វមានសាច់ជាអកប្ជាយក្ដី កាលបើក្រេបផឹកមិនត្រូវអាបត្តិ ។ ទឹកភ្នែក ទឹកមាត់ ទឹកសំបោរ ទឹកមូត្រ អាហារចាស់ សេម្ហ: មន្ទិលនៃធ្មេញ ពពឹកភ្នែក អាចម៍ត្រចៀក ញើសដែលកើតក្នុងកាយ របស់ទាំងអម្បាលនេះ រមែងគួរទាំងអស់ ។ ឯរបស់អម្បាលនោះ វត្ថុណាជ្រុះចាកទីហើយធ្លាក់ចុះក្នុងបាត្រ ឬក្នុងដៃ របស់នោះគប្បីទទួលប្រគេនសិន វត្ថុដែលជាប់នៅក្នុងខ្ជួន ជារបស់ទទួលប្រគេនស្រាប់ហើយ កាលបើធាន់បាយ បាយាសដែលក្ដៅ ញើសហូរតាមម្រាមដៃជាប់ជិតគ្នាចុះទៅ តាំងនៅក្នុងបាយបាយាស ឬកាលដើរទៅបិណ្ឌបាត ញើសហូរចាកដៃចុះទៅដល់កណ្ដាប់មាត់បាត្រ និងហូរអំពីកណ្ដាប់មាត់បាត្រចុះទៅកាន់ផ្ទៃបាត្រ ក្នុងញើសនោះ កិច្ចដែលនឹងប្រគេនមិនមាន ។ ក្នុងមហាភូត ដែលដុតភ្លើងនេះហើយ វត្ថុដែលនឹងមិនគួរមិនមាន តែវត្ថុដែលដុតភ្លើងនេះមិនល្អ

មិនគួរ តែដុតហើយដោយប្រពៃ សូម្បីជាធ្នឹងមនុស្សនឹងធ្វើឲ្យជាលម្អិត នឹងបង្ហោនចូលទៅក្នុងរបស់លិទ្ធស៊ីក៏គួរ ។

បដិគ្គហាណកថាចប់

វិជហានាទិបព្ធ: គម្រប់ ៦ ចប់

អាបត្តិទេសនាទិបព្ធ:គម្រប់ ៧

អាបត្តិទេសនាកថា

ពោលអំពីវិធីសម្តែងអាបត្តិ ។ អាបត្តិទាំងពួង ភិក្ខុកៃងត្រូវហើយ រមែងជាអាណាវីតិក្កមន្តរាយិក: គឺធ្វើអន្តរាយដល់សួគ៌ និងមគ្គផលនិព្វាន ព្រោះទោសដែលកន្ទងអាជ្ញាព្រះពុទ្ធអង្គ ព្រោះហេតុនោះ ភិក្ខុត្រូវហើយ ចំណែកអាបត្តិដែលជាវុដ្ឋានគামិនី គប្បីប្រាប់ប្តឹងដល់ភិក្ខុដែលជាសភាគ: ហើយ គប្បីរួចចេញដោយនៅបរិវាស និងប្រព្រឹត្តមានត្ត ។ ចំណែកអាបត្តិដែលជាទេសនាគামិនី តាំងអំពីថុល្លច្ច័យទៅ ដរាបដល់ទុព្ភាសិត ត្រូវហើយគប្បីសម្តែងនឹងសង្ឆ ឬគណ: ឬបុគ្គល សម្តែងនឹងសង្ឆ-គណ: នឹងលើកទុក នឹងពោលតែសម្តែងនឹងបុគ្គល ។ ភិក្ខុអ្នកត្រូវនោះ គប្បីចូលទៅរកភិក្ខុមួយអង្គ អង្គុយច្រហោងលើកដៃប្រណម្យ ថាបើចាស់ជាងអ្នកទទួល គប្បីពោលថា **អហំ អាវុសោ ឯកំ ថុល្លច្ចយំ**

អាបត្តឺ អាបន្នោ តំ បដិទេសេមិ ដូច្នេះ ។ ថាបើខ្ញីជាងអ្នកទទួល គប្បីពោលថា **អហំ ភន្តេ ឯកំ ។ ល ។ បដិទេសេមិ** ទាំងពីរយ៉ាងប្រែថា បពិត្រលោកដ៏មានអាយុ-លោកដ៏ចម្រើន ខ្ញុំត្រូវហើយនូវអាបត្តិបុល្លច្ច័យមួយ ឥឡូវនេះ ខ្ញុំសម្តែងចំពោះនូវអាបត្តិនោះ ។ អ្នកទទួលបើខ្ញីជាង គប្បីពោលថា **បស្សថ ភន្តេ** ប្រែថា បពិត្រព្រះករុណាដ៏ចម្រើន ព្រះករុណាឃើញឬ? ថាបើចាស់ជាង គប្បីពោលថា **បស្ស សិ អាវុសោ** ប្រែថា ម្នាលអ្នកដ៏មានអាយុ អ្នកឃើញ ឬ? អ្នកសម្តែងចាស់ជាង គប្បីពោលថា **អាម អាវុសោ បស្សាមិ** ប្រែថា ម្នាលអ្នកដ៏មានអាយុ អើខ្ញុំឃើញ ។ ថាបើខ្ញីជាងគប្បីពោលថា **អាម ភន្តេ បស្សាមិ** ប្រែថា បពិត្រព្រះករុណាដ៏ចម្រើន អើខ្ញុំព្រះករុណាឃើញ ។ អ្នកទទួលខ្ញីជាង គប្បីពោលថា **អាយតឺ ភន្តេ សំវេ-យ្យាថ** ប្រែថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់គប្បីសង្រ្ដួមតទៅចុះ ។ ថាបើចាស់ជាង គប្បីពោលថា **អាយតឺ អាវុសោ សំវ-យ្យាសិ** ប្រែថា ម្នាលលោកដ៏មានអាយុ លោកគប្បីសង្រ្ដួមតទៅចុះ ។ អ្នកសម្តែងចាស់ជាង គប្បីពោលថា **សាធុ សុដ្ឋុ អាវុសោ សំវ-រិស្សាមិ** ។ ថាបើខ្ញីជាង គប្បីពោលថា **សាធុ សុដ្ឋុ ភន្តេ សំវរិ-ស្សាមិ** ។ ទាំងពីរយ៉ាង ប្រែថា បពិត្រលោកដ៏មានអាយុ លោកដ៏ចម្រើនល្អហើយ ខ្ញុំនឹងសង្រ្ដួមដោយប្រពៃ ។ បើអាបត្តិពីរ គប្បីពោលតាមចាស់ ថា **អហំ អាវុសោ** ខ្ញីថា **អហំ ភន្តេ** ចាស់ ថា **អាវុសោ**

*ខ្ញុំ*ថា ភន្តេ *សម្តែងថា* ទ្វេ ថុល្លច្ចយោ អាបត្តិយោ អាបន្នោ តា បដិទេសេមិ *ដូច្នេះ កាលបើអ្នកទទួលពោលតាមចាស់តាមខ្ញុំ*ថា បស្សថ ភន្តេ ឬ បស្សសិ អាវុសោ *ដូច្នេះ*ហើយ *គប្បីពោលតាមចាស់ថា* អាម អាវុសោ បស្សាមិ *ខ្ញុំ*ថា អាម ភន្តេ បស្សាមិ *ដូច្នេះ កាលបើអ្នកទទួលពោលតាមចាស់*ថា អាយតឹ អាវុសោ សំវរេយ្យាសិ *ខ្ញុំ*ថា អាយតឹ ភន្តេ សំវរេយ្យាថ *ដូច្នេះ*ហើយ *គប្បីពោលតាមចាស់ថា* សាធុ សុដ្ឋុ អាវុសោ សំវរិស្សាមិ *ខ្ញុំ*ថា សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ *ដូច្នេះ ៣ ដងជាការប្រពៃ ។ ថាបើ អាបត្តិ ៣ ឡើងទៅ គប្បីពោលថា* អហំ អាវុសោ សម្ពហុលា ថុល្លច្ចយោ អាបត្តិយោ អាបន្នោ តា បដិទេសេមិ *ខ្ញុំ*ថា អហំ ភន្តេ សម្ពហុលា ថុល្លច្ចយោ អាបត្តិយោ អាបន្នោ តា បដិទេសេមិ ។ ល ។ សំវរិស្សាមិ ។ *ថាបើអាបត្តិ*មានវត្ថុផ្សេងៗ *គ្នា គប្បីពោលថា* អហំ អាវុសោ សម្ពហុលា ជាជាវត្ថុកាយោ ថុល្លច្ចយោ អាបត្តិយោ អាបន្នោ តា បដិទេសេមិ ។ ល ។ សំវរិស្សាមិ ។ អហំ ភន្តេ សម្ពហុលា ជាជាវត្ថុកាយោ ថុល្លច្ចយោ អាបត្តិ-យោ អាបន្នោ តា បដិទេសេមិ ។ ល ។ សំវរិស្សាមិ ។

ក្នុងអាបត្តិដទៃក៏ឲ្យផ្ទាស់ឈ្មោះដូច្នេះថា **អហំ ភន្តេ**[1] **ឯកំ ជិស្សក្ខិយំ ចាចិត្តិយំ ។ ល ។ ឯកំ ឧក្ក្ជ ។ ល ។ ឯកំ ឧញ្ញាសិតំ អាបត្តឺ អាបជ្ជោ តំ ។ ល ។ សំវរិ-ស្សាមិ** ។ ថាបើពីរ ឲ្យថា **ទ្វេ** ថាបើច្រើនអំពីបីឡើងទៅ ឲ្យថា **សម្ពហុលា** ថាបើមានវត្ថុផ្សេងៗ គ្នា ឲ្យថា **សម្ពហុលា ជាជាវត្ថុកាយោ** ដូច្នេះចុះ ។ តែអាបត្តិទុញ្ញាសិតមិនត្រូវថា **ជាជាវត្ថុកាយោ** ព្រោះមានសិក្ខាបទតែមួយ ។ អាបត្តិបាដិទេស-និយៈនោះ ពាក្យសម្តែងនៅខាងចុង ក្នុងសិក្ខាបទនោះឯង គប្បីដឹងដូចពោលហើយ ក្នុងបាដិទេសនិយវណ្ណនានោះចុះ ។ ឯនិស្សគ្គិយបាចិត្តិយាបត្តិនោះ កាលបើត្រូវហើយ គប្បីលះរបស់ដែលជានិស្សគ្គិយដល់សង្ឆ ឬគណៈ ឬបុគ្គលជាមុនសិន ហើយទើបសម្តែងអាបត្តិនោះចុះ ។ លះដល់សង្ឆដល់គណៈនឹងលើកទុក នឹងពោលតែកិរិយាលះដល់បុគ្គល ។ សំពត់អតិរេកចីវរនៃភិក្ខុ កន្ធង ១០ ថ្ងៃ ជានិស្សគ្គិយ ភិក្ខុនោះគប្បីចូលទៅរកភិក្ខុមួយអង្គ ធ្វើចីវរធ្យៀងស្មាម្ខាង អង្គុយច្រហោងលើកដៃប្រណម្យ ពោលថា **ឥទំ មេ ភន្តេ**[2] **ចីវរំ ឧសាហាតិក្ខន្តំ ជិស្សក្ខិយំ ឥមាហំ អាយស្មតោ ជិស្សជ្ជាមិ** ដូច្នេះ ឬកាន់យកសេចក្តីនោះ ពោលជាខេមរភាសាក៏បាន

(១-២) បើភិក្ខុអ្នកសម្តែងអាបត្តិ ឬលះចីវរ ចាស់វស្សាជាងអ្នកទទួល គប្បីថាអាវុសោ ជ្ជូស ភន្តេ ។

ថាបពិត្រព្រះករុណាដ៏ចម្រើន ចីវររបស់ខ្ញុំព្រះករុណានេះ កន្ធ៧ ១០ ថ្ងៃ ហើយ ជានិស្សគ្គិយ ខ្ញុំព្រះករុណាលះចីវរនេះ ដល់ព្រះករុណា ។ លះដូច្នេះហើយគប្បីសម្តែងអាបត្តិនោះដល់អ្នកទទួល ដូចពោលហើយក្នុងមុននោះចុះ ។ ហើយអ្នកទទួលគប្បីប្រគល់សំពត់នោះឲ្យវិញ ដោយពាក្យថា **ឥមំ ចីវរំ អាយស្មតោ ទជ្មិ** ដូច្នេះ ឬនឹងប្រគល់ដោយភាសារបស់ខ្លួនក៏បាន ថាខ្ញុំឲ្យចីវរនេះដល់លោក ថាបើអ្នកទទួលមិនប្រគល់ឲ្យវិញត្រូវទុក្កដ ។ បើសំពត់ច្រើន គប្បីលះថា **ឥមានិ មេ ភន្តេ ចីវរានិ ឧសាហាតិក្កន្តានិ និស្សគ្គិយានិ ឥមានាហំ អាយស្មតោ និស្សជ្ជামិ** ដូច្នេះ ។ បាលីប្រគល់ឲ្យវិញថា **ឥមានិ ចីវរានិ អាយស្មតោ ទជ្មិ** ដូច្នេះ ។ ថាបើសំពត់មួយនៅធ្លាយ ក្រៅហត្ថបាស គប្បីលះថា **ឯតំ មេ ភន្តេ ចីវរំ ។ ល ។ ឯតាហំ អាយស្មតោ និស្សជ្ជামি** ដូច្នេះ ។ ប្រគល់សំពត់ឲ្យវិញថា **ឯតំ ចីវរំ អាយស្មតោ ទជ្មិ** ដូច្នេះ ។ សំពត់ច្រើនគប្បីពោលថា **ឯតានិ មេ ភន្តេ ចីវរានិ ។ ល ។ ឯតានាហំ អាយស្មតោ និស្សជ្ជামি** ដូច្នេះ ។ ប្រគល់សំពត់ឲ្យថា **ឯតានិ ចីវរានិ អាយស្មតោ ទជ្មិ** ដូច្នេះ ។ គប្បីដឹងសេចក្តីនៃបាលីអម្បាលនោះចុះ ឬនឹងកាន់យកនូវសេចក្តីនោះ ពោលដោយខេមរភាសាក៏បាន **ឥមានិ ចីវរានិ** ប្រែថាសំពត់ទាំងឡាយនេះ

ឯតំ ចីវរំ ប្រែថាសំពត់នុ៎ះ ឯតានិ ចីវរានិ ប្រែថាសំពត់ទាំងឡាយអម្បាលនុ៎ះ ។ ថាបើត្រៃចីវរទាំង ៣ ត្រូវនិស្សគ្គិយ គប្បីលះថា ឥទំ មេ ភន្តេ តិចីវរំ ឯការត្តឹ វិប្ប្រវុដ្ឋំ អញ្ញត្រ ភិក្ខុសម្មតិយា និស្សក្ខិយំ ឥមាហំ អាយស្មតោ និស្សជ្ជាមិ ប្រែថា ត្រៃចីវររបស់ខ្ញុំព្រះករុណានេះ នៅប្រាសចាកហើយ អស់រាត្រីមួយ ត្រូវនិស្សគ្គិយ រៀរចាកភិក្ខុដែលបានសម្មតិ ខ្ញុំលះត្រៃចីវរនេះដល់ព្រះករុណា ។ មួយទៀត ក្នុងត្រៃចីវរទាំង ៣ នេះ ចីវរណាមួយត្រូវនិស្សគ្គិយ នឹងពោលតាមឈ្មោះក៏បាន បើសង្ឃាដិថា អយំ មេ ភន្តេ សង្ឃាដិ ឯការត្តឹ វិប្ប្រវុដ្ឋា អញ្ញត្រ ភិក្ខុសម្មតិយា និស្សក្ខិយា ឥមាហំ អាយស្មតោ និស្សជ្ជាមិ ដូច្នេះ ។ បើចីពរថា អយំ មេ ភន្តេ ឧត្តរ-សង្គោ[1] ឯការត្តឹ វិប្ប្រវុដ្ឋោ អញ្ញត្រ ភិក្ខុសម្មតិយា និស្សក្ខិយោ ឥមាហំ អាយស្មតោ និស្សជ្ជាមិ ដូច្នេះ ។ បើនៅធ្វាយ គប្បីពោលថា ឯតំ.... ឯតានិ.... ឯសា.... ឯសោ.... ជំនួសឥមស័ព្ទ ឲ្យត្រូវតាមលិង្គវចនវិភត្តិ របស់វត្ថុដែលត្រូវលះ ។ បាត្រកន្ទង ១០ ថ្ងៃ ជានិស្សគ្គិយ គប្បីលះថា អយំ មេ ភន្តេ បត្តោ ឧសាហាតិក្កន្តោ និស្សក្ខិយោ ឥមាហំ អាយស្មតោ និស្សជ្ជាមិ ប្រែថាបាត្ររបស់ខ្ញុំនេះ

(១) ឯការលះស្បង់ក៏ដូចជាការលះចីវរដែរ ប្លែកតែថាអន្តរវាសកោ ជួសឧត្តរាសង្គោ។

*កន្ទ*ង ១០ ថ្ងៃ*ហើ*យ ត្រូ*ន*ិ*ស*្ស*គ្គ*ិ*យ ខ្ញុ*ំ*ល*ះ*ប*ាត្ត*ន*េ*ះ ដ*ល*់*ល*ោ*ក*ដ*៏*ម*ាន* *អ*ាយ*ុ ។ ប*ាត្ត*ច*្រ*ើ*នថ*ា **ឥ*ម*េ ម*េ ភ*ន្ត*េ ប*ត*្ត*ា ឧ*ស*ាហ*ា*ត*ិ*ក*្ក*ន*្ត*ា ន*ិ*ស*្ស*ត*ិ*ក*្ខ*ិ*យ*ា ឥ*ម*ាហ*ំ* *អ*ាយ*ស*្ម*ត*ោ ន*ិ*ស*្ស*ជ*្ជ*ាម*ិ** *ដ*ូ*ច*ន*េ*ះ ។ ร*ប*ស*់*ផ*ា*ស*់*ប*ូ*រ*ត*្ម*ា*ន*ឹ*ង*ត*្រ*ហ*ស*្ត ត*្រ*ូ*ន*ិ*ស*្ស*ត*ិ*ក*្ខ*ិ*យ* *ត*ប*ា*ល*ះ*ថ*ា* **អ*ហ*ំ ភ*ន្ត*េ ជ*ា*ន*ប*្ប*ក*ា*រ*ក*ំ ក*យ*ិ*ក*្ក*យ*ំ ស*ម*ាប*ជ*ឿ ឥ*ដ*ំ ម*េ ភ*ន្ត*េ ន*ិ*ស*្ស*ត*ិ*ក*្ខ*ិ*យ*ំ ឥ*ម*ាហ*ំ* *អ*ាយ*ស*្ម*ត*ោ ន*ិ*ស*្ស*ជ*្ជ*ាម*ិ** *ដ*ូ*ច*ន*េ*ះ ។ *ស*ូ*ម*ប*ី*ជ*ា*ร*ប*ស*់*ដ*ទ*ៃ*ត*្រ*ូ*ន*ិ*ស*្ស*ត*ិ*ក*្ខ*ិ*យ* *ត*ប*ី*ក*ា*ន*់*យ*ក*ប*ា*ល*ី*ក*្ន*ុ*ង*វ*ិ*ក*ន*្ត*ន*ៃ*ស*ិ*ក*្ខ*ា*ប*ទ*ន*ោ*ះ*ៗ ម*ក*ល*ះ*ត*ា*ម*ត*ុ ម*ួ*យ*ន*ិ*ង* *ច*្រ*ើ*ន ន*ៅ*ជ*ិ*ត*ន*ិ*ង*ធ*្ង*ា*យ*ចុ*ះ ។ *វ*ិ*ធ*ី*ដ*ែ*ល*ទ*ទ*ួ*ល*អ*ា*ប*ត*្ត*ិ*ន*ិ*ង*ប*្រ*ត*ិ*ប*ត*ិ*ឲ* យ*ក*៏*ដ*ូ*ច*ត*្ម*ា* *ដ*ោ*យ*ន*ៃ*យ*ដ*ែ*ល*ព*ោ*ល*ម*ក*ហ*ើ*យ ។ ឯ*ร*ូ*ប*ិ*យ*ន*ិ*ង*ร*ប*ស*់*ដ*ែ*ល*ទ*ិ*ញ*ម*ក*ដ*ោ*យ* *ร*ូ*ป*ិ*យ ន*ិ*ង*ป*ា*ต*ร*ថ*្ម*ី ដ*ែ*ล*ภ*ิ*ก*ุ*ษ*ู*ม*ม*ก*អ*ំ*ព*ี*ม*ន*ุ*ษ*ย*ม*ิ*น*ม*ี*ม*ญ* า*ต*ิ ก*ុ*ង*ก*ា*ล* *ป*า*ต*ร*ช*า*ส*់*ม*ា*น*ช*ំ*ณ*ង*ม*ិ*ន*ท*ា*ន*់*ค*ร*ป*់ ๕ *ท*ั*ง* ๓ *น*ะ* *ค*ป*ี*ล*ะ*ด*ល*់* *ส*ង*ฆ*ม*ួ*យ*ជ*ំ*ព*ូ*ก ។ *ช*ា*ป*ើ*ส*ង*ฆ* យ*ค*ป*ี*ป*ร*ា*ប*់*ส*េ*จ*ก*ត*ី*ส*ង*ฆ*យ*ม*ุ*ข*ห*ើ*យ* *ท*ើ*ป*ล*ะ ด*ู*จ*ส*ំ*ព*ត*់*អ*ត*ิ*ร*ก*ช*ี*ว*ร*ส*ង*ฆ*យ*ช*ា*ม*ិ*ន*ป*ា*ន*អ*ธ*ิ*ฐ* า*น ก*ន*្ท*ง ๑๐* *ថ*្ង*ៃ*ទ*ៅ ค*ป*ี*ป*ร*ា*ប*់*ช*ា ป*ើ*ส*ំ*ព*ត*់*ន*េ*ះ*ช*ា*ส*់*ช*ា*ม*ិ*ន*ป*ា*ន*អ*ธ*ิ*ฐ*า*น*ห*ើ*យ* *ก*ា*ล*ป*ើ*ล*ะ*ป*ง*់*ด*ู*ข*ห*ะ ก*៏*ន*ឹ*ง*ช*ា*ก*ป*ិ*យ*ค*ួ*ร*ด*ល*់*ข*ុ*ំ ป*ร*ា*ป*់*ด*ู*ข*ห*ะ*ห*ើ*យ*ค*ป*ี* *ล*ะ*ด*ู*จ*ន*ៃ*យ*ม*ุ*น*ន*ោ*ះ*จ*ុ*ះ ព*្រ*ោ*ះ*ช*ា ก*ា*ล*ป*ร*ា*ป*់*ข*ឲ* យ*ด*ឹ*ง*ด*ู*ข*ห*ะ*ห*ើ*យ*ธ*ើ* *ว*ิ*น*ย*ก*ม*ฺ ม*ิ*น*ต*ร*ូ*ว*ม*ุ*ส*า*ว*ท ។ ม*ួ*យ*ท*ៀ*ต ก*ុ*ง*ถ*ៃ*ข*ោ*ส*ถ

បវារណា សង្ស័យនឹងអាបត្តិ គប្បីប្រាប់តាមសេចក្តីសង្ស័យមុនសិន ហើយគប្បីធ្វើឧបោសថ ឬបវារណា ។ ស្តាប់បាតិមោក្ខ ឬបវារណា កុំគប្បីធ្វើអន្តរាយដល់ឧបោសថ ដល់បវារណា ព្រោះមិនបានសម្តែងអាបត្តិហើយស្ងៀមនៅ គប្បីចូលទៅរកភិក្ខុមួយអង្គ ធ្វើចីវរធ្យៀងស្មាម្ខាង អង្គុយច្រហោងលើកដៃប្រណម្យពោលថា **អហំ ភន្តេ(១) ឯកិស្សា ចុល្លច្ចយាយ អាបត្តិយា វេមតិកោ យតា ជិញ្ចេមតិកោ ភវិស្សាមិ តតា តំ អាបត្តឹ បដិកវិស្សាមិ** *ប្រែថា បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំសង្ស័យក្នុងអាបត្តិចុល្លច្ចយ កាលណាអស់សង្ស័យ កាលនោះទើបនឹងសម្តែងនូវអាបត្តិនោះ ក្នុងកាលនោះ ។ អាបត្តិពីរថា* **អហំ ភន្តេ(២) ទ្វីសុ ចុល្លច្ចយាសុ អាបត្តីសុ វេមតិកោ ។ ល ។ តតា តា អាបត្តិយោ បដិកវិស្សាមិ** *។ ច្រើនថា* **សម្ពហុលាសុ ចុល្លច្ចយាសុ** *។ មានវត្ថុផ្សេងៗ ថា* **សម្ពហុលាសុ ឆាឆាវត្ថុ-កាសុ ចុល្លច្ចយាសុ** *។ សូម្បីអាបត្តិដទៃ ក៏ឲ្យផ្ទាស់ឈ្មោះសម្តែងដូចក្នុងបទចុល្លច្ចយ តាមអាបត្តិមួយនិងពីរនិងច្រើននិងវត្ថុផ្សេងៗ គ្នានោះចុះ ។ ក្នុងអន្ធកដ្ឋកថា ពោលថា បើមិនមានសេចក្តីសង្ស័យ សូម្បីនឹងអាងវត្ថុហើយសម្តែងក៏គួរ ។ វិធីសម្តែងដូច្នេះ កាលបើ*

(១-២) បើភិក្ខុចាស់វស្សា សម្តែងអាបត្តិ នឹងភិក្ខុខ្វីវស្សា គប្បីថាអាវុសោ ជួស ភន្តេ ។

ព្រះអាទិត្យ គឺពពកបិទបាំង សង្ស័យថាជាព្រឹក ឬរសៀល ហើយ ធាន់យាវកាលិកសោត ភិក្ខុនោះ គប្បីអាងវត្ថុប្រាប់ថា ខ្ញុំសង្ស័យ ហើយធាន់យាវកាលិក បើជាវេលាព្រឹកសោត ប្រាប់ថាខ្ញុំត្រូវទុក្ក-ដាបត្តិទាំងឡាយច្រើនព្រោះសង្ស័យ ថាបើជាវិកាល ក៏ប្រាប់ថាខ្ញុំ ត្រូវបាចិត្តិយាបត្តិទាំងឡាយច្រើន ដូច្នេះហើយ គប្បីសម្តែងថា **អហំ ភន្តេ**[១] **យា តស្មឹ វត្ថុស្មឹ សម្ពហុលា ទុក្ការ ១ ១ ១

អនតិរិត្តភោជនក៏គួរ ។ ក៏ឯអាបត្តិណា ដែលមានវត្ថុជាសភាគ:ស្មើគ្នា សូម្បីអាបត្តិនោះ សម្តែងរួចហើយ ក៏ឈ្មោះថាសម្តែងដោយប្រពៃ ឯអ្នកសម្តែងក៏ត្រឡប់ត្រូវទុក្ខដដន្ទៃទៀត ព្រោះសម្តែង អ្នកទទួលក៏ត្រូវទុក្ខដដន្ទៃទៀត ព្រោះទទួល អាបត្តិនោះឈ្មោះថាមានវត្ថុផ្សេងៗ អំពីគ្នាវិញ ព្រោះហេតុនោះ នឹងត្រឡប់សម្តែងដល់គ្នានិងគ្នាទៀតក៏គួរ ។ មួយទៀត កាលបើស្តាប់បាតិមោក្ខ ឬបវារណា បើរឭកអាបត្តិបានក៏គប្បីប្រាប់ដល់ភិក្ខុដែលនៅជិតតាមឈ្មោះអាបត្តិនោះ១ ថា **អហំ ភន្តេ ឯកំ ថុល្លច្ចយំ អាបត្តឺ អាបន្នោ ឥតោ រុដ្ឋ-ហិត្វា តំ អាបត្តឺ បដិកាវិស្សាមិ** ប្រែថាខ្ញុំត្រូវអាបត្តិថុល្លច្ច័យមួយ ក្រោកអំពីទីនេះហើយ នឹងធ្វើឲ្យច្បាស់នូវអាបត្តិនោះ ។ អាបត្តិពីរនិងច្រើននិងវត្ថុផ្សេងៗ គ្នា និងអាបត្តិដទ្ទៃ ក៏គប្បីប្រកបពាក្យដូចមុនចុះ គប្បីប្រាប់ដូច្នេះដល់ភិក្ខុដែលជាសភាគ: កុំគប្បីប្រាប់ដល់ភិក្ខុដែលជាវិសភាគ: ដ្បិតថា កាលបើប្រាប់ដល់ភិក្ខុដែលជាវិសភាគ: រ៉ាមនិងសង្ឆកេទជាដើម នឹងមានឡើង ព្រោះហេតុនោះ កុំប្រាប់ដល់ភិក្ខុដែលជាវិសភាគ: គប្បីចងចិត្តថាយើងក្រោកអំពីទីនេះហើយ នឹងសម្តែងហើយធ្វើឧបោសថ ធ្វើបវារណាទៅចុះ ។ បើនៅមានសង្ស័យ ក៏គប្បីប្រាប់ដល់ភិក្ខុអង្គុយជិត តាមសេចក្តីសង្ស័យដូចមុននោះចុះ ។ ថាបើក្នុងអាវាសជាមួយគ្នា ក្នុងថ្ងៃឧបោសថ ថ្ងៃបវារណា សង្ឆទាំងពួងត្រូវសភាគាបត្តិដូចគ្នាទាំងអស់ គប្បីបញ្ជូនភិក្ខុមួយអង្គ ទៅកាន់អាវាស

ជិតក្នុងថ្ងៃនោះថា អ្នកចូរទៅសម្តែងអាបត្តិមក យើងនឹងសម្តែងអាបត្តិ ក្នុងសំណាក់អ្នក ថាបើបានដូច្នេះ ជាការប្រពៃ ថាបើមិនបានទេ គប្បីឲ្យភិក្ខុអ្នកឈ្វាសសូត្រប្រកាសសង្ឆថា **សុណាតុ មេ ភន្តេ សង្ឆោ អយំ សញ្ជោ សង្ឆោ សភាគំ អាបត្តឺ អាបន្នោ យទា អញ្ញ ភិក្ខុ សុទ្ធំ អនាបត្តិកំ បស្ឆិស្ឆតិ តទា តស្ស សន្តិកេ តំ អាបត្តឺ បដិករិស្ឆតិ** ដូច្នេះ ហើយធ្វើឧបោសថ បវារណាចុះ ។ ថាបើសង្ស័យ គប្បីសូត្រប្រកាសសង្ឆថា **សុណាតុ មេ ភន្តេ សង្ឆោ អយំ សញ្ជោ សង្ឆោ សភាគាយ អាបត្តិយា វេមតិកោ យទា ឯ្ជមតិកោ ភវិស្ឆតិ តទា តំ អាបត្តឺ បដិករិស្ឆតិ** ដូច្នេះ ហើយធ្វើឧបោសថ បវារ-ណាចុះ ។ ថាបើភិក្ខុទាំងអម្បាលនោះ ភិក្ខុមួយអង្គ សម្គាល់ថា សម្តែងសភាគាបត្តិនោះគួរ នឹងសម្តែងក្នុងសំណាក់ភិក្ខុអង្គនោះសោត សម្តែងហើយ ឈ្មោះថាសម្តែងដោយប្រពៃពិត ភិក្ខុទាំងពីរនោះ ក៏ត្រូវអាបត្តិផ្សេងវត្ថុគ្នាទៅ ដូចពោលហើយក្នុងមុន ។ ព្រោះហេតុនោះ គប្បីត្រឡប់សម្តែងដល់គ្នានិងគ្នាទៀតចុះ ។ ភិក្ខុទាំងពីរអង្គក៏ជាអ្នកមិនមានអាបត្តិ ភិក្ខុទាំងឡាយដ៏សេស គប្បីសម្តែងឬប្រាប់សភាគាបត្តិ ក្នុងសំណាក់ភិក្ខុទាំងពីរនោះចុះ ។ ភិក្ខុមានអាបត្តិមិនទាន់សម្តែង ស្តាប់បាតិមោក្ខឬបវារណាត្រូវទុក្កដ ។ ក្នុងខុទ្ទកសិក្ខាពោលថា បារាជិក សង្ឆាទិសេសទាំងពីរនេះ ជាអទេសនាគាមិនី កុំសម្តែង និងកុំសម្តែងអនាបត្តិ អាបត្តិសម្តែងហើយ

កុំសម្តែងទៀត កុំសម្តែងនឹងភិក្ខុជានានាសំវាស និងកុំសម្តែងក្នុងសំណាក់ភិក្ខុ ៤-៥ អង្គ នៅក្រៅសីមា កុំសម្តែងក្នុងសំណាក់ភិក្ខុមួយអង្គម្តងព្រមគ្នា កុំសម្តែងដោយចិត្តមួយយ៉ាងដោយមិនធ្វើវចីភេទ គប្បីសម្តែងក្នុងសំណាក់នៃភិក្ខុដែលជាបកតត្ត: គឺភិក្ខុមិនត្រូវអន្ដិមវត្ថុ ឬភិក្ខុដែលសង្ឆមិនបានលើកវត្ត លើកឧបោសថ និងបវារណា ។

មួយទៀត អាបត្តិផ្សេងៗ កុំសម្តែងជាអាបត្តិមួយ បើអាបត្តិមួយសម្តែងជាអាបត្តិច្រើនឈ្មោះថាសម្តែងដោយប្រពៃ ។ ត្រូវបាពជិកហើយបដិញ្ញាខ្ជួនតាមត្រង់ ហើយលះភេទកិក្ខុចេញ ឈ្មោះថាសម្តែងបាពជិក ។

អាបត្តិទេសនាកថា ចប់

ឧចោសថកថា

វិធីធ្វើឧបោសថព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតថា **អនុជានាមិ ភិក្ខវេ ឧចោសថេ ចាតិមោក្ខំ ឧទ្ទិសិតុំ** *តថាគតអនុញ្ញាតឲ្យសម្តែងបាតិមោក្ខក្នុងថ្ងៃឧបោសថ ។ ឯថ្ងៃឧបោសថនោះមាន ៣ គឺចាតុទ្ទសិកោ ឧបោសថក្នុងថ្ងៃ ១៤ បណ្ណរសិកោ ឧបោសថក្នុងថ្ងៃ ១៥ និងសាមគ្គី គឺថ្ងៃព្រមព្រៀងគ្នា ។ រាប់តាំងអំពីថ្ងៃឧបោសថ ឬថ្ងៃបវារណាមុនមក បើថ្ងៃ ១៤ ឈ្មោះថាចាតុទ្ទសិកោ គប្បី*

តាំងញត្តិថា **អជ្ជុចោសថោ ចាតុទ្ទសោ** ដូច្នេះ ។ បើរាប់
បាន ១៥ ថ្ងៃ ឈ្មោះថាបណ្ណរសិកោ គប្បីតាំងញត្តិថា **អជ្ជុចោ-
សថោ បណ្ណរសោ** ដូច្នេះ ។ សង្ឆបែកបាក់គ្នាដោយវិវាទាធិករណ:
ដូចភិក្ខុស្រុកកោសម្ពី ដល់ថ្ងៃឧបោសថមិនបានធ្វើឧបោសថ ដល់
ថ្ងៃបវារណា មិនបានធ្វើបវារណា ហើយត្រឡប់ព្រមព្រៀងគ្នា រំដាប់
អធិករណ:ស្រេចក្នុងថ្ងៃណា ថ្ងៃនោះឈ្មោះថាជាថ្ងៃសាមគ្គី គប្បីធ្វើ
ឧបោសថក្នុងថ្ងៃនោះ តាំងញត្តិថា **អជ្ជុចោសថោ សាមគ្គី** ដូច្នេះ ។
ក្នុងរនោចខែអស្សុជ និងខ្នើតខែកត្តិក ជាខែមួយនេះ គប្បីធ្វើបវារណា ។
មួយទៀត ឧបោសថពោលដោយបុគ្គលអ្នកធ្វើមាន ៣ គឺសង្ឆឧបោសថ
១ គណឧបោសថ ១ បុគ្គលឧបោសថ ១ ។ ភិក្ខុតាំងអំពី ៤ អង្គឡើង
ទៅ គប្បីធ្វើសង្ឆឧបោសថ សូត្របាតិមោក្ខ ។ ភិក្ខុ ២-៣ អង្គគប្បីធ្វើ
គណឧបោសថ ប្រាប់បារិសុទ្ធិ ។ ភិក្ខុមួយអង្គ គប្បីធ្វើបុគ្គលឧបោសថ
គឺអធិដ្ឋាន ។ មួយទៀត ពោលដោយអាការនឹងគប្បីពោលមាន ៣ គឺសុត្ត-
ទ្ទេសឧបោសថ ១ បារិសុទ្ធិឧបោសថ ១ អធិដ្ឋានឧបោសថ ១ ។ ភិក្ខុតាំង
អំពី ៤ អង្គទៅ ឲ្យតាំងសង្ឆញត្តិថា **សុណាតុ មេ ភន្តេ សង្ឆោ**
ដូច្នេះជាដើម ហើយសូត្របាតិមោក្ខ ឈ្មោះថាសុត្តុទ្ទេសឧបោសថ ។
បារិសុទ្ធិឧបោសថនោះមាន ២ គឺប្រាប់ដល់គ្នានិងគ្នា ១ ប្រាប់ក្នុងសំណាក់
ភិក្ខុដទៃ ១ ។ ប្រាប់ដល់គ្នានិងគ្នាមាន ២ គឺតាំងញត្តិ ១ មិនតាំងញត្តិ ១ ។
ក្នុងអាវាសណា ដល់ថ្ងៃឧបោសថ ភិក្ខុមានតែ ៣ អង្គ ភិក្ខុទាំងឡាយ

នោះ គប្បីប្រជុំគ្នាហើយ ភិក្ខុអ្នកឈ្វាសមួយអង្គ គប្បីតាំងញត្តិថា **សុណាតុ មេ ភន្តេ អាយស្មន្តា អជ្ជុចោសថោ បណ្ណ-រសោ យទាយស្មន្តានំ បត្តកល្លំ មយំ អញ្ញមញ្ញំ ចារិសុទ្ធិ-ឧចោសថំ ករេយ្យាម** ដូច្នេះហើយ ភិក្ខុជាថេរៈគប្បីឃ្ពុំចីវរធ្វើងស្មាម្ខាងអង្គុយច្រហោង លើកដៃប្រណម្យ ពោលប្រាប់សេចក្តីជាអ្នកបរិសុទ្ធ ដល់ភិក្ខុទាំងឡាយនោះថា **បរិសុទ្ធោ អហំ អាវុសោ បរិសុទ្ធោតិ មំ ធារេថ** ដូច្នេះ ៣ ដង ហើយភិក្ខុកំលោះគប្បីធ្វើយ៉ាងនោះ ប្រាប់ដោយលំដាប់គ្នាថា **បរិសុទ្ធោ អហំ ភន្តេ បរិសុទ្ធោតិ មំ ធារេថ** ដូច្នេះ ៣ ដងដូចគ្នា ដូច្នេះឈ្មោះថាតាំងញត្តិ ។ បើនៅតែពីរអង្គ មិនត្រូវតាំងញត្តិ ប្រជុំគ្នាក្នុងសីមាហើយ ភិក្ខុជាថេរៈ គប្បីឃ្ពុំចីវរធ្វើងស្មាម្ខាង អង្គុយច្រហោងលើកដៃប្រណម្យ ពោលប្រាប់សេចក្តីជាអ្នកបរិសុទ្ធដល់ភិក្ខុកំលោះថា **បរិសុទ្ធោ អហំ អាវុសោ បរិសុទ្ធោតិ មំ ធារេហិ** ដូច្នេះ ៣ ដង ហើយភិក្ខុកំលោះគប្បីធ្វើយ៉ាងនោះ ពោលប្រាប់ព្រះថេរៈថា **បរិសុទ្ធោ អហំ ភន្តេ បរិសុទ្ធោតិ មំ ធារេថ** ដូច្នេះ ៣ ដង ដូច្នេះឈ្មោះថាមិនតាំងញត្តិ ។ ប្រាប់បរិសុទ្ធក្នុងសំណាក់ភិក្ខុដទៃនោះក៏មាន ២ គឺប្រាប់ក្នុងសំណាក់នៃភិក្ខុដែលបវារណាហើយ ១ ប្រាប់ក្នុងសំណាក់នៃភិក្ខុដែលមិនបានបវារណា ១ ។ ភិក្ខុចូលបច្ឆិមិកាវស្សា ឬចូលបុរិមិកាវស្សា តែវស្សាដាច់ លុះដល់ថ្ងៃបវារណា តិចជាងភិក្ខុអ្នកបវារណា គប្បីឲ្យ

កាយសាមគ្គី ភិក្ខុដទៃបវារណាហើយ គប្បីប្រាប់សេចក្តីបរិសុទ្ធរបស់ខ្លួន ក្នុងសំណាក់នៃភិក្ខុដែលបវារណាហើយនោះថា **បរិសុទ្ធោ អហំ អាវុសោ បរិសុទ្ធោតិ មំ ជានេថ** *ដូច្នេះ ៣ ដង ដូច្នេះ ឈ្មោះថាប្រាប់ក្នុងសំណាក់នៃភិក្ខុ ដែលបវារណាហើយ ។ ក្នុងថ្ងៃដទៃមិនមែនថ្ងៃបវារណា ភិក្ខុចៅអាវាសសូត្របាតិមោក្ខចប់ហើយ នៅមិនទាន់ក្រោក ឬក្រោកទៅខ្លះហើយ ភិក្ខុអាគន្តុក:ដទៃស្មើគ្នា ឬតិចជាងចៅអាវាសមកដល់ ភិក្ខុនោះគប្បីប្រាប់បរិសុទ្ធិក្នុងសំណាក់ចៅអាវាសដោយន័យដូចពោលមកហើយ ដូច្នេះឈ្មោះថាប្រាប់ក្នុងសំណាក់នៃភិក្ខុដែលមិនបានបវារណា ប្រាប់យ៉ាងនេះឈ្មោះថាបារិសុទ្ធិឧបោសថ ។*

អធិដ្ឋានឧបោសថនោះដូច្នេះ បើភិក្ខុនៅតែមួយអង្គ គប្បីធ្វើបុព្ព-ករណ:ទាំងពួងមានបោសរោងឧបោសថជាដើម ហើយអង្គុយរង់ចាំភិក្ខុដទៃដែលជាអាគន្តុក: ដឹងថាមិនមកហើយគប្បីអធិដ្ឋានថា **អជ្ជ មេ ឧបោសថោ** *ដូច្នេះ ។ ក្នុងអដ្ឋកថាបង្គាប់ឲ្យពោលពាក្យអធិដ្ឋានតាមថ្ងៃ បើថ្ងៃ ១៤ ថា* **អជ្ជ មេ ឧបោសថោ ចាតុទ្ទសោតិ អធិដ្ឋামិ** *។ បើថ្ងៃ ១៥ ថា* **អជ្ជ មេ ឧបោសថោ បណ្ណរសោតិ អធិដ្ឋামិ** *ដូច្នេះ ឈ្មោះថា អធិដ្ឋានឧបោសថ ។*

ឧបោសថពោលដោយថ្ងៃមាន ៣ ពោលដោយអ្នកធ្វើមាន ៣ ដោយអាការ:នឹងគប្បីធ្វើមាន ៣ ដូច្នេះ ត្រូវជាឧបោសថ ៩ ផងគ្នា កាលដល់ថ្ងៃឧបោសថ ថ្ងៃបវារណា ព្រមដោយលក្ខណ:ដូច្នេះ ភិក្ខុមិនធ្វើ

ឧបោសថ មិនធ្វើបវារណា ក្នុងថ្ងៃឧបោសថ ថ្ងៃបវារណានោះ នឹងចេញចាកអាវាស ឬចាកទីមិនមែនអាវាស ទៅកាន់អាវាស ឬកាន់ទីមិនមែនអាវាសដទៃ ដែលមិនមានភិក្ខុ ឬមានភិក្ខុ តែជានានាសំវាស ដើម្បីទៅនៅ ត្រូវទុក្កដ រៀរតែទៅជាមួយនឹងសង្ឆ ឬមានអន្តរាយ ។ កិច្ចដែលគប្បីធ្វើមុនអំពីប្រជុំ ដើម្បីនឹងធ្វើឧបោសថ ធ្វើបវារណា មាន គឺ បោសរោងឧបោសថ រោងបវារណា ១ បើវេលាយប់អុជប្រទីប ១ តម្កល់ទឹកធាន់ទឹកប្រើ ១ ក្រាលអាសនៈដើម្បីអង្គុយធ្វើឧបោសថ ធ្វើបវារណា ១ ទាំង ៤ នេះលោកហៅថា បុព្វករណៈ ។ ភិក្ខុមិនមានជំងឺ បើថេរៈបង្គាប់ហើយ មិនធ្វើបុព្វករណៈនោះ ត្រូវទុក្កដ ។ កិច្ចដែលនឹងគប្បីធ្វើមុនអំពីសូត្របាតិមោក្ខ បវារណា មាន ៥ គឺ នាំចន្ទនៃភិក្ខុដែលគួរនាំចន្ទ ១ នាំបារិសុទ្ធិ នាំបវារណា នៃភិក្ខុគួរបារិសុទ្ធិ គួរបវារណា ១ ប្រាប់រដូវថា រដូវនេះឈ្មោះនេះ ថ្ងៃឧបោសថក្នុងរដូវនេះ កន្ទងទៅហើយប៉ុណ្ណោះ ថ្ងៃឧបោសថ ថ្ងៃបវារណា មកដល់ថ្ងៃនេះ នៅសល់តែប៉ុណ្ណោះដូច្នេះ ១ ពាប់ភិក្ខុថាប៉ុណ្ណោះៗ ប្រជុំគ្នាក្នុងរោងឧបោសថ ក្នុងរោងបវារណា ១ ឲ្យឱ្យាទដល់នាងភិក្ខុនី ១ ទាំង ៥ នេះ លោកហៅថា បុព្វកិច្ច ។ ភិក្ខុនៅក្នុងខាងក្នុងសីមា ឈឺ ឬប្រកបដោយកិច្ចធំ មកកាន់រោងឧបោសថ រោងបវារណាមិនបាន ដល់ថ្ងៃឧបោសថត្រូវឲ្យចន្ទ ឲ្យបារិសុទ្ធិ ។ ដល់ថ្ងៃបវារណា ត្រូវឲ្យចន្ទ ឲ្យបវារណាដល់ភិក្ខុមួយអង្គ ក្យិរិយាឲ្យចន្ទៈនោះ ឲ្យសម្រេចការធ្វើឧបោសថ ធ្វើបវារណា នឹងសង្ឆ

កម្មដ៏សេសនៃសង្ឆម្យ៉ាង ឧបោសថ បវារណានៃខ្លួនមិនឈ្មោះថាធ្វើ ។ ចំណែកនាំបារិសុទ្ធិ នាំបវារណានោះ ឲ្យសម្រេច ការធ្វើឧបោសថ ធ្វើបវារណា របស់ខ្លួននិងរបស់សង្ឆផង តែមិនសម្រេចសង្ឆកម្មដ៏សេសនៃសង្ឆបាន ព្រោះហេតុនោះ កាលឲ្យបារិសុទ្ធិ ឲ្យបវារណា ត្រូវឲ្យឆន្ទៈផង ។ តែសព្វថ្ងៃនេះ ប្រើសីមាតូច ភិក្ខុនៅក្នុងសីមា មិនមាន កិច្ចដែលនាំឆន្ទៈ នាំបារិសុទ្ធិ នាំបវារណា ក៏មិនត្រូវធ្វើ ។ នាងភិក្ខុនីសព្វថ្ងៃនេះក៏មិនមាន ព្រោះហេតុនោះ ការឲ្យឱវាទដល់នាងភិក្ខុនី ក៏មិនត្រូវធ្វើ ។

អង្គនៃឧបោសថ អង្គនៃបវារណា មាន ៤ គឺ ថ្ងៃនោះជាថ្ងៃឧបោសថ ថ្ងៃបវារណា ទាំង ៣ គឺថ្ងៃ ១៤ ថ្ងៃ ១៥ ថ្ងៃសាមគ្គី ថ្ងៃណាមួយ ១ ភិក្ខុ ប៉ុន្មានគួរធ្វើសង្ឆឧបោសថ គណឧបោសថ និងសង្ឆបវារណា គណ-បវារណាបាន ភិក្ខុអម្បាលនោះ មិនលះហត្ថបាសគ្នា នៅក្នុងសីមាជាមួយគ្នា ១ អាបត្តិជាសភាគៈមានវត្ថុស្មើគ្នា ដូចធាន់ភោជន ក្នុងវិកាលដូចគ្នាមិនមានដល់សង្ឆ ១ វជ្ជនីយបុគ្គល ២១ មិនមានក្នុងហត្ថបាស ១ ឧបោសថ បវារណាព្រមដោយអង្គ ៤ នេះ ទើបគួរធ្វើ គួរពោលថា **បត្តកល្ប** បាន ។ ក៏ឯវជ្ជនីយបុគ្គល ២១ នោះគឺ គ្រហស្ថ ១ ភិក្ខុនី ១ នាងសិក្ខមានា ១ សាមណេរ ១ សាមណេរី ១ មនុស្សលាសិក្ខា ហើយ ១ មនុស្សត្រូវអន្តិមវត្ថុ ១ ភិក្ខុគឺសង្ឆលើកវត្តព្រោះមិនឃើញអាបត្តិ ១ ភិក្ខុគឺសង្ឆលើកវត្តព្រោះមិនសម្តែងអាបត្តិ ១ ភិក្ខុគឺសង្ឆលើក

វត្តព្រោះមិនបានលះទិដ្ឋិអាក្រក់ចេញ ១ បណ្ឌក ១ ថេយ្យសំវាស មនុស្សលួចកេទ លួចសំវាស ១ ភិក្ខុដែលចូលទៅកាន់លទ្ធិតិរ្ថិយ ១ សត្វតិរច្ឆាន ១ មនុស្សសម្លាប់មាតា ១ មនុស្សសម្លាប់បិតា ១ មនុស្ស សម្លាប់ព្រះអរហន្ត ១ មនុស្សទ្រុស្តនាងភិក្ខុនី ១ មនុស្សទម្លាយសង្ឆ ១ មនុស្សធ្វើលោហិតក្នុងព្រះកាយនៃព្រះពុទ្ធអង្គឲ្យកើតឡើង ១ មនុស្ស កេទ ២ គឺមានទាំងកេទប្រុស កេទស្រី ១ មនុស្ស ២១ នេះឈ្មោះថា វជ្ជនីយបុគ្គល ព្រោះសង្ឆគប្បីវៀរ គឺកុំឲ្យនៅរួមហត្ថបាស ។ ក្នុង មនុស្សទាំងអម្បាលនោះ កាលមនុស្សសង្ឆលើកវត្ត ៣ ជំពូក នៅក្នុង ហត្ថបាស សង្ឆធ្វើឧបោសថ ធ្វើបវារណាត្រូវបាចិត្តិយ ។ កាលមនុស្ស ដ៏សេសក្រៅអំពីមនុស្សទាំង ៣ ជំពូកនោះ មាននៅក្នុងហត្ថបាស សង្ឆធ្វើឧបោសថ ឬបវារណា ត្រូវទុក្កដ ។

ឧបោសថកម្មមាន ៤ ដូច្នេះ ជាវគ្គតែមិនជាធម៌ ១ ព្រមព្រៀងគ្នា តែមិនជាធម៌ ១ ជាវគ្គដោយធម៌ ១ ព្រមព្រៀងគ្នាដោយធម៌ ១ ។ ក្នុងវិហារមួយ ភិក្ខុនៅ ៤ អង្គ នាំធន្ទ:នាំបារិសុទ្ធិនៃភិក្ខុមួយអង្គទៅ តែ ៣ អង្គធ្វើបារិសុទ្ធិឧបោសថ ឬនៅ ៣ អង្គនាំធន្ទ:បារិសុទ្ធិនៃភិក្ខុមួយអង្គ ទៅ តែពីរអង្គសូត្របាតិមោក្ខ ដូច្នេះឈ្មោះថា **អឌម្ផេ វគ្គំ** *ជាវគ្គ តែមិនមែនជាធម៌ ។ បើ ៤ អង្គប្រជុំគ្នា ធ្វើបារិសុទ្ធិឧបោសថ ឬ ២ អង្គ ឬ ៣ អង្គសូត្របាតិមោក្ខ ដូច្នេះឈ្មោះថា* **អឌម្ផេ សមគ្គំ** *ព្រម ព្រៀងគ្នា តែមិនជាធម៌ ។ បើនៅ ៤ អង្គ នាំបារិសុទ្ធិនៃភិក្ខុមួយអង្គទៅ*

តែ ៣ អង្គសូត្របាតិមោក្ខ ឬនៅ ៣ អង្គ នាំបារិសុទ្ធិនៃភិក្ខុមួយអង្គទៅ តែ ២ អង្គធ្វើបារិសុទ្ធិឧបោសថ ដូច្នេះឈ្មោះថា **ឆម្មេន វក្ខ** ជាវគ្គ ដោយធម៌ ។ បើ ៤ អង្គនៅក្នុងទីជាមួយគ្នាទាំងអស់ ប្រជុំគ្នាសូត្របាតិមោក្ខ និងនៅ ៣ អង្គ ធ្វើបារិសុទ្ធិឧបោសថ និងនៅ ២ អង្គប្រាប់បារិសុទ្ធិដល់គ្នានិងគ្នា ដូច្នេះឈ្មោះថា **ឆម្មេន សមក្ខ** ព្រមព្រៀងគ្នាដោយធម៌ ។ កម្ម ៣ ខាងដើម មិនគួរធ្វើ គួរតែកម្មខាងចុង ១ យ៉ាង ។ មួយទៀត ភិក្ខុកុំគប្បីធ្វើកម្មមិនជាធម៌ ក្នុងកណ្ណាលសង្ឆ បើធ្វើត្រូវទុក្កដ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា កាលភិក្ខុដទៃធ្វើកម្មមិនជាធម៌ ភិក្ខុនៅ ២-៥ អង្គគប្បីហាមប្រាម មាននៅ ២-៣ អង្គគប្បីធ្វើឲ្យច្បាស់ នូវទិដ្ឋិសេចក្តីឃើញ ។ មួយអង្គ គប្បីអធិដ្ឋានថា កម្មនោះមិនគួរដូច្នេះ ។ មួយទៀត ភិក្ខុដទៃសូត្របាតិមោក្ខ ក្លែងធ្វើមិនឲ្យសង្ឆបានឮ ត្រូវទុក្កដ បើសំឡេងស្អក-ស្អារ ខំញ្ជាយាមថានឹងឲ្យបានឮ មិនត្រូវអាបត្តិ ។ មួយទៀត ភិក្ខុគឺព្រះថេរៈមិនបានអាវាធនាមុន សម្តែងបាតិមោក្ខឡើងក្នុងកណ្ណាលសង្ឆ ត្រូវទុក្កដ ។ សូត្របាតិមោក្ខជាធុរៈនៃព្រះថេរៈ ព្រះថេរៈគប្បីសូត្រឯង ឬអាវាធនាឲ្យអ្នកដទៃសូត្រ ដ្បិតថា ការសម្តែងបាតិមោក្ខជាការៈនៃភិក្ខុអ្នកឈ្វាស វិធីដែលអាវាធនាឲ្យសូត្របាតិមោក្ខ គប្បីដឹងដូចពោលហើយ ក្នុងអាវាធនាឲ្យសម្តែងធម៌នោះចុះ ។ អ្នកណាដឹងឧបោសថ ៩ និងដឹងឧបោសថកម្ម ២ បាតិមោក្ខ ២ បាតិមោក្ខុទ្ទេស ៩ ឬ ៥ អ្នកនោះឈ្មោះថាអ្នកឈ្វាស ។ បាតិមោក្ខុទ្ទេស ៥ នោះដូច្នេះ សូត្រនិទានុទ្ទេស

តាំងអំពី **សុណាតុ មេ ភន្តេ សង្ឆោ** ដរាបដល់ **ជានុ ហោតិ** ហើយសូត្រ **ឧទ្ទិដ្ឋំ ខោ អាយស្មន្តោ ឯកូនវីសតិ ។ ល ។ ឯវមេតំ ធារយាមិ** ចប់និទានុទ្ទេសដូច្នេះហើយ ឧទ្ទេសក្រៅនោះ ប្រកាសយកដោយសូត្រថា **សុតា ខោ បនាយស្មន្តេហិ ចត្តារោ ចារាជិកា ធម្មា ។ សុតា ខោ អាយស្មន្តេហិ តេរស សង្ឆាទិសេសា ធម្មា ។ ល ។ អវិវេចមានេហិ សិក្ខិតព្ពំ** ដូច្នេះ ឈ្មោះថាឧទ្ទេសជាបឋម ។

សូត្រដរាបដលចប់បារាជិកុទ្ទេសហើយ ឧទ្ទេសក្រៅនោះ ប្រកាសយកដោយសុត:ដូចមុន ដូច្នេះឈ្មោះថាជាឧទ្ទេសគម្រប់ ២ ។

សូត្រដរាបដល់ចប់ សង្ឆាទិសេសុទ្ទេសហើយ ឧទ្ទេសក្រៅនោះ ប្រកាសយកដោយសុត:ដូចមុន ដូច្នេះឈ្មោះថាជាឧទ្ទេសគម្រប់ ៣ ។

សូត្រដរាបដល់ចប់អនិយតុទ្ទេសហើយ ឧទ្ទេសក្រៅនោះ ប្រកាសយកដោយសុត ដូចមុន ដូច្នេះឈ្មោះថាឧទ្ទេសគម្រប់ ៤ ។

តាំងអំពីនិស្សគ្គិយុទ្ទេសទៅដរាបដល់ចប់បាតិមោក្ខទាំងអស់ដូច្នេះជាឧទ្ទេសគម្រប់ ៥ ឈ្មោះថាវិត្ថារុទ្ទេស ។

ក្នុងអាវាសណា ភិក្ខុអ្នកឈ្វាសដូច្នេះមិនមាន គប្បីអារាធនាតាំងអំពីព្រះមហាថេរ ចុះទៅដរាបដល់សង្ឆនវក: បើមិនមានភិក្ខុណាសូត្របាតិមោក្ខបាន ព្រះថេរ:គប្បីបង្គាប់ភិក្ខុកំលោះមួយអង្គ ឲ្យទៅកាន់អាវាសជិតក្នុងថ្ងៃនោះ ឲ្យរៀនបាតិមោក្ខមកដោយសង្ខេបឬដោយពិស្តារ

បើមិនបានដូច្នោះ ក្នុងអាវាសណាភិក្ខុឈ្វាសមាន ឲ្យភិក្ខុទាំងអម្បាលនោះ ទៅក្នុងអាវាសនោះ បើមិនទៅត្រូវទុក្កដ ។ មួយវិញទៀត បើមានភិក្ខុអ្នកឈ្វាសជាពហុស្សូត ជាលជ្ជីមកក្នុងអាវាសសោត ភិក្ខុចៅអាវាសគប្បីសង្គ្រោះអនុគ្រោះ និងលួងលោមដោយឲ្យចុណ្ណ:ជាដើម បើមិនធ្វើដូច្នោះ ត្រូវទុក្កដ ។

មួយទៀត កាលនៅចាំវស្សា ភិក្ខុអ្នកឈ្វាសដូច្នោះមិនមាន គប្បីបញ្ជូនភិក្ខុមួយអង្គទៅក្នុង ៧ ថ្ងៃ ឲ្យរៀនបាតិមោក្ខមកដោយសង្ខេប ឬពិស្តារ កាលមិនបានយ៉ាងនោះ បើនៅក្នុងវស្សានរដូវក្នុងអាវាសនោះ ត្រូវទុក្កដ ។ មួយទៀតមិនមានអន្តរាយ បើសូត្របាតិមោក្ខដោយសង្ខេប ត្រូវទុក្កដ ។ អន្តរាយមាន ១០ ប្រការគឺ កាលភិក្ខុប្រជុំគ្នាធ្វើឧបោសថ ម្ចាស់ផែនដីស្តេចយាងមក ឈ្មោះថារាជន្តរាយ ១ ចោរទាំងឡាយមកឈ្មោះថាចោរន្តរាយ ១ ភ្លើងព្រៃឆេះមកឬភ្លើងឆេះឡើងក្នុងអាវាស ឈ្មោះថាអគ្យន្តរាយ ១ មេឃតាំងឡើងឬទឹកជន់មក ឈ្មោះថាឧទកន្ត-រាយ ១ មនុស្សទាំងឡាយមកច្រើនឈ្មោះថាមនុស្សន្តរាយ ១ យក្សឬខ្មោចចាប់ភិក្ខុ ឈ្មោះថាអមនុស្សន្តរាយ ១ សត្វកាចមានខ្វាធំជាដើមចូលមក ឈ្មោះថាពាឡន្តរាយ ១ ពស់ជាដើមចិកភិក្ខុឈ្មោះថាសិរីសប្បន្តរាយ ១ ភិក្ខុឈឺ ឬ ភិក្ខុធ្វើកាលកិរិយា ឬមនុស្សមានវេរចាប់ភិក្ខុសម្ងាប់ ឈ្មោះថាជីវិតន្តរាយ ១ មនុស្សទាំងឡាយចាប់ភិក្ខុមួយអង្គ ឬច្រើន ដើម្បីនឹងឲ្យឃ្លាតចាកព្រហ្មចរិយ: ឈ្មោះថាព្រហ្មចរិយន្តរាយ ១ កាលមាន

អន្តរាយទាំង ១០ ប្រការដូច្នេះណាមួយ គប្បីសូត្របាតិមោក្ខដោយសង្ខេប គប្បីសូត្រតែឧទ្ទេស ជាបឋម ឬ គម្រប់ ២-៣-៤ តែក្នុងឧទ្ទេស គម្រប់ ២ ជាដើម ឧទ្ទេសណា សូត្រមិនទាន់ចប់ អន្តរាយមានមក សូម្បីឧទ្ទេសនោះ គប្បីប្រកាសយកដោយសុត: តែនិទានុទ្ទេស សូត្រ មិនទាន់ចប់ កុំគប្បីប្រកាសដោយសុត: គប្បីសូត្រទៅឲ្យចប់ ឧទ្ទេស ក្រៅនោះ គប្បីប្រកាសយកដោយសុត: កាលមិនមានអន្តរាយ គប្បី សូត្រដោយពិស្តារដរាបដល់ចប់ចុះ ។

មួយទៀត ក្នុងថ្ងៃឧបោសថ ថ្ងៃបវារណា ចៅអាវាស ឬអាគន្តុក: មិនដឹងថាភិក្ខុក្នុងខាងក្នុងសីមាមាន ធ្វើឧបោសថ ធ្វើបវារណា មិនត្រូវ អាបត្តិ បើដឹងថាមាន និងរង្គៀសសង្ស័យថានឹងគួរ ឬមិនគួរ ហើយ ធ្វើត្រូវទុក្កដ ។ បើគិតនឹងឲ្យភិក្ខុទាំងអម្បាលនោះវិនាស ហើយធ្វើត្រូវ ថុល្លច្ច័យ ។ បើកំពុងសូត្របាតិមោក្ខ ឬបវារណា ឬសូត្របាតិមោក្ខ ឬបវារណាចប់ហើយ នៅមិនទាន់ក្រោក ឬក្រោកអស់ហើយ ចៅអាវាស ឬអាគន្តុក:មកច្រើនជាង គប្បីសូត្របាតិមោក្ខ បវារណា ជាថ្មីទៀត បើស្មើគ្នា ឬតិចជាង កំពុងសូត្របាតិមោក្ខ បវារណា អ្នកមកថ្មីគប្បី ស្តាប់បាតិមោក្ខ បវារណាតទៅ ។ បើសូត្របាតិមោក្ខ ឬបវារណាចប់ ហើយនៅមិនទាន់ក្រោក ឬក្រោកទៅហើយ អ្នកមកថ្មីគប្បីប្រាប់បារិសុទ្ធិ គប្បីប្រាប់បវារណា ក្នុងសំណាក់អ្នកសូត្របាតិមោក្ខ អ្នកបវារណា ។ មួយទៀត ថ្ងៃឧបោសថ ថ្ងៃបវារណា ចៅអាវាសថា ថ្ងៃចាតុទ្ទសី

អាគន្ទុក: ថាថ្ងៃបណ្ណរសី បើចៅអាវាសច្រើនជាង ឬស្មើគ្នា អាគន្ទុក:គប្បីអនុវត្ត គឺប្រព្រឹត្តតាម គឺឲ្យតាំងញត្តិថា **ចាតុទ្ទសោ** ឬ **ចាតុទ្ទសី** បើអាគន្ទុក:ច្រើនជាង ឲ្យចៅអាវាសគប្បីអនុវត្ត គឺប្រព្រឹត្តតាមអាគន្ទុក: ឲ្យតាំងញត្តិថា **បណ្ណរសោ** ឬ **បណ្ណរសី** ។ ថ្ងៃឧបោសថ ថ្ងៃបវារណា ចៅអាវាសថាថ្ងៃបណ្ណរសី អាគន្ទុក:ថា ថ្ងៃចាតុទ្ទសី គប្បីដឹងដូចន័យដែលសម្តែងមកហើយ បើចៅអាវាសថាថ្ងៃ ១ កើត ថ្ងៃ ១ ពេច អាគន្ទុក:ថាថ្ងៃបណ្ណរសី បើចៅអាវាសច្រើនជាង ឬ ស្មើគ្នា ចៅអាវាសកុំគប្បីឲ្យកាយសាមគ្គីដល់អាគន្ទុក: គប្បីឲ្យអាគន្ទុក:ទៅខាងក្រៅសីមា ចៅអាវាសធ្វើឧបោសថ ធ្វើបវារណាទៅចុះ ។ បើអាគន្ទុកច្រើនជាងឲ្យចៅអាវាស គប្បីឲ្យកាយសាមគ្គីដល់អាគន្ទុក: ឬទៅខាងក្រៅសីមា បើចៅអាវាសថាថ្ងៃបណ្ណរសី អាគន្ទុក:ថាថ្ងៃ ១ កើត ថ្ងៃ ១ ពេច ក៏ដូចគ្នា ។

មួយវិញទៀត ធ្វើឧបោសថ ធ្វើបវារណា ក្នុងថ្ងៃដទៃក្រៅចាកថ្ងៃគម្រប់ ១៤ - ១៥ ថ្ងៃសាមគ្គី ត្រូវទុក្កដ ។ មួយទៀត ទ្រង់អនុញ្ញាតទុកថា ក្នុងថ្ងៃឧបោសថ ឲ្យភិក្ខុជាថេរ:ប្រជុំមុន ក្នុងអដ្ឋកថា ថាព្រះថេរ:មិនទៅប្រជុំមុន ត្រូវទុក្កដ ។

មិនសន្មតខ្ជួនមុន សួរ ឬធ្វើយ វិន័យក្នុងកណ្ណាលសង្ឆ ត្រូវទុក្កដ សន្មតខ្ជួនឯងក៏បាន ឲ្យអ្នកដទៃសន្មតក៏បាន អ្នកសូត្រសន្មតខ្ជួនឯងដោយញត្តិថា **សុណាតុ មេ ភន្តេ សង្ឆោ យទិ សង្ឆស្ស បត្តកល្លំ អហំ ឥត្ថន្នាមំ វិនយំ បុច្ឆេយ្យំ**

ដូច្នេះ ។ អ្នកដទៃសន្ទនឲ្យថា **សុណាតុ មេ ភន្តេ សង្ឆោ យទិ សង្ឆស្ស បត្តកល្លំ ឥត្ថន្នាមោ ឥត្ថន្នាមំ វិនយំ បុច្ឆេយ្យ** *ដូច្នេះ ។ អ្នកធ្វើយសន្ទនខ្លួនឯងថា* **សុណាតុ មេ ។ ល ។ បត្តកល្លំ អហំ ឥត្ថន្នាមេន វិនយំ បុដ្ឋោ វិសជ្ជេយ្យំ** *ដូច្នេះ ។ អ្នកដទៃសន្ទនឲ្យថា* **សុណាតុ មេ ។ ល ។ បត្តកល្លំ ឥត្ថន្នាមោ ឥត្ថន្នាមេន វិនយំ បុដ្ឋោ វិសជ្ជេយ្យ** *ដូច្នេះ ។ ក្នុងពាក្យថា* **ឥត្ថន្នាមោ ឥត្ថន្នាមេន** *នេះ ភិក្ខុឈ្មោះអ្វីឲ្យបញ្ចូលឈ្មោះនោះជំនួស ។ ពាក្យថា* **បរិសុទ្ធោ អហំ ភន្តេ បរិសុទ្ធោតិ មំ ជានេថ** *និងពាក្យថា* **បរិសុទ្ធោ អហំ អាវុសោ បរិសុទ្ធោតិ មំ ជានេហិ** *ទាំងពីរនេះ ប្រែថា ខ្ញុំព្រះករុណាជាអ្នកបរិសុទ្ធមិនមានអាបត្តិ លោកចូរទ្រទ្រង់ចាំទុកថា ខ្ញុំព្រះករុណាជាអ្នកបរិសុទ្ធចុះ ។ ឧបោសថនិងបវារណានេះដូចគ្នា តែបវារណាដែលមានប្លែកនោះនឹងពោលទៅខាងមុខ ។*

ឧបោសថកថា ចប់

វស្សូបនាយិកាកថា

ពោលអំពីវិធីចូលវស្សា ។ ការចូលវស្សាមានពុទ្ធានុញ្ញាតទុកថា **អនុជានាមិ ភិក្ខវេ វស្សានេ វស្សំ ឧបគន្តុំ**

។ ល ។ **ទ្វេ វស្សូបនាយិកា** តថាគតអនុញ្ញាតឲ្យចូលវស្សា ក្នុងរដូវក្ដៀង ។ ការចូលវស្សាមាន ២ គឺ **បុរិមិកា វស្សូបនាយិកា** ចូលវស្សាអំពីដំបូង គឺថ្ងៃព្រះចន្ទពេញវង់ សោយអាសាឡ្ហឫក្សកន្ទ្ធងទៅ ហើយ គឺជាថ្ងៃ ១ ពោចខែអាសាឡ្ហតាមកម្ពុជប្រទេសចារិតនេះ ជាថ្ងៃ ចូលវស្សាអំពីដំបូង ១ **បច្ឆិមិកា វស្សូបនាយិកា** ចូលវស្សាខាង ក្រោយ គឺថ្ងៃព្រះចន្ទពេញវង់ សោយឫក្សឈ្មោះថា អាសាឡ្ហ:កន្ទ្ធងទៅ ហើយមួយខែ គឺថ្ងៃ ១ ពោចខែស្រាពណ៌ នេះជាថ្ងៃចូលវស្សាជាខាង ក្រោយ ១ ។ កាលចូលវស្សាគប្បីបដិបត្តិវិហារបោសច្រាសតាំងទឹកធាន់ ទឹកប្រើទុក ធ្វើសាមីចិកម្មទាំងឡាយមានថ្វាយបង្គំព្រះចេតិយជាដើម ស្រេចហើយ គប្បីបញ្ចេញវាចាថា **ឥមស្មឺ វិហារេ ឥមំ តេមាសំ វស្សំ ឧបេមិ** ដូច្នេះ ១ ដង ២ ដង ឬ ៣ ដង ចូលវស្សាចុះ ។ បើមាន អាល័យថា យើងនឹងនៅក្នុងទីនេះ តែដោយមិនមានសតិ មិនបានចូល វស្សាដោយបញ្ចេញវាចា សេនាសន:ដែលខ្លួនកាន់យកហើយអំពីសង្ឆ ក៏ឈ្មោះថាកាន់យកដោយប្រពៃ វស្សាមិនដាច់ គួរបានដើម្បីបវារណា ពិត ដ្បិតថាទោះរៀរចាកវចីភេទ សូម្បីដោយមាត្រាថា ធ្វើសេចក្ដី អាល័យ ក៏ឈ្មោះថាចូលវស្សាដោយពិត ចិត្តុប្បាទដែលគិតថា យើងនឹង នៅចាំវស្សាក្នុងទីនេះដូច្នេះ ឈ្មោះថាមានអាល័យក្នុងទីនេះ ។ ដល់ថ្ងៃចូល វស្សា មិនបានប្រាថ្នានឹងចូលវស្សា ក្ដែងកន្ទ្ធងដើរចៀសទៅចាកអាវាស ត្រូវទុក្កដ ។ កាលមិនបានចូលវស្សាអំពីដំបូងដោយមានអន្តរាយណាមួយ

គប្បីចូលវស្សាខាងក្រោយ ដ្បិតថាមិនចូលវស្សាសោះ ត្រូវទុក្កដ ។ ចាំវស្សាមិនមានសេនាសនៈ ត្រូវទុក្កដ ។ សេនាសនៈប្រក់ដោយគ្រឿងប្រក់ទាំង ៥ ណាមួយ និងប្រកបដោយទ្វារសម្រាប់បិទបើកបាន មិនមានដល់ភិក្ខុណា ភិក្ខុនោះឈ្មោះថា មិនមានសេនាសនៈ ។ ចាំវស្សាក្នុងខ្ទមខ្ទោច ក្នុងឆត្រ ក្នុងពាង ក្នុងរូងឈើ ក្នុងប្រគាបឈើ ទាំងអម្បាលនេះ ត្រូវទុក្កដ ។ តែក្នុងប៉ាធានិងធ្វើកុដិដទៃទ្បើង ចាំវស្សាក៏គួរ ។ តែក្នុងឆត្រ និងពាង និងរូងឈើ ប្រគាបឈើ ទាំងអម្បាលនេះមិនគួរ ។ បើទីទាំងអម្បាលនោះ មានដំបូល និងជញ្ជាំងទ្វារបើកបិទបាននេះគួរ ។ នឹងចូលវស្សាក្នុងវជៈ គឺទីអាស្រ័យនៅនៃមនុស្សចិញ្ចឹមគោ និងក្នុងពួករទេះ ក្នុងទូកក៏គួរ ។ ទីអាស្រ័យនៅ នៃមនុស្សចិញ្ចឹមគោនោះ គេលើកទៅខាងណា កាលបើទៅជាមួយ វស្សាមិនដាច់ មិនត្រូវអាបត្តិ ដ្បិតទ្រង់អនុញ្ញាតឲ្យទៅជាមួយ តែកាលនឹងចូលវស្សាក្នុងពួករទេះនោះ ដល់ថ្ងៃចូលវស្សា គប្បីនិយាយនឹងឧបាសកថា បើបានកុដិទើបគួរ បើគេធ្វើថ្វាយ គប្បីចូលទៅក្នុងកុដិនោះ ពោលថា **ឥ ១ ១ ១

ថ្ងៃនោះជាថ្ងៃបវារណាសោត គប្បីបវារណា ក្នុងពួករនេះនោះចុះ ។ បើពួករនេះដល់ទីដែលភិក្ខុប្រាថ្នាខាងក្នុងវស្សាហើយ គេចៀសចេញទៅ ភិក្ខុគប្បីនៅក្នុងទីដែលខ្លួនប្រាថ្នា ហើយបវារណាជាមួយនឹងភិក្ខុទាំងឡាយក្នុងទីនោះចុះ សូម្បីពួករនេះគេឈប់នៅក្នុងស្រុកមួយ ឬព្រាត់ប្រាសខ្ចាត់ខ្ចាយគ្នាទៅ ក្នុងរវាងខាងក្នុងវស្សា ក៏គប្បីនៅជាមួយនឹងភិក្ខុទាំងឡាយក្នុងស្រុកនោះ ហើយបវារណាចុះ នឹងមិនបវារណានឹងទៅតទៅមិនគួរ ។ សូម្បីកាលនឹងចូលវស្សាក្នុងទូក ក៏ត្រូវចូលក្នុងកុដិពិត កាលស្វែងរកកុដិមិនបាន គប្បីធ្វើសេចក្តីអាល័យចុះ បើក្នុងខាងក្នុង ៣ ខែ ទូកនៅក្នុងសមុទ្រនោះឯង ក៏គប្បីបវារណាក្នុងទូកនោះចុះ ថាបើទូកដល់ច្រាំង ភិក្ខុប្រាថ្នានឹងទៅខាងមុខទៀត នឹងទៅមិនគួរ គប្បីនៅក្នុងស្រុកដែលទូកដល់ ហើយបវារណាជាមួយនឹងភិក្ខុទាំងឡាយចុះ ។ ថាបើទូកទៅក្នុងទីដទៃតាមមាត់ច្រាំង សូម្បីភិក្ខុប្រាថ្នានឹងនៅក្នុងភូមិដែលទូកចូលដល់មុនពិត ទូកចូរទៅចុះ ភិក្ខុគប្បីនៅក្នុងភូមិនោះ ហើយបវារណាជាមួយនឹងភិក្ខុទាំងឡាយចុះ ។ ក្នុងវជ: និងក្នុងពួករនេះ ក្នុងទូក ទាំង ៣ នេះ មិនត្រូវអាបត្តិ ព្រោះដាច់វស្សារមែងបានដើម្បីបវារណាដោយប្រការដូច្នេះ ។

ចូលវស្សាមិននៅអស់ ៣ ខែជាដំបូង ឬ ៣ ខែខាងក្រោយ ចៀសចេញទៅកាន់ចារិក ត្រូវទុក្កដ ។ តែចូលវស្សាហើយ សូម្បីមិនញ៉ាំងអរុណឲ្យតាំងឡើង នឹងចៀសទៅចាកអាវាសក្នុងថ្ងៃនោះដោយសត្តាហ-

ករណីយ គឺកិច្ចនឹងគប្បីធ្វើ ៧ ថ្ងៃ នឹងត្រឡប់មកខាងក្នុង ៧ ថ្ងៃ មិនត្រូវអាបត្តិ ។ នៅ ២-៣ ថ្ងៃទើបចៀសចេញទៅដោយសត្តាហករណីយ-កិច្ចនឹងត្រឡប់មកខាងក្នុង ៧ ថ្ងៃ នឹងបាច់ពោលទៅថ្ងៃ ។ ឯនឹងទៅដោយសត្តាហករណីយកិច្ចបាននោះដូច្នេះ មនុស្ស ៧ ជំពូក គឺ ភិក្ខុ ១ ភិក្ខុនី ១ នាងសិក្ខមានា ១ សាមណេរ ១ សាមណេរី ១ មាតា ១ បិតា ១ ទាំងអម្បាលនេះមានជំងឺ ឬមានហេតុដទៃ មានកើតសេចក្តីរសាប់រសល់ឡើងជាដើម សូម្បីមិនបញ្ជូនទូតមកនិមន្ត នឹងទៅដោយសត្តាហករណីយកិច្ចដើម្បីនឹងរក្សាជំងឺ និងរំងាប់សេចក្តីរសាប់រសល់ជាដើមក៏គួរ ។ តែមនុស្ស ២ ជំពូក គឺឧបាសក ឧបាសិកា គេសាងវិហារជាដើមនិងបញ្ជូនទូតមកឲ្យនិមន្តភិក្ខុទៅ ដើម្បីនឹងថ្វាយទាននិងស្តាប់ធម៌ជាដើម គប្បីទៅដោយសត្តាហករណីយកិច្ចចុះ កាលគេមិនបញ្ជូនទូតមកនិមន្ត កុំគប្បីទៅ ។ មួយទៀត នឹងទៅដោយកិច្ចសង្ឃ មានកាប់ឈើមកជួសជុលសេនា-សនៈជាដើមក៏គួរ ។

មួយទៀត នៅចាំវស្សាហើយ សត្វកាច ឬពស់ ចោរ ឬបិសាចបៀតបៀន និងគោចរគ្រាមភ្លើងឆេះ ឬទឹកលិចបន្សាត់ទៅក្តី ឬសេនា-សនៈភ្លើងឆេះ ឬអណ្តែតទឹកទៅក្តី ភិក្ខុលំបាកដោយបិណ្ឌបាត និងសេនាសនៈ នឹងមិនបានរបស់ធាន់ល្មមឆ្អែត ឬរបស់ធាន់ដែលជារបស់សប្បាយ ឬមិនបានកេសជ្ជៈដែលជារបស់សប្បាយ និងមនុស្សឧបដ្ឋាកដែលសមគួរ ហើយចៀសចេញទៅដោយគិតថា នេះជាអន្តរាយដូច្នេះ ក៏មិនត្រូវអាបត្តិ តែវស្សាដាច់ ។

មួយទៀត ស្រុកគោចរគ្រាម គេរត់នឹងចោរទៅអស់ ភិក្ខុនឹងទៅតាមអ្នកស្រុកក៏គួរ មួយទៀត នៅចាំវស្សា ស្រី ឬស្រីពេស្យាជាដើម មកលួងលោមថានឹងឲ្យប្រាក់មាសស្រែចំការ គោ និងទាស: ធីតា ភរិយា ឬឃើញកំណប់ទ្រព្យមិនមានម្ចាស់របស់ក្តី នឹងគិតថា ព្រះពុទ្ធអង្គទ្រង់ត្រាស់ទុកថា ចិត្តរមែងប្រែប្រួលរហ័ស អន្តរាយដល់ព្រហ្មចរិយ: នឹងគប្បីមានដល់យើង ដូច្នេះ ហើយចៀសចេញទៅ មិនត្រូវអាបត្តិ តែវស្សាដាច់ ។

មួយទៀត បានឃើញឬបានឮភិក្ខុទាំងឡាយ ព្យាយាមនឹងទម្លាយសង្ឆ នឹងគិតថា ព្រះអង្គទ្រង់ត្រាស់ទុកថា សង្ឆកេទជាគរុកម្ម កាលយើងនៅចំពោះមុខ កុំឲ្យសង្ឆបែកឡើយដូច្នេះ ហើយចៀសចេញទៅក្តី ឬបានឮថាក្នុងអាវាសឯណោះ ភិក្ខុនិងភិក្ខុនីព្យាយាមនឹងទម្លាយសង្ឆ និងគិតថាភិក្ខុទាំងអម្បាលនោះជាមិត្តសម្លាញ់នៃយើង យើងនឹងទៅដាស់តឿនហាមប្រាមលោក លោកគង់នឹងស្តាប់ពាក្យយើងដូច្នេះ ហើយចៀសចេញទៅមិនត្រូវអាបត្តិ តែវស្សាដាច់ ហើយនឹងបវារណាមិនបាន ។

មួយទៀត គេនិមន្តឲ្យចាំវស្សា ៣ ខែ នឹងទទួលនិមន្តគេហើយធ្វើឲ្យឃ្លាតទៅត្រូវបដិស្សវទុក្កដ មិនមែនតែធ្វើសេចក្តីនិមន្តចូលវស្សាឲ្យឃ្លាតម្យ៉ាងប៉ុណ្ណោះទេ សូម្បីគេនិមន្តថា លោកចូរទទួលកិច្ចាអស់ ៣ ខែ ឬប្តេជ្ញាគ្នាថា យើងទាំងពីរនឹងចាំវស្សាក្នុងទីនេះ នឹងរៀនបាលីក្នុងទីជាមួយគ្នាក្តី ទទួលហើយ ធ្វើឲ្យឃ្លាតទៅត្រូវទុក្កដ តែទុក្កដនោះ ព្រោះបឋមចិត្តបរិសុទ្ធ ចំណែកខាងក្រោយធ្វើឲ្យឃ្លាត បើដំបូងមានចិត្តមិន

បរិសុទ្ធ ត្រូវបាចិត្តិយ ព្រោះទទួលប្តេជ្ញា ត្រូវទុក្កដ ព្រោះធ្វើសេចក្តីទទួលឲ្យឃ្ងាត ។

មួយទៀត លោកប្រដៅទុកថា ភិក្ខុអ្នកចូលវស្សា គប្បីពោលដល់ភិក្ខុដែលតម្កល់និពន្ធវត្តទុកក្នុងខាងក្នុងវស្សា ឲ្យចងអំបោសទុក បើដងនិងបន្ទោះរកបានងាយ មួយអង្គ១ គប្បីចងអំបោសទុក ៥-៦ បាច់ ធ្វើដងទុកបាន ២ ឬ ៣ បើដងនិងបន្ទោះរកក្រ គប្បីចងអំបោស ២-៣ បាច់ ចងអំបោសដែលមានដងទុកបាន ១ សាមណេរទាំងឡាយគប្បីសាប់ដំ គប់ទុកម្នាក់បាន ៥ បាច់ៗ ក្នុងទីលំនៅ គប្បីប្រោះព្រំដោយទឹកអម្ងត់ សូម្បីកាលនឹងកតិកាគ្នា កុំគប្បីធ្វើអធម្មិកវត្ត គឺហាមគ្នាថា កុំប្រាប់បាលី កុំរៀនបាលី កុំស្វាធ្យាយ កុំបំបួសកុលបុត្រ និងកុំឲ្យឧបសម្បទា កុំឲ្យនិស្សយ កុំធ្វើធម្មស្សវនៈ ដ្បិតថាអាការដែលធ្វើទាំងពួងនោះ ជាការយឺតយូរ យើងទាំងឡាយជាមនុស្សមិនយឺតយូរ នឹងធ្វើតែសមណធម៌ម្យ៉ាងចុះ ឬទាំងអស់គ្នាចូរសមាទានកាន់ធុតង្គទាំង ១៣ យ៉ាង កុំសម្រេចការដេក ចូរឲ្យថ្ងៃយប់កន្ទងទៅដោយការឈរនិងចង្ក្រមន៍ចុះ ចូរកាន់យកមូគវត្ត សូម្បីអ្នកទៅដោយសត្តាហករណីយកិច្ច កុំគប្បីបានរបស់ចែកដូច្នេះឈ្មោះថាអធម្មិកវត្ត បើធ្វើត្រូវទុក្កដ ។ មូគវត្តនោះ គឺប្រកាន់មិននិយាយគ្នា ធ្វើដូច្នោះត្រូវទុក្កដ ។ គប្បីធ្វើកតិកាគ្នាដូច្នេះថា ធម្មតាបរិយត្តិធម៌ រមែងញ៉ាំងសទ្ធម្មទាំង ៣ ឲ្យខ្ជាប់ខ្ជួន ព្រោះហេតុនោះ លោកទាំងឡាយ ចូរសម្តែង និងរៀន ស្វាធ្យាយ ដោយគោរពចុះ

កុំធ្វើសេចក្ដីខ្ជាំងខ្ជប់ ដល់ភិក្ខុដែលនៅក្នុងបធានឃរ: គឺទីចម្រើនសមណធម៌ គប្បីទៅខាងក្នុងវិហារប្រាប់រៀនស្វាធ្យាយចុះ ចូរធ្វើធម្មស្សវន:ឲ្យមាំមួន កាលនឹងឲ្យកុលបុត្របួស គប្បីជម្រះឲ្យផុតបព្វជ្ជា-ទោស ជម្រះហើយឲ្យបព្វជ្ជា ជម្រះឲ្យផុតទោសហើយ ឲ្យឧបសម្បទា ជម្រះហើយឲ្យនិស្សយ ដ្បិតថាកុលបុត្រម្នាក់បានបព្វជ្ជានិងឧបសម្បទា នឹងញ៉ាំសាសនាទាំងអស់ឲ្យបិតថេរនៅបាន អ្នកទាំងឡាយ អាចសមាទានទូវធុតង្គ៦ប៉ុន្ម្មានដោយកម្ទាំងរបស់ខ្លួនបាន គប្បីសមាទានធុតង្គ៦ប៉ុណ្ណោះចុះ ក្នុងខាងក្នុងវស្សា ថ្ងៃទាំងអស់ និងយប់ក្នុងយាមដំបូងនិងបំផុត ចូរកុំប្រមាទ គប្បីប្រារព្ធសេចក្ដីព្យាយាមចុះ សូម្បីព្រះមហាថេរទាំងឡាយអំពីមុន លោកក៏រមែងកាត់បលិពោធទាំងពួង ហើយបំពេញឯកចារិយវត្ត នៅតែម្នាក់ឯងខាងក្នុងវស្សា ។

មួយទៀត គប្បីដឹងប្រមាណក្នុងការពោលការប្រារព្ធពោលកថាវត្ត ១០ ប្រារព្ធអសុក ១០ ប្រារព្ធអនុស្សតិ ១០ ប្រារព្ធអារម្មណ៍ ៣៨ ទើបគួរ គប្បីធ្វើវត្តដល់អាគន្ទុក: និងអបលោកន៍ ឲ្យរបស់ដល់ភិក្ខុទៅដោយសត្ការណីយកិច្ច ទើបគួរ កតិកាគ្នាដូច្នេះ ឈ្មោះថាធម្មិកវត្ត គប្បីធ្វើចុះ ។

មួយទៀត គប្បីប្រដៅភិក្ខុទាំងឡាយ កុំឲ្យពោលពាក្យទាស់ទែងពាក្យញុះញង់ចាក់ដោត ពាក្យទ្រគោះ ចូរពិចារណាដល់សីលកុំឲ្យចតុរារ័ក្ខសាបសូន្យទៅ ចូរមានមនសិការ: គឺធ្វើទុកក្នុងចិត្តឲ្យច្រើនរាល់ថ្ងៃៗចុះ ។

មួយទៀត គប្បីប្រាប់វត្តក្នុងទីដែលនឹងទំពាឈើស្ងួន កាលថ្វាយបង្គំ ព្រះចេតិយ ឬពោធិព្រឹក្ស ឬបូជាដោយគន្ធមាលាគ្រឿងក្រអូបកម្រងផ្កា ឬយកបាត្រច្រកក្នុងថង់កុំនិយាយ គប្បីប្រាប់ភិក្ខាចារវត្ត កុំគប្បីនិយាយ ប្រកបដោយបច្ច័យ ឬពាក្យមិនសមគួរ ជាមួយនឹងមនុស្សខាងក្នុងស្រុក គប្បីរក្សាឥន្ទ្រិយ គប្បីបំពេញខន្ធកវត្ត និងសេខិយវត្ត ។ ពាក្យពោល ជានិយ្យានិក: ដែលនឹងនាំចេញចាកទោស ទុក្ខដូច្នេះ គប្បីនិយាយ គប្បីប្រាប់ដល់គ្នានិងគ្នា ។

ពាក្យថា **ឥមស្មឺ វិហារេ ឥមំ តេមាសំ វស្សំ ឧបេមិ** ប្រែថា យើងចូលទៅជិតកាន់វស្សាអស់ត្រៃមាស ក្នុងវិហារ នេះ ។ ក៏ឯវិហារស័ព្ទនេះ ក្នុងបាលីច្រើនជាឈ្មោះនៃកុដិ ក្នុង អដ្ឋកថាខ្ទះថា ជាឈ្មោះនៃកុដិ ខ្ទះថាជាឈ្មោះនៃវត្ត ក្នុងបទនេះជាឈ្មោះ នៃកុដិឬវត្តក៏មិនប្រាកដ ព្រោះហេតុនោះ អធិដ្ឋានវស្សាព្រមគ្នាក្នុង ទីប្រជុំហើយ មកដល់កុដិអធិដ្ឋានដោយពាក្យនោះទៀត ទើបជាការល្អ សមដូចបាលីថា **ចាជិបនេ វិហារំ ឧបេតិ សេនាសនំ បញ្ញបេតិ** ដូច្នេះ ។ មួយទៀត ក្នុងទីប្រជុំពោលព្រមគ្នាថា **ឥមស្មឺ អាវាសេ ឥមំ តេមាសំ វស្សំ ឧបេមិ** ដូច្នេះ ក៏បាន ដ្ឋិតថា អាវាសស័ព្ទ ក្នុងបាលីថាឈ្មោះនៃវត្តដោយច្រើន ។

មួយទៀត ពោលដូច្នោះ ក៏សមក្នុងបាលីថា **ទ្វីសុ អាវាសេសុ វស្សំ វសតិ** ។ ដូច្នេះ ក៏ឯប្រជុំគ្នាហើយពោលពាក្យអធិដ្ឋានព្រមគ្នា នេះជាបូរាណគតិ ដើម្បីនឹងសម្តែងសាមគ្គី គឺសេចក្តីព្រមព្រៀង ។

មួយទៀត ពាក្យអធិដ្ឋានវស្សាសោត ក៏មិនមែនបាលីព្រះពុទ្ធដីកា គ្រាន់តែជាពាក្យអដ្ឋកថា ព្រោះហេតុនោះ ទើបលោកពោលថា ធ្វើតែសេចក្ដីអាល័យក៏បាន ។

មួយទៀត បូរាណគតិតមក លោកប្រាប់ខេត្តវត្ត និងប្រាប់ឲ្យស្គាល់អរុណ អរុណក្រហមរះឡើងមកហើយ ភិក្ខុអាចចេញចាកវត្តបាន បើចូលវត្តវិញ ឲ្យទាន់អរុណស មុនអរុណក្រហម ។

វស្សូបនាយិកាកថា ចប់

បវារណាកថា

ពោលអំពីការបវារណា មានពុទ្ធានុញ្ញាតថា **អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ ។ ល ។ បដិការិស្សាមិ** *តថាគតអនុញ្ញាតឲ្យភិក្ខុដែលនៅចាំវស្សាអស់រដូវភ្ជៀងហើយ បវារណាដោយបទ ៣ សណ្ឋាន គឺដោយបានឃើញ ដោយបានឮ ដោយបានរង្កៀស បវារណានោះ ជាសេចក្ដីអនុលោមដល់គ្នានិងគ្នា និងជាសេចក្ដីញ៉ាំងគ្នានិងគ្នា ឲ្យចេញចាកអាបត្តិ និងជាសេចក្ដីធ្វើវិន័យក្នុងខាងមុខដល់គ្នានិងគ្នា នៃអ្នកទាំងឡាយ ភិក្ខុទាំងឡាយ គប្បីបវារណាយ៉ាងនេះ ឲ្យភិក្ខុដែលឈ្វាសប្រកាសឲ្យសង្ឆដឹងដោយញត្តិថា* **សុណាតុ**

មេ ភន្តេ សង្ឆោ អជ្ជ បវារណា បណ្ណ្ណរសី ។ យទិ សង្ឆស្ស បត្តកល្លំ, សង្ឆោ បវារេយ្យ ។ *ដូច្នេះហើយ ភិក្ខុជាថេរៈគប្បីធ្វើចីវរធ្យៀងស្មាម្ខាង អង្គុយច្រហោងលើកដៃប្រណម្យ ពោលនឹងសង្ឆថា* **សង្ឆំ អាវុសោ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្ការេ យ វ, វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧចាគាយ, បស្សន្តោ បដិការិស្សាមិ ។ ទុតិយម្ឌិ អាវុសោ ។ ល ។ តតិយម្ឌិ អាវុសោ ។ ល ។ បវារេមិ ។ ល ។ បដិការិស្សាមិ ។** *ដូច្នេះហើយ ភិក្ខុកំលោះមួយអង្គ១ គប្បីធ្វើសំពត់ឧត្តរាសង្គធ្យៀងស្មាម្ខាង អង្គុយច្រហោងលើកដៃប្រណម្យ ពោលនឹងសង្ឆថា* **សង្ឆម្ភន្តេ បវារេមិ ។ ល ។ បដិ-ការិស្សាមិ ។ ទុតិយម្ឌិ ភន្តេ ។ ល ។ តតិយម្ឌិ ភន្តេ សង្ឆ ។ ល ។ បដិការិស្សាមិ** *វិធីដូច្នេះ ឈ្មោះថាបវារណា ។ ក៏ឯបវារណានោះ ពោលដោយថ្ងៃមាន ៣ គឺ ចាតុទ្ទសី ថ្ងៃ ១៤ បណ្ណ្ណរសី ថ្ងៃ ១៥ និងសាមគ្គី ថ្ងៃដែលសង្ឆព្រមព្រៀង ។ ពាក់អំពីថ្ងៃឧបោសថ មុនមកបាន ១៤ ថ្ងៃ ឲ្យតាំងញត្តិថា* **អជ្ជ បវារណា ចាតុទ្ទសី ។** *បើបាន ១៥ ថ្ងៃឲ្យតាំងញត្តិថា* **អជ្ជ បវារណា បណ្ណ្ណរសី** *ដូច្នេះ ។ បើចាំបុរិមិកាវស្សា ឲ្យធ្វើបវារណា ក្នុងថ្ងៃពេញបូណ៌មីខែអស្សុជ ។ បើវ៉ាទដោយការជម្ងោះឲ្យទាញបវារណាទៅដល់ថ្ងៃដាច់នៃខែអស្សុជ ឬ ថ្ងៃពេញបូណ៌មីខែកត្តិក ។ បើចាំបច្ឆិមិកាវស្សា ឲ្យធ្វើបវារណាក្នុងថ្ងៃ*

ពេញបូណ៌មីខែកត្តិក ក្នុងចន្ទោះ ១ ខែ លើកថ្ងៃ ២ ចេញ ជាខេត្តនៃថ្ងៃសាមគ្គីបវារណា ដូចពោលហើយក្នុងឧបោសថ ។

មួយទៀត បវារណាពោលដោយអ្នកធ្វើមាន ៣ គឺសង្ឆបវារណា ១ គណបវារណា ១ បុគ្គលបវារណា ១ ។ ភិក្ខុតាំងអំពី ៥ អង្គឡើងទៅឈ្មោះថាសង្ឆ គប្បីធ្វើបវារណា ដូចពោលហើយអំពីមុននោះចុះ ។ ភិក្ខុ ៤-៣-២- អង្គឈ្មោះថាគណ: គប្បីធ្វើបវារណាដូច្នេះ បើ ៤-៣ អង្គ ឲ្យភិក្ខុអ្នកឈ្វាសគប្បីប្រកាសឲ្យដឹងដោយគណញត្តិថា ៖

សុណាតុ មេ អាយស្មន្តោ អជ្ជ បវារណា បណ្ណរសី ។ យទាយស្មន្តានំ បត្តកល្លំ, មយំ អញ្ញមញ្ញំ បវារយ្យាម ។ ដូច្នេះ ហើយភិក្ខុជាថេរ:គប្បីធ្វើចីវរធ្យៀងស្មាម្ខាង អង្គុយច្រហោងលើកដៃប្រណាម្យពោលនឹងភិក្ខុទាំងឡាយនោះថា **អហំ អាវុសោ អាយ-ស្មន្តេ បវារេមិ ។ ល ។ បដិការិស្សामិ ។ ទុតិយម្ឌិ អាវុសោ ។ ល ។ តតិយម្ឌិ អាវុសោ អាយស្មន្តេ បវា-រេមិ ។ ល ។ បដិការិស្សामិ** ។ ដូច្នេះ ហើយភិក្ខុកំលោះគ្រប់ៗអង្គ គប្បីធ្វើដូច្នោះដោយលំដាប់ ពោលថា **អហំ ភន្តេ អាយស្មន្តេ ។ ល ។ បដិការិស្សामិ ។ ល ។ ទុតិយម្ឌិ ភន្តេ ។ ល ។ តតិ-យម្ឌិ ភន្តេ អាយស្មន្តេ បវារេមិ ។ ល ។ បដិការិស្សामិ** ដូច្នេះ ។ បើ ២ អង្គមិនត្រូវតាំងញត្តិ ប្រជុំគ្នាហើយ ភិក្ខុជាថេរ គប្បីឃ្ងុំចីវរធ្យៀងស្មាម្ខាង អង្គុយច្រហោងលើកដៃប្រណាម្យ ពោលនឹងភិក្ខុ

កំលោះថា **អហំ អាវុសោ អាយស្មន្តំ បវារេមិ ។ ល ។ វទតុ មំ អាយស្មា ។ ល ។ បដិការិស្សामि ។ ទุតិយម្ពិ អាវុសោ ។ ល ។ តតិយម្ពិ អាវុសោ អាយស្មន្តំ បវារេមិ ។ ល ។ បដិការិស្សামি** *។ ដូច្នេះហើយ ភិក្ខុកំលោះគប្បីធ្វើដូច្នោះ ពោលនឹងព្រះថេរថា* **អហំ ភន្តេ អាយ-ស្មន្តំ បវារេមិ ។ ល ។ បដិការិស្សামি ។ ទุតិយម្ពិ ភន្តេ ។ ល ។ តតិយម្ពិ ភន្តេ អាយស្មន្តំ បវារេមិ ។ ល ។ បដិការិស្សামি** *ដូច្នេះ ។ យ៉ាងនេះឈ្មោះថាគណបវា-រណា ។ មួយអង្គឈ្មោះថាបុគ្គល នៅមួយអង្គដល់ថ្ងៃបវារណា គប្បីធ្វើបុព្វករណៈមានបោសពោងបវារណាជាដើម ហើយអង្គុយចាំភិក្ខុដទៃក្នុងសីមា ភិក្ខុដទៃមកគប្បីធ្វើសង្ឆបវារណា ឬគណបវារណាជាមួយនឹងភិក្ខុនោះ តាមច្រើនតាមតិច បើឃើញថាមិនមក គប្បីអធិដ្ឋានថា* **អជ្ជ មេ បវារណា** *ដូច្នេះ ក្នុងអដ្ឋកថា ប្រាប់ថាឲ្យថែមថ្ងៃចូលផងថា* **អជ្ជ មេ បវារណា ចาตุទ្ទសីតិ**[1] **អធิដ្ឋามि** *ដូច្នេះ តាមថ្ងៃ ១៤-១៥ យ៉ាងនេះ ឈ្មោះថាបុគ្គលបវារណា ។ មួយទៀត បូរាណាចារ្យ លោកពោលទុកថា បវារណាមាន ៥ ប្រការ ដូចឧបោសថ តែមិនបញ្ញត្តឈ្មោះទុកឲ្យអស់ ចំណែកក្នុងមូលសិក្ខា ពោលថាបវារណា ពោលដោយអាការនឹងគប្បីធ្វើមាន ៣ គឺ តេរាចិកបវារណា ១ ទ្វេរាចិ-កបវារណា ១ ឯករាចិកបវារណា ១ ។*

(១) បើថ្ងៃ ១៥ ថាបណ្ណរសីតិ ជួស ចาตุទ្ទសីតិ ។

មួយទៀត បើពោលថាញត្តិបារាណា អញត្តិបារាណា និងអធិដ្ឋាន-បារាណាដូច្នេះក៏បាន ។ ញត្តិបារាណាមាន ២ គឺសង្ឆញត្តិបារាណា ១ គណញត្តិបារាណា ១ ។ អញត្តិបារាណាក៏មាន ២ គឺភិក្ខុ ២ អង្គបារាណាដល់គ្នា ១ ភិក្ខុមួយអង្គ ឬពីរអង្គ ឬអំពីបីអង្គឡើងទៅ បារាណាក្នុងសំណាក់ភិក្ខុដទៃដែលច្រើនជាង ធ្វើឧបោសថហើយ ១ ជា ២ ។ អធិដ្ឋានបារាណាគឺបុគ្គលបារាណានោះឯង ។

មួយទៀត តាំងសង្ឆញត្តិមាន ៥ គឺតាំងជាសព្វសង្គាហិកា ១ តាំងជា តេរាចិកា ១ តាំងជាទ្វេរាចិកា ១ តាំងជាឯករាចិកា ១ តាំងជាសមាន-វស្សិកា ១ ។ តាំងសូត្រថា **សុណាតុ ។ ល ។ បត្តកល្ល** *ហើយចុះខាងចុងថា* **សង្ឆោ បារាយ** *ដូច្នេះ ឈ្មោះថាសព្វសង្គា-ហិកញត្តិ កាលតាំងញត្តិដូច្នេះហើយ បារាណាមួយអង្គៗ ៣ ដង និងមួយអង្គៗ ២ ដង មួយអង្គៗ ម្តងក៏គួរ តែវស្សាស្មើគ្នា នឹងបារាណាព្រមគ្នាម្យ៉ាងមិនគួរ ។ កាលតាំងញត្តិចុះខាងចុងថា* **សង្ឆោ តេរាចិកំ បារាយ** *ដូច្នេះហើយ បារាណាមួយអង្គ ៣ ដងទើបគួរ យ៉ាងដទៃមិនគួរ ។ កាលតាំងញត្តិថា* **សង្ឆោ ទ្វេរាចិកំ** *បារាយ ដូច្នេះហើយ នឹងបារាណាមួយអង្គ ២ ដង ឬមួយអង្គ ៣ ដងក៏គួរ តែបារាណាមួយអង្គអស់វារៈម្តង និងវស្សាស្មើគ្នាថាព្រមគ្នាមិនគួរ ។ កាលតាំងញត្តិចុះខាងចុងថា* **សង្ឆោ ឯករាចិកំ** *បារាយ ដូច្នេះហើយ នឹងបារ-ណាមួយអង្គអស់វារៈម្តង ឬមួយអង្គអស់វារៈ ២ ដង ឬ ៣ដងក៏គួរ តែវស្សា*

ស្មើគ្នាថាព្រមគ្នាម្យ៉ាងមិនគួរ ។ កាលតាំងញត្តិចុះខាងចុងថា **សង្ឆោ សមានវស្សិកំ បវារេយ្យ** ដូច្នេះហើយបវារណាទាំងអស់គ្នាក៏គួរ ។ ដែលបវារណាមួយអង្គអស់វារៈ ២ ដង មួយអង្គអស់វារៈម្តងនិងវស្សាស្មើគ្នាថាព្រមគ្នាដូច្នេះ លុះតែមានហេតុទើបធ្វើបាន កាលមិនមានហេតុនឹងធ្វើមិនគួរ ហេតុនោះជាដើមថា ទាយកកំពុងថ្វាយទាន ឬភិក្ខុកំពុងស្តាប់ធម៌ ពាត្រីទៀបនឹងអស់ទៅ បវារណាមួយអង្គ ៣ ដងមិនទាន់ ឬមានអន្តរាយទាំង ១០ ប្រការណាមួយ បវារណាមួយអង្គ ៣ ដងមិនទាន់ ឲ្យបវារណាមួយអង្គៗ ២ដង កាលបវារណាមួយអង្គៗ ២ ដងមិនទាន់ ឲ្យបវារណាមួយអង្គម្តងៗ កាលថាមួយអង្គម្តងៗ មិនទាន់ ដែលមានវស្សាស្មើគ្នាឲ្យថាព្រមគ្នា តែត្រូវតាំងញត្តិដូច្នេះជាមុនថា **សុណាតុ មេ ភន្តេ សង្ឆោ អយំ ព្រហ្មចរិយន្តរាយោ ។ សចេ សង្ឆោ តេវាចិកំ បវារេស្សតិ, អប្ប្ការិតោវ សង្ឆោ ភវិស្សតិ, អថាយំ ព្រហ្មចរិយន្តរាយោ ភវិស្សតិ ។ យទិ សង្ឆស្ស បត្តកល្ល, សង្ឆោ ទ្វេវាចិកំ ។ ល ។ ឯកវាចិកំ ។ ល ។ សមានវស្សិកំ បវារេយ្យ** ។ ដូច្នេះ ហើយគប្បីបវារ-ណាតាមញត្តិនោះចុះ ដូច្នេះពោលលួមជាបែបយ៉ាង កាលបើមានហេតុដទៃ គប្បីតាំងញត្តិផ្ទាស់ទៅតាមហេតុនោះចុះ ។

មួយទៀត បវារណាកម្មមាន ៤ បើក្នុងអាវាសមួយកាលភិក្ខុនៅ ៥ អង្គ នាំបវារណានៃភិក្ខុមួយអង្គទៅ ភិក្ខុ ៤ អង្គតាំងគណញត្តិហើយបវារណាគ្នា

ឬនៅ ៤-៣ អង្គ នាំបារាណានៃភិក្ខុមួយអង្គទៅ ភិក្ខុ ៣ អង្គ ឬ ២ អង្គតាំងសង្ឆាញត្តិហើយបារាណាគ្នានិងគ្នា បារាណាកម្មទាំងពួងនេះឈ្មោះថា **អ**ធម្មេ**ន** **វ**ក្តំ ជាវគ្គមិនតាមធម៌ ។ ថាបើ ៥ អង្គប្រជុំក្នុងទីជាមួយគ្នាទាំងអស់ តាំងគណាញត្តិហើយបារាណា ឬ ៤-៣-២ អង្គនៅជាមួយគ្នាប្រជុំក្នុងទីជាមួយគ្នា តាំងសង្ឆាញត្តិហើយបារាណាគ្នា បារាណាកម្មទាំងពួងនេះឈ្មោះថា **អ**ធម្មេ**ន** **ស**មក្តំ ព្រមព្រៀងគ្នា តែមិនតាមធម៌ ។ ថាបើភិក្ខុ ៥ អង្គ នាំបារាណានៃភិក្ខុមួយអង្គទៅ ភិក្ខុ ៤ អង្គតាំងសង្ឆាញត្តិហើយបារាណា ឬ ៤-៣ អង្គ នាំបារាណានៃភិក្ខុមួយអង្គទៅ ភិក្ខុ ៣ អង្គ ឬ ២ អង្គតាំងគណាញត្តិ ហើយបារាណាគ្នានិងគ្នា បារាណាកម្មទាំងពួងនេះឈ្មោះថា **ធ**ម្មេ**ន** **វ**ក្តំ ជាវគ្គតែតាមធម៌ ។ ថាបើភិក្ខុ ៥ អង្គប្រជុំគ្នាក្នុងទីមួយ តាំងសង្ឆាញត្តិហើយបារាណា ភិក្ខុ ៤ អង្គ ឬ ៣ អង្គប្រជុំក្នុងទីជាមួយគ្នា តាំងគណាញត្តិហើយបារាណា និងភិក្ខុ ២ អង្គបារាណាដល់គ្នានិងគ្នា នៅតែមួយអង្គ ធ្វើអធិដ្ឋានបារាណា បារាណា-កម្មទាំងពួងនោះឈ្មោះថា **ធ**ម្មេ**ន** **ស**មក្តំ ព្រមព្រៀងគ្នាតាមធម៌ ក្នុងកម្មទាំង ៤ នេះ ៣ ខាងដើមមិនគួរ គួរតែខាងចុងប៉ុណ្ណោះ ។

មួយទៀត កាលព្រះថេរៈអង្គុយច្រហោងកំពុងបារាណា ភិក្ខុកំលោះ អង្គុយពាបចុះលើអាសនៈ ត្រូវទុក្កដ ។ ដ្បិតទ្រង់ឃាត់ទុកថា **ន ភិក្ខវេ ថេរេសុ ភិក្ខូសុ ឧក្កុដិកានិសិន្នេសុ បារិ-**

យមានេសុ អច្ឆិតព្ពំ យោ អច្ឆេយ្យ អាបត្តិ ឧក្កដ**ស្ស** ដូច្នេះ ។ ហើយទ្រង់អនុញ្ញាតឲ្យអង្គុយច្រហោងបវារណាតទៅ ក្នុងសម័យនោះ ព្រះថេរមួយរូបទុព្វលដោយជរា អង្គុយច្រហោង រង់ចាំភិក្ខុដែលបវារណា ហើយសន្ទប់ដួលចុះ ព្រះអង្គទ្រង់អនុញ្ញាតទៀត ឲ្យអង្គុយច្រហោងក្នុងលំដាប់នោះ ទម្រាំខ្ជូនបវារណាហើយ បវារណាហើយ ឲ្យអង្គុយរាបលើអាសនៈ វិនិច្ឆ័យក្រៅនោះ គប្បីដឹងដូចពោលហើយក្នុងឧបោសថ ។

នឹងពោលបាលីមុត្តកៈ វិនិច្ឆ័យតាមអដ្ឋកថា បើភិក្ខុចាំបុរិមិកាវស្សា ៥ អង្គ ចាំបច្ឆិមិកាវស្សា ៥ អង្គ កាលអ្នកចាំវស្សាអំពីដំបូង តាំងញត្តិបវារណាហើយ ភិក្ខុចាំវស្សាខាងក្រោយ គប្បីធ្វើបារិសុទ្ធិឧបោសថក្នុងសំណាក់នៃភិក្ខុចាំវស្សាអំពីដំបូងនោះចុះ កុំគប្បីតាំងញត្តិ ២ ដង ក្នុងរោងឧបោសថ ១ សូម្បីភិក្ខុចាំវស្សាខាងក្រោយ ៤ អង្គ ឬ ៣-២-១ អង្គ ន័យនោះក៏ដូចគ្នាពិត បើភិក្ខុចាំវស្សាអំពីដំបូង ៤ អង្គ ភិក្ខុចាំវស្សាខាងក្រោយ ៤ អង្គ ឬ ៣-២-១ អង្គ ន័យនោះក៏ដូចគ្នាពិត បើភិក្ខុចាំវស្សាដំបូង ៣ អង្គ ចាំវស្សាខាងក្រោយ ៣-២-១ អង្គ ន័យនោះក៏ដូចគ្នាដែរ ដូច្នេះឯងជាលក្ខណៈ ក្នុងបវារណាកម្មនេះ ។ បើភិក្ខុចាំវស្សាខាងក្រោយតិចជាង ឬស្មើគ្នានឹងភិក្ខុចាំវស្សាអំពីដំបូងសោត រមែងជាគណបូរកៈនៃសង្ឆបវារណាបាន គប្បីតាំងញត្តិជាសង្ឆបវារណាចុះ ។ បើភិក្ខុចាំវស្សាអំពីដំបូង ៣ អង្គជា ៤ នឹងភិក្ខុចាំវស្សាខាងក្រោយ ១ អង្គ

ភិក្ខុ ៤ អង្គ នឹងតាំងសង្ឆញ្ញត្តិហើយបវារណាមិនគួរ តែភិក្ខុ ១ អង្គនោះ រមែងជាគណាបូរកៈនៃគណាញត្តិបាន ព្រោះហេតុនោះ ភិក្ខុចាំវស្សាដំបូង ៣ អង្គ តាំងគណាញត្តិហើយ គប្បីបវារណាចុះ ភិក្ខុចាំវស្សាខាងក្រោយ ១ អង្គ គប្បីធ្វើបារិសុទ្ធិឧបោសថ ក្នុងសំណាក់នៃភិក្ខុទាំងឡាយនោះចុះ ។ ភិក្ខុចាំវស្សាអំពីដំបូង ២ អង្គ ភិក្ខុចាំវស្សាខាងក្រោយ ២ អង្គ ឬ ១ អង្គ នយ័នោះក៏ដូចគ្នាដែរ ។ ភិក្ខុចាំវស្សាអំពីដំបូង ១ អង្គ ភិក្ខុចាំវស្សាខាងក្រោយ ១ អង្គ ដូច្នេះ ឲ្យភិក្ខុ ១ អង្គ គប្បីបវារណាក្នុងសំណាក់នៃភិក្ខុ ១ អង្គ ភិក្ខុ ១ អង្គ ធ្វើបារិសុទ្ធិឧបោសថ ក្នុងសំណាក់នៃភិក្ខុ ១ អង្គនោះចុះ ។ បើភិក្ខុចាំវស្សាខាងក្រោយច្រើនជាងភិក្ខុចាំវស្សាអំពីដំបូងសូម្បី ១ អង្គ គប្បីសូត្របាតិមោក្ខឡើងមុន ខាងក្រោយភិក្ខុតិចជាងគប្បីប-វារណាក្នុងសំណាក់នៃភិក្ខុច្រើននោះចុះ ។ តែក្នុងថ្ងៃបវារណា ពេញបូណ៌មីខែកត្តិក បើភិក្ខុចាំវស្សាខាងក្រោយច្រើនជាង ឬស្មើគ្នានឹងភិក្ខុចាំវស្សាអំពីដំបូង ដែលបានបវារណាហើយក្នុងថ្ងៃមហាបវារណានោះសោត គប្បីតាំងញត្តិបវារណា ហើយបវារណាចុះ ។ កាលភិក្ខុចាំវស្សាខាងក្រោយបវារណាហើយ ភិក្ខុចាំវស្សាអំពីដំបូង គប្បីធ្វើបារិសុទ្ធិឧបោសថក្នុងសំណាក់នៃលោកទាំងឡាយនោះចុះ ។ បើភិក្ខុច្រើនបវារណាហើយក្នុងថ្ងៃមហាបវារណា ភិក្ខុចូលវស្សាខាងក្រោយតិចជាង សូម្បី ១ អង្គ កាលសូត្របាតិមោក្ខហើយ ខាងក្រោយភិក្ខុតិចជាងនោះ គប្បីបវារណាក្នុងសំណាក់នៃភិក្ខុច្រើននោះចុះ ។

មួយទៀត ភិក្ខុចាំវស្សាអំពីដំបូងនៅជាផាសុវិហារ គឺនៅដោយ សប្បាយឃើញថាបវារណា ក្នុងថ្ងៃមហាបវារណា និងសូន្យផាសុវិហារ បង់ ហើយនឹងធ្វើបវារណាសង្គហៈ គឺធ្វើឧបោសថក្នុងថ្ងៃនោះ បង្ហន់ ថ្ងៃបវារណាទៅក្នុងថ្ងៃពេញបូណ៌មីខែកត្តិក ដោយញត្តិកម្មក៏បាន ។

បាលីបវារណាថា **សង្ឆ្យម្ភន្តេ បវារេមិ ។ ល ។ បដិការិស្សាមិ** *ប្រែថា ខ្ញុំព្រះករុណាសូមបវារណានឹងសង្ឆ្យដោយ ការបានឃើញ ឬដោយបានឮ ឬដោយបានរង្កៀស លោក ទាំងឡាយដ៏មានអាយុ អាស្រ័យនូវសេចក្ដីអនុគ្រោះ ចូរពោលដាស់ តឿនខ្ញុំព្រះករុណាចុះ កាលខ្ញុំព្រះករុណាឃើញនឹងធ្វើតាម ។ បវារណា ដោយពាក្យប៉ុណ្ណោះ ទើបជាសេចក្ដីអនុលោមដល់គ្នានិងគ្នា និងញ៉ាំង គ្នានិងគ្នាឲ្យចេញចាកអាបត្តិ និងធ្វើវិន័យក្នុងខាងមុខ ។*

<u>បវារណាកថា</u> ចប់

សីមាកថា

ពោលអំពីសីមាដោយសង្ខេប ។ ឧបោសថ បវារណា និងសង្ឆ្យកម្ម ទាំងពួង ភិក្ខុត្រូវធ្វើក្នុងខាងក្នុងសីមា ព្រះអង្គទ្រង់អនុញ្ញាតសីមាទុក ដើម្បីនឹងឲ្យដឹងថាជាដែនសាមគ្គី ដោយពាក្យថា **អនុជានាមិ ភិក្ខវេ**

សីមំ សម្មន្ដ្ដិតុំ ។ ល ។ ជារយាមិ ដូច្នេះ ។ ឯសីមានោះ មាន ២ គឺពទ្ធសីមា ១ អពទ្ធសីមា ១ ។ សីមាដែលសង្ឃចងនិមិត្ដដោយនិមិត្ដសម្ដ្ដ ឲ្យផុតចាកសីមាវិបត្ដិ ១១ ប្រកបដោយសម្ដ្ដ ៣ ឈ្មោះថាពទ្ធសីមា ។ សីមាវិបត្ដិ ១១ នោះគឺ សីមាតូចណាស់មិនល្មមភិក្ខុ ២០ អង្គ អង្គុយបាន ១ សីមាធំហួសលើស ៣ យោជន៍ឡើងទៅ សូម្បីត្រឹមមួយសរសៃសក់ ១ សីមាមាននិមិត្ដមិនតគ្នា គឺសួរនិមិត្ដដើមហើយ មិនត្រឡប់មកសួរនិមិត្ដដើមទៀត ឬយកវត្ថុណាមួយមិនគួរជានិមិត្ដបាន មកធ្វើជានិមិត្ដក្នុងចន្ទោះ ១ យកស្រមោលកន្ទុំជាដើមជានិមិត្ដ ១ មិនមាននិមិត្ដ ១ សួរនិមិត្ដហើយឈរខាងក្រៅនិមិត្ដសម្ដ្ដ ១ សម្ដ្ដក្នុងស្ទឹង ១ ក្នុងសមុទ្ទ ១ ក្នុងជាតស្រះ ១ សម្ដ្ដទម្ងាយសីមាចាស់នៃភិក្ខុដទៃដោយសីមាខ្លួន ១ សម្ដ្ដគ្របសង្កត់សីមាចាស់នៃភិក្ខុដទៃ ១ ដូច្នេះ ឈ្មោះថាសីមាវិបត្ដិ ។ សម្ដ្ដសីមាធំហួស ទម្ងាយ និងសង្កត់សីមាចាស់នៃភិក្ខុដទៃ ៣ នេះ ត្រូវអាបត្ដិទុក្កដ ។ សីមាចាស់ជាធម៌ សីមាថ្មីមិនជាធម៌ ។ កាលនឹងសម្ដ្ដសីមាជិតគ្នា គប្ដ្ដតម្ដ្ដល់សីមន្ដ្ដរិក គឺទីជាចន្ទោះនៃដែនចុះទុកមុនសិនសឹមសម្ដ្ដ ។ សម្ដ្ដ ៣ នោះគឺនិមិត្ដសម្ដ្ដ ១ បរិសសម្ដ្ដ ១ កម្មវាចា-សម្ដ្ដ ១ ។

និមិត្ដមាន ៨ គឺ **បព្ជ្ជោ** ភ្នំធំប៉ុនដំរីឡើងទៅ ១ **ចាសាណោ** ថ្មប៉ុនដុំស្ករអំពៅទម្ងន់ ៣២ បល:ឡើងទៅ ១ **វនំ** ព្រៃឈើដែលមានខ្ទឹមខាងក្នុង ១ **រុក្ខោ** ជាតិដើមឈើដែលមានខ្ទឹមខាងក្នុងដែលរស់នៅ ១

មក្ខោ ផ្លូវដើរដោយជើងនិងផ្លូវរទេះ ១ **រម្ម្យិកោ** ដំបូក ១ **ឧទឺ** ស្ទឹង ដូចពោលហើយខាងដើម ១ **ឧទកំ** ទឹកដក់នៅក្នុងរណ្ដៅជាដើមដែលមិនហូរ ១ វត្ថុទាំង ៨ នេះ វត្ថុណាមួយយកជានិមិត្ត មិនយករបស់ដទៃជានិមិត្ត សួរក្នុងទិសនោះៗ ឈ្មោះថានិមិត្តសម្បត្តិ ។ ភិក្ខុ ៤ អង្គដោយកំណត់យ៉ាងតិចប្រជុំគ្នា ភិក្ខុក្រៅនោះនៅក្នុងគាមខេត្តនោះទាំងប៉ុន្មានមិនបានមកចូលក្នុងហត្ថបាស គប្បីនាំធនូ:មក ឬឲ្យចូលក្នុងពទ្ធសីមានៃខ្ជូន ឬឲ្យចុះទៅក្នុងស្ទឹង ឬក្នុងសមុទ្រ ក្នុងជាតស្រះ ហើយសម្មតិសីមាឈ្មោះថាបរិសសម្បត្តិ ។

ភិក្ខុអ្នកឈ្វាសសូត្រសម្មតិ ដោយញត្តិទុតិយកម្មវាចា បរិសុទ្ធ មិនបានវិបត្តិអក្ខរ:មានសិថិលជាធនិតជាដើម ដូច្នេះឈ្មោះថាកម្មវាចាសម្បត្តិ ។

មួយទៀត ពទ្ធសីមា ក្នុងបាលីមាន ២ គឺ **សមានសំវាសសីមា** សីមានមានសំវាសស្មើគ្នា ជាដែនសម្រាប់ធ្វើសង្ឆកម្មបានមួយដំបន់ ១ **អវិប្ឆាសសីមា** សីមាដែលសង្ឆសម្មតិគ្របសង្កត់សមានសំវាសសីមានោះចុះ ដោយញត្តិទុតិយកម្មវាចាដទៃទៀត ដើម្បីនឹងនៅប្រាសចាកត្រៃចីវរបានផង ១ ត្រូវជា ២ ។ បើពោលតាមអដ្ឋកថា មាន ៣ គឺបន្ថែមខណ្ឌសីមាចូលផង ខណ្ឌសីមានោះគឺសីមាតូចសម្មតិទុកក្នុងចន្ទោះពទ្ធ-សីមាធំនោះ ដើម្បីនឹងធ្វើសង្ឆកម្មងាយ មិនរង្គៀសដោយភិក្ខុដទៃ ដែលនឹងចូលមកក្នុងសីមានោះ ។ ឯអពទ្ធសីមានោះ គឺសីមាដែលសង្ឆមិនបានចង់ មាន ៣ គឺគាមសីមា ១ សត្ថព្ពន្ធរសីមា ១ ឧទកុក្ខេបសីមា ១ ។

គាមខេត្តមួយទំហំប៉ុន្មាន ឈ្មោះថាគាមសីមា ដោយបាលីថា **អសម្ម-តាយ ភិក្ខវេ សីមាយ អដ្ឋបិតាយ យំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ យា គាមស្ស វា គាមសីមា និគមស្ស វា និគមសីមា អយំ តត្ថ សមានសំវាសា ឯកុចោសថា** *សេចក្តីថា កាលសីមាសង្ឆមិនបានសម្មតិ មិនបានតម្កល់ទុក ភិក្ខុចូលទៅអាស្រ័យនៅក្នុងស្រុក ឬនិគមណា គាមសីមា ដែននៃស្រុក និគមសីមា ដែននៃនិគមណា ដែនក្នុងស្រុកឬនិគមនោះ ឈ្មោះថាសីមាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ។ ព្រៃមិនមែនស្រុកប្រមាណ ៧ អព្ពន្ធរៈដោយជុំវិញ ឈ្មោះថាសត្តព្ពន្ធរសីមា ដោយបាលីថា* **អគាមកេ ភិក្ខវេ អរញ្ញេ សមន្តា សត្តព្ភន្ត្ររា អយំ តត្ថ សមានសំវាសា ឯកុចោសថា** *ដូច្នេះ ។ កាលឈរនៅកណ្តាល ៧ អព្ពន្ធរៈ ក្នុងទិសទាំងពួងដោយធ្នុះរហូតទៅត្រូវជា ១៤ អព្ពន្ធរៈ អព្ពន្ធរៈ ១ មានប្រមាណ ២៨ ហត្ថ ។ ក្នុងស្ទឹងជាដើមទីខាងក្នុងកំណត់ដោយសាចទឹក ឈ្មោះថាឧទកុក្ខេបសីមា ដោយបាលីថា* **សព្វា ភិក្ខវេ ឧទី អសីមា សព្វោ សមុទ្ទោ អសីមោ សព្វោ ជាតស្សរោ អសីមោ ឧទិយា វា ភិក្ខវេ សមុទ្ទេ វា ជាតស្សរេ វា យំ មជ្ឈិមស្ស បុរិសស្ស សមន្តា ឧទកុក្ខេបា អយំ តត្ថ សមាន-សំវាសា ឯកុចោសថា ។**

សេចក្ដីថា ស្ទឹងទាំងមូលមិនមែនជាសីមា សមុទ្ទទាំងមូលមិនមែនជាសីមា ស្រះកើតឯងទាំងមូលមិនមែនជាសីមា គឺថាមិនមែនដូចជាគាមខេត្ត សូម្បីសម្មតិសីមា ក៏មិនជាការសម្មតិ ទីឯណាក្នុងស្ទឹងកើតឯងមិនមែនស្ទឹងជីក ឬក្នុងសមុទ្រ ឬក្នុងស្រះកើតឯងមិនមែនស្រះមនុស្សជីក កំណត់ដោយសាចទឹកនៃមជ្ឈិមបុរសដោយជុំវិញក្នុងទីនោះ ដូច្នេះ ឯងជាសីមា មានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ដូច្នេះ ។ ក្នុងរដូវភ្លៀង ៤ ខែ ភ្លៀង ៧ ថ្ងៃធ្លាក់គ្រប់កន្ទុះខែ ក្នុងស្ទឹងណា ក្នុងស្រះកើតឯងណា ទឹកមិនដាច់ នាងភិក្ខុនីស្ទៀកជាបរិមណ្ឌលមិនបានលើកជាយស្បង់ចុះធ្វង ល្ម្ងជាយស្បង់ទទឹកមាត្រាមួយធ្នាប់ឬពីរធ្នាប់ ដូច្នេះ ឈ្មោះថាស្ទឹង ឈ្មោះថាស្រះកើតឯង ។ ក្នុងស្ទឹង ក្នុងជាតស្រះក្នុងរដូវភ្លៀងស្រួល ៤ ខែ និងក្នុងសមុទ្ទវេលារលកប្រក្រតី លិចទីប៉ុន្ម្មាន អំពីទីប៉ុណ្ណោះចុះទៅ ជាកប្ដិយភូមិ ធ្វើសង្ឆកម្មក្នុងទីនោះបាន ភ្លៀងមិនស្រួលរដូវខែប្រាំង សូម្បីរីងស្ងួតទៅទីអម្ពាលនោះក៏គង់នៅជាកប្ដិយភូមិ បើគេជីកជាអណ្ដូងចុះទៅ ឬសាបពូជចុះ ទីនោះជាគាមខេត្ត ។ ឧទកុក្ខេ-បសីមាមិនបានចេញទៅក្រៅកប្ដិយភូមិទេ នៅតែក្នុងខាងក្នុង ។ អព្ភន្ត-រសីមានិងឧទកុក្ខេបសីមា ២ នេះ កំណត់អំពីឱកាសភិក្ខុឈរចេញទៅ ។

បើសង្ឆ ២ ពួកនឹងធ្វើសង្ឆកម្ម ឲ្យកំណត់ ៧ អព្ភន្ត: និងជួរសាចទឹកដទៃទៀតចុះ ក្នុងចន្ទោះជាឧបចារ: ភិក្ខុនៅខាងក្នុងទីកំណត់លះហត្ត-បាសគ្នាចេញក្ដី និងខាងក្រៅទីកំណត់ឈរ មិនទុកចន្ទោះជាឧបចារ:ក្ដី

ឲ្យកម្មកម្រើកបាន ។ មែកឈើក្នុងមហាសីមាទោរចូលទៅចុចផ្ទៃក្នុងខណ្ឌ-
សីមា ឬមែកឈើក្នុងខណ្ឌសីមាទោរចូលទៅចុចផ្ទៃក្នុងមហាសីមា មាននៅ
កាលនឹងធ្វើសង្ឆកម្ម គប្បីជម្រះចេញមុន ។ នឹងធ្វើសង្ឆកម្មក្នុងឧទកុក្ខេប-
សីមាគប្បីចុះធ្វើក្នុងទឹក ឬធ្វើលើវាន លើផែ លើទូក ដែលបោះបង្គោលចុះ
ក្នុងទឹកនោះ កុំបោះសសរ បោះបង្គោលលើច្រាំង និងចងដោយមែក
ឈើដែលដុះឡើងលើច្រាំង និងកុំចងក្នុងដើមឈើដែលដុះឡើងក្នុងទឹក
និងមែកដែលគងទៅលើច្រាំង និងគងមួយអន្ទើដោយមែកឈើលើច្រាំង
ដ្បិតថាកាលបើដូច្នេះ ឈ្មោះថាព័ន្ធព័ទ្ធគ្នា ។

មួយទៀត កុំបណ្ដែតទូក-ផែ ធ្វើសង្ឆកម្ម ដ្បិតថាញត្តិនឹងទៅ
នៅក្នុងទីដទៃ ១ អនុសាវនៈ នឹងទៅនៅក្នុងទីដទៃ ១ ។

មួយទៀត សម្មតិសីមាសង្ដត់ច្រាំងស្ទឹង ត្រូវទុក្កដ ។ ក្នុងច្រាំង
ស្ទឹងណាមានទូកជានិច្ច មានស្ពានជានិច្ច និងសម្មតិសីមាគ្របសង្ដត់
ច្រាំងស្ទឹងនោះគួរ ។

មួយទៀត សូត្របាតិមោក្ខតាមបរិវេណ មិនជាទីសង្ដើត ត្រូវ
ទុក្កដ ។ ទ្រង់អនុញ្ញាតឲ្យសម្មតិរោងឧបោសថទុកក្នុងទី ១ ដោយញត្តិ-
ទុតិយកម្មវាចា ក្នុងអាវាស ១ មានសីមាមួយ សម្មតិរោងឧបោសថ ២
តំបន់ ត្រូវអាបត្តិទុក្កដ ទ្រង់អនុញ្ញាតឲ្យរើមួយចេញ ។

សីមាកថា ចប់

អធិករណសមថកថា

ពោលអំពីវិធីរម្ងាប់អធិករណ៍

ឯអធិករណសមថ នោះ មាន ៧ យ៉ាងគឺ សម្មុខាវិន័យ ១ សតិ-
វិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណ: ១ យេភុយ្យសិកា ១
តស្សបាបិយសិកា ១ តិណវត្ថារក: ១ ឈ្មោះថា អធិករណសមថ:
ព្រោះជាធម៌រម្ងាប់អធិករណ៍ ៤ ។

ភិក្ខុវិវាទឈ្លោះគ្នាដោយភេទកវត្ថុ ១៨ យ៉ាង មានដើមថា នេះធម៌
នេះមិនមែនធម៌ នេះវិន័យ នេះមិនមែនវិន័យ ដូច្នេះឈ្មោះថា វិវាទ-
ធិករណ៍ ។ ឈ្មោះវិវាទដាល់តប់គ្នា មិនឈ្មោះថាវិវាទាធិករណ៍ទេ ។

ចោទគ្នាដោយសីលវិបត្តិ ទិដ្ឋិវិបត្តិ អាចារវិបត្តិ អាជីវវិបត្តិ
ណាមួយ ឈ្មោះថា អនុវាទាធិករណ៍ ។

អាបត្តិខន្ធទាំង ៧ ឈ្មោះថា អាបត្តាធិករណ៍ ។

សង្ឆកម្មទាំង ៤ គឺ អបលោកនកម្ម ១ ញត្តិកម្ម ១ ញត្តិទុតិយកម្ម ១
ញត្តិចតុត្ថកម្ម ១ ឈ្មោះថាកិច្ចាធិករណ៍ កម្មទាំង ៤ នេះ ឈ្មោះថា
អធិករណ៍នោះ ព្រោះនឹងគប្បីរម្ងាប់ ដោយសមថ ៧ ។

វិវាទាធិករណ៍ រម្ងាប់ដោយសមថ ២ គឺ សម្មុខាវិន័យ ១
យេភុយ្យសិកា ១ ។ កាលនឹងរម្ងាប់ដោយសម្មុខាវិន័យម្យ៉ាងនោះ
វិវាទកើតឡើងក្នុងវិហារណា សង្ឆកាត់សេចក្ដីក្នុងវិហារនោះ ឬ ភិក្ខុ

ទាំងឡាយ ទៅដើម្បីរម្ងាប់ក្នុងវិហារដទៃ នឹងកាត់សេចក្តីរម្ងាប់ក្នុងកណ្តាលផ្លូវក្តី ឬភិក្ខុទៅប្រគល់ដល់សង្ឆក្នុងវិហារឯណា សង្ឆក្នុងវិហារនោះកាត់សេចក្តីរម្ងាប់បង់ ឬសង្ឆក្នុងវិហារនោះមិនអាចរម្ងាប់បានសម្មតិភិក្ខុឡើង ដោយឧព្ជាហិកាកម្មវាចា ឲ្យជាភិក្ខុអ្នកវិនិច្ឆ័យកាត់សេចក្តីភិក្ខុអ្នកដែលបានសម្មតិនោះ កាត់សេចក្តីរម្ងាប់ទៅក្នុងវិហារនោះខ្លួនឯងក្តី កាលបើវិវាទាធិករណ៍នោះរម្ងាប់ទៅដូច្នោះ ណាជាភាពចំពោះមុខសង្ឆ ចំពោះមុខធម៌ ចំពោះមុខវិន័យ ចំពោះមុខបុគ្គល នេះឈ្មោះថាសម្មុខាវិន័យ ។ ការដែលការកសង្ឆព្រមព្រៀងចំពោះមុខគ្នាដោយសង្ឆសាមគ្គី នេះឈ្មោះថាភាពចំពោះមុខសង្ឆ ។ ភាពនៃវត្ថុដែលនឹងគប្បីរម្ងាប់នោះជារបស់ពិត ឈ្មោះថាភាពចំពោះមុខធម៌ ។ វត្ថុនឹងគប្បីរម្ងាប់ដោយប្រការយ៉ាងណា ភាពវត្ថុនោះមានចំពោះមុខដោយប្រការយ៉ាងនោះឯង ឈ្មោះថាភាពចំពោះមុខវិន័យ ។

អ្នកណាវិវាទនឹងអ្នកណា សេចក្តីថាមនុស្សទាំងពីរ ដែលជាសត្រូវនឹងគ្នាដោយអត្តនោះ ជាអ្នកនៅចំពោះមុខគ្នានិងគ្នា ឈ្មោះថាភាពចំពោះមុខបុគ្គល តែក្នុងវិវាទដែលរម្ងាប់ទៅ ដោយឧព្ជាហិកាកម្ម-វាចានោះ ភាពចំពោះមុខសង្ឆ រមែងសាបសូន្យទៅ ។ យ៉ាងនេះឯងឈ្មោះថាវិវាទាធិករណ៍ រម្ងាប់ទៅដោយសម្មុខាវិន័យប៉ុណ្ណោះ ។ ថាបើមិនរម្ងាប់ដូច្នោះទេ ហើយភិក្ខុដែលសង្ឆសម្មតិដោយឧព្ជាហិកា-កម្មវាចា ប្រគល់អធិករណ៍នោះ ឲ្យដល់សង្ឆ ដោយពាក្យថា

ខ្ញុំព្រះករុណាទាំងឡាយមិនអាចរម្ងាប់ដូច្នេះ តទៅ សង្ឆសម្មតិភិក្ខុព្រម ដោយអង្គ ៥ ឲ្យជាអ្នកចែកស្ងាក ហើយឲ្យភិក្ខុនោះចែកស្ងាកដោយ អាការ ៣ គឺ លាក់១ បើក ១ ខ្សឹបដាក់ត្រចៀក ១ ក្នុងបរិស័ទដែលប្រជុំនោះ ភិក្ខុជាធម្មវាទីបានស្ងាកនៃធម្មវាទីច្រើន ភិក្ខុទាំងឡាយនោះពោលកាត់ សេចក្ដីដូចម្ដេច អធិករណ៍រម្ងាប់ទៅយ៉ាងនោះ ដូច្នេះ ឈ្មោះថារម្ងាប់ ដោយសម្មុខាវិន័យផង ដោយយេកុយ្យសិកា គឺធម្មវាទីច្រើនជាងផង ក្នុងបទនេះសម្មុខាវិន័យ មានន័យដូចពោលហើយពិត តែដែលធ្វើ យេកុយ្យសិកាកម្ម គឺចែកស្ងាករកធម្មវាទីបានច្រើននេះឯង ឈ្មោះថាយេ-កុយ្យសិកា វិវាទាធិករណ៍រម្ងាប់ដោយសមថ: ២ ដូចពោលមកនេះឯង ។

អនុវាទាធិករណ៍រម្ងាប់ដោយសមថ: ៤ គឺ សម្មុខាវិន័យ ១ សតិ-វិន័យ ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១ ។ កាលរម្ងាប់ដោយ សម្មុខាវិន័យម្យ៉ាង អ្នកណាចោទ និងចោទអ្នកណា ព្រះវិន័យធរគប្បី ស្ដាប់ពាក្យនៃអ្នកទាំងពីរនោះ បើឃើញថាមិនមានអាបត្តិណាមួយ ឲ្យ អ្នកទាំងពីរអត់ទោសគ្នាចុះ បើឃើញថាមានអាបត្តិហើយ កាត់សេចក្ដីថា ក្នុងសេចក្ដីនោះជាអាបត្តិឈ្មោះនេះ អធិករណ៍នោះរម្ងាប់ទៅ ឈ្មោះថា រម្ងាប់ទៅដោយសម្មុខាវិន័យម្យ៉ាង លក្ខណៈនៃសម្មុខាវិន័យក្នុងបទនេះក៏ មានន័យដូចពោលហើយពិត ។ ក៏ឯភិក្ខុជាព្រះខីណាស្រព អ្នកដទៃចោទ ដោយសីលវិបត្តិមិនមានមូល ហើយមកសូមសតិវិន័យនឹងសង្ឆ សង្ឆ

ឲ្យសតិវិន័យដោយញត្តិចតុត្ថកម្មវាចាក្នុងកាលណា ក្នុងកាលនោះ អនុវា-ទាធិករណ៍ ឈ្មោះថារម្ងាប់ដោយសម្មុខាវិន័យផង ដោយសតិវិន័យផង តែកាលសង្ឆឲ្យសតិវិន័យហើយ ភិក្ខុអង្គណានឹងចោទលោកនោះទៀត មិនឡើងឡើយ ។ ក៏ឯភិក្ខុឆ្គត ប្រព្រឹត្តអជ្ឈាចារ ដោយសេចក្តីជាមនុស្ស ឆ្គត ភិក្ខុដទៃចោទថា លោកចូររឭកអាបត្តិដូច្នេះ។ សូម្បីភិក្ខុនោះពោល ថា កម្មដូច្នេះខ្ញុំព្រះករុណាជាមនុស្សឆ្គតធ្វើ រឭកមិនបានដូច្នេះ ភិក្ខុដទៃ នៅខំចោទក្តី ហើយភិក្ខុឆ្គតមកសូមអមុឬ្ហវិន័យ ដើម្បីនឹងមិនឲ្យចោទបាន ទៀត សង្ឆក៏ឲ្យអមុឬ្ហវិន័យដោយញត្តិចតុត្ថកម្មវាចាដល់ភិក្ខុនោះ ក្នុង កាលណា ក្នុងកាលនោះ អនុវាទាធិករណ៍ ឈ្មោះថារម្ងាប់ដោយ សម្មុខាវិន័យផង ដោយអមុឬ្ហវិន័យផង គ្រាកាលសង្ឆឲ្យអមុឬ្ហវិន័យ ហើយ ភិក្ខុអង្គណានឹងចោទភិក្ខុនោះទៀត ដោយហេតុនោះមិនឡើង ឡើយ ។ ក៏ឯភិក្ខុប្រព្រឹត្តអជ្ឈាចារ កាលត្រូវចោទដោយអាបត្តិបារាជិក ឬ ដោយអាបត្តិកៃ្សរបារាជិក កាលភិក្ខុនិយាយយកពាក្យដទៃមកគ្របបង្ហែ្ហ ចេញព្រោះជាមនុស្សលាមកណាស់ ក្រាស់ដោយបាប សង្ឆកាលសម្គាល់ ថាបើលោកនេះ នឹងមានមូលមិនដាច់ ហើយលោកនឹងបដិបត្តិប្រពៃ នឹងបានឱិសារណា (ការទាញចូល) បើលោកមានមូលដាច់ហើយសោត នេះឯងនឹងជានាសនា ការឲ្យវិនាសដល់លោកនោះ សង្ឆសម្គាល់ ដូច្នេះហើយ ធ្វើតស្សបាបិយសិកាកម្មដល់លោកនោះ ដោយញត្តិចតុត្ត-កម្មវាចា ក្នុងកាលណា ក្នុងកាលនោះ អនុវាទាធិករណ៍ឈ្មោះថារម្ងាប់

ដោយសម្មុខាវិន័យផង ដោយតស្សបាបិយសិកាផង ។ អនុវាទាធិ-
ករណ៍រម្ងាប់ដោយសមថ: ៤ ដូចពោលមកនេះឯង ។

អាបត្តាធិករណ៍ រមែងរម្ងាប់ដោយសមថ: ៣ គឺសម្មុខាវិន័យ ១ បដិញ្ញាតករណ: ១ តិណវត្ថារក: ១ ។ អាបត្តាធិករណ៍នោះ ដែលនឹងរម្ងាប់ដោយសម្មុខាវិន័យម្យ៉ាងមិនមាន លុះតែក្នុងកាលណាភិក្ខុសម្តែងលហុកាបត្តិ ក្នុងសំណាក់ភិក្ខុ ១ អង្គ ឬក្នុងកណ្តាលសង្ឆនិងគណ: ក្នុងកាលនោះ អាបត្តាធិករណ៍រមែងរម្ងាប់ដោយសម្មុខាវិន័យផង ដោយបដិញ្ញាតករណ:ផង ។ អ្នកណាសម្តែង សម្តែងនឹងអ្នកណា ការដែលមនុស្សទាំងពីរនោះនៅចំពោះមុខគ្នា ឈ្មោះថាការនៅចំពោះមុខបុគ្គលក្នុងសម្មុខាវិន័យនោះ ។ ការនៅចំពោះមុខក្រៅនោះ មានន័យដូចពោលហើយ ។ ក្នុងវេលាសម្តែងអាបត្តិ ចំពោះបុគ្គលនិងគណ: ការនៅព្រមចំពោះមុខសង្ឆក៏សាបសូន្យទៅ ។ ក្នុងការសម្តែងអាបត្តិនោះ ការប្តេជ្ញាថា ខ្ញុំព្រះករុណាត្រូវអាបត្តិឈ្មោះនេះក្តី និងប្តេជ្ញាថា ខ្ញុំព្រះករុណាឃើញអាបត្តិក្តី យ៉ាងណា ភិក្ខុអ្នកទទួលធ្វើតាមការប្តេជ្ញានោះ ពោលថា លោកគប្បីសង្រ្ជមតទៅ នេះឯងឈ្មោះថាបដិញ្ញាតករណ: ធ្វើតាមប្តេជ្ញា ។ ការសូមបរិវាសជាដើម នឹងឲ្យបរិវាសជាដើម តាមប្តេជ្ញា ឈ្មោះថាបដិញ្ញាតករណ:ក្នុងសង្ឆាទិសេស ។

ក៏ឯភិក្ខុទាំងឡាយ ២ ពួក ធ្វើការឈ្លោះគ្នា បានប្រព្រឹត្តអជ្ឈាចារ មិនជាកម្មនៃសមណ:ដ៏ច្រើន កាលលជ្ជីធម៌ សេចក្តីខ្មាសកើតឡើងវិញ

ហើយ លោកទាំងអម្បាលនោះគិតថា បើយើងទាំងឡាយ នឹងញ៉ាំងគ្នានិងគ្នា ឲ្យសម្តែងអាបត្តិទាំងអម្បាលនេះ អធិករណ៍នោះ គប្បីប្រព្រឹត្តទៅដើម្បីការរឹងរូសកាចសាហាវឡើង លោកឃើញទោសក្នុងការញ៉ាំងគ្នាឲ្យសម្តែងអាបត្តិដូច្នេះហើយ ទើបព្រមគ្នាធ្វើតិណវត្ថារកកម្មគឺសង្ឆកម្មតែមួយ សង្កត់ទោសនោះទុកដូចស្មៅ គ្របលាមក ក្នុងកាលណាក្នុងកាលនោះ អាបត្តាធិករណ៍ឈ្មោះថា រម្ងាប់ដោយសម្មុខាវិន័យផង ដោយតិណវត្ថារក:ផង ដ្បិតថាភិក្ខុទាំងប៉ុន្មានចូលទៅនៅក្នុងហត្ថបាសក្នុងខណ:ធ្វើតិណវត្ថារកកម្មនោះ លោកមិនធ្វើឲ្យច្បាស់នូវទិដ្ឋិថា កម្មនោះមិនគួរដូច្នេះ សូម្បីលោកដេកលក់នៅក្តី អាបត្តិទាំងពួងនៃលោកនោះ លើកតែអាបត្តិដែលជាទោសទន់ទាប គឺសង្ឆាទិសេស និងអាបត្តិជាគិហិបដិសំយុត្ត ប្រកបដោយគ្រហស្ថចេញ អាបត្តិក្រៅនោះបានធ្លាក់ទៅអស់ ។ អាបត្តាធិករណ៍រម្ងាប់ដោយសមថ: ៣ ដូចពោលមកនេះឯង ។

កិច្ចាធិករណ៍ រមែងរម្ងាប់ដោយសម្មុខាវិន័យម្យ៉ាង ។ អធិករណ: ៤ រមែងរម្ងាប់ដោយសមថ: ៧ តាមសមគួរដោយប្រការដូច្នេះឯង ។ អធិករណសមថកថា ដែលបានពោលមកនេះ ជាយ៉ាងសង្ខេប ។

អធិករណសមថកថា ចប់

ការវាការកថា

ពោលអំពីសេចក្ដីគោរពនិងមិនគោរព

ពោលអំពីសេចក្ដីមិនគោរពជាមុន សេចក្ដីមិនគោរពមាន ៦ យ៉ាង គឺ មិនគោរពក្នុងព្រះពុទ្ធ ១ មិនគោរពក្នុងព្រះធម៌ ១ មិនគោរពក្នុងព្រះសង្ឆ ១ មិនគោរពក្នុងសិក្ខា ១ មិនគោរពក្នុងអប្បមាទ ១ មិនគោរពក្នុងបដិសណ្ឋារ: ១ ត្រូវជា ៦ យ៉ាង ។

អ្នកណាកាលព្រះដ៏មានបុណ្យជាអម្ចាស់គង់ព្រះធរមាននៅ មិនបានទៅកាន់ទីឧបដ្ឋាក កាលព្រះអង្គបរិនិព្វានហើយ មិនទៅកាន់ទីចេតិយ ទីពោធិព្រឹក្ស ដើម្បីឧបដ្ឋាន និងមិនថ្វាយបង្គំនូវព្រះចេតិយ ឬនូវពោធិ-ព្រឹក្ស និងបាំងឆត្រពាក់ស្បែកជើងដើរទៅក្នុងលានព្រះចេតិយក្ដី គប្បីដឹងថាសេចក្ដីគោរពក្នុងព្រះពុទ្ធអង្គនៃអ្នកនោះមិនមាន។ក៏ឯអ្នកណាជាអ្នកអាចពិត ហើយមិនទៅកាន់ទីស្ដាប់ធម៌ មិនពោលនូវសរភញ្ញ: មិនពោលធម្មកថា និងទម្លាយធម្មសវន:ទៅក្ដី ឬចិត្តអណ្ដែតអណ្ដូង ឬមិនអើពើអង្គុយនៅក្នុងពោងធម្មសវន:ក្ដី ដូច្នេះគប្បីដឹងចុះថា សេចក្ដីគោរពក្នុងព្រះធម៌នៃអ្នកនោះមិនមាន ។ អ្នកណាមិនតាំងទុកចំពោះនូវការធ្វើសេចក្ដីកោតក្រែងក្នុងព្រះថេរ:និងភិក្ខុកំលោះ ឬភិក្ខុកណ្ដាលក្ដី នឹងសម្ដែងសេចក្ដីជាមនុស្សក្រមាច់កាយក្នុងទីទាំងឡាយ មានពោងឧបោសថ និងវិតក្កមាលក:គឺទីឈរឃ្ញុំចីវរ និងទៅបិណ្ឌបាតជាដើម នឹងមិនថ្វាយបង្គំ

តាមលំដាប់ភិក្ខុចាស់ ដូច្នេះគប្បីដឹងចុះថា សេចក្តីគោរពក្នុងព្រះសង្ឆនៃអ្នកនោះមិនមាន ។ អ្នកណាមិនសមាទានសិក្សានូវសិក្ខាទាំង ៣ គឺសីល សមាធិ បញ្ញា នេះ គប្បីដឹងចុះថា អ្នកនោះមិនគោរពក្នុងសិក្ខា ។ អ្នកណាតាំងនៅក្នុងសេចក្តីប្រមាទ ប្រាសចាកសតិ មិនញ៉ាំងអប្បមាទលក្ខណៈឲ្យចម្រើនឡើង គប្បីដឹងចុះថា អ្នកនោះមិនគោរពក្នុងអប្បមាទ ។ អ្នកណាមិនធ្វើនូវបដិសណ្ឋារៈទាំង ២ គឺអាមិសបដិសណ្ឋារៈ ការទទួលដោយអាមិស និងធម្មបដិសណ្ឋារៈ ការទទួលដោយធម៌ នេះគប្បីដឹងចុះថា អ្នកនោះ មិនគោរពក្នុងបដិសណ្ឋារៈ ។

ឯសេចក្តីគោរពក៏មាន ៦ ប្រការដែរ គឺគោរពក្នុងព្រះពុទ្ធ គោរពក្នុងព្រះធម៌ គោរពក្នុងព្រះសង្ឆ គោរពក្នុងសិក្ខា គោរពក្នុងអប្បមាទ គោរពក្នុងបដិសណ្ឋារៈ ត្រូវជា ៦ ប្រការ ។ សេចក្តីគោរពទាំង ៦ ប្រការនេះ គប្បីដឹងដោយពិស្តារ ដោយបរិយាយផ្ទុយអំពីអគារវៈ ដែលមានន័យក្នុងព្រះសូត្រថា សេចក្តីមិនគោរព ប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ សេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសេចក្តីចម្រើននោះចុះ ។

គារវាគារវកថា ចប់

សម្មជ្ជនានិសង្សកថា

សេចក្តីក្នុងកថា ដែលពោលមកក្នុងបពូ:នោះៗ សម្តែងខបដិបត្តិជាគ្រឿងជម្រះដុះខាត់សន្ធានៃអ្នកបដិបត្តិ ឲ្យស្អាតផ្ងរផង់ដូចអំបោសបោស

ប្រាសទីដែលមានសំរាម ឲ្យសម្រេចអានិសង្ស ៥ ប្រការ ។ ក៏ឯអានិសង្ស នៃកិរិយាបោសប្រាសលានព្រះចេតិយជាដើម លោកពោលទុកក្នុងគម្ពីរ បរិវារៈដូច្នេះថា អានិសង្សនៃកិរិយាបោសប្រាសមាន ៥ ប្រការ គឺ **សកចិត្តំ បសីឧតិ** ចិត្តរបស់ខ្លួនរមែងជ្រះថ្លាផ្ទរផង់ ដូចទត្តភិក្ខុបោសលានព្រះចេតិយ ហើយឈរសម្ងឹងមើល បានឱកាសកសិណហើយសម្រេចផលទាំងបី ១ **បរចិត្តំ បសីឧតិ** ចិត្តអ្នកដទៃរមែងជ្រះថ្លាផ្ទរផង់ដូចតិស្សភិក្ខុបោសលានព្រះចេតិយ ហើយឈរកាន់កញ្ជ្រែង ព្រះតិស្សទត្ត-ត្ថេរចុះចាកទូកឃើញលានព្រះចេតិយបោសហើយត្រេកអរមកសួរបញ្ហា ១ **ទេវតា អត្តមនា ហោតិ** ទេវតាត្រេកអរគាប់ចិត្តផង ដូចភិក្ខុមួយអង្គ បោសលានព្រះចេតិយ និងលានពោធិព្រឹក្សហើយទៅងូតទឹក ទេវតាក៏ជ្រះថ្លាមកឈរកាន់ផ្ការៃ ១ **ចាសានិកសំវត្តនិយំ កម្មំ ឧបចិតំ** អ្នកបោសប្រាសឈ្មោះថាសន្សំនូវកម្មដែលប្រព្រឹត្តទៅដើម្បីសេចក្តីជាអ្នកគួរជ្រះថ្លាដោយរូបក្នុងភពខាងមុខ ដូចព្រះអកយវេរ កាលជាតិអំពីមុនជាវេរៈចាស់ បានបោសលានព្រះចេតិយ និងបុត្រនៃអាមាត្យម្នាក់កាលជាតិអំពីមុនជាឧបាសក បានចាក់សំរាមដែលគេបោស អ្នកទាំង ២ នាក់មកក្នុងភពខាងមុខ ជាមនុស្សមានរូបល្អគួរឲ្យជ្រះថ្លា ១ **កាយស្ស ភេទា បរំ មរណា សុគតឹ សក្តំ លោកំ ឧបបជ្ជតិ** អ្នកបោសប្រាស ខាងមុខអំពីមរណៈ ព្រោះបែកធ្លាយនៃរាងកាយ រមែងទៅកាន់សួគ៌ទេវលោក ជាគតិដំណើរល្អ ១ ត្រូវជា ៥ ប្រការ ។

អានិសង្សនៃកិរិយាបោសច្រាសមាន ៥ ប្រការទៀត គឺចិត្តនៃខ្លួនជ្រះថ្លាផ្ទរផង់ ១ ចិត្តនៃអ្នកដទៃជ្រះថ្លាផ្ទរផង់ ១ ទេវតាត្រេកអរវីកវាយផង ១ **សត្ថុ សាសនំ កតំ ហោតិ** អ្នកបោសច្រាសឈ្មោះថាធ្វើតាមពាក្យប្រដៅនៃព្រះសាស្តា ដ្បិតថាវត្តគឺកិរិយាបោសច្រាសនេះ ព្រះពុទ្ធទាំងឡាយ បានទ្រង់សរសើរទុកហើយ ព្រោះហេតុនោះ កាលបើនឹងបោសច្រាស ក៏ឈ្មោះថាធ្វើតាមឱវាទពាក្យប្រដៅនៃព្រះសាស្តា ដូចលោកពោលទុកថា ព្រះសារីបុត្ត្រភ្ញ្ជចមិនបានបោស ទៅចូលនិពោធនៅក្នុងព្រៃហិមវន្ត ព្រះពុទ្ធអង្គទ្រង់ជ្រាបថាភ្ញ្ជច ស្តេចយាងទៅសម្តែងស្នាមព្រះបាទទុក អំពីនោះមកព្រះថេរៈជាម្ចាស់ សូម្បីលោកឈរក្នុងទីដែលដោះកុ្ម លោកក៏យកជើងបោសសំរាមមុនសិនហើយទើបឈរ ១ **បច្ឆិមា ជនតា ឌិដ្ឋានុគតឹ អាបជ្ជតិ** ប្រជុំជនដែលមានក្នុងអនាគត រមែងដល់នូវទិដ្ឋានុគតិ ប្រព្រឹត្តទៅតាម គឺធ្វើតាមបែបដែលខ្លួនធ្លាប់ឃើញ ១ រួមគ្នាត្រូវជា ៥ ប្រការ ។

សមជ្ជនានិសង្សកថា ចប់

កថាទាំងពួងក្នុងបទនោះៗ កថាណាដែលពោលដោយសង្ខេបនោះ បើកុលបុត្ត្រចង់ដឹងពិស្តារ គប្បីមើលក្នុងបាលីវិភង្គ ខន្ធកៈ និងបរិវារៈ អដ្ឋកថា ដីកាចុះ ។

អាបត្តិទេសនាទិបញ្ចៈ គម្រប់ ៧ ចប់

ចាឧកថា

សម្តែងអំពីបាទ ក្នុងអទិន្នាទាន និងបល: ដែលបានអាងទុកអំពីមុន ដែលថានឹងវិនិច្ឆ័យក្នុងទីបំផុតនៃវណ្ណនាទាំងពួងនោះ ។ ក៏ឯបាទក្នុងអទិន្នាទាននោះ ក្នុងបាលីថា ៥ មាសក: ជា ១ បាទ ក្នុងនគរពាជគ្រឹះ ក្នុងកាលនោះ ព្រោះបាលីថា **តេន ខោ បន សមយេន ពារាណសេ បញ្ចមាសកោ ចោរោ ហោតិ** *ដូច្នេះ ។ កាលបើចង់ដឹងមាសក: គប្បីដឹងមាត្រាក្នុងគម្ពីរអភិធានប្បទីបិកាថា ៖*

ចត្តារោ វីហយោ កុញ្ជោ ទ្វេ កុញ្ជា មាសកោ ភវេ

ដូច្នេះជាមុន ថាទម្ងន់ ៤ គ្រាប់ស្រូវ ជា ១ កុញ្ជា គឺ ១ បិច ។ ទម្ងន់ ២ កុញ្ជាជា ១ មាសក: ហៅថាសណ្តែកសក៏បាន ហៅថាមួយចិបក៏បាន ។ ៥ មាសក:នោះ ជា ១ បាទ មាត្រានេះជាកណ្តាល នឹងប្រើក្នុងមាសនិងទង់ហ្វ៊ាន និងប្រាក់ និងវត្ថុណាៗ ក៏បាន ។ មាសក:ក្នុងបាលីដែលជាមាសក:នៃមាសឬទង់ហ្វ៊ា ឬប្រាក់ ក៏មិនបានពោលទុកក្នុងបាលីនិងអដ្ឋកថា តែក្នុងអដ្ឋកថាពោលថា ២០ មាសក: ជា ១ កហាបណ: ព្រោះហេតុនោះ ៥ មាសក:ដែលជាចំណែកគម្រប់ ៤ នៃកហាបណ: ទើបជា ១ បាទ ក្នុងនគរពាជគ្រឹះ នាសម័យនោះ ហើយលោកពោលតទៅទៀតថា ដោយលក្ខណ:នោះក្នុងជនបទទាំងពួង គប្បីដឹងថា ភាគគម្រប់ ៤ នៃនីលកហាបណ:ជារបស់

បុរាណ ជា ១ បាទ មិនមែនភាគគម្រប់ ៤ នៃកហាបណៈដទៃ មានរុទ្ធ-ទាមកកហាបណៈជាដើម ។ សូម្បីព្រះពុទ្ធទាំងឡាយដែលជាអតីត អនាគត ព្រះអង្គក៏ទ្រង់បញ្ញត្តបារាជិក ដោយបាទដែលជាភាគគម្រប់ ៤ នៃ នីលកហាបណៈនោះ ព្រោះអដ្ឋកថាបាឬ:ពោលថា **បញ្ចមាសកោ ចាតោតិ តតា រាជតហោ វីសតិមាសកោ កហាបណោ ហោតិ តស្មា បញ្ចមាសកោ ចាតោ ឯតេន លក្ខណេន សព្វជនបទេសុ កហាបណាសុ ចតុត្តោ ភាគោ ចាតោតិ វេទិតព្ពោ ។ សោ ច ខោ ចោរាណាសុ នីលកហាបណាសុ វសេន ន ឥតរេសំ រុទ្ទ្រាមកាទីនំ ។ តេន ហិ ចាតេន អតីតា ពុទ្ធាបិ ចារាជិកំ បញ្ញាបេសុំ ។ អនាគតាបិ បញ្ញា-បេស្សន្តិ** *ដូច្នេះ ។ នីលកហាបណៈនោះ ក្នុងអដ្ឋកថា ក៏មិនប្រាប់ តម្រាធ្វើនឹងប្រមាណតម្លៃទុក តែក្នុងវិមតិវិនោទនីដីកា ប្រាប់ប្រមាណ តម្លៃនៃនីលកហាបណៈ និងរុទ្ទ្រាមកកហាបណៈទុកដូច្នេះថា គប្បី ដឹងនីលកហាបណៈនោះ គេធ្វើឲ្យកើតឡើងតាមតម្រាចាស់ ដល់ព្រម ដោយលក្ខណៈមានតម្លៃស្មើនឹងមាសឧត្តមប្រមាណ ២០ មាសកៈ ។ បាន ឮថា រុទ្ទ្រាមកកហាបណៈ តម្លៃដល់ភាគ ៣ នៃនីលកហាបណៈ ហើយលោកពោលតទៅថា ក្នុងប្រទេសណាមិនមាននីលកហាបណៈ ក្នុងប្រទេសនោះ គប្បីកំណត់បាទដោយកណ្ហៈស្មើតម្លៃ ៥ មាសកៈ នៃ*

មាសដែលគេដេញហើយប្រាសចាកទោសនោះចុះ ដោយបាឋ:ក្នុងវិមតិវិនោទនីថា **ចោរាណសត្តាណ្ឌរូបំ ឧប្ផាដិតោ រីសតិ មាសប្ឋមាណាឧត្តមសុវណ្ណាតួ្ឍនកោ លក្ខណសម្ឋ្ជោ ឌីលកហាបណោតិ ១ជិតពោ ។ រុ្ជ្ជ្ជ្ជ្ជ្ជ្ជ ឧប្ផាដិតោ រុ្ជ្ជ្ជ្ជ្ជ្ជ ។ សោ ការ ឌីលកហាបណាសួ តិភាគំ អតួ្ឍតិ យស្ម ១ ១ ១

ប្រាកដនៅក្នុងនីលកហាបណៈនោះពិត ឲ្យយកមាស ៥ មាសកៈ ប្រាក់ ៥ មាសកៈ ទង់ដែង ១០ មាសកៈ ជា ២០ មាសកៈផងគ្នា មកផ្សំគ្នាជាមួយ លោហៈគឺដែកប៉ុនគ្រាប់ស្រូវ ១ ផង ដើម្បីនឹងបញ្ចុះសាច់ យកដាក់ចុះក្នុងបាវរំលាយ ធ្វើជារូបបោះត្រាអក្សរ និងរូបដើងដំរីជាដើមណាមួយ ដូច្នេះឯងឈ្មោះថានីលកហាបណៈ ព្រោះជារបស់មិនមានទោស ។ ក្នុងប្រទេសណាមិនមាននីលកហាបណៈ ក្នុងប្រទេសនោះ ឲ្យយកមាសទម្ងន់ ២០ គ្រាប់ស្រូវ ជាតម្លៃ ១ បាទ ។ ភិក្ខុលួចរបស់តម្លៃស្មើនឹងតម្លៃមាសទម្ងន់ ២០ គ្រាប់ស្រូវ ត្រូវបារាជិក ។ ពាក្យនេះអាចារ្យឈ្មោះ វាចិស្សរៈ លោកពោលទុក ព្រោះដីកាបាឬ:ថា ៖ **មិស្សកកហាប-ណោយេវ នីលកហាបណោ តត្ថេវ ហិ ចោរាណ-សត្ថវិហិតលក្ខណំ ឧិស្សតិ បញ្ចមាសា សុវណ្ណស្ស តថា រជតស្ស ឧស មាសា តម្ពស្សាតិ ឯតេ រីសតិមាសេ មិស្សេត្វា ពន្ធិត្វាយ រីហិមត្តំ លោហំ បក្ខិបិត្វា អក្ខរានំ ច ហត្ថិចាចាឧីនមញ្ញតរញ្ច រូបំ ឧស្សេត្វា ឯតោ ឯិទ្ធោសត្ថា នីលកហាបណោ ជាម ហោតិ ។ ហោន្តិ ចេត្ត ។**

ហេមរជតម្ពេហិ សត្ថេ ឧិទ្ធិដ្ឋលក្ខណំ
អហាបេត្វា ឯតោ រីស មាសោ នីលកហាបណោ ។
ហេមចាឧំ សជ្ជុចាឧំ តម្ពចាឧទ្ធយំ ហិ សោ

មិស្សេត្វា រូបមេត្វា កាតុំ សត្ថេសុ ឧស្ឆ្ឍិតោ ។
ឯសោតិ រុច្ចតេ ហេសោ ជិញ្ជាសត្ថា តថេវ្ហិ តោ
ឥស្ស ចាតោ សុវណ្ណស្ស រីសរីហាត្ឍជាមកោ ។
យស្មឿ បន បនេសេ សោ ន វត្ត្ហិ ឥហាបណោ
រីសសោវណ្ណរីហាត្ឍ្ យ តប្ជាឧត្ឍ្ជ្ជ ។
រីសសោវណ្ណរីហាត្ឍ្ យ ថេនេត្ត ភិក្ខវ ។ ។
ចវ្ជ្ជ សាមញ្ញកុណ ឥ ឥ ។
ឥ ។ ។

មាសទម្ងន់ ២០ គ្រាប់ស្រូវ ជា ៥ បិច គិត ១៦ ទម្ងន់ ត្រូវជា ប្រាក់ ២ ស្លឹង ១ ហ្ជឿង ក្នុងប្រទេសស្យាមនេះ ជា ១ បាទ ក្នុង អទិន្នាទានសិក្ខាបទ តាមឧត្តរវិនិច្ឆ្ជយដីកា ។

*ក៏ឯរបស់ក្នុងស្យាមប្រទេសនេះតម្លៃក៏មិននឹង ជួនកាលលក់ ១៦ ទម្ងន់ខ្ជះ ១៧ ទម្ងន់ខ្ជះ ជួនកាលលក់ ១៨ ទម្ងន់ខ្ជះ ១៩ ទម្ងន់ខ្ជះ ដែល គិតមកតែ ១៦ ទម្ងន់នេះ ដើម្ប្ជីនឹងឲ្ជសមគ្នានឹងនីលកហាបណ: ដែល លោកប្ជ្ជ្ជ ១ ១ ១

ក៏ប៉ុន្តែក្នុងគម្ពីរសំខ្យាបកាសក: និងគម្ពីរវិនយសារ:ប្រាប់តម្រាធ្វើក៏ដូចគ្នា តែមិនលាយដែក ចំណែកគម្ពីរវិនយសារ: វាយតម្លៃទុកថា ៧ ទម្ងន់ ទម្ងន់ជាប្រាក់ ២ ស្លឹង ១ ពៃ និង ១ ចិប ជា ១ បាទ ។ ថាបើ ៨ ទម្ងន់ បានជាប្រាក់ ២ ស្លឹង ១ ហ្ស៊ឿង ជាបាទក្នុងអទិន្នាទានសិក្ខាបទ ។ ថាបើ ១០ ទម្ងន់ក៏លើសម្ចៃទង់ហ្ជ៊ាយ៉ាងល្អក្នុងស្យាមប្រទេសនេះទៅ ដ្ឋិតថា ទង់ហ្ជ៊ាយ៉ាងល្អក្នុងស្យាមប្រទេសនោះក៏ត្រឹមតែ ៩ ទម្ងន់ បើវាយតម្លៃ ៩ ទម្ងន់ ក៏លើសសាច់ទង់ហ្ជ៊ានោះទៅ ថាបើវាយតម្លៃត្រឹមតែ ៨ ទម្ងន់ ឃើញថាសមគួរ ដ្ឋិតថាតម្រាក្នុងដីកានោះ លាយដែកផងទើបសាច់ល្អ ឡើង វាយតម្លៃ ៨ ទម្ងន់ ទើបត្រូវល្អ សមគួរនឹងតម្លៃមាសទម្ងន់ ២ គ្រាប់ស្រូវផង ព្រោះឃើញថា ក្នុងកាលតែងដីកានោះ គេនឹងរាប់អានទង់ហ្ជ៊ា ដែលជានីលកហាបណ:នោះ មានតម្លៃច្រើនជាងប្រាក់ ៨ ទម្ងន់ ថយជាងមាស ៨ ទម្ងន់ ព្រោះហេតុនោះ គួរគិតមាស ១៦ ទម្ងន់ ទង់ហ្ជ៊ា ៨ ទម្ងន់ ដូចបានគិតមកហើយនេះ តែក្នុងដីកានៃកង្ខាវិតរណី ពោលថាភាគគម្រប់ ២០ នៃបុរាណកហាបណ: ឈ្មោះថាមាសក: មាសក:នោះហៅថាមញ្ញេដ្ឋីក៏មាន ដោយដីកាបាឬ:ថា **មាសកោ ចោរាណកស្ស កហាបណស្ស វីសតិមោ ភាគោ យោ ណោកេ មញ្ញេដ្ឋីតិបិ វុច្ចតិ** ដូច្នេះ ។ អ្នកស្រុកលង្ការម្នាក់ប្រាប់ថា **មញ្ញេដ្ឋី** នោះ ជាប្រាក់ ១ ហ្ស៊ឿងក្នុងស្យាមប្រទេស បើគិតតាមន័យនេះ ២ ស្លឹង ១ ហ្ស៊ឿងប្រាក់សៀម (ថៃ) ត្រូវជា ១ បាទក្នុងអទិន្នាទានសិក្ខាបទនេះ ។ បានឮថា ក្នុងប្រទេសភូមា

គ្រូខ្ទះ១ មាសក: ១ ជាប្រាក់ ១ ស្លឹង ។ ៥ មាសក:ជាប្រាក់ ៥ ស្លឹង ។ ពោលតាមវិមតិវិនោទនី និងគ្រូកូមា ៥ ស្លឹងជា ១ បាទ ។ ពោលតាមដីកានៃឧត្តរវិនិច្ឆ័យ និងពាក្យដែលអ្នកស្រុកលង្ការម្នាក់ពោលថា មញ្ញេដ្ឋី ជាហ្ជឿងនេះ ២ ស្លឹង ១ ហ្ជឿង ជា ១ បាទ ។ តាមគម្ពីរវិនយសារ: ២ ស្លឹងនិង ១ ពៃ ១ ចិប ជា ១ បាទ ។ បាទក្នុងអទិន្នាទានសិក្ខាបទ គិតតាមវាទ:នៃអាចារ្យផ្សេងៗ គ្នាដូច្នេះ ឲ្យអ្នកប្រាជ្ញដែលមានបញ្ញាពិចារណាតាមគម្ពីរនោះៗ និងសាកសួរមើលក្នុងប្រទេសផ្សេងៗ គប្បីកាន់យកតែត្រឹមត្រូវតាមគួរចុះ ។ (លោកអ្នកតែងគិតតម្លៃមាសនិងទង់ហ្ជាដូច្នេះ តាមតម្លៃដែលប្រើទិញដូរគ្នាក្នុងវេលាដែលតែងសៀវភៅនេះ) សេចក្ដីជំនុំអំពីតម្លៃបាទក្នុងអទិន្នា-ទានសិក្ខាបទ ដែលកិក្ខុលួចទ្រព្យអ្នកដទៃតម្លៃអំពីមួយបាទឡើងទៅ ត្រូវបារាជិក ។ ឯតម្លៃមួយបាទក្នុងអទិន្នាទានគឺ ៥ មាសក: ជា ១ បាទនោះ ក្នុងស្យាមប្រទេសបានវិនិច្ឆ័យថា ៥ មាសក:នោះគឺ ២ ស្លឹង ១ ហ្ជឿង ត្រូវជា ១ បាទក្នុងអទិន្នាទាន ។ ក៏ក្នុងសម័យដែលព្រះសង្ឆរ៉ាជ និងយ៉ាវ៉ាស ឋានានុសក្ដិទាំងពួងដែលបានជួបជុំជាសង្គ្ដីតិកាផ្ទៀងផ្ទាត់សិក្ខាវណ្ណនាក្នុងកម្ពុជប្រទេសនេះ យល់ឃើញព្រមគ្នាថា ប្រាក់រូបដំរីជាប្រាក់ក្នុងរាជសម្ដេចព្រះចោមក្ងៅ ដែលទ្រង់រៀបរយផ្ទៀងផ្ទាត់ព្រះវិន័យតាំងគណ:ធម្មយុត្តក្នុងស្យាមប្រទេស ដែលកំណត់ថា ២ ស្លឹង ១ ហ្ជឿង ជា ១ បាទនោះ យើងត្រូវយកប្រាក់រូបដំរីនោះជាសម្រេច យើងបានយកប្រាក់រូបដំរីនោះមកថ្លឹងធៀបនឹងប្រាក់ ១០ សេនបារ៉ាំងសែស ត្រូវជា

ប្រាក់ ៤០ សេន គឺ ជា ១ បាទ ក្នុងអទិន្នាទានសិក្ខាបទ កំណត់ក្នុងកម្ពុជប្រទេស ដែលប្រើក្នុងសម្័យនេះ ។

បាទកថា ចប់

ប្រមាណចាត្រនិងបល:

ពណ៌នាអំពីប្រមាណបាត្រ និងបល: តទៅ ។ បាត្រមាន ២ គឺបាត្រដៃក ១ បាត្រដី ១ ។ បាត្រទាំង ២ នេះ ប្រកបដោយប្រមាណទើបគួរអធិដ្ឋាននិងវិកប្ប ។ ប្រមាណនៃបាត្រមាន ៣ គឺ **ឧក្កដ្ឋោ** បាត្រខ្នាតធំ ១ **មជ្ឈិមោ** បាត្រខ្នាតកណ្តាល ១ **ឱមកោ** បាត្រខ្នាតតូច ១ ។ បាត្រខ្នាតធំនោះ ចុះបាយនៃអង្ករកន្ទ:អាឡ្ហក: និងចុះខាទនីយ: ស្មើនឹងភាគគម្រប់ ៤ នៃបាយ និងព្យញ្ជន:អន្ទ:ក់ (ម្ហូប) ល្មមសមគួរដល់បាយនោះ ។ បាត្រខ្នាតកណ្តាលចុះបាយនៃអង្ករ ១ នាឡិ បាត្រខ្នាតតូចចុះបាននៃអង្ករ ១ បត្ត: ទាំង ២ នេះក៏ចុះខាទនីយ:និងព្យញ្ជន:ដូចពោលមកហើយអំពីមុន ព្រោះបាលីថា **ឧក្កដ្ឋោ ជាម បត្តោ អឌ្ឍាឌ្ឍ្ឍ:ការ:ឧ:ំ ១ ១ ១

កន្ទះអាឡ្ហក:នោះ គឺអង្ករ ២ នាឡិមគធ: ក្នុងអន្ធកដ្ឋកថាពោលថា ឈ្មោះថានាឡិមគធ:នោះ ១២ បល:កន្ទះ ។ ក្នុងមហាអដ្ឋកថាពោលថា **បកតិនាឡិ** *នាឡិដោយប្រក្រតី ក្នុងសីហឬទ្ធីបក៏ធំទៅ* **ឧមិឌ្ឍនាឡិ** *នាឡិទមិឬ្ធក៏តូចទៅ* **មកធនាឡិ** *នាឡិមគធ: ទើបប្រកបដោយប្រមាណ ១ នាឡិកន្ទះ នៃនាឡិមគធ: ជានាឡិ សីហឬទ្ធីប ១ ព្រោះអដ្ឋកថាបាឬ:ថា* **អឌ្ឍាឌ្ឍ្ហោ ឧនំ កណ្ហាតីតិ មកធនាឡ្យា ទ្វិន្នំ តណ្ឌុលនាឡ្យានំ ឯ ឧនំ កណ្ហាតិ ។ មកធនាឡ្យ ជាម អឌ្ឍតេរសបលា ហោតីតិ អន្ធ-ដ្ឋកថាយំ វុត្តំ ។ សីហឬ្ធ ឧ ១ បកតិនាឡ្យ មហាឌ្ឍ, ឧមិឌ្ឍនាឡ្យ ខុទ្ទកា, មកធនាឡ្យ បមាណយុត្តា, តាយ មកធនាឡ្យ ឧ ១ ១ ១

កុញ្ជា ។ ២ កុញ្ជាជាមាសក: ។ ២ មាសក: ជាអក្ខ: ។ ៥ អក្ខ: ជាធរណ: ។ ៨ ធរណ:ជាសុវណ្ណ: ៥ ធរណ: ជានិក្ខ: ។ ៥ និក្ខ:ជា ១ បាទ ។ បាទនោះប្រព្រឹត្តទៅក្នុងចំណែកទី ៤ ។ ន័យនេះជាមតិនៃ អាចារ្យជំពូកខ្ញុ: ។ ន័យ ១ ទៀត ៤ គ្រាប់ស្រូវជាកុញ្ជា ។ ២ កុញ្ជា ជា មាសក: ។ ១០ មាសក: ជាអក្ខ: ។ ៨ អក្ខ:ជាធរណ: ។ ៥ ធរណ:ជា សុវណ្ណ: ។ ៥ សុវណ្ណ: ជានិក្ខ: ន័យដូច្នេះជាមតិនៃយើងទាំងឡាយ ។ បាទមួយប្រព្រឹត្តទៅក្នុងភាគគម្រប់ ៤ នៃវត្ថុណាមួយ គឺថាវត្ថុទាំងពួងនោះ បែងចេញទៅជា ៤ ភាគ ដូចសត្វចតុបាទ ភាគគម្រប់ ៤ ឈ្មោះថា បាទ ។ ១០ ធរណ: ជា បល: ។ ១០០ បល: ជាតុលា ។ ២០ តុលា ជាភារ: ។ កហាបណ:និងកវិសាបណ: ស័ព្ទទាំង ២ នេះជាឈ្មោះនៃវត្ថុ តែមួយ កវិស:ប្រែថារបស់សម្រាប់ចាយទិញ-ដូរ ដែលគេធ្វើប៉ុនផ្ទៃកវិស: ផ្ទៃកវិស:នោះថា ប៉ុនកូនស្ករ ។ គិតតាមន័យមុន ១ បល: ជាប្រាក់ទម្ងន់ ១ បាទ ២ ស្លឹង ២ ពៃ ។ ១២ បល: កន្ទ: ទម្ងន់ ៤ ដំឡឹង ៣ បាទ ២ ស្លឹង ១ ពៃជាទម្ងន់មគធនាឡិ ១ នាឡិមគធ: ។ គិតតាមន័យខាងក្រោយ ១ បល: ទម្ងន់ ៣ ដំឡឹង ២ ស្លឹង ។ ១២ បល:កន្ទ:នោះ ជាប្រាក់ ១ ជញ្ជីង ១៩ ដំឡឹង និង ១ ស្លឹង ជាទម្ងន់មគធនាឡិ ១ នាឡិមគធ: ។ តែគម្ពីរសំខ្យាបកាសក: ថា ៤ គ្រាប់ស្រូវ ជា ១ ចិច ។ ២ ចិច ជា ១ ចិប ។ ៥ ចិប ជា ២ អក្ខ: ។ ៨ អក្ខ: ជាធរណ: ។ ១០ ធរណ: ជាបល: ព្រោះបាឬ:ថា «ः

មាសកោ រីហយោ អដ្ឋ អក្ខំ ឯ រីហិរីសតិ

ថាមាសក: ១ ជា ៨ គ្រាប់ស្រូវ អក្ខ: ១ ជា ២០ គ្រាប់ស្រូវដូច្នេះ ។ គិតតាមន័យនេះ ១ បល: ទម្ងន់ ៣ បាទ ១ ហ្ជឿ ។ ១២ បល: កន្ទុះ ទម្ងន់ ៩ ដំឡឿ ៣ បាទ និង ២ ពៃ ជាទម្ងន់មគធនាឡិ ១ នាឡិមគធ: ។ សូម្បីសិលាដែលជានិមិត្តនៃសីមា ដែលលោកធ្វើយ៉ាងតូចទំហំធំប៉ុនដុំស្ករ អំពៅ ទម្ងន់ ៣២ បល: ក៏គួរគិតដោយបល:នេះ តែបើថាអ្នកប្រាជ្ញរង្ការ៉ាសថាតូចពេកណាស់ មើលទៅមិនល្មម តាមន័យនៃដីកាប្រាប់ទុកថា ឲ្យយកទឹកឬសណ្ដែកសច្ចឹង ឲ្យបានទម្ងន់ដូចពោលមកនេះ បញ្ចុះពេញក្នុងនាឡិណា នាឡិនោះឈ្មោះថាមគធនាឡិ ជា ១ នាឡិមគធ: ។ បល: មានផ្សេងៗ គ្នាដូច្នេះ អ្នកប្រាជ្ញដែលមានបញ្ញាគប្បីពិចារណាផ្ទៀងផ្ទាត់យកចុះ ។

គ្រានេះនឹងពណ៌នាមគធនាឡិតាមដីកាទៀត ក្នុងសារត្ថទីបនី-ដីកាពោលថា ៦ បសត: គឺ ៦ ទូកដៃ ឈ្មោះថាមគធនាឡិ ជា ១ នាឡិ-មគធ: ។ អាចារ្យដទៃឯទៀតពោលថា ៨ ទូកដៃ ឈ្មោះថាមគធនាឡិ ជា ១ នាឡិមគធ: ។ ពោលតាមអធិប្បាយនៃអាចារ្យមុន ៣ ទូកដៃជានាឡិ គឺ ១ នាឡិ ។ ២ នាឡិនោះជាមគធនាឡិ គឺ ១ នាឡិមគធ: ។ ពោលតាមអធិប្បាយនៃអាចារ្យខាងក្រោយ ៤ ទូកដៃជា ១ នាឡិ ។ នាឡិនោះ ជាមគធនាឡិ គឺ ១ នាឡិមគធ: ។ តែព្រះអាចារ្យធម្មបាលត្ថេរ លោកពោលទុកថា អាចារ្យទាំងឡាយ លោកពោលដូច្នេះ ៤ មុដ្ឋិក:

គឺ ៤ ក្តាប់ដោយប្រក្រតី ជាកុឌវ:គឺ ១ ទូកដៃ ។ ៤ ទូកដៃជានាឡិ គឺ ១ នាឡិ ។ ១៦ នាឡិនោះ ជា ១ ទោណ: ។ ក៏ឯទោណ: នោះជា ១២ មគធនាឡិ ព្រោះហេតុនោះ គប្បីដឹងដោយន័យដូច្នេះ ១ នាឡិមគធ: នោះ ចុះ ៥ ទូកដៃ និង ១ ក្តាប់ និង ១ ក្តាប់ទៀត បែងចែកជា ៣ ភាគ យកតែភាគគម្រប់ ៣ ដូច្នេះចុះ ព្រោះដីកាបាឋ:ថា ៖

**មកធជាឍ្ឍ ជាម ឆ បសតា ជាឍ្ឍ្ឍ្ឍ្ឍ្ឍ្ឍ, អដ្ឍ បស-តាតិ អបរេ ។ តត្ត បុរិមានំ មតេន តិបសតាយ ជាឍ្ឍ-យា ទ្វេ ជាឍ្ឍ្ឍ្ឍ្ឍ្ឍ្ឍ ឯកា មកធជាឍ្ឍ ហោតិ, បច្ឆិមានំ មតេន ចតុបសតាយ ជាឍ្ឍ្ឍ្ឍ ទ្វេ ជាឍ្ឍ្ឍ្ឍ ឯកា មកធជាឍ្ឍ ។ អាចរិយធម្មចាលត្ថេរេន បន បកតិយា ចតុមុដ្ឋិកំ កុឌ្ឍ្ឍ, ចតុកុឌ្ឍ្ឍ ជាឍ្ឍ, តាយ ជាឍ្ឍ្ឍ្ឍ សោឍ្ឍ្ឍ្ឍ្ឍ្ឍ ជាឍ្ឍ្ឍ្ឍ្ឍ្ឍ្ឍ ជោណ, តំ បន មកធជាឍ្ឍ្ឍ្ឍ ជ្ជ្ជ្ជ ជ្ជ្ជ ជ្ជ្ជ ហោន្តីតិ ១ ១ ១

តាមអធិប្បាយនៃអាចារ្យទាំងឡាយនោះ ។ ១ នាឡិមគធ: ជា ៤ នាឡិ ទមិល: សព្វថ្ងៃនេះ ដែលចំណុះ ៤ ទូកដៃនោះ ។ ក៏ឯកន្ទុះនាឡិមគធ: នោះឈ្មោះថា បត្ត: ដែលគេហៅថា **ឫភាណាឧមិលជាឍ្ឍ** *ថានាឡិ ទមិល:ចាស់ ។ ក៏ឯពាក្យបាលី ថាបាត្រខ្នាតតូចចុះបាយនៃអង្គ១ បត្ត: នោះក៏សមដូចពាក្យនៃអាចារ្យទាំងឡាយ ព្រោះថាសូម្បីលោកទាំងឡាយ ក៏កំណត់បត្ត:ទុកជា ២ គឺលោកិកបត្ត: និងមាគធបត្ត: ។ លោកិក-បត្ត:នោះ ១៦ បល: មាគធបត្ត: គុណ ២ ភាគ គឺជា ៣២ បល: ដូច្នេះ សម្តែងថា នាឡិមគធ:គុណ ២ ភាគដោយនាឡិលោកដូច្នេះ កាលបើកាន់យកដូច្នេះ សេចក្តីដែលពោលថា បាត្រខ្នាតតូច ចុះបាយល្មមយាបន-ម័ត្រ ក៏ជាការសម្រេចប្រាកដបាន ដ្បិតថាមិនអាចយកបាត្រដែលចុះបាយនៃអង្គ ៨ ទូកដៃ ចរទៅស្វែងរកបិណ្ឌបាត ធ្វើមិនឲ្យជាកំពូលមកចិញ្ចឹមជីវិតបាន ព្រោះហេតុនោះ ក្នុងអដ្ឋកថានៃវេរញ្ជកណ្ឌ ទើបពោលថា ដែលហៅថា ១ បត្ត: នោះ ប្រមាណនាឡិ គឺ ១ នាឡិ ល្មមចិញ្ចឹមជីវិតនៃបុរស ១ នាក់បាន ពាក្យនោះសមដូចពាក្យពោលថា បាយនៃអង្គ ១ បត្ត: មិនល្មមដល់មនុស្ស ២ នាក់ ពាក្យថាល្មមមនុស្ស ១ នាក់ ២ នាក់ ៣ នាក់ ក៏មានមកដូច្នេះ អ្នកប្រាជ្ញគប្បីរៀបរាប់តាមន័យដែលលោកពោលហើយ ក្នុងអដ្ឋកថាវេរញ្ជកណ្ឌនេះចុះ ដោយដីកាបាឋ:ថា* **ឧមិឍ្ឍជាឍ្ឍីតិ ឫភាណជាឍ្ឍឿ សង្ខ្យាយ រុត្តំ ។ សា ច ចតុមុដ្ឋិកេហិ ឧកុ១ហ្ជេហិ អដ្ឋ ឧកុ១ញ្ជ,**

តាយ ជាឍ្ឌិយា ទ្វេ ជាឍ្ឌិយោ មកធជាឍ្ឌិ កណ្ហាតិ, បុរាណា បន សីហឍ្ឌជាឍ្ឌី តិស្សោ ជាឍ្ឌិយោ កណ្ហាតីតិ វទន្តិ ។ តេសម្ចតេន មកធជាឍ្ឌិ ឥជានិ បវត្តមានាយ ចតុក្ខុឧញ្ចាយ ឧមិឍ្ឌជាឍ្ឌិយា ចតុ-ជាឍ្ឌិកា ហោតិ, តតោ មកធជាឍ្ឌិតោ ឧបឌ្ឍញ្ចុ បុរាណឧមិឍ្ឌជាឍ្ឌិសំខាតំ បត្តំ ជាម ហោតិ, ឯតេន ច ឱមកោ ជាម បត្តោ បត្តោធនំ កណ្ហាតីតិ ចាឍ្ឌិវចនញ្ចុ សមេតិ, លោកិយកេហិបិ លោកិកំ មាកធញ្ចេតិ បត្តទ្ចយំ សមុជាហដំ, លោកិកំ សោឍ្ឌសបលំ, មាកធំ ទ្ធិកុណ្ឌ មតន្តិ ឯវំ លោកិយជាឍ្ឌិយា មកធ-ជាឍ្ឌិ ឌិកុណ្ឌាតិ ឧស្ឍ្ឍិតា, ឯវញ្ចុ កយ្ហមានេ ឱម-កបត្តស្ឍ យាបនមត្តោធនតាហិតា សិទ្ធា ហោតិ, ន ហិ សក្ការ អជ្ជកុឧញ្ចុកោធនតាហិជ បត្តេន អជ្ចូបិកតំ បិណ្ឌាចាតំ បរិយេសិត្ចា យាបេតុំ, តេនេវ ឯវញ្ចកណ្ហាជ្ជកថាយំ បត្តោ ជាម ជាឍ្ឌិមត្តំ ហោតិ, ឯកស្ឍ បុរិសស្ឍ អលំ យាបជាយ, ឯ្ចតម្ឍ ហោតំ បត្តោធនោ ជាលមយំ ទ្ធិន្ធ្ចន្តិ ឯ្ចតំ, ឯកស្ឍ ទ្ធិន្ធ្ចំ តិណ្ណ្ហាម្ឍ ហោតីតិ ច អាកតំ, តស្ម្ចា ឥធ ឯ្ចតនយានុសារេន ឧហោតញ្ចុ *ជ្ចូ*ច្ចេះ ។

ក្នុងអដ្ឋកថាពោលថា បាត្រខ្នាតកណ្តាលចុះបាយនៃអង្ករ ១ នាឡិ*មគធ:* *បាត្រខ្នាតតូចចុះបាយនៃអង្ករកន្ទុះនាឡិមគធ:* *ដោយអដ្ឋក-ថាបាឋ:ថា* ជាឍ្យ៑ោ០ន០ន្តិ មកធ០ជ០ឍ្យ៑ា ឯ០ាយ ត០ណ្ហ០ាលជ០ឍ្យ៑ា ឋ៑ន០ំ ។ ២ត្ត០ាន០ន្តិ មកធ០ជ០ឍ្យ៑ា ឧ២ឆ្ឆ០ាជ០ឍ្យ៑ា០ាន០ំ *ដូច្នេះ ។*

*ក្នុងសារត្ថទីបនីដីកាពោលថា ព្រះសង្ខ្ម៑ីតិកាចារ្យឃើញថា ប្រមាណ*កន្ទុះនាឡិមគធ: *ជាបត្ត:មួយក្នុងបទនេះ* *ព្រោះពាក្យអដ្ឋកថាថា* *បាត្រខ្នាតតូចចុះបាយនៃអង្ករកន្ទុះនាឡិមគធ:នេះ* *សម្តែងថា ២ បត្ត:* *ជា ១ នាឡិមគធ:* *ក៏ឯបត្ត:នោះ* *គប្បីដឹងដោយលោកវោហារដូច្នេះថា ៤* *២ល: ជាកុ២ว: គឺ ១ ទូកដៃ ។ ៤ ទូកដៃជា ១ ២ត្ត:ដូច្នេះ* *ដោយដីកា-ឋ:ថា* មកធ០ជ០ឍ្យ៑ា ឧ២ឆ្ឆ២ាណ០ា ឥ០ ២ត្ត០ាតិ អ០ា ២ត្ត០ាន០ន្តិ មកធ០ជ០ឍ្យ៑ា ឧ២ឆ្ឆ០ាជ០ឍ្យ៑ា-០ាន០ន្តិ ។ ឥ២ិ០ា ច ២ត្ត២ូ០ំ មកធ០ជ០ឍ្យ៑ាតិ ០ស្ស០ាតំ ហ០ាតិ ។ ២ត្ត០ា ច ចតុ២ណ០ា ០ាកុ២ញ្ជ០ា ចតុ០ាកុ២ញ្ជ០ា ២ត្ត០ាតិ ឥ២ិ០ា ណ០ាកិ២ណ០ាវ០ា២ណ០ា ០ាវ០ិ០ាតញ្ជ០ា *ដូច្នេះ ។*

គ្រានេះនឹងពណ៌នា *មាត្រាសំខ្យាវាល់* *ដើម្បីនឹងឲ្យស្គាល់ឈ្មោះ* *ក្នុងលំដាប់នៃគ្រឿងវាល់* *តាមគម្ពីរអភិធានប្បទីបិកាថា ៖*

០ាកុ២ញ្ជ០ា ២ណ០ាតោ ឯ០ាកោ ២ត្ត០ា ០ាត ចតុ០ា ២ណ០ាយុ
០ាឆ្ហ០ាកោ ចតុ០ា ២ត្ត០ា ០ាោ០ណ០ាំ ០ា ចតុ០ាឆ្ហ០ាកំ ។

មានិកា ចតុរោ ទោណា　　ខារិត្តី ចតុមានិកំ
ខារិយោ រីស ភវេយ្យ　　សិយា តុម្ពោ ឧសម្ពណ្ណ ។
អាឍ្ឍកោ ជិត្តិយំ តុម្ពោ　　ឋត្តោ តុ ជាឍ្ឍ ជារិយំ
ភវេយ្យ សកដោ ចេកោ　　ឧស ទោណាតុ អម្ពណ្ណ ។

ដូច្នេះ ។

ថា ១ ទូកដៃ ជា ១ កុឌវ:, ៤ កុឌវ: ជាបត្ត:, ៤ បត្ត: ជាអាឍ្ឍក: ៤ អាឍ្ឍក:ជាទោណ:, ៤ ទោណ: ជាមានិកា, ៤ មានិកា ជាខារី, ២០ ខារី ជាភារ:, ១០ អម្ពណ: ជាតុម្ព:, ១ អម្ពណ: ជា ១០ ទោណ: អាឍ្ឍក:និងតុម្ព: សព្ទ ២ នេះជាឈ្មោះជាមួយគ្នា បត្ត:និងនាឍ្ឍ សព្ទ ២ នេះជាឈ្មោះជាមួយគ្នា ។ ភារ:និងសកដ: សព្ទ ២ នេះជាឈ្មោះជាមួយគ្នាប្រែថា រទេះ ។ កាលបើពោលតាមលំដាប់ដូច្នេះ មើលទៅដូចជាមិនត្រូវនឹងព្រះបាលីប្រមាណបាត្រ ។ ប្រមាណបាត្រក្នុងបត្ត:នោះ ម្យ៉ាង នាឍ្ឍនោះម្យ៉ាងដូច្នេះ **អឌ្ឍាឍ្ឍកោឧនំ ជាឍ្ឍិកោឧនំ ឋត្តោឧនំ** *ដូចប្រែមកហើយក្នុងមុននោះ ។*

ក្នុងគម្ពីរសំខ្យាបកាសក:ពោលថា មួយទូកដៃ ជាកុឌវ: ១, ម្យ៉ាងទៀត ៤ មុដ្ឋិក: គឺ ៤ ក្តាប់ឈ្មោះថាកុឌវ: ១, ៥ កុឌវ: នោះជាមុដ្ឋិ ១ មុដ្ឋិនោះបែងជា ៣ ភាគ ភាគគម្រប់ ៣ ជា ១ នាឍ្ឍិមគធ:, ៣ នាឍ្ឍិមគធ: ជា ១ អាឍ្ឍក:, ៤ កុឌវ:ជា ១ បត្ត: ។ ន័យមួយទៀត ៦ បសត: គឺ ៦ ទូកដៃ ជា ១ បត្ត: ។ ន័យមួយទៀត ១ ទូកដៃ ជា ១ បត្ត: ។ បត្ត:ណា

ដែលហៅថានាឡិ នាឡិនោះជានាឡិតូច ៤ នាឡិតូចនោះជាអាឡ្ហក: ១ ដោយបាឋ:ថា ៖

ឧ្ឍ ១ ១ ១

ដែលពោលមកនេះ ដើម្បីនឹងឲ្យឃើញថាបត្ត: នាឡិ មានផ្សេងៗ គ្នា រួមនាឡិមគធ:ដែលពោលមកនេះ តាមសេចក្ដីក្នុងអដ្ឋកថា ដីកានិង គម្ពីរដ៏សេស មាន ៨ យ៉ាង គឺទមូន់ ៤ ដំឡឹង ៣ បាទ ២ ស្លឹង ១ ពៃម្យ៉ាង, ទមូន់ ១ ជញ្ជីង ១៩ ដំឡឹង ១ ស្លឹងម្យ៉ាង, ទមូន់ ៩ ដំឡឹង ៣ បាទ ២ ពៃម្យ៉ាង, ២១ ក្តាប់និងភាគគម្រប់ ៣ នៃក្តាប់ ១ ម្យ៉ាង, ២៤ ក្តាប់ម្យ៉ាង ៣២ ក្តាប់ម្យ៉ាង, ៦៤ ក្តាប់ម្យ៉ាង, ៦ ក្តាប់ និង ១ ក្តាប់ទៀត បែងជា ៣ ភាគ យកតែ ២ ភាគម្យ៉ាង, ជា ៨ យ៉ាងដូច្នេះ ។ នាឡិមគធ: ដែលមានផ្សេងៗ គ្នាដូច្នេះ អ្នកប្រាជ្ញគប្បីពិចារណា សាកសួរកាន់យកចុះ តែគួរនឹងកាន់ថា បាយនៃអង្ករ ១ បត្ត: ល្មមបុរសម្នាក់ស៊ីឆ្អែត, បាយនៃ អង្ករ ១ នាឡិ ល្មមបុរសពីរនាក់ស៊ីឆ្អែត, បាយនៃអង្ករ ២ នាឡិល្មមបុរស ៤ នាក់ស៊ីឆ្អែត, នេះជាលក្ខណ:សមគួរនឹងន័យក្នុងអដ្ឋកថានៃវេរញ្ជកណ្ឌ អង្ករដែលវាស់ដោយនាឡិចុះទមូន់ ៩ ដំឡឹង ៣ បាទ ២ ពៃ ល្មមបុរស ម្នាក់ អង្ករ ២៤ ក្តាប់ ល្មមមនុស្ស ២ នាក់បរិភោគ ។

ប្រមាណបាត្រនិងបល: ចប់

អន្ទាសំខ្យា មាត្រាវាស់

ពណ៌នាអំពីអន្ទាសំខ្យា មាត្រាសម្រាប់វាស់ ដើម្បីឲ្យដឹងគាវុតនិង យោជន៍ជាដើម ដែលមានមកក្នុងសិក្ខាបទខ្ទះ មាត្រាក្នុងគម្ពីរអភិធានប្ប-ទីបិកាថា:

ឆត្តឹសបរមាណ្ឌាន- មេកោណ្ដ ច ឆតឹស តេ
តជ្ជារី តាបិ ឆត្ដឹស រថវេណ្ដ្ដ ច ឆតឹស តេ
លិក្ខា តា សត្ត ឩកា តា ធញ្ញមាសោបិ សត្ត តេ
សត្ដាង្គុលិមង្គុ ទ្ធិច្ច ទ្ធិ ទ្ធ ទ្ធ ទ្ធ ទ្ធ
រតនំ តានិ សត្ដ្ដ យដ្ឋិ តា ទ្ធ ទ្ធ ទ្ធ
ការ្ដ្ដ ទ្ធ ទ្ធ ទ្ធ ទ្ធ ទ្ធ ទ្ធ ទ្ធ
ធនុ

សិន ជាយោជន៍ ៥០០ ជួរធ្នូ គឺ ២.០០០ ហត្ថ ជាកោស: ៤ កោស: ជាគាវុត ៤ គាវុត គឺ ៤០០ សិន ជាយោជន៍ ចម្ងាយ ១០០០ ហត្ថ ជួរសំឡេងស្រែកនៃឧសភរាជ ជាសរុសក: ៨ សរុសក: ជាគាវុត ៤ គាវុត គឺ ៤០០ សិន ជាយោជន៍ ជួរកម្ទាំងគោឧសភរាជ គឺ ១៤ ហត្ថ ជាពលុសក: ៨ ពលុសក: ជាគាវុត ៤ គាវុតគឺ ៥ សិន ១២ ញ្ញាម ជាយោជន៍ ១ជួរខ្ជូនគោឧសភរាជ គឺ ៧ ហត្ថ ជាសរីរុសក: ៨០ សរីរុសក:ជា ១ គាវុត ៤ គាវុត គឺ ២៨ សិន ជាយោជន៍ ១៧៥ ហត្ថ ជាករីស: ៦៤ ករីស: ជាគាវុត ៤ គាវុត គឺ ៥៦០ សិន ជាយោជន៍ ២៨ ហត្ថ ជាអព្ពន្ធរ: ៤០០ អព្ពន្ធរ: ជាគាវុត ៤ គាវុត គឺ ៥៦០ សិន ជាយោជន៍ ប្រមាណផ្សេងគ្នាដូច្នេះ គប្បីចេះប្រើ ប្រមាណយ៉ាងតូច និងយ៉ាងខ្ជី ប្រើក្នុងការវាស់របស់ទៅដោយទទឹង (ផ្ដេក) ដូចវាស់ផ្ទៃជាដើម ប្រមាណយ៉ាងធំ យ៉ាងវែង ប្រើវាស់របស់ដែលខ្ពស់ឡើង-ទៅ (បញ្ឈរ) ដូចវាស់ដើមឈើនិងភ្នំជាដើម ។

អន្ទាសំខ្យា មាត្រាវាស់ ចប់

ប្រមាណចាត្រ

សេចក្ដីជំនុំ ក្នុងនាឡិមគធ:ដែលប្រមាណបាត្របរិក្ខារ ៣ យ៉ាង ឲ្យយល់ ព្រះសង្ឆ្យេវ:ភនុ:ថេ:និងយ:ភវ:សហានានុសក្ដិទាំងពួង ដែល

បានជួបជុំសង្គីតិកាធ្វើផ្ទាត់សិក្ខាវណ្ណនាក្នុងកម្ពុជប្រទេសនេះ យល់ឃើញព្រមគ្នាថា បាត្របរិក្ខារខ្នាតធំដែលចុះបាយនៃអង្គរកន្ទុះអាឡ្ហក: នោះ គឺអង្គរ ២ នាឡិមគធ: ដែលថា ២ នាឡិមគធ:នោះ គិតជានាឡិដែលប្រើក្នុងកម្ពុជប្រទេសនេះ ត្រូវជា ៤ នាឡិ ។ បាត្រខ្នាតកណ្ដាលដែលចុះបាយនៃអង្គរមួយនាឡិមគធ: គិតជានាឡិដែលប្រើក្នុងកម្ពុជ-ប្រទេសនេះត្រូវជា ២ នាឡិ ។ បាត្រខ្នាតតូច ដែលចុះបាយនៃអង្គរ ១ បត្ត:គឺកន្ទុះនាឡិមគធ: គិតជានាឡិដែលប្រើក្នុងកម្ពុជាប្រទេសនេះ ត្រូវជា ១ នាឡិ ។ មួយនាឡិមគធ:យើងវិនិច្ឆ័យថា ត្រូវជា ២ នាឡិប្រក្រតីនោះ ព្រោះយើងអាងបាលីក្នុងដីកាបាឋ:ថា **លោកិយនាឡ្យា មគ-ធនាឡ្យ ទ្វិកុណាតិ ឧស្ឃ្ជិតា** *យើងបានយកស្រូវមកថ្ងឹងធ្ងៀបមើលតាមត្រាជូរខ្មែរ និងជញ្ជីងចិន និងជញ្ជីងបារាំងសែស ស្រូវមួយនាឡិប្រក្រតី គិតជាក្រាមបារាំងសែសត្រូវជា ៦០០ ក្រាម ២ នាឡិប្រក្រតី ត្រូវជា ១២០០ ក្រាម ។*

ប្រមាណបាត្រ ចប់

ប្រមាណសុគតវិធត្ថិ

ពណ៌នាអំពីសុគតវិទត្ថិ ចំអាមនៃព្រះសុគត និងសុគតផ្ទុលីផ្ទាប់នៃព្រះសុគត ដោយសង្ខេប ។ សិក្ខាបទខ្ទះ កំណត់ដោយចំអាម

ព្រះសុគត សិក្ខាបទខ្ញុះ កំណត់ដោយផ្ទាប់ព្រះសុគត ។ ក្នុងអដ្ឋកថា នៃសញ្ញាចិកកុដិសិក្ខាបទពោលថា **សុគតវិទត្ថិ ជាម ឥជានិ មជ្ឈិមស្ស បុរិសស្ស តិស្សោ វិទត្ថិយោ, ១ ១ ១

បុរសថយទាបចុះ ៣ ក្បៀស តាំងអំពីព្រះពុទ្ធអង្គនិព្វានហើយមកដល់ ២៤៥៦ ព្រះវស្សានេះ គិតជារយឆ្នាំបាន ២៤ ដងកន្ទះ គិតថែមឡើងទៅ ១០០ ឆ្នាំ ៣ ក្បៀស ២៤ ដងកន្ទះ ត្រូវជា ១៨ ធ្នាប់និង ២ ក្បៀស ២ អនុក្បៀស ក៏ដឹងថាមជ្ឈិមបុរសក្នុងសម័យពុទ្ធកាលកាយខ្ពស់ ៩២ ធ្នាប់និង ១ ក្បៀសម្ចាស់ខ្លួន ជា ៩៦ ធ្នាប់ជាងឈើសេស កាយមជ្ឈិម-បុរសនោះ ចែកចេញជា ៣ ភាគ យកភាគទី ២ ថែមបញ្ចូលជាកាយព្រះសុគត ខ្ពស់ ១២៩ ធ្នាប់ជាងឈើ ជា ៥ ហត្ថ ៩ ធ្នាប់ជាងឈើ ។ ១៦ ធ្នាប់និង ២ អនុក្បៀសជាងឈើសព្វថ្ងៃនេះ ជា ១ ចំអាមព្រះសុគត ។ ១ ក្បៀសចែកជា ២ ភាគហៅថាអនុក្បៀស ៥ ក្បៀសនិងអនុក្បៀសដ៏សេសជាងឈើ ជា ១ ធ្នាប់ព្រះសុគត ។

នឹងសម្តែងអំពីប្រមាណក្នុងសិក្ខាបទបញ្ញត្តិ ដែលកំណត់ដោយចំអាមនិងធ្នាប់ព្រះសុគត ក្នុងសញ្ញាចិកកុដិសិក្ខាបទ ថាកិក្ខុគប្បីធ្វើកុដិ ដោយគ្រឿងទព្វសម្ភារ: ដែលសូមគេមកដោយខ្លួនឯង បណ្តាយ ១២ ចំអាម ទទឹង ៧ ចំអាម ដោយចំអាមព្រះសុគត លោកកំណត់ទុកថា **ឌីឃតោ វទ្ឍកីហត្ថេន ទ្វិកលាឌិកឯកង្គុលុត្តរអដ្ឋហត្ថ ប្ប មាណា ហោតិ, តិរិយតោ បន ទ្វាទុកលុត្តរតិកលាឌិក-ចតុរង្គុលុត្តរវិឌត្ថាឌិកចតុហត្ថ ប្ប មាណា ហោតិ ។** *ថាសញ្ញាចិកកុដិ បណ្តាយ ៨ ហត្ថ និង ១ ធ្នាប់ និង ២ ក្បៀស ទទឹង ៤ ហត្ថ ១ ចំអាម និង ៤ ធ្នាប់ និង ៣ ក្បៀស និង ២ អនុក្បៀសជាងឈើ ។*

ក្នុងនិសីទនសន្ថតសិក្ខាបទថា ភិក្ខុគប្បីកាន់យកសន្ថតចាស់ដោយជុំវិញ ឲ្យបាន ១ ចំអាមព្រះសុគត លាយនឹងសន្ថតថ្មី លោកកំណត់ទុកថា **វិនត្ថិមត្តន្តិ ឥមានិ វឌ្ឍកីដ្ឋលេន ទ្វីហាត្ថុកលាហិ សហ សោឡសដ្ឋលានិ ភវេយ្យានិ** ថាចំអាមព្រះសុគតនោះ ១៦ ធ្នាប់ និង ២ អនុក្បៀសជាងឈើ ។ ក្នុងមញ្ចសិក្ខាបទថា ប្រមាណដើងគ្រែ ៨ ធ្នាប់ ដោយធ្នាប់ព្រះសុគត លោកកំណត់ទុកថា **តិកលាឍិកឧសដ្ឋលចាឧកំ ហោតិ** ដូច្នេះ ថាដើងគ្រែកម្ពស់ ១០ ធ្នាប់ជាងឈើ និង ៣ ក្បៀស ។ ក្នុងនិសីទនសិក្ខាបទ ថាប្រមាណនិសីទន: បណ្តោយ ២ ចំអាម ទទឹង ១ ចំអាមកន្ទះ ជាយ ១ ចំអាម ដោយចំអាមព្រះសុគត លោកកំណត់ទុកថា **ឌីឃតោ វឌ្ឍកីដ្ឋលេន ឯកកលាឍិកពត្តឹសដ្ឋលំ ហោតិ វិត្ថារតោ តីហាត្ថុកលាហិ សហ ហត្ថប្ឋមាណំ ហោតិ, ឧសា បន ទ្វីហាត្ថុកលាហិ សហ សោឡសដ្ឋលា ហោតិ** ដូច្នេះ ។ ថាសំពត់និសីទន: បណ្តោយ ៣២ ធ្នាប់ជាងឈើ និង ១ ក្បៀស ទទឹង ១ ហត្ថ និង ៣ អនុក្បៀស ជាយ ១៦ ធ្នាប់ជាងឈើ និង ២ អនុក្បៀស ។ ក្នុងកណ្ឌុបដិច្ឆាទិសិក្ខាបទថា ប្រមាណសំពត់បិទបូស បណ្តោយ ៤ ចំអាម ទទឹង ២ ចំអាម ដោយចំអាមព្រះសុគត លោកកំណត់ទុកថា **ឌីឃតោ វឌ្ឍកីហត្ថេន ទ្វិកលាឍិក-ចតុរដ្ឋុលុត្តរវិនត្ថ្យាឍិកទ្វិហត្ថប្ឋមាណា ហោតិ, វិត្ថារតោ**

បន ឯកកលាធិកអដ្ឋង្គុលុត្តរហត្ថប្បមាណា **ហោតិ** *ដូច្នេះ ។ ថាសំពត់បិទបូស បណ្តោយ ២ ហត្ថ ១ ចំអាម ៤ ផ្ទាប់ ២ ក្បៀស ជាងឈើ ទទឹង ១ ហត្ថ ៨ ផ្ទាប់ និង ១ ក្បៀស ។ ក្នុងវស្សិកសាដិកា-សិក្ខាបទ ប្រមាណសំពត់ងូតទឹកភ្លៀង បណ្តោយ ៦ ចំអាមទទឹង ២ ចំអាមកន្ទុះ ដោយចំអាមព្រះសុគត លោកកំណត់ទុកថា* **ឌីឃតោ** **វ**ឌ្ឍ**ការ**ហត្ថេ**ន** **ត**ីហ**ិ** **ក**លា**ហ**ិ **ស**ហ **ច**តុ**ហ**ត្ថ**ប្ប**មា-ណា **ហោ**តិ, **ត**ិ**ឋ**ិ**យ**តោ **ឯ**ការ**ុ**ក**ុ**ល**ុ**ត្ត**ុ**ត**ុ**ក**ុ**ល**ាធ**ិ**ក-**ច**ត**ុ**ង**្ក**ុ**ល**ុ**ត្ត**ុ**ត**ុ**ធ**ិ**ត**ុ**ហ**ត្ថ**ប្ប**មាណា **ហោ**តិ *ដូច្នេះ ។ ថាសំពត់ងូតទឹកភ្លៀង បណ្តោយ ៤ ហត្ថ និង ៣ ក្បៀសជាងឈើ ទទឹង ១ ហត្ថ ១ ចំអាម ៤ ផ្ទាប់ និង ១ ក្បៀស និង ១ អនុក្បៀសទៀត ។ ក្នុងនន្ទសិក្ខាបទថា ធ្វើចីវរឲ្យប៉ុនសុគតចីវរ ឬធំលើសជាងនោះ ត្រូវ ឆេទនកបាចិត្តិយ ប្រមាណសុគតចីវរ បណ្តោយ ៩ ចំអាម ទទឹង ៦ ចំអាមដោយចំអាមព្រះសុគត លោកកំណត់ទុកថា* **ว**ฑ**ฒ**ก**ี**ห**า**ต**ฺ**ต**ฺ**ต**ฺ**ต**ฺ **ฉ**ี**ย**ต**ว** **ฉ**ฺ**ว**ฺ**ว**ฺ**ว

តិកលាដិកឧសង្ខ្លុំ ហោតិ, វិត្ថារតោ បន ទ្វាទុក-លាដិកាយ ឯកកលាយ សហ បញ្ចង្ខ្លុំ ដូច្នេះ ។ ថាបច្ចិមចីវរ បណ្តោយ ១០ ផ្ទាប់ និង ៣ ក្បៀស ទទឹង ៥ ផ្ទាប់ ១ ក្បៀសនិង ២ អនុក្បៀសជាងឈើទៀត ។ ពាក្យដែលពណ៌នាមកនេះកាត់សេចក្តីដោយសង្ខេប ល្មមឲ្យដឹងហេតុដែលលោកបានគិតសុគត-វិទត្ថិ នឹងតែងគម្ពីរសុគតវិទត្ថិវិធានបករណៈ បើបណ្ឌិតជាតិប្រាជ្ញាចង់ដឹងពិស្តារ គប្បីមើលក្នុងគម្ពីរសុគតវិទត្ថិវិធានបករណៈចុះ ដ្បិតថាហេតុឧទាហរណ៍ ដែលសាធកៈឲ្យឃើញថា ព្រះកាយនៃព្រះពុទ្ធអង្គមិនខ្ពស់ពេកជាងកាយប្រក្រតីមនុស្ស និងវិធីលេខដោយពិស្តារ នឹងកំណត់អវយវៈនៃព្រះពុទ្ធអង្គ និងកំណត់ប្រមាណក្នុងសិក្ខាបទទាំងពួងលោកសម្តែងទុកក្នុងគម្ពីរនោះ ដោយពិស្តារ ឬអ្នកប្រាជ្ញដែលមានបញ្ញាបានហេតុដទៃដែលនឹងសាធកៈឲ្យឃើញច្បាស់ថា កាយព្រះពុទ្ធអង្គខ្ពស់ប៉ុណ្ណោះ ក៏គប្បីគិតតាមហេតុន័យដែលបានពណ៌នាមកនោះចុះ ។

សេចក្តីជំនុំ ក្នុងសុគតវិទត្ថិ ចំអាមព្រះសុគត ដែលព្រះសង្ឆវេរានុ-ថេរៈនិងយ៉ាវ៉ាសហានានុសក្តិទាំងពួង ដែលបានសមូហៈជួបជុំសង្ខ្ចីតិកាផ្ទៀងផ្ទាត់សិក្ខាវណ្ណនា ក្នុងកម្ពុជប្រទេសនេះ យល់ឃើញព្រមគ្នាថា ១ ផ្ទាប់ព្រះសុគត ត្រូវជា ២៨ មិល្លីម៉ែត្រ និង ២ ឌិសមិល្លីម៉ែត្រ[(១)]។ ១ ចំអាមព្រះសុគត ត្រូវជា ៣៤ សង់ទីម៉ែត្រ ។

(១) មួយផ្ទាប់ព្រះសុគតត្រូវជា ០^{ម}, ០២៨៣...។

កុដិបណ្ដាយ ១២ ចំអាមព្រះសុគត ត្រូវជា ៤ ម៉ែត្រ ៨ សង់ទីម៉ែត្រ ទទឹង ៧ ចំអាមព្រះសុគត ត្រូវជា ២ ម៉ែត្រ ៣៨ សង់ទីម៉ែត្រ ។

ជើងគ្រែកម្ពស់ ៨ ផ្ទាប់ព្រះសុគត ត្រូវជា ២២ សង់ទីម៉ែត្រ ៥ មិល្លី-ម៉ែត្រ ។

និសីទនៈបណ្ដាយ ២ ចំអាមព្រះសុគត ត្រូវជា ៦៨ សង់ទីម៉ែត្រ ទទឹង ១ ចំអាម ៦ ផ្ទាប់ព្រះសុគត ត្រូវជា ៥១ សង់ទីម៉ែត្រ, ជាយ ១ ចំអាម ត្រូវជា ៣៤ សង់ទីម៉ែត្រ ។

សំពត់បិទបូសបណ្ដាយ ៤ ចំអាមព្រះសុគត ត្រូវជា ១ ម៉ែត្រ ៣៦ សង់ទីម៉ែត្រ ទទឹង ២ ចំអាមព្រះសុគត ត្រូវជា ៦៨ សង់ទីម៉ែត្រ ។

វស្សិកសាដិកាបណ្ដាយ ៦ ចំអាមព្រះសុគត ត្រូវជា ២ ម៉ែត្រ ៤ សង់ទីម៉ែត្រ ទទឹង ២ ចំអាម ៦ ផ្ទាប់ព្រះសុគត ត្រូវជា ៨៥ សង់ទីម៉ែត្រ ។

សុគតចីវរ បណ្ដាយ ៩ ចំអាមព្រះសុគត ត្រូវជា ៣ ម៉ែត្រ ៦ សង់ទីម៉ែត្រ ទទឹង ៦ ចំអាមព្រះសុគត ត្រូវជា ២ ម៉ែត្រ ៤ សង់ទីម៉ែត្រ ។

ប្រមាណសុគតវិទត្ថិ ចប់

ឯត្ថាវតា បុព្វសិក្ខាវណ្ណនា និដ្ឋិតា

បុព្វសិក្ខាវណ្ណនា ចប់តែប៉ុណ្ណេះ

បរមពុទ្ធានុសាសនីអធិប្បាយ

ពុទ្ធស្ស ភគវតោ អរហតោ បរិនិព្ពុតកាលតោ បដ្ឋាយ ចតុបញ្ញាសាតិរេកានំ ចតុសតាធិកានំ ទ្វិន្នំ វស្សសហស្សានមុបរិ សុការសំវច្ឆរតោ យាវ ព្យត្ថ្យសំ-វច្ឆរ អយំ បុព្ពសិក្ខាវណ្ណនា សំសន្ទេត្វា អភិសំ-ខតលិក្ខិតា សព្ពសោ បរិនិដ្ឋិតាតិ ។

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌ *បន្ទាត់* *ទំព័រ*

ធម្មសម្បត្តិ.....អក្សរក ដល់រ

រតនត្តយបឋ

ពុទ្ធរតនកថា..... ៨ ៤

ធម្មរតនកថា..... ១ ៥៨

សង្ឆរតនកថា..... ១ ១១៦

អាបត្តិជាមាឌិបឋ

អាបត្តិនាមកថា..... ១៣ ១៣១

សិក្ខាបទបរិច្ឆេទកថា..... ១ ១៣៧

សមុដ្ឋានាទិកថា..... ៥ ១៤៣

អាការ:ដែលភិក្ខុនឹងត្រូវអាបត្តិ..... ៦ ១៥២

បដិបត្តិមុខបឋ

ឋានជិកុទ្ទេស

មេថុនសិក្ខាបទជាបឋម.....៧ ១៥៦

អទិន្នាទានសិក្ខាបទគម្រប់២.....១៣ ១៦៣

មនុស្សវិគ្គហសិក្ខាបទគម្រប់ ៣.....១៦ ១៨១

ឧត្តរិមនុស្សធម្មសិក្ខាបទគម្រប់ ៤.....១១ ១៨៨

សង្ឆាទិសេសុទ្ទេស

សញ្ចេតនិកសិក្ខាបទ.....១៣ ១៩២

កាយសំសគ្គសិក្ខាបទ..... ៥ ១៩៤

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌ *បន្ទាត់ ទំព័រ*

សង្ឆាទិសេសុទ្ទេស

ទុដ្ឋុល្លវាចសិក្ខាបទ ៧ ១៩៦

អត្តកាមបារិចរិយសិក្ខាបទ.....១២ ១៩៨

សញ្ចរិតសិក្ខាបទ ៨ ១៩៩

កុដិការសិក្ខាបទ.....១០ ២០២

មហាល្លកសិក្ខាបទ ៦ ២០៤

អមូលកសិក្ខាបទ ១២ ២០៤

អញ្ញភាគិយសិក្ខាបទ..... ៩ ២០៨

សង្ឃភេទសិក្ខាបទ ១៣ ២០៩

ភេទានុវត្តកសិក្ខាបទ.....១៨ ២១០

ទុព្ធចជាតិកសិក្ខាបទ.....១៣ ២១១

កុលទូសកសិក្ខាបទ ៧ ២១២

អនិយតុទ្ទេស

អលំកម្មនិយសិក្ខាបទ ១១ ២១៤

នាលំកម្មនិយសិក្ខាបទ ៩ ២១៦

ថុល្លច្ចយាបត្តិ..... ១ ២១៨

និស្សគ្គិយុទ្ទេស បីវរវគ្គទី ១

បឋមកឋិនសិក្ខាបទ ១៦ ២២៥

ទុតិយកឋិនសិក្ខាបទ..... ៥ ២២៨

តតិយកឋិនសិក្ខាបទ.....១២ ២៣០

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌	*បន្ទាត់*	*ទំព័រ*
និស្សគ្គិយុទ្ធេស ចីវរវគ្គទី ១		
បុរាណចីវរសិក្ខាបទ	៦	២៣១
ចីវរបដិគ្គហាណសិក្ខាបទ	១១	២៣១
អញ្ញាតកវិញ្ញត្តិសិក្ខាបទ	១៦	២៣១
តទុត្តរិសិក្ខាបទ	១០	២៣៤
បឋមឧបក្ខដសិក្ខាបទ	១៥	២៣៥
ទុតិយឧបក្ខដសិក្ខាបទ	១៨	២៣៦
រាជសិក្ខាបទ	៦	២៣៧
និស្សគ្គិយុទ្ធេស កោសិយវគ្គទី ២		
កោសិយសិក្ខាបទ	១៨	២៤០
សុទ្ធកាឡកសិក្ខាបទ	១	២៤២
ទ្វេភាគសិក្ខាបទ	៦	២៤២
ឆព្ភស្សសិក្ខាបទ	១៣	២៤២
និសីទនសន្ថតសិក្ខាបទ	១	២៤៣
ឯឡកលោមសិក្ខាបទ	១០	២៤៣
ឯឡកលោមធោវាបនសិក្ខាបទ	១៧	២៤៣
រូបិយសិក្ខាបទ	៧	២៤៤
រូបិយសំវោហារសិក្ខាបទ	២	២៤៨
កយវិក្កយសិក្ខាបទ	២	២៤៩
និស្សគ្គិយុទ្ធេស បត្តវគ្គទី ៣		
បត្តសិក្ខាបទ	៣	២៥១

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌	*បន្ទាត់*	*ទំព័រ*
និស្សគ្គិយុទ្ធេស បត្តវគ្គទី ៣		
ឩនបញ្ចពន្ធនសិក្ខាបទ	១២	២៥១
ភេសជ្ជសិក្ខាបទ	២	២៥៣
វស្សិកសាដកសិក្ខាបទ	៥	២៥៤
ចីវរាច្ឆិន្ទនសិក្ខាបទ	១៣	២៥៤
សុត្តវិញ្ញត្តិសិក្ខាបទ	២	២៥៧
មហាបេសការសិក្ខាបទ	២	២៥៨
អច្ចេកចីវរសិក្ខាបទ	២	២៥៩
សាសង្កសិក្ខាបទ	២	២៦០
បរិណតសិក្ខាបទ	២	២៦១
បាចិត្តិយុទ្ធេស មុសាវាទវគ្គទី ១		
មុសាវាទសិក្ខាបទ	១៧	២៦២
ឱមសវាទសិក្ខាបទ	៦	២៦៤
បេសុញ្ញសិក្ខាបទ	២	២៦៨
បទសោធម្មសិក្ខាបទ	៨	២៦៩
សហសេយ្យសិក្ខាបទ	៥	២៧២
ទុតិយសហសេយ្យសិក្ខាបទ	៨	២៧៤
ធម្មទេសនាសិក្ខាបទ	២	២៧៥
ភូតារោចនសិក្ខាបទ	១២	២៧៦
ទុដ្ឋុល្លារោចនសិក្ខាបទ	១៦	២៧៦
បថវីខណនសិក្ខាបទ	១១	២៧៨

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌	*បន្ទាត់*	*ទំព័រ*
បាចិត្តិយុទ្ធេស ភូតគាមវគ្គទី ២		
ភូតគាមសិក្ខាបទ	២០	២៨០
អញ្ញវាទកសិក្ខាបទ	៨	២៨៣
ឧជ្ជាបនកសិក្ខាបទ	១០	២៨៤
បឋមសេនាសនសិក្ខាបទ	១៨	២៨៥
ទុតិយសេនាសនសិក្ខាបទ	១៧	២៨៨
អនុប្បខជ្ជសិក្ខាបទ	២	២៩១
និក្កឌ្ឍនសិក្ខាបទ	១៣	២៩២
វេហាសកុដិសិក្ខាបទ	៥	២៩៤
មហាល្លកវិហារសិក្ខាបទ	១៤	២៩៤
សប្បាណកសិក្ខាបទ	១៧	២៩៥
បាចិត្តិយុទ្ធេស ឱវាទវគ្គទី ៣		
ឱវាទសិក្ខាបទ	៩	២៩៧
អដ្ឋង្គតសិក្ខាបទ	១២	២៩៨
ឧបស្សុយសិក្ខាបទ	១៦	២៩៨
អាមិសសិក្ខាបទ	២	២៩៩
ចីវរទានសិក្ខាបទ	៦	២៩៩
ចីវរសិព្វនសិក្ខាបទ	១០	២៩៩
សំវិធានសិក្ខាបទ	១៣	២៩៩
នាវាភិរូហនសិក្ខាបទ	២	៣០០
បរិបាចនសិក្ខាបទ	៧	៣០០
រហោនិសជ្ជសិក្ខាបទ	១២	៣០០

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌	*បន្ទាត់*	*ទំព័រ*
បាចិត្តិយុទ្ធេស ភោជនវគ្គទី ៤		
អាវសថបិណ្ឌសិក្ខាបទ	...... ៣	៣០១
គណភោជនសិក្ខាបទ	...... ១២	៣០២
បរម្ផរភោជនសិក្ខាបទ	...... ២	៣០៥
កាណមាតាសិក្ខាបទ	...... ១៤	៣០៦
បឋមបវារណាសិក្ខាបទ	...... ១៧	៣០៧
ទុតិយបវារណាសិក្ខាបទ	...... ៦	៣១៦
វិកាលភោជនសិក្ខាបទ	...... ១១	៣១៧
សន្និធិការកសិក្ខាបទ	...... ១២	៣១៨
បណីតភោជនសិក្ខាបទ	...... ១៨	៣១៩
ទន្តបោណសិក្ខាបទ	...... ១០	៣២១
បាចិត្តិយុទ្ធេស អចេលកវគ្គទី ៥		
អចេលកសិក្ខាបទ	...... ៨	៣២៣
ឧយ្យោជនសិក្ខាបទ	...... ១៤	៣២៣
សភោជនសិក្ខាបទ	...... ៧	៣២៥
បឋមរហោនិសជ្ជសិក្ខាបទ	...... ១៤	៣២៥
ទុតិយរហោនិសជ្ជសិក្ខាបទ	...... ២	៣២៦
ចារិត្តសិក្ខាបទ	...... ៩	៣២៦
មហានាមសិក្ខាបទ	...... ៦	៣២៨
ឧយ្យុត្តសិក្ខាបទ	...... ៩	៣២៩
សេនាវាសសិក្ខាបទ	...... ១៨	៣៣០
ឧយ្យោធិកសិក្ខាបទ	...... ៦	៣៣១

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌	*បន្ទាត់*	*ទំព័រ*
បាចិត្តិយុទ្ធេស សុរាបានវគ្គទី ៦		
សុរាបានសិក្ខាបទ	៣	៣៣២
អង្គុលិបតោទកសិក្ខាបទ	២	៣៣៣
ហាស្យធម្មសិក្ខាបទ	១៨	៣៣៣
អនាទរិយសិក្ខាបទ	២	៣៣៥
ភឹសាបនសិក្ខាបទ	៥	៣៣៦
ជោតិសមាទហានសិក្ខាបទ	២	៣៣៧
នហានសិក្ខាបទ	៦	៣៣៨
ទុព្ឋណ្ណករណសិក្ខាបទ	៥	៣៣៩
រិកប្បនសិក្ខាបទ	១២	៣៤០
អបនិធានសិក្ខាបទ	១៣	៣៤១
បាចិត្តិយុទ្ធេស សប្បាណកវគ្គទី ៧		
សញ្ចិច្ចបាណសិក្ខាបទ	១៧	៣៤២
សប្បាណកសិក្ខាបទ	១០	៣៤៣
ឧក្កោដនសិក្ខាបទ	១៦	៣៤៣
ទុដ្ឋុល្លបដិច្ឆាទនសិក្ខាបទ	២	៣៤៥
ឧនវីសតិវស្សសិក្ខាបទ	១០	៣៤៦
ថេយ្យសត្ថសិក្ខាបទ	៥	៣៤៧
សំវិធានសិក្ខាបទ	១៣	៣៤៨
អរិដ្ឋសិក្ខាបទ	១២	៣៤៩
ឧក្ខិត្តសម្ភោគសិក្ខាបទ	១០	៣៥០
កណ្ឌកសិក្ខាបទ	១១	៣៥១

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌	*បន្ទាត់*	*ទំព័រ*
បាចិត្តិយុទ្ធេស សហធម្មិកវគ្គទី ៨		
សហធម្មិកសិក្ខាបទ	១៤	៣៥២
វិលេខនសិក្ខាបទ	១៧	៣៥៣
មោហានសិក្ខាបទ	១៧	៣៥៤
បហារទានសិក្ខាបទ	១៤	៣៥៥
តលសត្តិកសិក្ខាបទ	១១	៣៥៦
អមូលកសិក្ខាបទ	២	៣៥៧
សញ្ចិច្ចសិក្ខាបទ	២	៣៥៨
ឧបស្សុតិសិក្ខាបទ	២	៣៥៩
កម្មប្បដិពាហានសិក្ខាបទ	៨	៣៦០
ឆន្ទំអទត្វាបក្កមនសិក្ខាបទ	៨	៣៦១
ទព្ធសិក្ខាបទ	២	៣៦៣
បរិណាមនសិក្ខាបទ	៩	៣៦៣
បាចិត្តិយុទ្ធេស រាជវគ្គទី ៩		
អន្តេបុរសិក្ខាបទ	១៨	៣៦៣
រតនសិក្ខាបទ	៨	៣៦៤
វិកាលគាមប្បវេសនសិក្ខាបទ	២	៣៦៧
សូចិឃរសិក្ខាបទ	១៦	៣៦៨
ឆេទនកសិក្ខាបទ	២	៣៧០
តុលោនទ្ធសិក្ខាបទ	១៧	៣៧០
និសីទនសិក្ខាបទ	១៣	៣៧១

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌	*បន្ទាត់*	*ទំព័រ*
បាចិត្តិយុទ្ធេស រាជវគ្គទី ៩		
កណ្ឌុបដិច្ឆាទិសិក្ខាបទ	១៣	៣៧២
វស្សិកសាដិកសិក្ខាបទ	៧	៣៧៣
ឧន្ទសិក្ខាបទ	១៤	៣៧៣
ប្រមាណនៃចំអាមព្រះសុគត	៨	៣៧៤
បាដិទេសនីយុទ្ធេស មាន ៤ សិក្ខាបទ		
សិក្ខាបទជាបឋម	១២	៣៧៥
សិក្ខាបទគម្រប់ ២	២	៣៧៦
សិក្ខាបទគម្រប់ ៣	១១	៣៧៦
សិក្ខាបទគម្រប់ ៤	២	៣៧៧
សេខិយុទ្ធេស សារុប្ប មាន ២៦ សិក្ខាបទ		
សិក្ខាបទជាបឋម	១៦	៣៧៩
សិក្ខាបទគម្រប់ ២	៥	៣៨២
សិក្ខាបទគម្រប់ ៣	១០	៣៨២
សិក្ខាបទគម្រប់ ៤	១៤	៣៨២
សិក្ខាបទគម្រប់ ៥	៦	៣៨៣
សិក្ខាបទគម្រប់ ៦	៩	៣៨៣
សិក្ខាបទគម្រប់ ៧	១២	៣៨៣
សិក្ខាបទគម្រប់ ៨	១៦	៣៨៣
សិក្ខាបទគម្រប់ ៩	១៨	៣៨៣
សិក្ខាបទគម្រប់ ១០	៤	៣៨៤

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌	*បន្ទាត់*	*ទំព័រ*
សេខិយុទ្ទេស សារុប្ប៎ា មាន ២៦ សិក្ខាបទ		
សិក្ខាបទគម្រប់ ១១	៩	៣៨៤
សិក្ខាបទគម្រប់ ១២	១១	៣៨៤
សិក្ខាបទគម្រប់ ១៣	១៤	៣៨៤
សិក្ខាបទគម្រប់ ១៤	១៦	៣៨៤
សិក្ខាបទគម្រប់ ១៥	១១	៣៨៥
សិក្ខាបទគម្រប់ ១៦	១៤	៣៨៥
សិក្ខាបទគម្រប់ ១៧	១៧	៣៨៥
សិក្ខាបទគម្រប់ ១៨	១៩	៣៨៥
សិក្ខាបទគម្រប់ ១៩	២	៣៨៦
សិក្ខាបទគម្រប់ ២០	៤	៣៨៦
សិក្ខាបទគម្រប់ ២១	៩	៣៨៦
សិក្ខាបទគម្រប់ ២២	១១	៣៨៦
សិក្ខាបទគម្រប់ ២៣	១៤	៣៨៦
សិក្ខាបទគម្រប់ ២៤	១៦	៣៨៦
សិក្ខាបទគម្រប់ ២៥	១៩	៣៨៦
សិក្ខាបទគម្រប់ ២៦	៤	៣៨៧
សេខិយុទ្ទេស ភោជនប្ប៎ដិសំយុត្ត មាន ៣០ សិក្ខាបទ		
សិក្ខាបទជាបឋម	៣	៣៨៨
សិក្ខាបទគម្រប់ ២	៦	៣៨៨
សិក្ខាបទគម្រប់ ៣	៨	៣៨៨
សិក្ខាបទគម្រប់ ៤	១៧	៣៨៨

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌	*បន្ទាត់*	*ទំព័រ*
សេខិយុទ្ទេស គោជនប្បដិសំយុត្ត មាន ៣០ សិក្ខាបទ		
សិក្ខាបទគម្រប់ ៥	១៥	៣៨៩
សិក្ខាបទគម្រប់ ៦	១៧	៣៨៩
សិក្ខាបទគម្រប់ ៧	១៩	៣៨៩
សិក្ខាបទគម្រប់ ៨	៦	៣៩០
សិក្ខាបទគម្រប់ ៩	១១	៣៩០
សិក្ខាបទគម្រប់ ១០	១៥	៣៩០
សិក្ខាបទគម្រប់ ១១	២	៣៩១
សិក្ខាបទគម្រប់ ១២	៦	៣៩១
សិក្ខាបទគម្រប់ ១៣	១០	៣៩១
សិក្ខាបទគម្រប់ ១៤	១៤	៣៩១
សិក្ខាបទគម្រប់ ១៥	១៧	៣៩១
សិក្ខាបទគម្រប់ ១៦	១៩	៣៩១
សិក្ខាបទគម្រប់ ១៧	៦	៣៩២
សិក្ខាបទគម្រប់ ១៨	១១	៣៩២
សិក្ខាបទគម្រប់ ១៩	១៤	៣៩២
សិក្ខាបទគម្រប់ ២០	១៧	៣៩២
សិក្ខាបទគម្រប់ ២១	២	៣៩៣
សិក្ខាបទគម្រប់ ២២	៥	៣៩៣
សិក្ខាបទគម្រប់ ២៣	៨	៣៩៣
សិក្ខាបទគម្រប់ ២៤	១០	៣៩៣
សិក្ខាបទគម្រប់ ២៥	១២	៣៩៣

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌	*បន្ទាត់*	*ទំព័រ*
សេខិយុទ្ទេស ភោជនប្បដិសំយុត្ត មាន ៣០ សិក្ខាបទ		
សិក្ខាបទគម្រប់ ២៦	១៤	៣៨៣
សិក្ខាបទគម្រប់ ២៧	១៨	៣៩៣
សិក្ខាបទគម្រប់ ២៨	២	៣៩៤
សិក្ខាបទគម្រប់ ២៩	៥	៣៩៤
សិក្ខាបទគម្រប់ ៣០	១៣	៣៩៤
សេខិយុទ្ទេស ធម្មទេសនាបដិសំយុត្ត មាន ១៦ សិក្ខាបទ		
សិក្ខាបទជាបឋម	១០	៣៩៥
សិក្ខាបទគម្រប់ ២	១៨	៣៩៥
សិក្ខាបទគម្រប់ ៣	៥	៣៩៦
សិក្ខាបទគម្រប់ ៤	១០	៣៩៦
សិក្ខាបទគម្រប់ ៥	២	៣៩៧
សិក្ខាបទគម្រប់ ៦	៦	៣៩៧
សិក្ខាបទគម្រប់ ៧	១២	៣៩៧
សិក្ខាបទគម្រប់ ៨	៦	៣៩៨
សិក្ខាបទគម្រប់ ៩	១៤	៣៩៨
សិក្ខាបទគម្រប់ ១០	១៧	៣៩៨
សិក្ខាបទគម្រប់ ១១	២	៣៩៩
សិក្ខាបទគម្រប់ ១២	៥	៣៩៩
សិក្ខាបទគម្រប់ ១៣	៨	៣៩៩
សិក្ខាបទគម្រប់ ១៤	១១	៣៩៩

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌	*បន្ទាត់*	*ទំព័រ*
សេខិយុទ្ទេស ធម្មទេសនាបដិសំយុត្ត មាន ១៦ សិក្ខាបទ		
សិក្ខាបទគម្រប់ ១៥	១៩	៣៩៩
សិក្ខាបទគម្រប់ ១៦	៧	៤០០
សេខិយុទ្ទេស បកិណ្ណក: មាន ៣ សិក្ខាបទ		
សិក្ខាបទជាបឋម	១៧	៤០០
សិក្ខាបទគម្រប់ ២	២	៤០១
សិក្ខាបទគម្រប់ ៣	១៣	៤០១
ចីវរបដិសំយុត្តកថា	១	៤០៤
យានាទិកថា	៨	៤១០
មំសកថា	១	៤១៩
តិរច្ឆានវិជ្ជាទិកថា	១២	៤២២
សទ្ធាទេយ្យាទិកថា	១៧	៤២៨
កុលទូសកកម្ម	១៧	៤៣៥
បាបសមាចារកថា	៥	៤៤១
អនាចារកថា	១	៤៤៧
បរិក្ខារកថា	១២	៤៤៩
មណ្ឌនាទិកថា	៧	៤៥៩
បត្តបដិសំយុត្តកថា	៦	៤៦៩
សេនាសនបដិសំយុត្តកថា	៩	៤៧៧
អនាមាសាទិកថា	៩	៥០៥
អចិត្តកបញ្ញត្តិកថា	១	៥១២

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌	*បន្ទាត់*	*ទំព័រ*
វិញ្ញត្តិកថា	៩	៥២៦
មេណ្ឌកបញ្ញត្តិ	៨	៥៣១
គោបកទានកថា	៩	៥៣៣
អារក្ខាយាចនកថា	៥	៥៣៧
បរិភោគកថា	១៤	៥៣៩

វត្តកថា

អាគន្តុកវត្ត	៥	៥៤២
អាវាសិកវត្ត	១៣	៥៤៤
គមិកវត្ត	១៧	៥៤៦
អនុមោទនវត្ត	៦	៥៤៨
ភត្តគ្គវត្ត	១	៥៥០
បិណ្ឌចារិកវត្ត	៥	៥៥៣
អរញ្ញិកវត្ត	៥	៥៥៥
សេនាសនវត្ត	១៣	៥៥៦
ជន្តាឃរវត្ត	៩	៥៥៩
រច្ចកុដិវត្ត	៧	៥៦១
ឧបជ្ឌាយវត្ត	៥	៥៦៤
សទ្ធិវិហារិកវត្ត	៩	៥៧០
អាចរិយវត្ត	១៣	៥៧១
អន្តេវាសិកវត្ត	១	៥៧២

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌ *បន្ទាត់* *ទំព័រ*

វត្តកថា

វិធីកាន់យកនិស្ស័យ	១០	៥៧២
ការរម្ងាប់និស្ស័យ	១	៥៧៦
ប្រភេទនៃទុក្កដាបត្តិ	៨	៥៨៤

ចាលីឧក្លាជ

វិនីតវត្ថុទុក្កដ	៩	៥៨៦
វិភង្គទុក្កដ	១៦	៥៨៩
ខន្ធកទុក្កដ	១២	៥៩០
បាលីមុត្តកទុក្កដ	១០	៥៩៦
នឹងពណ៌នាក្នុងទុព្ភាសិតាបត្តិ	១២	៦០២

កាលិកបព្វ:

យាវជីវិក	៧	៦០៣
យាវកាលិក	១	៦០៧
យាមកាលិក	៥	៦១១
សត្តាហកាលិក	១១	៦១៤
កាលិកសំសគ្គកថា	៦	៦២៥
នឹងពណ៌នាក្នុងអន្ដោវុត្ត	១៧	៦២៧
កប្ប៊ិយភូមិកថា	១៦	៦២៨
ខុទ្ទកកថា	១៥	៦៣៦
មហាបទេស	១៣	៦៤២

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌	*បន្ទាត់*	*ទំព័រ*
ពិន្ធាធិដ្ឋានាធិបព្វ:		
វិធីអធិដ្ឋាននិងបច្ចុទ្ធរសំពត់	១៥	៦៤៦
វិកប្បនកថា	៧	៦៥៩
វិធីអធិដ្ឋានបាត្រ	១៧	៦៦៣
វិធីវិកប្បបាត្រ	១៥	៦៦៩
សេចក្តីប្រែអំពីវិធីមានពិន្ទុជាដើម	១៦	៦៧០
វិជហានាធិបព្វ:		
វិជហានកថា	១៤	៦៧៣
ទានាទិកថា	៨	៦៧៦
បដិគ្គហណកថា	៥	៦៨០
អាបត្តិទេសនាធិបព្វ:		
អាបត្តិទេសនាកថា	៧	៦៩៩
ឧបោសថកថា	១១	៧១០
វស្សូបនាយិកាកថា	១៦	៧២២
បវារណាកថា	៩	៧៣១
សីមាកថា	១៤	៧៤០
អធិករណសមថកថា	១	៧៤៦
គារវាគារវកថា	១	៧៥២
សម្មជ្ជនានិសង្សកថា	១៧	៧៥៣

សន្លឹកចង្អុលប្រាប់មាតិកា

មាតិកាធម៌ *បន្ទាត់* *ទំព័រ*

អាបត្តិនេសនាឧិបត្ថ:

បាទកថា	១	៧៥៦
ប្រមាណបាត្រ និង បល:	៥	៧៦៣
អទ្ធាសំខ្យា មាត្រាវាស់	១៦	៧៧៣
ប្រមាណបាត្រ	១៦	៧៧៥
ប្រមាណសុគតវិទត្ថិ	១៦	៧៧៦
បរមពុទ្ធានុសាសនីអធិប្បាយ	១	៧៨៣

(*ចប់*)

រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

គណៈកម្មការពុទ្ធិកវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ និងបោះពុម្ពសាឡើងវិញនូវសៀវភៅព្រះវិនយវណ្ណនា ដែលជាស្នាដៃ របស់លោកអ្នកប្រាជ្ញជំនាន់មុន គឺអាស្រ័យដោយការមើលឃើញនូវកត្តាចាំបាច់ មួយចំនួនដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាជ្ញចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ដោយកុសលផលបុណ្យទាំងអម្ពាលមាណ ដែលកើតអំពីធម្មទាននេះ
សូមឲ្យព្រះពុទ្ធសាសនាផ្សាយទៅគ្រប់ទិសទីទូទាំងសកលលោក
សូមឲ្យសព្វសត្វទាំងឡាយទាំងពួងបាននូវសេចក្ដីសុខសួស្ដី
សូមឲ្យមនុស្សគ្រប់ជាតិសាសន៍មានភាតរភាពនឹងគ្នា
សូមឲ្យពិភពលោកទាំងមូលមានសុខសន្ដិភាព ។

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ
ឬចង់បានសៀវភៅធម៌យកទៅអាន សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោម:
វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩
អ៊ីមែល: maha.panna@gmail.com
គេហទំព័រ: http://www.mahapanna.org